ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការណែនាំ	ឲ្យធ្វើល្អទៅ
ឲ្យរុំសមាធិចិត្ត	កុំឲ្យហ្មងសៅ
ជីវិនេះលោកហៅ	ពុទ្ធសាសនា

ប.ព.

ព្រះពុទ្ធសាសនា និងអព្ភុទ្ធសាសនិក

(វិចារណកថា)

លោក ដេង-ជ្រឿន ពិតន្ធ

ព្រះពុទ្ធសាសនា ជាសាសនារបស់មនុស្សអស្ចារ្យម្នាក់ មានព្រះបរមនាមព្រះសិទ្ធត្ថ ជាសាក្យគោត្រ ក្នុងនគរកបិលពស្តុនៃដែនសក្កៈ ឥឡូវហៅថា «នេប៉ាល់» ក្នុងប្រទេសឥណ្ឌា ។ ក្រោយដែលព្រះសិទ្ធត្ថបានធ្វើទុក្ករកិរិយាអស់ ៦ ព្រះវស្សាក្នុងព្រៃ ទ្រង់ក៏បានត្រាស់ដឹងនូវសច្ចធម៌ ហើយបានមានថ្មីហៅថាព្រះពុទ្ធ ។ តមក ព្រះពុទ្ធទេសនាប្រដៅមនុស្សទូទៅ ដោយប្រកាន់យកកម្មៈជាមូលដ្ឋាននៃសេចក្តីសុខទុក្ខរបស់សត្វក្នុងលោក ។ ទើបសាសនានេះ មានឈ្មោះថាព្រះពុទ្ធសាសនាតរហូតមក ។

នៅក្នុងលោក មិនមែនមានតែព្រះពុទ្ធសាសនាមួយទេ គឺមានសាសនាដទៃទៀត ។ ក្រៅពីព្រះពុទ្ធសាសនា គេសង្កេតឃើញមានសាសនាព្រាហ្មណ៍ សាសនាមហាម៉ត និងសាសនាគ្រិស្ត ។ សាសនា

ព្រាហ្មណ៍ជាសាសនាដែលបរិស័ទគោរពព្រះ ៣ ព្រះអង្គ គឺ ព្រះព្រហ្ម ព្រះវិស្ណុ និងព្រះនារាយណ៍ ។ ព្រះទាំងបីព្រះអង្គនេះ មានតែនាម មិនមានរូបជាមនុស្សឬជាទេវតា ឲ្យយើញជាក់ស្តែងទេ ។ សាសនាមហាម៉ត មានព្រះមហាម៉តជាមេតំណាងសាសនា ។ ឥស្លាមសាសនានេះ ប្រដៅឲ្យប្រកាន់យកព្រហ្មលិខិត ពុកជារគាលជាតាកសិនៃមនុស្ស ។ ឯសាសនាគ្រិស្ត មានព្រះហ្សេស៊ូគ្រិស្ត (Jésus-Christ ជាមេដឹកនាំ ។ សាសនានេះ ប្រកាន់ថាព្រះគ្រិស្តជាកូនព្រះនាទិទេព ដែលព្រះបិតាឲ្យមកកើតជាមនុស្ស ដើម្បីទទួលរ៉ាប់រងទោសរបស់សត្វលោក ។

សាសនាទាំងបួនខាងលើ សំដែងទ្រឹស្តីជាមនុស្ស ត្រូវតែធ្វើអំពើល្អ រហើយឲ្យវៀរចាកអំពើអាក្រក់ ។ មិនតែប៉ុណ្ណោះ សាសនាថាន សំដែងថា មានស្ថានសួគ៌ជាកន្លែងជាទីសំណាក់អាស្រ័យនៅនៃអ្នកធ្វើអំពើល្អ ខាងក្រោយដែលទុនស្លាប់ទៅ ទីឯមានស្ថាននរកជាកន្លែងជាទីសំណាក់នៅនៃអ្នកដែលធ្វើអំពើអាក្រក់ ។ តាមការដឹង យើញថា សាសនាទាំងនេះ គោលថាមានស្ថានសួគ៌ទីឯស្ថាននរកដូចគ្នា ។

ដូច្នេះស្ថានសួគ៌ ទីឯស្ថាននរក ជាទ្រឹស្តីដ៏ពិតប្រាជកនៃសាសនាទាំងឡាយក្នុងលោក ។ ចំពោះសាសនាបី គឺព្រាហ្មណសាសនា ឥស្លាមសាសនា ទីឯគ្រិស្តសាសនា បរិស័ទនៃសាសនាទីមួយ ។ ឬមនុស្សក្នុង

សង្គមសាសនានោះនោះ មិនសូវដែលឮគោលរិះគន់ ទើរគោលជំនាស់ ថាជាសាសនា ដែលធ្វើឲ្យមានការគេគក់អួលដល់វឌ្ឍនភាព នៃសង្គម មនុស្ស មិនសូវដែលឮគោលថា សំដីរបស់ព្រះគេ ត្រង់នេះសម ត្រង់នោះ មិនសម ឬនន័យថា គេចង់ធ្វើអ្វី គេធ្វើទៅ គេចង់ដឿ គេដឿទៅ បើគេ មិនកាន់មិនដឿក៏ប៉ុន្មាទៅ តែត្រង់សំដីបន្ទោសចំពោះសាសនា គឺមិនមាន។ គេនិយមទុកសាសនា ជាវត្ថុតំរេសសាច់ដោយឡែក ។ បមាដូចជាព្រះ មហាក្សត្រជាបុគ្គលជាទីសក្ការបូជានៃប្រជាពលរដ្ឋ ហើយស្ថិតនៅខ្ពស់ ហួសការប្រណាមនិន្ទា ។

ចំពោះព្រះពុទ្ធសាសនាវិញ ជាសាសនាដែលប្រជាពលរដ្ឋខ្មែរស៊ើរ ១០០ ភាគ ១០០ កាន់ទឹងប្រតិបត្តិតាម ។ មានខ្មែរខ្លះ តែភាគតិច និយម គោលរិះគន់ ខ្លះហួតដល់ទៅប្រមាថថាសាសនាព្រះពុទ្ធ ធ្វើឲ្យមនុស្សខ្វិលប្រទេសខ្មែរបានជាមានការចំរើនមិនចប់ចូលណា មកពីមានព្រះពុទ្ធសាសនា ជាឈើភ្ជាស់កាំកន់មិនឲ្យរេរេលឿនទៅបានដោយស្រួល ។ អ្នកដែលថា នេះខ្លះក៏បានរៀនលទ្ធិព្រះពុទ្ធសាសនា ខ្លះបានឃើញតែទម្រង់ក្រៅ ត្រង់ជម្រៅអត្ថន័យនៃសាសនា ខ្លួនគ្មានដឹងសោះ តែអាចហ៊ានមាត់ថាឯងចេះ ឯចុះចាំងត្រាវ ចាំងងងិត ទៅបានដែរ ។ ពិតមែនតែកន្លងបាប់ដួងមនុស្ស មានមាត្រខ្លះ ចែងថាមនុស្សមានសេរីភាពក្នុងជំនឿ ក្នុងការគិត តាំងពី ណាសត្វយ៉ាងបាន តែមុនទឹងរិះគន់ មុនទឹងនិន្ទា គួរដេញឹងគិតមួយស្របក់

សំនួរថាអាត្មាអញមានសញ្ញាតជាអ្វី? អាត្មាអញដែលបានកើតមានរូបមានកាយជាមនុស្សនេះ ដោយសារនរណា ? នរនោះមានសញ្ញាតជាអ្វី? គោរពសាសនាអ្វី? បើអញថាយ៉ាងនេះ នឹងអាចផ្តល់ជល់ជាតិខ្លួន ខ្លួលខ្លួនជាកុសល ឬជាអកុសលធំប៉ុណ្ណា ? សំដីជាអកុសលនៃខ្លួននឹងអាចបង្កើតជាបដិភាគនិមាសាសនាបានឬទេ ? ខ្លួននឹងអាចឡើងកាន់ឋានៈជាមេដឹកនាំជាតិបានដែរឬទេ ? ខ្លួនមានបរិស័ទបុះបូលចំនួនប៉ុន្មានហើយ? ។

តាមការសង្កេតឃើញ សម័យឥឡូវ តំនិតរបបរួមរវាងមនុស្សសាកលមានពកជាងពីមុនហើយ ទោះអ្នកណាកាន់សាសនាណាក៏ដោយ កាន់របៀបត្រង់ត្រង់ប្រទេសផ្សេងពីគ្នាក៏ដោយ តំនិតដ៏ប្រពៃនេះ បានមានឡើង ព្រោះគេយល់ថា មនុស្សរមែងត្រូវការរស់ ត្រូវការសន្តិភាពជួបគ្នាគួរតបា្តកាន់ដៃគ្នាកសាងសន្តិភាព ។ តើមានប្រយោជន៍អ្វីនឹងចោទគ្នានឹងរិះគន់និន្ទាគ្នា ថាព្រោះតែកាន់សាសនានេះ សាសនានោះ ? តើមានប្រយោជន៍អ្វីនឹងធ្វើទុក្ខគ្នា ព្រោះតែគេប្រកាន់របៀបត្រង់ត្រង់ដូចពីខ្លួន ? ឧបមាដូចជាកង្កែមួយ មានត្រួសារច្រើន ត្រួសារខ្លះចិញ្ចឹមដំរែ ដោយធ្វើបបរពោត ខ្លះទៀតដោយរបរស្រូវ ដោយរបរធ្វើការពជការ . . . តាមការពិសោធន៍ គឺមិនដែលឃើញមិនដែលឮ ថាត្រួសារនេះទៅរិះគន់និន្ទាដល់ត្រួសារដទៃ ព្រោះតែគេមិនប្រកាន់មុខរបរដូចខ្លួន ។

ឥឡូវខ្ញុំលើកបញ្ហាស្តីពីការរិះគន់និន្ទាចំពោះព្រះពុទ្ធសាសនាវិញ ។

ដែលរិះគន់និន្ទាខ្លះ ភាគច្រើនជាអ្នកស្រាវជ្រាវដោយរិះគិតវិទ្យាសាស្ត្រ ហើយ
លង់ចិត្តគិតស្មានថា មានតែវិទ្យាសាស្ត្រទេ ដែលអាចដឹកនាំលោកទៅរក
សេចក្តីចំរើនបាន ។ ការយល់នេះ ត្រូវបានតែមួយផ្នែកទេ ។ ការចំរើន
ធំធឹងប្រព្រឹត្តទៅពេញលក្ខណៈបាន លុះណាតែមានសន្តិភាពចំបូណិ ។
យើញហើយស្រាប់ សព្វថ្ងៃ វិទ្យាសាស្ត្រកើតមានចំបូណិមែន តើមនុស្ស
លោកគ្រប់សញ្ជាតិ បានសុខសន្តិភាពចំបូណិឬទេ? ចើឲ្យសាសនាចំរើន
វិញ ហើយកុំឲ្យលាយឡំដោយនយោបាយ យល់ថាសុខសន្តិភាពនឹង
មានច្រាកដ ព្រោះការសុខទុក្ខនៃមនុស្ស មិនមែនសម្រេចដោយសម្ភារៈ
ជាប្រមាណទេ គឺសម្រេចដោយចិត្តស្ងប់ ចិត្តមេត្តា ចិត្តមានខន្តី ។ ចំពោះ
រឿងនេះ សាសនាណាក៏មានប្រឿនប្រដៅ តែតាមការសំគាល់នឹងការ
ដឹង ព្រមទាំងការត្រិះរិះ យើញថាព្រះពុទ្ធសាសនា ប្រដៅច្រើនជាងសាស
នាដទៃ ។ ពុទ្ធឧប៉ាទមិនឲ្យពុទ្ធបរិស័ទ គោរពត្រឹមតែជីវិតមនុស្សផង
គ្នាទេ ឲ្យគោរពសត្វតិរច្ឆានផងថែមទៀត ព្រោះសាសនានេះ យោល
ទៅរកការរស់នៅជាប្រមាណ ។ អ្វីដែលត្រូវការរស់ រមែងស្រឡាញ់ជីវិត
រមែងក្តៅក្រហាយនឹងគេ ដែលធ្វើឲ្យបាត់បង់ជីវិតខ្លួន ។ ការក្តៅក្រហាយ
នេះហើយដែលគ្នាយទៅជាកំណើ ។ ដើម្បីរំលត់កំណើ មានតែរកចំកន្លែ
សាសនា ចុះបើតិះដៀលសាសនាទៅហើយ ត្រូវតែរកកំណើមករំលត់កំណើ
ដែលជាការផ្ទុយនឹងវិត្តធម្មជាតិ ។

ដូច្នេះត្រូវសន្និដ្ឋានថា អ្នកតិះដៀល អ្នកប៉ះគន់ អ្នកប្រមាថសាសនា ជាពិសេសព្រះពុទ្ធសាសនា ពុកជាមនុស្សមានការកាន់ប្រឡាំយ៉ាន់ធំ ។

អ្នកប្រជុំគាត់ច្រើនក្នុងលោក និយមព្រះពុទ្ធសាសនា ពុតជាសាសនាស្តីពីការស្វែងរកសន្តិភាព ស្តីពីការស្វែងរកសុចរិតយុត្តិធម៌ច្រើន ដើម្បីមនុស្ស ប្រសើរជាងសាសនាដទៃ ព្រោះជម្រៅអត្ថន័យនៃសាសនានេះ ស្ថិតនៅត្រង់មេត្តា ករុណា សច្ចធម៌យុត្តិធម៌ ។

អាស្រ័យហេតុនេះ ទើបមានការស្តាយពន់ពេក ចំពោះវិទ្យាសាស្ត្រខ្លះ ដែលនិយមតាំងចិត្តពោលប៉ះគន់ធ្ងន់ធ្ងន់ចំពោះព្រះពុទ្ធសាសនា ដែលជាបង្គោលចិត្តរបស់ខ្មែរតាំងប្រទេស ។

ចំពោះរឿងសាសនា កុំថាឡើយមនុស្សសាមញ្ញ សូម្បីមហាវិទ្ធបុរសដ៏ឆ្នើមមានជាអាទិ៍ គឺសម្តេចព្រះនរោត្តម-សីហនុ ព្រះបិតាឯករាជ្យជាតិ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ទ្រង់ក៏ប្រកាន់ពុកសាសនា ពិសេសព្រះពុទ្ធសាសនា ជាវត្ថុដ៏ប្រសើរបំផុត ប្រៀបបាននឹងជាតិដែរ បានជាកន្ត្រឹជាវចនា មានសាសនានៅកន្លែងនោះផង «ជាតិ សាសនា ព្រះរាជបល្ល័ង្ក» ។

ព្រះចៅអធិរាជណាប៉ូឡេអុងទី ១ នៃប្រទេសបារាំង បានពុកមនុស្សដូចជាខ្លួក ដែលនឹងត្រូវតែរៀបរៀបៅតាមកម្លាំងខ្សាច់ ប្រសិនបើគ្មានសាសនាជាបង្គោលចិត្ត ។ ដូច្នេះហើយ បានជាព្រះចៅអធិរាជអង្គនេះ

គោលថា «សាសនាខុកដូចជាចង្កឹត» របស់ខូកគឺមនុស្ស ។ មនុស្ស
ណាដែលគ្មានសាសនា ខុកដូចជាខូកគ្មានចង្កឹត ។

សូមអ្នកវៀកសាស្ត្រគ្រែម ។ មុនទីឯរែនឥប្ដប្រមាថព្រះពុទ្ធសាសនា
មេត្តាត្រែរែនឲ្យសព្វ ដញ្ជឹងឲ្យត្រប់ កុំចេះតែថាឲ្យរួចតាមាត់ ។ ពាក្យចាស់
គោលខុកមកថា «នោចចាក់គ្រាន់ជួស ពាក្យជ្រុលហួសជួសមិនបាន» ។

បើមិនមានព្រះនរបតី ជាអ្នកគ្រប់គ្រងដឹកនាំ
ដោយប្រពៃទេ ប្រជាជនខុកដូចជាខាងមិនមាន
ចង្កឹត ឥឡូវឆ្វេងលិចលង់កងដលជ ។
ព្រះនរបតីគ្រប់គ្រងរក្សាទូវប្រជាជន ប្រជាជន
ធ្វើឲ្យចំរើនព្រះនរបតី ការគ្រប់គ្រងប្រសើរ
ជាងសេចក្ដីចំរើន បើមិនមានការគ្រប់គ្រងរក្សា
សេចក្ដីចំរើននោះទេ សេចក្ដីចំរើនឥឡូវប្រ
រៃនាសអន្តរាយបាត់បង់ទៅវិញ ។

ហ៊ីគោបទេស

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ុំ រៀបរៀង

តមក

៩– ឧបត្តម្ភកកម្ម

ឧបត្តម្ភកំ ជាម កុសលោបិ លព្ភតិ អកុសលោបិ ឯកន្តោ ហិ កុសលំ កត្វា សុគតិកវេ ឯវត្តិ កត្ត បិតោ បុនប្បុនំ កុសលំ កត្វា តំកម្មំ ឧបត្តម្ភអនេកាធិ វស្សសតសហស្សធិ សុគតិកវេ យេវ វិចរតិ ។

លំដាប់នេះ សូមវិសជ្ជនាកន្លងកម្មបច្ច័យ អធិប្បាយនូវឧបត្តម្ភកកម្ម តទៅ ដំណើរសេចក្តីថា យំ ឧបត្តម្ភេតីតិ ឧបត្តម្ភំ ឧបត្តម្ភំយេវ ឧបត្តម្ភកំ កម្មឯណា ជាកម្មខ្ពុកបំរុងនូវកម្មដែលកំពុងតែឲ្យផល កម្មនោះឈ្មោះថា ឧបត្តម្ភកកម្ម ។

ឧបត្តម្ភកកម្មនោះ លោកអាចារ្យកំណត់យកតាំងខាងកុសលតាំងខាងអកុសល គឺកម្មជាកុសលក៏ខ្ពុកបម្រុងកម្មដ៏ជាកុសល កម្មជាអកុសលក៏ខ្ពុកបម្រុងកម្មដ៏ជាអកុសល ។ ឯកន្តោ ហិ កុសលំ កត្វា មែនពិត បុគ្គលតួកខ្លះក្នុងលោកនេះ ធ្វើកន្លងការកុសលក្នុង

លោកនេះហើយ លុះអស់ជីវិត ចាន់ទៅកើតក្នុងសុគតិភព កាលទៅកន្លងក្នុងសុគតិភពនោះ ក៏ធ្វើកន្លងការកុសលតទៅខាងមុខ ។ ទៀត ចំនុកបម្រុងនូវកម្មនោះ នៅកន្លងសុគតិភព អស់យេធ្នាំ ពាន់ធ្នាំ សែនធ្នាំជាច្រើន ។ បុគ្គលពួកខ្លះធ្វើអកុសលកម្ម ជាជាប់ក្នុងលោកនេះ លុះអស់ជីវិត ទៅកើតក្នុងទុគ្គតិភព កាលទៅកន្លងទុគ្គតិភពនោះ ធ្វើអកុសលនោះរឿយ ។ ចំនុកបម្រុងនូវអកុសលកម្មនោះ នៅកន្លងទុគ្គតិភព អស់កាលដ៏យូរអង្វែងប្រមាណជោយសែនធ្នាំជាច្រើន ។

អបរោ ឧយោ ន័យដទៃទៀតថា ជនកកម្មរមែងញ៉ាំនវិបាកខន្ធនឹងកម្មជួរបឲ្យកើតក្នុងបដិសន្ធិកាលនឹងបវត្តិកាល ។ ឯឧបត្ថម្ភកកម្មនេះមិនអាចញ៉ាំនវិបាកខន្ធនឹងកម្មជួរបឲ្យកើតក្នុងបដិសន្ធិកាល នឹង បវត្តិកាលបានទេ អាស្រ័យ ឯឥន្ទ្រិយ កម្មដទៃឲ្យបដិសន្ធិ ហើយឧបត្ថម្ភកកម្មខាងកុសល ក៏ចំនុកបម្រុងឲ្យបុគ្គលដែលមានសុខស្រាប់ហើយ ដែលមានទ្រព្យស្រាប់ហើយ ឲ្យបានសេចក្តីសុខច្រើនឡើងទៅទៀត ឲ្យតែតែមានទ្រព្យបរិបូណ៌ច្រើនឡើងទៅទៀត ។ ចំណែកឧបត្ថម្ភកកម្មខាងអកុសលវិញ គឺបុគ្គលដែលជាអ្នកកំសត់ទុគ៌តមានទុក្ខលំបាកស្រាប់ហើយ ក៏ចំនុកបម្រុងឲ្យបានសេចក្តីកំសត់ទុគ៌ត មានទុក្ខលំបាកតែតែច្រើនឡើងកាលំពេលវេលា ។

កុសលកម្ម ចំនុកបម្រុងមនុស្សឲ្យបានទ្រព្យ ឲ្យបានសេចក្តីសុខច្រើន

ឧបាសិកាទៅនោះ ដូចជាព្រះចុងអង្គមាសកពាជ កាលដើមឡើយ ជាអ្នកក្រសត់ទុគ៌តអនាថា អតញ្ញាតិសន្តាន មានទ្រព្យតែកន្ទុះមាសកប៉ុណ្ណោះ កុសលកម្មក៏ចបត្តម្ភឲ្យបានជាព្រះមហាក្សត្រ ក្នុងនគរពារាណសី ។

រឿងព្រះបាទអង្គមាសកពាជ

អតិតេ ពារាណសិយំ ក្នុងអតីតកាល មានបុរសម្នាក់ជាមនុស្សក្រសត់ទុគ៌ត ទៅកន្លែងនគរពារាណសី សង់ផ្ទះទៅក្បែរព្រៃវនគរខាងទិសឧត្តរ ធ្វើការស៊ីឈ្នួលដង្ហែកចង្កឹមជីវិតជានិច្ចកាល លុះយូរមក បានទ្រព្យកន្ទុះមាសក ទើបយកទៅកប់លាក់ទុកក្នុងចន្លោះដង្គ ដែលគេលើកថ្មល់ ហើយស៊ីឈ្នួលដង្ហែកគេទៀត រហូតដល់ព្រៃវនគរទិសខាងត្បូង។ ខាងក្រោយមក បានស្រីក្រសត់ទុគ៌តម្នាក់ធ្វើជាភរិយា ខាងនេះមានទ្រព្យកន្ទុះមាសកដូចគ្នា ។

គ្រានោះ ព្រះបាទពារាណសីឲ្យប៉ាវតែងប្រកាសប្រាប់អ្នកនគរឲ្យនាំគ្នាលេងមហោស្រព បើអ្នកណាមិនព្រមលេងទេ អ្នកនោះនឹងមានទោស ។ ស្វាមីភរិយាប្រឹក្សាគ្នាថា ទ្រព្យរបស់យើងមានកន្ទុះមាសកម្នាក់រួមគ្នាបានជាមួយមាសក មួយភាគនឹងទិញគ្រឿងក្រអូប មួយភាគទៀតនឹងទិញសុកមេរ័យ មច្ឆមំសាហារ ដើម្បីឲ្យបានលេងមហោស្រពតាមបង្គាប់ អ្នកបួរទៅកាយយកទ្រព្យរបស់អ្នកមក ។ ស្វាមីបានឮភរិយាប្រាប់ដូច្នោះ គ្រែកអរណាស់ ក៏ម្នាទៅយកទ្រព្យដែលខ្លួនកប់

លាក់ខុកក្នុងចន្ទោះឥដ្ឋ នៅកែវភ្នែកខាងទិសឧត្តរ បម្រាយប្រមាណ
១២ យោជន៍ ទៅដល់ភាក់កណ្តាលផ្លូវ ជួនពេលថ្ងៃត្រង់ រស្មីព្រះអាទិត្យក្តៅ
ដូចរងើកភ្លើង ផ្ទៃប្រថពី ដូចជាគេកេយដ៏ក្រាស់ ហុយដូចអណ្តាតភ្លើង
បុរសកំសត់ទុគ៌តដើរជាន់ក្បាច់ក្តៅ មិនក្រៀមមុខសោះ ស្រែកច្រៀង
បណ្តើរដើរចេណ្តើរហួតដល់មុខព្រះលាន ។

តទា ឧដ្ឋយោ គ្រានោះ ព្រះជាឧទ័យកជ ស្តេចឈរជើត
ស័ហបញ្ជរ ទតទៅឃើញបុរសកំសត់ទុគ៌ត ស្រែកច្រៀងដើរទៅតាមមុខ
ព្រះលានដូច្នោះ ទ្រង់ទឹកព្រះហឫទ័យ ក៏ឲ្យរាជបុរសទៅហៅបុរសនោះចូលមក
គាល់ ហើយត្រាស់សួរថា ភទ្រោ អាភទ្រោ អ្នកមកពីណា ឥឡូវ ទៅ
ឯណា ក្នុងពេលរស្មីព្រះអាទិត្យកំពុងតែក្តៅខ្លាំងដូចជាអណ្តាតភ្លើង អ្នក
ដើរស្រែកច្រៀងហាក់ដូចជាឥតក្តៅសោះ យើងមានសេចក្តីសង្ស័យ
ណាស់ អ្នកចូរប្រាប់យើងឲ្យច្បាស់ កុំលាក់លៀមឡើយ ។

បុរសកំសត់ក្រាបទូលថា មហារាជ បពិត្រក្សត្រប្រសើរ រស្មី
ព្រះអាទិត្យដ៏ក្តៅនេះ មិនមែនក្តៅក្រៃលែងខ្លាំងជាងរស្មីនៃកំដៅ ព្រោះ
ភគះខេ ខ្ញុំព្រះអង្គនឹងទៅយកទ្រព្យមកផ្សំជាមួយភរិយា ។

ព្រះជាឧពាភណសី ជាន់ទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏ត្រេកអរ ទើប
បែងចែកសម្បត្តិចេញភាក់កណ្តាល ព្រះរាជទានខ្លះឲ្យជាសម្ងាញ់របស់ព្រះ
អង្គ តម្រង់ជាណាវែត្រជាមួយគ្នា ហើយទ្រង់ឲ្យនាំយកស្រីកំសត់ជា

ភរិយោនោះមកតាំងជាអគ្គមហេសី ទ្រង់ឲ្យប្រកាសប្រាប់អ្នកខនតថា ឥឡូវនេះ ក្សត្រសោយភោជសម្បត្តិពីរព្រះអង្គរួមគ្នា អង្គថ្មីទ្រង់ព្រះនាមថា ព្រះបាទអគ្គមាសកភជ ។

ឫសគល់ បានសេរីភោជសម្បត្តិដូច្នេះ ដោយអំណាចនៃបត្តុកកម្មមកចំនុកបម្រុងឲ្យបានទ្រព្យសម្បត្តិនឹងឲ្យបានជាព្រះមហាក្សត្រគ្រប់គ្រងរាជ្យពាក់កណ្តាល ។ សេចក្តីនេះ មានក្នុងអដ្ឋកថាធម្មបទ ភាគ៤ សាលជាតក លើកមកសំដែងឲ្យឃើញជាឧទាហរណ៍ នៃឧបត្តុកកម្មខាងកុសល ។

ន័យមួយទៀត ឧបត្តុកកម្មនោះរមែងចំនុកបម្រុងនូវសុខនឹងទុក្ខដែលកម្មដទៃឲ្យផល គឺខាងកុសលឲ្យផលជាសុខរួចហើយ ក៏ឲ្យបានសុខតែតែច្រើនឡើងទៅទៀត ខាងអកុសលឲ្យផលជាទុក្ខរួចហើយ ក៏ឲ្យបានទុក្ខតែតែច្រើនឡើងទៅទៀត ។

ឧបត្តុកកម្មខាងកុសលតាមឧបត្តុក គឺធ្វើឲ្យអន្តរាយវិនាសឆាប់ឆាំទៅ ញុំាងសម្បត្តិឲ្យកើតឆាប់ឆាប់ណាឡើង សម្បត្តិមិនទាន់បានក៏ជួយឲ្យបានហើយជួយឲ្យតែតែចំរើនច្រើន ។ ឡើងទៅទៀត ចាប់ដើមអំពីជាតក្នុងតគិមាតា តាមចំនុកបម្រុងមិនឲ្យទុក្ខកើតឡើងបាន អន្តរាយទាំងឡាយភ្ញាប់មានដល់មាតាបិតាជាប្រក្រតី អន្តរាយទាំងនោះកំប្រាសចាកទៅរហូតដល់ទាសកម្មករ អ្នកបម្រើក្នុងផ្ទះនោះ ក៏ប្រាសចាកអន្តរាយដែរយ៉ាងនេះឈ្មោះថាឧបត្តុកកម្មញុំាងអន្តរាយទាំងឡាយឲ្យវិនាសអស់ទៅ

ឧបត្ថម្ភកម្មញ្ញាំងសម្បត្តិឲ្យមានបរិបូណ៌នោះ គឺចាប់ដើមអំពីពាក
មកកើតកង្វល់តិចមាត សម្បត្តិក្នុងផ្ទះនោះកើតបរិបូណ៌ឥតចប់ប្រមាណមិន
បាន ឯនិក្ខមនីយោ កំណាប់ទ្រព្យកើតខាងក្រោយផ្ទះ ខាងមុខផ្ទះ ដូច
ទឹកហូរបើឥតចង់បរិភោគគោជនាហារឬបចង់ស្លៀកពាក់តាក់តែងខ្លួនដោយ
វត្ថុអ្វី ក៏មានគេនាំយកមកឲ្យ សម្បត្តិការំ កច្ឆន្តិ មានាបិតានៃពាក
នោះ ទ្រព្យអ្នកដទៃកប់ទុកក្នុងដីណា ។ ក៏មកកាន់ដីចំពោះមុខ ឃានឃើញ
ទ្រព្យនោះ ផ្អែជ្រុយោ មេគោដែលចិញ្ចឹមក៏មានទឹកដោះច្រើន ឲ្យទឹក
ដោះត្រប់ពេល មិនជាច់ គោចាំងឡាយ ក៏ច្រាសចាកកេតនុបទ្រវន្តកយ ។
សស្សញ្ច សម្បជ្ជន្តិ សន្ទូងចាំងឡាយដែលបុគ្គលសាបព្រោះក្នុង
ស្រែ ក៏ដុះលូតលាស់បរិបូណ៌ ទ្រព្យដែលបុគ្គលចាំងឡាយមកឲ្យកទៅ
កំតេយកមកសងវិញតាមធម្មតា មិនចាប់ទៅសួរនាំតមការខ្លួនឯងឡើយ
ឧដ្ឋានាសកម្មការអ្នកបម្រើកំដាយស្តីប្រដៅតែងធ្វើតាមវាចា កម្មន្តា
ឯ អបរិហាយន្តិ ការងារមិនបានសាបសូន្យ គឺជាអ្នកធ្វើការមិនខ្ជិល
ច្រអូស មិនចាប់ព្រឹកជាសត្វើនស្តីថា បរិហារំ លភតិ ចាប់ដើម
អំពីពាកចុះកាន់ថ្ងៃអាគា ក៏បានថ្នាំជាគ្រឿងរក្សាតគិរហូតដល់ប្រសូត
ចេញពីគភ៌ ។ កុមារពេទ្យ ពួកគ្រូកុមារចាំងឡាយ មកប្រដូនគ្នាជួយថែរក្សា
ព្យាបាល លុះដល់ចំរើនវ័យធំឡើង បើកើតកង្វល់ត្រកូលគហបតីក៏បាន
ធ្វើជាសេដ្ឋី បើកើតកង្វល់ត្រកូលអមាត្យ ក៏បានធ្វើជាសេនាបតី ។ ឧបត្ថម្ភ

កកម្មយ៉ាងនេះ ឈ្មោះថាទុកចម្រុងឲ្យនូវកោតសម្បត្តិ ញ៉ាំងកោតសម្បត្តិឲ្យកើតឡើង អបរិសុទ្ធយោ ជុគ្គលនោះពុំមានអន្តរាយឡើយ ដោយសម្បត្តិបរិបូណ៌ជាកបជស់អស់ជាតិ យ៉ាងនេះឈ្មោះថាទុបត្ថម្ភកកម្មខាងកុសល ចានជស់បុគ្គលដែលកុសលទុកចម្រុង ដូចព្រះចាទអគ្គមាសកកជ ដែលកុសលទុកចម្រុងឲ្យបានទ្រព្យជាច្រើន រហូតជស់បានសោយរាជសម្បត្តិកន្លងនូវពាកណាសីពាក់កណ្តាល ដូចរឿងជាមកខាងដើម ។

ឯទុបត្ថម្ភកកម្មខាងអកុសលវិញ គឺអកុសលកម្មទុកចម្រុងតាំងពីចុះចាប់ផ្ទៃមាតាថ្នូ ។ រមែងញ៉ាំងអន្តរាយឲ្យកើតមានឡើងតាំងពីពាកនោះចុះចាប់ផ្ទៃក្នុម ។ មាតាចិតានៃពាកនោះ ចេះតែមានទុក្ខព្រួយលំបាកពុំមានសេចក្តីសុខឡើយ ។ យ បរិសុទ្ធយោ អន្តរាយតាំងឡាយណាដែលកើតមានហើយកំតែងចំរើនច្រើនឡើងថែមទៀត អន្តរាយណាមិនទាន់កើតមាន កំភៀងកើតមាន ។ ទុបត្ថម្ភកកម្មយ៉ាងនេះ ឈ្មោះថាទុបត្ថម្ភកកម្មខាងអកុសល ញ៉ាំងអន្តរាយឲ្យកើតមាន ញ៉ាំងកោតសម្បត្តិឲ្យវិនាសភៅ គឺថាចាប់ដើមអំពីពាកមកកើតក្នុងផ្ទៃមាតា មាតាចិតានោះទ្រាប់មានទ្រព្យច្រើន ទ្រព្យនោះក៏អស់ភៅសូន្យភៅ ជួនកាលមានភ្លើងឆេះផ្ទះ ជួនកាលត្រូវភាជក័យ ប៉ោះចេញភៅជួញផ្លូវចឹក ខូកលិចរេចខ្យោ មេគោដែលចិញ្ចឹម គ្មានទឹកដោះ គោដែលចិញ្ចឹមទ្រាប់ជាន

សុខ ត្រឡប់ទៅជាបានទុក្ខវិញ តើមានភេតផ្សេង ។ កើតឡើងដល់គោ
ពាល៌នោះ ។ វប្បដ្ឋានេ សសប្បដិ សន្ទូលពាល៌ឲ្យយកទ្រព្យសម្ប
ព្រោះតែវិនាសខូចខាត ជនពាល៌ឲ្យយមានតាសាតាស៊ីជាដើម ធ្លាប់ស្តី
ប្រដៅដាំយ កិត្រឡប់ទៅជាលំបាកស្តីប្រដៅវិញ មិនស្តែតទៅកន្លងទ
ការងារកើសាបសូន្យខកខានធ្វើ បរិហារំ ឯ លកតិ តាំងពីពេល
ពាកមកកើតក្នុងផ្ទៃមាតា ចេះតែមានស្អប់ខ្ពើមមាតាបិតា ថ្នាំសម្រាប់
រក្សាតកិតកមិនបាន ។ តោមារតោវេជ្ជោ កុមារតេឲ្យពាល៌ឲ្យយ
គ្មានចិត្តត្រេកអរដួយថែរក្សា ។ បើពាកនោះកើតក្នុងត្រកូលសេដ្ឋី ទ្រព្យ
ដែលមានពាល៌ប៉ុន្មាន តំអន្តរាយអស់ ធ្លាក់ខ្លួនទៅជាអ្នកកំសត់ទុគ្គត
អនាថា ។ បើពាកនោះកើតក្នុងត្រកូលអមាត្យ កិត្រូវពេសនិរាទេស
បណ្តេញចេញពីនគរ ព្រោះហេតុព្រះមហាក្សត្រទ្រង់មានព្រះរាជបញ្ជា
ឲ្យបណ្តេញចេញ ។ យ៉ាងនេះឈ្មោះថាទុបត្តម្ភកកម្មទាងអកុសល ។

បុគ្គលដែលមានទុបត្តម្ភកកម្មទាងអកុសលផ្តល់ផ្តួលាពេសឲ្យតែតែ
វិនាសអន្តរាយច្រើន ។ ទៅទៀតនោះ មកពីពេសនៃខ្លួនគ្មានចិត្តមេត្តា
មិនធ្វើបាន ខ្លាំង ប្រទូសរាយដល់អ្នកមិនប្រទូសរាយ សមតាមរឿងអតី-
តនិទានមានក្នុងព្រះសុត្តន្តបិដកដូចតទៅនេះ៖

(ទៅមានត)

ទ្វាទសកម្មកថា

ព្រះមុនីកោសល សូរ-ហាយ

អធិបតីវត្ត នៃក្រុមដំបូលព្រះវត្តចំដក តែងរៀបរៀង

ទ្វាទសកម្មកថា

សម្តែងអំពីកម្ម ១២ យ៉ាង

កម្មពួកទី ១ ឱ្យផលតាមគ្រា

១– ទិដ្ឋធម្មវេទនីយកម្ម កម្មឱ្យផលក្នុងបច្ចុប្បន្ន ។

២– ឧបបជ្ជវេទនីយកម្ម កម្មឱ្យផលក្នុងជាតិជាបន្ទាប់ ។

៣– អបរាបរវេទនីយកម្ម កម្មឱ្យផលក្នុងជាតិតៗ ទៅ។

៤– អហោសិកម្ម កម្មដែលគ្រាន់ផលអស់ហើយ ។

កម្មពួកទី ២ ឱ្យផលតាមកិច្ច

៥– ជនកកម្ម កម្មញ៉ាំងសត្វឱ្យកើត ។

៦– ឧបត្ថម្ភកកម្ម កម្មដែលជួយជ្រោមជ្រែង ។

៧– ឧបបីឡកកម្ម កម្មដែលបៀតបៀន ។

៨– ឧបឃាតកម្ម កម្មដែលផ្តាច់ផ្តិល ។

ពួកកម្មទី ៣ ឱ្យផលតាមលំដាប់

៩– ជនុកម្ម កម្មដ៏ធ្ងន់ ។

๑๐- พหุลกรรม กรรมដែលសន្សំច្រើន ។

๑๑- អាសន្នកรรม กรรมដែលធ្វើក្នុងវេលាជិតស្លាប់ ។

๑๒- คตัณกรรม กรรมដែលគ្រាន់តែធ្វើឥតចេតនា ។

กรรม ๑๒ យ៉ាងនេះ មាន ๓ ពួក គឺកรรมពួកទី ๑ ឲ្យផលតាមគ្រា กรรมពួកទី ๒ ឲ្យផលតាមកិច្ច กรรมពួកទី ๓ ឲ្យផលតាមលំដាប់ ។

ពាក្យថា « ឲ្យផលតាមគ្រា » សំដៅយកផលរបស់กรรม គោះបីជាกุสล ឬជាអกุสล ដែលបុគ្គលធ្វើហើយ กรรมនោះរមែងឲ្យផលយើញជាក់ច្បាស់ តាមសមគួរកន្លងវេលា ឬក្នុងขณៈមិនយូរប៉ុន្មាន បន្ទាប់អំពីកាលនៃជាតិដែលខ្លួនធ្វើមក ។

ពាក្យថា « ឲ្យផលតាមកិច្ច » សំដៅយកផលរបស់កិច្ចការ គឺថា កិច្ចធំឬតូច ធ្ងន់ឬស្រាល ក៏រមែងកើតផលតាមកម្លាំង នៃកិច្ចដែលបុគ្គលធ្វើ ។

ពាក្យថា « ឲ្យផលតាមលំដាប់ » សំដៅយកផលរបស់กรรมដែលបុគ្គលធ្វើ ជាផលដែលត្រូវឲ្យ ក្នុងกาลជាលំដាប់នៃជាតិ របស់បុគ្គលអ្នកធ្វើ ដូចជាអ្នកធ្វើអំពើជាกุสล ឬអกุสលក្នុងជាតិនេះ នឹងត្រូវទទួលផលក្នុងជាតិជាលំដាប់ ។ តទៅអនាគត ។

អធិប្បាយពង្រីកសេចក្តី

១- ឯដ្ឋធម្មវេទនីយកម្ម កម្មនេះ លោកតំណាត់យកតាំងកុសលតាំងអកុសល ជាកម្មដែលតើតក្នុងបឋមជវនៈ មានកម្លាំងក្លៀវក្លាជាងជវនៈទី ២ អាចឲ្យផលក្នុងបច្ចុប្បន្ន គឺកុសលកម្មដែលបុគ្គលធ្វើក្នុងជាតិនេះ ឲ្យផលសម្រេចក្នុងជាតិនេះ អកុសលកម្មដែលបុគ្គលធ្វើក្នុងជាតិនេះ ក៏ឲ្យផលសម្រេចក្នុងជាតិនេះ ។ ការធ្វើបុណ្យឬធ្វើបាបដែលអាចឲ្យផលក្នុងបច្ចុប្បន្ននោះ អាស្រ័យកម្លាំងរបស់ជវនចិត្ត បើជវនចិត្តជាកុសល ក៏ឲ្យសម្រេចការជាបុណ្យ បើជវនចិត្តជាអកុសល ក៏ឲ្យសម្រេចការបាប ។ ផលរបស់កម្មនោះ ក៏បង្ហាញឲ្យឃើញជាក់ច្បាស់ដោយអំណាចកម្លាំងនៃជវនចិត្ត ក្នុងកាលដែលធ្វើ ព្រោះថា កុសលនិងអកុសលតាំងអស់ កាលដែលបុគ្គលធ្វើ សុទ្ធតែប្រកបដោយជវនចិត្តដែលមានកម្លាំងក្លៀវក្លា ឬទន់ខ្សោយជាដរាប បើកម្មប្រកបដោយជវនចិត្តខ្លាំងក្លា ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ កាលបើកម្មជវៈ មិនអាចឲ្យផលបានទេ ក៏ក្លាយទៅជាអហោសិកម្ម ជាកម្មគ្រឹនផលអស់ហើយ ជាកម្មលែងមានផល ដែលត្រូវឲ្យកើតក្នុងបច្ចុប្បន្ន ខ្ជិលអនាគតទៀតហើយ ។ ទិដ្ឋធម្មវេទនីយកម្ម នេះ មានឧទាហរណ៍ប្រៀបដូចជាព្រានម្រឹគ ដែលលបលាក់ខ្លួនចាំបាញ់ម្រឹគ កាលបើឃើញម្រឹគមកដល់ ខ្លួនក៏យឹតធ្នូបាញ់ទៅម្រឹគនោះ ព្រួញដែលព្រានបាញ់ទៅនោះ បើត្រូវម្រឹគបានដូចបំណង ព្រានម្រឹគ

កំចាស់កន្លែងអង្គុយនោះចេញ ហើយយកម្រឹតនោះមកតម្កល់ស្បែកគោ
សាច់ យកទៅចំអិនបរិភោគ ។ ម៉ើនាយព្រានចាញ់ម្រឹតមិនត្រូវ ព្រោះ
ហេតុម្រឹតនោះដឹងខ្លួន គេចរត់ចាត់ទៅ សេចក្តីនេះយ៉ាងណាមិញ នាយ
ព្រានម្រឹតនោះ បុគ្គលគប្បីយល់ថា ដូចជា ទិដ្ឋធម្មវេទនីយកម្ម
សត្វម្រឹតដូចជាផលនៃទិដ្ឋធម្មវេទនីយកម្ម កាលព្រានចាញ់ត្រូវម្រឹតបាន
ដូចបំណង ប្រៀបដូចជាកម្មឲ្យផលក្នុងជាតិនេះ កាលម៉ើព្រានចាញ់
ម្រឹតមិនត្រូវ ម្រឹតផ្តើលរត់គេចចាត់ទៅ ប្រៀបដូចជាកម្មដែលពុំអាច
ជ្រៀតជ្រែកឲ្យផលក្នុងបច្ចុប្បន្នបាន កម្មនោះគំរៅជា អ្អហោសិកម្ម ។

២- ឧបបជ្ជវេទនីយកម្ម កម្មឲ្យផលក្នុងជាតិជាបន្ទាប់ ។ កុ-
សលកម្ម ឬអកុសលកម្ម ដែលកើតខ្លាំងដោយសត្តមជវន (ជវនទី ៧)ជា
កម្មឲ្យផលក្នុងជាតិជាបន្ទាប់អំពីជាតិរបស់បុគ្គល ដែលប្រព្រឹត្តធ្វើ ។
ឧបបជ្ជវេទនីយកម្ម នេះ ម៉ើជាផ្នែកខាងកុសល បានដល់សមាបត្តិ
៨ ប្រការ គឺរូបសមាបត្តិ ៤ អរូបសមាបត្តិ ៤ ។ ម៉ើជាផ្នែកខាងអកុសល
បានដល់អនន្តរិយកម្ម ៥ ប្រការ ។ យោគាវចរកុលបុត្រ អ្នកចំរើនឈាន
ស្គាត់ជំនាញ ក្នុងរូបជ្ឈាន លុះច្យុតចាកអត្តភាពនេះ កំរៅកើតក្នុងព្រហ្ម-
លោក ដោយកម្លាំងសមាបត្តិណាមួយដែលឲ្យផលបានមុន ឯសមាបត្តិ
ទាំង ៧ នោះ កំរៅជាអហោសិកម្ម ដ្ឋាកាឲ្យផលទៀត ចំណែកខាង

អនន្តរិយកម្មទាំង ៥ ក៏ដូចគ្នា ចើបុគ្គលណា ធ្វើអនន្តរិយកម្មទាំង ៥ បុគ្គលនោះត្រូវទទួលផលអនន្តរិយកម្មណាមួយ ដែលតាក់តែងឲ្យបដិសន្ធិបានមុន ឯអនន្តរិយកម្មទាំង ៤ នោះ ក៏ទៅជាអហោសិកម្ម ។

ឧបបជ្ជវេទនីយកម្ម នេះ ជាកម្មដែលត្រូវឲ្យផលក្នុងជាតិទី ២ ដូចយ៉ាងស្តេចអជាតសត្តុ ឮស្តាប់ពាក្យកុក្កុវេវត្ត ធ្វើអំពើបិតុឃាតចំពោះព្រះរាជបិតារបស់ខ្លួន លុះស្តេចអជាតសត្តុ ដល់ខួរមរណភាព ក៏ទៅកើតក្នុងនរក រងទុក្ខវេទនាអស់កាលយូរ ក្នុងជាតិជាបន្ទាប់ គឺជាតិជាគំរប់ពីរ អំពីជាតិជាបច្ចុប្បន្នរបស់ខ្លួន ។

៣- អបរាបរវេទនីយកម្ម កម្មឲ្យផលក្នុងជាតិតៗទៅ កម្មនេះកើតឡើងក្បៀវក្បាដ៏សមគួរ ក្នុងចន្លោះនៃជវនវារៈទាំងពីរ គឺបឋមជវន ខីណសត្តមជវន កម្មនេះមិនទៅជាអហោសិកម្មទេ តែងជាប់តាមបុគ្គលអ្នកធ្វើតរៀងទៅ ចើបុគ្គលនោះមិនទាន់បានសម្រេចអរហត្ត ដរាបណា កម្មនេះក៏តាមឲ្យផលដរាបនោះ រាប់តាំងអំពី ១០ ជាតិ រហូតជាដើមឡើងទៅ តាមចើបានឱកាស ក្នុងកាលណា ក៏ឲ្យផលក្នុងកាលនោះ ។ អបរាបរវេទនីយកម្ម នេះ បុគ្គលតម្រិះដឹងដោយពាក្យឧបមា ដូចត្រាន់សុនខ ។

ធម្មតាសុនខដែលត្រាន់ពាន្យះ ឲ្យដេញម្រ័តនោះ សុនខក៏ស្ទុះចោលទៅស្តាត់ទាន់ស្មាខ្លះ ខាងក្នែងខ្លះ ដេញតាមទៅ តាល់តែកាល

ណាដេញតាមទាន់ ក៏ទាំម្រឹត ក្នុងកាលនោះ មិនអាចលែងវិញទេ ។ សុខៗដែលប្រឹងប្រែងដេញតាមទាំម្រឹតទាល់តែទាំបាន យ៉ាងណាមិញ អបរាបរវេទនីយកម្ម កំដាច់តាមសត្វដែលត្រាច់ត្អូតត់ចាប់កំណើត គឺក្នុងកំណើតទាំង ៤ ក្នុងតតិយាំង ៥ ក្នុងវិញ្ញាណដ្ឋិតិទាំង ៧ ក៏យ៉ាងនោះដែរ ។ ពួកសត្វទាំងអស់ មិនអាចនឹងគេចចេញអំពី អបរាបរវេទនីយកម្ម នោះបានឡើយ បើពុំកជាទៅពួនក្នុងមហាសមុទ្រក្តី ក្នុងភ្នែកភ្នក្តី ឋិតនៅឰដអាកាសក្តី ក៏មិនរួចអំពីអបរាបរវេទនីយកម្ម ក្នុងកាលណាមួយទេ ។ កម្មដែលសត្វបានធ្វើនោះ គេនៅជាកុសលកម្ម ឬអកុសលកម្ម ឈ្មោះថាជាកម្មរបស់ខ្លួនដោយពិត មិនមែនអន្តរាយទៅអំពីសត្វដែលជាអ្នកធ្វើនោះទេ លោកប្រៀបដូចជាស្រមោលដែលជាប្រចាំតាមតែងអនុលោមទៅតាមប្រាណ ។ ការធ្វើប្រកបដោយសុចរិត ក៏រមែងឲ្យផលជាសុខសួស្តីជាប់តាមខ្លួន ការធ្វើប្រកបដោយទុច្ចរិត ក៏រមែងឲ្យផលជាទុក្ខភ័យជាប់តាមខ្លួនទៅ ។ ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា ប្រាថ្នាសេចក្តីសុខដើម្បីខ្លួន គប្បីបំពេញនូវកុសលកម្ម គប្បីប្រព្រឹត្តធម៌ជាសុចរិត គ្រប់គ្រាន់ គប្បីលះបង់អកុសលកម្ម វៀរចាកការប្រព្រឹត្តទុច្ចរិត ។

៤- អហោសិកម្ម កម្មដែលគ្រាន់ផលអស់ហើយ ឬនៅផ្តល់កម្មនោះជាកុសល ឬអកុសល ដែលកន្លងកាលផុតទៅ មិនអាចឲ្យផលជាកម្ម ឲ្យផលមិនកើត ដោយហេតុកម្មទាំង ៣ ខាងដើម ត្រឿតត្រែកឲ្យ

ជាន់មុន ព្រោះហេតុនោះ អរហោសិកម្ម នេះ ឈ្មោះថាជាកម្មមិនឲ្យផល
ទៅវិញ លោកប្រៀបដូចជាផ្លែក្រូចជាតិ មានផ្លែដូងជាដើម ដែលខូចពីដំ
សម្រាប់ដុះអស់ហើយ មិនអាចនឹងដុះលូតលាស់ឡើងបាន ។

៥- ជនកកម្ម កម្មញ៉ាំងសត្វឲ្យកើត ។ កម្មនេះនៅក្នុងពួក
កម្មឲ្យផលតាមកិច្ច បានដល់កុសលកម្ម ទឹងអកុសលកម្ម ដែលញ៉ាំងសត្វ
ឲ្យកើតក្នុងបដិសន្ធិកាល កម្មនេះ ឲ្យផលច់តែក្នុងបដិសន្ធិកាល
ប៉ុណ្ណោះ ។ កម្មដែលឲ្យផលតាមនាទីដូច្នេះ លោកហៅថា ជនកកម្ម
បណ្ឌិតគប្បីសន្និដ្ឋានថា កុសលកម្ម ឬអកុសលកម្ម ដែលឲ្យផលក្នុងបវត្តិ
កាល បន្ទាប់អំពីបដិសន្ធិកាលនោះ គឺជាកម្មដទៃដោយឡែក មិនមែន
ជាជនកកម្មឡើយ ប្រៀបដូចជា មាតាគ្រាន់តែជាអ្នកបង្កើតបុត្រប៉ុណ្ណោះ
ឯត្រង់ការចិញ្ចឹមថែរក្សានោះ ជាភ្នាក់ងារបស់មេនំ សេចក្តីនេះយ៉ាងណា
ជនកកម្ម គ្រាន់តែជាភ្នាក់ងារក្នុងការណែនាំបដិសន្ធិឲ្យកើត បន្ទាប់មក
ទើបមានឧបត្ថម្ភកម្ម ឧបឃាតកម្ម បន្តមកទៀត ក៏យ៉ាងនោះដែរ ។

៦- ឧបត្ថម្ភកកម្ម កម្មដែលជួយជ្រោមជ្រែង បានដល់កុ-
សលនឹងអកុសល ដែលជាប់តាមទំនុកបំរុងគាំពារក្នុងបវត្តិកាល ។
ឧបត្ថម្ភកកម្ម នេះ បណ្ឌិតគប្បីយល់ថា ជាកុសលក៏មាន អកុសលក៏
មាន ប៉ុន្តែមតិនៃអ្នកប្រាជ្ញខ្លះថា ឧបត្ថម្ភកកម្ម នេះ ជាកុសលសុទ្ធ មិន

ភព់យកអកុសលវិញ ។ ក្នុងបករណៈវិសុទ្ធិមគ្គ ទីឆគម្ពីរ មនោរថបូ
រណី ថា ឧបត្ថម្ភកកម្ម បានដល់កម្មទាំងកុសល ទាំងអកុសល មិនសំដៅ
យកចំពោះកុសលតែម្យ៉ាងទេ ដូចបុគ្គលពួកខ្លះ ធ្វើការកុសលណាមួយ
លុះដល់ធ្វើមរណកាល ក៏ទៅកើតក្នុងសុគតិភព លុះបិតទៅក្នុងសុគតិភព
នោះ ក៏ចំប្រឹងប្រែងធ្វើកុសលរឿយ ។ កុសលកម្មរបស់បុគ្គលនោះឈ្មោះ
ថាជាឧបត្ថម្ភកកម្ម ជាបច្ច័យដួយជ្រោមជ្រែងឲ្យបុគ្គលនោះ បានទទួល
ផលជាសុខ អស់កាលដ៏វែង បន្តទៅទៀតនេះឈ្មោះថា ឧបត្ថម្ភកកម្ម
ជាកុសល ។ បុគ្គលខ្លះធ្វើអកុសលកម្មផ្សេង ។ លុះធ្វើមរណកាល ក៏ទៅ
កើតក្នុងទុគ្គតិភពនោះ ក៏ធ្វើបាបកម្មណាមួយថែមទៀត បុគ្គលនោះក៏បាន
ទទួលទុក្ខវេទនាក្នុងភពនោះ អស់កាលយូរតទៅទៀត នេះឈ្មោះថា
ឧបត្ថម្ភកកម្ម ជាអកុសល ។

ឧបត្ថម្ភកកម្ម នេះ មានសេចក្តីផ្សេងគ្នា សូមឲ្យលោកអ្នកឈ្វាស
រៃ ត្រិះរិះពិចារណា យកសេចក្តីតាមគាប់ចិត្តចុះ ។

៧- ឧបបីឡកកម្ម កម្មដែលបៀតបៀន បានដល់កម្មទាំងកុសល
ទាំងអកុសល ដែលសម្រេចតិចបៀតបៀន ខ្លួវផលរបស់កម្មដទៃ ដូច
យ៉ាងកុសលកម្មកំពុងឲ្យផលក្នុងកាលណាមួយ ក៏ស្រាប់តែមានអកុសល
កម្មមកជ្រៀតជ្រែក បៀតបៀន ខ្លួវផលរបស់កុសលកម្មនោះ។ ឧបបីឡ

កកម្ម រមែងជាប់តាមបៀតបៀនញាំញីខ្លួនសុខទុក្ខ មិនឲ្យសុខទុក្ខ
រកែតឡើង ដូនតៅអស់កាលយូរបាន ។

ឧបបីឡកកម្ម នេះ បើខាងកុសលកំពុងឲ្យផល រមែងតែមាន
អកុសល ជាឧបបីឡកកម្ម បើខាងអកុសលកំពុងឲ្យផល រមែងតែមាន
កុសលជាឧបបីឡកកម្ម គឺជាកុសលកម្ម បៀតបៀនឃាត់ហាមខ្លួន
អកុសល មិនឲ្យមានឱកាសឲ្យផលបាន អកុសលកម្មក៏បៀតបៀនឃាត់
ហាមខ្លួនកុសល មិនឲ្យមានឱកាសឲ្យផលបានវិញដែរ មួយទៀត កុសល
កម្ម ជាឧបបីឡកកម្មរបស់អកុសល ដើមឯអកុសលកម្ម ជាឧបបីឡកកម្ម
របស់កុសលវិញដែរ ។

๘- ឧបឃាតកម្ម កម្មដែលផ្តាច់ផ្តិល បានដល់កម្មទាំងពីរ
គឺទាំងកុសល ទាំងអកុសល បើកុសលកម្មតាមទាន់ រមែងផ្តាច់បង់ខ្លួន
អកុសលកម្ម បើអកុសលកម្មតាមទាន់ រមែងផ្តាច់បង់ខ្លួនផលរបស់កុសល
កម្ម ។ កុសលកម្ម ជាឧបឃាតកម្មរបស់អកុសល ចំណែកខាងអកុ-
សលកម្មក៏ជាឧបឃាតកម្មរបស់កុសលវិញដែរ ។ កម្មនេះ លោក
ហៅថា ឧបច្ឆេទកកម្ម ដូច្នេះវិញក៏បាន ។ ឧបឃាតកម្ម នេះ មាន
សេចក្តីប្រហែលគ្នានឹងឧបបីឡកកម្មដែរ ផ្សេងគ្នាតែត្រង់ការឲ្យផលយូរ
នឹងឆាប់ប៉ុណ្ណោះ គឺឧបឃាតកម្ម កាលបើជាប់តាមហើយ ក៏ផ្តាច់បង់សង្កត់

សង្ខិនដោយធាប់រហ័ស មិនបៀតបៀនបណ្តាយឲ្យយូរ អស់កាលវេលាវែងដូចឧបច្ឆិកកម្មខេ ។

៩- គរុកម្ម កម្មកំណន់ ជានជល់កម្មតាំង ២ ចំណែក គឺ តាំងកុសល តាំងអកុសល ។ កុសលកម្ម លោកសំដៅយកមហគ្គតកម្ម ៩ គឺ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ នេះចាត់ជាគរុកម្មខាងកុសល ព្រោះជាហេតុនាឲ្យកើតផលដ៏ខ្ពង់ខ្ពស់ក្នុងជាតិជាលំដាប់ ។ អកុសលកម្មសំដៅយកអនន្តរិយកម្មតាំង ៥ មានមាតុឃាតជាដើម នេះចាត់ជាគរុកម្មខាងអកុសល ដោយហេតុថា បុគ្គលដែលធ្វើអនន្តរិយកម្មតាំង ៥ ណាមួយ បើទុកជាដឹងថាខ្លួនធ្វើកម្មអាក្រក់ណាស់ ហើយក្រោយមកមានចិត្តប្រែចិត្តដោយវិធីណាមួយ មានបព្វជ្ជា ឌីឆ្នៃបសម្បទាជាដើម ក៏ព្រះអង្គមិនអនុញ្ញាតចំពោះវិធីនោះឡើយ សូម្បីទៅជាត្រហស្ថ ខំចំរើនសមថកម្មដ្ឋាន ក៏មិនអាចសម្រេចមគ្គផលបាន ពោះបីធ្វើបុណ្យណាមួយ ដើម្បីលុបលាងពោសអនន្តរិយកម្មនោះក៏ពុំបាននឡើយ ។ បុគ្គលអកធ្វើអនន្តរិយកម្មនោះ លុះធ្វើកាលកិរិយា ទៀងតែទៅកើតក្នុងនរកដោយពិត ព្រោះអំពើនោះ ជាអំពើជាបមានទម្ងន់ណាស់ ទើបលោកចាត់ជា គរុកម្ម (កម្មដ៏ធ្ងន់) ។

១០- ពហុលកម្ម កម្មដែលសន្សំច្រើន ជានជល់កម្មតាំង ២ ចំ

វិណាក គឺទាំងកុសលទាំងអកុសល ។ កុសលណាមួយដែលបុគ្គលធ្វើជាញឹកញយ ជាកុសលមានកម្លាំង ប្រកបដោយសោមនស្សចេតនាក្នុងកាលទាំង ៣ គឺកាលខាងដើម នៃការធ្វើបុណ្យប្រកបដោយសោមនស្ស កាលកំពុងធ្វើក៏មានសោមនស្ស កាលបើធ្វើរួចហើយ ក៏មានសោមនស្សទៀត កម្មនេះទើរហៅថា អាចិណ្ណកម្មកិច្ចាន ។ ផ្នែកខាងអកុសលនោះ គឺអកុសលណាមួយដែលបុគ្គលសន្សំធ្វើញឹកញយ ជាអកុសលមានកម្លាំងប្រកបដោយទោមនស្ស ក្នុងកាលទាំង ៣ ដូចខាងកុសលដែរ ។ អកុសលកម្ម ប្រកបដោយទោមស្សដំក្រៀវក្រា ដែលភ្ជាក់ផៅក្នុងសេចក្តីក្រោធ មានការគាចយោរយៅ អាចហ៊ាន ដេរវាយ កាប់ សម្លាប់មនុស្ស សត្វជាដៃ ។ កម្មនេះច្រើនតែឲ្យផល យើញជាក់ច្បាស់ ក្នុងកាលដែលមានជម្ងឺធ្ងន់ប៉ះពាល់ម្តង ។ ដោយនិមិត្តយើញជាក់ច្បាស់ ព្រោះកម្មនោះមានការសៅនៃបច្ចុប្បន្ន (បច្ចុប្បន្នដោយការសេពគប់ថ្មីកើរឿយ ។ ក្នុងមនោទ្វារ) ។

๑๑– អាសន្នកម្ម កម្មដែលធ្វើក្នុងវេលាជិតស្លាប់ ចាន់ជាល់កម្មទាំង ២ គឺទាំងកុសលទាំងអកុសល ។ កុសលនឹងអកុសលដែលបុគ្គលធ្វើនោះ ហើយទំពាលើកយើញច្រាកដក្នុងមនោទ្វារ ក្នុងវេលាជិតធ្វើកាលកិរិយា កម្មនោះឈ្មោះថាអាសន្នកម្ម ឬហៅថា យថាសន្នកម្មក៏

ចាន ។ អាសន្នកម្ម នេះ មិនអាចនឹងមានកម្មដទៃចូលជ្រៀតជ្រែក ដណ្តើមឲ្យផលបានមុនឡើយ ព្រោះតែនឹងតែមហគ្គតកុសលនឹងអនន្តរិយកម្ម ។ ឯកម្មដទៃ ។ ឲ្យផលមុនបានដោយក្រណាស់ សូម្បីអាសន្នកម្ម មានប្រមាណតិចតួចដោយ ច្រើនតែឲ្យផលបានមុន ជាងកម្មដទៃជាជាងប្រៀបដូចជាគោចាស់ដែលឈរនៅជិតមាត់ទ្វារក្រោល កាលម្ចាស់គោបានបើកទ្វារក្រោលភ្លាម គោចាស់នោះក៏អាចចេញតាមទ្វារបានមុនជាងគោក្មេង សេចក្តីនេះយ៉ាងណា អាសន្នកម្ម កម្មដែលបុគ្គលនឹកឃើញក្នុងកាលវៀចមរណៈ ក៏អាចឲ្យផលបានមុន ជាងកម្មឯទៀត ក៏យ៉ាងនោះដែរ ។

๑๒- ពហុលកម្ម កម្មដែលគ្រាន់តែធ្វើ ឥតចេតនា សំដៅយកកុសលកម្មនឹងអកុសលកម្ម ដែលជាកម្មស្តួចស្តើង ឬកម្មស្រាល ។ ជាកម្មផុតចាកកម្មទាំង ៣ គឺ គរុកម្ម ๑ ពហុលកម្ម ๑ អាសន្នកម្ម ๑ កដត្តាកម្ម មិនកប់បញ្ចូលក្នុងកម្មទាំង ๓ នេះឡើយ ។ កម្មនេះហៅថា កដត្តាវាបនកម្ម ក៏ចាន ។ មួយទៀត អំពើបេះសម្លាប់បុគ្គលដែលប្រកបដោយកាយ វចា ចិត្ត ដោយពុំបានដឹងថាជាបុណ្យឬជាបាប គឺការធ្វើដោយមិនដឹងថា ត្រូវឬខុសទេ គ្រាន់តែធ្វើទៅតាមទម្លាប់ប៉ុណ្ណោះ កម្មនេះ លុះដល់កាលដែលឲ្យផល ក៏ពុំមានកំណត់ ប្រៀបដូចជាកូនសេដែល

គេថ្នាក់ឆ្ពោះទៅទីណាមួយ ធម្មតាកូនសរ ដែលគេថ្នាក់ទៅខោះ មិនអាចនឹងកំណត់ថា ភ្នាក់កន្លែងនេះនោះបានទេ សេចក្តីនេះយ៉ាងណា កដូច្នាកម្ម អាចឲ្យផលដល់បុគ្គលអ្នកធ្វើ តាមអំណាចកម្មរបស់ខ្លួនជាយថាពិត ប៉ុន្តែពុំអាចកំណត់កាលវេលាបាន កំយ៉ាងនោះដែរ ។

ការបញ្ជាក់អំពីកម្ម ដូចបានអធិប្បាយមកនេះ ជាផ្លូវដ៏ល្អដែលព្រះសម្មាសម្ពុទ្ធសំដែងទុកមកហើយ ដើម្បីពន្យល់ឲ្យយើញថា បណ្តាកម្មទាំងអស់ កម្មណាមួយសុទ្ធតែជាហេតុ កាលបើហេតុមាន ផលក៏រមែងមានតាមផលទាំងអស់ ទោះបីជាសុខឬជាទុក្ខ រមែងចេញផ្តើមមកអំពីហេតុដោយមានហេតុជាប្រកាន (ហេតុជាដែនសម្រាប់កើត) ។ កម្មប្រៀបដូចជាដើមឈើ ផ្លាឬផ្លែ ដូចជាតួផល ។ ផលល្អក្តី ផលអាក្រក់ក្តី សុទ្ធតែកើតមកអំពីហេតុខាងក្នុង ពោលគឺកម្មរបស់អ្នកធ្វើ គឺជាកម្មរបស់បុគ្គលណា ផលក៏ឲ្យដល់បុគ្គលនោះវិញ តាមសមគួរដល់កម្មាំងកម្មរបស់ខ្លួន ដោយពិត ។ កម្មជាបុណ្យឬកម្មជាបាប ទៀងតែឲ្យផលជាជាតិ ពុំមានវត្តសក្តិសំខ្ចីណាមួយ មកជ្រៀតជ្រែកឲ្យផលឲ្យសោះឡើយ សូមបងប្អូនពិចារណាអំពីកម្មនេះដ៏ប្លែកឲ្យ ដោយសេចក្តីថា បើបុគ្គលធ្វើអំពើអាក្រក់ ហើយទំបន់ស្រន់សំបួងសង្រួងចំពោះតែសក្តិសិទ្ធិ ឬចំពោះព្រះជាម្ចាស់ថា «សូមឲ្យបានផលជាសុខ សូស្តីដល់អាត្មាអញ» ។ អំពើអាក្រក់ដែលបុគ្គលណាធ្វើហើយ បុគ្គលនោះត្រូវបានទទួលផលអាក្រក់វិញជាប្រាកដមិនអាចប៉ែរ ដោយ

ការបន់ស្រន់ដូច្នោះឡើយ ។

ការសំដែងអំពីកម្មនេះ ដើម្បីញុំាងឱមហាជនឲ្យស្គាល់ហេតុផល នឹងបានចៀសចាង រៀចាកចាបកម្ម ឬអកុសលកម្មឲ្យស្រឡះ ចេញចាកទន្ទីសន្តាន ហើយនឹងបានសេពគប់ អប់រំ ចំរើន ធ្វើឲ្យរឿយ ។ នូវបុញ្ញកម្ម ឬកុសល ឲ្យមានបរិបូណ៌ក្នុងខន្ធសន្តាន ។

ចប់ប៉ុណ្ណេះ ។

លោកថារីក្តុំ ព្រះសុមេរុធំ ខ្ពង់ខ្ពស់តណា
ប្រាំបីម៉ឺនស្បាន់ បួនពាន់យោជន៍ប្រា- កដគុណមាតា
ខ្ពស់លើសលែងនោះ ។ រីចក្រកល ខូលាយពិស្តារ
ធំធេងខ្លាំងនោះ ខូលាយលើសក្រៃ ឥតអ្វីស្មើស្មោះ
លើកយកគុណានោះ មកធ្វើមពុំបាន ។ រីមហាសមុទ្រ
ជ្រៅលង្ហៀបំផុត ពេកពន់ប្រមាណ មោះគុណមាតា
ក្សាត្រួយប្រាណ ជ្រៅក្រៃជលដ្ឋាន ជលសាគរវិញ ។
រីមហាប្រថពី ការគេតផែនដី ក្រាស់ក្រៃពាសពេញ
ខូពាន់ឯចក្រាឡ ថាស្រាលស្តើងវិញ គុណម្តាយនោះមិញ
ក្រាស់ក្រៃគណនា ។

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរចែកចូល
ឲ្យបានខ្ជាប់ខ្ជួន	គង់វិស្សគត់មត់
ព្រោះអក្សរជាតិ	ដោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

បញ្ហាជីវិត (វិចារណាកថា)

សហជីវិន ជ.ល.ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ និពន្ធ

ព្រះមុនីគោសល ស្វរ.មហាយ អធិបតីវិនក្រុមដំដុំព្រះត្រៃបិដក ពិនិត្យ ។

យោបល់អ្នកខ្លះ ប្រកាសពិត តែថាជីវិត ជាទោសទុក្ខ
ព្រោះត្រូវរក្សា ការគ្រប់មុខ តាំងពីស៊ីបុក ទំនុកកាយ ។
ខ្លះថា ជីវិត ឥតទោសទៀរ ជាធម្មជាតិថ្លៃ.ថ្នូ ឆើតឆាយ
ជាទីនាំសុខ មកផ្គុំកាយ មនុស្សសត្វតាំងឡាយ តែងចង់បាន ។
ឯអ្នកខ្លះទៀត ជ្រៀតពន្យល់ ប្រមូលយោបល់ តាំងពីរស្មោន
ប្រកាសប្រកាន់ ថា លំអាន ជីវិតគឺបាន តាំងពីរបែប ។
ដើម្បីលើងហេតុ សង្កេតការណ៍ បញ្ជោញភស្តុតាង បញ្ជាក់អែប
យើងសូមវែកញែក ដោយសង្ខេប ទុកជាបទបែប តិចារណា ។
ទីមួយ យោបល់ យល់ជាប់ចិត្ត ដែលថាជីវិត ទុក្ខខ្លោចផ្សា
ទ្រឹស្តីនេះឯង ចែងច្បាប់ថា មនុស្សយើងត្រូវតែ ដែលប្រឹងរស់ ។

ចន្លោះការគេត ឱនឯការស្ងាប់ លំបាកយ៉ាកយ៉ាប់ សព្វទាំងអស់
ដូចជាច្រឹងរក ទ្រព្យរបស់ រកកិត្តិយស ខ្ពស់ឧត្តម ។
បើមិនច្រឹងរក ភអត់ជាយ បើគ្មានច្រាកចាយ ការគ្រានំ
អម្ចាំហើយគ្រប់គ្នា ត្រូវតែទំ សម្បែស្បែនឡុំ កសាងកម្ម ។
បញ្ចេញទឹកភ្នែស បញ្ចូលទ្រព្យ ច្រឹងដឹកការយកម៉ ប្រណាំងជាំ
ទិញដូរបណ្តាក់ លក់បញ្ជាំ រងកម្មក្តៅកាយ ក្រហាយចិត្ត ។
ពេលថ្ងៃក្តៅថែស សឹងឆេះក្បាល ធ្វើការក្តៅពល កំគ្មានគិត
ត្រូវក្តៀងខ្លះ រះតួរកិត កំចិត្តឥតរេរះ រវែះខ្មៀយណាយ ។
តែក្រោកពីដេក ម៉ើកក្អែកឡើង ទាំងគេទាំងយើង ដើងប្រញាយ
ចេញទៅធ្វើការ ដ៏រវាំងឡាយ ព្រោះតែរូបកាយ ចង់រស់ពិត ។
អ្នកដែលក្រពេក ដេកសម្ងំ ជកដង្ហឹមធំ ក្រៀមក្រំចិត្ត
ខ្លះជ្រលុះសាង ខាងខុចតែ បង្ខិតបង្ខំ បង្ខូតគេ ។
ខ្លះទៀតលួចប្លន់ ជាន់លើឆ្អាប់ ហ៊ានជាញ់ចាក់គាប់ ក្បត់ឪម៉ែ
ខ្លះជាអ្នកវ ឃុកប្លាក់ខែ ខ្លះទៀតពូកែ ខាងលីសែង ។
ម៉ើលចុះ ជាស្រែរ ធំអ៊ីម្ល៉ះ ចំលើចង្កេះ គួរឲ្យស្ញែង
គោតគេព្រនាក់ ជាក់ដូចលេង ម្ចាក់ឯងឈានដើរ ធ្វើកាហ៊ែ ។
តើអ្វីទៅអេះ ? ដែលវុញច្រាន ឲ្យគ្នាច្រឹងប្រាណ គ្មានប្រណី
មិនតឹងដែរឬ ហ្នឹងឬអ្វី នេះឯងទ្រឹស្តី ដែលថាខុក្ខ ។

តាសេសសៅខៀត រូបកាន់កាយ ដែលអាស្រ័យថ្កាយ ម្ហូបគ្រប់មុខ
បើមានស៊ីហើយ នៅឈឺចុក មានពេតកាលខ្លះ រុកថែមខៀត ។
ប្រឹងតែថែខ្លួន ផ្លូនសំអាត កំយក្រែងឧត្តាត កាតជ្រែកជ្រៀត
ឈឺនេះឈឺខោះ ព្រួយចង្អៀត នេះខៀត ក៏គ្រោះ ព្រោះជីវិត ។
រួមមកថា រស់ ព្រោះប្រឹងណាស់ ហេតុនេះ ឃើញច្បាស់ ថាទុក្ខពិត
គ្មានផ្លូវណាមួយ ឲ្យជឿចិត្ត តែថា ជីវិត សុខស្រួលទេ ។
ទីពីរ យោចល់ ឃល់លើអ្វី ដែលចេញទ្រឹស្តី យ៉ាងហូរហៃ
ប្រាប់ថា ជីវិត ឥតទុក្ខទេ តើគេចង់ថា អាថ៌ដូចម្តេច ។
រឿងនេះ គេចង់ថា ជីវិត ដែលស្ថិតសព្វថៃ្ង ថៃ្ងជាងពេជ្រ
វាជាប្រភព សុខជានិច្ច ទោះមនុស្សដូចម្តេច ក៏ប្រាថ្នា ។
បើជាសំបុក ទុក្ខរំខាន ម្តេចក៏ចង់ចាន តែគ្រប់គ្នា
បើពិតជាហេតុ ទុក្ខវេទនា ម៉្លេះគ្មានអ្នកណា ត្រូវការឡើយ ។
គេស្អប់អាក្រក់ ទើបរកស្អ ស្អប់ខ្មៅរកស អ៊ីចឹងហើយ
ចុះជីវិតវិញ នោះមិត្រអើយ មិត្រឆ្លើយថាស្អប់ ឬស្រឡាញ់ ។
បើថាស្រឡាញ់ គេញាប់សុខ បើស្អប់ទើបទុក្ខ ពិតឥតកាល់
តែដើរសួរចុះ ខុសសុំទាញ់ បើគ្មានស្រឡាញ់ គឺគ្មានមនុស្ស ។
ដូច្នេះ ចេះប្រាប់សព្វបរិយាយ ជីវិតសប្បាយ នេះឥតខុស
បើនៅសង្ស័យ ថាកំហុស យើងសូមបំផុស ន័យតទៅ ។

ជីវិត ចាន់ដល់ការស៊ាកន បិតថេរបួបគ្រាណាវិញ្ញាណនៅ
ជីវិតមិនមែនរឿងផ្សាភ្ជាប់ តាមពិតគេហៅថាថ្ងៃថ្លា ។
ម៉ែវាជារបស់ ថ្លៃពិសុទ្ធ ពិសេសបំផុត ដូច្នេះណា
នោះគេអាចហៅ ខ្លួរវាថា ជាសុខធម្មតា គ្មានទុក្ខទេ ។
ដូចជាដុំពេជ្រ រំលេចស្រស់ ជាតែខ្ពស់សឹងអស់គេ
បើយើងមានច្រើន យើងតែងតែ រីករាយមិនចិត្តប្រែ កើតតែកាយ ។
តែបើមានពេជ្រ ពាក់ច្រើនយើង ចិត្តតែងរោរឡើង ភ្ញាសប្បាយ
ព្រោះពេជ្រជារបស់ ខ្ពស់ថ្លៃដោយ ម៉ាក្តីសប្បាយ មកឱ្យច្រើន ។
បើច្រើនវិនាស ដុំពេជ្រវិញ យើងបែរទៅម្ខាង ទុក្ខកំរាន
ដូចយើងច្រើនសុខ ពីសន្តាន តែងមានចិត្តស្តាយ ក្តាយជាទុក្ខ ។
រីឯជីវិត គឺតដូច្នោះ ច្រើនច្រើយសន្ធឹង ហៅថាសុខ
បើច្រើនជីវិត ពិតជាទុក្ខ ប្រៀបទឹងច្រើនសុខត្រូវពេកពន់ៗ
អ្នកដែលមានពេជ្រ តែងតិតខ្លាំង ភ័យក្រែងចោរខ្លាំង មកលួចប្លន់
រឿងនេះក៏ព្រោះតែនរជន តិតតន់ក្រែងពេជ្រ ជាប់ខ្លួនគេ ។
ព្រោះពេជ្រជាជួង ដើមនៃសុខ ឯទុក្ខមិនមែន តេជ្រលង់ទេ
ដូចអ្នកចាន់សុខ តែងតិតរេ ក្រែងគេលួចសុខ ដូច្នោះឯង ។
រីឯជីវិត ក្រឹតតម្រូវ មានផ្លូវត្រូវថា ចរចាថ្លៃង ។
ជាសុខថ្លៃថ្លា យើញជាក់ស្តែង មនុស្សស្រែងតែងចាន់មានមូលមក។

ត្រង់ប្រាណវិនាស ឋាត់ទៅវិញ　　ក៏គេខុកខ្ចូមម្ចាញ់ពេញកវែក
ដូចអ្នកឋាត់សុខ តែងខុកកក　　ទឹកខកស្ពាយវា ជាធម្មតា ។
ឯមនុស្សប្រឹងប្រាណ គ្មានឈប់ឈរ　　ប្រកបរកមធនទានា
ទ្រាំក្តៅក្រជាក់ ញាក់ខ្លោចផ្សា　　តែគ្រាន់តែជាថ្នូរជីវិត ។
ដូចយើងចង់ឋាន ឡានដុះលេង　　ខាល់តែខ្លះខ្លែង វែងរិះគិត
រកលុយកាក់ច្រើន ល្មមតម្រឹត　　ទើបឋានដូចចិត្ត ដែលត្រូវការ ។
បើឥតលុយកាក់ ប្រាក់ទៅទិញ　　ចំណង់នោះមិញ ឥតអស់ការ
មិនមែនអ្នកលក់ ចាំដេកខាត　　តន្សារខុកដល់ ជាតិក្រោយទៀយ ។
រីឯជីវិត ក៏ដូច្នោះ　　ត្រូវតែស្រាយដោះ អ័ចង៏ហើយ
បើមនុស្សថ្ងៃក្តៃ ដេកត្រងើយ　　អាចធ្វើយថាតិត ជីវិតគ្មាន ។
ប្រសិនត្រូវការ ប្រាថ្នាតេជ្រ　　ដែលជាធំរំលេចស្មើសួរកាន្ត
ត្រូវតែខំប្រឹង ឲ្យតឹងប្រាណ　　រកប្រាក់ឲ្យបានយកទៅជូរ ។
ជីវិតវិញសោត ក៏ដូច្នោះ　　ត្រូវយកការនោះ ខុកជាថ្នូរ
ត្រូវស្វែងសម្បត្តិ ឲ្យសម្បូណ៌　　ទើបអាចនឹងជូរ ជីវិតបាន ។
ប្រសិនរកទ្រព្យ មិនគ្រប់គ្រាន់　　ជីវិតក៏អន់ អាប់ឥតក្បាន្ត
ព្រោះថ្នូរខ្លួនតិច ធ្វើម្តេចបាន　　ជីវិតក្តៅឆ្អាន មានសុខពេញ ។
តែថើរកទ្រព្យបានគ្រប់គ្រឿង　　ជីវិតរុងរឿង ឥតខុកម្ញាញ
ព្រោះថ្នូរគេត្រម ល្មមលៃទិញ　　ជីវិតនោះមិញ ពេញសុខសាន្ត ។

អ្នកដែលចង់សេ្រះព្រោះខ្លាចងាប់ អ្នកដែលចង់ស្លាប់ព្រោះព្រួយប្រាណ
មានទោសទុក្ខធំតែពុំបាន យ៉ាងហ្នឹងទើបហ៊ានថែកហានទៅ ។
ទោសទុក្ខគ្មានទេ កន្លងជីវិត តែមនុស្សព្រួយចិត្ត គិតក្តួលក្តៅ
ទឹកយើញតែទុក្ខ មុខហ្នឹងសៅ លែងចង់សេ្រទៅ កន្លះលោកផង ។
ប្រៀបដូចមនុស្សម្នាក់ជំពាក់គេ មានខែ្យមាសតេជ្រ ច្រើនកន្ទុង
ដល់គេតារពេក ដេកមួហ្នឹង លក់មាសតេជ្រសង លែងអាល័យ ។
មាសតេជ្រជារបស់ថ្លៃមែនពិត តែថាលក់និតកឹអស់ន័យ
លក់សងគេក្លាម តាមតម្លៃ ឈប់ដេកស្រមៃ គេស្តីតារ ។
រីអ្នកចង់ងាប់ ព្រោះជាប់ទុក្ខ ជាប់ទោសផ្តាល់មុខ ផុតពុះតារ
អស់ផ្លូវត្រូវតែ ប្រែបង់ការ ប្រថុយសង្វាយកទៅសង ។
ទោសទុក្ខទោះឯង ក៏វែងឆ្ងន់ មានតែជីពជន្ម ទើបលុបមរង
យកទៅផាត់សេ្មាយថយថែមសង វួចគ្នាតែម្តង កន្លះលោកហ្នឹង ។
ហ៊ានទេះឯងហើយ ដែលធ្វើយថា ជីវិតថ្លៃថ្លា ឥតប៉ិនថ្លឹង
ជាសុខក្សេមក្សាន្ត មានទីពឹង មនុស្សត្រូវតែប្រឹង រក្សាទុក ។
នេះឯងយោបល់យល់កន្លងចិត្ត ប្រាប់ថាជីវិត ពិតជាសុខ
គ្មានផ្លូវណាទ្បើយ ធ្វើយថាទុក្ខ ដូចកយទំនុក មកប៉ុណ្ណឹង ។
ទីបីយោបល់យល់អារកាត់ អ្នកខ្លះបញ្ឆិតបញ្ឆោថ្លឹង
លាប់ចោលទ្រុស្តី ងាប់ពីរហ្នឹង ហើយតឹងប្រកែកជដែកថា ។

ជីវិតស្ថិតនៅផ្លូវកណ្តាល មិនជ្រាលភលៅ ផ្លូវខាងណា
គ្មានសុខគ្មានទុក្ខ ជាធម្មតា គេអាចហៅថា អព្យាក្រឹត ។
បើវាឯកា ជាប្រក្រតី ឥតអ្វីមកជ្រែក ក្នុងជីវិត
ខ្លួនហៅថាសុខ ក៏ពុំពិត ថាទុក្ខវិបរិត ក៏ពុំបាន ។
ប្រៀបដូចក្អែកជា មើលដំតឆ្ងាយ ឃើញរូបគាំងឆ្ងាយ សព្វទីហាន
ខោះបីរូបល្អ ស្រស់កុំថាន ឬរូបសាមាន្យ អាក្រក់ក្តី ។
មិនមែនក្អែកខ្លះ ជាជាងធ្វាក់ ឲ្យរូបវិលក្សណ៍ល្អពិសី
ឬឲ្យអាក្រក់ មិនគប្បី តាមពិតអ្វី ។ មានរូបកង ។
វាស្រេចតែតាមសភាពវា មិនមែនក្អែកណា ចេះកសាង
ក្អែកគ្រាន់តែឃើញ រូបត្រប់យ៉ាង នេះ ជាគំស្តុតាង យ៉ាងច្បាស់ ។
ដំណើរជីវិត ពិនិត្យទៅ ពិសោធរកន់ជ្រៅ ឲ្យត្រូវអស់
គឺវាមានត្រឹម តែការរស់ នាំឲ្យអស់ប៉ុណ្ណឹងឯង ។
ត្រង់រឿងសុខទុក្ខ ស្រលះតែកយ លំបាកសប្បាយ ដែលគេថ្លែង
ខោះវាត្រូវជា ធម្មជាតិផ្សេង ចែកចែងជាស្រេច ដាច់ដោយឡែក ។
ចំណែកជីវិត គឺតែរស់ ត្រង់រឿងតាបខ្ពស់ សុខទុក្ខប្លែក
មិនមែនជីវិតជាអ្នកចែក ប្រៀបបានខ្លួនក្អែក ដូច្នោះឯង ។
បើហ៊ានថាពិតជីវិតទុក្ខ ឯសុខគឺត្រូវតែថ្លាថ្លែង
ព្រោះសុខនឹងទុក្ខ តែរនេះឯង វាតែងនៅចាំ ផ្គាស់ប្តូរគ្នា ។

ប្រៀបដូចអាក្រក់ ហើយនឹងល្អ ឬមានទឹងក្រ ខ្ចូចទឹងជា
ពាំងនេះជាគូ គួរផងវា តែងជាស់ប្តូរគ្នា ជាលំអាន ។
តើបើមានល្អ សឹងតល្អក់ ឯក្តីអាក្រក់ ត្រូវតែមាន
ឥតក្តីពាំងទៅ តែឯកហ៊ាន ថានេះឥតស្មាន គ្មានខ្វាចក្រែង ។
មួយទៀតការរស់ បើគ្រោះខុក្ខ ឬជួកត់ត្រូវសុខ ដូចគេថ្លែង
សុខ-ទុក្ខពាំងនេះ កំពុងផ្សែង ការរស់គ្មានបែង បន្តើតឡើយ ។
ប៉ុន្តែ ការរស់ គឺជីវិត ជាអព្យាក្រឹត្យ ពិតមែនហើយ
តែងមានសុខទុក្ខ ទៅកិតកើយ មិនមែនទៅខ្លីយ ម្នាក់ឯងឡេ ។
ព្រោះកាយកើតបាន មានឈាមសាច់ ត្រូវការចាំបាច់ ច្រើនហូរហៃ
ដំបូង ចង់សៅ ដើម្បីរៃ ចាប់ប្រែប្រឹងប្រែងស្វែងរកសុខ ។ ។
ការស្វែងរកស្រួលក្តួលក្តៅណាស់ តែងតែរេរ៉ៃ លើក្តីទុក្ខ
ជៀលជាឧបស័គ្គ ស្ងាក់ពីមុខ ទម្រាំបានសុខ មានទុក្ខធំ ។
គិតទៅជីវិត មិនឥតគ្នា ត្រូវរងវេទនា ពាំងពីក្រែម
តើសុខនឹងទុក្ខ មកជ្រែកគ្នុំ ច្របូកច្របល់ ផ្សំចូលគ្នា ។
ពេលខ្លះជីវិត ជាសុខស្រួល ពេលខ្លះខ្ទួល ទុក្ខវេទនា
សប្បាយលំបាក ផ្ទាស់វេនគ្នា តាមព្រៃវាសនាវបស់មនុស្ស ។
ដូច្នេះ បើរួម សុខទុក្ខផង ដោយចង់គ្មានចែក ញែកគ្នាខោះ
ជីវិតគឺច្បាស់ អាចសង្គ្រោះ ឲ្យឈ្នះពីរយ៉ាងខាងធម្មសាស្ត្រ ។

ហៅសុខក៏ថាន ទុក្ខក៏ថាន ឬរួមតាំរហាន ឲ្យជាក់ច្បាស់
ថាជាសុខខ្លះ ជាទុក្ខខ្លះ ធ្វើយនេះត្រូវណាស់ អស់តាំ។
ហៃមិត្តតាំង ឮយ៉ាយ ច្រើនជ្រុយឆ្ងុះ ស្តាប់មើលទៅចុះចូរជោះសា
យោបល់តាំងបី លៃខាងណា ត្រូវល្អខ្លៃថ្លាសមសារជាង ។
សូមមិត្រជួយតបសងឲ្យជាក់ ប្រត្យក្សជាយន្តវ៉ែនវែងឆ
ខ្ញុំចង់ដឹងថាណាត្រូវជាង ឬតាំងបីយ៉ាង ម៉ាំងតាំងអស់ ។
បញ្ហានេះចោទ តាំសោធចិត្ត ចង់ឃើញគំនិតដឹងខ្ពង់ខ្ពស់
នៃមិត្រនារី នឹងបុរស តើចេញមកស្រស់រះបៀបណា ។
បើមិត្រគិតយល់ ផ្តល់ចម្លើយ សូមធ្វើយមកភ្លាមតាមប្រាជ្ញា
ឲ្យឃើញថាត្រូវ ព្រោះផ្លូវណា កុំខ្លាចគេថា អ្វីឲ្យឡើយ ។
ដ្បិតអីស្រី ប្រុស មនុស្សសោកស តែងមានយោបល់យល់ឆ្ងន់ធ្វើយ
ថ្លៃកៗ តាំគ្នាអីចឹងហើយ កុំគិតអ្វីឡើយ ធ្វើយមកចុះ ។
ប៉ុន្តែ ខ្ញុំចង់ស្រង់គំនិត ដែលពិតមិត្រស្រាវជ្រាវកែងឆ្ងុះ
តើផលទ្រឹស្តី តាំងបីខ្ទុះ ភជុះមែកជាងទៅខាងណា ។
ដូចជាយោបល់ យល់ចាប់ចិត្ត ថាដុំដីរិត ទុក្ខខ្លោចច្បា
បើគេប្រកាន់ជួរច្នេះណា តើគេនឹងជាមនុស្សអ្វីទៅ ។
ជាមនុស្សចេះចង់ខ្ពង់ខ្ពស់ប្រាណា ចង់មានចង់ចាន ចង់រស់ទៅ
ចង់ជួយសាងជាតិញាតិសាច់ផង ឬចង់រត់ទៅ ទៅណាវិញ ។

តើគេនិងជាមនុស្សហ៊ីហា លេងស្រីផឹកស្រា ចាវដង់សុំញ៉ា
ត្រូវការសេបញ្ជាយសុខសាយគេញ ឬមនោគោម្នេញគេញក្រៃលែង ។
ជាមនុស្សខ្ទុះមិត្រគិតតែបាន ដើម្បីរស់កន ខ្ជិនប្រាណឯង
ឬមនុស្សមានមែក ចេះចែកចែង ចែកសុខគេឯងស្មែងតែលួម ។
មិនលោភមិនលន់ធ្ងន់ខុសច្បាប ចរចើងចង់ចិត្តឥតចេះត្រួម
ឬជាមនុស្សក្តើដើរតែឬម ដូចកមរមាស់រស់ដោយគេ ។
ឬក៏គេនោះរស់ម្តេចវិញ សូមមិត្រចំពេញឲ្យហូរហៀ
ឲ្យឃើញហេតុផលយល់ប្រាជ្ញប្រៃ តាមកិច្ចលៀចកែ ខ្មែរអ្នកជា ។
រឯទីពីរ និងទីបី កំមានសេចក្តីន័យដូចគ្នា
ខ្ញុំចង់តែដឹងដំណឹងថា តើគេក្លាយជា មនុស្សដូចម្តេច ។
គឺថាបើគេប្រកាន់ចិត្ត ថាដូងជីវិត ពិតជាងគេជ្រៃ
ជាទីញុំាងសុខឲ្យសម្រេច គ្មានមនុស្សណាគេចមិនប្រាថ្នា ។
បើយល់យ៉ាងហ្នឹងគេប្រឹងតិត ព្រមប្រាណប្រព្រឹត្តទៅយ៉ាងណា
ដើម្បីតម្រូវ ផ្លូវតម្រា ដែលថាជីវិតពិតជាសុខ
រីខាងយោបល់យល់ដឹងតិត ថាអត្បាក្រិត្យឥតចេញមុខ
រួមបានតាំងសុខបានតាំងខ្លួន តើរៀបខំខ្នុកដូចម្តេចវិញ ។
អ្នកដែលប្រកាន់កំណាន់នេះ ខឹងទៅម៉ែចអេះសូមបំពេញ
តើគេរស់នៅដូចអ្វីវិញ ឱតប្តូចំណេញយ៉ាងណាខ្លះ ។

ប្រស្នានេះគួរស្ងួរយោចល់ ប្រយោជន៍ដំកល់កាព្យសាស្ត្រ
គំនិតសិល្បៈដ៏ជាក់ច្បាស់ ទឹងចិត្តសាស្ត្រឆ្ងាស់សម័យ ។
ទឹងជាប្រយោជន៍យ៉ាងខ្ពស់ ខាងការអប់រំផ្ទៃសង្ឃ
ឲ្យជាអ្នកសាងខាងប្រពៃ សូមមិត្រគិតលៃ ធ្វើយៅអើយ ។

- ចប់ -

នារីណា ប្តីដេរប្រពេច ប្តូរប្តីសំឡឹងសំឡក់
ដោយក្តីក្រោធ នៅតែធ្វើទឹកមុខស្រស់ស្រាយញញឹម
នារីនោះ ទើបឈ្មោះថាស្រីមានលក្ខណ៍ ។
ស្រីណាស្រឡាញ់ប្តី ពោះជាប្តីនៅក្រុង ឬនៅ
ស្រុកព្រៃ ឬពុំនោះទេ ជាប្តីគ្មានបុណ្យ ឬ មាន
បុណ្យក្តី ស្រីនោះទើបលោកចាំងមូលឲ្យសេចក្តីសុខ ។
សេចក្តីពិត កស្តាជាគ្រឿងអលង្ការនៃនារីចាំងឡាយ
នារីឥតកស្តា ឈ្មោះថាមិនមានគ្រឿងអលង្ការ
បើទុកជាមានរូបល្អ ក៏មិនឈ្មោះថាមានរូបដែរ ។

ហិតោបទេស

(តមក)

អធិរេជ្ញិត គុ. ដែលឲ្យក្រៃលែង ដែលឥទ្ធិពល ។

អធិគស្ត គុ. ដែលគេសរសើរ ។

អធិគិរោធរម ក្រ. វិ. នៅលើក ។

អធិគី ក្រ. សម្រាក ដេក នៅ ជាក់ ។

អធិគ្រយណី ស្ត្រី. ខ្នះ ។

អធិគ្រិ ក្រ. ជាក់ក្រៃលែង ផ្អែក ។ – គ្រិត គុ. ដែលជាក់ ដែលនៅលើ ដែលចូលទៅ ដែលសង្កត់លើ ។

អធិគ្រឺ គុ. ដែលមានសិរី ដែលមានតម្លៃ ដែលមានអធិបតេយ្យ ។

អធិម្ហ្វ (ស្ហ) ក្រ. នៅក្រៃលែង ចុំលើ នៅគ្រប់គ្រង ត្រួតត្រា ។ – ម្ហិត គុ. ដែលបិទនៅ ដែលត្រួតត្រា ដែលនាំ ។

អធិម្ហ្វត្តួ ភ. ន. តាយ មេ ។

អធិម្ហ្វាន ឧទុំ ឋានក្រៃលែង ទីស្នាក់ការ កន្លែង ។ អំណាច ទីតាំង មូលដ្ឋាន ។ – ន្តិ គុ. ដែលមានទីឋានក្រៃលែង ។

អធិម្ហ្វេយ្យ គុ. ដែលនៅក្រៃលែង ដែលះភ័ ។

អធិសេនាបតិ ចុំ. អធិសេនាបតី ទត្តមសេនិយនាយក ។

អធិស្ឋានម៑ ក្រ. វិ. ដឹងដោះ ។

អធិស្សរ គុ. ដែលលឿនក្រៃលែង ។

អធិហស្តិ ក្រ. វិ. លើដំរី ។

អធិហ្វ្រែ ក្រ តាំងទៅក្រៃលែង ធ្វើឲ្យមាន ធ្វើឡើង ។

អធី (អធិ+ឥ) ក្រ. ទៅក្រៃលែង ស្គាល់ យល់ រៀន ។ អធីត គុ. ដែលរៀនហើយ ។

អធីការ ប៉ុ. អធិការ ការត្រួតត្រា ។

អធីក្ស (អធិ+ឦក្ស) ក្រ. មើលក្រៃលែង សង្ស័យ ។

អធីគ័ន៑ គុ ដែលរាប់រកថ្លា ការចេះដឹង(ខាងវេទ) ។

អធីន គុ. ដែលអាស្រ័យ ដែលនៅក្រោម ។

អធីរ គុ. ដែលមិនក្លាហាន ដែលខ្លាច ដែលខ្សត់ខ្សោយ ។

អធីរតា ស្រ. ភាវនៃបុគ្គលមិនក្លាហាន កម្លាច កំសោយ ។

អធីរាក្ស គុ. ដែលមានភ្នែកមិនឆាប់ ដែលមានភ្នែកក្រឡេចក្រឡាច់ ។

អធីវាស ប៉ុ. លំនៅ ទីស្នាក់ការ ។

អធីឝ ប៉ុ. ជំនាន់ក្រៃលែង ម្ចាស់ ។ – តា ស្រ. ភាវនៃជំនាន់ក្រៃលែង ។

អធិគីត្ត ក. ន. ព្រះរាជា ចៅហ្វាយ ។

រឿងអាប៊ូលហ្គាំអ្ហរិស៍

លោក ង៉ាយ - ល្មុត តំណាងភស្ត្រា ប្រែរៀបរៀង

នៅបុពណាកាល កន្លងំលែងនៅហើយជាយូរអង្វែង មានយុវជនមួយរូបនាមថា អាប៊ូលហ្គាំអ្ហរិស៍ ជាកូនអ្នកឈ្មួញមួយធំខាងដើងសំពៅបិតនៅតួដ៏ក្រុង ឆាសព៉ ។ កន្លងំយែជាកុមារ បិតាតែងនាំក្មេងនេះធ្វើដំណើរ ជួញព្រៃ តាមសមុទ្រឥណ្ឌៀ ។ លុះដល់អាយុ ១២ ឆ្នាំ អាប៊ូលហ្គាំអ្ហរិស៍ ចាន់ស្គាល់គោះតាំងឡាយចំនួនប្រហែលជាងពាក់កណ្តាលកន្លងំសមុទ្រនេះ ។ កិច្ចការដំនួញចាន់ផ្តល់នូវលទ្ធផលដ៏ប្រពៃ កំកន្លងប្រមាណជា ១០ ឆ្នាំ ប៉ុណ្ណោះ ពាណិជនេះ នៅជាអ្នកមានទ្រព្យសម្បត្តិលើសជាច់តេតាំងអស់ នៅទីក្រុងឆាសព៉ ។

មានមួយថ្ងៃ ឪពុកនិយាយទៅកាន់កូនថា : កូនសំឡាញ់អើយ ! ឪពុកមានកិច្ចការខាក់ខ្នងជាច្រើន ត្រូវតែដម្រះបញ្ជីប្រាក់កាស តម្លៃខ្នងញ ឥព៉ាន់យើង . . . ។ល។ ឲ្យជ្រះស្រឡះ ជាមួយនឹងមហាសេដ្ឋីនាម «ហាប៊ីប» ដែលឪពុកខាក់ខ្នងគេស៊ីជាមួយនឹងលោក នៅទីក្រុងសេវេនឌ៊ប ។ ឪពុកគិតប្រគល់រឿងនេះ តាមតែកូនគិតគួរផ្តៀងផ្តាត់សម្រេចយ៉ាងម្តេចឲ្យខាងតែចាន់បញ្ជីនេះជ្រះស្រឡះគ្នាទៅចុះ ។

អាប៊ូលហ្គាំអ្ហរិស៍ ក៏ខ្លួលចាត់ការ តាមចំរោងឪពុក ថ្វីបើមានសេចក្តីខ្នុកខ្នួយ ដោយត្រូវធ្វើដំណើរឃ្លាតពីស្រុកទេស ជាយូរថ្ងៃ

តែយុវជននេះ ចង់ឃើញទីក្រុង សេរេនឌីប ខោះណាស់ដែរ ព្រោះ
ពីកាលមុន ចានធ្លាប់ស្គាល់ទីក្រុងនេះដែរ តែខ្លួនទៅក្មេងពេក ឥឡូវ
ស្រពិចស្រពិល ចង់ភ្លេចទៅវិញអស់ទៅហើយ ។

ក្រោយដែលចានខ្ចួលលិខិតប្រគល់អំណាច នឹងសេចក្តីផ្តាំផ្ញើ
សព្វគ្រប់ព្រមទាំងបញ្ជីផ្សេង ។ . . ។ល។ អំពីឥវ៉ាក អាប៊ូលហ្វាំ-
អ្ហរីស ចេញដំណើរទាំងទឹកភ្នែក ដល់កំពង់ ចាសវ៉ា ចុះកន្លងសំពៅ
មួយ មានផ្ទុកទំនិញនាំទៅទីក្រុង សុវ៉ាត ហើយត្រូវបន្តដំណើរពីខោះ
ទៅកោះ សេរេនឌីប ។

សំពៅត្រូវធ្វើដំណើរឆ្លងកាត់ឈូងសមុទ្រតាមចាសវ៉ា ដែល
មានបណ្តោយប្រហែល ៣០០លៀ (ប្រមាណ ១.៦០០ គីឡូម៉ែត្រ)
ទទឹង ៥ លៀ (២០០ គីឡូម៉ែត្រ) ។ ឈូងសមុទ្រនេះ ទៅផុតខាង
កើតគឺប្រទេស អាវ៉ាប ឯណោះ ដែលជាមហាប្រទេសមួយធំសម្បើយ
រុងរឿងណាស់ ហើយឋិតនៅ សន្ធឹងចំពាក់កណ្តាលប្រទេសបែរ្ស
ប្រមូលបញ្ចូលរួមគ្នាវែងអន្លាយសំដៅត្រង់ទៅតាមហៅថា ឧមុស ។
សំពៅចានឈប់សម្រាកបន្តិចទៅទីក្រុង ឧមុសនេះ រួចធ្វើដំណើរ
កាត់ត្រង់ចូលទៅកន្លងសមុទ្រ បែរ្ស ហើយបត់ទៅខាងកើត ឆ្ពោះទៅ
ទីក្រុង សុវ៉ាត ។ យើងចានដល់ទីក្រុង សុវ៉ាត ដោយសុវត្ថិភាព
ចានផ្ទេរទំនិញ រួចធ្វើដំណើរទៅទៀត តាមផ្លូវត្រង់ទៅកោះសេរេនឌីប

តែម្តង ដល់ហើយ ក៏រើខំទិញដែលមានតាំងប៉ុន្មានចេញពីសំពៅ ។

អា – កិច្ចការជាដំបូងបំផុតរបស់ខ្ញុំគឺ ខ្ញុំត្រូវតែទៅសួរគេ តើលោកមហាសេដ្ឋី ហាប៊ីប លោកឋិតនៅត្រង់ណា ? ។ មានគេប្រាប់ខ្ញុំភ្លាម ខ្លួរអេសយដ្ឋានរបស់លោកនេះ ព្រោះនរណាក៏គេស្គាល់លោកដែរ គឺជាអ្នកមានទ្រព្យសម្បត្តិជាងគេតាំងអស់កន្លែងនេះ ហើយលោកជាមនុស្សស្មោគគ្រហស្ថបូតខ្លៀងពាត់ណាស់ ។ ម៉ាគាលខ្ញុំបានទៅជួបលោកភ្លាម លោកទទួលខ្ញុំ ដោយសេចក្តីអនុគ្រោះពន់ពានជាទីបំផុត ក្រោយពីលោកបានទុបរឹតថើបខ្ញុំជាច្រើនដង ។

ហា – កុំអ្នកមានចិត្តខឹសខាល់ញាញើតអ្វីឲ្យសោះ អ្នកចង់យ៉ាងម្តេច ស្រេចហើយតែអ្នក ។

អា – តមក ដោយលោក ហាប៊ីប ជ្រាបកិច្ចការនោះច្បាស់លាស់ ហើយដោយការគិតគូរបញ្ជាពាំងនោះ គិតនាំគ្នាកតែសេចក្តីសុខ-រឹត មិនយូរថ្លៃប៉ុន្មាន បញ្ជាពាំងនោះ ឃានត្រូវស៊ីសងទូខាត់គ្នាស្រេច ។ កន្លងតែខំនេះ ខ្ញុំបានចេញទៅដើរកំសាន្ត មើលទីក្រុងបានឃើញរបស់ថ្លៃៗ ជាច្រើនអស្ចារ្យ ។ ខ្ញុំបានសង្កេតមើលរបៀបរបបច្បាប់សម្រាប់ប្រជាពលរដ្ឋ ទំនៀមទម្លាប់ កិច្ចការរបស់តុលាវដ្ឋ កិច្ចរបស់រដ្ឋាភិបាល . . . . ជល់ប្រមាណជា ៩ ឬ ១០ សប្តាហ៍ ខ្ញុំគិតវិលទៅស្រុកខ្ញុំវិញ ទទួលទៅនោះ កញ្ញ មានសំពៅមួយនៃទីក្រុងសុភ័ត បិត

នៅទីក្រុង សេវេនឱប នោះដែរ បម្រុងនឹងលើកយុថ្កាចេញដំណើរត្រឡប់ទៅវិញ ។

ថ្ងៃមួយ មុនចេញដំណើរទៅស្រុកខ្ញុំវិញ នៅពេលថ្ងៃត្រង់ ខ្ញុំចូនចេញពីទីលំនៅ ទៅកាន់តេហដ្ឋានលោកមហាសេដ្ឋី ហាច័ប ។ កន្លងពេលធ្វើដំណើរ ខ្ញុំប្រទះឃើញលោកស្រីមួយ ប្រកបដោយសំលៀកបំពាក់គ្រឿងអលង្ការស្រោចស្រង់ខ្លួនល្អជាពន់ពេក ហើយមានទាសីម្នាក់កាន់អីវ៉ាន់ផ្សែង ។ ដើរតាមពីក្រោយដោយសេចក្តីគោរពធន ។ ថ្វីបើលោកស្រីយ៉ាំរ៉ាំព្រួចបំចាំងមុខ ដោយសំតត់ក្រាស់បន្តិចក៏ពិតមែន ខ្ញុំស្រាប់តែកាន់តាំងស្មារតីក្រេបខ្លួនឈរស្រឡាំងកាំង ក្អែតចាំងពីរសម្ងឹងឥតដាក់ភ្នែកទៅលោកស្រី លោកស្រីមានរូបឆោមរឆាមពីណាតែតាយស្រស់ម៉ត់ត្រង ដំណើរល្អតល្អន់ ទុកចេញស្មើតដូចគេស្ងួយ ល្អហើយសមធន ថ្លៃកចំលែកពីគេឯង ថើស្តីដោយធៀបប្រៀបទៅនឹងបណ្តាស្រីក្នុងទីនោះ លោកស្រីនេះ ដូចជាកដហង្សក្នុងហ្វូងក្អែក ។ ខ្ញុំលាន់មាត់ចាំងពុំដឹងខ្លួនថា ៖ ឃើ ! ចុះល្អអីល្អម្ទេះ ! . . . ប្រហែលជាស្រីស្អំសំណាប់ទី១ របស់ព្រះករុណាមហាកជាហើយ មើលទៅ ! . . . លោកស្រីក្រឡេកសម្ងឹងហើយ សម្ងឹងទៀតមកខ្ញុំ ក៏ដើរហួសទៅដោយឥតមានបន្លាញឫកពា កិរិយាអ្វី ឲ្យខ្ញុំសំគាល់បានថា តើលោកស្រីសប្បាយចិត្តឬខឹងចំពោះពាក្យដែលខ្ញុំពោលភ្លាត់មាត់នោះទេឬយ ។ ខ្ញុំក៏នៅឈរធ្មឹងអស់

មួយសន្ទុះ ស្រាប់តែមានបុរសម្នាក់មកដល់ ណាឡុំពុំដឹង មកពីបស្ចាឡុំអង្រួន ឡុំភ្ញាក់ប៉ុនតេចាល តែទំធ្វើជាត្រងើយសួរទៅថា ៖ អ្នកមានការអ្វី? មនុស្សប្រុសនោះ ឆ្លើយដោយគោរពថា ៖ ឡុំចាខចានខលួលបង្គាប់អំពីលោកស្រីជាម្ចាស់ឡុំ លោកឲ្យឡុំប្រចាខមកអញ្ជើញ សូមលោកម្ចាស់ប្រុសអញ្ជើញតាមឡុំប្រចាខមក ។

បើពិតជាបង្គាប់នេះ ចេញមកអំពីលោកស្រីជាម្ចាស់អ្នកមែន ឡុំខ ខ្លួលភ្លាមដោយរ័ករាយ តាមតែកទៅដាយ៉ាងណាកំទៅ ។ ចុះ ! (មាត់ឆ្លើយដូច្នេះ តែក្នុងឡុំបុកហឹប ។ ។ ។ ។ ខាសាឆ្លើយមកឡុំវិញថាំងដៃប្រណម្យសំពះញ៉ែ ។ ថា : ពិតមែនហើយ ! តើជាបង្គាប់របស់លោកស្រីជាម្ចាស់ឡុំ តែលោកឥតបានប្រាប់ឡុំថា លោកចង់យ៉ាងណាទេ សូមលោកម្ចាស់ប្រុសអាណិតអញ្ជើញ ខាន ! បើលោកម្ចាស់អញ្ជើញតាមឡុំប្រាកដជាលោកម្ចាស់ឥតស្តាយក្រោយទេ មើលទៅ ! ។

ចំពោះរឿងនេះ គួរតែឡុំគិតយើញដល់ការចេញដំណើរ នៅថ្ងៃស្អែកនេះ មិនដូច្នោះ ឡុំទៅជាក្មេចក្តាំងដើរតាមខាសានោះទៅវិញ ដើរទៅបត់ប៉ែន តាមផ្លូវគ្មេចប្រកល្អក កំទៅដល់ប្រាសាខមួយយ៉ាងធំសំបើមជាទីមានោរម្យសុខុមតម្លឹកោពយ៉ាងអស្ចារ្យ នាឲ្យគាន់ស្មារតីមមឹងមមាំង តែឡុំប្រឹងខប់ខ្ជួនមិនឲ្យខាសានោះដឹង . . . យើងទាំងពីរនាក់ នាំគ្នាដើរចូលទៅកន្លែងប្រាសាខនោះ ទៅដល់សាលមួយយ៉ាងធំ មហាធំ ឡុំត្រូវ

រង់ចាំនៅទីនោះ ។ ខ្ញុំមានសេចក្តីស្ញើចសរសើរ ដោយពិនិត្យមើលឃើញ សាលនេះគុបតែងលំអល្អពន់ពេក សុទ្ធសឹងតែរបស់មានតម្លៃច្រើន មិនដឹងបើនឹកចប់ តែខ្ញុំចេះតែទឹកមុខមើលដល់លោកស្រីជាម្ចាស់ក្រុងសាខនេះ ។

ជាដំបូង ខ្ញុំឃើញស្រី១ ជាច្រើន មានចាស់ មានក្មេង រូបកាន់តែតាយល្អ ។ ឥតខ្ចោះចូលមកកាន់សាលនោះ តែខ្ញុំដើរណេះណោះ ធ្វើព្រងើយដូចជាឥតយកចិត្តទុកដាក់អ្វីនឹងស្រីពាំងនោះ បន្ទាប់បន្តិចតមក ពួកស្រីឱ្យសញ្ញាគ្នា ហើយនាំគ្នាលុតជង្គង់ក្រាបក្បាលចុះ នាកាលនោះ ខ្ញុំឃើញលោកស្រីជាម្ចាស់ក្រុងសាខចេញមក គ្រាន់តែក្រឡេកមុខឃើញក៏ខ្ញុំស្គាល់ភ្លាម ឃាំងចង្ការស់ ដោយកំពស់ទឹងទឹកមុខសណ្ឋានទ្រង់ទ្រាយម្តងនេះ លោកស្រីគ្មានចាំងមុខទេ ខ្ញុំឃើញកាន់តែល្អលើសមុនទៅទៀត ប្រកបដោយសំអាងសុទ្ធសឹងជាពេជ្រពាំងគ្រាប់ ។ ចិញ្ចៀន កងក្រវិលរំលេចភ្លឺឆ្អែតជាខ្លួរមកតត . . . ក្អឺចាំស្មើព្រោងព្រាត សំលៀកបំពាក់សោតកំភ្លឺច្រាល ត្រូវនឹងលោកស្រីស្អាតល្អសោភាច្រឡឹង. សមរម្យឥតខាស់ថែមទៀត ខ្ញុំមើលឥតដាក់ភ្នែក គាន់តាំងស្មារតី លោកស្រីដ៏មានសម្ផស្សអំណោយទាន នាងឃើញខ្ញុំសំឡឹងឥតព្រិចភ្នែកដូច្នេះ ក៏នាងញញឹម ។ អញ្ជើញមើលអង្គុយលើសុវណ្ណកោះមួយ មានសណ្ឋានដូចមកុដរាជ្យតូច ឯពួកស្រីស្អិតម្រៀបគ្នាជាពីរជួរ ខាងស្តាំ ខាងឆ្វេង

នៃបអង្គុលោកស្រី មើលទៅដូចព្រះចន្ទពេញវង់កណ្តាលតារាពាន . .
ស្រេចហើយ លោកស្រីល្អសោភិន មានប្រសាសន៍យ៉ាងខន់ក្តួនថា: អ្នក
ប្រុសដួងចិត្តប្អូន សូមអ្នកមកអាយដីតខ្ញុំ. . . ខ្ញុំ (អ) កំដើរសន្ធឹម ។
.សសៀរទៅដីត បន្ទូនកាយគោរព . . ។ ក្រៅពីរូបខ្ញុំ (ក) ប្រាកដជា
មានសេចក្តីចាំឆ្ងាក់អាក់អន់ចិត្តហើយ អ្នកប្រុស ចំពោះអំពើឆ្គាំឆ្គងរបស់
អ្នកដែលបានប្រព្រឹត្ត ក្នុងទីប្រជុំជនសាធារណៈដូច្នោះតែខ្ញុំស្មានមើលទៅ
ប្រហែលរូបអ្នកជាបវេនា បានជាអ្នកត្រូវបានខូលសេចក្តីអត់ទន្ទេលសំលា
ត្រាប្រណីអំពីសំណាក់ខ្ញុំដូច្នេះ ! ខ្ញុំនិយាយដោយត្រង់ទៅប្អូនថា ទោះបី
ភ្លាយលើមេឃផង ក៏តប្បីតែមានគំនឹតដូចខ្ញុំដែរ តើនិងតបធំផ្តល់សេចក្តី
សុខចំរើនឲ្យអ្នកត្រប់ពេលវេលា . . . ។ បើអ្នកប្រុសតាំងខ្លួនអ្នកឲ្យ
សមរម្យនឹងខ្ញុំ ដោយខៃឲ្យចំណង់មួយដងស្មោះស្ម័ត្រ ខ្ញុំនឹងអនុញ្ញាតអ្នក
ឲ្យអ្នកបើបស្រូបយកកូនបាទដៃខ្ញុំបាន សេចក្តីអនុគ្រោះនេះ ខ្ញុំពុំដែល
មានដល់បុគ្គលរូបណាមួយសោះឡើយ រហូតមកទល់ពេលនេះ . . . ។
ដល់ឮពាក្យខន់ក្តួនបែបនេះ ខ្ញុំ (អ) មានបីតិព្រួចត្រេកអរដូចអណ្តែត
ខ្លួនតាំងលុតជង្គង់តាំងមាត់ថា ខ្ញុ ! សម្តេចពជិនីអើយ ! ខូលព្រះបង្គំបាន
ឮព្រះសវនីយមែនឬទេ? ខូលព្រះបង្គំឮមែនឬទេ ខ្ញុវព្រះបន្ទូលថាស្តេច
ទ្រង់ព្រះមេត្តាលើកបវេនកំសត់ម្នាក់ដល់ឋានៈដូច្នេះ? គ្រាន់តែបវេនានោះ
លាន់មាត់ដោយពុំដឹងខ្លួនថា តប្បីខ្ញុកព្រះអង្គកន់ទីសក្ការៈបូជាប៉ុណ្ណោះ !

ក - សាធុ ! សេចក្តីលស់សាត្រាប្រណីកាន់តែធំឡើង ។ ប៉ុណ្ណា សេចក្តីយល់ឃើញថា ខ្លួនអ្នកប្រុសពុំសមរម្យនឹងខ្ញុំ កាន់តែធំឡើង ។ ប៉ុណ្ណោះដែរ នេះបើស្តីដោយធៀបប្រៀបតីយ៉ាងហ្នឹង ! ។ ចូរអ្នកប្រុសប្រាប់ខ្ញុំ តើអ្នកមកពីស្រុកណា ? ជាតិកំណើតរបស់អ្នក ? ហេតុម្តេចបានជាអ្នកមកទីក្រុង សេរេនឌីប ?

ខ្ញុំ(អ) បានសារសតួរឿបកប់អស់អាថសេចក្តី អំពីរឿងខ្ញុំតាំងពីខាងដើមដល់ខាងចុង ។ នាកាលព្រះពន្ធនីខ្លះបានជ្រាបថា ស្អែកនេះខ្ញុំត្រូវបុះសំពៅធ្វើដំណើរត្រឡប់ទៅបាសរ៉ាវិញ ព្រះអង្គខ្លះមានសេចក្តីរំភើបព្រះរាជហឫទ័យខ្លាំង . . . ។

(ក) - ភ្លា ! ម្តេចដូច្នោះទៅវិញ ! អ្នកប្រុសចង់ចាកចោលខ្ញុំភ្លាមទៅហើយ ! បណ្តាកោះកន្ទឹងសមុទ្រឥណ្ឌៀ កោះមួយដែលល្អជាងគេនេះ តើគ្មានប្រយោជាយ៉ាងអ្នក ឲ្យនៅនេះយូរបន្តិចទៅទៀតបានទេឬ ? ។

(អ) - ហា ! ខ្ញុំដកដង្ហើមធំយូរ- ហើយថា ធ្លើមេចទៅលោកម្ចាស់ខ្ញុំអើយ ? ។

(ក) - ដូច្នេះ អ្នកប្រុសនៅតែប្រកាន់ថា ត្រូវតែចេញដំណើរមានមិនបាន យ៉ាងនេះឬអី ? ។

(អ) - មាន ! បន្ទាប់ពីបានពើបប្រទះ សេចក្តីសង្ឃឹមប្រកប

ដោយមហាជោគជ័យមង្គលសួស្តី ដែលព្រះអង្គទ្រង់ចាន់ចាប់ឆ្លើយឲ្យខ្ញុំលួចព្រះបង្គំយើញលឺម ។ ដូច្នេះ សរមួចពាជាន់ជាម្ចាស់អើយ ! ខ្ញុំលួចព្រះបង្គំឥតមានចិត្តណាមួយសោះឡើយ ខ្ញុំសូមព្រះពាជាប្ញទ័យ ។

(ក) - បើអ្នកប្រុសមានទឹកចិត្តដូច្នេះ ប្រាកដជាអ្នកនឹងនាំឲ្យខ្ញុំចានសប្បាយរីករាយ ខ្ញុំក៏នឹងឥតស្តាយក្រោយ ដោយចានត្រើសរើសយកអ្នកប្រុសក្នុងគ្រាតេលានេះ ។

(ខ) - សរមួចព្រះពាជានិទ្រង់ចាប់ដៃខាញ្ញុំ ឲ្យអង្គុយក្បែរព្រះអង្គ លើព្រះសុវណ្ណគោដ្ឋ: . . . ។ ស្រេចហើយទ្រង់មានព្រះសារាន្ទ័យ . . . ។

(ក) -. ខ្ញុំជាបុត្រីតែមួយរបស់ឯកឧត្តមនាយកគណៈវេជ្ជមន្ត្រីនៃព្រះពាណាកោះ សេរេនីប ។ ឪពុកខ្ញុំ គាត់ឧលួលអនិច្ចកម្មទៅហើយ ឥឡូវនេះ ខ្ញុំចង់សម្រេចយ៉ាងមេច ស្រេចហើយតែចិត្តខ្ញុំ ។ មហាសេដ្ឋីកនឹងដូនេះ តែងតែនាំគ្នារហបរកខ្ញុំ តែខ្ញុំគេចខ្លួនរហូតមកដល់តេលានេះ ។ រូបនោមទ្រង់ទ្រាយទឹកមុខរបស់អ្នកប្រុសជាទីពេញចិត្តរបស់ខ្ញុំ ខ្ញុំសុខចិត្តស្រឡាញ់តែប្រុសនេះមួយប៉ុណ្ណោះ ដើម្បីត្រចាញ់វៃញជីវិតយើងតំាងពីរបញ្ចូលគ្នាជាតួនមួយ រួមរស់សប្បាយរីករាយចាយវាយ ខ្ញុំសូមព្រះពាជាទ្រង់ប្រោនឥតគណនា ដែលបិតាខ្ញុំ នាកាលលោកដើរការក្នុងតំណែងតាំងឡាយ លោកចានសន្សំប្រមូល ក្នុងកំឡុង

៤០ឆ្នាំ ។

(អា)- ខ្ញុំសូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅ . . . ពាក្យ
ផ្ញើមស្លៀមរបស់លោកស្រីអំពីភោគទ្រព្យ ជារឿងបន្ទាប់បន្សំទេ ឯរឿងដែលពាក់ចិត្តខ្ញុំជាខ្លាំងបំផុតនោះ មិនគឺអ្វីក្រៅពីរូបកល្យាណមានលំអគ្រប់លក្ខណៈផ្ទាំងរលើងរលង់ស្រឡះស្រស់បំព្រង របស់លោកស្រីប៉ុណ្ណោះ ហើយដែលជាទីចាប់អារម្មណ៍របស់ខ្ញុំគេកូចមិនកើតក្នុងជីវិតនេះ ។

បន្ទាប់គេ យើងពាំងពីរបាននិយាយសំណេះសំណាលអំពីកិច្ចការផ្សេងៗ ។ ខ្ញុំបានសង្កេតឃើញថា ធម្មជាតិបានបង្កើតនាងនេះមកសមប្រកបព្រមគ្រប់លក្ខណៈ ល្អពាំងចិត្ត ល្អពាំងរូបកាយ ។ សន្ទនាត្រូវឈប់ដោយមានទាសា ១២ នាក់ ចូលមករៀបចំប្រជាប់ប្រជាគ្រប់សព្វ សម្រាប់ពេលបាយមួយយ៉ាងធំ ។ ស្រេចហើយ នាងកនហ្ការឌឹកដៃខ្ញុំទៅអង្គុយទៅតុ ដោយជាក់ខ្ញុំទៅខាងស្តាំនាង ពាំងពីរនាក់ក៏ខួលភោជនាហារដ៏ឯនាងកនហ្ការ នាងធ្វើជាអ្នកបំរើខ្លួនឯង ចាប់ម្ហូបណាឆ្ងាញ់ ជាងគេជូនខ្ញុំ ដោយសេចក្តីស្និទ្ធស្នាលគួរសមជាទីបំផុត ព្រមពាំងស្រាទំពាំងបាយជូរនានាយ៉ាងប្រណីត តម្រូវទៅនឹងភោជនាហារនោះ ។ ។ សុពុទំពាំងបាយជូរបង្ហាញរស្មីពីកន្លែងរបស់នាងមាស មានកូនទឹងនុជារស់នាំឲ្យខ្ញុំត្រឹកមត្រឹស្បែក ក្រវល់ក្រវាយក្នុងចិត្ត ម្តង ។ រឿយ ។ រំដរកែកដួងប្រស្រីទៀតថា ម្ហូលនាងកនហ្ការ ធឿបនាថាក់ថ្នមបបោសអង្អែលខ្ញុំ សមនឹងកក្រនាង

ញញឹមម្ដង ។ ក្រអឺតក្រអៅ ម្រាមដៃល្អតល្អន់លើកតែវាដូនមកខ្ញុំក្ដង
សេចក្ដីគួរសមជាទីបំផុត . . . នៅពេលដូនអ្ញមកខ្ញុំ នាងមានវាចា
ថា ៖ សូមបងម្ចាស់ចិត្ត កុំល្បែងមើល ច! . . ច! . . . នាងសុទ្ធ
តែដឹងសុកនោះ ។ មុនល្បែងមើលជាដកប ។ ដូច្នេះសុកនោះកាន់តែមាន
ទុជាសេះទៀងទៀតដល់ខ្ញុំ ។ ខ្ញុំខ្លួលតែវាហើយ ក្រែបយ៉ាងយូរខ្លាំង
សប់ស្មេហានោះ ។ នៅផុតពេលភាគទីយកោដទីយហារ សៅកាន់ដ
ឡាយរបស់នាងជួបជុំគ្នាកន្លះសាល ហើយចែកមុខការគ្នា ៖ ខ្លះកាន់គ្រឿង
ដូរឬជន្ត្រីដេញដំផ្ទុកូត ហើយចាប់ច្រៀង ខ្លះកាន់ផ្សំគ្នាដោយសិល្បៈទំនង
សេចក្ដីធ្វើវិទ្វាតយ៉ាងប្រសប់ យ៉ាងអស្ចារ្យ ហើយជារឿយ ។ . . ត្រង់
ចង្អាក់ដូរឬតន្ត្រីផ្អែមល្ហែម ក្អែកនាងកនហ្វូងនឹងក្អែកខ្ញុំផ្ដៅតផ្ដិតផ្ដងជាប់
គ្នា លួងលោមថ្នមថ្នមទៅវិញទៅមក ត្រជាក់កន្លះបេះដូងឆ្ងាយដង្ហើមធំ
ម្ដង ។ រឿងខ្លួន . . . ។

(នៅមានត)

រឿងសាមកុក

ទុកញ៉ាវិជុលកជសេនា ន្ធ-តាន វែប្រៀបរឿង

(តមក)

រឿងសាមកុកទុកដាំយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទំនងបេះខបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។
——— យូរ-អ៊ិន ———

មិនត្រូវគិតលះចោលសោះ ឯសង្គ្រាមនោះ គឺបួងឯងដែលនាំសម្ងាប់ចិត្តអ្នក ។ ក៏ត្រូវតាំងចិត្តគិតសងសឹកវិញឲ្យបាន ទើបនឹងមានកេរ្តិ៍ឈ្មោះជាមនុស្សក្រតញ្ញូនឹងឋិតា ឥឡូវខ្លួនអ្នកជាក់មកនៅក្នុងទីនេះអស់តម្រិះនឹងគិតយកខ្លួនឲ្យរួចហើយ បើនឹងរកទៅរកឡៅជឿនចៅហ្វាយស្រុកសែឈួនក៏មិនបាន បើនឹងត្រឡប់ទៅពប់អានឡៃឡូវិញ អៀវសុងក៏បេះតែញុះញង់ឲ្យខាស់អញ្ជាស្រេច សព្វថ្ងៃនេះឡៃឡូក៏ប្រើខាហានមកចាំស្កាត់ផ្លូវនៅត្រប់តំបន់អស់ហើយ អ្នកនឹងចូលទៅធ្វើយ៉ោះសាឲ្យឡៃឡូដឿស្កាប់ឯណាបាន បើគ្មានផ្លូវទៅដូច្នេះ បើអ្នកនឹងរត់រកយំលាយខ្លួនឡៅតិឲ្យបែកក៏មិនងាយ មួយទៀត ក៏មិនបានតាប់ប្រសើរនឹងឡៃឡូ ជានាយចៅហ្វាយថ្នាក់នោះទេ គួរតែនឹងគិតគ្នាមើល

កងខ្ញុំឲ្យដឹងថា វេលានេះខ្ញុំអ្នកមកនៅកងកណ្តាលកងក្តៅដូច្នេះ ត្រូវ
រិះគិតដកខ្ជួនឲ្យរួចទើបពេញជាជាតិតាហានមានប្រាជ្ញា ខ្ញុំយល់ឃើញថា
ដែលអ្នកនឹងដំអីធីងនៅដូច្នេះ ក័យអន្តរាយគឺតងំនឹងមានដល់ខ្ជួនអ្នកជាប្រាក
កដ កាលគ្រាអ្នកទៅបង្កងនៅតំបន់អ៊ុយរោ ចាញ់ប្រៀបបូនួ ដែលទៅ
នោះ កំបានសេចក្តីលំបាកគន់ប្រមាណណាស់ គ្រានេះ នោះបើថា
អ្នកនឹងមិនស្លាប់ គឺគង់បានកតប្រសព្វលើសេចក្តីអាប់យស់លើសជាងពី
គ្រាមុននោះទៅទៀត នឹងរំឭកមើលមុខគេក៏មិនពេញភ្នែក ហេតុ
នេះ បានជាខ្ញុំតិតសង្វែត មកជួយរំលឹកស្មារតីដោយមេត្រីភាពអាន ។

ម៉ាឈៀវឮដូច្នោះក៏សោយសេចក្តីខឹង បោះត្រចៀកចេញពីដៃ ហើយ
ក្រោកឡើងតំនាប់លីអ៊ុនថា ដែលអ្នកមករំលឹកខ្ញុំដូច្នេះគួរសមណាស់តែ
ខ្ជួននៅកងចិចង្អៀតចង្អល់គិតមិនយល់ច្បាស់ផ្លូវ ដែលនឹងដើរទៅមុខ
ក្រោយ បើអ្នកមានចិត្តអាណិតខ្ញុំ មេត្តាជួយណែនាំចំភ្លឺចុះ ខ្ញុំនឹងខ្ជួល
ធ្វើតាម ។ លីអ៊ុនតបថា ខ្ញុំនឹងជួយណែនាំរំលឹកឲ្យអ្នកយល់ក៏បានខ្លះដែរ
តែថាពួកតាហានរបស់អ្នក កាន់អាវុធឈរប្រចាំនឹងច្រើនអន្តរាយខ្លាំង ។ នឹងថា
ការអ្វីបាន ។ ម៉ាឈៀក៏បណ្តេញពួកតាហានចាំងនោះ ឲ្យចេញទៅ
ខាងក្រៅអស់ ។ លីអ៊ុនតបថា ទៀតនោះ ចំពោះជាពួជព្រះពជវង្ស
ព្រះចៅហៀនតេប្រាកដ ប្រកបចាំងចិត្តអធ្យាស្រ័យធ្ងន់ណាយ តែងតែ
ខំទុកបម្រុងដែនដីឲ្យបានសេចក្តីសុខតទៅ ដូចជាម៉ាថេងចិតាអ្នកកាល

រស់នៅ ។ កូនស្រីកហិតោនោះ កំពុងពិគ្រោះត្រូវតែនឹងគ្នានឹងខ្លៅថាយ
នឹងជួយគ្នាកំចាត់ចូរឆ្ងេញ ព្រោះឃើញថាជាតួសត្រូវរាជសម្បត្តិតែ
ណាស តារនោះក៏តែតពុំទាន់បានសម្រេច ឥឡូវត្រូវអ្នកមកចំពាក់ខ្នងនៅ
ដូច្នេះ បើប្រសិនជាអ្នកនឹងរិះតែតៅនៅនឹងខ្លៅពីរញ ដើម្បីនឹងជួយ
បំពេញតែនតែតធ្វើការបំបាត់ចូរឆ្ងេញ អ្នកកំពុងរលាយសេចក្តីខ្លួនតែ
ម្នេញនោះអស់តៅ ទាំងឈ្មោះសំឡេងអ្នកកំនៅឮល្បីជាប្រាកដតៅមុខ
រឿត ។

ម៉ាំឈៀវបានឮដូច្នោះ កំពុងអំណរណាស់ ឲ្យហៅខ្លួនអៀវចេក
វែលជាតាហានឿវឡូចូលមក ហើយកំចាប់សម្ងាប់មួយរំពេច ហើយកាត់
យកក្បាលអៀវចេកនោះនាំតៅជាមួយនឹងលីអ៊ុន នឹងតាហានទាំងពួងតៅ
ឯទីតយហែជាំងគួន ។ ឯខ្លៅតាំងថា ម៉ាំឈៀវលុះកូនៗជាយលី
អ៊ុន បានចូលខ្លួនមកជាមួយនឹងលីអ៊ុនដូច្នោះ កំពុងសេចក្តីត្រេកអរ
ពន់ប្រមាណណាស់ ចេញតៅចាំទទួលម៉ាំឈៀវនាំចូលមក ។ ម៉ាំឈៀវ
តំនាច់ខ្លៅតាហើយថា វែលខ្ញុំបានបានមកនៅនឹងលោកជាអ្នកមានសតិ
បញ្ញាដូច្នេះ ខ្ញុំពុំមានអំណរណាស់ ចេមាដូចនៅកូនិតិនឹត មានតេ
នាំឲ្យមកជល់នឹវែលភ្លឺ នោះអ្វីជារបស់លោក ត្រូវការប្រើខ្ញុំពុះ ខ្ញុំចា
នឹងសុំទទួលយកការធ្វើឲ្យត្រាតែអស់ជម្រះប្រាកដ នឹងសតិកំភ្លាំងឆង
ដាវែតមិនតិតស្តាយឡើយ ។ ខណៈនោះ សុំនទៀនដឹងថា ម៉ាំឈៀវចូល

ទៅនៅនឹងខ្លៅតាំហើយ កំលាអៀរសុងត្រឡប់ទៅប្តីនឹងខ្លៅតាត្រប់ប្រការ ។

ខ្លៅតាបង្គាប់បង្គត់តាត់នឹងហាក់ជុន ឲ្យនៅរក្សាបន្ទាយ ហើយឲ្យរៀបចំតាហានលើកត្រឡប់ទៅនឹងកាយយកស្រុកសែឈួន លុះទៅដល់ស្រុកតំមកុក ជូឡុង ហានតុងជីង កំចេញមកទទួលខ្លៅតាចូលទៅក្នុងស្រុក ហើយដំកថា ឥឡូវខ្លៅដៀងប្រើខ្លៅយួន ទឹងម៉ាហ៊ានលើកតាហានមកជាច្រើន ខ្ញុំបាទនឹងសុំអាសាចេញទៅតាត់ក្បាលនាយតាហានទាំងពីរមកជូនលោក ។ ខ្លៅតាក៏ចៃកឲ្យទៅ ។ ជូឡុងដឹះសេះនាតាហានចេញពីស្រុកតំមកុក បានច្បាងនឹងនាយតាហានទាំងពីរ ។ ឯខ្លៅតាទៅក្នុងស្រុកឲ្យរៀបតុលៀងម៉ាឈៀវទៅមិនទាន់ឌឹងសម្រេច ទទួលឃើញជូឡុងយួរក្បាលខ្លៅយួនចូលមកជូនខ្លៅតា ។ ម៉ាឈៀវឃើញដូច្នោះ កំភ័យស្ទុតតិតថា ជូឡុងនាយតាហាននេះ មានថ្វីដៃហ៊ានសរហួនណាស់ ម៉ាឈៀវក៏តែតែកោតក្រែងខ្លៅតាពន់ប្រមាណាស់ ទើបដំកឲ្យខ្លៅតាថា ឯស្រុកសែឈួននោះ លោកកុំបាច់លើកកងទ័ពទៅឲ្យបានសេចក្តីលំបាកខ្លឹយត្រួយដល់តាហានឡើយ ខ្ញុំបាទនឹងសុំទទួលអាសាចូលទៅនិយាយនឹងខ្លៅដៀងឲ្យចេញមកចំណុះចុះចូលលោកដោយស្រួល ចើខ្លៅដៀងរឹងខ្ទឹង ខ្ញុំបាទនឹងម៉ាតាយជាប្អូនឌឹងលើកតាហានទៅកាយយកស្រុកសែឈួនឲ្យបាន ។ ខ្លៅតាបានឮដូច្នោះក៏មានអំណរណាស់ លុះលៀងអាហារស្រេចហើយ នាយតាហានទាំងពួងក៏លាទៅគាន់ពីសំ

ណាក់ ។

ខណៈនោះ មានឥឥហានដែលមកកងឥតឥង់ឥតឡៅយួន ម៉ាហ៊ីនេនោះ
បែកវាត់ត្រឡប់ទៅច្រាច់ឡៅដៀងត្រប់ប្រការ ឡៅដៀងដឹងដូច្នោះ កំភ័យ
ខ្លាំងណាស់ ទ្បែចំខ្លួរស្រុកដឹតឥាំងអស់ ហើយទ្បែឥហានរក្សាសើន
បន្ទាយដុំវិញម៉ាមួនណាស់ ។ ខណៈនោះ ម៉ាឈៀវតំលាឡៅពីលើក
កងឥតត្រង់ទៅស្រុកសែឈួន ។

ឥហានដែលនៅលើសើនបន្ទាយ ឃើញម៉ាឈៀវលើកមកដឹតកំ
វែង កំចូលទៅច្រាច់ឡៅដៀងថា ឥឡូវម៉ាឈៀវលើកកងឥតមកព័ទ្ធ
ដឹតគូកំវែងស្រុកហើយ ។ ឡៅដៀងកំរឡើងទៅមើលសើនបន្ទាយខ្លួន
ម៉ាឈៀវក្រឡេកទៅឃើញ កំស្រែកអញ្ជើញឡៅដៀងឡាតមុខ
ចេញមកទឹងសុំទំយោយការឥង ។

ឡៅដៀងឮហើយ កំអើតមុខចេញទៅ ហើយស្រែកថា អ្នកឯងចង់
ទំយោយការអ្វីកំឡៃស្តីមកចុះ ។ ម៉ាឈៀវថា ព័ដើមយើងលើកឥហាន
ខ្មៀវឡៅធ្វើសង្គ្រាមទឹងឡៅពី ច្រាច់ទឹងជួយការពារស្រុកលោក តែ
អៀវសុងភ្ញាក់ភ្ញាងខ្មៀវឡៃមានសេចក្តីសង្ស័យទឹងយើង ។ ទើបនាំឥ
ហានទៅទៅទឹងឡៅពី ឥឡូវត្រូវលោកវ៉ៃតឥជាប្រញាប់ ចេញមកចំណុះ
ចុះចូល លើកស្រុកប្រគល់ជូនឡៅពីដោយល្អចុះ ទើបទឹងផុតសេចក្តីអន្ត
រាយ មិនមានដល់ខ្លួនលោក ហើយបណ្តាលក្រុកងស្រុក កំទឹងឥាន

សេចក្តីសុខតទៅ ចើរលោកទៅតែរំងទំនឹង យើងនឹងអាសាខ្លៅពី ៗយ
យកស្រុកសែលឈួនឲ្យគាល់តែបាន ។

ខ្លៅដៀងឮដូច្នោះ ក៏ឲ្យស្តុតស្មារតីក័យគាល់តែដួលចុះសន្ធប់ទៅវិ
ញ ។ ឥប្រឹក្សាទំនឹងគាហានទាំងពួងគំនាំគ្នាគ្រាប់ឲ្យដឹងស្មារតីឡើង
វិញ ។ ខ្លៅដៀងប្រឹក្សាទំនឹងគាហានទាំងពួងថា ការទាំងនេះ យើងមិន
បានត្រៀមរៀបឲ្យហូតជាមុន ទើបបណ្តាលឲ្យចាញ់ប្រៀបគេ លុះទំនឹងប្រឹង
ក្តងវេលានេះ ចេះតែស៊ូច្បាងទៅ ការកំគាន់តែប្រគាល់ខ្លួនដល់ប៉ុណ្ណោះ
ទៅហើយ យើងអាណិតអាណាប្រជានុពស្ត្រ ច្រោះថ្នាទំនឹងមិនឲ្យបាន
សេចក្តីក្តៅក្រហាយ តែតទំនឹងចេញទៅសុំចំណុះលើកស្រុកឲ្យខ្លៅពី តើ
អ្នកទាំងអស់គ្នានឹងយល់ឃើញប្រការម្តេច ។ គាំងហាធ្វើយថា គាហាន
ដែលមានក្តងស្រុកយើងក៏ច្រើនដែរ តែតឃើញចំនួន ៣ ម៉ឺនបាយ ទាំង
ស្រួតអង្គរស្បៀងអាហារកំបិបូណិល្អម ទំនឹងដប់លៀងគាហានត្រង់ត្រាន់
បានក្តងកេង ១ ឆ្នាំ ដែលលោកទំនឹងលើកស្រុកទៅឲ្យខ្លៅពីដោយងាយ
នេះមិនគួរសោះ ។

ខ្លៅដៀងតបថា ចំតាយើងទំនឹងខ្លួនយើង បានមកទៅកងស្រុកនេះ
ជល់តំណត់ ៦០-៣០ ឆ្នាំហើយ បណ្តាកស្តួអ្នកស្រុកក៏មិនដែលបានខ្វះខ្ត
លំបាក ពីព្រោះអ្វី គ្រានេះខ្លៅពីលើកកងទំពមកធ្វើអន្តរាយអាណាខ្លួត
ហើយ ទ្រព្វានចូលមកដល់ដៃនស្រុកយើងហើយ ពស្តួទាំងឡាយក៏

ចានសេចក្តីក្តៅក្រហាយគ្រប់ ៣ ឆ្នាំមកហើយ ខ្ញុំនយើងមានចិត្តអាណិតអាណាប្រជាទុក្ខស្តួណាស់ ចានជារិះគិតនឹងលន់តួចំណុះឡៅពី ។ ទៅដីវិញប្រឹក្សាឆ្លើយថា លោកគិតនេះត្រូវណាស់ ព្រោះខ្ញុំចានចានយើញភ្លាយសម្រាប់ស្រុកសែឈួននោះចាត់ទៅ មានភ្លាយមួយដួងធំរះឡើងដំនួស មានតន្ទីរស្មីភ្លឺដូចព្រះចន្ទ មានភ្លាយតូច ។ ចោមកោមជាបរិវារចោមកោមច្រើនណាស់ ហើយខ្ញុំចានចានឮកូនក្មេងក្នុងស្រុកសែឈួនធ្វើភ្លេងលេងថា បើអ្នកណាមានឹងចង់ពិសាអាហារថ្មី ចូរចាំម្ចាស់ផែនដីថ្មីមកឈរស្រុកនេះចុះ ទើបចានសមតាមសេចក្តីប្រាថ្នា ។

អ៊ុយគួន ឡៅចាំ ចានឮដូច្នោះ ក៏ខឹងណាស់ កន្ត្រាក់យកគ្រប់ឹមកកាន់តិតនឹងសម្ងាប់ចៅដីវិញ ឡៅដៀងក៏ស្ទុះទៅយាត់ ខ្លួលមានបំរើចូលទៅប្តឹងឡៅដៀងថា ទៅចេនដែលជាចាស់ដូចេត្រនោះ លបរត់ចេញទៅទៅខាងឡៅពីទៅហើយ ឡៅដៀងចានឮដូច្នោះ ក៏រីករាយតូចចិត្តអង្គុយយំ ហើយត្រឡប់ចូលទៅខាងក្នុង លុះវេលាព្រឹកឡើងខាយភ្លាចូលមកប្តឹងឡៅដៀងថា ឥឡូវឡៅពីលើកកងទ័ពមកពីតយហែចាំងគួនមកហើយ បោះទ័ពនៅខាងត្រៀស្រុកយើងនេះ ឲ្យកាន់យ៉ាងចូលមករកលោក ឡៅដៀងបង្គាប់ឲ្យបើកភ្លាស្រុកខ្លួលចូលមក ខាយភ្លាក៏ចេញបើកភ្លាខ្លួល ។

ឯកាន់យ៉ាងនោះក៏ដឹះរះចូលទៅដល់កណ្តាលស្រុក ដ៏ន្តី

យើញដូច្នោះក៏ខឹងណាស់ តន្ត្រាក់ក្រជើក្រវែងឡើង ហើយស្រែកឲ្យកាន់
យ៉ុងថា ឯងឯងជាជាតិថាកខាប ហេតុម្តេចទើបហ៊ានដង្ហែរទេះចូលមក
ដល់កណ្តាលស្រុក ឯងមើលងាយយើងថា កងស្រុកសែសឈ្មួនទេះ គ្មាន
មនុស្សល្អទេឬ? ទើបព្រហើនដូច្នេះ ។ កាន់យ៉ុងឮដូច្នោះក៏ចុះពីលើ
រទេះ គំនាប់សួរឈ្មោះគ្នាទៅវិញទៅមក ហើយកាន់យ៉ុងថា ខ្ញុំជាខ
មនុស្សប្រមាខ ហ៊ានដង្ហែរទេះចូលមកដល់កណ្តាលស្រុក អ្នកកុំប្រកាន់
ទោសឡើយ ។ ជនពីគំរោយកំហឹង ទើបអាំកាន់យ៉ុងចូលទៅជួប
នឹងខ្លៅជៀង ។ កាន់យ៉ុងនគំនាប់ហើយដំកថថា ខ្លៅពីនោះជាមនុស្ស
មានស្មារតី មានចិត្តអាណិតអាណាថណ្តាកស្ត្រីច្រើនណាស់ ទើប
លោកតាំងចិត្តលំអុតលំនដល់ខ្លៅពីដោយសុចរិត ហើយខ្លៅពីក៏ខឹង
មិនបានប្រទូសកាយដល់លោកទេ ។

ខ្លៅជៀងឮដូច្នោះ កំបណ្តាលចិត្តគិតញញើតកោតខ្លាចខ្លៅពីខ្លាំង
ណាស់ ទើបនិយាយជាពាក្យជាច់ថា អ្នកពស់គ្នាកុំចិនិយាយរឹងខឹង
នឹងយើងឡើយ យើងនឹងនំនុកបម្រុងអាណាប្រជាកស្ត្រីតាំងពួងឲ្យបាន
សេចក្តីសុខតទៅ ក្នុងគ្រានេះ យើងនឹងចេញទៅលន់តួសុំចំណុះចុះចូល
ខ្លៅពី ទើបឲ្យរៀបតុលៀងកាន់យ៉ុង ឲ្យបរិភោគអាហារ លុះលៀង
រួចហើយ កំយកគ្រាសម្រាប់ដាវខ្លុវអែសវេសទ្រឡែលល្អត្រកាលនាំគ
ហានចេញទៅគំនាប់ខ្លៅពីក្នុងបន្ទាយ ។ ខ្លៅពីឃើញដូច្នោះ ក៏ចុះទៅ

ឪញដៃឡៅជៀងឲ្យឡើងទៅអង្គុយជាន់លើ ឡៅតាយាហើយនិយាយនឹងឡៅជៀងថា ខ្លួនយើងនេះ មានចិត្តសុចរិតគិតនឹងខំទុកបំរុងផែនដីឲ្យបណ្តាកស្ត្រីបានសេចក្តីសុខតទៅ ដែលរំមកធ្វើតាំងម្ល៉ះ ដោយសេចក្តីចាំចិត្ត លុះនឹងមិនគិតធ្វើដូច្នេះ ការដែលគិតទុកនោះក៏មិនបានរហូត អ្នកចូរយើញដល់ផែនដីដែលបាននេចក្តីក្តៅក្រហាយនោះចុះ កុំបីប្រកាន់ទោសដល់យើងឡើយ ។

ឡៅជៀងតបថា ធម្មតាអ្នកដែលនឹងខំទុកបំរុងផែនដីនោះ ពោះដូចម្តេចក៏ត្រូវតែធ្វើដូចជាលោកនោះតាំងអស់ ខ្ញុំបានឥតគិតអ្វីសោះឡើយ ហើយក៏លើកគ្រាសម្រាប់ងារនោះជូនទៅឲ្យ ឡៅតា ព្រមតាំងបណ្តាការតាំងពួន ឡៅតា ទទួលហើយ ក៏មានសេចក្តីសោមនស្សសាទរអរពេកណាស់ ។ ឡៅជៀង ក៏អញ្ជើញឡៅតា នឹងបណ្តាសេនាតាហានចូលទៅកន្លែងស្រុក ។ ខណៈនោះ មនុស្សម្នាមហាជនតាំងព្យាយតាំងពួនបណ្តាដែលមានកន្លែងកំឡុងស្រុកសែឈួនតាំងប៉ុន្មាន បានក្រឡេកយើញឡៅតាចូលទៅ ក៏ស្រុះស្រួលបបួលគ្នាអុជទៀនធូបបូជាពិការឡៅតា តាមលំដាប់មាតាតាំងសងខាងរៀងទៅ ។ ឡៅតានោះ លុះក្រឡេកយើញដូច្នោះ ក៏មានចិត្តត្រេកអរណាស់ កាលបើយាត្រាទៅដល់ទីតេហង្ឃាននិយាយការកជការហើយ ក៏យើញទីប្រឹក្សារបស់ឡៅជៀងតាំងប៉ុន្មានចូលទៅត្រៀមចាំតំនាប់ឡៅតាតាំងអស់ បានតែឈ្មោះអ៊ុយ គួន ១ ឡៅ

ចាំ ។ ម៉ែនហ្នេះចូលទៅដំនាប់ខ្លួនឯង ។

តួកមាហានឡៅពីដំណឹងជូនប្អោះ កំបបួលគ្នានឹងទៅចាប់អ៊ុយ គួន ខឹងឡៅចាំ សម្លាប់ចេញ ។ ឡៅតឿពាក្យមាហានខំយាយគ្នាជូនប្អោះ កំភ្លែងប្តូនថ្មាច់ថា ឲ្យសម្លាប់ឲ្យអស់ទាំងតួជនឆ្នាំងញ្ញាតិកាទីឪស្ត្រីបក្សពួកកុំឲ្យសល់ ហើយឡៅពីកំស្រួតតាមមាហានទាំងពួងទៅ លុះទៅដល់មុខអ៊ុយ គួន ឡៅចាំ ឡៅពីកំឃាត់ហាមមាហានទាំងពួង ឲ្យបង្អន់ឈប់ ហើយភ្លែងស្រែកប្រកាសឲ្យឮច្បាស់ទៅដល់អ៊ុយ គួន ឡៅចាំថា ឯអ៊ុយ គួន ខឹងឡៅចាំនោះ គេជាមនុស្សមានសេចក្តីស័ត្យត្រង់ធំនាយទៅហ្នាយណាស់ គួរយើងនឹងចិញ្ចឹមក្បុកតទៅ កុំបីអស់អ្នកទាំងពួងធ្វើអន្តរាយគេឡើយ សូម្បីតែអំបោះមួយសរសៃឬម្ជុលមួយ កំមិនត្រូវធ្វើឲ្យបាត់បង់គេជាដាច់ខាត បើនរណាមិនស្តាប់ពាក្យយើងហាមឃាត់ទេ យើងនឹងពុះពោះសម្លាប់ដីតែៗ អ៊ុយគួន ឡៅចាំ ឮឡៅពីស្រែកប្រកាសដូច្នោះក៏ពិគ្រោះគ្នាថា ឡៅពីនេះគេជាមនុស្សល្អ មានអធ្យាស្រ័យសុភាពរៀបរយដូចពាក្យគេនិយាយមែនៗ គួរតែយើងនឹងចូលទៅធ្វើការដង្ហែងពុះលុះនិយាយហើយក៏នាំគ្នាចេញទៅតំនាប់គោរពឡៅពីៗ ក៏ទទួលកេរកាយហើយនាំយួនអ៊ុយគួន ឧឡៅចាំ ទៅទីលំទៅ រួចតិតាំងឲ្យនៅកងដែដែលតាមដើម ។

ខ្ញុំរៀបនិយាយនឹងឡៅពីថា ស្រុកសែឈួនសព្វថ្ងៃនេះ ចានពប

ទាបស្រួលបួលហើយ ដែលនឹងឲ្យមានចៅហ្វាយស្រុក ២ រូបនោះ មិនគួរសោះ គួរតែឲ្យខ្លៅដឿងទៅស្រុកកេងដីវិញ ។ ខ្លៅតិចា ខ្ញុំយើងទើបតែនឹងបានស្រុកសែឈួននេះ ចើនឹងឲ្យខ្លៅដឿងទៅនៅស្រុកកេងដីវ មនុស្សទាំងពួងនឹងតវាទានិន្ទាថា យើងកែងបញ្ជោតខ្លៅដឿងឲ្យខូចស្រុកសែឈួន ។

ខុងចេងថា ឯខ្លៅដឿងនេះជាមនុស្សមិនចេះដឹងអ្វីសោះ ហើយវៃមាំងខ្លួចចិត្តគំនិតទៅហើយ ចើយើងនឹងទុកឲ្យនៅក្នុងស្រុកនេះជាមួយយូរទៅ ខ្លាចមានគេនាំញុះញង់ តង់នឹងស្តាប់ដឿពាក្យគេ ខ្ញុំលោកតំតង់នឹងបានសេចក្តីរំខានចិត្តទៅថ្ងៃក្រោយ ។ ខ្លៅតិយល់ឃើញត្រូវលុះកន្ទងមកមួយថ្ងៃ ខ្លៅតិកឲ្យអញ្ជើញខ្លៅដឿង ទៅលៀងអាហារហើយនិយាយថា យើងនឹងឲ្យអ្នកទៅនៅឈរស្រុកកងអាន ។ ខ្លៅដឿងកំខ្លួលប្រសាសន៍ ។ ខ្លៅតិកឲ្យធ្វើត្រាតាំង ។ ខ្លៅដឿងជាដីវ៉ៃយចុងក្នុង ឲ្យនាំត្រប់ត្រួសារចេញទៅឈរស្រុកកងអាន ដែលឡើងស្រុកឡាំគុន កងដែនស្រុកកេងដីវ ។ ខ្លៅតិប្រគល់ត្រាតាំងឲ្យខ្លៅដឿងហើយថា មាសប្រាក់នឹងប្រព្យសម្បត្តិរបស់អ្នកតាំងប៉ុន្មាន ចូរនាំយកទៅតាំងអស់ចុះ ។ ខ្លៅដឿងខ្លួលយកត្រាសម្រាប់ងារ ហើយក៏នាំត្រប់ត្រួរនឹងបក្សពួកទៅនៅស្រុកកងអាន ។

ឯខ្លៅតិកាលបានស្រុកសែឈួនហើយ បណ្តាខ្លៅប្រុក្សានឹងសេនា

ខាហានរបស់ខ្លៅដៀនចាំងប៉ុន្មាន ខ្លៅតិតំតាំងឲ្យក្រីចាប៉ុចប្លុះបង្ក្រិទាំង
រដ្ឋបាលទាំងអស់ តែហួតចេងនោះ តាំងឲ្យធ្វើចាលរដ្ឋស្រុកសែឈួន
ហើយខ្លៅតិតាំងខ្លួនបេងជាអាចារ្យចំសម្រាប់ប្រៀនប្រដៅ តាំងគួន
អ៊ូ ឲ្យជាចៅហ្វាយស្រុកគេងជីវ ឯខ្លៀវហ៊ុយ ជូឡុង អ៊ុយអៀន ហាន
គុង មាំឈ្មៅ ៥ នាក់នេះ ជាទាយខាហានឯក ស៊ុនវៀន កាន់យ៉ឹង
ប៊ីតុក ប៊ីហាន គួនប៉េង ជីវគេង ខ្លៅហាន លៀវហ៊ួ ម៉ាចេក ម៉ាលៀង
ចៀងអួន អ៊ីចៀ ចាំងនេះជាទាម៉ឺនធំតួចតាមលំដាប់ ហើយឲ្យចំណាច់
ឆ្អែនជាច្រើនគ្រប់ៗគ្នា តែជីវគេង គួនប៉េង ចាត់ឲ្យទៅទៅជួយគ្នើ
រាជការគួនអ៊ូឯស្រុកគេងជីវ ហើយខ្លៅតិចាត់មាស ៥០០ ជញ្ជីង ប្រាក់
១០០០ ជញ្ជីង អ៊ុំប៉ៃះ ៥ ពាន់ម៉ឺន ព្រៃយ៉ាងល្អ ១ ពាន់ផាប់ ឲ្យខាហាន
នាំទៅឲ្យជាបំណាច់គួនអ៊ូ ឯស្រុកគេងជីវ ដើម្បីឲ្យចែកបណ្តាកូនខាហាន
តាមបំណាច់ ។

លុះវេលាព្រឹក ខ្លៅតិឲ្យបើកជង្រុកស្រូវ ទំងចំណីត្រីសាច់ស្បៀង
អាហារចែកអ្នកស្រុក ទំងរៀបចំលតាមសមគួរគ្រប់ៗគ្នា ។ អស់បណ្តា
មន្ត្រីសម្ព្រាមហាជនមុខមន្ត្រី កំប៉ុងក្នុងស្រុកសែឈួន កំមានសេចក្តីសុខ
ទំរំទុក្ខចាកគយន្តាយសប្បាយគ្រប់ៗគ្នា ។ ខ្លៅតិក៏បង្គាប់ថា ជីស្ងួនប្បារ
ស្រែចម្ការ ដែលគ្មានម្ចាស់កាន់កាប់ចុះបញ្ជីជាកម្មសិទ្ធិខេ ត្រូវបែងឲ្យ
ចានតន្តៅជាសម្រាប់មុខមន្ត្រីតួចធំ ដើម្បីជាកម្លាំងរាជការ ។ ជូឡុង

ឆ្លើយថា ស្រុកសែឈួននេះមានសឹកសង្គ្រាម បណ្តាពស្ត្រកំភ្លាត់ភ្លាត់ពីភូមិលំនៅ មិនបានធ្វើស្រែចម្ការ ដែលនឹងយកពន្ធពីស្រែចម្ការមកបែងវែកថែកឲ្យតាមុំនមុខមន្ត្រីនោះ បណ្តាពស្ត្រនឹងបានសេចក្តីក្តៅក្រហាយណាស់ គួរលោកឲ្យប៉ាវតង់ប្រាប់ពស្ត្រថា ភូមិលំនៅនឹងសួនច្បារស្រែចម្ការរបស់នរណា ក៏ឲ្យមកនៅធ្វើរកខួលបានតាមដើមចុះ ទើបពស្ត្រនឹងបានសេចក្តីសុខតទៅ ។ ឲ្យតាយល់ត្រូវផង ទើបឲ្យប៉ាវតង់ប្រាប់ពស្ត្រតាមពាក្យដូឲ្យឯង ។

ឲ្យតាន់យាយ ទន់ខ្ទន់ចេងថា ច្បាប់សម្រាប់ស្រុកសែឈួននោះ យើងត្រូវលើកចោលចេញ ហើយសុំឲ្យលោកតាក់តែងច្បាប់ថ្មីសម្រាប់ស្រុកឡើងវិញ ហើយឲ្យចាត់ទោសមនុស្សដែលប្រព្រឹត្តខុសឲ្យធ្ងន់ជាងច្បាប់ចាស់ ទើបមនុស្សទន់ខ្ទាបអាប្រតិបត្តិតាម ស្រុកទេសទើបនឹងបានរាបចតរាបតទៅ ។ ហួតចេងថា កាលគ្រាព្រះចៅហាន់កោចបានសោយរាជសម្បត្តិនោះ ស្តេចឲ្យតែងច្បាប់កាត់ទោសមនុស្សដែលប្រព្រឹត្តខុសខុកជាប្រមាណ លុះដល់ព្រះចៅហៀនតគ្រានេះ ទ្រង់ឲ្យតែងច្បាប់កាត់ទោសឲ្យធ្ងន់ជាងច្បាប់ចាស់ បានជាមនុស្សកើតក្តៅក្រហាយជាចលាចលដូច្នេះ ហេតុនេះ គួរឲ្យលោកត្រិះរិះបន្ថយទោសឲ្យស្រាលទៅវិញ តាមច្បាប់បុរាណនឹងបានសេចក្តីសុខធូរខួលាយ ។

ខុនចេងថា ពាក្យដែលអ្នកនិយាយនេះគួរប្រពៃណាស់ ព្រោះតាំង

ព័ត្រាព្រះចៅហាន់កោចោ ឲ្យតែងច្បាប់ទុកនោះ មិនមែនទុកមកដល់ព្រះចៅហៀនតេះទេ វែលានេះនាម៉ឺនមន្ត្រីបណ្តាកស្ត្រគ្រប់អាណាខេត្តក្នុងប្រទេសចិន ក៏មិនបាននេចក្តីសុខសោះឡើយ ដូចខ្លាដៀនសោត ក៏ជាមនុស្សមិនស្លូវមានជម្រះវិជ្ជា ឥន្ទ្រកអំណាចអាជ្ញាសង្គ្រប់សង្គិនមិនបាន បើនឹងទុកបំរុងនរណា ។ ក៏រើសយកតែមនុស្សគ្រាប់ឥតប្រាជ្ញាដូចគ្នា តាំងធ្វើជានាម៉ឺនធំ ម្ល៉ោះហើយមនុស្សនោះក៏មានចិត្តកំរើលរលះបង់ច្បាប់សម្រាប់ផែនដី មានតែនេចក្តីតំហែងសង្គ្រប់សង្គិនអាណាប្រជាទុក្ខស្ត្រគ្រាមអំណាចចិត្ត ពស្ត្រកំបាននេចក្តីក្តៅក្រហាយ ដោយហេតុដូច្នឹតអំពើដូច្នោះឯង បានជាត្រូវអន្តរាយខ្លួចស្រុកទេសទៅ គ្រានេះ យើងត្រូវលើកច្បាប់ចាស់ចោលចេញ តាំងបទបញ្ញត្តច្បាប់ថ្មីបំពេញឲ្យធ្លើនេចសមនុស្ស ដែលប្រព្រឹត្តទុសនោះមិញឲ្យធ្ងន់សហ័ស ដើម្បីឲ្យមនុស្សគាំងអស់នោះ ខ្លាចញ្ញើត ឥន្ទ្រកតាមច្បាប់តទៅ បើនាហ្នឹងឥន្ទ្រកបណ្តាកស្ត្រឯណា ឃើញនរណាប្រព្រឹត្តទុសអំពីបញ្ញត្តច្បាប់ក៏ត្រូវចុះនេចសតាមនេចសានុនេចស បើឃើញនរណាប្រព្រឹត្តសេចក្តីតាប់ប្រសើរក៏ត្រូវឲ្យបានបំណាច់ផ្នាន់ឲ្យមានឡើង ទើបឥន្ទ្រកបានថ្កុំថ្កើងស្រុកទេសជាវិញ្ញូនាការតទៅ ។ ហួតចេង បានស្តាប់ក៏តាប់ចិត្ត តិតយល់ត្រូវប្រាកដ ទុនតំនាប់ទ្បើពី ឥន្ទ្រកុងចេង ខ្លួលតាមប្រសាសន៍ត្រូវប្រការ ។

ពុងចេង ក៏តែងរចនាច្បាប់តាមខម្ចាប់ទំនៀមផែនដី ឥន្ទ្រកាត់នេចស

ឡើងធ្វើជាងប្រក្រតីបុកណា ហើយបញ្ជូនទៅឡាត់ខេត្តខ័ណ្ឌ ដែលនៅ
ក្រោមបង្គាប់ចាំង ៤ ដំបន់ ជាខេត្តសម្រាប់ឡើងស្រុកសែឈួន ទៅ
ហ្វាយស្រុកចាំងអស់នោះ ទឹងទៅហ្វាយស្រុកសម្រាប់ត្រី-ចគ្វា ដែល
ឡើងត ។ ជាលំដាប់គ្នាចាំងមួយរយៗហ្វាយដំបន់ កំពុងលើតាមបញ្ជូត
ចាំងអស់ បណ្ដាពស្ត្រាឡាត់ខេត្តខ័ណ្ឌ កំពុងសេចក្ដីសុខសប្បាយ
ស្មើមក្បាន្តលើសជាងពីដើម ។

លុះនៅមក ថ្ងៃមួយ ឡៅពីចេញទិយាយភាគារ មានចំរើសុីប
ការចូលទៅប្ដឹងថា ដ្បិតមានចំរើតួនអ្ញ តួនបង់ទឹងចូលមកគំនាប់លោក
ឡៅពីកំឡៃហៅតួនបង់ចូលទៅ តួនបង់គំនាប់ហើយដំរាបថា តួនអ្ញ
បិតាខ្ញុំបាទ មានសេចក្ដីគ្រេកអរព្រះគេជព្រះគុណ ដែលលោកបានឲ្យបំ
ណាច់រង្វាន់ទៅនោះច្រើនណាស់ បានជាប្រើខ្ញុំបាទឲ្យចូលមកដំរាប ១១
បិតាខ្ញុំបាទផ្ដាំមកថា ដ្បិតបានឮដំណឹងលឺទៅដល់ថា ម៉ាឈៀវនោះ
ជាមនុស្សមានថ្នូរដៃខ្លាំងពូកែណាស់ទឹងកេនរណាស្មើគ្មាន បិតាខ្ញុំបាទទឹង
សុំមកតស៊ូកម្លាំង ទឹងម៉ាឈៀវលឿងមើល ។

ឡៅពីឮដូច្នោះក៏ព័យក្បាក់ស្មារតី ទើបប្រឹក្សាទឹងខុងបង់ថា តួន
អ្ញទឹងបង់មកលឿងថ្នូរដៃទឹងម៉ាឈៀវនោះ ម៉េអ្នកឯណាក្បាត់ចំណាប់ខន់
ថយក៏តង់ទឹងជាប់ពាក្យបានគ្នា តទៅ លោកទឹងតតប្រការម្ដង ។ ខុងបង់
ថា លោកកុំព្រួយ ខ្ញុំទឹងធ្វើសំបុត្រធ្វើទៅឲ្យតួនអ្ញឲ្យរសាយសេចក្ដីឥច្ឆា

ព្យាបាទនោះចេញ ។ ឡៅតឺថា ការនេះបើបង្អង់ឲ្យយូរ មុខជាគួនអ៊ូ
ទីដមកដល់ នាំឲ្យច្រួយរលៃខ្លីដែរ បើដូច្នេះ គួរតែលោកធ្វើសំបុត្រ
ផ្ញើទៅឲ្យឆាប់ កុំឲ្យគួនអ៊ូមកដល់មុន ។ ទុដ៏បេដ៏កំធ្វើសំបុត្រសរសើរ
លើកគួនអ៊ូគ្រប់ប្រការ រួចប្រគេចិនស្រោមប្រគល់ឲ្យគួនប៉ែង ។ ខ្ចួល
ហើយកំលាត្រឡប់ទៅវិញ លុះទៅដល់ស្រុកកេងជីវ កំយកសំបុត្រនោះ
ទៅជូនគួនអ៊ូ ហើយពណិនាសេចក្តីឲ្យស្តាប់គ្រប់ប្រការ ។

គួនអ៊ូខ្ចួលសំបុត្រទៅមើលឃើញសេចក្តីថា ទុដ៏បេដ៏ឲ្យពរមក
គួនអ៊ូពីបុដ៏គុនឲ្យបានជ្រាប ព្រោះយើដ៏ដឹដ៏ថា អ្នកមានសេចក្តីវិតក្ក ព្រោះ
ម៉ាឈៀវនោះ មិនគួរទេ ព្រោះថ្លៃដែម៉ាឈៀវនោះប្រៀបស្មើនឹដ៏ថ្លៃដៃឿ
ហ៊ុយ ប្អូនអ្នក ឯការកល់សឹកសង្គ្រាមនោះ ថ្លៃដៃអ្នកលើសជាដ៏ម៉ាឈៀវ
ច្រើនណាស់ ដែលអ្នកនឹដ៏លះបដ៏ស្រុកកេងជីវទៅលឿដ៏ថ្លៃដៃគ្នាដ៏ម៉ា
ឈៀវនោះ មិនស្រួលទេ ក្រែដ៏មានសេចក្តីអន្តរាយដល់ស្រុកកេងជីវ
ខ្ញុនអ្នកក៏ត្រូវមានទោសទុស ព្រោះធ្វេសប្រហែស ការនេះសូមឲ្យអ្នកត្រិះ
រិះតាមគួរសិនទើបបាន លុះមើលចប់សេចក្តីហើយ គួនអ៊ូក៏មានសេច
ក្តីត្រែកអរគិតថា ទុដ៏បេដ៏នោះសមគួរជាគ្រូអាចារ្យប្រដៅយើដ៏បានណាស់
ទើបយកសំបុត្រនោះបង្ហាញអស់នាម៉ឺនមុខមន្ត្រីនឹដ៏ធាហានតាំដ៏ពួដ៏ហើយ
ថា តាដើមយើដ៏គិតវិតក្កព្រោះឮថា ម៉ាឈៀវមានថ្លៃដៃខ្ពាំដ៏ពួកណាស់
គិតនឹដ៏បដ៏ទៅលឿដ៏ថ្លៃដៃមើល ឥឡូវយើដ៏ក៏អស់សេចក្តីវិតក្កហើយ ។

សាមកុក្កខ្សែ ៥៥

តាំងពីស៊ុនគួនដំណឹងថា ខ្លៅពីរាយយកបានស្រុកសែឈួន ស៊ុនគួនគិតនឹងរាយយកស្រុកកេងជាវិញ រហូតដល់ចូលឆ្នាំរាយយកបានស្រុកហាន់តុងតាំងខ្លៀវឡឈ្លេរជាចៅហ្វាយស្រុកដូចដើម ។

ឯស៊ុនគួននោះ លុះដឹងកិត្តិស័ព្ទថា ខ្លៅពីរាយយកបានស្រុកសែឈួនហើយ ឲ្យខ្លៅដៀងទៅនៅស្រុកកងអានដូច្នោះ ក៏ពិគ្រោះនឹងទីប្រឹក្សាតាំងពួងថា ខ្លៅពីខ្លីស្រុកកេងជាវត្ថុកជាទីអាស្រ័យ យើងត្រូវតែឲ្យតាយកស្រុកនោះមកឡើងស្រុកយើងវិញ បើខ្លៅពីរឹងទទឹងមិនព្រមឲ្យ យើងនឹងលើកកងទ័ពទៅរាយយកឲ្យបានតែបាន អ្នកតាំងពួងនឹងយល់ឃើញដូចម្តេច ? ។

ខ្លៀវចៀវធ្វើយថា សឹកសង្គ្រាមទើបតែនឹងស្ងប់ ពលសាហានក៏កំពុងហត់នឿយណាស់ ដែលនឹងលើកកងទ័ពទៅរាយយកស្រុកកេងជាវិញនោះ សុំឲ្យលោកឈប់បង្អន់ជាសិន ខ្ញុំបានទឹងរិះគិតឲ្យខ្លៅពីលើកបង្វិលស្រុកកេងជាវិញតាមស្រួល ។ ស៊ុនគួនសួរថា គំនិតអ្នកនឹងរិះគិតប្រការម្តេច ។ ខ្លៀវចៀវថា ដែលខ្លៅពីគិតធ្វើការតាំងពួងនោះ ក៏ប្រស្រ័យសេចក្តីរិះគិតរបស់ខុងបេង ឯខុងបេងនោះជាបួនដួកាត់កិន សុំឲ្យលោកយកគ្រប់គ្រងរបស់ដូកាត់កិនជាក់តុកពុក ហើយឲ្យ

ជូកាត់កិនទៅនិយាយនឹងពុងបេង ឲ្យបង្វិលស្រុកកេងដីវិញ ជូនលោកវិញជាប្រញាប់ កុំមុខជានឹងបាន ។

ស៊ុនគួនតបថា ជូកាត់កិននោះ ជាមនុស្សខ្មៅត្រងិលសុចរិតណាស់ ហើយគ្មានទោសពុលតិអ្វីផង បើយើងនឹងធ្វើទោសដូចពាក្យអ្នកថា កាលណាជូកាត់កិននឹងមិនចូលចិត្តគិតពីនឹងយើង ម្យ៉ាងទៀត មនុស្សទាំងពួង កំពុងនឹងតវ៉ាខ្ញុំយើងទៀត ។ ខ្មៅវិញវិថាបើជាលោកនឹងត្រូវធ្វើការនេះ មានតែត្រូវហៅជូកាត់កិនមកប្រាប់ឲ្យដឹងជាមុនថា ដែលលោកយកគ្រាប់ត្រមកធ្វើទោសនោះគឺកុលទុបាយទេ កុំឲ្យគួចចិត្តឡើយ ជូកាត់កិនជាមនុស្សមានសតិបញ្ញា កំពង់ទឹងយល់តាមអធ្យាស្រ័យលោកមិនមានស៊ុនគួនយល់ឃើញត្រូវ កំឲ្យហៅជូកាត់កិនមកនិយាយតាមដំណើរទុបាយដែលគិតនោះឲ្យស្តាប់គ្រប់ប្រការ ហើយក៏តែងជាសំបុត្រប្រគល់ឲ្យជូកាត់កិនកាន់យកទៅ ឯគ្រួសារជូកាត់កិនទាំងប៉ុន្មានក៏ឲ្យយកទៅដាក់គុកឃុំទុកទាំងអស់ ជូកាត់កិនកាន់សំបុត្រនោះលាស៊ុនគួនចេញទៅស្រុកសៃឈួន លុះទៅដល់ហើយក៏ប្រាប់អ្នកចាំទ្វារ ។ អ្នកចាំទ្វារ ក៏ចូលទៅជំរាបខ្មៅតិថា ឥឡូវជូកាត់កិនទឹងចូលមករកលោក ។

ខ្មៅតិដឹងសេចក្តីសួរពុងបេងថា ជូកាត់កិនបងលោកដែលមករកយើងក្នុងវេលានេះដោយហេតុអ្វីអេះ ។ ពុងបេងថាដែលបងខ្ញុំមកនេះប្រាកដជាស៊ុនគួនប្រើឲ្យមកការយកស្រុកកេងដីវិញហើយ ខ្មៅតិសួរថា

របើដូច្នោះ លោកនឹងឲ្យនិយាយការនេះថាម្តេច ខ្ញុំបង្គំក៏ចូលទៅឱបក្រចុះ
ឱបភ័ក្ត្រឲ្យធ្វើយតបតាមពាក្យខ្ញុំបង្គំពន្យល់សព្វគ្រប់ ហើយខ្ញុំបង្គំក៏
បញ្ជាទៅតំនាក់ខ្លួលជូកាន់កន្ទេះទៅឈរចាំឯផ្ទះខ្លួលក្បែរ ជូកាត់កន្ទក់
ក្លែងធ្វើជាយំខ្សឹកខ្សួលយូរណាស់ ខ្ញុំបង្គំឃើញដូច្នោះក៏ក្លែងសួរថា អ្នក
បង្គំមកឃើញមុខខ្ញុំជាប្អូនហើយ ហេតុម្តេចត្រឡប់ទៅជាយំវិញ គួរតែ
ត្រេកអរសោះ ជូកាត់កន្ទក់ថា ឥឡូវនេះ ស៊ុនតួនចាប់យកតំរាយបុត្រ
របស់បង្គំទៅជាក់គុកអស់ទៅហើយ មុខជានឹងជល់ខ្លូវសេចក្តីស្លាប់ទាំង-
អស់គ្នា ខ្ញុំបង្គំថា កើតហេតុទាំងនេះ ព្រោះស៊ុនតួនបង្គំបានស្រុក
កេងដីវៃទៅវិញ បានជាធ្វើដូច្នេះ ហើយធ្វើជាសួរថា ដែលអ្នកបង្គំ
អញ្ជើញមកនេះ ស៊ុនតួនប្រើមកឬវត់មកទេ ? ជូកាត់កន្ទក់ថា ស៊ុនតួន
ប្រើឲ្យបង្គំមក យកទាំងសំបុត្រនេះមកជូនខ្ញុំតាមផង ។ ខ្ញុំបង្គំថា បើការ
តែប៉ុណ្ណោះ កុំឲ្យអ្នកបង្គំព្រួយ សឹមយើងនាំគ្នាទៅជួបនឹងខ្ញុំតាមី ហើយ
ខ្ញុំនឹងនិយាយឲ្យខ្ញុំតាមីបង្វិលស្រុកកេងដីវៃឲ្យស៊ុនតួនវិញ ។ ជូកាត់កន្ទក់ឮ
ដូច្នោះក៏ត្រេកអរណាស់ ។

ខ្ញុំបង្គំក៏នាំជូកាត់កន្ទក់ចូលទៅតំនាក់ខ្ញុំតាមី ហើយជូកាត់កន្ទក់ក៏ជូន
សំបុត្រនោះទៅឲ្យខ្ញុំតាមី ។ ខ្លួលយកសំបុត្រនោះទៅមើលឃើញសេច-
ក្តីថា តាំដើមខ្ញុំតាមីបានខ្ចីស្រុកកេងដីវៃគុកជាតិអាស្រ័យ ឥឡូវដល់សន្យា
រហើយ ត្រូវឲ្យខ្ញុំតាមីបង្វិលស្រុកនោះឲ្យស៊ុនតួនវិញ ខ្ញុំតាមីឃើញ

សេចក្តីដូច្នេះ ក៏ធ្វើជាទឹងប្រឡាតខ្លាំង តាំងតែធ្វើយតបទៅដូគាត់កំនត់តាម
ពាក្យខុងវេងតឡាល់ថា កាលថ្ងៃមុន ស៊ុនគួនបានលើកប្អូនក្រមុំឲ្យយើង
យកធ្វើជាកវិយា យើងក៏បាននាំយកខុកស្រុកកេងដ៏វែ លុះយើងលើក
ទ័ពមកវាយយកស្រុកសែឈួន ស៊ុនគួនក៏មិនមានកោតក្រែងចិត្ត គិតប្រើ
ឧបាយមកបញ្ឆោតយកកវិយាយើងទៅខុកឯស្រុកកាំងតាំងវិញ ឥឡូវទៅ
ខខូចឲ្យមកតំងពាយកស្រុកកេងដ៏វែទៀត គឺស៊ុនគួនគិតធ្វើការចាំងម្ល៉ះ
ដូចជាមិនជាអ្នកឆ្លាសោះ ហេតុនេះ គួរយើងលើកទ័ពទៅកយយកស្រុក
តាំងតាំងឲ្យបាន ។

ខុងវេងបានស្តាប់ហើយ ក៏ធ្វើជាយ៉ាំយែកនិយាយនឹងឡៅពីថា
វេលានេះ ស៊ុនគួនឲ្យចាប់កវិយាបុត្រនិងស្ត្រីគ្រួបក្បួកបងខ្ញុំទៅជាក់គុក
ខុកតាំងអស់ ប្រាថ្នាតែនឹងពាយកស្រុកកេងដ៏វែឲ្យបាន បើមិនបានក៏នឹង
ធ្វើអន្តរាយបងខ្ញុំ និងកវិយាបុត្រឲ្យបានសេចក្តីព្រួយលំបាកដល់ខ្លួនដ៏វែត
អន្តរាយ បើបងខ្ញុំបានស្លាប់ខ្លាតខ្លួយវេលាណា ខ្លួនខ្ញុំបានក៏គង់និងមរណា
វេលានោះជាប្រាកដ ហេតុនេះ សូមឲ្យលោកអាណិតអាសូរបង្ហិលស្រុក
កេងដ៏វែឲ្យស៊ុនគួនចុះ ដើម្បីជាផ្លូវសង្គ្រោះឲ្យដូគាត់កំនត់និងខ្ញុំបាន បានគង់
ដ៏វែតទៅយើញមុខគ្នាតទៅ ។ ឡៅពីក៏ធ្វើជាព្រងើយ បែបមិនឮមិន
ដឹងមិនយល់ ។ ខុងវេងក៏តែតែយំសោកជាខ្លាំងលំអង្វរឡៅពីយូរ
ណាស់ ។ ឡៅពីថាស្រុកកេងដ៏វែនោះ មានទៃត្រូសម្រាប់ឡើង

ដល់ ៦ មណ្ឌល យើងនឹងឲ្យខូចដូចម្តេចបាន តែយើងយោគយល់ដល់មុខពាំងពីរនាក់ ដែលខូចមកនិយាយហើយ យើងត្រូវឲ្យស្រុកខៀន-សា ១ ស្រុកឡែងឡេង ១ និងស្រុកហ៊ុយអៀង ១ ពាំង ៣ តំបន់នេះវិញឲ្យស៊ុនគួនវាក់កណ្តាលចុះ ។

ខុងវេងឮដូច្នោះ កំឡើងរត្រេកអរពេកយនិយាយថា បើលោកមានមេត្តាដូច្នោះហើយ សុំឲ្យឡើងសំបុត្រឲ្យដូកាត់កិនទៅដល់គួនអ៊ូឲ្យជាន់ជាមុន នឹងបានវិលត្រឡប់ ៣ តំបន់នោះឲ្យទៅស៊ុនគួន ។ ឡៅតីកំឡើងសំបុត្រជាសេចក្តីថា ឡៅតីព្រមលើកស្រុកខៀងសា ១ ស្រុកឡែងឡេង ១ ស្រុកហ៊ុយអៀង ១ ដែលឡើងស្រុកកេងជីវនោះឲ្យទៅជាចំណុះរបស់ស៊ុនគួនចុះ លុះតែងសំបុត្រនោះរួចហើយ កំប្រគល់ឲ្យដូកាត់កិនហើយថា បើការណាអ្នកនឹងទៅកេងគួនអ៊ូនោះ ចូរឲ្យលំអុតលំនួនិយាយដោយសុភាព ព្រោះចិត្តគួនអ៊ូនោះរួសរហ័សណាស់ សូម្បីខ្លួនយើងឯងក៏ត្រែងខ្លាចណាស់ដែរ ។ ដូកាត់កិនទទួលប្រសាសន៍និងសំបុត្រហើយ កំណត្រឡប់ទៅស្រុកកេងជីវ ហើយឲ្យពាហានាំចូលទៅជួបនឹងគួនអ៊ូ. តាណិនារឿងក៏ឲ្យគួនអ៊ូស្តាប់ត្រប់ប្រការ ដូនពាំងសំបុត្រនោះឲ្យទៅគួន-អ៊ូមើល ។

គួនអ៊ូឃើញសំបុត្រដូច្នោះក៏និយាយថា ឡៅតី ខៀវហ៊ុយនឹងយើងកំពុងរួមចិត្តដ៏វិតមួយនឹងគ្នា ច្រើនថ្ងៃធ្វើការដកាមមកបំរុងនឹងជួយកម្ចាត់ខែន

ដ៏ឱ្យបានសេចក្តីសុខ អាណាខ្មែត្រចាំឆ្នាំអស់នេះ ក៏សុទ្ធតែជាដែនដីរបស់ព្រះចៅហៀនតេ តែវេលានេះមានមនុស្សអ្នកមានថ្លៃដៃខ្លាំងពូកែប្រែនយល់ឃើញថា ដែនដីតើតចាចលត្រង់មណ្ឌលខ្មែត្រង់ណា បានជានាំគ្នាពកំឆ្នាំងពារខ្មែត្រង់ណាដែន ជាតំណាន់របស់ខ្លួនខោះខុតតាមចំណែកៗ ឯធម្មតាអ្នកធ្វើពជការ ជាចៅហ្វាយខ្មែត្រង់ណាមួយៗ ខោះក៏ត្រូវតែតាំងចិត្តជាសុចរិតក្នុងពជការ បើមានព្រះតម្រាស់បង្គាប់មកយ៉ាងណា ក៏ត្រូវឱ្យតិចារណាមើលតាមគួរនឹងអធ្យាស្រ័យ បើឃើញត្រូវ គួរឱ្យធ្វើតាម បើឃើញគាស់ខុសពីបទចំរាមត្រង់ប្រការឯណា ត្រូវឱ្យមកប្តឹងទៅអ្នកកាន់កាប់ពជការជាដំឱ្យបានជ្រាប ឥឡូវ ឡៅតីបងយើងនឹងឱ្យបង្ខិលស្រុក ៣ ដំបន់ទៅឱ្យស៊ុនគួនខោះ យើងយល់ឃើញមិនគួរយើងមិនព្រមធ្វើតាមបង្គាប់ឡៅតីពេ អ្នកបួលទៅប្រាប់ស៊ុនគួនឱ្យដឹងចុះ។

ជូកាត់កិនឮគួនអ៊ូថាជូនោះក៏ចេះតែអង្វរថា សូមឱ្យលោកអាណិតឈ្លេងយល់ទៅដល់ខ្ញុំចុះ ស៊ុនគួនឃើញថា ខ្ញុំនឹងខុងបងជាបងប្អូននឹងគ្នា បានជាគេចាប់យកបុត្រតំរោរបស់ខ្ញុំទៅជាកគុកខុក ហើយប្រើខ្ញុំឱ្យនាំសំបុត្រមកពារស្រុកកេងជ័រឱ្យបាន បើមិនបានបង្ខិលស្រុកនេះឱ្យគេទេ គេឱ្យសម្លាប់បុត្រតំរោរបស់ខ្ញុំចាំងអស់ គួនអ៊ូថាដែលស៊ុនគួនធ្វើដូច្នេះជាកលឧបាយបញ្ឆោត ប្រាថ្នាតែនឹងពារយកស្រុកកេងជ័រឱ្យបាន ជូកាត់កិនថា លោកចរចាដូច្នេះដូចជាមនុស្សមិនចេះគិតអ្វីសោះ ។

គួនអ៊ូ ឮដូច្នោះក៏ខឹងណាស់ ហូតក្រចឹចេញហើយថា បើយើងមិនគិតយល់ដល់ខុងបេង ក៏ខឹងត្រូវកាត់ក្បាលអ្នកឥឡូវនេះចេញ តាំងពីនេះតទៅ អ្នកកំមកនិយាយមើលងាយប្រមាថយើងដូច្នេះទៀត បើមិនស្តាប់ទេយើងក៏មិនអត់ឡើយ ។ គួនបើងឮហើយ ក៏ចូលទៅអង្វរឃាត់ថា បិតាកុំអាលធ្វើវាដូច្នេះឡើយ គួរយើញយល់ទៅដល់ខុងបេងចុះ។ គួនអ៊ូតបថា ជូកាត់កិនេះ ព្រោះមើលងាយយើងពេកណាស់ បើកុំតែយើងយោគយល់ទៅដល់ខុងបេង ខឹងកាត់ក្បាលចេញឥឡូវនេះ ។ ជូកាន់កិនបានសេចក្តីអប្បយសណាស់ ក៏វិលត្រឡប់ទៅស្រុកសឈួនវិញ ។ណៈនោះខុលខុងបេង ឃុំនាំពាហានចេញទៅត្រួតគយ ។ ជូកាន់កិន ក៏ចូលទៅជួបនឹងឡៅពី ហើយយំរៃកនិយាយឲ្យឡៅពីស្តាប់តាមហេតុដែលគួនអ៊ូប្រឆាំងនឹងសម្ងាប់នោះគ្រប់ប្រការ ។

ឡៅពីតបថា យើងបានប្រាប់អ្នកហើយថា ចិត្តគួនអ៊ូនោះកាចរួសហើសណាស់ អ្នកចូលវិលត្រឡប់ទៅប្រាប់ស៊ុនគួនដោយល្អស៊ុនចុះថា សូមឲ្យបង្អង់ទំព័រយើងលើកទ័ពទៅវាយយកស្រុកហាន់តុង បានវិលាណា យើងនឹងយកគួនអ៊ូ ឲ្យទៅឈរធ្វើជាចៅហ្វាយស្រុកហាន់តុង នឹងប្រគល់ស្រុកគេងជីវ ព្រមទាំងស្រុកដែលឡើងទាំងប៉ុន្មានឲ្យស៊ុនគួនវិញទាំងអស់ ។ ជូកាត់កិនមិនដឹងតបថាយ៉ាងណា ក៏លាត្រឡប់វិលទៅស្រុកគាំងគាំងវិញ លុះទៅដល់ហើយក៏តណិនារឿងរ៉ាវឲ្យស៊ុនគួនស្តាប់ តាម

ដែលខ្លៅតិនឹងគួនអ៊ូថា ប្រការម្តេច ។ នោះត្រង់ប្រការ ។

ស៊ុនគួនស្តាប់ហើយក៏ទីងណាស់ថា ដែលខ្លៅតិនឹងគួនអ៊ូនិយាយ ឲ្យយាំងម្តេចនោះ គឺជាសេចក្តីចេញមកពីគំនិតខ្លួនបេងជាប្អូនអ្នកឯងតាំងអស់ ។ ជូកាត់កិនឆ្លើយថា ខ្លួនបេងក៏ជាខ្លួនតោមស្ម្រាលិតខ្ញុំបាទណាស់ដែរ បានតាំងជួយអង្វរលេនគួនសខ្លៅតិ ។ ក៏បង្គាប់ទៅគួនអ៊ូឲ្យបង្កិលស្រុក ៣ ដំបន់ជូនមកលោក លុះខ្ញុំបាទទៅច្រាប់គួនអ៊ូ ។ ទីងប្រតែកមិនព្រមឲ្យ ហើយគិតនឹងសម្លាប់ខ្ញុំបាទទៀត ។ ស៊ុនគួនថា គេបានចេញវាចាថា ទីងបង្កិលស្រុក ៣ ដំបន់ឲ្យយើងហើយ យើងត្រូវតែចាត់តាហាន ដែលមានថ្នូរដៃខ្លាំងពូកែទៅឈរឆក្សាស្រុកតាំង ៣ ដំបន់នោះទុក ដើម្បីនឹងមើលកលការគួនអ៊ូ តើនឹងធ្វើប្រការម្តេច ។

ជូកាន់កិនថា លោកគិតនោះគួរប្រពៃណាស់ ស៊ុនគួនក៏បង្គាប់ឲ្យបើកលៃងបុត្រតំរាយជូកាន់កិនដែលឃុំនោះចេញអស់ ហើយចាត់ប្រើតាហានដែលមានថ្នូរដៃទៅឈរឆក្សាស្រុកតាំង ៣ ដំបន់ តែងាយតាហានតាំង ៣ នាក់ដែលទៅនោះ លើមកថ្លឹងស៊ុនគួនថា បានលើកគ្នាទៅដិតទីងដល់ស្រុកតាំង ៣ អន្ទើនោះហើយ គួនអ៊ូលើកពលទៅដេញកំចាត់កំចាយ មិនព្រមឲ្យចូលទៅក្នុងស្រុកនិមួយ ។ បាន ដើរចំបាន់បំពារចូលទៅតាមតេលការ យើញថា គួនអ៊ូទីងប្រហារជំរៃឲ្យអន្តរាយតាំងអស់គ្នា ។

ស៊ុនគួនឮដូច្នោះក៏ទីងណាស់ ទើបឲ្យគេហៅខ្លោសុកចូលមកសួរថា

ទ្បៀតព័ទ្ធខ្ញុំស្រុកកេងដីវាខុកប្រស្រ័យនោះ ចាន់ប្តូរថាចេ័កាលណា វាយចានស្រុកសែឈួនហើយ ទឹងបង្វិលស្រុកកេងដីវាឲ្យយើងវិញ ខ្លួនអ្នកកំចូលជាអ្នកធានាក្នុងរឿងនេះ ឥឡូវទ្បៀតព័កយចានស្រុកសែឈួនហើយ ចានចេញសំបុត្រប្រាប់ទៅគួនអ៊ួឲ្យបង្វិលស្រុក ៣ ដំបន់ឲ្យយើង ឥឡូវគួនអ៊ូរឹងទទឹងមិនព្រមឲ្យ ថែមទាំងធ្វើខុកបុកម្នេញដោយរំលោភទៀត ខ្លួនអ្នកជាធានាតើធ្វើលេងទេឬ ?

ទ្បៀសុកថា ការនេះមិនមែនខ្ញុំចាទទឹងសៀមព្រងើយទេ ដែលគួនអ៊ូធ្វើដូច្នេះ ខ្ញុំចាទទឹងសុំគិតធ្វើកលទុចាយមួយ ១ មុនជាទឹងចានស្រុកកេងដីវាដោយងាយ ស៊ុនគួនសួរថា ទុចាយអ្នកប្រការម្តេច ? ទ្បៀសុកថា ខ្ញុំចាទគិតឲ្យទៅតាំងបន្ទាយនៅមាត់តាមស្រុកយើង ឲ្យតាហានតួនបង្កប់ចាំគ្រប់ច្រក ហើយឲ្យទៅអញ្ជើញគួនអ៊ូមកស៊ីលៀង ខ្ញុំចាទទឹងនិយាយតាយកស្រុកកេងដីវិញដោយល្អ បើគួនអ៊ូរឹងទទឹងទឹងឲ្យតាហានដែលចង្កប់នោះ ចាប់ខ្លួនសម្លាប់ចេញ បើគួនអ៊ូមិនមកតាមសេចក្តីខ្ញុំចាទទេ សឹមលោកលើកកងទ័ពចេញទៅច្បាំងយកស្រុកកេងដីវិញ ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

ប្រែតាមភាសាចាក់ដែងដោយ លោក ផេង-ទ្រីវ

៨៦) យាយចាស់ដឹងស្រីបំពើពីរនាក់

យាយចាស់ម្នាក់ មានស្រីបំរើពីរនាក់ ។ នាងទាំងពីរ ត្រូវតែរៀនដឹងអាអម្បោះកលថ្ងៃ គ្មានឈប់ឡើយ ។ យាយចាស់គ្មានព្រួយអ្វី ក្រៅតែពីចែកមុខការ ឲ្យនាងទាំងពីរធ្វើប៉ុណ្ណោះ ។

កាលណាព្រះអាទិត្យបំរុងនឹងរះ ហោតត្រូវតែរៀល ខ្លាអម្បោះត្រូវឲ្យមាន គឺថា ត្រូវតែឲ្យមានការធ្វើ ឥតឈប់ឈរឲ្យសោះ ។

កាលណាមេឃក្រហមឯកើត មានឈ្មោលចង្រៃមួយ ចាប់ផ្តើមក្អេងយាយចាស់យើង ចង្រៃជាងមានទៅទៀត ចាប់ស្រែកសំឡេងក្អែលក្រខ្វក់គួរឲ្យខ្ពើម អុជចង្កៀងកាន់ដើរតម្រង់ទៅត្រែដែលស្រីបំរើទាំងពីរកំពុងតែដេក តាមអំពើចិត្តនឹងយ៉ាងឆ្ងាញ់ ។

នាងមួយ បើកភ្នែកមួងត្រឹមៗ នាងមួយ លាតសន្ធឹងដៃម្ខាង ហើយនាងទាំងពីរនេះក្តៅចិត្តពេក ទើបនិយាយរងំៗ ថា : អាមានំចង្រៃ! អាឯងខឿនតែស្ងាប់មិនខាន! ថាដូច្នោះហើយ ស្រីបំរើទាំងពីរលបៗចាប់មួលកមានំស្ងាប់ ដែលជាសត្វសម្រាប់ផ្តើជាស៊ាល់ព្រឹកនោះ ។

ឃាតកម្មនេះ មិនបានធ្វើឲ្យមានការចំរើនអ្វីដល់ខ្លួនសោះ មានតែចំលាក់ទម្ងន់មកលើអាត្មាលើសមុនថែមទៀត គឺថាផ្ទុយទៅវិញ ស្រីបំរើ

ទើបតែនឹងដេក យាយចាស់ ដោយបារម្ភខ្លាចក្រែងហួសម៉ោង ក៏ដើរ
កុប ។ ដូចជាម្រិញតង្វាល តេញតាំងផ្ទះ (ដាស់ស្រីចំរើឲ្យឡើងធ្វើការ) ។

ដូច្នេះហើយ ចានថា: ជាញឹកញាយណាស់ កាលណាគេគិតនឹង
ដោះខ្លួនឲ្យចេញរួចពីកិច្ចការដ៏អាក្រក់អ្វីមួយ (ជួនកាល) តើតចូលកាន់
តែជ្រៅលើសមុនថែមទៀត តស្មុតាងដូចស្រីចំរើតាំងពីដែលត្រូវខួល
រង្វាន់ធ្ងន់លើសមុន ។

លុះអត់ពីមាន់ភៅ (គ្មានអ្វីជាគោល) យាយចាស់ធ្វើឲ្យស្រីចំរើ
មានការលំបាកច្រើនហួសប្រមាណ ។

៨៧ – មនុស្សព្រៃនឹងអ្នកជំណើរ

នៅរូងភ្នំ មនុស្សព្រៃនឹងកូន រៀបចំនឹងបរិភោគបបរ ដោយលើក
ភាជន៍ហុត ។

គេបានឃើញប្តីប្រពន្ធនឹងកូន នាំគ្នាអង្គុយលើស្មៅគ្មានកម្រាល
គ្មានសំពត់អ្វីឡើយ តែតាំងអស់គ្នា បរិភោគយ៉ាងឆ្ងាញ់ ។

(ឧកាសនោះ) មានអ្នកដំណើរម្នាក់ រងាញាក់ ចូលទៅក្នុងរូងនោះ
ដើម្បីសុំជ្រកភ្លៀង ។ មនុស្សព្រៃក៏អញ្ជើញអ្នកដំណើរឲ្យបរិភោគបបរ
រួមស៊ីខ្លួនជាមួយ ។ ភ្ញៀវគិតព្រមទទួលតាមសេចក្តីអញ្ជើញឥតមន្ទិល
បង្អង់ ។ ដំបូងអ្នកនេះ កំដៅម្រមដៃខ្លួន ដោយផ្តុំខ្យល់ដាក់ ។
រួចគាត់ផ្តុំដាក់ចានបបរក្តៅ ដែលគេហុចឲ្យមកនោះទៀត ។

ឃើញដូច្នោះ មនុស្សព្រៃរឿងឆ្ងល់ ទើបសួរថា «អ្នកធ្វើយ៉ាងនេះ ប្រយោជន៍អ្វី ? »។ - អ្នកដំណើរធ្វើយ៉ាងប្រាប់ថា «ផ្ទុំដំបូង ដើម្បីកំដៅដៃរបស់ខ្ញុំ ផ្ទុំម្តងទៀត ដើម្បីធ្វើឲ្យបបរត្រជាក់»។ - មនុស្សព្រៃពោលថា : «អ្នកត្រូវបន្ថយដំណើររបស់អ្នកទៅវិញចុះ»។ ឥឡូវនេះ អើយ ! ខ្ញុំមិនអាចអាស្រ័យដំណេកក្នុងផ្ទះជាមួយអ្នកបានទេ ។

ចូរចេញចេញ លោកអ្នកណា ដែលមានមាត់អាចផ្លុំក្តៅដូចត្រជាក់ដូចគ្នា ។

៨៨ - ខ្លាឃ្មុំនឹងមិត្តពីរនាក់

មិត្តពីរនាក់ ដោយត្រូវការប្រាក់ជាប្រញាប់ ក៏ទៅនិយាយលក់ស្បែកខ្លាឃ្មុំនៅរស់ (មិនទាន់ចាប់បាន) ទឹងអ្នកដឹតខាង ជាអ្នកដំបូងញៀស្បែកសត្វមានកេម ។ លុះនិយាយត្រូវប្លែគ្នា ព្រមទាំងបុះកិច្ចសន្យារហើយ មិត្តទាំងពីរក៏ចេញស្វែងរកខ្លាឃ្មុំ ហើយប្រទះឃើញមួយយ៉ាងធំ រត់ជាកំមក អ្នកទាំងពីរភ័យស្លុត ដូចជាខ្លះបាត់ត្រូវ ។

អាម្នាក់ស្ទុះទៅឡើងទៅពួនឯបុងឈើមាន់ អាម្នាក់ទៀត ភ័យត្រជាក់ខ្លួនស្រេងគិតអ្វីមិនទាន់ ក៏ដេកផ្កាប់មុខធ្វើជាស្លាប់ ព្រោះបានឮគេនិយាយថា ខ្លាឃ្មុំមិនស៊ូដៃលស៊ីខ្មោចស្លាប់ស្រាប់ទេ ។ ខ្លាឃ្មុំ ឃើញមនុស្សដេកស្រាប់នៅដដែ ក៏ស្មានជាមនុស្សស្លាប់មែន ។ ដោយខ្លាចគេចោកបញ្ឆោត ក៏ដើរទៅចាប់បន្ទឹលទៅ បន្ទឹលមក ដើម្បីពិនិត្យមើល

ហើយថែមទាំងយកច្រមុះទៅដិតហិតដង្ហើមមើលផង ។ ខ្ញុំឃ្មុំនិយាយថា : ក្រាកដជាខ្មោចមែន ត្រូវតែឆេយចេញ ព្រោះធុំក្លិនហើយ ។ លោលដូច្នោះហើយ ខ្ញុំឃ្មុំដើរចូលទៅក្នុងព្រៃដិតខាងបាត់ទៅ ។

មិត្រម្នាក់ដែលឡើងដើមឈើ ត្រឡប់ចុះមកវិញ រត់ឆ្ពោះទៅរកមិត្រវបស់ខ្លួន ហើយនិយាយថា : ជាការអស្ចារ្យពេកណាស់ហើយ ដែលគ្រាន់តែបានក័យប៉ុណ្ណោះ រួចគេសួរបន្តមថា : អើ ! ចុះម្តេចទៅ ស្បែកកនោះ ? កខ្វក់ជាក់ត្រដៀកមិត្រឯង ថាម្តេចខ្លះ ? ព្រោះឃើញកចូលទៅដិតណាស់ ហើយចាប់ចង្កឹលមិត្រឯងនឹងដើងវាផង ។

- កបានប្រាប់អញថា : មិនត្រូវលក់ស្បែកខ្ញុំឃ្មុំ ដែលគេមិនទាន់សម្លាប់នោះទេ ។

៨៩ - សត្វសិង្ហនឹងព្រានព្រៃ

មនុស្សអំនួតម្នាក់ ជាអ្នកលេងខាងបាញ់ ទើបនឹងបាត់ព្រួញមួយ ហើយសង្ស័យក្រែងសិង្ហចាប់ស៊ី ក៏ទៅជួបនឹងអ្នកតង្វាលពពែ រួចសួរថា : សូមមេត្តាប្រាប់ខ្ញុំឲ្យដឹងច្បាស់ក្នុងនាមជាមេចារល្អបន្តិចខ្ញុំផង ខ្ញុំនឹងសងសឹកព្រួញឲ្យបាន ។

អ្នកតង្វាលពោលថា : ខ្ញុំ ! ខ្ញុំតែងជួនបៀមមួយឲ្យដល់ក១ក្បាលមួយ ក្រាល់ខែ បានជាខ្ញុំអាចគោចរបានទៅដ៏ឆ្ងាយ តាមសេចក្តីប្រាថ្នា ហើយខ្ញុំក៏បានសុខ អំពីរឿងនេះដែរ ។

កន្លះពេលដែលឧទាំងតាមនាក់ កំពុងតែសន្ទនាគ្នា ស្រាប់តែសិង្ហ
មួយចេញមក ដើរយ៉ាងរហ័សមកភ្លេត ។

អ្នកអន្ធតស្ទុះរត់ភ្លែត ហើយស្រែកបន់ថា : ទ្រព្រះគុណាទេព្តាអើយ !
សូមលោកមេត្តាជួយបង្ហាញប្រាប់ខ្ញុំ នូវកន្លែងណាមួយ ដែលអាចឲ្យខ្ញុំ
រួចរស់ដឹងតែបាន ។

ដែលហៅថា មានសេចក្តីភ្ញាហានដ៏ពិតប្រាកដនោះ គឺនៅត្រង់ដែល
មានគ្រោះភ័យ ជាបន្ទាន់នោះឯង ។ ឧទាហរណ៍ ដូចអ្នកអន្ធត ដែល
ជាប់នៅសួងភ្លេសិង្ហ ស្រាប់តែឮសំលេងសត្វសំដី រួចស្ទុះរត់ភ្លាមទៅ
ពេលដែលឃើញសិង្ហមក ។

> គួរតែប្តីឲ្យមួយរយ តែមិនគួរធ្វើឲ្យកើត
> វិកលមួយទេ នេះជាមតិនៃអ្នកប្រាជ្ញ
> សូម្បីមិនមានមូលហេតុអ្វីជាមាំមួន ហើយ
> ក៏ធ្វើវិកលដែរ នេះជាលក្ខណៈមនុស្ស
> ល្ងង់ទេ ។
>
> ហិតោបទេស

១២ – យើងត្រូវចែកការគ្នាធ្វើ

Partageons le travail

រឿងព្រៃងទីបេត៍

ប្រែពីភាសាចាក់ង ដោយលោក ភ័យ-ប៊ុក

មានថូដីអង្ក ១ ឆ្នាំងខ្លះដី (tourte de terre) (l) ១ ស្លែក្តោប ១ រុយ ១ កន្ទេរមគ្រាប់ថ្ពាំ ១ ទំនិមួល ១ បានទៅប្រជុំគ្នាដើម្បីចែកការគ្នាធ្វើសព្វ ២ខ្លួន ។ ថូដីអង្កជាអ្នកខ្លួលចាត់ការនេះ ។ ថូនេះបានបង្កាប់ឲ្យឆ្នាំងខ្លះដីទៅកជង់ចំក ឲ្យស្លែក្តោបនាំគោញីទៅបម្ការ រុយនាំគោឈ្មោលទៅឲ្យស៊ីស្មៅ គ្រាប់ថ្ពាំកន្ទគ្រាប់ស្រូវសាឡី ហើយយកទៅបក់ទំនិងតួលបក់ ម្ទុលត្រូវបោសប្រាស នៅចាំគេហដ្ឋាន ។

ថូដីអង្ក ដល់ចែកការគ្រប់គ្នារួចស្រេច កំឡើងទៅស្ថិតនៅលើខ្លួថ្មក់មួយ ហើយក៏អង្គុយសម្លឹមគិតដញ្ជឹងអំពីការដែលខ្លួនត្រូវធ្វើក្នុងថ្ងៃនេះ ។

ឆ្នាំងខ្លះដីបានយកភ្លុមទៅជង់ចំក ។ តែឆ្នាំងខ្លះដីអង្កនោះ ត្រូវចំកខ្លាតទៅលើកំលោយអស់គ្មានសល់ ។ ព្រោះហេតុដូច្នេះ គេហដ្ឋានក៏គ្មានចឹកប្រើប្រាស់ទេ ។ ស្លែក្តោបបានទាំគោញីទៅបម្ការ រុយនាំគោឈ្មោលទៅស៊ីស្មៅ ។ នៅតាមផ្លូវដែលទៅ គោញីដោយសេចក្តីស្រេកឃ្លានក៏ស៊ីស្លែក្តោបអស់ ។ រាស្មានៃរុយត្រូវធ្លាក់កប់ទៅក្នុងអាចម៍គោ ដោយខ្លួនហ៊ីរដិតគោឈ្មោលនោះតេក ។ ព្រោះហេតុដូច្នោះ គោ

1—tourte de terre ប្រែថាឆ្នាំង តំនួនជាមិនសម ប្រហែលជាអ្នកនិពន្ធច្រលំនឹងពាក្យថា tourtière ប្រែថា ឆ្នាំងខ្លះទេដឹង ?

ញ៉ាំនឹងគោឈ្មោលនោះមិនបានវិលត្រឡប់មកកាន់គេហដ្ឋានវិញទេ ។

កន្ទេញមគ្រាប់ថ្ពៅបានទៅបក់ស្រូវឯតា្បល់បក់ ។ ដល់កន្ទេញមគ្រាប់ថ្ពៅទៅដល់ពីនោះ ស្រាប់តែកណ្ដោបក់ទៅណាបាត់ ។ កន្ទេញមគ្រាប់ថ្ពៅក៏មិនបានវិលត្រឡប់ទៅគេហដ្ឋានវិញ ។

ម្ទុលបានគ្រាប់ដើរកកំរោបាស តែរកមិនឃើញ ។ រួចម្ទុលនោះរត់ចុះឡើង ក៏រកមើលទៅតាមចង្អឹរចង្អឹកបាត់ ។ ព្រោះហេតុដូច្នេះ គេហដ្ឋានក៏មិនបានចាសសំអាត ។

ថ្លូដ៏នោះកំសត់ទៅអស់យូរកាល លើកូថ្ងាក់នោះ មានចិត្តព្រួយបារម្ភជាខ្លាំង ដោយមិនឃើញកាសាដែលប្រើទៅ មិនបានឃើញវិលត្រឡប់មកគេហដ្ឋានវិញ ។ ថ្លូដ៏ក៏ទឹកភ្នែនឯងថា: « ពួកនេះជាពួកគ្មានសមត្ថភាពគ្រប់គ្រាន់ ត្រូវតែអញទៅមើលត្រួតត្រាខ្លួនឯង តើវាទៅទីណាកន្លែងណា ! » ។

ក្រោយដែលបានត្រិះរិះដូច្នេះ ថ្លូដ៏អង្គកំលោតពីលើកូមកក្រោម មិនបានគិតថាខ្លួនធ្លាក់ដ៏អង្គ ក៏បែកបាក់ខ្លួចខ្លីគ្មានសល់ ។ ព្រោះហេតុដូច្នេះ គ្មានអ្នកណាថែទាំជួរសម្បង់សោះឡើយ ។

តតិរៀង: មនុស្សល្ងីល្ងើគ្មានប្រាជ្ញា ទំរបនាការខាំងឡាយ មិនបានសម្រេចដ៏ាយ រំនាសកាយខ្លាយមរណា ។ ធ្វើការមិនស្គាល់កាលយល់ធ្វន់ជាស្រាលតាមលក្ខណា មិនដឹងហេតុផលា អវិជ្ជាបានគេសតំាយ ។

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
ប. ក.

ប្រាសាទវត្តនគរ

(នៅខេត្តកំពង់ចាម)

នៅខាងលិចចំ នៃក្រុងកំពង់ចាម, តាមដងផ្លូវជាតិលេខ ៧ ទៅ ពីក្រុងភ្នំពេញ, មានប្រាសាទបុកណាមួយ ដែលអ្នកស្រុកសំគាល់ឈ្មោះថា « ប្រាសាទវត្តនគរ » ។ ចម្ងាយចូលពីផ្លូវជាតិតែប្រមាណ ២០០ ម៉ែត្រ ប៉ុណ្ណោះ មានក្រាលថ្មស្អាតស្អំស្រួលងាយធ្វើដំណើរបានត្រង់រដូវ ។ អ្នកស្រុករមែងចេញចូលក្នុងបុកណាដ្ឋាននេះរឿងកាលថ្ងៃពុំមានដាច់ ព្រោះនៅជិតទីប្រជុំជនខេត្ត ដែលមានមនុស្សច្រើនផង ខ្ជិនដោយមានប្រាសាទបុកណា, វត្តព័រ ព្រមទាំងបូជនីយដ្ឋានដទៃទៀតផង ។ អាស្រ័យហេតុនេះ អ្នកនៅជិតខាងក្រុងកំពង់ចាម ឬអ្នកជាទេសចរនៅកំសាន្តក្រុងកំពង់ចាម រមែងធ្លាប់ស្គាល់ប្រាសាទនេះច្បាស់លាស់ណាស់ ប៉ុន្តែប្រវត្តិពង្សាវតារនៃបុកណាដ្ឋាននេះ ច្រើនពុំសូវបានច្បាស់តាមសន្ធានចិត្តអ្នកទាំងនោះនៅឡើយ ដ្បិតគេច្រើនតែនិយាយតាមឮៗ គ្នាហូរហែមក

រកហេតុផលពុំបានជាក់លាក់ ។ ដូច្នេះហើយ ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ ជាមជ្ឈមណ្ឌលរក្សា នឹងប្រមូលឯកសារបុរាណបុកណា , ដែលកើតមានឡើង ជាង ៣០ ឆ្នាំមកហើយនោះ ត្រូវតែអធិប្បាយឡើងវិញជូនដំនូរមជាតិយើង បានយល់ច្បាស់ហើយបណ្តុះការស្រឡាញ់កេតិកកណ្ឌជាតិ ដែលមានសឹងតាសតេញក្នុងប្រទេស ។

បើយើងធ្វើដំណើរតាំពីកំពេញទៅ យើងបានដល់ប្រាសាទនេះ មុនឡើងដល់ក្រុងកំពង់ចាម គឺនៅខ្នុះតែបីគីឡូម៉ែត្រ ហើយបែរទាងលិចផ្លូវជាតិគឺខាងស្តាំដៃ , យើងនឹងប្រទះផ្លូវលំយ៉ាងស្អាតត្រង់ភ្លឹងតាមបន្ទាះដើមរុក្ខជាតិសងខាង គួរជាទីមនោរម្យ ។ សព្វថ្ងៃទីតាំងនៃប្រាសាទនេះស្ថិតនៅក្នុងឃុំអំម្ពិល ស្រុកកំពង់សៀម (កំពង់ចាម) ។

តួប្រាសាទ នឹងបរិវេណប្រាសាទទាំងមូល បែរមុខឆ្ពោះទៅទិសខាងកើត តម្រង់ទៅរកផ្លូវជាតិ ។

កាលណាចូលមកកាន់បុកណាដ្ឋាននេះ យើងប្រទះជាបឋមនូវកំពូលប្រាង្គមួយធ្វើពីថ្មបាយក្រៀម មានចន្ទោះប្រកប្រមាណជា ៣ ម៉ែត្រប៉ុណ្ណោះ នៅខាងលើពុំមានកំពូលអ្វីជាធើតឆាយទេ ទំនងជារុះធ្លាក់អស់ដោយសារការចាស់ទ្រុឌទ្រោមកន្លងកាលជាច្រើនឆ្នាំ ។ បំពាក់តងតាក់លើគ្រាន់តែនៅសល់សណ្ឋានជាកន្ទោងប្រាង្គ ប្តូរហៅតាមភាសាអ្នកស្រុកជ្រលងថា « គោបុរៈ » ប៉ុណ្ណោះ ។ ស្ថាប័នឯគោបុរៈនេះ សងខាងមាន

កំពែងថ្មដែលមានកំពស់ប្រមាណជា ៣ ម៉ែត្រ កម្រាស់ ០ ម ៦០ សព្វថ្ងៃ
ជ្រុះធ្លាក់អស់ច្រើនអន្ធើណាស់ទៅហើយ ។ ខាងលើកំពែងនេះទៀត
មានលំអដោយថ្មសំលៀងដែលធ្លាក់ជាសន្ធឹក ចុងស្រួចខ្ពង់ជាស្ទឹកឈើ
មានរៀងដូច្នែគ្នាភ្ញឹកអេញ ។ ខ្ញុំឯងគ្មានេះវាយន្តតូចអាចចេញចូល
បានយ៉ាងស្រួល ឯវាយន្តធំគេងមានការប្រយ័ត្នប្រយែងបន្តិច ព្រោះ
ចង្អៀតសងខាងផង ពីលើផង ក្រែងប៉ះ នាំឲ្យមានគ្រោះថ្នាក់ ។

ចូលផុតពីខ្ញុំឯងគ្មានេះក្នុង យើងប្រទះឃើញខាងឆ្វេងដៃមានស្រះ
មួយធំ មានទឹកថ្លាឆ្អែតដក់ខ្ជបប្រាំងខ្ជបវស្សាសំរាប់ផ្តល់ជាសេចក្តីត្រូវ
ការប្រើប្រាស់បានត្រប់ពេល ។ ជុំវិញស្រះ មានខឿនថ្មព័ន្ធជុំ តែយើង
ឃើញរៀបថ្មដោយមានចាយអបូកស្លាប់ផង មានតែជណ្តើរពីរគីខាងដើង
មួយ ខាងត្បូងមួយប៉ុណ្ណោះ ដែលទៅជាប់ជាគាំថ្មបុកណ ឥតស្លាប់
ដោយចាយអេ ។ មាត់ស្រះចំហៀងខាងត្បូង មានដើមដូងដុះត្រៀប
ចោលម្ចាស់ត្រលែតួរជាទីមនោរម្យ គ្របដណ្តប់លើដីពាលយ៉ាងស្រឡះ
ខ្លាយ ។ ត្រង់ពាលនេះ មានវត្តមួយប្រកបដោយព្រះវិហារ កុដិ
សាលាយ៉ាងរៀបរយក្នុងស្រុកហៅថា ,, វត្តនគរក្រៅ ,, ។
យើងដាក់បែរមកខាងស្តាំដៃម្តង ។ ខាងនេះ មានគូហាមួយសង់
របៀបជាផ្ទះអ្នកតាចិន ដ៏មានខ្ញុំឯងគូបមួយស្មុយព្រួតូវអក្សរចិនជា
លំអរ(១) ។ កូនឆ្នាំគូបមួយក្រាលឥដ្ឋយ៉ាងស្អាត សំពះនាំដំហានទេសចរ

---

១ - អក្សរចិនបើម៉ាត់ថា សាម-ប៉ាវ-កុង ប្រែថាព្រឹទ្ធាចារ្យប្រកបដោយចំណេះបីយ៉ាង ។

ចាំងឡាយឲ្យដើរចូលទៅក្នុងគូហានេះបានយ៉ាងស្រួល ។ តាមមែន តែគូហានេះបែរមុខមកត្បូង ប៉ុន្តែរូបដំមាករបស់ចាំងបីទៅក្នុងនេះ មិនបែរមុខត្រង់មកត្បូងទទួលអ្នកដើរចូលទៅទេ បែរជាឆ្ពោះមុខទៅខាងលិចវិញ ដូច្នេះអ្នកដើរចូលទៅ ត្រូវត្រឡប់ខ្លួនមកខាងស្តាំដៃទៀត ទើបបានប្រទះនឹងរូបនេះ ។ បដិមាកររបស់អង្គនេះ មានទំហំធំជាងមនុស្សធម្មតា ហើយទៅក្បាលមានកំពូលស្រួចបន្តិចបន្តួចដូចជាមួលីព្រះពុទ្ធរូប ។ រូបនៅចំកណ្តាល ដាក់ខ្ពស់លើអាសនៈអង្គុយតែនក្តែន ដៃសំពះប្រណម្យឆ្ពោះទៅខាងមុខ តិចសាងលិចចំ ។ រូបពីរសងខាងទៅជាបក្ខានអាសនៈទេ ហើយជារូបឈរកាន់ដំបងបញ្ជាចំពីមុខ ។ រូបចាំងបីនេះ ធ្លើពីថ្មដូចគ្នា តែសព្វថ្ងៃគេបំពងសក្តិចញ្ចាចថ្នាត់សាច់ថ្មទៅហើយ ។ អ្នកស្រុកហៅបដិមាករនេះថា "តាព្រហ្ម" ។ សឹងមានរឿងព្រេងមួយចំនានពីប្រវត្តិ តាព្រហ្មនេះថា គាត់ភ័ន្តច្រឡំស្រឡាញ់ម្តាយឯង យកធ្វើជាប្រពន្ធ ទ្បាំរហើយបានជាគាត់ត្រូវធ្វើរូបគាត់អង្គុយសំពះម្តាយ ដែលគេបញ្ជាអង្គុយមួយខាងលិច តែពីមុខគាត់ចំនោះឯង (១) ។

ហួសពីគូហានេះបន្តិច មានផ្លូវមួយបែរទៅស្តាំដៃសសៀរឯបទឹងគុហាតាព្រហ្ម ។ ជង្ហូវនេះកោង ដាំមានចេតិយតម្រៀបគ្នា ទឹងគុហាតូចមួយទៀតជ្រកក្រោមដើមពោធិ ដែលក្នុងនោះមានដាក់ព្រះពុទ្ធរូបបដិមាកររួចក្តីកើយាមួយអង្គ, ទៅដល់ត្រង់គាជាប់ខាងជើងផ្លូវផង ។

១- សូមអានរឿងតាព្រហ្មនៅក្នុងសៀវភៅរឿងព្រេងខ្មែរភាគ៥ផ្សាយពីពុទ្ធសាសនបណ្ឌិត្យ។

យើងមើលមកផ្លូវត្រង់ទៅលិចវិញ, នេះពិតជាផ្លូវពីបុកណា, យើញ
មានសភាពត្រង់ក្តីន ឆ្ពោះទៅកាន់ខ្ទោងទ្វារកំពែងមួយជាន់ទៀត ។ មុន
ដល់ខ្ទោងទ្វារ មានវាលមួយកាបស្មើទៅខាងស្តាំដៃ ប្រកបដោយរឿងថ្ម
ចាយក្រៀមព័ទ្ធជុំវិញ ព្រមទាំងមានក្បាច់ថ្នាក់ជារូបខាត សន្ធឹងខ្លួនជា
បង្អាន់ដៃនឹងគោថ្មដំ ។ ទៅអើតកស្ទឹងតម្រៀបគ្នាបែបជាព្រលានមួយ ។

គោបុរៈជាន់ទី ២ នេះ មានទំហំប្រហែលគ្នានឹងជាន់ទី ១ ដែរ
យើងគោលរួចមកពីខាងដើមដែរ ប៉ុន្តែ ទៅមានសភាពតន់ត្រង់ក្បាច់ក្បូរ
ច្រើនជាង ។ ចូលផុតទៅទៀត យើងប្រទះនឹងកូនសាលាពីរសងខាងផ្លូវ
នៅជ្រកក្រោមដើមពោធិ៍ធំៗម្ខាងមួយ ។ កូនសាលាទាំងនេះ ទើបតែសង់
ក្នុងរវាង ៥០.៦០ ឆ្នាំ កន្លងទៅប៉ុណ្ណោះទេ សំពាប់ឲ្យអ្នកដំណើរទាំងឡាយ
ឈប់សំរាក ព្រោះជាទីចំហឥតមានជញ្ជាំង មានតែដំបូលក្បឿងនឹងឈើ
ក្រោមក្រាលឥដ្ឋកន្ទែងយ៉ាងស្អាត ។ ទៅចុងសាលដុំវិញផ្នែកខាងកន្ត
មានតំនូរនិទានរឿងផ្សេង ។ កន្លងសជាតក៍យ៉ាងល្អមើល ។ ទៅជាប់នឹង
សាលាទាំងពីរនេះ មានស្រះធំៗពីរទៀតនៅម្ខាងមួយ ដែលមានទ្រង់.
ព្រាយដូចស្រះមួយទៅពីមុខគុហាតាព្រហ្ម ដែលយើងនិយាយរួចមកខ្លះ
ហើយដែរ តែស្រះពីរនេះតូចជាង ហើយមានទឹកតែកន្លះផ្លូវប៉ុណ្ណោះ ។
យើងដើរឆ្ពោះទៅមុខតែបន្តិច ក៏ដល់គោបុរៈមួយជាន់ទៀត ជាជាន់ទី ៣
ដែលមានសណ្ឋានបែបពាង ដូចជាទី ១ និងទី ២ ដែរ តែមានទៅសេស

សល់កំពូលច្រាំងខ្ពស់ជាងគេបំផុត ។ ហើយកំពែងកំនៅល្អស្អាតខ្លាំងណាស់ ។ កំពែងនេះ មានសណ្ឋានជារាងខ្លង គឺមានជញ្ជាំងសងខាងសំរាប់ទុកបន្ទោះកណ្តាលនៅចំហ អាចឲ្យមនុស្សដើរនៅបាន ។ ប៉ារាំណារាងខ្លងនេះកងបួនជ្រុងត្រង់ មានច្រកប្រកបដោយកំពូល តែពីរទេ គឺខាងកើតនឹងខាងលិច ។ ខាងក្នុងនឹងខាងក្រៅកំពែងនេះ ដីស្រឡះស្រឡាំជាទីតែកយដល់អ្នកទេសចរចាំងភ្លាយ ។ ចូលផុតពីកំពែងនេះភ្លាម គេឃើញនៅចំកណ្តាលទី មានច្រាំងណ្តើមួយខ្ពស់ប្រមាណជា ១៥ ម៉ែត្រ។ ជាន់ក្រោមកងបួនជ្រុង មានទំហំមួយជ្រុង ។ ប្រមាណ ៨ ម៉ែត្រ ។ នៅលើកំពូលគ្មានរចនាជាមុខរបរទេ គ្រាន់តែមានជាស្បាច់សន្ធាប់ថ្នាក់ ។ ខំនងជាត្រូបកផ្កាឈូក ឯចុងស្រួចបំផុតជ្រុះភ្លាក់ចាត់ពុំដឹងជាបែបណា គ្រាន់តែនៅឃើញជានជាសណ្ឋានមូល ប្រហែលកំពូលចេតីយ ។ ចុះពីថ្នាក់លើដែលមានស្បាច់ជាត្រូបកផ្កាឈូកកងមូលនោះមក ថ្នាក់ក្រោមបែរជាមានកងបួនជ្រុងរហូតដល់ដី ។ ត្រង់ផ្ទាល់នឹងដីនេះ មានសុំមប្រកបដោយស្បាច់បែបរចនាអង្គរ ហើយនៅផ្ទាំងថ្មជាផ្លែនៃសុំមគ្រាំង ៤ ទិស គឺខាងកើត ខាងជើង ខាងត្បូង នឹង ខាងលិច មានទ្វាក់ជារឿងពុទ្ធប្បវត្តិ ត្រង់ផ្លែគាំងបួន ។ តីផ្លែលើសុំមគ្រាទិសបូព៌ ទ្វាក់រូបភាពដំណាលការព្រះពុទ្ធទ្រង់ផ្ទាញ់មាកធិកជ, ផ្លែកខាងជើង ដំណាលការព្រះសុទ្ធត្តកុមារយាងចាកព្រះកជនិវេសន៍ តន់លើកណ្តកអាជានេយ្យ ,

ផ្នែកខាងត្បូង ដំណាលគាលព្រះពោធិសត្វទ្រង់កាត់ព្រះផ្នងនៅក្បែរស្ទឹង
អនោមា ទីឆ្ងាយ ៤ នៅខាងលិច ដំណាលត្រង់ព្រះពុទ្ធទ្រង់គង់មាន
អគ្គសាវ័កអមអង្គ ។ ក្បាច់ក្របរំណែរូបចម្លាក់ផ្តែនមួយ ។ ធ្លាក់ជារូបខាត
ពីរ សន្ធឹងខ្នងត្រង់តាមកាន់ត្រីកោន ប្រជាក់កន្ទុយគ្នាទៅលើ ក្បាល
សំយុងចុះក្រោមអើតចេញទៅបង្គន់ម្ខាងម្ខាក់ ។ នៅចន្លោះស៊ុមចាំង ៤ នេះ
មានដំកល់ព្រះពុទ្ធរូបមានវិជ័យមួយអង្គ ។ គ្រង់ចន្លោះទ្វារចាំងបួន ។ សព្វ
ថ្ងៃព្រះពុទ្ធបដិមាចាំងបួននេះ បិទមាសភ្ញីចាញ់ ។ មិនតែប៉ុណ្ណោះ
អ្នកស្រុកសម័យក្រោយ បានសាងព្រះវិហារមួយចំពីខាងកើតច្រកឆ្ពណ៌
ហើយយកដំបូលម្ខាង ទៅចំពាក់លើច្រកឆ្ពណ៌នោះផង ។ ព្រះវិហារនេះ
សង់ពីបាយអ ដំបូលប្រក់ក្បឿងពណ៌ភ្លឺផ្នែកឆ្ពិនផ្តៅ តែឥតមានជញ្ជាំង
ទេ ។ នៅក្រោមដំបូលវិហារផ្នែកខាងកើត មានសិលាចារឹកមួយផ្ទាំង
ដំកល់យ៉ាងស្អាតបាត ដូចជាសន្ធឹកសីមាពីរបួនជ្រុងសំបែត ។ អក្សរនៅ
ច្បាស់ឥតមានរបករបេះឡើយ គឺនៅផ្នែកខាងមុខជាអក្ខរបទភាសាបាលី
ហើយនៅផ្នែកខាងចំហៀង ជាអក្ខរបទភាសាខ្មែរ ។ នៅផ្នែកភាសា
បាលី គេអាចដកស្រង់សេចក្តីបានយ៉ាងសង្ខេបថា ៖

" ខ្ញុំស្រីសុគន្ធបទ ទីឆ្ងាយមហេសី ចាំងពីរនាក់មានចិត្តសទ្ធាចំពោះ
ព្រះពុទ្ធសាសនា មានបំណងឲ្យបានរស់នៅជាន់ក្នុងលោកនេះ ដើម្បី
សាងកុសលសំអាតមនុស្ស , សូមឲ្យការប្រតិបត្តិរបស់យើងបានបរិសុទ្ធ ,

សូមសម្បត្តិទ្រព្យយើងខ្ញុំបានជាការចំណាយក្នុងផ្លូវធម៌ ហើយយើងខ្ញុំនឹកគិតជានិច្ចដល់ព្រះនិព្វានបរមសុខ ។ ល្អឹកណាពន្លឺព្រះអាទិត្យបានដើរដល់ទីបំផុតនៃទ្វីបលោកលែងមានឡើងវិញ យើងខ្ញុំក៏សូមលាចាកផែនដីនេះទៅកាន់សុគតិភព ប្រកបដោយនាមពិរោះពិសាជានិច្ចដែរ ,, ។

នៅផ្នែកចំហៀង គេអានបានជាភាសាខ្មែរ ដែលចាប់ន័យយ៉ាងសង្ខេបបានថា ៖

« ឧកញ៉ា យស មានសទ្ធាជ្រះថ្លាបានសាងព្រះពុទ្ធរូបជាច្រើនអង្គដំកល់នៅចំកណ្តាលវត្តកុក្កជ័យ (ក្រុងឆ្ពណ៌កណ្តាល) ដើម្បីវេរថ្វាយចំពោះព្រះនាគសេនបពិត្រ (នាយកនៃអាគមនោះ) កាលពីថ្ងៃព្រហស្បតិ៍ ១៤កើត ខែអាសាធ ឆ្នាំវាល ១៤៨៨ សក(១) (រវាង គ្រិស្តសករាជ ១១) ,, ។

តាមពាក្យមានដែលស្រង់បានពីក្នុងអត្ថបទខាងលើនេះ យើងសន្និដ្ឋានបានថា ក្រុងសាខនេះ មានរូបភាពច្បាស់លាស់មកអង្កែងហើយ តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញជាច្រើន បានគេដាននឹងឃើញថា ក្រុងសាខនេះកសាងឡើងតាំងពីក្នុងកាលព្រះបាទជ័យវរ្ម័នទី ៧(២) ព្រោះគេសំគាល់បានត្រង់បែបបទរចនាជាបែបព្រះពុទ្ធសាសនាមានរូបចំលាក់នៅផ្នែងខាងពីរឿងពុទ្ធប្បវត្តិជាដើម ។ ម្យ៉ាងទៀតអ្នកស្រាវជ្រាវបានគេឃើញ ជាក្រុងសាខវត្តនេះ មានទ្រង់ទ្រាយដូចគ្នាបេះបិទនឹងក្រុងសាខតាព្រហ្ម នៅ

១- Notice sur le Wat-Nokor ដាក់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ លេខ M.S.P. M-8 ។ ២ - ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ បោះពុម្ពកាំង . ទ.ត់ ទំព័រ ៨១ ។

ខន្ធ្ចាត់ (តាកែវ) ជាន់សិល្បៈស្ថាបត្យកម្ម (Art architectural), ជាន់ធំហាំបែបផែន (Schéma) នៃប្រាសាទជាន់មូល ។ បើយើញដូចនេះ យើងចាប់សេចក្តីបានថា សេចក្តីសន្និដ្ឋានខាងលើ សមហេតុផលហើយ ព្រោះថាកន្លះរដ្ឋកាលនៃព្រះចាន់ជយវរ្ម័នទី ៧ រវាងសតវត្សទី ១៣ ពិតជាព្រះអង្គទ្រង់បានពង្រីកពុទ្ធសាសនាមែន ដែលពីរដ្ឋកាលមុន ។ មក ពុំសូវបានជុះជាលខេ ។ សកម្មភាពនេះរកដោយសារសេចក្តីផ្តើមគំនិតរបស់ព្រះនាងឥន្ទ្រទេវី ជាព្រះអគ្គមហេសីនៃព្រះអង្គ ។

បន្ទាប់ពីប្រាសាទដែលមានវិហារសង់ច្នៃក្បាច់ជាមួយផង នៅចំកណ្តាលបរិវេណដែលគោលមកនេះ ខេសចរអាចធ្វើដំណើរបានតាមច្រាំងខ្ពស់រំញោលហើយចេញតាមចន្លោះខ្លោងទ្វារខាងលិចព័ទ្ធទៅឆ្ងែកបាន ទៅស្តាំក៏បាន គឺចេញផុតពីបរិវេណកំពែងទី ៣ ហើយ ។ តទៅវិញយើងទៅកន្លែងបរិវេណទី ២ បើងាកទៅខាងឆ្វេងមុន យើងប្រទះតុហាពីរនៅខន្ធឹមគ្នា គឺមួយខាងលិចមានតែព្រះពុទ្ធរូបតូចធំជាច្រើនដំកល់កន្លះខោះ ឯមួយទៀតខាងកើត មានជញ្ជាំងដិតជិតស្រួលបួលដំកល់ព្រះពុទ្ធរូបបន្តិចៗតាមច្រវែងពីព្រះសិរដល់ព្រះបាទប្រមាណជា ១០ ម៉ែត្រ ។ លុះដើរហួសពីនេះ ងាកព័ទ្ធទៅចំហៀងខាងស្តាំវិញ យើងឃើញតុហាពីរខន្ធឹមគ្នាដែរ គឺមួយខាងលិចគ្រាន់តែជាទីដំកល់ព្រះពុទ្ធរូបតូចធំប៉ុណ្ណោះ ឯមួយទៀតខាងកើតវិញឃើញមានចេតិយមួយយកឥដ្ឋជាបរិវារ លាបលន្ទពណ៌ក្រហមក្រមៅ(១)

១- ចេតិយនេះ ដែលព្រឹទ្ធាចារ្យនិយាយថាជាចេតិយយាយពៅអ្នកព្រាហ្មណ៍ ដែលតាត់សំពះឆ្ពោះមកពេក ។

ខ្ពស់មានព្រះពុទ្ធរូប ៤ ព្រះអង្គ ក្នុងមួយអង្គ ។ មានទំហំកែនប្រមាណជា ជាង ១ ម៉ែត្រ តង់ព័ទ្ធជុំវិញបែរព្រះភក្ត្រឆ្ពោះទៅកាន់ទិសធំៗទាំងបួន ។

កាលណាយើងធ្វើដំណើរចេញពីទីនេះទៅទៀត សង្ស័យតាមកំពែងថ្មជាន់ទី ២ ត្រង់ជ្រុងខាងជើងចំ យើងអាចចេញបានតាមចន្លោះថ្មដែលរុះធ្លាក់មកនៅតាមនឹងដី , ហើយយើងប្រទះឃើញស្រះបុរាណយ៉ាងធំមួយទៀតប៉ុនគ្នានឹងស្រះនៅពីមុខគុហាតាព្រហ្មដែរ ។ ចាប់ពីមាត់ស្រះទៅលិច មានកុដិ-សាលាជាអាគារមួយទៀត ដែលអ្នកស្រុកហៅថា „ វត្តនគរកុង ,, ។

ការពិសោធន៍ប្រាសាទបុរាណនេះ ពុំមែនជាការងាយប៉ុន្មានទេ ព្រោះបរិវេណតូចល្មម ហើយគ្មានថ្នាក់ថ្នៃឲ្យយើងពីចុកឡើងចុះឡើយ ។ ដូច្នេះ យើងអាចចូលទៅពិសោធន៍បានត្រឹមពេលឲ្យតែជាវេលាថ្ងៃ ប៉ុន្តែបើជួនជាយើងដើរមើលនៅពេលរសៀលតាមវិញ យើងនឹងមានចិត្តអណ្តែតអណ្តូងថ្ងៃក្រោយ ព្រោះប្រទះនឹងព្រះសុរិយាដែលហៀបនឹងអស្តង្គត ហើយចាប់ផ្តើមសាបតំរែតំរងស្ងើជះមកពេញលើប្រាង្គណ៍ នឹងកំពែងថ្ម ជាប់ជាមួយក្លិនប្រហើរនៃដើមស្រូវដែលនៅក្នុងវាលស្រែ ព័ទ្ធជុំវិញបុរាណស្ថាននេះ ហាក់ដូចជាក្លិនក្រអូបនៃកិត្តិនាមខ្មែរ ដែលធ្លាប់មានមកពីអតីតកាលហើយ ។


អនុសំវច្ឆរមហាសន្និបាទនៃមន្ត្រីសង្ឃលើកទី ២០

គ.ស. ១៩៦៤

អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ២០ បានធ្វើពីថ្ងៃពុធ ៨ កេីត ដល់ថ្ងៃចន្ទ ១៤ កេីតខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥០៦ (៨-១-៦៤) នៅវត្តបទុមវតីកដវាកម នីឯវត្តទុណ្ណាលោម ក្រោមព្រះរាជាធិបតីភាព នៃសម្តេចព្រះសង្ឃរាជតំណាងព្រះគណៈ ។

ថ្ងៃទី ១

ថ្ងៃពុធ ៨ កេីតខែបុស្ស (៨-១-៦៤) វេលាម៉ោង ១៤ នឹង ៣០នាទី ម៉ោង ១៥ ជាពេលចេីកទុកាសធ្វេីមហាសន្និបាត នៃមន្ត្រីសង្ឃតំណាងព្រះគណៈដោយលោក ព័យ-ប៊ុក នាយកការិយាល័យក្រសួងជម្នះ លោក យីន-ចីម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ លោក តែ-ម៉ុងហាប់ អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ព្រមទាំងសហការីឯទៀតផងដែរ បានអញ្ជេីញជូនជំណេីរទៅកាន់វត្តបទុមវតី នីឯវត្តទុណ្ណាលោមផង ដេីម្បីចេីកសម័យប្រជុំមហាសន្និបាតសម្រាប់ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥០៦ ។



សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងព្រះសុន្ទរកថា នៅឧកាសពិធីអនុស្សាវរីយ៍ មន្ត្រីសង្ឃលើកទី ២០ នៅយ៉ាពុទ្ធិកវិទ្យាល័យ
ព្រះសុភម្រឹត ថ្ងៃទី ១០-១-៦៤

ថ្ងៃទី ២

ថ្ងៃព្រហស្បតិ៍ ១០ កេីតខែបុស្ស (៨.១.៦៤) ពេលម៉ោង ៨ ព្រឹក មានការនិមន្តព្រះសង្ឃគាំង៩ព័រគណៈ ចំនួន ៤០អង្គ ចំរេីនសត្តប្បកណាកិធម្ម ១ក្ខិសព្រះរាជកុសលថ្វាយព្រះចិតារ នៅចេតិយគាំងគួងាង មុខព្រះវិហារព្រះកែវមរកត ។ នៅម៉ោង ១០ នឹង ៣០ នាទី ព្រះសង្ឃគាំង៩ព័រគណៈ:ខួលចង្ហាន់ថ្ងៃត្រង់នៅវត្តបទុមវតី នឹងវត្ត១ណ្ណាលោម ចំពោះមុខអនុរដ្ឋលេខាធិការក្រសួងធម្មការ ។

ថ្ងៃទី ៣


ថ្ងៃសុក្រ ១១ កេីតខែបុស្ស (១០.១.៦៤) ពេលម៉ោង ៨ ព្រឹក ក្រសួងធម្មការ បានបេីកអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលេីកទី ២០ នៅយីនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ ។

ចាប់តាំង៩ព័រម៉ោង ៧ នឹង ៣០ នាទីៗ នៅតន្លែងប្រារព្ធពិធីនោះ គេសង្កេតឃេីញផ្នែកខាងបព្វជិត គឺ សម្តេចព្រះសង្ឃរាជគណៈ:មហានិកាយ សម្តេចព្រះសង្ឃរាជគណៈ:ធម្មយុត្តិកនិកាយ ព្រះពោធិវង្ស-ហួត-តាត ចាងហ្វាងខួរនៃពុទ្ធិកសិក្សា ព្រះសង្ឃជាពជាគណៈ:ហានាខួក្រម មេគណ អនុគណ គ្រប់ខែត្រ-ស្រុក ចៅអធិការគ្រប់វត្តក្នុងរាជ

ធានី ព្រមទាំងព្រះសង្ឃជាច្រើនរយអង្គទៀត ដែលនិមន្តមកពីវត្តនានា
ក្នុងក្រុងនិងខេត្តក្រៅ ដើម្បីរួបរួមក្នុងមហាសន្និបាតនេះ ។

ផ្នែកខាងត្រហាំ គេសង្កេតឃើញ សម្តេចព្រះស្វាន្តវឌ្ឍនាភ-
ក្ញាចំរើនវង្ស ប៉ែង-ខៀ៉ះ យុគន្ធរ សម្តេចវ៉ាងវរវៀងជ័យអធិបតីស្រីង្គារ
ម៉ែន-នុត ទីប្រឹក្សាអមព្រះអង្គ ឯកឧត្តម អ៊ឹង-ហុងសាង ប្រធានវង្សសភា
អ្នកអង្គម្ចាស់នរោត្តម ម៉ុងតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ
អ្នកអង្គម្ចាស់នរោត្តមកន្តុល នាយករដ្ឋមន្ត្រី សមាជិកខ្លះនៃសភាតំណាង
និងសមាជិកខ្លះនៃរាជរដ្ឋាភិបាល ព្រមទាំងវរជនឯទៀតជាច្រើនដែល
យើងសូមអភ័យទោសដោយមិនបានរាប់នាមក្នុងទីនេះ ខាងក្រសួងធម្មការ
មានសហជីវិន មែន-ណុំ អនុរដ្ឋលេខាធិការក្រសួងធម្មការជាអ្នកចាត់ចែង
តិចិ សហជីវិន ង៉ែយ-ប៊ុក នាយកការិយាល័យ ព្រមទាំងមន្ត្រីតំណាងក្រ
សួងនានា ប្រធានពុទ្ធិកសមាគម ប្រធានពុទ្ធិកសមាគមវិទ្យាល័យព្រះសុក-
ម្រិត ប្រធានសមាគមគិលានសង្គ្រោះ សាស្ត្រាចារ្យនៃពុទ្ធិកមហាវិទ្យា
ល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុកម្រិត ព្រមទាំងមន្ត្រី
ភ្នាក់ងារពាណិជ្ជកម្មនិងប្រជាពលរដ្ឋជាច្រើនរូបទៀត ចូលរួមដង្ហែរ
មក ដើម្បីរួបរួមជាកិត្តិយសក្នុងពិធីនេះដែរ ។

នៅវេលាម៉ោង ៨ និង ៣០ នាទី សម្តេចព្រះប្រមុខរដ្ឋ ដោយមាន
សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារផ្ទាល់ព្រះអង្គអម



ព្រះសង្ឃកំពុងគង់ស្តាប់ ព្រះសុគន្ធរោចា នៃសម្តេចព្រះប្រមុខរដ្ឋ នៅទីកាសព៌ាធអនុស្សាវរីយ៍សង្ឃនៃលើកទី ៦០
ថ្ងៃទី ១០ - ១ - ៦៤ នាយ៉ាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

ព្រះកដដំណើរផង ជានេះស្តេចយាងមកដល់កន្លែងប្រារព្ធពិធី ដោយ
បានទទួលការកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីក្រុមចាហានរក្សាព្រះអង្គ ដែលលើក
ការពារធ្វើនូវកិច្ច ទីដែលបន្ទូរបទភ្លើងចរលើសាថ្វាយជាព្រះកដកិត្តិយស ។

បន្ទាប់មក សម្តេចឥ ទ្រង់បានទទួលការគ្រាបថ្វាយបង្គំអំពីឥស្សរជន
ជាន់ខ្ពស់នៃមន្ត្រីអ្នកការងារជាន់ឆ្លាយ ដែលរង់ចាំគ្រាបថ្វាយបង្គំសំដែង
សេចក្តីស្វាមីភក្តិចំពោះព្រះអង្គនៅក្បែរទ្វារចូល ហើយដង្ហែព្រះកដដំណើរ
ចូលទៅថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជជាន់ឥតណេះ
ជាប្រធាន ។ ខណៈនោះ បទភ្លេងជាតិកំបន្ទរឡើងជាគ្រឿងញ៉ាំងកម្ម
វិធីឲ្យប្រព្រឹត្តទៅដោយសភាពយ៉ាងរុងរឿងក្រៃលែង ។

សូមបញ្ជាក់ថា នៅតាមដងផ្លូវពីមុខមន្ទីរដ្ឋសភាមកដល់ពុទ្ធិកមហា
វិទ្យាល័យព្រះសីហនុកដ មានប្រជាពលរដ្ឋជារាប់ពាន់នាក់បានឈរ
រំពង្គណាប់តកស្រាប់ ដើម្បីរង់ចាំតោរពនមស្ការថ្លែងសេចក្តីគោរពចំពោះ
សម្តេចព្រះបិតាឯករាជ្យជាតិ ជាទីស្នេហានឹងជាទីរលឹករបស់ខ្លួន ហើយ
បានទះដៃថ្វាយព្រះពរជយយ៉ាងកងរំពងនឹងយ៉ាងយូរ នៅវេលាដែល
សម្តេចជាអម្ចាស់ស្តេចយាងមកដល់ ។

ក្រោយដែលសម្តេចឥ ព្រះបិតាឯករាជ្យជាតិ ស្តេចតង្គំប្រថាប់លើ
ព្រះសុវណ្ណកោដ្ឋៈ ក្នុងយានៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត សម្រួលព្រះឥ
យាបថហើយ ព្រះសង្ឃក៏បានស្វាធ្យាយធម្មដេរន្តាប្រសិទ្ធិពរថ្វាយ

ចំពោះសម្តេចព្រះប្រមុខរដ្ឋ ដើម្បីជាសុភមង្គលដ៏ប្រសើរចំពោះព្រះអង្គ
សុះស្រេចហើយ សហជីវិន ម៉ែន-ឈុំ អនុវុដ្ឋលេខាធិការក្រសួងធម្មការ
បានថ្លែងសុន្ទរកថាថ្វាយព្រះពរស្វាគមន៍ចំពោះព្រះអង្គ ។ ឯសុន្ទរកថានេះ
យើងបុះផ្សាយនៅចំព័រខាងក្រោយ ។

បន្ទាប់ពីសុន្ទរកថាស្វាគមន៍នៃសហជីវិន ម៉ែន-ឈុំមក ព្រះតេជព្រគុណ
កែ-អឿន មេគណខេត្តសៀមរាប បានថ្លែងសុន្ទរកថាមួយក្នុងនាមនៃ
មន្ត្រីសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជជាំង ព័រគណៈជាប្រធាន ដោយ
បញ្ជាក់អំពីការប្រព្រឹត្តទៅប្រកបដោយការរីកចំរើនយ៉ាងប្រពៃ នៃពុទ្ធសា-
សនា ក្នុងកម្ពុជរដ្ឋជាំងមួល ក្នុងសម័យសង្គម ។

តមក សម្តេចព្រះបិតាឯករាជ្យជាតិ បានថ្លែងព្រះសង្កត់ថាឥតព្រាង
ទុកមួយ បញ្ជាក់អំពីការកសាងនិងសមិទ្ធិថ្មី ។ ជាអស្ចារ្យរបស់សង្គម
ករស្ត្រនិយម ចាប់តាំងពីអនុសំវច្ឆរៈ ទី ១៩ មកដល់អនុសំវច្ឆរៈ ទី ២០
នេះ និងនយោបាយក្នុងប្រទេស ក្រៅប្រទេស ក្នុងបច្ចុប្បន្ន ដោយ
ទ្រង់ដៅបញ្ជាក់ថា ព្រោះតែយើងតាន់យាំងខ្លាច់ខ្លួនទូរអញ្ជាក្រែតមិន
សំអៀនទៅថ្កុកកុមួយនិស្ត ឬ លោកសេរីនេះហើយ ទើបកម្ពុជរដ្ឋយើង
បានទៅជាគោះសន្តិភាពមួយកន្លះពិភពលោក ។

លុះចប់ព្រះសង្កត់ថាដ៏មានខ្លឹមសារនេះហើយ សម្តេចព្រះបិតាជាតិ
ទ្រង់ក៏ក្រាបថ្វាយបង្គំលាព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជជាំង

ព័រគណៈជាប្រធាន ហើយដោយមានព្រះពុទ្ធបរិពារជាច្រើនអមដង្ហែបាន
ស្តេចយាងនិវត្តចូលព្រះបរមកដ៏ឥតវិញ ដោយព្រះសុត្តិភាព ។

ពិធីនេះ បានចប់សព្វគ្រប់នៅវេលាម៉ោង ១១ នឹង ៣០ នាទី ក្នុង
បរិយាកាសដ៏ជាទីសប្បាយរីករាយ ។

ចាប់តាំងពីថ្ងៃទី ១២ រហូតដល់ថ្ងៃទី ១៣ មករា ១៩៦៤ ព្រះ
សង្ឃគាំងពីគណៈប្រជុំនៅវត្ត ១ ណ្ណាលោម នឹងវត្តបទុមវតី ក្រោមព្រះ
ពុទ្ធជាបតីភាពនៃសម្តេចព្រះសង្ឃរាជគាំងពីគណៈ ដែលព្រះអង្គទ្រង់ចាត់
ចែងធ្វើ ។

សេចក្តីប្រកាសស្តីពីពិធីអនុស្សាវរីយ៍មហាសន្និបាតលើកទី ២០ នៃ
មន្ត្រីសង្ឃ ក្នុងព្រះពុទ្ធសាសនាចក្រកម្ពុជាឯករាជ្យ ចប់តែប៉ុណ្ណេះ ។

សុន្ទរកថា

សហជីវិន ម៉ែ ង - ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ

សូមព្រះតេជៈដ៏តលើសលើតួង

សូមព្រះពុទ្ធជានក្រាបបង្គំទូលសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមក្រសួងធម្មការនិងសាសនសិក្សាធិការ ខ្ញុំសូមព្រះពុទ្ធជានព្រះបរមកដវរៀកាស ថ្វាយនូវអំណរព្រះមហាករុណាគុណដ៏លើសលុប ដោយកតញ្ញូធម៌យ៉ាងស្មោះជាទីបំផុត ចំពោះសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ដ៏ជាទីគោរព ជាទីស្នេហានៃពលរដ្ឋទូទៅ ដែលទ្រង់សព្វព្រះពុទ្ធហឫទ័យ ស្តេចយាងមកជាព្រះពុទ្ធធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឧកាសបើកពិធីអនុស្សាវរីយ៍មហាសន្និបាតទី ២០ នៃមន្ត្រីសង្ឃ សម្រាប់ឆ្នាំថោះបញ្ចស័ក ព.ស. ២៥០៦ ។ ព្រះពុទ្ធកាយវិការដ៏វិសេសនេះ ខ្ញុំបាទសូមលើកតំកើងតលើសលុបលើសិរសា ព្រោះក្នុងបច្ចុប្បន្នកាលនេះ ព្រះអង្គកំពុងមានព្រះពុទ្ធករណីយកិច្ចដ៏មមាញឹក ចំពោះការស្ថាបនាជាតិជាច្រើនយ៉ាង មានទ្រង់កែទម្រង់នយោបាយសេដ្ឋកិច្ច ខិតខំហ៊ានវាតជាដើម ។

សូមព្រះតេជៈតំកល់លើតួង សូមព្រះពុទ្ធជានព្រះបរមកដវរៀកាសថ្វាយ ក្រាបបង្គំទូលសម្តេចព្រះសង្ឃរាជ-ព្រះសង្ឃរាជគណៈហានានុក្រម-



សម្តេចព្រះប្រមុខរដ្ឋ និងសម្តេចព្រះមហាសង្ឃរាជទី ១ ទ្រង់កំពុងសន្ទនា នៅទីពាស
ពិធីអនុស្សាវរីយ៍មន្ត្រីសង្ឃ លើកទី ២០ នៅយំពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត ថ្ងៃទី
១០ - ១ - ៦៤

មេគណ អនុគណនិងឱវាទាចារ្យគ្រប់ព្រះតំណ ដែលនិមន្តមកពីក្នុងក្រុង
និងខេត្តក្រៅនានា ក្នុងឱកាសសាធារណភាព ។

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជ :

សូមពិតប្រាកដជាតា ព្រះគុណាត្រប់ព្រះអង្គ :

ខួលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះគុណា សូមថ្វាយអំណរព្រះគុណយ៉ាងក្រៃលែងចំពោះសម្តេចព្រះសង្ឃរាជ និងព្រះគុណាត្រប់ព្រះអង្គ ដែលបានស្តេចយាង និមន្តមកគាន់រីប្រជុំសន្និបាតនេះជាកិត្តិយស ដើម្បីភ្ញាំងពិធីនេះ ឲ្យរឹងតែតែបានរុងរឿងឡើងជាតិយ៉ាកាត ។

សូមព្រះតេជៈតំកល់លើត្បូង :

នៅក្នុងឆ្នាំដែលកន្លងទៅនេះ ក្រសួងធម្មការនិងសាសនសិក្សាធិការបានចាត់ការខាងផ្នែកព្រះពុទ្ធសាសនា តាមគម្រោយព្រះមាតានយោបាយនៃសម្តេចជាអម្ចាស់ ដែលព្រះអង្គតែងតែទ្រង់លើកជារឿយ ។ ថា: ការស្តាប់នាជាតិនិងច្តើងរុងរឿងបានដោយអាស្រ័យការចំរើនស្មើ ។ គ្នាត្រប់វិស័យ មានវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ជាដើម ។

ដូច្នេះ ក្រសួងធម្មការដែលជាផ្នែកមួយខាងវប្បធម៌ ក៏បានរំលឹកនៅក្នុងការកិច្ចនេះ មានការសិក្សាខាងទូរព្រះពុទ្ធសាសនានិងទូរលោកការចុះត្បូងផ្សាយសៀវភៅសិក្ខាច្បាប់ផ្សេង ។ ការរៀបចំទូរតម្រាប់តម្រាប្បំប្បុកណារបស់ជាតិ ការតាំងជាបណ្ណាល័យសាធារណៈ និងការប្រ

ម្ចាស់ផ្ទះឯកសារចំនៀមទម្លាប់ប្រពៃណីរបស់ប្រទេស ដែលអាស្រ័យតាមរបបរស់នៅរបស់ជាតិតាំងពីព្រេងនាយ រហូតមកដល់បច្ចុប្បន្នកាលនេះ ។ កាលបើស្រាវជ្រាវរកវិវរកបានគ្រាសក្រែលហើយ ក្រសួងធម្មការបានចាត់ការបោះពុម្ពផ្សាយឲ្យប្រជាពលរដ្ឋទូទៅ បានជ្រាបច្បាស់នូវរឿងរ៉ាវស្រុកខេត្តរបស់ខ្លួន ដែលជាហេតុដឹកនាំឲ្យមានទំនុកស្រឡាញ់ជាតិកាន់តែច្បាស់ឡើង ទំនងឲ្យជុះស្មារតីថ្មី ។ សម្រាប់ជួយជ្រោមជ្រែងក្នុងការកសាងប្រទេសជាតិ តាមផែនការដ៏ធ្ងន់ធ្ងរនៃសម្តេចសហជីវិនជាអម្ចាស់ត្រួតការ: ខេត្ត: ។ មិនតែប៉ុណ្ណោះ អាស្រ័យដោយព្រះមាតានយោបាយអត្សាក្រឹត ដែលសម្តេចទ្រង់បានស្ថាបនាឡើង ការបោះពុម្ពនេះក៏បានផ្សាយទៅ ជាការផ្គាស់ប្តូរវប្បធម៌ជាមួយប្រទេសជាមិត្តនានាក្នុងលោក ។

រីឯការរៀនសូត្រ នៅក្នុងពុទ្ធិកឧត្តមសិក្សា មធ្យមសិក្សា ទំនងបឋមសិក្សា កម្មវិធីបានតម្រូវឲ្យមានរៀនវិជ្ជាផ្លូវធម៌ ទំនងផ្លូវលោក ដើម្បីអប់រំបណ្តុះនិស្ស័យសមណនិស្សិត ដែលជាអនាគតពលរដ្ឋខ្មែរនោះ ឲ្យក្របដណ្តប់នូវសឯកជ្ឈជាតិបានជាក់ច្បាស់ ទំនងឲ្យរៀបចំចរិយាស្របទៅនឹងព្រះពុទ្ធនយោបាយរបស់សម្តេចក្នុងការកសាងជាតិ ។ ព្រោះជាស្ថាប័ននានាក្នុងព្រះពុទ្ធសាសនា ទំនងថ្កើងថ្កើងទៅបានក៏អាស្រ័យដោយស្រុកខេត្តបានចំរើនផលិតផល ប្រជាពលរដ្ឋមានជីវភាពរុងរឿង ។

ការដែលសម្តេចទ្រង់តែងម្រង់សេដ្ឋកិច្ច ដែលបានប្រកបដោយជោគជ័យ កិតិតជាធ្វើឲ្យព្រះពុទ្ធសាសនាមានដំហរធំបុងស្គុកស្គម្ភជាកំយោភាពតទៅ ។

អាស្រ័យដោយព្រះមាគាំនយោបាយរបស់សម្តេចឧដ៏ស័ក្តិសិទ្ធិនេះ បានជាព្រះសង្ឃជាច្រើនរូបយើង ព្រះអង្គបានយកព្រះទ័យទុកដាក់ជួយអប់រំពុទ្ធបរិស័ទឲ្យជ្រះថ្លាក្នុងការកសាងជាតិ មានការកសាងមន្ទីរពេទ្យ កសាងសាលារៀន ការលើកទំនប់លើកថ្នល់សាធារណៈ ទឹងការជាំកូនឈើក្នុងវត្ត ទឹងទំស្រែចំការជាដើម ។

កាយវិការទឹងសម្តីទ្រង់សំខាន់ ។ ចាំងនេះ គឺពិតជាកើតឡើងដោយសារតម្រាយយ៉ាងពិសិដ្ឋរបស់សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ ទឹងព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ដ៏ឆ្នើមរបស់ខ្មែរ ព្រោះត្រង់ពេលដែលព្រះអង្គទ្រង់យាងទៅធ្វើព្រះកដឋស្សនកិច្ចទៅទីទាំងនានា ព្រះអង្គតែងថ្លែងជាសំឡេងកូនចៅកន្លងមកសាងជាតិទឹងវិស័យកសាងព្រះពុទ្ធសាសនា ហើយទ្រង់ជាន កសាងផ្ទាល់ព្រះអង្គផង ។ តាហារណ៍: ដូចព្រះអង្គទ្រង់ចំណាយព្រះកដទ្រព្យច្រើនលើសលុប កសាងព្រះវិហារវត្តអាកម មានវត្តនៅខេត្តតេនតិរីនៅក្រុងព្រះសីហនុ ទឹងគ្រឹះស្ថានថ្មី នៅពុទ្ធិកវិទ្យាល័យនេះជាដើម ។ ព្រះកាយវិការដ៏ប្រពៃទាំងនេះ បញ្ជាក់ឲ្យខ្ញុំព្រះបង្គំជាខ្ញុំត្រចំគ្នាយល់ច្បាស់ថា: ព្រះកដឋល្ងន្តដែលមានសម្តេចព្រះមហាក្សត្រីយានី ទឹងឆ

សម្តេចសហជាវិន ទ្រង់ជាទិម្តក្តរូបក្នុងវេលានេះ ទ្រង់កសាងជាតិ សាសនាជាកង់តុទ្ធចក្រទ្រង់ឯអាណាចក្រ ឲ្យវិលលៀនទៅស្របគ្នាជាដរាបជាកស្តុតាងដូចជាតីអតីតកាល ព្រះមហាក្សត្រសម័យអង្គរ ទ្រង់ចាន់ស្តាបនាខ្នងតឹកទៅចាកយណ៍ ស្តាបនាមន្ទីរព្យាលភេតជាច្រើនអន្ទឹកឆ្ងាយក្នុងអាណាចក្រ ទ្រង់ស្តាបនាផ្លូវថ្នល់ពីអង្គរមកទុតុង្គ លុះមកដល់រជ្ជកាលព្រះករុណាព្រះចាន់សម្តេចព្រះអង្គខ្លួន ព្រះបរមរាជ្ជ ព្រះអង្គទ្រង់ស្តាបនាផ្លូវពីទុតុង្គទៅកម កសាងវត្តអារាមយ៉ាងច្រើន ទ្រង់រៀបរៀងក្បួនច្បាប់តម្រាប់តម្រាជាភាសាជាតិ ហើយតមកព្រះករុណាព្រះចាន់សម្តេចព្រះនរោត្តម ទ្រង់ចាន់សាងព្រះវិហារព្រះវែតរមកិត ព្រះករុណាព្រះចាន់សម្តេចព្រះស៊ីសុវត្ថិ ព្រះអង្គទ្រង់ចាន់បង្កើតព្រះពជបណ្ណាល័យ សាលាចាលី មន្ទីរពុទ្ធសាសនបណ្ឌិត្យ ព្រះករុណាព្រះចាន់សម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះអង្គទ្រង់ចាត់ឲ្យប្រែព្រះត្រៃបិដក ។ លុះមកដល់បច្ចុប្បន្នសម្តេចសហជាវិនជាអម្ចាស់ ព្រះអង្គទ្រង់ចន្ទព្រះពជរបស់កម្ពុជាថ្ងៃថ្ងាន់នេះ ហើយទ្រង់ចាន់ពន្រីកព្រះសកម្មភាព ឲ្យរឹងតែងធំទូលំទូលាយឡើងទៀត ។ ការទុបត្ថម្ភព្រះពុទ្ធសាសនានៃសម្តេចសហជាវិនជាអម្ចាស់ពុំត្រឹមតែក្នុងប្រទេសប៉ុណ្ណោះទេ គេឃើញក្រៅប្រទេសក៏ដោយ ឲ្យតែមានអ្វីជាទុបស័គ្គដល់ព្រះពុទ្ធសាសនា ព្រះអង្គតែងទ្រង់ព្រះតម្រិះដល់ជានិច្ច ដូចជាជួយគាំទ្រព្រះពុទ្ធសាសនា នៅវៀតណាមខាងត្បូងនៅពេល

មានតេយ្យាយើដ៏ជាន់កង់ត្រាមុននេះជាដើម ។ ពាំងនេះជាព្រះគុណូបការៈ
ដ្ឋន់អនេកនៃព្រះរាជបល្ល័ង្ក ។

កង់តេលដែលព្រះអង្គទ្រង់ឃាងមកជាព្រះរាជាធិបតីភាព នាវេលានេះ
-ក៏នើរតែបញ្ជាក់ទូវព្រះគុណូបការៈ ខ្ញុំដឹងគឺព្រះទ័យជ្រះថ្លារបស់ព្រះ
អង្គក្នុងការជ្រោមជ្រែងជល់កង់តុន្ធចប្រ ខ្ញុំដឹងអាណាចក្រទ្យវជ្រឿនលឿន
ទៅមុខជាមិនខ្លាំ ។

ជាអាសាន ទូលព្រះបង្គំជាខ្ញុំ សូមលំទតលំនុនកាយទុំសជល់
គុណព្រះរតនត្រ័យ ខ្ញុំដឹងតែស័ក្តិសិទ្ធិពាំងអស់កង់លោក មានជាមើព្រះ
អតីតមហាក្សត្រខ្មែរពាំងឡាយខ្ញុំដឹងទៅតាពាំងមុំនលោកជាតុ មានទៅតា
ស្វែតច្ចត្រនៃប្រទេសកម្ពុជានេះជាដើម សូមលោកជួយពិភ័ក្សាអង្គសម្តេច
ព្រះមហាក្សត្រីយានី ខ្ញុំដឹងសម្តេចព្រះទបយុវរាជជាម្ចាស់ សូមព្រះអង្គ
ប្រកបដោយព្រះបរមសុទសួស្តី មានព្រះជន្មាយុយឺនយូរ ដើម្បីបានជាម្ចប់
ដ៏មហាត្រជាក់នៃតលរដ្ឋខ្មែរទូទៅ ហើយសូមព្រះអង្គបានឈ្នះអស់មារ
សត្រូវ ពាំងកង់ប្រទេស ពាំងក្រៅប្រទេស គ្រប់ទិសទី កុំបីបៀតបៀនព្រះ
អង្គតទៅ :

សូមព្រះតេជៈតំកល់លើត្បូង :

រឿងតាំងចៅអធិការសម្រាប់វត្តនានា

តារាងឈ្មោះនាមព្រះតេជព្រះគុណដែលបានទទួលសញ្ញាប័ត្រ
ចាត់តាំងជាចៅអធិការនៃគ្រូសូត្រនៃវត្តនានា ក្នុងព្រះរាជអា
ណាចក្រ ចាប់ពីឆ្នាំ ១៩៦២

១– ព្រះតេជព្រះគុណ ព្រាប-អ៊ុម នាមឆាយាធម្មសរ កើតឆ្នាំ
ជូត អាយុ ៣៩ ឆ្នាំ វស្សា ១៩ បានទទួលការតែងតាំងជាគ្រូសូត្រក្នុង
វត្តចេតិយ ឃុំសំបួរ ស្រុកសៀមភប ខែត្រសៀមភប លេខសញ្ញាប័ត្រ
៣.៣៩៦ ចុះថ្ងៃទី ១៩.៩.៦២ ។

២– ព្រះតេជព្រះគុណ លី-សុខ នាមឆាយា ឥន្ទសិរី កើតពី ព.ស.
២៤៧៩ អាយុ ២៦ ឆ្នាំ វស្សាបាន ៦ បានទទួលតែងតាំងជាគ្រូសូត្រទ្វេន
ក្នុងវត្តចេតិយ ឃុំសំបួរ ស្រុកសៀមភប ខេត្តសៀមភប លេខសញ្ញាប័ត្រ
៣.៣៩៧ ចុះថ្ងៃទី ១៩.៩.៦២ ។

៣– ព្រះតេជព្រះគុណ ថោង-ឡុង នាមឆាយាឥន្ទសិរី កើតឆ្នាំច
អាយុ ២៨ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តកំរៀមក្រោម
ឃុំ ស្រុក ខេត្តសៀមភប លេខសញ្ញាប័ត្រ ៣.៣៩៨ ចុះថ្ងៃទី ៩-៩-
៦២ ។

៤– ព្រះតេជព្រះគុណ ពៅ-ពេជ នាមឆាយាធម្មជោត កើតពី
គ.ស. ១៩៣៤ អាយុ ២៩ ឆ្នាំ វស្សាបាន ១០ បានទទួលតែងតាំងជា

ចៅអធិការ កុដិវត្ត ព្រែកពាក ឃុំថ្នាឆ្នង់ ស្រុកដំណាល ខេត្តស្វាយរៀង លេខសញ្ញាប័ត្រ ៣.៣៩៩ ចុះថ្ងៃទី ១៩-៩-៦២ ។

៥- ព្រះតេជព្រះគុណ ស៊ូវ-នន្ទ នាមឆាយានារោ កើតឆ្នាំរកា អាយុ ២៩ ឆ្នាំ វស្សាបាន ១០ បានទទួលតែងតាំងជាចៅអធិការកុដិវត្តតេន-ទិបាកម ឃុំតន្លាធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៤០០ ចុះថ្ងៃទី ១៩-៩-៦២ ។

៦- ព្រះតេជព្រះគុណ ចេក-សំ នាមឆាយាឥន្ទសរ កើតឆ្នាំមមែ អាយុ ៣២ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ កុដិវត្តត្រែក ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០១ ចុះថ្ងៃទី ១៩-៩-៦២ ។

៦- ព្រះតេជព្រះគុណ ចាប-ផន នាមឆាយាឥន្ទសុវណ្ណ កើតឆ្នាំឆ្លូវ អាយុ ២៩ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រធ្វើ កុដិវត្តត្រែក ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០២ ចុះថ្ងៃទី ១៩-៩-៦២ ។

៨- ព្រះតេជព្រះគុណ សាត់-សែម នាមឆាយាឥន្ទសរ កើតឆ្នាំរកា អាយុ ៤២ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំវត្តបន្ទាយស្រី ឃុំដំដែក ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០៣ ចុះថ្ងៃទី ១៩-៩-៦២ ។

៩- ព្រះតេជព្រះគុណ អ៊ុន-អ៊ីន នាមឆាយាសុវណ្ណតេរ៉ កើតឆ្នាំ
ពេង អាយុ ៣៤ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាគ្រូសូត្រធ្វើង ក្នុង
វត្តបន្ទាយស្រី ឃុំដំដែក ស្រុកសូក្រនិគម ខេត្តសៀមរាប លេខសញ្ញា-
ប័ត្រ ៣៤០៤ ចុះថ្ងៃទី ១៩-៩-៦២ ។

១០- ព្រះតេជព្រះគុណ ជួន.ឌឹម នាមឆាយាជម្មសុវណ្ណ កើតឆ្នាំ
កែ អាយុ ៥៥ ឆ្នាំ វស្សា ៣២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្ត
រលួស ឃុំ ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣៤០៥
ចុះថ្ងៃទី ១៩ ៩.៦២ ។

១១- ព្រះតេជព្រះគុណ សាន់.សយ នាមឆាយាសុវណ្ណសរ កើត
ឆ្នាំ គ.ស. ១៩០៩ អាយុ ៥៣ ឆ្នាំ វស្សា ៣៣ បានទទួលតែងតាំងជា
ចៅអធិការក្នុងវត្តពោធិរាមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល
លេខសញ្ញាប័ត្រ ៣៤០៦ ចុះថ្ងៃទី ១៩.៩.៦២ ។

(នៅមានត)

បំណោទគំនិត

មានសត្វមួយ ប៉ែតែកាត់ក្បាលចេញ ក្បាយនៅជា
វត្តមានតម្លៃ ។ តើសត្វនោះឈ្មោះដូចម្តេច ?

បើអ្នកអានណា អាចកាយើញ ហើយជាខន្ធើចម្លើយត្រឹមត្រូវ
សរសើរផ្ញើនក្នុងទំព័រទស្សនាវដ្តីយើង ក្នុងលេខបន្ទាប់ ។

តម្លៃជីវិត

ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៦ លេខ ២ ខែ កុម្ភៈ

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ភ្នំពេញ -

ខ.ស.ជ្ជ ៤-៦-៦៤.



អង្គុលិសនិយម

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញារាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

	ទំព័រ
ផ្នែកសាសនា	
- វោរកថា ព្រះសាសនមុនី កឹម-ភួ ក្រុមដំណុំ ព្រះត្រៃបិដក តែងរៀបរៀង	១១១
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ូ តែងរៀបរៀង (ត)	១២៦
- ព្រះវិធូរជាតក	១៣៤
ផ្នែកអក្សរសាស្ត្រ	
- គួរតែប្រឡេះការខ្វះចោល (វិចារណកថា) លោក ផេង-ជ្រើរ និពន្ធ	១៤៩
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	១៦១
- រឿងអាថ៌លហ្គាំអ៊ូរិស៍ លោក ភ័យ-ល្មុត ដំណាងភាស្ត្រ ប្រែរៀបរៀង	១៦៣
- ល្បើកឡាហ្វុងតែន លោក ផេង-ជ្រើរ ប្រែពីភាសាជាវ៉ាំង (ត)	១៧១
- រឿងសាមកុក អ្នកនាគញ៉ាវិបុលរាជសេនា ឆូ-ពាន ប្រែរៀបរៀង (ត)	១៧៦
- រឿងព្រេងចិន (ការសង់ស៊ីកនៃទន្លេយ) លោក ភ័យ-ប៊ុក ប្រែពីភាសាជាវ៉ាំង (ត)	២០៧
- ទំនៀមទម្លាប់ខ្មែរ លទ្ធផលនៃការប្រឡងទំនៀមទម្លាប់ខ្មែរ ក្នុងជម្មាសទី ២ ឆ្នាំ ១៩៦៣	២១០
ផ្នែកកំណត់ទីធ្លប្រវត្តិការណ៍	
- ប្រវត្តិនៃវត្តប្រាង្គ រៀបរៀងដោយព្រះគេជព្រះគុណព្រះពោធិវង្ស ហូត-ខាត អគ្គាធិការនៃពុទ្ធិកសិក្សា	២១៥
- រឿងតាំងលើអធិការ និងគ្រួសក្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ	២២២
- ដំណឹងពីពុទ្ធសាសនបណ្ឌិត្យ	២២៨

មួយឆ្នាំមាន ១២ លៀវភៅ តម្លៃជាវ ២៣០០

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការណែនាំ	ឲ្យធ្វើល្អទៅ
ឲ្យចិត្តស្អាតស្អំ	កុំឲ្យហួងហែង
ជីវិតនេះលោកហៅ	ពុទ្ធសាសនា

ប.ព.

រឿងកថា

ព្រះសាសនមុនី កើម-ទូ ក្រុមដំទុំព្រះត្រៃបិដក

តែងរៀបរៀង

ឥ ហិ រោរេន រោរានិ សម្មុន្នីធ កុទាចនំ អរោរេនប សម្មុន្នី ឯសធម្មោ សនន្តនោ ។ ប្រែថា : ភ្លៀងធំនឹងឮ ក្នុងលោកនេះ មិនដែលរម្ងាប់ដោយភ្លៀង ក្នុងកាលណាម្តងទេ ភ្លៀងធំនឹងរម្ងាប់បាន ដោយសារតែមិនមានភ្លៀងប៉ុណ្ណោះឯង ធម៌នេះជាបវេណីរបស់អ្នកប្រាជ្ញពីបូរាណ ។

រឿងខាងក្រោមនេះ ជាខបញ្ចាក់នូវពុទ្ធទស្សនាខ្លះ ។

ជម្លោះរវាងក្អែក និង មៀម

ក្នុងសម័យដែលព្រះពុទ្ធជាបរមគ្រូនៃយើងទាំងឡាយ ទ្រង់ប្រថាប់គ្រាស់ដីនៅក្នុងលោកហើយ ព្រះអង្គទ្រង់គង់នៅវត្តជេតពន ជិតក្រុងសាវត្ថី ។ ជម្លោះរវាងក្អែកនិងមៀម បានតែមានជាខ្លឹមជាប់តាំងពីព្រេងនាយមក ជួនកាលក្នុងវេលាថ្ងៃ ក្អែកដេញចឹក

សម្ងាប់មៀម ដល់រសៀលយប់ មៀមដេញចឹកសម្ងាប់ក្អែកវិញ ពីព្រោះក្អែកមៀមភ្លឺកន្លងពេលយប់ជាងពេលថ្ងៃ ។ ជួនកាលយប់ខ្លះ មៀមចឹកសម្ងាប់ក្អែកអស់ជាច្រើន ក្អែកខ្លះដាច់តង្កាក់ចុះពីលើដំណើរឈើមកលើដែនដីត្រង់អាស្រមរបស់តិក្ខមួយរូបដែលនៅក្នុងទីបរិវេណដ៏តព្រំត្រង្គដេតតនជាកន្លែងដែលលោកតែងបោសសំអាតជាប្រក្រតី ។ ពេលតែព្រឹក តិក្ខុនោះតែងតែយើញក្អាលក្អែកជាច្រើនក្បាលធ្លាក់ចុះមកក្នុងទីដ៏តអាស្រមរបស់ខ្លួន ក៏យកហេតុនោះទៅប្រាប់តិក្ខុតាំងឡាយ តិក្ខុតាំងនោះនាំរឿងដ៏ចំឡែកនោះទៅក្រាបបង្គំទូលព្រះពុទ្ធជាម្ចាស់ទៀត ទើបព្រះអង្គទ្រង់សម្តែងថា ម្នាលតិក្ខុតាំងឡាយ ក្អែកនិងមៀម នោះ ដែលតើតហេតុឈ្លោះតាស់ទែងនិងគ្នា មិនមែនទើបតែនឹងមានក្នុងកាលឥឡូវនេះទេ គឺមានតាំងតែពីដើមមកជាយូរអង្វែងណាស់មកហើយ ។ តិក្ខុតាំងឡាយ ក្រាបទូលសួរថា ចុះក្អែក នឹង មៀម ដែលមានពំនៀរនឹងគ្នាយ៉ាងនេះ តើកើតមានតាំងពីកាលណាមក ព្រះអង្គ ? ព្រះសម្ពុទ្ធទ្រង់សម្តែងប្រាប់តិក្ខុតាំងឡាយនោះថា :

រឿងវិវាទរវាងក្អែក និង មៀម នេះ មានតាំងពីបឋមកប្បដែលទើបនឹងកើតដំបូងឡើងជាដំបូង កាលបើផែនដីកើតឡើងហើយ ឯពួកមនុស្ស និង ពួកសត្វ ក៏កើតមានឡើងដែរ ។ សម័យនោះ តាំងមនុស្សតាំងសត្វទូទៅមានហាននេះស្មើ ។ គ្នា គេមិនមានតាំងនរណាមួយឲ្យជាអ្នកមានឥស្សរ

ភាពសម្រាប់ត្រួតត្រាមើលការពុំសត្រូវដល់គ្នានឹងគ្នា ទៅឡើយទេ ម្ល៉ោះហើយ មនុស្សនិងសត្វទាំងនោះ កាលបើមានកិលេសតិលោភៈ ទោសៈ មោហៈ កើតចំរើនឡើងហើយ ក៏ចេះតែមានការលំលោភឈ្លានពានបៀតបៀនគ្នាទៅវិញទៅមក ។ កាលជាខាងក្រោយមក ពួកមនុស្សបានប្រជុំពិភាក្សាគ្នាថា យើងគួរតែជ្រើសរើសនរណាម្នាក់ដែលមានរូបសម្បត្តិសមមៀ មានប្រាជ្ញាឈ្លាសវៃ ព្រមទាំងមានចរិយា ឫកពា សណ្តាប់ធ្នាប់ល្អ គួរជាទីគោរពចិត្តនៃជនទាំងពួងឲ្យធ្វើជាធំ (ស្តេច) សម្រាប់ត្រួតត្រាមើលការពុំសត្រូវរបស់មនុស្សទាំងឡាយខ្លួនៅ លុះប្រឹក្សាព្រមព្រៀងគ្នាហើយ ក៏លើកបុរសម្នាក់ដែលគេយល់ថា មានលក្ខណៈសមមៀឲ្យធ្វើជាស្តេចឡើង ហើយថ្វាយព្រះនាមថា ព្រះបាទសម្មតរាជ (ស្តេចកើតឡើងដោយប្រជាជនសន្មត) មានតាំងពីកាលនោះមក ។

ចំណែកខាងពួកសត្វចតុប្បាទ (សត្វដើរ ៤) បានប្រជុំប្រឹក្សាគ្នារើសរកសត្វឲ្យធ្វើជាស្តេច លុះប្រឹក្សាគ្នាទៅឃើញថា សត្វសីហៈ ជាសត្វសមមៀមានឥទ្ធិតេជៈខ្លាំងពូកែលើសសត្វទាំងឡាយឯទៀត អាចនឹងត្រួតត្រាលើសត្វដទៃបាន ក៏ព្រមព្រៀងគ្នាលើកសត្វសីហៈតាំងឲ្យធ្វើជាស្តេចឡើងហៅថា រាជសីហៈ ឬ រាជសីហ៍ (សីហៈ ជាស្តេចនៃសត្វចតុប្បាទទាំងឡាយ) មានតាំងពីកាលនោះមក ។

ចំណែកខាងពួកមច្ឆា (ត្រី) ក្នុងមហាសមុទ្រ ក៏មានយោបល់យល់

ឃើញដូចជាពួកសត្វចតុប្បាទដែរ លុះប្រឹក្សាទៅ មានការត្រូមត្រៀនគ្នាហើយ ក៏លើកត្រីឈ្មោះអានន្ទ ឲ្យធ្វើជាស្តេច ត្រួតត្រាលើត្រីទាំងឡាយទូទៅ (អានន្ទមច្ឆា ជាស្តេចនៃត្រីទាំងឡាយ) មានតាំងពីកាលនោះមក ។

គ្រានោះ ពួកបក្សី (សត្វស្លាប) ក្នុងហិមវន្តប្បទេស ជាន់ប្រជុំគ្នានៅទីដ៏កំបុតមួយ ប្រឹក្សាគ្នាថា ពួកមនុស្សតែជ្រើសរើសគ្នា តាំងឲ្យធ្វើជាស្តេចសម្រាប់ត្រួតត្រាគ្នា មានរួចហើយ ឯខាងពួកសត្វចតុប្បាទ ទីងពួកមច្ឆា គេក៏បានរៀបចំគ្នាឲ្យមានស្តេចអស់ហើយដែរ នៅតែពួកយើងជាបក្សីមិនទាន់មានស្តេចដូចគេនៅឡើយ ការនៅដោយគ្មានសេចក្តីគោរពកោតខ្លាចគ្នាទៅវិញទៅមកដូច្នេះនេះ ជាការពុំគួរដល់ពួកយើងឥតស្មានទេ បើដូច្នេះ ពួកយើងគួរតែជ្រើសរើសយកអ្នកណាមួយឲ្យធ្វើជាស្តេចខ្លឹង ។ ខណៈនោះ មៀមមានសេចក្តីព្រួយ ដោយខ្លាចក្រែងហានៈស្តេចនោះបានទៅលើក្អែក ក៏ខំដើរធ្វើអន្តរាគមន៍ទីងបក្សីឯទៀត ពីមួយទៅមួយថា ពួកយើងកុំយកក្អែកឲ្យធ្វើជាស្តេច ព្រោះក្អែកនេះ រូបអាក្រក់ណាស់ ហើយខ្មៅឃ្មីត គ្មានសល់ចន្លោះត្រង់ណាទេ បើរូបខ្មៅហើយ ចិត្តក៏ខ្មៅអាក្រក់ដែរ ទាំងប្លកពាក៌ភបថោកទៀត ជាអ្នករបិញ្ញរបុញ្ញ ទិលខ្លួចណាស់ បើពួកយើងលើកក្អែកឲ្យធ្វើជាស្តេច ពួកយើងមុខជាត្រូវបានទទួលទុក្ខវេទនាអំពីក្អែកនោះវិញពុំខានឡើយ ។ ឯក្អែក បានដឹងនូវយ

កលរបស់មៀមដែលដើរភ្ញាក់ញាស់ដូច្នោះហើយ កំតិតខុកក្នុងចិត្តថា មិនអីទេ មៀមឯងនឹងតែនឹងដឹងគ្នា ។

ក្នុងពេលដែលពួកសត្វបក្សីមកជួបជុំគ្នាហើយ មានបក្សីមួយឡើងប្រកាសថា អ្នកកាល់គ្នាចូរស្តាប់ខ្ញុំ ឥឡូវនេះ យើងគួរជ្រើសរើសអ្នកណាឲ្យធ្វើជាស្តេច ? បក្សីទាំងអស់នាំគ្នាគយគន់រកមើលក្នុងចំណោមបក្សីទាំងនោះទៅ ឃើញមៀមជាសត្វអង់អាច គួរឲ្យធ្វើជាស្តេច ហើយក៏បត្តាញ្ញាយោបល់ស្របគ្នាថា ពួកយើងពេញចិត្តនឹងមៀមនេះគួរយកមៀមឲ្យធ្វើជាស្តេច ។ គ្រានោះ មានបក្សីមួយទៀតឡើងប្រកាសថា ឥឡូវបើអ្នកកាល់គ្នាពេញចិត្តនឹងមៀមហើយ យើងសូមប្រកាស ៣ ដងថា អ្នកទាំងអស់គ្នា ប្រាកដជាពេញចិត្តនឹងមៀមមែនឬ ? បើអ្នកណាមិនពេញចិត្តទេ ចូរឆ្លើយមក ។ ប្រកាសលើកទី១ បក្សីទាំងអស់នៅស្ងៀម ប្រកាសលើកទី ២ ក៏គ្មានបក្សីណាឆ្លើយ ប៉ុន្តែក្អែកទំប្រឹងគ្រាំអត់មិនបានទាន់ថា អ្នកឯងលើកទី ១ នឹង លើកទី ២ លុះដល់ប្រកាសលើកទី ៣ ក្អែកកំសុះក្រោកឡើងជំទាស់ភ្លាមថា ខ្ញុំមិនពេញចិត្តទេ បើយកមៀមឲ្យធ្វើជាស្តេច។ – ហេតុអ្វីបានជាអ្នកឯងមិនពេញចិត្តនឹងមៀម ? – បានជាខ្ញុំមិនពេញចិត្តព្រោះមៀមមានលក្ខណៈមួយខុសពីគេឯទៀត ។ – មៀមមានលក្ខណៈខុសពីគេត្រង់ណាខ្លះ ចូរអ្នកឯងថាមកមើល ? – ខ្ញុំមិនហ៊ានថាទេ លុះតែអ្នកទាំងអស់គ្នាអនុញ្ញាតឲ្យ ហើយក៏ចាំងើបខួលខុសត្រូវផង ទើប

ខ្ញុំហ៊ានថា ។ – តើមិនអីទេ យើងតាំងអស់គ្នាអនុញ្ញាតឲ្យហើយ ចូរថា
មកចុះ! – ខ្ញុំស្ទើរតែមិនហ៊ានថាទេ ប៉ុន្តែបើអ្នកពាល់គ្នាបង្ខំឲ្យខ្ញុំថាហើយ ខ្ញុំ
ត្រូវតែប្រថុយថាទៅចុះ អ្នកពាល់គ្នាចូរសង្កេតមើលមុខ និងក្អែកបស់មៀម
នេះចុះ មានលក្ខណៈខុសពីគេឯង មុខគាត់នេះ ទឹងដូចជា មិនទឹង
ក្អែកក្រហមលឿន ជាពិសេស ចូរសង្កេតមើលទឹកមុខចុះ គាត់នេះមិន
គាន់ទឹងមុខក្រញ៉ូវគាក្រក់ម្ល៉េះទៅហើយ ចំណង់បើជល់ទឹងឡើង តើមុខនឹង
ឡើងគាក្រក់យ៉ាងណាទៅទៀត ហេតុនេះ ឋានជាខ្ញុំមិនពេញចិត្ត បើ
យើងលើកមៀមអកិសេកឲ្យធ្វើជាស្តេចគាន់អំណាចទៅ មុខមៀមមិនគាន់
ទឹង គាក្រក់ម្ន៉ឹងទៅហើយ កាលបើជល់ពេលគាត់ទឹងឡើង នឹងទៅជាយ៉ាង
ណាទៅទៀត មុខជាធ្វើយើងតាំងអស់គ្នាឲ្យបែកបាក់ខ្ចប់ខ្ចឹស្ងាប់អស់ជា
ពុំខាន ដូចជាអំបិលដែលគេជាក់ក្នុងអំបែងកំពុងក្តៅ ។

ក្អែក កាលបើបានឱយាយរិះគន់មៀមហ៊ាំងនេះហើយ ក៏ស្រែក
ដោយសម្រែកយ៉ាងខ្លាំងថា «បើយកមៀមឲ្យធ្វើជាស្តេច យើងមិនព្រម
ជាដាច់ខាត» ហើយស្ទុះហើរត់ទៅ ។ ឯមៀម កើតសេចក្តីក្តៅ
ក្រហាយខ្លាំង ក៏ស្ទុះហើរដេញតាមតប់ចុងក្អែកចាត់ទៅ ។ ត្រានោះពួក
បក្សីបែកគ្នាជាពីរក្រុម : មួយក្រុមកាន់ដើងខាងក្អែក មួយក្រុមទៀតកាន់
ដើងខាងមៀម ។ បក្សីណាដែលកាន់ខាងក្អែក បក្សីនោះហៅថា ទិវាចរ
(ពួកបក្សីចេញស្វែងរកចំណីតែក្នុងវេលាថ្ងៃ) បក្សីណាដែលកាន់ខាង

រមៀម បក្សីនោះហៅថា វត្តិចរបក្សក (ពួកបក្សីចេញស្វែងរកចំណី តែកន្លងវេលាយប់) ដើម្បីគេចចៀសមិនឲ្យជួបនឹងក្អែក ។ ក្អែក និងរមៀម ដែលកើតហេតុវៃកខាស់ខែងគ្នាជាច្រើន ចនំពាំនៀរនឹងគ្នាទៅវិញទៅមក នេះ មានតាំងពីកាលនោះមក ។

បន្ទាប់ពីនោះមក បក្សីទាំងឡាយក៏នាំគ្នាលើកហង្សឲ្យធ្វើជាស្តេច ឡើង ទើបមានពាក្យហៅជាប់មកថា «ហ៊ំសកជា ស្តេចគឺហង្ស ឬ រាជហង្ស ហង្សជាស្តេចនៃពួកបក្សី» មានតាំងពីកាលនោះមក ។

(តិកនិបាតជាតក)

ជម្ងោរវ៉ាង

ពស់ ធឺង ស្លា

កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងទាំងឡាយ ព្រះអង្គច្រាន ច្រាស់ដឹងខ្លឹងក្នុងលោកហើយ ទ្រង់គង់នៅវត្តជេតពន ជិតរាជធានី សាវត្ថី ។ គ្រានោះ ភិក្ខុទាំងឡាយនាំគ្នាដើរចូលទៅកាន់ស្រុកមួយ ដើម្បីបិណ្ឌបាត លុះដល់ពាក់កណ្តាលផ្លូវ បានប្រទះឃើញពស់ធឺងស្លា កំពុងតែពស់ខែងគ្នា ចៀតបៀនគ្នាដោយកម្លាំងកាយទៅវិញទៅមក ។ លុះដល់ទីបំផុតនៃការឈ្លោះគ្នា ពស់ក៏ដល់នូវទុក្ខវិលវិលកាត ពិការ ចំមុខយកម្ខាំងដោយការចាញ់ៗជាយកលរបស់ស្លា ។

កិត្តិតាំងនោះ កាលបើត្រឡប់មកពីចំណូចុតវិញហើយ នាំគ្នាចូលទៅគាន់សំណាក់ព្រះពុទ្ធជាម្ចាស់ ហើយក្រាបបង្គំទូលអំពីដំណើរតាស់ធំងស្ពានកើតរវាងតាស់ខែងធំងគ្នា ថ្វាយព្រះអង្គទ្រង់ព្រះសណ្តាប់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលកិត្តិតាំងឣ្ហាយ សត្វតាំងពីរតី តាស់ធំងស្ពានេះ មិនមែនទើបធំងកើតរវាងធំងគ្នាក្នុងកាលឥឡូវនេះទេ តែកើតរវាងធំងគ្នាយ៉ាងនេះ តាំងពីព្រេងនាយមកម៉្លេះ កាលនោះ តថាគតជារោធសត្វនៅឡើយ ឋានកើតក្នុងត្រកូលនៃព្រាហ្មណ៍នៅក្នុងស្រុកមួយជិតក្រុងពារាណសី លុះមានវ័យចំរើនធំឡើងហើយ ក៏ចេញទៅចំពេញវិជ្ជាឯនតរតក្កសិលា ។ ការសិក្សាវិជ្ជារបស់តោធសត្វមិនយូរប៉ុន្មាន ក៏ឋានចេះដឹងសព្វគ្រប់ ហើយត្រឡប់មកនៅគ្រប់គ្រងគេហដ្ឋានប្រកបអាជីវកម្មតាមប្រពៃណីរបស់ត្រកូល លុះដល់បច្ចឹមវ័យ តោធសត្វក៏លះបង់ឃរាវាស ចេញទៅបួសជាឥសី តាំងអាស្រមនៅក្នុងហិមវន្តប្បទេស ឋានបំពេញតបធម៌ ហើយញុំាងអភិញ្ញា ទំងសមាបត្តិឲ្យកើតឡើងនៅជាសុខសាន្តក្នុងទីនោះដោយអាស្រ័យនូវមើមឈើនឹងផ្លែឈើជាអាហារ ។

នៅចុងទីចង្រ្កមនៃតាបសជាតោធសត្វ មានស្ពាមួយធ្លើរូងនៅក្នុងដំបូកមួយ មានតាស់មួយទៅទំងតល់ឈើជិតស្ពានោះដែរ ។ សត្វតាំងពីរនេះ រៀងឃើញគ្នាគាល់ណា រមែងតែឈ្លោះបៀតបៀនគ្នាជាធម្មតា ។ តាស់ជាសត្វល្ងង់ ហើយខ្ជិលមិនចេះធ្លើរូងនៅ ឃើញស្ពាមានរូងនៅ

ស្រួល កំតិតថា អញនឹងសម្លាប់ស្ពានោះយកធ្វើជាអាហារដង នឹងយក
រូងវាទៅដង ។ ឯស្ពា ក៏ជានដឹងថា តាស់បំរុងនឹងញាំជាខ្លួនឲ្យនៅសេ
ជីវិត ក៏ប្រុងស្មៀតប្រយ័ត្នខ្លួនជានិច្ច ដើម្បីតទល់នឹងតាស់នោះវិញដែរ ។
រោងឯសត្វជានយើញតាសនឹងស្ពា តាស់ចែងគ្នាស្ទើរតែពាល់ថ្ងៃ ក៏ញា-
យាមឲ្យឆ្ងាចំពោះសត្វជាំងពីរឲ្យមានសាមគ្គីរួបរួមគ្នា កុំឲ្យតាស់ចែង
នឹងគ្នាតទៅទៀត ។ ឯតាស់នឹងស្ពា ដោយអំណាចជានស្តាប់ឮពាក្យ
តាបសហើយ ក៏ផ្អាកឈប់ឈ្លោះគ្នាដែរ ប៉ុន្តែកំហឹងនិងការចងគំនុំនឹងគ្នា
ទៅវិញទៅមក ពុំទាន់លេតជាត់នៅឡើយ ។

ថ្ងៃមួយ តាស់ចេញទៅស្វែងរកអាហារខាងក្រៅជាត់ទៅ ស្ពាដេក
ហាមាត់បង្ហោញចង្កឹម ជាក់ក្បាលប៉ឹមនឹងមាត់រូង កំពុងលក់ដកដង្ហើម
ចេញចូលឮសូរឃូ ឃូ យ៉ាងស្រួល ។ តាបសដើរទៅជិតដំបូក ជាន
យើញស្ពានោះកំពុងដេកលក់ដូច្នោះ ក៏ស្រែកសួរថា នែស្ពា ! ឯងដេក
ធ្វើអាការដូច្នេះ ហាក់ដូចជាប្រុងស្មៀតការពារនឹងភ័យអ្វីមួយដែលនឹងមាន
មកដល់ខ្លួនឯងឬ ? – ស្ពា: ខ្ញុំសព្វថ្ងៃនៅជាមួយនឹងបច្ចាមិត្ត គួរតែខ្ញុំប្រុង
ប្រយ័ត្នជានិច្ចគ្រប់តំរិយោបថដូច្នេះ ទើបជាន។ – តាបស: អ្នកណាជាបច្ចាមិត្ត
និងឯង ដែលប្រុងនឹងធ្វើឲ្យឯងមានភ័យ ? – ស្ពា: តាស់ជាបច្ចាមិត្តនឹងខ្ញុំ ។
តាបស: ឯងកុំភ័យព្រួយបារម្ភអ្វី យើងនឹងធ្វើមិនឲ្យតាស់នោះប្រទូស
បៀតបៀនដល់ឯងទៀតទេ កុំឲ្យឯងរន្ធត់ស្ញើសចិត្តនឹងតាស់នោះតទៅទៀត

ស្តាះ ។ ព្រះបរមសាស្តាគង់ ខ្ញុំស្តាប់ចាន់អស់ហើយ ប៉ុន្តែនៅមិនទាន់អស់ហើយពីក្នុងចិត្តខ្ញុំសោះ ។ តាបសពោធិសត្វ ចិតនៅជាសុខក្នុងឈានសមាបត្តិ លុះដល់ទីបំផុតនៃអាយុ ក៏ចាន់ទៅកើតក្នុងព្រហ្មលោកនាយទៅ ។ ឯតស់ ទាំង ស្តាខោះគ្រាន់តែមិនចាន់ឈ្លោះបៀតបៀនគ្នាក្នុងជាតិនោះ ដោយអំណាច ព្រះពុទ្ធនៃពោធិសត្វ ប៉ុន្តែកំហឹងនិងការចងពំនៀរគុំគួនទាំងគ្នាទៅវិញទៅមក ជាប់មានតាំងពីកាលនោះមក ។

(ខុកនិបាតជាតក)

ជម្ងោះវាង

ខ្លាឃ្មុំ ទាំង ជើមពង្រ

ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធជាបរមសាស្តានៃយើង គ្រង់គង់នៅទៀបឆ្នេរនៃស្ទឹងអេហិណី ដើម្បីសំដែងធម៌រម្ងាប់ខ្លួនអធិករណ៍នៃពួកព្រះញាតិវង្សព្រះអង្គ ក្នុងពេលនោះ ព្រះអង្គទ្រង់លើកយកធម៌ទាំងរឿងផ្សេង ។ ជាច្រើនមកសំដែង ដើម្បីឲ្យពួកព្រះញាតិទាំងនោះស្តាប់ហើយទាំងឲ្យលះបង់នូវការវិវាទ ដែលជាហេតុនាំឲ្យចងពៀរវេរទាំងគ្នាតទៅក្នុងអនាគតទៀត ។

ក្នុងទីនេះ ខ្ញុំសូមលើកយកចំពោះតែរឿងខ្លាឃ្មុំ ទាំង ជើមពង្រ ដែលចងពៀរទាំងគ្នា មកដំណាលដូចជាសណ្តាប់ដូចតទៅនេះ ៖

នៅខាងក្រៅទីក្រុងពារាណសី មានស្រុកមួយច្រើនតែពួកជាងឈើ

នៅអាស្រ័យ ។ បណ្តាពួកជាងឈើដែលនៅក្នុងស្រុកនោះ មានជាងឈើម្នាក់តែងទៅនាំយកឈើចាំងឡាយអំពីព្រៃមកធ្វើគ្រឿងរថ (រទេះ) សម្រាប់លក់ចិញ្ចឹមជីវិត ។ កាលនោះ មានដើមពង្រមួយដើមធំ ដុះនៅក្នុងហិមវន្តប្បទេស ។ មានខ្វាឃ្មុំមួយស្វែងរកចំណីបរិភោគ ហើយមកដេកនៅក្បែរគល់ពង្រនោះ ។ ប្អូនជាក្នុងថ្ងៃនោះ មានខ្យល់បក់មកមែកពង្រសួតក្រៀមមួយបាក់ធ្លាក់ចុះមកដោយកម្លាំងខ្យល់ ក៏សង្កត់លើកខ្វាឃ្មុំ ។ ខ្វាឃ្មុំមានសេចក្តីឈឺចាប់យ៉ាងខ្លាំង ពាំងមានសេចក្តីតិតក័យដោយមិនដឹងជាអ្វី ក៏ស្ទុះរត់ចេញទៅខាងក្រៅ បន្តិចត្រឡប់មករកមើលត្រង់តន្ទែងនោះវិញមិនឃើញអ្វីប្លែកសោះ ឃើញតែមែកពង្រដែលបាក់ធ្លាក់មកនោះ ។ ខ្វាឃ្មុំក៏តសេចក្តីក្រោធមិនសមហេតុផល ត្រឡប់ជាទំនងតំនុំទំនឹងដើមពង្រដោយគិតថា ឥឡូវនេះដឹងជាមានសីហៈ ឬខ្លាធំណាមួយមកដេញព្យាបាទដល់អញក៏ទេដែរ ទំនងជាមានទេព្តានៅទឹងដើមឈើនេះកាច់មែកពង្រទម្លាក់មកលើអញ ដែលកំពុងដេកនៅទីនេះ មិនអីទេ គន់តែទំនងដឹងគ្នា ។ ខ្វាឃ្មុំទើបណាស់ ក៏ស្ទុះទៅប្រហារដើមពង្រនោះដោយចង្កូម ហើយគំរាមក្តេវគាថា អញគ្មានត្រូវការស៊ីស្លឹកនឹងមែកឈើរបស់អ្នកឯងទេ ម្តេចក៏ឯងមកបៀតបៀនអញ អញមានទោសកំហុសដូចម្តេច ? តើមិនអីទេ ចាំមើលតែពីរបីថ្ងៃទៀត អញនឹងឲ្យគេកាប់តាស់រំលើងដើមឈើព្រមទាំងឫសគល់របស់អ្នកឯង ហើយឲ្យគេ

ភាគ់ជាកំណាត់តូចកំណាត់ធំផងខ្លែតពុំមាន ។ គ្រានោះ ជាងឈើនោះឯង ចាននាំកម្មករពីរបីនាក់ បររទេះចូលទៅក្នុងព្រៃដើម្បីរកឈើធ្វើគ្រឿងរទេះ ។ លុះដល់ព្រៃហើយ កិបញ្ជាប់រទេះឲ្យឈប់ក្នុងទីមួយ នាំគ្នាគាន់កាំបិត និងពូថៅដើរចូលទៅជិតដើមពង្រនោះ ។ ខ្លាឃ្មុំឃើញជាងឈើនោះគិតថា «អីថ្ងៃនេះ អញចាននឃើញខ្នងបច្ចាមិត្តហើយ» ក៏ស្ទុះមកឈរជិតដើមពង្រ ។ ចំណែកខាងជាងឈើ ដើរបណ្តើរគយគន់រកមើលបណ្តើរ ក្រែងប្រទះឈើដែលខ្លួនត្រូវការ ។ ខ្លាឃ្មុំស្រែកសួរថា នែជាងឈើ! អ្នកឯងគាន់ដាំងជាប់នូវដៃ ដើរចូលមកក្នុងព្រៃធ្វើអ្វីរកកាប់ឈើអ៊ី? ជាងឈើ: ខ្ញុំមករកកាប់ឈើណាដែលមានសាច់ជាប់ល្អយកទៅធ្វើគ្រឿងរទេះ ។

-ខ្លាឃ្មុំ: ខ្ញុំនៅក្នុងព្រៃនេះ ខ្ញុំស្គាល់ឈើគ្រប់ពាំងអស់ តើឈើណាជាប់ ណាមិនជាប់ ឥតមានតក់ជាំងពីខ្ញុំទេ ។- ជាងឈើ: ខ្មែនហើយ អ្នកឯងនៅព្រៃស្គាល់ឈើល្អ ខ្លះឈើមិនល្អ ចុះឈើអ្វីដែលមានសាច់ជាប់ម៉ាំមួនល្អ? - ខ្លាឃ្មុំ: កាំងក្តក្តី តគីរក្តី ផ្តិតក្តី សុក្រំក្តី ដើមត្រចៀកប្រើសក្តី ឈើពាំងនេះ សុទ្ធតែឈើមានខ្លឹមមែនហើយ ប៉ុន្តែមិនសូវជាប់ម៉ាំល្អប៉ុន្មានទេ បើបានឈើឈ្មោះផន្លះ (តង្រ) ជាប់ម៉ាំល្អណាស់ ប្រើប្រាស់ទៅមិនងាយខូចទេ បើបែរជាយកទៅធ្វើគ្រឿងរទេះ មានខ្លឹកធំជាដើម ក៏រឹតតែជាប់ម៉ាំ ប្រសើរណាស់ទៅទៀត ។

ជាងឈើឮពាក្យខ្វាឃ្មុំប្រាប់ហើយ ក៏មានសោមនស្សរីករាយសប្បាយចិត្ត គិតថា ថ្ងៃនេះ អញ៎មានកំពូលណាស់តើ ចូលមកកន្លែងព្រៃ មានសត្វគិនប្លន់ប្រាប់ឈើដែលគួរយកទៅធ្វើគ្រឿងរនេះ ក៏សួរទៅខ្វាឃ្មុំថា ចុះដើមពង្រនោះ មានតាតបែបដូចម្តេចខ្លះទៅ ព្រោះខ្ញុំមិនដែលស្គាល់។ – ខ្វាឃ្មុំ: ស្មឹកវាកន្លះធំត្រវែងបន្តិច មែកវាកន្លះសាយាសំយុងចុះក្រោម ផ្លែវាកន្លះមូលដមបន្តិច ជាបង្គ្រាម។ ពួកមនុស្សតែងបេះយកទៅធ្វើជាអាហារបរិភោគ ឈើនេះសំខាន់ណាស់ បើយកធ្វើជាគាត្តី ជាខ្នងកន្ត្តី ជាដុំក្តី ជាប់ហើយធន់ជាងឈើដទៃ គ្មានឈើណាវិសេសជាងពង្រទៅទៀតទេ។ – ជាងឈើ: ចុះកន្លែងណាដែលមានដើមពង្រ? – ខ្វាឃ្មុំ: បើអ្នកឯងមិនស្គាល់ទេ ចូរមើលមកខ្ញុំ ខ្ញុំឈរជិតដើមឈើណា ដើមឈើនោះឯងហៅថា ពង្រ។ ខ្វាឃ្មុំ លុះបានប្រាប់ជាងឈើឲ្យស្គាល់ច្បាស់ហើយ ក៏មានចិត្តត្រេកអរណាស់ ដោយគិតថា ខ្ញុំឯងបានសម្រេចដូចបំណងរបស់ខ្លួន ហើយថយទៅសម្ងំនៅក្នុងទីមួយលបចាំមើលកន្សែរនោះដែរ។ ខណៈនោះ ជាងឈើក៏រៀបចំប្រុាក្បាច់ដើមពង្រនោះ។

រួចទៅគាត់ ដែលនៅនឹងដើមឈើនោះគិតថា ឥឡូវ គ្រាន់ថ្នាក់ដល់ហើយតើ! អន្ត្តាយនេះ ប្រុាកដជាកើតមកពីខ្វាឃ្មុំនោះឯង ជាអ្នកញុះញង់បង្ក្តហេតុ ឯមែកពង្រដែលប្លាក់ភ្លាក់ទៅលើវានោះ ដោយសារឲ្យលាទេ មិនមែនអញធ្វើឡើយ សូម្បីតែតុក្តូរបន្តិចបន្តួច ក៏អញមិន

ដែលធ្វើឲ្យគ្នាក់ចុះទៅលើកដែរ តម្លៃវាត្រឡប់ចង់តំខ្ពុសទំនងមិនសម
ហេតុផល ធ្វើវិនាសវេស់អញឲ្យវិនាស ស្អីយចុះ អញបើបំណាច់នឹង
វិនាស តើត្រូវតែធ្វើខ្ញុំនោះឲ្យវិនាសដូចអញដែរ តំដំណែងគេជា
ចុះសម្ងាត់ បែបភាគជាអ្នកធ្វើការក្នុងព្រៃ ហើយដើរចូលទៅជិតជាង
ឈើនោះសួរថា នែជាងឈើ អ្នកឯងកាប់ឈើនេះ បម្រុងនឹងយកទៅធ្វើ
អ្វី? – ជាងឈើ: យកទៅធ្វើខ្នងតង់រនេះគេថា ឈើហ្នឹងជាប់ ។– រុក្ខទេវ
តា: អ្នកណាច្រាប់អ្នកឯង? – ជាងឈើ: ខ្ញុំច្រាប់ខ្ញុំ ។– រុក្ខទេវតា: ចើ
ខ្ញុំច្រាប់ ការនោះច្រាកដមែនហើយ ប៉ុន្តែឈើនេះ បើយកទៅប្រើ
សុទ្ធតែវាមិនសូវជា ជាប់តំណាត់ប៉ុន្មានទេ ចើបានសែ្រកខ្ញុំត្រង់តវប្រ
មាណប៉ុន ៥ ឆ្នាប់ទទឹង យកមកតាសព័ទ្ធមណ្ឌលខ្នងតង់ពីក្រៅឲ្យជូចគេ
ព័ទ្ធដោយបន្ទះដែក ហើយយកខ្ញាញ់តម្រកលាបសាប់ឈើនោះខ្លះផង
ហ្នឹងវិធីតែជាប់អំណាត់ណាស់ទៅទៀត។ – ជាងឈើ: ឲ្យខ្ញុំទៅរកសែ្រក
និងខ្ញាញ់ខ្ញុំនោះតាណា បាន ។ – រុក្ខទេវតា: អ្នកឯងកុំលួងតេក ដើម
តង្រែនេះដុះនៅក្នុងព្រៃមិនតែទៅណា បាត់ទេ ខ្ញុំណាដែលច្រាប់អ្នក
ឯងថា ឈើនឹងជាប់ អ្នកឯងចូរទៅកាន់សំណាក់ខ្ញុំនោះ ខ្ញុំយាយ
បញ្ជាតវាថា ឈើដែលអ្នកឯងបង្ហាញខ្ញុំនោះ តម្លៃវាឲ្យខ្ញុំកាប់កាត់ត្រង់
តវែងណាខ្លះ ចូរនាំវាឲ្យមកបង្ហាញ កាលបើវាមកហើយកុំតែយក
ចុងមាត់បង្ហាញថា អ្នកឯងចូរកាត់ត្រង់នេះឬ ចូរកាត់ត្រង់នោះ អ្នកឯង

យកភួយថ្មីជំនួសវិញ ហើយតន្ទុះយកស្បែកត្រមាំដ៏សាច់ក្រយកទៅបរកោតទៅ ។

ជាដំណើរបានធ្វើតាមពាក្យដែលក្អែកវែងនោះបង្គាប់ហើយ កិសាប់ក្លាយទៅជាមាសទាំងនោះបាន ហើយការតន្ទុះយកស្បែក សាច់និងក្អែកក៏រួចហើយ ទើបកាប់ដើមពង្រនោះជាមាសក្រោយទាំងយកទៅ ព្រោះហេតុនោះ បានជាក្អែក កាលណាហើរប្រទះឃើញដើមពង្រ តែងតែសុះទៅជាំកកេរជាធម្មតា ព្រោះមានពាំនៀនដំណឹងគ្នា ជាប់តាំងពីកាលនោះមក ។

(តេរសនិបាតជាតក)

ប៉ុគ្គលគួរបង់ស្តានមេត្រី មួយអន្ធើដោយសត្រូវ
ដែលធ្វើទុបការៈ តែកុំធ្វើមួយអន្ធើដោយមិត្រ ដែលធ្វើអបការៈ (ទោស) ឡើយ ទុបការៈនឹងអបការៈ ទាំងពីរប្រការនេះ ជាលក្ខណៈដែលបុគ្គលគប្បីកំណត់ដឹងចំពោះសត្រូវនឹងមិត្រទាំងឡាយ ។

ហិតោបទេស

ព្រះអភិធម្មបិដក

(កម្ពីរត្រៃមហាបដ្ឋាន)

លោក ប៊ូ - ប៊ុំ រៀបរៀង

តមក

រឿងអ្នកឆ្កួលសេដ្ឋី

មានសេដ្ឋីម្នាក់ឈ្មោះអានន្ទសេដ្ឋី ជាមនុស្សកំណាញ់ស្អប់ជន ខាន កំមិនឲ្យ ស៊ីលក៏មិនឲ្យ ដែលបានជាសេដ្ឋីក្នុងជាតិនេះ ព្រោះខ្លួនបាន ប្រគេនអាហារបិណ្ឌបាតខាងដល់ព្រះកិកុសង្ឃ ដែលមកបិណ្ឌបាតពីជាតិ មុន ។ កុសលដែលខ្លួនបានប្រគេនបិណ្ឌបាតខាងនោះ នាំបដិសន្ធិក្នុង ជាតិនោះ លុះរលត់បញ្ចក្ខន្ធពីជាតិជាសេដ្ឋី ទៅកើតក្នុងត្រកូលចណ្ឌាល ទៅកែវគ្រាវផ្ទះនៃខ្លួន ។ អកុសលកម្មតាម១បត្ថម្ភត្រកូលនោះមិនឲ្យបាន សេចក្តីសុខសោះ តាំងពីពាក់នោះមកបាច់បដិសន្ធិក្នុងផ្ទៃមាតាមក ។ មនុស្សទាំងឡាយ ទើបប្រឹក្សាគ្នាថា កាលពីដើម យើងមិនដែលមានទុក្ខ យ៉ាងនេះទេ សូម្បីគ្មានលាភសក្ការៈសូមខាងតែមិនបាន កំមានតែម្នាក់ ។ ប៉ុណ្ណោះមិនមែនទាំងអស់គ្នាទេ មកដល់គ្រានេះ យើងជាមនុស្សឥតលាភ សូមខាងតែមិនបានត្រប់គ្នា គ្មានអ្នកណាពាក់អ្វីបានសោះ ចេះតែនាំស ទៅកាល់តេលវេលា ។

ក្រការមួយទៀត កាលពីដើម ម៉ែទុកជាយើងខាល់ក្រយ៉ាងណា

យើងគឺទៅតែស្រឡាញ់ពាក់អាទគ្នាដែរ ចុះគេលនេះបែរជាស្អប់គ្នាទៅវិញ ប្រហែលជាមនុស្សកាឡកណ្តើមកគើត យើងចូរបែកគ្នាជាពីរពួកចុះ សេចក្តីចំរើនធំឆើតមានដល់ពួកយើងពាំងឡាយ បើមនុស្សកាឡកណ្តើទៅក្នុងពួកណា ពួកនោះគឺធំវិនាសច្រើនសម្បត្តិ ស្មែងរកលាភលែងបានបើមនុស្សកាឡកណ្តើគ្មានក្នុងពួកណា ពួកនោះគឺធំរកលាភបានដូចពីមុនមក ។ ពួកមនុស្សចណ្តាលប្រឹក្សាគ្នាដូច្នេះហើយ គឺបែកគ្នាទៅជាពីរពួក ។ ពួកណាដែលមានចិត្តាការនោះមិនបានទៅជាមួយទេ ពួកនោះគឺរកច្រើនចិញ្ចឹមជីវិតបានដោយងាយ ។ ពួកណាដែលមានចិត្តាការនោះទៅជាមួយ ពួកនោះគឺបែរតែវិនាសទៅ ។ សូម្បីតែអហារធំធេរិកោគគឺគ្មាន ។ ឱ្យ គោដ្ឋាសា ហុត្វា ជនពាំងឡាយគឺបែកខ្ញែកចេញពីគ្នាជាពីរផ្នែកទៀត លុះដល់មានចិត្តានៃការនោះទៅទៅជាមួយគ្នា ខាងចិត្តានៃការនោះគឺបែកចេញទៅពីតរៃយ៉ា ស្មែងរកលាភបានចិញ្ចឹមខ្លួនដោយសេចក្តីសុខសប្បាយ ឯមានានៃការនោះប្រកបដោយសេចក្តីអត់ឃ្លានវេទនាលំបាកវេហូតដល់សម្រាលកូន កាលសម្រាលកូនរួចហើយថ្ងៃណា គឺនាំការនោះដើរទៅរកសួមមានគេ ក្នុងថ្ងៃនោះសូម្បីតែបាយមួយចំអែត ក៏រកមិនបាន បើថ្ងៃណាមានាទៅសួមមានគេតែម្នាក់ឯង មិនយកកូនទៅផងទេ ថ្ងៃនោះ ទើបបានបាយគ្រាន់ចិញ្ចឹមជីវិតនឹងបុត្រ ។ មានាចេះតែគ្រាំវេទនាវេហូតដល់កូននោះចេះដើរ

មាតាទើបបណ្តាយបុត្រនោះឲ្យដើរចេញពីខ្លួនទៅតែម្នាក់ឯង ។

ចំណែកមាតានោះ ឮកេរើញខ្លួនជាតិនៃខ្លួន ហេតុតែកុសលដែលខ្លួនបានធ្វើពុំមកពីជាតិមុន គឺដើរតាមផ្លូវទៅដល់ផ្ទះដែលខ្លួនធ្លាប់នៅកន្លងកាលកើតជាអានន្ទសេដ្ឋី ក៏ចាំបាន ទើបចូលទៅក្នុងភូមិរបស់ខ្លួននោះ ព្រោះតែតស់គាល់ថាផ្ទះនោះជាផ្ទះរបស់ខ្លួន ។ បណ្តាជនអ្នករក្សាទ្វារក៏ហាមឃាត់បណ្តេញថា ម្នាលចណ្ឌាល ឯងកុំចូលមកឡើយ ។ ក្មេងចណ្ឌាលនោះ ពុកជាគេហាមឃាត់យ៉ាងណាក៏មិនស្តាប់ ស្រែកតបវិញថា ផ្ទះរបស់អញ ។ ខ្ញុំឯងចូលទៅរកកូនប្រុសស្រីរបស់អញ ទីនេះជាលំនៅរបស់អញ អ្នកចូរកុំហាមឃាត់អញដូច្នេះឡើយ មិនសមគួរទេ ។ ក្មេងចណ្ឌាលថាដូច្នោះហើយ ក៏ចូលទៅក្នុងភូមិ អ្នកចាំទ្វារក៏ឃាក្មេងនោះយ៉ាងដំណាំពាល់តែដួលដេកនៅទីនោះ ។

ក្មេងចណ្ឌាលនេះពុំគួរទៅនាដូច្នេះ តាស្រ័យនូវបត្តមួកកម្មខាងអកុសលខ្នុកបម្រុង គឺមានសេចក្តីពុំក្លាចហើយធ្វើឲ្យបានពុំក្លាតែច្រើនឡើងទៀត ។ នូវបត្តមួកកម្មនេះ ជាបច្ច័យគឺខ្នុកបម្រុងខាងខាងបុណ្យខាងខាងបាបខាងពីរប្រការ ។ នូវបត្តមួកកម្មខាងកុសលក៏ជាប់តាមខ្នុកបម្រុងនូវបុគ្គលដែលមានសុខ មានទ្រព្យស្រាប់ហើយ ឲ្យតែតែមានច្រើនឡើងទៀត ចំណែកនូវបត្តមួកកម្មខាងអកុសលវិញ ក៏ជាប់តាមខ្នុកបម្រុងនូវបុគ្គលដែលវិនាសហើយ ឲ្យតែតែវិនាសកស់តេលទៅទៀត ។ ឯផល

នៃទុបត្តម្ភកកម្មទាំងអកុសលនេះ កើតមានដល់បុគ្គល ហេតុតែខ្លួនប្រទូសភាយដល់អ្នកមិនបានប្រទូសភាយ ឥតជាមនុស្សគ្មានកតញ្ញូ ។ បុគ្គលប្រទូសភាយដល់អ្នកមិនបានប្រទូសភាយ ក្នុងបច្ចុប្បន្នជាតិ តែគ្មានសេចក្តីសុខសួស្តីដល់ខ្លួនក្នុងជាតិមុខ តែងតែសោយទុក្ខពាធមិនអស់ សមតាមព្រះពុទ្ធភាសិតថា ៖

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ ៖ បុគ្គលណាប្រទូសភាយ ចំពោះអ្នកមិនបានប្រទូសភាយដល់ខ្លួន បុគ្គលនោះតែងបានសោយទុក្ខជាច្រើន តែចំតែងតែអណ្តែតអណ្តូងភាយមាយៅជាឆ្កួត ត្រូវមានរៅស្រាប់ តែនៅសល់ចំពាតៅ តែវាស្ងួតក្លាយៅជាដុំឥដ្ឋ តែវាមុត្តាក្លាយៅជាគ្នីង តែងមានគេនិយាយបង្អាប់បង្អែច តែខ្លួនមិនបានឮលមិនបានឮមិនបានឃើញ ត្រឡប់ជាមានគេនិយាយបង្អាប់ថាខ្លួនបានឮលបានឮបានឃើញ ខ្លួនមិនមែនជាចោរ គេប្រជុំគ្នានិយាយថាខ្លួនជាចោរ លុះរលត់បញ្ចក្ខន្ធ តែងទៅកើតក្នុងអបាយភូមិមានឧរគជាដើម ។

ម្យ៉ាងទៀត បុគ្គលដែលប្រទូសភាយចំពោះអ្នកមិនប្រទូសដល់ខ្លួនតាលនៅក្នុងមនុស្សលោកនេះ តែងមានអគ្គីជាប្រក្រតី តែងអគ្គីដែលកើតពីរន្លះ បើភ្លើងប្រក្រតីមិនឆេះផ្ទះទេ ភ្លើងដែលកើតពីរន្លះក៏កើតមានមកដុតផ្ទះឲ្យឆេះ ឲ្យមានសេចក្តីវិនាសអន្តរាយទៅ ។

ហេតុនោះ បណ្ឌិតទាំងឡាយ បើប្រាថ្នាតែនឹងឲ្យប្រាសចាកសេចក្តី

វិនាស ប្លែកពីមានចិត្តតស៊ប្រទូសរាយចំពោះអ្នកមិនប្រទុសរាយដល់ខ្លួន ក៏នឹងបានតាំងនៅក្នុងសិរីសួស្តីមង្គលក្នុងលោកនេះ នឹងលោកខាងមុខតាមក្រសែព្រះពុទ្ធដីកាដែលត្រាស់ទេសនាទុកដូច្នេះ ។

ឧបត្ថម្ភកកម្ម សង្ខេបប៉ុណ្ណោះ ។

១០- ឧបបីឡកកម្ម

ឧបបីឡកំ នាម អញ្ញេន កម្មេន និដ្ឋាយ បដិសន្ធិយា តេជវន្តិ ចាកេ ឧបបជ្ជនកំ សុខទុក្ខំ បីឡេតិ តាបេតិ អទ្ធានំ បវត្តិតុំ ន ទេតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មបច្ច័យ សំដែងនូវឧបបីឡកកម្ម តទៅ ដំណើរសេចក្តីថា យំ កម្មំ បីឡេតិ កម្មឯណាដែលបៀតបៀននូវសុខទុក្ខដែលកម្មជនៃឲ្យកើត ដែលកម្មជនៃឲ្យបដិសន្ធិ ហើយកាត់ផ្តាច់នូវសុខទុក្ខដែលកម្មជនៃឲ្យកើត មិនបើកឱកាសឲ្យកម្មជនៃឲ្យផល កាត់ផ្តាច់នូវផលនៃកម្មជនៃ ហើយឲ្យផលដោយខ្លួនឯងវិញ កម្មនោះឈ្មោះថា ឧបបីឡកកម្ម ។

ឧបបីឡកកម្មនោះ មាន កុសលកំមាន អកុសលកំមាន ។ ឧបបីឡកកម្មខាងកុសល បើអកុសលកម្មកំពុងតែឲ្យផល ក៏កាត់ផលនៃអកុសលកម្ម ឲ្យផលដោយខ្លួនឯងវិញ ។ ឧបបីឡកកម្មអកុសល កាលកុសលកម្មកំពុងតែឲ្យផល ក៏កាត់ផ្តាច់នូវផលនៃអកុសលកម្ម ហើយឲ្យផល

ដោយខ្លួនឯងវិញ ប្រៀបដូចដើមឈើពន្លកឈើនឹងពន្លកស្មៅ ដែរឬយ៉ាង
ណា ក៏ដែរយ៉ាងនោះ ឬគ្គលណាមួយ មិនចង់ឲ្យដើមឈើ ឬស្មៅដុះដាល
ឡើងទេ គប្បីកាត់ដោយសស្ត្រាឬដំដោយដំបង ដើមឈើ ពន្លកឈើ
នឹងស្មៅវល្លិ៍នោះ មិនអាចនឹងដុះដាលឡើងជូរច្នេះ ភិក្ខុសង្ឃ បច្ចុប្បន្ន
កាលកុសលកម្មកំពុងតែឲ្យផល អកុសលកម្មក៏កាត់ផលនៃកុសលកម្ម
ចេញ គឺមិនឲ្យកុសលកម្មឲ្យផលបាន ។

ម្យ៉ាងទៀត កាលអកុសលកម្មកំពុងឲ្យផល កុសលកម្មក៏កាត់ផល
នៃអកុសលកម្មចេញ គឺមិនឲ្យអកុសលកម្មឲ្យផលកើត មានឧបមេយ្យ
ដូច្នោះ ឥត្ថំ សុជម្បតិស្សុ អកុសលកម្មំ បណ្ឌិតបុគ្គល
ចាំងឲ្យនោះ អកុសលកម្មនៃសុនក្ខត្តលិច្ឆវីកាត់ផលនៃកុសលកម្មចេញ
ហើយ អកុសលកម្មឲ្យផលដោយខ្លួនឯងវិញ មិនឲ្យកុសលកម្មឲ្យផល
កើត មានដំណាលថា ៖

សុនក្ខត្តលិច្ឆវី ដើមដំបូងជាមនុស្សជ្រះថ្លាក្នុងព្រះបវរពុទ្ធសាសនា
ទើបមកសូមបព្វជ្ជាក្នុងសំណាក់នៃសម្តេចព្រះបរមសាស្តាចារ្យ ព្រះអង្គក៏
ប្រទានបព្វជ្ជូបសម្បទា ហើយត្រាស់ប្រាប់ព្រះកម្មដ្ឋាន ឲ្យចំរើនព្រះ
វិបស្សនា ។ សុនក្ខត្តលិច្ឆវីកុំនោះបាននូវអភិញ្ញា គឺទិព្វចក្ខុញ្ញាណ
ហេតុព្រោះពុទ្ធអង្គប្រទានឲ្យនូវនិយ ឬានទិព្វចក្ខុញ្ញាណនោះដោយឆាប់ហ៊ាស
លុះបានទិព្វចក្ខុញ្ញាណហើយ ក្រាបទូលសូមនូវបែកម្មកាវនា ក្នុងទិព្វ

ឧសោភតរៅខៀត ។ ព្រះពុទ្ធអង្គក៏ប្រទានឱ្យតាមពាក្យនៃព្រះសុនក្ខត្តលិច្ឆវី ។ នោះធ្វើបវារកម្មអាវនាជាយូរយោរប្រមាណបានបីឆ្នាំ ព្រះមានព្រះភាគមិនបានប្រទានខ្ញុំទេ ។ ព្រះសុនក្ខត្តលិច្ឆវីមិនបានឮចិត្តសោភតតាមសេចក្តីប្រាថ្នា ទើបត្រិះរិះថា សម្តេចព្រះមានព្រះភាគនេះប្រហែលជាគ្រង់ជ្រាបតែត្រឹមចិត្តបក្ខប៉ុណ្ណោះទេ កាលប្រាប់ឱ្យបវារកម្មក្នុងចិត្តបក្ខនោះ គ្រង់ប្រទានទ័យឱ្យ។ ចុះយប្រៀបប្រាយឱ្យ។ តាសដល់យើងមានប្រការផ្សេង ។ យើងក៏បានដោយឆាប់រហ័ស លុះមកដល់ចិត្តសោត យើងបវារកម្មមកអស់ចំនួនបីឆ្នាំហើយ ព្រះពុទ្ធអង្គមិនបានត្រាស់ប្រាប់។ ចុះយប្រៀបប្រាយឱ្យ។ តាសសោះ បើព្រះអង្គស្គាត់ដំនាញចិត្តសោតក្នុងព្រះហឫទ័យ ក៏មុខជាប្រាប់។ ចុះយឱ្យយើងដឹងមិនខាន នោះព្រះអង្គចុះអកិញ្ចាត្រឹមតែចិត្តបក្ខប៉ុណ្ណោះ កាលព្រះសុនក្ខត្តលិច្ឆវីគំណត់សំគាល់ម៉ាក្នុងចិត្តដូច្នេះហើយ ក៏ប្រាប់លាសិក្ខានឹងប្រាប់លាព្រះរតនត្រ័យថា ខ្ញុំព្រះអង្គនឹងលះបង់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃ នឹងលះបង់នូវសិក្ខាហើយ ព្រះមានព្រះភាគចូរដឹងចុះថា ខ្ញុំព្រះអង្គមិនបានប្រតិបត្តិក្នុងព្រះពុទ្ធសាសនាឧសោភតទេ នឹងសូមជាគ្រហស្ថប្រតិបត្តិខាងក្រៅព្រះពុទ្ធសាសនាវិញ ។ សុនក្ខត្តលិច្ឆវីនោះលាសិក្ខាបទហើយ ក៏ទៅកាន់សំណាក់នៃគ្រូឈ្មោះថាឥត្ថគន្ធនាជបុត្រ ប្រតិបត្តិសិក្ខាវេស័យ ។ លិច្ឆវីនោះកំពប់ចូលក្នុងពួកតិត្ថិយបក្ខន្ទៈ ហាមមិនឱ្យ។ បសម្បន្នក្នុងព្រះពុទ្ធសាសនាខៀត ។

មានបុព្វកម្មនៃសុនក្ខត្តលិច្ឆវីនោះថា ក្នុងអតីតកាលជាមនុស្សមានផ្ទះ
នៅជិតព្រះវិហារ ថ្ងៃមួយ សាមណេរទៅលេងជលធារដោះខ្លួក បុរសនោះ
ឆ្លងទឹកទៅមាត់កំពង់ ឃើញសាមណេរអុំខ្លួកមកដឹត ក៏កើតចិត្តខឹងខ្លាំង
ជាងទឹកទៅលើសាមណេរ ។ សាមណេរខ្ចាចខ្លាច ខំគេចចេញជាលំដាប
ឃ្លាងខ្លួកលិចក្នុងទឹក ។ សាមណេរខ្ចាចស្ងាប់ ឱយយស់ដៃត្រកោះជាក
ប្រាប់ឲ្យបុរសនោះ។ ខុះត្រចៀកសាមណេរតែបែដៃ ហើយលើកសាមណេរ
តំទឹកយកឡើងមកលើច្រាំង ។ ហេតុកម្មជាអកុសល ដែលខ្លួនខុះត្រចៀក
សាមណេរផតនោះ ជាន់ប្រាប់សកយនឹងសាមណេរអ្នកមានសីល ឲ្យ
ជាន់សេចក្តីលំបាកសោយទុក្ខវេទនា ។

ហេតុដូច្នោះ សម្តេចព្រះបរមសាស្តាទ្រង់តិចាណោយើញថាសុនក្ខ
ត្តលិច្ឆវីនោះ ន៏ឯមិនជាន់ចិត្តសោតញ្ញាណទេ ព្រោះកម្មដែលខុះត្រចៀក
សាមណេរហាមឃាត់ចិត្តសោត ជាន់ជាព្រះអង្គមិនប្រជាន់ន័យ ។
សុនក្ខត្តលិច្ឆវីនោះ ចំរើនឆ្ងាសមណធម៌ ។ មិនអាចនឹងឲ្យផលជាន់ឡើយ
លុះអស់ជាតិតែហើយទៅកើតក្នុងនរក គ្មានកំណត់ថាន៏ឯរួចពីនរកនៅគ្រា
ណាទេ អកុសលកម្មកាត់ផលកុសលកម្មជាន់ ដ្បិតកម្មបៃស់សុនក្ខត្ត
លិច្ឆវីនោះជាកម្មធំ ព្រោះទៅតេញចិត្តប្រតិបត្តិតាមតិរ្ថិយនិគ្រន្ថជាមនុស្ស
មិច្ឆាទិដ្ឋិដ៏ខ្លាំងពាត់ ។ អកុសលកម្មនៃសុនក្ខត្តលិច្ឆវីនោះជាឧបបីឡិកកម្ម
តឺបៀតបៀនខ្លួកកុសលកម្ម មិនឲ្យកុសលកម្មឲ្យផលជាន់ ។

(នៅមានត)

វិធ្សរជាតក

ឯមោតស្ស បណ្ណា កាសិយាសិ ឧព្ភលាតំ នាមំ សត្ថា ជេតវនេ វិហរន្តោ បញ្ញាចារមិំ អារព្ភ កថេសិ ។ កោសាឝកៅ បពិត្រសាធុសប្បុរសឥងតាំងឡាយអើយ សត្ថា មោ: សត្ថវ-ហោ សត្ថជាយកោ រ៉ព្រះអង្គដ៏ជានាយក តែងនឹងនាំសត្វឥងតាំងឡាយ កៀរប្រមូលបញ្ជូលទៅកាន់អម្រឹតបុរីស្រឹមហានគរនិព្វានដ៏ជាស្ថានចរមសុខប្រសើរ វិហរន្តោ មោ: ចក្ខុ ឥរិយាបថេសុ វិសជាមេន្តោ ក៏ព្រះអង្គសម្រេច សម្រាន្តខានទូវព្រះឥរិយាបថស្រួតត់ ព្រះអង្គមានបួនមិនឲ្យជួនសន្ទុះ ចិត្តសត្វឥងតាំងឡាយឡើយ ជេតវនេ ឮជនគាកមនាមហៅព្រះស្រីដ៏យជេតពន មហាវិហារ អារព្ភមោះ អារម្មណំ កត្វា ដើមព្រះអង្គឆ្ពោះឲ្យអារម្មណ៍ជានតិច បញ្ញាចារមិំ និងប្រាជ្ញាជាមីវិសេស កថេសិ មោះឯម្មិនេសេសិ ដើមព្រះអង្គសម្តែងថ្លែងធម្មទេសនា ឥងំ វិដុរជាតកំ នេះទូវនិទាន និយាយ ដំណើរដំណាលកាលពោធិសត្វ ព្រះអង្គអន្ទោលទៅមកឮជនពាជ្ជសង្ឃារគ្រាស យោនយកតំណើត កើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមហៅព្រះពិធូរបណ្ឌិត អាធិតាថាបនេន អត្តជា ឧបលិក្ខិតំ ព្រះអង្គកត់សំគាល់ទូវព្រះគាថានេះ ថា បណ្ណា កាសិយាសិ ឧព្ភលាតំ នេះហោង តជាដើមបទកំណត់អក្សរបរិគាថា ឯនិយាយនិទានព្រះតំ

ជួរជាតកនេះ ឯកនិវសំ ហិ តំក្ខ ន ធម្មសភាយំ កថំ សមុដ្ឋា
បេសុំ ។ បពិត្រអើយ មានកាលសម័យថ្ងៃមួយ អស់តំកុសឡអង្គអហ-
ន្តា ទំណាស្រុតផងតាំងឡាយ សំដែងស្រើបស្រួល បបួលគ្នាទៅដំនុំនៅ
ធម្មសភាសាលា មានតំកុមួយអង្គតង់ទៅឋាននោះ មានព្រះពុទ្ធដីកាទៅ
អស់តំកុកំឡោះផងតាំងឡាយថា អាវុសោ វត សន្តា មហាបញ្ញា
ថាម្នាលអាវុសោតំកុតាំងឡាយ ទាព្រះដ៏ជាតួនៃយើងនេះ ព្រះអង្គមាន
ព្រះប្រាជ្ញានោះ ក្រៃក្រឡាមហាប្រថពី ព្រះអង្គមានប្រាជ្ញានោះទាប់រៃ
ក្រៃលែង ខំឯកជហង្សរៃញ ព្រះអង្គមានប្រាជ្ញានោះតែងជាសំរើបសំរួល
អស់ចិត្តសត្វផងតាំងឡាយ ព្រះអង្គមានប្រាជ្ញានោះស្រួចមុតថ្លាក្រៃលែង
ខំដំលំតែងឥដ្ឋពាំជមាកជាក ព្រះអង្គមានប្រាជ្ញានោះតែងខំដំលាយ
ខ្លួ មិច្ចាទិដ្ឋិខ្លួស្តុផងតាំងឡាយ ព្រះអង្គមានប្រាជ្ញានោះជ្រៅក្រៃលែង
ខំដំជំរៅមហាសមុទ្រ ព្រះអង្គមានប្រាជ្ញានោះក្រាស់ក្រៃរៃធាប់ តែង
ខំដំបុកបៃខញ្ជាមកនាំខ្លួ ប្រាជ្ញា អ្នកផងដទៃ មិនឲ្យខើសខាល់
បានឡើយ ខោះមហាសត្រអ្នកប្រាជ្ញបណ្ឌិត ព្រាហ្មណ៍ត្រិទ្ធ ក៏បុកពេ
ហិតផងតាំងឡាយ បេះខ្លួអាប្រស្នាសុខុមលាត់លបកំបាំង ប៉ុន្មានៗ ក្តី
មកដណ្តើងព្រះអង្គ ។ យកប្រាជ្ញាវិសេសអាចច្រៀងលុះខំលាយ ខ្លួបំណង
អ្នកផងនោះ មិនឲ្យមានខើសខាល់ សល់ដំពាក់ខំដំអ្នកឯណាឡើយ ហើយ
ព្រះអង្គឲ្យទុកខ្នាន ដំបូន្មានប្រដៅ អស់អ្នកតាំងអម្បាលនោះអំពីសម្បត្តិ

និព្វាន ឲ្យផ្តិតផ្ទង់ដំរាំស្មារតី ខ្ញុំលយកខ្ញុំវបញ្ចាសីលចាំង ៥ ប្រៃតៃ
ខ្ញុំវព្រះត្រៃសរណាគមន៍ ប្រសើរ ហើយព្រះអង្គដំកល់ អស់អ្នកចាំងអម្បាល
នោះក្នុងសម្បត្តិសួគ៌ សម្បត្តិនិព្វានជាស្ថានបរមសុខ ប្រសើរហោង
បពិត្រអើយ កាលអស់កិក្ខុផងចាំងឡាយបបួលគ្នាទៅ និយាយសរសើរ
ដំណើរអំពី ព្រះប្បាជ្ញាចារមីវិសេសនៃព្រះដ៏មានបុណ្យ ទៅនាធម្មសភា
លានោះ មិនជាត់ស្ងាត់ឡើយ ឮដ្រួតដ្រាបដរាបទៅដល់ព្រះស្រោតនៃព្រ
នៃព្រះដ៏មានបុណ្យ ព្រះអង្គដ្រាបអស់កិក្ខុចាំងឡាយនិយាយសរសើរ
អំពីប្បាជ្ញាចារមី វិសេសដូច្នេះ ទើបព្រះអង្គទ្រង់ពិចារណាថា កិក្ខុផងចាំង
នោះ សរសើរព្រះប្បាជ្ញាចារមីអញតថាគត ថាជាអស្ចារ្យត្រកាល តែ
អស្ចារ្យអ្វីណាក្នុងពេលដែលតថាគតបានត្រាស់ជាព្រះពុទ្ធនេះ ថាបើ
ប្បាជ្ញាថាអស្ចារ្យត្រកាលក្រៃនោះ កាលអញតថាគតយោនយកកំណើត
កើតជាតោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមហោ ព្រះពិធូរបណ្ឌិតនោះទើប
ហៅថាអស្ចារ្យត្រកាលក្រៃអេះ បើដូច្នេះគួរអញតថាគតនឹងលាទៅ
កាន់ជំនុំអស់កិក្ខុផងបន្តិចអេះ ថាបើអញមិនទៅកាន់ទីជំនុំកិក្ខុផងឥឡូវ
នេះឡើយ ណា អញតថាគតយោនយកកំណើតកើតជាព្រះពិធូរបណ្ឌិតនឹង
ចាត់ស្ងាត់ទៅសួរខ្ញុំវសោះខេហោង ។ ព្រះអង្គទ្រង់ព្រះចំណាំខ្ញុំវប្រការ
អម្បាលនោះហើយ ទើបស្តេចលាទៅស្រង់ខ្ញុំវទឹកអប់ត្រឡប់ខ្ញុំវតន្ត
តិរោរស្រេចហើយ ស្តេចទ្រង់ខ្ញុំវស្បង់មានពណ៌ស្រស់ល្អដូចផ្កាច្បាចតឹម

រហើយទើបស្តេចយកទូវព្រះកាយពន្ធមកវណ្ណព្រះអង្គ ដ៏មានពណ៌ខោះដូចផ្កាបន្ទោរ ប្រាកដតាមព្រាតនៅលើកំពូលភ្នំព្រះសុមេរុបពិតមាជ ទើបព្រះអង្គទ្រង់ព្រះត្រៃចីវរឈ្មោះមហាបង្សុកូល ឃ្លុំត្រលុំស្រេចហើយ ស្តេចសីហនាទគគាតចេញអំពីព្រះសុគន្ធកុដិស្រីសយនាក្រឡាព្រះបន្ទំ ទៅកាន់ជំនុំអស់កុក្ខដងតាំងឡាយ ស្តេចឡើងលើធម្មាសនៈ គឺអ្នកគ្រាលទូវកំពាលចៀមចំព្រៃព្រំសឹងដ៏ខ្ពង់ខ្ពស់ល្អខ្ពស់ប្រសើរ ហើយមានព្រះពុទ្ធដីកាដណ្តឹងអស់កុក្ខសង្ឃអង្គអាហុតិ្តណាស្រេចដងតាំងឡាយថា កិត្តេថ ភៃកុក្ខដងតាំងឡាយអើយ ហេតុអ្វីអ្នកតាំងឡាយ កំស្រើបស្រួលបបួលគ្នាមកអង្គុយស្រដីនិយាយមិនត្រជាស់ឡើងចេញទៅឥដ្ឋៃ រកចំរើនមេត្តាភាវនាប្រាថ្នាឲ្យបានសម្បត្តិមគ្គផលដល់និព្វានប្រសើរ។ ទើបអស់កុក្ខដងតាំងឡាយ សឹងលើកទូវកំបង់អញ្ជលីជាក់លើសៀសាអង្គ ហើយក្រាបថ្វាយបង្គំប្រណម្យទូលថា កច្ចេ កកវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ យើងខ្ញុំមកជំនុំគ្នានៅនាសភាសាលានេះ មិនស្រដីសរសើរអំពីសម្បត្តិនៃព្រហ្មចរមេចក្រតត្តិកដទៀយ យើងខ្ញុំមិនអាចស្រដីអំពីឥត្ថភាពបុរិសភាព គឺរូបស្រីប្រុស ឲ្យទុសជាមទ្ទិលក្នុង ព្រះសាសនាព្រះអង្គមោះគ្មានទៀយ យើងខ្ញុំស្រដីតែអំពីដំណើរព្រះប្រាជ្ញាចារើរសេសព្រះអង្គដ៏ជាម្ចាស់កុដតាត្រៃ នៃយើងខ្ញុំនេះឯង ទើបព្រះដ៏មានបុណ្យព្រះអង្គមានព្រះបន្ទូលថា ភៃអាវុសោតិក្ខដងតាំងឡាយអើយ នាព្រះចារើរអញ

តថាគតនេះ មិនជាអស្ចារ្យច្រើនដូច្នេះឡើយ នេះហៅថាវិស័យព្រះពុទ្ធ
ពាំងឡាយ បើបានត្រាស់ច្រើនជាញឹកញាប់ ជាព្រះពុទ្ធច្រើនដូច
ដូចអញតថាគតហើយ ក៏ស៊ីងមានច្រើនជាច្រើន តែងនឹងរាត់ចំណាយ អន្យ
តរ័ឡើងហើយ បន្ទោបង់នូវសន្ទនៈកន្លង នៃទេវតាតួចធំ ឥន្ទព្រហ្មនាគជ
ឃក្ខ គន្ធប អាសុរ មហាក្សត្រាធិរាជ អ្នកច្រើនជាពាំងឡាយ តើកុ
អើយ ថាបើសរសើរច្រើនជាច្រើនអញតថាគតអស្ចារ្យត្រកាលក្រៃលែង តែ
កាលតថាគត អន្ទោលទៅមក ដោយយកកំណើតកើតជាពោធិសត្វមួយ
ព្រះអង្គទ្រង់ព្រះនាមហៅថា ចៅពិធូរអ្នកច្រើន អាចឲ្យដំបូន្មាន ឃក្ខសេ
នាបតីមួយឈ្មោះបណ្ណកឃក្ស នៅនាក់ពួលក្នុងកៃលាសគីរីបពិត ច្រើនជ
មានកំពស់ ៦ យោជន៍ ដោយច្រើនជាអត្មាអញ ឲ្យឃក្សនោះនឹកសបង់
ហើយផ្តន់ឲ្យដើរតែជាតាមផងនឹងសាងសន្សំ ព្រះចារមីពោធិសម្ភារ ធឹងឲ្យ
ជាន់ត្រាស់ ច្រើនជា សព្វេញ្ញូតញ្ញាណជាព្រះពុទ្ធច្រើនជ កាលនោះជា
អស្ចារ្យក្រៃ ។ តណ្ហាំ អបោសិ ព្រះអង្គបន្ទូលតែមួយព្រះឧស្ន្ទជួបច្នោះ
ហើយ ស្តេចបញ្ឈប់ព្រះពុទ្ធដីកា តង់សៀមវៀរហោង ទើបពាក្យចំណោទ
ថាអ្នក ការណ៍ហេតុអ្វីព្រះដ៏មានបុណ្យ ព្រះអង្គមានព្រះបន្ទូលតែមួយ
ព្រះឧស្ន្ទពីរព្រះឧស្ន្ទ ខ្ញុំៈហើយក៏បញ្ឈប់ព្រះពុទ្ធដីកាតង់សៀមវៀរ ធម្មទេ
សនាអស់តែម្ល៉េះឯង ឬមួយព្រះអង្គខ្លួន ។ ពាក្យចំឡើយថាបពិត្រ អ្នកអើយ
អ្វីក៏ព្រះអង្គនឹងមានខ្លួនឡើយ ហើយធម្មទេសនាព្រះអង្គសោត ពាំង

៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ហើយមានព្រះបន្ទូលតែមួយព្រះឱស្ឋព្រះ
ឱស្ឋម្ចាស់ក្បូថាធម្មទេសនានោះអស់ដូច្នោះ ។ ចោទថាបើព្រះអង្គមិនទ្វិល
ឡើយ ហើយធម្មទេសនាព្រះអង្គថាមិនអស់ ដ្បិតអ្វីក៏ព្រះអង្គមិនសម្តែង
ថ្លែងធម្មទេសនាឲ្យឆ្ងាយខ្លួលាយទៅហ៊ឺ: ឆ្លើយថា នាព្រះអង្គមិនសម្តែង
ឲ្យឆ្ងាយខ្លួលាយទៅនោះ កំព្រះអង្គនិងរមិលមើលកំណើតសត្វផងតាំង
ឡាយ សត្វឯណាចូលចិត្ត សត្វឯណាពុំចូលចិត្តនឹងធម្មទេសនា ថា
បើសត្វឯណាចូលចិត្តនឹងធម៌វិសេសហើយ សត្វនោះសឹងត្រេកអរសរ
សើរថា ទុព្រះពុទ្ធអើយ ព្រះអង្គទេសនាពីពេះអ្វី មាលឲ្យយហ: សត្វឯ
ណាបើសរសើរធម្មទេសនាដូច្នោះហើយ រីសត្វនោះស្មើបានឡើងស្ថិតលើ
ក្រឡាខាងកជវេ ខឹងអណ្តែតត្រសែតឡើងទៅសម្បត្តិសួគ៌ សម្បត្តិ
និព្វានទោះទៀងប្រាកដហោង សត្វឯណាបើបានឮធម្មទេសនាហើយ
ទៀបប្រែតិះដៀលធម្មទេសនាហើយ រីសត្វនោះស្មើជាក់ដែកដុលប៉ុនដើម
ត្នោតទៅក ហើយទៅហែលខឹកសមុទ្រជំពែក ហែលតែខ្លួនទេម្តេច
ភ្លាស ។ ឮទំនិងរួចពុំរួច ចំណង់បើជាក់ជាំងដែកដុលផងសោត តែងនឹង
តាំងអាត្មាលិចលង់ទៅក្នុងអន្ទង់ជ្រៅ គោលគឺតតាដូរសត្វរនោះប្រាកដ
ហោង បើដូច្នោះ ហាក់ដូចព្រះអង្គទេសនាតាំងសត្វទៅនរកវិញ ហេតុ
ដូច្នេះឯង ទើបព្រះអង្គមានបន្ទូលតែមួយព្រះឱស្ឋពីព្រះឱស្ឋជាហេតុបន្ទិច
ហើយ ព្រះអង្គបញ្ជាប់ព្រះពុទ្ធដីកាស្ងៀមទៅថា បើមានអ្នកឯណាមួយសូម

អាភាធនា និមន្តព្រះអង្គទើបព្រះអង្គសម្តែងវិថ្លង់ឲ្យឆ្ងាយខ្លួលាយទៅហោង។
កាលនោះ អស់ភិក្ខុផងចាំងឆ្ងាយ សឹងលើកតំបង់អញ្ជលីជាក់លើសិរសា
អាត្មាទៀត ។ ហើយក្រាបថ្វាយបង្គំប្រណម្យ សូមអាភធនាធម្មទេសនាថា
កន្លែ ភគវា បពិត្រព្រះដ៏មានបុណ្យ ព្រះអង្គអាចប្រតង្រះលំយោយខ្លួ
ចំណងវដ្តសង្សារផងចាំងឆ្ងាយហើយ នាព្រះអង្គមានបន្ទូលអម្បាញមិញ
ថាព្រះអង្គយោនយកកំណើតកើតជាតោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាម
ហៅចៅពិជូរអគ្រប្បាជ្ញនោះ សូមព្រះអង្គយកព្រះប្រាជ្ញាញាណវិសេស ១
ឈ្មោះបុព្វេនិវាសានុស្សតិញ្ញាណនោះ ទៅឧបត្រាសោប អស់ខ្លួសន្តានធ
ធម៌ចាំងឆ្ងាយ មកសំដែងសណ្តាប់ប្រាប់អស់យើងខ្ញុំផងកាលឥឡូវនេះ ។
ទើបព្រះដ៏មានបុណ្យ ព្រះអង្គខ្លួលយកនិមន្តអស់ភិក្ខុផងចាំងឆ្ងាយ ព្រះ
អង្គយកព្រះប្រាជ្ញាញាណវិសេសមកដំកល់ទុកក្នុងហឫទ័យ ហើយព្រះ
អង្គដើកព្រះឧស្ណច្រាលរស្មីដូចត្តកម្ពល បញ្ចាញខ្លួព្រះសូរសៀង
នោះ មូលក្រាងក្រអៅជ្រៅជ្រះផ្លែមល្អែមពីពេះសោះសាទបមាដ៏ដូចសូរ
សម្ងួនព្រហ្ម ទុតួមប្រសើរដំណើរដំណាលកាលព្រះអង្គទ្រង់ធម្មទេសនា
កន្ទួនរំលងទៅហើយនោះ បន្ទូលថា អតីតេ ភិក្ខវេ កុរុរដ្ឋេ ថា
ម្នាលភិក្ខុផងចាំងឆ្ងាយអើយ ភិក្ខុអើយ នាកាលកតកាន់តប្បាកាលចាំង
កំចាំងជាត់ស្ងាត់រំលងកន្ទួងយូរទៅហើយនោះ មានមហាក្សត្រាធិរាជ ១
ព្រះអង្គទ្រង់ព្រះនាមហៅព្រះបាទធនញ្ជាយកោរព្យរាជ សោយរាជសម្បត្តិ

នៅនាឥន្ទបថបូរីស្រីមហានគរ មានកូដវាំងដូនោះឯង ហើយមហាសូត្រ
នោះមានអាមាត្យមួយឈ្មោះចៅពិជូរអ្នកជ្រាជ្ញ កំតែងនឹងប្រដៅអាថ
ធម៌សេចក្តីលោភ័យលោភាវេហាគតិតការចេញចូលសត្វថ្មីមិនបាត់ក្រែនឹង
ចៅពិជូរអ្នកជ្រាជ្ញនោះឡើយ ហើយចៅពិជូរអ្នកជ្រាជ្ញ កំតែងនឹងសម្តែង
ធម្មទេសនានោះផ្អែមល្ហែម ពិពេះសោះសាមហិមាក្រៃពេក តែងលួង
លោមអស់ស្តេចអំឡុងសកលទ្វីបមកនៅចាំស្តាប់ធម្មទេសនានោះ ហើយ
មហាសូត្រចាំងអម្បាលនោះ មិនអាល័យមមែមមាញឹកឡើក នៅគាន់ជ-
សម្បត្តិ និត្តែព្រះនគរបាវរាជសេមាទិវៃ ឡើយ នាអស់មហាសូត្រ
ចាំងអម្បាលនោះ មិនអាល័យចង់នៅគាន់ពជសម្បត្តិនោះ តើនឹងគណនា
ឧបមាដូចអ្វី ថាដូចដំរីផងចាំងឡាយ កំលុះចេញអំពីព្រៃហនកន្ទែង
លុះលែងអាត្មាទិវៃ ហើយ កំមកចង់ស្តាប់សព្ទពីណាព្រះបាទទេនពជ
នោះពិពេះសោះសា មិនអាល័យនៅព្រៃស្តានកន្ទែង លុះលែងអាត្មាទិវៃ
នាចៅពិជូរអ្នកជ្រាជ្ញសម្តែងធម្មទេសនា ជាសណ្តាប់អស់មហាជនផងចាំង
ឡាយនោះ មិនយល់ជាចៅពិជូរអ្នកជ្រាជ្ញនោះឡើយ យល់ហាក់ដូចដំ
ណើរព្រះពុទ្ធ ព្រះអគ្គសម្តែងធម្មទេសនាជាសណ្តាប់នៃទេវតា មនុស្សសត្វ
ផងចាំងឡាយ រីចៅពិជូរនោះសោត ប្រកបទ្វេយសសក្តិ ល្ងើងរុងរឿងនៅ
កូដវាំង្ស ឥន្ទបថបូរីស្រីមហានគរនោះហោង បពិត្រអើយ អធិប្បាយនិយាយ
នេះយើងសណ្តែតទុកទ្វេនេះស្ងែះសិន យើងនឹងសម្តែងថ្វែងនិយាយមួយ

វិញទៀត កាលនោះមានព្រាហ្មណ៍ ៤ នាក់ មានទ្រព្យសម្បត្តិនោះច្រើន ជាមិត្រសំឡាញ់ទិត្យនៅពាក្យណាណាបួរស្រែមហានគរ រីព្រាហ្មណ៍ទាំង ៤ នាក់នោះ លុះដល់ដកចាស់ហើយ សង្ឃារនោះរាពុំទៀងឡើយ ហើយបបួលគ្នាចេញទៅអំពីនគរនោះ ហើយដើរចូលទៅកន្លែព្រៃហិមពាន្ត បួសជាតាបសមហាឫស្សី បង្កើតនូវអភិញ្ញាសមាបត្តិ ហើយតែងនឹងស្វែងរក ផ្លែឈើ មើមឈើ មកបរិភោគសព្វថ្ងៃជាចំណីអាហារពុំដែលដាច់ឡើយ នៅជាកំឡុងទៅ រីតាបសទាំង ៤ នាក់នោះ មានចិត្តចង់រកបិណ្ឌបាតជាយគេនាន់ហោង លុះព្រឹកឡើងហើយ តាបសទាំង ៤ អង្គនោះនាំគ្នាដើរចេញអំពីព្រៃកដល់ព្រាន ចូលទៅកាន់ចំបាកនគរ ប្រយោជន៍ដើម្បីនឹងស្វែងរកបិណ្ឌបាតជាយគេ រីកុដុម្ពនគរនោះ មានកុដុម្ពិក ៤ នាក់ជាមិត្តសំឡាញ់ជាន់គ្នា កាលបើបានយល់តាបសទាំង ៤ អង្គ សឹងដឹងប្រកបខ្លួរវិរិយាបថស្រគត់គ្នាទ្វេយចូលទៅដូច្នេះហើយ រីកុដុម្ពិកទាំង ៤ នាក់ សឹងដឹងចិត្តត្រេកអរជ្រះថ្លាសទ្ធាចុះមកពីផ្ទះអាត្មាពីនៃ ។ ទៅថ្វាយបង្គំសូមទទួលភាជន៍ចាយអំពីដៃតាបសទាំង ៤ នោះ ហើយនាំយកមួយទៅកាន់ផ្ទះអាត្មាពីនៃ ។ ហោង កាលបើបានទៅដល់ផ្ទះអាត្មាហើយសឹងដឹងប្រប្រជាប់ចង្ហាន់ ប្រគេនឲ្យបានស្រេចទៅហើយ មកស្រដីផ្តាំផ្តែផ្តាំពាក្យថា បពិត្រព្រះតាបសទាំង ៤ ព្រះអង្គអើយ ចាប់ដើមអំពីថ្ងៃនេះទៅសូមអាភធានាមន្តមកផ្ទះយើងខ្ញុំសព្វថ្ងៃ ។ ហោង ។ រីតាបសទាំង ៤ អង្គ

នោះ សឹងទទួលតាក្យប្តេជ្ញាពីកងទ្រុម្ភ័កទាំង ៤ នាក់នោះ ហើយលាទៅទៅ
ខាងក្រៅ។ល។ ចំរើនមេត្តាភាវនា ហើយតែងមកកាន់ផ្ទះកុងទ្រុម្ភ័កទាំង
៤នោះ ពុំដែលដាច់ឡើយ តាបសទាំង ៤អង្គនោះតាបស ១ អង្គ ទៅ
ធ្វើសំណឹងថ្ងៃទៅឰដពីកពក្រៃត្រីន្ស្ស រីតាបស ១ អង្គ ទៅធ្វើសំណឹងថ្ងៃ
ទៅឰដពីកពនាគនាយ រីតាបសមួយអង្គទៅធ្វើសំណឹងថ្ងៃទៅឰដពី
កពសុបណ្ណគ្រុឌជ រីតាបស ១ អង្គ ធ្វើសំណឹងថ្ងៃទៅឰដពីកពមនុស្ស
ក្បាន ជាហានព្រះបាទធនញ្ជយកោរព្យាជ ឯតាបសទាំង ៤ នោះមិញសឹង
ជំរើលមើលយល់ សម្បត្តិសំបូរណ៍ឥស្សរសស្តាជ៌ក្បាកអធិកក្រៃនៃព្រះ
មហាក្សត្រាធិរាជទាំង ៤ នោះ ហើយមកស្រដីសរសើរដំណើរដំណាល
កាលអាត្មាបានយល់នោះប្រាប់ទៅបាសក តែងបម្រើបដ្ឋាក អាត្មាទី
ក្រៃ ទាំង ៤ នោះហោង រីកុងទ្រុម្ភ័កទាំង ៤ នាក់នោះ សឹងជាមានចិត្តត្រេកអរ
ជ្រះថ្លាសទ្ធា សង្ឃឹតធ្វើបុណ្យឲ្យទានប្រាថ្នាឲ្យបាន់ទៅកើតជាមហាក្សត្រ
សោយរាជសម្បត្តិស្តិតនៅស្ថានពិមាននៃ ជីតុនអាត្មាមកប្រាប់នោះហោង
រីកុងទ្រុម្ភ័កទាំង ៤ អ្នកនោះ កាលបើលែងជាតិអំពីមនុស្ស សឹងបានទៅកើត
នៅឋានដូចបំណងប្រាថ្នាអ្នកនោះ អាត្មាទីក្រៃ ១ ម្នាក់ទៅកើតជាសម្តេច
ឥន្ទ្រាធិរាជ ម្នាក់ទៅកើតជាព្រះបាទពិរុណាឥតរាជម្នាក់ទៅកើតជាព្រះបាទ
សុបណ្ណគ្រុឌជ ម្នាក់ទៅជាប់ប្រតិសន្ធិនៅក្នុងទេវវរព្រះអគ្គមហេសី
នៃព្រះបាទធនញ្ជយកោរព្យាជ នាងទ្រង់តតិលុះក្រៃ ១០ ត្រប់បរិបូណ៌ពុំ

ឃ្លះឡើយ ខាងប្រសូតព្រះកដបុត្រប្រុស ឲ្យឈ្មោះថាធនញ្ជយកុមារ
កាលនោះហោង ឯព្រះតាបសទាំង៤ អង្គនោះសោតហោង កាលណា
បើលែងជាតិអំពីមនុស្សលោកនេះ សឹងបានទៅកើតនាព្រហ្មលោកនាយ
ហោង រីថាធនញ្ជយកុមារ កាលណាបើចំរើនធំឡើងហើយ សម្តេច
ព្រះវរបិតាព្រះអង្គសុតតទៅ ទើបអស់មុខមន្ត្រី សេនាបតីផងអភិសេកព្រះ
កដបុត្រនោះឲ្យសោយរាជ្យគ្រងស្នងសម្តេចព្រះវរបិតាជាមហាក្សត្រ ព្រះ
អង្គទ្រង់ព្រះនាមហៅព្រះបាទធនញ្ជយកោរព្យរាជ សោយរាជសម្បត្តិ
ដោយទូវធម៌ ចិញ្ចឹមអស់អាណាប្រជានុកស្ត្រផងទាំងឡាយដោយប្រពៃ
រីមហាក្សត្រនោះសោត ព្រះអង្គឡាច់ក្រសាលទូវលែងស្តា ឥតមហាក្សត្រ
ណាមួយ នឹងឈ្នះព្រះអង្គបានឡើយ ហើយព្រះអង្គតែងធ្វើបុណ្យឲ្យទាន
រក្សាសីល ព្យាយាមចំរើនមេត្តាភាវនាពុំដែលដាច់ឡើយ ហេតុព្រះអង្គស្ថិត
ដោយទូវដំបូន្មាននៃចៅពិធូរអ្នកប្រាជ្ញនោះហោង ។ មានកាលមួយថ្ងៃ ព្រះ
បាទធនញ្ជយ កោរព្យរាជ ព្រះអង្គអាចស្នាមានចាំសីល៩ចោសថហើយចេ
ជូរចេញអញ្ជើចាំសីលនាស្ថានសួត់បន្តិចបានអេះ ស្តេចគិតអម្បាលនោះ
ហើយ ស្តេចលីលាទៅកាន់ព្រៃ១ព្យានស្ថានសួត់តាប់ចិត្តសាងសីល
ប្រសើរហោង ។ រីសម្តេចឥន្ទ្រាធិរាជសោត ស្នាមានចាំសីលបរិសុទ្ធ
រហើយ បន្តូលថាអញចាំសីលស្ថានទេវលោកនេះ វាកន្ទ្រិលអំពល់ពេក
បើដូចេ្នះអញនឹងទៅចាំសីលឯមនុស្សលោកនាយ សម្តេចឥន្ទ្រាធិរាជគិត

អម្បាលនោះហើយ កំហោះទៅកាន់ព្រៃទ្យាននន់ស្ថានស្ងាត់គាប់ចិត្ត សាធសីលបរិសុទ្ធហោង រួចព្រះបាទនាគរាជស្នាក់នៅចាំសីលទ្បោសថ គិតថា បើអញចាំសីលនៅនេះហើយ ទីធកើតកង្វល់ពលិភោជនៅនាពិភពនាគនោះ បើដូច្នេះអញទៅចាំសីលព្រៃទ្យាន ស្តេចគិតអំបាលនោះហើយ ឡើងមកអំពីពិភពនាគ មកកាន់ព្រៃទ្យាន ស្តេចនន់សាធសីលប្រសើរហោង រួចព្រះបាទសុបណ្ណគ្រុឌរាជស្នាក់នៅចាំសីលទ្បោសថ ហើយក្រែងមានកង្វល់ ពលិភោជនាព្រៃកោ ស្រេចហើយ មកកាន់ព្រៃទ្យាននន់នាស្ថានស្ងាត់ ហើយសាធសីលសមណធម្មប្រសើរហោង ។ លុះសម័យថ្ងៃរសៀលហើយ មហាក្សត្រាធិរាជទាំង ៤ ព្រះអង្គនោះ សឹងចេញមកអំពីស្ថាន អាត្មាទីខៃ។ មកប្រជុំគ្នានាស្រះថ្លល់មង្គលទ្បោក្សណៈ ។ រួមហាក្សត្រទាំង ៤ ព្រះអង្គរមិលមើលទៅឃើញគ្នាទៅមកហើយ ហេតុតែជាមិត្រសំឡាញ់គ្នាអំពីមុនមិញ កាលបើបានឃើញគ្នាហើយ មានចិត្តរមែត្រេកត្រេកអរសោទរព្រមគ្នាផង ធ្វើពាក្យផ្តែផ្តាំលាក្តីមតីពេះ សួរទុក្ខសុខគ្នាទៅវិញទៅមកហើយ ហេតុតែជាមិត្តកាលនោះហោង ។ ឯសម្តេចឥន្ទ្រាធិរាជ ព្រះអង្គតន់លើក្រឡាកម្ពលសិលា រួមហាក្សត្រទាំង ៣ អង្គនោះ សឹងតន់អាស្នាសំគួរនឹងអាត្មាតន់ដោយលំនៅអាត្មាទីខៃហោង ។ លំដាប់នោះឥន្ទ្រាធិរាជ បន្ទូលទៅនឹងមហាក្សត្រទាំង ៣ ថា ព្រះអង្គអើយ នាយើងទាំង ៤ នេះ សឹងតែមហាក្សត្រសោយរាជសម្បត្តិបីតនៅនគរទើ

វៃ ។ ហោង កំមកចាំស័ល នាស្ថានសួគ៌នេះជាមួយនឹងគ្នា ជាស័ល្លអ្នក
ឯណាប្រសើរលើស ។ លំដាប់នោះព្រះបាទពិរុណនាគរាជ ឆ្លើយថាមហា
រាជ ស័ល្លខ្ញុំឯងប្រសើរលើសមហារាជទាំង៣ព្រះអង្គ ព្រះអង្គ ហេតុអ្វីខ្ញុំថា
ស័ល្លខ្ញុំគប្រសើរនោះ ដ្បិតព្រះបាទសុបណ្ណគ្រុឌរាជនេះ គាត់ជាសត្រូវ
នឹងខ្ញុំ មិនប៉ុន្តែកាលឥឡូវនេះឡើយ ជាសត្រូវនឹងខ្ញុំប្រចាំកាល រឿង
រាបដរាបមកដល់ឥឡូវនេះ ហើយខ្ញុំបានយល់ សត្រូវនឹងធ្វើឲ្យខ្ញុំ
ក្ស័យជីវិតហើយ ខ្ញុំមិនទាំងនឹងសត្រូវឡើយ ព្រះបាទពិរុណនាគរាជ
មិនបន្ទូលតទៅឡើយ សូត្រជាបទគាថា ជាប្រឋមដើមបទថា យោ កោ
បនេយ្យ កកោតិ កោបំ ។ ថាបពិត្រមហារាជ នាឮប់ព្រះគា
ថាលោកថា នែអ្នកឯណាមួយនោះ ក្សត្រក្តី ព្រាហ្មណ៍ក្តី ដ៏មានចិត្តអំណត់
អត់មិនទាំងនឹងអ្នកជាសត្រូវនឹងអាត្មា គួរនឹងទាំងនោះ កំអ្នកនោះហោង មាន
ធម៌សប្បុរសមិនទាំងដល់ម្តងឡើយ នោះយោបល់ក្តីកំពុងតែក្នុងចិត្តឯង
មិនឲ្យដឹងជាក់ច្បាស់ឡើយ ក៏ហេតុនោះហោង អ្នកប្រាជ្ញលោកសឹងសរ
សើរអ្នកនោះឯងជាស្រមណ៍ខត្តមថ្លៃឮដរាបលោកនោះហោង ។ រីព្រះបាទ
សុបណ្ណគ្រុឌរាជស្តាប់ហើយឆ្លើយថា មហារាជ ស័ល្លខ្ញុំប្រសើរលើស
មហារាជទាំង៣ វិញ ដ្បិតអ្វីខ្ញុំថាស័ល្លខ្ញុំប្រសើរលើស ព្រោះព្រះបាទពិ
រុណនាគរាជនេះ គាត់ជាចំណីអាហារត្រកាលខ្ញុំឯងនោះ គាត់នៅ
កណ្តាលប្រវាលតតមហាសមុទ្រ ម្តេចអញខ្ញុំទៅចាប់ឆក់ឆួលយួរយកមក

ជាចំណីតាហោរ នេះម្តងបានយល់ទូវមុខដាក់ហើយ តួរតែនឹងចាប់ធីជាចំណីតាហាខ្ញុំ ។ អត់ទូវសំរេកគំលាន ខ្ញុំមិនចាប់ស៊ីឡើយ ខ្ញុំភ្ញាចជាប់សីលខ្ញុំ ហេតុនោះហោង ខ្ញុំថាសីលខ្ញុំប្រសើរហោក់លើស ។ ព្រះបាទសុបណ្ណគ្រុឌជ បន្ទូលទ្បើ៉ះហើយ សូត្រជាបទគាថាថា : ឧដោ ឧកោ យោ សហាតោ ជិយ្យិ ។ ថាបតីត្រមហាជ នូវអ្នកឯណាមួយមានដៃជើងដល់ឆ្នើងខ្លួន ហើយអាចអត់ទូវសំរេកគំលានខ្លួនឥន្ទ្រិយមិនមានចិត្តមិញ្ញាទិដ្ឋិ រ៉ែអ្នកប្រាជ្ញលោកសឹងសរសើរអ្នកនោះជាស្រមណ៍ឧត្តមក្រៃ ឮដល់លោកនេះហោង ។ លំដាប់នោះ សម្តេចឥន្ទ្រាធិរាជបន្ទូលថា មហោរាជ សីលអញប្រសើរលើស ដ្បិតអញលះបង់នូវរាជសម្បត្តិ សួគ៌ទេវលោកនាយដ៏ជាបរមសុខ មានប្រការផ្សេងៗ មកចាំសីលឮដល់មនុស្សលោកនេះ ហេតុនោះហោង៍អញថា សីលអញប្រសើរលើសនឹងសីលមហាជតាំង ៣ វិញហោង៍ សម្តេចឥន្ទ្រាធិរាជបន្ទូលទ្បើ៉ះហើយសូត្រជាបទព្រះគាថា ថា : ខិឌ្ឌំ រតឹ វិបុ្បជហិ ត្វា សព្វំ ។ ថាមហាជ នូវអ្នកឯណាមួយ អាចលះបង់នូវចំណងបញ្ចកាមគុណតាំងពួងនឹងខ្លួន ទំនឹងភក្ស ទំនឹងចិត្ត មិនស្រដីភក្សកូតដល់តិចឡើយ ហើយវៀរអំពើស្ពាន៍អាត្មាដោយប្រដាប់ប្រដា វៀរអំពើហាក់សេព មេថុនធម្ម រ៉ែអ្នកប្រាជ្ញឯង សឹងតែសរសើរអ្នកនោះ ថាស្រមណ៍ឧត្តមក្រៃ ឮដល់លោកនេះហោង ។ ឯព្រះបាទធនញ្ជយកោរព្យ

ភាជស្តាប់ហើយ ឆ្លើយថាមហាភាជ ខ្ញុំប្រាសលះបង់ព្រះភាជមន្ទីរនូវស្រីព្រះ
ស្ងួមួយម៉ឺនប្រាំពាន់ច្រើនណាស់ក្រៃ ឥឡូវនេះខ្ញុំមកកាន់ព្រៃព្រះហោម-
ពាន្ត ទទ្បានសាងសង់ធ្វើធម៌ ចាំសីលប្រសើរ នោះយល់ជាសីលខ្ញុំប្រសើរ
លើស ។ រីព្រះចុងធនញ្ជយកោរព្យភាជ បន្ទូលម្ល៉ោះហើយសូត្រជា
បទគាថា ថា : បរិក្កមិំ លោភធម្មា សព្វំ ។ ថាបពិត្រមមហាភាជ នូវអ្នកឯណាមួយដឹងដោយប្រាជ្ញបីប្រការ ហើយត្រមលះបង់
នូវសម្បត្តិសម្បូរណ៌ឥសូរទ្រព្យរបស់យសស្តិ ហើយចេះខ្ជាន់អាត្មាប្រ
ពៃ មិនអាល័យមមៃមមាញឹករលឹកគៀកកូនប្រពន្ធ អ្នកប្រាជ្ញធឆ៌តាំងឡាយ
លោកសឹងសរសើរអ្នកនោះថា ជាស្រមណតុត្តមក្រៃឮដលោកនេះហោង។

(នៅមានត)

នរជនណា យកធម៌ជាក់ពីមុខ មិន រវល់គិតថា ម្ចាស់ស្រឡាញ់ ឬមិនស្រ ឡាញ់ ហើយអាចហ៊ានតុះពារពោលពាក្យ មិនជាឱនាប់ចិត្តចំពោះម្ចាស់ផង នរជននោះ ពុកជាមិត្រព្រះរាជាពិត ។
ហិតោបទេស

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរថែរក្សា
ឲ្យបានខ្ជាប់ខ្ជួន	គង់វង្សតរៀងទៅ
ព្រោះអក្សរជាតិ	ពោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ច. ព.

គួរតែប្រឡែះភ្នែរ:ខ្លះបោល

(វិចារណាកថា)

លោក ជេង-ជ្រៀ និតន្ត

មនុស្សពីរនាក់តែប្រណាំងគ្នា ម្នាក់ចេះតែឈ្នះ ។ អ្នកជនចេះតែបន្ទោសអ្នកចាញ់ថាហេតុអ្វីក៏ខ្ជិល មិនហាត់តែ មិនខំតែឲ្យលឿនជាន់គេ ឬណាយឲ្យតែចាញ់គេកាល់ក្តា មិនដឹងតែលណាទើបជាន់ជោគជ័យម្តង ព្រោះខ្លួនក៏អាយុប្រហែលទើរគេ សុខភាពក៏មានបរិបូណ៌ដូចគេ តើប្រការម្តេចក៏យ៉ាងនេះ ?

មុនដំបូង អ្នកចាញ់ចេះតែធ្លាប់ទើរខ្លួនឯងថា មិនគួរបើជួបប្រទះសោះ ឬមួយមកពីពូជខ្លួន ឬមួយប្រហែលមកពីខ្លួនគ្មានសំណាងខាងតែងឈ្នះ ឬជាទំណាស់ដែរ នៅតែតែមិនជាន់គេ ។ លុះជញ្ជឹងទើរពិចារណាកេហតុផលទៅ ស្រាប់តែលេចឡើងមក តែមកពីខ្លួនស្ទើរតាក់តែងការច្រើនស្រេចចំពោក ប្រាកដជាខ្ជោគារនេះហើយដែលធ្វើឲ្យខ្លួនតែមិនសូវលឿន ព្រោះណា ខ្លើសចំណែង ណាធ្ងន់ ខាំងនេះហើយជាប្រកបដែលនាំឲ្យ

ខ្លួនជួបច្រកតែនឹងបាត់ជ័យ ។

ឥឡូវយើងពិចារណាមើលការវិនិច្ឆ័យនៃអ្នកចាញ់ ដោយសំអាងថាមកតែពីសំលៀកបំពាក់ច្រើនស្រទាប់ ក្នុងកាលនៃការរត់ប្រណាំងតើមានសភាវសមហេតុផលឬទេ?

ការវិនិច្ឆ័យនេះ គឺពិតជាត្រូវប្រាកដ មិនចាំបាច់ធ្វើការសង្កេតយូរឡើយ ព្រោះម្នាក់ ខ្លួនស្រាលត្រមាំងមិនមានវត្ថុអ្វីជាគ្រឿងធ្វើឲ្យរំខានដល់ចលនារបស់ខ្លួន អ្នកនេះត្រូវតែរត់ឈ្នះអ្នកម្នាក់ដទៃដែលមានខ្លួនរុំព័ទ្ធដោយគ្រឿងរំខានជាជាងប ។ ចំពោះរឿងនេះ មិនគួរបន្ទោសអ្នកចាញ់ឲ្យសោះ ចើតាមត្រូវ គួរសរសើរទៅវិញ ដ្បិតគ្មានសុទ្ធខ្លះ ចានរំយ៉ំពេញមុខជារវេតធ្វេសប្រហែស ឯបាត់ជ័យ មិនមែនមកពីខ្លួនធ្ងិលទេ គឺមានតគ្គារក្រៅចូលមករំខានទេតើ ។

សេចក្តីពណ៌នាខាងលើនេះ ជាការប្រៀបធៀបនៃសេចក្តីពិចារណាដោះស្រាយ ស្តីពីការសិក្សាខ្លួនឯងទៅប្រទេសយើង ដើម្បីឲ្យងាយយល់ នឹងធាប់ចូលចិត្តស្តាប់ចាន ។

ចូរយើងត្រឡប់មើលទៅប្រទេសនា ។ ក្នុងសាកលលោក ជាតិសេស គឺប្រទេសណាដែលមានវឌ្ឍនភាពបរិបូណ៌ខាងការសិក្សា សំគាល់មើលថាតើប្រទេសនោះ ។ តម្រូវការសិក្សាដល់ឃុវជនរបស់គេ មានប៉ុន្មានបែប ប៉ុន្មានយ៉ាង ? តាមភ្នាប់ចាន់ដឹង ហើយប្រហែលជាការណ៍ពិតផង រឿងលែងតែប្រទេសបិតនៅក្នុងអាណាព្យាបាលចេញ ឃុវជន

ក្នុងប្រទេសណា ក៏មានការតម្កល់ចុងសិក្សាតែភាសាជាតិរបស់ខ្លួនប៉ុណ្ណោះ។ ចូរក្រឡេកមើលថយក្រោយម្តង ក្នុងសម័យដែលចាប់ពីមិនទាន់ចូលមកក្នុងប្រទេសកម្ពុជា កូនខ្មែរទៅរៀនអក្សរទៅតាមវត្តអារាមនៃព្រះសង្ឃ ក្នុងរយៈពេលតែមួយឆ្នាំ យ៉ាងយូរណាស់ត្រឹមពីរឆ្នាំ ក្មេងទោះចេះអានអក្សរខ្មែរសព្វគ្រប់ គឺថាចេះអានគ្មានខាត់ ឈ្មោះថាអក្សរខ្មែរ គេមានជម្រៅសេចក្តីដូចម្តេច ក៏អាចអានបានចាំងអស់ ។ សេចក្តីនេះបញ្ជាក់ឲ្យយើញថា ការសិក្សាភាសាតែមួយ ចំពោះរូបជនតែម្នាក់ វែមានរបៀនយ៉ាងនេះ ។

ទៅបច្ចុប្បន្នសម័យ ការចេះអានស្ទាត់នូវភាសាជាតិ មានរយៈពេលយូរបន្តិច (៤ឬ៥ ឆ្នាំ) ការយឺតយូរនេះ បណ្តាលមកពីអ្វី ? ដូចបានពោលមកហើយ គឺបណ្តាលមកពីការសិក្សាវិជ្ជាច្រើនមុខ ហួសកម្លាំងនៃយុវជន ជាពិសេស គឺភាសាបរទេស ជាភាសាដែលយុវជនយើងមិនធ្លាប់ឮ មិនធ្លាប់ស្តាប់ តាំងពីកុមារភាពមក ។ ខ្ញុំយល់ថា គ្រប់សាសន៍តាំងអស់កន្លងលោក រៀវលែងតែមនុស្សព្រៃចេញ មិនមានសាសន៍ណាមួយ ប្រសើរជាងសាសន៍ណាមួយឡើយ កុំឲ្យតែសាសន៍នោះមានគេសង្គត់សង្កិន ទប់ខ្សែបង្ខ្រៀ និយាយនេះគឺចំពោះការសិក្សាវិជ្ជា ។ តួយ៉ាង យុវជនខ្មែរ កាលក្នុងសម័យអាណាព្យាបាលចាប់តាំង ភាគតិចណាស់ដែលមានវិជ្ជាជាន់ខ្ពស់ ។ តាមដែលខ្ញុំដឹង ក្នុងបណ្តាប្រជាពលរដ្ឋខ្មែរ

ចំនួន ៥ លាននាក់ អ្នកដែលមានសញ្ញាប័ត្រមធ្យមសិក្សាប្រហែលមិនដល់ ៣ ១០ នាក់ផង អ្នកដែលមានសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ យ៉ាងច្រើន ប្រហែល ១០០ នាក់ ក្នុងរយៈវេលា ១ សតវត្ស ។ ទើបមានកើតជាបណ្ដោចទៀងថា ហេតុដូចម្ដេចក៏ក្នុងសម័យអាណាព្យាបាលបាត់ជនជាតិខ្មែរមានសញ្ញាប័ត្រមធ្យមសិក្សាតិចម្ល៉ះ (សូមឲ្យចំពោះសញ្ញាប័ត្រឧត្តមសិក្សា) ។ បើតាមការពិសោធន៍ ខឹងការសង្កេត គឺរឿងនេះមកតែពីគេមិនត្រូវការឲ្យយើងចេះ ។

សួរថាបើគេមិនត្រូវការចង់ឲ្យយើងចេះ ហេតុម្ដេចក៏គេបង្កើតសាលារៀន ហើយជួយចំណុចបំរុង មានចាំងឲ្យអាហារូបករណ៍ផង ?

ចំពោះសំនួរនេះ គឺមិនពិបាកនឹងឆ្លើយទេ កិច្ចការចាំងប៉ុន្មានដូចពោលខាងលើ គេធ្វើឡើងដើម្បីវត្តុបំណងតែម្យ៉ាង ។ ឯវត្តុបំណងនោះ ទៅត្រង់រកមនុស្សឲ្យជួយគេតែប៉ុណ្ណោះ ដែលខំចង់ឲ្យយើងក្លាយទៅជាអ្នកចេះត្រឹមត្រូវពិតប្រាកដ ដើម្បីចំរើនជាតិ ដើម្បីកសាងជាតិ ដូចព្រះរាជហឫទ័យប៉ុនប៉ងនៃសម្ដេចឪយើងនោះ គឥតអង្គឺមានឡើយ ។ ឧបមាដូចអ្នកស្រែចំការចង្អាត់ឬតគ្រាប់គោក្របី ឲ្យចេះស្គាប់ឆ្ងន-ស្គាំ ឲ្យដឹងថាទៅ-ឈប់ ។ល។ គេធ្វើដូច្នេះ ដើម្បីប្រយោជន៍អ្វី ? ដើម្បីឲ្យគោឬក្របី មានចិត្តគំនិតជាបែបមនុស្សឬ ? អ្នកណាដែលយល់យ៉ាងនេះ ឈ្មោះថាមានការគាន់ច្រឡំពិត ។ គេបង្អាត់ឬតគ្រាប់គោក្របី ដើម្បីគ្រាន់តែ

ឲ្យជួយធ្វើការ ដើម្បីបន្ទុកម្ចាស់គេតែ ។ សេចក្តីនេះមានទុបមាយ៉ាងណា អាណាព្យាបាលថ្នាក់ឆ ដែលបានបង្ហាត់បង្រៀនយើងក្នុងជាន់នោះ ក៏មានទុបមេយ៉ាងដូច្នោះ បានជាគេបង្កើតមុខវិជ្ជាយ៉ាងច្រើនហើយពិបាកផង ដែលជាហេតុកាត់ឆន្ទៈតម្រូវនៃយុវជនយើង ។

ចុះសម័យឥឡូវនេះ ប្រទេសកម្ពុជាយើង មានឯកភាពប្លែកពីបរទេសក្នុងអាណាព្យាបាលអ្វីខ្លះណាក៏ដឹងដែរថា កម្ពុជា ជាប្រទេសឯករាជ្យតាំងពីឆ្នាំ ១៩៥៣ មែ៎ះ ។ ពាក្យថាឯករាជ្យ តើមានប៉ុន្មានប្រការ ? ប្រការទី ១ គឺឯករាជ្យខាងនយោបាយ ប្រការទី ២ ឯករាជ្យខាងតុលាការ ប្រការទី ៣ ឯករាជ្យខាងសេដ្ឋកិច្ច ប្រការទី ៤ ឯករាជ្យខាងវប្បធម៌ ។ ចាប់ពីឆ្នាំ ១៩៦៤ តទៅ ឯករាជ្យខាងសេដ្ឋកិច្ចខ្មែរមានហើយ ចំណែកឯករាជ្យខាងអក្សរសាស្ត្រវិញ មានសភាពជាក់ឮស្តាប់ប្លែកទេ ! បើតាមរដ្ឋធម្មនុញ្ញយើង គឺមានចែងត្រង់មាត្រា ៣ ថាអក្សរជាផ្លូវការ គឺអក្សរខ្មែរ ។ តាមសេចក្តីនេះ ឯករាជ្យខាងអក្សរសាស្ត្រមានហើយដែរ ។ ប៉ុន្តែ តាមការសង្កេតត្រួតមជ្ឈដ្ឋានក្នុងប្រទេស មានសាលារៀនជាដើម ឃើញថាការប្រើអក្សរជាតិ ដូចជាមិនទាន់ពេញលេញ។ ចំពោះសាលារៀន ចាប់ពីថ្នាក់មជ្ឈមដ្ឋានឡើងរហូតទៅ ភាសាបរទេសចូលមកជ្រៀតជ្រែកជាជាងភាសាជាតិ ហើយជាការចាំបាច់ផង ។ សព្វថ្ងៃភាសាជាតិក្នុងសាលារៀន មានឥទ្ធិពលតែពីថ្នាក់កុមារដ្ឋានដល់អាទិកដ្ឋានប៉ុណ្ណោះ ។ តពីនេះទៅ ឥទ្ធិពលខ្លួនត្រូវតែប្រជែងនឹងភាសាបរទេស

ហើយថយចុះបន្តិចម្តង ។ ជល់ទីអាសោនៃការសិក្សា នៃយុវជនវិញ ។ ត្រង់នេះជាចំណុចសំខាន់នៃបទពិចារណា ។ គួរសរសើរអ្នកតែឈ្នះព្រោះតែអ្នកនោះមានខ្លួនដែលគ្មានអ្វីមកធ្វើឲ្យរំខានឬ? គួរបង្អាប់បន្ទុះអ្នកបរាជ័យ ព្រោះតែអ្នកនោះមានអាគ្នារួបរឹតដោយគ្រឿងរំខានឬ ? តាមយោបល់ខ្ញុំ មិនគួរអ្នកផងពោលសរសើរអ្នកទី ១ ហើយបង្អាប់បន្ទុះអ្នកទី ២ ឡើយ ព្រោះគូប្រជែងមានការៈមិនស្មើគ្នា ។ ចូរយើងសង្កេតមើលអ្នកប្រជាល់ក្តី សេះរត់ប្រណាំងក្តី មុននឹងគេយកគូប្រជែងបញ្ចូលកន្លែងសៀវៀនប្រឡងនិទ្ទេ គេនិយមថ្លឹងទម្ងន់មើលជាដរាប លុះតែគូប្រជែងមានទម្ងន់ស្មើគ្នា ទើបគេអនុញ្ញាតឲ្យចូលប្រឡងនិទ្ទេគ្នា ការធ្វើយ៉ាងនេះឈ្មោះថាប្រកបដោយយុត្តិធម៌ ។

តើយើងគួរដោះស្រាយដូចម្តេច ចំពោះការសិក្សាកន្លែងមួយជាដរាបឲ្យដែលកំពុងត្រូវការអ្នកបច្ចេកទេសច្រើន ឲ្យសមល្មមទៅតាមការកែទម្រង់សេដ្ឋកិច្ចនៃសម្តេចឥ ជាការកែទម្រង់ដ៏ប្រពៃអស្ចារ្យ ។ ឬយើងនៅតែពេញចិត្តចំពោះត្រង់ឲ្យមានពន្ធុកច្រើន តែឥតប្រយោជន៍ ឬក៏ឲ្យមានពន្ធុកមួយ តែបានការ? ខ្ញុំយល់ថា ដើម្បីធ្វើយតបឲ្យត្រឹមត្រូវល្អនឹងការកែទម្រង់ខាងសេដ្ឋកិច្ចនៃសម្តេចឥ គួរតប្បីតែកែកម្មវិធីសិក្សាជាថ្មី បើមិនដូចនោះទេ មិនដាយនឹងកែអ្នកបច្ចេកទេសឲ្យត្រប់គ្រាន់ ដើម្បីជួយផែនការសម្តេចព្រះបិតាសេដ្ឋកិច្ចជាតិបានឡើយ ។ យើងឃើញស្រាប់ហើយ

ប្រទេសកម្ពុជា ខ្វះអ្នកបច្ចេកទេសសម្រាមណាស់ ។ តាមការសង្កេត
អ្នកបច្ចេកទេសខ្មែរខ្លាំក់ ត្រូវគ្រប់គ្រងមុខការច្រើនកន្លែង ដែលជាហេតុ
នាំឲ្យមានការត្រួតពិនិត្យមិនសូវដិតដល់ ឃ្លេ ។ ឃើញមានគ្រោះថ្នាក់ខាង
ហិរញ្ញវត្ថុជាតិត្រង់នេះម្តង ត្រង់នោះម្តង ។ល។ គួរឲ្យស្តាយពន់ពេក
ដែលយើងនាំគ្នាចំសន្សឹតាំងពី ១ សេន ១ កាក់ឡើង ដើម្បីពូតផ្គុំជា
សម្បត្តិជាតិ ហើយគេលណាគ្រោះថ្នាក់ខាងហិរញ្ញវត្ថុជាតិកើតមានម្តងគឺ
កប់រយលាន ដែលអ្នកគួចគាបបានពួរហើយ មានសេចក្តីព្រឺនឹងតក់ស្លុតពន់
ប្រមាណ ។ ឯគ្រោះថ្នាក់ខាងហិរញ្ញវត្ថុជាតិនេះ បណ្តាលមកតែពីយើង
មានអ្នកបច្ចេកវេសមិនគ្រប់គ្រាន់ ។ ការខ្វះអ្នកបច្ចេកទេស បណ្តាលមក
តែពីអ្នកសិក្សាជាតិមិនមានកម្លាំងធួនល្មម ទើបបន្តវិជ្ជាឲ្យបានដល់ទីដៅ ។

សួរថា ហេតុអ្វីក៏មិនទំប្រឹងឲ្យទៅដល់ទីដៅ ?

ឆ្លើយថា បានជាទៅមិនដល់ទីដៅ ព្រោះត្រូវអីវ៉ាន់អាតុយ ដោយ
ហេតុមកពីទំប្រឹងក្នុងគ្រាមុនជ្រុលពេក បើមិនទំប្រឹង រត់មិនខាន់តែដែល
ជាហេតុបណ្តាលឲ្យមានភាក្សាទន្ទាថាខ្វះខ្លឹល ម្ល៉ោះហើយធ្វើអាតុយ
ត្រូវតែអីវ៉ាន់នេះ ទើបបន្តដំណើរតទៅទៀតពុំបានឆ្ងាយ ។

ដើម្បីកុំឲ្យធ្វើអាតុយអីវ៉ា ត្រូវតែសំខៃ ត្រូវតែកុំផ្តុកឲ្យធ្ងន់ពេក នេះ
ហើយជាបញ្ហា ដែលត្រូវដោះស្រាយជាបន្ទាន់ទន្ទឹមគ្នាទើបការកែទម្រង់
សេដ្ឋកិច្ចជាតិ ។

ចំពោះរឿងនេះ តាមយោបល់ខ្ញុំ គួរតែប្តូរតែកែប្រែកម្មវិធីសិក្សាខ្លះ ដូចជាសម្តេចឯកបានមានព្រះបន្ទូលម្តងរួចហើយក្នុងពេលសមាជៈ ទី១ ទ្រង់ថ្លែងថា ភាសាបរទេស គួរឲ្យសិស្សសិក្សានៅថ្នាក់លើបានហើយ ទី២ ទ្រង់ថ្លែងថា ការសិក្សាគួមិនសាស្ត្រ ខឹងប្រវត្តិសាស្ត្របរទេសវែងៗពេក មិនជាបានផលអ្វីដល់ជាតិប៉ុន្មានឡើយ ។ ព្រះយោបល់ដ៏ប្រសើរថ្លៃថ្លានេះ តាមមតិខ្ញុំ គឺយោលទៅរកហេតុដូចតទៅៈ ភាសាបរទេស គួរពុកឲ្យសិក្សាដោយឡែក គឺថាបង្កើតវិជ្ជាស្ថានផ្សេង សម្រាប់តែអ្នកស្ម័គ្រក្នុងការសិក្សាភាសាចំនឹងនេះ មិនគប្បីយកមកបញ្ចូលលាយឡំក្នុងកម្មវិធីសិក្សាខ្លួនៅរបស់ជាតិឡើយ ធ្វើដូច្នេះ ជាតិនឹងអាចមានរបៀបក្នុងការសិក្សាដូចប្រទេសដទៃក្នុងលោកបាន ហើយអ្នកបច្ចេកទេសជាតិ នឹងមានចំនួនគ្រប់គ្រាន់ដល់សេចក្តីត្រូវការនៃកិច្ចការជាតិទាំងឡាយ ជាពិតប្រាកដ ។

សួរថា បើឲ្យសិក្សាតែភាសាជាតិ រហូតដល់ទុតមវិជ្ជា តើនឹងយកអ្នកចេះតែភាសាជាតិមកធ្វើជាអ្នកបច្ចេកទេសដូចម្តេចកើត ព្រោះអ្នកបច្ចេកទេស ត្រូវមានវិជ្ជាតែមួយយ៉ាងជាក់ប្លាស់ តាមមែកធាងរបស់ វា ដូចជាអ្នកបច្ចេកទេសខាងកសិកម្ម អ្នកបច្ចេកទេសខាងពេទ្យ អ្នកបច្ចេកទេសខាងពាណិជ្ជកម្ម ។ល។ ហើយវិជ្ជាខាងបច្ចេកទេសទាំងនេះសោត សព្វថ្ងៃបិតនៅតែក្នុងភ្លៃនៃភាសាបរទេស ? ។

ឆ្លើយថា រឿងនេះជាការងាយទេ ។ សព្វថ្ងៃ យើងមានអ្នកបង្ហូតទេស
ជាតិ ដែលចេះភាសាបរទេសយ៉ាងច្បាស់ ច្រើនស្ទើរគ្រប់វិស័យហើយ
ដែរតួរតែបង្ហាត់ឯអ្នកទាំងនេះ ជាគណៈកម្មការទាំងប្រកាសភ្លាម ហើយប្រែ
វិញបង្ហូតទេសគ្រប់មែកធាងទាំងនេះមកជាភាសាជាតិវិញ ក៏ងាយស្រួច
បើមានសុធន្ទះហើយ មិនមានអ្វីគាចមកកកាងដំណើរបានឡើយ ។ កូន
ខ្មែរសិក្សាភាសាខ្មែរ ពន្ធេញមេលេខជាភាសាខ្មែរ រឿងវិជ្ជាបង្ហូតទេស
ជាភាសាខ្លួន តាមយោបល់ខ្ញុំ ថាទឹងមានសន្ទុះលឿន ជួចប្រទេសដទៃ
មិនខាន មិនយូរប៉ុន្មាន អ្នកបង្ហូតទេសជាតិ ឧទ្ទឹងមានចំនួនគ្រប់គ្រាន់
ដល់ការប្រើប្រាស ដែលជាហេតុបន្ទួយយ៉ាងច្រើនជាអតិបរមា ទ្វារថវិកា
ជាតិ ក្នុងការជួលបរទេសឲ្យមកជួយ ។ មិនតែប៉ុណ្ណោះសោត គឺធ្លាជាល់
ការចំណាយខាងសម្ភារៈថែមទៀត មានក្រដាសជាដើម ។ ដោយអា-
ស្រ័យការពឹងផ្អែកទៅលើអ្នកបង្ហូតទេសបរទេសច្រើន យើងត្រូវតែប្រើក្រ
ដាសខ្លួ ១ ជាតិរ បើមិនធ្វើយ៉ាងនេះ ជនបរទេសមិនយល់ការណ៍អ្វីក្នុង
តំបូកសាងជាតិរបស់ខ្មែរ ។

ម្យ៉ាងទៀត តាមការសង្កេតរបស់ខ្ញុំ ភាសាក្នុងតំបូការពេជការ ថ្វីត្បិត
តែមានចែងក្នុងរដ្ឋធម្មនុញ្ញថា «អក្សរប្រើជាផ្លូវការគឺអក្សរខ្មែរ» តំបិតនៅ
ដោយភាគច្រើន ជាភាសាបរទេស ។ សូម្បីក្នុងក្រដាសដែលចោះពុម្ព
ជាអក្សរជាតិហើយ ក៏អ្នកពេជការយើងភាគច្រើន ឧយមបុះបំពេញតែជា

អក្សរបរទេស ។ ការណ៍នេះសឲ្យឃើញនូវការពេញចិត្តជាអតិបរមា ចំពោះអក្សរបរទេស នៃអ្នកពាក្យខ្មែរជាំងឡាយជាពិសេស គឺចៅក្រសួងនានា ។ ត្រង់នេះ សូមចេីកវង់ក្រចកបន្តិច : ចេីមានពាក្យអ្វីសរសេរជាអក្សរជាតិ ឯកទត្តមយេីង មិនពេញចិត្តក្រឡេកមេីលទេ ត្រូវរកយកណ្តឹងហៅស្មៀនឬលេខាមកមេីលឲ្យស្តាប់ ឬសង្ខេបជាភាសាបរទេសឲ្យ ផ្ទុយទៅវិញ បេីពាក្យនោះជាអក្សរបរទេសវិញ អានហេីយអានទៀត ពិពេះណាស់ ពិពេះណាស់ បេីមានពាក្យថ្មីមួយដែលអាត្មាមិនចេះ ស្ទុះភ្លែតបេីកវចនានុក្រមភ្លាម ហេីយខេះក្បាលខ្លួនឯងថាមិនគួរអញមិនចេះសោះពាក្យនេះ ជួនកាលពេញចិត្តពេក កត់ទុកក្នុងកូនសៀវភៅមួយក៏មាន ។ ហេីយបេីកាសាជាតិវិញ គ្រាន់តែគេបង្កើតពាក្យថ្មីខ្លះ ដេីម្បីបង្ក្រឹបក្នុងការប្រើប្រាស ឯកទត្តមយេីង តោលចាក់ដោតជាយកពាក្យ « ជាលីឬស៊ំស្ត្រិត » មកប្រេី ដាំឲ្យតែខេីសខែង ។ ហេតុអ្វីក៏ដូច្នេះ ជាមកពីឯកទត្តមយេីង មិនទម្លាប់គានភាសាជាតិតាំងពីកុមារមក ។

ប្រសិនបេីមិនកែប្រែកម្មវិធីសិក្សាសាធារណៈ ឲ្យគាន់ពេលវេលាទេ រឿងនិយមភាសានៃអ្នកពាក្យខ្មែរ នឹងក្លាយទៅជាការប្រកាន់វណ្ណៈដូចនៅសហរដ្ឋអាមេរិកមិនខាន ។ ចូរសង្កេតតាមឪពុកម្តាយឲ្យច្បាស់ចុះ សព្វថ្ងៃកូនអ្នកខ្មែរសិក្សាគន់ច្រេីន មិនទៅសិក្សាឯសាលារៀនជាតិ លាយឡំជាមួយ

កុមារខ្លះទៀតឡើយ គេនិយមទៅសិក្សាឯសាលារៀនបារាំង (Descartes) មានខ្លះទៅរៀនឯប្រទេសក្រៅតែម្តង ។ ចំពោះរឿងនេះ តើគេយល់ថា ភាសាជាតិនឹងភាសាបរទេសមានតម្លៃផ្សេងគ្នាយ៉ាងណា ? ខ្ញុំសូមឆ្លើយភ្លាមថា គឺគេចុកភាសាបរទេស ជាភាសាត្រួត ជាភាសានាយក ឯភាសាជាតិ ជាទាសភាសា អ្នករៀនចេះភាសានេះ ទោះបីមានជម្រៅយ៉ាងណា ក៏ទៅតែមិនដល់ភាសាបរទេសដែលគេចេះតែបន្តិចបន្តួច គឺថាអ្នកចេះភាសាជាតិ ត្រូវតែទៅក្រោមបង្គាប់គេជាដរាប ។

សួរថា ប្រសិនបើឲ្យអ្នកចេះតែភាសាជាតិ ដឹកនាំកិច្ចការផ្ទៃ ហើយអ្នកចេះភាសាបរទេសត្រូវទៅក្រោមបង្គាប់វិញ តើទៅរួចឬទេ ?

ឆ្លើយថា ក្នុងបច្ចុប្បន្ននេះ ភ្លាមៗ ចើតាមយោបល់ខ្ញុំ គឺទៅមិនរួចទាល់តែសោះ ត្បិតវិជ្ជាបរទេសផ្សេង ។ បិតទៅតែក្នុងវិស័យភាសាបរទេស លុះណាតែរៀបចាកការយ៉ាងម្ចាស់ទ្វារវិជ្ជាបរទេសចាំងនោះចេញមក ហើយរបាបត្រាកទៅក្នុងវិស័យភាសាជាតិ នោះអ្នកចេះតែភាសាជាតិ ទើបអាចត្រួតពិនិត្យនឹងដឹកនាំកិច្ចការផ្ទៃបាន ។ ចូរយើងក្រឡេកមើល ហើយគួរឲ្យខ្មាស់ប្លែ ប្រទេសឯកពាជ្យចាំងឡាយក្នុងសាកលលោក រៀបលែងតែប្រទេសឥណ្ឌៀចេញ ព្រោះប្រទេសនេះមានតាមភាសាច្រើនរាត (២២០ភាសា) និយមនិយាយនឹងសរសេរជាផ្លូវការខ្លួនភាសាជាតិរបស់គេ គឺថាគេស្រឡាញ់នឹងគោរពកម្លាំងតែក្នុងបុព្វបុរស

គេ ។ គួរឲ្យស្ទើចសរសើរណាស់ នូវប្រទេសចិន ដែលមានតួរអក្សរច្រើន
ទឹងផ្សែង ។ ជាប់សន្ធានពីគ្នា ហើយបើចង់ចេះអានសារតែមានចំនួនត្រូវឲ្យ
ចេះ ២៥០០ ពាក្យ បើចង់ឲ្យទៅជាអ្នកចេះ ត្រូវឲ្យចេះ ៤០០០ ពាក្យ ដោះ
ប៉ុយ៉ាងនេះ តំនេះនិយាយ ប្រើប្រាស់ភាសាគេសព្វគ្រប់ គ្មានពឹងផ្អែក
ទៅលើអក្សរបរទេស ក្នុងកិច្ចការសាធារណៈ ទាំងនេះសឲ្យឃើញថា គេ
ស្រឡាញ់ភាសាជាតិគេពន់ពេក គេធ្វើឲ្យអក្សរទឹងភាសាគេ មានឯក
ភាពដូចរៃស៊ីយដែរឯង ។

ស៊ុបសេចក្តី ប្រទេសកម្ពុជា ដែលខ្វះអ្នកបង្ហើកទេសជាតិ មកពីយុវជន
សិក្សាភាសាច្រើន មុខវិជ្ជាក៏ច្រើន ដែលជាហេតុធ្វើឲ្យគ្នាអស់កម្លាំង មុន
ចានដល់ទីដៅ ដូចដែលខ្ញុំចានពណ៌នារួចហើយ ។ តាមយោបល់ខ្ញុំ គឺថា
ហើយថាទៀត គួរតែប្តូរតែកែប្រែកម្មវិធីសិក្សា ខន្ធឹមគ្នាទឹងការកែទម្រង់
រដ្ឋកិច្ចជាតិនៃសម្តេចឪ ដើម្បី ទី ១ ឲ្យមានអ្នកបង្ហើកទេសជាតិគ្រប់គ្រាន់
ដល់សេចក្តីត្រូវការនៃជាតិ ព្រោះកាលសម័យកសាងនគរវត្ត ដែលសព្វ
ថ្ងៃគ្មានអ្នកបង្ហើកទេសបរទេសណា អាចធ្វើដូចបាន សម័យនោះគឺតាក់
តែងស្តាបនាឡើងតែដោយស្នាដៃនៃអ្នកបង្ហើកទេសជាតិ ឥតពឹងផ្អែកបរ-
ទេសមកជួយឡើយ ទី ២ កុំឲ្យមានគំនិតប្រកាន់វណ្ណៈ ដែលជាហេតុទឹង
ធ្វើឲ្យមានការក្តៅក្រហាយទៅអនាគត ទី ៣ ឲ្យអក្សរសាស្ត្រទឹងភាសា
ជាតិរីកចំរើនទឹងមានតម្លៃស្មើដូចអារ្យប្រទេសឯកពាក្យ។ ទី ៤ ឲ្យមាន
ការធ្វើស្រាលដល់ថវិការជាតិ ដែលជាហេតុញ៉ាំងដីវភាពប្រជាពលរដ្ឋឲ្យរឹង
រឹតតែប្រសើរតទៅ ។

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង-ខាត់ រៀបរៀង

(តមក)

អធីម្ត ន ពុំ.ការសុំទឹកពីសំណាក់ត្រូ ។

អធុនា ក. ឥឡូវនេះ ។

អធុនាតន–ឝី គុ. នៃលពីឥឡូវនេះទៅ ។

អធ្រុវ ស្ត្រី. ស្ថានការណ៍នៃលមិនមែនជាធុរៈនៃអ្នកនាំ ។

អធ្វមក គុ. នៃលមានផ្សែងមិនខាន ។

អធ្វតិ ស្ត្រី. កិរិយាមិនឆ្ងំឆ្ងល ; កិរិយាមិនរឹងប៉ឹង ។

អធ្វម្ត គុ. នៃលរឹងមិនមាន នៃលសុភាព នៃលរាបសា ។

អធ្វម្យ គុ. នៃលឈ្លះមិនមាន នៃលមិនឈ្លះ នៃលក្លាមិនចុះ ។

អធៃយ៌ំ ន ពុំ. កិរិយាមិនឆ្ងំឆ្ងល កិរិយាមិនម៉ឺងម៉ាត់ កំសោយ ។

អធោ មើល អធស៑ ។

អធៅត គុ. នៃលមិនលាង នៃលមិនស្អាត ក្រខ្វក់ ។

អធ្យក្ស ពុំ. អធិការ អនុរក្ស មេ នាយ ។

អធ្យក្សរម៑ ក្រ. វិ. តាមឫទ្ធិ ។

អជ្ឈគ្គិ ក្រ. វិ. លើភ្នើង ។

អជ្ឈធិន គុ. នៃលចុះក្តួល នៃលភក្តី ។

អជ្ឈធ្យេម៉ ក្រ. វិ. តាមធ្លុះ ។

អជ្ឈយន ឧ ប្ចុ. កិរិយាសិក្សា (ខាងគន្ថីរវេទ) ។

អជ្ឈធ៌ គុ. នៃលប្រៃលែងដោយពាក់កណ្តាល នៃលលើសពាក់កណ្តាល ។
– គុណ គុ នៃលមានគុណប្រៃលែងដោយពាក់កណ្តាល ។ – គត
គុ. នៃលមានរយប្រៃលែងដោយពាក់កណ្តាល (១៥០)

អជ្ឈហិណីយ គុ. នៃលគួរនិល់កិរិយាខ្ជះខ្ជៅដោយប្រៃលែង ។

អជ្ឈវសា ក្រ. គឺតវ៉ា កាន់កាប់ ត្រាំរិះ ។ អជ្ឈវសិត គុ.
នៃលសម្រេចហើយ នៃលកាន់កាប់ហើយ នៃលល្បីហើយ ។

អជ្ឈវសាយ ប្ចុ. កិរិយាប្តេជ្ញាធំប្រៃលែង សេចក្តីព្យាយាម អជ្ឈវសា-
យិន គុ. នៃលប្តេជ្ញាថា នៃលសម្រេចថា ។

អជ្ឈាកាឝម ក្រ. វិ. ឮដអាកាស ។

អជ្ឈាក្រម៉ ក្រ. ដើរទៅប្រៃលែង លោត ជ្រាយ ជាក់ ជ្រើសរើស។

អជ្ឈាគម៉ ទៅប្រៃលែង ឆ្លាក់ ឆ្លុះ ឆ្លុយ ។

អជ្ឈាបរ៉ ក្រ. ប្រព្រឹត្តទៅប្រៃលែង ប្រើប្រាស ។

រឿង អាប៊ូលហ្វាអ៊ីរ៉ិស (ត)

លោក ភ៉ាយ ស្មុត តំណាងកម្ពុជ ប្រែរៀបរៀង

បន្ទាប់ពីសេវកាទាជកាតាំងនេះ ទាងកនហ្សាឌុកក៏ចាប់ប្រឡែងជាមួយខ្លួនឯង សំឡេងស្រួយដូចតារ៉ើ សូរសេពពិពេរអណ្តែតអណ្តូងលើសមហោស្រពយ៉ាងល្អ នៅទៀលោក ដូចចាស់ព្រឹទ្ធាចារ្យតែងដំណាលនោះទៅទៀត ។ ចាយរួចហើយ មានគេយកកាដន់មាសតូចមួយ មកដាក់នៅក្បែរកេងច៍នោះ មានសំបកសម្បុរល្អែន ដែលមានខ្លឹនត្រអូបល្អពិសេសជាងគេ កងកោះ សេរេនឌីប ។ យើងតាំងពីនាក់លាងដៃនឹងទឹកអប់ក្រអូបអស្ចារ្យនោះ ស្រេចហើយក៏អង្គុយ ដោយមានចិត្តចាប់អារម្មណ៍ខ្លាំង ទៅលើចំរៀង ឌីងរបាំតាំងឡាយ រហូតដល់យប់យឺនសម័យ ។ នាកាលខ្ញុំក្រោកឈរឡើងចង់គោរពលា ទាងកនហ្សាឌុកក៏ស្រែកថា ៖ ចុះអ្នកប្រុសសំឡាញ់ មានសេចក្តីថ្នាំងថ្នាក់អ្វីបានជាគិតអញ្ជើញចោលខ្ញុំឲ្យនៅតំព្រាម្នាក់ឯង ?

(ត.) – ខ្ញុំឥតមានសេចក្តីថ្នាំងថ្នាក់អ្វីបន្តិចបន្តួចសោះឡើយ សូមលោកស្រីអភ័យទោស ចំពោះការឆ្គាំឆ្គងនេះឲ្យទាន ។ ហេតុបានជាខ្ញុំចង់សុំលា ព្រោះខ្ញុំយល់ថា លោកមហាសេដ្ឋី ហាប៊ីប ប្រាកដជាលោកមានព្រួយបារម្ភ ដោយមិនឃើញខ្ញុំទៅជួបនឹងលោក ហើយលោកនឹង

មានទុក្ខព្រួយកាន់តែខ្លាំងទៅទៀត ប្រសិនបើលោកពុំយើញខ្ញុំ ទៅទទួលទានដំណេក នៅផ្ទះលោកទេ ។ សេចក្តីខ្វល់ខ្វាយរបស់ខ្ញុំ នាំឲ្យនាងកនហ្សាឌុ យល់អធ្យាស្រ័យបានភ្លាម តែនាងពុំព្រមឲ្យខ្ញុំទៅដាក់បង្គំលាលោកមហាសេដ្ឋី ដោយខ្លួនឯងទេ នាងទទួលសុំឲ្យខ្ញុំសរសេរសំបុត្រ ហើយនាងខ្វល់ខ្វាយជួយរៀបរៀងសេចក្តីផង សេចក្តីថា ៖ «ខ្ញុំមានការមមាញឹកយ៉ាងសំខាន់ជាចាំបាច់ តម្រូវបង្ខំឲ្យខ្ញុំពន្យារដំណើរខ្ញុំ ទៅតិចបីថ្ងៃទាងមុខទៀត ហើយសូមលោកមហាសេដ្ឋី កុំមានព្រួយបារម្ភអ្វីនឹងខ្ញុំឲ្យសោះ» ។ ដល់បានសេចក្តីអះអាងជាខ្លឹកក់ក្តៅដូច្នេះស្រេចហើយ នាងកនហ្សាឌុ ដឹកដៃខ្ញុំ ចូលទៅកន្លែងបន្ទប់មួយយ៉ាងធំទូលាយ ដែលនាងបានរៀបចំជាស្រេចទុកឲ្យខ្ញុំ ។ បន្ទប់នេះ ជាបន្ទប់មានលំអចាញ់បន្ទប់ដទៃ ក្នុងប្រាសាទលោកស្រី ទោះជាតអង្គឹមានឡើយ ។ នាងស្តុកទុកខ្ញុំឲ្យនៅក្នុងបន្ទប់នេះ បន្ទាប់ពីនាងចេញផុតក្រៅពីបន្ទប់ទៅ មានខ្ញុំចំរើជារាប់រយ នាំយកទៅជូនខ្ញុំ ដោយគោរពន្ធូវប្រដាប់ប្រដាត្រប់ចៃបត្រប់យ៉ាង សម្រាប់ផ្គាស់សំលៀកបំពាក់ ហើយខ្ញុំតំណាងនេះអញ្ជើញខ្ញុំ ដោយលំអុតលំនែនកាយ សូមឲ្យខ្ញុំសម្រាកសម្រន្តជាសុខសាន្តតទៅ ។

ក្នុងពេលស្ងាត់តែម្នាក់ឯង ចិត្ត (អា.) មមៃគិតថា ៖ រឿងនេះតើនឹងទៅជាយ៉ាងណាហ្ន៎? អញមានសំណាងល្អឬអ្វី? ប្រាសាទនេះសម្បូណ៌

សប្បាយអ្វីម្ទេះ ? អញត្រូវសង្ឃឹមថាទទេថា បន្តិចទៀត អញនឹងបានជាប្តីលោកស្រី កញ្ញាកបកល្បាណី ឥតបីមានគូប្រៀបនេះ..ទេ! ទេ! ឯងកុំទៅលង់ខ្លួនក្នុងផ្លូវខុសផ្លូវប្លុះ នេះគឺជាអន្ទាក់ជាក់ឯងទេតើ!... ឯងមិនត្រូវស្រមៃរឿងវង្វេងចង់បានច្រឡាសម្បត្តិខាងនេះ គោគច្រឡាប្លុំណ្ណេះ មិនយូរប៉ុន្មាន ដួចក្លាកូឡាប ត្រូវស្ងិតស្រនោងជ្រុះរលាយអស់ទៅ ដួចយល់សប្តិ ក៏មានទម្លាប់យ៉ាងដូច្នោះដែរ..ទេ! ទេ! ប្លុះទាត់កនហ្នឹងនាងមានប្រយោជន៍អ្វី ឧត្តមតបាកបញ្ឆោតអញ ? អញត្រូវខ្ចុកចិត្តដោយស្មោះចំពោះលើសីលធម៌របស់ខ្លួន.. ឫកពារសណ្តាប់ធ្នាប់របស់ខ្លួន ភាសា ទាស៊ីពាំងឡាយ យើញមិនធ្លុងនឹងធ្លុងមច្ឆាតត្រឹមត្រូវល្អ ហើយជាប្រក្រតីធម្មតារបស់គេ...កូនវាន់ក្អែកខាងស្រីទៀត ខ្ញុំយើញមែនទែកស្នេហាដោយក្តីពិត ។ ចេញជាប់មកលើរូបអញ ។ ដូច្នេះ ខ្ញុំយប្លុះ! អញត្រូវមានសេចក្តីគេកយសប្បាយ ខំទុកខ្ចុកចិត្ត ទៅលើខាង..ទេ! ត្រូវអញតិតឲ្យស្រួល...ម្ល៉ោះហើយ ជួនកាលខ្ញុំសប្បាយ ជួនកាលខ្ញុំមានសេចក្តីព្រួយសោយសៅសល់ ប៉ាដូចសំរៀមួយសោតអណ្តែតកណ្តាលមហាសាគរ មានឱ្យលិលវិលវល់បក់ចោកមកពីគ្រប់ទិសទី...ខ្ញុំដេកមិនលក់សោះ ទៅចល់ទឹងភ្លឺថ្ងៃរៃតែម្តង ។

នៅពេលព្រះអាទិត្យរះ កាំរស្មីតន្ទឺចូលកន្លងបន្ទប់ខ្ញុំ ទាំឲ្យតុខ្លួគ្រឿងសម្ភារៈ ចាំងព្រោងព្រាត ខ្ញុំក្រោកពីដំណេក ។ នាកាលឮសូរខ្ញុំដើរ

ខ្ញុំចំរើតាំងប៉ុន្មានដែលថ្នាក់ថ្នមខ្ញុំតិចល្អ ទាំងគ្នាចូលមកក្នុងបន្ទប់ខ្ញុំ ទៅរៀបរៀនកាលខ្លួន មានការអាវរៃងល្អ ។ អស្ចារ្យ ខ្ញុំក៏ជ្រើសរើសយកមួយគឺអាវសូត្រពណ៌ខៀវប៉ាក់មាស រំលេចក្បាច់ដែលខ្ញុំពេញចិត្តរកតិចបំផុតគ្មាន . . . ស្ទើរតែពាក់អាវពុំទាន់រួចផង ស្រាប់តែនាងកនហ្សុ អញ្ជើញមកជល់ ហើយសួរខ្ញុំថា ៖

(ក.) – ចាស ! សួស្តីអ្នកប្រុស ! តើអ្នកសម្រាន្តបានសុខសាន្តឬទេ ?

(អ.) – បាទ ចាន ! សូមអភ័យទោស លោកស្រី ! ខ្ញុំខ្លួលចានដំណេកមិនលក់សោះ ខល់និងក្តី ។ ចំពោះចម្ងាយនេះ នាងស្រីស្មានថាខ្ញុំសប្បាយចិត្តយ៉ាងក្រៃលែង នាងគំងាកលឿនត្រឡប់ទៅវិញ ធ្វើមុខភ្លឹម ។ ដោយពុំបានគិតអ្វីឲ្យបានពេញលេញទេ អំពីសំដីសុចរិតស្មោះត្រង់របស់ខ្ញុំ ខ្ញុំត្រូវបិតនៅ ក្នុងស្ថានភាពដដែលនេះ អស់រយៈពេល ៨ ថ្ងៃ ក្នុងច្រាសខនាងកញ្ញា កនហ្សុ ។ បុគ្គលិកពាំងអស់យកចិត្តទុកដាក់គោរពផ្គត់ផ្គង់ថ្នមខ្ញុំ ដូចជាស្តេចមួយព្រះអង្គ លោកស្រីខៀកគំលោកបញ្ជោញចំពោះខ្ញុំ ទូវប្តកាប្រមប្រិយស្រស់ប៉ែប្រៃ ព្រមទាំងសេចក្តីថ្នមបបោសអង្អែលផ្គាប់ចិត្តខ្ញុំ ដោយភាពរាងផ្អែមល្ហែម ដើមក្អែកកន្ទុយក្អែកច្រើនបែបច្រើនយ៉ាង ជាសក្ខីភាពនៃសេចក្តីស្នេហាដ៏ស្មោះស្ម័គ្រពិត ។ ។

មានមួយថ្ងៃ យើងទាំងពីរនាក់គ្នាដើរកំសាន្ត ក្នុងសួនច្បារ ។

(ក.) – បើអ្នកប្រុសស្លូតត្រង់ មេត្តាដល់រូបខ្ញុំដោយសុទ្ធចិត្ត ខ្ញុំទឹងសុំស្នើយោបល់មួយ យោបល់នេះ ប្រហែលជានឹងនាំឲ្យអ្នកប្រុសដួងចិត្តខ្ញុំ សប្បាយរីករាយជាពុំខាន បាស! ។

(អ.) – ម្ចាស់ចិត្តខ្ញុំអើយ! ប្រសាសន៍ស្រីអូន «ប្រហែល» តាក្យមួយមាត់នេះ ដូចជាវប្តែលំពែងមកស៊កសៀតក្នុងទ្រូងខ្ញុំដូច្នោះ ។

(ក.) – បាស: បើដូច្នោះ អ្នកប្រុសជាទីគោរពខ្ញុំអើយ សូមអ្នកសន្យា សូមអ្នកសច្ចានឹងខ្ញុំថា អ្នកជាមហាបុរសមានចិត្តទៀងភាត់ស្មោះត្រង់ចំពោះរូបខ្ញុំ ។ ខ្ញុំសូមប្រកាសស្វាមីភ័ក្តិ ចំពោះអ្នកតែមួយ សូមអ្នកទុកខ្លួនខ្ញុំជាដៃម្ខាងរបស់អ្នក សូមអ្នកប្រុសយកដៃនេះ ទៅថ្នមថ្នាក់ដាក់កន្ទុយដួងចិត្តអ្នកចុះ ។ យើងទាំងពីរ យើងត្រូវវេញបញ្ចូលគ្នាជាធ្លុងមួយដោយតិច្ចពិសិដ្ឋ តោលគឺអាពាហពិពាហជាពុំខាន បាស! ។

(អ.) – សមនឹងលោកស្រី ជាអ្នកមានជាតិកំណើត ហើយរស់នៅក្នុងបណ្តាអ្នកគាំពារព្រះសាសនាហៅថា គួរអែប្រ៉ែ គោរពបូជាព្រះអគ្គិនីនិងព្រះអាទិត្យ រីឯខ្លួនខ្ញុំជាអ្នកម៉ាហ្គូម៉ែត សំដីនាងស្រី នាំឲ្យខ្ញុំឮជំនួរតីមមិងមមាំង មុខស្លុកស្លាំង ខ្ញុំខ្លាសំអៀន កែកខ្ញុំសំយ៉ុងចុះ ៖ តុស្តីសេចក្តីត្រេកអរសប្បាយកើយលើមុខខ្ញុំ ប្រែក្លាយស្រទំភ្លាម ទៅជារសេះរសោះគិតអ្វីមិនយើញ . . . ។

លោកស្រីកនហ្សាឌ្ធ ទាំងមុខស្រឡាំ ទាំងកែកបញ្ជូរ ស្រែក

ឡើងថា ៖ ខ្ញុំឥតស្មានឃើញសោះថា សេចក្តីស្មើដូច្នេះ ជាគ្រឿងខំ
ទាស់ចិត្ត អ្នកដ៏ធំដល់ម្ល៉ះ ! អំពីសេចក្តីស្មើអំបាញ់មិញ ខ្ញុំស្មានថា
យើងតាំងពីត្រាកដជារកយសប្បាយរកអ្វីប្រៀបគ្នាទេ ទេះមិនដូច្នោះ
សេចក្តីស្រងូតស្រងាត់របស់អ្នក ត្រូវបាននឹងថា អ្នកដេរប្រពេចដាក់
បណ្តាសាខ្ញុំយ៉ាងធ្ងន់ ។ ចុះយ៉ាងមេច មើ ! តើអ្នកគិតថាយកខ្ញុំធ្វើប្រពន្ធ
វាអាប់តិត្តិយសអ្នកណាស់ យ៉ាងនេះ ឬអី ?

(អ.) - ទ្រង់ដ៏មានបុណ្យអើយ ! មេចក៏លោកស្រីដាក់ទុបសគ្គធំ
ដុតវិស័យខ្ញុំនឹងពុះពារបានដូច្នេះ ? តាំងដៃប្រណម្យទៀលើមេឃ តាំង
លុតជង្គង់ . . . ។

(ក.) - ទុបសគ្គ តុំគាចតាទពារបាន ? . . . មើ ! ចុះទុបសគ្គអី ?

(អ) - សាសនារបស់ខ្ញុំ ! ខ្ញុំកន្ទុងរំលងមិនបាននោះឡើយ ទូវ
មូលធម៌ ដៃលលោកបានហាមហើយជាស្រេច ក្នុងរឿងអាពាហ៍
ពិពាហ៍ . . . ។

(ក) - អ្នកប្រុសអើយ ! សូមអ្នកកុំមានសេចក្តីសង្ស័យអ្វី ខ្ញុំជា
មនុស្សអ្នកចេះគិតល្អិតល្អន់ ដូចអ្នកដែរ ។ ក្នុងរឿងសាសនានេះ បើ
ពុកជាគេយកអធិពជមួយព្រះអង្គមកឲ្យខ្ញុំផង ក៏ខ្ញុំពុំព្រមយកអ្នកម៉ាហ្គូម៉ិត
ធ្វើជាប្តីដែរ ។ តែក្នុងរឿងនេះ មុនឯងយើងរួមកសនាគ្នា អ្នកប្រុស
ត្រូវស្បថអះអាងថា អ្នកមានចិត្តស្មោះត្រង់ មកទុបក្រសោបបីត្រកង ចិត្ត

ស្មោះត្រង់របស់ខ្ញុំមិន . . . ត្រង់ៗនេះ អ្នកគ្រូកាល មិនព្រមបន្ទឹងខ្លួ
ពាក្យស័ព្ទនេះ ដូច្នេះអ្នកជាមនុស្សអកតញ្ញូតាលសាមានយ៉ងណាយ៉ងដែលធំបំផុត
ក្នុងពិភពលោក . . . ។

(ក) - សំដីគាំងប៉ុន្មាននេះ ដោយនាងកន្ទបហ្យាខ បញ្ចេញសំឡេង
ខ្ញុំ ។ ខ្លាំងៗ ញាប់ៗ នាំឲ្យខ្ញុំស្ទុះគន់ដៃខន់ជើងក៏យខ្លាំងញ័រចំប្រប់គាំង
ខ្លួន ហាមាត់ធ្វើយទៅវិញមិនរួច . . . ម្ចាស់ហើយលោកស្រីកាន់តែរម៉ាំង
រម៉ៃកប្រមោកដោយឥតមេត្តាមកលើខ្ញុំ ស្តីបន្ទោសហើយបន្ទោសទៀត
គាំងចិត្តកហូរស្រក់សស្រាក់ . . . . . នាងទៅជាស្រីមួយកាចសំបើម
អស្ចារ្យ . . . ខុសខ្លាចផ្សារបស់នាងយ៉ាងណា ខ្ញុំក៏ដូច្នោះដែរ ។
យ៉ាងម្តេចកំដោយ ! . . . ខ្ញុំនៅតែគាំងស្មារតីរឹងប៉ឹង . . . ដល់នៅតែយើញ
ខ្ញុំខឹងស្មារតីដូច្នេះ នាងកាន់តែឆួលខ្លាំង ហើយមានខុសខ្លាចឆ្ងល កាន់តែ
កំរើយកាពទៅទៀត ក្រោកឈរទៅទ្រុំដើរចាត់ ព្រោះនាងពុំព្រមរឿបាទថា ការប្រែកែរបស់ខ្ញុំ ជាសេចក្តីនិច្ចយជាប់អហង្កាស្មោពារ...
ចុងក្រោយបំផុត នាងក៏និយាយថា ៖ ណ្ហើយចុះ ! ខ្ញុំជូនពេល ៨ ថ្ងៃ ឲ្យ
អ្នកប្រុសពិចារណាគិត . . . ។

(ក.) - ដល់ ៨ ថ្ងៃ ១ សេចក្តីសម្រេចរបស់ខ្ញុំ នៅនឹងថ្កល់
ដដែលឥតប្រែប្រួល . . . នាងពន្យារពេល ៨ ថ្ងៃថ្មីទៀត ដោយកំញើញគំ
រាមខ្ញុំថានឹងត្រូវខុសខ្លោសយ៉ាងការុណធ្ងន់បំផុត បើខ្ញុំនៅតែប្រែកែកតទៅ

ទៀត ។ ខ្ញុំដល់ចាញ់ចេះ តុំដឹងធ្វើម្តេចឲ្យខ្ញុំយល់ព្រមកើត រីឯថ្ងៃចេះតែកន្ទុដដែ ។ នាងស្រីក៏មានចង្កាប់ ឲ្យគេនាំខ្ញុំ ទៅកន្លែមហាគេហដ្ឋានមួយយ៉ាងល្អ ដែលឋិតនៅកន្លែបរិវេណប្រាសាទនាង ។ នៅទីនោះ កណ្តាលចំណោមស្រីជាច្រើន នាងអង្គុយរង់ចាំខ្ញុំ លើអាសនៈមួយ មានសណ្ឋានដូចរាជបល្ល័ង្កខ្ពស់ពីរថ្នាក់ជាណ្តើរ ។ នាងមានទឹកមុខ មិនមែនដូចជាចៅក្រមគឺងឺនដូចមុនទេ ។ នាងមានឫកពាសូភាពរាបទាបស្លូត ជាគួរសង្ឃឹមយ៉ាងល្អក្នុងចិត្តខ្ញុំ ។ តាំងមុខមាំប្រាកដប្រជា តាំងខ្លួនញ័រ ។ ចំប្រប់ ខ្ញុំដើរទៅជិតនាង ។

(នៅមានត)

បំណោទ ទី ២

ខ្ញុំជារបស់មួយ បើនៅតាំងខ្លួន តាំងដើងមនុស្សក្នុងលោកនិយម ស្រឡាញ់ចូលចិត្តគ្រប់គ្នា តែបើគេកាត់ដើងខ្ញុំចោល ខ្ញុំក្លាយជាកម្មវត្ថុសម្រាប់តែគេចំអកសើចលេង តើខ្ញុំជាអ្វី ?

រឿងល្បែកឡាហ្វុងតែន

ប្រែពីភាសាចិនដោយ លោក ដេង-ទ្រីវ

(ត)

៩០) មាន់ស្មារ ធ្នា ធំជាងកូនកណ្តុរ

កូនកណ្តុរមួយទៅក្មេង មិនធ្លាប់ដែលបានឃើញអ្វី ប៉ះតែធំជាងខ្លួនគ្រោះថ្នាក់ដោយមិនដឹងខ្លួន ។

រឿងដូចតទៅ ជាសេចក្តីដែលកវីលោករៀបរាប់ប្រាប់មក :

ខ្ញុំគ្រាន់តែឆ្ងល់គាត់ក្តីចាំជាយដែលឃាំងពីនេះ ហើយកំពុងតែរត់ទៅមកលេងកំសាន្តសប្បាយតាមអំពើចិត្ត ស្រាប់តែខ្ញុំឃើញសត្វពីរ : អាមួយស្លូតស្អាតគួរឱ្យស្រឡាញ់ អាមួយសំដីច្រើន ហើយឥតដែលនៅស្ងៀមម្តង សំឡេងរាំរែងរែស នៅលើក្បាលមានសាច់មួយដុំក្រហមរដាល មានដូចជាដៃដែលខ្លះៗល់ ដើម្បីចង់ហើរ កន្ទុយលាក្រញាំងដូចជាផ្លិត ។

គឺជាមាន់ស្មារហើយ ដែលកូនកណ្តុរបានឮលោករៀបរាប់ប្រាប់ម្តាយរាវនេះ ហាក់ដូចជាសត្វមកពីប្រទេសអាមេរិក ។

កូនកណ្តុរនិយាយទៀតថា : សត្វនេះយកដៃចាំងពីរនេះឆ្ពឹងចំនីរសងខាង បន្លោញស្ទូរសេតូយ៉ាងអាក្រក់ តាល់តែខ្ញុំដែលជាអ្នកមានសេចក្តីក្លាហានផងគ្រាំមិនបាន ត្រូវតែភ័យតក់ រួចដើរប្រទេចរាយ៉ាងខ្លាំងឥតសំចៃ ។

ប្រសិនបើគ្មានក៏ ខ្ញុំប្រហែលនឹងមានការខាត់ខន់ជាមួយអាមួយនោះដែលមានខ្នងដូចជាស្លឹតពន់ពេក តែថាវាមានរោមខន់ល្មើយដូចយើងពណ៌អុជ ។ កន្ទុយវែង អាការគួរសម ទឹកមុខសុភាព តែប៉ុន្តែក្អែកភ្លឺចាំង ខ្ញុំដឿជាក់ថាវាហ្នឹងជាសត្វគួរតែកប់រកយកជាគ្នា ជាមួយអស់លោកកណ្តុរពាំងព្រាយ ព្រោះវាមានត្រចៀកប្រហែលនឹងត្រចៀកយើង។ ខ្ញុំរៀបនឹងចូលទៅខាត់ខន់ជាមួយវា ស្រាប់តែអាមួយនោះស្រែកខ្ទំងពេក ខ្ញុំក៏ភ័យរត់មក ។

មេកណ្តុរនិយាយថា ៖ ម្នាលកូនសម្លាញ់ ! អាមួយដែលថាមានខ្នងស្លឹតបូតនោះគឺជាគ្នា ។ នេះមានទឹកមុខលាក់តុត ប្រកបដោយកលល្បិចដែលនាំឲ្យឯងមានការកាន់ច្រឡំដោយអាការខាងក្រៅបេះពាំ អាមួយនោះផ្ទុយទៅវិញ ជាសត្វមានសភាពឥតស្រដៀងនឹងយើងសោះ ប្រហែលមានថ្ងៃណាមួយនឹងបានជាចំណីអាហាររបស់យើងទៅវិញទេ ។ ចំណែកឆ្មាមិនដូច្នោះទេ ការមងឹតែចាប់យើងធ្វើជាអាហាររបស់វា ។ ដកឋណាកូនឯង មានដំរិតរស់នៅ ដកឋនោះចូរប្រយ័ត្នកុំនៃច្ចំយមនុស្សតាមទឹកមុខឲ្យសោះ ។

៩១) សត្វកើតជីម្ងឺពិស

មានវិបរិត្តភាព ជាន់សាបគ្រោះខ្លាំកេរវែកម្ចាស់តេញ ជាវិបរិត្តភាពដែលខ្លួនឯងបានបង្កើតឡើង ដើម្បីធ្វើទោសដល់អ្នកប្រព្រឹត្តបទ

ទ្រក្ដួរខៅលើផែនដី ចានជាខេត្តឲ្យផម្ងិតសមកសម្លាប់សត្វនានា ព្រោះពិសអាចសម្លាប់ក្នុងមួយថ្ងៃចានច្រើន ។

សត្វមិនមែនស្លាប់តាំងអស់ទេ តែសត្វឈឺតាំងអស់ គេមិនយើញសត្វត្រាប់សូរស្នែងរកអាហារចិត្តាមដីតែសោះ ព្រោះមិនមានអាហារចំណីណាធ្វើឲ្យសត្វមានចិត្តចង់សោះ ចចកក្តី កន្ត្រាំងក្តី ឈប់ត្រូវគានឹងរំពាដំទ្វាញ់ពីសារ ។ សត្វលលកស្ទុះហើរតត់គៀសខ្លួន ឈប់មានសេចក្តីស្នេហា ឈប់មានការសប្បាយរីករាយ ។

យើញហេតុដូច្នោះ សីង្ហប្រដុំអស់ពួកសត្វ ហើយគោលថា៖ «ម្នាលមិត្រភក្តិជាទីស្នេហាតាំងឡាយ ខ្ញុំជឿថាខេត្តចានធ្វើឲ្យមានសេចក្តីទុក្ខវេទនានេះដល់ពួកយើងណាដែលមានកំហុសហើយ បណ្តាយើងតាំងអស់អ្នកដែលមានទោសជួន គួរគប្បីធ្វើពលីកម្ម ដើម្បីរំងាប់កំហឹងខេត្តា ធ្វើដូច្នេះប្រហែលជានឹងមានការសេះស្បើយខ្លះ ។ ប្រវត្តិសាស្ត្រប្រាប់យើងថា បើមានទុបត្តិហេតុយ៉ាងនេះ គេនិយមធ្វើពលីកម្មដូច្នេះឯង ។ យើងមិនត្រូវបណ្តែតបណ្តោយឲ្យសោះ ត្រូវពិចិត្យដោយឥតយោគយល់ ឬបន្ទរបន្ទាយ ខ្លួនសតិសម្បជញ្ញៈរបស់យើង ។ ចំណែកខ្ញុំ ដើម្បីបំពេញបម្ងាញ់ ខ្ញុំចានចាប់ហែកស៊ីខ្លួនឯងជាច្រើន តើចៀមតាំងនោះចានធ្វើអ្វីដល់ខ្ញុំ ? គឺមិនមានការប្រមាថមើលងាយអ្វីសោះ ជួនកាលខ្ញុំស៊ីតាំងអ្នកឆ្ងាលផងចៀមទៀត ។ ដូច្នេះខ្ញុំនឹងធ្វើពលី-

កម្មដែរ ប្រសិនបើជាត្រូវធ្វើ តែប៉ុន្តែខ្ញុំយល់ថាម្នាក់ ។ គប្បីខ្លួលស្គាល់ទោសរបស់ខ្លួនដូចខ្ញុំ ព្រោះភាមច្បាប់យុត្តិធម៌ គេត្រូវតែពេញចិត្តឲ្យអ្នកដែលមានទោសធ្ងន់ជាងគេស្វាប់ ។

កន្ត្រាំងគោលទៀងថា : «ព្រះករុណាថ្លៃវិសេស ! ព្រះអង្គជាព្រះមហាក្សត្រ ប្រកបដោយសេចក្តីមេត្តាករុណាពន់ពេក សេចក្តីព្រួយបារម្ភនៃព្រះអង្គនេះ គេញាំហៅមានសារៈសំខាន់ក្រៃលែង ។ ចំណែកដែលព្រះអង្គទ្រង់សោយចៀមជាសត្វថោកទាបនោះ ទ្រង់ទុកថាព្រះអង្គជាអ្នកមានកំហុសឬ ? សូមទ្រង់ព្រះមេត្តាទ្រាស ! គឺឥតមានកំហុសទាល់តែសោះ ឯការដែលព្រះអង្គសោយវានេះ មានតែទ្រង់ប្រទានកិត្តិយសដ៏ច្រើនដល់វាវិញទេតើ សូមទ្រង់ជ្រាបក្រាមល្អង់ជួលព្រះបាទ ។ ចំណែកអ្នកតង្វាលវិញ គេអាចចាត់ទុកថាជាមនុស្សដែលគួរតែខ្លួលរសេចក្តីទុក្ខគ្រប់យ៉ាង ព្រោះមនុស្សទាំងនេះហើយបានប្រព្រឹត្តអំពើឃោរឃៅមកលើសត្វទាំងឡាយ » ។ កន្ត្រាំងនិយាយប្រាប់សង្ឃដូច្នេះ ឯពួកអ្នកបញ្ញោះកំនាំគ្នាខ្លះដៃប្រាវឡើង ។

ចំពោះរឿងនេះ គេមិនហ៊ានលួកឲ្យជ្រុលហួសដល់ការប្រមាថបន្តិចបន្តួចដែលអាចអត់ទោសឲ្យបាន នៃសត្វខ្លា សត្វខ្លាឃ្មុំ ទើបសត្វមានពិសដែរឡើយ ។ បើតាមសំដីដែលគេនិយាយ គឺត្រូវទុកសត្វកំណាចទាំងនោះរហូតដល់ឆ្នៃសាមញ្ញ ជាតួព្រះតួច ។ ។

សត្វលាដើរទេន ។ ចូលមក ហើយគោលថា : ខ្ញុំលព្រះបង្គំចាំ ជានថាមានពេល ១ ខ្ញុំលព្រះបង្គំជាខ្ញុំដើរចូលទៅក្នុងកលស្មៅរបស់លោក សង្ឃ (moines) ខ្ញុំលឃ្លាន ហើយមានស្មៅខ្ចីទៅច័នោះស្រាប់ មិនដឹងជាមានខ្មោចអ្វីមកដម្រុលឲ្យខ្ញុំលព្រះបង្គំជ្រោចស្មៅនោះ ស៊ីអស់បន្តិច ខ្ញុំលព្រះបង្គំសូមក្រាបបង្គំខ្ញុំលថ្វាយត្រង់ស្មោះ ថាខ្ញុំលព្រះបង្គំមិនមានសិទ្ធិអ្វីតាល់តែសោះ ទៅលើស្មៅនោះ ។ សេចក្តីប៉ុណ្ណេះ សូមទ្រង់ជ្រាបក្រោមល្អង់ធ្លីព្រះបាទ ។

គ្រាន់តែបានឮលាគោលដូច្នោះ គេស្រែកសុំឲ្យវិនិច្ឆ័យសត្វលា ។ ចចកមួយធ្នាតនិយាយថា ត្រូវតែឲ្យសត្វចង្រៃនេះធ្វើតលំកម្ម ព្រោះវិបត្តិភាពចាំងអស់ បណ្តាលមកពីវា ។ ម្នាះហើយគេវិនិច្ឆ័យកាត់ទោសដ៏ស្រាលនេះ ថាត្រូវយកលាទៅចងកញ្ជ្រែ ។

គ្រាន់តែស៊ីស្មៅគេ ! ទោសអ្វីក៏ធ្ងន់សម្លើមម្ល៉េះ ! មានតែសេចក្តីស្អប់ខើមគាចលប់លាឯបទ១ក្រិដ្ឋរបស់លាបាន គេក៏នាំគ្នាសម្រេចកិច្ច វៅ ។

សេចក្តីវិនិច្ឆ័យនៃតុលាការ ធ្វើឲ្យសម្រេចឲ្យអ្នកទៅជាស ប្តូរទៀ អនុលោមទៅតាមអ្នកជាមនុស្សមានអានុភាព ឬជាមនុស្សខ្លាំងឡាយ ។

(នៅមានត)

រឿងសាមកុក

ខុតញ៉ាវិបុលកដសេនា ឆ្នូ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លាទូសាស្ត្រ
អ្នកវិងវៃឆ្លាសបើបានអាន
ទំងបេះខួរយកលប់ចំណាន
ទាំងមានសន្តានស្នេហាជាតិ ។
ឃ្លោ-អ៊ុន

ស៊ុនគួនស្តាប់យល់ឃើញត្រូវ កំពាត់ចៃដន្យហានតាមពាក្យខ្សោ-សុកនិយាយ ។ ដាំតែកថា លោកកុំអាលមាក់ដាំយប្រមាទ ព្រោះគួនអ៊ូនោះមានថ្នូដៃពូកែជាខាហានខ្លា បើមិនសមនឹងសេចក្តីតែតុបាយនោះដោយប្រការឯណា កំនឹងត្រឡប់អន្តរាយដល់យើងវិញ ស៊ុនគួនឮដូច្នោះកំរើឆ្ងល់ថា ចាំតាលណាទើបយកស្រុកកេងដីវិឡាន ហើយបង្គាប់ឲ្យខ្សោសុកធ្វើតាមគំនិតដែលគិតខុកនោះឲ្យសម្រេច ។ ខ្សោសុកខ្លួលបង្គាប់ហើយក៏លាចេញទៅចាត់រៀបចំខ្លួកចម្បាំង លុះបានព្រមចាំងខាហានយោធាហើយ ក៏ចេញទៅចុះយុថ្កាទៅមាត់ភាមខ្សែកទៅហើយឡើងទៅតាំងបន្ទាយលើគោក រួចចាត់ឲ្យកាំឡេង ១ លីបង ១ លើកខាហានទៅពួនបង្កប់គ្រប់យ៉ៈដែលគិតខុកនោះ ហើយឲ្យរៀបតុលៀងអាហារស្រេចកាលណា ក៏ធ្វើសំបុត្រចាត់ប៉ារឲ្យទៅអញ្ជើញគួនអ៊ូមក

បរិភោគ ឯបំរើដែលកាន់សំបុត្រនោះ លើសមនុស្សដែលចេះសំដី លុះ
ទៅដល់ស្រុកកេងដីវិហើយ ក៏និយាយឲ្យគួនបើងយល់តាមសំបុត្រខ្លា
សុក ។

គួនបើងក៏នាំអ្នកកាន់សំបុត្រនោះ ចូលទៅគំនាប់គួនអ៊ូ ហើយ
ជូនសំបុត្រនោះទៅគួនអ៊ូ ។ មើលឃើញសេចក្តីថា ខ្លាសុកសុំ
អញ្ជើញទៅពិសាលៀងឯបន្ទាយមាត់តាមឲ្យកូនទៅ គួអ៊ូក៏ប្រាប់អ្នកកាន់
សំបុត្រនោះថា ឲ្យស្រួតទៅប្រាប់ខ្លាសុកចុះ ចាំព្រឹកស្អែកយើងនឹងទៅ។
បំរើនោះក៏លាគួនអ៊ូត្រឡប់ទៅវិញ ។ គួនបើងដាកបគួនអ៊ូថា ដែលខ្លា
សុកឲ្យមកអញ្ជើញបិតាទៅពិសាលៀងនោះ ខ្ញុំបាទឃើញថា ខឹងជា
កល។ បាយទេ ហេតុម្តេចក៏បិតាទទួលថាទៅ ។

គួនអ៊ូឮហើយក៏អស់សំណើចហើយតបថា ហេតុនាំឯងនេះ ព្រោះ
ដូនាត់កំនៅទៅប្រាប់ស៊ុនគួន បានជាខ្លាសុកគិតកល។ បាយឲ្យអញ្ជើញ
យើងទៅស៊ីលៀង ហើយខឹងបានតាយកស្រុកកេងដីវិញ ដើម្បីឲ្យ
បានជាកម្មសិទ្ធិរបស់ស៊ុនគួន បើយើងនិងមិនទៅវេលានេះ ពួកស្រុក
កាំងតាំងនឹងមើលងាយថាយើងខ្លាច ព្រឹកស្អែកឡើង យើងនឹងនាំគ ហាន
តែ ២០ នាក់ ចុះទូកហែសទៅស៊ីលៀង ដើម្បីនឹងមើលកលការខ្លាសុក
ទើងខ្លាចញាញើតល់តែងដែលយើងកាន់ទៅនេះដែរឬទេ ? ។ គួនបើង
ថា ខ្ញុំនបិតាដូចជាមានគុណដែលនឹងកន្ទុងចូលទៅក្នុងពួកចោរនោះ

មិនគួរ ខ្ញុំបាទក្រែងស្រុកកេងដីវានេះនឹងកើតអន្តរាយ ឲ្យតាំងនឹងសំតាល់
គោសថា ចិតាធ្វេសប្រហែស ។

គួនអ៊ូតបថា ចៅកុំរវីតក្តីឡើយ ឯចិតានេះកំមានថ្ងៃដែលល្បីល្បាញ
ពូកៅ សូម្បីតាហានចូរធ្លាប់សែន ច្រើនហួសប្រមាណ ចិតាមានតែសេះ
មួយ អាចការពារមិនឲ្យព្រួញគាវុធដឹតដល់ខ្លួនបាន អាចបរសេះរុកកន
ចំពានចូលចៅ-ចេញមកច្រើនគ្រាច្រើនក្រឡប់ ទុបមាបីដូចជាគេចូលក្នុង
គុម្ពឫស្សីនឹងចេញមកវិញបានដោយងាយ នឹងខ្លាចអ៊ូថ្ងៃតាហានស្រុក
កាំងតាំងប៉ុណ្ណោះ បើដូចជាហ្វូងជ្រូកនឹងរកស្វាហាប់គ្មានសោះ ចិតាបាន
ចេញវាចាថាចៅហើយនឹងឲ្យខូចសំដីថ្ងៃ ។ ម៉ាសៀងឆ្វើយថា បើលោក
នឹងអញ្ជើញចៅ ក៏ត្រូវប្រុងប្រយ័ត្នគឺតរាំងមុខក្រោយកុំឲ្យប្លោះការ ។
គួនអ៊ូថា ដែលអស់អ្នកមកវិលឹកគ្រានេះកំគួរហើយ ខ្លួនយើងនឹងគួនប៉ង
នឹងនាំតាហានចេញចៅ ៤-៥រយ ហើយបង្គាប់គួនប៉ងឲ្យត្រួតត្រាតាហាន
ចាំង ៥០០ ចុះខ្លួកចម្បាំង ១០ ប្រចាំត្រួតមើលការ បើឃើញយើងរំលាក
ខង់ចុះវិលាណា ត្រូវបរពលចូលចៅជួយឲ្យរួសកន់ គួនប៉ងខ្លួលបង្គាប់ហើយ កំចេញចៅចាត់ចែងតុកត្រម តាមគួនអ៊ូបង្គាប់ ។

លុះបំរើនាំសំបុត្រនោះវិលចៅដល់បន្ទាយ ក៏និយាយប្រាប់ឲ្យសុក
ថា គួនអ៊ូត្រេកអរខ្លួលថា នឹងមកព្រឹកស្អែក ឲ្យសុកត្រេកអរណាស់
ទើបប្រឹក្សានឹងលីបងថា ឯគួនអ៊ូនោះ មានថ្ងៃដៃខ្លាំងពូកែណាស់ នឹងមក

ស្អែកនេះហើយ យើងនឹងតតប្រការដូចម្តេច ។ លំបងថា កាំភ្លើងនឹងខ្ញុំបាទ កំបានចាត់ចែងគាហានបង្កប់នៅខាងក្រៅជាពីរកន្លែង បើយើញគួនអ្វីគ្មានពួកគាហានមកជាមួយជាច្រើនទេ យើងនឹងបញ្ជាគាហានដែលបង្កប់នោះ ឲ្យចេញមកតែត្រឹម ៥០ នាក់ បើបានការហើយ នឹងព្រួតគ្នាចាប់គួនអ្វីសំឡាប់ចេញ បើគួនអ្វីមានគាហានមកផង ខ្ញុំបាននឹងកាំភ្លើងចាំស្តាប់សំឡេងជាវ បើឮកាលណានឹងយុំគាហានរាយប្រសព្វរួចចាប់ខ្លួនគួនអ្វីឲ្យបាន ។

ខ្លោសុកយល់ឃើញត្រូវដូង្ហ លុះដល់ពេលព្រឹកកំចាត់ចែងតាមតំនិតដែលគិតខុក ហើយឲ្យគាហានទៅចាំមើលគួនអ្វីជាមានគាហានមកជាមួយឬទេ ប៉ំរើនោះ កំត្រឡប់មកប្រាប់ខ្លោសុកវិញថា យើញគួនអ្វីបុះខ្លកហ៊ាសតួច ១ មក មានពួកដើងចៃប្រហែល ២០ នាក់ នឹងខំក្រហមសម្រាប់កួនអ្វី ឯគួនអ្វីនោះតែងខ្លួនហ៊ីហាពាក់អាវត្រពាណិស្វាយជួតក្បាលត្រពាណិទៀវ មិនបានពាក់ក្រោះ យើញដីវែងលីលំពែងអង្គុយអមគួនអ្វី ឯគាហានដែលមកជាមួយនោះ សុទ្ធតែមានថ្នើរដៃខ្លាំងពូកែប្រហែល ៧ ៨ នាក់ ។ ខ្លោសុកឮហើយ កំចេញទៅខ្លួលយើញគួនអ្វីតែងខ្លួនហ៊ីហា មានគាហានមកជាច្រើនគ្នា ខ្លោសុកនឹកញាញើតក្រែងធ្វើការនោះពុំសម្រេច លុះនាំគួនអ្វីចូលទៅដល់កូនបន្ទាយកំតាំងតំនាប់គ្នា ហើយខ្លោសុកក៏អញ្ជើញគួនអ្វីបរិភោគអាហារ ។

ខ្ញុំណៈកាលកំពុងសេតសុកនោះ ខ្ញុំសុកកំញាប់ញ៉ាអេស់ពាំងខ្លួន មិនហ៊ានពាំងនើបមុខមើលគួនអ៊ូផង ឮតែមនុស្សបំរើចាក់ស្រាឲ្យគួនអ៊ូពីកគួនអ៊ូពីកស្រាក្អាម កំមិនបានកោតញាក្រើត តាំងតែនិយាយពីរឿងចម្លែងហើយក៏សើចកេះកយសប្បាយ ខ្ញុំសុកកំសម្លឹងបុងតែកមើលគួនអ៊ូយើញកាន់តែស្រវឹងខ្លាំងកំតាំងនិយាយថា យើងមានសេចក្តីមួយៗ នឹងសុំប្រាប្តចរចានឹងលោក ។ គួនអ៊ូសួរថា អ្នកនិយាយការអ្វី ។ ខ្ញុំសុកឆ្លើយថា ពីដើម ស៊ុនគួនឲ្យយើងមកតាយកស្រុកកេងជីវ ២-៣ ដង ហើយឡៅពីចេះតែបណ្តោះបណ្តែថា សុំស្រុកកេងជីវខុកជាទីគាស្រ័យសិន បើកាលណាវាយបានស្រុកសែឈួនហើយ នឹងបង្ហិលស្រុកកេងជីវឲ្យវិញ សេចក្តីនេះយើងបានព្រមតាមនឹងស៊ុនគួនម៉ាមួនណាស់ ឥឡូវឡៅពីវាយបានស្រុកសែឈួនហើយ ដែលនឹងហួនហែងស្រុកកេងជីវខុកនោះក៏មិនគួរសោះឡើយ ។ គួនអ៊ូតបថា អ្នកមានសំបុត្រឲ្យបំរើនាំទៅឲ្យខ្ញុំ ដើម្បីនឹងឲ្យមកបរិភោគអាហារតែម្យ៉ាងជាការសប្បាយ ឥឡូវត្រូវការអ្វីបានជាមកប្រាប្តរឿងស្រុកខេសទៅវិញដូច្នេះ មិនគួរសោះ ត្រូវតែស្ងៀមទៅសិនចុះ ។

ខ្ញុំសុកថា ចៅហ្វាយនាយយើងជាធំក្នុងស្រុកកាំងតាំង ក៏តិតនឹងផ្សាយដែនដីឲ្យធំទូលាយទៅទៀត តែនៅមានចិត្តអាណិតលោកនឹងខ្ញុំពីដែលរត់ពីចូតមក ឲ្យបានជាស្រុកកេងជីវនៅជាបណ្តោះអាសន្ន

ឥឡូវត្រូវឲ្យខ្លៅពីតិតដល់ផ្លូវមេត្រីបស់នាយយើង ចានជាឲ្យមានសំបុត្រ
អញ្ជើញលោកមក ដើម្បីនឹងការយកស្រុក ៣ ដំបន់ ដែលខ្លៅពីត្រូម
ឲ្យនាយយើងជាមុនមកហើយនោះ ដែលលោកមកទាំងនេះ ពុកនោះមិន
គួរសោះ ។

គួនអ៊ូថា កាលគ្រាចូធូលើកទ័ពមកវាយយកស្រុកតាំងតាំងនោះ ខ្លៅ
ពីកំពត់កេណ្ឌ ពាហាន ៣៧ស្លាត់ច្បាំងនឹងទ័ពចូធូជាច្រើនដំបន់ ពាហាន
តាំងពួនកំចានស៊ូនឹងព្រួញគ្នានឹងអាវុធផ្សេង ។ ចានសេចក្តីលំបាកវេទនា
គ្រប់គ្នា ប្រាជ្ញាដែលធ្វើការចានជ័យជំនះចូធូគ្រានោះ មិនពីព្រោះខ្លៅពី
ប្រើខ្លួនបេងទៅជួយទេឬ ហើយខ្លៅពីកំចានបង់ពាតស្បៀងអាហារជា
ច្រើន តែត្រឹមស្រុកតេងដីវប៉ុណ្ណោះ មិនសមគួរជាប់ណាប់ខ្លៅពី ទឹង
ពាហានដែលចានធ្វើការទៀយហាត់នោះទេឬ ហេតុម្តេចចានជាអ្នកមក
បង្កើតដីការស្រុកតេងដីវដដែល ។ ដូច្នេះ ។

ខ្លោសុកថា កាលខ្លៅពីទឹងលោកបែកទ័ពមកពីកលទៀងប៉ាន់ប៉ាំ
នាយយើងតិតអាណិតអាសូរ ចានជាឲ្យស្រុកតេងដីវទៅជាបណ្ណោះអាសន្ន
គ្រាតែតាំងខ្លួនចានដល់ប៉ុណ្ណោះ ហើយខ្លៅពីនោះកំជាមនុស្សមានសេចក្តី
ស័ត្យចានចេញមាត់ថាពីការអ្វី ។ កំមិនដែលឲ្យខ្លួចវាចាសោះ ដែលខ្លួន
លោកមកនិយាយដូច្នេះ មនុស្សតាំងពួនទឹងកន្លងមើលងាយចាន គួនអ៊ូ
ថា ការតាំងពួនខ្លះ មិនមែនជាសិទ្ធិដាច់ពាតលើខ្លួនយើងទេ តែចំពោះ

លើខ្លៅពីជាន់ថ្មាយសម្រេចសេចក្តី តាមតែអ្នកនឹងនិយាយគ្នាចុះ ។ ខ្លោសុកថា យើងដឹងថា ខ្លួនលោកនឹងខ្លៅពីបានប្តេជ្ញាស្បថស្បានគ្នា ពុកជាបងប្អូនរួមទទេរជាមួយគ្នា បើនឹងមានការអ្វីមកជារបស់ខ្លៅពី ក៏ដូចជារបស់លោកដែរ ធុរៈអ្វីជារបស់លោកក៏ដូចជាធុរៈរបស់ខ្លៅពី ហេតុម្តេចលោកមកធ្វើត្រងើយកន្តើយដូច្នេះ គួនអ៊ូក៏មិនធ្វើយតបថាអ្វី។ ជាវឆេងថាហានគួនអ៊ូស្រែកថា អាណាទេតូចាំងអស់នេះសុទ្ធតែរបស់ព្រះចៅហៀនតែចាំងមួល ហេតុអ្វីខ្លោសុកមកថាស្រុកគេងជាវជារបស់ស៊ុនគួនវិញ ។

គួនអ៊ូឮជាវឆេងស្រែកដូច្នេះ ក៏ធ្វើជាខឹង ក្រោកចេញមក ឲ្យន័យជាវឆេងដឹងហេតុហើយ ក៏ដណ្តើមយកលំពែងមកកាន់ហើយស្រែកថា យើងនឹងខ្លោសុកកំពុងនិយាយគ្នាពីការស្រុកទេស ហេតុម្តេចខ្លួនគ្រាន់តែជាភាហានសម្រាប់លីលំពែងតាមមក អាចហ៊ានចូលមកនិយាយផងដូច្នេះជាការមិនសមគួរសោះ ខ្លួនត្រូវចេញពីទីនេះ ទៅក្រៅបន្តិចទៅ ។ ជាវឆេងដឹងន័យគួនអ៊ូដូច្នោះ ក៏ដោះខ្លួនចេញទៅខាងក្រៅ ហើយយកខន់ក្រហមបោកឡើងជាសំគាល់ ។

គួនបេងឃើញខន់សំគាល់ដូច្នោះ ក៏បង្ខំភាហានឲ្យចែវទូកចម្ងាំងចាំង ៤០ ចូលទៅដល់មុខបន្ទាយ ឯគួនអ៊ូក៏ធ្វើជាស្រវឹង ត្រវែងលំពែងដៃម្ខាង ដៃម្ខាងកាន់ដៃខ្លោសុកហើយថា អ្នកហៅមកបរិភោគអាហារ

ពេលនេះ ខ្ញុំគិអរគុណណាស់ហើយ តែហេតុម្តេចក៏ចាន់ជាយកការស្រុកកេងដ៏វែមកប្រាប្តឲ្យរំខានមិនចាន់ឲ្យសប្បាយទៅវិញដូច្នេះ ឥឡូវយើងគំស្រាំងជ្រុលបន្តិចទៅហើយ បើមិនគិតដល់ការដែលធ្លាប់កាន់ស្រឡាញ់គ្នាមកពីដើម ក៏ធឹងបណ្តាលឲ្យកើតជារឿងខាស់ខែងគ្នាជាធំ ខ្ញុំក៏ម្ងាប់កំហឹងច្រើនណាស់ ពេលនេះសុំលាអ្នកត្រឡប់ទៅវិញសិន ចាំថ្ងៃក្រោយខ្ញុំនឹងសុំអញ្ជើញអ្នក ទៅពិសាលៀងខាង ខ្ញុំឯស្រុកកេងដ៏វែម្តងវិញ ហើយក៏ដឹកដៃខ្លោសុកចេញទៅដល់ត្រើបន្តាយ ។

ឯកាំខ្លែងនិងលីបងដែលឃុំខាហានទៅតួនបង្គប់ទៅស្រែរនោះ លុះក្រខ្លែកយើញគួនអ៊ូកាន់លំពែងម្ខាង ដឹកដៃខ្លោសុកម្ខាងចេញមក លុះនឹងស្ទុះចេញទៅធ្វើអន្តរាយគួនអ៊ូតាមសញ្ញា ក៏ឮកខ្ញាចថា គួនអ៊ូនឹងប្រហារជីវិតខ្លោសុកជាប្រាកដ ឯគួនអ៊ូសោតក៏ដឹកដៃខ្លោសុកទៅដល់មាត់ច្រាំងតាំងតែនិយាយថា យើងអរគុណអ្នកច្រើនណាស់ សុំឲ្យអ្នកទៅជាសុខសប្បាយចុះ ជាហើយក៏គំនាប់លាខ្លោសុកចុះទៅក្នុងទូក ឲ្យខាហានបើកក្តោងចេញទៅដល់ស្រុកកេងដ៏វែ ឯខ្លោសុកក៏ត្រឡប់ចូលក្នុងជង្ហាយវិញ ហើយឲ្យរកហៅកាំខ្លែង នឹងលីបងចូលទៅប្រឹក្សាថា យើងគិតធ្វើប្រទូសព៌ាយគួនអ៊ូគ្រានេះ ក៏មិនសមសេចក្តីគិតសោះ បើដូច្នេះយើងនឹងគិតធ្វើម្តេចតទៅទៀត ។ លីបងឆ្លើយថា លោកត្រូវធ្វើសំបុត្រមួយទៅដល់ស៊ុនគួនថា ការដែលគិតធ្វើអន្តរាយគួនអ៊ូនោះ មិនបានដូចប្រាថ្នា

ទេ សុំឲ្យរៀបចាត់ចែងលើកទាហានជាតួហៈខ្ញុំ ទៅវាយយកស្រុកកេងដីវតែម្តងទៅចុះ ឯការខាងមាត់កំពង់នេះ ត្រូវឲ្យលោកទៅគ្រប់គ្រងរក្សាកុំឲ្យកើតអន្តរាយ ។ ខ្លោសុកយល់ឃើញត្រូវ ក៏តែងសំបុត្រតាមពាក្យលីបង ហើយប្រើបំរើសេះឲ្យកាន់ចូលទៅឲ្យស៊ុនគួនឯស្រុកកាំងតាំង ។

ស៊ុនគួនទទួលសំបុត្រមើល ដឹងសេចក្តីហើយ ក៏ទិនទាំងណាស់ទើបឲ្យកេណ្ឌទាហានអស់ពីក្នុងដែនស្រុកកាំងតាំងត្រៀមទុកស្រេច ដើម្បីនឹងលើកទៅវាយយកស្រុកកេងដីវ ទទួលមានបំរើសេះពីទិសខាងជើងចូលមកថ្លឹងរាជការថា ឥឡូវចូរកេណ្ឌទាហានបានប្រមាណ ៣ម៉ឺន ទើបលើកចុះមកវាយយកស្រុកកាំងតាំងហើយ ស៊ុនគួនឮដូច្នោះ ក៏តក់ស្លុតស្មារតី ទើបឲ្យតែងសំបុត្រប្តឹងរាជការខាងទិសឯជើងទៅដល់ខ្លោសុកថា យើងត្រូវលើកទ័ពទៅតាំងទទួលកងទ័ពចូរទៅដំបន់ហាប់ហ៊ុយឲ្យខ្លោសុកទៅរក្សាមាត់កំពង់យើងឲ្យមាំមួន ហើយស៊ុនគួនក៏ឲ្យទាហានលើកទៅតាំងលន់ទ័ពទៅដំបន់យើស៊ូ តួស៊ុនគួនឯងក៏លើកពលទៅតាំងទៅដំបន់ហាប់ហ៊ុយ ប្រុងថ្នាំនឹងទទួលទ័ពចូរ ។

ឯចូរគូក៏ត្រៀមពលយោធា ត្រមះត្រៀងស្រេចការណានឹងលើកចេញចាកស្រុកក្រុង ទទួលចោ៉ាហាន់តាន់សំបុត្រ ១ ច្បាប់យកទៅជូនចូរគូទទួលយកទៅមើលឃើញសេចក្តីថា ខ្ញុំបាទចោ៉ាហាន់សូមគាំទាប់មហាចបកដទ័ពយុទ្ធសូមជ្រាប ព្រោះពាក្យចូរណាគោលពុកថា ចណ្តា

ទាហានសេនាដែលជាទ័ពមេកងនោះ បើទំនងលើកពលទៅធ្វើសង្គ្រាម ទៅទីណាដំបន់ណា ត្រូវឲ្យចំរុងសេនាទាហានទំនងគ្រឿងសាស្ត្រាវុធឲ្យគ្រប់ជាគេដរាបសិ៍ ហើយសន្សឹមលើកតួហរៈចេញទៅជាធម្មតា ចំណែកខាងក្នាត់ជារវង្គបាលសោត ក៏ត្រូវឲ្យប្រកបចិត្តគិតអធ្យាស្រ័យប្រណីខ្លួនទៅដល់អាណាប្រជាខុកស្តួឲ្យនៅជាសុខ ហើយត្រូវទំនុកបំរុងស្រុកទេសខុកជាទីពិសិតគេដរ សេចក្តីពាំង ២ ប្រការនេះ បើអ្នកណាធ្វើបាន ទើបនឹងតាំងខ្លួនធ្វើជាធំបានតទៅ ឯអាណាខេត្តពាំងអស់នេះ សុទ្ធតែកើតចលាចលកល់ថ្ងៃ-វែង តុំពាន់ស្ងប់កបខាប លោកបានចេញទៅថង្គ្រាបបាន ៩ ភាគហើយ ទៅសល់តែ ១ ភាគ គឺស្រុកកាំងតាំងនឹងស្រុកសែឈួន ដូចជាស្រុកកាំងតាំងនោះ ផ្លូវកំដាច់ស្រយាលឆ្ងាយ ព្រោះជាជាយមាត់ទន្លេសមុទ្រផុតស្រុកពាំងតួង ឯស្រុកសែឈួនសោត កំដាផ្លូវទៅមកលំបាកណាស់ ព្រោះជាច្រកជ្រោះជ្រលងដងលង្វែកក្តុំច្រែនអន្ទឹ បើលោកនឹងលើកទ័ពទៅវាយយកស្រុកកាំងតាំងគ្រានេះ មុខជាពលទាហានបានសេចក្តីលំបាកណាស់ សុំឲ្យលោកបង្អង់ឈប់ចំរុងសេនាទាហាន ឲ្យមានកម្លាំងសិនសឹមលើកទៅ គង់នឹងមានជ័យដំនេរដោយងាយ ។

ចូធូរមើលយល់សេចក្តីសំបុត្រដូច្នោះហើយ ក៏ឲ្យបញ្ជាប់កងទ័ពពុកមួយអន្ទឹ ហើយតាំងរិះគិតធ្វើតាមឧបាយនៃសំបុត្រចៅហាន់នោះ ទោះមាននរណាទាំងពួកែក្លាហាន ក៏ឲ្យយកខ្លួនមកបូលធ្វើការកេងការព្យា-

ជាលក្ខណៈ ក្នុងខណៈនោះ មានឈ្មោះអង្គសាន តោសុំបអ៊ុំទ្រ
ចាប់ ៤ នាក់នេះប្រឹក្សាយោបល់គ្នា កំចូលទៅជំរាបប្តីឯកូនថាព្រះតេជ
ព្រះគុណជាមនុស្សមានសតិបញ្ញា ជានទុកបំរុងស្រុកទេសដែនដីឲ្យ
ជានសេចក្តីសុខក្សេមក្សាន្ត ជានច្រើបច្រាមសឹកសត្រូវកំរាបជាបអស់
ហើយ គួរនឹងលើកទីជាម្ចាស់វុយអង្គ តើស្តេចតាន់ក្រមជាន ចូនួ
ជានស្តាប់ក៏មិនជាន់តបប្រការម្តេច ស៊ុនហ៊ីវត្តមន្ត្រីចាំង ៤ នាក់ស្តី
សេចក្តីដូច្នោះ កំឆ្លើយថាស់ថា សត្វថ្ងៃនេះ លោកកំជានជាទីវុយកុង
ហើយតើជាធំលើសមន្ត្រីខ្ញុំឯជតារាចាំងតួង ដែលអ្នក ៤ នាក់ សុំឲ្យលោក
ឡើងទីជាវុយអង្គនោះ លើសនិស្ស័យណាស់ ។

ចូនួឮដូច្នោះ កំខឹងច្រឡោតថា អ្នកឯងមកស្រដីមើលងាយយ៉ាងនេះ
ឱងចង់ឲ្យដូចស៊ុនហុកទៅឬ ។ ស៊ុនហ៊ីរយើញចូនួខឹងដូច្នោះ ក៏មិនហ៊ាន
តបថាអ្វីទៀត ទើបលាត្រឡប់ថយចេញមក លុះទៅដល់ផ្ទះអាត្មាក៏ឲ្យ
ឈឺផ្សាភ្លោមនស្សតូចចិត្តណាស់ ចេះតែក្រំចិត្តខាល់តែគ្រប់ជីវិតទៅ ចូនួ
ដឹងជាស៊ុនហ៊ីរមនិចូតកម្ម ក៏អាណិតស្តាយណាស់ ឲ្យយកវេស់មាសប្រាក់
ទៅរៀបធ្វើការសពតាមទម្លាប់ប្រពៃណី ហើយឲ្យហៅទៅបញ្ចុះតាម
ទំនៀម ឯការដែលប្រុងខឹងឡើងទីជាវុយអង្គនោះ ចូនួក៏បង្អង់ទៅវិញ ។

លុះអំណើះមកថ្ងៃមួយនោះ ចូនួក៏កាន់ក្រមីចូលទៅទាន់ក្នុងព្រះ
បរមរាជវាំង ព្រះបៅហៀនតេ ទ្រង់ព្រះនាមហុកហ៊ី ជាព្រះអគ្គមហេសី

ក្រឡេកឃើញកំសុតព្រះខ័យ ចូរតូកំឲ្យលន់ឃុយថា ឥឡូវស៊ុនតួនទៅ
ភាយស្រុកកាំងតាំង នឹងឡៅពីទៅភាយស្រុកសៃឈួនចាំង៦មណ្ឌលនេះរឹង
ខឹង ខ្លាំងតូរកែមិនបានមកចំណុះបុះចូលស្តាប់បង្គាប់ក្រោមព្រះបាទតាម
ចូកណាកដប្រពៃណីជាយូរមកហើយ ។ ព្រះចៅហៀនតេទ្រង់តម្រាស់
ត្រាស់តបថា ការចាំងនេះ នឹងមកប្រាប់យើងធ្វើអ្វី នឹងត្រូវការអ្វីក៏
ស្រេចតែវុយកុងចុះ ។ ចូរតូឮព្រះពាក្យដូច្នោះ ក៏ខឹងណាស់ ធ្វើយតបថា
ព្រះអង្គទ្រង់មានព្រះបន្ទូលដូច្នោះ ដូចជាតាំងឲ្យមនុស្សចាំងតួងមានសេចក្តី
គរហានិន្ទាដល់ខ្លួនព្រះបង្គំ ។ ព្រះចៅហៀនតេត្រាស់ថា ការស្រុក
ខេសចាំងប៉ុន្មាន បើលោកមិនជួយចំទុកបំរុងទេ ក៏មិនបានសេចក្តីសុខ
ក្សេមក្សាន្ត ព្រោះដែនដីចាំងនេះ ពិតជារបស់យើងមែន តែស្រេចនៅ
លោកចាត់ចែងចាំងអស់ហើយ បើលោកនឹងតតែធ្វើការអ្វីៗយើងនឹងខឹង
លោកបាន ។

ចូរតូឮដូច្នោះ ក៏តែតែខឹងខ្លាំងណាស់ មិនបានគំនាប់លាតាមទំនៀម
ក៏លែតែឡប់ទៅកាន់ទីលំនៅវិញ ។ ខ្លីចាំងតួង កាលបើឃើញចូរតូរួលផុត
ទៅហើយ ក៏នាំគ្នាចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេថា ទូលព្រះ
បង្គំជាខ្ញុំបានឮកិត្តិសព្ទថា ចូរតូនោះគិតនឹងឡើងធ្វើជាស្តេចតាងក្រម យូរ
ទៅទូលព្រះបង្គំជាខ្ញុំយល់ឃើញថា មុខជាក្សត់ជណ្តើមយកកដសម្បត្តិ
ជាប្រាកដពុំខាន ព្រះចៅហៀនតេនឹងព្រះនាងហុកហើអគ្គមហេសីទ្រង់

ព្រះសណ្តាប់ដូច្នោះ កំរ្តេកកន្សែងពិលាប ហើយស្តេចយាងចូលទៅក្នុងព្រះបន្ទំតាំង ២ ព្រះអង្គ ។ ព្រះនាងហុកហៅក្រាបទូលថា ហុកអ្ញុនបិតាខ្ញុំម្ចាស់ ឃើញបួនធ្វើការរំលោភអាក្រក់ កំមានចិត្តក្តាញ់ក្តៅពន់ប្រមាណណាស់ គិតតែនឹងសម្លាប់បួនឲ្យចេញឲ្យបាន ខ្ញុំម្ចាស់នឹងធ្វើសំបុត្រផ្ញើទៅបិតាខ្ញុំម្ចាស់ ឲ្យទ័រនៃគិតកំចាត់វាចេញឲ្យបានឆាប់ ។

ព្រះចៅហៀនតេត្រាស់ថា ដែលចៅនឹងឲ្យសំបុត្រទៅដល់បិតានោះ យើងខ្លាចក្រែងដូច កាលយើងសរសេរអក្សរនឹងលោហិតទៅដល់ តាំងសិនធ្វើការមិនកំចាំង បួនឆ្លៀតបាន កំសម្លាប់អស់តាំងពួកក្រុមជាច្រើននាក់ ត្រានេះ បើចៅនឹងធ្វើការក្រែងមិនដឹត យើងនឹងនាំគ្នាក្សយជីវិតទេជំនឹង ? ។ ព្រះនាងហុកហៅទូលថា ព្រះអង្គនឹងខ្ញុំម្ចាស់មានជីវិតរស់នៅសព្វថ្ងៃនេះ ទុបមាដូចត្រឡាចនៅកងបង្ហា មិនមានពេលណាឲ្យសប្បាយនោះគ្មាន បើតេជៈបារមីរបស់ព្រះអង្គនឹងខ្ញុំម្ចាស់មានមកកំតង់តិតធ្វើការនេះបានរហូតទៅ បើគ្មានបុណ្យវាសនាមកទេ ស្លាប់ដំរិតទៅ ប្រសើរជាងរស់នៅ ខ្ញុំម្ចាស់ឃើញបកស៊ុនទន្លីនោះមានចិត្តសុចរិតទៀងត្រង់ ល្មមនឹងប្រើការបាន ទើងឲ្យកាន់សំបុត្រចេញទៅឲ្យបិតាខ្ញុំម្ចាស់ ។

ព្រះចៅហៀនតេយល់ឃើញត្រូវ ក៏ត្រាស់ឲ្យហៅបកស៊ុនទន្លីចូលទៅគាល់ ហើយទ្រង់ព្រះកន្សែងត្រាស់ប្រាប្តរឿងដែលជាខុសនោះ

ឲ្យស្តាប់ហើយគ្រាស់ថា បពួធ្លើការអាក្រក់ណាមក ទាល់តែបានឡើងយសសក្តិជាទីវុយកុង ហើយនៅមានចិត្តគិតប្រឆឹងនឹងលើកខ្លួនជាទីវុយអង្វៀត ប្រថ្នាខឹងជ្រៀតជ្រែកដណ្តើមយកការសម្បត្តិរបស់យើង ខ្លួនយើងនឹងអគ្គមហេសីបានសេចក្តីទុក្ខក្តៅ ដូចដែកនៅក្នុងគំនរក្តៅជានិច្ចនិរន្តរ៍ នឹងតយគន់មើលក៏មិនឃើញមានអ្នកឯណានឹងជួយឲ្យរួចពីសេចក្តីក្តៅនេះបាន ឃើញតែអ្នកមួយដែលនឹងជួយឲ្យបានសេចក្តីសុខជាស្វាត់កាន់សំបុត្រទៅដល់ហុកអ្ងួនដែលជាបិតាព្រះអគ្គមហេសីនៃយើង ដើម្បីនឹងឲ្យជួយកំចាត់បពួធ្លេចេញ ។

បកស៊ុនបានឮព្រះបន្ទូលដូច្នោះ ក៏យំរឭកខ្លួលអួលទុក ក្រាបទូលស្នងព្រះពរថ្លាថា ខ្ញុំលព្រះបង្គំជាខ្ញុំបានទៅជាសុខក្រមមួយព្រះបរមគោធិសម្ភារព្រះអង្គមកយូរហើយ រំលេចនេះនឹងសុំយកជីវិតគិតធ្វើថ្វាយព្រះតេជព្រះគុណកាន់សំបុត្រចេញទៅឲ្យបាន សូមឲ្យទ្រង់ព្រះអក្សរបុះព្រះនាងហុកហៅកិសរាសេសំបុត្រតាមរឿងក៏រ ដែលមានសេចក្តីទុក្ខក្តៅគ្រប់ប្រការ ហើយប្រកាស្រមេចិទយ៉ាងជិតប្រគល់ឲ្យបកស៊ុន ។ ខ្លួលយកសំបុត្រនោះទៅលាក់កន្ទក់កន្ទុងសក់ ហើយក៏ថ្វាយបង្គំលាចេញទៅ ពីក្នុងព្រះមរមាជក៏តម្រង់ទៅផ្ទះហ៊ុកអ្ងួន លុះទៅដល់ហើយក៏ហុចសំបុត្រឲ្យទៅហុកអ្ងួន ហើយនិយាយប្រាប់សេចក្តីគ្រប់ប្រការ ។

ហុកអ្ងួនខ្លួលសំបុត្រទៅមើលដឹងថា លាយលក្ខអក្សរដៃព្រះនាងហុក

ហៅដាបុត្រច្រាច់សេចក្តីខុសត្រូវគ្រប់ប្រការថា ការនេះយើញតែចិត្តនឹងដួយរិះគិតការកំចាំង ដើម្បីនឹងកំចាត់ចូឆូចេញ ទើបផែនដីនឹងបានសេចក្តីសុខតទៅ ហុកអ្នឧដ៏ងក្នង់សេចក្តីសំបុត្រដូច្នោះក៏និយាយថា សព្វថ្ងៃនេះចូឆូកំរើបចិត្តគិតធ្វើការជាធំពន្ធឹកពេកណាស់ ចាំងត្រូវចៀកនឹងក្អែកក៏មានជ្រួតជ្រាបដ៏ងខ្លួនទៅគ្រប់ប្រកល្អកមិនសូវកែចាំង ដែលយើងនឹងធ្វើការអ្វីជាសេចក្តីស្រាលគំនិតគិតឲ្យជ្រៅល្អិតខេ ក៏គង់មិនសម្រេច គេចត្រូវប្រាប់រំណែងព័ន្ធលើខ្លួនវិញមិនខាន ... បើដូច្នោះគួរតែឲ្យសំបុត្រសម្ងាត់ទៅដល់ខ្មៅពីនឹងស៊ុនគួន ឲ្យលើកកងទ័ពមកធ្វើការខាងក្រៅ ចូឆូក៏គង់ចេញទៅធ្វើការតទល់ ហើយយើងចាត់មនុស្សដែលមានចិត្តសុចរិតត្រង់នឹងផែនដីទៅធ្វើការជាកលសឹកខាងក្នង់តង់នឹងបានសម្រេចតាមប្រាថ្នា បកស៊ុនស្តាប់ឃល់ឃើញត្រូវ ហុកអ្នឧក៏តែងសំបុត្រ ២ ច្បាប់បញ្ជូនឲ្យទៅខ្មៅពីនឹងស៊ុនគួន ហើយសរសេរសំបុត្រច្រាច់រឿងក៏រវែលតិតនោះ ផ្ញើទៅព្រះខាងហុកហៅឲ្យក្រាបបង្គំទូលព្រះទៅហៀនតេ ១ ច្បាប់ រួចបិទត្រាមប្រគល់ឲ្យបកស៊ុន ។

បកស៊ុនទទួលសំបុត្រនោះមកសឹកលាក់ក្នង់ក្នង់សក់ ហើយលាត្រឡប់ចូលទៅក្នង់ព្រះបរមរាជវាំង ។ណៈនោះមានស្រីដែលស៊ើបការណ៍របស់ចូឆូនៅក្នង់ព្រះបរមរាជវាំង បានដឹងសេចក្តីច្បាស់ក៏ទៅច្រាច់ចូឆូ ។ បានដឹងការណ៍ក៏នាំគ្នាហានស្រួតទៅស្អាក់ចាំបកស៊ុន នៅមាត់ទ្វារព្រះពជ

វ៉ាន លុះឃើញបកស៊ុនដើរចូលមក ចូឆ្លូសួរថា អ្នកឯងនិះទើបមកពីណា ? បកស៊ុនឆ្លើយថា ព្រះទាន់ហុកហៅទ្រង់ប្រឈួន ឲ្យខ្ញុំចាប់ចេញទៅរកគេឲ្យហ្ន ចូឆ្លូថា ឯណាមិនឃើញគេឲ្យនោះ បកស៊ុនឆ្លើយតែថា គេឲ្យមកតាមក្រោយ ចូឆ្លូថា ខ្លួនមានពិរុទ្ធហើយ ទើបឲ្យទាហានដោះអាវបកស៊ុនពិនិត្យមើលក៏មិនឃើញមានអ្វីជាសំគាល់ ក៏ឲ្យបើកលែងបកស៊ុនដើរចេញទៅ បកស៊ុនដើរចេញទៅបានប្រហែល ១០ ត្បាម ខ្លួចឲ្យលង់ផាត់ភ្លាត់ម្ខាងពីលើក្បាល ចូឆ្លូឃើញដូច្នោះក៏មានសេចក្តីសង្ស័យ ទើបឲ្យហៅបកស៊ុនត្រឡប់មកពិនិត្យមើលម្តងទៀត ក៏មិនឃើញមានពិរុទ្ធអ្វី ចូឆ្លូឲ្យបើកលែងទៅ បកស៊ុនក៏យកតក់ស្លុតលាចូឆ្លូដើរចេញទៅកំមួកលើក្បាលរបើតភ្លាក់ទៅវិញ ព្រោះក័យតក្តមាខ្លាំងណាស់ ប្រឹងដើរហ៊ោសទៅឲ្យផុត ចូឆ្លូឃើញប្លែកគំតថា បកស៊ុនប្រហែលមានហេតុអ្វីក្នុងខ្លួនបានជាតកស្លុតដូច្នេះ ក៏ឲ្យហៅត្រឡប់មកពិនិត្យមើលទៀត លុះសង្កេតមើលសព្វទៅ ក៏ឃើញសំបុត្រនូវកងកងសក់បកស៊ុន ចូឆ្លូឲ្យទាហានយ៉ុំខ្លួនខុត ហើយយកសំបុត្រនោះមកហែកស្រាមមើលឃើញសេចក្តីថា ខ្ញុំហុកអួនដែលគំតនឹងកំចាត់ចូឆ្លូចេញនោះ ចាំគំតផ្ញើសំបុត្រទៅបង្ហុះបង្កាលឲ្យដាច់ឫទ្ធិនឹងស៊ុនគួនឲ្យលើកកងទ័ពមកសង់ ទើបនឹងគំតការនោះបានរហូត ។

ចូឆ្លូឃើញសេចក្តីសំបុត្រដូច្នោះក៏ខឹងណាស់ ឲ្យទាហានចាំ

បកស៊ីនៅឯផ្ទះ ហើយក៏ឃុំខ្លួនបកស៊ីនទុក ទាំងហាន៣ នាក់នៅតែក្នុងផ្ទះហុកអួន ចាប់ខ្លួនហុកអួននឹងគ្រប់ស្ត្រីគ្រប់ក្មេងពួកទាំងអស់ យកទៅដាក់គុកទុក ហើយរឹបយកទ្រព្យរបស់អស់លើងពីក្នុងផ្ទះគ្រែផ្ទះ ពួកហាន កំរើយើញសំបុត្រព្រះនាងហុកហ៊ៅខៅលើផ្ទះហុកអួនយកទៅជូន ចួនួ ។ ខ្លួលយកទៅមើលឃើញសេចក្តីខឹងណាស់ ប្រើហាន១ឲ្យទៅតាមចាប់បណ្តាវ័ត្រាតណា ញាតិបងប្អូនព្រះនាងហុកហ៊ៅ យកទៅដាក់គុកទាំងអស់ លុះវេលាព្រឹក ចូនួប្រើអេកលីឲ្យលើកហាន ៣០០ នាក់ កាន់គ្រឿងសាស្ត្រាវុធគ្រប់ដៃ ហើយចូលទៅប្រគំនឹងយកគ្រាសម្រាប់ព្រះអគ្គមហេសី ។ ណៈនោះព្រះចៅហៀនតេ ទ្រង់ស្តេចយាងចេញមកកាន់តែប្រជុំ ខ្លួនម៉ឺនមន្ត្រី ខតព្រះនេត្រឃើញអេកលីលើកហានចូលមកសន្ធឹកសន្ធាប់ដូច្នោះ ក៏ទ្រង់ត្រាសសួរថា អ្នកឯងចូលមកនេះដោយមានការអ្វី អេកលីខូលថា ដោយកុងប្រើឲ្យខូលបង្គំជាខ្ញុំចូលមកយកគ្រាសម្រាប់តែព្រះអគ្គមហេសី ។

ព្រះចៅហៀនតេ ទ្រង់ព្រះសណ្តាប់ស្តេតព្រះតែយ ទ្រង់ព្រះដំរិះថា ការដែលគិតនោះប្រហែលជាដឹងដល់ចូនួហើយឬ ឬនជាកើតហេតុដូច្នេះ ទ្រង់មានព្រះហរិតក្តុក្តួលមនស្សពន់ប្រមាណណាស់ ម៉ឺនឬនត្រាស់ថាប្រការដូចម្តេចសោះ អេកលីក៏នាំហានចូលទៅដល់ស្លែងក្នុង ហើយស្រែកប្រកាសថា ស្រីចំរើងណាដែលឬនក្សាគ្រាសម្រាប់តែព្រះ

អគ្គមហេសីនោះ ចូរយកគ្រានោះមកប្រគល់ឲ្យយើងជាប្រញាប់ តាមបង្គាប់ព្រៃយកុង ស្រីម៉ាវែលសម្រាប់រក្សាគ្រាបានឮដូច្នោះភ័យតក់ស្លុតក្នុងចិត្ត ទើបយកគ្រានោះប្រគល់ឲ្យអកលី ។ បានគ្រាហើយ កំនាំទៅប្រគល់ឲ្យចូទូ ។

ឯណានោះ ព្រះនាងហុកហៅយើញតាហានចូទូទៅស្រែកកំហែងឲយកគ្រាសម្រាប់ទីព្រះអគ្គមហេសីដូច្នោះ ក៏ភ័យខ្លាំងណាស់ ទើបគិតថា សេចក្តីដែលគិតឲ្យសំបុត្រដល់ឪពុកនោះ ប្រហែលចូទូដឹងច្រាកដហើយ ទើបបង្កើតហេតុដូច្នេះ ឥឡូវនេះជីវិតរបស់យើងមុខជាស្ទាប់អន្តរាយជាច្រាកដហើយ ។ ព្រះនាងក៏ចូលទៅក្នុងក្នុងព្រះដំណាក់មួយអន្លើ ហើយបង្គាប់ឲ្យចាក់សោទីក្នុងនឹងក្រៅ ក្រែងថាមិនឲ្យអ្នកឯណាចូលទៅធ្វើអន្តរាយបាន ។

ចូទូ កំប្រើហ៊ុយហឺមឲ្យនាំតាហាន ៩០០ ចូលទៅចាប់ព្រះនាងហុកហៅ ហួហ៊ុំមកាលចូលទៅដល់ល្វែងក្នុង កំសួរស្រីម៉ាវែងតួងថា ព្រះនាងហុកហៅនៅឯណា បណ្តាស្រីខាងក្នុង បានឮដូច្នោះ ភ័យខ្លាំងណាស់ឆ្លើយថា ព្រះនាងហុកហៅគង់ទៅក្នុងឯណាមិនដឹងទេ ហួហ៊ុំមនាំតាហានចូលទៅរកមើលគ្រប់ទីតន្លែងក៏មិនប្រទះឃើញឮសោះ លុះក្រឡេកឃើញដំណាក់មួយខ្នងចំទ្វារដិតថ្មកណាស់ ក៏ឲ្យតាហានបុកទំលាយចូលទៅ ហួហ៊ុំមចូលទៅតាមឃើញព្រះនាងហុកហៅនៅក្នុងក្នុង

ដំណាក់នោះ កំចូលទៅចាប់សក់ដឹកកន្ត្រាក់អូសចេញមកពីក្នុងដំណាក់ ព្រះនាងហុកហៅតំយូងំណាស់ កំស្រែកយំប្តឹងអង្វរថា លោកបួរ អាណិត កុំឲ្យខ្ញុំដល់នូវសេចក្តីស្លាប់ឡើយ ហួហ៊ុមថា យើងជាបំរើតេ ធ្វើតែតាមបង្គាប់នាយទៅហ្នឹង សូមនាងហុកហៅទៅអង្វរយុកុងចុះ ហើយកំដឹកសក់អូសកន្ត្រាក់ ព្រះនាងចេញមកពីក្នុងព្រះដំណាក់ ទៅដល់មុខព្រះលាន ។

ព្រះចៅហៀនតេឃើញដូច្នោះ ស្តុតព្រះទ័យខ្លាំងណាស់ ហើយស្តេចចេញទៅទូលព្រះអគ្គមហេសីទ្រង់ព្រះកន្សែងសោកាពិលាក ព្រះនាងហុកហៅកំទ្រង់ព្រះកន្សែងទូលតបថា ជីវិតខ្ញុំម្ចាស់ វេលានេះមុខជាមិនរួចឡើយ ព្រះចៅហៀនតេត្រាស់ប្រសាសន៍ថា ពេលវេលានេះជាកម្មវេរវេរបស់យើង តាមមកទាន់ហើយ កុំថាឡើយតែជីវិតចៅដែលត្រូវស្លាប់នោះ ទោះជីវិតយើងនេះក៏មិនដឹងថានឹងមានសេចក្តីអន្តរាយនោះទំនឹងមកដល់ពេលណា ហួហ៊ុមឃើញដូច្នោះក៏ស្រែកកំហឹកថា យុកុងឲ្យមកយកខ្លួនព្រះអគ្គមហេសីចេញទៅជាប្រញាប់ ហេតុម្តេចក្រុអង្គមកទ្រង់ព្រះកន្សែងឲ្យយុគារណ៍ដូច្នេះ ទោសនោះមិនធ្លាក់ទៅលើមនុស្សបំរើទេឬ ? ថាហើយក៏ឲ្យគហានអូសតាញកន្ត្រាក់នាំព្រះនាងចេញ ។

ព្រះចៅហៀនតេទតឃើញ ក៏រឹតតែទ្រង់ព្រះកន្សែងពន់ពេកណាស់ មុខគួរឲ្យអាសូរព្រះមហាក្សត្រ ដែលពាជសម្បត្តិមកតើតវិបរិតដូច្នេះ លុះ

ទ្រង់ក្រឡេកទៅឃើញអេកលី ដែលបួងឆ្លៀតប្រើឱ្យយកគ្រាសម្រាប់ទីព្រះអគ្គមហេសីនោះត្រឡប់បួលមកគាល់កំគ្រាស់សួរអេកលីថា ស្រុកទេសយើងពីដើមមកមានកើតហេតុដូច្នេះទេ ? អ្នកឯងដែលឃើញខ្លះឬទេ អេកលីក៏មិនបានទូលតបថា ប្រការម្តេច ព្រះចៅហៀនតេក៏ទ្រង់ព្រះកន្សែងពាល់តែដួលសន្លប់ទៅវិនោះ អេកលីឃើញដូច្នោះ កំប្រើនទ្លីឱ្យបួលទៅគ្រាប់ព្រះអង្គ ឬានដឹងព្រះស្មារតីឡើងវិញ ហើយអញ្ជើញស្តេចឱ្យទៅខាងក្នុង ។

ខណៈនោះហូហ៊ុម ក៏នាំព្រះនាងហុកហ៊ៅទៅជួនបួង ។ កំសួរថា ខ្លួនអញទុស្សាហ៍រិះគិតបំបាត់សឹកសត្រូវចម្រូងចម្រៃក្នុងព្រះនគរ ឬកបាបហេតុអ្វីខ្លួនឯងដែលឬានតែសេចក្តីសុខក៏ទៅមិនគាប់ចិត្តទៀត ឯងជាមនុស្សមិនដឹងគុណ គិតខុរយសគុ្មស្តគុណអញ គប់គិតគ្នាទីឯងអាពុកបង់ធ្វើខុកឱ្យអញនៅសរីញដូច្នេះ បើអញទឹងខុកឱ្យឯងទៅតទៅទៀត តង់ទីឯងប្រគុំសកយអញពុំឱាន ថាហើយក៏ឱ្យគាហានយកដំបងសំពងកយដំពាល់តែព្រះនាងហុកហ៊ៅខួលអនិច្ចកម្មកន្ទខណៈនោះ ហើយឱ្យគាហានទៅចាប់ព្រះកដបុត្រព្រះនាងហុកហ៊ៅទាំងពីរព្រះអង្គ ដែលកើតពីព្រះចៅហៀនតេនោះ នាំទៅប្រហារជីវិតបង់ លុះវេលាកណ្តាលយប់ បួងក៏ឱ្យនាំយកខ្លួនហុកអួន ទឹងបកស៊ុន ទៅបណ្តាត្រប់បក្សពួកទាំងប៉ុន្មាន ហើយទឹងបង់ប្អូនសាច់សន្តានព្រះនាងហុកហ៊ៅទៅប្រហារជីវិតទាំងអស់ ។

ខណៈនោះ ព្រះចៅហៀតេ តាំងពីបានទៅគង់នៅក្រុងហ៊ូគោចំនួន ១៩ ឆ្នាំ (ពុទ្ធសករាជ ៧៩៧) វេលានោះព្រះអង្គទ្រង់សោកាល័យព្រះអគ្គមហេសី នូវព្រះរាជបុត្រតាំងពីព្រះអង្គគ្រប់វេលា មិនបានស្រង់មិនបានស្វាយព្រះក្រយាហារជាយូរថ្ងៃ ចូឆូដឹងដូច្នោះ ក៏ចូលទៅគាល់ហើយទូលថា ព្រះអង្គកំទ្រង់ព្រះវិតក្កសោះឡើយ ដូចជាខ្ញុំទូលបង្គំនេះ ពីដើមរៀងមកក៏បានទូលទុកថា នឹងជួយទំនុកបំរុងផែនដីតទៅ ដើម្បីណាប្រព្រឹត្តខុសត្រូវក៏ត្រូវធ្វើតាមគុណនឹងទោស ទូលព្រះបង្គំមិនបានគិតជាចិត្តពីរសោះ តាំងចិត្តស្មោះថានឹងជួយទំនុកបំរុងព្រះអង្គដោយសុចរិតជ្រាក ឥឡូវនេះទូលព្រះបង្គំក៏នៅមានបុត្រីម្នាក់ មានប្រាជ្ញាធ្វើវិធានប្រកបដោយអធ្យាស្រ័យខ្ពង់ត្រង់ល្អ ទូលព្រះបង្គំនឹងថ្វាយព្រះអង្គ ព្រះចៅរហៀនតេទ្រង់ព្រះសណ្តាប់ក៏មិនអាចនឹងខឹងទាស់អធ្យាស្រ័យ ព្រមទទួលតាមពាក្យចូឆូទូលនោះគ្រប់ប្រការ ។

ខណៈនោះ ព្រះចៅហៀតេគង់ក្នុងក្រុងហ៊ូគោ ២០ ឆ្នាំ (ពុទ្ធសករាជ ៧៩៨) ជាខេសកាលវិមាយចូលឆ្នាំចិន ឆូឆូក៏រៀបតុបតែងស្ត្រីទាំងចូលទៅថ្វាយព្រះចៅហៀនតេ ហើយតាំងបុត្រីនោះពេញទីជាអគ្គមហេសីបណ្តាខាម៉ីនសព្វមុខមន្ត្រីព្រះចៅហៀនតេ ក៏គោតខ្ចាចអំណាចឆូឆូតាំងអស់ នឹងរកអ្នកឯណា ១ អាចពិតទូលពោលទឹងទាស់ដោយប្រការម្តង។ ក៏គ្មាន ចូឆូក៏តែតំរើបចិត្តគិតធ្វើអាក្រក់ផ្សេង ។ តាមអំពើចិត្តឥតកោត

ញ្ញាញើតព្រះចស្តា ។

ថ្ងៃមួយ ចូធ្វូឲ្យហៅនាម៉ឺនមុខមន្ត្រីចូលទៅប្រជុំប្រឹក្សាថា យើងបានចំរុងសេនាគាហានកំមានកម្លាំងបរិបូណ៌ហើយ ឥឡូវយើងចង់លើកទ័ពទៅវាយយកស្រុកសៃឈួន ឧទ្ធស្រុកគាំងគាំង អ្នកទាំងអស់គ្នាឧទ្ធយល់យើញដូចម្តេច គាសៀងធ្វើយថា សុំលោកឲ្យហៅខ្ញុំនចាយីនឧទ្ធហែហួតុនឲ្យចូលមកប្រឹក្សាការពេជការសិន បើយើញបានការហើយសឹមលោកលើកកងទ័ពទៅចុះ ចូធ្វូយល់យើញត្រូវផង កំប្រើប៉ារើឲ្យស្រួតរួតទៅហៅខ្ញុំនចាយីន ឧទ្ធហែហួតុន ដែលនៅស្រុកស៊ុងយ៉ុងឲ្យចូលមក ។

ឯចាយីនឧទ្ធហែហួតុនដឹងការកំស្រួតរួតចូលទៅដល់ក្រុងហួតៅ តែចាយីនចូលទៅដល់មុន ខណៈនោះចូធ្វូសេពសុភស្រីឆីកំចូលទៅដេកនាងក្នុង ខ្លួលចាយីនឡើងទៅឧទ្ធចូលទៅគំនាប់ចូធ្វូ ទៅធ្លូកាន់លំតែងយាមនៅខាងក្រៅ កាលយើញចាយីនចូលទៅដល់ កំយាត់ហាមថា អ្នកកំអាលចូលទៅ ចាយីនឮដូច្នោះ ខឹងណាស់ថា ខ្ញុំនអញជាកូនកុយស្វាលោហិតបេះមហាឧបាជ ខ្ញុំនគ្រាន់តែជានាយគាហានទេ ហេតុម្តេចគាចហ៊ានមកហាមឃាត់អញដូច្នេះ ទៅធ្លូតបថាអ្នកឯងជាកូនកុយវុយកុងកំមែន តែវុយកុងចាត់ប្រើឲ្យខ្ញុំនចេញទៅឈរវៃត្រក្រៅទៅហើយ ខ្ញុំនយើងជានាយគាហានទៅរក្សាអង្គខាងក្នុង អ្នកឯងមកពីស្រុកឆ្ងាយ យើងនឧទ្ធបណ្តាយឲ្យចូលទៅតែម្តងម្តេចបាន ចាយីនត្រឡប់តិតយើញ

ត្រូវ កំចាយចេញទៅនៅខាងក្រៅវិញ ។

ក្នុងខណៈ ដែលចោយិនទីដ៏ទៅធ្វើប្រកែកគ្នានោះ ចូធូនៅមិនទាន់ដេកលក់ទេ ឮនូវសំដីទៅធ្វើនិយាយដូច្នោះ ឃើញត្រូវតាមទម្លាប់ខ្លួនឯង កំសរសើរទៅធ្វើថា មានតម្រិះប្រាជ្ញាជាមនុស្សខ្លាំងត្រង់ លុះហៃហ្គីខុនមកដល់ខ្លួន ចោយិនទីដ៏ហៃហ្គីខុន កំចូលទៅគាប់ចូធូ ។ មានសេចក្តីត្រេកអរណាស់ ទើបប្រឹក្សាចោយិនទីដ៏ហៃហ្គីខុនថា យើងគិតនឹងលើកកងទ័ពទៅកាន់ស្រុកគាំងតាំង ហើយនឹងស្រុតសែឈួន អ្នកគាំងពីរនឹងយល់ឃើញយ៉ាងម្តេច ? ។

ហៃហ្គីខុនទ្វើឃថា ស្រុកគាំងតាំងនោះ សុំឲ្យលោកបង្អង់ទុកសិនចុះ ព្រោះស្រុកហាន់តុងបីដូចជាដើមដូវស្រុកសែឈួន សុំឲ្យលោកលើកកងទ័ពទៅកាន់យកស្រុកហាន់តុងឲ្យបានសិន សឹមលើកទៅកាន់យកស្រុកសែឈួន គង់នឹងបានដោយងាយ ឯការខាងស្រុកគាំងតាំងវិញ សឹមគិតជាក្រោយតទៅ ចូធូយល់ឃើញត្រូវផង កំឲ្យគេណូប្រមូលពលទាហានជាច្រើន ហើយឲ្យហៃហ្គីអៀនទីដ៏ទៅវាយជាមេកងទ័ពមុខ ចូធូជាមេទ័ពលួង ឲ្យចោយិនទីដ៏ហៃហ្គីខុនជាមេកងទ័ពក្រោយ ឲ្យទាំងស្រុងលុះបានឫក្សជ័យមង្គល កំរៀបពលយោធាចេញពីក្រុងហ្គីតោ តម្រង់ទៅស្រុកហាន់តុង ។

ខណៈនោះ មានបំរើសេះដឹងការណ៍ កំស្រូតទៅប្រាប់ខៀវឡៃទៅ

ហ្វាយស្រុកហាន់តុង ។ ដឹងហើយក៏ប្រឹក្សាទីឯកខៀវអួយថា ចូរឆ្លើកទ័ពមកគ្រានេះ យើងទីឯកគិតការពារប្រការម្តេច ខៀវអួយថា ឯស្រុកហាន់តុងនេះជាទីបង្ខំតបង្អស់ មានតែតយអេងប៉ើងគួនជាទីប្រដុំផ្លូវសំខាន់ បើប្រសិនជាខូចទីតយនោះហើយ ស្រុកហាន់តុងក៏ទីឯកខូចទៅឯង ។ ឯមុខតយអេងប៉ើងគួននោះ មានកុំជាម្ខាង ព្រៃកម្ខាង សូមឲ្យលោកចាត់ទាហានជាពីរកងទៅតាំងបន្ទាយឲ្យមាំមួននៅទីនោះ ដើម្បីទីឯកចាំទទួលវរកងទ័ពចូរឆ្លើបទីឯកបាន ឯខ្លួនលោកត្រូវនៅរក្សាការពារស្រុកទុកឲ្យមាំមួន ។

ខៀវឡស្តាប់យល់យើញត្រូវ ក៏ចាត់ឲ្យខៀវអួយទីឯកខៀវហៀម ខៀវងុង លើកហាទាន់ជាច្រើនតបន្ទាយរក្សាតយអេងប៉ើងគួននោះ នាយទាហានតាំង ៣ នាក់ក៏នាំទាហានទៅដល់ទីនោះ ខៀវអួយក៏នៅរក្សាទីតយនោះ ខៀវហៀម ខៀវងុងក៏នាំទាហានចេញផ្លូវឆ្ងាយប្រហែល ៦០០ សិន ឲ្យតាំងបន្ទាយពាយទ័ពនៅចាំងសងខាងផ្លូវ ម្ខាង ៥០០ បន្ទាយ ហើយត្រួតត្រារក្សាពួកពលយោធា ទីឯការពារបន្ទាយជាមាំមួនណាស់ ។

ឯហេហ៊ូអៀនទីឯកខៀវឃាប់ដែលជានាយទ័ពមុខនោះ លុះលើកពលទៅដល់ប្រទល់មុខគ្នាដឹងថាទាហានខៀវឡ ចេញមកតាំងបន្ទាយពាយតាមមុខតយ កំឈប់ទ័ពឲ្យតាំងបន្ទាយនៅឆ្ងាយពីគ្នាប្រមាណ ១៥០ សិន

តង់តោលយប់នោះ តាហានហៃហ៊ួអៀនទឹងខៀវខាប់ខ្សើយណាស់ តំជាក់
ឈប់សម្រាកកម្លាំង តាំងតែធ្វេសប្រហែសប្រមាទពុំសូវគិតយាមល្បាតជា
ម៉ាំមួន ដួនយប់ជ្រៅដល់យាម ១ ថ្ងាយ អៀរហៀម អៀរង៉ុងដឹងថាកង
ទ័ពចូនួលើកទ័ពមកតាំងនៅជិតគ្នាដូច្នោះ តំប្រឹក្សាគ្នាថា ទ័ពមុខចូនួលទើប
ទឹងមកដល់ តាហានតំពុងហត់ខ្សើយណាស់ខ្លះតំដេកលក់ដេរដាសយើង
ត្រូវកន្ទុយសេចញ៉ាទៅឫទ្ធបន្ទាយ តង់ទឹងដាយថាទង់ជ័យជំនះជាប្រាកដ
លុះតិតស្រេច តំចាត់ចែងវែងតាហានលបចេញទៅ យកភ្លើងដុតនេះ
សន្ធោសន្ធៅគ្រប់បន្ទាយហៃហ៊ួអៀនទឹងខៀវខាប់នោះ ហើយតំបវេលចូលគ្រលុកគ្រុកចំពារជុំវិញបន្ទាយ ឃានបែកភ្ញាយប្រកាប់សម្លាប់តាហានហៃហ៊ួអៀនទឹងខៀវខាប់ស្ងាប់ជាច្រើនណាស់ ឯហៃហ៊ួអៀនខៀវខាប់ខ្លួវតាហានដែលមិនបានដឹងខ្លួន តំបែកប្រតាត់ប្រពួនខ្ចាត់ខ្ចាយរត់ទៅក្រោយបណ្តាយគ្នា ចូលទៅពណ៌នាប្រាប់ចូនួត្រប់ប្រការ ។

ចូនួដឹងដូច្នោះ ទឹងណាស់ថា ខ្លួនឯងបានធ្វើសឹកសង្គ្រាមជាមួយទឹងយើងរៀងមកជាយូរហើយ មិនគួរឡើយទឹងធ្វេសប្រមាទ គួរតែគិតឲ្យដឹងបទចាទតាមទម្លាប់លើកទ័ពទៅដល់យល់ថា តាហានតំពុងហត់ខ្សើយត្រូវឲ្យជាកំយាមល្បាតក្រវែលប្រុងប្រយ័ត្នការ ឲ្យមាំមួនឲ្យណាស់ វេលានេះខ្លួនមកធ្វើល្មើសធ្វេសប្រហែស ហេតុការណ៍ឲ្យបាដ័យដល់សត្រូវដូច្នេះ គោសខ្លួនជាទម្ងន់ធ្ងន់តាន់ប្រមាណណាស់ ថាហើយ តំបង្គាប់ឲ្យ

ចាប់ខ្លួនហែហ្វូងអៀនទឹងខៀវទាប់ទៅសម្លាប់ ទ័ព្រឹក្សាទាំងអស់នាំគ្នាចូលទៅតំនាប់ស៊ុំទោស ចូទ្ធូអត់សន្តោសលើកទោសឲ្យ ហើយលើកកងទ័ពស្រួតចូលទៅទៀត ឯផ្លូវដែលទឹងធ្វើដំណើរទ័ពទៅនោះ ជាប្រកជ្រោះជ្រលងដ៏កុំខ្លុតមញ្ជាតសឹ្មតណាស់ បណ្តាពលយោធាក៏យាត្រាទៅដោយលំបាកតន់តេក ចូទ្ធូថា យើងមិនបានដឹងសោះថាផ្លូវមកស្រុកនេះដាច់ស្រយាលលំបាកដូច្នេះសោះ ប្រសិនបើដឹងយ៉ាងនេះ យើងមិនលើកទ័ពមកទេ ហើយឲ្យមានចិត្តគិតព្រួយក្រែងសត្រូវយកពាហនមកញ្ជួនបង្កប់នៅពីនោះ ទៅធ្វើទឹងស៊ុឡុងឮដូច្នោះ ក៏ចូលទៅទូលប្រាប់ចូទ្ធូថា វុយកុងកុំមានប្រសាសន៍ដូច្នេះ បើពាហនទាំងអស់ដឹងទឹងនាំឲ្យព្រួយចិត្តពុំបានគិតនឹងរំធើការ ចូទ្ធូយល់ឃើញត្រូវផង លុះដើរធ្វើទៅដល់កន្លែងបន្ទាយចាស់ ដែលហែហ្វូងអៀនទឹងខៀវទាប់តាំងពុក ហើយក្តៅនេះអស់ចូទ្ធូក៏បោះទ័ពទៅពីនោះ ឲ្យកងបន្ទាយកយចំរូងឡើងវិញ លុះធ្វើរួចក៏តំណាប់នាយពាហនឲ្យប្រុងប្រយ័ត្នត្រួតត្រា រក្សាទ្វារស់ប្តូរយោមលក្ខណ៍ក្រែវលែមិនឲ្យធ្វេសប្រហែស ។

លុះវេលាត្រឹក ចូទ្ធូក៏ជិះសេះនាំទៅជួ ស៊ុឡុងចេញពីបន្ទាយទៅដល់ទ័ពមួយ កំឡើងទៅលើកពួលភ្នំនោះ សំឡឹងមើលទៅឃើញសត្រូវតាំងទ័ពទៅតយជាមាំមួនណាស់ មើលទៅប្រកបផ្លូវដែលទឹងចូលទៅតាំងបង្ក័ងគ្នាកំណាត់ខ្នែងលំបាកទឹងយកជ័យជំនះដោយក្រ និយាយមិន

ខាន់ផុតមាត់ស្រាប់តែឮសំឡេងផាវនឹងសន្ធឹកស្រែក ហៅគឹកកងរំពងចូលមកចាំងសងខាងផ្ទះ ចូធ្លកើយណាស់ក៏និយាយថា យើងនឹងតាំងប្បាំងយ៉ាងម្តេច ទៅជូធ្វើយថា លោកកុំព្រួយ តែខ្លួនខ្ញុំបាទមួយក៏ខ្លួលអាសាប្បាំងបាន មិនមានឲ្យអន្តរាយដល់លោកទេ ហើយក៏និយាយនឹងស៊ីឡុងថា ឲ្យនាំវុយកុងត្រឡប់ទៅបន្ទាយវិញចុះ ខណៈនោះ អៀវហៀមអៀវឆុងក៏បរសេះនាំគាហានចេញមកពីសងខាងផ្ទះ ទៅជូក៏ចាប់ដាវញាក់សេះចូលប្រយុទ្ធគ្នា អៀវហៀម អៀវឆុងតទល់កម្លាំងពុំបាន ក៏ញាក់សេះនាំគាហានរត់ទៅ ។

ឯហៅហ្គីអៀនឆឹងទៀតទាប់ បានឮសំឡេងហោកញ្ជ្រៀវគឹកកង ក៏នាំគាហានផងគ្នតាមទៅ ដើម្បីនឹងជួយចូធ្លុ លុះទៅដល់មាត់ផ្លូវក្រឡេកឃើញស៊ីឡុងនាំចូធ្លុចុះពីលើភ្នំមកវិញ ក៏ស្រួតទៅខ្លួលដោយសេចក្តីត្រេកអរ ឯទៅជូក៏តាមមកពីក្រោយបណ្តាយគ្នា ចូធ្លុក៏ម៉ាន់គាហានចូលក្នុងបន្ទាយវិញ តែតែតាំងនៅក្នុងបន្ទាយខោះពេញ ៥០ ថ្ងៃ ហើយចូធ្លុក្លែងនិយាយថា យើងលើកកងទ័ពមកធ្វើការគ្រានេះ ពលគាហានមានសេចក្តីលំបាកណាស់ ឃើញថានឹងវាយយកស្រុកហាន់តុងមិនបានទេ ត្រូវតែគិតលើកទ័ពត្រឡប់ទៅក្រុងវិញស្រួលជាង គាសៀងធ្វើយថាលោកលើកកងទ័ពមកគ្រានេះ ទៅមិនទាន់បានប្បាំងតាំងតទល់គ្នាជាម៉ាំមួនសោះបានប្រទះគ្នាតែបុងដៃបុងជើង ទៅមិនទាន់ឃើញថ្ងៃដៃ គាហានស្រុកហាន់ភុងនៅឡើយ ហេតុម្តេចលោកនឹងចង់លើកកងទ័ពត្រឡប់ទៅវិញ ។

ចូនទូនឮដូច្នេះប្រាប់ថា យើងឃើញគាហានស្រុកហាន់តុងចេញមកតាំងបន្ទាយម៉ាមួនមិនមានប្រមាទ យើងលើកកងទ័ពត្រឡប់ទៅវិញនោះព្រោះចង់ឲ្យពួកគ្តត្តសត្តូនេះ ទៅដល់សត្រូវខាងនោះ បើឮហើយកំតង់ទឹងប្រមាទមិនខាន បើយើងឃើញបានចំណាប់លោណាទឹងបានលើកគាហានទៅព័ទ្ធវាយចំលាយយកបន្ទាយគយអេងប៉ើងគួន កំទឹងបានជាយងាយ ការសឿងឮដូច្នោះគិសរសើរថា សេចក្តីត្រិះរិះរបស់ពុយកុងនេះប្រពៃណាស់ ប៉ាដូចជាទៅគា ។

ចូនទូនិយាយទឹងទៀវាប់ទឹងហៃហ៊ូអៀនថា គោសកំហុសរបស់អ្នកតាំងពីរនេះ ជាទម្ងន់គ្រាមុនម្តងហើយ គ្រានេះយើងនឹងឲ្យទៅធ្វើការម្តងទៀតដើម្បីកែខ្លួន បើធ្វើការម្តងទៀតមិនបានការ យើងត្រូវឲ្យប្រហារជីវិតចេញ ទៀវាប់ទឹងហៃហ៊ូអៀនកំទទួលថា បើលោកទឹងប្រើឲ្យទៅធ្វើការអ្វី ។ ខ្ញុំបានកំសុំទទួលយកការងារធ្វើការនោះឲ្យបានការ ចូនទូថា អ្នកឯងតាំងពីនោក់ត្រូវទាំងហានញែកគ្នាព័ទ្ធទៅតាមផ្លូវ តាមក្រោយបន្ទាយអេងប៉ើងគួន ខ្លួនយើងទឹងលើកទៅវាយ ទៅវាយពីមុខបន្ទាយទៀវាប់ ហៃហ៊ូអៀនទទួលបង្គាប់ហើយកំចេញទៅចាត់ការជាស្រេច ។

ឯអៀងង៊ុងកំប្រឹក្សាទឹងអៀវហៀមថា វេលានេះ ខ្ញុំបានឮកិត្តិស័ព្ទថាចូនប្រ៊ុនទឹងលើកទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោវិញ ហើយត្រូវតែលើកគាហានតាមទៅវាយពីក្រោយ មុខជាទឹងបែកខ្ចាយជាប្រាកដ អៀវហៀមតបថា អ្នកឯងគិតកំរើបដូច្នេះមិនត្រូវទេ ព្រោះចូនទូនោះចំណានក្នុងកល

សឹកសង្គ្រាមណាស់ រាមនចេះល្ហែងបញ្ឈប់តវៀចជាគ្រាន់ ។ ជាវៀចដែលនិងដឿតាមកិត្តិស័ព្ទយកជាប្រាកដនោះខ្ញុំមិនយល់ឡងនេ អៀវឆ្ងុងមិនស្គាច់ ប្រញាប់ចាត់ចែងតាហានចាំង ៥០០ បន្ទាយ ទើបយកអ្នកកាន់បន្ទាយនោះសុទ្ធតែមនុស្សឈឺនិងពិការ ហើយលើកពលរយោធាដែលមាំមួនទៅតាំងព័ទ្ធមាត់ច្រាយ ក្នុងពេលនោះ មេឃចុះអ័ព្ទងងឹតណាស់ នឹងមើលផ្លូវព្រៃក៏មិនឃើញច្បាស់ អៀវឆ្ងុងគិតថារម្ភខ្លាច ក៏បញ្ឈប់ទ័ពតាំងបន្ទាយនៅកណ្តាលផ្លូវ ។

ហៃហ៊ូអៀនលើកតាហានព័ទ្ធពីក្រោយមកក្នុងយប់នោះ មេឃងងឹតណាស់ចាន់ឮសំឡេងមនុស្សន៏ងសេះសន្ធឹកសន្ធាប់ក៏គិតថា ប្រហែលតាហានស្រុកហាន់តុងមកពួនបង្កប់នៅទីនេះដឹង ក៏បង្គំលើកតាហានស្រុកទៅឲ្យផុត ឯកងទ័ពហៃហ៊ូអៀនោះមិនចាន់លើកតម្រង់ទៅត្រង់តយេ ប៉ុន្តែវង្វេងផ្លូវសំដៅទៅតានលើបន្ទាយអៀវឆ្ងុងនោះ លុះទៅដល់បន្ទាយនោះហើយ ខ្លួលមេឃស្រឡះ អស់ពួកតាហានអៀវឆ្ងុង ដែលនៅក្នុងបន្ទាយស្មានថាអៀវឆ្ងុងលើកទ័ពមកវិញក៏ចាំគ្នាបើកទ្វារចូលហៃហ៊ូអៀនក៏លើកតាហានចូលទៅក្នុងបន្ទាយ ដើរត្រួតពិនិត្យមើលត្រប់បន្ទាយចាំង ៥០០ ឃើញតាហានចាំងនោះសុទ្ធតែមនុស្សឈឺពិការ ហៃហ៊ូអៀនក៏ឲ្យយកភ្លើងដុតបន្ទាយចាំងអស់នោះចេះឡើង ពួកតាហានចាំងនោះក៏រត់រួចរៅខ្លះ ស្រែតីនោះកើស្លាប់និងភ្លើងចេះ ត្រូវប្រហារដោយគ្រឿងសាស្ត្រាវុធស្លាប់ច្រើនណាស់ ។

អៀវហៀមឃើញពន្ធូរក្ងើងនេះឡើងគ្រប់បន្ទាយអៀវធ្លុង គំលើកមាហានទៅដួយ ហៃហ្ងឺអៀនឃើញដូច្នោះ កំបរសេះចូលទៅប្រយុទ្ធគ្នានឹងអៀវហៀមបាន ៤ ក្មេង អៀវហៀមទ្រាំកម្លាំងពុំបាន កិញ្ជាក់សេះនាំមាហានត់ចូលបន្ទាយ ខ្លួលឃើញខៀវអាប់នៅក្នុងបន្ទាយពេញតាំងអស់ អៀវហៀមបកប្រាស់ត្រឡប់នាំមាហានត់តម្រង់តាមផ្លូវសំដៅទៅស្រុកឡាំតេង ។

ឯអៀវធ្លុងឃើញពន្ធូរក្ងើងនេះឡើងគ្រប់បន្ទាយដូច្នោះ ក៏ទឹកតិតថាមុខជាកងទ័ពចូលបង្កុតជាពិតប្រាកដហើយ លុះនឹងថយត្រឡប់ទៅក្រោយខ្លាចទ័ពចូលធ្លូនឹងលើកដេញតាម ម្ល៉ោះហើយចេះតែអល់ឯកទៅទីនោះ ខ្លួលមាហានចូលធ្លូលើកពយប្រសប់ខ្លួប់តេញមកតាំង ៣ ថ្ងៃ អៀវធ្លុងមាល់ច្រចកិលុះចង់មាហានបរសេះដោះយកតែខ្លួនតែយកតែឯង ប្រពន្ធនឹងអៀវអាប់ក៏ចូលប្រកាប់គ្នាជាសន្ធឹកណាស់ ខៀវអាប់ក៏លើកលំតែងឡើងចាក់ត្រូវអៀវធ្លុងភ្លាត់ពីលើសេះស្លាប់ ខណៈនោះភាកោនអៀវធ្លុងដែលបែកតត់ទៅ ក៏យកសេចក្តីនោះទៅអធិប្បាយប្រាប់ខៀវអូយគ្រប់ប្រការ ខៀវអូយឮដូច្នោះក៏ភ័យណាស់ លុះចាលបន្ទាយនោះ ហើយនាំមាហានត់ត្រឡប់ទៅស្រុកហាន់តុងវិញ ។

ខណៈនោះ ចូធ្លូកំលើកមាហានទ័ពហ្លួងចូលទៅក្នុងបន្ទាយអេងប៉ើងគ្នួន ឯខៀវអូយនោះ កាលតត់ត្រឡប់ទៅកំដួបប្រទះនឹងអៀវហៀម

ទើបនាំគ្នាចូលទៅក្នុងស្រុកហាន់តុង ហើយខៀវអួយនិយាយប្រាប់ខៀវឡាថា ខួចបន្ទាយមុខតយ៉ាងធ្ងន់ស្អាំនោះ ព្រោះអៀវតុង អៀវហៀមធ្វេសប្រហែសណាស់ ខ្ញុំបាទឃើញសឹកលើសកម្លាំងនឹងខប់ពុំឈ្នះ បានជាលះចង់ចោលបន្ទាយរត់ចូលមកដំរបការឲ្យលោកជ្រាប ។

ខៀវឡាឮដូច្នោះកំរឹងណាស់ ឥន្ត្រាថ្ងៃចាប់ខ្លួនអៀវហៀមទៅសំឡាប់ចេញ អៀវហៀមក្រើយដោះសាថា ទោសខ្ញុំបាទនេះពុំសណាស់មែនហើយ តែថាមិនខមូនស្មើនឹងអៀវតុងទេ ព្រោះដើមហេតុអៀវតុងលើកទ័ពទៅវាយបន្ទាយចូលមុន ខ្ញុំបាទបាននិយាយហាមឃាត់អៀវតុងមិនស្តាប់ ចេះតែខ្លួចលើកទៅតាលតែសត្រូវកន្ទុងចូលមកដុតបន្ទាយនេះអស់ ខ្ញុំបាទឃើញពន្ធីក្តៅនេះឡើងសន្ធឹកណាស់ ក៏លើកតាហានទៅជួយ លុះវាយមកតាហានចូលមុ ក៏លើកគ្នាមកវាយដណ្តើមយកបន្ទាយបាន ដែលទោសខ្ញុំបាទពុំសនោះ ស្រេចនៅលោកមេត្តាពុកដ៏តែចុះ និងបានធ្វើការកែខ្លួនម្តងទៀត បើក្រោយ ។ ខ្ញុំបាទលើកទ័ពទៅហើយ ចែវជាចាញ់ត្រឡប់វិញដូចគ្នានេះ សូមឲ្យលោកសម្លាប់ចុះ ខៀវឡាក៏ត្រមអនុញ្ញាតលើកទោស ហើយកេណ្ឌតាហាន ៦ ម៉ឺន ប្រគល់ឲ្យអៀវហៀមលើកទៅវាយកនឹងទ័ពចូលមុ ដណ្តើមយកបន្ទាយនោះវិញ អៀវហៀមក៏នាំតាហានចាំង ៦ ម៉ឺននោះ លើកចេញទៅដល់ស្រុកឡាំតេង ហើយក៏ចោះទ័ពតាំងបន្ទាយនៅពីនោះ ។

(នៅមានត)

រឿងត្រែងចិន: ការសងសឹកនៃទន្សាយ

La Revanche du lapin (Conte Tibétain)

រឿងត្រែងទីបេត

លោក ប៉ាយ-ប៊ីកក ប្រែពីភាសាចាក់ង

តាំងពីយូរកាលមកហើយ មានទន្សាយមួយបិតនៅជិតសិង្ហ ។ ពិត
មែនតែសត្វទាំងពីរបិតនៅជិតគ្នា តែមានការឈ្លោះគ្នាជានិច្ច ។ សិង្ហ
ជាសត្វអំនួត តែងអួតអាងថាខ្លួនមានពលភាពអស្ចារ្យ ។ សិង្ហប្រមាថ
មើលងាយទន្សាយ ដេរដៀលត្មះទន្សាយកាល់ៗថ្ងៃ ថែមទាំងតំរៀញ
គំរាមទៀត ។ ទន្សាយជញ្ជឹងគិតរំរេក ខ្លួមធ្យាបាយផ្សេង ។ ដើម្បី
សងសឹកឲ្យបាន ។ មានមួយថ្ងៃ ទន្សាយពោលទៅកាន់សិង្ហថា :

« ឱបងសិង្ហ ! ខ្ញុំបានជួបនឹងសត្វមួយមានរូបកាន់ជួបបងឯង ហើយ
វាពោលថា : « ឯងស្គាល់អ្នកណា ហ៊ានបង់ល្បងនឹងកំឡាំងអញឬទេ ! ចូរ
ឯងហៅវាមក ។ បើវាមិនមកទេ ត្រូវតែវាស្លាប់បង្គាប់អញ ហើយត្រូវ
តែវាបម្រើអញ » ។

សិង្ហតបទៅទន្សាយវិញថា : « ឯងមានបានឮយល់ច្បាស់ពីពលភាព
អញឬទេ ? » ។

ទន្សាយតបទៅវិញថា : « មែនពិត ខ្ញុំបានឮណាស់តាំងពីឯងឯង តែ
ត្រូវខ្ញុំបិតនៅស្ងៀមទៅវិញ ព្រោះថា កាលដែលខ្ញុំសរសើរពីពលភាព
បងឯង វាទៅជាសើចឡកឡឺយឲ្យខ្ញុំ ហើយវាថាខ្លួនបងឯងមិនដល់

ទាសីរាជឯង" ។

សង្ឃកិមានចិត្តទោមនស្សតែតទបមា ហើយស្រែកជាយ៉ាងខ្លាំងថា:

"សត្វនោះវានៅឯណា ? សត្វនោះវាបិតនៅត្រង់ណា ? ប្រាប់ឲ្យឆាប់ ។

ពោលដូច្នោះ សត្វទន្សាយក៏នាំសង្ឃទៅដល់ខាងក្រោយភ្នំមួយ ហើយក៏ចង្អុលបង្ហាញសង្ឃ នូវអណ្តូងមួយ ហើយថា:

"សត្វនុ៎ះ វានៅក្នុងអណ្តូងឯនុ៎ះ ។

សត្វសង្ឃក៏ចូលទៅជិតអណ្តូង ពេលក្រែកទៅក្នុងទឹកអណ្តូងឃើញសត្វអ្វីមួយមានពលកាយធំក្រៃលែង មានទ្រង់ទ្រាយដូចខ្លួន មានដំណើរប្រហែលខ្លួន ហើយសត្វនោះវាបែរមកមើលខ្លួន មុខកំណាចបំផុត។ សង្ឃក៏ស្រែកជាយ៉ាងខ្លាំង បញ្ចាមិត្តខ្លួន ធ្វើតាមខ្លួនចាំងអស់ ។ សង្ឃខឹងខ្លាំងពាល់តែកេសរឆើបឡើងប្រែង សត្វទៅក្នុងអណ្តូងនោះ ក៏មានសកាពដូចគ្នា ។ សត្វសង្ឃបញ្ចេញចង្កឹម លោតដើងទៅមុខ ហើយ . . . ក្រឡេកមើលទៅក្រោមក្នុងអណ្តូង សត្វនោះក៏មានរូបកាយអាកប្បកិរិយាដូចគ្នា ។ សង្ឃមានចិត្តប្រកបដោយទោសៈជាអតិបរមា ទើបលោតទៅក្នុងអណ្តូងនោះ ដើម្បីនឹងចាំសម្លាប់បញ្ចាមិត្តខ្លួន (ស្រមោលខ្លួន) ក៏លង់ទឹកស្លាប់នៅទីនោះទៅ ។

ក្នុងរឿងការសេងស្រឹក នៃទន្សាយនេះ អ្នកនិពន្ធ បានចារឹក សុ-

ភាសិត ជាគ្រឿងទូន្មាន មានសេចក្តី ដូចតទៅ: សិង្ហ្គោតមានះ តាមទន្សាយ យល់ស្រមោលកាយអណ្តូងជ្រៅ ស្មានថាបក្ខាមិត្រឋិតនៅ ទំស្តុះលោតទៅលង់ទឹកស្លាប់ ។ ត្រូវតិចារណាមុនធ្វើកិច្ចការសារ តើកុំប្រញាប់ ប៉ើមិនដូច្នោះពុំបានតាប់ ខឹងស្លាប់ដូចសិង្ហ្គគ្រោះប្រមាទ ។

(នៅមានទៀត)

បម្លើយតបនឹងចំណោទក្នុងទស្សនាវដ្តីកម្ពុជសុរិយា

លេខ ១ ខែមករា ១៩៦៤

បឧពាក្យ ៧

ពួកសត្វមានក្បាលច្រើនពេញពាស តែសត្វមានថ្លែកពេកក្រៃ កាត់ ,, ៧ ,, នៅ ,, ១ ,, មានតម្លៃ សត្វនេះឯងនៃ ដែលចោទសួរ ។

ភី-ធៀនឡាយ

សេចក្តីគោតសរសើរ

សូមថ្លែងអំណរគុណ និងកោតសរសើរ យ៉ាងក្រៃលែង ចំពោះប្រាជ្ញាដ៏ឆ្លាតវៃ នៃឯក-ឧត្តម ភី-ធៀនឡាយ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលអាចរកឃើញ នូវចំណោទរបស់យើង នៅវេលាដែលឯកឧត្តម បានឃើញនៅទំព័រកម្ពុជសុរិយាភ្លាម ដោយដងព្រិះដ៏ឆ្លងយ្យុះឡើយ ។

ជាទៃតឯកឧត្តម ភី ធៀនឡាយ មានយុវជនច្រើនទៀត បានរកឃើញនូវឯកឧត្តមខាងលើនេះ តែចម្ងើយមកដល់ក្រោយបន្តិច យើងសូមថ្លែងសេចក្តីសរសើរដ៏យ៉ាងក្រៃលែងណាស់នៃះ ។

ពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា មិត្រអ្នកអានទាំងឡាយមុខជានឹងយកចិត្តទុកដាក់ក្នុងការដោះស្រាយ ចំណោទរបស់យើងតទៅទៀតមិនខាន នឹងចុះផ្សាយសេចក្តីកោតសរសើរ ដល់អ្នកឆ្លើយត្រូវមុនគេជាមិនខាន ។ ពុទ្ធសាសនបណ្ឌិត្យ

សូមមើលចំណោទទី ២ នៅទំព័រ ១៣០

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរថ្នឹងឃ្នាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

(នៅឆមាសទី ២ ឆ្នាំ ១៩៦៣)

នៅឆមាសទី ២ នៃឆ្នាំ ១៩៦៣ គឺពីខែកក្កដា ដល់ខែធ្នូ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានប្រកាសបើកសម័យប្រឡងប្រជែងជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ៦ មុខ គឺ :

១- អំពីឆៀន ,

២- អំពីរង្វាស់រង្វាល់ ។

ដើម្បីប្រមូលយកឯកសារចាំង៉ាយពីមុខនេះ មកក្សាទុក ជាគោលជាវិភាគរបស់ជាតិ តទៅអនាគត ។

ក្នុងរយៈពេល ៦ ខែ ក្រោយពេលដែលបានប្រកាសហើយ ក្រុមជំនុំបានទទួលឯកសាររឿងចាំង ៦ មុខនេះ ៥៧ រឿង អំពីបេក្ខជនខ្លះ អំពីសមាជិកធ្វើយធ្វងរបស់ក្រុមជំនុំខ្លះ មានចំនួន ៣៥ រូប ចាំងបញ្ជាក់

ទាំងគ្រហស្ថ ដែលបានសរសេរមកជាក់ច្បាស់ គឺ :

១- លោក ឱន-សុផុន	១៩- លោក ខូវ-សុខ
២- " ស៊ៅ-ឡាប	២០- " មាស-សោម
៣- " គង់-សុខ	២១- " កែវ-វ៉ែន
៤- " ភ័ណ់-គូ	២២- " អ៊ុន-មៅ
៥- " ឆួង-អ៊ូប	២៣- " សុះ-ខូវ
៦- " សាំង-ឡុង	២៤- " គៀត-តី
៧- " ឈិន-យឹម	២៥- " សុខ-ព្រំ
៨- " កែវ-កុល	២៦- " ង៉ែត-ហ៊ុន
៩- " ខេត-រស់	២៧- " រៀម-យឹម
១០- " កង-កែម	២៨- តំកូ ឡុង-ស៊ីសុយ៉ាត់
១១- " ជោក-ថេង	២៩- " តេជ្រ-ស៊ីមន
១២- " គឹម-ម៉ាន	៣០- " ជាប-ប៊ុន
១៣- " កែវ-ហាង្ស	៣១- " កែវ-ថៃ
១៤- " សេង-គឹមសិង់	៣២- " កែ ប៊ិន
១៥- " ក្រាក់-ខាត់	៣៣- " ខួន-ឈន
១៦- " ម៉ក់-ប៉េង	៣៤- " ជ៉ា-ហោង
១៧- " ណុប-ភាង	៣៥- " ទិត្យ-សុខ
១៨- " អ៊ុយ-សុយ	

ក្រុមដំនុំបានជួបជុំពិនិត្យឯកសារប្រឡងទាំងនោះ ដោយហ្មត់ចត់ទៅ
ក៏បានសម្រេចលទ្ធផលពិតប្រាកដដូចតទៅនេះ :

ក- ផ្នែកវៀងទៀង :

លោក អ៊ុយ-ស៊ុយ នៅឃុំមេត្រឹង ស្រុកដើនវៃ ខេត្តកំពង់ចាម
បានជាប់លេខ ៣ ត្រូវបានវង្វាន់ ៦០០រ០០ ។

តឹក្ខ ឡុង-ស៊ីសុយាត់ លេខាធិការអនុគណ ស្រុកកំចាយមារ តង់
នៅវត្តស្នោង ខេត្តព្រៃវែង បានជាប់លេខ ៤ ត្រូវបានវង្វាន់ ៤០០រ០០ ។

ខ- ផ្នែកវៀងវង្វាស់វង្វាល់ :

លោក កង-កែម នៅឃុំកំពង់ហ្លួង ស្រុកតញ្ជាឮ ខេត្តតណ្តាល
បានជាប់លេខ ២ ត្រូវបានវង្វាន់ ៨០០រ០០ ។

លោក សាង-ឡុង គ្រូបង្រៀននៅសាលាព្រជ្រាំង ឃុំតានកេង
ស្រុកកំចាយមារ ខេត្តព្រៃវែង បានជាប់លេខ ៣ ត្រូវបានវង្វាន់ ៦០០រ០០ ។

លោក ឌួង-អ៊ូច អតីតមេឃុំ ។ អង្គាញ់ ស្រុកព្រៃកប្បាស ខេត្ត
តាកែវ បានជាប់លេខ ៤ ត្រូវបានវង្វាន់ ៤០០រ០០ ។

នៅធម្មាសនៈ ២ ជាមួយគ្នានេះ ក្រៅអំពីការប្រឡង ក្រុមដំនុំចង់
បានជាបន្ទាន់ នូវឯកសារស្តីពីវប្បធម៌ប្រពៃណីរបស់ជាតិ ដូចជារបាំយីកេ
ភាំស្នែងខ្សាច់-ភ្នំកន្ទែរជាដើម ហើយបានសួរដោយផ្ទាល់ ចំពោះអ្នក
ចេះដឹងទាំងឡាយ ជាសមាជិកធ្លាយឆ្លងខ្លះ មិនមែនជាសមាជិកធ្លាយឆ្លង

ខ្ញុំ ទាំងបញ្ជាដែតទាំងត្រហស្ត ឲ្យសរសេរឱ្យការណ៍មកក្រុមដំខ្ញុំ ។

សំខ្ជួរនេះ ក៏ជាឧសម្រេចលទ្ធផលយ៉ាងតាប់ប្រសើរ គឺក្រុមដំខ្ញុំ ជាឧខ្ជួលឯកសារស្តីពីរជុំចំនួន ១០ រឿង អំពីអស់លោកចំនួន ១០ រូបគឺ :

១- លោក ម៉ក់-ថេង	:	៦- កិក្ខុ	ម៉ី-សាន
២- " កែវ-កុល	:	៧- "	ជាប-ច័ន្ទ
៣- " រៀម-យឹម	:	៨- លោក	ជឹម-ឈុំ
៤- " កែវ-ហង្ស	:	៩- "	កែវ-ម៉ុញ
៥- " ខេត-វស់	:	១០- "	កួយ-យក់ហួ


រង្វាន់ដែលត្រូវជាឧដល់បេក្ខជន ដល់សមាជិកធ្វើយធ្ងន ឧីឯក្រៅអំពីសមាជិកទាំងនោះ ក្រុមដំខ្ញុំជាឧចែកជូនតាមថ្នាក់រង្វាន់ប្រឡង-រង្វាន់សមាជិក-ឧីឯអ្នកធ្វើអំណោយហើយ ។

ក្រុមដំខ្ញុំមានសេចក្តីត្រេកអរក្រៃពេក ចំពោះអស់លោក-អ្នកជាបេក្ខជន ជាសមាជិកធ្វើយធ្ងន ឧីឯក្រៅពីសមាជិកដូចជាឧកយតាមខាងលើនេះ ដែលជាឧយល់ឮវិឧ្ឋមប្រយោជន៍នៃការស្រាវជ្រាវ ឧីឯការរក្សាពុកនូវអារ្យធម៌របស់ជាតិ ហើយជាឧសរសេរឯកសារស្តីអំពីខ្មែរ អំពីរង្វាស់រង្វាល់ ឧីឯអំពីរចាំប្រពៃណីរបស់ជាតិ ទៅជាក់ប្រឡង ទៅធ្វើអំណោយដល់ក្រុមដំខ្ញុំ ។ សូមប្រកាសជាឧឮៗកែនខ្ជួលអំណរគុណរបស់លោក-អ្នកទាំងនេះជាកិយ្យាកាត ហើយនៅធមាសទី ១ ឆ្នាំ ១៩៦៤ នេះ

ក្រុមដំនុំបានបើកសម័យប្រឡងជាថ្មីទៀតស្តីអំពី «កូមីខ្មែរ» ។ ប្រកាសប្រឡងនេះបានចែកផ្សាយខួងទៅហើយ បើអស់លោកអ្នកបានជ្រាបហើយត្រូវការប្រឡងសូមសរសេរតែងទៅឲ្យក្រុមដំនុំ ក្រុមដំនុំនឹងពិនិត្យ ហើយជូនវិញ្ញាន់តទៅទៀត ។

ក្រុមដំនុំសូមខចួលអំណរគុណនិងសង្ឃឹមខុកជាមុន ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ



ព្រះវិហារវត្តប្រាង្គ (ខណ្ឌ) ទើបនឹងកសាងថ្មីឡើងវិញ ហើយបញ្ចុះសីមាថ្មីង កាលពីថ្ងៃទី ១៩ កុម្ភៈ ១៩៦៤
ក្រោមព្រះអធិបតីភាពជំទាំងខ្ពស់នៃសម្តេចឪ ។

ប្រវត្តិនៃវត្តប្រាង្គ

រៀបរៀងដោយ ព្រះគោធិវង្ស ហ្សត-តាត
អគ្គាធិការនៃពុទ្ធិកសិក្សា

ហេតុដូចម្តេចបានជាគេហៅថា វត្តច្រាង្គ ? បានជាហៅថាវត្តប្រាង្គ ព្រោះនៅកន្លែងនេះមានព្រះប្រាង្គ ១ មានចំហាំដ៏ធំ ជាបូជនីយវត្ថុដ៏ប្រសើរដែលគេបានកសាងពុតមកជាយូរអង្វែងច្រើនសតវត្សរ៍ហើយ ។ រីឯវត្តនេះ គេបានកសាង ក្នុងពេលជាមានក្រោយនៃព្រះប្រាង្គនោះ ទើបគេយកព្រះប្រាង្គនោះជាឈ្មោះវត្ត ហៅថា វត្តព្រះច្រាង្គ ដូចគាល គេហៅថា វត្តពុទ្ធច្រាង្គ ព្រោះព្រះប្រាង្គនោះ គេតំកល់ព្រះបរមសារីរិកធាតុនៃព្រះពុទ្ធជាម្ចាស់ លុះតមក ដល់បច្ចុប្បន្នកាលនេះ គេហៅថា វត្តច្រាង្គ ។ តាមនាមនៃព្រះភូមិប្រាង្គនុ៎ះឯង ។

វត្តប្រាង្គសព្វថ្ងៃនេះ បិតនៅកន្លែងឃុំកំពង់ចាស់ ស្រុកទង្គុន ខេត្តកំពង់ស្ពឺ ។ បើធ្វើដំណើរតាមក្រុងកំពត ត្រូវទៅតាមផ្លូវជាតិលេខ ៣ ហួស-បាត់ដំបង ចម្ងាយ ៣៩ គីឡូម៉ែត្រ ។

កាលព្រះមហាក្សត្រតង់នៅរាជធានីទង្គុនមានជ័យនៅឡើយ វត្តប្រាង្គជាវត្តធំស្កុកស្កម្មណាស់ ទីដីវត្តមានទំហំធំទូលាយ ភាគខាងត្បូងមានព្រំប្រទល់ទឹកតែងព្រះបរមរាជវាំងស្រះសារពើយុត្ត ភាគខាងជើង

មានត្រំប្រទល់ទឹងផ្សារទុដង្គ ខាងកើតមានត្រំប្រទល់ទឹងស្រះកែវ ខាងលិចមានត្រំប្រទល់ទឹងស្ថាមក្លោះ ។ វត្តច្រាង្គកង់សម័យនោះ មានសភាពរុងរឿងណាស់ ដោយសម្តេចព្រះមហាសង្ឃរាជ ព្រះនាម ធៀង (សុវណ្ណោ កោសរ:) ទ្រង់គង់នៅជាប្រមុខសង្ឃកង់ទីវត្តច្រាង្គនោះ ទាំងព្រះពាជាគណៈហានានុក្រម កំគង់រួមនៅក្នុងទីវត្តនោះដែរ ។ វត្តច្រាង្គនោះ កាលក្នុងរជ្ជកាលនៃព្រះចុងសម្តេចព្រះហរីរក្សាពម ជាវត្តសម្បូណ៌ដោយគម្ពីរជើកា និងក្បួនច្បាប់ខាងព្រះពុទ្ធសាសនា ទាំងចាស់ទាំងសម្រាយដ៏ច្រើន ជាវត្តដែលចានបណ្តុះពូជនៃពួកព្រះសង្ឃជាបណ្ឌិតមានចំនួនច្រើន ជាវត្តព្រះពាជទ្រព្យដូចជាវត្តទុណ្ណាលោម នៅក្រុងភ្នំពេញសព្វថ្ងៃនេះដែរ ។ លុះតមក ក្រោយពេលដែលព្រះករុណាព្រះចុងសម្តេចព្រះនរោត្តមទ្រង់ស្តេចចេញចាកពាជធានីទុដង្គមានជ័យ មកគង់នៅពាជធានីភ្នំពេញ ក្នុងឆ្នាំឆ្លូវសប្តស័ក ព.ស. ២៤០៩ គ.ស.១៨៦៥ សម្តេចព្រះមហាសង្ឃរាជព្រះនាម ធៀង មួយអន្ទើរជាមួយព្រះពាជាគណៈហានានុក្រម ក៏ចេញចាកវត្តច្រាង្គមកគង់នៅវត្តទុណ្ណាលោម ក្រុងភ្នំពេញក្នុងពេលនោះ សម្តេចព្រះមហាសង្ឃរាជ ទ្រង់ចានាំយកមកជាមួយព្រះអង្គ នូវគម្ពីរជើកាក្បួនច្បាប់ជាច្រើន អំពីវត្តច្រាង្គ មកតំកល់ទុកនៅវត្តទុណ្ណាលោម មិនតែប៉ុណ្ណោះ ព្រះពាជាគណៈធំ-តូចទាំងឡាយ ដែលនិមន្តដង្ហែសម្តេចព្រះមហាសង្ឃរាជមកគង់ឯក្រុងភ្នំពេញ ក៏សុទ្ធសឹងតែចានាំ

យកខ្លួនតែម្តងដើរតាមផ្លូវ ។ ជាប់ជាមួយមកផង ម្ល៉ោះហើយ នៅទីវត្តច្រាំង
មានសេសសល់តម្លើងកាន់ច្បាប់ខ្លះបន្តិចបន្តួច ។ សភាពរឿងក៏
ថយចុះដោយលំដាប់ ប៉ុន្តែមិនមែនថយដល់ថ្នាក់ធ្លាក់រូបភាពដើមឡើយ
ដោយមានព្រះសង្ឃជាពជាតណៈ ដែលជាបណ្ឌិតគង់នៅជាបៅអធិការតមក មានលោកគ្រូព្រះធម្មឃោសាចារ្យព្រះនាម មាស ជាដើម លោក
ទំរឹងប្រែងរបត្តម្តងបន្តិចបន្តួចឲ្យនៅមានសេចក្តីចំរើនតាមរឿងជាលំដាប់ត ។
មក មិនឲ្យធុត មិនឲ្យជាប់ ។

ចុះវត្តច្រាំង គេកសាងតាំងពុទ្ធសករាជប៉ុន្មាន ? អ្នកណាជាអ្នក
ផ្តើម កសាងដំបូង ។

បញ្ហានេះ ឥតមានឯកសារអ្វីទាំងបញ្ជាក់ឲ្យដឹងច្បាស់លាស់ថាវត្ត
ច្រាំង គេកសាងតាំងពីកាលណាឡើយ ទាំងអ្នកផ្តើមកសាងដំបូង ក៏ឥត
មានចារឹកអ្វីបញ្ជាក់ឲ្យដឹងច្បាស់ដែរ ។ តាមព្រះរាជពង្សាវតារប្រទេស
កម្ពុជា ចាន់ឲ្យតែមានមួយអន្លើថា នៅឆ្នាំរកាឯកស័ក ព.ស. ២៣៩៣
គ.ស. ១៨៤៩ ព្រះចៅទ្រង់ព្រះហរិរក្សរាមា (ព្រះអង្គដួង) ទ្រង់មាន
ព្រះបញ្ជាឲ្យកសាងវិហារវត្តពុទ្ធច្រាំងសព្វថ្ងៃនេះ សេចក្តីនេះគ្រាន់តែ
បញ្ជាក់ចំពោះការកសាងវិហារជាមួយចាស់ថាតាវតែប៉ុណ្ណោះ មិនមែន
បញ្ជាក់ពីការកសាងវត្តចាំងមូលឡើយ ។ តាមការសង្កេតនិងការពិនិត្យ
ម៉ាលដោយល្អិតល្អន់ទៅ ឃើញថា ដែលព្រះចៅទ្រង់ព្រះហរិរក្សរាមា

ទ្រង់មានព្រះបញ្ជាឲ្យកសាងវិហារនោះ មិនមែនកសាងជាដំបូងបំផុតឡើយ តែរុះរើវិហារចាស់ដែលមានមកយូរយារណាស់ហើយ។ កសាងពង្រីកឲ្យខ្ពស់ឡើងធំឡើងតែប៉ុណ្ណោះ ព្រោះបានដឹកដីត្រង់កន្លែងវិហារយើញមានជណ្តើរឥដ្ឋខ្លះ ជញ្ជាំងឥដ្ឋខ្លះ កប់នៅក្នុងដី នាំឲ្យសន្និដ្ឋានបានយ៉ាងជាក់ច្បាស់ថា មានវិហារចាស់ពីបុរាណនៅត្រង់កន្លែងវិហារដែលព្រះបាទសម្តេចព្រះហរិរក្សរាម ទ្រង់មានព្រះបញ្ជាឲ្យកសាងនោះ។

សេចក្តីខាងលើនេះ អាចនាំឲ្យសន្និដ្ឋានបានថា វត្តប្រាង្គជាវត្តចាស់បុរាណយូរអង្វែងហើយ។

ម្យ៉ាងទៀត តាមការសង្កេតមើលទីធរណីវត្តជាំងមូល និងកន្លែងស្ថាបនាវិហារដែលជាគោលចារឹករបស់វត្ត អាចឲ្យយល់បានថែមទៀតថាវត្តប្រាង្គប្រាកដជាគេកសាងយូរអង្វែងហើយ តាំងពីមុនពេលដែលព្រះបាទសម្តេចព្រះហរិរក្សរាម ទ្រង់មានព្រះបញ្ជាឲ្យស្ថាបនាព្រះបរមកដជាំងស្រះសារតើយុគនោះទៅទៀត ដោយមានគ្រឿងសង្កេតដូចតទៅនេះ ៖

๑- ទីដីវត្តភាគខាងត្បូង មានព្រំប្រទល់ជាប់នឹងកំពែងព្រះបរមកដជាំង ស្រះសារតើយុគ។

๒- វិហារបែរទៅជិតព្រះបរមកដជាំង គិតពីកំពែងវិហារទៅទល់នឹងកំពែងព្រះបរមកដជាំង ប្រមាណជា ๒๐ ម៉ែត្រប៉ុណ្ណោះ។

គ្រឿងសង្កេតជាំងពីរយ៉ាងខាងលើនេះ បើគិតតាមពាណាទៅ គង់

យើញដោយឥតសង្ស័យថា ប្រសិនបើព្រះពជ្រពំនឹកើតមុនវត្ត ទីដីវត្តមុខ ជាពុំគាចនៅជាប់គ្នានឹងព្រះពជ្រពំនបានទេ ពាំនឹវិហារខឿតសោត ក៏ពុំត្រូវអនុញ្ញាតឲ្យកសាងនៅក្បែរព្រះពជ្រពំនដែរ ។ តាមការសង្កេតដោយល្អិតល្អៅ យើញថា កាលមុនកសាងព្រះពជ្រពំន ទីធរណីវត្តប្រាង្គធំខ្ពស់ជាយៅភាគខាងត្បូង កន្លែងវិហារប្រែហាលជានៅចំភាគកណ្តាលវត្ត ព្រោះតាមធម្មតា គារកសាងវត្តនីមួយ ។ តែតែងតែកសាងវិហារនៅចំភាគកណ្តាល ប៉ុន្តែលុះដល់ពេលដែលកសាងព្រះពជ្រពំនស្រះសារតើយុត្តជាខាងក្រោយ នៅទីដីភាគខាងត្បូងវត្តប្រាង្គ ក៏កាត់យកទីធរណីវត្ត ១ ភាគ ៣ ចានជាកន្លែងវិហារបិតនៅកៀកជិតនឹងព្រះពជ្រពំន ។

ម្យ៉ាងទៀត បើសង្កេតមើលតាមព្រះពជ្រពង្សាវតារប្រទេសកម្ពុជា យើញសេចក្តីកាន់តែច្បាស់លាស់ថែមទៀតថា ព្រះបាទសម្តេចព្រះហរិរក្សព្រមា ទ្រង់សោយរាជសម្បត្តិកន្លង ព.ស. ២៣៩១ គ.ស. ១៨៤៧ ដល់ ព.ស. ២៣៩៣ គ.ស. ១៨៤៩ ទ្រង់មានព្រះរាជបញ្ជាឲ្យកសាងវិហារវត្តប្រាង្គ លុះដល់ឆ្នាំខាលឆស័ក ព.ស. ២៣៩៨ គ.ស. ១៨៥៤ ទើបទ្រង់មានព្រះរាជបញ្ជាឲ្យកសាងព្រះបរមរាជពជ្រពំនស្រះសារតើយុត្ត នៅទីដីខាងកើតឆៀងអគ្នេយ៍នៃព្រះពជ្រពំនចាស់ ។ បើគិតតាមកាលវិភាគខាងលើនេះ ពាំយើញច្បាស់ថា កសាងវិហារវត្តប្រាង្គមុនកសាងព្រះពជ្រពំនស្រះសារតើយុត្ត ៥ ឆ្នាំ បើគិតពីពេលដែលកសាងព្រះពជ្រពំននៅ

គ.ស. ១៨៩៤ មកដល់ គ ស· ១៨៦៣ នេះ ទើបទទឹងបាន ១០៩ ឆ្នាំ ប៉ុណ្ណោះ ។ តាមការពិនិត្យពិចារណាដូចខាងលើនេះ ឃើញច្បាស់ថាវត្ត ច្រាង្គគេកសាងមុនព្រះបរមពជរ៉ាំងស្រះសារតើយុត្ត យូរវែងឆ្ងាយណាស់ ។

សេចក្តីបំរើនរុងរឿងនៃវត្តច្រាង្គពីអតីតកាល

វត្តច្រាង្គ តាមការពិនិត្យមើលដោយសព្វគ្រប់ៗ ឃើញថាកើតមានឡើងយូរអង្វែងហើយ ប៉ុន្តែក្នុងរជ្ជកាលនៃព្រះមហាក្សត្រមុន ។ វត្តច្រាង្គពុំច្រកជជាមានសេចក្តីចំរើនរុងរឿងយ៉ាងណា ។ ឡើយ ដោយពុំមានឯកសារអ្វីនឹងបញ្ជាក់ឲ្យច្បាស់លាស់ ។ ទើបតែក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះហរីរក្សកមា (ព្រះអង្គដួង) ឃើញថាវត្តនេះមានសេចក្តីចំរើនរុងរឿងមានកិត្តិនាមដ៏ប្រសើរ ដោយមានឥតិមានបញ្ជាក់ឲ្យដឹងក្នុងព្រះរាជក្សារតារប្រទេសកម្ពុជាថា ៖

១- សម្តេចព្រះសង្ឃរាជ ព្រះនាម ទៀង ទ្រង់ជាប្រមុខសង្ឃនៅក្នុងព្រះរាជអាណាចក្រកម្ពុជា ទ្រង់គង់នៅវត្តច្រាង្គ ហើយទ្រង់ជាចៅអធិការនៃវត្តច្រាង្គផង ។

២- ព្រះរាជាគណៈមហានិកាយ ជាអ្នកច្រាជូនខាងព្រះពុទ្ធសាសនាក៏គង់នៅក្នុងវត្តច្រាង្គនោះដោយច្រើន ។

៣- ព្រះករុណាព្រះបាទសម្តេចព្រះហរីរក្សកមា ទ្រង់ចំបួសព្រះ

ពាជទ្រសេតីវព្រះអង្គតី ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ កាលទ្រង់នៅជាព្រះ
ពាជកុមារនៅឡើយ ឲ្យចូលកាន់បព្វជ្ជា ជាសាមណេរក្នុងសំណាក់លោកគ្រូ
ព្រះមហាព្រហ្មមុនី (មា) នៅក្នុងវត្តប្រាង្គ ខណៈព្រះអង្គម្ចាស់ស៊ីវត្ថា កាល
ដែលទ្រង់នៅជាព្រះពាជកុមារឲ្យចូលកាន់បព្វជ្ជា ជាសាមណេរក្នុងសំណាក់
សម្តេចព្រះមហាសង្ឃរាជ ខៀង កាលទ្រង់ថតនៅកន្លែងតំណែងជាព្រះ
មហាវិមលធម្ម ក្នុងវត្តប្រាង្គជាមួយគ្នា ។

៤- ព្រះបាទសម្តេចព្រះហរិរក្សរាមា ទ្រង់បានទុកវត្តប្រាង្គជាវត្ត
ព្រះពាជទ្រព្យ ទ្រង់ជួយទបត្ថម្ភវត្តប្រាង្គឲ្យបានថ្កុំថ្កើងរុងរឿងមានការ
គោរពរាប់អានជាដើម រហូតដល់ផុតរជ្ជកាលរបស់ព្រះអង្គ (គ.ស-១៨៤៧-
១៨៦០ ។

(នៅមានត)

មនុស្សស្រីឆ៊ីស្រា មនុស្សឆ្កួត មនុស្ស
កាចកំពោល មនុស្សអស់កម្លាំង មនុស្ស
អត់ឃ្លាន មនុស្សល្មោភ មនុស្សខ្វាច
មនុស្សរហ័សក្តៅ ឧដ៏មនុស្សបរិភោគ
កាម មនុស្សពាំងអស់នេះ មិនបេះដមិនខ ។

ហិរោបទេស

អំពីព្រះគ្រូឥតជីព្រះគុណ

ដែលបានទទួលសញ្ញាប័ត្រចាត់តាំង

ជាចៅអធិការនៃគ្រូសូត្រក្នុងវត្តនានា

ក្នុងព្រះរាជអាណាចក្រ

(ក)

១២- ព្រះតេជព្រះគុណ សុក-អួន នាមឆាយាពុទ្ធបញ្ញា អាយុ ៧៦ ឆ្នាំ វស្សា ៣២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តពោធិភមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣.៤០៧ ចុះថ្ងៃទី ១៨-៤-៦២ ។

១៣- ព្រះតេជគុណ ឃាន-ឃី នាមឆាយាធម្មសរកើតពី គ.ស. ១៨៦២ អាយុ ៤០ ឆ្នាំ វស្សា ២០ បានទទួលតែងតាំងជាគ្រូសូត្រធ្វើក្នុងវត្តពោធិភមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣.៤០៨ ចុះថ្ងៃទី ១៨-៤-៦២ ។

១៤- ព្រះតេជព្រះគុណ គុប-ជាន់ នាមឆាយាសទ្ធម្មចៅតិប្បរោ កើតឆ្នាំមមែ អាយុ ៤៤ ឆ្នាំ វស្សា ២៣ បានទទួលតែងតាំងជាចៅអធិការវត្តប្រាសាទ ឃុំដូង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣.៤០៩ ចុះថ្ងៃ ១០-១០-៦២ ។

១៥- ព្រះតេជព្រះគុណ ខូច-សុខ នាមឆាយាកន្តធម្មោ កើត

ឆ្នាំថោះ អាយុ ៦០ ឆ្នាំ វស្សា ៨ ជាខេត្តលែងតាំងជាគ្រូសូត្រស្តាំ ក្នុង
វត្តប្រាសាទ ឃុំដូង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣.៤១០
ចុះថ្ងៃទី ១០-១០-៦២ ។

១៦- ព្រះតេជព្រះគុណ ប៉ែន-ឡាញ់ នាមឆាយាអរុណវតី កើតឆ្នាំ
មមី អាយុ ២១ ឆ្នាំ វស្សា ១ ជាខេត្តលែងតាំងជាគ្រូសូត្រធ្វេង ក្នុង
វត្តប្រាសាទ ឃុំដូង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣៤១១
ចុះថ្ងៃទី ១០-១០-៦២ ។

១៧- ព្រះតេជព្រះគុណ សេវ-តាំង នាមឆាយាមង្គលជោតិ
កើតពីគ.ស. ១៨២៦ អាយុ ៣៦ ឆ្នាំ វស្សា ១៦ ជាខេត្តលែងតាំង
ជាចៅអធិការក្នុងវត្តតាកំង ឃុំពប ស្រុកតាកំង ខេត្តព្រៃវែង លេខសញ្ញា-
បត្រ ៣៤១៤ ចុះថ្ងៃទី ១៤.១៤-៦២ ។

១៨- ព្រះតេជព្រះគុណ ឃី-ស៊ីមលាង នាមឆាយាខន្ធជោតិ កើត
ពីគ.ស. ១៨៤៧ អាយុ ៦៥ ឆ្នាំ វស្សា ៤៥ ជាខេត្តលែងតាំងជាចៅ
អធិការក្នុងវត្តសំប៉ាន ឃុំ ស្រុក កោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ
៣៤១៣ ចុះថ្ងៃទី ២៤-១០-៦២ ។

១៩- ព្រះតេជព្រះគុណ ញ៉ិល-ជីវ នាមឆាយាតេជវុឌ្ឍកើតឆ្នាំមមែ
អាយុ ៣៤ ឆ្នាំ វស្សា ១៣ ជាខេត្តលែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តសំ-
ប៉ាន ឃុំ ស្រុក កោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៤ ចុះថ្ងៃទី

២២-១០-៦២ ។

២០- ព្រះតេជព្រះគុណ ខឹម-ដុល នាមឆាយាបញ្ញាបរិយោ កើតពី គ.ស ១៩៣៤ អាយុ ២៨ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រធ្វើកិច្ចក្នុងវត្តសំបាន ឃុំ ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៥ ចុះថ្ងៃទី ២២-១០-៦២ ។

២១- ព្រះតេជព្រះគុណ ពាន់-ស្វាយ នាមឆាយានន្ទត្ថេរោ កើតឆ្នាំមមី អាយុ ៦៩ ឆ្នាំ វស្សា ៤៤ បានទទួលតែងតាំងជាចៅអធិការកិច្ចក្នុងវត្តតាំងរនាម ឃុំប្រទះឡាង ស្រុកកំពង់ត្រាច ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៦ ចុះថ្ងៃទី ២២-១០-៦២ ។

២២- ព្រះតេជព្រះគុណ ឡេង-អ៊ុច នាមឆាយាអគគធម្មោ កើតឆ្នាំរកា អាយុ ៣០ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការកិច្ចក្នុងវត្តព្រៃស្តីឃុំចោមចៅ ស្រុកកំពង់ត្រាច ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៧ ចុះថ្ងៃទី ២២-១០-៦២ ។

២៣- ព្រះតេជព្រះគុណ កែ-ស៊ុន នាមឆាយាសុវណ្ណបញ្ញា កើតឆ្នាំម្សាញ់ អាយុ ៣៤ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការកិច្ចក្នុងវត្តជ្រុំត្រៀល ឃុំក្បាលរមាស ស្រុក ខេត្តកំពត លេខសញ្ញាបត្រ ៣៤១៨ ចុះថ្ងៃទី ២៨-១០-៦២ ។

២៤- ព្រះតេជព្រះគុណ វ៉ែន-សួន នាមឆាយាចន្ទប្បជ្ជោតោ

កើតឆ្នាំមមី អាយុ ៤៥ ឆ្នាំ វស្សា ២៥ ជានិមួយតែងតាំងជាចៅអធិការ
កន្លែងវត្តពួនកំថ្ម ឃុំត្រពាំងសាប ស្រុកជាអី ខេត្តតាកែវ លេខសញ្ញាបត្រ
៣៤១៩ ចុះថ្ងៃទី ២២-១១-៦២ ។

ព្រះតេជព្រះគុណ អ៊ុង-សារឿន នាមឆាយា ឧត្តរប្បញ្ញោ កើតពី
គ.ស ១៩៣១ អាយុ ៣១ ឆ្នាំ វស្សា ៦ ជានិមួយតែងតាំងជាគ្រូសូត្រស្តាំ
ក្នុងវត្តពួនកំថ្ម ឃុំត្រពាំងសាប ស្រុកជាអី ខេត្តតាកែវ លេខសញ្ញាបត្រ
៣៤២០ ចុះថ្ងៃទី ២២-១១-៦២ ។

២៦- ព្រះតេជព្រះគុណ ឌី-ប៊ុនឌុ នាមឆាយាញាណគុត្តោ កើត
ឆ្នាំមមែ អាយុ ៣២ ឆ្នាំ វស្សា ១២ ជានិមួយតែងតាំងជាចៅអធិការកន្លែងវត្ត
សៀមម្កុំខ្ពុំ ឃុំកំពុន ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង លេខសញ្ញាបត្រ
៣៥១៨ ចុះថ្ងៃទី ១២-៦-៦៣ ។

២៧- ព្រះតេជព្រះគុណ ឌី-ស៊ុ នាមឆាយាបញ្ញាវង្សោ កើត
ឆ្នាំពេង អាយុ ៣៥ ឆ្នាំ វស្សា ១៥ ជានិមួយតែងតាំងជាចៅអធិការកន្លែងវត្ត
បរមជាសុក ឃុំកំពុន ស្រុកខេត្តជជែល លេខសញ្ញាបត្រ ៣៥២០ ចុះថ្ងៃ
ទី ១២-៦-៦៣ ។

២៨-ព្រះតេជព្រះគុណ ស៊ុត.ង៉ាម នាមឆាយាចិត្តហង្សោ កើត
ឆ្នាំ ច អាយុ ៤១ ឆ្នាំ វស្សា ២១ ជានិមួយតែងតាំងជាចៅអធិការកន្លែងវត្តផ្ទះ
ស៊ីកែវ ឃុំ ស្រុក ខេត្ត ស្ទឹងត្រែង លេខសញ្ញាបត្រ ៣៥២១ ចុះថ្ងៃទី

១២.៦.៦៣ ។

២៩- ព្រះតេជព្រះគុណ ង្ហួន-ម៉ា នាមឆាយាដៅតង្គ្រៃ កើតឆ្នាំជូត អាយុ ៥៣ ឆ្នាំ វស្សា ២៩ បានទទួលតែងតាំងជាចៅអធិការកុដិវត្តកោនសាំង ឃុំកោះសម្ពាយ ស្រុក ខេត្តជវែល លេខសញ្ញាបត្រ ៣៥២២ ចុះថ្ងៃទី ១២-៦-៦៣ ។

៣០- ព្រះតេជព្រះគុណ ផែង-ហួត នាមឆាយាឥន្ទប្បញ្ញា កើតពីឆ.ស. ១៩១២ អាយុ ៥១ ឆ្នាំ វស្សា ២៨ បានទទួលតែងតាំងជាចៅអធិការកុដិវត្តប្រជានន ឃុំឆក់ឈើនាង ស្រុកកំពង់ត្រាច ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៥២៣ ចុះថ្ងៃទី ២៥-៦-៦៣ ។

៣១- ព្រះតេជព្រះគុណ ណុប-សួង នាមឆាយាឥន្ទប្បញ្ញា កើតពីឆ ស. ១៩០៨ អាយុ ៥៥ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្តស្រុក ខេត្តជវែល លេខសញ្ញាបត្រ ៣៥២៤ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣២- ព្រះតេជព្រះគុណ ចៀម-ពុំ នាមឆាយាឥតប្បញ្ញា កើតពីឆ.ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្តជវែល លេខសញ្ញាបត្រ ៣៥២៥ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៣- ព្រះតេជព្រះគុណ អឿ-សំអាន នាមឆាយាឥន្ទត្ថេរ កើត

ឆ្នាំច អាយុ ៤១ ឆ្នាំ វស្សា ២០ ជានខេត្តលែងតាំងជាចៅអធិការកុដិវត្ត គោកបន្ទាន់ ឃុំចោមចៅ ស្រុក ខេត្តជជែល លេខសញ្ញាបត្រ ៣៥២៦ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៤- ព្រះតេជព្រះគុណ លុយ ខុន នាមឆាយាជម្មវរៃ កើត ព.ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ៥ ជានខេត្តលែងតាំងជាគ្រូសូត្រស្តាំកុដិវត្តឃុំស្រុក ខេត្តជជែល លេខសញ្ញាបត្រ ៣៥២៧ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៥- ព្រះតេជព្រះគុណ អ៊ូ សម នាមឆាយាចន្ទត្តេរ កើតព.ស. ១៩០៣ អាយុ ៦១ ឆ្នាំ វស្សា ៣៣ ជានខេត្តលែងតាំងជាចៅអធិការ កុដិវត្តពលសណ្តែក ឃុំគោរះ ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៥២៨ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៦- ព្រះតេជព្រះគុណ ចិន.សុខ នាមឆាយាសុវណ្ណជោតិ កើតព.ស. ១៩០៨ អាយុ ៥៥ ឆ្នាំ វស្សា ៣៣ ជានខេត្តលែងតាំងជាគ្រូសូត្រស្តាំកុដិវត្ត ឃុំ ស្រុក ខេត្តជជែល លេខសញ្ញាបត្រ ៣៥២៩ ចុះថ្ងៃទី ២៥.៦.៦៣ ។

(នៅមានត)

ដំណឹងអំពីពុទ្ធសាសនបណ្ឌិត្យ

ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងដល់សាធារណជនថា សៀវភៅប្រជុំរឿងព្រេងខ្មែរ «ភាគ ៥» បានបោះពុម្ពចេញផ្សាយហើយ ។ សៀវភៅនេះ ក្រុមដ៏ខ្ពុំខ្ពំទៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវជ្រើសរើសយកឯកសាររឿងព្រេង ដែលទាក់ទងដោយប្រវត្តិសាស្ត្រ ទំនៀមសាស្ត្រ នៃប្រទេសកម្ពុជា ហើយដែលជារឿងនៅមានអាថ៌កំបាំងចំពោះអ្នកសិក្សានៅឡើយ ដូចជារឿងប្រាសាទបុកណា-ទីក្រុងចាស់ ។ -កុំ- នឹងចឹងបួងជាច្រើន នៅកម្ពុជាណាចក្រយើង មានរឿងកុំបាយ៉ាំកោរ -កុំសំពៅ -កុំព្រះរាជទ្រព្យ -កុំប្រុសកុំស្រី – ក្រុងឧត្តុង្គ – ក្រុងកុំពេញ – ប្រាសាទតាព្រហ្ម – ប្រាសាទព្រហ្មតិល - ទឹងប្រាសាទខាងភ្នៀជាដើម ដែលសុទ្ធតែជារឿងព្រេងយ៉ាងល្បាស់ល្បាស់ មានអត្ថរស គួរជាទីចាប់អារម្មណ៍ ហើយជារឿងអាចផ្តល់នូវសារប្រយោជន៍ដល់អស់លោកអ្នកអានយ៉ាងវិសេសវិសាល ។

សៀវភៅប្រជុំរឿងព្រេងខ្មែរ «ភាគ ៥» បោះពុម្ពគ្រាជបួងនេះ មានចំនួនតិចណាស់ ដូច្នេះ សូមលោកអ្នក អញ្ជើញជាវដោយរួសរាន់ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ តម្លៃ ២៥រ០០ មួយក្បាល ។

ភគ្គជសុត្តិយា


ទស្សនាវដ្ដី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៦ លេខ ៣ ខែ មិនា

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ក្នុង ១៣ -



ភ្នំពេញសន្ទេយ៍

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

	ទំព័រ
ផ្នែកសាសនា	
- សប្បុរិសធម្មកថា តែងរៀបរៀងដោយ ភិក្ខុ អ៊ុង-សុខ វត្តពិភទ្ធរង្សី	២២៩
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ី តែងរៀបរៀង (ត)	២៤១
- អ្នកមានគុណ រៀបរៀងដោយលោក ហេង-សមអាន នៅសេនាធិការយោធភូមិភាគ ទី ១ ខេត្តកំពង់ចាម	២៤៩
- ព្រះវិន្ធរជាតក (ត)	២៦៥
ផ្នែកអក្សរសាស្ត្រ	
- ជម្ងឺ ម៉ក្រូ និងជម្ងឺវិទ្យុ (វិចារណកថា) លោក ផេង-ត្រែវ និពន្ធ	២៧៧
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ម៉ាង-ខាត់ រៀបរៀង (ត)	២៨៦
- រឿងអាថ៌សហ្គាស៊ូរ៉ាស់ លោក ភ័យ-ស្មុត ដំណាងភាស្ត្រ ប្រែរៀបរៀង	២៨៨
- ល្បែកប្បាហុងតែន លោក ផេង ត្រែវ ប្រែពីភាសាថាវ៉ាំង (ត)	២៩៦
- រឿងសាមកុក អ្នកឯកញ៉ារិបុលរាជសេនា ង្វ-កន ប្រែរៀបរៀង (ត)	៣០០
- ព្រះរាជនិពន្ធ រាឧស្តេ ស្រាវជ្រាវ ដោយលោក ឧ-គាម	៣០៧
- រឿងព្រេងនិទាន (បទពីរភ្លែងធ្វើជាស្តេច) លោក ភ័យ-ប៊ុក ប្រែពីភាសាថាវ៉ាំង (ត)	៣២០
- ទំនៀមទម្លាប់ខ្មែរ: ល្ខោនជាមោចឹយ	៣៤៤
ផ្នែកកំណត់និងប្រវត្តិការណ៍	
- ប្រវត្តិនៃវត្តប្រាង្គ រៀបរៀងដោយព្រះគេជព្រះគុណព្រះពោធិវង្ស ហ្គត-ភាគ អគ្គាធិការនៃពុទ្ធិកសិក្សា	៣៣៨
- បុណ្យបញ្ចុះសីមា និងធ្វងវិហារវត្តប្រាង្គ	៣៤៣
- រឿងតាំងលើអធិការ និងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ	៣៤៦

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ៤៣០រ៉ៀល

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការសមមក ឲ្យធ្វើល្អទៅ
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

សប្បុរិសធម្មកថា

រៀបរៀងដោយភិក្ខុ ម៉ឺង-សុ ១ វត្តពីកខ្លូវឡ្លី

ឥមោ តសរ្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

ពេលនេះ នឹងសំដែងអំពីសប្បុរស ព្រមទាំងធម៌របស់សប្បុរស ដោយសេចក្តីសង្ខេប តាមក្រសែនៃព្រះពុទ្ធដីកានឹងអដ្ឋកថា ដើម្បីជាសណ្តាប់នៃពុទ្ធបរិស័ទទាំងឡាយ ដូចមានសេចក្តីដែលត្រូវសំដែងតទៅ :

ពាក្យថា « អ្នកសប្បុរស » គឺបុគ្គលដែលប្រកបដោយធម៌សុចរិតត្រង់ត្រែងគឺ កាយ វាចា ចិត្ត ជាអ្នកយើញប្រយោជន៍ដ៏ធំទូលាយជាសាធារណៈដល់អ្នកដទៃ មិនយើញត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ យ៉ាងនេះជាដើម ហៅថា « អ្នកសប្បុរសយ៉ាងឧត្តុង្គ » ។

មួយទៀតមនុស្សអ្នកមានចិត្តល្អ មានការប្រព្រឹត្តរៀបរយត្រូវល្អចំពោះលោកអ្នកមានគុណ ចំពោះព្រះសង្ឃ គ្រហស្ថ ចាស់ទុំ ជាអ្នកមានសីលធម៌គួរជាទីជ្រះថ្លាដល់ក្នុងអ្នកផង គឺហៅថា «អ្នកសប្បុរស» ។

ពាក្យថា «សប្បុរស» នេះ មកអំពីបាលីថា «សន្ត:» មានអត្ថប្រែបាន ៦ យ៉ាងគឺ :

១- សន្ត: ប្រែថា «មាន មានគ្រប់គ្រាន់» ដូចបាលីថា : ខ្វេមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា ឧបលព្ភា លោកស្មឹ «ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ គេរកបានដោយក្រដៃលមានក្នុងលោក ។

២- សន្ត: ប្រែថា «មនុស្សល្អ» ដូចបាលីថា សន្តោ ហវេ សព្ភិ ភវេយ្យន្តិ ពួកមនុស្សល្អរមែងនិយាយនឹងមនុស្សល្អ» ។

៣- សន្ត: ប្រែថា «ហត់នឿយ» ដូចបាលីថា : ទីឃំ សន្តស្ស យោជនំ «យោជន៍វែងដល់បុគ្គលអ្នកនឿយហត់ ។

៤- សន្ត: ប្រែថា «រលត់» ដូចបាលីថា : អយញ្ចវិតក្កោ អយញ្ចវិចារោ សន្តា ហោន្តិ «វិតក្កនេះក្តី វិចារនេះក្តី ជាធម៌រលត់ហើយ» ។

៥- សន្ត: ប្រែថា «ល្អិតល្អន» ដូចបាលីថា អធិគតោ ខោ ម្យាយំ ធម្មោ សន្តោ បណីតោ «ធម៌នេះជាធម៌ល្អិតល្អនប្រសើរ ដែលតថាគតត្រាស់ដឹងហើយ ។

៦- សន្តៈ ថ្លែ «ស្ងប់រម្ងាប់ ប្រៀបរយ» ដូចជាលិថា : ទុបសន្ត
ស្ស សទា សតិមតោ «បុគ្គលអ្នកស្ងប់រម្ងាប់ ប្រៀបរយ មានស្មារតីគ្រប់
កាលទាំងពួង» ។

ពាក្យថា «អ្នកសប្បុរស» ក្នុងទីនេះ សំដៅយកមនុស្សល្អ ឬ
មនុស្សប្រពៃជា ដែលមានសីលធម៌ មានសណ្តាប់ធ្នាប់ដោយកាយវាចាចិត្ត
ជាសុចរិត អាចឲ្យអ្នកផងគួរសេពគប់ទុកចិត្តស្គាល់បាន ។ បុគ្គល
ប្លែកម្នាក់ឆ្ងាយនឹងគ្នាដោយកណាយកិច្ចផ្សេង ។ តាំងពីពីរនាក់ឡើងទៅ
ទោះបីជាតិជាមួយគ្នាក្តី ជាតិផ្សេងពីគ្នាក្តី គេហៅថា សហភាព ប្រែថា
«ការនៅរួមរបៀបជាពួកជាមួយគ្នា» ។ ពួកជនក្នុងសហភាពនោះ។ កាល
បើគ្មានមនុស្សសប្បុរស តែមនុស្សល្អហើយ ទោះបីប្រកបកិច្ចការអ្វីនឹ
មួយក៏មិនបានសម្រេចផលដោយល្អដែរ ច្រើនតែមានទុបស័គ្គស្អាក់ស្ទើរ
ដំណើរសេចក្តីចំរើនទៅវិញ ។ មែនពិត មនុស្សទាំងអស់ក្នុងលោក
ដែលមានកិច្ចការត្រូវធ្វើ សុទ្ធតែពាក់ព័ន្ធដោយពួកគណៈ បើមិនច្រើនក៏
តិច ព្រោះថាមនុស្សយើងនឹងនៅតាមចំនើងខ្លួនម្នាក់ឯងដោយមិនបាច់
ពឹងអាស្រ័យ នឹងអ្នកណាមួយនោះពុំបានឡើយ ។ តាមជម្មតា មនុស្ស
ក្នុងលោកនេះ តែងមានអជ្ឈាស្រ័យ មានគំនិតផ្សេងៗគ្នា គឺមនុស្សខ្លះមាន
អជ្ឈាស្រ័យល្អ គួរគប់រក គួរពាក់អាន មានចិត្តទូលាយផ្សាយប្រយោជន៍
ដល់ជាតិ សាសនា ចេស់ខ្លួន ដោយសុចរិតធម៌ស្មោះត្រង់ល្អប្រកបដោយ

មេត្តាករុណា ចំពោះបុគ្គលខ្លួនឯងមិនសើមមុខ មិនចំពោះតែត្រកូលគ្រួសារខ្លួនឡើយ បុគ្គលបែបនេះលោកហៅថា សប្បុរស ។ មនុស្សសប្បុរស គាលបើមានទៅក្នុងគណៈណា ក្នុងសមាគមណាឬក្នុងទីប្រជុំណា រមែងឲ្យសម្រេចផលល្អ ញុំាងប្រយោជន៍ឲ្យសម្រេចដោយសុវត្ថិភាពដល់គណៈនោះ ដល់សមាគមនោះ ដល់ទីប្រជុំនោះដោយពិតពុំខាន ។ ព្រោះហេតុនោះ ការសេពគប់ត្រូវជ្រើសរើសតាមនិត្យបុគ្គលដែលល្អ ដោយហ្មត់ចត់ទើបជាការល្អ ។ មនុស្សខ្លះមានអធ្យាស្រ័យគ្រោតគ្រាតអាក្រក់ គ្មានសុចរិតធម៌ គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តឫស្យា ឈ្នានិសដិះជាន់ លោភរកប្រយោជន៍តាំងបំពាន គិតតែខាងបានប្រយោជន៍មកខ្លួនដោយផ្លូវខុសច្បាប់ មានចិត្តច្រណែនចាកមេត្តាករុណាក្សត់ចិត្តនឹងមនុស្សជាតិផងគ្នា បុគ្គលបែបនេះលោកហៅថា អសប្បុរសគ្រោតគ្រាតបំផុត ។ ក្នុងប្រទេសណាឬក្នុងសមាគមណា បើមានមនុស្សអសប្បុរសនៅលាយឡំផង ប្រទេសនោះនឹងសមាគមនោះនឹងមានអនាធិបតេយ្យ ហើយវិនាសហិនហោចឆាប់ខ្លាយចុះជាលំដាប់ ។

មួយទៀត ពាក្យថា «សប្បុរស» សំគាល់យកមនុស្សមានសុចរិតធម៌ ។ សុចរិតធម៌ទុកដូចជាសញ្ញាប័ត្រមួយដ៏ប្រសើរបំផុត គាលបើបុរសស្ត្រីណាមួយ មានសុចរិតធម៌ បុរសស្ត្រីនោះ គេហៅថាមនុស្សសប្បុរស ។ សុចរិតធម៌ ជាគ្រឿងសំគាល់មួយសម្រាប់តាយថាន

ជាសប្បុរស ដែលផ្ទុយគ្នាអំពីអសប្បុរសជាយថាពិត ព្រោះថាធម៌បេស់សប្បុរសនឹងអសប្បុរស ហ្វាងគ្នាដូចទិសខាងកើតនឹងទិសខាងលិច ។

ព្រះពុទ្ធសាសនាជាសាសនាដែលសម្បូរទៅដោយសុចរិតធម៌នេះច្រើនជាទីបំផុត ។ អ្នកដែលបានសន្សំសុចរិតធម៌ រមែងបាននូវសេចក្តីសុខគាំងបច្ចុប្បន្នគាំងបរលោក ។ សុចរិតធម៌ ជាមូលហេតុនៃសេចក្តីផ្ទុយគ្នានឹងទុច្ចរិត បំណែកឯទុច្ចរិតក៏ជាមូលហេតុនៃសេចក្តីទុក្ខ ឬជាមូលហេតុនៃអសន្តិសុខ យ៉ាងនេះវិញក៏បាន ។ រដ្ឋាភិបាលក្នុងប្រទេសនីមួយ ។ ក៏ត្រូវគិតអំពើសុចរិតនឹងទុច្ចរិតដែរ គឺថាត្រូវប្រមូលសន្សំសុចរិតនឹងត្រូវតែលាងនឹងបន្សាត់ទុច្ចរិតចេញឲ្យអស់ទើបបាននាំប្រសើរ ។

ពុទ្ធសាសនា ឈ្មោះថា សភាសន្តិសុខផ្លូវធម៌ ដែលមានព្រះសម្មាសម្ពុទ្ធជាប្រធានបេស់សភា ។ សភាសន្តិសុខកងលោក ក្រៅអំពីព្រះពុទ្ធសាសនាឈ្មោះថា សភាសន្តិសុខផ្លូវលោក ជាសភាសម្រាប់រក្សាការពារប្រទេស ដើម្បីកុំឲ្យកើតសង្គ្រាមរវាងប្រជាជនកងលោក ឬកុំឲ្យមានការចលាចលប៉ុណ្ណោះ ទោះបីមានសភាសន្តិសុខផ្លូវលោកត្រមាំងមានគ្រឿងអាវុធជាដំនួយយ៉ាងនេះហើយ ក៏គង់តែកើតសង្គ្រាមឡើងបានកងកាលខ្លះពុំខាន ដូចយ៉ាងសង្គ្រាមលោកលើកទី២ អង្គការសហប្រជាជាតិក្តី ទៅសហរដ្ឋអាមេរិកក្តី សុទ្ធតែជាសភាសន្តិសុខសំរាប់លត់ភ្លើងទុក្ខកងលោក បានផលខ្លះពិតមែនហើយ តែថាសភា

សន្តិសុខនេះសម្រាប់តែសេចក្តីស្ងប់ខាងក្រៅតែម្យ៉ាង ។ ចំណែកខាងព្រះពុទ្ធសាសនា ជាសភាសន្តិសុខផ្លូវធម៌ដ៏ប្រសើរបំផុត ព្រោះគោលបម្រាប់សត្រូវបានតាំងខាងក្នុងតាំងខាងក្រៅ ហើយនាំអ្នកសមាដកឲ្យបានមគ្គផលនិព្វាន មានកម្មវិធីដ៏ជ្រាលជ្រៅសុខុមភាពច្រើនប្រការណាស់ ហើយគួរកត់ថាជាសភាចាស់ទុំមានអាយុដ៏វែងឆ្ងាយណាស់មកហើយ គួរយើងជាពុទ្ធបរិស័ទរៀបចំជួសជុលឲ្យមានរបៀបរៀបរយឡើង ។ ម្ខាងទៀត សភាសន្តិសុខតាព្រះពុទ្ធសាសនានេះ មិនចាប់ប្រើគ្រឿងអាវុធយុទ្ធភណ្ឌ ដូចសភាសន្តិសុខផ្លូវលោកឡើយ ។ ចំណែកខាងគ្រឿងអាវុធយុទ្ធភណ្ឌ ក្នុងផ្លូវព្រះពុទ្ធសាសនាក៏មានប្រើដែរ តែជាអាវុធដោយនាមធម៌ សម្រាប់តស៊ូនឹងបច្ចាមិត្រតឹតកិលេសមានលោភៈជាដើម មិនមែនអាវុធមានរូបដែលធ្វើអំពីវត្ថុផ្សេង ។ មានដែកជាដើមនោះទេ ។

អាវុធក្នុងព្រះពុទ្ធសាសនាមាន ៣ យ៉ាងគឺ :

១- សុតាវុធ ការស្តាប់ ការរៀន ការប្រតិបត្តិធម៌ដោយគោរព នេះឯងគុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា

២- បរិវិតក្កាវុធ ការនៅដោយស្ងប់ស្ងាត់ចាកពួកគណៈ ស្ងប់ស្ងាត់ចាកកិលេសមានរាគៈជាដើម ឬស្ងប់ស្ងាត់ចាកនីវរណធម៌ទាំង៥យ៉ាង មានកាមច្ឆន្ទៈជាដើម នេះឯងគុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា

៣- បញ្ញាវុធ ការពិចារណាពាក្យពេកហេតុផលរបស់សេចក្តីសុខ

ទុក្ខ ន័ដ៏ហោគុដលនៃលក្ខណ ៣ យ៉ាង មានអនិច្ចលក្ខណជាដើមរបស់បញ្ចក្ខន្ធ នេះឯងទុកជាអាវុធព្រះពុទ្ធសាសនា ។

មួយទៀតព្រះពុទ្ធសាសនា មានដំបូន្មានដ៏ល្អ ។ ទៀតជាប្រើនណាស់ សម្រាប់ប្រដៅប្រជាជន ដែលមិនគានមានសុចរិតធម៌ឲ្យមានសុចរិតធម៌ឡើង ដែលមិនមានហានៈជាអសប្បុរសធ្វើឲ្យទៅជាមនុស្សសប្បុរសឡើងបាន ពាំនាំនេះឯងក៏ទុកជាអាវុធដ៏ប្រសើរ ដែលនាំមនុស្សឲ្យក្លាយជាសប្បុរស ។

មួយទៀត សភាគីទីប្រជុំនិយាយការឯណា ដែលមិនមានមនុស្សសប្បុរសជាសមាជិក ទីនោះមិនឈ្មោះថាជាសភាឡើយ សមដូចពុទ្ធភាសិតក្នុងសំយុត្តនិកាយថា :

ឆេសា សភា យត្ថ ន សន្តិ សន្តោ
សន្តោ ន តេ យេ ន វទន្តិ ធម្មំ
ភគញ្ច នោសញ្ច បហាយ មោហំ
ធម្មំ វទន្តោ ច ភវន្តិ សន្តោ ។

ប្រែថា មនុស្សសប្បុរសគាំងឡាយ មិនមានក្នុងពួកណា ពួកនោះមិនឈ្មោះថាជាសភាទេ ពួកជនណាមិនទិយាយធម៌ ពួកជននោះមិនឈ្មោះថាសប្បុរសទេ លុះតែពួកជនណាដែលលះបង់នូវភគៈ ទោសៈ មោហៈ ហើយ និយាយនូវធម៌ ទើបឈ្មោះថា «អ្នកសប្បុរស» ។

ពុទ្ធកាសិតនេះ វិនិច្ឆ័យអំពីសភាវៈរបស់សមាជិកសប្បុរសនិងអសប្បុរសត្រមាំងវិនិច្ឆ័យអំពីបុគ្គលដែលគួរហៅថាមនុស្សសប្បុរស ។

ចំណាប្រទេសណា ដែលសម្បូណ៌ដោយមនុស្សសប្បុរស ទំនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខ សេចក្តីចំរើន ដោយពិតប្រាកដ ឥតអាក់ កុំថាឡើយដល់ទៅសង្គ្រាម សូម្បីតែចោរលួចប្លន់ក៏ពុំមានឡើយ ។ មួយវិញទៀត ធម៌របស់សប្បុរស ឬធម៌សម្រាប់សំគាល់ឲ្យដឹងថា អ្នកនេះជាមនុស្សសប្បុរសឬអសប្បុរសនោះ លោកហៅថាសប្បុរសធម៌មាន ៧ យ៉ាងគឺ :

១- ធម្មញ្ញុតា សេចក្តីដឹងធម៌ សំដៅយកការដឹងហេតុនៃសេចក្តីសុខ-ទុក្ខ ហើយការយកហេតុនៃសេចក្តីសុខ លះបង់ហេតុនៃសេចក្តីទុក្ខចេញ;

២- អត្ថញ្ញុតា សេចក្តីដឹងអត្ថគឺដឹងផលនៃសេចក្តីសុខ ទុក្ខ ហើយតាំងចិត្តសង្កៀស គឺត្រេកអរតាមមានតាមបាន

៣- អត្តញ្ញុតា សេចក្តីដឹងខ្លួន គឺដឹងថាអាត្មាអញមានជាតិត្រកូលថោកទាបប្លែកឲ្យសង់យ៉ាងណា ហើយប្រព្រឹត្តខ្លួនឲ្យសមគួរ មិនឲ្យជាខំទាស់ដល់អ្នកដទៃ

៤- មត្តញ្ញុតា សេចក្តីដឹងប្រមាណ គឺដឹងប្លាស់ក្តងការស្វែងរក កងការខ្ជួលយក កងការចរិកាគប្រើប្រាស់ចំពោះតែល្មម ។

ហើយគាបចេះលែលកឲ្យសមគួរដល់ប្រមាណ ប្រកបដោយធម៌សន្តោស សមគួរដល់ប្រទេសជាតិរបស់ខ្លួន មិនស្តុះស្តារ មិនលោតឡើងឲ្យ ហួសហេតុពេក ទុសចំនង ដែលនាំឲ្យខូចតម្លៃកិត្តិយសរបស់ជាតិសាសនារបស់ខ្លួន ព្រោះតែនយោបាយរបស់គេនោះឡើយ ។

๔- កាលញ្ញូតា សេចក្តីដឹងកាល គឺដឹងថាកាលវេលានេះគួរប្រកបកិច្ចការនោះ។ កាលវេលានេះមិនគួរប្រកបកិច្ចការនោះ។ ល ។

๖- បរិសញ្ញូតា សេចក្តីដឹងបរិស័ទ គឺដឹងថាប្រជុំជននេះមានហានៈវៃបនេះ មានកំរិយាវៃបនេះ ហើយប្រព្រឹត្តខ្លួនតម្រូវឲ្យសមដល់អធ្យាស្រ័យនៃបរិស័ទនោះ ។

๗- បុគ្គលបរោបរញ្ញូតា សេចក្តីដឹងបុគ្គលជាន់ខ្ពស់កណ្តាល ទាប គឺដឹងថា បុគ្គលនេះជាមនុស្សសប្បុរស គឺមនុស្សដែលគួរសេពគប់ បុគ្គលនេះជាមនុស្សអសប្បុរសគឺមនុស្សអាក្រក់ដែលមិនគួរសេពគប់ជាដើម ។

សប្បុរិសធម៌ ๗ ប្រការនេះ ទុកជាគ្រាប្រថាប់ប្តូជាសញ្ញាប័ត្រមួយសម្រាប់ឲ្យតាយថាបានថា : បើនរណាមានធម៌ ๗ ប្រការនេះ នរនោះទើបឈ្មោះថាជាមនុស្សសប្បុរសដោយពិត បើបុគ្គលណាមិនមានធម៌ ๗ ប្រការនេះទេ បុគ្គលនោះក៏ឈ្មោះថាជាមនុស្សអសប្បុរស ។

មនុស្សយើង ដោយប្រក្រតី រមែងមានធម៌ទាំងនេះតាំងនៅក្នុងខ្លួន

មិនមាន ដើម្បីមានច្រើនក៏គង់មានតិច ។ អ្នកដែលមានធម៌នេះតិច មិនគ្រប់គ្រាន់ក្នុងសន្តាន រមែងភៀងជាមនុស្សមានសេចក្តីអង់អាចតិច មានសេចក្តីសុខចំរើនក៏តិចតាមលំដាប់ ។ អ្នកដែលមានធម៌ពាំងនេះច្រើនក្នុងសន្តាន រមែងបានជាមនុស្សមានសមត្ថភាព ថ្លៃថ្លា មោះមុត អង់អាចច្រើន ធ្វើប្រយោជន៍ដល់ខ្លួនទំនឹងជាតិសាសនារបស់ខ្លួនក៏បានច្រើន ពាំងសេចក្តីសុខ ការសរសើរនឹងកេរ្តិ៍ឈ្មោះ យសសក្តិមានច្រើន ។

ព្រះពុទ្ធសាសនា ជាបដិបទាឲ្យកើតសន្តិសុខដោយសូតសុភាព សម្រាប់ដឹកនាំមនុស្សឲ្យទៅជាសប្បុរស ។ ឯពាក្យ «សន្តិសុខ» នេះសំដៅយកសេចក្តីសុខសាន្តពាំងលោកនេះពាំងលោកខាងមុខ ។ មួយទៀត សេចក្តីសុខនេះមានពីរយ៉ាងគឺ : សេចក្តីសុខដែលកើតអំពីការសូម្បីរម្ងាប់ចាកទុក្ខទោសតែក៏ដោយសត្រូវ ជាសេចក្តីសុខសម្រាប់ប្រទេសជាតិរបស់មនុស្ស·ទេព្តា ដែលនៅលាយឡំដោយទុក្ខខ្លះ ហៅថាសាមិសសុខ ១ សេចក្តីសុខស្អាតបរិសុទ្ធដែលកើតអំពីការសូម្បីរម្ងាប់ចាកកិលេសចាកបញ្ចកន្ធ . គឺថាសេចក្តីសុខដែលមិនលាយឡំដោយទុក្ខទោសតែតទៅទៀត ជាឧដល់សេចក្តីសុខរបស់ព្រះនិព្វាន នេះលោកហៅថានិរាមិសសុខ ១ ព្រះពុទ្ធសាសនាតែងឲ្យសម្រេចផលដ៏ពូលាយ គឺសុខពីរប្រការនេះឯង ។

ព្រះពុទ្ធសាសនាប្រៀបដូចជាផ្ទះផ្សារមួយខ្នង ដែលមានទំនិញល្អៗជា

ច្រើន ហើយជាទំនិញសុទ្ធតែវត្ថុបរិសុទ្ធ មិនមែនជារបស់ក្លែងក្លាយឬមានពិសពុលស្អុយក្រហាយ ដូចពាននឹងព្រះគឺសាសនាឯទៀតៗ នោះទេ ព្រះគឺព្រះពុទ្ធសាសនានេះ បើតាមលក់ចំពោះតែរបស់ណាដែលមិនជាសត្រូវ ទំនិញបរិសុទ្ធនោះគឺមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើមនឹងកុសលធម៌ទាំងឡាយឯទៀតៗ ជាច្រើន គួរតែប្រជាជនគ្រប់លោកចូលមកទិញទំនិញល្អៗ នោះតាមត្រូវការ ។ ព្រះពុទ្ធសាសនា មានបញ្ញត្តសិក្ខាបទជាសាធារណៈដល់មនុស្សទាំងមនុស្សទាំងគ្នា ព្រមទាំងដល់មនុស្សទាំងតិរច្ឆានឥតមានរើសជាតិឡើយ ពោះបើមនុស្សក៏ត្រូវមានធម៌សុចរិតក្នុងសន្តានរាងសត្វតិរច្ឆាន ។ ព្រោះសត្វតិរច្ឆានមានជីវិតជាទីស្រឡាញ់មានមេ មានឪ មានកូនជាទីស្រឡាញ់របស់វាយ៉ាំងណា មនុស្សយើងក៏យ៉ាំងនោះដែរ ។ សាសនាឯទៀតៗ ក្រៅពីនេះឬបញ្ជាប់បញ្ញត្តរបស់ប្រទេសទាំងឡាយក្នុងលោក ច្រើនតែបញ្ញត្តតឹងរឹងតែក្នុងរាងមនុស្សទាំងមនុស្ស ដូចយ៉ាំងផ្លូវបាណាតិបាតឬអទិន្នាទានជាដើម ចំពោះតែមនុស្សទាំងដូចគ្នា ត្រង់មនុស្សសម្លាប់តិរច្ឆានឬលួចបន្លំដណ្តើមស៊ីតសត្វតិរច្ឆានកូនចៅសត្វតិរច្ឆាន មិនឃើញមានបញ្ញត្តផងឡើយ ។

បុគ្គលជាមនុស្សជាតិណាមួយ កាន់ធម៌សុចរិតខ្ជិលខ្ជាត់ពិតត្រង់ក្នុងការរបស់ប្រទេស របស់សាសនា ទាំងរាងមនុស្សទាំងមនុស្សដូចគ្នា. ពោះបើជាមនុស្សជាន់ខាងបន្តជាន់ខ្ពស់ ក៏មិនត្រូវប្រមាថមើលងាយចៀត

បៀនរំបងជាន់ដល់គ្នាខឹងគ្នាទេ តាំងមនុស្សកំត្រូវគាន់ធម៌សុចរិតចំពោះតែរាល់ថ្ងៃដែរ ។ បុគ្គលអ្នកគាន់ធម៌តាមបញ្ញត្តនៃព្រះពុទ្ធសាសនាដូច្នេះ ហៅថាសប្បុរសៈ ។ មនុស្សសប្បុរសនេះ ច្រើនមានតែក្នុងព្រះពុទ្ធសាសនា អ្នកដែលគាន់ធម៌សុចរិតរើសមុខដោយអាងថា : ខ្លួនអញជាមនុស្សជាន់ខ្ពស់ ជាអ្នកមានយសសក្តិអំណាច ជាមនុស្សមានកម្លាំងទ្រព្យធនច្រើន ជាមនុស្សមានទុច្ចាយកំចួកលច្រើន ហើយបៀតបៀនសង្កត់សង្កិនមនុស្សដែលថោកទាបបៀតបៀនមនុស្សដែលឥតយសសក្តិ មើលងាយមនុស្សដែលក្រខ័ឡទ្រព្យសម្បត្តិ ចោកច្រាសបំផ្តាត់មនុស្សដែលល្ងង់ខ្លៅដែលគ្មានទុច្ចាយ អ្នកដែលមានសេចក្តីប្រមាថពាយងាយដូច្នេះ ចោះបីបន្ទុំខ្លួននៅក្នុងសាសនាក៏ហៅថាអសប្បុរសដែរ ។

ជនជាខៃ តែជាអ្នកធ្វើប្រយោជន៍ឲ្យយើង ទុកជាផៅពង្ស
ឯផៅពង្សពិត តែជាអ្នកមិនធ្វើប្រយោជន៍ឲ្យយើង ក៏ទុក
ជាអ្នកជាខៃ ភេតកើតក្នុងកាយយើងពិត ។ រកប្រ
យោជន៍គ្មាន ថ្នាំកើតនៅក្នុងព្រៃ ធ្វើប្រយោជន៍ឲ្យយើង

ហ៊ាតោបទេស

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាយដ្ឋាន)

លោក ប៊ូ - ប៉ូ រៀបរៀង

តមក

កុសលជាឧបបីឡ្យកកម្មនោះ គឺបុគ្គលធ្វើអកុសលកម្មរួចហើយ កុសលមកបៀតបៀនអកុសល កុសលឲ្យផលដោយខ្លួនឯង មិនឲ្យអកុសលឲ្យផលឡើយ ដូចជាកុសលនៃនាយចោរឃាតកបុរសអ្នកសម្លាប់ចោរឈ្មោះវាតកាលកបុរស ។

រឿងនាយចោរឃាតក

ភាជកហោ កាំរ ចានឮរឿងមកថា នាយចោរឃាតកនោះជាអ្នកសម្លាប់ចោរនៅកន្លែងគរពជគ្រឹះ ព្រះមហាក្សត្រទ្រង់តាំងទុកកន្លែងនោះឲ្យជាអ្នកសម្លាប់ចោរ បើអ្នកស្រុកចាប់ចោរបានតិចក្តីច្រើនក្តី នាំយកមកដល់ហើយ នាយចោរឃាតកឈ្មោះវាតកាលកនោះ ចេះតែសម្លាប់ចោលចាំងអស់ ត្រប់ពេលវេលា ឥតលោះមានថ្ងៃណាឡើយ ។ នាយចោរឃាតកនោះសម្លាប់ចោរតាំងតែខ្លួនទៅក្នុងរហូតដល់ចាស់ជកចំនួន ៩០ ឆ្នាំមកហើយ ដល់គ្រាខ្លួនចាស់ជក ឋយកម្លាំង គាប់ចោរតែម្តងមិនស្លាប់ខ្លះត្រូវគាប់តិចបីដងទើបចោរស្លាប់ ។

វញ្ញោ អាភោចេសុំ អមាត្យទាំងឡាយនាំសេចក្តីនោះក្រាបទូលចំពោះព្រះមហាក្សត្រថា មហាស្វកោ ន សក្កោតិ នាយពោធិសត្តនោះថាស់ជាពុទ្ធលក្ខណៈហើយ មិនអាចប្រហារទូវពោធិសត្តទាំងឡាយឲ្យក្ស័យជីវិតដោយការប្រហារតែម្តងបានទេ ធ្វើឲ្យពួកពោធិសត្តលំបាកខ្លាំងណាស់ សូមព្រះអង្គទ្រង់ជ្រាប ។

ព្រះបរមក្សត្រមានព្រះទន្ទឹងត្រាស់ថា អបេថ ចំបើដូច្នោះហើយអ្នកទាល់តែចូរដក បញ្ឈប់ទូវនាយឧត្តមពោធិសត្តនោះចុះ ចូរតាំងទូវបុរសដទៃទៀតក្នុងដំណែងពោធិសត្តនោះវិញ ។ អមាត្យទាំងពួង ក៏ធ្វើតាមព្រះពាជបញ្ជា បញ្ឈប់នាយឧត្តមបុរសនោះចេញហើយយកបុរសដទៃទៀតមកធ្វើជំនួសវិញ ។

ចំណែកនាយឧត្តមបុរសនោះ លុះបានរួចផុតពីដំណែងជាអ្នកសម្លាប់ពោធិសត្តហើយ ក៏នឹកចង់ស្វែកដណ្តប់សំពត់ថ្មី តាក់តែងខ្លួនប្រណាដោយគ្រឿងក្លាមានក្លិនក្រអូប ប្រាថ្នានឹងបរិភោគនូវបាយបាយាស នឹងចង់ប្រស់ព្រំកាយដោយគ្រឿងអប់ ចង់ដួតទឹកដម្រះកាយ ដោយទឹកក្រអូប ព្រោះថានាយឧត្តមពោធិសត្តនោះ កាលនៅធ្វើការសម្លាប់ពោធិសត្តណា មិនដែលបានស្វែកតាក់សំពត់អាវថ្មី មិនដែលបានស្វែកគ្រឿងក្លានឹងបរិភោគបាយបាយាស នឹងលុបលាងកាយដោយគ្រឿងអប់ ដម្រះកាយដោយទឹកក្រអូបដូចនោះ ។ ហេតុដូច្នោះ នាយឧត្តមពោធិសត្តនោះ លុះ

ចេញពុតពីដំណែងជាតេជ្ជឃាតហើយ ទើបខឹកក្នុងចិត្តថា មេ ចរិតំ តំង តាអញប្រព្រឹត្តអំពើដ៏សោហ្មនេះ ជាយូរយារណាស់ ប្រមាណ៥០ឆ្នាំ ហើយ មិនដែលបានបរិភោគអាហារល្អ។ មិនដែលបានស្លៀកពាក់សំពត់ អាវថ្មី។ សោះ តែពួកគឺស្រែកហៅកេះយាមកបង្គាប់ឲ្យដណ្តើបាយបាយាស ហើយឲ្យយកគ្រឿងលំអិតក្រអូបសម្រាប់ដូតទឹក ហើយទៅឯកំពង់ទឹក ដូតជម្រះសរីរៈឥន្ទ្រិយកក់ក្សាលដោយប្រេងដែលចម្រាញ់បានមួយរយដង ហើយស្លៀកពាក់សំពត់អាវថ្មី លុបលាងសរីរកាយដោយគ្រឿងក្រអូប សៀតម្លាគាក់តែងខ្លួនដោយប្រដាប់យ៉ាងល្អឆើតឆាយ ដើរមកតាមមាគ៌ាវិថីកំពុងឃើញព្រះធម្មសេនាបតីសារីបុត្រនិមន្តពីមុខខ្លួនចូលមក ទើបមានចិត្តសោមនស្សរីករាយ គិតថាអញចេញពុតពីកម្មដ៏សៅហ្មងក្នុងថ្ងៃនេះ ស្រាប់តែបានមកជួបប្រទះនឹងលោកម្ចាស់សារីបុត្រ គួរតែអញនឹងធ្វើកុសលប្រគេនអាហារបិណ្ឌបាត គិតរួចក៏គាងជង្គង់ឲ្យទទួលអាហារបិណ្ឌបាតក្នុងគេហស្ថាន ហើយទទួលបាត្រព្រះមហាថេរៈទៅឯផ្ទះ និមន្តចូលទៅខាងក្នុងផ្ទះ ហើយឲ្យគង់លើអាសនៈដែលតាក់តែងល្អស្អាត ហើយចាត់ចែងអង្គាសដោយបាយបាយាសដ៏ឈ្ងុយដោយសប្បិ ទំនិលអិតនៃស្ករគ្រាម។

អនុមោទនំ អកាសិ ព្រះសារីបុត្តត្ថេរជាម្ចាស់ធ្វើភត្តកិច្ចស្រេចហើយ ក៏ធ្វើអនុមោទនាថា ឯវំ មោគ្គ អ្នកប្រាថ្នាយ៉ាងណា សូមឲ្យបានសម្រេចយ៉ាងនោះចុះ ឥច្ឆិតំ បត្ថិតំ សេចក្តីប្រាថ្នាដែលអ្នកប្រាថ្នា

ហើយដោយការយល់ច្បាស់ដឹងចិត្ត ចូរឲ្យបានសម្រេចយ៉ាងដាច់ហ៊ាស
សេចក្តីត្រិះរិះទាំងឡាយចូរពេញបរិបូណ៌ក្នុង
ខន្ធសន្តានប្រៀបដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី បើមិនដូច្នោះទេ សេចក្តី
ត្រិះរិះរបស់អ្នកចូរសម្រេចតាមប្រាថ្នា ដូចជាកែវមណីដោតដែលឲ្យ
សម្រេចកិច្ចគ្រប់ប្រការ ឆាំ សក្កស្ស សោ ទាំ ទានេះជា
ជណ្តើរឡើងទៅកាន់ស្ថានសួគ៌ អាចតំណាត់បង់នូវសេចក្តីពាល់ក្រចាន
អាចវេចខ្ចប់ទៅនូវសម្បត្តិក្នុងមាតិម្រាំទឹងដល់នូវនិព្វាន ទានេះជា
គន្ធធូបទៅនិព្វាន ។ ព្រះសារីបុត្តត្ថេរជាម្ចាស់ធ្វើអនុមោទនាដូច្នេះ
នាយវាតកាលកនោះ ចាន់ស្តាប់ចប់ហើយ ក៏ចាន់នូវអនុលោមញ្ញ ។ ព្រះ
សារីបុត្តត្ថេរធ្វើអនុមោទនាចប់ហើយ ក៏ចុះចាកគេហស្ថាន នាយវាតកាលក
កាន់ចាត្រជួនដំណើរហួតទៅដល់ខាងក្រៅកូមិ ប្រគេនចាត្រទៅព្រះថេរ
ហើយត្រឡប់មកវិញ ដល់ពាក់កណ្តាលផ្លូវ មានមេឃាមកដល់នាយវាត-
កាលកឲ្យដួលដេកក្បែរដីតទៅ លុះរលត់បញ្ចក្ខន្ធហើយ ចាន់ទៅកើត
ក្នុងតាវត្តឹង្សព្រហ្មលោក ចាន់សោយទិព្វសម្បត្តិ មានខាងខេតអប្សរជាបរិវារ ។

កុសលកម្មនៃនាយវាតកាលកនេះឈ្មោះថា កុសលកាត់អកុសល.
ចាន ព្រោះហេតុប្រគេនបិណ្ឌចាតប្រកបដោយសេចក្តីជ្រះថ្លាក្នុងកាល
ពាំងបី គឺបុព្វចេតនា មុញ្ចនចេតនា ចាគចេតនា កុសលដើរកាត់
អកុសលចាន់ដូចរៀបរាប់មកនេះ ។

ទុបបិត្តិកកម្ម សង្ខេបប៉ុណ្ណេះ ៖

๑๑- อุปปัชชเวทนียกรรม (๑)

กุสลเจตนาคือ บุญ ปาฏิปทาสฺส ปาฏิปาฏิยา กุสลเจตนาเยว เวทิตพฺพา สา ปน สตฺตสุ วาเรสุ ยาว สตฺตสุ สมาปตฺตีสุ ปวตฺตีติ ฯ

ในคำนี้ พึงทราบความแห่งกรรมที่ชื่อว่าอุปปัชชเวทนียกรรมก่อน ฯ อาจารย์ทั้งหลายกล่าวไว้ว่า อุปปัชชเวทนียกรรมนี้ มีเนื้อความดังกล่าวมาแล้วนั่นแหละ อุปปัชชเวทนียกรรมนี้ อุปปัชชเวทนียกรรมนี้ มีเนื้อความต่างกันอย่างไร ? ตอบว่า ต่างกันอย่างนี้ คือ อุปปัชชเวทนียกรรมนั้นแปลว่าเกิด อุปปัชชเวทนียกรรมนั้นแปลว่าสำเร็จ อุปปัชชเวทนียกรรมนั้นแปลว่าให้ผล ฯ

ถามว่าเหตุไรจึงกล่าวว่า กุสลเจตนาคือ บุญ ก็บุญเป็นอกุศล ให้ผลเป็นสุข ส่วนอกุศลเป็นกุศล ให้ผลเป็นทุกข์ ก็ไม่ได้ยินว่าเป็นกุศลให้ผลเป็นกุศล ส่วนอกุศลเป็นอกุศลให้ผลเป็นอกุศล ฯ

เรื่องพระเถระชื่อว่าปาฏิปทา

ได้ยินว่า พระเถระชื่อว่าปาฏิปทา ในกาลก่อนแต่พระศาสนาของพระสัมมาสัมพุทธเจ้าพระนามว่าปทุมุตตระ

๑- ในคัมภีร์ฉบับหนึ่งเรียกว่า อุปปัชชกรรม ฯ

បុត្រប្រកបដោយសទ្ធា បព្វជ្ជាទបសម្បត្តជាកត្តកតព្រះបវរពុទ្ធសាសនា ចំពោះព្រះសមណគោតមមកបានមួយម៉ុនឆ្នាំ ថ្ងៃមួយ ជិះទូកទន្លេឆ្លងស្ទឹងទៅត្រើយម្ខាង កាលចុះទៅដល់ទូកនោះ ចាប់ពាក្យស្ទឹកវៃទឹកទៅតែស្បែរច្រាំង លុះទូកលឿនទៅ មិនបានលែងស្ទឹកវៃទឹកនោះចោល ស្ទឹកវៃទឹកក៏ជាប់ដោយអំណាចកម្លាំងទូកលឿនទៅ លុះទន្លេទៅដល់ត្រើយម្ខាងហើយ ទឹកមិនឃើញ ចំណោះលង់មក កាលជិតនឹងរលត់បញ្ចក្ខន្ធទើបទឹកពួកឃើញព័ររឿងធ្វើឲ្យជាប់ស្ទឹកវៃទឹកនោះ ប៉ុន្តែនឹងរកតត្តកអង្គណាមួយសំដែងអាបត្តិនោះមិនបាន ។ កំពុងនោះកើតវិប្បដិសារៈ មានសេចក្តីក្តៅក្រហាយតានតឹងក្នុងចិត្ត លុះអស់ជីវិត បានទៅកើតក្នុងក់ណោតសត្វតិរច្ឆាន ជាស្តេចនាគដោយអំណាចនៃអកុសល ឯសមណធម៌ដែលខ្លួនប្រព្រឹត្តចំនួនមួយម៉ុនឆ្នាំនោះ មិនបានឲ្យផលទេ ព្រោះហេតុអកុសលជាទបច្ចេកកម្មកាត់កុសល ។

ហេតុនោះ សម្តេចព្រះបរមគុរុសពលទើបត្រាស់ទេសនាថា កម្មនេះឈ្មោះថាបច្ច័យ ។ ឯកុសលកម្មកាត់ផ្តាច់អកុសលកម្មចេញក៏មាន ដូចបុគ្គលធ្វើតែអំពើអកុសលមកជាយូរយារច្រើនឆ្នាំ កាលជិតនឹងអស់ជីវិតក៏ត្រេកអរកន្ត់ត្មុំបូជា លុះរលត់បញ្ចក្ខន្ធហើយ កុសលនោះកាត់ផ្តាច់អកុសលបាន ។ ទៅកើតក្នុងស្ថានសួគ៌ ដូចជាបិតានៃព្រះមហាវេរមួយអង្គ ។

រឿងនាយព្រានម្រឹគ

មានៈនាយព្រានម្រឹគម្នាក់ ជាបិតានៃព្រះមហាវេរ តែងដើរបោះញ៉ាំ
សម្លាប់សត្វលក់ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃជាយូរឆ្នាំ លុះដល់ខួបជាស់ជក
ហើយ ក៏ចូលទៅប្រុងនៅជាមួយព្រះមហាវេរជាកូនរបស់ខ្លួន ។ ព្រះមហា
វេរជាបុត្រក្រាបបិទាឲ្យបរិភោគវារ ។ កាលតិក្ខជាស់ជកធ្វើបរិភោគវារ
យូរទៅ ព្រះកម្មដ្ឋានក៏មិនបានកើតមានច្បាស់ដល់ចិត្តសោះ ដេរតែឲ្យ
នឹកព្រួយឃើញតែការវៃលខ្លួនសម្លាប់ម្រឹគ មិនអាចតាំងសតិស្មារតីចំពោះ
ព្រះកម្មដ្ឋានបាន ទើបចូលទៅប្រាប់ព្រះមហាវេរជាបុត្រ ។ ព្រះមហា
វេរក៏ប្រាប់ឲ្យចំរើនព្រះកម្មដ្ឋានខោះជានិច្ចតមកទៀត ។

កាលតិក្ខជាស់ជកនោះ មានជម្ងឺឈឺធ្ងន់ដាក់ស្លាប់ដែរ ព្រះមហាវេរ
ជាបុត្រគិតថា បិតាអញនេះ កាលចេះស្លាប់ទៅហើយ មិនគួរទុំដាំទៅ
ខ្ពុគ្គតិទេ ទើបព្រះមហាវេរគាក់តែងគ្រឿងសក្ការបូជា យកទៅដាក់ទៅ
ខាងក្បាលដំណេកបិតា ហើយប្រាប់ថា បិតាចូរញ៉ាំងចិត្តឲ្យជ្រះថ្លាចុះ
គ្រឿងសក្ការបូជានេះ អាត្មាគាក់តែងខុកឲ្យលោកជាបិតាយកទៅថ្វាយ
បង្គំព្រះចេតិយ ។ តិក្ខជាស់ជកក៏មានចិត្តត្រេកអរគិតប្រាថ្នាទំនងមស្សការ
ព្រះចេតិយដោយគ្រឿងសក្ការបូជានោះ លុះរលត់បង្កួតក្ខន្ធក៏បានទៅឆ្លើង
ទៅកើតកងស្ថានសួគ៌ នេះឈ្មោះថាកុសលកម្មជាឧបច្ឆេទកកម្មកាត់អកុ-
សល ហាមឃាត់អកុសលមិនឲ្យ ។ ផល កុសលឲ្យផលខ្លួនឯងវិញដូច្នេះ ។

កុសលក្តី អកុសលក្តី តាំងពីប្រកាស ម្នាក់ប្រាថ្នាផ្តល់ឱ្យថាជាអចិន្ត្រៃយ្យ មិនគួរអ្នកណាខំតប្តឹតតែ ព្រោះសម្តេចព្រះភគវន្តបានត្រាស់ប្រាប់ព្រះសទ្ធម្មទេសនាថា កម្មវិស័យជាអចិន្ត្រៃយ្យៈ គឺអ្នកណាតែងតែខំញ៉ាំងចិត្តអ្នកនោះឱ្យកើតមាយ ។ ឯការដែលកុសលនឹងកាត់ផលហាមឃាត់ផលនៃអកុសលនោះ ដោយអំណាចនៃកុសលជាយថាសន្តកម្ម គឺនឹកវាស្រមៃឃើញឬធ្វើទៅពេលជិតអស់ជីវិត កុសលនោះកាត់ផ្តាច់នូវផលនៃអកុសលបាន ។ ហេតុនោះ បុគ្គលដែលកើតមកកន្លងលោកវិស័យ កាលតាំងនៅក្នុងបឋមវ័យ មិនបានធ្វើនូវទីពឹង គឺការកុសលសីលទានជាដើម លុះដល់មជ្ឈិមវ័យ ចូរខំសព្វាហ៍ធ្វើការកុសល ។ ការកើតមកក្នុងវដ្តសង្សារនេះ ប្រៀបដូចមនុស្សដើរតាមមាគ៌ា បុគ្គលដែលបានរចនាការកសាងកុសលខុក ប្រៀបដូចអ្នកដំណើរមានស្បៀងទៅតាមផ្លូវ ។ ធម្មតាអ្នកដើរផ្លូវឆ្ងាយ ហើយមានស្បៀងនោះ សូម្បីតែនឹងយកទៅដល់ប៉ុន្មានថ្ងៃទៅដល់ប៉ុន្មាន ។ ក្តី កំអាចទៅដល់ទីកន្លែងដែលខ្លួនប្រាថ្នាបានទៅនោះបានសេចក្តីនេះមានឧបមាដូចម្តេច ។ បុគ្គលដែលកើតមកក្នុងសង្សារវដ្តមានចិត្តប្រាថ្នាព្រះអមតមហានិព្វាន ហើយកសាងធ្វើការកុសលមិនធ្វេសប្រហែស កាលខ្លួនធ្វើដំណើរទៅកាន់ផ្លូវតែសង្សារវដ្ត សូម្បីមិនបានអស់ជាតិអស់ភព ក៏នឹងបានបរិភោគផលនៃកុសលជាស្បៀងរៀងរហូតទៅ ដើម្បីមួលបណ្តាលឱ្យបានកាលណា ក៏នឹងបានសម្រេចដូចសេចក្តីប្រាថ្នាកាលនោះ ព្រោះខ្លួនមានស្បៀង គឺសីលនឹងទានជាដើម ។

អ្នកមានគុណ

ពាក្យកាព្យ

និពន្ធដោយលោក ហោង-សមអាង

នៅសេនាធិការយោធភូមិភាគទី ១ វៃត្រកំពង់ចាម
អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្សាពលថ្មើរជើន
វៃត្រពោធិសត្វ

សេចក្តីផ្តើម

បទព្រហ្មគីតិ

ខ្ញុំសូមអភិវាទ ព្រះលោកនាថជាអម្ចាស់
ព្រះអង្គទ្រង់ជាន់ត្រាស់ ធម៌ល្អណាស់ដល់សព្វសត្វ ។
រៃលមានចិត្តជ្រះថ្លា បំណ្រាថ្នាទឹងប្រតិបត្តិ
ដើម្បីកាយកំចាត់ ខ្លួកិលេសគេះឆាបឆាប់ ។
ខ្ញុំសូមក្រាបវន្ទា ព្រះធម្មាដ៏ចំណាប់
ជ្រាលជ្រៅតាមលំដាប់ ប្រសើរជាងច្បាប់ដទៃ ។
គឺជាពាក្យប្រធាន ល្អឥតមានល្អក់មោះមៃ
ស្ងួតស្អាតពាន់ប្រពៃ ថ្វាយព្រះឧស្ភព្រះសម្ពុទ្ធ ។
ខ្ញុំសូមបង្គំផ្ទាំ ឆ្ពោះព្រះសង្ឃអគ្គកុលបុត្រ
មានសីលដ៏បរិសុទ្ធ រឹសេសផុតមនុស្សខេត្តា ។

លោកមានចិត្តស្អាតជាត ត្រាប់តុវាទព្រះសាស្តា
ជាស្រែមានផ្លែផ្កា មានដីជាតវាតគ្នាតើត ។
ដោយតេជនមស្ការ ត្តែអស្ចារ្យវិសេសឆើត
ទុបស័ត្តបំរុងកើត សូមវិនាសចៀសចេញក្រៅ ។
សូមក្នុកក្តៅឆ័ទ្រាំម មេទុក្ខមនាំសោកសៅ
រលត់រលាយទៅ សូមសុខសាន្តជាន់ជិតវេរ ។
តទៅសូមបរិយាយ កែរដោះស្រាយទុកជាក្តី
អ្នកមានគុណលើខ្នែរ តីម៉ែ.ឪពាំងខ្ញុំហារ ។
នឹងគុណព្រះអគ្គៈ មហាវីរៈដ៏អស្ចារ្យ
ដែលទ្រង់ទំពាត់ការ កសាងជាតិជាន់សុខសាន្ត ។
តស៊ូនឹងទុបស័ត្ត ទ្រង់លុកស្នាក់ត្រង់ទីសហាន
ដើម្បីរកសុខសាន្ត ឲ្យជាតិខ្មែរជាន់សប្បាយ ។
មិនខ្លុសពីឪពុក ដែលស្វែងលុកលុកគ្នាយ
ទុបស័ត្តជាក់ផ្ទុះផ្ទាយ ដើម្បីរកន្លែងមាសប្រាក់ ។
ចិញ្ចឹមកូនប្រុសស្រី ដោយមេត្រីក្តីពាក់ពាក់
ខ្ញុំស្រាយការយបញ្ជាក់ ជាពាក្យការពិតមានសម្រស់ ។

អ្នកមានគុណ

មាតានឹងបិតា ក្នុងលោកត្រូវតាំងអស់

តែងមានចិត្តសប្បុរស　　ចំពោះកូនត្រប់ ๆ ប្រាណ ។
លោកអាចថែរក្សា　　បុត្តធីតាទាំងឡាយជាន
បិតនៅសុខក្សេមក្សាន្ត　　អាស្រ័យព្រហ្មវិហារធម៌ ។
ឥពុក-ម្តាយទាំងឡាយ　　លោកតែងផ្សាយដោយស្មោះសរ
ខ្ជូរព្រហ្មវិហារធម៌　　ដល់ត្រប់កូនទាំងប្រុសស្រី ។
ស្មើស្មើគ្នាទាំងអស់　　ញញឹមស្រស់ស្មោះមេត្រី
ថ្នាក់ថ្នមបមមតរបី　　យ៉ាងជិតស្និទ្ធឥតហ្មងសៅ ។
មិនថាកូនមានត្រ　　អាក្រក់ល្អកាយសម្ភៅ
កូនចេះកូនល្ងង់ខ្លៅ　　តមដំបៅមោសាំស្រែង ។
រឿចមាត់រឿចចង្កា　　ខ្វាក់ខ្វេតាក្សាលត្រមែង
ខ្វិនដើងខ្លៅកន្ទែង　　តឿកន្តុញសុញ្ញកថា ។
លោកទំប្រឹងស្វះស្វែង　　ត្រប់កន្ទែងទិសទាទា
ថ្ងៃយប់ត្រប់វេលា　　ដើម្បីកេសុភមង្គល ។
មិនតែប៉ុណ្ណោះឯង　　ម៉ែឪតែងតែកង្វល់
កង់ចិត្តគិតទៅដល់　　កូនប្រុសស្រីពល់យប់ថ្ងៃ ។
ខ្លាចក្រែងកូនកើតទុក្ខ　　ជម្ងឺរុកពេតព៉ាំ
ឬក្រែងចោរចង្រៃ　　ប្លន់ដណ្តើមទ្រព្យសម្បត្តិ ។
លោកតែងបន់ខ្លាឃ　　ដែលក្សេមហាស្វេតឆត្រ

របស់ព្រះមហាក្សត្រ កម្ពុជាចុងក្រឡឺស្បី ។
ខ្ញុំដឹងវត្តស័ក្តិសិទ្ធិ ពួកគេពិតកន្លងលោកិយ
សុំឲ្យកូនប្រុសស្រី កើតសួស្តីតាំងយប់ថ្ងៃ ។
ពីសេសជាងនេះទៀត មែនទ្រឹតអចិន្ត្រៃ
ប្រដៅកូនពាល់ថ្ងៃ ឲ្យសុំវិល័យតាមទំយម ។
ឲ្យកូនតាំងប្រុសស្រី ស្គាល់ត្រូវ ខុសច្បាប់សង្គម
ស្គាល់ក្មេង ស្គាល់ចាស់ទុំ ស្គាល់អ្នកធំអុំមីងមា ។
ឲ្យញាតិមិត្រដឹតធ្ងួយ មូលស្រស់ស្រាយស្នូត្រចិន្តា
រាប់អានស្និទ្ធស្នេហា ឬក្តីតាយ៉ាងដឹតដិត ។
ឲ្យកូនចំរៀនសូត្រ ចេះរហូតថ្នាក់បណ្ឌិត
រៀនសព្វវិជ្ជាពិត តាមកម្លាំងនៃបញ្ញា ។
ឲ្យកូនចេះរួមរក់ មូលស្មោះស្ម័គ្រស្មើចិន្តា
រាប់អានស្និទ្ធស្នេហា ជាសាមគ្គីស្អិតជាប់ខៅ ។
ចំណោមកូនស្រីប្រុស មានត្រូវខុសមានសទ្ធៅ
មានច្រើនជាមានល្អងំទ្បៅ ពាលកទ្បើនឆិចណ្ឌិត ។
បើកូនប្រុសស្រីណា កាន់តែរិយាខុចូរតែ
កោងកាចត្រហោងពិត ហ៊ានប្រមាថឪពុកម្តាយ ។
ប្រព្រឹត្តដល់កញ្ជោ ធឹកសុកមេអន្តកយ
លេងលែងស្បែងក្តាល់តាំងឡាយ រួមសប្បាយស្រីតេស្បា ។

ដើរលេងយប់ហួសយាម
ជាប់ពាក់ពាមស្ទឹងស្នួហា

ខ្លាចមនុស្សព្រាលឫស្សា
ចាយបង្អិនទ្រព្យទាំងឡាយ ។

ម៉ែម៉ងមិនស្ទៀមស្ងាត់
តែងតំបាត់ដោយខុបាយ

អំពើល្មើសទាំងឡាយ
របស់កូនប្រុសស្រីនោះ ។

ដោយដេរវាយជ្រាំជាក់
តំហិកជាក់យ៉ាងខ្លោះ

ពោលពាក្យមិនពិរោះ
ជាក់ណាកម្មឥតប្រណី ។

កាត់កាលំលែងពាក់រក
លែងឲ្យជ្រកមួមមេត្រី

លែងឲ្យនំចំណី
ចាយទឹកធីដូចពាលំថ្ងូ ។

ប្រសិនខឹងខ្លាំងក្លា
យ៉ាងនេះណាទៅគាល់ឃ្លួ

កុងចិត្តតែពាលំថ្ងូ
អាណិតកូន កាត់មិនជាប់ ។

តែងតែហៅពាក់រក
ឲ្យចូលមកមួមជាសាច់

ចិត្តម្តាយកាត់មិនជាប់
ដូចកាត់សាច់របស់ឯង ។

ម៉ែមានគុណធ្ងន់
ចិត្តខ្លោចខន់ធន់ពាក្យស្នែង

ដែលកូនពោលឥតក្រែង
យ៉ាងគំរោះគំរើយបាន ។

នេះគឺព្រហ្មវិហារ
ប្អូនប្រការកុងសន្តាន

ទើបគាបអត់ធន់បាន
ពាក្យកូនប្រុសស្រីទាំងឡាយ ។

កូនណាក៏យជ្រាំជាក់
តំហិកជាក់ម្តុកម្តាយ

កូននោះទឹងអន្តរាយ
កាយវង្កតឥតបីឃ្លាត ។

រីអង្គព្រះចេស្តា ព្រះបិតាឯកពាជ្យជាតិ
ទ្រង់ទំព្រឹងទ្វីឃ្លាត កសាងជាតិគ្មានឈប់ឈរ ។
ព្រះន័យត្រជាក់សាយ ទ្រង់ផ្សព្វផ្សាយដោយស្មោះសរ
ខ្ជូវត្រហ្វិហារធម៌ ដល់កូនចៅស្មើៗគ្នា ។
មិនថាតហបត៌ ពស្ត្រមន្ត្រីពជវន្ត្យ
ព្រះន័យស្និទ្ធស្នេហា គ្រប់តំបន់អស់ជាសាកល ។
ទ្រង់ទិតទំខ្វល់ខ្វាយ មិនដំនេញយព្រះកាយពល
វិស្វនរកសុកមន្តល ប្រថាន់ដល់គ្រប់កូនចៅ ។
កាលមុនធ្នាំហាបី ពស្ត្រប្រុសស្រីសោយសោកសៅ
រងទុក្ខកកកុញក្តៅ ដោយបរទេសជាន់ញាំញី ។
សម្តេចត្រែចលើលា ចាកភាពជាធានី
ហោះផ្ទៅលើតីវ៉ែ ទៅប្រទេសមហាអំណាច ។
ព្រះអង្គទ្រង់ប្រតាំង ទឹងថ្កាក់ឯយ៉ាងអង់អាច
តាមការយកអំណាច ឯកពាជ្យជាតិកម្ពុជា ។
មិនបានដួចបំណង ទ្រង់ហោះត្រឡប់ចូលសេមា
ចន្លើតខ្ជូវ ផែនការ· ព្រះសីហាធ្ងុ ល្បីខ្លាយខ្ចរ ។
ពស្ត្រខ្មែរប្រុសលានានាក់ មានចិត្តស្ម័គ្រស្មោះសរ
ក្រោកឈរច្រើនកុះករ តាមអំណាចមកត្រួតត្រា ។

ប្រជារាស្ត្រជាតិយើង កាន់តាំងក្តីនឹងឈើសង្ហា
មែកស្ងួនត្បូលាយគ្រា ចូលតវាយាំងគ្នាហាន ។
ចាក់ធ្លុះយើញជាក់ច្បាស់ កិតក័យណាស់ញាក់ញ័រប្រាណ
ចុះចាកពីត្រឹះស្ថាន ចូលបង្គំសុំជីវិត ។
ថ្វាយខ្លួនថ្វាយអំណាច ញ៉ាំបន្ទាយព្រះទ្រង់ឫទ្ធិ
ក្នុងថ្ងៃច្រាំបួនតិត វិច្ឆិកា ឆ្នាំហាបី (១) ។
ដោយគ្មានញាំងដំណក់ ឈាមឲ្យស្រក់លើផែនដី
នៃជាតិខ្មែរប្រុសស្រី មួយដំណក់គ្មានសោះណា ។
គ្រប់ស្តេចប្រមុខរដ្ឋ បានសន្មតថ្លែងថា
ព្រះសីហនុសព្វា អង្គទ្រង់បារមីប្លែង ។
ដោះជាតិពីទុក្ខព្រួយ លើកជាតិស្មួយទ្រូតម្តើង
បានខ្ពស់មុខមាត់ឡើង ដោយព្រះបញ្ញាបារមី ។
យៀកមិញពេញព្រឹក្សា ប៉ង់ច្រាថ្នាចូលវាតទី
ជិះជាន់បួនញាំញី យកទឹកដីរបស់ខ្មែរ ។
នៅខែត្របាត់ដំបង សត្រូវប៉ង់ឱនងាកក្រែរ
ផែនដីរបស់ខ្មែរ បញ្ចូលទៅប្រទេសវៀត ។
ព្រះបិតាសន្តិភាព ទេញបង្ក្រាបខ្មាំងពាលា

---

១) ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ។

ជីកនាំកស្តេច្រជា ច្រតិចត្តិការសោមគ្គី ។
ដោយមានលោកមេទ័ព តាមហៃជាប់ព្រះចក្រី
លោកឧត្តមសេនីយ លង់ ណុល ល្បីថ្លៃដៃខែន ។
សម្តេចព្រះបិតា ទ្រង់យាត្រាត្រង់កន្លែង
ជិតឆ្ងាយប្រឹងស្ទុះស្វែង រកសន្តិភាពជូនជាតិខ្មែរ ។
យាងមុខតង់ទេមរៈ ភូមិខ្ញុស្ត្រីស្មោះមិនបែរ
នារីជើរពលខ្មែរ ហៃតាន់តាប់ក្រោយព្រះអង្គ ។
យាងដោយព្រះឋាម ក្នុងអង្វាមិនបង្អង់
សំដៅឆ្ពោះទៅត្រង់ ទល់មុខខ្នាំងតាំងតរ ។
ទ្រង់យាងចូលទន្ទ្រាន លុកកុកកន្ទុកព្រឹក្សា
ឆ្លងត្រែកត្រែកព្រឹក្សា ហាលក្លៀងខ្យល់កំដៅថ្ងៃ ។
ព្រះទ័យត្រជាក់សាយ មិនដឹងណាយព្រះកាយថ្ងៃ
ស្ទុះស្វែងតំាងយប់ថ្ងៃ ការពារជាតិបានសុខសាន្ត ។
ឋារមីសម្តេចឥ ខ្នាំងសត្រូវតំាងប៉ុន្មាន
មិនអាចទប់ទល់ឋាន រត់ច្រាសច្រាណបន់ដូនតា ។
ក្រេះចេះនឹងស្ទឹងត្រែង យួនប្រឹងប្រែងប៉ងត្រួតត្រា
មិនខ្វាចរិទ្ធិពេស្តា ព្រះបិតាទ្រង់ឋារមី ។
កំទ្រង់ទំប្រឹងត្បៀត យាងទៅខៀតក័ក្តប្រឹមប្រិយ

កំចាត់ខ្មាំងតិរ័យ ចេញពីដីកម្ពុជា ។
សត្រូវចេញអស់ហើយ ខ្មែរបានស្បើយចាកវេទនា
ក្បួមក្បាច្ចបានត្រង់គ្នា រន្ធិលរ្យំពេញលោកា ។
មិនតែប៉ុណ្ណោះឯង ទ្រង់ប្រទានប្រែនទំនាក
ទាំដែនកម្ពុជា ចូលក្នុង អ្ង ស ប ជាតិ(១)។
ជារដ្ឋអព្យាក្រឹត ប្រាកដពិតឥតរាថ
ថ្វីដែរស្ដេចមិនឲ្យឃ្លាត កាន់ជាប់ស្ថិតបញ្ជាសិលា ។
ចង់ស្គាទរួមមេត្រី លោកសេរីប្ដូច្នាំ
និងលោកកុម្មុយនិស្ដណា ប្ដូច្នាំអស្ចារ្យក្រៃ ។
អព្យាក្រឹតខ្មែរល្អ ស្អាតបវរឥតកាខ្វៃ
មហាយក្សអបអរក្រៃ ស្ដេចបញ្ជាព្រះចក្រី ។
តេជៈអព្យាក្រឹត រដ្ឋន្ធាយ-ជិតប្ដូច្នាំល្អ
ចូលមកក្នុមមេត្រី តាំងខ្លួននៅជាសុខសាន្ដ ។
ប្រទេសនៅដិតខាង ធ្វើក្អែងក្អាងប្ដូតសាមាន្យ
មិនខ្វាចអំណាចក្បួន អព្យាក្រឹតរបស់ខ្មែរ
លើកទ័ពចាំងបំពាន លុកលុកពនៅក្បែរ ។

---

១) អ ស ប: អង្គការសហប្រជាជាតិ (ONU ; organisation des nations unies)

ជាយដែនរបស់ខ្មែរ ដែលជារដ្ឋភ្ជាប់ស្បៃនាម ។
សម្តេចប្រធាជអង់អាច មិនស្មុគស្មាញមេសង្គ្រាម
ដែលវាទំព្យាយាម ការសង្គ្រាមក្នុងលោកា ។
ទ្រង់ចេញតប្រឆាំង ដោយកម្លាំងព្រះបញ្ញា
ព្រះទីស្នាព្រះបិតា ហាកាលណាសង្គ្រាមស្ងប់ ។
បរទេសខៅជិតខាង ដែលក្អេងក្អាងកាលថ្ងៃយប់
ចុះញ៉ែមជាក់មុខជ្រប់ ធ្វើមុខជូរឈ្មោកមើលដី ។
សម្តេចព្រះអគ្គៈ មហាវីរៈទ្រង់ជាមេ
ដឹកនាំកស្ត្រេប្រុសស្រី ខ្លួមន្ត្រីគ្រប់ដំណែង ។
ខឹងអ្នកខនយោធាយ កបច្រាំដ្រាំយាំនវែងវែង
ចូលស្នូរជួយចាត់ចែង លើកតំកើងកម្ពុជា ។
ពួតដៃក្នុងសង្គម ពស្ត្រេនិយមរួមសាមគ្គា
តែមួយជួយគ្រប់គ្នា អ៊ុំនាវាតាមតម្រាយ ។
ហើយទ្រង់ប្រឹនប្រជៀ នាំកូនចៅឲ្យចំណាយ
កម្លាំងចិត្តនឹងកាយ ធ្វើខ្លួការហត្ថកម្ម ។
ព្រះអង្គទ្រង់ជាគ្រូ ធ្វើតំរូវលវង្ចាំ
កងការហត្ថកម្ម ដាំដើមឈើធ្វើសាលា ។
ជីកស្រះអណ្តូងទំក ពស្ត្រេងូតងឹតតាមចំន្លា

សែនដ៏ជាក់សាលា ធ្វើសួនផ្កាច្បារបវរ ។
លើកផ្លូវគមនាគមន៍ ព័ទ្ធកន្ទឹងឃុំដោយស្មោះសរ
ភ្ជួរស្រែខ្មែរត្រែកអរ ផ្តើលឈូឆដួយលើកគ្នា ។
ជីកស្រះប្រឡាយទឹក ខ្មែរសន្ធឹកប្រមូលមាមគ្នា
មន្ត្រីកស្ត្រប្រជា គ្រប់ ។ គ្នាចំប្រឹងប្រែង ។
ដោយការហត្ថកម្ម ផលដំណាំគ្រប់កន្លែង
បង្ហាញផលជាក់ស្តែង គ្រប់កន្លែងស្រែចំការ ។
អ្នកក្រទៅជាមាន ទ្រព្យធនធានមានច្រើមសារ
បរិភោគសុទ្ធអាហារ ធ្លាញ់ពិសារពេលៗថ្ងៃ ។
មានឡានមានកង់ជិះ យានជំនិះស៊ីវិល័យ
សប្បាយកាយចិត្តក្រៃ ស្មាព្រះហស្តព្រះចៅ ។
ប៉ែមានកស្ត្រប្រុសស្រី តហឋតីមន្ត្រីណា
កាន់ខ្លួកិរិយា ទុច្ចរិតកង់សង្គម ។
ប្រកាន់បក្សស្មោះធ្វេង វិលវង្វេងតាមពួកក្រុម
ឃ្លាតចាកច្បាប់សង្គម ពស្ត្រនិយមអព្យាក្រឹត ។
សម្តែចគ្រង់ប្រដៅ ខ្លួកក្លួនចៅនោះពិត ។
ឲ្យប្រែកែតំនិត ដំណាមកចាំងប្រុសស្រី ។
ព្រះច័យសែនត្រជាក់ ទឹកព្រះកត្តញ្ញាញ៉ាំមប្រិយ

រក្សាសីលប្រក្រតី ខ្មែរប្រុសស្រីស្និទ្ធស្នេហា ។
និងរកព្រះមហាក្សត្រ ជាមិត្តភក្តីចេះស្គា
ឋិតប្រមុខរដ្ឋណា ស្មើព្រះអង្គគ្មានសោះឡើយ ។
ប្រទេសជានសុខសាន្ត ខ្មែរគ្រប់ប្រជាជានរហើយ
ខុកខ្លួចឡើយគ្មានសោះឡើយ ស្នាព្រះហស្តមហាក្សត្រក្បាន្ត ។
សម្តេចមានគុណធ្ងន់ ធ្ងន់លើសលន់តន់ប្រមាណ
មិនអាចប្រៀបផ្ទឹមជាន តីគុណធ្ងន់លើសមាតា ។
ព្រះគុណធ្ងន់សែនធ្ងន់ ធ្ងន់លើសលន់ឥតឧបមា
ពលរដ្ឋជាតិខេមរា តែងគោរពព្រះចក្រី ។
ប្រសិនមានកូន-ចៅ ណាចិត្តភ្លេចពាលអប្រិយ
គោងកាចអន្សតិរ្ថិយ ហ៊ានប្រមាថព្រះចេស្តា ។
បង្កើតអសន្តិសុខ ក្នុងភូមិស្រុកនៃអាត្មា
កូនចៅនោះឈ្មោះថា អតតញ្ញូអាក្រក់ក្រៃ ។
រមែងតែងវិនាស ហ៊ានប្រ៉ាប់មាសមានតម្លៃ
រងខុកខ្លួចខែនាក្រៃ ពាល់យប់ថ្ងៃឥតស្រាកស្រាន្ត ។

បឧកាកកតិ

មាតាបិតា

គុណធ្ងន់ណាស់ណា ធ្ងន់ប្រៀបពុំបាន ធ្ងន់លើសទឹកដី

ប្រុសស្រីត្រប់ប្រាណ មិនអាចសងជាន គុណលោកតាំងទ្វី ។
មាសប៉ុនដូងខ្ញុំ
តវ្ចស់ស្មើភ្នំ សុមេរុតែរ ឬកែវមេកតិ
តេជវ័ន្តមណី ធំប៉ុនតែរ ថ្លៃពុំស្មើណា ។
បើកូនប្រុសស្រី
ណាមានចារមើ ឫទ្ធិវេស្ដា តំចាត់សត្រូវ
ដល់ខ្លួវបក លើកសួយមាតា. បិតាព័ន្ធប្រាណ ។
ជាស្ដេចមហាចក្រ
រុងរឿងអន័ន្ត ខ្ពង់ខ្ពស់ថ្កើងថ្កាន កិត្តិនាមល្បីឮ
រន្ទឺត្រប់ហាន មនុស្សយក្សត្រប់ប្រាណ ខ្លួបខ្លាចវេស្ដា ។
យ៉ាំងនេះកំដោយ
ព្រះពុទ្ធមិនឲ្យ កូនខោះឈ្មោះថា ជាអ្នកតបស្នង
សងគុណមាតា បិតាស្នេហា តាំងព័ន្ធខោះជាន ។
សម្ដេចបិតា
ប្រមុខរដ្ឋា តម្កល់ក្បែរក្បាន ទ្រង់មានព្រះគុណ
ធ្ងន់ពន់ប្រមាណ លើខ្នែរត្រប់ប្រាណ តូងតម្កល់ ។
ខុកស្មើមែន
ស្ដេចទ្រង់តាំងផ្ទៃ ប្រុសស្រីត្រប់គ្នា សាងប្រទេសជាតិ
ផុតឃ្លាតវៃ ភក្ដ្រែខ្នែរត្រប់គ្នា ជានសុខក្បែរក្បាន ។

បើកូនប្រុសស្រី

ណាពាលតំរិយ គោងកាចសាមាន្យ អកតញ្ញូ
ម្ហូរខ្ជូសន្ដាន តំយាតដល់ច្រាណ មាតាបិតា ។

ប្អូកស្ដ្រីមន្ដ្រី

ណាពាលតំរិយ ប្រមាថខេស្ដា ញ៉ាំងប្រទេសជាតិ
ក្រុមញាតិកា ធ្លាក់ក្នុងជលសា មហាតយន្ដរាយ ។

រីកូនប្រុសស្រី

ប្អូកស្ដ្រីមន្ដ្រី ខោះខឹងខ្ជាត់ខ្ជាយ ព្រាត់ច្រាសសោកសៅ
ខ្លុំក្ដៅក្រហាយ ស្រែកយំសោកស្ដាយ ក្នុងនាលោកិយ ។

លុះស្លាប់ច្យាត់ទៅ

ចាប់កំណើតនៅ នរកអវិចី ទោសខ្លាចម្ហែក
ធ្ងន់ម្ហែកសោកិយ ខ្លុំក្នុងអវិចី ខ្លុំក្រៀបពុំបាន ។

នរកអវិចី

គ្មានតួរតន្ដ្រី កំដរកំសាន្ដ មានតែសម្រែក
ស្ងូរស្រែកត្រែកច្រាណ ស្រែកគ្មានស្រាកស្រាន្ដ ច្រាណក្ដៅខ្លោចផ្សា ។

នរកអវិចី

នេះទៅប្រក្រតី ភក្ដ្រីទិព្វ អណ្ដាតសន្ធៅ
នេះទៅនោះណា ក្ដៅឥតឧបមា លើសក្ដៅលោកិយ ។

ពួកនិរយបាល

ខៅជានិច្ចកាល　　ចាំតែក្រញ៉ី　　ក់យវ័ធកាយា
ឥតគ្រាប្រណី　　កាប់ពុះសំរិះសើ　　ចំបែកសសាដ៍ ។

ចោះចូលរណ្តៅ

រត់លឿនសំដៅ　　មិនខៅរេរា　　ពួកនិរយបាល
ពុះក្បាលមរណា　　កើត·ស្លាប់ស្ទុះវារ　　ក្នុងភ្លើងនោះឯង ។

កើតស្លាប់កើតស្លាប់

លំបាកយ៉ាកយ៉ាប់　　ខៅជាអង្វែង　　ទុក្ខជូនអនេក
ភ្លើងបែកជាផ្សែង　　នេះគ្រប់កន្លែង　　ជាអចិន្ត្រៃ ។

នរកអវិចី

ទុក្ខជាប្រក្រតី　　យូរយោពេកក្រៃ　　អាយុមួយកប្ប
ឥតកប់ខ្វៃខ្វៃ　　មានតែទុបមេយ្យ　　តាមព្រះសម្ពុទ្ធ

រួចពីអវិចី

ជាប្រេតអប្រិយ　　ឆ័ន្ទុះឈាមឯង　　ភ្លើងនេះអណ្តាត
ក្អែកត្មាតទឹងខ្វែង　　ចំពុះខុងដែង　　តាមចឹកក្រញ៉ី ។

រួចពីប្រេតត្រិរ្ឋាណ

ចាប់តំណើតជាន　　ជាគោក្របី　　ចំរើអ្នកស្រុក
ជាទុក្ខប្រក្រតី　　ឬមានទំពាត្រី　　ស្មៅអាំងប្រឡាក់ ។

ប្តូរព័ត៌វច្ចាន

ចាប់កំណើតបាន ជាមនុស្សគ្រមតាត់ ដំបៅពកយូរំ
ខ្ញុំនឹងដើរឆាក់ ក្បែរតាំងពីរខ្លាក់ កក្ងិតកង្វក់ក្បែរ ។
ប្តូរឆ្កែលាលា
ព្រោះគោសាងជា អ្នកមានគុណឯង ប្រមាថមើលងាយ
និយាយចាត់ចែង ឥតគោតឥតក្រែង តែងប្លាក់អាម៉ែ ។
ដូចទុកជាវណ៌
រឿងកាវយ៉ាងល្អ នៅក្នុងបាលី ខ្ញុំជ្រាវរកវក
នាំមកស្រដី កាត់បំព្រួញខ្លី ស្តីអត់ច្បាយ ។
(នៅមានត)

បំណោទគំនិតទី ៣

ក្នុងក្រុមអ្នកបំរើជាតិចាំង ៣៣ នាក់ ខ្ញុំជាអ្នកទី ៣៣ ។ ប្រសិនបើគ្មានខ្ញុំទេ កុំពេញក្តី ខេត្រចាត់ដំបងក្តី- កំពង់ចាមក្តី កំពតក្តី កំពង់ឆ្នាំងក្តី កំពង់ធំក្តី កំពង់ស្តីក្តី ឥណ្ឌមិនមានខ្សែយ ។ តើខ្ញុំជាអ្វី ?

មិត្តអ្នកអាន ណារកឃើញមុខគេនឹងកុះផ្សាយសេចក្តីសរសើរ ក្នុងទស្សនាវដ្តីយើង

រីមហាក្សត្រទាំង ៤ ព្រះអង្គ សឹងតែសរសើរសើរសើលអាត្មាឯងទើរ ។ ថា ប្រសើរលើសគ្នា ខ្លួវប្រការអម្បាលនោះហើយ អណ្តាច់នោះ សម្តេចឥន្ទ្រាធិរាជ មានព្រះបន្ទូលដណ្តឹងទៅព្រះបាទធនញ្ជ័យ កោរព្យាកដថា នែព្រះបាទធនញ្ជ័យ កោរព្យាកដ ក្នុងនគរអ្នក តើមានអ្នកប្រាជ្ញឬទេ ហើយអ្នកថា បើអ្នកប្រាជ្ញមានហើយ យើងនឹងឲ្យទៅអញ្ជើញ អ្នកកាត់សន្ធិះកង្ខានេះឲ្យយើង ថាបើកើតសេចក្តីវែងទាំងអម្បាលនេះ នៅនាក្រែត្រីឆ្ងាយមិញ ឈ្លាឆ្លាយ អញឯងនឹងស្រាលជ្រើសរើសកេខេរបុត្រឯណា ១ មានប្រាជ្ញា ឲ្យមកកាត់សន្ធិះកង្ខានេះឲ្យយើង ១ សោត ថាបើកើតសេចក្តីវែងទាំងអម្បាលនេះ នៅនាបុង្គរកោនគរពិតពព្រះបាទសុបណ្ណគ្រុឌកដនាយមិញ ឈ្លាឆ្លាយ ឯព្រះបាទសុបណ្ណគ្រុឌកដ ជ្រើសរើសរកបក្សីបក្សាឯណា ១ មានប្រាជ្ញា មកកាត់សន្ធិះកង្ខាឲ្យយើង មួយសោត ថាបើសេចក្តីវែងទាំងអម្បាលនេះ នៅនាពិតពនាគនាយមិញ ឈ្លាឆ្លាយ ឯព្រះបាទឥរាណានាគរាជ ឱឍ ជ្រើសរើសរកនាគីនាគា មច្ឆាឯណាមួយមានប្រាជ្ញា មកកាត់សន្ធិះកង្ខានេះឲ្យយើង ។ ឥឡូវនេះ តើតមានសេចក្តីវែងទាំងអម្បាលនេះ ក្នុងខេត្តឯណានគរ ព្រះបាទធនញ្ជ័យកោរព្យាកដ ឯប្របាទធនញ្ជ័យ ត្រូវរកអ្នកប្រាជ្ញឲ្យកាត់សន្ធិះកង្ខា ថានែ ប្របាទធនញ្ជ័យ កោរព្យាកដ

ឯអ្នកប្រាជ្ញតើមានឬទេ ? អ្នកស្តាប់ពាក្យនេះ ប្រថាទនឥញ្ជ័យ គោរព្យាកដ
ឆ្លើយថាមហាកដ នាអ្នកប្រាជ្ញខ្ញុំនោះ ឈ្មោះចៅពិធូរអ្នកប្រាជ្ញ តែង
ឱនប្រដៅដមិអាថ៌ សេចក្តីលោភ័យ លោភ ជាគ្នាក់ជាសត្តូចៃខ្ញុំឯង
ក៏ចៅអ្នកប្រាជ្ញនោះឱនចន្ទោបន៍ទូរសន្ទុះកង្វានេះឲ្យយើង គួរយើងឱនចៅ
កាន់សំណាក់ចៅពិធូរអ្នកប្រាជ្ញហោង រមហាក្សត្រ ៣ ព្រះអង្គ នោះ
សឹងស្តាប់ហើយ មានព្រះហឫទ័យនោះត្រេកអរសាទរពេកហោង ។ ម្ល៉ោះ
ហើយ មហាក្សត្រ ៤ ព្រះអង្គនោះ នាំគ្នាលីលាចេញចៅអំពីព្រៃទ្យាន
ចៅកាន់ធម្មសភាសាលា ហើយឲ្យចៅអញ្ជើញព្រាពោធិសត្វ ។ រំពោធិសត្វ
សោត អ្នកស្តៀកស ស្តាយឈៀងស ប្រជាប់ប្រជាអាត្មាស្រេចហើយ
អញ្ជើញឲ្យឡើងគង់លើត្រែខែនទិព្វ ប្រជាប់ប្រសើរ ហើយមហាក្សត្រ
ចាំង ៤ ព្រះអង្គ ធ្វើការប្រស្រ័យសួរទូលពតិមានសុខទុក្ខអ្វី ។ សឹងនៅ
ស្តាយឮដសមគួរនឹងអាត្មាទីណៃ ។ ហើយទើបថា ណៃ ចៅពិធូរអ្នកប្រាជ្ញ
យើងកើតមានសន្ទុះកង្វា ចូរចៅបន្ទោបន៍ឲ្យយើងហោង ។ មហាក្សត្រមិន
បន្ទូលទេឡើយ សូត្រជាបទគាថា ៖ បុព្វេ ច កតការ មនោមបញ្ញំ ។ ណៃ
ចៅពិធូរអ្នកប្រាជ្ញអើយ ឥឡូវនេះ យើងមានពាក្យដំណោះប្រកែកដដែក
ឱនស័លធង្គា កើតនៅនាយើងចាំង ៤ នេះ កំយើងមកដណ្តើងចៅជា
អ្នកប្រាជ្ញ អាចដឹងខុសដឹងគាប់ ដឹងគួរពុំគួរ ចៅសោតមានប្រាជ្ញា
ច្រើនឥតអ្នកឯណាមួយ ឱនស្មើបានឡើយ ចូរចៅកាត់សន្ទុះកង្វា ពាក្យ

វិចិកិច្ឆា តើតមានក្នុងចិត្តយើងខ្ញុំ ឲ្យជ្រះស្រឡះឲ្យយើងហោង នា
យើងទាំង ៤ នេះសោត ទើងទូន្មរួចអំពីពាក្យសន្ទិះកង្ខា ដោយសារប្រាជ្ញ
ទៅហោង ។ អណ្តាប់នោះ ពោធិសត្វស្តាប់បន្ទូលមហាក្សត្រទាំង ៤ ព្រះ
អង្គហើយ អ្នកឆ្លើយថាបពិត្រមហាកជ ខ្ញុំពុំទាន់ដឹងព្រះបន្ទូលព្រះអង្គឯ
ណា បន្ទូលតាប់ ព្រះអង្គឯណាបន្ទូលមិនតាប់ នាតើតវ៉ាទ ឈ្លោះប្រកែក
ជជែកគ្នាទាំងអម្បាលនេះ ហេតុដ្បិតតែគាស្រ័យនឹងសីលព្រះអង្គទ័ទៃ ។
ហោង ។ ពោធិសត្វមិនស្រដីទេឡើយ សូត្រជាបទគាថា: យេ ប ឥស្ថិ
តា អត្ថទស្សា កវិទ្ធី ។ ថាបពិត្រមហាកជទុតមកទ្វង វៃក្រៃលែង
នៃក្សត្រទង់ទាំងឡាយអើយ នរអ្នកប្រាជ្ញឯណា ។ មានប្រាជ្ញាឈ្វៃតែង
នឹងយល់សរតើសេចក្តីផងទាំងឡាយសឹងពិចារណា ដោយដំណើរពាក្យ
តិះដៀល មានសេចក្តីគេប្រាប់នោះហោង ថាបើអ្នកដឹងសេចក្តីនោះ
ពុំទាន់សំដែងថ្វែងប្រាប់ដើមសេចក្តីឡើយ រីអ្នកប្រាជ្ញទើងពិចារណា សេចក្តី
ម្តេចបាន ព្រះអង្គ ។ រីព្រះបាទពរុណនាគរាជ តើមានយោបល់ដូចម្តេច
ព្រះបាទសុបណ្ណគ្រុឌរាជ តើមានព្រះបន្ទូលដូចម្តេច រីសេម្តេចព្រះឥន្ទ្រាធិ
រាជ តើមានព្រះបន្ទូលដូចម្តេច ព្រះបាទធនញ្ជ័យកោរព្យរាជដ៏ជាម្ចាស់
ខ្ញុំនោះ តើមានព្រះបន្ទូលដូចម្តេច? លំដាប់នោះ មហាក្សត្រទាំង ៤ ព្រះ
អង្គ សឹងសូត្រជាបទព្រះគាថាប្រាប់ទៅ ពោធិសត្វថា : ១ ឆ្លិ ហាវេ
គាសតិ ឆាកកជា ។ ព្រះបាទពរុណនាគរាជ ប្រាប់ថា ម្នៃហៅតិចូរ

អ្នកប្រាជ្ញអើយ អញនេះមានចិត្តអំណាត់អត់មិនខឹង ទើសត្រូវឡើយ ព្រះ
ចាខសុបណ្ណគ្រុឌពាជប្រាប់ថា ម្នៃចៅពិធូរអ្នកប្រាជ្ញអើយ អញនេះមាន
ចិត្តអំណាត់អត់ខ្លួសសំរេតំលាខផង សម្តែចឥន្ទ្រាធិពាជសរសើរប្រាប់ថា
ម្នៃចៅពិធូរអ្នកប្រាជ្ញអើយ អញនេះប្រាសលះបង់ខ្លួបញ្ញាគាមគុណ ទើប
ប្រសើរ ព្រះចាខធនញ្ជ័យពោរព្យាពាជ ប្រាប់ថា ចៅពិធូរចាអ្នកប្រាជ្ញ
អើយ អញនេះប្រឡែងលែងបង់ខ្លួរស្រីព្រះស្តេក្រមការបរិភោរផង មាន
កង្វល់អំពល់តិចឡើយ ។ រីពោធិសត្វស្តាប់ ព្រះបន្ទូលព្រះមហាសត្វត្រ
តាំង ៤ ព្រះអង្គ សរសើរដំណើរសីលអាត្មាទីម្តៃ ។ សំដែងថ្លែងប្រាប់
អម្បាលនោះហើយ ទើបព្រះអង្គពោធិសត្វ អ្នកសូត្រជាបទព្រះគាថា :
សញ្ញមិ ឯតាមិ សុភាសិតាមិ ។ បពិត្រមហាពាជតាំង ៤ ព្រះអង្គ
អើយខាព្រះអង្គ មានព្រះបន្ទូលនោះពីរោះ ។ តេក ខឹងរកព្រះអង្គឯណា
មានព្រះបន្ទូលមិនពីរោះដល់តិចនោះគ្មានឡើយ មហាពាជអើយ ខាតំណើត
គុណសីលតាំង ៤ ចំពូកនោះ ថាបើស្តិតនៅបុគ្គលឯណាហើយ ។ បុគ្គល
នោះ ប្រសើរក្រៃតេកហាង មហាពាជ ខ្ញុំខឹងពុំហ៊ានខ្លួលទេ ខ្លួលថ្លាយនោះ
ក្រែងពុំសព្វព្រះពាជហឫទ័យ ដូច្នេះខ្ញុំខឹង ។ បមាថ្លាយវិញ នោះទើបព្រះអង្គ
សព្វព្រះពាជហឫទ័យថ្លៃវិសេសជាន មហាពាជ ព្រះអង្គបន្ទូលនេះ តំណឹង
តែចាំសីលនោះស្មើគ្នា ។ បមាដូចជាងធ្វើតង់រនេះ កាលណាបើតាត់ឈើ
អំពីព្រៃមកហើយ យកមកចាំងគោសរូសចេញស្រួច ស្រាប់តាបបោះ

បញ្ចូលកាប់ពាក់កន្ទំផ្ចង់ស្រេច សឹងតែឈើទំនៃ ១ ខ័ន្ធគ្នា តតែ ១ ដុំ ធ្ងន់ ក្រាច អាចមកក្រឡឹងផងខ័ន្ធគ្នានោះ ពោះយោបល់ខ័ន្ធចាក់ក្បាច់ម្តេច ។ ក្តី តតមានជម្ងោះប្រកែកជជែកខ័ន្ធគ្នាដល់តិចឡើយ ឯតតែខ័ន្ធថាអញជាតតែ ការណ៍អ្វីខ័ន្ធទៅរត់ក្រលឹង ខ័ន្ធ ១ ដុំ ឯធ្ងន់ខ័ន្ធថាអញជាធ្ងន់ ការណ៍អ្វី អញខ័ន្ធទៅរត់ក្រឡឹងខ័ន្ធក្រាច មហាកជមិនដែលមានតតថាដូច្នោះឡើយ សឹងតែរត់ក្រឡឹងស្មើគ្នា ឯសិលមហាកជ ចាំង ៤ ព្រះអង្គនោះ សឹងស្មើគ្នា ហោង មហាកជអើយ អ្នកឯណាថាបើបានស្តែតដោយខ្លួនមិចាំង ៤ ជំពូកនេះហើយ រីអ្នកនោះសឹងថាជាប្រសើរសមតួតមថ្ងៃ ឮដល់លោកនេះ ហោង ។ រីមហាក្សត្រចាំង ៤ ព្រះអង្គនោះសោត ស្តាប់ពាក្យពោធិសត្វ ហើយ មានព្រះរាជហឫទ័យនោះត្រេកអរសោនរៃត្រេកត ហើយសរសើរ ចម្ងើយធ្វើយប្រស្នានៃពោធិសត្វសូត្រជាបទព្រះគាថា : តុវំ ឧ សេ ជ្ញា ភូមឧត្តភេ សី ។ ថាបៃហៅពិធូរអ្នកប្រាជ្ញអើយ ហៅប្រសើរអ្វីមាលាយ ហៅចេះធម៌ ហៅដឹងធម៌ ហៅជាអ្នកប្រាជ្ញ - អាចកាត់សង្ខ័យកង្វា វិចិកិច្ឆា នៃយើង អ្វីខ័ន្ធមានទើសខាល់សល់ជំពាក់ដល់តិចនោះគ្មានឡើយ ។ បម ដូចជាដ៏អាកុក មានណារមុតមាំល្អ អារជាច់រឿក មិនឲ្យមាន ស្រែកគល់មួយចំណិតសក់ឡើយ មហាក្សត្រចាំង ៤ ព្រះអង្គ សឹងសរ សើរពោធិសត្វ ខ្លួរប្រការអម្បាលនោះហើយ អណ្តាប់នោះ សម្តេចឥន្ទ្រា ធិរាជសឹងយកសំពត់ខ្មុកលិខ្ញ មានសាច់នោះស្តើងដូចផ្សែងក្តៅ ខៀវ

ស្ត្ច ដូចដ្ឋាន់លបុស្សប្រាសលែងមន្ទិល ខឹងកាត់ថ្លៃពុំបានឡើយ ហើយបួ-
ជាធម៌ទេសនាហោង រ៉ព្រះបាទសុបណ្ណគ្រុឌជ សឹងយកសុពណ៌មាលា
មាសបូជាពោធិសត្វសូត្រជាបទព្រះគាថា: សុវណ្ណមាលំ សតបត្ត
ជលំ ជាហៃហៅតាំងពួរអ្នកប្រាជ្ញអើយ អញត្រេកអរនឹងចម្ងើយប្រស្នាហៅ
ហើយអញយកនូវសុពណ៌មាលាមាសដ៏មានត្រចកនោះ ១០០ ស្រាប់
ដ៏មានកេសរនោះរំលេចរចនា ន័ហៅនូវតន:នោះមួយពាន់ អញបូជាធម្ម
ទេសនាហៅហោង រ៉ព្រះបាទពរុណនាគរាជ យកតែរមនីរត្ន ខឹងកាត់ថ្លៃពុំ
បានឡើយ សឹងមានពន្ធីរស្មី ដូចភ្លើងរុងរឿង បង្កើតតេជៈជារគ្រឿងប្រដាប់
សំរាប់ព្រះសូរិន្ទនោះ អញយកមកបូជាធម្មទេស្នាហៅហោង ។ រ៉ព្រះបាទ
ធនញ្ជ័យកោរព្យរាជ សឹងយកដំរីសេះ រទេះ ក្រប៉ ជូជាធម្មទេស្នាពោធិ
សត្វ សូត្រជាបទព្រះគាថា: តវំ សហស្ស ឧសភញ្ញជានំ ។ ហៃ
ហៅតាំងពួរអ្នកប្រាជ្ញអើយ អាត្មាត្រេកអរ ខឹងចម្ងើយហៅហើយ អញយក
គោឧសភរាជមួយពាន់ នូវដំរី ជាប្រសើរថ្លៃ នូវរទេះធំមសេះ ១០ នូវស្រុក
ធំ ១៦ បូជាធម្មទេស្នាហៅហោង ។ រ៉មហាក្សត្រទាំងបួនព្រះអង្គ បូជា
ធម្មទេស្នាពោធិសត្វស្រេចហើយ លាហៅកាន់ព្រះនគរ អាត្មាខ្ញុំ ។
ហោង ។ សីលវិភាឧកល្ហាំ ឯដ្ឋតិ រ៉ខឹងស្រដ៏ព្រះមហាក្សត្រទាំង ៤
វិភាទសីលខឹងគ្នានោះ ពោធិសត្វអ្នកកាត់សេចក្តីមិញ កំស្រេចនូវប្រការអំ
ពាលនេះហោង ។ តេសុ ជាតកជសុ្ស កវិយា វិមលាទេវី-

ជាម ។ បពិត្រអើយ នាមហាសុត្រតាំង ៣ នោះ យើងមិនស្រដីឡើយ
យើងនឹងស្រដីតែព្រះបាទតុណនាគរាជ កាលបើបានទៅដល់តាកតនាគ
នាយហើយ ព្រះបាទតុណនាគរាជនោះ មានព្រះរាជទេវី ១ ព្រះអង្គ
ទ្រង់ព្រះនាមឈ្មោះនាងវិមលា ទេវី នាងវិមលាមើលពុំឃើញលំពែរមណីរត្ន
នៅព្រះសូរង្គព្រះបាទតុណនាគរាជនោះ ដូច្នោះហើយ បានដណ្តឹងថា
បពិត្រព្រះសម្មតិទេព មហារាជអើយ នាគែរមណីរត្នៈជាគ្រឿងប្រដាប់សំ
រាប់ ព្រះសូរង្គព្រះអង្គ តើបាត់ទៅឯណា ពុំឃើញហ៎ះ ? រីព្រះបាទតុណ
នាគរាជស្តាប់ហើយ ទ្រង់ឃើញថា ម្នែនាងវិមលាទេវីអើយ នាកាលអញ
ឡើងទៅកាន់មនុស្សលោកនាយនោះ កំអញបានស្តាប់ធម៌ទេសនា ចៅពិ
ធូរអ្នកប្រាជ្ញ ជាកូននៃបទុព្រាហ្មណ៍នោះ នាងអើយពាក្យសោះសា ក្រែ
ពេក នាងអើយអញពុំអាច ដើម្បីទប់ទល់អាត្មាភាពនោះបានឡើយ អញ
យកែរមណីរត្នៈនោះ បូជាធម៌ទេសនានៃចៅពិធូរអ្នកប្រាជ្ញ នាងអើយមិន
ប៉ុន្មែនអញឡើយ សម្តេចឥន្ទ្រាធិរាជក៏យកសំពត់ទុកុលទិព្វ បូជាធម៌ទេ-
ស្នា ចៅពិធូរអ្នកប្រាជ្ញ រីព្រះបាទសុបណ្ណគ្រុឌរាជ យកសុពណ៌ាភរណ
មាលាមាស បូជាធម្មទេស្នាចៅពិធូរអ្នកប្រាជ្ញ រីព្រះបាទធនញ្ជ័យ
កោរព្យរាជ យកគោ ១សែនរាជមួយពាន់ ខ្ចីរាជ៍ជ័យ ខ្ចីរាទេះចំបាំសេះ
១០ ខ្នើសេះធំ ១៦ បូជាធម៌ ចៅពិធូរអ្នកប្រាជ្ញដែរ ។ នាងអើយ រីចៅ
ពិធូរអ្នកប្រាជ្ញនោះ ចេះសំដែងធម្មទេស្នាផ្ចង់ស្លាមពាក្យសោះសាមហិមា

ក្រៃពេក នាងអើយ រឹតសំស្តេចតាំងអង្គុងសកលជម្ពូទ្វីបនោះ តែងចូលចិត្តចង់ស្តាប់ធម្មទេស្នា មិនអាចដើម្បីនឹងទៅកាន់ស្ថានលំនៅអាត្មាឯងបានឡើយ ដ្បិតចក្កលក្ខវាឡុះប្រែន នោះមកចង់ស្តាប់សព្ទពិន ព្រះបាទខេនកជ មិនអាចដើម្បីនឹងទៅកាន់ស្ថានលំនៅកន្លែងអាត្មាបានឡើយ ឯណោះ ឯនាងវិមលាទេវី ឮពាក្យថា ចៅពិធូរអ្នកប្រាជ្ញចេះសំដែងប្លែងធម៌ទេសនានោះផ្អែមល្ហែមពិរោះដូច្នោះហើយ នាងគិតក្នុងព្រះកជហឫទ័យ នៃនាងនឹងចង់ស្តាប់ធម្មទេស្នាចៅពិធូរអ្នកប្រាជ្ញនោះ ទៅរំហើយនាងថ្វាយបង្គំប្រណម្យខ្លួន ព្រះបាទពុរាណនាគរាជ ថាបពិត្រព្រះសម្មតិទេពមហាកជក្សត្រថ្លៃប្រសើរអើយ សូមទានព្រះអង្គឲ្យទៅនាំចៅពិធូរអ្នកប្រាជ្ញនោះមកឲ្យសំដែងធម្មទេស្នា ហើយខ្ញុំនឹងស្តាប់បន្តិចហ: ព្រះបាទពុរាណនាគរាជស្តាប់ពាក្យនាងវិមលាទេវី ស្រដីដូច្នោះហើយ ព្រះអង្គឆ្លើយតបទៅវិញថា ម្នាលនាងវិមលាទេវី នាងអើយ ឥតអ្នកឯណា ១ ក៏នឹងអាចទៅនាំចៅពិធូរអ្នកប្រាជ្ញនោះមកអំពីកណ្តាលដំខុំអស់ស្តេចមួយរយ ទឹង ១ នោះមកដល់ពិភពនាគនេះបានឡើយ នាងអើយ មានស្តេចមួយរយ ទឹង ១ ខ្លួនជាអង្គុង ក្នុងសកលជម្ពូទ្វីប តែងនឹងស្តាប់ធម្មទេស្នាកម្រៃកអ្នកឯណាក៏នឹងទៅនាំមកបានឡើយ នាងថា ចៅពិធូរអ្នកប្រាជ្ញនោះ ងាយដោយតាមនាង ។ ស្រដីម្តេចដូច្នោះ ។ នាងវិមលាទេវីស្តាប់ព្រះបន្ទូលព្រះបាទពុរាណនាគរាជ ខ្លួរប្រការអំបាលនោះហើយ ទើបនាងមានយោបល់

ទ្រូងយល់ក្តីព្រះកដហប្ញទ័យក្សត្រីនាងថា បើអញស្រដីតែពាក្យខ្លះខ្លោះ
មិនបានអេះ ថាបើអញធ្វើជាឈឺ ថាអញចង់ស៊ីថ្នើមចៅពីជូរអ្នកប្រាជ្ញខ្លោះ
វិញហើយតើ ស្តេចនឹងលែងទៅយកឲ្យអញបានហះ ការណាបើនាង
គិតនូវប្រការអំបាលនោះហើយ នាងធ្វើជាឈឺធ្ងន់ ៗ ពន់ប្រមាណ នាង
ចូលទៅកន្លែងមានសិរីសួស្តី ហើយនាងផ្តាំអស់ស្រីព្រះស្នំផងតាំង-
ឡាយថា ម្នាលគ្នាយើងផងតាំងឡាយអើយ ថាបើព្រះមហាក្សត្រ
ស្តេចមានព្រះបន្ទូលរកអញ ចូរអ្នកតាំងឡាយថ្វាយបង្គំប្រណម្យទូលឲ្យ
បានទ្រង់ជ្រាបថាអញមានជម្ងឺឈឺធ្ងន់ពន់ប្រមាណ នាងផ្តាំអស់ស្រី ។
ព្រះស្នំអំបាលនោះហើយ ទើបនាងចូលទៅផ្ទំ លើក្រឡាព្រះបន្ទំបរម-
សុខសួស្តីហោង ។ ព្រះចាតពុណាគាមជ ទតព្រះនេត្រស្មោះឆ្ពោះទៅមិន
យល់នាងវិមលាទេវីមកគង់ ដូចកាលប្រក្រតីឡើយ ទើបស្តេចមានព្រះ
ពាក្យទន្លាយដណ្តឹងទៅកាន់អស់ស្រីតាំងឡាយ ថាហៃអស់គ្នាយើងតាំង
ឡាយអើយ នែនាងវិមលាទេវី តើនាងទៅឯណា កំមិនមកគាល់អញដូច
ប្រក្រតីសព្វមួយដង អស់ស្រីតាំងឡាយ ក្រាបថ្វាយបង្គំប្រណម្យទូល
ថាបពិត្រព្រះសម្មតិទេពមហាពដអើយ ព្រះអង្គមិនជ្រាបសភាពជានាង
អផ្សុកទេហះ ។ ព្រះអង្គ ស្តេចស្តាប់ហើយឆ្លើយថា អញមិនដឹងឡើយ ។
យីព្រះអង្គអើយ នាងមានជម្ងឺ អផ្សុកជាទុក្ខតិចអីព្រះអង្គ ។ ព្រះចាតពុណ
នាគពដ ព្រះអង្គជ្រាបសភាពជានាងវិមលាទេវី អផ្សុកដូច្នោះហើយ

ព្រះអង្គមិនអាចដើម្បីនឹងចប់ចេល់ដំណាលអាត្មាភាពនោះបានឡើយ ស្តេចលាចូលទៅ ក្នុងព្រះកជមន្ទីរហើយ ស្តេចគង់ខាងត្រែក្រឡាបខ្ញុំ នាងវិមលាទេវីហើយ ស្តេចយកព្រះហស្តថ្លៃមកបោសអង្អែលព្រះសិរសីនាងហើយ មានព្រះបន្ទូលដណ្តឹងទៅ សូត្រជាបទព្រះគាថា: បណ្ឌាកាសិ យា សិ ឧត្តលា វិមលេ ។ ម្នៃនាងវិមលាទេវី ដំណាស្រីមានរូបទ្រង់គួរមសមខ្លួនរលក្ខណា នាងមានរូបនោះល្អ កម្រមាន ៦ នៅនាពិភពនាតនេះ វិមលានាងមានជម្ងឺឈឺអីហើយនាង នាងឈឺក្បាលឬនាងឈឺថ្លើ ឬមួយនាងឈឺអស់សរសៃតាំង ៣០ នាងមិនច្រាបចង ។ ទើរតេទ្យរមមុតនាប់ឆុត មកកក្តាំចាប់ចាប់ក្បាដោះចេញជម្ងឺអំពីអាត្មានាង វិមលា ហេតុអ្វីនាងមានរូបនោះស្តាំងស្តមថយកម្លាំង ខ្សោងតាំងសម្បារមិនយល់ ដូចអំពីមុន យល់ចំថ្លែកថ្លូកនឹងក្អែកបងហ៊ះណានាង ។ នាងវិមលាទេវីស្តាប់ព្រះបន្ទូល ព្រះបាទពុណនាគាជ ខ្លួវប្រការអម្បាលនោះហើយ ថ្វាយបង្គំប្រណម្យទូលថៅមហាក្សត្រសូត្រជាបទព្រះគាថា: ឧម្មោ មនុជេសុ មាតីទំ ជនិន្ទ ។ ម្នាលត្រព្រះអង្គដំណាស្តេចធំទ្រង់មកក្នុងនៃអ្នកជងតាំងឡាយអើយ ធម្មតាកើតជាស្រីនៅនាលោកយ៉ាងនេះហើយ រីអ្នកប្រាជ្ញជងអំពីបុរាណ លោកពោលថា មានចំណង់ស្រី ៣ ប្រការ: ចំណង់មួយនោះ បងឲ្យមានប្តី ចំណង់មួយមានប្តីហើយ ហាក់តែចិត្តបងឲ្យប្តីនោះមានយសក្តិឲ្យសក្តិទ្រង់ក្តីទ្រង់ថ្លៃក្រលែងអ្នកធងតាំងឡាយ រីចំណង់មួយ

ចង់ឲ្យមានសម្បត្តិច្រើនឲ្យបានច្រើន ហើយខ្ញុំចង់ប្រដាប់ស្អាតឲ្យថ្លៃថ្នូរក្នុងរឿងប្រពៃ រីឯណាំមួយនោះ ក្រៃលែងខ្លាំងណាស់ ស្រី ៣ ប្រការ ដាក់ក្បាល បតិព្រះអង្គដ៏ជាធំឧត្តមក្រៃលែងអ្នកផងទាំងឡាយអើយ រីឯថ្លៃថ្នូ ចំណាំខ្ញុំមួយនោះ ក្រៃវិសេសក្រៃលែងខ្លាំងណាស់ស្រី ៣ ប្រការនោះ កាលខ្ញុំចាប់ផ្តើមមានជម្ងឺឈឺនោះ៧សាបមាត់ខ្ញុំ រីសាបមាត់គេទាំងឡាយ គេចង់ឆ្ងាយ ព្រះអង្គអើយ រីសាបមាត់ខ្ញុំនេះ ពុំដូចកាលដាលជាចង់ឆ្ងាយ ឯថ្នើមចៅពាំងដូរអ្នកប្រាជ្ញវិញ អាចបានមកដោយខ្លួនមិនខ្ញុំឆ្ងាយថ្នើមចៅពាំងដូរអ្នកប្រាជ្ញនោះ ថាបើពុំបានទាំមកដោយខ្លួនមិនឲ្យខ្ញុំឆ្ងាយថ្នើមចៅពាំងដូរអ្នកប្រាជ្ញនោះឡើយ ក៏ខ្ញុំនឹងស្វាយបង់ចោលព្រះអង្គដ៏ជាតម្លៃនក្រឡានោះ ប្រាកដហោង ។ ឯព្រះចាតុរណាគតជ ស្តាប់នាងវិមលាស្រីដូច្នោះហើយ ព្រះអង្គលោមនាង សូត្រជាបទព្រះគាថា : ចន្ទំ ខោ ភ្ញិ វិមលេ នោ មាឧប្បាយសិ ។ ថាវៃមានិវិមលាទេវីប្អូនស្រីសម្លាញ់បងអើយ នាងប្រាថ្នាបង់យល់ព្រះអាទិត្យ ព្រះច័ន្ទ តាកបាន បងនឹងប្រែកាឡា និម្មិតអាត្ម ជាព្រះអាទិត្យ ព្រះច័ន្ទ បងនឹងឲ្យនាងយល់ដឹងព្រះអាទិត្យ ព្រះច័ន្ទ កម្រមាន ខ្លួកិកពនាគនេះ ចូរនាងប្រាថ្នាបង់យល់ឲ្យលាស់អស់ឥតអ្នកទៅ៎ កំបងនឹងត្រកងថ្នមនាងឡើង ឲ្យអស់ស្រីព្រះស្ងួសៅដែងទាំងឡាយ កាន់ខ្លួរធ្លុតកន្ទុយសត្វ មកបក់ថ្នាយនាងហើយ បងនឹងបង្ហាញនាងថា នាងអើយនេះឯងហៅឲ្យលាស់ឥតអង្គនិមល

ឥឡូវនេះនាងក្រាបថ្វាយបង្គំសុំថ្វែមចៅពិធូរអ្នកក្រាបូនោះ នាងអើយតែគួរចៅពិធូរអ្នកក្រាបូនោះមិញ កម្រនឹងបានយល់ហ៊ានចំណងបើថ្វែមចៅពិធូរអ្នកក្រាបូនោះ មហាកម្រក្រៃណាស់ហោង នាងអើយកម្រអ្នកឯណាមួយ មានអំណាចនឹងអាចចៅនាំចៅពិធូរអ្នកក្រាបូនោះ បានមកដល់ពិភពនេះឡើយ ។ ឯនាងវិមលាទេវីនោះ ស្តាប់ព្រះបន្ទូល ព្រះបាទពរុណនាគរាជ ខ្លូវប្រកាអម្បាលនោះហើយ ក្សត្រីនាងគិតក្នុងចិត្តឯងថា បើអញមិនបានស្តាប់ធម៌ទេសនានៃចៅពិធូរអ្នកក្រាបូនោះឡើយ សំអញក្រែងជីវិត ក្រាកដកាលឥឡូវនេះឯងពុំខានឡើយ ។ នាងគិតខ្លូវប្រកាអំបាលនោះហើយ នាងប្រក្រាយឲ្យមហាក្សត្រហើយ នាងយកព្រះសុគតនោះមកគ្រងព្រះភ័ក្ត្រ ហើយនាងផ្ទំសៀមចៅហោង ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរថែថ្លៃ
ឲ្យបានខ្ពាប់ខ្ពស់	គង់រឹងរឿតតំមត់
ព្រោះអក្សរជាតិ	គោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

ជីម្ងឹមីក្រូ - ឆឹងជីម្ងឹវិទ្យុ

(វិទារណាកថា)

លោក ជេង-ជ្រើរ និពន្ធ

មុននឹងដោះស្រាយបញ្ហានេះ គួរតែបរិកប្បុព្វហេតុដែលនាំឲ្យមាន «មីក្រូ» ឆឹងគោលចំណងជំនាន់ស្តីពីការផ្សាយដំណឹងតាមវិទ្យុ ។

មីក្រូនេះ ជាមធ្យោបាយពង្រីកសំឡេងឲ្យបានខ្លាំង ។

សួរថា: ហេតុដូចម្តេចក៏គេត្រូវការឲ្យសំឡេងលាន់ខ្លាំងជាងប្រក្រតី?

ឆ្លើយថា: ចំពោះរឿងនេះ តាមបណ្តាលមកពីទី ១ សំឡេងនោះជាការចាំបាច់ ព្រមទាំងមានប្រយោជន៍ដល់ជនកាតប្រែន ដែលត្រូវការចង់ឮ ឆឹងចង់ស្តាប់ - ទី ២ សំឡេងនោះឮមិនខ្លាំង មិនច្បាស់ឆឹងមិនជ្រួតជ្រាបសព្វត្រប់ពៀកនៃអ្នកត្រូវការ ។ អាស្រ័យហេតុនេះ ទើបគេបង្កើតឲ្យមានមីក្រូពង្រីកសំឡេងនេះឡើង ពាក្យខ្មែរសព្វថ្ងៃ ហៅប្រដាប់នេះថា «ឧត្តោសនកណ្ឋ» ។ ពាក្យ «មីក្រូ» ជាភាសាបារាំង ។

ឧទាហរណ៍ ដូចជាមានពិធីដ៏ធំឡោកមួយ ហើយមានឥស្សរជន

ជាអាចិន្តេសម្តេចទ្រង់ ព្រះបិតាឯកកាឋ្យជាតិ ទ្រង់សព្វព្រះកដហឫទ័យថ្លៃថ្លៃ
អ្វីៗសោតទាំងពួងចៅព្រះអង្គ ព្រោះព្រះភាវៈបស់ព្រះអង្គ មានសារសំខាន់ពន់
ពេក ដូចម្ហូបចំណីប្រកបដោយឱជារសដ៏ថ្លៃថ្លា ជនណាកំដោយ មិនថា
ប្រុសឬស្រី មិនថាក្មេងឬចាស់ រមែងពេញចិត្តក្រៃជញ្ជក់ចង់ឆ្អែចង់ស្កប់
យ៉ាងក្រៃលែង ។ ដោយមនុស្សច្រើនអនេកត្រូវការចង់ឆ្អែ ចង់ស្កប់
ព្រះភាវោះ ហើយដោយសម្តេចមានព្រះសូរសៀងមិនអាចជ្រួតជ្រាប
ដល់អ្នកត្រូវការគ្រប់គ្នា ព្រោះសំឡេងមនុស្ស ទោះបីអ្នកនោះមានកម្លាំង
ភ្លឺកែយ៉ាងណា ក៏មិនអាចស្ទុះឮទៅបានឆ្ងាយដូចផ្សាយតាមទូរស័ព្ទ
ឡើយ ហេតុនេះហើយ បានជាគេត្រូវតែប្រើទូរស័ព្ទ ដើម្បីបំពង
នឹងពង្រីកសំឡេងឲ្យឮខ្លាំងនឹងឆ្ងាយ តម្រូវតាមសេចក្តីត្រូវការ ។

សួរថា : ចុះបើគ្រាន់តែនិមន្តព្រះសង្ឃបួន.ដប់អង្គមកធ្វើពិធីអ្វីមួយ
ខាងសាសនា នៅក្នុងក្រុមគ្រួសារខ្លួន មានកៀរយ៉ាងច្រើន ១០០ នាក់
ប៉ុណ្ណោះ តើប្រើទូរស័ព្ទបានលាភដូចម្តេច ? ខ្លាចក្រែងអ្នក
ស្រុកផ្ទះជិតខាងមិនដឹង មិនឮថាខ្លួនបានធ្វើការកុសលឬ ? ខ្លាចក្រែង
កៀរស្តាប់ព្រះសង្ឃសូត្រមន្តប្លែកស្មូ មិនឮឬ ?

ឆ្លើយថា : ចំពោះសំនួរខាងលើ គឺមានសភាពដូចមិនសូវសម ។
បើតាមការសង្កេត នៅក្នុងភូមិនីមួយ ។ មុខនឹងធ្វើបុណ្យអ្វី ។ ទំនៀមបង្គាប់
សាមីជនឲ្យដើរដំណឹងជាតិជាដរាប ។ ដូច្នេះបញ្ហាស្តីពីរឿងថាក្រែងញាតិ

មិនដឹងផង តុំបានចោទទេ ។ បញ្ហាមួយទៀត ដែលថាត្រែងក្បៀសស្តាប់ព្រះសង្ឃពុំពុះ តំហាក់ដូចជាគ្មានន័យដែរ ព្រោះមនុស្ស ១០០ នាក់ ដើរតាមការគិសោធន៍ អាចស្តាប់សំឡេងធម៌ព្រះសង្ឃបានច្បាស់ កុំឲ្យតែមានក្តែងស្រែកប្រឡែងគ្នាឮឮពេក ។ ក្នុងសម័យមុន តើមានម៉ាក្រូឯណា តំគេអាចធ្វើបុណ្យបានដោយស្រួល រហូតដល់បុណ្យសីមាផង ។ របៀបចិន មនុស្សគាត់ច្រើនន័យមកប្រើទៅគ្មាសនកណ្តូកក្នុងសម័យនេះ ដើម្បីអ្វី ? ប្រមួយមកពីគេមានច្បាក់ច្រើនចាយមិនអស់ ហើយគេមានសទ្ធាជ្រះថ្លាត្រូវការបូជាម្ចាស់ទៅគ្មាសនកណ្តូផង ? បើយោបល់នេះជាការពិតគួរគេបញ្ជីអ្នកម្ចាស់បុណ្យ ចែកចាយធនធានខ្លួនដល់ក្បៀផងទើបសម ព្រោះសុទ្ធសឹងជាអ្នកបុណ្យដូចគ្នា ។

រឿងអាពាហ៍ពិពាហ៍ តំមានចំនងដូចគ្នានឹងការធ្វើបុណ្យដែរ គឺថាបើមានរៀបការនៅទីណាម្តង ។ មនុស្សអ្នកជិតខាងតែងតួលបានដំណេកពុំបានឡើយ ។ បើគេរៀបការ ១ យប់ ១ ថ្ងៃ អ្នកជិតខាង តោះប៉ីគ្មានចិត្តចង់ តំគោងតែចូលក្នុងតិចនេះជាមួយគេអស់ ១ យប់ ១ ថ្ងៃដែរ ។

សួរថា : ចូលជាមួយនឹងគេដូចម្តេច បើខ្លួនទៅផ្ទះដទៃ ហើយគ្មានការតាក់តែងនឹងគេរឿងរៀបមង្គលការសោះ ?

ឆ្លើយថា : ទៅគ្មាសនកណ្តូ ក៏ដឹកឲ្យត្រូវតែចូល ។ បើគេមានដេក ១ យប់ ខ្លួនក៏ត្រូវតែមានដេក ១ យប់ដូចគ្នា ។ ការស្រែកប្រឹងកំតាំង

ពិភេះ ពាំងមិនពិភេះ ការស្រែកអំពាវនាវរកសម្លេសមស្ងាបត្រា រកជបស្រា ..សម្រែកអស់នេះ វាមកបួលរុករើកកូរពេញតែក្នុងធ្នះអ្នកជវៃ ដែលជាហេតុឲ្យអ្នកនេះវេលជាមួយ រហូតដល់ចប់ ។

សួរថា : ហេតុម្តេច ក៏គេបួលចត្តយកទៅស្នាសនកណ្ឌ មកប្រើកន្ត័ពីដើម្បីមួយជាឯកជនម៉្លេះ ?

ឆ្លើយថា : វាគ្មានហេតុដ៏ចាំបាច់អ្វីពាំងអស់ទេ នេះគឺជាជម្ងឺធ្ងន់ទេតើ ព្រោះមនុស្សភាគច្រើន ពេញចិត្តនឹងការគោតសរសើរ ពោះបើខ្លួនមិនត្រូវដល់ការសរសើរក៏ដោយ និយមការហឺហាហឺកហាក់ ចង់ឲ្យគេឯងដឹងឮថាខ្លួនធ្វើនេះឬធ្វើនោះ ហើយមិនបានពិចារណាឲ្យយល់ច្បាស់ ថាការប្រព្រឹត្តិរបស់ខ្លួនសមហេតុផលឬទេ? រួចគិតស្មានថាការគាប់ប្រសើរណាស់ ដែលមានផ្សាយសំឡេងឲ្យឮខ្ទាំង តាមទៅស្នាសនកណ្ឌ ពោះបើសំឡេងនោះ។ មានអត្ថប្រយោជន៍ក្តី មិនមានក្តី គួរក្តីពុំគួរក្តី ធ្វើឲ្យអ្នកដឹតខាងវិញនយ៉ាងណាក្តី ក៏សាមីជនមិនបានគិតដល់ម្តង ធ្វើយ៉ាងណាឲ្យតែមានការក្អួតក្តាំងខ្លួឡូ រំដើបរំដួល ផ្តើលក្អែងតែប៉ុណ្ណោះ ។

មែនពិត ប្រសិនបើចង់ណាស់ បើគេញ៉ាំចិត្តណាស់ ក៏ត្រូវតាំងតែសូមមេត្តាកុំឲ្យហួសមាត្រា ។

ឯការផ្សាយដំណឹងតាមវិទ្យុជាតិ ក៏មានសភាពប្រហែលគ្នាន័ះរឿងខាងលើនេះដែរ ។ ការផ្សាយដំណឹងនេះ ជាការចាំបាច់ មិនមែនជាការ

បន្ទាប់បន្សំខ្លះ ។

សួរថា : ហេតុម្តេចក៏គេផ្សាយដំណឹងតាមវិទ្យុជាតិ ?

ឆ្លើយថា: ព្រោះជាដំណឹងដែលមានអត្ថប្រយោជន៍ខ្លួនទៅដល់សាធារណជន ថែមទាំងសាធារណជនអន្តរជាតិផង មានជាអាទិ៍ដំណឹងស្តីពីនយោបាយក្នុងប្រទេសនឹងក្រៅប្រទេស ដំណឹងស្តីពីការកសាងជាតិរឿងកំសាន្តចិត្ត ដំណឹងស្តីពីមរណភាពនៃឥស្សរជន ។ល។ បណ្តាដំណឹងទាំងប៉ុន្មានដែលមានចុះផ្សាយក្នុងវិទ្យុជាតិ មានដំណឹងមួយដែលគួរលើកយកមកពិចារណា គឺដំណឹងមរណភាព ។ ឯដំណឹងដទៃ ខ្ញុំយល់ថាសុទ្ធសឹងជាការគួរគប្បីទាំងអស់ ដែលថាពិកេះប្តូមិនពិកេះទេ ជាការៈនៃអ្នកនិពន្ធ ។

សួរថា : ហេតុដូចម្តេច ក៏យកដំណឹងមរណភាពមកផ្សាយឲ្យសាធារណជនដឹង មិនត្រឹមតែសាធារណជនខ្មែរទេ គឺរហូតដល់សាធារណជនអន្តរជាតិថែមទៀត ។ តាមធ្លាប់ដឹងមក ដំណឹងស្លាប់នេះ (ក្នុងប្រទេសដទៃ ខ្ញុំមិនបានស្គាល់ទំនៀមទម្លាប់គេជាក់ច្បាស់) ក្នុងប្រទេសកម្ពុជា គេមិនសូវចូលចិត្តចង់ស្តាប់ចង់ឮទេ ហេតុអ្វីក៏យកមកផ្សាយ ? ពេលព្រឹក ក្រុមវិទ្យុជាតិមិនអនុញ្ញាតឲ្យផ្សាយដំណឹងមរណភាពទេ ។ មានអ្នកខ្លះទៀតឃើញមនុស្សស្លាប់ មិនកោតទាំងចូលជិតផង ។

ឆ្លើយថា: តាមធម្មតានឹងការពិសោធន៍ គេយកដំណឹងនេះមកផ្សាយតាមវិទ្យុវាទមិនបាន ដោយហេតុអ្នកស្លាប់នោះជាឥស្សរជន ជាអាទិ៍

តព្រះមហាក្សត្រ ឬនាម៉ឺនឥឆ៌ពាំងតួន ព្រោះជនពាំងនេះ ខ្លះមានប្រជាប្រិយភាព ខ្លះជាទីគោរព ជាទីស្នេហាសក្ការបូជានៃប្រជាពលរដ្ឋ ខ្លះត្រូវមានការពាក់ព័ន្ធរវាងកិច្ចការពាក់ព័ន្ធ ។ ពុំនោះសោត ព្រះសង្ឃមានព្រះហានសមណសក្តិខ្ពង់ខ្ពស់ ឬជាចៅអធិការនៃគ្រួសូត្រដែលមានសិស្សគណច្រើន ។ ទោះបីដំណឹងមរណភាពជាដំណឹងអព្ភូតមង្គល ក៏ចំពោះជនខាងលើ តប្បីតែផ្សាយឲ្យគេដឹង ព្រោះដើម្បីជាដំណឹងដល់ប្រជាពលរដ្ឋនៃអ្នកពាក់ព័ន្ធ ។ ឬដល់សិស្សគណលោកដែលនៅឆ្ងាយ ព្រមទាំងដល់ឧបាសកឧបាសិកាដែលធ្លាប់គោរពបូជាលោក ។

មានដំណឹងមួយទៀតដែលគួរផ្សាយឲ្យសាធារណជនដឹងដែរ គឺមរណភាពនៃមហាចោរ ដែលធ្លាប់តែធ្វើទុក្ខធ្វើបាបដល់អ្នកស្រុកជិតខាង ឬអ្នកស្រុកខ្លួនឯង ។ បើគាលណាដំណឹងនេះផ្សាយទៅ នាំឲ្យមានការឈប់ព្រួយបារម្ភផង នាំឲ្យជនាខុនធូរទ្រូង មានចិត្តសប្បាយរីករាយក្នុងការប្រកបមុខរបរ ដើម្បីជីវភាពធម្មតាផង ។

សួរថា : បុរជនសាមញ្ញ តើមានប្រយោជន៍អ្វីនឹងយកដំណឹងមរណភាពនៃជននោះ មកផ្សាយតាមវិទ្យុជាតិ ?

ឆ្លើយថា : បើតាមការគ្រិះះ នឹងការសង្កេតឃើញថាវត្ថុមានផលប្រយោជន៍អ្វីតាំងតែសោះ ព្រោះខ្លួនបុគ្គលម្នាក់ ។ មានប្រជាប្រិយភាពឯណា ? មានការពាក់ព័ន្ធនឹងសាធារណជនឯណា ? មានតែបងប្អូន

កូនចៅខ្លួនក្នុងស្រុកប៉ុណ្ណោះទេ ដែលត្រូវការដឹង បើនាំឲ្យមានប្រយោជន៍ទៅវិញនោះ មានប្រាកដមែន ព្រោះជ្រាយម្តង ។ ត្រូវបង់ថ្លៃឲ្យក្រុមវិញ្ញាតិ បើក្រុមវិញ្ញាមិនយកថ្លៃ ក៏គួរទឹកដល់ការរិះគន់ពីខ្លួនឯង ។

ចំពោះរឿងនេះ គួរឲ្យអស់សំណើចពន់ពេកណាស់ ។ ប៉ាន់ជាអស់សំណើច ព្រោះខ្ញុំនឹកដល់រឿងមួយដូចតទៅ ៖

«ដំណាលថា មានលោកគ្រូចៅអធិការមួយអង្គ លោកតែងតែគោរពវិន័យណាស់ ។ វិន័យហាមមិនឲ្យព្រះសង្ឃប្រើប្រាក់ត្រង្គុះមានតំហែតាំងពីប៉ុនក្អែកមាន់ឡើងទៅ ។ ព្រះតេជព្រះគុណអង្គនេះ កាលណាឆាន់ចង្ហាន់រួចហើយ លោកតែងលើកជាត្របញ្ចាំងថ្លៃសំឡឹងខាងក្នុងមើល ក្រែងជាត្រលោកធ្លុះធ្លាយតម្រិតដែលវិន័យហាមឃាត់មិនឲ្យប្រើ ។ ម្ល៉ោះហើយ តែឆាន់រួចលោកនិយមលើកជាត្រសំឡឹងមើលជាដរាប មិនដែលលះថ្លៃណា ។

ចំណែកព្រះកិច្ចសង្ឃជាសិស្សតណារបស់លោក ដោយគោរពគ្រូ យើញគ្រូធ្វើដូច្នោះ ក៏នាំគ្នាធ្វើតាម គ្មានពិចារណា គ្មានសួរបញ្ជាក់អ្វីសោះ ។

ខាងក្រោយដែលព្រះតេជព្រះគុណចៅអធិការនោះសុគតទៅ ព្រះសង្ឃជាសិស្សតណាំងប៉ុន្មាន នៅតែប្រព្រឹត្តតាមចំនៀមទម្លាប់គ្រូរបស់ខ្លួនតមក កាលណាឆាន់រួច នាំគ្នាលើកជាត្របញ្ចាំងថ្លៃសំឡឹងមើលជាធម្មតា ទោះបីជាត្រមិនធ្លុះក៏ដោយ ។

លោកគ្រូចៅអធិការថ្មី មានព្រះហឫទ័យធ្ងន់ពន់ពេក ចំពោះព្រះសង្ឃក្នុងវត្តខោះ តែឆាន់រួច តែងនាំគ្នាលើកចូរត្របញ្ចាំងវៃថ្ងូរហើយសំឡឹងមើលទៅក្នុង ។

មាន ១ ថ្ងៃ លោកគ្រូចៅអធិការថ្មី ប្រជុំអស់កិក្ខុសង្ឃក្នុងគាកម ហើយសួរថា : ដែលអស់លោក កាលណាឆាន់រួច នាំគ្នាលើកចូរត្របញ្ចាំងវៃថ្ងូរមើល តើអស់លោកធ្វើនេះប្រយោជន៍អ្វី ? ធ្វើតាមលោកណា ? មានវិន័យបង្គាប់ឲ្យធ្វើឬ ?

ព្រះកិក្ខុ ១ អង្គ ដែលមានភេហារគ្រាន់បើធ្វើឃើញថា : ខានប្រាសដែលយើងខ្ញុំធ្វើនេះ គឺធ្វើតាមព្រះសពាទេតើ ព្រោះព្រះសព កាលលោកនៅព្រះជន្មនៅឡើយ តែងតែធ្វើយ៉ាងនេះ នៅពេលដែលលោកឆាន់រួច ។

ព្រះតេជព្រះគុណចៅអធិការថ្មី ដោយលោកទ្វាតវាងវៃកំឃើញភ្លាមថាដែលព្រះសពបានធ្វើនោះ មកពីលោកខ្លាចត្រែងថាត្រូលោកធ្លុះធ្លាយដែលវិន័យបានហាមឃាត់ ហើយកិក្ខុសង្ឃដែលធ្វើតាម គឺធ្វើដោយសេចក្តីឆ្កួត ធ្វើដោយគ្មានការពិចារណា ។ ទើបលោកចៅអធិការ មានពុទ្ធដីកាប្រាប់ហេតុផលស្តីពីការលើកចូរត្រ នៃព្រះសព ឲ្យកិក្ខុសង្ឃភាំងនោះដឹង ។ ចាប់ពីពេលនោះមក លោកសង្ឃក្នុងវត្ត អៀនខ្លួនកំឈប់ប្រព្រឹត្តដូចជាន់មុនទៀត ។

ទាហរណ៍នេះ បង្ហាញឲ្យយើញថា មុនធ្វើអ្វី គួរពិចារណាត្រិះរិះ

សិន គួរចោទសួរឲ្យដឹងថា ដែលគេធ្វើឯចេះឬឯចុះ តើដើម្បីប្រយោជន៍អ្វី ? បើមិនបានគិត មិនបានពិចារណា មិនបានចោទសួរទេ ហើយស្រាប់តែធ្វើតាមគេទៅ និងបណ្តាលឲ្យមានលទ្ធផលអាក្រក់កំមាន និងបណ្តាលជាកម្មវត្ថុខាងសំណើចនៃជនដទៃកំមាន ខាងការរិះគន់កំមានដូចរឿងលោកសង្ឃលើកជាត្រមើលខាងលើនេះឯង ។

ចំពោះដម្ងីមីក្រូ ដែលសាធារណជននិយមប្រើ ក្នុងទុកាសពិធីបុណ្យបន្តិចបន្តួច និងកន្ងិតពីរៀបអាពាហ៍ពិពាហ៍ ការណ៍នេះ បណ្តាលឲ្យមានលទ្ធផលអាក្រក់ពីរយ៉ាង : ទី ១ ធ្វើឲ្យអ្នកជិតខាងរំខាន ទី ២ នាំបងខាតបច្ចុយវត្ថុប្រយោជន៍ ដ្បិតបច្ចុយជាវត្ថុក្រ មិនគួរគប្បីចំណាយដោយមិនសមហេតុសមផលឡើយ ។ ឯការរំខានទៀត ក៏មិនមែនជាល្អ ការណ៍នេះនឹងបង្កើតឲ្យមានបរិយាកាសអាប់អួរ រវាងអ្នកជិតខាង ។

ចំពោះការផ្សាយដំណឹងមរណភាព តាមវិទ្យុជាតិ រឿងនេះនាំឲ្យខាតបង់បច្ចុយវត្ថុផលធង និងនាំឲ្យគេរិះគន់ដល់ការមិនមានវិចារណញ្ញាណយើងផង ព្រោះយើងជាអ្នកសាមញ្ញ ។ គេមិនដែលស្គាល់ឈ្មោះម្ចាស់ស្មាដៃជាប្រយោជន៍សាធារណៈ ក៏គ្មាន ។

រួមសេចក្តី: ការនិយមប្រើម៉ីក្រូកន្ងិតពេលមានបុណ្យ និងពេលរៀបការបន្តិចបន្តួចត្រមាំងការចុះផ្សាយតាមវិទ្យុជាតិ នូវមរណភាពនៃជនសាមញ្ញ ពុតជាដម្ងីធ្ងងមួយកន្ងែប្រទេស ដែលគួរតែបំបាត់ កុំឲ្យមានតទៅទើបប្រពៃ ។

វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង-ខាត់ រៀបរៀង

(តមក)

អធ្យាត្ម ន ពុំ. អាត្មានិក្រៃលែង សត្វប្រសើរ ។ – ចេតស៑ ពុំ. អ្នក ចំរើនអធ្យាត្មនិ ។– ជ្ញាន ន ពុំ. កិរិយាចេះដូរអធ្យាត្មនិ – ទគ. គុ. ដែលឃើញអធ្យាត្មនិ – តិ ពុំ. ជនអ្នកពេញចិត្តចំរើនអធ្យាត្មនិ ។ អធ្យាត្មោត្ត កាណ្ឌ ន ពុំ. ក័ណ្ឌក្រោយនៃ អធ្យាត្ម-ភាយណៈ ។

អធ្យាត្មិក គុ. ដែលប្រកបដោយអាត្មនដ៏ក្រៃលែង ។

អធ្យាបក ពុំ. សាស្ត្រាចារ្យ ។

អធ្យាបន ន ពុំ. កិរិយារៀន (គម្ពីរវេទ) ។

អធ្យាប្យ គុ. ដែលគប្បីរៀន ។

អធ្យាយ ពុំ ការស្វាធ្យាយ (គម្ពីរវេទ) ពេលស្វាធ្យាយ រឹត្ត ។

អធ្យារុហ ក្រ. ឡើងទៅក្រៃលែង លេចឡើង ដំឡើងថ្នាក់ លើកទៅ តាំយកទៅ ។

អធ្យារោបណា ន ពុំ. កិរិយាចង (ខ្សែធ្នូ) ដំឡើង ។

អធ្យាវិហនិក ន ពុំ. សម្បត្តិការិយា (ដែលការហើយតាំពីផ្ទះខ្លួនទៅផ្ទះ ស្វាមី) ។

អង្គ្យាសិ ក្រ. អង្គុយក្រៃលែង កាន់ដំណែង នៅរួមសុខទុក្ខ ក្លួល (ធ្វើការ) ដើរមើល ។ - អង្គ្យាសិត គុ. ដែលអាស្រ័យនៅ ។ ឧបុ. កិរិយាអាស្រ័យនៅ កិរិយាកាន់មុខដំណែង ។

អង្គ្យាសន ន ឧបុ. អង្គ្យាសិន ទីសំណាក់ ។

អង្គ្យាសិតវ្យ គុ ដែលគប្បីទទួលបន្ទុក ។

អង្គ្យាសិន គុ. ដែលអង្គុយក្រៃលែង ដែលតាំងនៅ ។

អង្គ្យរសិ ក្រ. វិ ឮងំទ្រូង ។

អង្គ្យមិត គុ ដែលនៅ ដែលកាន់កាប់ ។

អង្គ្យមិតេ ក្រ. វិ. ព័ត្រឹកព្រាង ។

អង្គ្យវ្យ គុ. ដែលកើតឡើង ដែលផ្សាយក្លិន ។ ដែលកំណត់ទុក ។ ឧបុ. ក្លិនមុខការ ។ ឧឌ្ឍ ស្រ. ប្រពន្ធដែលមានប្តី រៀបការម្តងទៀត ។

អង្គ្យធិ ក្រ. លាភ សន្ធឹង ។

អង្គ្យតវ្យ អង្គ្យតេយ្យ គុ ដែលគប្បីសិក្សា ។

អង្គ្យធិត គុ. ដែលភាន្តក ។

អង្គ្រុវ្យ គុ ដែលមិនទៀងទាត់ អនិច្ច ។

រឿងអាប៉ូលហ្វាអ៊ូរីស៍

(ក)

លោក ភីយ.ល្មត តំណាងកម្ម្ត

ប្រែរៀបរៀង

នៅពេលក្រោយពីអស់ស្រីស្រឡាញ់ ដែលអង្គុយហ្មបហ្មាយនោះ ចេញអស់ទៅ ការណ៍នេះពុំមែនអាថ៌កំបាំងទេ នាងកនហ្វាឧទ្ធិយាយមកកាន់ខ្ញុំថា ៖

-(ក) .- អើ ! អ្នកប្រុសសំឡាញ់អើយ ! ឥឡូវអ្នកប្រែក្លាយខ្លួនអ្នក ទៅជាបុរសមានចិត្តត្រឹមត្រូវហើយឬនៅ ? ការពិតត្រង់ៗពាក្យណា ដណ្តឹងសួរហើយសួរទៀត ក្នុងខ្លួនអ្នកគេឲ្យឃើញខុសត្រូវក្នុងប៉ុន្មានថ្ងៃក្រោយនេះ តើបានត្រៃនឹងព្រួតចិត្តរឹងរូសកំណាចយ៉ាងកំសាកថោកទាបនៃអ្នក ឲ្យងាកត្រឡប់ជាចិត្តសមបំណងខ្ញុំហើយ ឬនៅឡើយទេ ? ។ នាងបន្ទន់សម្លេងនាងយ៉ាងផ្អែមល្ហែមមុត កន្ទុយភ្នែកចោលយ៉ាងត្រជាក់ស្ងួតទៅចំភ្នែកខ្ញុំ (អ) ដែលជាហេតុបណ្តាលសេចក្តីសោកស្តាយអាណិតដល់កត្តស្រស់ញញឹមនេះ ពាល់តែខ្ញុំហាត់ត្រលឹង ។ ខ្ញុំដេកដួលគាំងស្មារតី នៅដើងរាជបល្ល័ង្ក . . . នាងស្រីស្ងួនប្រញាប់ប្រញាល់មកគ្រលើកខ្ញុំ ។ នៅពេលដែលខ្ញុំភ្ញាក់ខ្លួនបើកភ្នែកវិញ ខ្ញុំឃើញនាងឈ្លោកមកលើខ្ញុំ ជាងគេមុននាងរសាប់រសល់ខ្លាំង ...

ខ្ញុំអង្វរសុំអ្នកស្រី កុំព័យព្រួយបារម្ភណ៍អ្វីនឹងបុរសកំសត់មួយនេះ ។ ទាន
បានឆ្លើយមកខ្ញុំវិញ ខឌួចហើយខឌួចទៀត ប្រាសប្រាល់អង្គុះអង្គែងឆ
យ៉ាងម៉ាងថា ៖

(ក) – ឧ ! ខ្ញុំខុសខ្លួនហើយ ! ខ្ញុំយល់ថាប្រាកដជាមានអ្វីមួយ
ជាខ្លីជាប់ចិត្តអ្នកប្រុសដោយស្នេហា ជាងខ្ញុំហើយមើលទៅ !

(អ)– ទេ! ទេ! តែវាព្រលឹងអើយ ! មានតែប្លុងខឆ្កែតែមួយ
នេះប៉ុណ្ណោះទេ ជាខ្លីពេញចិត្តខ្ញុំលើសអ្វីៗ ទាំងអស់ ។ តែសូមតែវា
បណ្តែលចិត្តបងពិចារណាមើលបុះ ៖ បងបានប្រគល់កាយចិត្តថ្វាយ
ចំពោះព្រះដ៏មានបុណ្យទៅហើយ តើមានអ្វីមួយត្រូវធ្វើខ្លួនបងឲ្យទាប
ថោកលើសទៅទៀត ប្រសិនបើបងជាមនុស្សខ្សោយដល់ទៅធ្វើកិត្តិយស
ខ្លួនឲ្យសៅហ្មងដូច្នេះ ?

(ក) – ណ្តើយ ! កុំនិយាយ ! អ្នកឯងជាមនុស្សចិត្តលាមកអា-
ក្រក់ ! ដោយហេតុអ្នកមិនបូជាកាយចិត្តអ្នកឲ្យខ្ញុំ នេះជាកស្តុតាងបង្ហាញ
ឲ្យឃើញច្បាស់ថា អ្នកឥតស្រឡាញ់ខ្ញុំពាល់តែសោះ ។ បើដូច្នោះសូម
អ្នកអញ្ជើញទៅបុះ ខ្ញុំខ្ជាស់ណាស់ ខ្ញុំអង្វរកអ្នកឥតទៅទៀតភ្លុះចេ ។
ខ្ញុំអស់ស្អាបសូដ៏អ្វីតទៅទៀតហើយ ខ្ញុំត្រូវបោះបង់អ្នកហើយ អ្នកជា
មនុស្សអកតញ្ញូ-អសប្បុរស- - - ចាប់ពីថ្ងៃនេះតទៅ អ្នកត្រូវឈប់
មកជួបខ្ញុំ ។ ត្រូវអ្នកងើចាំស្តាប់បង្គាប់របស់ខ្ញុំ បន្តិចទៀត អ្នកជ្រាប

ហើយ តើសេចក្តីវិនិច្ឆ័យរបស់ខ្ញុំនោះយ៉ាងណា ? ។

(អ).- និយាយផុតមាត់ភ្លាម នាងស្រស់ក៏ដើរចេញមួយរំពេចពី មហាគេហដ្ឋានចាំងចិត្តរំភើបខ្លាំង ដំណើរមានគេចំភ្នែក ។ ខ្ញុំក៏មានចិត្ត រំភើបស្មើនឹងនាងដែរ ។ កន្លងពេលនោះ ខ្ញុំគិតក្នុងថា តើអញត្រូវតាម ច្រកណា ? ធ្វើម៉េចទៅ បើមានគេយាមល្បាតខ្ញុំជុំវិញជានិច្ចដូច្នេះ ។ ខ្ញុំកែតែទៅជំពប់លោក ហាប្លឹបក៏ពុំបានឆង ថាខ្ញុំបិតនៅទីណា ហើយ មានអាសន្នដល់ខ្លួនខ្ញុំយ៉ាងណា . . . ។ កាលថ្ងៃ ខ្ញុំរង់ចាំស្តាប់ តើគេកាត់ទោសខ្ញុំយ៉ាងណា . . . រង់ចាំ ។ ។ ។ អស់ប៊ីសជ្ឈាហ:ពុំ ឃើញមានលេចឮអ្វីសោះ ។ សេចក្តីវេទនាកាយចិត្តខ្លាំងពេកដូច្នេះទាំ ឲ្យខ្ញុំកើតទុក្ខខ្លោចផ្សាអត់ទ្រាំស្ទើរពុំបាន ស្ទាប់ទៅវិញគាប់ប្រសើរជាង ។ ខ្ទុះ ! នៅពេលព្រឹកថ្ងៃមួយ នាកាល ខ្ញុំស្ទៀកពាក់រួចភ្លាម ស្រាប់តែខ្ញុំ ឃើញទាសាទាសីច្រាំ ឬច្រាំមួយនាក់របស់នាងគនហ្សាឌ ចូលមកកន្លង បន្ទប់ខ្ញុំ ។ អ្នកទាំងនេះនាំមនុស្សមួយពួកប្រដាប់ដោយសំលៀកបំពាក់ ផ្សេងគ្នាពីអ្នកនៅកោះ សេរេនឌីប ។ អ្នកម្នាក់នោះសំណាំសំសួន ប្រហែលជាទាយគេ ឈរសម្លឹងមុខខ្ញុំមួយសន្ទុះ ហើយដើរឈាន ជំហានមួយ ។ ក៏បង្គាប់ខ្ញុំឲ្យដើរតាមគាត់ទៅ ដោយប្រើសម្លេងខ្លី ។ ជា បង្គាប់បញ្ជាមជ្ឈត្ត ឥតត្រូវការស្តាប់ពាក្យសួររបស់ខ្ញុំឡើយ ។ យើងទាំង អស់ទាំងគ្នាដើរកាត់ច្រកសាច ។ នាកាលដែនទឹងចេញពីបរិវេណច្រកសាច

ខ្ញុំសួរទៅអ្នកម្នាក់ថា ៖ ចុះលោកនាំខ្ញុំទៅឯណា ? - ស្រាប់អ្នកភ្ញាំបានទេ បន្តិចទៀត អ្នកនឹងដឹងហើយ !

X X X

(អ) ·- ដូច្នេះ ខ្ញុំត្រូវដើរតាមមនុស្សចាំងនោះ រហូតដល់តំពង់ទឹកក៏ចុះសំពៅជាមួយនឹងគេ ។ គេរៀបចំក្តាមលើកយកថ្មាបើកក្តោងចេញដំណើរទៅ ។

កាលណាយើងទៅដល់តណ្ឌាលសមុទ្រ ថៅកែសំពៅស្រាប់ខ្ញុំថា ពីដើមគាត់ជាពលរដ្ឋនៃព្រះរាជាណាចក្រនាមគូលកុដ្ឋ ហើយថា លោកស្រីតនហ្សាឌុបានឲ្យខ្ញុំ (អ) ទៅគាត់ ដើម្បីធ្វើជាទាសា តែលក្ខណ្ឌថា គាត់មិនត្រូវអនុញ្ញាតសោះឡើយ ឲ្យខ្ញុំត្រឡប់ទៅចាស៉ាវិញ ។

នេះហើយគឺការសងសឹករបស់នាងតនហ្សាឌុ ។

ខ្ញុំមានសេចក្តីក្រៀមក្រំខ្លាំង កាលខ្ញុំនឹកថា ខ្លួនខ្ញុំលែងឃើញមាតុភូមិ លែងឃើញឪពុកខ្ញុំ ។ តែប៉ុន្តែ ខ្ញុំទំធ្វើខ្លួនខ្ញុំជាទាសាត្រឹមត្រូវ មានសណ្តាប់ធ្នាប់ល្អ មានកិរិយាភាព តែងការបំរើថៅកែខ្ញុំ ។ ថៅកែនេះជាមនុស្សមានចិត្តល្អ ហើយស្រាប់ផ្កាងវៃ ។ ខ្ញុំពុំមែនរំពៃតែចាត់ការឲ្យត្រឹមត្រង់ប៉ុណ្ណោះទេ ខ្ញុំទំសង្កេតមើលតើថៅកែចង់អ្វី ខ្ញុំបំពេញចិត្តគាត់ភ្លាម ហើយខ្ញុំឃើញថា ថៅកែលោកកាន់តែសប្បាយចិត្តនឹងខ្ញុំឡើង ។ រៀងរាល់ថ្ងៃ ។

យើងធ្វើដំណើរជុំវិញកោះ សេរេនឌីប ដើម្បីទៅចូលតង់ឈូង

សមុទ្រ ថេនកាល ពីទិសខាងជើង ។ ឈូងសមុទ្រនេះធំជាងគេទាំងអស់
នៅអាស៊ីទ្វីប ហើយក្នុងឈូងសមុទ្រនេះ មានព្រះកជាណាចក្រចំនួនពីរ
គឺ៖ ថេនកាល និងគូលកុន្ត ។ នៅគេលយើងកាច់ចង្កូតសំពៅចូល ស្រាប់
តែមានខ្យល់ព្យុះមួយ បក់ប្រោកមកយ៉ាងខ្លាំងក្លា ជាមហាភ័យតែម្តង ។
យើងចង់ពាក្យតែក្តោងយ៉ាងណាក៏ដោយ យើងចង់បង្វៀងតែម យ៉ាង
ណាក៏ដោយ យើងចង់ចេីកជាចំណិតត្រសក់យ៉ាងណាក៏ដោយ ---(ល)
ឃេីញថាឥតប្រយោជន៍ទាំងអស់ ។ កម្មករសំពៅបញ្ចេញវាំងសិល្ប៍
ចំណេះចេ្បីចបន្តួចអស់ ឃេីញអស់ដៃចាញ់ចេះនឹងគេ . . . សំពៅ
ក៏អណ្តែតតាមខ្យល់ទៅ ។ មេធ្យោបាយចុងក្រោយបំផុតគឺ ដេីម្បីចៀស
វាងកុំឲ្យសំពៅលិចលង់ក្នុងមហាសាគរ យើងត្រូវឈប់ចូតចែវឆ្នេីម្ខាងទាំង
អស់ ហើយបណ្តោយតាមតែរលកមានរលកដកពពារធំ ។ រលកបណ្តេីរ
ភ្នូនដោះក្រមុំផងក៏មាន ពោរពេញបក់ប្រោកយកទៅឯណាក៏តាមយថាកម្ម
ទៅចុះ- . - ចេះតែអណ្តែតទៅ ។ ។ លុះតែឃេីញគោះជ្រានិងគោះ
ស៊ូម៉ាត្រា បែរមកទៅពីខាងឆ្វេងយើងទៅវិញ គិតពីកន្លែងដេីមរបស់យើង
មកពីនេះ ប្រហែលចម្ងាយ ៦០០ ល្បឺ (ប្រហែល ២.៩០០ គីឡូម៉ែត្រ)
រហេីយបេីគិតត្រឡប់ទៅផ្លូវដែលយើងធ្វេីដំណេីរគោះវិញ ប្រហែលឆ្ងាយ
ជាងនេះទៅទៀត ឃេីញថាយើងឋិតនៅខ្ទឹមគោះម៉ូលុក គឺខាងត្បូង
គោះ ហ្វីលីពីន(ម៉ាំនីល)ឯណោះទៅក្នុងសមុទ្រឆ្ងាយលន្ធឹងស្ងាត់ឆេង

ជាចំណែងដែន ដែលពួកយើងខ្ញុំតាំងអស់គ្នាមិនដែលស្គាល់សោះ ។
ប្រមាណបីយប់បីថ្ងៃ ឮស្តាប់ក៏ជានស្រាកបន្តិច ។ បក់ឲ្យខ្យល់ល្អ យើងបើកសំពៅជានស្រួល យើងរែកយកសប្បាយ ។ តែមិនជានប៉ុន្មាន ស្រាប់តែយើងមានសេចក្តីខ្វក់ខ្វល់ចិត្ត ដោយយើងជានពើបតះប្រទះរឿងចំឡែកមួយដែលតាំគួរជឿជាន ។

ឯរឿងនេះគឺដូច្នេះ :

យើងជានលើកក្តោងត្រឡប់មករកផ្លូវដើមយើងវិញ ធ្វើដំណើរដើរមកដល់រកោះជ្វា គឺយើងមកពីទិសឯកើត គ្រានោះយើងជានឃើញទៅស្បែរយើង ខ្លួមនុស្សប្រុសមួយលែងខ្លួនជ្រាំង អាក្រាតខ្លេ តោងបណ្តែតខ្លួនទឹកតារមួយសន្ធឹក ។ មនុស្សនោះស្រែកហៅយើងឲ្យជួយ ។ យើងស្រាយសំបុកគួនខ្លួកគួចឲ្យមនុស្សនោះឡើង ស្រង់យកមកលើសំពៅ ។ ម្ចាស់អើយសេចក្តីមេត្តានេះ នាំឲ្យយើងមានទុក្ខសោកយ៉ាងសំបើម ។

មនុស្សនោះចំណាស់ប្រហែលអាយុ ៤០ ឆ្នាំ មានមាឌដងខ្លួនធំខ្ពស់ជាអស្ចារ្យ ស្បាលរាង្រែសជាងក្រឡឹកត្រីបន្តិច សក់ក្រាស្ពួញចាក់កណ្តាញ់ព្រំខ្លួទៅរកាទៅមកដូចជាឈ្នួត កែកដូចខ្លា ប្រមុះសំបើតប្រហោងត្រហួ ។ មាត់ក៏មានតែមម្ខាង ។ ជិតដល់ត្រចៀក ។ កាលណាហាមាត់ម្ខង ។ ឃើញធ្មេញវែង ។ ស្រួច ។ ដៃតំរែតញ័រ ។ ជាន់ចុះ ជានដៃធំ ។

នៅបុងម្រាមដៃ មានក្រចកវែងខុប។ ហើយវាធំជាងគេបំផុត ទឹកមុខវាជាមនុស្សអសប្បុរសគោរពតែញៀវដោយពាស: អាចប្រែក្លាយភ្លាម។ ឲ្យខ្លាចយើងដល់យើង ថ្វីបើយើងមានសេចក្តីឆាលិតអាស្រូវដល់វាអំបាញ់មិញនេះ។ ខាកាលបានឈរចេញមុខលោក ដើហាអូស្ត្រូ ថៅតែយើងភ្លាម មនុស្សនោះមានវាចាថា : សេដ្ឋី អើយ! ខ្ញុំបានរួចរស់ដីតែដោយសារលោក កុំតែបានលោក ខ្ញុំស្លាប់ចាត់ថៅហើយ! ។

(ខ) - ពិតប្រាកដហើយ បើអ្នកគ្មានសំណាងជួបនឹងយើងទេ អ្នកត្រូវលង់លិចស្លាប់ជាខ្មោចហើយ ! ។

មនុស្សនោះឆ្លើយថា : ហ្ន៎! ខ្ញុំលង់ទឹកស្លាប់! មើលខ្ញុំឲ្យប្លាស់ ខ្ញុំមិនមែនស្លាប់ដោយលង់ទឹកទេ ។ ខ្ញុំចង់នៅពាប់ឆ្នាំកន្ទឹកកំបាន គ្មានជាការណ៍អ្វីទេ ការណ៍ដែលនាំឲ្យខ្ញុំមួលខ្លួននេះ គឺខ្ញុំឃ្លានបាយ ខ្ញុំឃ្លានណាស់ ស្ទើរវិហែករហុយក្រពះថៅហើយ ។ ដប់ពីរមោងថៅហើយ ខ្ញុំឥតបានទទួលទានអាហារសោះ គឺរយៈពេលវែងហួសហេតុថៅហើយ ចំពោះមនុស្សអ្នកស៊ីច្រើនដូចខ្ញុំ ។ ដូច្នេះ តាមតែលោកអភ័យទោសថៅចុះ សូមមេត្តាឲ្យទានខ្ញុំ ដើម្បីលើកតម្ងាន កុំថៅរកចំណីមួយអ្វីល្អខោះ តាមតែស្ដី ក៏ខ្ញុំទទួលទានបានដែរ ។

អ្នកទាំងអស់កំពុងឈរមើលស្រឡាំងកាំង លោកដើហាអូស្ត្រូបង្គាប់ឲ្យរៀបម្ហូបអាហារ សម្រាប់ចំនួនមនុស្សប្រាំមួយនាក់ចរិកោតហើយ

ឲ្យយកទោអាវមកឲ្យមនុស្សនោះស្លៀកពាក់ផង ។

- ទោអាវ! អរគុណហើយលោក ខ្ញុំជាមនុស្សស្រោតដូច្នេះជាដាច !

- ល្អហើយ ! កាលណាអ្នកឯងនៅតែម្នាក់ឯង នោះខ្ញុំឃើញថាប្រពៃតែនេះ បើអ្នកនៅជាមួយនឹងយើងទាំងអាក្រាតដូច្នេះ ដូចជាពុំសមមេឃ ! ខនលគកអីចឹងទេ !

អូ ! បន្តិចទៅ កំអ្នកឯងសាំងក្អែកទៅហើយ !

សេចក្តីតបវិញទាំងគំរើលដូច្នេះ បញ្ជាក់ឲ្យយើងយល់ច្បាងថាមនុស្សនេះមានខួរក្បាលពុំសូវស្រួល ។ ដោយសេចក្តីស្រេកឃ្លានបេះតែតឿនមនុស្សនេះអន្ទះអន្ទែងសុំឲ្យរៀបចាយឆាប់ ។ ខ្ញុំដើរលើសំពៅត្រហឹមទាំងធ្វេញក្អែកក្រហមវិលលៀនផ្អែរ ។ នាគាលម្ហូបអាហារមកដល់ ភតាំងស្ទុះក្អែតទៅតមញាត់ ។ អស់លើងក្តាម ហើយសុំមេគ្តាថែមទៀត ។ លោក ឱហាអូស្ត្រ ចង់ដឹងចុះបុំន្មានទៅទើបឆ្អែត! កំបង្គាប់ឲ្យរៀបតុដូចមុនទៀត តុទី ២ នេះកំអស់តិញក្តាមទៅទៀត ។ យើងស្មានថាប្រហែលគ្រប់គ្រាន់ហើយតែខុសស្រឡះ ភាស៊ុយាងតឹងរឹងឲ្យថែមទៀត ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន

ប្រែតាមសាច្បាប់ដោយ លោក ផេង-ទ្រីវ

(៣)

៩២) រវេះធំជិសត្វរុយ

មានសេះប្រុំមួយ យ៉ាងមាំ ។ ខំអូសរវេះមួយឡើងខួល ផ្លូវសុទ្ធ តែភ្លាច់ដីពិបាក ហើយមានខ្យែចាំងមកពីគ្រប់ទិស ។

ស្រាប់ លោកសង្ឃ-ចាស់ ។ នាំគ្នាចុះអស់ សេះខំប្រឹងបែកញើសហូរញើសហាត់រហុះ ស្ទើរផុតជង្គើម ។ រុយមួយហើរមកជិតសេះ មានចំណង់ចង់ញ៉ាំងសេះឲ្យដើរដោយស្មារស្ទាបនៃអាត្មា ស៊ុះទៅទាំសេះនេះម្តងសេះនោះម្តង ហើយគិតថាវាចង់ធ្វើរវេះឲ្យលឿនទៅបាន ដួនហើរទៅចំលើចខ្នោល ដួនហើរទៅចំលើច្រមុះនាយសារថី ។

នៅពេលដែលរវេះកម្រើកបរទៅ ហើយដែលវាឃើញមនុស្សទាំងឡាយនាំគ្នាដើរតាម រុយយល់ថាជោគជ័យនេះ ជាស្នាដៃរបស់វាតែម្នាក់ឯង វាហើរទៅ ហើរមក យ៉ាងរហ័សរហួន ។បមាដូចជាត្រីខ្ទុចល្អ នៅពេលចម្យាំង ស៊ុះទៅចាត់ការគ្រប់កន្លែង បង្ខំឲ្យតាហានស៊ុះចូល ដើម្បីនឹងយកជ័យជំនះបានឆាប់ ។

នៅពេលនោះ រុយពោលគ្អូញក្អែរថា វាខំធ្វើតែម្នាក់ឯង ថាវាជាអ្នកយកចិត្តទុកដាក់ទាំងអស់ ថាគ្មានអ្នកណាម្នាក់ជួយសេះសោះ តើថាលោក

សង្ឃតិតតែក្តៀតពេល អានសៀវភៅជាមិ ស្រីតិតតែប្រឹង តើពេលហ្នឹង ឬ ត្រូវតិតពីចម្រៀង ! នាងរុយស្ទុះហើរពីតុះពីតឡើង នាំឲ្យតែអង្គុយទៅនឹងត្រចៀកមនុស្សពាំងនោះ ។

ជាអាសាន រះខេះកំបានទៅដល់លើខ្លួល ! ឃើញដូច្នោះ រុយពោលថា៖ ឥឡូវ ត្រូវយើងសំពាកដកដង្ហើមឲ្យស្រួលបន្តិចបុះ ! ខ្ញុំទំប្រឹងភ្ញាំងណាស់ តាំងពីយើងពាំងអស់គ្នា ទៅឯកល ផ្ទៃកបម្ល៉ុះ ដូច្នេះសូមលោកសេះឲ្យថ្ងៃឈ្នួលមក ។

ចំពោះរឿងនេះ មានជនជាច្រើន ធ្វើជាវហ៍សហួនចូលលាយឡំក្នុងកិច្ចការពាំងឡាយ តីហាក់ដូចថាខ្លួនជាអ្នកធ្វើការចាំបាច់គ្រប់ទីកន្លែងតែតាមការណ៍ពិត តីធ្វើឲ្យតែទើសចែងគេគ្រប់ទីកន្លែងវិញសោះ គួរតែប្រែតែកំចាត់ចោលចេញ ទូវជនបែបនេះ ។

៩៣) មច្ចុរាជ និង អ្នកជម្ងឺដកបង្គាមាន់

អ្នកដកបង្គាមាន់ម្នាក់ អាយុជាងមួយរយឆ្នាំហើយ ចេះតែគ្មូញក្តែរជាក់មច្ចុរាជថា មច្ចុរាជប្រញាប់មកបង្គំរតេឲ្យទៅឆាប់ម្ល៉ុះ រកតែលៃពេលធ្វើលិទ្ធប្រគល់មរតកស្ទើរមិនទាន់ យ៉ាំងហោចណាស់តិត្រូវឲ្យដំណឹងមុនដែរ ។ អ្នកដកបង្គាមាន់នោះពោលថា៖ តើមកបង្គំរតេឲ្យទៅភ្លាម ។ ដូច្នេះ មានយុត្តិធម៌ឬទេ ? ត្រូវមច្ចុរាជឯងបង្អន់បន្តិចសិន ប្រតន្ទខ្ញុំមិនព្រមឲ្យខ្ញុំទៅ ដោយគ្មានគេហ៍ទៅជាមួយផងឡើយ ហើយខ្ញុំទៅមានទៅ

ម្នាក់ដែលខ្ញុំត្រូវរៀបចំឲ្យគាត់មានផ្ទះសំបែង មច្ចុរាជត្រូវដឹងថា ខ្ញុំត្រូវទៅ
តាមពីផ្ទះដំបូងទៀត ។ មច្ចុរាជចង្រៃ ! អ្នកឯងប្រញាប់អ្វីម្ល៉េះ ។

មច្ចុរាជឆ្លើយតបទៅអ្នកដកចង្កាមាន់នោះវិញថា : នែលោកតា !
ខ្ញុំពុំមែនមកពញ្ជាក់លោកតាឯណា ។ លោកតាពោលតួញាំត្អែរអំពីការ
បង្ខំរបស់ខ្ញុំ ដោយឥតសមហេតុ-ផល : ចូរគិតមើល ! លោកតាមិនមែន
មានអាយុ ១០០ ឆ្នាំ ហើយទេឬ ? ចូរលោកតាចង្អុលប្រាប់ខ្ញុំនូវមនុស្ស
ពីរនាក់ ដែលមានអាយុ ចំណាស់លោកតា នៅទីក្រុងប៉ារីស (Paris)(១)
ហើយរកមនុស្សចំណាស់បែបនេះទៀត ចំនួន ១០ នាក់ ក្នុងប្រទេស
ចាក់ឆ្ង ! តើមានឬទេ ? បើលោកតាប្រាប់មក ខ្ញុំត្រូវជូនយោបល់ខ្លះដល់
លោកតា ជាយោបល់ដែលញ៉ាំងឲ្យលោកតាយល់ដូចតទៅ: គឺថាខ្ញុំបាន
ឃើញលិខិតប្រគល់មរតកលោកតាឆ្លើរួចហើយ ចៅលោកតាមានគ្រួសារ
ហើយ ផ្ទះលោកតាសង់ស្អាតហើយ ។ រឿងដើរ – កម្រើក – សញ្ញា
មនោសញ្ចេតនា ទាំងអស់នេះ ឃ្លាតចេញពីលោកតាហើយ ។ តើហ្នឹង
មិនមែនហៅថាគេឲ្យដំណឹងដល់លោកតាទេឬ ? អណ្តាតលែងដឹងរស
ជាតិ ត្រចៀកស្តាប់អ្វីមិនឮ អ្វីត្រប់សត្វហាក់ដូចជាស្ងួតស្រពោន ចំពោះ
លោកតា ហើយកាលវៃលាមានសភាពច្រើនហួស ចំពោះលោកតា ។
ស្តាយសម្បត្តិ ដែលឈប់ជាប្រយោជន៍ដល់ខ្លួន ។ ខ្ញុំសូមចង្រ៉ាញ
ចំពោះលោកតា នូវមិត្តភក្តិលោកតាដែលខ្វះស្ងាប់ ខ្វះតំពូនដកចង្កា

១– រដ្ឋធានីនៃប្រទេសបារាំង ។

មាន់ ខ្ទះកំពុងឈើ តើរឿងពាក់ព័ន្ធនេះ មិនមែនជាការឲ្យដំណឹងទេឬ ? ដូច្នេះ សូមលោកគាអញ្ជើញ កុំតក់ធ្វើអ្វី មិនជាប្រយោជន៍អ្វីដល់ពួកគាទេ ដែលលោកគាថា បង្អន់បន្តិច ដើម្បីធ្វើលិខិតប្រគល់មកគេនោះ ។

មច្ចុរាជយល់ត្រូវ ។ ខ្ញុំប្រាប់ថា អាយុប៉ុណ្ណោះហើយ គេត្រូវតែថយចេញពីដីវិលាភ ដូចជាគេថយចេញពីតន្ទែងដប់លៀង ដោយថ្ងៃនីមួយៗដល់ម្ចាស់ផ្ទះ ហើយគេត្រូវតែរៀបចំបង្វែចរបស់គេ ទុកឲ្យស្រួចព្រោះ តើគេអាចនឹងពន្យារពេលឈប់បានប៉ុន្មាន ក្នុងការធ្វើដំណើរនេះ ?

បពិត្រលោកគា ! សូមលោកគា កុំកន្ធក់កន្ធេញ សូមលោកគាក្រឡេកមើល យុវជនពាក់ព័ន្ធនោះស្ងាប់ សូមលោកគា ក្រឡេកមើលយុវជនពាក់ព័ន្ធនោះដើរ សូមលោកគា ក្រឡេកមើលយុវជនពាក់ព័ន្ធនោះគង់ខ្ពោះ ទៅតែតែសេចក្តីស្លាប់ ទោះបីសេចក្តីស្លាប់ប្រកបដោយកិត្តិយស ទោះបីស្លាប់ល្អ ឬស្លាប់អាក្រក់ គឺខឿនពិតជាស្លាប់ហើយ ។ ខ្ញុំបានអំពាវនាវប្រាប់លោកគាច្រើនលើកហើយថា ខ្ញុំមិនមានការបន្ទរបន្ទាយចំពោះមុខវាខ្ញុំនេះទេ អ្នកខ្លាចស្លាប់ជាងគេ រមែងស្លាប់ដោយសេចក្តីស្តាយច្រើន។

អ្នកមានចិត្តអាណិត តែងពោលពាក្យជាទីគាប់ចិត្ត អ្នកក្រៀវក្សា តែងមិនពោលអួតខ្លួន អ្នកឲ្យទាន តែងឲ្យទានមិនរើសមុខ អ្នកមានប្រាជ្ញប្រតិភាព តែងមិនគោងគាប ។

រឿងសាមកុក

ទុកញ៉ាវិចុលភដសេនា ន្ធ-ភកន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លុងសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងដេះទាយកលល្បិចណាន
ពាំងមានសន្តានស្នេហាជាតិ ។

ឃ្លោ-អ៊ុន

ចូរឆ្ងល់ប្រើហែហួអៀនតាំងពាន ២០០០ នាក់ដាកឆ័ងមុខ ហើយចេញពីបន្ទាយធំទៅមុន មានបំរើរេសេះស៊ើបដំណឹងត្រឡប់ទៅប្រាប់ហែហួអៀនថា ឥឡូវនេះអៀវហៀមលើកកងទ័ពមកតាំងបន្ទាយ ដែនស្រុកខ្ញុំគេនប្រើនណាស់ ហែហួអៀនឮដូច្នោះ ក៏ឲ្យបោះទ័ពតាំងបន្ទាយនៅទីនោះ អៀវហៀមដឹងថា ហែហួអៀនលើកកងទ័ពហួងចូលមកតាំងបន្ទាយនៅដូច្នោះ ក៏ប្រើឈ្មៀងតីលើកពលពាន់ចេញទៅនឹងច្បាំងតយុទ្ធគ្នានឹងហែហួអៀន ។ ឃើញដូច្នោះ ក៏លើកពលពាន់ចេញទៅត្រៀមចាំនៅមុខបន្ទាយ ហើយបរេសេះចូលទៅប្រយុទ្ធគ្នានឹងឈ្មៀងតីបាន ៣ ភ្លេង ហែហួអៀនក៏យកដាវកាប់ត្រូវឈ្មៀងតីដាច់តាត់តណ្តាលខ្លួន ជាពីរកំណាត់ស្លាប់ ។

អៀវហៀមឃើញឈ្មៀងតីស្លាប់ក៏ខឹងណាស់ លោតឡើងរេសេះចេញទៅតស៊ូនឹងហែហួអៀនបាន ៣០ ភ្លេង នៅមិនទាន់ចាញ់ឈ្នះហែ-ហួអៀនឡើយ ជាញាក់សេះថយតៅទៅក្រោយ អៀវហៀមមិនដឹងកលកំ

ដេញបណ្តោយតាមទៅ ហែហួអៀនញាក់សេះត្រឡប់មក កាប់ត្រូវអៀវ
ហៀមជ្រាក់ពីលើសេះស្លាប់ តាហានចាំងតួនក៏ជាក់បែកខ្ចាត់ខ្ចាយអស់
ទៅ ។

មានប៉ំរើសេះទៅប្រាប់ចូនធូថា ហែហួអៀនមានដំយជំនះហើយ
ចូនធូក៏មានចិត្តសោមនស្សណាស់ ទើបលើកទ័ពហួងកន្ធង់ចូលទៅតាំង
បន្ទាយនៅជិតស្រុកហានតុង ខៀវឡងដឹងដូច្នោះ ក៏ប្រកាន់ទឹងតាហាន
ចាំងតួនថាអៀវហៀមក៏ដល់ខ្លួវសេចក្តីស្លាប់ទៅហើយ ឥឡូវចូនធូក៏លើក
ទ័ពហួងកន្ធង់ចូលមកជិតស្រុកយើងណាស់ អ្នកចាំងអស់គ្នាទឹងជួយនេះ
គិតប្រការម្តេច ? ៖ឆ្លើយថា មាំឈ្មៀវនោះប្រែចិត្តចេញពីលោកហើយ
ទៅតែជាំងតេក ព្រោះឈឺទៅផងមិនបាន ឯជាំងតេកនោះមានថ្វីដៃខ្លាំង
ក្លាតែណាស់ចាំងចិត្តក៏សុចរិតពិតត្រង់ ខ្ញុំបាទបានឮស់ដំនិយាយសរសើរ
គុណលោកថា កាលមាំឈ្មៀវតៅបែកពី ចូនធូមកទីពឹងបុណ្យលោកនៅទី
នោះ ជាំងតេកក៏បានសេចក្តីសុខ ដោយសារគិតតែធ្វើការតបស្នងសង
គុណលោកមិនដាច់ឥម៉ាត់ បើដូច្នេះ គួរតែលោកឲ្យហៅខ្លួនជាំងតេកមក
ប្រើការឲ្យលើកតលយោជា ចេញទៅតទឹងចូនធូទើបបាន ។

ខៀវឡងបានឮដូច្នោះ ក៏មានចិត្តសោមនស្សណាស់ ឲ្យប៉ំរើទៅ
ហៅជាំងតេកមកឲ្យប៉ំណាច់ផ្ទាន់ជាច្រើន ហើយថា យើងត្រូវឲ្យអ្នកចេញ
ទៅប្រាំងទឹងតាហានចូនធូបានទេ ? ។ ជាំងតេកឆ្លើយថា ខ្ញុំបាទទឹងស៊ុ
ធ្វើការតបស្នងសងគុណលោកត្រាតែអស់ដំរិតចុះ ។ រំលោះនោះ ខៀវឡ

ក៏ចាត់ខាហានឲ្យចាំងតេក ១ ម៉ឺន ។ ចាំងតេកក៏លាខៀវឲ្យនាំខាហានចេញទៅ លុះទៅដល់ប្រទល់ខ័ណ្ឌគ្នា កឲ្យតាំងបន្ទាយជាមាំមួន ហើយចាំងតេកក៏ឡើងសេះនាំខាហានទៅដល់មុខបន្ទាយចូឆូ ហើយស្រែកចំអកបញ្ជឹចិត្តឲ្យចូឆូជាពាក្យអាស្រូវកាសឡេង ។ ។ ចូឆូឮដូច្នោះគិសួរខាហានថា ខាហានខៀវឲ្យនេះឈ្មោះអ្វី ? ។ មានខាហានម្នាក់ស្គាល់ឮស្រាប់ប្រាប់ថា ឈ្មោះចាំងតេក ។

ចូឆូឮដូច្នោះ ក៏នឹករលឹកឡើងថា ចាំងតេកនេះមានថ្លៃដៃខ្លាំងពូកែណាស់ គឺជាខាហានមាំឈ្នៀវ កាលគ្រាច្បាំងគ្នាទៅដំបន់ស្ទឹងអ៊ុយហោវដលមកនៅនឹងខៀវឲ្យនេះ ព្រោះសេចក្តីប្រថាំចិត្ត ឯមាំឈ្នៀវក៏តត់ចូលទៅនៅនឹងខ្លៅពីឯស្រុកសែឈួនទៅហើយ យើងត្រូវរិះគិតយកខ្លួនចាំងតេកមកធ្វើការជាមួយឯង ថាហើយក៏បង្គាប់ខាហានពាំងពួងថា ចាំងតេកនោះមានកម្លាំងនឹងថ្លៃដៃខ្លាំងពូកែណាស់ បើអ្នកកាល់គ្នានឹងចេញទៅច្បាំងនោះ ទោះបីចាំងតេកនោះនឹងចាញ់ប្រៀបយ៉ាងណា ក៏កុំធ្វើអន្តរាយឲ្យដល់ក្ស័យជីវិតឡើយ ចូរប្រយ័ត្នគិតតដៃឲ្យល្មមតែចាំងតេកជយកម្លាំងចុះ រហើយនឹងតេចាយចាប់ខ្លួនឲ្យបានគាំងរស់ នាំមកឲ្យយើងឲ្យបាន ។

ខៀវខាប់ខ្លួលប្រសាសន៍ហើយ ក៏ឡើងសេះចេញទៅច្បាំងនឹងចាំងតេកបាន ៥ ក្បួង ខៀវខាប់ក៏ជយរត់ចូលបន្ទាយ ហែហួរអៀនក៏ជរសេះចូលច្បាំងនឹងចាំងតេកបាន ៧ ក្បួង ហែហួរអៀនក៏ជយសេះរត់ត្រឡប់មក

ក្រោយវិញ ស៊ុឡងក៏បរសេះចូលប្រយុទ្ធនឹងជ្រាំងតេកបាន ១០ ភ្លេង ស៊ុឡងក៏ធ្វើជាបរយកតែចូលទៅក្នុងបន្ទាយវិញ ទៅធ្លុកបរសេះកំផាវចេញទៅច្បាំងនឹងជ្រាំងតេកបាន ៩០ ភ្លេង ទៅធ្លុកញាក់សេះបរត្រឡប់មកវិញ។ ជ្រាំងតេកបានជ័យជំនះអស់ពួកមាហានចូធ្លុតាំង ៤ នាយ ហើយក៏នាំមាហានចូលទៅក្នុងបន្ទាយវិញ ។

ឯនាយមាហានចូធ្លុតាំង៤នាក់ក៏នាំគ្នាស្ដីថា ជ្រាំងតេកនោះចំណានក្នុងការសង្គ្រាមណាស់ ។ ចូធ្លុក៏មានសេចក្ដីត្រេកអរ ទើបប្រឹក្សាជ្រុជ្ញានឹងចងដំណឹងគំនិតនាយមាហានទាំង ៤ នាក់នោះ នឹងគិតប្រការម្ដេច ទើបនឹងយកខ្លួនជ្រាំងតេកឲ្យមកនៅនឹងយើងបាន ។ ការសឿងធ្វើយថា ខ្ញុំបានដឹងថា ខៀវឡូនោះមានទំប្រឹក្សាម្នាក់ឈ្មោះអៀវសុង ឯអៀវសុងនោះជាមនុស្សលោភទ្រព្យសម្បត្តិណាស់ ប្រជ្ញាតែនឹងរកទ្រព្យយកមកពុកជាប្រយោជន៍ខ្លួន សុំឲ្យលោកគិតចាត់ចែងរកបរស់ទ្រព្យឲ្យនាំយកទៅឲ្យអៀវសុងឲ្យអៀវសុងគិតញុះញង់ខៀវឡូថា ជ្រាំងតេកនោះមិនមានចិត្តនឹងគិតច្បាំងទេ គិតតែនឹងប្រែចិត្តក្បត់ពីខៀវឡូ ។ កំតង់នឹងមានសេចក្ដីសង្ស័យនឹងជ្រាំងតេក រួចសឹមលោកគិតតទៅ គង់នឹងបានខ្លួនជ្រាំងតេកដោយងាយ ។

ចូធ្លុថាអ្នកគិតដូច្នេះ ត្រូវណាស់ តែយើងនឹងឲ្យនរណានាំរបស់ទាំងនោះ ចូលទៅឲ្យអៀវសុងក្នុងស្រុកហាន់តុងនោះបាន? ។ ការសឿង

ថាពេលព្រឹកស្អែក បើយើញចាំងតេកចេញមកឲ្យាំង ឲ្យលោកធ្វើជាចោលបន្ទាយរត់ចេញទៅ ចាំងតេកកំគង់ទីឯចូលទៅកន្លែងបន្ទាយនោះ ហើយលោកត្រូវកេមនុស្សណាដែលចេះនិយាយស្តីម៉ាំមួន ឲ្យយកមាសប្រាក់មកផែជាផែនបន្ទុះឲ្យចំរើលាក់ទុកកន្លែងអាវហើយបង្គាប់ថា បើចាំងតេកបែកត្រឡប់ចូលទៅក្នុងស្រុកវិញ ក៏ឲ្យចំរើនោះបន្ទុំចូលទៅជាមួយនឹងបានយកវបស់ចាំងនោះទៅឲ្យអៀវសុង ដល់ពេលយប់កាលណាសឹមលោកលើកទាហានចូលទៅបន្ទុំបន្ទាយ ចាំងតេកកំគង់ទីឯបែកធ្វើយរត់ចូលទៅក្នុងស្រុកវិញ ។ ចូឆួយលំយើញត្រូវផង កំចាត់ទាហានដែលមានប្រាជ្ញាម្នាក់ឲ្យធ្វើតាមពាក្យគាសៀង ហើយឲ្យស៊ុឡង់ទីឯទៅធ្វើជាកងចញ្ចោត ឲ្យខៀវគាប់ទីឯហួរអៀនលើកទាហានទៅតួនបង្ក្រាបទៅសងខាងផ្លូវ ។ នាយទាហានចាំង ៤ នាក់ ក៏ធ្វើតាមពាក្យចូឆួបង្គាប់គ្រប់ប្រការ ។

ឯចាំងតេកនោះ លុះយើញទៅធ្វើទីស៊ុឡង់លើកទាហានចូលទៅកំនាំទាហានចូលប្រយុទ្ធគ្នាទីឯទៅធ្វើ ស៊ុឡង់ក្នុងកណ្តាលខ្ចាត ។ ស៊ុឡង់ទីឯទៅធ្វើជាចយត្រឡប់ទៅវិញមិនបានចូលបន្ទាយ ។ ចាំងតេកកំលើកទាហានតាមទៅដល់មុខបន្ទាយចូឆួ ។ កំនាំទាហានរត់ចេញពីបន្ទាយ ចាំងតេកក៏លើកទាហានចូលទៅកន្លែងបន្ទាយ រែសបានត្រឿងសស្ត្រាវុធ ទីឯស្បៀងអាហារជាច្រើនណាស់ ចាំងតេកមានចិត្តកំរើប

ឲ្យតាំងតុះត្រៀមខុក លុះគេលកណ្តាលយប់ក៏នាំគាហានតាំងពួនស៊ីផឹកនៅក្នុងបន្ទាយគ្រហឹងអឺងកង ។

ឯស៊ីឡូនិងនៅធូក៏នាំគាហានចូលតីខាងទិសឯដើង ហៅហួអៀននាំគាហានចូលពីទិសឯកើត ខៀវគាប់នាំគាហានចូលពីទិសឯលិច ជា៣បែក ពុកតែទិសឯត្បូងបើកចំហ ព្រោះជាផ្លូវនឹងចូលទៅឯស្រុកហាន់តុង ។ លុះបានឮសូរផ្ទាវដាស់គាល់កាលណា ក៏នាំគ្នាជុតបន្ទាយឲ្យឆេះខ្លើងជា ៣ អន្ទឹ ហើយមកពលចូលលុកក្នុងបន្ទាយនោះ ។

ឯណៈនោះ ជ្រាំងតេកតទល់ពុំឈ្នះ ក៏នាំគាហានរត់ចេញទៅតាមទ្វារទិសឯត្បូង បួលទៅក្នុងស្រុកហាន់តុងវិញ គាហានបួនម្នាក់ដែលបន្ទំនៅក្នុងបន្ទាយនោះ កំបួលទៅតាមដល់ស្រុកហាន់តុងផង ក៏រះទៅដល់ហើយ ក៏ទៅរកអៀវសុងយកគ្រឿងទាសប្រាក់នោះទៅដំណាងហើយដំណបថា ត្បិតបួនធ្លាប់ទីវុយកុងជាមួយដំណឹងថា លោកមានតម្រូវប្រាជ្ញាជាមិត្តស្រលាញ់គ្នានឹងខៀវឡ សុំឲ្យលោកស្មោះសរជួយរះគិញញ៉ះញង់ឲ្យខៀវឡមានសេចក្តីសង្ស័យនឹងជ្រាំងតេក ឯផ្លូវមេត្រីរបស់លោកនឹងវុយកុងនោះ តង់នឹងមានតទៅមុខទៀត ។

អៀវសុងឃើញទាសនឹងប្រាក់ក៏មានចិត្តសោមនស្សត្រេកអរពន់ប្រមាណណាស់ ប្រាប់មកទាហាននោះថា អ្នកឯងវិលទៅប្រាប់ដួនដូនការដែលប្រាប្តូរមកខាងនេះប៉ុន្មាន យើងនឹងជួយរះគិតឲ្យបានដូចចិត្តខាងអស

តាហានគោះតំលាភៅគ្រាប់ចូលឆ្លៃត្រប់ប្រការ ចូលឆ្លងដំណឹងដូច្នោះក៏អរណាស់ ។

ឯអៀវសុងក៏ចូលទៅញុះញង់ខៀវឡៃថា ចាំងតេកគោះចេញទៅ ភយបន្ទាយចូលឆ្លងបានរបស់ទ្រព្យច្រើនណាស់ លុះនឹងរំនៅច្បាងនឹងចូលឆ្លងទៅ ខ្លាចក្រែងលោកដឹងការណ៍ថាបានរបស់ទ្រព្យពុក ចាំងតេកក្លែងធ្វើជាចោលបន្ទាយបែកឆ្ងាយរត់ត្រឡប់មកវិញ ប្រាថ្នាតែនឹងយករបស់គោះមិញ មកលាក់ពុកជាប្រយោជន៍ខ្លួន ។

ខណៈនោះ ខលួលចាំងតេកចូលទៅតំនាប់ខៀវឡៃ ហើយពណិនាសេចក្តីដែលបានទៅធ្វើការបែកត់មកឲ្យខៀវឡៃស្តាប់ត្រប់ប្រការ ។ ខៀវឡៃបានឮហើយ កំពុងគ្រោះមើលឃើញសមប្រកបនឹងពាក្យអៀវសុងនិយាយ ក៏មានសេចក្តីខឹងខ្លាំងណាស់ បង្គាប់តាហានឲ្យយកខ្លួនចាំងតេកទៅសម្លាប់ចេញ ដើម្បីផ្តៅចូលទៅអង្វរសូមទោស ខៀវឡៃក៏និយាយនឹងចាំងតេកថា យើងត្រមលើកទោសខ្លួនតាមដើម្បីសុំម្តងចុះតែគេលត្រឹកស្អែកនេះ ត្រូវនាំតាហានចេញទៅច្បាងខៀត បើគ្មានដំយុជំនះ លះបង់បន្ទាយរត់ចូលមកដូចម្តងនេះ យើងនឹងឲ្យកាត់ក្បាលខ្លួនចេញជាក្រាកដ ។ ចាំងតេកស្តាប់ហើយក៏មានសេចក្តីត្រេកអរណាស់ ខលួលបង្គាប់ខៀវឡៃ ហើយលាថយចេញទៅចាត់ចែងតាហានត្រៀមបម្រុងការ ។

(នៅមានត)

ព្រះរាជនិពន្ធរាមកេរ្តិ៍

អារម្ភកថា

ស្រាវជ្រាវដោយ លោក ឌុ . គាម

ព្រះរាជនិពន្ធរាមកេរ្តិ៍នេះ ជាឈ្មោះសៀវភៅមួយដែលខ្ញុំបានឃើញ នៅលើក្របសៀវភៅដែលព្រះគ្រូវាំង ជរ ព្រះនាមដើម អ្នកប្រែរឿង ។ លោកប្រែតាំងពីថ្ងៃអាទិត្យ ១០ កើតខែអស្សុជ ឆ្នាំកុរ បញ្ចស័ក ត្រូវនឹងថ្ងៃទី ២០ តុលា ឆ្នាំ ១៨២៣ ចប់នៅថ្ងៃពុធខែមាឃ ៤ កើត ឆ្នាំជូតទស័ក ព.ស. ២៦៦៧ ត្រូវនឹងថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៨២៥ ។

ព្រះគ្រូវាំងជរព្រះនាម ដើម សុគតនៅវត្តឧណ្ណាលោម ។ លោកបានប្រែរឿងរឿងរាមកេរ្តិ៍ចប់ហើយ លោករក្សាទុកដោយមិនដែលឲ្យនរណាខ្ចីចំឡងឬអាន ព្រោះលោកខ្វាចបាត់រឿងរបស់លោក ។ ពេលដែលលោកមានព្រះជន្មនៅឡើយ ចិត្តខ្ញុំចង់អានចង់ចំឡងរឿងរាមកេរ្តិ៍នេះជាពន់ពេក តែមិនដឹងជាធ្វើដូចម្តេចនឹងយកអានបាន ។ ចិត្តរបស់ខ្ញុំនៅតែប៉ងចង់បានរាមកេរ្តិ៍នេះយកមកផ្សាយឲ្យជនខ្លួនបានជ្រាបធង ។ មិនត្រឹមតែខ្ញុំសុំអានទេ គ្រាន់តែខ្ញុំសុំលោកមើលឲ្យឃើញច្បាស់នូវភាសៀវភៅ ក៏លោកមិនចេះកុំឲ្យមើលដែរ ព្រោះលោកខ្វាចបាត់ខ្វាចខូច នេះសរឲ្យឃើញថា លោកទុកជាក់ឥតវាងរបស់លោកមែន ។

ចុះហេតុអ្វីបានជាពេលនេះ ព្រះរាជនិពន្ធកម្រើ្តត្រូវបានយកមកបោះពុម្ពផ្សាយវិញ ?

ព្រះវិជ្ជាធរ អនិច្ចធម្មៅ សៀវភៅនេះនៅក្នុងការគ្រប់គ្រងរបស់កិក្ខុ សរ-មាង ។ តែសូមជ្រាបថា ពេលដែលអត់ព្រះត្រូវអង្គនេះ សៀវភៅកម្រើ្តរបាំត់របាំយៅកន្លែងនេះខ្លះ កន្លែងនោះខ្លះ ដល់ខ្ញុំមកពីសហរដ្ឋអាមេរិកវិញ ខ្ញុំទៅសុំពីកិក្ខុ សរ-មាង យកមកចុកជាសម្បត្តិផ្ទាល់ខ្លួន ។ ព្រះកិក្ខុអង្គនេះជាអ្នកស្រឡាញ់អក្សរសាស្ត្រ លោកយល់ច្បាស់ទូវដំរៀបនៃអក្សរសាស្ត្រ លោកក៏ឲ្យមកខ្ញុំ ។ ភាគដែលបាត់ទៅខ្លះ ខ្ញុំទៅតាមរកយកមកបានគ្រប់ភាគវិញ ។

រៀបសរសេរ

សៀវភៅនេះ សរសេរលើក្រដាស់ស្តើង ដែលយើងហៅថាក្រដាស់ចិន ហើយទុកម្រាក្សណ៍ក្រចឆ្វេងចំនួន ១០៧ ខ្សែ ។ ដល់មកសម័យក្រដាស់សម្លាណិ លោកញាយាមចម្លងទុកក្នុងសៀវភៅធំស្រួលអាន តែលោកចម្លងបានតែ ១ សៀវភៅ លោកក៏ទុលអនិច្ចធម្មៅ ។

ព្រះរាជនិពន្ធកម្រើ្តនេះ លោកសរសេរជាពីរបែបគឺ៖

១ - ពាក្យកាយ

តាមខ្ញុំសង្កេតមើលពាក្យនៅក្នុងរឿងនេះ ខ្ញុំតែងជួបប្រទះដូចសំដី

នៅក្នុងរឿងកមរកេ្ខវដែលបោះនៅពុទ្ធសាសនបណ្ឌិត្យ ហើយមានពាក្យ
ខ្លះមិនមាននៅក្នុងវចនានុក្រមខ្មែរយើងផង តែខ្ញុំបានយកវចនានុក្រម
សំស្ក្រឹតមកពិនិត្យមើលទៅ ឃើញថាមានឈ្មោះ យក្ស ឬ ឋក្ស នោះ ។
មែន ទើបខ្ញុំកត់ទុកដាក់នៅក្នុងបទានុក្រម ។ នៅមានពាក្យខ្លះទៀត
ច្រើនតែពាក្យដែលមាននៅសិលាចារឹកខ្មែរយើងសម័យអង្គរ ។

២- ពាក្យកាព្យ

សំដីនៅក្នុងកមរកេ្ខវនេះ មានខ្លះសរសេរជាកាព្យ ខ្លះសរសេរកេយ
ដូចខាងលើ តែទុកជាសរសេរកេយ ក៏នៅតែជួនណាំគ្នាដែរ ។ ខ្ញុំសូម
ជូនប្រយោគកាព្យខ្លះគឺ :

រកជនិពន្ធរឿងកមរកេ្ខវ រិះរកមរឿងកុំពិសយ៍
មិនជាខ្វឹមសារព្រះរក្ខន័យ កុំទុកព្រះទ័យជាទីតាំង ។
បើស្តាប់ឲ្យធាប់ក្រឡាប់ចិត្ត ចូរគិតអនិច្ចាពីអនិច្ច
សញ្ញាវិញ្ញាណមានសញ្ញា. ត្រង់ទាំងស្រីប្រុសមានវិជ្ជា ។

ដោយខ្ញុំយល់ឃើញថាកមរកេ្ខវដែលបោះផ្សាយពីពុទ្ធសាសនបណ្ឌិត្យ
មិនត្រង់ត្រាន់ ខ្ញុំគិយកឬរឿងនេះមកចុះក្នុងកម្ពុជសុរិយាម្ពង ។ ដូច្នេះខ្ញុំ
អនុញ្ញាតឲ្យចុះក្នុងកម្ពុជសុរិយា តែមួយឡើងទេ ហើយកេ្សមទុំមិនឲ្យ
បម្ងន់ចេញទៅបោះពុម្ពឬតូរប្រែឡើយ ។

ព្រះរាជនិពន្ធរាមកេរ្តិ៍

តាមការស្រាវជ្រាវបស់ ខ.តាម

(រក្សាសិទ្ធិមិនឲ្យបង្ហូរ មិនឲ្យគួរប្លែយ)

ភាគ ១

ព្រះរាជនិពន្ធរាមកេរ្តិ៍ខ្សែ ១ និយាយតាំងពីតែហិរណយក្ស អ្នកផែនដី លុះទៅព្រះជាអតោមទន្ត ប្រគល់រាជសម្បត្តិឲ្យព្រះជាអង្គជាល ដល់ទៅអស្សុរព្រហ្មឡើងទៅសូមពរពីព្រះឥស្សរ លុះដល់ទៅត្រីបូរាមឡើងទៅចំអាចំអន់ឲ្យស្រីសួតំ ។

ខ្ញុំឯសំដែងពីហិរណយក្សទៅសូមពរពីព្រះឥស្សរតាំងពីដើមបានខ្លាំងពួកែ ព្រះឥន្ទ្រព្រហ្មស្ថានសួគ៌ ១៦ ជាន់ក៏ក្រែងខ្លាចអំណាចបារមីមិនមានអ្នកណាហ៊ានតបទ្វី រួចតាំងអ្នករដ្ឋផែនដី ទ្វីបទាំងបួនកេះ អមរគោយានីកំបានស្រេចហើយ រាម្អុរគ្រឿតនាយកផែនដីទៅបាតាល ។

កាលខោះពួកខេវគា ត្រង់ស្ថានភ័យរំដួល ទាំងគ្នាចុះមក លុះដល់ស្ថានតិរីកោសថ្វាយបង្គំទូលព្រះឥស្សរថា ហិរណយក្សវាញាំញីស្ថានទាំង ១៦ ជាន់លើក្រោម ហើយមិនតែប៉ុណ្ណោះវាម្អុរទាំងផែនដី ឥឡូវនេះ វានាំចុះយកទៅបាតាល ខេវបុត្រខេវគាមានព្រហ្មទណ្ឌធ្ងន់អន្តរាយស្ទាប់វិនាសអស់ហោង ។ សូមទ្រង់ព្រះករុណាជួយជីវិត អ្នកទាំងអស់ផង គ្រានោះព្រះឥស្សរបានស្តាប់ហើយ ទ្រង់ខ្ញាល់ ហើយមានបន្ទូលថា អាហិរណយក្សនេះ វាមិនគាន់តាស្សសត្សដូចបណ្តាំអញ ទើបតុកវាពុំបានកំទ្រង់ប្រើព្រះនាកមណ៌ឲ្យទៅចំផ្ទាញអស្សុរហិរណយក្ស សម្លាប់បង់ទៅ។

កាលនោះព្រះនាគយណ៍ ទទួលព្រះឧត្តារៈហើយ ថ្វាយបង្គំហោះចុះ
ទៅបាតាល លុះដល់ ទើបឃើញហិរណ្យកូសែងបុទ្ធីត្បៀតផែនដី
ចាំង ៣ ហើយព្រះនាគយណ៍កំទិមិតទួនទៅជាជ្រូកស ចង្អុមពេជ្រដេញ
ខ្វេះអសុក កាលនោះ ហិរណ្យកូយើញជ្រូករត់ដម្រង់ចូលមក អសុក
កំទ្រង់ក្រវៃក្រោធណាស់ កែកឡើងក្រហមដូចភ្លើង ទន្ទ្រើដើងលាន់ឮ
ចាំងត្រយ៉ចក្រ ព្រោះមិនដឹងជាព្រះនាគយណ៍ អសុកកំចូលដេញជ្រូក
កាលនោះជ្រូកព្រះនាគយណ៍ កំចូលប្រយុទ្ធជាញ័យ ទ្រង់ខ្វេះដើងដៃ
ទួនអសុកដួលជាច់ជាពីរ ប៊ីតំណាត់ស្លាប់ទៅ ។ សម្លាប់ស្រេច ជ្រូកព្រះ-
នាគយណ៍កំយកផែនដីមកលាតុកដូចដែលវិញ ។ ហើយទ្រង់ប្រែកាយ
ជាព្រះនាគយណ៍វិញ គាន់ដំបងពេជ្រហោះឆ្ពោះទៅលើមេឃ ហើយដល់
សមុទ្រកំទ្រង់ចុះមកតង់ទៅឆ្នេរសមុទ្រជាកណ្តាលជាធំទូលាយ កំចូលទ្រង់
បន្ទំតាំងពិធីលើបល្ល័ង្កនាគព្រួតចឹកកាយបរិកម្មតាមពិធីការហើយ កំបង្កើត
ដុះផ្កាឈូកពីផ្ចិតព្រះអង្គ តមកកើតជាកុមារប្រុសមួយល្អុះល្អះ ទៅកន្ទុងផ្កា-
ឈូក ហើយព្រះនាគយណ៍កំទ្រង់ត្រេកអរណាស់ បេះយកកុមារពាហោះ
យកមក លុះដល់ ទើបចូលទៅគាល់ព្រះឥស្សរ យកកុមារថ្វាយហើយទូល
ពីការសម្លាប់ហិរណ្យកូ សព្វគ្រប់តាមដំណើរហើយ ។ ព្រះឥស្សរ
យើញកុមារនោះ កំទ្រង់មានព្រះទ័យនោះត្រេកអរ ហើយទើបមានព្រះ-
បន្ទូលថា អាហិរណ្យកូវ៉ាស្លាប់ទៅ ត្រ័យលោកកំបានសុខសប្បាយ

ស្មោះសរ ឯអង្គកុមារនេះកំពូដតង្ឃវង្សព្រះនាកយណ៍ នឹងកើតជាដើម
តង្ឃក្រុសត្រ ប្រសើរលើសលោកក្នុងជម្ពូទ្វីបជាន់ក្រៃលែង នឹងបាន
រំលត់ទុក្ខបង្ក្រាបកង្វល់លោកាត្រៃតាកតហោង ។ ត្រាសហើយទើបមាន
ទេវឧង្ការបង្គាប់និងព្រះឥន្ទ្រា ឲ្យចុះទៅកសាងព្រះនគរកុនិងជម្ពូទ្វីប ឲ្យ
ទុត្តមរុងរឿងមង្គលសួស្តីពិជ័យជានិ៍ កាលនោះព្រះឥន្ទ្រាកំក្រាបថ្វាយបង្គំ
ទទួលព្រះឧង្ការព្រះឥសូរ ហើយហោះត្រឡប់មក កាន់ស្ថានតាមនវិញ
កំតង់លើបល្ល័ង្កវ័ត្ន ទ្រង់បង្គាប់ព្រះមាតុលីឲ្យកណ្តាហូនទេតទេវឲ្យនាំ
គ្នាចុះទៅ ។ សាងជានិ៍ ។ កាលមោះព្រះមាតុលីថ្វាយបង្គំហើយដោយ
គ្រែកអវថយមក ទើបចាត់ពួកទេវតាជាបរិវារសុទ្ធតែមានប្រាជ្ញាក្សៀវក្សាហាន ពួកមួយកាន់ទង់មយូរនាំមុខ ពួកមួយកាន់ទង់ពណ៌ស៊ីមួងរូបតេសរ
ភជសីហ ពួកមួយកាន់ទង់រូបមករពណ៌ខៀវ ពួកមួយកាន់ផ្កាបទុម ព្យ
ហៃហាមអមស្តេចដ៏រឿកវ័ណត្រមគ្នារង់ចាំស្តេចទន្ទឹងចរលីលា ។ កាលនោះ
អង្គសម្តេចមាឃភឡទេវរាជស្តេចចុះស្រេចព្រះគង្គាជំរះអង្គ នាងទេតកញ្ញា
នៅចាំបំរើស្រេចទើបស្តេចមកគង់លើ ពួកវ័ណតេជ្រយន្តរថដ៏រ
ហើយហោះចុះមកដល់ជម្ពូទ្វីប កំទ្រង់ក្រឡេកត្រង់ទិសខាងទិសឦសានទើប
ឃើញទិសបូណ៌ភូមិគីនពសុនាជាល្អត្រឹមត្រូវ មានមហាឥសី ៤ អង្គទ្រង់
ព្រឹទ្ធិបរិកម្មចំរើនឈាន កំទ្រង់បញ្ជាប់ពួកទេវបរិវារកំទ្រង់ចុះតាពួកវ័ណ
កំចូលទៅកាន់ព្រះមហាឥសី កំថ្វាយបង្គំនមស្ការ ហើយទ្រង់សួរថា

ព្រះមហាឥសីដែលព្រះអង្គមកសាងព្រឹទ្ធនៅក្នុងព្រៃនេះ មកចាប់ផ្តើមនៅ
ឆ្នាំហើយ ចាំង ៤ អង្គក៏ចាននេសចក្តីសុខទុក្ខដូចម្តេច ហើយទ្រង់ព្រះនាម
អ្វីខ្លះ ទើបមហាឥសីចាំងបួនចាននស្តាប់ហើយទើបទូលតបទៅវិញថា អាត្មា
ចាំងបួនបែបនេះមកនៅសាងព្រឹទ្ធ ក្នុងព្រៃអរញ្ញានេះប្រមាណចាប់ចាននមួយ
សែនឆ្នាំហើយ រីឯនាមករនោះ អាត្មាឈ្មោះអាចន្ទតាវី ១ អង្គមួយនោះ
ឈ្មោះយុត្តអក្ខរៈ អង្គមួយនោះទៀតឈ្មោះទេហឥសី អង្គមួយនោះ
ឈ្មោះ យោគៈ ឥសីមានតបតេជចូន្តីស្មើគ្នា ។ ទើបមហាឥសីក៏សួរទៅ
ព្រះឥន្ទ្រវិញ ហេតុដូចម្តេចក៏ចាននជាស្តេចចុះមកព្រមចាំងទេវបរិវារជា
អស្ចារ្យណាស់ ។ កាលនោះព្រះឥន្ទ្រាធិរាជចាននស្តាប់ ក៏ទូលតបតុន
ដីកាព្រះមហាឥសី ដែលខ្ញុំមកចាំងនេះ ព្រះអាចារ្យត្រូតអង្គព្រះឥសូរជា
ម្ចាស់ ឲ្យខ្ញុំមកសាងព្រះនគរពេជនាទីថ្វាយទេវពេជកុមារ ព្រះឥន្ទ្រក៏ទ្រង់
សម្តែងហេតុតាំងតែពីដើមដល់ចុងរៀងមកថ្វាយមហាឥសី មហាឥសី
ក៏ជ្រាបសេចក្តីសព្វគ្រប់ ក៏ត្រេកអរ ទើបមានតុន្ធដីកាថាព្រៃនេះល្អ
ប្រសើរណាស់ ឈ្មោះហៅថា ធាកវតី នៅខាងទិសបូពាត្រូវដោយ
លក្ខណាជាទី អាត្មានឹងប្រាប់នាមតាមឈ្មោះនគរឲ្យជាមង្គលសិរីសួ-
ស្តីប្រសើរ ចូរយកឈ្មោះព្រៃនេះនិងនាមអាត្មាចាំង ៤ ជាកំផ្លុំនឹងគ្នា
ឈ្មោះហៅថាក្រុងស្រីអយុជ្ឈាធាវតីហោង ខ័ណ្ឌជាព្រៃតតអង្វែងរៀងទៅ ។
កាលបើព្រះឥន្ទ្រចាននស្តាប់ព្រះឥសីប្រាប់ ជូរញ្ជះហើយក៏

ចូលចិត្ត ទើបប្រើឲ្យព្រះវេស្សកម្មទៅបុត្រទីម្នាក់ឆ្ងាយ ព្រះនគរឲ្យ
ទទួលរីកអធិកទត្តមុខរឿងធំទូលាយពណ្ណរាយល្អល្អះ ។ គ្រានោះព្រះ
វេស្សកម្មទៅបុត្រទទួលទៅទន្លាយស្រេច ហើយក៏នាំគ្នាទៅឈរនៅត្រង់
មុខស្ថានទេពាក្សា ជាលំដាប់ព្រៃនោះ កំពង់សំណែងឥន្ទ្រទ្វីបទីម្នាក់ជា
ព្រះនគរស្រេចមួយរំពេច រីមហាប្រាសាទទាំងប៉ុន្មានល្អរុងរឿងកំពស់
ស្មើនឹងអាកាសក្តីប្រាលរន្ធាលសុទ្ធសឹងតែកែវកែមរចនាហើយមានរោងរថ
ឆ្នូង ស្តាំ ឋនូប ស្រស់ស្អាតក្រមការសេនាអមាត្យតាហានមានសេះដំរីជាដើម
គ្រប់បរិបូណ៌ស្រេចមានកំផែងរាជធានី ហើយមានស្រះស្រង់ទទ្យាន ហើយ
ទើបប្រកបតាមនគរគាំងជាមង្គលសួស្តីដូចពាណិជាមកហើយយកទ្វីបទាំង
៤មកទៅជាបរិវារពល ប្រជានុរាស្ត្រធនធាំងឡាយសប្បាយរុងរឿងហើយ
ស្តេចវើសស្រីស្តុំក្រមការយកឲ្យតែល្អគ្រប់លក្ខណ៌បញ្ចតិធកល្យាណី ប្រ-
មាណ ៥ ម៉ឺន ៦ ពាន់ ។ លុះសាងព្រះនគរស្រេច អង្គព្រះអគ្គ្រាធិរាជ
កំនាំហ្វូងទេពទៅទីទៅក្នុងកែលាស លុះដល់ហើយក៏នាំគ្នាថ្វាយបង្គំព្រះ-
ឥសូរទូលតាមសេចក្តី ដែលទ្រង់ប្រើឲ្យទៅសាងព្រះនគរនោះជាស្រេច
ហើយសូមទ្រង់ជ្រាប ។ ព្រះឥសូរក៏បានជ្រាបហើយក៏ត្រេកអរណាស់
ទើបត្រាស់ទៅទន្លាយថា ម្នាលចៅ ចូរអ្នកចុះទៅត្រង់ក្រុងស្រីអយុធ្យានា-
ការតិ រាជស្ថានជាតំពូលលើសលោតាមហាប្រុសើរ ចៅឯងជាតួជាតឲ្យ
វង្សក្រកូលព្រះមាកយណ៌ចៅនឹងបានបង្ក្រាបអសុរកាត ទើបព្រះមានមាន

សន្ធតឲ្យឈ្មោះជាអនោមាទន្តខេវសុរិវង្ស ទ្រង់ប្រទានព្រះទម្រង់ នូវសេវ
ព្រះទំនួត្រីពេជ្រដំបង ហើយទ្រង់ឲ្យពារប្រសិទ្ធិឲ្យមានតបៈតេជៈបុព្វីកានុ-
ភាព កុំឲ្យសត្រូវណាមកតបុទ្ធីបានឡើយ ហើយឲ្យរុងរឿងវឌ្ឍនាការ
មង្គលសួស្តីហោង ។ ព្រះអនោមាទន្តក៏ក្រាបថ្វាយបង្គំទទួលពរព្រះឥសូរ
និងខេពសាវុធទាំងពួងស្រេចហើយ ក៏ទូលថាសូមទ្រង់ព្រះករុណាជួយ
ទំនុកបំរុងរក្សាផង ទើបព្រះឥសូរបង្គាប់ទៅព្រះឥន្ទ្រាធិរាជនិងខេវបុត្រ
ខេវតាទាំងពួងថា ឲ្យយកត្រុងកជាវ ជាយានឲ្យទៅអញ្ជើះ ហែទៅ
សោយរាជ្យក្នុងវិលាថ្ងៃ នេះជាថ្ងៃមង្គលឫក្សល្អត្រូវប្រគល់នគរឲ្យទៅ
អញ្ជើសោយរាជ្យ ព្រះឥន្ទ្រកំទទួលព្រះឧត្តារហើយថ្វាយបង្គំលាមកចាត់
ចែងរៀបចាំជង្រែព្រះអនោមាទន្ត រួចអនោមាទន្ត កំទ្រង់ត្រឿងប្រដាប់
ប្រដារស្រេចហើយក៏កាន់ធ្នូសរដំបងត្រីពេជ្រ ហើយព្រះឥន្ទ្រលុះបានដំណើ
ឫក្សពេលកំនាំអនោមាទន្តហោះចុះមក ដល់នគរក្រុងស្រីអយុជ្ឈាក៏អញ្ជើ-
សេកឲ្យសោយរាជសម្បត្តិជាសុខក្សេមក្សាន្ត ហើយតាំងចាត់រើសរកយក
ស្រីពីទន្តរកោដ្ឋីបមក ឈ្មោះនាងមណីកេសរល្អស្អិតត្រចង់ត្រចះដូច
ដួងព្រះចន្ទមកធ្វើជាព្រះអគ្គមហេសីធំ ហើយមានស្រីព្រះស្នំក្រមការមួយ
ម៉ឺនប្រាំមួយពាន់ជាកំណាន់តាល់ចំរើ មួយទៀតមានសេនាពាហនសេនា
បតិមន្ត្រីតូចធំគ្រប់ប្រការ ថ្វាយរាជកុមារក្សាធានីស្រេចហើយ ទើប
ព្រះឥន្ទ្រាថ្វាយជ័យថ្វាយពរ ទាំងទេពនិករអមរមេឃកំថ្វាយស័ង្ខសាធុការ

រហាង ។ រួចហើយព្រះអង្គខ្ញុំនិងទៅអមរកាំរហាះទៅកាន់ស្ថានពិមានវិញ
រហាង ។ លុះដល់ព្រះអនោមាទន្តស្តេចក៏សោយរាជ្យតាំងក្នុងនគរស្រី
អយុជ្ឈា ក៏ទ្រង់មានតេជៈតបៈចូលទៅក្នុងព្រលោកតាំងបី ក៏ពឹងបុណ្យ
សម្ភារព្រះបារមីត្រង់នគរ ពួកបច្ចាមិត្រតែឮកំកោតក្រែងស្ងែងស្ងប់ព្រឺ
រោម តាំងពួកពិឡាធរកិន្នរយក្សត្រុង គន្ធព្វគន្ធព នគរគួចជំ ក៏
សឹងតែខ្លួចខ្លាចតាំងអស់ហោងស្តេចតង់ជាសុខក្សេមក្សាន្តសម្រាន្តព្រះអង្គ
នេះនិងសំដែងតទៅ ពីសហម្បតិ្តព្រហ្មទៅក្នុងពិមានរ័ត្នមណីមាន
សេចក្តីសុខត្រង់ពីរភ្រឺ លុះមួយថ្ងៃក៏មានសេចក្តីរលឹកនឹកដល់ សហ-
មល្លីវនជាសុរិវន្តព្រឹក្ស ដែលឲ្យទៅសោយរាជ្យទៅនគរក្រុងកោះ
លង្កា ដែលរត់ខ្លាចចក្រព្រះនារាយណ៍ទៅទៅនគរចោតាលដែនខនគរលង្កា
ខ្ញុំបនោះ មិនមានអ្នកណារក្សាពាជាស្ថានសួច់ស្ងាត់សូន្យឈឹងយូរមកជា
អង្វែង ក៏នឹកស្តាយវង្សព្រហ្មនិងអស់ទៅ បើដូច្នោះអញនឹងតិតសាងនគរ
ឲ្យរុងរឿងឡើងវិញឲ្យកុកជាល័ក្ខណ៍នគរបវរពាជានី ។ ព្រហ្មគិតហើយ
ទើបមានទេវបញ្ជាត្រាស់បង្គាប់ទៅព្រហ្មជាបរិវារឲ្យរៀបហង្សមាសជាដំនិះ
អញនឹងដឹះចុះទៅសាងនគរលង្កាខ្ញុំប ។ ទើបអង្គជាព្រហ្មខ្លួនឯង
ក៏ថ្វាយបង្គំលាថយមកគេណ្ឌពួកព្រហ្មស្មុខ្លួនតែមានបុត្តិកាទុកាពក្តាហានពួក
មួយកាន់ខន់ទាំពលព្រហ្មចរយោគ្រា មួយពួកទៀតស្មុខ្លួនតែកាន់ស្មូតច្បូត្រ
ហែរឆ្វេងស្តាំ ពួកខ្លះកាន់ខន់រូបក្មេក ហែទាន់ហង្សមាស ពួកមួយទៀត

ហែតាន់ខ្សែរឿងរាយដុំវិញមានត្រៃស័ង្ខនោតតាឡូតធំជាដើមហែស្តេចចុះ
មក ។ កាលនោះ ព្រះបាទសហម្បតិព្រហ្មកំតង់លើហង្សមាសទុកាស
ចុះមក ឃើញក្តុងនិលក្រឡាខ្ពង់ខ្ពស់កំពស់អាកាសធំ ក្រៃលែងនៅ
កណ្តាលពិភពជាន់ជាប្រស្ថាន សម្បុរពណ៌ខៀវដូចនីលវត្តាចុងកំពូលក្តុ
នោះមានម័ក្តុក្តែក មហាការ្យសិទ្ធិឫទ្ធិក្រៃ ក្តុនោះប្រសើរណាស់ ទើប
ព្រហ្មប្រើព្រះ វេស្សន្តព្រហ្ម និម្មិតសាងសុទ្ធតែកែវសុវណ្ណមណីតែ
ដោយឫទ្ធិសត្តា មានកំផែងសព្វគ្រប់ជាស្រេច សាងប្រាសាទមីកំពូល
ប្រាំល្អដូចជាស្ថានត្រៃត្រឹង្ស ទើបយកនតមហាសមុទ្រជាបន្ទាយដុំវិញ
ចាត់ពួកហ្វូងត្រីជានាយកងល្បាតដើងទឹក ត្រីឆ្លាមមកពាំនូនជាតយចាំ
ល្បាតខាងក្រោម ខាងក្រោយព្រះមហាសមុទ្រនោះឲ្យតីរសឿយក្សរក្សា
ហើយចាត់ឫទ្ធិកាល្បអសុកឃុំពលយោធា មួយសែនគោដក្រៃលែងក្សា
ខាងផ្លូវអាកាសផ្លូវសួគ៌ គន្ធ័ន ក្រៃលែងក្សានៅខាងចក្រវាឡ ចាត់ចែង
រៀបចំនគរជារួចស្រេច ។ ទើបព្រះបាទសហម្បតិព្រហ្មទ្រង់សន្ទុត់
នាមនតា ឲ្យឈ្មោះហៅថានតក្រុងលង្កាទ្វីប ទើបចាត់យកអសុរ
ពួកមានតីក្តុងក្រវាឡ អស្សកណ្ណ មកជាសេនាគាមាត្យពលរហ៍ចាំង-
អស់មួយសែនគោដក្តុមណ្ឌ ស្រេចហើយទើបគ្រាស់ច្រាច់ទៅជតា
ព្រហ្ម ដំរែះចំណានខាងសៃយវេមន្តនោះ ចុះមកសោយរាជ្យគ្រង
សម្បត្តិសុរីរង្សត្រកូលតរៀងមកក្នុងត្រៃលោកហោង ។ អង្គជតា

ព្រហ្មបានស្តាប់ទេវតាថ្លែង កំលើកករអញ្ជលីទូលតបទៅវិញ ដែលព្រះអង្គ
ទ្រង់មេត្តាករុណានោះព្រះគុណធ្ងន់ជាងផុតលើសិរសា ទ្រង់ត្រាស់ប្រើ
ហើយ កំទូលតាមព្រះតថាគត កាលនោះព្រះបាទសហម្បតីព្រហ្មបាន
ស្តាប់ហើយកំត្រេកអរសាទរណាស់ ទើបឲ្យនាងមលិកា ទ្រង់ចម្ការពិធ
កល្យាណី ជាស្រីមានលក្ខណាមកធ្វើជាអគ្គមហេសី ហើយរើសស្រី
ទេពកញ្ញាព្រហ្មយកមកធ្វើជាស្នំក្រមការ ចំរើនាល់ហ្មឺមួយម៉ឺនប្រាំមួយ
ពាន់ជាប្រក្រតី ។ ហើយសហម្បតីព្រហ្មទ្រង់ព្រះពានត្រាស់ដំបន្ទរពេជ្រ
មានឫទ្ធិអានុភាព ហើយប្រទានឆ្លើយសំរាប់ព្រះនគរ ប្រាប់ថាបើកើត
មានពួកបច្ចាមិត្រលើកមកច្បាំងយកជានិច្ចកាលណាហើយ ឲ្យយកឆ្លើ
យ តែបើកច្បាំងព្រះនគរ នឹងចាំផ្ទៃព្រះអាទិត្យថាត់ឆ្ងាំតដូចយប់ ពួក
សត្រូវនោះនឹងមើលមកក្រុងយើងតុំយើញ ខាងយើង មើលទៅយើញពួក
សត្រូវតាំងអស់ ឆ្លើយនេះមានអានុភាពណាស់ ទេវបុត្រទេវតា
ឥន្ទ្រព្រហ្មអសុរកេតតាំងប៉ុន្មានកំរួបរួចអំណោចឫទ្ធិ ។ កាលនោះព្រះបាទ
ចតុរតក្រព្រហ្មកំក្រាបថ្វាយបង្គំ ទទួលត្រាស់ដំបន្ទរពេជ្រហើយ រៀនវេទ-
មន្តកំចាំបានអស់ដូចសេចក្តីហើយកំត្រេកអរសោមនស្សណាស់ហោង ។
ព្រះបាទសហម្បតីព្រហ្មកំប្រគល់ពរសម្បត្តិនៅក្រុងលង្កា ឲ្យហើយកំឲ្យ
ពរសព្វសាធុការថាឲ្យអ្នកមានសិរីសួស្តីមង្គលវឌ្ឍនាការ ឈ្នះអស់សត្រូវ
តាំង ១០ ទិសកុំឲ្យមកបៀតបៀនផ្តន្ទាបាន ឲ្យពរស្រេចហើយស្តេចកំ

ឡើងតន់លើហាង្រមាសហោះឡើង ទៅគាន់ប្រាសាទវិមានស្ថានអាភ្នា
វិញហោង រីឯព្រះបាទចតុរកត្រូគ្រប់គ្រងសោយរាជសម្បត្តិ នៅក្រុង
លង្កាទ្វីបនិងនាងមល្ងិកាជាអគ្គមហេសី ទ្វាស្រីស្តុំក្រមការាំង ១.៦០០
ជាសុខក្សេមក្សាន្តសម្រាន្តព្រះទ័យជូនជាស្ថានត្រៃត្រឹង្សាសួគ៌ លុះយូរ
បន្តិចទៅ នាងមល្ងិកាជាអគ្គមហេសី ក៏ទ្រង់គតិត្រប់ទសមាសក៏ប្រសូត
ព្រះរាជបុត្រាមួយ កើតទៅជារូបអសុភមុខ ១ ដៃ ៤ ព្រះបិតាមាតាចាំង
ពីរ ក៏ត្រេកអរសោមនស្សសោទរហើយ ក៏ប្រទានឈ្មោះហៅថា
ឡាត្សរៀន ព្រហ្មមានឫទ្ធិតានុភាពឫទ្ធិខ្លាយ សាយសព្វត្រប់ទនតរ
ចាំងអស់ហោង ។

នេះនឹងនិយាយអំពី ព្រះចាទអនោមាទន្ត ទ្រង់សោយរាជសម្បត្តិ
បានមួយម៉ឺនឆ្នាំ មានព្រះរាជបុត្រាមួយទ្រង់ព្រះនាមឈ្មោះព្រះចាទ អជ្ជ-
ចាល មានឫទ្ធិអានុភាពណាស់ ឮដូចៅដល់ទ្វីបចាំង ៣ ក៏ខ្លាចភ្លាច
អំណាចព្រះចារមីព្រះអង្គហោង ហើយព្រះចាទអនោមាទន្ត អភិសេក
ព្រះរាជបុត្រា ឲ្យសោយរាជសម្បត្តិគ្រង់ស្នងរួចស្រេច ស្តេចក៏ទ្រង់សុវណ្ណ
គតិទៅ ។

(នៅមានត)

រឿងព្រៃងបិន: (តមក)

Le Renard roi (Conte Tibétain)

ចចកកែ្លងនើ្វជាស្តេច

លោក ក៉ាយ-ប៊ុក ប្រែពីភាសាថាក់ង

តាំងពីយូរណាស់មកហើយ មានចចកមួយល្មោកខាងការហារពន់ប្រមាណ ចូលទៅក្នុងភូមិមួយ ដើម្បីនឹងលួចមាន់តេជាអាហារ ។ ទៅដល់ជិតកេងរម្ងាស់ (ឆ្នះ) ចចកក៏ឮាក់ទៅក្នុងផ្ទាំងខ្ទះរម្ងាស់នោះ ។ ចចកបានតត់ចេញពីផ្ទាំងខ្ទះចោលចូលទៅក្នុងចំលំនៅរបស់ខ្លួន ។ ចចកដែលមានខ្លួនជ្រលក់ឆ្នះ ក៏មានសភាពភ្លឺរលើបរលោងចាំងចែងដូចត្បូង ។ ចចកបានចោលទៅដល់ក្នុងព្រៃមួយ ។ មានពួកចចកឯទៀត បានមើលមកចចកដែលចោលនោះ ឃើញថ្លែកអស្ចារ្យ ។ ពួកចចកទាំងនោះក៏សួរចចកដែលថ្លែកនោះថា :

« អ្នកឯងជាសត្វអ្វី ? »

ចចកថ្លែកនោះ ក៏តបថា : ខ្ញុំជាសត្វនាមថា « អ្នកពាក់មកុដកដ » (Porte Couronne) ។ ព្រះចៅអធិកដនៃមហារមេឃ បានឲ្យខ្ញុំមកធ្វើជាស្តេចនៃចតុប្បាទទាំងឡាយ ។

ពួកចចកទាំងឡាយ ក៏យកព្រះរាជទ្រព្យរៀបផ្សាយចំពោះសត្វទាំងឡាយ ។ សត្វទាំងឡាយក៏មកមើលមហាភជរបស់ខ្លួន ឃើញថ្លែកពីសត្វចតុប្បាទទាំងឡាយ ។ ពួកសត្វទាំងនោះ ក៏ព្រមព្រៀងគ្នាលើកចចកដែល

ភ្នាក់ក្នុងឆ្នូះនេះ ជាមហាពរបស់ខ្ញុំ ។

អ្នកពាក់មកុដពាជ ក៏ឡើងជិះអស្សតរ តាំងសិង្ហជាព្រះពាជគ្គរៈហើយ មានសត្វចតុប្បាទជាបរិវារជាច្រើន បានធ្វើព្រះពាជដំណើរ ទៅតាមទិសជនបទនៃប្រទេសរបស់ខ្លួន ។

តមក អ្នកពាក់មកុដពាជ បានមានបន្ទូលឲ្យហៅនូវសត្វចតុប្បាទឯទៀតៗ ឲ្យចូលមកក្រាបបង្គំគាល់ ។

មានកាលមួយថ្ងៃ អ្នកពាក់មកុដពាជ នឹកឃើញដល់មាតារបស់ខ្លួន ដែលស្ថិតនៅជ្រលងភ្នំឆ្ងាយ ហើយមានចំណងឲ្យមាតានេះមកសោយសម្បត្តិនឹងកិត្តិយសរបស់ខ្លួន ។ អ្នកពាក់មកុដពាជ ក៏បានត្រាស់ប្រើបាចកមួយឲ្យយកព្រះពាជឧបហារយៅជូនមាតាថា «មាតាខ្ញុំ ! សូមមាតាអញ្ជើញមកប្រញាប់ កូនមាតាឥឡូវនេះ បានសោយពាជ្យាស្តេចហើយ ។

មាតានៃអ្នកពាក់មកុដពាជ លុះបានទទួលព្រះពាជសារលិខិតកូនហើយ ក៏សួរទៅអ្នកនាំសារថា :

« តើកូនដែលជាទីស្នេហារបស់ខ្ញុំយ៉ាំងណាទៅ ឥឡូវនេះ តើរស់នៅកែបណាខ្លះ ? »

បាចកនាំសារតបទៅមាតាបាចកមហាពរវិញថា :

« កូននោះសព្វថ្ងៃ មានជីវភាពថ្កុំថ្កើងរុងរឿងអស្ចារ្យពន់ពេក !

ជីវភាពនោះ មានសភាពអធិកអធមត្រចះត្រចង់ជាអស្ចារ្យណាស់ ។

កណ្តាលព្រះពជសេវៀមាត្យ មានសត្វសិង្ហ ខ្លា ដំរី ហើយមានសត្វចចកចាំងឡាយ ជាព្រះពជបរិវារ ។ កូននោះធ្វើកិច្ចការអ្វីតាមចំនើនចិត្តហើយ មួយថ្ងៃ ។ ឮតែពាក្យជេរប្រទេចផ្តាសាសត្វ ដែលស្ថិតនៅជុំវិញខ្លួន គ្រាន់តែមានពាក្យខុសគ្គឆ៍ចន្តិចបន្តួច កូននោះក៏ខឹងគោមស្ទាជាខ្លាំង . . . ។

ចចកមាតា មិនពេញចិត្តនឹងកូន ចំពោះអាកប្បកិរិយា ដែលធ្វើថៃ្មនេះ ។

ចចកមាតា ក៏ប្រាប់ទៅចចកនាំសារវិញថា : បើធ្វើអាកប្បកិរិយាថៃ្មនេះ ខ្ញុំមិនទៅទេ ឲ្យទៅប្រាប់ចចកកូនខ្ញុំចុះ ។

ពោលដូច្នេះ ចចកមាតា ក៏ស្ថិតនៅចំកន្លែងដដែល មិនទៅណាមកណាសោះឡើយ ។

តែចចកនាំសារ ចានយល់តាមសេចក្តីពិត ខ្លាំរឿងអ្នកតាក់មកុដរាជសត្វត្រប់ប្រាកា ។ ដល់ចចកនាំសារវិលត្រឡប់មកកាន់ក៏ចចកមហារាជវិញ ក៏ពោលថា :

ខ្ញុំជំនឿរឿងចាំងអស់ហើយ ។ បើតាមសេចក្តីពិត អ្នកតាក់មកុដរាជ គឺជាចចកធម្មតាដូចគេយើងដូច្នេះ ខ្ញុំជំនឿហើយ ព្រោះខ្ញុំចានយើញចចកជាមាតា មានរូបកន្ទ្រក់ក្រាយដូចចចកចាំងឡាយពិត ។

កន្លងពេលនោះ ពួកសត្វដែលស្ថិតនៅអមចចកមហាកដ កំមានចិត្តចោមនស្សតឧបមា ហើយកំចង់បញ្ជាក់តើចចកមហាកដនេះ ជាចចកធម្មតាឬ ? មានចចកមួយស្រែកថា :

« សូមឱ្យចចកចាំងឡាយស្រែកចាំងអស់គ្នាឡើង ! បើអ្នកពាក់មកុដកដជាចចកធម្មតា មុខជាលោកស្រែកមានសូរសៃដូចចចកយើងហើយ ។

ពួកចចកចាំងឡាយកំស្រែកព្រម ។ គ្នា ។

ចចកដែលក្លែងខ្លួនជាស្តេច កន្លងពេលដែលគង់លើខ្នងដំរីដើរប្រពាតសប្បាយ ដល់ឮសម្រែកចចកចាំងឡាយដូច្នោះ កំស្រែកតាម ។

ដំរីឮសូរសៃម្រែកនោះ កំឈប់លែងដើរតទៅទៀត កំយល់ជាក់ច្បាស់ថា អ្នកពាក់មកុដកដនេះ ជាចចកក្លែងក្លាយ ហើយកំមានចិត្តខឹងមហិមា ។

ដំរីពោលថា : « ម្តេចកើឯងហ៊ានមកជិះលើខ្នងអញ អាត្រហ៊ីន . . . ថាដូច្នោះហើយ ដំរីកំក្រវាត់ចចកមហាកដធ្លាក់ដល់ផែនប្រថពី រួចយកដើងជាន់ស្ទីយជីវិតមួយរំពេចនោះទៅ ។

ចប់រឿងចចកក្លែងធ្វើជាស្តេច នៅមានរឿងទី ១៩ « រឿងកូនអូត » តទៅទៀត ។

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

ល្ខោនបាមោច័យ

ឈ្មោះល្ខោនបាមោច័យ នេះបានតែលេចមាននៅឡើងនៅកន្លងវាងក្រោយសង្គ្រាមលោកលើកទី ១ ។ សម័យនោះឯង ប្រទេសយើងក៏ទទួលភ្ញៀវកើតឡើងជាវង់ល្ខោនបែបថ្មីមួយប្រភេទហៅថា បាមោច័យ ដែលជាពាក្យគាន់ក្លាយតាមសៀមមកពីពាក្យបាលី «បាមោជ្ជ» ន័យសំស្ក្រឹត «ប្រាមោទ្យ» មានន័យថា «របាំគួររីករាយ» ប៉ុន្តែសៀមវិលកដើង «យ» ចេញពីតួ «ទ» ទៅហើយប្រកបគ្នា ទ នឹង យ ទៅជា «ច័យ» ទទួលសៀម អាន «ទ» ជា «ច» ទៅទៀត ច័យ ក៏ក្លាយទៅជា «ច័យ» រហូតមក ។

កាលល្ខោននេះមកដល់ក្នុងប្រទេសយើងដំបូង ដោយជាការប្លែកផងអ្នកស្រុកយើងក៏នាំគ្នាអបអរសាទរទទួលកម្សាន្តយ៉ាងគគ្រឹកគគ្រេង តាំងតាមស្រុកភូមិក្រៅពីរាជធានីក្តី កំនិយាយចេញឈ្មោះរបាំនេះរឿយៗ ។ អ្នកខ្លះដែលជាអ្នកកំប្លែង ឬជាអ្នកស្រឡាញ់សិល្បៈរបាំពិត ។ នោះ ក៏បានចូលខ្លួនទៅក្នុងវង់របាំនេះថែមទៀតផង ។ ហេតុមួយទៀតដែលនាំឲ្យបានលេចឮឈ្មោះល្ខោនបាមោច័យខ្លាំងយ៉ាងហ៊ឺសណាស់ គឺល្ខោន

នេះ មានតួកូនពាំសុទ្ធតែជាស្រី ។ តើអ្នកធ្វើជាតួប្រុសកំជាមនុស្សស្រីដែរ ឯប្រុសៗវិញ មានមុខងារគ្រាន់ជាអ្នករៀបចំឆាក លេងក្នុង ខឹង ធ្វើជាតួកប៉ុណ្ណោះ ។ អាស្រ័យដោយតួសុទ្ធតែស្ត្រីនេះឯងដែលនាំឲ្យកើតជាទស្សនីយភាពចំឡែក ធ្វើឲ្យអ្នកស្រុកខាត់ចិត្តពន់ពេក នេះម្យ៉ាង ម្យ៉ាងទៀតដោយរបៀបសម្តែង ឬសាច់រឿងដែលគេយកមកសម្តែងនេះសោតក៏សុទ្ធសឹងរឿងថ្មី ។ ក្នុងបច្ចុប្បន្ន ត្រូវចំសេចក្តីចូលចិត្តរបស់អ្នកស្រុកសម័យថ្មីធង ។ និយាយឲ្យខ្វីតើល្ខោនចាមោយនេះហើយ ដែលជាបែបល្ខោនសម័យថ្មីមួយរបស់ខ្មែរយើង ដែលកើតមានឡើងនៅក្នុងឆាកខាងដើមនៃគ្រីស្តសតវត្សទី ២០ ។ ប៉ុន្តែជាការគួរឲ្យស្តាយពេក ព្រោះមានអាយុមិនបានប៉ុន្មាន ល្ខោននេះក៏ចាត់ឈ្មោះជាត់សម្ងួតអស់ទៅវិញ។ ដោយការស្តាយ ហើយដោយយល់ថាជំនាន់មុននៅប្រទេសយើងក៏បានចុះបង្កើតជាល្ខោនបែបទំនើបថ្មី (Théâtre moderne) បានមួយបែបនឹងគេដែរនោះ យើងត្រូវតែកត់ត្រាពុកខ្លួរបៀបរបបនៃល្ខោនចាមោយនេះពុកសម្រាប់ជាទិដ្ឋានុគតិបង្ហាញឲ្យអ្នកស្រុកជាន់ក្រោយ ។ ម៉ៅទៀត បានស្គាល់បានដឹង ពីរបៀបពីសម្រស់នៃសិល្បៈចាំប្រកេទថ្មីនេះផង ។ ការកត់ត្រាពុកក្នុងទំនេះ យើងរកបានដោយការស្រាវជ្រាវស៊ើបសួរប៉ុណ្ណោះ មិនមែនបានឃើញផ្លាល់ខឹងភ្នែកដូចជាយើងកែ ឆៃយ៉ាំ ត្រូដំ ។ល។ ឡើយ ព្រោះនៅគ្រាយើងតែងអត្ថបទនេះ ចាំល្ខោនចាមោយ

បាត់រូបស្មោះពីអាណាចក្រយើងទៅហើយ ។ ហេតុនេះ ថើមានការខ្វះខាតខ្លះ ប្លុសេចក្តីពន្យល់ត្រង់អត្ថន័យខ្លះពុំសូវច្បាស់នោះ ក៏ពិតជាកើតឡើងដោយសារហេតុក្រៅចេតនាតែប៉ុណ្ណោះ ដ្បិតឯកសារភាគច្រើនត្រូវបានបាត់បង់ពីរជ្រុំនេះមកដល់ក្រុមដំខ្ញុំយើង ក៏មានស្តួចស្តើងដែរ (១) ។

ដូច្នេះយើងសង្ឃឹមថាពុំមានតាមឯកសារផង តាមការសាកសួរផ្ទាល់ពីចាស់ទុំដែលធ្លាប់ឃើញផ្ទាល់ភ្នែកផង អាចយកជាគំណត់សេចក្តីបានដូចតទៅ ៖

ក- អំពីគ្រឿងសម្ភារៈ

គ្រឿងសម្ភារៈសម្រាប់ប្រកបវិស័យនេះ ចែកចេញបានជាបីផ្នែក គឺ គ្រឿងភ្លេង អលង្ការ និងប្រដាប់តែងលំអផង ។ សម្ភារៈទាំងបីផ្នែកនេះ យើងសង្កេតឃើញដូចតទៅ :

១- គ្រឿងភ្លេង .- ប្រដាប់ប្រដាភ្លេងសម្រាប់ប្រកបវិស័យនេះ សុទ្ធសឹងជាគ្រឿងភ្លេងក្នុងវិស័យតន្ត្រីទំនើបថ្មីរបស់អ៊ីរ៉ុប ដែលគេហៅថា អ័រកេស្ត្រ (Orchestre)(២) មានត្រែធំ-តូច ស្គរធំ-តូច រួបរួមបញ្ចូលគ្នាដូចជាវង់ភ្លេងដែលខ្មែរយើងធ្លាប់ហៅថា ភ្លេងចាក់ឆ ឬភ្លេងម៉ានីល (មិន

---

១. ឯកសារលេខ ៦៣-០៥៨ របស់លោក ភួយ.យក់ហួ ដែលជាអ្នកធ្លាប់កាន់តំណែងជាមេចំរៀងម្នាយរវាងនៅខែត្រជាច់ដំបង តែវង់ភ្លេងអ្នកស្រីរៀម ជាម្តាយក្មេករបស់លោក។

២. ជាវង់ភ្លេងបុរាណរបស់ក្រុមល្ខោនក្រឹក ដែលលេងអមជាមួយចម្រៀងដែលច្រៀងជាក្រុម។

ចាប់ពាប់រៀបពីរបៀបធ្វើគ្រឿងក្ងេងខ្លះទេ ដូរ្តាសព្វថ្ងៃ ក្ងេងខ្លះកំពុងតែមានតម្លៃសាយសព្វពេញក្នុងស្រុកខ្មែរយើង) ។

២- គ្រឿងអលង្ការ .- គ្រឿងអលង្ការរបស់ក្រុមល្ខោនខ្លះពុំមានអ្វីប្លែកដែលយើងមិនធ្លាប់ឃើញនោះឡើយ ព្រោះរឿងដែលគេយកមកសម្តែងតាំងពីបុរាណ សឹងជារឿងចំនើបថ្មីតាំងអស់ (តាមប្រលោមលោកដែលមានស្រាប់ ឬមួយជាតែងឡើងថ្មី) ម្ល៉ោះហើយរឿងតែងតាយកតំរូបភៅតាមភាពធម្មតានេះដែរ គឺភាគច្រើនជាសំលៀកបំពាក់សាកលនិយម (ខោខ្សែ-អាវសឺមីសឬអាវបើកក ស្រីអាវម៉ូត សំពត់ហូលឬសំពត់ពណិតាមដំណើររឿង) ។ ជួនកាលក្រុមល្ខោនខ្លះសម្តែងរឿងបូកណា តាមសាស្ត្រាខ្មែរយើងខ្លះដែរ ប៉ុន្តែមិនតាក់តែងខ្លួនភៅតាមបូកណាសុទ្ធទេ គឺចោះយកតែអង្ខេត្រង់ណាមួយមកសម្តែងដែលតាក់តែងតាមរបៀបចំនើបថ្មីលាយលុកគ្នាផង ម្ល៉ោះហើយសំលៀកបំពាក់ក៏នៅតែជារបៀបថ្មីដ៏ច្រើនពុំចាប់មានគ្រឿងចំឡែកអ្វីខ្លៅទេ ។ ជួនកាលខ្លះទៀតគេលេងរឿងបូកណារបស់អឺរុប ជាពិសេសគឺរឿងរបស់ជនជាតិបារាំង (១) មានរឿងត្រេងខ្លះ រឿងរៃបប្រវត្តិសាស្ត្រខ្លះ ឯសំលៀកបំពាក់តែងតាយប្រជាប់អាវុធដែលតួកាន់ជាដើមក៏និយមយកតាមលក្ខណៈសំលៀកបំពាក់បូកណារបស់បារាំងនោះភៅ ។

១- ព្រោះសម័យនោះ នៅក្នុងអាណានិគមបារាំង ហើយបារាំងកំពុងបង្ហាត់ខ្មែរឲ្យចេះតាំអក្សរសាស្ត្របារាំងផង ។

៣- ប្រដាប់តែងឆាក -ក្នុងការសម្តែងល្ខោនសម័យថ្មីនេះ ក៏ត្រូវការប្រដាប់តែងឆាកដែរ ដើម្បីឲ្យគេដឹងថាកន្លែងនេះជាកន្លែងណា ជាពេលណា ជាសម័យណា ជាដើម។ ប្រដាប់តែងឆាកនេះ ត្រូវតែមានតាមសមរម្យ ដូចជាតុ កៅអី ជាដើម ដែល

មួយរឿងនេះត្រូវលេង ២ ម៉ោងកន្លះយ៉ាងយូរ ហើយក្នុង ២ ម៉ោងកន្លះ
នេះ ត្រូវចែកចេញជា ៣ ឬជា ៥ ឈុត ក្នុងមួយឈុត ។ មានច្រើនឆាក
ទៅទៀត ។ តាមការនិយមមក បើរឿងវែងមាន ៥ ឈុត គឺ ១ ឈុត
ជាការបង្ហាញតួ ២ ឈុតជាការចាប់បញ្ហា ខឹង ២ ឈុតទៀត ជាការ
ដោះស្រាយបញ្ហា នោះវិញ ។ ឯរឿងខ្លីមាន ៣ ឈុត គឺ ១ ឈុតបង្ហាញ
តួ ១ ឈុតបំផុសជាបញ្ហាឡើង ហើយ ១ ឈុតទៀតជាការដោះស្រាយ
បញ្ចប់ ។ ផ្នែករឿងនោះសោត គោងតែយករឿងដែលមានដំណើរស្របទៅនឹងការពិតក្នុងជីវិតធម្មតាមែន ។ មកអធិប្បាយ ប្រសិនជាយករឿង
បែបបុរាណខ្លះ តំរូវយកតែអន្ទីណាមួយដែលប្រកបដោយបញ្ហាប្លាស់
លាស់មកសម្រួលឲ្យបានចប់សព្វគ្រប់ក្នុងរយៈជាងពីរម៉ោងនេះ ។ តាម
ទំលាប់មក រឿងបុរាណគេច្រើនតែយកពីរឿងបរទេសជិតខាងយើង ដូច
ជារឿង អ្នកឈ្នះដប់ទិស (របស់កូមា) រឿងឥណាវ (របស់ម៉ាឡាយូ)
រឿងមួយតាន់មួយយប់ (របស់អារ៉ាប់) ខឹងរឿងខាងសង់ទ្រីយ៉ុង (របស់
ចាក់ង) ជាដើម ។

២- តួយវិការនិងបទច្រៀង.-

តាលណាពោលពីតួយវិការ គឺសំដៅដល់តួ (ខ្មែរយើងច្រើន
ហៅថាតួនាំ) ពាក់ប្រុសស្រី ។ ក្នុងពេលដែលចេញមកសម្តែងជាភ្នាំង
រឿងណាមួយ តួត្រូវដើរចេញមកតាមសភាពធម្មតារបស់មនុស្ស គឺដើរ

រឿន ដើរយើតប្តូរតំតាមតែដំណើររឿងតម្រូវឲ្យ ។បមាថា បើព្រួយដំណើរចេញមកកំព្រួយ បើប្រញាប់ចេញមកតាមប្រញាប់ ហើយចើរតំប្រជេញប្រចាប់ កំតោងតែធ្វើឲ្យដូចកាយវិការមែនខែនដែរ ។ ការសន្ទនាគ្នា សុទ្ធតែជាសំឡេងធម្មតាពុំបាច់ច្រៀង ពុំបាច់ពត់សំឡេងឲ្យខុសប្លែកពីធម្មតាឡើយ ប៉ុន្តែបើត្រូវការថ្លែងសេចក្តីវែងកប់រៀបពីមនោសញ្ចេតនា មានការក័យក៉ប់ពីស្នេហា ពីទុក្ខព្រួយ ពីសេចក្តីនំតរូកជាដើម កំមានច្រៀងជាមួយដែរ ។ . រមៀបច្រៀងនេះ ច្រើនតែបទខំនើបថ្មី ដែលពួកក្រុមភ្លេងគេតែងឡើងដោយខ្លួនគេ ដោយប្រដិតយកបទពីបរទេសខ្លះ ពីបទបូរាណខ្មែរយើងខ្លះ ។ ពាហាណ៍ដូចជាបទខោចយ៉ បទដួងចំប៉ា បទឡាវឡឹក បទសែនស្រណោះ បទចៅដក បទខ្មែរពាក់មាស បទសារិយ៉ាំង, . . . កាលណាបើច្រៀងចប់ថ្នាហៀបនឹងចប់ ទើបភ្លេងចាប់លេងខ្ទួលត្រមគ្នាឡើងតាមបទដែលគួបានច្រៀងរួចមកហើយ ។

ដូច្នេះ សរុបទៅគឺ កាយវិការនៃល្ខោននេះ ជាកាយវិការត្រាប់តាមកាយវិការមែន ។ រឯសំមនុស្សត្រប់ដំណើរប្រព្រឹត្តិទៅនៃនវិយោបថមានការដេក ដើរ ឈរ អង្គុយ ។

៣– ការតុបតែងឆាក :–

ដូចបានពណ៌នាខ្លះមកហើយ ក្នុងវិធីប្រជាប់តែងឆាក ថាគេត្រូវមានអ្វីខ្លះ ។ សម្រាប់លំអឆាកល្ខោននេះ តែងឲ្យវែនេះត្រូវនិយាយជាបន្ត

ទៅទៀតអំពីរបៀបរៀបចំកន្លែងការគួបតែងផាក ។ របស់សំខាន់ជាងគេគឺ តាប្លូកំនន ឧទាហរណ៍រូបភាពជ្រៀកកាត់ (Découpé) ។ តាប្លូគេត្បូរទៅភ្ជាប់នឹងខ្នងលើនៃដំបូលកេង បើមានចំនួនប៉ុន្មានក៏ដោយ ក៏ត្បូរគេម្រៀបគ្នាពីមុខពីក្រោយដែរ ។ គ្នាតែកុំឲ្យប៉ះគ្នា ព្រោះនាំឲ្យពិបាកមួរឡើង ឬ លាចំលាក់ចុះ ។ សន្លឹងមានខ្សែរ៉ែតហើយចំលាក់កន្ទុយខ្សែមកក្រោមសំរាប់មនុស្សម្នាកចាំរូតឡើងរូតចុះតាមពេលត្រូវការ ។

ក់ឆនខបំពីក្រៅចំផុតផាកនោះ មិនមានខ្សែរ៉ែតរូតមួរឡើងលើដូចតាប្លូទេ គឺមានកន្ទុយខ្សែបង់ជាយកំនន់ត្រង់បត្រាសមុខគ្នាចំពាក់កណ្តាលហើយចាញ់តែចេកទៅសន្លឹងក្តារ ឬបិទវិញនៅពេលណាដែលអស់មួយឈុត ។ (ជួនគេបើកឡើងលើក៏មាន) ។

ផ្ទាំងគំនូរជ្រៀកកាត់ ដែលកាត់ជារូបផ្សេង ។ នោះមានពីរបែប គឺមួយបែប ជាកាតបញ្ជរ ពីក្តារផាកឡើងទៅលើនូវដែលសំរាប់បង្ហាញតាប្លូ គឺទៅលើកំនន់រាយដែលត្បូរខាងលើជាច្រើនផ្ទាំងពីមុខពីក្រោយ សំរាប់ការពារកុំឲ្យទស្សនិកជនមើលឃើញដំបូលកេង ។ រូបបញ្ជរនេះមានជារូបសសរផ្ទះ ម្ខាងទៀតជាដើមឈើ ព្រោះសំរាប់ប្រើការពីរយ៉ាង គឺកាលណាជាផាកក្នុងផ្ទះគេយកខាងរូបសសរផ្ទះ បើជាផាកក្នុងព្រៃគេចំបែរត្រឡប់យកខាងរូបដើមឈើចេញមកក្រៅវិញ ។ មួយបែបទៀតរូបគំនូរជ្រៀកកាត់ ដែលមានធ្នឹងឈើធ្វើជាគ្រែងចាញ់លាតសន្ធឹងសាច់សំពត់

ផ្នាំដ៏ឥតខ្ចូវផងនោះ មានជារូបភាពថ្មែក ។ ច្រើនយ៉ាង មានរូបដុំថ្ម រូបដើមឈើ រូបផ្ទះស្មឹក ឋ្មង់ថ្ម មានគ្រាវបង្ហិចល្មមឲ្យមនុស្សដើរចេញចូលបាន ។ រូបនេះមានតួចមានធំ តាមតែចំហំរូប ហើយបើកដ៏ឈុតណាមានន័យយ៉ាងម៉ាទៅណា ដូចជាកដ៏ផ្ទះ ឋ្មកដ៏សួន ឋ្មកដ៏ភ្នំ អ្នករៀបចំគេលើកយកផ្នាំដ៏នោះមកតាំងក្នុង ។ ជាមួយគ្នាអីដែរ ។

ឯពន្លឺភ្លើងដំនាន់ដំបូងនៃល្ខោននេះ គេប្រើចង្កៀងគោមព្យួរ តែក្រោយមកប្រើភ្លើងអគ្គិសនីដែរ ដ្បិតគេលែងតែគេលយប់ ។

គ – ប្រវត្តិល្ខោនបាមោបំយ

ពីតមែនតែល្ខោននេះ ថយក្រោយទៅមិនបានដាយូរប៉ុន្មានប៉ុន្តែប្រវត្តិរបស់ល្ខោននេះ ហាក់ដូចជាបង់រលាយត្រឹម ។ ម៉ើលលែងឮស្គាល់ទៅហើយ ដោយហេតុអ្នកស្រុកនៅសម័យនោះ គ្រាន់តែនាំគ្នាន័យមនុស្សនា ពុំសូវបានដេញដោល សញ្ញឹងរំលេកដើមកំណើតឲ្យដែងឆ្ងាយឡើយ រីឯអ្នកដែលបានដឹងផ្ទាល់ខ្លួនក្តី ក៏ពុំបានសរសេរកត់ត្រាខុកកស្តុកតាងជាលាយលក្ខណ៍អក្សរខុកតមកដែរ សព្វថ្ងៃទៅសល់តែការចងចាំដោយន័យាយនឹងមាត់ខេប៉ុណ្ណោះ ។ តាមការស៊ើបសួរខ្ញុំអំពីចាស់ ។ ដែលចូលចិត្តនឹងល្ខោននេះ ស្ទាប់បានយើញនឹងខ្លះឮស្គាប់ការចាំរឿងល្ខោននេះផ្ទាល់ខ្លួនតែម្តងផងនោះ យើងប្រមូលយកពតិមានបានជាន័យចុំនាងក្រោមនេះ ។

នៅពេលផុតរលត់សង្គ្រាមលោកលើកទី ១ (១៩១៤-១៩១៨) ទៅ ក្រោយនោះបន្តិចកំលេចឃើញមានរបាំល្ខោនជាមោយ័កើតមានឡើងក្នុងស្រុកយើង ។ ខបង្ហូរខ្លះនេះបូលមកប្រទេសខ្មែរយើងយើញពីផ្លូវ គឺស្រុកសៀមនឹងស្រុកយួន ។ កាលនោះស្រុកយួនក្តីស្រុកសៀមក្តី សុទ្ធសឹងជាប្រទេសខ្លះអាតអាងក្បួនខ្នាតសិល្បៈ ម្ល៉ោះហើយក៏រត់រកម៉ូទ្យាស្រុកយកសិល្បៈរបស់ប្រទេសជិតខាង ឬប្រទេសឆ្ងាយ ។ ណាមួយយកមកធ្វើជាសិល្បៈផងខ្លួន ។ ហេតុនេះគួរតែជេញជាលស្ទុះទៅរកមែកជាងឲ្យយើញសព្វឫសគល់ពីដើមមកសិន ។

ប្រទេសយួនជាអ្នកបណ្តុះបណ្តាលវប្បធម៌ជាតិខ្លួនតាមរបៀបវប្បធម៌ចិន ជាកស្តូតាងគឺតួអក្សរ(១) ក្បាច់ចំឡាក់ សាសនា សិល្បៈនឹងចំនៀមចំលាប់ខ្លួនទៅ ។ សិល្បៈល្ខោនចិន ក៏ត្រូវយួនយកមកផ្នែរបនាជាសិល្បៈជាតិតែដែរ(២) ប៉ុន្តែរូបរាងកិនកាតទៅតែដដែលត្រាន់តែប្លែកភាសាតែប៉ុណ្ណោះ ។ ម្ល៉ោះហើយ តំនិតការឡែត្រង់ត្រួយសិល្បៈទៅជាបក្ខងជនជាតិយួនជានិច្ច តែវិធីការឡែតុំមែនទេះតែធ្វើកើតបានក្លាម ។ ទេ គោងតែយកលំនាំរបស់នណាមួយធ្វើជាបែបបទផ្តួចផ្តើមតំនិតផង ។ ជួនជាពេល

១- សព្ទថ្មៃគេប្តូរជាតួអក្សរឡាំង (Romanisé) វិញ តែអក្សរឈ្មោះពីដើមជាអក្សរចិនសុទ្ធ ខុសតែសំឡេងអានទេ ។

២- តាមសៀវភៅ (Théatres Vietnamiens Editons, de langues étrangéres, Hanoi) ជាកើតដើមដំបូងពីពួកឈ្លើយសង្គ្រាមជាតិចិន ។

ជាពាំងមកធ្វើជាអាណាព្យាបាល លើដែនភុងកឹង (វៀតណាមខាងជើង) ដែនអណ្ណាម (វៀតណាមកណ្តាល) ទឹងជាអាណានិគមលើដែនកូសាំងស៊ីន(វៀតណាមខាងត្បូង)ជាពាំងនាំយកស្លោនគេដែលហៅថា«តេអាត្រ» មកផ្សាយលើទឹកដីយួនយ៉ាងតាសតេញស្រុក ជាតំសេសក្នុងមជ្ឈដ្ឋានមន្ត្រីពាជការ ទឹង អ្នកមានទ្រព្យសម្បត្តិ ។ បណ្តាមក បណ្តាជនអ្នកសិល្បៈយួន ក៏ធ្វើតឹកាសប្រឹងយកបែបស្លោនជាពាំងនេះបញ្ចូលថែមទៅក្នុងស្លោនបូកណខ្លួនជាស្លោនច្រៀង (Théatre chanté) ដែលយកតំបន់មកនោះឲ្យទៅជាបែបស្លោនសម័យថ្មីមួយទៀង មានច្រៀងតែតំបន់ តេនិយមនិយាយច្រើនទៅជាបែបស្លោននិយាយ (Théâtre Parlé) រីឯហើយឲ្យឈ្មោះថាកៃលឿង (១) ។ ស្លោនកៃលឿង កំពុងចូលមកលេងនៅស្រុកខ្មែរម្តង ។ ដែរ ព្រោះកាលនោះជាយួន ទឹងខ្មែរយើងស្ថិតនៅក្នុងបន្ទុកពាជការវៀតណាមជាមួយគ្នា ។ អ្នកស្រុកខ្មែរទស្សនាស្លោននេះទៅ ឃើញថាប្លែកភ្នែកណាស់ដែរ នាំឲ្យអ្នកសិល្បៈស្រុកយើងសំគាល់ខ្លួនខ្លះចំណុចខ្លះសំរាប់តាក់តែងបញ្ចូលក្នុងសិល្បៈយើងផង ។

ចំណែកប្រទេសសៀម សៀមនេះជាស្រុកទើបទឹងកើតថ្មីនៅរាងសតវត្សទី ៨ នៃគ្រិស្តសករាជ ។ វប្បធម៌ខ្លួនទៅរបស់សៀម សុទ្ធសឹងជាវប្បធម៌ខ្មែរស្ទើរតែទាំងអស់ មានតែបន្តិចបន្តួចដែលសេសសល់មកពីពួក

---

១ - តាមសៀវភៅ Théâtre Vietnamien ថា កៃលឿង មានឈ្មោះឡាំងទៀតហោហាត់ចៅ ។

រដ្ឋភាសាខ្មែរត្រង់នោះ ប្តូរដោយមកពីខេត្តណាន់ចាងប្រទេសចិនមកជាមួយពួកជនជាតិថៃ (១) ដែលចូលមកស្ថាបនាអាណាចក្រនេះ ។ ម្ល៉ោះហើយសិល្បៈរបស់សៀម ជាសិល្បៈខ្មែរទាំងស្រុងដែលពួកនេះបានចូលមកពត្តាពតីសម័យអង្គរ ហើយដឹកនាំក្បួនខ្លួនយើងយកទៅ ។ មិនតែប៉ុណ្ណោះ ពួកនេះបានតាក់តែងធ្វើជាវេន៍រចាំតេឡើង តាប្រឌិតយកវេន៍រចាំកំភ្លាច់ ដែលសំដែងជាឆាករឿងស្នា មានឆាកមុខ ប្រកបជាមួយក្តេងពិណពាទ្យ ។ គេដាក់ឈ្មោះរចាំនេះថា លះខោន (២) ហើយរចាំលះខោននេះ មិនបានតង់ទ្រឹយូរទេ ក៏ពួកសិល្បៈសៀម ដែលនិយមតាមសិល្បៈ ពួកអង់គ្លេសម៉ាំគ្នាតែ ក្រោះពេលនោះសៀមកំពុងតែនិយមការរាជមិបស្ថិមប្រទេសបែបអង់គ្លេសខ្លាំងណាស់ ។ ការប្រឌិតបញ្ចូលថែមនេះមានបង្កេកខេសខាងការតែងរឿង រៀបឆាក រៀបលេងខ្លះ ហើយ

១- ពួកថៃជាកុលសម្ពន្ធធំមួយនៅក្នុងប្រទេសចិនភាគខាងត្បូង ។

២- តាមហេកសិដេស សរសេរចុះក្នុង Bulletin de la S.E.I. 3e et 4e Trimestre 1963 P.499 ជាពាក្យ "ខោន" មកពីពាក្យខ្មែរ "ខោល" ដែលជាស្វាធំមួយប្រភេទ ដ្បិតរចាំរំរឿងស្នា គេឲ្យឈ្មោះថា រចាំខោល ។ ក្រោយទៅសៀម ជាស្ទ្បាខោន ព្រោះចាត់សំឡៀងរចាំនៅតែ "លះខោន" ។ សេចក្តីសន្និដ្ឋាន ១ ទៀតថា មកពីពាក្យធើមខ្មែរហៅ រចាំនគរ ជានសៀមយកទៅ អានតាមសំឡៀងសៀមថា "នះខន" តំពាក្យនគរនេះឯង ឬមួយកំពាក្យនេះសៀមអានក្លាយមកពីពាក្យថ្លងថា "ឡាកុន" ដែលប្រែថា រឿងរចាំ ។

សំគាល់ឈ្មោះថ្មីមួយថា « លៈខោនលិកេ ឬ លិកេ» (๑) ។ គឺជាលិកេនេះហើយ ដែលមានរបៀបសម្តែង ចេះតែប្រែក្លាយបន្តិចម្តង ។ មកតាមបែបល្ខោនសម័យថ្មីអំពីអ៊ីរុប ហើយគឺជាលិកេនេះទៀត ដែលកាន់ឡើងមកជាលៈខោន រួចពីនេះទៅជាលៈខោនចាមោច័យ ដូចជាយើងកប់រៀបមកខាងលើស្រាប់ ។ លៈខោនបែបនេះឯង តែងបានគាំពារមកសម្តែងក្នុងតំបន់ដីខ្មែរជារឿយ ។ ដែរ ជាពិសេសនៅខេត្តបាត់ដំបង ព្រោះជាខេត្តនៅជិតព្រំដែនសៀម ហើយដូនកាលខ្លះ ពួកសិល្បៈខ្មែរយើងធ្លាប់ចូលទៅទស្សនាលៈខោននេះឯខេត្តអញ្ចើដែលនៅជិតទល់ដែន គេអាចចេញចូលទៅមកបានដោយងាយ ។ ម្ល៉ោះហើយ ឥឡូវលេងនេះកំពុងចូលមកស្រុកខ្មែរ តាមបណ្តាលចិត្តគំនិតខ្មែរទើបឃើញបង្កើតជាក្រុមល្ខោន (๒) មួយប្រភេទថ្មីឲ្យឈ្មោះថា « ច្រាមោច័យ ឬ ចាមោច័យ » ដែលក្លាយតាមសំឡេងសៀមអាន « ច » ទៅជា « ជ » នោះ ទើបបានជាឈ្មោះថា « ចាមោច័យ » តរហូតមក ។

ដូច្នេះ ល្ខោនចាមោច័យ យើងសន្និដ្ឋានបានថា ជាល្ខោនបែបចំនើបថ្មីមួយដែលខ្មែរយើងទើបតែប្តូរតិកខ្ជឿន ក្នុងភាគខាងដើមនៃសតវត្សទី ២๐ យើងនេះ គឺក្នុងរវាង គ. ស. ๑๙๒๐ ដល់ ๑๙๔๐ ទើបអស់រយៈពេល

๑- លិកេ នេះមិនលេងមានបែបនៃខ្លួនយ៉ាងកៅខ្មែរយើងទេ គឺជាបែបនៃល្ខោនជាន់ថ្មីទៅវិញ ឯបែបយីកេជាន់ចាស់នោះក៏ហៅ យីកេ ដូចយើងដែរ ។ ๒- ពាក្យល្ខោន ក្លាយពីពាក្យ លៈខោនរបស់សៀម ។

ទៅវិញដោយសារមានស្លាកថាស័ក ឬឆ្ងីតស្រុកថាសាក់ (កម្ពុជាក្រោម) មកប្រណាំងប្រជែងយកជោគជ័យបានទៅ ។ ហេតុដែលនាំឲ្យស្លាកថាស័កឈ្នះ មកពីស្លាកថាស័កមិនចំនេះចេះហួសពេកទៅមានប្រឿងច្រើន លេងរឿងបូកណា ។ បើសំឡេងតាមសារស្ត្រាវិញ ឯស្លាកថាមោចយថ្មពេក លេងតែរឿងជាន់ថ្មីមិនសូវមានប្រឿង នាំឲ្យអ្នកស្រុកភាគច្រើនដែលតុំរាន់យល់ចៃដន្យសិល្បៈចំនេះចាស់នោះ ឈោងចាប់តុំដល់ ហេតុហ្នឹងហើយបានជាស្លាកថាមោចយថាត់ចង់ឥតលទ្ធិផលទៅ ។

ការសេពគប់ (ពាក្យ ៧)

គប់ពាលបានទុក្ខប្រាសសុខឡាយ គប់ពាលអន្តរាយកាយមួយម្ចាង គប់ពាលហិនហោចប្រយោជន៍ផង គប់ពាលកន្ទងប្បាប់វិញ្ញូ ។ ពាលោពាលមារយោទ្ធោក ប្រវិញ្ញូនធោកផ្តង់ជីវី ផ្តង់តែដីវិតឥតខ្លឹមសារ ឧរកប្រៃវារីវិញ្ញូតុំកន្លង់ ។ ស្មានថាទុច្ចរិតសប្បាយលន់ តុំច្បែតតុំច្បន់ផ្តុំកលុះហល់ សាងតែអំពើអកុសល រើរកទុក្ខខ្វល់ជិលបរលោក ។

គប់ប្រាជ្ញបានសុខស្រណុកខ្លួន គប់ប្រាជ្ញតាប់ដួនបានសៅសោក គប់ប្រាជ្ញប្រាសទុកមានន័យដោគ តាំងពីឥតលោកយោគបរាជិត ។ អ្នកប្រាជ្ញតំកាយបានថ្កើងឃើញ ក្តើឈ្មោះខ្ចង់ខ្ពស់សុះសព្វញាតិ ប្រាប់ផ្លូវសុចរិតតុំឃ្លាត អ្នកផងសង្វាតស្វះស្វែងរក ។ ធ្វើចង្កាតិដោះសុគន្ធា ជនផងតាមមើលមក ក្រេបស្រង់យកក្លិនថ្លៃឥតខ្លា គ្មោះឆ្ងាន់លៃលាទុក្ខក្នុងប្រា ។

ធ្វើដូច្នេះពួរអស់ក្មេងទាំងឡាយ កែកុនខ្វល់ខ្វាយរិះរកអាន លះពាលយកប្រាជ្ញបានសុខសាន្ត ហិនសូន្យនិព្វានប្រសើរអើយ ។

ផេង-ជ្រឿ

ផ្នែកកំណាត់ឯកប្រវត្តិការណ៍

ប្រវត្តិនៃវត្តប្រាង្គ

រៀបរៀងដោយ ព្រះពោធិវង្ស ហ្សួត-តាត

អគ្គាធិការនៃពុទ្ធិកសិក្សា

នាមនៃចៅអធិការវត្តប្រាង្គ

តាំងពីពេលក្រោយដែលសម្តេចព្រះមហាសង្ឃរាជព្រះនាម ធឿង ជាចៅអធិការវត្តប្រាង្គ ទ្រង់ស្តេចចេញចាកវត្តប្រាង្គមកគង់នៅវត្តចន្លោមក្រុងភ្នំពេញ ក្នុង គ.ស. ១៨៦៩ ព្រះសង្ឃចាស់ឯទៀតដែលធ្វើជាចៅអធិការវត្តប្រាង្គបន្តបន្ទាប់គ្នាមក ដោយលំដាប់រហូតដល់សព្វថ្ងៃនេះមានចំនួន ៩ រូបដូចមានឈ្មោះខាងក្រោមនេះគឺ :

១- លោកគ្រូព្រះមហា ជាយ

២- ព្រះធម្មោសាថាវ្យ មាស

៣- ព្រះធម្មោសាថាវ្យ យិន

៤- ព្រះធម្មោសាថាវ្យ ឡិក

៥- ព្រះគ្រូគេនមុនី តែក

៦- ព្រះមហា ឆន

៧- ចៅអធិការ សេង

៨- ចៅអធិការ តេជ្ជ.ម៊ី

៩- ព្រះគ្រូគោធិញ្ញាណ ឌិត.កុំ ចៅអធិការបច្ចុប្បន្ន

គិតតាំងពីចៅអធិការទី ១ ក្នុង គ.ស.១៨៦៥ ដល់ទី ៩ ក្នុង គ.ស.
១៩៦៣នេះ យើញថាមានរយៈកាល ៩៨ ឆ្នាំហើយ ។

ក្នុងរយៈកាល ៩៨ ឆ្នាំនេះ វត្តប្រាង្គជួនកាលមានសេចក្តីចំរើនរុងរឿង ជួនកាលក៏មិនមានសេចក្តីចំរើនរុងរឿង ព្រោះកាលវេលាបែតនៅក្នុងអនិច្ចលក្ខណធម៌ជានិច្ច ។

កាលនៅទីបំផុតនៃការត្រួតត្រួងលោកគ្រូចៅអធិការទី ៣ គឺលោកគ្រូព្រះធម្មឃោសាចារ្យ យិន មានហេតុ ១ ដំកាចអាក្រក់កើតឡើងក្នុងទីវត្តប្រាង្គ ទាំឲ្យវត្តប្រាង្គបានខូចខួលខ្លាំងវិបត្តិ ១ ជំងឺគ្រោះថ្នាក់ដែលពុំធ្លាប់ជួបប្រទះ គឺកើតជម្ងឺអាសន្នកេតនៅក្នុងទីវត្តត្រឹមតែ ១ ថ្ងៃ ១ យប់ប៉ុណ្ណោះ ជម្ងឺនោះអាចផ្តាច់ខ្លួនបានតែព្រះសង្ឃក្នុងទីវត្តប្រាង្គអស់ចំនួន ១៦ រូប រួមទាំងលោកគ្រូព្រះធម្មឃោសាចារ្យ យិន ទំនឹងលោកគ្រូសូត្រ គឺព្រះចៅឡាត់ ឆន ជង ។ ក្នុងពេលនោះ ព្រះសង្ឃដែលសេសសល់ក្នុងវត្តត្រូវតែចេញពីវត្តអស់ឥតមានសល់ ។ ពួកពុទ្ធបរិស័ទជើងវត្តជិតឆ្ងាយក៏ឥតហ៊ានចូលមកក្នុងវត្តសោះឡើយ ។ ម្ល៉ោះហើយ វត្តប្រាង្គនោះត្រូវនៅដោយស្ងាត់ជ្រងំ ដូចជាមនុស្សដែលផុតខ្យល់ចេញចូលហើយ សល់នៅតែរូបកាយជាសាកសពទទេ ក្នុងកណ្តាលព្រៃ ។ វត្តប្រាង្គក្នុងពេលនោះ

ត្រូវនៅកន្លែងកណ្តាប់ដៃនៃពួកចោរ ព្រមទាំងបិតនៅកន្លែងកណ្តាលនៃសម្រែក វែកលួចាំងយប់ទាំងថ្ងៃ ដូច្នេះហើយបានជាវត្តប្រាង្គបានត្រូវទទួលមហន្តរាយយ៉ាងសម្បើម គឺសម្បត្តិដ៏មានតម្លៃ ដែលមាននៅកន្លែងវត្តទាំងប៉ុន្មានត្រូវនាសអន្តរាយអស់គ្មានសល់ ។

វត្តប្រាង្គដែលទទួលគ្រោះថ្នាក់ កន្លែងសម័យនោះអស់ចំនួន ១៥ ថ្ងៃ ក្រោយពីនោះ សម្តេចព្រះមហាសង្ឃរាជព្រះនាម ឆៀង ទ្រង់បានចាត់តាំងព្រះធម្មយោសាចារ្យ ឱ្យទៅធ្វើជាចៅអធិការវត្តប្រាង្គតមក ។

លុះដល់ចៅអធិការទី ៦ វត្តប្រាង្គមានការរើរៀបចំខាងការសិក្សាខ្លះខាងផ្លូវប្រតិបត្តិខ្លះ តែមិនបានប្រព្រឹត្តទៅស្រួល ចេះតែអាក់អន្លួលដោយមានឧបស័គ្គស្ទាក់ផ្លូវជាដរាប ។

កន្លះយៈកាលនៃចៅអធិការទី ៧ ទី ៨ ទី ៩ វត្តប្រាង្គក៏ត្រឡប់បានចំរុងចំរើនឡើងដោយការសិក្សា និងការប្រតិបត្តិដ៏សមរម្យតាមព្រះពុទ្ធសាសនា ព្រមទាំងបានចំរើនដោយទីសេនាសនៈត្រប់យ៉ាង ឧបស័គ្គទាំងឡាយក៏រលាយរលត់ទៅជាលំដាប់ ។ ចំណែកភិក្ខុសាមណេរក្នុងទីវត្តប្រាង្គ ក៏មានបរិបូណ៌ ក្នុង ១ ខែ ។ មានចំនួន ៧០ ឬ ៨០ អង្គដែលចេញពីវត្តនានា ក្នុងព្រះពុទ្ធអាណាចក្រ មកសូមសំណាក់អាស្រ័យនៅក្នុងវត្តប្រាង្គ ដើម្បីសិក្សាព្រះបរិយត្តិធម៌ ទីនឹងចំណេះវិជ្ជាផ្សេង ។ ព្រោះ

នៅវត្តប្រាង្គ មានសាលាតុំទី១កបឋមសិក្សា តាំងពី គ.ស. ១៩៣៤ រហូតដល់ឆ្នាំ ១៩៦៣ នេះ តុំដែលមានការអោកខានក្នុងឆ្នាំណាមួយ ខ្សោយ គឺមានអាចារ្យសម្រាប់បង្ហាត់បង្រៀន មានសមណនិស្សិត បរិបូណ៌ តាំងពីទ្វេបរិស័ទចំណុះដើងវត្ត ក៏មានសទ្ធាជ្រះថ្លាជួយទេវត្តម្ភ ដោយចតុប្បច្ច័យ ល្មមព្រះកិច្ចសង្ឃ សំណាក់អាស្រ័យរៀនសូត្របានដោយសុខស្រួល ។

ដែលជាតំរេសជាងគេ គឺលោកហៅអធិការទី ៩ ក្នុងបច្ចុប្បន្នកាលនេះ ។ លោកហៅអធិការនេះឈ្មោះ ឯត-កុំ មានសមណសក្តិជាព្រះគ្រូពោធិញ្ញាណ លោកត្រូវជាហៅទួតនៃលោកគ្រូព្រះធម្មឃោសាចារ្យ មាស ជាហៅអធិការទីពីរ ។ តាំងពីលោកបានទទួលហានេះជាហៅអធិការមកទល់នឹងឆ្នាំ ១៩៦៣ នេះ ជាង ១០ ឆ្នាំហើយ ក្នុងវត្តប្រាង្គ មានសេចក្តីចំរុងចំរើនគ្រប់ផ្នែក សេចក្តីសុខសាន្តក៏មានបរិបូណ៌ តាំងពីទ្វេបរិស័ទក៏មានសាមគ្គីធម៌ល្អ ព្រោះលោកហៅអធិការនេះស្លូតបូត មានឫកពាសុភាពកបសារ មានចរិយាសមរម្យ គួរឱ្យគេពេញចិត្តជ្រះថ្លាឯចំណេះវិជ្ជាគួរសមខ្លះ មានត្រឹមតែវិញ្ញាបនប័ត្រនៃសាលាតុំទី១កបឋមសិក្សាប៉ុណ្ណោះ ប៉ុន្តែជាអ្នកឈ្វាស់វៃក្នុងកិច្ចការទាំងពួង ហើយទំនើងប្រែងប្រែងបំពេញកិច្ចការគ្រប់យ៉ាង ឥតប្រហែសធ្វេស ។

ក្រោពីហៅអធិការ មានខ្ញុំខ្ញុំ គឺព្រះពោធិវង្ស ហួត-តាត ដែល

មានជាតិកូមិនៅជ្រុងដុង្គវែង ចាន់មកសិក្សាឯវត្ត ណ្ណាលោម ក្រុង ភ្នំពេញ តាំងពីកាលនៅជាសាមណេរអាយុ ១៣ ឆ្នាំ លុះដល់មានវ័យ ចំរើនឡើងចាន់ខ្ញុំលួសជា ឧបសម្បទាជាភិក្ខុនៅវត្ត ណ្ណាលោម ហើយតមក ខ្ញុំចាន់ជួយចំពេញកិច្ចការគ្រប់ផ្នែកក្នុងទីវត្តច្រាង្គ រួបរួមជាមួយនឹងលោក ចៅអធិការវត្តច្រាង្គ តាំងពីចៅអធិការទី ៦ រហូតដល់ចៅអធិការទី ៩ ថ្ងៃនេះ ។

នៅក្នុងទីវត្តច្រាង្គ មានវត្ថុដ៏ប្រសើរ ជាគោលចារឹកសម្រាប់វត្ត មានពីរគឺ ព្រះច្រាង្គ ទីដ៏វិហារ ។

ព្រះច្រាង្គ

ព្រះច្រាង្គដែលមានរូបភាព ភ្ជាប់ក្នុងសៀវភៅនេះ គឺសម្តេចព្រះ មហាសង្ឃរាជព្រះនាម ឆៀង ទ្រង់បានជួសជុលឡើងជាថ្មី ដោយទ្រង់ ឧកដល់ព្រះពជបណ្តាំនៃព្រះបាទសម្តេចព្រះហរិរក្សរាមា ។ កាលមុន សម្តេចព្រះមហាសង្ឃរាជទ្រង់ជួសជុលនោះ ព្រះច្រាង្គនេះបឹតនៅក្នុង សភាពទ្រុឌទ្រោមជាក់បែកច្រើនណាស់ មានដើមឈើតូច-ធំដុះទ្រុប ទ្រុលគ្រប់ជ្រុងជ្រាក់ កន្លែងខ្លះជាក់បែកខ្លួចភ្លាំរបេះរបកឥដ្ឋចេញអស់ កន្លែង ខ្លះក៏សល់នៅ ល្មមឲ្យសង្កេតយល់បានថាមានរូបភាពយ៉ាងនេះ។ ព្រះ ព្រះច្រាង្គនេះតាមការពិនិត្យសង្កេតមើលដោយល្អិតល្អៀត ឃើញថាគេ កសាងមកជាយូរអង្វែងច្រើនសតវត្សរ៍ហើយ មុនការកសាងវត្តច្រាង្គនោះ ទៅទៀត ។

(នៅមានត)



សម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ទ្រង់កំពុងស្តេចលើកម្រាលដ៏ប្រណិត
ពោរពេញដោយបុប្ផា ថ្វាយព្រះអង្គដែលយុវតីដ៏ស្រស់ប្រឹមប្រិយ ជាចង្វាយជាព្រះ
បរមកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឧកាសពិធីសម្ពោធ ធ្វើងព្រះវិហារ - បញ្ចុះសីមាវត្តព្រាង្គ
(ទន្លុង្គ) នៅថ្ងៃទី ២៤ - កុម្ភៈ ១៩៦៤.

បុណ្យឆ្លងវិហារវត្តប្រាង្គ និងបញ្ចុះសីមា

ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមាតាជាតិ នឹង

សម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គតុច្ឆសាសនូបត្ថម្ភក៍

ឧដុង្គជារាជធានីបុរាណរបស់ប្រទេសកម្ពុជា មុនព្រះរាជធានីភ្នំពេញ ចម្ងាយប្រមាណ ៤០ គីឡូម៉ែត្រពីភ្នំពេញ ។ យើងនៅចាំបានថា ឧដុង្គជាអតីតរាជធានីខ្មែរ ដែលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទ្រង់ចោះបង់ចោលនៅឆ្នាំ ១៨៦៥ ។ តាំងពីពេលនោះមក ឧដុង្គក្លាយទៅជាទីស្ងាត់ តែកិត្តិនាមឧដុង្គនៅមានល្បីជាដរាបរហូតមកដល់សព្វថ្ងៃ ។

ឧដុង្គក្លាយទៅជាទីស្ងាត់ ស្ទើរចុះអន្ទុះស្បៃវែយ៉ាងជានិទៅហើយ ស្រាប់តែនៅថ្ងៃសៅរ៍ទី ២៤ កុម្ភៈ ១៩៦៤ អន្ទុះស្បៃវែយមួយដំមហាស្ចារ្យមកចំផុសឲ្យនឹកឃើញដល់ថ្ងៃដែលព្រះរាជធានីតាំងនៅឧដុង្គមុននេះ ១០០ ឆ្នាំ ។ ថ្ងៃទី ២៤ កុម្ភៈនេះ មិនតឹអ្វីទេ គឺជាថ្ងៃបុណ្យបញ្ចុះសីមាវត្តប្រាង្គ ។

កម្មវិធីបុណ្យបញ្ចុះសីមាវត្តប្រាង្គ គឺចាប់ពីថ្ងៃ ១៩ កុម្ភៈ រហូតដល់ថ្ងៃ ២៤ កុម្ភៈ ឆ្នាំ ១៩៦៤ ។ នៅថ្ងៃទី ១ ពេលម៉ោង ៤ រសៀល មានពិធីរំលឹកគុណព្រះរតនត្រ័យនឹងប្រកាសទៅវត្ត ហើយហែនិមន្តសីមាចូលទៅតម្កល់ក្នុងព្រះវិហារ ។ នៅពេលយប់ មានអុជប្រទីបជ្វាលា ហើយ

មានព្រះសង្ឃ ១០០អង្គ ចំរើនព្រះបរិត្ត-រៀនមិត្តសីមានីមួយវាហារថ្វាយព្រះភិក្ខុសង្ឃ មានអុជកាំជ្រួចផង ។ បន្ទាប់មក ទើបមានព្រះធម្មកថិកមួយព្រះអង្គ សំដែងព្រះធម៌ទេសនា ។

នៅថ្ងៃទី ២ ពេលព្រឹកម៉ោង ៧ ប្រគេនយាគូចំពោះព្រះសង្ឃ ម៉ោង ១០ កន្លះប្រគេនចង្ហាន់ ម៉ោង ៣ រសៀលធម្មកថិក ១ ព្រះអង្គ សំដែងធម៌ទេសនា រួចប្រគេនកេសដូរព្រះសង្ឃ ។ យប់ម៉ោង ៨ និមន្តព្រះសង្ឃ ១០០ អង្គចំរើនព្រះបរិត្ត-អុជកាំជ្រួច-ហើយនិមន្តព្រះធម្មកថិក ទេសនាព្រះធម្មគ្រាស់-ធ្វើពុទ្ធាភិសេក ។

នៅថ្ងៃទី ៣ ពេលព្រឹកដូចថ្ងៃទី ២ ។ ពេលម៉ោង ៨ យប់ ចំរើនព្រះបរិត្ត ម៉ោង ៨ ព្រះសង្ឃ ១០០ អង្គ ធ្វើសង្ឃកម្ម គឺសូត្រដកសីមាចាស់ចងសីមាថ្មី ។

ថ្ងៃទី ៤ គឺថ្ងៃទី ២៤ កុម្ភៈ ១៩៦៤ ជាថ្ងៃបំផុសទឿនកដល់អនុស្សាវរីយ៍នៃសម័យកាជាទីខុដ្ឋគ្ន ។ នៅម៉ោង ៨ កន្លះ ពុទ្ធបរិស័ទកកកុញមកវេចាំទទួលសម្តេចព្រះមហាក្សត្រិយានី ទីឯសម្តេចព្រះប្រមុខរដ្ឋ ។ ចំណែកព្រះសង្ឃវិញ គេសង្កេតឃើញមានសម្តេចព្រះសង្ឃកដតាំងពីព្រះអង្គជាប្រធាន ។ នៅម៉ោង ៨,៤០ នាទី ប្រជាពលករអើតងើយទៅលើមេឃ ខ្ទឹងវេចាំព្រះកដឋក្ស័ចក្រជាព្រះកដទីតាំង ។ នៅពេលនេះហើយវដលប្រជាពលរដ្ឋនៅខុដ្ឋគ្ន វេចាំធ្វើគារវកិច្ច ចំពោះសម្តេចព្រះ



សម្តេចមហាព្រះប្រមុខរាជ្ឋ ទ្រង់ព័ទ្ធដង្ហែរស្តេចលើកម្រាល ពោរពេញដោយបុប្ផាផៃលតារីផ្ទៃ
ស្រស់ច្រើនប្រើយ ជាឧថ្វាយដាព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសពិធីសម្ពោធផ្នូងព្រះ
វិហារវត្តប្រាង្គ (ខន្តីធ្ងង) នៅថ្ងៃទី ២២ កុម្ភៈ ១៩៦៤

មាតាជាតិ ទីឆ្នាំសម្តេចព្រះបិតាឯកឧត្តមជាតិ ។ នៅម៉ោង ៨,៤៥ មហាបក្ខ័ចក្រុបានទាំព្រះពរជាដំណើរនៃសម្តេចនៅដល់ទីក្រុងភ្នំពេញ ។ ពេលសម្តេចយាងចុះពីឧទ្ធម្ភាគចក្រ ឥស្សរជនខ្មែរជាច្រើនបានទៅគាល់ថ្វាយព្រះពរស្វាគមន៍ដល់សម្តេច ។ មានជាអាទិ៍តីសហជីវិន សាន.ណាក ចៅហ្វាយខែត្រកំពង់ស្ពឺ អភិបាលម្ចាស់ម៉ឺនតាណា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ អភិបាលម្ចាស់កន្លះ នាយករដ្ឋមន្ត្រី សហជីវិន អ៊ឹង.ហ៊ុនសាធ ប្រធានរដ្ឋសភា ឯកឧត្តម សាន.យ៉ុន ឧត្តមសេនីយ៍ឯក ង៉ោ.ហ៊ួ សមាជិកសភាចាំងពីរ សមាជិកអង្គកិច្ចសាល ។

នៅម៉ោង ៩ សម្តេចព្រះមាតាជាតិ ស្តេចយាងមកតាមព្រះវិថីចាំងវេយន្តកាត់ក្រុងភ្នំពេញ ។ ព្រះអង្គបានឧទ្ទិសកងរាជឃ្លាំងរ ជាទិព្វគ្រឿងថ្វាយព្រះពរស្វាគមន៍ ហើយទីឆ្នាំរកិច្ចព័តឆ្នាំឆ្លាំឆ្នាតិ ទីឆ្នាំការបន្ទុំក្នុងជាតិថ្វាយជាព្រះរាជកិត្តិយស ។

លុះសម្តេចចាំងពីព្រះអង្គទ្រង់តង់សម្រួលព្រះឥរិយាបថហើយ ទើបព្រះសង្ឃស្វាធ្យាយធម៌ជយន្តោថ្វាយ ដើម្បីជោគជ័យសិរីសួស្តី ។

បន្ទាប់មក ព្រះពោធិវង្ស ហួត.តាត ថ្លែងសុន្ទរកថារៀបរាប់អំពីការកសាងវិហារថ្មី ហើយទីឆ្នាំថ្វាយចំពោះសម្តេចជាអម្ចាស់ចាំងពីព្រះអង្គខ្លួនព្រះបុញ្ញាភិសិកុសល ដែលកើតឡើងពីការកសាងព្រះវិហារនេះ ។

(នៅមានត)

អំពីព្រះនាមព្រះតេជព្រះគុណ

ដែលបានទទួលសញ្ញាប័ត្រចាត់តាំង

ជាចៅអធិការនិងគ្រូសូត្រក្នុងវត្តនានា

ក្នុងព្រះរាជអាណាចក្រ

(ក)

៣៧- ព្រះតេជព្រះគុណ អ៊ុំ-សាំងសាន នាមនាយាសុន្ទរប្បញ្ញា កើតឆ្នាំ ស.ស. ១៨៣៩ អាយុ ២៣ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រធ្វើង ក្នុងវត្តភូនកុំថ្ម ឃុំត្រពាំងសាន ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣៤២១ ចុះថ្ងៃទី ២២-១១-៦២ ។

៣៨- ព្រះតេជព្រះគុណ ទិត-ឡូត នាមនាយាបញ្ញាជោតិ កើតឆ្នាំ ស.ស. ១៨៤៥ អាយុ ៦៩ ឆ្នាំ វស្សា ៤៨ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តខ្លុំទាងដើង ឃុំកំពង់ពពិល ស្រុកពាក់ឯ ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣៤២២ ចុះថ្ងៃទី ២២-១១-៦២ ។

៣៩- ព្រះតេជព្រះគុណ សុក-សុន នាមនាយាឥន្ទបញ្ញា កើតឆ្នាំ ស.ស. ១៨២៩ អាយុ ៣៣ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាឧបជ្ឈាយ៍ក្នុងវត្តចេតិយថ្ម ឃុំវិហារហ្លួង ស្រុកពញាក្រុ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤២៣ ចុះថ្ងៃទី ៣-១២-៦២ ។

៤០- ព្រះតេជព្រះគុណ អ៊ុំ-សិន នាមនាយាសុថនថេរ កើតឆ្នាំ ស.ស. ១៨៣៥ អាយុ ៦៧ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាចៅអធិការ

ក្នុងវត្តចេតិយថ្មី ឃុំវិហារហ្លួង ស្រុកតញ្ញាញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៦២៤ ចុះថ្ងៃទី ៣-១២-៦៦ ។

៦១- ព្រះតេជព្រះគុណ ពត-សុខ នាមឆាយា ខនបញ្ញាថេរ កើតឆ្នាំ ត.ស. ១៩២៥ អាយុ ៣៧ ឆ្នាំ វស្សា ១៨ បានខិតខំលះតែងតាំងជាឧបជ្ឈាយ៍ ក្នុងវត្តជ្រោយពិស ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៦២៥ ចុះថ្ងៃទី ៣-១២-៦៦ ។

៦២- ព្រះតេជព្រះគុណ អួង-ប៊ក់ នាមឆាយាគម្ពីរជ្លោតតោ កើតឆ្នាំ ត.ស. ១៩៣៤ អាយុ ៦៨ ឆ្នាំ វស្សា ៧ បានខិតខំលះតែងតាំងជាចៅអធិការ វត្តជ្រោយពិស ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៦២៦ ចុះថ្ងៃទី ៣-១២-៦៦ ។

៦៣- ព្រះតេជព្រះគុណ អ៊ុក-ប៉ម នាមឆាយាឥន្ទវង្សោ កើតឆ្នាំ ត.ស. ១៩៣៦ អាយុ ៣០ ឆ្នាំ វស្សា ១០ បានខិតខំលះតែងតាំងជាគ្រូសូត្រស្តាំក្នុង វត្តជ្រោយពិស ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៦២៧ ចុះថ្ងៃទី ៣-១២-៦៦ ។

៦៤- ព្រះតេជព្រះគុណ តង់-សុត នាមឆាយាធម្មោបទីបោ កើតឆ្នាំ ត.ស. ១៩៣៩ អាយុ ២៧ ឆ្នាំ វស្សា ៦ បានខិតខំលះតែងតាំងជាគ្រូសូត្រ ឆ្វេង ក្នុងវត្តជ្រោយពិស ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៦២៨ ចុះថ្ងៃទី ៣-១២-៦៦ ។

៤៥- ព្រះតេជព្រះគុណ ង៉ិម-សុខុន នាមនាយាពុទ្ធបញ្ញោ កើតពី គ.ស. ១៩២៨ អាយុ ៣៤ ឆ្នាំ វស្សា ១២ ជានខេត្តលែងតាំងជាគ្រូសូត្រស្តាំ កន្លែងវត្តមង្គលសត្តាវ័ន ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤២៩ ចុះថ្ងៃទី ១៥ ១២ ៦២ ។

៤៦- ព្រះតេជព្រះគុណ ម៉ា-សារេត នាមនាយាកតិវេក កើតពី គ.ស. ១៩៣៩ អាយុ ២៣ ឆ្នាំ វស្សា ៤ ជានខេត្តលែងតាំងជាគ្រូសូត្រឆ្វេង កន្លែងវត្តមង្គលសត្តាវ័ន ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣០ ចុះថ្ងៃទី ១៥-១២-៦២ ។

៤៧- ព្រតេជព្រះគុណ អ៊ុយ-ឡឹង នាមនាយាតិស្សត្ថេរ កើតពី គ.ស. ១៩០១ អាយុ ៦១ ឆ្នាំ វស្សា ៣៧ ជានខេត្តលែងតាំងជាគ្រូសូត្រស្តាំ កន្លែងវត្តសួនពេជ្រ ឃុំកន្ទោក ស្រុកកំពង់ចាម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣១ ចុះថ្ងៃទី ១៥-១២-៦២ ។

៤៨- ព្រះតេជព្រះគុណ ចោយ-ឡឹង នាមនាយាមង្គលត្ថេរ កើតពី ឆ្នាំរកា អាយុ ៤២ ឆ្នាំ វស្សា ២២ ជានខេត្តលែងតាំងជាគ្រូសូត្រឆ្វេង កន្លែងវត្តសួនពេជ្រ ឃុំកន្ទោក ស្រុកកំពង់ចាម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣២ ចុះថ្ងៃទី ១៥-១២-៦២ ។

៤៩- ព្រះតេជព្រះគុណ លឹម-លន់ នាមនាយាខេមានន្ទោ កើតពី គ.ស. ១៩៣៣ អាយុ ២៣ ឆ្នាំ វស្សា ៩ ជានខេត្តលែងតាំងជាគ្រូ

សូត្រស្តាំ វត្តសំរោង ឃុំថ្នល ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣៣ ចុះថ្ងៃទី ១៩.១២.៦២ ។

៥០- ព្រះតេជព្រះគុណ យូ.យ៉ែម នាមធម្មាភិសិទ្ធគ្គោ កើតពីគ.ស. ១៩០៥ អាយុ ៥៧ ឆ្នាំ វស្សា ៨ ជានគ្រូលតែងតាំងជាគ្រូសូត្រធ្វើកម្មវត្តសំរោង ឃុំថ្នល ស្រុកកំពង់ញ្ញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣៤ ចុះថ្ងៃទី ១៩.១២.៦២ ។

៥១- ព្រះតេជព្រះគុណ ភួច-ស្មុក នាមធម្មាសុវណ្ណប្បញ្ញោ កើតពី គ.ស. ១៩៤០ អាយុ ៧៤ ឆ្នាំ វស្សា ១៩ ជានគ្រូលតែងតាំងជាចៅអធិការកម្មវត្តពោធិវង្ស ឃុំចំការសំរោង ស្រុក ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣៤៣៥ ចុះថ្ងៃទី ១៩.១២.៦២ ។

៥២- ព្រះតេជព្រះគុណ ខេត-តាប់ នាមធម្មាអភក្ខសោ កើតពី គ.ស. ១៩៤០ អាយុ ២៤ ឆ្នាំ វស្សា ៥ ជានគ្រូលតែងតាំងជាគ្រូសូត្រស្តាំកម្មវត្តពោធិវង្ស ឃុំចំការសំរោង ស្រុកខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣៤៣៦ ចុះថ្ងៃទី ១៩.១២.៦២ ។

ព្រះតេជព្រះគុណ ម៉ឺង-ឃៀម នាមធម្មាយាចន្ទសោភោ កើតពី គ.ស. ១៩៣៩ អាយុ ២៥ ឆ្នាំ វស្សា ៤ ជានគ្រូលតែងតាំងជាគ្រូសូត្រធ្វើកម្មវត្តពោធិវង្ស ឃុំចំការសំរោង ស្រុកខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣៤៣៧ ចុះថ្ងៃទី ១៩-១២-៦២ ។

៥៤- ព្រះតេជព្រះគុណ ហែម-នាង នាមឆាយាឥន្ទបញ្ញាត្ថេរ កើតពីត.ស. ១៨១៤ អាយុ ៥០ ឆ្នាំ វស្សា ២៧ ជានាយកវត្តកំពង់កែវអណ្តែត ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៣៨ ចុះថ្ងៃទី ១៥-១២-៦២ ។

៥៥- ព្រះតេជព្រះគុណ តាង-ញឹម នាមឆាយាសុវណ្ណកេសរ កើតពីត.ស. ១៨២០ អាយុ ៤៤ ឆ្នាំ វស្សា ៨ ជានាយកវត្តកំពង់កែវអណ្តែតឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៣៩ ចុះថ្ងៃទី ១៥-១២-៦២ ។

៥៦- ព្រះតេជព្រះគុណ ហ៊ីយ-នាង នាមឆាយា ឥន្ទជ្ជោ កើតពីត.ស. ១៨៤៦ អាយុ ៧០ ឆ្នាំ វស្សា ៦ ជានាយកវត្តកំពង់កែវអណ្តែត ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៤០ ចុះថ្ងៃទី ១៥-១២-៦២ ។

៥៧- ព្រះតេជព្រះគុណ ភ័ន់.រ៉ែន នាមឆាយា ធម្មរក្ខិត កើតពីត.ស. ១៨១៤ អាយុ ៤៨ ឆ្នាំ វស្សា ២៧ ជានាយកវត្តសិរីវន្ធា ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៤១ ចុះថ្ងៃ ២៨-១២-៦២ ។

(នៅមានត)

ភាវនាសទ្ទិយា

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៦ លេខ ៤ ខែ មេសា

ព. ស. ២៥០៦ គ. ស. ១៩៦៤

ក្នុងឱកាសចូលឆ្នាំថ្មី


សូមព្រះតេជៈតំកល់លើត្បូង

សូមព្រះរាជទាន ក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រិយានី នឹង
សម្តេចព្រះទេបយុវរាជ ព្រះប្រមុខរដ្ឋ ក្រោមល្អង់ធួលព្រះបាទ
សូមទ្រង់ជ្រាប ។

ក្នុងឱកាសចូលឆ្នាំថ្មី គឺឆ្នាំកេរឯស័កព ស.២៥០៧ គ.ស.១៩៦៤នេះ
ខ្ញុំព្រះបង្គំជាខ្ញុំទាំងឡាយ ក្រុមពុទ្ធសាសនបណ្ឌិត្យ
សូមលំអុតលំនន់តាយភ្លាចិត្ត ក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរព
ដ៏ជ្រាលជ្រៅនឹងដឹងស្មោះស្ម័គ្រ ចំពោះសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ
ជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចព្រះទេបយុវរាជ ព្រះប្រមុខរដ្ឋកម្ពុជា នូវព្រះពរ
សព្វសាធុការមហាប្រសើរក្រៃលែង

សូមអានុភាពដ៏អស្ចារ្យនៃគុណព្រះរតនត្រៃ នឹងវត្ថុសក្តិសិទ្ធិក្នុងលោក មាន
ទេព្តារក្សាព្រះមហាស្វេតច្ឆត្រជាដើម ជួយបីបាច់ថ្នាក់ថ្នមថែរក្សាការពារ សម្តេច
តាំងពីព្រះអង្គជាទំស្នេហាស្ទើជីវិត សូមព្រះអង្គទ្រង់ប្រកបដោយព្រះបរមសុខ
សុភមង្គល សិរីសួស្តីគ្រប់យ៉ាងក្នុងព្រះសិរីរាជសម្បត្តិ មានព្រះជន្មាយុយឺនយូរ
ជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ដល់កូនចៅព្រះអង្គ សូមព្រះអង្គទ្រង់ឈ្វេ
អស់មារសត្រូវគ្រប់ទិសទី សូមព្រះរាជបំណង មុតដូចអាវុធទិព្វ អាចពុះពារទុប
សន្តគ្រប់បែបយ៉ាង ឲ្យវិនាសអន្តរាយខ្ចាត់ខ្ចាយ កុំបីមកកាត់ឆ្ងាយឡើយ ។

ពុទ្ធសាសនបណ្ឌិត្យ



ភ័ណ្ឌសុទ្ធិយោ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញារាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

	ទំព័រ
ផ្នែកសាសនា	
- ជាយបរាជិកថា រៀបរៀងដោយ ព្រះភិក្ខុ ពុទ - វ័ន គង់វត្តកោះភ្នំពេញ . . .	៣៥១
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ - ប៊ី តែងរៀបរៀង (ត) . . .	៣៦២
- អ្នកមានគុ.ណ រៀបរៀងដោយលោក ហេង - សមអាន នៅសេនាធិការ ខេត្តកំពង់ចាម	៣៦៩
- ព្រះវិច្ឆរដាតក (ត)	៣៨១
ផ្នែកអក្សរសាស្ត្រ	
- បម្លាំងក្នុងលោក (វិចារណកថា) រៀបរៀងដោយ ប៊ូ - ឆរិន្ទ សង្កាត់លេខ ៤ ក្រុងភ្នំពេញ	៣៩២
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហាជាំង - ខាត់ រៀបរៀង (ត)	៣៩៩
- រឿងអាថ៌លហ្គាំគូរីស៍ លោក ភ័យ - ល្មុត ជំណាងអក្សរ ប្រែរៀបរៀង (ត) . .	៤០១
- ល្បែកឃ្លាហ្គុងតែន លោក ផេង - ទ្រីវ ប្រែពីភាសាចាវ៉ាំង (ត)	៤០៩
- រឿងសាមកុក អ្នកនាកញ្ញាវិបុលរាជសេនា ន្ហ - កន ប្រែរៀបរៀង (ត) . . .	៤១៤
- ព្រះរាជនិពន្ធ រាមកេរ្តិ៍ ស្រោវគ្រោវ ដោយលោក ខ - គាម (ត)	៤២៥
- រឿងព្រេងចិន (រឿងក្តីនអូឌួ) លោក ភ័យ - ប៊ុក ប្រែពីភាសាចាវ៉ាំង (ត) . .	៤៣៤
- ទំនៀមទម្លាប់ខ្មែរ៖ រឿងព្រេងចឹងតេ	៤៣៩
ផ្នែកកំណត់ទីធីប្រវត្តិការណ៍	
- ប្រវត្តិនៃវត្តប្រាង្គ រៀបរៀងដោយព្រះគេជព្រះគុណព្រះពោធិវង្ស ហួត-ភាត (ត) .	៤៤៣
- បុណ្យបញ្ចុះសីមា និងធ្វើឧព្រះវិហារវត្តប្រាង្គ (តចប់)	៤៥៤
- រឿងតាំងលើអធិការ និងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ (ត) . .	៤៥៨
- សេចក្តីផ្សេងៗ	៤៦៥

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អហើ
ឲ្យឱ្យសមាត់ចិត្ត កុំឲ្យហ្មងសៅ
ប៊ីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

ជីយបរាជីយកថា

រៀបរៀងដោយភិក្ខុ ពុទ្ធ - សាវ័ន គង់នៅវត្តកោះភ្នំពេញ

ជនោ តស្ស កកវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះ ព្រះសត្វមុនីអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះសទ្ធម្ម និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

វេលានេះ អាត្មាភាព សូមសំដែងអំពី «ជីយបរាជីយកថា» រៀបរាប់អំពីការឈ្នះ និងការចាញ់របស់មនុស្សលោក តាមន័យដែលមានមកក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយត្រង់សុខវគ្គ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធមាមកជនទូទៅ និងជាគ្រឿងពិចារណាកុងបញ្ហាជីវិតរបស់សត្តនិករ ឲ្យឃើញដោយប្រចក្ខថា មានប្រយោជន៍ឬមិនមាន ខឿនគាត់ឬមិនខឿនគាត់ ដូចតទៅ ៖

កាលព្រះអនាវរណញ្ញាណ ទ្រង់តម្កល់សម្រេចសម្រាន្តព្រះអរិយបថកុងវត្តជេតពន ជាអាកមរបស់អនាថបិណ្ឌិកសេដ្ឋី ខឿបក្រុងសាវត្ថី

ទ្រង់ស្តែងសព្រះពុទ្ធមានធម៌ទេសនា ប្រោសឲ្យការបរាជ័យរបស់ព្រះបាទកោ
សលរាជ ។

សេចក្តីដំណាលថា : ព្រះរាជអង្គនោះ ទ្រង់ធ្វើពិធីយុទ្ធសាស្ត្រ
ទ័ពព្រះបាទអជាតសត្តុ ប៉ុន្តែទ្រង់បរាជ័យចាញ់ថ្កុំថ្កែព្រះបាទអជាតសត្តុ
អស់វារៈពីរដង លុះដល់លើកទី ៣ ព្រះអង្គទ្រង់មានតម្រិះក្នុងព្រះរាជចិន្តា
«បើគាត្មាអញមិនអាចញាំង់ចារកដែលមានចិត្តក្បរក្នុងមាត់ឲ្យត្រឡប់ចាញ់
វិញបានទេ តើការរស់នៅ មានប្រយោជន៍ដល់គាត្មាអញឬទេ ? ។

ព្រះអង្គក៏ទ្រង់អត់ព្រះស្វាយ ផ្ទុំជាទុក្ខក្រៀមក្រំ លើខែនទីសយនា
ក្រឡាព្រះបន្ទំ ។ ដំណឹង៎នោះ ក៏លេចឮទៅសុសសាយជ្រាបដល់ព្រះ
សម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទើបព្រះអង្គទ្រង់សម្តែងព្រះគាថា ប្រោសឲ្យ
ចំពោះភិក្ខុទាំង៎ឮយថា :

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ

ប្រែថា : បុគ្គលអ្នកឈ្នះរមែង៎បានខ្ពួលខ្ពូវពៀរ បុគ្គលដែលត្រូវ
គេផ្តាញ់ហើយ តែង៎នៅជាទុក្ខ (ឯព្រះខីណាស្រពដែលមានកាត់ក្តីលេស
ស្ងប់រម្ងាប់ហើយ តែង៎នៅជាសុខ ព្រោះ (លោក) ដម្រុះចោលហើយ
ខ្ពូវការឈ្នះនិង៎ការចាញ់ ។

អធិប្បាយថា : បុគ្គលអ្នកមានជ័យជំនះ មានមេទ័ពជាដើមដែលឈ្នះកងទ័ពដទៃ ជាបច្ចាមិត្ត រមែងគន់គាន់ចានខ្លួវគៀរវែក គឺមុខជានឹងមានថ្ងៃ ២ ឆ្នាំ ណាមួយ ពួកបច្ចាមិត្តទាំងនោះនឹងឲ្យចាញ់វិញជាពុំខាន ។ អ្នកចាញ់គេគឺបុគ្គលដែលគេឲ្យបរាជ័យហើយ រមែងព្រួយចារម្ភជាទុក្ខ គ្រប់គ្រាយបថទាំងពួង ដោយមានការឈឺចាប់ក្តៅក្រហល់ក្រហាយ អន្ទះអន្ទែងក្នុងចិត្ត ទឹកគ្រតជាទម្ងន់ថា : តាលណាហ្ន៎! អញនឹងអាចមើលយើញខ្ញុំពួកបច្ចាមិត្ត គឺធ្វើពួកបច្ចាមិត្តឲ្យបរាជ័យ រត់ខ្ចាត់ខ្ចាយចេញពីមុខបាន ។

បុគ្គលដែលមានកាយ វាចា ចិត្តស្ងប់រម្ងាប់ សំដៅយកព្រះវិណាស្រព ដែលលោកមានពាក្យចំក្លែសស្ងប់ហើយ ក្នុងសន្តាន លះបង់ខ្លួវការឈ្លោះនឹងការចាញ់បានហើយគឺមិនមានសិក្សត្រូវអ្វីមួយដែលលោកត្រូវផ្តាញ់ឬបសគ្គណាមួយដែលត្រូវផ្តាញ់ ចំពោះលោកឡើយ ម្ល៉ោះហើយលោករមែងនៅជាសុខគ្រប់គ្រាយបថទាំងពួង ពោះបីដើរ ឈរអង្គុយដេកក្តីក៏ជាសុខឥតមានកង្វល់អ្វីឡើយ ។

មួយទៀត ការធ្វើបម្បាំងនីមួយ ។ មិនមែនមានសុខតែបរាជ័យប្លែកអបរាជ័យទាំងអស់នោះទេ រមែងមានស៊ីមានសង គឺជួនកាលក៏ខ្លួនមានជ័យជំនះលើពួកបច្ចាមិត្ត ជួនកាលក៏ត្រូវចាញ់វិញ សូម្បីតែអ្នកមានជ័យជំនះហើយ ក៏ពុំអាចរក្សាសិទ្ធិនោះ ឲ្យតង់ស្ថិតស្ថេរជាស្ថាពរ

ចានឡើយតង់មានទុកាសណាមួយ ពួកបច្ចាមិត្តខាងនោះ ទើបមក
ដណ្តើមរបស់ខាងយកសិន្ធិសេរីភាពនោះចានវិញជាពិតប្រាកដ ។

មានតែព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់ទេ ដែលទ្រង់ធ្វើយចាកសិក
សត្រូវ ទ្រង់កំចាត់បង់ចោលស្រឡះ ខ្វះសិក្ខសត្រូវពោលគឺកិលេស
ដោយអំណាចអរិយមគ្គញាណ ឥតមានសេសសល់នៅក្នុងសន្តានរបស់
ព្រះអង្គ ដែលទ្រង់ពុំដែលឈ្នះអស់ជាតិជាអនេក ទ្រង់ឈ្នះហើយ
លែងត្រឡប់ចាញ់វិញ ទ្រង់គង់នៅជាសុខ ឥតមានកង្វល់អ្វី ប៉ះដូចជាទេព
តា ដែលស្ថិតនៅកន្លែងព្រហ្មលោកជាន់អកនិដ្ឋ: សមដូចព្រះពុទ្ធដីកា ទ្រង់
ត្រាស់ចំពោះមាណពិកជមានចិត្តជ្រះថ្លា នៅក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា :

សុសុខំ វត ជីវាម យេសំ នោ នត្ថិ កិញ្ចនំ
បីតភក្ខា ភវិស្សាម យថា អភស្សរា ។

ប្រែថា : ការមិនមានកង្វល់ ដល់ពួកយើងឯណា ពួកយើង
នោះទើបរស់នៅជាសុខស្រួលក្រៃពេក ពួកយើងនោះ នឹងជាអ្នកមានជាតិ
ជាអាហារ ដូចជាពួកទេពតាដែលស្ថិតនៅក្នុងព្រហ្មលោកជាន់អកនិដ្ឋ: ។

សេចក្តីថា : កិលេសជាតិ ដែលដឹកនាំចិត្តគំនិតរបស់សព្វសត្វ
ឲ្យរវើរវាយ ឲ្យមានកង្វល់ ហៅថា កិញ្ចនៈមាន ៣ យ៉ាងគឺ :

១– រាគកិញ្ចនំ កង្វល់គឺរាគៈ
២– ទោសកិញ្ចនំ កង្វល់គឺទោសៈ

៣- ឱឃមាកិញ្ចនំ កង្ខល់គឺមោហៈ

ខ ១- សេចក្តីត្រេកត្រអាល រីករាយ ជាប់ចិត្ត ក្នុងវត្ថុកាម ធ្លុង ។ មានរូប សម្លេង ក្លិន រស សម្ផស្ស ដែលជាទីពេញចិត្ត គាប ជាប់ចិត្តឱ្យមនុស្សត្រេកត្រអាលក្នុងកាយ អន្ទះអន្ទែងវង្វេងក្រម នេះលោកហៅថា ឱឃកិញ្ចនៈ កង្ខល់គឺឱឃៈ ។

បុគ្គលដែលត្រូវឱឃៈធ្វើឱ្យជាប់ចិត្តហើយ ដែលត្រូវឱឃៈគ្របសង្កត់ ហើយ មានចិត្តត្រូវឱឃៈញាំញីបានហើយ តែងគិតដើម្បីបៀតបៀនខ្លួន ខ្លះ ដើម្បីបៀតបៀនអ្នកដទៃខ្លះ ដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃ ទាំងពីរខ្លះ ។ បុគ្គលដែលត្រូវឱឃៈធ្វើឱ្យជាប់ចិត្តហើយត្រូវឱឃៈ គ្របសង្កត់ហើយ មានចិត្តត្រូវឱឃៈញាំញីបានហើយយ៉ាងនេះរមែងហ៊ាន ប្រព្រឹត្តធ្វើទ្វារអំពើទុច្ចរិតដោយកាយ វាចា ចិត្ត មានសម្លាប់សត្វ លួច លាក់ឆក់ដណ្តើម ប្រពន្ធអ្នកដទៃ ហ៊ានប្រព្រឹត្តអនាចារចំពោះកូន ប្រពន្ធអ្នកដទៃ ហ៊ានទោចបញ្ឆោតប្រវ័ញ្ចយកទ្រព្យសម្បត្តិអ្នកដទៃ ។ ឱឃៈនេះមានទោសកំរើនលះបង់កំបានដោយកម្រ ដោយយឺតយូរ ទៀតផង ។

ខ ២- សេចក្តីប្រកូស្តចំពោះសត្វនិងសង្ខារ ដែលកើតអំពីបដិឃៈ ការក្រៃក្រោត ការអាក់អន់ចិត្ត ដែលដេកគ្រាំសម្ងំនៅក្នុងសន្តានចិត្តក្តី បណ្តាលចេញមកខាងក្រៅក្តី មានអាការយោរយៅ នេះលោកហៅថា

ពោសកិញ្ចនៈ កង្វល់គឺពោសៈ ។

សត្វលោក កាលបើត្រូវពោសៈប្រទូស្តហើយ រមែងហ៊ានប្រទូស្ត ចំពោះបុព្វការីបុគ្គល មានមាតាបិតាបង្កើតរបស់ខ្លួនឯងក៏មាន ចំពោះគ្រូ ចារ្យាយរបស់ខ្លួនក៏មាន ចំពោះញាតិ មិត្រ សាលោហិត មានបងប្អូន ប្រុសស្រីជាដើមក៏មាន ។ ដូចនិគន្ថកិក្ខុវេវិច្ឆត្តជែលមាននៅកន្លែតម្ពីរធម្ម បទខុទ្ទកនិកាយ ត្រង់ឃមកវគ្គ សូមសំដែងដោយសង្ខេប ដើម្បីជា ភស្តុតាងដូចតទៅនេះ :

មានសេចក្តីដំណាលថា : កិក្ខុវេវិច្ឆត្ត ត្រូវជាអនុជ ដ៏ជូនមួយ នឹងព្រះសក្យមុនីគោតមបរមសម្ពុទ្ធ មានព្រះវរមាតាព្រះអង្គ ។ កិក្ខុអង្គ នេះ កាលពីដើមឡើយ ជាអ្នកមានបសន្នចិត្តជ្រះថ្លាចំពោះលទ្ធិនៃព្រះ ពុទ្ធសាសនា បានស្តែចិត្តចូលបួសជាមួយនឹងក្សត្រ ៥ អង្គ គឺ : កិក្ខុ យសក្សត្រ ១ អនុរុទ្ធ ១ អានន្ទ ១ ភគុ ១ កិម្ពិល ១ លុះបួសហើយមិនយូរ ប៉ុន្មាន ក៏កើតពោសចិត្ត តាំងចិត្តជាបច្ចាមិត្ត ប្រតាំងចំពោះព្រះអង្គ ដែលជាសាស្ត្តាចារ្យរបស់ខ្លួន ហើយទំច្រឹងច្រែងស្វែងរកកលោ ជាយ ផ្សែង ។ ដើម្បីធ្វើតតព្រះអង្គគឺ :

លើកទី ១ – ពៅល្ងង់ល្ងួងលោម ញុះញង់ ចោកបញ្ឆោតព្រះ រាជកុមារព្រះនាម អជាតសត្តុ ត្រូវជាបុត្តព្រះបាទពិម្ពិសារ ឲ្យច្រឡំ រដឿដោយកន្តច្រឡំថា : បើរាជកុមារត្រូវការសោយរាជសម្បត្តិ ត្រូវធ្វើ

គត់ព្រះវិចិត្រាវចសំទ្រង់ចុះ មុខជានឹងបានសោយភជ្ឈជាក្រោកជ ចំណែកយើងវិញ គឺបង្គំឃាជព្រះមានព្រះភាគដែរ ដើម្បីឱ្យបានត្រាស់ជាព្រះពុទ្ធ ។

លើកទី ២- គឺបញ្ជាឱ្យពួកភ្នង់ជួ ទៅប្រហារព្រះអគ្គីទៀត

លើកទី ៣ - គឺឡើងលើកំពូលភ្នំគិជ្ឈកូដ ដោយខ្លួនឯង ហើយគ្រវែងដុំថ្ម ប្រមៀលចុះពីលើភ្នំមក បង្គឱ្យត្រូវខ្លួចខ្លីរបស់ព្រះអង្គតែម្តង តែតុំបានសំរេចដូចបំណង ។

លុះលើកទី ៤ - គឺបង្គាប់ចញ្ចាហ្មាជំរី ឱ្យលែងដំរីនាឡាគិរីដែលជាសត្វកាចសាហាវជាងគេបំផុត ឱ្យទៅព្រួចព្រះអង្គទៀត តែអំពើអកុសលបាបលាមកពាំងប៉ុន្មាននោះ តុំបានសម្រេចដូចបំណងឡើយ ។ ទើបគ្នានោះ ខាងក្រោយមក គឺក្លាយខ្លួនជាអនាថបុគ្គល សាបសូន្យអស់ទ្រព្យ អំណាច លុះដល់ទីបំផុត ក៏ត្រូវព្រះធរណីស្រូបខ្លួនយកបាត់ទៅ ។

រឿងនេះបានសេចក្តីថា: ទោសៈ តែងញាំងសេចក្តីវិនាសឱ្យកើតឡើងដល់ខ្លួនឯង ញាំងអ្នកដទៃដែលស្និទ្ធស្នាលមជាមួយឱ្យខូចខួលខុសព្រួយឱ្យវិនាសហិនហោច ដូចខ្លួនឯងដែរ ។ ទោសៈ រមែងបំផ្លាញ ចិត្ត គំនិត រាងកាយ របស់ជនណាល ៗ មិនឱ្យស្គាល់នូវគុណប្រយោជន៍ដែលកើតឡើងក្នុងសន្តានរបស់ខ្លួនឯងបំរុងកើតឡើងចំពោះខ្លួន ។ បុគ្គលដែលត្រូវទោសៈប្រកួសស្គរហើយ រមែងឃ្លាតចាកសុចរិតធម៌ រឹតវាតែកន្ធរអសប្បុរសធម៌ ទីបំផុត

អ្នកបង្កើតហេតុនៃកុប្បកម្ម ឲ្យកើតមានឡើងជានិច្ចនិរន្តរ៍ ដែលមិនស្គាល់នូវប្រយោជន៍របស់ខ្លួនជាដើម បុគ្គលដែលត្រូវទោសៈត្រូវសង្កត់ហើយ រមែងមិនយល់នូវធម៌ សូម្បីត្រឹមតែកម្មបថ ១០ បុគ្គល កាលបើត្រូវទោសៈគ្របសង្កត់ហើយ ការងឹតងឹងល់ជ្រុលជ្រប់ នឹងកើតមានឡើងដោយក្រៃលែង រមែងឲ្យទោសៈទៅជាខ្វល់វល់រវាម ឥតអៀនខ្មាស់អ្នកដទៃ អាចបង្ហាញអាកប្បកិរិយាដោយឥតលាក់លៀម ។ ទោសកិញ្ចនៈនេះ មានទោសច្រើន យើញយ៉ាងប្រត្យក្សក្នុងបច្ចុប្បន្ន ប៉ុន្តែជាកិលេសជាតដែលបុគ្គលងាយនឹងលះបង់ចាន់ជាដោយងាប់រហ័សដែរទេ ។

៣- ការវង្វេងក័ន្តប្រឡំ ការងឹតងឹងល់មិនយល់សេចក្តីពិត គឺមិនស្គាល់អរិយសច្ចទាំង ៤ មានទុក្ខសច្ចជាដើម ឬវង្វេងទៅក្នុងហេតុការណ៍ណាមួយ ដែលមិនស្មានថាខ្លួនជាអ្នកវង្វេង នេះលោកហៅថា មោហកិញ្ចនៈ កង្វល់គឺមោហៈ ។

មោហកិញ្ចនៈនេះ ជាកិលេសជាត សម្រាប់ដឹកនាំសត្វឲ្យលិចលង់នៅក្នុងវដ្តសង្សារដែរ ឲ្យខ្ជួលរងទុក្ខទោស ពៀរ វេរ ឋណ្ហាលឲ្យតានតឹងខន្ធិះខ្វិកខ្វួល អណ្តឹតអណ្តក់នៅក្នុងលោកពុំបានឲ្យសត្វលោកធ្វើនូវទីបំផុតនៃសេចក្តីទុក្ខបានដោយងាយឡើយ ។ បុគ្គលដែលត្រូវមោហៈជះជាន់ញាំញីបានហើយ ហ៊ានប្រទូស្តចំពោះមាតាបិតាក៏មាន ចំពោះព្រះបិតយ៍ឬព្រះពោធិព្រឹក្សដ៏ក៏មាន ចំពោះបព្វជិតក៏មាន ហើយ

តែងបានខ្លួនតាក្យនិន្នាក្នុងទីផ្សេង ។ ដែលខ្លួនទៅហើយ ។ មោហៈ កិញ្ចនៈនេះ មានទោសកំច្រើន ថែមទាំងលះបង់ក៏បានដោយកម្រខ្លាតផង ។

ទុបក្លិសសងដៃខ្លាត ដែលជាមេពេត ច្រើនដេកគ្រាំទៅក្នុងសន្ដានចិត្ត តែងធ្វើចិត្តសត្វលោកឲ្យសៅហ្មង មិនឲ្យមានពន្លឺរស្មី ភ្លឺស្វាងរុងរឿងទៅបានឡើយ ។ ទុបក្លិសនោះមាន ១០ យ៉ាងគឺ :

១- អកិដ្ឋាវិសមលោកៈ សេចក្ដីលោភមិនស្មើ គឺអកិដ្ឋា

២- ព្យាបាទៈ ចង់តំទុំតុំគួន បំរុងនឹងធ្វើគេឲ្យវិនាស

៣- កោធៈ ក្រោធ ខឹងហើយបញ្ចេញកាយ វាចា ដៃវាយជាដើម

៤- ឧបនាហៈ ខ្ជប់កំហឹងទុក

៥- មក្ខៈ លុបគុណ គឺបំភ្លេចគុណគេ

៦- បធ្បាសៈ ការពាយប្ដូរស្មើ ឬប្រណាំងប្រជែងវាសនា

៧- ឥស្សាៈ សេចក្ដីឫស្សា ច្រណែនឈ្នានិស

៨- មច្ឆរិយ សេចក្ដីកំណាញ់ស្ងួតស្ងាញ

៩- មាយា ការប្រព្រឹត្តិ លាក់លៀមពុតត្បុត

១០- សាឋេយ្យៈ អំនួត ឬការពាយមែម

១១- ឋម្ភៈ ការចចេសរឹងត្អឹង

១២- សារម្ភៈ ការប្រណាំងប្រជែង

១៣- មានៈ ការប្រកាន់ខ្លួន

១៤= អតិមានៈ ការប្រកាន់ខ្លួនហួសប្រមាណ គឺមើលងាយគេ

១៥= មទៈ ការស្រវឹង

១៦= បមាទៈ ការធ្វេសប្រហែស

ឧបក្កិលេសចាំង ១៦ ខេះ សុទ្ធតែជាឫសគល់នៃអកុសលធម៌ចាំងអស់ សម្រាប់ធ្វើសន្តានចិត្តរបស់សត្តនិករ ដែលកើតមកក្នុងពិភពលោកចាំងមូល ឲ្យគេរល្អក់ ឲ្យសៅហ្មង ឲ្យមានមុខឈមទៅរកផ្លូវអកុសល ហើយដឹកនាំសត្វចាំងឡាយ ឲ្យគប់ប្រសប់ជួបប្រទះតែនឹងរសេចក្តីទុក្ខគ្រប់យ៉ាង ចាំងក្នុងបច្ចុប្បន្ន ចាំងក្នុងបរលោក ។

ដូច្នេះ អស់លោក អ្នកសប្បុរសជាពុទ្ធបរិស័ទចាំងឡាយដែលប្រាថ្នាចង់បានសុខ និងវឌ្ឍនធម៌ គប្បីពិនិត្យពិចារណាកន្លងចិត្តរបស់ខ្លួន ហើយឃើញឧបក្កិលេសណាមួយ ជាប់ជិតជាមួយនៅក្នុងខ្លួនសន្តានរបស់ខ្លួនហើយ គួរខំប្រឹងប្រែងកំចាត់ចោលចេញ ដើម្បីនឹងធ្វើចិត្តឲ្យបានបរិសុទ្ធស្អាត ឬមួយសេចក្តីរាប់រកពួកជនជាបណ្ឌិតអត្តកោវិទ ដែលលោកមានគំនិតដ៏ប្រសើរ មានអធ្យាស្រ័យដ៏បរិសុទ្ធ ព្រមទាំងមានសន្តានចិត្តចេះសន្តោស មិនស្វែងរកភោគសម្បត្តិខាងមិត្រភ័ក្តិ ចេះបីបាច់ថែរក្សា

សេចក្តីសុខទុក្ខរវាងញាតិមិត្រ មិនឲ្យបែកចាក់សាមគ្គី ព្រោះពួកជនជាបណ្ឌិតនោះ អាចដឹកនាំបង្ហាញផ្លូវ អាក្រក់ ល្អ បុណ្យបាប គុណទោស ចំរើន វិនាស ដល់ពួកជនរួបរួមជាមួយ ឲ្យទទួលការបង់វត្តន៍តឹង្ហាស់ហាន:តាមមួយៗភាព ទៅជាបណ្ឌិតភាព តាំងពីអនាគតទៅជាទុគ្គមភាព តាំងពីទុក្ខភាព ទៅជាសុខភាព តាំងក្នុងលោកនេះ ឧត្តមលោកខាងមុខ ជាកិយ្យាភាពតទៅ ។

ការសំដែង «ជយបាជយកថា» រៀបចប់អំពីការឈ្នះនិងការចាញ់របស់មនុស្សលោក ចប់ដោយសង្ខេបប៉ុណ្ណោះ ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាយដ្ឋាន)

លោក ប៊ូ - ប៉ុំ រៀបរៀង

គមក

ឯបុគ្គលដែលមិនបានធ្វើកុសលការកុសល ប្រៀបដូចបុគ្គលដើរផ្លូវឆ្ងាយ គ្មានស្បៀង អង្គាសមក្តបដិបន្ទោសាម ឈ្មោះថាបុគ្គលធ្វើដំណើរដើរផ្លូវឆ្ងាយ ហើយគ្មានស្បៀងនោះ តែងមិនបានទៅដល់ទីកន្លែងដែលខ្លួនប្រាថ្នាទីនោះ យ៉ាងណាមិញ សេចក្តីនេះមានឧបមាដូចម្តេច ។ បុគ្គលទីនឹងធ្វើឲ្យផុតចាកសង្សារវដ្តបាន បើគ្មានស្បៀងគឺកុសលទេ ក៏មិនអាចនឹងធ្វើឲ្យផុតពីសង្សារវដ្តបានឡើយ មានឧបមេយ្យដូច្នោះ ។

ហេតុនោះឯង សាធុជនប្រាថ្នាទីនយោនខ្លួនឲ្យផុតពីសង្សារវដ្ត គប្បីរកស្បៀងគឺទានទុកសម្រាប់បរិភោគទៅក្នុងផ្លូវឆ្ងាយ ទីនឹងធ្វើឲ្យផុតពីសេចក្តីតាល់ក្រ ទីនឹងធ្វើបានវត្ថុអ្វី កំបានវត្ថុនោះដូចបំណង ។ បើរកស្បៀងគឺសីល ដើម្បីទីនដើរផ្លូវទៅបានចៀសផុតពីចម្រូងពីបន្ទា គឺដើរទៅបានសុខស្រួល ។ បើរកស្បៀងគឺព្រះធម្មទេសនា កាលដើរទៅតាមផ្លូវមិនខាន់ដល់ទីឆ្ងាន់ទេ ទីនឹងមិនទៅកាន់អបាយភូមិ ។ បើរកស្បៀងគឺបុណ្យ ទីនឹងបាបប្រាសចាកបបស់លាមកតាំងឡាយ ទីនដើរទៅបានសុខសប្បាយដរាបដល់ទីឆ្ងាន ។ បើរកស្បៀងគឺសទ្ធាការជឿក្នុងព្រះពុទ្ធ

គុណព្រះធម្មគុណនឹងព្រះសង្ឃគុណ ដឿមាំរហូតដល់ផលសីលទានការកុសលមិនតិតត្រឡប់ថយក្រោយ កាលមិនថយក្រោយហើយ ក៏ដល់ត្រើយគឺព្រះនិព្វានបាន ។ ឯផ្លូវព្រះនិព្វាននោះឆ្ងាយក្រៃលែង ឆ្ងាយជាងផ្លូវកន្លាះពាន់ពួន កម្រនឹងធ្វើរំលងឲ្យផុតទៅបាន ពាល់តែមានស្បៀងគឺកុសល ទើបនឹងធ្វើទៅបាន ។

បុគ្គលខ្លះមានកុសលច្រើនក៏ពិតមែនហើយ ប៉ុន្តែមិនបានជ្រាប្ញាដូព្រះនិព្វាន ក៏មិនបានសម្រេចព្រះនិព្វានដែរ ព្រោះខ្លួនមានតំនិតយល់ឃើញខុស គឺគិតឃើញថាព្រះនិព្វាននោះរលត់សូន្យទៅហើយ ពុំមានអ្នកណាម្នាក់ដឹងឃើញផងទេ គ្រាន់តែបានឮថាជាបរមសុខប៉ុណ្ណោះ លុះគិតឃើញដូច្នោះហើយ ក៏មិនចង់ទៅព្រះនិព្វាន កាលបើមិនចង់ទៅព្រះនិព្វានហើយ ក៏មិនបានដល់ទៅព្រះនិព្វានដែរ ប្រៀបដូចអ្នកមានទ្រព្យសម្បត្តិច្រើនក៏មែនហើយ ប៉ុន្តែមិនចង់បរិភោគរបស់អ្វីៗសោះ ក៏មិនបានសម្រេចដូចសេចក្តីប្រាថ្នាដែរ ។ ឯបុគ្គលធ្វើការកុសលហើយមិនប្រាថ្នាទូន្មិព្វានសម្បត្តិទេ ប្រាថ្នាតែសុខក្នុងមនុស្សនឹងសួគ៌ប៉ុណ្ណោះបុគ្គលនោះឈ្មោះថាប្រាថ្នាខុស ។ អ្នកធ្វើកុសលហើយ បើគាំងចិត្តប្រាថ្នារបស់អ្វីៗ ក៏គង់តែបានសម្រេចរបស់នោះៗដូចប្រាថ្នា ប៉ុន្តែបុគ្គលដែលប្រាថ្នាតែមនុស្សសម្បត្តិនឹងសួគ៌សម្បត្តិ មិនប្រាថ្នាព្រះនិព្វានទេនោះសេចក្តីសុខក្នុងមនុស្សក៏នឹងបាន សេចក្តីសុខក្នុងឋានសួគ៌ក៏នឹងបាន លុះអស់

ផលបុណ្យហើយជាបច្ច័យនឹងឲ្យកើតកុងត្រកូលមិច្ចាទិដ្ឋ ព្រោះខ្លួនយល់
ឃើញថាព្រះនិព្វានគ្មានសេចក្តីសុខដូចមនុស្សនឹងសួគ៌ ។ ហេតុនោះ
អ្នកណាធ្វើកុសលហើយមិនប្រាថ្នាព្រះនិព្វាន អ្នកនោះឈ្មោះថាមានចិត្ត
ប្រាថ្នាខ្ពស់ ។ អ្នកណាធ្វើកុសលហើយប្រាថ្នាព្រះនិព្វាន អ្នកនោះឈ្មោះ
ថាប្រាថ្នាត្រូវ ព្រោះធ្វើខ្លួនឲ្យផុតចាកកងវដ្តសង្សារ តាលបើមិនពាន់
ដល់ព្រះនិព្វានទេ ក៏នឹងបានទៅចួលសម្បត្តិមនុស្សនឹងសួគ៌ ។ អ្នកធ្វើ
កុសលហើយ ប្រាថ្នាតែព្រះនិព្វានមួយមុខប៉ុណ្ណោះ មិនប្រាថ្នាសម្បត្តិ
មនុស្សនឹងសួគ៌ផងទេ ក៏តែងតែបានសម្បត្តិមនុស្សនឹងសួគ៌ជាំងពីរនោះពុំ
ខានដែរ ត្រង់ថាសម្បត្តិមនុស្សនឹងសួគ៌ជាំងពីរប្រការនេះ នៅទាងដើមឡើយ
ផ្តែលនឹងទៅកាន់ព្រះនិព្វាន ។ អ្នកប្រាជ្ញមិនគួរប្រមាទថាកុសលតែបច្ចុប្ប
បន្នចស្ទុះស្តើងនេះ មិនដឹងជាកាលណានឹងបានទៅដល់ព្រះនិព្វានទេ
សូម្បីបដូចព្រះនិព្វាននោះនៅឆ្ងាយក្រៃលែង មិនដាយនឹងបានសម្រេច
ដូចប្រាថ្នាទេ ។ អ្នកខ្លះគិតាឃើញថា បើពុកជាបានដល់ព្រះនិព្វានក៏ឃ្លាតឆ្ងាយ
ណាស់ បើយ៉ាងគិតចុះផុតគឹកថ្ងៃនេកល្បជែរ ឃល់ឃើញយ៉ាងនេះ
ហើយក៏មិនប្រាថ្នាព្រះនិព្វាន ។ អ្នកធ្វើកុសលហើយមិនប្រាថ្នាព្រះនិព្វាន
ប្រាថ្នាតែសម្បត្តិមនុស្ស នឹងសួគ៌ប៉ុណ្ណោះ ឈ្មោះថាអ្នកប្រាថ្នាខ្ពស់ ។
អ្នកធ្វើកុសលហើយ តាំងចិត្តប្រាថ្នាព្រះនិព្វាន បើពុកជាមិនទាន់
ដល់ព្រះនិព្វានក្តាម ក៏តែងតែបានទៅជិតព្រះនិព្វានកាល់ជាតិជែរ មាន

ព្រះបាលីក្នុងសង្គាយបែបត្តិសូត្រថា បុគ្គលធ្វើកុសលតែបន្តិចបន្តួច តឹបបរ
មួយចោយ ចាយមួយកែប៉ុណ្ណោះ ប៉ុន្តែតាំងចិត្តថ្វាយថា ទានរបស់ខ្ញុំនេះ
ចូរជាបច្ច័យនាំមកខ្ញុំអាសវក្ខ័យ តឹព្រះនិព្វាន ជាទីអស់នៃអាសវៈមក
ឲ្យដល់ខ្ញុំ តឹថាខ្ញុំសូមឲ្យបានដល់ព្រះនិព្វានជាទីអស់អាសវៈ បើថ្វាយ
ដូច្នេះហើយ ក៏អាចឲ្យសម្រេចសេចក្តីថ្វាយបាន ឈ្មោះថាជាអ្នកថ្វាយ
ត្រូវ ព្រោះយោនិខ្លួនឲ្យផុតចាកសង្សារវដ្ត ប្រៀបដូចអ្នកមានទ្រព្យតិច
តួចប្រមាណមួយកាកណិក បើទុស្សាហ៍សន្សំខុក ក៏បានមានច្រើនស្តុក
ស្តម្ភ ទៅជាសេដ្ឋី ដូចមាណពម្នាក់ជាអន្តេវាសិកនៃពុល្លកសេដ្ឋី មុនដំបូង
មានតែសត្វកណ្តុរមួយ ថ្លៃមួយកាកណិកប៉ុណ្ណោះ ប៉ុន្តែចិត្តមិនប្រមាទ ចេះ
តែរំសន្សំប្រមូលទ្រព្យបានច្រើនឡើង ។ រហូតដល់បានធំជាសេដ្ឋី ។

ឯអ្នកដែលធ្វើតិចតួចការកុសលកសិ ហើយតាំងសេចក្តីថ្វាយកំដូចគ្នា
ដែរ ដើមដំបូងធ្វើតែបន្តិចបន្តួច លុះសន្សំញឹយ ។ ទៅ កំផុំគ្នាទៅជា
ច្រើន តាលត្រប់ចំនួនតាមអរិយប្រពៃណីមួលបណិធិ របស់ព្រះអរិយៈ
ហើយ ក៏ឆ្ងាយបានសម្រេចដូចចិត្តថ្វាយ ។ ហេតុនោះ បានជាលោកសំដែង
ថា បុគ្គលអ្នកមានបញ្ញាកុំគប្បីប្រមាទនូវការកុសលឡើយ ។ អង្គសម្តេច
ព្រះបរមេសពលប្រទានព្រះសទ្ធម្មទេសនាទុកថា ៖

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ ប៉ុណ្ណោះ
ជាដើម សេចក្តីថា បុគ្គលធ្វើការកុសលហើយ កុំគប្បីប្រមាទនូវការ

កុសលដែលបានធ្វើរួចហើយនោះថា កុសលមានប្រមាណប៉ុណ្ណេះ កាលណានឹងបានផល កាលណានឹងបានសោយនូវផលនៃកុសលមានប្រមាណប៉ុណ្ណេះ កុំគប្បីប្រមាទដូច្នេះឡើយ គប្បីតែញុំាងចិត្តឲ្យត្រេកអរថា ការកុសលដែលតញ្ជាបានធ្វើរួចហើយនេះ កម្របុគ្គលនឹងធ្វើបាន អ្នកខ្លះបើខុកជាមានទ្រព្យសម្បត្តិច្រើនដល់ប៉ុន្មាន ។ ក៏មិនអាចនឹងធ្វើកើតដែរ ថោកគាំ ថោកគាំបំ អាចិណ្ណំ លុះតែតាឃើញដូច្នោះហើយក៏ចេះតែទំាសន្សំរឿយ ។ ៧ តំាង ។ ផ្សំគ្នាថៅជាច្រើន ក៏នឹងពេញថៅដោយកុសលភស្ដ ដូចក្អមទឹកដែលបុគ្គលចើកមាត់ចំហ ហើយដំកល់ទុកត្រង់កន្លែងទឹកភ្លៀងធ្លាក់ ទឹកភ្លៀងធ្លាក់ចុះក្នុងក្អមម្ដងមួយដំណក់ ញាយ ។ ថៅ ក្អមក៏នឹងពេញពោរពោយទឹកភ្លៀង ។ សេចក្ដីនេះមានឧបមាដូចម្ដេច បុគ្គលមិនប្រមាទក្នុងការកុសល ធ្វើកុសលរឿយ ។ ក៏នឹងបានពេញពោរថៅដោយកងការកុសលផលបុណ្យ កុសលនោះក៏នឹងតំាងខ្ទុកបម្រុងឲ្យបានថៅជិតព្រះនិព្វានរាល់គ្រា ។

ប្រការមួយទៀត បណ្ឌិតជាតិអ្នកមានប្រាជ្ញាដ៏ល្អ ខាងអកុសលសោត ក៏កុំប្រមាទដូចគ្នា ។ ឯអកុសលជាអំពើថោចអាក្រក់លាមកនោះ បើបុគ្គលណាធ្វើ ក៏អាចដឹកនាំបុគ្គលនោះថៅកាន់ចតុរបាយ ។ កុសលអំពើល្អប្រៃ បើបុគ្គលណាធ្វើ ក៏នឹងដឹកនាំបុគ្គលនោះថៅកាន់សុគតិ-ភពជាប្រាកដ ដែលជាឥតផលនោះពុំមែនទេ ។ ខាងកុសលនេះមាន

ផលនាំឲ្យបានសុខ ។ ឯអកុសល មានផលនាំឲ្យបានទុក្ខ គ្រាន់តែ
ថ្លែកគ្នាយ៉ាងនេះ ។ ហេតុនោះ បុគ្គលអ្នកមានបញ្ញាដ៏ល្អ ចូរចៀសវាង
ឲ្យឆ្ងាយចាកអកុសល ស្វែងរកតែកុសលចុះ ប្រៀបដូចបុគ្គលដើរជាន់
អក់ហើយ ទំជុសលាងអក់នោះ ក៏គង់តែអស់អក់ពីជើងមិនខាន ។ បើ
បុគ្គលធ្វើកុសលអ្វី ។ ត្រូវតែច្រើនឡើងដូរព្រះនិព្វាន ។

ម្យ៉ាងទៀត បុគ្គលត្រូវធ្វើព្រះពុទ្ធគុណជាអារម្មណ៍ ព្រោះសម្តេច
ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរថា មានផលនឹងកប់មិនអស់ឡើយ ។
អច្ឆរិយសោ ឧម្មារបុប្ផមិវ ដោយហេតុនៅ បុគ្គលគ្រាន់តែបូជា
ព្រះពុទ្ធដោយផ្កាខនោងឬផ្កាត្រកៀតមួយប៉ុណ្ណោះ កុសលកាលីនឹងកប់មិន
អស់ ។ បើបុគ្គលឃើញអ្នកដទៃធ្វើកុសលអ្វី ។ ត្រូវជួយរីករាយអនុមោទ-
នា ។ បើបុគ្គលធ្វើកុសលអ្វី ។ ត្រូវផ្សាយផលបុណ្យឲ្យអ្នកដទៃផង ត្បិត
ការផ្សាយផលបុណ្យឲ្យអ្នកដទៃនោះ កប់ចូលកន្លងចិត្តមេត្តា ។ បើបុគ្គល
ឃើញអ្នកដទៃធ្វើកុសលហើយមានចិត្តរីករាយផង ជាហេតុនឹងញ៉ាំងខ្លួន
ឲ្យបានទៅកើតទៅឋានសួគ៌ ដូចជាដុល្លៈអាមាត្យដែលមានចិត្តជ្រះថ្លា
ក្នុងអសទិសទាន នៃព្រះបាទបសេនទិកោសល ។ ចំណែកបុគ្គលកំ-
ណាញ់កន្លងទានបើស់អ្នកដទៃវិញ បើឃើញគេធ្វើទានក៏មានចិត្តឫស្សាច្រ-
ណែន ជាហេតុនឹងឲ្យទៅកើតកន្លងគេដូចជាកាឡៈអាមាត្យដែលកំណាញ់
កន្លងអសទិសទានមានចិត្តឫស្សា ។ តម្លៃកុសលនឹងអកុសលនេះ ជា

ហេតុជាបច្ច័យនឹងឲ្យសត្វអ្នកធ្វើបានសោយសុខនឹងខុសគ្នាពីរប្រការ ។

ហេតុនោះ សម្តេចព្រះបរមសាស្តាចារ្យទើបទ្រង់ត្រាស់ប្រទានព្រះសទ្ធម្មទេសនាថា កម្មនេះជាបច្ច័យតាប់ចូលក្នុងបច្ច័យ ២៤ ប្រការដូច្នេះ ។

កម្មបច្ច័យ ចប់តែប៉ុណ្ណោះ ។

(នៅមានត)

ឆាកកំផ្លែង (ពេលរៀនវេយ្យាករណ៍)

អ្នកគ្រូសួរសិស្សថា : ស្រៈនិស្ស័យមានប៉ុន្មានយ៉ាង ? ពួកសិស្សភាគច្រើនលើកដៃហើយថា : អ្នកគ្រូ ខ្ញុំ ! អ្នកគ្រូ ខ្ញុំ ! អ្នកគ្រូ ខ្ញុំ ! រញ៉ . . . . ។

អ្នកគ្រូញញឹម ។ ដោយគំនិតថាពួកសិស្សអញភាគច្រើនចេះមេរៀនច្រាន់បើ ។ ទើបឆាត់ចង្អុលទៅអាមួយអង្គុយចុងគេ ក្បែរដំញ៉ាំង ។ សិស្សនោះក្រោកឈរហើយឆ្លើយថា : ស្រៈនិស្ស័យមានពីរយ៉ាង គឺស្រៈពេញតួ នឹងស្រៈក្បាលខ្នះ ។ សិស្សឯទៀតសំឡឹងមុខអ្នកឆ្លើយ អ្នកគ្រូយើងឡើងមុខក្រហម ហើយគំហកឲ្យថា : អាចោលម្សៀត អង្គុយចុះ !

មានសិស្សម្នាក់ក្លាហានអង្គុយតុកណ្តាល ក្រោកឈរឡើង ហើយឆ្លើយថា : ស្រៈនិស្ស័យមានពីរយ៉ាង គឺស្រៈឃោស នឹងស្រៈអឃោសៈ ។

អ្នកគ្រូប្រែទឹកមុខឡើងស្រស់វិញ ព្រោះគ្រូវិត្រង់ចំណុចខ្លួន ហើយពោលថា : អើគ្រូវិហើយ ទំណេះទំណោះ ស្រាប់តែមានសិស្សម្នាក់អង្គុយពីក្រោយបង្អែបំប្រកាសឡើងលួចបិទៈ អ្នកគ្រូ ! អ្នកគ្រូ ! អក្សរ «គ» ដែលប្រើស្ទឹងនឹងស្រៈនិស្ស័យ «ឃោសៈ» គឺត្រីសព្ទ «-» នៅពីលើស្រៈ «ុ» រត់ទៅណាបាត់មិនឃើញទាន !

អ្នកគ្រូឆ្លើយថា : អាចំកួត ! «-» នៅលើអក្សរ «គ» ហ្នឹងហើយ ម្តេចអាឯងថាទៅណាបាត់ !

ពួកសិស្សតបថា : ទាន ! ត្រីសព្ទ «-» ហ្នឹងដាវបស់អក្សរ (គ) ពីកំណើតទេតើទាន ! ឯត្រីសព្ទ (-) ទៀតបេស់ស្រៈ (ុ) មិនឃើញផង !

អ្នកគ្រូយើងធ្វើមុខថ្ងូរ . . . ហើយឆ្លើយប្រាប់ថា : ល្អើយរឿងនេះ កុំនិយាយធ្វើអី អញមិនដឹងទេ ៖ ងាប់ឆ្កាំតសភាខាងអក្សរសាស្ត្រកើត សឹមនិយាយ ។ ផេង.ទ្រីវ

អ្នកមានគុណ

បទភាគ្យ ៧

រៀបរៀងដោយលោក ហោង-សមអាង នៅសេនាធិការយោធភូមិភាគទី ១ ខេត្តកំពង់ចាម អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្សាថ្មីរដ្ឋ ខេត្តពោធិសាត់ ៖

(ក)

ខ្ញុំសូមប់ម្ចាស់ម្ចាយនុពុត　　មានរឿងតាំងពីពុកត្រីខ្ទប្រាជ្ញប្រាយ
លោកបានរៀបរៀងស្តីបរិយាយ　　រៀងធ្លាយតមកជាសេចក្តី ៖
កន្លងមកខ្ញុំយ៉ាងពិស្តារ　　ស្រងយកខ្ញុំមសារបំព្រួញខ្លី
បទភាគ្យប្រាំពីរវេរសេចក្តី　　សំដីចាប់ចួនផ្ងួនគ្រប់ហ្មា ។
កន្លងកាលកន្លងយូរយារណាស់　　មានរឿងវ៉ាច្បាស់ចែងពណិនា
មានបុរសម្នាក់ស្ថិតនៅនា　　កន្លងជនភាពណាស៊ី ។
តភតញ្ញូសុំខ្ញុំម្ចន់　　ដើម្បីឲ្យស្គប់នុពុត-ម្ចាយ ។
ញុះញ៉ង់អុជគាលកល់ក្រី　　ដោយតាមប្រពន្ធមិនគិតឡាយ
បុរសកំសាកស្មារតីខ្លាន់　　កំចាត់កំចាយម្ចាយ-នុពុត ។
គិតតែត្រឹមរំរេកចាយ　　ប្រាប់ថាញាតិមិត្រនៅឯស្រុក
ថ្ងៃមួយដើរទៅអង្គុយផឹក　　កើតទុក្ខតែតែកេតកុំភ្លៃ ។
ឯណោះត្បូកផឹកមែ-ពុក

ផ្តាំមកឲ្យខ្ញុំនាំពុកម៉ែ ទៅលេងលំហែបាន ៣ ថ្ងៃ
កូនក៏រឭកនឹកអាល័យ ភល់ ។ តែថ្ងៃមិនដែលភាន ។
យាយ-តាក៏ឧកយសប្បាយចិត្ត នឹកឆ័អតីតញាតិសន្តាន
មិត្តភ័ក្តិម្រាត់ក្តីចាំឆ័ប៉ុន្មាន ដែលធ្លាប់រួបរួមសង្ឃឹមស្នេហា ។
ក៏សួរទៅកូនប្រុសសម្លាញ់ តើកូននាំអញទៅថ្ងៃណា
ម៉ែ-ឪអារណាស់ប្រុសស្នេហា រឭកមើ-ងាបាលថ្ងៃ ។
កូនប្រុសតំរេកអន្សត់ឆ្ងៃ លុងដោយសំដីស្រីចម្រៃ
ច្រើបថ្លា ‹‹ ម៉ែ-ពុកកុំសង្ស័យ ខ្ញុំនាំទៅថ្ងៃនេះឯណា ›› ។
ហើយរៀបរាប់ទំនៀមក្រមី តាន់មោងខ្មែរតែជាប់ជាតិ
បាននាំមាតាឪចិតា ចូលព្រៃព្រឹក្សាមហាសែនឆ្ងាយ ។
លុះដល់ព្រៃស្ងាត់ជ្រាត់សូរសព្ទ ក៏និយាយច្រើបឪពុក-ម្តាយ
‹‹ ម៉ែ-ឪ ! ព្រៃនេះមានអន្តរាយ ពួកចោរទាំងឡាយតែងភាន ។
ឪតាន់ខ្មែរបរកុំតិតភ័យ កូនដើរកន្ទឹព្រៃចាំមើលវាំ
បើចោរព្រៃឃើញឪជីវ ខ្លួនឯងត្រាមត្រាំគ្រាន់អាណិត ›› ។
ថាហើយហុចខ្សែទៅឲ្យឪ ចុះដើរតាមផ្លូវទៅប្រកិត
តាំងស្រែកសំឡតតាមតែចិត្ត គ្មានតិតអាណិតឪពុក-ម្តាយ ។
ហើយស្ទុះចូលវាយដំជ្រាំធាក់ បែកឈាមសស្រាក់ធ្លាក់ហូរខ្លាយ
គ្មានចិត្តអាណិតឪពុក-ម្តាយ បែកឈាមហូរខ្លាយសព្វកាយា ។
កំពុងតែវាយយាយ-តាស្រែក សូរស័ព្ទសម្រែកស្រែកប្លាស់ថា

កូនអើយ ! ចូរតេ់កៀសអាត្មា　　កុំនៅនេះណាប្រុសសម្លាញ់ ។

ចោរវាយប្រហារនុពុក-ម្តាយ　　កូនៈចៀសឲ្យឆ្ងាយកុំតិតអញ

ម៉ែ.នុស្លាប់ចុះប្រុសសម្លាញ់　　ត្រោះអញចាស់ហើយប្រុសស្នេហា ។

ម៉ែ-នុស្រែកហើយស្រែកប្រាប់ខ្លៀត　　កូនភាលចោលមេ្លៀតវាយខ្លៀតណា

ភាលតែមាតានឹងបិតា　　ដល់ខ្លួមែរណាតាំងពីនាក់ (១) ។

ឃល់ថាស្លាប់ចាត់សូន្យសញ្ញី　　កូនភាលតិ្តយេតាញកន្ទ្រាក់

មាតាបិតាតាំងពីរនាក់　　ទម្លាក់មកដីដូចឆ្កែឆ្កា ។

ហើយវិលត្រឡប់ទៅត្រែះស្ថាន　　ប៊ីបមថ្មមប្រាណស្ងំខ្លួនស្នេហា

រួមក្បែរស្មោះស្ម័ត្រស្មើដីវ　　ខឹងស្រីឫសាកាឡកណ្តៀ ។

លុះស្លាប់ចាត់បងឯស្លាត់ចាត់ទៅ　　ចាប់តំណើតទៅឋានអវិចី

យមបាលតាប់តាត់ផ្តាច់សិរសៃ　　ចោះកន្ទឹអវិចីឆេះតាយា ។

ឆេះកន្ទឹនរកអស់១កប្ប　　ទើបចាប់តំណើតជាមនុស្សា

ត្រូវចោរអោសាច់ផ្តាច់ដីវ　　តាប់តាត់សិរសោ ៥០០ ជាតិ ។

បឋព្រហ្មកិតិ

ខោសាយនុពុក.ម្តាយ　　ខ្ញុំដោះស្រាយមិនឲ្យហ្មាត

តីព្រះពុទ្ធោភាខ　　ដែលមានទៅកន្ទឹ ម.អ (២) ។

១- ក្នុងគម្ពីរមង្គលត្ថទីបនីថា ត្រាន់តែវាយបន្តិចបន្តួច កំពើតចិត្តអាណិតនឹពុកម្តាយ នាំយកទៅផ្ទះ ហើយទំថែរក្សាមិនឲ្យហ្មង ។

២- មង្គលសត្ថទីបនី អដ្ឋកថា ។

ចង់ជាបទព្រហ្មគីតិ រឿងអតីតពិតជាល្អ
ចាប់ប្លួនផ្លួនបន្ត បណ្តាក់ល្អត្រង់ត្រគ្នាឃ្លា ។
កង់កាលពីអតីត មានរឿងពិតចែងតណ៌ខា
ពីដនទ្រុស្តមាតា ស្ថិតនៅក្រុងពារាណសី ។
ឈ្មោះមិត្តវិន្ទុកៈ ទៀអប្បលក្ខណ៍អន្សត្តីយ
ជាកូនមហាសេដ្ឋី ខ្ញុំប្រុសស្រីគាល់និត្យនៅ ។
សេដ្ឋីជាបិតា ធ្វើកិរិយាចែកស្ថានទៅ
មិត្តវិន្ទុកៈនៅ តែពីរនាក់និងមាតា ។
ថ្ងៃ១ ដេកព្រួយចិត្ត សញ្ជឹងគិតកង់ចិន្តា
ចង់ចេញជួញប្រែ-ផ្តា តាមកេត្រាទៅទីឆ្ងាយ ។
គិតហើយដើរចូលទៅ កាន់លំនៅរបស់ម្តាយ
ក្រាបថ្វាយ « ខ្ញុំទៅឆ្ងាយ ធ្វើដំនួញតាមសំទៅ » ។
មាតាសែនស្រណោះ កូនតម្មោះចាកចេញទៅ
តាមផ្លូវសមុទ្រជ្រៅ ខ្លាចក្រែងមានកងន្តកាយ ។
កំសត់លោមបុត្រា អង្វរថា កូនមាសម្តាយ
ប្អូរកូនកុំទៅឆ្ងាយ អាណិតម្តាយណាប្រុសណា ! ។
ខ្លុកម្តាយនៅម្នាក់ឯង វែងចំចែងកង់ទុក
កុំទៅណាប្រុសណា អាណិតម្តាយកាន់តែចាស់ ។

សម្បុរគួរឲ្យខ្ពាប មានសត្វតាចច្រើនដេរដាស
ក្រពើធ្វាមច្រើនណាស់ ក្នុងសមុទ្រណាប្រុសម្ខាយ ។
ចូរកូនប្រុសកុំទៅ តាមសំពៅខ្ញុំចអន្តរាយ
មាសប្រាក់តេជ្រាំងឡាយ ក្នុងផ្ទះយើងមានច្រើនក្រៃ » ។
លួងលោមអង្វរហើយ មិនតន្ត្រើយចូលចាប់ដៃ
ឆុបរឹតស្មិទស្នេហ៍ក្រៃ កូនប្រុសមួយត្រួយដីវ ។
ឯមិត្តវិទូក: ទ្វៀតអប្សលក្ខណ៍ប្រុសម្ខាតា
ស្ទុះចេញពីហត្ថា នៃមាតាហើយក្រញ៉ី ។
រាយដែចាត់ឆាត់តប់ ដួលសន្ធប់ឆុតស្មាតើ
កូនតាលអន្សតិ្ថយ លោតរំលងខ្នងទៀតណា ។
រត់លឿនឆ្ពោះត្រង់ទៅ ជិះសំពៅកាត់ជលសា
ត្រវែក្តោងលឿនណាស់ណា ដល់កណ្តាលមហាសាគរ ។
សំពៅកើនឆ្ងាយឆ្ងល់ ចលាចលខ្វល់វឹកវរ
តិតភ័យក្នែកចត្បូរ ផ្ទៃលលង្ហរតាំងប្រុសស្រី ។
នាំគ្នាពិភាក្សា ក្នុងកេត្រាប្តូរសំដី
ថា « មានតាឈ្មោកណ្តើ ពាលអប្រិយទៅជាមួយ » ។
កំឆ្លើស្មោកឲ្យចាប់ តាមលំដាប់ដោះខ្លួនព្រួយ
មានស្មោកអាក្រក់មួយ ដើម្បីជួយនូវមរណៈ ។

ស្វាកដែលអាក្រក់នោះ ចាន់ទៅឈ្មោះវិន្ទុក:
ជាមនុស្សគាលអប្បលក្ខណ៍ អស់ពារៈតាំង ៣ ជន ។
អ្នកជិះផុតពុទ្ធព្រួយ ធ្វើក្បូនមួយឲ្យជិះឆ្លង
ទៅត្រើយមិនឲ្យហ្មង តាមចំណងច័ន្ទប្រាថ្នា ។
ខ្យល់ព្យុះបោកបក់ផាត់ ក្បូនរសាត់កាត់ជលសា
ជល់កោះមួយឈ្មោះថា ទុខគនរកធំ ។
រីមិត្តវិន្ទុក: ឃើញប្រច័ក្សហាក់សង្គ្រម
ឬមហានគរធំ ភជគន័ទីសប្បាយ ។
ក៏ឡើងដើរចូលទៅ ចិលំទៅសត្វតាំងឡាយ
កំពុងក្តៅក្រហាយ ពុក្ខវិតកាយឥតឈប់ឈរ ។
ចំណងចងកាយា ឃើញច្បាស់ថាគ្រឿងលំអ
ចិញ្ចៀនកងវែកត ភ្លឺចិត្តឯងល្អអនន្ត ។
កងចក្រជាប់លើក្បាល ខ្លួនវិលភ្ញាល់ឈាមសស្រាក់
ជាមកុដរតន: ភ្លឺចិត្តឯងរំលេចចរ ។
ចាន់ឃើញដូច្នោះហើយ មិនកន្តើយពោលអង្វរ
“ម្នាលអ្នកប្រពៃវរ តាយស្រស់ល្អគ្រប់លក្ខណ: ។
ខ្ញុំខំប្រឹងស្វះស្វែង យូរអង្វែងហើយណាអ្នក
ដើម្បីរកតន: តែវាកងពាក់កើនវែង ។

សូមលោកត្រាស់មេត្តា ជល់ខ្ញុំណា ណាម្ចាស់ថ្លៃ
សូមតាក់បានមួយថ្លៃ ខ្លួរមកុដតេជ្រនឹងសង្វារ ។ ។
រីសត្តនរកនោះ ឮដូច្នោះយល់អស់អាថ៌
« មិនមែនអស្លក្ខ័ណ កងសង្វារខេណាមិត្ត ។
គឺឮស់ជាចំណង ឃើមថាលចង់ប្រដូតរឹត
ខឹងកង់ចក្រណាមិត្រ ខួងក្បាលខ្ញុំឈឺគោកក្រៃ ។ ។
មិត្តវិទ្ធុកៈថា « មិត្តស្នេហាកុំសង្ស័យ
មាស-ពេជ្រកំលេចក្រៃ ផ្សាយពន្លឺភ្លឺចំភ្នែង ។
ខ្ញុំឃើញក្រោកជណាស់ ខឹងក្អែកឮស់យ៉ាងជាក់ស្តែង
អ្នកកុំកន្តោងឯង ខ្ញុំសូមតែងខ្លួនបានម្តង » ។ ។
នរកខ្លួតឥតស្រាក រោះកង់ចក្រខឹងចំណង
ចំណងស្ទុះទៅចង រួតរឹតមិត្តវិទ្ធុកៈ ។
កង់ចក្រជាក់លើក្បាល ខួងវិលឮស់ឈាមស្រក់
ខ្លួរជំពង់អនិត្យ ឈាមស្រក់ចាកកាយា ។ ។
មិត្តវិទ្ធុកៈទៀ សោយសោកសៅក្តៅខ្លោចផ្សា
ទោសកយកម៌មាតា វេទនាអចិន្ត្រៃយ៍ ។

បទ ៣ ក្យ ៧

ខ្ញុំសូមវែកញែកឲ្យជាក់ច្បាស់ ជនល្មើសមុខក្រាស់គាចចង្រៃ

អតីតនិទានបានកែឆ្នៃ ស្មារព្រៃនឹមនុស្សអន្សត្តិយ ។
កាលពីអតីតព្រឹទ្ធព្រៃនាយ នៅភូមិដីតជាយដែនកាសី
មានព្រានម្រឹគម្នាក់តាលអប្រិយ រកស៊ីបរបាញ់អចិន្ត្រៃយ៍ ។
យកសាច់លក់ដូរប្តូរយកក្រាក់ សំលៀកបំពាក់ស៊ីវិឡៃ
ស្រូវឱ្យដំណើបព្រានកែវ ដូរពាល់ ។ ថ្លៃមិនដែលខាន ។
បានក្រាក់ស៊ីចាយសប្បាយចិត្ត ជាមួយវរមិត្រកែវកល្យាណ
ប្រពន្ធល្អប្លែកចំឡែកក្រាណ សមួសុក្រកល្យាណស្រស់ប្រិមប្រិយ។
ថ្ងៃ ១ ព្រានព្រួយចិត្តអស្ចារ្យ ដោយអស់អាហារនំចំណី
កំលោភរិយាសាច់សឹង ចូលអរញ្ញតែម្នាក់ឯង ។
ទំប្រឹងរុករើមើលរកសត្វ ក្នុងព្រៃសូន្យស្ងាត់ជាត់សូរសៃង
ដើរឆ្ងាយ ។ ទៅជាប់សន្ទែង ហួសតែកន្លែងដែលធ្លាប់ចាញ់ ។
ដល់ពេលព្រលប់យប់សូន្យឈឹង ព្រានព្រៃទំប្រឹងដោយចិត្តក្លាញ់
ឡើងលើដើមឈើចាំប្រុងចាញ់ ក្នុកក្លាញ់ក្នុងចិត្តឥតឧបមា ។
រាយោចក់ផាត់រសាត់មក ព្រានព្រៃនឹកក្នុកព្រឺកាយា
នឹកដល់សម្ផស្សស្រស់ស្នេហា ស្រែកច្រៀងសកម្មតែម្នាក់ឯង ។

មើលហ្ន៎ ! ព្រះចន្ទកាន់តែភ្លឺ
ផ្សព្វផ្សាយពន្លឺ ភ្លឺចិញ្ចែង
ខ្ញុំនឹកស្រណោះម៉ែកែវខ្ញែង
ដែលធ្លាប់ច្រវែឡែង លេងនឹងស្រី ។

ឥឡូវឃ្លាតឆ្ងាយ ពីគាយពៅ
ឆ្ងាប់នៃបងនឹត្យនៅ កល់កត្រី
ស្តាយអើយសែនស្តាយ គាយសង្ខី
ឆ្ងាប់ថ្នាក់ថ្នមបី ស្រីបវរ ។

លុះព្រឹកព្រាងស្ងាត់ព្រះសុរិយា ... រះច្បាស់កាលណាព្រានរត្រកអរ
ស្តាយចុងយទៅតាកថាតះបញ្ចរ ... ដៃគាន់ធ្នូសរបង្ហុចញ៉ាស់សត្វ ។
ចំដើរព្រៃកុកកុលក្តៅ ... កន្ធរចិត្តមួមៅក្តៅតេកក្តាត់
ស្ទះស្ទើរបង្ហោចញ៉ាក្នុងព្រៃស្ងាត់ ... គ្មានបានជួបសត្វអ្វីមួយសោះ ។
ក្អែកតន់រៃលៃតិនិត្យ ... ពីដំណៅឆ្ងាយគ្មានបន្ទោះ
តុម្ពោតតូចធំសព្វកៀនកោះ ... គ្មានសល់បន្ទោះសោះឡើយណា ។
កំពុងតែប្រុង ។ ប្រយ័ត្ន ... សម្ងំឆកសត្វក្នុងព្រឹក្ស
ស្រាប់តែពើបតះប្រទះភ្លា ... មួយធំណាស់ណាក្បាលធំធើ ។
ព្រានកិតក័យណាស់ស្រែកយំងោំង ... ប្រឹងសុះលោតគោងឡើងដើមឈើ
ពេលនោះស្ងាសនៅតីលើ ... ខាញ្ជឡើងដើមឈើធ្វើព្រងើយ ។
ភ្លាមើញស្ងាសចាប់ខាញ្ជដៃ ... ព្រានតាលចង្រៃឡើងផុតហើយ
ក្រវែក្រោធពិរោធតុំមានស្បើយ ... គោលថា ស្ងាអើយ ! អើបងស្ងា ។
ខ្ញុំទំប្រឹងដេញចាប់ព្រានព្រៃ ... បងធំធើថ្នមក្រែងតនុបមា
ចូរបងខម្ងាក់ព្រានមកណា ... បងកុំរក្សាព្រានកម្ងៅ ។

បងអើយខ្ញុំប្រាប់បងជាមុន　　បងកុំធ្វើគុណមនុស្សក្បាលខ្មៅ
បងព្រានចុះមកខ្ញុំស៊ីនៅ　　ខុកនាំហ្មងសៅក្តៅក្រហាយ ។ ។
រឯសេ្តចស្វាចិត្តស្មោះសរ　　ជាសត្វខានធម៌ប្រចាំកាយ
មេត្តាករុណាស្វាតែងផ្សាយ　　ដល់សត្វពាំងឡាយមិនរើសមុខ ។
ស្វាសខ្លួនខ្លះវាការៈ　　ដោយចិត្តស្មោះស្ម័គ្រគេញាបន្ទុក
ហ៊ានចេញការពារពាក់ព័ន្ធមុខ　　ការពេញបន្ទុកដោយប្រាជ្ញា ។
ក្រែកឈរធ្វើយតបយ៉ាងអង់អាច　　មិនតក់ស្លុតខ្លាចអំណាចខ្លាច
«បងអើយ! ព្រានព្រៃកំយុអាត្មា　　រត់មកប្រាប់ថាការដ៏វិត ។
ខ្ញុំសែនអាណិតឥតប្រៀបបាន　　មិនអាចរុញព្រានបានទេមិត្រ
ចុះមនុស្សក្បាលខ្មៅខ្មៅខ្លួនវិត　　ព្រៃព្រឹក្សសំដែងវិចិត្រយ៉ាងណា ? ។
ខ្លាធំក្រែកអរមុខរីករាយ　　នាំរឿងព្រៃនាយនិយាយថា
បងអើយចាំស្តាប់សំដីកថា ៖

រឿងមនុស្ស-ពស់-ខ្លា ឆ្លាក់រណ្តៅ

កាលពីអតីតព្រឹទ្ធព្រៃនាយ　　មានរឿងនិយាយមនុស្សក្បាលខ្មៅ
រងទុក្ខក្តុកក្តួលក្តុកសោយសោកសៅ　　នៅក្នុងរណ្តៅក្តៅខ្លោចផ្សា
ជាមួយសត្វខ្លាឪសត្វពស់　　ស្ទើរស្លាប់ស្ទើរស្រែកអាត្មា
អត់ជាយអត់ទឹកមួយសប្តាហ៍　　ស្ទាំងស្គមកាយាស្ងួតក្រៀម ។
កាលនោះមានព្រាហ្មណ៍សប្បុរស　　មុខរីកយស្រស់ញញឹមប្រៃ

រកស៊ីគាប់ទុសពាល់ ៗ ថ្ងៃ លក់យកកំរៃជួនមាតា ។
មានកាលថ្ងៃ១ ព្រាហ្មណ៍រូតរះ ចេញចាកពីផ្ទះចូលព្រឹក្ស
កំដុបសត្វតស៊ីមនុស្សន្ទើងខ្លា កំពុងសោកក្នុងរណ្តៅ ។
ព្រាហ្មណ៍ឃើញដូច្នោះអាណិតក្រៃ ស្ទុះញាប់ដើងដៃទៅកេះផ្តៅ
គាប់ជាសង្រែកទម្លាក់ទៅ ចុះក្នុងរណ្តៅដោយស្មោះសរ ។
ខ្លាតស៊ីឃើញឮស្លាស់លែងយំស្រែក លោតតោងសង្រែកសែនត្រេកអរ
ព្រាហ្មណ៍យោងខ្លើងផុតរួចពីមរណ ខ្លាតស៊ីត្រេកអរជំពប់ថា ។
«លោកម្ចាស់មានគុណធ្ងន់សែនធ្ងន់ ធ្ងន់ក្រៃលើសលន់ឥតឧបមា
ខ្ញុំនឹងជាសត្វតស៊ីន្ទើងខ្លា មានតែហត្ថាលើកប្រណម្យ ។
ប្រសិនបើលោកមានធុរៈ ដល់ខ្ញុំមរណៈគ្រោះថ្នាក់ធំ
សូមលោកវត្ថុកន្ទឹកដល់ខ្ញុំ ហ៊ានជានាសុំប្តូរជីវិត ។
តែលោកកុំយកមនុស្សក្បាលខ្មៅ ចេញពីរណ្តៅជ្រៅឥតឆ្ងឹត
ព្រោះមនុស្សក្បាលខ្មៅខ្មៅខ្ញុំស្តមិត្រ ឲ្យគេសម្លុតតាមមិនខាន» ។
ប្រាប់ហើយខ្លាតស៊ីក្រាបលាព្រាហ្មណ៍ ចេញចាកទៅភ្នំមេឆ្ពោះទីឋាន
ជួបជុំក្រុមញាតិមិត្រសន្ទាន ជាន់សុខក្សេមក្សាន្តគ្រប់ទីកា ។
ឯព្រាហ្មណ៍កម្ទេចមិនផ្តេសផ្តាស អាណិតព្រានណាស់ជាតិដូចគ្នា
កំពុងតែងើលក្នុងវេទនា ទ្រុឌទ្រោមគ្រាំគ្រាក្នុងរណ្តៅ ។
ព្រាហ្មណ៍មិនដឿឮពាក្យខ្លាខឹងតស៊ូ ទំស្រងំជាន់សម្លុតមនុស្សក្បាលខ្មៅ

រួចតាមរណៈនៃរណ្តៅ　　មនុស្សពាលក្បាលខ្មៅនិយាយថា ។

«ខ្ញុំបានអត្តគុណនឹងលោកម្ចាស់　　គុណលោកធ្ងន់ណាស់ឥតឧបមា

គ្មានអ្វីសងគុណលោកឡើយណា　　មានតែហត្ថាប្តូរយកជីវិត ។

ខ្ញុំជាជាងមាសយ៉ាងចំណាន　　មានគេហដ្ឋានទៅក្រុងធំ (១)

លោកមានការអ្វីទៅរកខ្ញុំ　　ឯទីក្រុងធំខ្ញុំជូនបាន ។

ហើយមនុស្សក្បាលខ្មៅខ្មៀតលា　　លុតក្រាបវន្ទាបង្គំទ្រាំណា

លាត្រាហ្មណ៍ចេញទៅគេហដ្ឋាន　　បានសុខក្សេមក្សាន្តពាល់ពាក្រ ។

១– រាជធានីពារាណសី ។

(នៅមានត)

ប្រមឹកសុភ　　ស្រវឹងដោយមានី
វាក់ការបរបាញ់　　លេងល្បែងក្តាល់
រឹបជាន់ទ្រព្យសម្បត្តិ　　រាបាអាក្រក់
ខ្លាកម្មដ៏អាក្រក់　　តាំងអស់នេះជា
សេចក្តីអន្តរាយនៃមនុស្ស ។

ហ៊ិរពោធសេ

វិធ្លរជាតក (ត)

បពិត្រអើយ ព្រះបាទពិរុណនាគរាជនោះមិញ ឃើលទាំងភ្ញៀវសំបាធដូច្នោះហើយ មហាសត្រមានព្រះរាជហឫទ័យនោះជាទុក្ខអង្រួតមហាមាក្រៃពេក មហាសត្រគ្រាំងរាជ មិនអាចដើម្បីនឹងចំណាំដំណើរអាគ្នានោះបានឡើយ ស្តេចកំលោះ ចូលទៅគង់ក្នុងវិមានសិរីសួស្តីនៃព្រះអគ្គឯងហើយ ស្តេចទ្រង់ព្រះបន្ទូលពាក្យណា ក្នុងព្រះរាជហឫទ័យនៃព្រះអគ្គឯងថា នាងវិមលាទេវី នាងអើយ ប្រាថ្នាម្តេចបង់ធ្វើម្ចាស់តាំងអ្នកប្រាជ្ញ កុំបាជាលះចោលឡើយ សូម្បីតែតបបាត់ជូនអ្នកប្រាជ្ញនោះ ម្តេចក៏ម្ចាស់នឹងបានយល់ហ្ន៎ ឥតអ្នកឯណា ១ ក៏នឹងមានប្ញទ្ធិអានុភាព មានអំណាច អាចទៅនាំចៅតាំងអ្នកប្រាជ្ញនោះមកអំពីអង្គ្រឹសកលដម្ពូទ្វីបនោះ មកដល់ពិភពលោកនេះបានឡើយ ក៏នឹងយកចោលចោទម្ចាស់អ្នកប្រាជ្ញនោះ ឲ្យនាងស៊ីដោយចំណាំនាងហោង ។ ព្រះបាទពិរុណនាគរាជថា នុអញ្ញាអើយ មានទុក្ខក្នុងខ្លួនធ្ងន់ពន់ប្រមាណអ្វី មាល្បាយអេះ ស្តេចទ្រង់ព្រះចំណាំ ពាក្យណាខ្ញុំប្រកាសអម្បាលនោះហើយ ស្តេចគង់សុបសៅស្រណោះហោង ។ អថ ឆិតា ឥរន្ធតី ជាម ជាតកកញ្ញា សញ្ញា. លក្ខាវបដិមណ្ឌិតា មហាឡេន សិរីវិលាសេន ។ បពិត្រអើយ ឮដកាលនោះ ព្រះបាទពិរុណនាគរាជទើងនាងវិមលាទេវី មានព្រះរាជបុត្រ ១ ព្រះអង្គទ្រង់មានព្រះនាមឈ្មោះនាង ឥរន្ធតី(១) ដ៏ជាកូនស្រីក្រមុំមាន

---

១ – ក្នុងគម្ពីរសោស្ត្រស្ងឹកវិត គេនិយមហៅឈ្មោះនាងនាគកញ្ញាថា «អារិនៃវតី» ។

នរលក្ខណ៍ឧត្តមសមនូវរូបនោះល្អកម្រនិងមាននៅពាក់ពាន់នេះ ឥន្ទតី
នាងប្រដាប់សម្រាប់អង្គនាងជាដើម តើស្នាប់ព្រះជង្គង់ អង្គព្រះហរុក
ខ្លួមកុដ អាភរណ អង្គម ព្រះសូរងកងចំញៀនស្រេចហើយ ទើបនាង
ទ្រង់ព្រះពស្ត្រ ព្រះសុកតដ៏មានតណាស្នាំនោះល្អប្រពៃ ស្រេចហើយនៃ
ទើបនាងលីលា ទៅតាល់សម្តេច ព្រះវរបិតាធរាជ ដល់ហើយ នាង
ថ្វាយបង្គំប្រណម្យសម្តេច ព្រះវរបិតាធរាជ ហើយនាងបិតហាន១ ដំណើរ
គួរនឹងគាត្មាហើយ ទើបនាងរមិលមើលទៅឃើញសម្តេចព្រះវរបិតាធរាជពុំ
សុខសប្បាយដូច្នោះហើយទើបនាងទូលជណ្តើងទៅ សូត្រជាបទគាថាដូច្នេះ
កិន្ន តាត តុវំ បជ្ឈាយសិ បទុម ហត្ថកតំវ តេ មុខំ
កីទុម្មនរូបោសិ ។បពិត្រសម្តេចព្រះវរបិតាធរាជអម្ចាស់វិសេសអើយ
ហេតុអ្វីព្រះគុណសុបសៅស្រងើយដ៏មានព្រះភក្ត្រនោះក្រហមពុំ ហាក់ដូច
ខឹងស្រក់ឈាមចេញ ដ៏ដូចអ្នកយកកង្កាឈូកមកញីឈ្វីឲ្យដកណ្តាល ព្រះ
ភក្ត្រជាក់លើឫងតែង អ្នកនោះចេញទៅកណ្តាលថ្ងៃ សឹងដឹតស្វិតត្រដែ
ស្រែពោន នោះមានប្រការម្តេចមិញ រ៉ាព្រះភក្ត្រព្រះអង្គនោះ ស្វិតដ្រែ
ដូច្នោះហោង បពិត្រព្រះវរបិតាអម្ចាស់វិសេសខ្ញុំអើយ ព្រះអង្គមានព្រះ
រាជហឫទ័យ ជាទុក្ខអង្វែក ដ្បិតអីក្រែងមានសត្រូវមកក្នុងព្រះនគរឬម្តេច
កាលនោះព្រះពិរុណានាគរាជ ស្តាប់ពាក្យនាងឥន្ទតី ស្រដីដូច្នោះហើយ
មានព្រះបន្ទូលទៅនឹងនាងឥន្ទតីថា ម្នៀកកូនស្រីសំឡាញ់អាពុកអើយ

រីអាតុកជាទុក្ខតាំងអម្បាលនេះ មិនប៉ុន្មែនសេចក្តីអ្វី ប៉ីត្រែ ខ្ញុំនឹងនាងវិមលាទេវី ដំណាម្តាយនៃនាងឡើយ ឯម្តាយនាងប្រាថ្នាចង់តែស៊ុំថ្វើមចៅពិធូរអ្នកប្រាជ្ញ ហៃឥន្ទតីកូនស្រីសំឡាញ់អាតុកអើយ នាងវិមលាទេវីថាបើពុំបានស៊ុំថ្វើម ចៅពិធូរអ្នកប្រាជ្ញនោះឡើយ នាងនឹងក្សយជីវិតប្រាកដហោង ហៃនាងឥន្ទតី នាងអើយ កុំថាតែថ្វើមឡើយ សូម្បីតែគួចៅពិធូរអ្នកប្រាជ្ញនោះ យល់ថា កម្រៃគ្រែនឹងបាន ឯនាងឥន្ទតីអើយ អាតុកគិតទៅហើយ អាស្រូវនាងណាស់ហ៎ះ ឥតអ្នកឯណា ១ មានវិជ្ជាអានុភាព មានអំណាចអាចទៅនាំមកឲ្យបានឡើយ ហៃឥន្ទតីកូនស្រីសំឡាញ់អើយ មិនគួរគប្បីស្រដីនឹងនាងឡើយ ថាបើនាងចង់ឲ្យម្តាយនាងមានជីវិតរស់នៅ ចូរនាងទៅស្វែងរកអ្នកប្រាជ្ញណា មានប្រជ្ញាអានុភាព មានអំណាចច្រើន អាចទៅនាំចៅពិធូរអ្នកប្រាជ្ញមកឲ្យដោយចំណាំម្តាយនៃនាងបាន ហើយចូរនាងទៅជាតិយោអ្នកនោះហោង ។ តែន ប៉ុន្តែ ។ បិតុ ឪពុក ឃ សា សុត្វាន ឯកាំ រត្តិ ឯក្នុងអាសប្ប តិ ចរិ ។ នាងឥន្ទតី ស្តាប់ព្រះបន្ទូលព្រះវរបិតាធរជហើយ នាងថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះសម្មតិទេព្វ មហារាជអើយ ថាបើដូច្នោះហើយ កុំឲ្យព្រះអង្គព្រួយ ព្រះរាជហឫទ័យឡើយ ខ្ញុំឯង នឹងទៅរកថ្វើមចៅពិធូរអ្នកប្រាជ្ញនោះមកឲ្យ ដោយចំណាំព្រះរាជហឫទ័យនៃសម្តេចព្រះវរមាតាខ្ញុំហោង ។ ម្នាះហើយនាងឥន្ទតី

នាងសោមសម្តេចព្រះវរបិតាធំជហើយ នាងថ្វាយបង្គំប្រណម្យលា
សម្តេចព្រះវរបិតាធំជទៅសោមនាងវិមលាទេវី ដំណាសម្តេចព្រះវរមាតា
ហើយនាងលាទៅគាន់ស្នែងមានសិរីសួស្តី យកសំពត់ដក់គាំ មាន
រស្មីនោះក្រហមច្រាលរន្ធាលល្អ នាងទ្រង់ ហើយនាងយកសែ្បក្រមៃ
មកពាក់លើព្រះអង្គ ហើយនាងលាតែក្រាយដជាយចំលាយចំកមហា
សមុទ្រច្រាកដខ្សើងអំពីពិភពនាគនាយ នាងលាដោយឆ្នេរមហាស-
មុទ្រច្រាកដខៀបព្រៃ ប្រទេស ខេត្ត វៃម ព្រះហេមពាន្ត ស្ថាន
ស្ងាត់ជាប្រទេសវិសេស ប្រសើរ ហើយនាងទៅគាន់ក្នុមួយឈ្មោះកា-
ឡាតីរអញ្ជើនបពិតច្រាកដ មានកំពស់ ៦០ យោជន៍ពិត មានចំហាំនោះ
រពេញ តាន់ខ្ពាន់ខ្ពាប់ សឹងល្អបរិសុទ្ធ បពិត្រអើយ រីនាងឥន្ទ្រ-
នាងទៅបេះផ្កាឈើមកក្រងជាកម្រងមាលាផ្កាក្ងៃ ហើយនាងទៅច្រាយភាយ
រលើកំពូលក្នុកាឡាតីរអញ្ជើនបពិតច្រាកដ ដូចកម្រងមណីរត្ន តិតជិតិចត្រ
ប្រពៃហើយនែ ទើបនាងឥន្ទ្រតីឈរលើកម្រងផ្កា ហើយនាងកំច្រៀង
មានសូរសំឡេងនោះផ្អែមល្ហែមពីរោះសោះសា ស្រែកសូត្រជាបទព្រះគា
ថា ។ កេ កន្ទុព្ធេ រក្ខសេ ជាកេ កេ កឹ បុរិសេ
កេ ច មានុសេ បណ្ឌិតេ សព្វកាមទេ ទីឃរត្តំ កត្តា
មេ កវិស្សតិ ខេតាត យក្ខ តន្ទព្ធ អាសុរតព បុរសឯណាហើយ ថាបើ
អ្នកនោះមានបារមី រិទ្ធិអានុភាព មានអំណាចអាចទៅនាំថ្ងៃមចាំពីជួរអ្នក

ប្រាថ្នាដូនោះមកឲ្យដោយចំណាន់ ម្តាយខ្ញុំ ខ្ញុំនឹងទៅជាកំរៀវនៃអ្នកនោះ ហោង នាខ្ញុំទៅជាកំរៀវនៃអ្នកនោះ មិនប៉ុន្តែថ្ងៃមួយថ្ងៃពីរឡើយ ទ័យត្តំ អស់កាលដ៏លង់ទៅហោង បពិត្រអើយ កាលនាងឥន្ទតីទៅប្រឹងកំលើក្តាឡាតិរអញ្ចឹនបពិតនោះ មិនចុតស្ងាត់ ប៉ុន្តែនាងឯងទេឡើយ ។ តស្មឹ ១ណោ វេស្សវ៉ែណាមហារាជស្ស កាតិនេយ្យោ បុណ្ណោ តោ នាម ។

ខ្សែទី ២

បពិត្រអើយ កាលនោះ មានយក្ខសេនា ១ ជាកូនព្រះបាទ វេស្សវ៉ែណ កូវែរពេ មហារាជ រៀយក្ខសេនានោះឈ្មោះ បុណ្ណកយក្ខ មានរស់ទ្ធ ១ ឈ្មោះ មនោម័យ ដ៏មានប្រវែងខ្លួនប្រមាណបានបីគាវ៉ុតប្រាកដក្រៃពេក បុណ្ណកយក្ខ ទ្បាចន៍ត្រឿងប្រដាប់សម្រាប់ មនោ-ម័យជារដើម តឹស្មាប់ត្រាប់តណ្តាល បុស្ស នៅន ។ ណ្តាដ៏ចស្រវៃសស្សត្រ វៃសមកែមកញ្ចាក់ ក្តក់ក្តីល្ខីសន៏ល្អប្រពៃស្រេចហើយនៃ បុណ្ណកយក្ខ ស៊ុះ ផែនប្រចួបទៀន៏លើខ្លួនមនោម័យ ដៃកាន់រំពាត់ប៉ាត់ទៀនថា ហឺៈ ។ ក្នុណោ នោះ មនោម័យ ស៊ុះហិចហោះអណ្តែតត្រសែតទៅនាកណ្តាលអាកាស បុណ្ណកយក្ខបរសេះទៀបហៀបនឹងដល់ក្តំអញ្ចឹនបពិត ឮសត្តុត្រសេះទៀន ថាកឹក ។ បុណ្ណកយក្ខស្រែកថា ចាយ៉ាបជ័យបានលាភប្រាកដក្នុងថ្ងៃនេះ ឯងមិនទេឡើយ ម្នាៈហើយកំបរសេះ ហោះរៀង ។ ទៀប ហៀប នឹងដល់តំពូលភ្នំនោះកូវ ឮសត្តុនាងប្រឹងនោះក្តង ។ ម្នាក់ឯងនោះដឹ

. មានសំឡេងនោះស្រែទន់ ដាំផ្អែមល្ហែមពពោះដូច្នោះហើយ បុណ្ណកយក្ខ
មិនអាចដើម្បីនឹងខំប៉ប៉ល់ ដំកល់អាត្មាភាពនោះបានឡើយ ហេតុតែ
បុណ្ណកយក្ខនឹងបានឧបនិស្ស័យនឹងព្រះពុទ្ធជាតិមុនមក ឬបុណ្ណ-
កយក្ខ កាលបើបានឮពាក្យនាងវនិតា ដង្ហើយស្រែកច្រៀងលើ
កំពូលភ្នំនោះដូច្នោះហើយ បុណ្ណកយក្ខ ព្រឺព្រួច ក្រលួចអស់អង្គ
ស្រយ៉ង់ដំហកូច៎យ មិនអាចដើម្បីនឹងបរសេះមនោមយឲ្យរៃរួស ចង្អុស
ទៅនោះបានឡើយ ទើបបុណ្ណកយក្ខញាក់កន្ត្រាក់ស្ទុះមនោមយ
ចរបង្វិលវិលមកកាន់នាងវនិតា បុណ្ណកយក្ខស្រដីទៅកាន់នាងវនិតា
ថា ភរឌ្ឌ ម្នាលនាងអើយ នាងកុំច្រៀងពេកឡើយ កុំច្រៀងពេក
ខ្លាច ភស្មកក ហៃនាងប្អូនស្រីសំឡាញ់បងអើយ នាងអើយកុំនាង
ចាម្តេឡើយ ជានាបងឯង ខំឯងទៅស្វែងរកថ្នើមចៀមពីធូរអ្នកច្រាជនាំមកឲ្យ
ដោយចំណាន់ នៃចិត្តម្ចាយនាងហោង បុណ្ណកយក្ខ មិនស្រដីទេឡើយ
លោមនាងវនិតា សូត្រជាបទព្រះគាថា : អស្សាស ហោស្សាមិ
តេ បតី ថាម្នាលនាងមានវាំង់ក្អែកល្អ ឥតដំណោះតេះជៀល ក្អែក
នៃអ្នកឯងចាំងឡាយឡើយ ចូរនាងមានដង្ហើមចេញចូលឲ្យធូរស្រណុក
សុខសប្បាយ ជានាបងឯង ខំឯងជាស្វាមីនៃនាងឯងហោង ហើយបង
ខំឯងទៅនាំថ្នើមចៀមពីធូរអ្នកច្រាជ មកឲ្យដោយចំណាំចិត្តម្ចាយនាងហោង
បុណ្ណកយក្ខស្រដីនូវប្រការអម្បាលនោះហើយ តិតកឯចិត្តថា អញខំឯ

ចាប់នាងនេះបញ្ជូនលើសេះបរនាំទៅ ដោយខ្លាចត្រកាលនាប់ហោង
ប៉ុណ្ណាកយក្ខតិតអំបាលនោះហើយ ចុះអំពីលើខ្នងសេះមនោម័យប្រៃ
ស្អាតសីហនាទ គន្ធាតដើរចូលទៅ ចាប់ដៃនៃនាងឥន្ទតី ទើបនាង
ឥន្ទតីយល់ ប៉ុណ្ណាកយក្ខនឹងចាប់ដៃនាងដូច្នោះ នាងជាត់ខ្លួនចេញ
នាងស្រដីថា ហៃចៅមាណពអើយ រឿងនេះមិនជាស្រួ សើរើរើរ
វាយ ស្រីបស្រាលសរសេរសាជារណមកប្រឿងលេង ដោយខ្លាចគ្គ
សប្បាយ កយមាយអាស្រូវគាសតីកិច្ចការម្តាយអាពុកឲ្យបានតែសុខក្នុង
ព្រៃនេះឡើយ ចៅអើយ រឿងនេះជាព្រះពជបុត្រនៃមហាក្សត្រាធិពជ
មួយព្រះអង្គទ្រង់នាម ហៅព្រះបាទពិរុណនាគពជ សោយពជ្យសម្បត្តិ
ស្ថិតនៅឰដពិភពនាគនាយ រីឯព្រះវរមាតាអញ ទ្រង់ព្រះនាមហៅនាង
វិមលាទេវី ជាំជាព្រះអគ្គមហេសី ធំនៃព្រះមហាក្សត្រាធិពជនោះឯង ថា
ហៃចៅមាណពកំឡោះអើយ ថាចើរចៅចង់ច្រឡំថាអញជាកវយោ
នៃចៅ មកយើងនាំគ្នាទៅកាន់ព្រះអង្គតាំងពីឯនាយ ថាបើព្រះអង្គតាំងពីរ
សត្វព្រះពជហឫទ័យហើយ ព្រះអង្គប្រដាប់ប្រដាការអាពាហ៍ពិពាហ៍ជា
ឧត្តមផ្ទៃអញនឹងចៅជាប្តីប្រពន្ធនឹងគ្នា ។ កាលណោះបុណ្ណកយក្ខស្តាប់ពាក្យ
នាងឥន្ទតី ស្រដីដូច្នោះហើយ ក៏មានចិត្តនោះត្រេកអរស្មោះសរ ទឹង
នាងឥន្ទតីពេកហោង ម្ល៉ោះហើយបុណ្ណកយក្ខលើកនាងឥន្ទតី បញ្ជូន
លើខ្នងសេះមនោម័យ បរបំផាយដំណាយទឹកនឡមហាសមុទ្រច្រោកដ

ជ្រែកចុះទៅកាន់ពិភពនាគនាយ កាលថើបបានដល់ហើយ នាងឥន្ធតីនោះ
ចុះទៅអំពីលើខ្នងសេះមនោម័យមួយអន្ទើប្រពៃស្អាត សីហនាជគាគ
ចូលទៅកាន់ស្ថានលំនៅនៃនាងឯង រីឯណាកយក្ខនោះសោតចង់សេះម-
នោម័យមួយអន្ទើហើយ បុណ្ណកយក្ខឡើងទៅកាន់ព្រះបាទពិរុណនាគ
រាជស្រេចថ្វាយបង្គំប្រណម្យខួលសូត្រជាបទព្រះគាថា ជាតោវ វតោ
សុ ណាហិ មេ ជាកញ្ចិរំ ។ បពិត្រព្រះអង្គដ៏ជាធំ១ត្តមប្រសើរអើយ
សូមទានព្រះអង្គទ្រង់ខួលយកមាសប្រាក់តែវតង ពៃទូរ្យរតន៍ ខ្ញុំប្រុសស្រី
ដ៏រឹសេះរនេះគោក្របីជាច្រើនទាន់ស្ងា សូមទានព្រះអង្គទ្រង់មេត្តាជាក្រ
យាស់ពះនៃខ្ញុំហោង បពិត្រព្រះអង្គអើយ ខ្ញុំមិនប្រាថ្នារបស់អ្វីមួយជាទៃ
បើក្រៃ ទឹងនាងឥន្ធតី ខ្ញុំសូមនាងជាភរិយានៃខ្ញុំ សូមទានព្រះអង្គផ្សំខ្ញុំ
ទឹងនាងជាប្តីប្រពន្ធផងគ្នាហោង ។ បពិត្រអើយ កាលនោះ ព្រះបាទពិរុណ
នាគរាជស្តាប់ពាក្យបុណ្ណកយក្ខ ស្រដីដូច្នោះហើយ មានព្រះបន្ទូលទៅ
កាន់បុណ្ណកយក្ខថា ម្នៃចៅមាណពអើយ ថាម៉េចៅចង់បាននាងឥន្ធតី
កូនស្រីនៃអញហើយ ចូរចៅចាំអញទៅគិតនឹងនាងវិមលាទេវីជាម្តាយ
នៃនាងឥន្ធតី បើគេចូលចិត្តមិញ ក៏បាន ល្អីកបើគេពុំចូលចិត្តទៀយ
នោះចៅខាន ពុំបានឡើយ ម្នៃមាណពចៅអើយ រីឯប់មេបាចាស់ខ្ញុំ
លោកវាមង់តែនជាក់ខ្លុកកូនចៅឲ្យមានប្តីមានផ្ទះសំបែង តែនគិតអស់មេ
ចាប្រៀនលាន កល្យាណមិត្រសំឡាញ់ផងថា បើពុំបានគិតឡើយ នៅ

ផងគ្នាទៅ ល្អកជាមិនល្អ ល្អកបើកើតជាជំលោះ ប្រកែកជជែកអំពី
សន្តានញាតិផៅខាងណា ។ ហើយកាន់តែកើតជាបន្ទោស ចុចថយឯក្រោយ
វិញហោង ព្រះបាទពាំណោនាគរាជបន្ទូលនឹងបុណ្ណកយក្ខម្ចាំៈហើយ
ស្តេចលីលាចូលទៅក្នុងព្រះរាជមន្ទីរ ស្តេចគង់ទាន់នាងវិមលាទេវី ថា
ម៉ែហានាងវិមលាទេវី ប្អូនស្រីសំឡាញ់បងអើយ ឥឡូវនេះ មានមាណព
១ មកអំពីឯណា ក៏មិនដឹងឡើយ មកសូមនាងឥន្ទេតីកូនស្រីសំឡាញ់
យើង ឥឡូវនេះ តើនាងនឹងគិតម្តេចទៅ ស្តេចថាបើដោយចិត្តអញ
ហើយ អញនឹងបង់ឲ្យនាងឥន្ទេតី កូនស្រីសំឡាញ់យើងឲ្យទៅចៅមា-
ណពនោះឯង រឯចិត្តនាង តើនាង ទឹងឲ្យគេឬទេនាង បើនាងឲ្យក៏នាង
ឲ្យ បើនាងមិនឲ្យក៏នាងថាមកឲ្យដឹង នាងវិមលាទេវីស្តាប់ហើយ ក្រាប
ថ្វាយបង្គំប្រណម្យខ្ញុលថា បពិត្រព្រះសម្មតិទេពមហាកដអើយ កុំថាតែ
ចៅមាណពនោះ យកទ្រព្យទាំងអម្បាលនោះមកឲ្យ ហើយសូមនាង
ឥន្ទេតី តីកូនសំឡាញ់ខ្ញុំនឹងយកជាប្រពន្ធ សូម្បីចៅមាណពនោះយកមាស
ប្រាក់តែវែកងសព្វតិពិធរតនៈមកចាក់ជារតេញទាំងពិភពនាគនេះក្តី ក៏
នឹងមិនឲ្យនាងឥន្ទេតី កូនស្រីសំឡាញ់ខ្ញុំជាប្រពន្ធឡើយ បពិត្រ
ព្រះសម្មតិទេពមហាកដអើយ ថាដើមាណពនោះមានឫទ្ធិអានុភាពទៅ
នាំថ្មើមចៅពិភពអ្នកប្រាជ្ញមកដោយទូវិធមិ ដល់ពិភពនាគនោះ ក៏ខ្ញុំនឹង
ឲ្យឥន្ទេតីទៅជាប្រពន្ធចៅមាណពនោះហោង ខ្ញុំមិនប្រាថ្នាទ្រព្យរបស់

អ្វីដទៃបើក្រែងនឹងថ្វាយចៅពិធូរអ្នកច្រាជ្រូវឡើយ ខ្ញុំយកតែថ្វាយចៅពិធូរជា
ខាន់ស្លាក្រយាសំគរខ្ញុំហោង ព្រះបាទពិរុណនាគរាជស្តាប់ហើយស្តេច
លើសាចេញទៅអំពីព្រះរាជមន្ទីរហើយ មានព្រះបន្ទូលទៅនឹងបុណ្ណកយក្ខ
ថាហៃចៅមាណពអើយ ឥឡូវនេះ នាងវិមលាទេវីស្រដីថា កុំចាំចៅ
យកគ្រឿងទាំងអម្បាលនោះមកឲ្យឡើយ ទោះបីយកមាសប្រាក់រតនាមក
ចាក់ជារូបេញ្ចាំងពិភពនាគនេះក្តី ក៏នាងមិនឲ្យនាងឥន្ទតីកូនស្រីសំ
ឡាញ់នាងជាប្រពន្ធចៅឡើយ ថាបើចៅមានឫទ្ធីអានុភាពអាចទៅនាំថ្វាយ
ចៅពិធូរអ្នកច្រាជ្រូមកដោយខ្លួនវិញមិ ឃានជាល់ពិភពនាគនេះហើយ នាង
និងឲ្យកូនស្រីសំឡាញ់នាងទៅចៅហោង បុណ្ណកយក្ខស្តាប់ហើយទះដៃ
ជាងការក្រពើយថា អៃយ៉ាអញគិតស្មានជាគ្រឿងបស់អ្វី ។ ទោះ
យល់ជាកម្រមក្តីចហ៎ះ ថាបើច្រាថ្វាយចៅពិធូរអ្នកច្រាជ្រូទោះពាក្យ
ហ៎ះឯងអេះ កុំថាចៅពិធូរអ្នកច្រាជ្រូតែមួយតែពីរឡើយ ទោះបីចៅពិធូរ
អ្នកច្រាជ្រូនោះជារយជាពាន់ ជាម៉ឺន ជាសែនក្តី ក៏ខ្ញុំនឹងទៅចាប់ចៅពិ-
ធូរអ្នកច្រាជ្រូនោះយកមកថ្វាយព្រះអង្គឥឡូវនេះឯង បពិត្រមហាពជអើយ
រីចៅពិធូរអ្នកច្រាជ្រូនោះ តើគាត់តូចឬធំ សឬខ្មៅ ជាត់ឬស្គម គាត់ចាប
ឬខ្ពស់ សក់គាត់តើវែងឬខ្លី សំដីគាត់នោះរឹងឬខន់ ក៏ខ្ញុំនឹងទៅសួរពេក
ក្រែងអ្នកស្រុកនោះគេច្រាប់ខ្ញុំមិនជាក់ ជាចៅពិធូរអ្នកច្រាជ្រូនោះឡើយ ។
ហើយខ្ញុំទៅចាប់ឯអ្នកខ្លៅថាជាអ្នកច្រាជ្រូ ល្អីកខ្ញុំអាចនាំមកថ្វាយព្រះអង្គ

ហើយ ព្រះអង្គនឹងមានព្រះបន្ទូលថា នែចៅមាណពអើយ នេះមិនគឺចៅតែងតួរអ្នកប្រាជ្ញទេឬអី ប្រសិនបើដូច្នោះវិញហើយ ការអសារឥតការហោង នាងឥន្ទតីអសារមិនបានជាការយ៉ាងខ្លាំងឬអី ដូច្នោះហើយ សូមសម្តេចមហាក្សត្រប្រាប់ខ្ញុំឲ្យបានជាក់ច្បាស់ប្រាកដហោង ។

(នៅមានត)

កំឡាំងសាមគ្គី (កាព្យពាក្យ ៤)

ការរួបរួមគ្នា កើតជាកម្លាំង កំឡាំងនោះខ្លាំង មាំមួនមហិមា គ្មានដ៏នណាអាច ប្រមាទតវ៉ា ឃាឃីពាជា បានឡើយបំណង ។ បើនៅតែឯង គ្មានដ៏នណាផង រួមជាមិត្តគ្រង សត្រូវមើលងាយ សរសៃសូត្រមួយ ខ្សល់បក់ដាច់ដាយ ដាច់ធ្លាក់ទៅឆ្ងាយ ហេតុគ្មានពំនឹង ។ គ្មានញាតិពំនាក់ ពឹងពាក់ពុំបាន ពុំបានរឹងប៉ឹង ដាច់ឆាប់ដោះក្រៃ សរសៃសូត្រច្រើន ក្រើនតួតដៃ ពួតព័ទ្ធជើងដៃ ការឡើងខ្សែ ។ ពួរតួចតួរធំ ជាក់មាំពូកែ ឥតមានប្រែខ្វៃ បែរបែកទៅផ្លាស ស្ងិតក្រៃលែងស្ងិត ដាច់មិនរវិសាស យកទៅប្រើប្រាស ធ្វើចក្តីប្រាថ្នា ។ មិនដាយដាច់ដោច រហោចទៅណា បងអ្នកនា ដាច់ពោកពន្ធុង ទោះសត្វដំរី ធំក្រៃចម្បង ពើពុំជនឯង ហេតុដោយច្រើនធ្មុង ។ នេះប្រៀបធ្វើជាចិត្ត ដើម្បីស្និទ្ធស្នាង តាំងមូលស្មុគ្រគោកគង់ ប្រសើរល្អណាស់ ទោះកំចូរស្រាលធ្ងន់ ឯងអាចរែកពន់ ទៅបានសព្វថា ។ ទោះខ្លាំងសត្រូវ បងប្អូនរុកពួន រុកពួលទន្ទ្រាន ពុំបានឡើយច័ង កំឡាំងសាមគ្គី ខ្លាំងក្រៃកន្ធង ខ្លាំងលើសអ្វីផង ដែលហៅថាខ្លាំង ។ ផលនៃសាមគ្គី អាចឲ្យតតាំង តយុទ្ធប្រដាំង ឈ្នះសត្រូវបាន ហើយនាំបានសុខ ផុតទុក្ខរំខាន រុងរឿងល្បីឈ្មោះល្អ ទៅអនាគត ។ ចូរភ្ញើងទាំងឡាយ រក្សាឲ្យគង់ ទុកឲ្យមាំជាប់ នូវធម៌សាមគ្គី ធម៌នោះប្រពៃ ថ្លាថ្លៃពេញទី ក្ខានអ្វីដាច្រឹ នៅឥណោកឃ ។

ផើង-ជ្រើរ

អក្សរសាស្ត្រខ្មែរ	ខ្មែរធ្លាប់ចែកឲ្យគេ
ឲ្យបានខ្លាចខ្លួន	គង់រឹងរឿងតាមតែ
ព្រោះអក្សរជាតិ	គោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ

ប. ព.

បម្រាំងក្នុងលោក

(វិចារណាកថា)

រៀបរៀងដោយ ប៊ូ-ឧទិន្ន

សង្ឃាត់លេខ ៥ ក្រុងភ្នំពេញ

ខ្ញុំបានអានអត្ថបទមួយរបស់លោក ហ៊ែល-ស៊ុំថា ប្រធាននៃសមាគមអ្នកនិពន្ធខ្មែរ ។ អត្ថបទនោះស្តីអំពីចរិយាសាស្ត្រ តទល់និងវិទ្យាសាស្ត្រដែលផ្សាយក្នុងទស្សនាវដ្តីអ្នកនិពន្ធខ្មែរ ឆ្នាំទី ១ លេខ ២ ទំព័រ ៣៦ . . . ខ្ញុំមានចិត្តចាប់អារម្មណ៍ខ្លឹមអត្ថបទរបស់លោកនេះ យ៉ាងខ្លាំង ហើយខ្ញុំមានយោបល់ស្របតាមលោកដែរ ដោយហេតុខ្ញុំធ្លាប់បានពិចារណាការរកហេតុផលក្នុងបញ្ហាបម្រាំងនេះមកពីមុន ។ ខ្លះដែរ ។ ខ្ញុំអត់ត្រាំពុំបាន ទើបខ្ញុំសរសេរអំពីយោបល់ខ្លះរបស់ខ្ញុំចំពោះបញ្ហាថា :

«បើវិទ្យាសាស្ត្រ មិនមែនជាបុព្វហេតុនៃបម្រាំងទេ តើមានធម្មជាតិ

អ៊ីចឹងទេតើ ជាបុព្វហេតុនៃចម្បាងនៅវិញ ?

មុននឹងដោះស្រាយប្រស្នាងាយដើមនេះឲ្យបានដាច់ខាតយល់នោះ ខ្ញុំសូមធ្វើអត្ថាធិប្បាយបញ្ជាក់អំពី

ធម្មជាតិចម្បាង

ក) ដោយទាហរណ៍យ៉ាងខ្លី – មនុស្សពាល់ត្រូវសឹងជាប់ជានដឹងឮឬបានឃើញច្បាស់នឹងភ្នែកខ្លួនហើយនូវចម្បាងក្នុងប្រទេសឬនៅគ្រាប្រទេសសព្វថ្ងៃនេះ ។

ដូចជាកាលខ្លួនខ្ញុំនៅតូចក្មេងតូចជាប់ជានមើលល្ខោនជាសាក់ ខ្ញុំខ្លាចស្បថសែនត្រង់ជាកចម្បាងរកងមនុស្សនឹងយក្ស ដោយឃើញមុខយក្សនោះគាក្រក់ណាស់ ខ្លាំងឲ្យខ្ញុំខ្លាចជាខ្លាំង ថែមទាំងឮសម្លេងយក្សក្រវែស្រែកឡូឡាទៀត ខ្ញុំតែតែតក់ស្លុតចង់រត់ចេញពីកេងល្ខោន ប៉ុន្តែ ម៉ែគាត់ចាប់ដៃខ្ញុំជាប់ ។ តមកក្រោយទៀត ខ្ញុំកាន់តែធំខ្លួនដឹងក្តីគ្រាន់បើហើយ ខ្ញុំឮថាស់ខុំទិយាយគ្នាតិចាក់ឯច្បាំងនឹងសៀម តិជប៉ុនច្បាំងនឹងអាមេរិក ។ ក្នុងខ្មែរទាំងសងខាង មានស្លាប់ចាត់ចង់ដាក់តែអស់ជាច្រើនព្រាត់ច្រាស់ម៉ែឪប្រពន្ធកូន ។ ខ្ញុំឮដូច្នេះតែតែកតក់យជាងមើលល្ខោនទៅទៀត ព្រោះល្ខោននោះច្បាំងគ្នាគ្មានស្លាប់ទេ គ្រាន់តែគេធ្វើគ្រាប់ចម្បាងប៉ុណ្ណោះ ។

ទាហរណ៍សង្ខេបប៉ុណ្ណេះ សូមឲ្យអស់លោកជ្រាបច្បាស់ហើយ

អំពីចម្ងាំង ខ្ញុំមិនចង់យោយឲ្យពិស្តារទៅទៀតទេ ព្រោះយើងអាចយល់បានដោយងាយថា ចម្ងាំងគឺជាការប្រើកម្ងាំងមនុស្ស ដើម្បីដណ្តើមយកជ័យជំនះគ្នាទៅវិញទៅមក ដោយប្រើយុទ្ធោបករណ៍ ឬប្រើយុទ្ធាជ្ញាយវង្វេង ។ ពីគ្នា ។ បើខុកជាគេប្រើដុំថ្ម-ឆ្នាំង ឬប្រើកាំភ្លើង គ្រាប់បែក បរមាណូជាដើម ក៏រួមហៅថា ចម្ងាំងដែរ ។

๒) ដោយទាហរណ៍ជំពិស្តារ – បើយើងគ្រាន់តែយល់អំពីចម្ងាំងហើយនៅស្មើមឈឹងត្រឹមហ្នឹងទៅ នោះយើងមិនអាចនឹងជ្ងាន់ជ្ងឹងនូវបុព្វហេតុនៃចម្ងាំងទេ ។ ដូច្នេះ តពីនេះទៅ យើងត្រូវប្រើវិភាគញ្ញាណស្រាវជ្រាវរកនូវតុដែលជាបុព្វហេតុរបស់ចម្ងាំង ឲ្យឃើញច្បាស់លាស់ ។

បុព្វហេតុនៃបម្ងាំង

តាមទ្រឹស្តីរបស់បណ្តាជនពួកខ្លះ យល់ឃើញថា «ចម្ងាំងកើតមានឡើងនោះ មកតែពីការខ្វះខាតគ្រឿងឧបភោគបរិភោគ ពីដណ្តើមកសុការពីការបែងចែកលាភសក្ការៈមិនស្មើភាគគ្នា ទើបបានជាមានអស្ថិមានៈប្រកាន់វណ្ណៈ ប្រកាន់ពូជសាសន៍ពួករបងគ្នាឯង ក្នុងប្រទេសជាមួយគ្នាក៏មាន រវាងអន្តរជាតិ នៅប្រទេសនានាក៏មាន ។ «ទ្រឹស្តីបែបនេះហៅថា «សេដ្ឋបច្ចយនិយម» (Séterminisme économique) ។

តាមការសង្កេតរបស់ខ្ញុំដ៏ខ្ចនខ្ចាយ ខ្ញុំយល់ឃើញថា : ចម្ងាំង

មាន ២ ប្រភេទ គឺចម្បាំងធំ ១ ប្រភេទ ចម្បាំងតូច ១ ប្រភេទ ។ ចម្បាំងធំ សំដៅយកការប្រហារគ្នាដោយគ្រឿងសស្ត្រាវុធយុទ្ធភ័ណ្ឌ គេហៅជាចម្បាំងទំនឹងជាតិគ្នាឯងក្នុងប្រទេសជាមួយគ្នាក្តី គេហៅម្បាំងទំនឹងជាតិដទៃ ប្រទេសដទៃក្តី ។ ចម្បាំងធំនេះ មិនមែនកើតមានឡើងឯង។ តែម្តងទេ ក៏តែងកើតមានឡើងពីចម្បាំងតូចជាមុន ។ ចម្បាំងតូចសំដៅយកការប្រើពាក្យសំដីប្តឹកប្តាញតាមសារពត៌មាន ដូចការសែត ទិតប៍ណ្ណជាដើម។ ប៉ុន្តែគេយើងកាល់គ្នាក្តៅខ្លួន មិនបានជាចាប់ក្តីកន្តឹកនាដល់ចម្បាំងតូចនេះផងសោះ បេះតែនាំគ្នាបើកភ្នែកធំ ។ សម្លឹងមើលទៅដល់ចម្បាំងធំតែម្តង ហើយព្រឺខ្លួនក្រៃពេកស្មាលន់មាត់ថា „អៃយ៉ា ! បរមាណូ ! „ តាមពិត យើងមិនគួរបំភ្លេចចម្បាំងតូចចោលទេ បើបំភ្លេចចោលហើយមុខជាកើតចម្បាំងធំមិនខាន សឹងមានសុភាសិតជាពាក្យខ្មែរបុកណាថា « អ្នកតូចបង្ខូចអាជំ ក្មេងឆេះពីសម្រាម» ។

រឿងចម្បាំងតូចនេះ គួយ៉ាងដូចប្រទេសកម្ពុជាយើង តាំងពីបានឯករាជ្យបរិបូណ៌មក ធ្លើជាប្រទេសអភ្យក្រិតមកវាង ១០ ជាយឆ្នាំហើយ បេះតែមានចម្បាំងតូចលេចចេញមកពីមហាប្រទេសខ្លះកាល់ថ្ងៃ។ ចំពោះមកលើប្រទេសយើង គាល់តែអស់លោកមេទ័ពនាយមកកូមិន្ទុយើងក្តៅក្រហាយជាខ្លាំង ក្រាបទូលឥន្ទ្រសុំព្រះបរមកជាខ្មាញ្ញតិសម្តេចព្រះប្រមុខរដ្ឋបេញ្ជើចម្បាំងធំ ប៉ុន្តែ អង្គសម្តេចឪយើង ទ្រង់ជាអគ្គមគ្គុទ្ទេសដ៏ឆ្នើម

ប្រកបដោយគតិបណ្ឌិត ព្រះរាជាឈ្វេងយល់ដល់អាក្រក់ដែលកើតមានពីចម្បាំងធំនោះ បើទុកជាយើងចាញ់ឈ្នះគេ ក៏គង់តែស្ងាប់កូនចៅព្រះអង្គដែរ ហេតុនេះ ព្រះរាជាចេះតែទំរកមធ្យោបាយដោះស្រាយដោយសន្តិវិធី ដើម្បីនឹងរំលត់ចម្បាំងកុំឲ្យអស់ទៅ ។ តទៅមុខ ប្រសិនបើចម្បាំងកុំបីមិនរលត់ទេ នៅតែកាលជាលដល់ទៅកើតចម្បាំងធំទៀតនោះ មិនមែនភ្ជាក់កំហុសលើសម្តេចឪយើងទេ មុខជាភ្ជាក់កំហុសទៅលើមហាប្រទេសណាដែលមិនព្រមឈប់ធ្វើចម្បាំងកុំបី មកលើប្រទេសខ្លះនោះពាំងស្រុងរឿងចម្បាំងកុំបីនេះ អ្នកសង្កេតការអន្តរជាតិបានយល់ច្បាស់ណាស់មកហើយ ។

គួរឲ្យយើងខឹកឆ្ងល់ដែរថា តើចម្បាំងកុំបីនោះ គឺជាអ្វី? យើងត្រូវឆ្លើយថា ចម្បាំងកុំបីនោះ គឺជាសង្គ្រាម (ការប៉ះទង្គិចគ្នា ឬការប្រជាំងគ្នា) ។ ឧទាហរណ៍ដូចជាការចោទប្រកាន់គ្នាដោយពាក្យសំដីឬដោយលាយលក្ខអក្សរ ។ល។ សង្គ្រាមនេះមិនទាន់ដល់ថ្នាក់ប្រយុទ្ធគ្នាដោយគ្រឿងសស្ត្រាវុធទេ គឺគេគ្រាន់តែចាក់ដោតតិះដៀលគ្នាដោយសំដីឬដោយតួអក្សរប៉ុណ្ណោះ ដែលយើងធ្លាប់និយាយគ្នាមកហើយថា « សង្គ្រាមជ្រុលកា » ។

ប៉ុន្តែ មានមនុស្សភាគច្រើនសន្និដ្ឋានថា សង្គ្រាមនេះពុំមែនជាចម្បាំងទេ ព្រោះគេឥតសម្លាប់អ្នកណាសោះ គេគ្រាន់តែធ្វើឲ្យមានការ

ខន្ធិចដោយពាក្យសំដីប៉ុណ្ណោះ ។ ការធ្វើនេះមិនមែនជាបុព្វហេតុបណ្តាលឲ្យក្រុយជីវិតមនុស្សទេ ។ សេចក្តីសន្និដ្ឋានបែបនេះ ហ្វាន់ឡាយណាស់ចាត់ថាមិនយល់បច្ច័យនៃចម្បាំងតូចនោះឡើយ ។

តាមការណ៍ពិត ការប្រដាំងគ្នាដោយពាក្យសំដីនោះឯងហើយជាមូលហេតុនៃចម្បាំងធំ ។ បើចម្បាំងតូចកើតមានតាន់តែច្រើន ។ ឡើងហើយអាចបណ្តាលឲ្យផ្ទុះទៅជាចម្បាំងធំបាន ។ ចម្បាំងធំត្រូវប្រើយុទ្ធោបករណ៍ សង្គ្រាមក្នុងវិធានការសម្ភារៈ (Conlit dans le plan matériel)

ក្នុងប្រយោគដែលគេថាប់ន័យថា «យើងត្រូវតែតស៊ូ ដើម្បីធ្វើឲ្យកើតមានសន្តិភាព» ប្រយោគមួយទៀតថា «យើងត្រូវតែធ្វើវិធីសាស្ត្រប្រដាំងនឹងពួកយុទ្ធិកៈអ្នកបង្កបង្កើតសង្គ្រាមឲ្យបាត់ជ័យទៅ ដើម្បីឲ្យសន្តិភាពបានឈ្នះអស់សន្តិភាពក្នុងសកលលោកជាស្ថាពរ» ។ ប្រយោគទាំង ២ ឃ្លានេះ ឥតបានន័យថាជាអ្វីសោះ បានន័យប្រហែលគ្នានឹងថា សម្លាប់ដើម្បីឲ្យរស់ ។ សង្គ្រាមនៅតែមានជាដែល ។ សន្តិភាពបានតែមួយៗណៈប៉ុណ្ណោះ កំលោយបាត់ទៅវិញ ។

ចើដូច្នេះ តើយើងត្រូវធ្វើដូចម្តេច ទើបអាចនឹង

បំបាត់ចម្បាំងឲ្យអស់រលីងពីសកលលោកបាន ?

ប្រស្នានេះ បើតាមយោបល់ដ៏ស្ងួចស្តើងរបស់ខ្ញុំ ។ ដើម្បីពុកជាមុនថា ការធ្វើចម្បាំងដោយប្រើយុទ្ធោបករណ៍នោះ ពុំមែនជាការបំបាត់

ចម្បាំងឲ្យអស់រលើងពីសកលលោកទៅទេ ។ បើយើងចង់ឲ្យអស់ចម្បាំងនោះ លុះតែយើងលះបង់ចោលខ្លួនតំនិតជាកលោភៈ ដែលប្រឆាំងនឹងតំនិតរបស់ពួកយុទ្ធិកៈអ្នកបង្កសង្គ្រាម គឺថា យើងត្រូវរកមធ្យោបាយធ្វើឲ្យមនុស្សទាំងអស់ ក្នុងសកលលោកមានមនោតតិសុចរិតស្មូតត្រង់ទៅវិញទៅមកវិញ ។ បើនិយាយតាមព្រះពុទ្ធាភិប្បាយថា ចម្បាំងកើតពីមនុស្សម្នាក់ៗរួបរួមគ្នាទៅជាយោធាជាកងទ័ព បើមនុស្សម្នាក់ចំបាត់តាមតណ្ហាឲ្យអស់ពីចិត្តខ្លួនចេញ ទើបបានផុតរលត់ចម្បាំងក្នុងលោក ពោះចម្បាំងត្រជាក់ក្តី ក្តៅក្តី ។

ព្រះរាជាអង្គណា មានពេទ្យរាជគ្រូ ទីឆ
មន្ត្រី សុទ្ធតែជាអ្នកបញ្ជោរ ព្រះរាជា
អង្គនោះ ទីឆស្តេចព្រះសរីរៈ៧យគុណ
ធមិ ទីឆអន្តរាយ ឃ្លាំងដោយធាប់រហ័ស

ហិតោបទេស

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ជា ជ - ខាត់ រៀបរៀង

(តមក)

អង្ឃ្រិ ប៉ុ. អង្គ ផ្នែ ជំណើរ ចំណាយ ជំណើរនឹងពេលជំណើរ ។ អង្ឃ្រក ដែលទៅតាមផ្លូវ ដែលទៅនឹងផ្លូវ ប៉ុ. អ្នកដើរកំសាន្ត អ្នកជំណើរ ។ អង្ឃ្រវេម គុ. ដែលកាន់យកភាពជាអ្នកប្រកាន់មស្ត ដែលជាប្រដនិយេស ។ អង្ឃ្រតិន ប៉ុ. អ្នកបង្ហាញផ្លូវ អ្នកនាំផ្លូវ មគ្គុទ្ទេសក៍ ។

អង្ឃ្រិ ប៉ុ. អ្នកជំណើរ ។

អង្ឃ្រ ប៉ុ. ទេវតាយ យញ្ញពិធី ។ - ត គុ. ដែលតាំងទៅដើម្បីយញ្ញពិធី។

អង្ឃ្យ៉ ប៉ុ. ព្រាហ្មណ៍អ្នកធ្វើយញ្ញពិធី ។

អង្ឃ្ល គុ. ដែលមិនអន្តរាយ (ដែលមានអន្តរាយមិនមាន) ។

អង្ឃ្ឋ ប៉ុ. អង្គ ផ្នែ ។

អង្ឃ្ឋ ប៉ុ. អង្គន កិរិយាមិនមានស្មារ លទ្ធិមួគ : ។

អង្ឆ មើល អ ២ ។

អង្ឆ ធាតុ. អនីតិ អានយតិ - ដឹកដង្ហើម ។

អង្ឆ សព្ទតាម. មើល ឥទមិ ។

អង្ឆ ប៉ុ. ខ្យល់ដឹកដង្ហើម ។

អនង់ត គុ. ដែលមានចំណែកមិនមាន (មតិក)។

អនក្ខិ មើល អក្ខិ ។

អនក្ខជ្ជ ដែលចេះជាស្លាមិនមាន ដែលមិនចេះជាស្លា ។

អនក្ខត្រគណ គុ. ដែលមានពួកនក្សត្រមិនមាន ។

អនក្ខរ គុះ ដែលចេញសំឡេងមិនមាន ដែលគ្មានថ្ងូង ។ ក្ខរៈ អនក្រ. វិ. ដោយតិតមាត់ក ។

អនក្ខរិតព គុ. ដែលមានបន្ទាត់ក្នុងក្លែកមិនមាន ។

អនគ្ឃ គុ. ដែលមានអាក្រាតមិនមាន ដែលមិនរលស ។

អនគ្គិ គុ. ដែលមានភ្លើងមិនមាន ដែលមិនរកក្បាភ្លើង ។ - ក គុ. ដែលមានភ្លើងមិនមាន ។ - ទ្ធ ប៉ុ. ពហុ. ឈ្មោះព្រាហ្មណ៍ ។

អនឃ គុ. ដែលមានប្រលោក់មិនមាន ដែលគ្មានទោស ដែលមិនអន្តរាយ ដែលគ្មានព្រួយ ។ អនឃា ស្រ្តី ឈ្មោះទន្លេ ។

អនង្គណិតព គុ. (ពុកមាត់) ដែលមិនដុះ ។

អនង្គុតិ គុ. ដែលមានកង្វៃមិនមាន ដែលមិនព្រមស្តាប់ការកង្វៃ (ដែលមិនព្រមទៅតាមឬ ដែលប្រើការកង្វៃ បង្គាប់) ។

រឿងអាប៊ូលហ្វាអ៊ូរីស៍

(ភ)

លោក ប៉ាយ.ល្មុត តំណាងកម្ពុជ

ប្រែរៀបរៀង

អន់ចិត្តខ្លាំងនឹងសេចក្តីព្រហើន នៃបុគ្គលចំឡែកនេះ ថាសាម្នាក់អត់ត្រាំពុំបាន ស្ទុះទៅវាយដាល់ តែវាស់ខ្លីដែលមកថាសានោះធ្វើសញ្ញាដោយញាក់មុខត្រចាប់ រួចឈោងដៃមកត្របួចស្មា ចាក់ទឹងក្រចកវាសានោះស្លាប់ភ្លាមទៅ ។ ឃើញដូច្នោះ តម្កុរសំពៅចាំងអស់ ខ្លះកាន់ដាវ ខ្លះកាន់លំពែង ឈូឆរព្រួតគ្នាទៅវាយកាប់ចាក់មនុស្សកំណាចនៃសាច់រាំងដូចគេជ្រូតតរលាត់អ្វីបន្តិចសោះ ។ ដាវលំពែងខ្លះបាក់ ខ្លះរមួលមូរមុខ ។ វាស់ឯងសឹកមកវិញ លោតសំដៅទៅថាសាម្នាក់ ដែលនៅនោះជាងគេ ចាប់បានក្រញីរៃកហួរទ្រិចខ្លីស្លាប់ភ្លាម ចំពោះមុខយើងតែម្តង ដូច្នេះយើងចាំងអស់គ្នាមិចក្អែកលោតព្រមគ្នា ទៅចោមរោមបម្រុងនឹងប្រាន់ខ្មាំងទឹក តែវាឈានទើងថ្កល់ ឥតកម្រើកបន្តិចបន្តួចសោះវាមានដើងដៃសរសៃរឹងអស្ចារ្យផង ក្រចកខ្លាំង ។ បេះវាមុតដូចដែកគោលចោះទៅនឹងក្តារសំពៅរឹងម៉ឺងដូចស្នឹងផង ម្ខាំរហើយវាញញឹម ។ ញាក់ចិញ្ចើមដាក់យើងវិញ ដោយគេចង្រៃយ ហើយមានវាចាថា ៖

តាមត្រង់ទៅចុះ ! សំឡាញ់ចាំងល្ងាយអើយ ! អ្នកឯងចង់មកតស៊ូ

ខ្ញុំនោះ មានផ្លូវតែមួយប៉ុណ្ណោះឯង គឺចាញ់ខ្ញុំ ! អ្នកត្រូវតែរៀនស្គាប់បង្គាប់ខ្ញុំទៅវិញល្អជាង ! ខ្ញុំឈ្នះមនុស្សធ្វើរូសចាំងឲ្យាយជាងអ្នកឯងអស់ទៅហើយ ! បើអ្នកនៅតែខ្ជូចខ្ជីនឹងខ្ញុំ ខ្ញុំនឹងសម្លាប់អ្នកឯងចាំងអស់ ដូចអាពីរនាក់ខ្លុះ ! ។

សំដីនេះ នាំឲ្យយើងចាំងអស់គ្នាខ្លាចរត្រដាក់ដៃត្រដាក់ដើងជាក់ជាវជាក់ដំបង កំនាំគ្នាសើចរៀបចំតុអាហារ ឲ្យដន់កំណាចនោះខ្លៅ ក្នុងសេចក្តីរៀបរយ ។ ខ្លៅតហើយ ! ភតមញ្ជាយ ។ ចាត់អស់មួយតុនេះភ្លាមទៅខ្លៅ . . . ឆ្អែតហើយទើបមានចិត្តគោរពនឹងមេត្តាករុណាហើយឲ្យតវសព្វសាធុការដល់យើងចាំងអស់គ្នា រួចភបួងសួងសូមឲ្យដួបប្រទះនឹងសំពៅមួយខ្លៅតសម្បូណ៌ដោយស្បៀងអាហារនឹងអាសវាសោតចូលសំពៅនោះតទៅ . . . លុះតែដល់ពេលនោះ ទើបយើងចំនេរទៅកើត ។ ក្នុងពេលនេះយើងមិនចាន់ច្បូងខ្ជូនទេ ។ ចាប់រាគតុជាតម្រាប់ឆ្លួនម្តងនេះ ឃើញថាឆ្អែតឆ្អន់មែនទែន ដោយយើងឃើញពោះវាប៉ាំងក្រអឺងក្រអាង ។ យើងខ្សឹបខ្សៀវគ្នា មានសេចក្តីសង្ឃឹមថា បន្តិចខ្លៅតប្រហែលវាដេកលក់ ហើយយើងនឹងឆ្លៀតឱកាសនោះប្រាន់ចាត់ចម្លាក់សម្លុះឲ្យស្លាប់តែម្តងទៅ ។ នោះយើងមានស្បៀងអាហារគោតច្រើនចាំងម្នាក់ដោយ ។ វានេះជាយក្ខ មិនប៉ុន្មានថ្ងៃទេ ! មុខតែចាស៊ីអស់ហើយស៊ីចាំងស្លាលយើងចាំងអស់គ្នាផងក៏មិនដឹង ! ។ យើងគិតគ្នាប៉ុណ្ណោះ

ដូចជាវាគ្រាន់ញ៉ាំណាដើរតែម្តង ! សត្វតំណាចនេះស្រាប់តែប្រាប់យើងថា ៖ ខ្ញុំមិនចេះដេកសោះឡើយ . . . . អាហារដែលចូលទៅក្នុងខ្លួនខ្ញុំគាំងប៉ុន្មាន អំបាញ់មិញ គឺជាស្រេចស្រាប់សម្រាប់ឱ្យខ្ញុំឆ្អែតគាំងចិត្ត ឆ្អែតគាំងសេចក្តីស្រេកឃ្លានរបស់រូបកាយខ្ញុំ ។

វាហៅយើងម្នាក់ម្តង ។ ទៅសួរ អំពីស្រុកទេសចំនៀមទម្ងាប់ដំណើរផ្សងព្រេងរបស់យើង ។ យើងបានធ្វើយរៀបរាប់តាមដំណើរ ថ្វីបើយើងមានសេចក្តីចង្អៀតចង្អល់ចិត្ត ។ វាមិនដេកគាល់តែសោះ ។ យើងគាំងអស់គ្នាកើតទុក្ខយ៉ាងភ្លាំង ចុះវាសនាអ្វីក៏អាក្រក់មែន ? រំឯថៅតែសំពៅ លោកមុខស្រស់តអស់សង្ឃឹមដឿជាក់ថា ត្រូវវិនាសបាត់បង់ជីវិតមានទៅដល់គោះកូលកុង្គ ។

តំពូងតែនាំគ្នាកើតទុក្ខជាមួយដូច្នេះ ស្រាប់តែមេយងងឹត យើងស្មានថា ប្រហែលមានព្យុះសង្ឃរាមកដល់ ។ សូវឱ្យមានព្យុះសង្ឃរាដូច្នេះទៅវិញល្អជាង ព្រោះយក្ខនេះដល់វាស៊ីស្បៀងអាហារយើងអស់ការណា មុខតែយើងគាំងអស់គ្នាទៅជាចំណីវាទៀតជាប្រាកដពុំលែងឡើយ ។ សេចក្តីស្មានរបស់យើងនេះខុសស្រឡះ ៖ ពពកមួយដុំធំ ឱនចំហាយទឹកបែកផ្សែង ដែលយើងឃើញនោះ គឺជាសត្វឥន្ទ្រីមហាសូរ្យមួយ មានមាឌធំសំបើម សត្វធំដល់ម្លេះ យើងមិនដែលជួបប្រទះឃើញសោះ ។ មហាបក្សានេះ វាបោះភួយលឿនដូចព្រួញ មកចំសំពៅ

យើងហក់ចុះមកឆាបឆក់ យកអាយក្ងុកំណាចនោះទៅដោយស្រួល ព្រោះ
យក្ងុនោះឥតដឹងខ្លួន ពុំឃើញមានប្រយុទ្ធតស៊ូអ្វីសោះនឹងសត្វនោះ ។
ថ្វីបើដូច្នោះ ស្រាប់តែដល់ទៅលើមេឃ យក្ងុនោះវាចុចក្រចកវាចូលទៅ
ក្នុងសាច់សត្វឥន្ទ្រីរួចវាខ្ទេចយកសាច់ចាំងដុំៗមកស៊ី ស៊ីចាំងស្ងាបសត្វ
ចកូរនោះផងទៀត ។ សត្វឥន្ទ្រីឈឺណាស់ ស្រែកឮកក្រើកមហាសា-
តរ តាំងយកក្រចកវាខ្ទេះក្អែកយក្ងុខ្ចាក់ចាំងពីរ ចាំងក្អែកខ្ចាក់យក្ងុនៅតែ
ទំខ្ទេះយកបេះដូងឥន្ទ្រីមកបរិភោគ ។ ឯសត្វឥន្ទ្រីដ៏ងដូច្នោះ វាក៏ប្រមូល
កម្លាំងក្នុងខ្លួនវាចាំងប៉ុន្មានទំប្រឹងត្រដរពួយមួយចំពុះ ឆ្ទុះលលាដ៍ក្បាលយក្ង
សត្វចកូរនិងយក្ង កំណាត់គ្រាំចាំងពីរ នៅតែរើយើង លិចស្ងាប់ក្នុងសមុទ្រ
អស់ទៅ ។

X

X X

យើងចាំងអស់គ្នាវាយកញ្ចាក់លោតកញ្ឆេងក្នុងសំពៅ សប្បាយរីក
រាយណាស់ ។ តែយើងមានសេចក្តីស្តាយថា មិនគួរឲ្យយនឹងសត្វឥន្ទ្រី
ស្លាប់ សត្វនេះមានគុណនឹងយើង ។ ម្យ៉ាងទៀតយើងចេះតែឆ្ងល់គិត
មិនយល់ថា ចុះមានពួជមនុស្សអីក៏ថ្លែកអស្ចារ្យម្ល៉េះ ? នៅក្នុងពិភពលោក
យើង ។

ដល់យើងបានរួចពីយក្ងុអសុរយង់ឃ្នងហើយ យើងបន្តដំណើរទៅ
ទៀត ។ សំណាងល្អ ខ្យល់រំភើយៗល្មម សំពៅអណ្តែតបានលឿន

ជារច្រើនថ្ងៃតមក យើងឃើញទីដីគោកលិម ។ កម្មករនាវាងជើង
ក្តោង បានឲ្យយោបល់ថា បើយើងឋិតនៅខាងសមុទ្រខ្ពស់ដូច្នេះ ទីដី
ស្រួចខ្ទុះត្រូវជាបុងកោះភ្នាំបែកខាងលិច មានកោះស៊ុមាត្រានៅខាងកើត
បន្តោះនោះ ជាប្រកសមុទ្រឈ្មោះ ឡាសុន្ត ជិតទីក្រុងបាន់តាំ ។

យើងចាំងអស់គ្នារីករាយសប្បាយណាស់ ដោយបានឃើញដូច្នេះ
នាំគ្នាទំដួយបំប៉ោងក្តោង ខ្លួលពេលនោះឡស់បញ្ចូនល្អ ត្រូវទិសផង
មិនយូរប៉ុន្មាន យើងក៏បានសំចតរើទំនិញ នៅកំពង់នៃក្រុងបាន់តាំនេះ ។
យើងនាំគ្នាទិញស្បៀងអាហារជាថ្មី ស្រេចហើយ យើងបន្តដំណើរហួត
ដល់កោះដំឡូលាញមួយឈ្មោះបាតាវី ។ នៅទីនេះថៅកែយើង លោក
មានកិច្ចការត្រូវចំពេញផងដែរ ។ ទីនេះឆ្ងាយពីក្រុងបាន់តាំ ប្រហែល
១៧ ឬ ២០ ល្បើ (៦០ ឬ ៨០ គីឡូម៉ែត្រ) ស្រេចហើយយើងត្រូវធ្វើ
ដំណើរតាមផ្លូវគាត់ ប្រហែលមួយថ្ងៃ ទើបដល់ព្រះពន្ធអាណាចក្រនាម
គួលកុង្គ ។

នាកាលយើងដល់កំពង់នៃពន្ធាទីក្នាម មានជនាតុជនកុះករឈ្លូតរ
មកខ្លួលយើងដោយទុបអរសោទរ ព្រោះថៅកែយើង លោកជាមនុស្ស
មួយ មានគេស្រឡាញ់រាប់អានច្រើន ។ ចំណែកខាងគ្រួសារលោក
នោះ យើញថាមានសេចក្តីរីករាយសប្បាយជាពន់ពេកណាស់ ។ ប្រពន្ធ
និងកូនស្រីរបស់លោក នាំគ្នាទាំងម្តាយទាំងកូន មកទុបលោកមិនចេះ

អស់មិនចេះហើយ ទឹកមុខខន់ក្ងន់គោរព ឯលោកក៏ឃើញសប្បាយរីករាយណាស់ ចិត្តប្រកបដោយមុទិតាធម៌ ទៅកាន់ប្រពន្ធកូនដល់ទឹកភ្នែករលេងរលោង . . . ។ លោកថៅកែបានតាំងខ្លួនខ្ញុំ (អា) ទៅបង្ហាញអស់លោកស្រីចាំងនេះ ដោយមានប្រសាសន៍ថា ឈ្មោះតាថូលហ្វាំអ៊ូស៍នេះជាខាសា ដែលលោកកាប់អានជាពិសេស ហើយប្រគល់ជូនតាមតែលោកស្រីប្រើប្រាស់តាមត្រូវការតទៅ ។

X X

X

លុះចំណេរកាលតមកមិនយូរប៉ុន្មាន លោកស្រីចាំងអស់នោះ មានសេចក្តីអាណិតកាប់អានខ្ញុំជាខ្លាំង ខណៈដែលអ្នកមិនប្រសើរល្អដែរ បានតែរួបខ្ញុំមួយនេះឯង ទើបពេញចិត្តលោក ។ ខាសា ខាស៊ី ចាំងឡាយឥតមានសេចក្តីប្រណែនអ្វីទេ នាំគ្នាកាន់តែសប្បាយចិត្តខ្លាំងទៅទៀត ដោយឃើញខ្ញុំបានតាប់ដូច្នេះ ។ ជាការណ៍ពិត ចំណែកខាងខ្ញុំ ។ ក៏ខំលួងលោមអ្នកចាំងនោះ ឲ្យធូរឲ្យស្រួលហើយជារឿយ ។ ខ្ញុំចែកចាយទ្រព្យធនវត្ថុនានាទៅឲ្យអ្នកដែលមិនគួរចាំងបានផងនោះដែរ ។ ដូច្នេះលោកឌ៉ីហាអូស្ស៊ូ មានសេចក្តីអនុគ្រោះ ដល់ខ្ញុំកាន់តែធំឡើង ។ ទើបមានថ្ងៃមួយលោកមានប្រសាសន៍ទៅនឹងខ្ញុំថា ៖

អាថូលហ្វាំអ៊ូស៍ ! អ្នកប្រហែលជាបានសង្កេតឃើញថា ខ្ញុំគុកជាក់អ្នក ពុំសូវខាសាចាំងឡាយឯទៀត ។ ។ ខ្ញុំនិយាយឆ្លើយសំដៅចុះថា

ខ្ញុំនឹងមានសេចក្តីអាណិតអាសូរដល់អ្នក លើសពីនេះទៅទៀត ។ អ្នក
បានយើញខាង ហ្វាំក្រែន្ទិសាកូនរបស់ខ្ញុំហើយ តាមខ្ញុំស្មានតែទៅទីកោះ
គួលកុន្ធនេះ គ្មានកញ្ញាណាស្អាតល្អជាងទេ ខ្ញុំបានស្ងាបសួនចិត្តកូនខ្ញុំ
ហើយ មើលទៅរូបអាប៊ូលហ្វាំអ៊ូរ៉ែសឯង តុំមែនជាទីស្អប់ខ្ពើមរបស់ពាក់ទេ ។

ឮដូច្នេះខ្ញុំ (អ) កំភាំងស្មារតី ចេញស្តីមិនរួច ។ លោកខើហា
អូស្ស យើញមុខខ្ញុំស្ងើរតែឥតញញឹមសោះ ទើបលោកថែមសេចក្តីថា ៖
ចុះម្តេចទៅវិញ ! សេចក្តីដែលខ្ញុំស្នើអំបាញ់មិញ មិនគាប់ចិត្តអ្នកទេឬអ្វី ?
នាងហ្វាំក្រែន្ទិសាកូនខ្ញុំទៅធ្វើជាប្រពន្ធរបស់អ្នក រួចអ្នកត្រូវខួលសម្បត្តិ
ទ្រព្យខ្ញុំជាមរតក . . . (ល) អត្ថប្រយោជន៍ប៉ុណ្ណោះមិនសមល្មម ឥតឯចិត្ត
ទាស្មាក់ដូចអ្នកឯងឬអ្វី ?

(អ)– មហាស្រេដ្ឋ ដ៏ជាទីគោរពខ្ញុំអើយ ! ខ្លួនខ្ញុំប្រថាពបានធ្វើជាកូន
ប្រសាលោក កិត្តិយសនេះ ខ្ញុំចង់បានជាខ្លាំងផុត ប៉ះលោកបួលសាសន៍
ម៉ាហ្គូម៉ែតដូចខ្ញុំទៅក៏ . . . តែលោកល្អនឹងខ្ញុំណាស់ . . .

(ខ)– ត ! បើមានទុច្ចសត្តតែមួយនេះទេ ជាគ្រឿងកំណត់អ្នកនោះ
មិនយូរប៉ុន្មានទេ បន្តិចទៀតយើងស្រុះស្រួលគ្នាបានហើយ ព្រោះខ្ញុំនឹង
សម្រេចចិត្តថា ខ្ញុំបួលសាសនាម៉ាហ្គូម៉ែត ឯកូនស្រីខ្ញុំក៏ដូច្នោះដែរ ។ អ្នក
បួសលោកបានដាក់ឫទ្ធាប់ទាំងឱ្យយបង្ខិលខួរក្បាលខ្ញុំ ថ្ងៃបើខ្ញុំនឿយណាយ
អស់កម្លាំងកាយ-ចិត្ត ទៅថ្វាយបង្គំធ្វើពលិកម្មបូជា សូត្រធម៌គោរឈ្មោះ

គោញ្ជើងនោះហើយកំដោយ ! ខ្ញុំជាមនុស្សដ៏ងងុលក្រវាជាពន់ពេក មិនសមឡើយខ្ញុំទៅខ្ចប់ជាមួយគ្នា តាមដំនឿអមង្គល ខ្ញុំជឿជាក់ថា ត្រូវមានអ្វីប្រសើរខ្ពស់លើសលើព្រះអាទិទេពម្ចាស់សួគ៌ជាមិនខាន ? ។ ដូច្នេះ កូនអើយ ! ត្រូវកូនឧស្សាហ៍ព្យាយាមតាមសេចក្តីស្នើរបស់ឪពុកចុះ កុំញាប់ញ័រតាមអ្វីឱ្យសោះ ឪពុកសុំឱ្យកូនឧស្សាហ៍ព្យាយាមទៅ !

(អ)-ចោះបើខ្ញុំខំប្រឹងស្មារតីយ៉ាងណាក៏ដោយ - មើលទៅប្រហែលជាដោយហេតុ ខ្ញុំយើញទាំងកន្ទុយភ្នែកពុំដឹង !- អាការជាតិការជាដែលគេផ្តួចផ្តើមក្នុងគ្រានេះ នាំឱ្យខ្ញុំមានសេចក្តីខ្ជិលរអិលជាដំបូង ។ ក្នុងពេលនោះ ខ្ញុំឥតមានបញ្ចេញអាការអ្វីឡើយ ទៅតាន់ចៅហ្វាយខ្ញុំ ។ ដោយស្មានថា ខ្ញុំយល់ព្រមហើយ ព្រោះពុំឮប្រកែកអ្វីសោះ លោកក៏អញ្ជើញទៅឯយកប់រឿងនេះ ជាដំណឹងដល់ប្រពន្ធនឹងកូនស្រីរបស់លោក ។ បន្ទាន់ក្រោមតមក ខ្លួនខ្ញុំមានសេរីភាពនិយាយជាមួយនឹងនាងហ្ការ៉ូឌ្ញិនិសាចង់ញញឹមញញែមញញាក់ញញោច ដើមក្អែកកន្ទុយក្អែកជាកំគាយ៉ាងណាបានតាមចិត្ត ។ នាងមានសេចក្តីរីករាយស្រស់ប៉ះព្រងើយ ខ្ញុំទឹកថាប្រហែលជានាងស្រឡាញ់ខ្ញុំខ្លាំងដោយសុទ្ធចិត្ត . . . តែបន្តិចមក ខ្ញុំបានដឹងថា សេចក្តីដែលខ្ញុំស្មាននេះ គឺខុសស្រឡះ !

(នៅមានត)

ល្បែកទ្បាហ្គុងតែន

ប្រែតីកាសាថ្មាំងដោយលោក ដេង-ទ្រីវ

(ក)

៩៤)- សំឡាញ់ពីរនាក់

មានមិត្រពីរនាក់អាស្រ័យនៅ «ម៉ូណូម៉ូតាថ៌» (១) : មិត្រទាំងពីរនេះមានទ្រព្យសម្បត្តិ ប្រហាក់ប្រហែលគ្នា ។ មិត្រភក្តិក្នុងប្រទេសទាំងនោះ តំមានតម្លៃ ដូចមិត្រភក្តិ ក្នុងប្រទេសយើងដែរ ។

មានយប់មួយ នៅពេលដែលមិត្រទាំងពីរបួប តំពុងទទួលទានដំណេក ស្រាប់តែមិត្រម្នាក់ស្ទុះក្រោកដូចមានអាសន្នលោតចុះពីគ្រែ រត់ទៅឯផ្ទះមិត្រជាទីស្នេហា ហើយជាស់ជាប់រើទាំងទ្បាយក្បាក់គ្មានសល់។

មិត្រដែលកំពុងដេក តំស្ទុះក្រោកឡើងទាំងភ្ញាល់ ឆាកទៅយកច្រាក់ យកអាវុធ រត់មកដួបនឹងមិត្រហើយសួរថា : ខ្ញុំមិនដែលឮប់ឃើញសំឡាញ់ស្ទុះស្ទាក្នុងពេលដែលគេកំពុងដេកយ៉ាងនេះ តាមដែលខ្ញុំឮប់ដឹង សំឡាញ់ជាមនុស្សចេះសំចៃពេលគ្រាន់ចើ សំរាប់ការទទួលទានដំណេក តើសម្លាញ់ មានចើនាតបង់ច្រាក់កាស ដោយលែងភ្ញាល់ឬ? ច្រាក់ឯណោះ ! ហ៊ានតទៅ ឬសម្លាញ់មានចើតើតជម្ងោះអ្វី ខ្ញុំមានដាវ យើងទៅជាមួយគ្នា ; ឬសម្លាញ់អង្គុតខ្លាំងតេក ព្រោះដេកតែ

(១)- ម៉ូណូម៉ូតាថ៌ ជាប្រទេសមួយនៅអាហ្វ្រិកខាងត្បូង ។

ម្ចាក់ឯងជាន់ច្បោះ ? ខ្ញុំមានចាវស្រីម្នាក់រូបឆងគួរសម សម្លាញ់ត្រូវការ ឬ ខ្ញុំឲ្យគេហៅមក ?

មិត្រនោះឆ្លើយថា : ៤ អ្វីក៏មានតាំងអស់ ខ្ញុំសូមអរគុណនឹងសម្លាញ់ហើយ ។ តំពុងដេក ខ្ញុំយល់សប្តិឃើញសម្លាញ់ឯងដូចមានសេចក្តីព្រួយបន្តិច ដោយខ្ញុំខ្លាចក្រែងវាជួចជាក្តងយល់សប្តិ ទើបខ្ញុំតំមកសួរយ៉ាងហ៊ាសនេះ ។ ដំណើរដែលខ្ញុំមកនេះ មានយល់សប្តិចង្រៃជាហេតុ ។

បណ្តាមិត្រតាំងពីរ តើមិត្រណាដែលមានចិត្តស្នេហាជាងគេ ? ចំពោះរឿងនេះ សូមអ្នកអានវិនិច្ឆ័យផងចុះ ។

មិត្រពិតប្រាកដ ពុកជាវត្ថុមួយដ៏ផ្អែមល្ហែម ! មិត្រនោះមែងតែងស្វែងរកនូវសេចក្តីត្រូវការរបស់អ្នក រហូតដល់ក្តងបេះដូងអ្នក គេមានអជ្ឈាស្រ័យ ចំពោះការរំខានរបស់អ្នក គឺថាមិនបណ្តោយឲ្យអ្នកស្វែងរកសេចក្តីត្រូវការដោយខ្លួនអ្នកឡើយ ។ ពោះជាយល់សប្តិក្តី ពោះជាអ្វីដទៃក្តី ពាក្យនេះតែងធ្វើឲ្យមិត្រព្រួយចារម្ភជានិច្ច កាលបើរឿងនេះមានការពាក់ព័ន្ធដល់មិត្ររបស់គេ ។

៩៥)- អ្នកទទួលបញ្ជើមិនស្មោះត្រង់

ដោយសារតែខេត្តស្មាតើ ខ្ញុំបានយកសត្វតាំងឡាយមកថ្វាយមានណា ។ ប្រហែលជាតួដទៃនឹងផ្តល់នូវជោគជ័យស្តួចស្តើងដល់ខ្ញុំ ។ តួ

អត្ថបទពាំងឡាយរបស់ខ្ញុំ ។ ឲ្យចបក និយាយនឹងខ្លែ សត្វពាំងឡាយ ល្មមគួរសម ត្រូវធ្វើជាតួផ្សេង ។ ខ្លះជាមនុស្សឆ្កួត ខ្លះជាបណ្ឌិត ប៉ុន្តែ យើញថា តួជាមនុស្សឆ្កួត មានចំនួនច្រើនបរិបូណ៌ជាង ។ មិនតែ ប៉ុណ្ណោះ ខ្ញុំយកអ្នកចោកបញ្ឆោត យកចោរ អ្នកស្មោកអាក្រក់ អ្នក អកតញ្ញូ អ្នកច្រមាច លលាតែ អ្នកល្ងីល្ងើ ទឹងបញ្ឆោរ មកជាក់ផងដែរ រួចខ្ញុំបញ្ចូលក្រុមអ្នកកុហកថែមមកទៀត ព្រោះបណ្ឌិតតែងតែលាថា ៖ មនុស្សនិយមកុហកជាច្រមាណ ។ ប្រសិនបើមានតែក្រុមមនុស្ស ស្រ-ឡាញ់ថាកថាបតែនឹងមិនអាចដឹងខ្លួនកំហុសនៃមនុស្សពាំងឡាយបានយើង ពាំងអស់គ្នាសុទ្ធសឹងនិយាយកុហកពាំងធំពាំងតូច តែបើអ្នកណាហ៊ាន និយាយពាក្យកុហក ខ្ញុំនឹងប្រធាំងជាដាច់ខាត ។ ហើយទោះបើមានអ្នក ណាមួយ នឹងត្រូវការកុហក ក៏អ្នកកុហកដឹងតប្រាកដ នឹងមិនមានសភាព ដូចជាលោក « អេសុប » (Esope) (១) នឹងលោក (ហោមែរ) (២) (Homère) ឡើយ គឺថាសម្ងស្ងើត្រជាក់ផ្អែម នៃចិត្តគតជាច្រើន ដែលកើតមានឡើង ដោយសិល្បៈដ៏ឧត្តមរបស់លោក ក្រោមសំពត់តំណាកុហក រមែងផ្តល់ដល់យើងនូវការណ៍ពិត ។ លោកពាំងពីរបូបធ្វើសៀវភៅមួយ ដែលខ្ញុំចូលចិត្ត ថាគួរតម្លៃឲ្យមានដំណែតតម្កើងចំជុតគ្នាន ។ អ្នក ណាដែលច្រឡាំងអ្វី កុំកុហកដូចលោកខាងលើ ។ ហើយកុហកដូចជា

---

១ - ពាក្យជាតិក្រេក ២ - អ្នកនិពន្ធជាតិក្រេកដ៏ល្បីល្បាញ ។

អ្នកខ្លួលបញ្ជោរម្ចាស់ចានធ្លាយ រួចត្រូវខ្លួលទោសព្រោះតែសំដីនៃអង្គត្រូវចាត់ទុកជាអ្នកកំណាច ឥតជាអ្នកល្ងីល្ងើ ។ រឿងនេះមានដូចតទៅ ៖

មានពាណិជម្នាក់នៃប្រទេស « ពែរ្ស » (Perse) កាលដែលទៅដំណើរញ ចានយកដែកប្រហែល ១០០ គីឡូ ទៅផ្ញើទុកនឹងអ្នកផ្ទះដិតខាង ។ លុះត្រឡប់មកវិញ ពាណិជនោះទៅសុំយកដែកមកវិញ ។

អ្នកខ្លួលបញ្ជោរថ្លាប់ថា : ដែករបស់អ្នក ? ខ្ញុំស្គាយណាស់ ព្រោះមានកណ្តុរមួយ ស៊ីអស់រលីង ។ ចំពោះរឿងនេះ ខ្ញុំបានស្តីបន្ទោសយ៉ាងខ្លាំង ដល់មនុស្សទាំងឡាយក្នុងផ្ទះដែរ តែធ្វើដូចម្តេច ? ព្រោះក្រង់ស្រែរវៃមិនមានរន្ធជានិច្ច ។

ពាណិជនោះគំរោតរឿងបែកដ៏អស្ចារ្យនេះពេក ហើយធ្វើជារឿងនោះទុកជាការណ៍ពិត ។ កន្លងពីនោះមកមិនបានប៉ុន្មានថ្ងៃ ពាណិជបានគិតដោយសម្ងាត់ ឲ្យគេលបលួចចាប់កូនអ្នកដិតខាងយកទៅលាក់ទុក រួចទៅអញ្ជើញឪពុកកូននោះមកតិះសៀង គាត់នេះសុំទោសទាំងទឹកភ្នែកថាមិនបានទៅទេ ព្រោះសេចក្តីសប្បាយរីករាយគ្រប់ជាត់អស់ហើយ ។ ពោលថា ៖ ខ្ញុំស្រឡាញ់កូនស្មើជីវិត ខ្ញុំមានតែកមួយហ្នឹង ឥឡូវអ្នកណាលួចចាប់យកទៅបាត់ហើយ តាមតែអ្នកអភ័យទោសដល់ខ្ញុំផងចុះ ខ្ញុំព្រួយពេកណាស់ ។

ពាណិជឆ្លើយថា ៖ ពីមុនមិញ ពេលល្ងាចដិតយប់ ខ្ញុំឃើញ

សត្វគួរកហើរមកធាបធត់កូនអ្នកខៅ សំដៅតែហាស្ថានតភ្លាស់មួយ ។

ឥតុកធ្វើយថា៖ អ្នកឯងនិយាយយ៉ាងនេះ ខ្ញុំរកដឿមិនកើត មិនដែលឮសត្វណា អាចធាបធត់យកខៅបានខ្លួវតែបែបនេះ ? តើគួរដឿបានឬទេ សត្វគួរកអាចធាបធត់កូនខ្ញុំយកខៅបាន ? ពាណិជធ្វើយថា៖ ចំពោះរឿងហ្នឹង ខ្ញុំមិនធ្វើយជំងាស់ទង្គឹអ្នកទេ ព្រោះខ្ញុំយើញថាច្បាស់ទង្គឹក្នុកបស់ខ្ញុំ គឺយើញកធាបយកកូនអ្នកខៅមែន ហើយខ្ញុំមិនយើញមានអ្វី ដែលបង្ខំឲ្យអ្នកសង្ស័យបន្តិចបន្តួចសោះ ខៅតែលខាងក្រោយដែលខ្ញុំនិយាយរឿងនេះ ។ តើអ្នកយើញជាការប្លែកអស្ចារ្យឬទេ ដែលកណ្តុរតែមួយ អាចស៊ីអស់ដែក ១០០ គីឡូបាន ហើយសត្វគួរកមិនអាចធាបយកបានខ្លួវកូនក្មេងទម្ងន់តែ ៥០ គីឡូ ?

ឥតុកកូនក្មេងតាល់ប្រាជ្ញ ក៏ប្រគល់ដែកមកឲ្យពាណិជ ។ កំត្រឡប់ប្រគល់កូនខៅឲ្យវិញ ។

(នៅមានត)

ព្រះពជាអង្គណា មានសេចក្តីរីកយទង្គឹង
សេចក្តីក្រោធស្ងើគា មានសេចក្តីត្រេក
អរក្នុងសាស្ត្រទង្គឹអាថិ មានការខំនុក
បំរុង អាមាត្យអស់កាលជានិច្ច ដែនដី
តប្បីចំរើនខ្លួវត្រូវចំពោះព្រះពជាអង្គនោះ
ហិតោបទេស

រឿងសាមកុក

ឧកញ៉ាវិបុលវាដសេនា ឩ-ឥន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃ្លាសាស្ត្រ
អ្នកវាងវៃឆ្លាសចេះជានអាន
នឹងបេះខួរជាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

——— ឃ្យោ-អ៊ុន ———

ឯបូធូនោះ លុះដល់ពេលយប់ស្ងាត់ ក៏ចាត់ប្រើខ្លែវខាប់ ទំនិញហ្វាំអឿនលើកតាហានទៅភ្ជួនបង្កប់ថ្នៅលើកំពូលភ្នំទាំងសងខាង ហើយឲ្យតាហានឡើងទៅដឹករណ្តៅមួយគ្រាប់ ហើយយកដីគ្របពីលើមាត់រណ្តៅលុញឲ្យស្មើតមិនឲ្យក្រឡេកយល់ លុះដល់ពេលខៀបភ្លឺស្រាងក៏ចាត់តាហានឲ្យលើកទៅលាយកំណែងស្រុក ឯខ្លួនបូធូនឹងតាហានប្រមាណ ១៤-១៥ នាក់ក៏ឡើងទៅលើកំពូលភ្នំដែលដឹករណ្តៅខុតនោះ ។

លុះព្រឹកឡើង ចាំងតេកលើកតាហានបើកទ្វារស្រុកចេញទៅតាំងតែចោមរោមយកលាយកងខ្ញីតបូធូ ទៅឆ្ងាយឃើញដូច្នោះក៏បរសេះបួលច្បាំងនឹងចាំងតេកជាប់ដៃគ្នាទៅវិញទៅមក ហើយធ្វើជាថយរត់ទៅក្រោយ ចាំងតេកឃើញថ្មានចំណាប់ ក៏ប្រញាប់បរសេះដេញតាមទៅដល់កំពូលភ្នំ ។

បូធូនៅលើកំពូលភ្នំខ្ពស់ត្រដែត ឃើញចាំងតេកដេញទៅឆ្ងាយឡើងមកក៏

ស្រែកស្តីទៅចុំដែតថា ស្រុកហាន់តុងបាត់ដួចជានៅក្នុងកណ្តាប់ដៃយើងអស់ហើយ ហើយខ្មៅខ្សោះបាត់ដួចកូនមាន់ យើងនឹងចូលគាច់ចំលាយឲ្យបានឥឡូវនេះ បើស្រុកហាន់តុងបានយើងហើយ ខ្លួនអ្នកឯងក៏គង់នឹងស្វាប់អសារឥតការ ហេតុនេះ អ្នកគួរតែមានប្រាជ្ញាចូលមកលន់តួចំណុះយើងដោយស្រួលបួលទៅចុះ ទើបនឹងរួចពីសេចក្តីស្វាប់ ។

ចុំដែតបានឮដូច្នោះក៏គិតថា បើប្រសិនជាយើងនឹងចាប់គាហានបានដល់រយនាក់ទាំងទៅឲ្យខ្មៅខ្សោះ ក៏មិនស្មើនឹងចាប់បានខ្លួនចួនដួតែមួយនោះឡើយ គិតហើយក៏ញាក់សេះឡើងទៅលើកំពូលភ្នំដោយមិនដឹងកល១ចាយ ខ្លួលឮស្ងួរជាវ សេះនោះក៏ស្ទុះទៅចំមាត់រណ្តៅចាំដែតក៏ធ្លាក់ពីលើសេះចុះទៅក្នុងរណ្តៅ ។ ពួកគាហានចួនធួក៏ស្ទុះស្រួចូលទៅព័ទ្ធចាប់ខ្លួនចុំដែតេក ចងបានហើយទាំងទៅឲ្យចួនធួ ។

ចួនធួយើញដូច្នោះ កំភ្លែងធ្វើជាឃាត់ហាមគាហានចាំងអស់នោះកុំឲ្យវាយឡើយ ចួនធួចុះទៅពីលើសេះ ស្រាយចំណងចុំដែតេកចេញអស់ហើយសួរថា ខ្លួនអ្នកនឹងព្រមទៅធ្វើការជាមួយនឹងយើងតទៅឬ ? យើងនឹងទុកអាយុជីវិត ចុំដែតេកក៏និកគិតតែក្នុងចិត្តថា ចិត្តចួនធួនេះមិនមានអាឃាតញាប់ទេនឹងយើងសោះ ឯខ្មៅខ្សោះជាមនុស្សចិត្តស្រាលត្រចៀកស្រាល គ្មានពិគ្រោះពិចារណាឲ្យដឹងការល្អាស់ប្រាកដរកឲ្យយើញខុសនឹងត្រូវសោះ គិតហើយក៏ធ្វើយថា ខ្លួនខ្ញុំបាទជាសត្រូវខ្លាំង

ឧត្តមលោក ។ ចាប់ខ្លួនបានមិនសម្លាប់នោះ ព្រះគុណជាទម្ងន់មិនមានទីបំផុត ខ្ញុំសូមផ្ញើអាយុជីវិតនឹងលោក សូមចូលធ្វើការតបស្នងព្រះគុណ ត្រាតែអស់ជីវិត ។

ចូឆួបានស្តាប់ហើយក៏មានអំណរណាស់ ទើបឲ្យរកសេះ ១ មកឲ្យចាំងគេកដែរ ហើយក៏នាំចូលទៅក្នុងបន្ទាយ រួចឲ្យរៀបតុលៀងអាហារហើយឲ្យបំណាច់ច្រាក់មាសដល់ចាំងគេកជាច្រើន លុះវេលាព្រឹកឡើងចូឆួក៏ប្រើគាហានឲ្យយកដើងជណ្តើរនឹងចង្កៀង ទៅដាក់ភ្ជាប់នឹងកំផែងស្រុក ឯគាហានដែលនៅលើសើនបន្ទាយក៏ចាប់ខ្លួចុះចូលមក ហើយចោលទម្លាក់ដុំថ្មមកត្រូវគាហានចូឆួរបួសពិការស្លាប់ជាច្រើន ពួកគាហានចូឆួក៏យកស្ពាន់ធមិនឹងរំសេវមកលាយគ្នាដាក់ជាឈ្នួនក្នុងដុំដី ហើយចោលចូលទៅលើដំបូលផ្ទះ ឈ្នួននោះក៏ឆេះពាសដាលគ្រប់ដំបូលផ្ទះរបស់អ្នកស្រុកពេញពាសឡើង ពួកអ្នកស្រុកចាំងអស់គ្នាក៏នាំគ្នារត់បាន ។

ខៀវឡាំងថា ចាំងគេកប្រចិត្តក្បត់ចូលទៅខាងចូឆួហើយ កំប្រឹក្សានឹងគាហានចាំងពួងថា វេលានេះ ចាំងគេកចេញជាក្បត់នឹងយើងទៅនៅខាងចូឆួហើយ ចូឆួក៏លើកកងទ័ពមកដល់ដើងកំផែងខៀត តើអ្នកណាគ្នានឹងជួយតតប្រការម្តេច ? ។ ខៀវអូយឆ្លើយថា ការដែលនឹងការពារស្រុកទុកឲ្យបាននោះមុខជាមិនកើតទេ គួរតែដុតចំផ្ទាញ់ភូមិស្រុកចាំងនេះឲ្យវិនាសអស់ចេញ កុំឲ្យចូឆួបានរបស់ទ្រព្យអ្វីឡើយ ហើយខ្លួនលោក

ក៏ត្រូវនៅត្រង់គ្រួ ខ្ញុំឯងលុះតែចេញទៅនៅស្រុកចាំតុងវិញ ។
អៀវសុងធ្វើយថា ដែលខ្ញុំឯងធ្វើយថា ដែលខ្ញុំឯងធ្វើតាមពាក្យខៀវអួយនោះ
មិនគួរទេ បើប្រសិនជារត់ចេញទៅនៅស្រុកចាំតុង ក៏គង់មិនរួចពីដៃបូធូ
សុំឲ្យលោកចេញទៅលន់តួ សុំចំណុះបុះបូលដោយល្អទៅវិញស្រួលជាង ។

ខៀវឡ ជានស្តាប់ខៀវអួយ ខ្ញុំឯងអៀវសុងថាខុសដំណើរសេចក្តីគ្នា
ដូច្នោះ ក៏មិនអស់សង្ស័យ មិនដឹងខ្ញុំឯងយកសំដីខាងណា ហើយថា
កាលពីដើម យើងគិតខ្ញុំឯងតាំងខ្លួននោះ ច្រកថ្នាខ្ញុំឯងជួយខំខ្មុកបំរុងអាណា
ប្រជាខ្មុកស្តេចឲ្យជានះសេចក្តីសុខ ឥឡូវនេះ មានកម្មជារហេតុឲ្យខ្មុកមក
បណ្តាលឲ្យខាល់ខ្លួនដល់ខ្លីនៅហើយ បើខ្ញុំឯងដុតបំផ្លាញគ្រឿងរបស់ខ្ញុំឯង
ស្បៀងអាហារសម្រាប់ស្រុកចេញមិនគួរ ។ តែនាំគ្នារត់ចេញទៅឲ្យ
ផុតអំពីភ័យអន្តរាយចុះ លុះដល់ពេលយាម ២ ជាយ ខៀវឡក៏នាំគ្រប់
គ្រួខ្ញុំឯងស្មគ្រប់ក្បាលពួករត់ចេញតាមផ្លូវទ្វារទិសខាងត្បូង ជម្រង់ទៅស្រុកចាំ-
តុង ។ បូធូដឹងដូច្នោះ ក៏មិនបានឲ្យខាហានដេញតាមខៀវឡនោះទេ
លុះត្រឹកឡើង បូធូក៏នាំខាហានខាំងភ្លងចូលទៅកង់ស្រុកហាន់តុង បូធូ
យើញយ៉ាងខ្ញុំឯងច្រកចាក់សោរជាប់ ក៏បង្គាប់ខាហានឲ្យតុះដំលាយទ្វារ
ចូលទៅយើញរបស់គ្រឿងនៅច្រើនណាស់ បូធូក៏បង្កើតចិត្តសង្ឃឹកអាណិត
គិតថា ខៀវឡនោះជាមនុស្សខៀងត្រង់ មិនបានធ្វើអន្តរាយរបស់គ្រឿង
កង់ស្រុកឲ្យនៅសល់យកតែខ្លួនទៅតួនក្នុងខ្ញុំដៃ សមដូចពាក្យបុរាណ

រោលទុក ចូរឆ្លូកំតែងជាសំបុត្រមានចំនុកចំនៀមតាមធម្មិល្ហ បញ្ចុះបញ្ចូលចិត្តខៀវឡឲ្យវិលមកចំណុះចុះចូលតាមស្រួលៗចុះ ចូរឆ្លូថា មិនបានប្រកាន់ទោសពៃអ្វីទេ បំរើកំកាន់សំបុត្រនោះទៅឲ្យខៀវឡ ឯស្រុកចាំតុង ។

ខៀវឡបានយល់សេចក្តីកូនសំបុត្រដូច្នោះ កំរេះតែគិតខ្លាចក្រែងចូរឆ្លូនឹងធ្វើកលទុច្ចរិតបញ្ឆោត ទើបប្រឹក្សានឹងខៀវអូយជាប្អូន តាមសេចក្តីសំបុត្រចូរឆ្លូនោះ ។ ខៀវអូយថា ឯចិត្តចូរឆ្លូនោះប្រកបដោយកលទុច្ចរិតប្រាកដច្រើនប្រការណាស់ ដែលនឹងចូលទៅលន់តួនោះ ខ្ញុំថាមិនយល់ឆន្ទៈទេ សុំឲ្យគិតតែរក្សាស្រុកចាំតុងទុកឲ្យគង់នៅចុះ បើចូរឆ្លូលើកទ័ពតាមមកនឹងបានតទល់ច្បាំងគ្នាជាមិនខាន ខៀវឡក៏ទទួលស្តាប់ពាក្យខៀវអូយជាប្អូន រៀបសុងកំលាបធ្វើសំបុត្រស្វាត់ ប្រើប៉ារើឲ្យទាំទៅឲ្យចូរឆ្លូឯស្រុកហាន់តុង ។

ចូរឆ្លូទទួលសំបុត្រនោះទៅមើល ឃើញសេចក្តីថា ខ្ញុំបាទរៀបសុងសូមគំនាប់មកដល់វុយកុងបានជ្រាប ដែលខៀវឡរឹងទទឹង មិនព្រមចូលមកលន់តួលោកនោះ ព្រោះខៀវអូយជាប្អូនទាំរឹងទទឹង សូមឲ្យលោកលើកទ័ពទៅកាយស្រុកចាំតុងចុះ ខ្ញុំបាទនឹងទទួលជាកលសឹកខាងក្នុង , ចូរឆ្លូឃើញសេចក្តីដូច្នោះក៏មានអំណរណាស់ ទើបចាត់ចែងកងទ័ពលើកទៅតាំងនៅជិតស្រុកចាំតុង ។

ឯខៀវឡុះដឹងថា ចូនធូលើកទ័ពទៅដល់កំប្រឹក្សាទីឆ្ងាយ ទាហានចាំឆ្ងាំឆ្ងល់ថា តម្រូវចូនធូលើកទ័ពមកយើងនឹងគិតការពារប្រការម្តេច ខៀវអួយថា ខ្ញុំបាទនឹងសុំអាសាលើកទ័ពចេញទៅច្បាំងនឹងចូនធូ ហើយខៀវអួយកំចាត់ចែងទាហានលើកចេញទៅ ។

ចូនធូឃើញដូច្នោះ កំប្រើទៅធូចេញទៅតនឹងខៀវអួយបាន ៥ ភ្លេង ទៅធូកំយកលំពែងចាក់ត្រូវខៀវអួយភ្លាក់ពីលើសេះស្លាប់ ទាហានចាំឆ្ងាំឆ្ងល់កំបែកគេចូលទៅប្រជប់ខៀវឡ ។ ដឹងដូច្នោះ កំព័យស្មូតស្មារតើ ទើបគេណែនាំទាហានឡើងរក្សាសើនបន្ទាយជាមាំមួន អៀវសុង់ឃើញដូច្នោះទើបក្លែងគេចនិយាយនឹងខៀវឡថា ដែលនឹងស្មៀម នៅដូច្នេះមិនស្រួលទេ ព្រោះសត្រូវមកតាំងនៅភ្នំខ្ពង់ជុំវិញស្រុកហើយ ខ្ញុំបាទនឹងសុំរក្សាស្រុកខុក ឯខ្លួនលោកត្រូវចេញទៅធ្វើសង្គ្រាមតនឹងចូនធូទើបសមគួរជាជាតិទាហាន ចាំឆ្ងាំឈ្នោះសម្លេងលោក កំនឹងលឺតទៅមុខវែងឆ្ងាយ ។

ខៀវឡមិនដឹងកលឧបាយ កំរៀបទាហានលើកចេញ ឯទាហានដែលចេញទៅជាមួយនឹងខៀវឡនោះ កំត្រឡប់វិលទៅនៅរក្សាត្រួតត្រួតក្នុងស្រុកវិញចាំឆ្ងាំអស់ ខៀវឡឃើញដូច្នោះកំរឹតតែតំយណាស់ ទើបញាក់សេះបែកត្រឡប់តេះទៅដល់ដើងកំដែងស្រុក ចូនធូឃើញដូច្នោះ កំលើកទាហានដេញតាមទៅ ។

អៀវសុង់នៅលើសើនបន្ទាយ ឃើញខៀវឡតេះត្រឡប់មកកំឲ្យ

ភាហានចំខ្ញុំស្រុកដ៏តន់ដ៏ចូលតុំបាន ចូរឃើញកំស្រែតៅខៀវឡាថា ខ្ញុំអ្នកឯងដ៏ដល់សេចក្តីស្លាប់ហើយគ្រានេះ បើប្រសិនជាចូលមកលន់តួ ចុះចូលយើងតាមសុភាព យើងក៏ទុកជីវិតឲ្យរស់នៅតៅ ។ ខៀវឡាឮដូច្នោះ ក៏លោតចុះពីលើសេះចោះអាវុធចេញពីដៃ ហើយដើរចូលទៅគាប់ចូតួ ។ ក៏មានចិត្តអាណិតអាសូរណាស់ ទើបនាំខៀវឡាចូលទៅក្នុងស្រុកជ្រាំតុង ហើយតាំងខៀវឡាឲ្យធ្វើជាចៅហ្វាយស្រុកជ្រាំតុង ចំណែកភាហានរបស់ខៀវឡានោះ ចូរកុំតាំងឲ្យធ្វើការតាមធំ-តូច តាមគុណចំណាច់ ។

ចូរប្រាប្រាមអាណាខេត្ត ដែលខ្លើងស្តាប់បង្គាប់ស្រុកហាន់តុងនោះកថាថាតាំងអស់ហើយ កំចែកចំណាច់ផ្ទាំនំពលភាហានតាមសមគួរ ហើយឲ្យគេហៅខ្ញុំអៀវសុងចូលទៅប្រាប់ថា ខ្ញុំអ្នកឯងជាមនុស្សលោកលាភសក្ការៈអតិតញ្ញូនិគុណគេពេកណាស់ ឃើញតែត្រឹមរបស់ខ្លួនជាមុខ គួរឬមកប្រែចិត្តក្បត់ខៀវឡាដែលមានគុណលើខ្ញុំន ម៉ើយើងនឹងចាញ់មេរក្សាខ្ញុំនជាពួកផងតៅមុខទៀត ខ្ញុំនកំតង់នឹងប្រែចិត្តគំតប្រទូស-ភយដល់យើង ៗ ទៅចូលខាងសត្រូវដូចជាគ្រាន់ឡូវនេះដែរ ថាហើយកំប្រើភាហានចាប់យកខ្ញុំអៀវសុងទៅចងធ្លាងតាត់ក្បាលសម្លាប់ចង់ ហើយយកក្បាលដោតផ្សាល់មុខឲ្យអ្នកតាំងភ្លងយកតម្រាប់តាម តាលចូរប្រាប់ប្រាមស្រុកហាន់តុងនឹងអាណាខេត្តដែលខ្លើងតាំងប៉ុន្មាននោះ មនុស្ស

តាំងពួងកំសត្មតហៅថាដែនខោះថាតាំងឈួន គឺជាផ្លូវដាច់ស្រយាលខាងទិសបូព៌ ។

សាមកុកខ្សែ ៥៦

តាំងពីសុមាអ៊ីពឲ្យលំឲ្យក្លូចលើកទ័ពទៅវាយយកស្រុកសែឈួន ក្លូចមិនក្រែង រហូតដល់ក្លូចឲ្យសម្លាប់ពួកនាម៉ឺនក្នុងស្រុកហ៊ូគោ ដែលផ្ញើយកត់ភ្លើងពួកល្បាត់ ៣០ នាក់ ។

ខណៈនោះ សុមាអ៊ីបានចូលទៅនៅនឹងក្លូចតាំងពីនៅស្រុកហ៊ូគោ ក្លូចឲ្យសុមាអ៊ីជាសមុហបញ្ជាកូនខាហាន ។ សុមាអ៊ីចូលទៅគាប់ក្លូចហើយថា គ្រានេះ វុយកុងលើកទ័ពមកកាយបានស្រុកហាន់តុងហើយ ខ្ញុំបាទក្តីត្តិសព្ទថា ខ្មៅតិបានស្រុកសែឈួនហើយ បណ្តាញាះខ្មៅដៀងចេញពីស្រុកទៅ អាណាប្រជាទុកស្តួតាំងពួងដែលនៅក្នុងស្រុកសែឈួននោះនៅមិនបានជាប្រក្រតីនឹងខ្មៅតិទេ ដែលលោកលើកទ័ពមកដល់ពីនេះហើយ កំជាផ្លូវដាច់ស្រយាលឆ្ងាយណាស់ បើនឹងលើកទ័ពត្រឡប់ទៅវិញក៏មិនគួរសោះ ការណាឡើយនឹងបានលើកមកទៀត សូមឲ្យលោកលើកទៅកាយយកស្រុកសែឈួនឲ្យបានក្នុងគ្រានេះតែម្តងទៅ រួចសឹមលើកត្រឡប់ទៅវិញ ។

ក្លូចឮដូច្នោះ កំធ្វើជាជកដង្ហើមធំហើយភ្ញែងថា ធម្មតាកើតមកជាមនុស្សនេះ ការដើមនឹងគិតថារកតែមួយ លុះបានរួចហើយក៏គិត

តំរើបនឹងរកឲ្យបាន ២តង្វើងទៅ ព្រោះសេចក្តីលោភ ជួបជាបានស្រុកហាន់តុងហើយថែមទាំងចង់បានស្រុកសែឈួនទៀត ស្រុកទាំងនេះសុទ្ធតែធ្លាប់ជាចំស្រយោលឆ្ងាយណាស់ ។

ឡៅហួថា ដែលសុមាអ៊ុនិយាយនោះ គួរប្រពៃណាស់ បើលោកនឹងបង្ក្អនឹងពុកឲ្យឃ្លេចៅ ខ្ញុំនេះតង់នឹងមានសតិបញ្ញារិះគិតបង្កាះបង្កាលបណ្តាកស្តេកក្នុងស្រុកសែឈួនឲ្យមានចិត្តប្រក្រតីស្រួលទៅ ទាំងគួនអ្វីទៀរហ៊ុយ ដូច្នឹង សឹងតែជាតាហានឯកនឹងតាហានក្រៅពីនេះក៏មានច្រើនអនេកណាស់ បើលោកនឹងលើកទៅវាយយកជាក្រាយក៏ដោយ រសេចក្តីលំបាក។ ចូរគួរតបថា យើងលើកមកគ្រានេះ ផ្លូវកំជាចំស្រយោលឆ្ងាយណាស់ ប្រការមួយទៀត ចានស្រុកហាន់តុងហើយ តាហានក៏កំពុងហត់ទៀយ ដែលនឹងលើកទៅវាយស្រុកសែឈួនទៀតនោះ យើងមិនទាន់ឃើញផងទេ ហើយក៏តាំងបម្រុងសេនាតាហានទៅកុងស្រុកចាំតុង ។

ឯអស់អាណាប្រជានុកស្តេកក្នុងស្រុកសែឈួន នឹងបណ្តាអាណាវ៉ែត្រដែលឡើងទាំងប៉ុន្មាន លុះបានដឹងកិត្តិសព្ទថា ចូរគួរលើកកងទ័ពមកវាយយកស្រុកហាន់តុងបានដូច្នោះ ទាំងអស់គ្នានោះក៏នាំគ្នាខ្លាចតក់ស្លុតភ័យខ្លាចចូរគួរពន់ប្រមាណ ក្រែងចូរគួរនឹងរុកពនទ្រានលើកទ័ពទៅវាយយកស្រុកសែឈួនទៀត ។ ឡៅតាជឹងថាបណ្តាកស្តេទាំងពួងតក់ស្លុតភ័ត

ក័យខ្លាចដូច្នោះ កំពត់គ្រោះស្លាប់ខ្លួនបេងថា បណ្តាភស្តុកង់ស្រុកយើង ខ្លាចបំបួនទឹងលើកទ័ពមកធ្វើអន្តរាយ ដូច្នេះលោកនឹងត្រិះរិះគិតប្រការម្តេច?

ខុងបេងថា នេះលោកកុំព្រួយចិត្តឡើយ ខ្ញុំនឹងគិតកល។ ជាយមិនឲ្យបំបួនលើកទ័ពមកធ្វើអន្តរាយដល់ស្រុកយើង នឹងឲ្យលើកទ័ពត្រឡប់ទៅវិញ ។ ឡៅពីសួរថា លោកនឹងគិតប្រការម្តេច? ខុងបេងថា ឯបំបួនោះ រមែងខ្លាចញាញើតស៊ុនកួនជាជាងប ជាន់ជាឲ្យហែហ្មងនឹងទៀវលៀវទៅឈរស្រុកហាប់ជ្រាំ តាលបំបួនលើកកងទ័ពមកយាយកស្រុកហាន់តុងនេះ ក័យកហែហ្មងមកជង ។ នេះសូមឲ្យលោកចាត់ប្រើប៉ើណាដែលមានតម្រេះប្រាជ្ញាឲ្យទៅនិយាយនឹងស៊ុនកួនថា ឡៅពីនឹងឲ្យស្រុកកាំងហែ ស្រុកទៀវសា ស្រុកហ៊ុយអៀងមកជូនលោកហើយញុះញង់ឲ្យស៊ុនកួនលើកទ័ពទៅកាយយកស្រុកហាប់ជ្រាំ បើបំបួនដឹងវេលាណា ក៏នឹងកង្វល់រវល់ចិត្តគិតលើកទ័ពទៅជួយគ្នាជាប្រាកជ ។

(នៅមានត)

ព្រះរាជនិពន្ធរាមកេរ៌

អារម្ភកថា

ស្រាវជ្រាវដោយ លោក ឌុ. គាម (ត)

ខ្ញុំដែលសង្ឃរាជ ព្រហ្មទៅកុំចក្រពាឡ ក្នុងចិត្តគ្រាថ្នាថ្នមចង់បានទាំងពួកទៅឲ្យលើសជាងទេវបុត្រទេវតា ព្រះឥន្ទព្រះព្រហ្មយមយក្សទាំងពួងហើយវាទៈសរ្សើរទៅគាល់ចំពោះព្រះឥសូរញុយ ។ ជាយូរខ្នាត់អង្វែងលុះមានសម័យថ្ងៃមួយ អសុរកំតិតក្នុងចិត្តថា អញខ្ញុំដែលទៅគាល់ព្រះឥសូរជាម្ចាស់សូមពរឫទ្ធិ អំពីព្រះអង្គឲ្យបានដូចសេចក្តីគ្រាថ្នាហោង ។ អសុរគិតហើយ កំណែងគ្រឿងប្រដាប់ស្រេចហើយ កំហោះទៅដល់កុំភែលាស ចូលទៅគាល់ព្រះឥសូរជាកំពូលកុំត្រើយហើយអសុរ កំក្រាបថ្វាយបង្គំទូលថា ខ្ញុំព្រះករុណានេះទៅសរ្សើរគាល់ហ្មាប់ព្រះបាទជាខ្ញុំព្រះករុណាកំមិនដែលប្រទានរបស់អ្វីឲ្យទានខោះកំគ្មាន ឥឡូវនេះខ្ញុំលព្រះបង្គំជាខ្ញុំសុំព្រះកដទានដំបងពេជ្រមួយ ហើយខ្ញុំពរកុំឲ្យអ្នកណាគប្បីបានឡើយ តាមតែទ្រង់ព្រះមេត្តាប្រោស ។ កាលខោះ អង្គព្រះសយម្ភូញាណបានស្តាប់ពាក្យអសុរ សូមដូច្នោះហើយ កំមានព្រះតាយខោះអាសូរកុំណាណាស់ ទើបប្រទានដំបងពេជ្រ ១ ហើយទ្រង់ប្រសិទ្ធពរឲ្យអសុរ ចូរអ្នកទាំងពួងកែដូចសេចក្តីគ្រាថ្នា ឲ្យឈ្នះអស់បច្ចាមិត្តទាំង ១០ ទិស កុំឲ្យមកតប្តឹងអាទុកាពន្ធិនអ្នកបានឡើយ ។ អសុរព្រហ្មកំក្រាប

ថ្វាយបង្គំខ្ញុំលុយយកដំបងពេជ្រនិងពរស្រេចហើយ កំមានចិត្តនោះត្រេក
អរណាស់ កំថ្វាយបង្គំលាហោះចាកស្ថានកៃលាស ហើយកំទ្រង់សំដែង
ឫទ្ធិអានុភាពលើមកស្ថានតិមានអាត្មាវិញហោង ។ ឈប់សូរ ។ នឹង
សំដែងពីព្រះបាទ មាលីវាគ្គព្រហ្ម លុះឃើញព្រះឥសូរជាម្ចាស់ទ្រង់
ប្រទានដំបងពេជ្រនិងពរឲ្យអាសុរព្រហ្មដូច្នោះហើយ កំមានចិត្តនោះភ័យ
ជាខ្លាំណាស់ គិតចិត្តអសុរនេះ វាគាបយោរយៅអប្រិយណាស់ វានឹង
ធ្វើបាបអស់ទេវលោកគ្រប់ស្ថាន ទ្រង់គិតដូច្នោះហើយ កំក្រាបទូលព្រះឥ
សូរថាដែលព្រះអង្គទ្រង់ប្រទានដំបងពេជ្រនិងពរទៅអសុរនោះ ខ្ញុំពជា
អ្នកចិត្តបាបឫស្យាមិច្ឆាទិដ្ឋិ ឃើញជាវានិងបៀតបៀនត្រៃលោក នឹងបាន
សេចក្តីក្តៅក្រហាយ ពុំនោះនឹងដល់ទៅព្រះបាទអដ្ឋបាលដែលត្រង់កជ្ឈ
ទៅខាងស្រីអយុធ្យាជាកតីនឹងតដៃនិងវាពុំបាន ដូច្នេះសូមទ្រង់ព្រះករុណា
ប្រទានទេពអាវុធបាន១ គ្រាន់នឹងបានបង្ក្រាបអសុរព្រហ្មតទៅ ត្រាយលោក
នឹងបានជាខ្លីពីធ្លព្រះបាទមើផង ។ កាលនោះព្រះឥសូរបានស្តាប់មាលីវាគ្គ
ព្រហ្មទូលដូច្នោះហើយ កំមានព្រះឫទ័យនោះតិតដល់ព្រះបាទអនោមាទន្ត
ជាអនិច្ចាអើយ វង្សព្រះនាគយណ៍នេះអញកំក្លេចសោះ កាលដើមឡើយ
អញបានឲ្យអនោមាទន្តសោយពជ្ឈទៅជម្ពូទ្វីប ឥឡូវនេះកំសុតតទៅទៅ
តែព្រះពជបុត្រឲ្យសោយពជ្ឈស្មង់គ្រប់ត្រង់នតតទៅ អញក្លេចសោះមា-
លីវាគ្គព្រហ្ម កុំតែឯងដឹងថាទើបនឹកឃើញ គ្រាសំហើយទើបឲ្យព្រះវ័នមួយ

ហើយប្រសិទ្ធីពរឲ្យឈ្នះលើដំបងពេជ្រអសុរព្រហ្ម ហើយក៏ឲ្យទៅមាលីវគ្គព្រហ្មយកទៅឲ្យព្រះចាន់អង្គជ្ញាលហោង ។ ព្រះចាន់មាលីវគ្គព្រហ្មក៏ទទួលយកព្រះខ័នទៅថ្វាយព្រះចាន់អង្គជ្ញាល លុះហោះទៅដល់ខនព្រះចាន់អង្គជ្ញាល នៅកណ្តាលអាកាស ចំពោះត្រង់បង្អួចខ្វារប្រាសាទ ហើយក៏ស្រែកប្រាប់ទៅថា ណែព្រះចាន់អង្គជ្ញាលអើយ ឥឡូវនេះព្រះឥសូរជាម្ចាស់ត្រាស់ប្រើយើងមក យកព្រះខ័នពេជ្រមួយមកឲ្យអ្នកហោង។ ព្រះចាន់អង្គជ្ញាលស្តេចទៅគង់នៅលើប្រាសាទអង្គុយលើបល្ល័ង្កពេជ្រកែវ ឮឮឮ

ប្រទានដំបងនិងពេជ្រនិងតារឲ្យវា រីឯសុរព្រហ្មនេះយើញថាវាធំជាងបៀត បៀនត្រីយលោកទាំង ៣ មិនតែម្នាក់ឡើយ វាធំមកបំផ្លាញដល់អ្នកខ្លាំង ទើបខ្ញុំក្រាបបង្គំទូលសុំព្រះទ័នពេជ្រឲ្យឈ្នះលើដំបងនិងពេជ្រអសុរព្រហ្ម ព្រះអង្គក៏ទ្រង់ប្រទានឲ្យខ្ញុំយកមកជូនអ្នក ។ ព្រះបាទអជ្ជុឋាលបានស្តាប់សព្វគ្រប់ហើយ ក៏មានព្រះទ័យខ្ពោះត្រេកអរណាស់និងព្រះគុណអ្នកជាទីបំផុត ហើយព្រះអង្គក៏បែរព្រះភក្ត្រ ត្រង់ទៅស្តាននៃលាសហើយក៏លើកដៃថ្វាយបង្គំទូលយកព្រះទ័នពេជ្រ ហើយមានភាពនិយាយនិងព្រះបាទមាលីវាគ្គព្រហ្មថា យើងទាំងពីរនាក់នេះសូមមេត្រីជាមិត្តនិងគ្នាដល់យាវជីវិតទៅហោង ។ កាលនោះ ព្រះបាទមាលីវាគ្គព្រហ្មទូលសច្ចាប្រណិធានិងគ្នា ហើយក៏លាវិលទៅស្តានអាត្មាវិញហោង ។

ទំនិងនិយាយពីអសុរព្រហ្មនោះ តាំងតែពីបានដំបងនិងពេជ្រវិលណាហើយ ក៏មានចិត្តខ្ពោះមិច្ចាទិដ្ឋិលោកលន់តន់ប្រមាណ តិតបង់ទៅបង្ក្រាបឲ្យកបដោយអំណាចឫទ្ធិអានុភាពទាំង ១០ ទិស តិតដូច្នោះហើយអសុរព្រហ្ម ក៏សំដែងឫទ្ធិហោះទៅកណ្តាលអាកាស ហើយស្រែកប្រកាសថា ខ្ញុំនអញឈ្មោះអសុរព្រហ្ម មានឫទ្ធិអានុភាពគ្មានអ្នកណាស្មើបាន ឥឡូវនេះអញនឹងបំផ្លាញត្រីយលោកទាំង ៣ ឲ្យវិនាសដោយឫទ្ធិអញហោង ។ វ៉ែស្រែកហើយក៏សំដែងឫទ្ធិដេញវាយអស់ទេវលោកគ្រប់ស្តាន ទាំងតន្ទ័នសុបណ្ណគ្រុឌមហាឥស្សរជាកោលាហល ។ រីឯអស់ទេវលោកគ្រប់ស្តានទូវ៉ៃ-

ព្យាធរកំន្ទរនាគតន្ទ័ពូ តន្ទន៍ សុបណ្ណគ្រុឌមហាឥសីពាំងអស់នោះ
កំព័យតក់ស្លុតរន្ធត់រត់ចោលស្ថានសីមាអាស្រមទៀត ។ ហើយមកប្រជុំគ្នា
ហោះទៅឯនគរព្រះចុតអដ្ឋបាល ទូលថាអសុរព្រហ្មកំណាចវាឡើង
ទៅធ្វើបាបយើងកាល់គ្នា ឥឡូវនេះវាទៅ ។ ពើងក្តៅកៃណាស សូមព្រះ
អង្គអញ្ជើញទៅបង្ក្រាបប្រាប់អសុរ ជួយរម្ងាប់ឲ្យត្រួយលោកបានសេចក្តី
សុខសប្បាយដោយបុណ្យបារមីព្រះអង្គហោង ។ ព្រះចុតអដ្ឋបាលបាន
ស្តាប់អ្នកពាំងអស់ទូលដូច្នោះហើយ កំនឹកក្រោធនឹងអសុរព្រហ្មណាស់
ព្រះអង្គក៏ស្តេចយាងទៅហោង លុះមកដល់ហើយ អសុរព្រហ្មកំត្រឡែក
ឃើញព្រះអង្គហើយ កំស្ទុះទៅឈរពាំងពាំងពីមុខរាជរថ ហើយកំស្រែក
ថា អ្នកណាកំអាចហ៊ានមកតវ៉ាខ្ញុំនឹងអញ មិនខ្លាចស្លាប់ខ្លួថាហើយ
អសុរព្រហ្មក៏ក្រេវក្រោធណាស់ កំស្ទុះហោះទៅថា ឯងនេះទាមកឈ្មោះ
អ្វី ជាតិឯងជាមនុស្សកំមានចិត្តអហ៊ាការមកតវ៉ាស្តា ត្រៃលោកពាំង ៣
កំថាក់បបួរបួរខ្លាចអំណាចបារមីប្អូនអញពាំងអស់ហោង ខ្លួនឯងនេះជា
មនុស្សតូចណាស់ ប្រៀបដូចអំពិលអំពែកកំហ៊ានមកផ្តាញ់ពាក្យព្រះអាទិត្យ
ដ៏វិតឯងឃើញជាក្បាយនឹងដៃអញពុំលែងឡើយ ។ រីឯព្រះចុតអដ្ឋបាល
បានស្តាប់ពាក្យអាសុរហើយកំខ្ញាន់ក្រោធ ទើបស្តេចមានព្រះបន្ទូលតប
ទៅថា ឯងឬឈ្មោះអសុរព្រហ្ម ឯងកុំអាលអួតប្អូនឲ្យឡើយ ឯងនេះប្រៀប
ដូចជាសត្វអម្រើតា កាលណាឡើយកំមកអួតចន់ប្រឡងប្អូនឯងស្តេចភជ

ស៊ីហ៍ដូចម្តេចជាន ខ្ញុំនអញនេះឈ្មោះព្រះបាទអជ្ជុឋាលធិបតីគ្រងបូរីស្រីអាយុធ្យាធ្លាកវត៌ មហាឥស៊ីទៅលោកគ្រប់ស្ថានបានអញ្ជើញអញមកប្រហារជីវិតអាឯងក្នុងគ្រានេះ ។ អសុរព្រហ្ម បានស្តាប់ហើយក៏ក្រវែល្រាជណាស់ ទាំងាត់សង្កើតឆ្នេញហើយក៏ស្ទុះទៅលើកដាវព្រះអង្គច្បាំងគ្នា លុះតតាំងគ្នាបន្តិចទៅ ព្រះបាទអជ្ជុឋាល ក៏ចាប់សម្លាប់អសុរព្រហ្មស្លាប់ទៅដោយឫទ្ធិបារមីព្រះអង្គហោង ។ ក្នុងគ្រានោះ អស់ពួកទេវលោកគ្រប់ស្ថាន បានឃើញវង្សព្រះនាកយណ៍សម្លាប់អសុរព្រហ្មស្លាប់ដូចសេចក្តីក្រុងថ្នាហើយ ក៏មានសេចក្តីខ្លោះត្រេកអរសាទរពេកក្រៃដែរស្រែកឲ្យស័ព្ទសាធុការឮរពរជ័យហើយ ក៏ចុះមកនៅញាសតាំងព្រះឆវីហោង ។ រីព្រះបាទអជ្ជុឋាលនោះលុះសម្លាប់អសុរស្រេចហើយ ព្រះអង្គក៏កាត់ក្បាលអសុរព្រហ្មយកមកដាក់ខ័ណ្ឌកនៃព្រះជវថ ហើយក៏ស្តេចបរកជវថហោះមកនគរវិញ ដល់ហើយក៏ស្តេចយកក្បាលអសុរព្រហ្មនោះមកដោតទុកនឹងសួនទ្រាន ហើយទ្រង់ដាក់បណ្តាសាឲ្យចាំសួនទ្រាន ដូចព្រះទេស្តព្រះអង្គថា ខ្មោចអសុរក៏នៅចាំរក្សាសួនព្រះអង្គហោង ។

និយាយពីព្រះបាទមាលីវត្តព្រហ្មមេតវង្សវង្សា ខ័ណ្ឌព្រះបាទតុរកក្តែដែលសោយរាជ្យនគរក្រុងលង្កាទ្វីប តាំងតែព្រះអង្គបានមិត្តរួមដំរែនឹងព្រះបាទអជ្ជុឋាលដែលគ្រប់គ្រងនគរស្រីអយុធ្យា តាំងចិត្តសុចរិតនឹង

គ្នា ទើបស្តេចឡើងទៅគាល់ព្រះឥសូរឯស្ថានកៃលាសបព៌ត ។ លុះមកដល់ហើយ ព្រមទាំងហ្វូងទេពទេវនិតន្នឹងកិន្នរនាគ តាបសឥសីប្រជុំព្រមព្រះចាតុមាលីវត្តព្រហ្ម ក៏ក្រាបថ្វាយបង្គំទូលទៅព្រះឥសូរថា ទូលព្រះបង្គំជាខ្ញុំសុំឲ្យមានមាត់ចិត្តដូចសេចក្តីប្រាថ្នា ។ កាលនោះ ព្រះសយម្ភូវនាថបានស្តាប់ហើយព្រះអង្គទ្រង់រំពឹងដោយចិត្តញាណទៅទ្រង់ជ្រាបថា ព្រហ្មនេះមានសេចក្តីកាន់សាសនាសុចរិតពិតត្រង់ គួរអញនឹងប្រសិទ្ធពរឲ្យ តិតហើយព្រះអង្គទ្រង់ប្រទានពរឲ្យសំរេចដូចសេចក្តីប្រាថ្នាអ្នកហោង ។ ហើយព្រះអង្គទ្រង់ឲ្យនាមឈ្មោះជាមាលីវាកជាវិញហោង ហើយឲ្យធំលើអសុរកាតគ្រប់ទាំងខេត្តទាំងអស់ហោង ព្រះចាតុមាលីវាកបានពរប្រសិទ្ធពីព្រះឥសូរហើយក៏ត្រេកអរ ក្រាបថ្វាយបង្គំលាវិលមកស្ថានអាត្មាវិញហោង ។

ខ្ញុំនឹងសំដែងពីព្រះចាតុសហមាលីវនយក្ស ដែលត្រង់ក្រុងលង្កាមកពីមុននោះ តាលវត្តុភ្លាចចក្រពេជ្រព្រះនាភយណ៍នោះ ទៅនៅឯជាតាលព្រះអង្គជាតូជពង្សវង្សនិងព្រហ្ម បានដឹងថាព្រះចាតុសហមាត្រ-ព្រហ្មចុះមកសាងនគរលង្កាទ្វីបជាថ្មីទៀត ឲ្យធនាព្រហ្មសោយរាជសម្បត្តិ ដែនាព្រហ្មនោះត្រូវជាតូជពង្សវង្សនិងគ្នាទ្រង់នាមថាព្រះចាតុចតុរភក្ត្រ នោះសហមាលីវនមានសេចក្តីត្រេកអរណាស់ តាំតបានធនាព្រហ្មនេះម្រះសើរណាស់ ទើបបានដាល់ក្សណ៍ដែនដីតពង្សវង្សត្រកូលដូច្នេះ គួរអញនឹងឡើងទៅឯក្រុងលង្កាទ្វីប តិតហើយក៏បង្គាប់ប្រាប់ទៅសេនា

អាមាត្យឲ្យរៀបបុស្បបុកវត្ថុកែវ ទឹងរហ៍ពលសកលយោធាស្រែច ស្តេច
ចាប់ដំបងពេជ្រហើយហៀរហោះមកដល់ក្រុងលង្កាទ្វីប ព្រះចាខតុរកត្រ
យើញព្រះសោយមកដូច្នោះ ហើយក៏ខ្ជួលតំទាប់គ្នា ហើយក៏ទាញដៃ
ឲ្យឡើងមកគង់បល្ល័ង្កជាមួយទឹងគ្នា រីសហាមលីនក៏ចបព្រះចាខតុរកត្រ
ហើយក៏ស្រក់ទឹកភ្នែកព្រះនេត្រា ត្រាស់ថាខ្ញុំនេះបានសេចក្តីលំបាក
គេកយ៉ាកណាស់ តួតអង្គព្រះនាកយណ៍លោកធ្វើបាបផ្តន្ទាមិនឲ្យដំនា-
ទីស ខ្ញុំបានជាធំនៅក្នុងក្រុងលង្កាទ្វីប បានជាខ្ញុំនាំគ្នារត់ទៅនៅឯនគរ
ក្រុងចាតាលវិញ លុះខ្ញុំបានដឹងដំណឹងថា ព្រះចាសហាមត្តមហាព្រហ្ម
លោកឲ្យចុះមកសាងនាទីលង្កាទ្វីប ឲ្យអ្នកមកគ្រងរាជសម្បត្តិជាថ្មីទៀត
នោះ ខ្ញុំមានសេចក្តីត្រេកអរមនស្សណាស់ទើបបានជាខ្ញុំទំរឭកមកកាន
សម្ងាញ់ ដោយសារខ្ញុំនាំគេមកគ្នាជាយូរអង្វែង ។ កាលនោះ ព្រះ
ចាខតុរកត្រ បានស្តាប់ព្រះចាសហាមលីនទូលរៀបរាប់តាំងពីដើមរៀងមក
មិនអាចនឹងទប់ទល់ដំកល់អាត្មាភាពពុំបានក៏សោយសោក រួចស្រែចក៏
មានវាចា អនិច្ចាអើយមិនត្រូវឲ្យដល់ម្ល៉ឹង ឯព្រះអង្គជាតង្ស្រាង្សព្រហ្ម កំ
ព្រះអង្គមានសេចក្តីព្រួយត្រង់ចិត្តត្រី បានចុះមកកសាងក្រុងលង្កាទ្វីប
ទៀត ឲ្យខ្ញុំមកសោយរាជ្យតពួជតង្ស្រាង្សក្នុងនគរក្រុងលង្កាទ្វីបទៅហោង
ប្អូរអ្នកអញ្ជើញមកនៅជាមួយនឹងខ្ញុំ ទឹងបានបំរុងរក្សាអាណាចក្រជាសុខ
ក្សេមក្សាន្តក្នុងខែត្រទ័ណ្ឌព័ទ្ធសេមាលង្កាទ្វីប ។ ព្រះចាសហាមលីនេ

ចានស្តាប់ហើយក៏មានសេចក្តីត្រេកអរដូចចានចំពោះមកសេពសោយ កំ
ព្រង់នុបព្រះចាខចតុរកក្តែជាសម្ងាញ់ថា ខ្ញុំអរគុណនិងអ្នកហើយ តទៅ
នេះខ្ញុំគ្មានរបស់អ្វីជូនសម្ងាញ់ មានតែបុស្បកតែមួយនេះមានឫទ្ធិវិសេស
ណាស់ ជូនសំណាញ់ឯង ពុកជាកើតក្នុងព្រៃនគរឯទៅមុខពុកនឹងជំនួស
ខ្លួនខ្ញុំ ឯបុស្បកតែនេះ រៀវតែសត្រូវមេម៉ាយនោះដុះហើយ មិនអាណាត
លឿនទៅឡើយ តែក្រៅពីនោះតាមចិត្តប្រាថ្នា ខ្លួនឯងទៅទីស្ថានណាក៏
ដូចចិត្តប្រាថ្នាហោង ។ ព្រះចាខចតុរកក្តែ មានព្រះទ័យនោះត្រេកអរក្រៃ
ណាស់ ខ្ចូលយកបុស្បកតែមណីហើយថាសម្ងាញ់ឲ្យខ្ញុំ ។ អរគុណ
ព្រះគុណអ្នកណាស់ ។ ស្រេចហើយសហាយលីវនកំលាត្រឡប់លែមក
កាន់នគរវិញហោង ។ ព្រះចាខចតុរកក្តែយកក្បាសោយកដសម្បត្តិចាន៦
ម៉ឺនខ្នាក់ក៏សុវណ្ណគតទៅ ឯាត្សខ្មៀនជាព្រះកដបុត្រចានគ្រង់កដ្បាសោយ
សម្បត្តិជាធំក្នុងក្រុងលង្កាទ្វីប មានមហេសី ៥ អគ្គសុទ្ធតែគ្រង់លក្ខណ
នាមនាងជាធំនោះនាងជាវីសុមន្ទា បន្ទាប់នោះឈ្មោះនាងចិត្តមាលី មួយ
មកខ្មៀតឈ្មោះនាងសុវណ្ណមាលៃ មួយមកខ្មៀតឈ្មោះនាងប្រវៃសុ
មួយឈ្មោះនាងវជ្ជតារើ គ្រប់ចាំង ៥ នាក់សុទ្ធតែមានរូបឆោមឆាយល្អ
ស្អិតដូចទេពកញ្ញាធិតាស្រីស្ងួតិ ព្រះចាខឯាត្សខ្មៀនសោយកដក្នុង
ក្រុងលង្កាទ្វីប ទ្រង់តេជានុភាពឫទ្ធិខ្លាំងសាយសព្វជាទី ព្រះអង្គគង់
ជាសុខក្សេមក្សាន្តរៀងទៅហោង ។ កាលនោះ ព្រះចាខមាលីវកដដែល

ស្ថិតនៅតំពូលភ្នំយតហ្វារ មានសេចក្តីរលឹកនឹកដល់ព្រះឃោសតុរកក្រុងវេស្សន្តរ តិតហើយព្រះអង្គក៏ហោះបុះមកគាន់តរលឹកខ្លី ។

(សូមចាំអានភាគ ២ តទៅទៀត)

១៥- រឿងកូនអូដ្ឋ

Le Petit chamelon (Conte mongol)

លោក ភ៉ាយ-ប៊ិក ប្រែពីភាសាចាវ៉ាង

(ក)

មានសេដ្ឋីម្នាក់ចានរៀបរៀបហាមន្តីលការបុត្រ័ខ្លួន ឧដ្ឋបុត្រានៃនាហ្នឹង ធំម្នាក់ ហើយចានប្រគល់ទ្រព្យចំណែងដែលជាសត្វអូដ្ឋ ស ១០០ ក្បាល ។ បណ្តាអូដ្ឋទាំងឡាយ មានកូនអូដ្ឋមួយដែលគេផ្តាច់ដោះពីមេវ តាមគៅជាមួយឥង ។

មេអូដ្ឋនឹកកូនខ្លួនដែលឃ្លាតចាកគៅទីឆ្ងាយ កូនអូដ្ឋក៏នឹកមាតាពន់ពេកណាស់ដែរ ! ។

ដល់កូនអូដ្ឋនោះដើរចានបន្តិច ក៏រត់ចេញពីហ្វូងអូដ្ឋទាំងឡាយមានចំណែងតែមួយ : ចង់ជួបនឹងមេវ ។ កូនអូដ្ឋនោះគំបោលយ៉ាងប្រញាប់ប្រញាល់ រេះគេចផ្រកនឹងដើមត្រែង ផ្ទៀងត្រចៀកស្តាប់ត្រែងតេមកតាម។

កូនអូដ្ឋនឹកសប្បាយក្នុងចិត្តថា : «ជាការស្រួលពន់ពេកដោយចានដេកនៅលើខ្នងមាតា ក្រឡេកមើលត្នែកមាតាភ្លឺដូចព្រះអាទិត្យព្រះចន្ទ ត្រចៀកទូទឹកដោះមាតាមានទុជារសាយ៉ាងត្រែលែង . . . » ។

កំពុងតែគិតដូច្នេះ កូនអូដ្ឋនោះស្រាប់តែជួបប្រទះនឹងបឹងមួយធំ ដែលខ្លួនមិនអាចនឹងឆ្លងទៅត្រើយម្ខាងចាន ។

កូនអូដ្ឋឈរនៅត្រង់ មិនដឹងជាទឹកគិតយ៉ាងណា . . . ស្រាប់តែមានត្រីមួយធំផុះពីបឹងនោះមក ។

ត្រីធំនោះមានសមានចិត្តចំពោះកូនអូដ្ឋនោះ ក៏ឲ្យកូនអូដ្ឋដុះលើខ្នងខ្លួនធ្វើជាបឹងនោះនៅត្រើយម្ខាង ជានស្មុះក្បែរក្បាល . . . ។ តែការស្មុះនេះ កូនអូដ្ឋជានតែមួយភ្លែត ហើយត្រូវប្រទះនឹងគ្រោះថ្នាក់មួយទៀតយ៉ាងធ្ងន់ គឺមានអ្នកឃ្វាលអូដ្ឋមួយចាប់យកទៅ ។ អ្នកឃ្វាលអូដ្ឋនោះ ជានយកកូនអូដ្ឋទៅចងភ្ជាប់នឹងអូដ្ឋធំមួយ តែកូនអូដ្ឋនោះនឹកមេជានខ្លោចក៏ចេះតែស្រែកហៅ ។

អូដ្ឋធំនោះជានឮកូនអូដ្ឋតិណានា អំពីរឿងព័ត៌មានសព្វគ្រប់ ក៏មានសមានចិត្តព្រមចាំងក្រុណាចំពោះកូនអូដ្ឋ ក៏ទាំងខ្លែងដែលចងកកូនអូដ្ឋ ក៏បណ្តាយឲ្យកូនអូដ្ឋតេះទៅរកមេចុះ ។

កូនអូដ្ឋទំណោលតេះចាកចេញពីទីនោះទៅដល់តន្លែងមេ ។

អូដ្ឋជាមេដោយនឹកកូនជាន់ពេក ក៏ទៅជាឈឺដឹកស្លាប់ខ្លួន ។ ដេកទៅលើស្មៅមេអូដ្ឋមានទឹកភ្នែកហូរហៀរសស្រាកហើយពោលថា :

« ម្តាយជឹតស្លាប់ហើយកូន ! តែក្រោយដែលម្តាយស្លាប់ទៅ ចាយចំខៀតមានតណ្ហាជាតិ ចាំដើមដុះលើក្បាលម្តាយ ។ កូនឯងយកតណ្ហាជាតិនោះមួយដើមពុះជាបីបម្រែក ហើយឯងចរកោតទៅ ។ រួចកូនឯងដើរទៅទិសខាងដើង ដើម្បីនឹងទៅនៅជាមួយចងឲ្យឯង ។ ឯបងឲ្យឯង

នោះតូចតែមានសក់កវែង ហើយភាមានសម្បុរពណ៌ស ដូចជាកូនឯង
ទើងម្តាយដូច្នោះ ។ ឯងរស់នៅជាមួយនឹងបងប្អូនឯង ហើយឯងនឹងបាន
សុខមួយជីវិត ។

« តែត្រូវឯងចាំបណ្តាំម្តាយកុំភ្លេច ! បើឯងទៅរកបងប្អូនឯង ឯង
កុំត្រូវដេកនៅលើកំភួច ។ ប្តូនៅទីកន្លែងដែលមនុស្សបោះដំរែសម្រាក ត្រូវ
តែកូនឯងដេកខាងក្បែងបន្លើកំភួច ។ នោះទើបសុខ ។ ម្យ៉ាងវិញទៀតបើឯង
បានទៅដល់បងប្អូនឯងហើយ ឯងត្រូវដើរចំកណ្តាលហ្វូងតទៅទៀត » ។

ក្រោយដែលបានប្តូន្មានបុត្រដូច្នេះម្តាយកូនអូដ្ឋនោះ ក៏ទទួលមរណ
ភាពទៅ ។

ម្តាយកូនអូដ្ឋស្លាប់បានបីថ្ងៃ មានតិណ្ណជាតិបីដើមដុះលើក្បាលនោះ
កូនអូដ្ឋក៏ជកតិណ្ណជាតិទាំងបីដើមមកបរិភោគ ហើយធ្វើដំណើរទៅខាង
ដើង ដើម្បីនឹងស្វែងរកអូដ្ឋជាបងប្អូនរបស់ខ្លួន ។

តែកូនអូដ្ឋនេះមានចរិយាថ្លៃថ្នូចង់ពិសោធលមើលបណ្តាំម្តាយ ក៏គិត
ថា :

« អញចង់ដេកមួយយប់នៅលើកូនភ្នំនេះ តើវាយ៉ាងណាទៅ » ។

នៅលើកូនភ្នំនោះ មានពពួយបក់ប្លោកខ្លាំង ហើយមានអាកាស
ត្រជាក់រងាពន់ពេក ។

កូនអូដ្ឋនឹកដល់បណ្តាំម្តាយ « ព្រោះហេតុដូច្នេះ បានជាម្តាយអញ
លោកមិនឲ្យអញដេកលើកំពូលភ្នំភួចនេះ » ។

តែកូនអូដ្ឋនេះ នៅតែមានមនោមានះតិតថា : « អញ្ចាចដំដេកនៅជិតជំរំមនុស្សស្រមាក » ។ រួចកូនអូដ្ឋនោះក៏ធ្វើតាមដែលខ្លួនគិត ។

តែក្នុងពេលយប់នោះ មានសត្វតិរច្ឆានជាច្រើនមករកសំណល់អាហារ ទាំងឆ្កែនេះដេកមិនបាន ។

កូនអូដ្ឋនឹកដល់បណ្តាំម្តាយ ។

« ព្រោះហេតុដូច្នោះបានជាម្តាយអញបានផ្តាំអញថា កុំឲ្យដេកនៅជិតជំរំមនុស្ស » ។

យប់ទីបីកូនអូដ្ឋ នៅដេកលើដំហៀងក្នុងខាងក្រៅ ។ យប់នោះកូនអូដ្ឋដេកលក់ស្រួលគ្មានអ្វីជាទុក្ខសោះឡើយ ។

ថ្ងៃទីបួនកូនអូដ្ឋនោះ បាននៅដល់ហ្វូងអូដ្ឋ ដែលមានបងប្អូនខ្លួននៅកងហ្វូងនោះ ។

តែកូនអូដ្ឋនៅគិតថា :

« ហេតុដូចម្តេច បានជាម្តាយបង្គំអញឲ្យដើរតាមក្រោយបងប្អូនអញ ហើយត្រូវតែដើរចំកណ្តាលហ្វូងអូដ្ឋតាំងពីយប់នោះជាការចាំបាច់ »។

កូនអូដ្ឋនោះ ត្រេចទៅពីមុខហ្វូង ហើយត្រូវពួកអូដ្ឋជាមេហ្វូងទាំពីខាងក្រោយ ។

ក្រោយមកទៀត កូនអូដ្ឋនោះដើរពីក្រោយហ្វូងវិញ ហើយមានកូនអូដ្ឋញីមួយទាំពីក្រោយទៀត ។

លំដាប់តមក កូនអូដ្ឋនោះដើរទៅខាងដំហៀងហ្វូងនោះ កិត្រៃបំរះលើឆ្អឹងភ្លាច់ហុយចូលក្នែកស្ទើរខ្វាក់ ។

កូនអូដ្ឋខើចដឹងខ្លួនជាក់ច្បាស់ ថា ឥឡូវម្តាយថាឲ្យអញដើរចំកណ្តាលហ្វូងជាវាចាមានសារៈសំខាន់ ហើយពីថ្ងៃនេះតទៅត្រូវតែអញដើរចំកណ្តាលហ្វូងតរៀងទៅ ។ តាំងពីគេលនោះមកដំណើរការណ៍បានស្រួលសុខសប្បាយ គ្មានអ្វីជាទុក្ខសន្តមកកាំឥតបានឡើយ ។ បងប្អូនរបស់កូនអូដ្ឋនោះកើតចាំចាប់បានស្មៅបរិភោគដ៏បរិបូណ៌ ឆឹតឆែកបានតាមចំណង់ ហើយថែមទាំងបានសង្វាតរឿងកាំរៃដែលអូដ្ឋជាបងប្អូនបានខិតខាន់ច្រាប់ ។ កូនអូដ្ឋរស់នៅជាមួយបងប្អូនជាសុខក្សេមក្សាន្តជានិរន្តរ៍តរៀងទៅ ។

កូនអូដ្ឋនឹកកង់ចិត្តថា : « វាចាម្តាយជាវាចាប្រកបដោយគតិបណ្ឌិត ខ្ញុំសូមសំដែងចំពោះមាតាខ្លួនតគ្គញ្ញតាធម៌យ៉ាងជ្រាលជ្រៅ » ។

រឿងនេះបានតតំដូចខាងក្រោម : « ឥឡូមាតា បណ្ឌិតលោកថាប្រយោជន៍និរន្តរ៍ បានសុខសួស្តី ផលស្លក្រែចគ្រាន់ វាចាសោភ័ណគួរគាន់ឱ្យខ្ជាប់ » ។

ចប់រឿងព្រេងលេខ ១៥ រឿងស្តីពីកូនអូដ្ឋទៅមាន « រឿងលេខ ១៦ សេចក្តីយុត្តិធម៌ ទើងប្រាក់ » តទៅខ្មែត ។

ទំនៀមទម្លាប នៃទេមរជាតិ
ខ្មែរគួរថ្នឹឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

រឿងព្រេងបឹងពេ

(នៅខេត្តកំពង់ស្ពឺ)

លោក លី-ជាមគេង

សមាជិកក្រុមជំនុំ ទំនៀមទម្លាប់រៀបរៀង

នៅក្នុងឃុំសង្កែសាខប ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មានត្រពាំង
មួយ អ្នកស្រុកហៅថាត្រពាំង «ឫទីរតេ» ។ ត្រពាំងនេះមានលក្ខណៈ
ប្លែកដែលនាំឲ្យអ្នកស្រុកជិតខាង និងអ្នកដំណើរណាដែលបាននៅជល់ទី
នោះ ចាប់អារម្មណ៍គ្រប់ៗគ្នា ។ ទំហំត្រពាំងមិនជាធំប៉ុន្មានទេ ប្រ-
មាណជាមាត់ទន្លេ១០០ម៉ែត្រប៉ុណ្ណោះ ។ មាត់ត្រពាំងជុំវិញ មានកក់
ដុះខ្ចាត់ខ្ចាប់តុំដែលសត្វជាតុណាមួយចូលទៅស៊ីក្រកខ្សែយ ឯដីត្រង់ដុះ
កក់នោះមានសភាពទន់ជ្រាយល្មមដើរបាន ឥតជ្រុងដើងទេ តែទៅជល់
កណ្តាលត្រពាំង បែរជាមានត្រើបមួយដុំដុះស្មៅខ្លះកក់ខ្លះ ហើយដីនោះ
ជាកក់ល្មោកស្មោះ ។ បើគេចង់ធ្វើនត្រើបនេះ គាល់តែយកឈើវែង ។
ជាក់តង រួចដើរស្ទួតលើឈើនោះទើបបាន ។ មានអ្នកស្រុកនិយាយ
បន្ថែមទៀតថា កាលដំនាន់ចាក់ឥតនៅជាអាណាព្យាបាលប្រទេសខ្មែរ

កាលនោះ ចាក់ងងឹតពន្លឺតិត្យមើលប្រដូចនឹងធ្វើស្ពានគួង ហើយបុកសរសេរ
ស្ពានចំកណ្តាលត្រង់ងងឹតនោះ ។ ពេលនោះគេឃើញមានដូចជាផ្សែងចំ-
ហាយហុយ ។ ចេញពីត្រឹបនេះមក ។ លុះពន្លឺតិត្យសង្កើតក្នុងត្រឹបកណ្តាល
នេះទៅ ឃើញមានថ្មដុំមួល ។ ជារច្រើនដុំ សំបកស្រាក្រហម ។ រៀប
ដូចជាថ្មបាយក្រៀម ឯសាច់ថ្មខាងក្នុងពណ៌សក្អុះ ហើយទៅចន្លោះ ។
នោះមានទឹកថ្លាហូរវហែង ។ ចេញពីនេះថ្មមកផង ។ តំកេងការស្ថាបនា
ស្ពាន ពីដំនាន់នោះក៏ពុំបានសម្រេចឡើយ ។

ដោយឃើញមានលក្ខណៈប្លែក ។ ហើយជាធម្មតា នៅស្រុកខ្មែរ
យើង តែមានទឹកទន្លែងពីបូកណាប្លែក ។ យ៉ាងនេះ ប្រាកដជាមានរឿង
ព្រេងនិទានប្រចាំទឹកទន្លែងនោះជាមិនខាន ហេតុនេះ ក្រុមដំនុំចំនៀម
ទម្លាប់ខ្មែរ ដែលត្រូវកែរកឯកសារដើមសល់ពុក កំបានអំពាវនាវស៊ើបសួរ
រករឿងព្រេងស្តីពីត្រង់ងងឹតនេះឡើង ។ ជាក់ពូល្អ លោកជា-ញុញ
ស្នងការប៉ូលីស លោកបានយកចិត្តទុកដាក់រករឿងនេះផង ព្រោះ
លោកធ្លាប់ទៅឃើញផ្ទាល់ខ្លួនក្នុង កាលដែលលោកទៅបំពេញមុខការ
នៅខេត្តកំពង់ស្ពឺ ។ មិនយូរប៉ុន្មានលោកយកប្រជាប់ថតសំឡេងមួយ
មកចាក់ជូនក្រុមដំនុំស្តាប់ ដែលលោកបានថតសំឡេងរបស់លោក ខូច-
ក៉ន់ ភ្នាក់ងារប៉ូលិសក្រុងកំពង់ស្ពឺ ខ្លះនៅហូរវែងអំពីរឿងព្រេងចំងងឹត ។
ដំបូងលោក ខូច-ក៉ន់ ជញ្ជាក់ពីពេលវេលាថា កាលនោះលោកត្រូវ

រាជការខេត្តបានចាត់ឲ្យលោកទៅចំពេញបេសកកម្មតាមស្រុក ឃុំ ឥតមានជាមួយដំណើរពិនិត្យការនៃលោកប្រមុខខេត្ត ។ ពេលយប់មួយនៅសំណាក់ក្នុងឃុំសង្កែសាខប លោកក៏បានសួរទៅអ្នកស្រុកដែលមកចោមរោមថា តូមីងណាចេះចាំរឿងព្រេងអ្វីសុំនិទានមក ចែកចាយគ្នាស្តាប់កែអង្សុក ។ កាលនោះមានតាម្នាក់អាយុ ៧០ ជាយបានឆ្លើយថា គាត់ចេះរឿងត្រពាំងជីជីតេ ព្រោះគាត់ធ្លាប់ស្តាប់ម្តាយគាត់និទានពីដើមមក ។ រឿងនោះ មានសេចក្តីជាសង្ខេបដូចតទៅនេះ ៖

កាលពីបុរាណត្រង់ត្រពាំងយូរយារណាស់មកហើយ មានសេដ្ឋីម្នាក់មានទ្រព្យយ៉ាងស្តុកស្តម្ភ រស់នៅមានកូមិការត្រង់ត្រពាំងជីជីតេនេះ ។ សេដ្ឋីពាំងពីនោក់ប្តីប្រពន្ធ ពិតមែនតែសម្បូណិសម្បត្តិទ្រព្យមែនហើយ ប៉ុន្តែមានចិត្តកំណាញ់ពន់ពេកណាស់ ។ គោនសម្បត្តិចូលមកពាំងអម្បាលម៉ានមិនដឹងយកចំណាយឲ្យរបៀបនៅឡើយទេ ពោះបីការចំណាយនោះជាការពាំបាច់យ៉ាងណាក៏ដោយ ហើយពុំសូវចេះយោគយល់មុខអ្នកក្រឡត់ពាំងឡើយផង ។ សេដ្ឋីមានកូនពីរនាក់ ប្រុសមួយ ស្រីម្នាក់ ដែលជាទីស្រឡាញ់ទៀងចិត្តណាស់ ទៅណាមកណាម្តង ។ មានរាល់ពិរោះដែលបិទមាសដាំពេជ្រដាំត្បូងក្តីក្តីដូនម្តេ ជាយានយ៉ាងប្រសើរនាំឲ្យអ្នកស្រុកខ្លួទៅ យល់ហើយទឹកស្ទើចដល់គោនសម្បត្តិនៃសេដ្ឋីនេះពន់ពេកមានមនុស្សដាប់ពាក់រាប់ ៩០០ នាក់ ត្រមាំងគោ រាល់ សេះ ជាង ៩០០

ម្ហូយមុខ ។ ជាជនជាន់ផង ។ នៅក្នុងស្រុះខាងក្រោយផ្ទះដែលមានទឹកថ្លាច្រើន សម្រាប់ជាទីសម្រាកលំហែទុក្ខសោកនៃគ្រួសារសេដ្ឋីនោះ មានចិញ្ចឹមក្រពើមួយយ៉ាងធំ ។ ប្រុបមាត់ស្រុះមានដំបូលមួយកន្លែងដែលជាទីតាំងខ្លួនអ្នកតា រក្សាក្រពើរក្សាភូមិភរនោះជាំដូល ។ គ្រួសារសេដ្ឋីក្តី គ្រួសារអ្នកត្រៀងលានជិតខាងក្តី តែងមកបែបបន់អ្នកតានេះឲ្យបានសម្រេចសមប្រាថ្នារៀង ។ ខ្លួន ។

ថ្ងៃមួយសេដ្ឋីនិយាយពាក្យនឹងភរិយាថា ៖

- នែកាណាអើយ ! កូនប្រុស កូនស្រីយើង ធំល្មមមានគូស្រករៀងខ្លួនហើយ ប៉ុន្តែខ្ញុំគិតទៅឃើញថា បើយើងទៅដណ្តឹងកូនអ្នកដទៃមកផ្សំផ្គុំនឹងកូនប្រុសយើង ឬទុកកូនស្រីយើងឲ្យជាគូនឹងអ្នកដទៃទៅ ឃើញថាយើងពិតជាពិបាកខាតបង់ចែករំលែកទ្រព្យសម្បត្តិជាមិនខាន ។ ហេតុនេះ កុំឲ្យពិបាក គួរតែរៀបផ្សំផ្គុំកូនប្រុស កូនស្រីយើងជាប្តីប្រពន្ធតែម្តងទៅ ដើម្បីទៅថែទាំសម្បត្តិយើងតទៅកុំឲ្យពិបាក ។

ប្រពន្ធកាលបើបានស្តាប់ហើយ សមនឹងចិត្តមច្ឆរិយៈគំណាញ់របស់គាត់ផង ក៏ព្រមព្រៀងតាមប្តី ហើយក៏ចាត់ឆ្មើរពេងក្រសាលអញ្ជើញក្មេរៃដ៏តង្វាយមកក្នុងពិធីអាពាហ៍ពិពាហ៍កូនប្រុសស្រីនេះ ។ កាន់តែជិតដល់ថ្ងៃណាស់ហើយ ប្រពន្ធសេដ្ឋីនឹកស្មានប្រាក់កាសដែលនឹងចំណាយទិញម្ហូបអាហារក្នុងគេលរៀបការកូន ទើបគាត់នឹកឃើញគំនិត

មួយ និយាយពាក្យទៅប្តីវិញថា ៖

-ទុកណាអើយ ! ក្នុងពេលរៀបការកូនយើងនេះ ខ្ញុំស្តាយប្រាក់ការសងគេញូវមួយអាហារណាស់ បើយើងកាប់គេក្របីក៏យើញថាខ្ជិលខាតសត្វដែលជួយធ្វើការកសិយើងដែរ ។ ដូច្នេះ ខ្ញុំយល់ថា បើយើងសំឡាប់ក្រពើដែលយើងចិញ្ចឹមនៅក្នុងស្រះក្រោយផ្ទះ យកសាច់វាមកធ្វើម្ហូបលៀងភ្ញៀវវិញ ខ្ញុំយល់យើញថាមិនខាតបង់ឡើយ ព្រោះសត្វថ្លៃក្រពើគ្មានបានជួយការកសិអ្វីយើងទេ !

សេដ្ឋីឮពាក្យប្រពន្ធ ពេញចិត្តណាស់ ទើបម្ចាស់ឲ្យអ្នកបំរើប្រុងការសំឡាប់ក្រពើយកសាច់ធ្វើម្ហូបតាមគំនិតប្រពន្ធគិត ។

និយាយពីជាស្រីម្នាក់របស់សេដ្ឋីឈ្មោះនាង តី ដែលជាអ្នកឲ្យអាហារដល់ក្រពើ រាល់ថ្ងៃ ឃប់មួយនាងឃើញសប្តីយើញអ្នកការក្អួរក្រពើប្រាប់ថា «តីឯងកុំស៊ីការកូនសេដ្ឋីឲ្យសោះហ្នា៎ ព្រោះការនេះគេកាប់ក្រពើយកសាច់លៀងភ្ញៀវហើយ ហើយតីឯងចាំមើលចុះ អ្នកណាស៊ីការនេះខ្លះនឹងយើញខាន់ហន់ក្បាលជាមិនខាន» ។ នាងតីភ្ញាក់ផ្អើលសញ្ជឹងគិតតែម្នាក់ឯង ។ លុះដល់ថ្ងៃគេរៀបការគេត្រឹកគគ្រែង មានភ្ញៀវជិតឆ្ងាយមកអ្វីអ្វ នាងតីគេចវេះចេញពីផ្ទះបាត់ទៅ ។ ពេលកំពុងស៊ីផឹកអឺកធឺកជួបជុំគ្នានោះ ស្រាប់តែព្រះឆវីស្រួតចាំងរែងចំត្រង់ផ្ទះសេដ្ឋីដែលកំពុងការកូន លិចបាត់អស់ទៅ ។

នាងតាំងបើយើញហេតុកេតអស្ចារ្យដូច្នេះ នាងព្រួយចិត្តរលឹកអាល័យដល់ចៅហ្វាយក្នុង។ ពាំងពីរនាក់ដែលធ្លាប់មានចិត្តសន្តោសមេត្តាដល់ខ្លួនកាលពីមុនរៀងមក។ ស្វាងពីសោកហើយ នាងនឹកដល់គុណអ្នកតាដែលបានមកជ្រាបនាងឲ្យដៀសផុតពីគ្រោះថ្នាក់ ។ ម្ល៉ោះហើយនាងក៏ទៅគោរសក់ថ្វាយអ្នកតា ជាការតបស្នងសងគុណអ្នកតាវិញ ។ មុននឹងគោរ នាងបុះទៅក្នុងស្រះកក់សក់ឲ្យជោក គឺស្រះជាលំនៅរបស់ក្រពើប្រុសនឹងខ្លួមអ្នកតា ។ ហេតុនេះហើយបានជាស្រះនេះ សព្វថ្ងៃអ្នកស្រុកហៅថា «ត្រពាំងកក់» គឺជាត្រពាំងដែលនាងតាកក់សក់ ។ រួចនាងឡើងទៅលើខ្នងគោរសក់ទៀត បានជាខ្នងនេះគេឲ្យឈ្មោះថា «ខ្នងគោរសក់នាងតា» ហើយហៅក្លាយ ។ មកថា «ខ្នងគោរតាតី ។ » ជាប់រហូតសព្វថ្ងៃ ។ ដោយនឹកអាល័យម្ចាស់ស្រី·ប្រុសពុំមានភ្លេចនាងតាក៏ទៅតាំងលំនៅ នៅកែវតន្ទែងព្រះធរណីស្រុកបវេសដ្ឋ ហើយដែលស្រុតទៅជាត្រពាំងធំមួយ គឺជាត្រពាំងដែលគេហៅថា «ត្រពាំងចឹងតេ· សព្វថ្ងៃនេះ ។ មិនយូរប៉ុន្មានមានបុរសម្នាក់មកតាក់ទងនឹងនាងតា ធ្វើជាប្រពន្ធបានទៅជាមួយគ្នាជាសុខសាន្ត ប្រកបរបរជាំដំណាំផ្សេងៗ ។ លុះនាងតាមានផ្ទៃពោះបាន ៦ ខែ បុរសនោះក៏នឹកឃើញខឿយណាយក្នុងកងទុក្ខកង្វល់លោភ័យ ក៏លួចរត់ចោលប្រពន្ធទៅជួសធ្វើជាអ្នកសង្គ្រាមទៅឯភ្នំខ្មោល ។

ចំណែកខាងតីនាងនៅតែម្នាក់ឯងហូតដល់ត្រប់ខែហើយ កំសត់-
ក្រលប្អូនកូនប្រុសមួយ ។ រៀលប្រសូតបុត្រអ្នកកូមិដតខាង មកដួយអប
អរសាទរ កំសន្ធតខាមកូនប្រុសនេះថា « បុត្តកុមារ » កាលបើប្អូនចំរើន
វ័យបាន ១៣ ឆ្នាំ បុត្តកុមារចេះតែសួរវេកម្តាយ លុះញឹកញាយតេកម្តាយ
ក៏ប្រាប់ត្រង់ថាវេឪពុកឯងនៅបួសចម្រើនភាវនានៅភ្នំឡោលនោះទៅហើយ
បើឯងចង់ឃើញត្រូវដើរស្វែងរកកន្លែងព្រៃនោះទៅ កាលបើឃើញហើយ
ត្រូវឯងរំលឹកពីរឿងដើមរបស់ម្តាយ កាលដែលជួបនឹងឪពុកឯងកាលតំដ-
បូនោះប្រាប់ឲ្យហូរហែរទើបគេស្គាល់» ។ ខាងនិយាយរឿងដើមរបស់
ខ្លួនប្រាប់កូនសព្វគ្រប់ ហើយកូនក៏លាចេញទៅ ។ បុត្តកុមារ ស្វែង
រកឪពុក អស់ពេលយ៉ាងយូរនៅកន្លែងព្រៃ ទើបបានទៅប្រទះឃើញតា-
បសមួយអង្គគង់ភាវនានៅក្រោមដើមឈើ លើថ្មមួយផ្ទាំងធំ ។ កុមារ
ថ្វាយបង្គំហើយ ក៏យកប់រឿងខ្លួនសព្វគ្រប់ឲ្យតាបសស្តាប់ តាបសតុំ
ពាន់ដឿថាកូនខេ កំតាំងអធិដ្ឋានថា ប្រសិនកុមារនេះជាកូនខ្ញុំមែន កាល
ណាខ្ញុំទះកុមារមួយដៃទៅ សុំឲ្យកុមារអណ្តែតមកលើស្មាខ្ញុំ» ។ ថា
ហើយតាបសយកដៃស្តាំទះទៅ ស្រាប់តែកុមារអណ្តែតមកនៅលើស្មា
ឆ្វេងដូចសេចក្តីប្រាថ្នា ទើបតាបសដឿថា ជាកូនខ្លួនពិតតាំងពីនោះមក
តាបសចាប់បង្រៀនវិជ្ជាសិល្បសាស្ត្រដល់កូនជារៀងរាល់ថ្ងៃ ។ លុះប្រ-
មាណជាច្រើនឆ្នាំតមក កូនក៏សុំលាឪពុកទៅរកម្តាយវិញ ឪពុកគ្មានអ្វីជា

ប្រសើរខុកជាកើរឡើយ មានតែគ្រាប់ត្រសក់ចីគ្រាប់ ហុចទៅឱ្យកូន ហើយផ្តាំថា «គ្រាប់ត្រសក់ចីគ្រាប់នេះទឹងផ្តល់កិត្តិយសយ៉ាងធំឱ្យកូនទៅ គេលមុខជាប្រាកដ ដល់កូនដាំទៅហើយបានផ្លែជាដំបូង ត្រូវតែបេះផ្លែនោះទៅថ្វាយស្តេចកុំខាន (១) ឯទីតន្លែងដាំ ត្រូវដាំទៅមាត់ត្រពាំងដែលជាលំទៅស្ថានបស់ម្តាយឯង ហើយត្រូវសន្មតហៅតន្លែងនោះថា «ចឹងតី ។ »តាមឈ្មោះម្តាយឯងរហូតទៅ» ។

កុមារថ្វាយបង្គំឪពុកចីដង ហើយលាធ្វើដំណើរទៅរកម្តាយដែលកាន់តែចាស់ ហើយក៏ប្រាប់ម្តាយឱ្យសន្មតនាមត្រពាំងក្បែរផ្ទះនេះហៅថា ចឹងតី ។ តាមបណ្តាំឪពុក ហើយដែលសព្វថ្ងៃនេះគ្រាយទៅជា«ចឹងតេ» ទៅវិញ ។ រឿងពាំវដើមនៃចឹងតេ មានប៉ុណ្ណេះឯង គឺកើតមកពីពាក្យតាបសចូសី សន្មតតាមឈ្មោះនាងតី ដែលជាអ្នកស្ថិតទៅត្រង់មាត់ត្រពាំង គឺជាតន្លែងដែលព្រះឆវណីស្រុតស្រូបយកពួកសេដ្ឋីទ្រីស្តស្សខុសប្រពៃណី ។ ដូច្នេះហើយ បានជាខ្ញុំបាទយើងមិនទុយមបរិកោគសាច់ក្រតើ ហើយមានជំនឿមួយថា ចង្រៃណាស់ផង ។

---

(១) សូមអានបន្តទៅរឿងតាត្រសក់ផ្លែចិន ដែលមានក្នុងព្រះរាជពង្សាវតារខ្មែរ ។

ប្រវត្តិនៃវត្តប្រាង្គ (ត)

រៀបរៀងដោយ ព្រះគោធិវង្ស ហ្សត.តាត

អគ្គាធិការនៃពុទ្ធិកសិក្សា

កាលសម្តេចព្រះមហាសង្ឃរាជព្រះនាម ឌៀង ទ្រង់ឆ្លើមតាត់ការ
ជួសជុលព្រះប្រាង្គនោះ នៅភាគដើមនៃរជ្ជកាលព្រះបាទសម្តេចព្រះ
ស៊ីសុវត្ថិ ក្នុងពុទ្ធសករាជ ២៤៤៨ គ.ស. ១៩០៥ ហានេះហើយស្រេចក្នុង
ពុទ្ធសករាជ ២៤៥១ គ.ស. ១៩០៨ ក្នុងឆ្នាំនោះ សម្តេចព្រះមហាសង្ឃ
រាជទ្រង់ប្រារព្ធនឹងជង្រែព្រះបរមសារីរិកធាតុ ពីក្រុងភ្នំពេញ ដោយក្បួន
នាវាតាមផ្លូវទឹកទៅកាន់វត្តប្រាង្គ ដើម្បីធ្វើបុណ្យសម្ពោធព្រះប្រាង្គ ហើយ
នឹងតំលៀព្រះបរមសារីរិកធាតុក្នុងព្រះប្រាង្គ ដែលទើបនឹងជួសជុលរួចថ្មីៗ
នៅក្នុងរដូវចេញវស្សា ព្រោះក្នុងសម័យនោះ ពុំមានផ្លូវថ្នល់សម្រាប់
ទៅមក ពាំនាំរថយន្តភួច-ជំកិពុំមានទេ ។ ទឹកទន្លេក្នុងឆ្នាំនោះ ស្រកយ៉ាង
រហ័សតាំងពីក្នុងវស្សា ដល់ពេលចេញវស្សា ទឹកស្រកអស់ជាច្រើន ។
សម្តេចព្រះមហាសង្ឃរាជទ្រង់បរិតក្តថា បើទឹកទន្លេស្រកអស់យ៉ាងនេះ
ការដង្ហែព្រះបរមសារីរិកធាតុដោយក្បួននាវាតាមផ្លូវទឹកខ្លោះទៅកំពង់ហ្លួង
ហើយចូលទៅតាមព្រែកតាមជំនឹកហួតទៅដល់ទុង្គខ្នោះ នឹងពុំសម្រេច

ឡើយ ។ ដើម្បីសម្តេចព្រះមហាសង្ឃរាជទ្រង់អធិដ្ឋានចំពោះព្រះបរមសារីរិកធាតុថា បើព្រះបរមសារីរិកធាតុនេះជារបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូពិតមែន សូមឲ្យទឹកទន្លេត្រឡប់ឡើងមកវិញ ដើម្បីនឹងបានរៀបចំធ្វើពិធីដង្ហែព្រះបរមសារីរិកធាតុនេះ តាមផ្លូវទឹកឲ្យបានជាទឹកអធិកអធម សមតាមព្រះកិត្តិយសរបស់ព្រះអង្គ ។

ទឹកទន្លេក៏ត្រឡប់ឡើងម្តងទៀត សមតាមសេចក្តីអធិដ្ឋានរបស់សម្តេចព្រះមហាសង្ឃរាជ ។ ទឹកទន្លេដែលឡើងនោះ ច្រើនជាងមុនហូរចូលទៅតាមព្រែកសាយការយគេញចំនួន ទឹកចូលរហូតដល់ស្រះកែវជិតផ្សារទន្លុង្គ នៅប្រមាណជា ១៩០ ម៉ែត្រ ទឹងដល់ទៅវត្តច្រាំង្គ ។

សម្តេចព្រះមហាសង្ឃរាជ ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ទើបទ្រង់ព្រះរាជបញ្ជាឲ្យចាត់ការរៀបពិធីក្សួនហែព្រះបរមសារីរិកធាតុ ដោយព្រះករុណាជាម្ចាស់ដឹកទ្រង់សព្វព្រះរាជហឫទ័យឲ្យយកក្សួនហែព្រះរាជទ្រព្យទៅដួយដង្ហែ ឲ្យបានទៅជាពិធីដ៏ទឹកអធិកអធម ហែតាំពីក្រុងភ្នំពេញ ៣ ថ្ងៃ រួចទើបដង្ហែដោយក្សួនខាងតាមផ្លូវទឹកឆ្ពោះទៅកំពង់ហ្លួង ។ កាលដែលដល់ទៅកំពង់ហ្លួង មានការរៀបចំពិធីដង្ហែព្រះបរមសារីរិកធាតុ តាមផ្លូវគោកអស់រយៈ ៦ គីឡូម៉ែត្រ ដោយក្សួនដង្ហែដ៏អធិកអធមក្រៃលែង រហូតដល់ទៅវត្តច្រាំង្គ ។ រីឯខាងចាំនប៉ុន្មានដែលដង្ហែព្រះបរមសារីរិធាតុ ពីភ្នំពេញទៅ ក៏បានចូលទៅតាម



ព្រះស្រាង្គដ៏ល្អធើតជាយនេះ មានតំកល់ព្រះបរមសារីរិកធាតុព្រះពុទ្ធជាម្ចាស់ ហើយបិតនៅឦសាងជើង
ព្រះវិហារវត្តស្រាង្គ (ឧដុង្គ)

ព្រែកតាមជំនឹក រហូតដល់ភៅស្រះកែវ ។


សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀ ជ ទ្រង់ជំនាន់ចាត់ឲ្យរៀបចំតំកល់ព្រះបរមសារីរិកធាតុ ក្នុងធម្មសាលាវត្តច្រាំង ហើយធ្វើបុណ្យសម្ពោធព្រះច្រាំង ៣ ថ្ងៃ ទើបដង្ហែព្រះបរមសារីរិធាតុ ទៅតំកល់លើព្រះច្រាំងនៅថ្ងៃព្រហស្បតិ៍ ១២ កេីត ខែអស្សុជ ឆ្នាំវក សំរឹទ្ធិស័ក ក្នុងពុទ្ធសករាជ ២៤៥១ គ.ស. ១៩០៨ ពេលថ្ងៃរសៀល ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិត ព្រះចាន ឧសម្តេចព្រះស៊ីសុវត្ថិ ។

ក្នុងពិធីបុណ្យនោះ តាមពត៌មានក្នុងព្រះរាជឥស្សរកោរថា ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ធ្វើព្រះរាជដំណើរពីក្នុងភេញ ទៅតាមព្រះទីនាំងនាវ ទៅថ្ងៃពុធ ១១ កេីត ខែអស្សុជ ឆ្នាំវកសំរឹទ្ធិស័ក ទៅវេលាម៉ោង ១៧,៣០ ដល់ម៉ោង ២៤,៣០ ដល់កំពង់ហ្លួងហើយ ទ្រង់ផ្លូវទៅក្នុងព្រះទីនាំងនាវនោះ ។ លុះព្រឹកឡើងថ្ងៃ ១២ កេីត ពេលម៉ោង ៦ ព្រឹក ព្រះទីនាំងនាវចូលតាមព្រែកតាមជំនឹក ដល់ភៅស្រះកែវម៉ោង ១០ ព្រឹក ។ ដល់ម៉ោង ១៤ ទ្រង់យាងដោយព្រះបាទចូលទៅវត្តច្រាំង គោរពព្រះបរមសារីរិកធាតុ ហើយទ្រង់ប្រោរឮដង្ហែព្រះបរមសារីរិកធាតុប្រទក្សិណវិហារវត្តច្រាំង ៣ ដុំ ទើបដង្ហែទៅតំកល់លើព្រះច្រាំង ក្រោមមុខព្រហ្ម រួចទ្រង់ព្រះពរនិវត្តន៍មកកាន់ព្រះទីនាំងនាវវិញ ទ្រង់ផ្លូវទៅស្រះកែវនោះ ១

យប់ទៀត ។ លុះដល់ថ្ងៃ ១៣ កេច ពេលម៉ោង ១០ ទើបទ្រង់ព្រះ
រាជនិវេតន៍មកគាន់ព្រះរាជធានីគ្នុំពេញ ។

សូមពុទ្ធបរិស័ទចាំងឡាយជ្រាបថា ព្រះប្រាង្គដែលបានតំកល់ព្រះ
បរមសារីរិកធាតុនៅខាងលើនេះ ជាបូជនីយវត្ថុមួយប្រសើរ សម្រាប់
ពុទ្ធសាសនិកជនចាំងបព្វជិត-គ្រហស្ថ គោរពធ្វើសក្ការបូជា ដោយចិត្ត
ជ្រះថ្លា ហើយអាចធ្វើឲ្យកើតផលប្រយោជន៍ ចំពោះពុទ្ធសាសនិកជន
ចាំងឡាយបាន ។

លុះតមក ដល់ពេលក្រោយអំពីពេលដែលសម្តេចព្រះមហាសង្ឃរាជ
ព្រះនាម ឆៀង ទ្រង់ព្រះវង្គតទៅ កន្លងពេលខោះខ្លួនខ្ញុំ (ព្រះគោធិ
វង្ស ឬ តាត) នៅជាយុវភិក្ខុនៅឡើយ បានដឹងថា រាជការបាន
ជំនុំសម្រេចថា បូជនីយដ្ឋានចាំងប៉ុន្មាន មានព្រះប្រាង្គជាដើមដែល
សម្តេចព្រះមហាសង្ឃរាជទ្រង់បានស្តាបនា ត្រូវទុកជាសម្បត្តិព្រះពុទ្ធសាសនា
ចាំងអស់ ។ ហេតុនោះបានជា តមក ដល់កន្លងរង្គកាលព្រះកុណាជាម្ចាស់
ជីវិតព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះប្រាង្គនេះ មានប្រែប្រែបកខ្លះ
ក្នុងដោយហេតុគ្រឿងសម្ភារៈដែលយកមកកសាងកន្លងសម័យនោះ តែ
មានស៊ុមដ៏ត-ដែរសោះឡើយ មានតែកំបោរសន្ធឹងឡាប់ប៉ុណ្ណោះ ។ គ្រា
នោះ លោកឡឺវេស៊ីជនត៍ទៀត្រកំពង់ស្ពឺ បានប្តឹងមកពុជការកន្លងព្រះបរម-
រាជវាំង ។ បានចាត់ការឲ្យវិស្វកជាតិបារាំងសេសទៅតិទ្យាមើលព្រះប្រាង្គ



ព្រះវិហារវត្តប្រាង្គ (ឧត្តុង្គ) បញ្ចុះសីមាខ្ងែងថ្មី នៅថ្ងៃទី ១៩ កុម្ភៈ ១៩៦៤

នេះ ហើយបានឱ្យជួសជុល ព្រមទាំងបានទម្លុះព្រះក្រោន្តដាក់បំពង់ទឹក ឱ្យទឹកហូរចុះមក ចូលទៅក្នុងស្រះខាងមុខវិហារ ។

តពីនោះមក ព្រះក្រោន្តនេះ ឥតមានការជួសជុលអ្វីធំដុំទេ មានបន្តិចបន្តួចដោយលោកចៅអធិការវត្តក្រោន្តបានថែទាំឱ្យជាំរះកូនឈើតូច ។ ដែលដុះជ្រៀតជ្រែកតាមចន្លោះកំពោរ ឥដ្ឋ នាំឱ្យរបើករបកកំពោរបូកគ្រប់ថ្នាក់ ។ ក្រៅពីនេះ មានទេពាសកម្មាក់ឈ្មោះ ស្រី ជាង ទីឥន ទេពាសិកា ហុក នៅផ្សារទុង្គ បានលាបទឹកកំពោរម្តង ។ លុះមកដល់ឆ្នាំខាលចត្វាស័ក ព.ស.២៥០៥ គ.ស.១៩៦៣ គហបតី តាង ងួនអាន ទីឥអ្នកស្រី ស-តិមសេង ជាកវិយា នៅក្រុងភ្នំពេញ មានសទ្ធាជ្រះថ្លាបានជួសជុលព្រះក្រោន្ត ត្រង់កន្ទែងដែលប្រែះបាក់បែកទាំងប៉ុន្មានឱ្យបានល្អឡើងវិញ ទាំងកំពែងក្រៅក៏ឱ្យជួសជុលផងដែរ រួចហើយឱ្យដុសជម្រះសែ្វឱ្យស្អាត ហើយបានឱ្យលាបលនជាថ្មី តាំងពីខាងលើរហូតមកខាងក្រោម ហើយបានដាក់ភ្លើងអគ្គិសនីជាពុទ្ធបូជា នៅគ្រប់ថ្នាក់រហូតដល់កំពូលខាងលើ ។

វិហារ

វិហារដែលមានរូបភាពស្ថាប់ត្នឹងសៀវភៅនេះជាទេពាសថាគារដែលទើបកសាងរួចថ្មីៗ នេះ ។ ឯវិហារចាស់បានត្រូវរុះរើចេញ ឥតមានសេសសល់គ្រឿងសម្ភារៈអ្វីបន្តិចបន្តួចសោះឡើយ ព្រោះវិហារចាស់នោះ

មានសភាពទ្រុឌទ្រោមណាស់ ដោយបានកសាងយូរអង្វែងហើយ ។
តាមព្រះរាជពង្សាវតារប្រទេសកម្ពុជាថា ព្រះបាទសម្តេចព្រះហរិរ័ក្សភមា
(ព្រះអង្គឌួង) ទ្រង់មានព្រះបញ្ជាឲ្យកសាងវិហារវត្តពុទ្ធប្រាង្គកំពង់ឆ្នាំរកា
ឯកស័ក ព.ស. ២៣៨៣ គ.ស. ១៨៤៩ គិតមកដល់ឆ្នាំជូតទោស័ក
ព.ស. ២៥០៣ គ.ស. ១៩៦០ នេះ ឃើញ ១១០ ឆ្នាំហើយ ។

វិហារចាស់ដែលព្រះបាទសម្តេចព្រះហរិរ័ក្សភមាទ្រង់មានព្រះបញ្ជា
ឲ្យកសាងនោះ មានទំហំទទឹង ១៧ ម៉ែត្រ បណ្តោយ ៣១ ម៉ែត្រ កសាង
ដោយគ្រឿងឈើ តែជញ្ជាំងធ្វើដោយឥដ្ឋមានកម្រាស់ ១ម.២០ ព្រោះ
ជញ្ជាំងស្រោមសសរឈើធំ ។ ដំបូលប្រក់ក្បឿង ។

កន្លងរយៈកាល ១១០ ឆ្នាំ ដែលបានគណនាពីឆ្នាំកសាងកន្លងគ.ស.
១៨៤៩ ដល់ ១៩៦០ នេះ វិហារនោះត្រូវបានជួសជុលពីរលើកគឺ :

ជួសជុលលើកទី ១ កន្លងពេលដែលលោកគ្រូព្រះធម្មឃោសាចារ្យ
មាស ធ្វើជាចៅអធិការ តែជួសជុលកន្លងពេលនោះត្រាន់តែថ្វាស់គ្រឿង
ឈើខាងលើ ។

ជួសជុលលើកទី ២ កន្លងពេលចុងរជ្ជកាលនៃព្រះករុណាជាម្ចាស់ជីវិត
ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ក្រោយពេលដែលព្រះអង្គបានជ្រាបថាវិហារ
វត្តប្រាង្គទ្រុឌទ្រោមពុកផុយខ្លាំងជាច្រើន ព្រះអង្គមានព្រះរាជហឫទ័យនឹក
ក្តុកឃើញថា វិហារវត្តប្រាង្គនោះជាព្រះកេរ្តិ៍របស់សម្តេចព្រះហរិរ័ក្សភមា



សម្តេចសហជីវិនព្រះប្រមុខរដ្ឋ កំពុងទ្រង់ទទួលអបអរសាទរនឹងក្មួនចៅប្រុសស្រី ក្មេងចាស់ ដែលចោមរោមថ្វាយបង្គំព្រះអង្គ ក្នុងពិធីសម្ពោធក្នុងព្រះវិហារវត្តប្រាង្គ (ទន្លុង្គ) នៅថ្ងៃទី ២២-២-៦៥

ជាព្រះវរពជបិតារបស់ព្រះអង្គ ទាំងព្រះអគ្គសាវក កាលនៅជាព្រះពជកុមារ
កំបានបួសកាន់បព្វជ្ជាជាសាមណេរកន្លងវិហារវត្តក្រុងនោះដែរ ទើបទ្រង់
មានព្រះពជបញ្ជាឲ្យជាងជួសជុលវិហារនោះ ។ ការជួសជុលក្នុងពេល
នោះ បានរើយកសសរឈើចេញទាំងអស់ ហើយបាក់ស៊ុមដំណត់ដែតធ្វើ
ជាសសរជំនួសវិញ ។ ឯគ្រឿងឈើ គ្រាន់តែជួសជុលផ្លាស់ឈើដែល
ពុក ។ ចេញខ្លះប៉ុណ្ណោះ ជហ្វា ជង្គារ នាគ ដែលពីដើមធ្លើដោយឈើ
បានរើយកចេញ ហើយធ្លើដោយស៊ុមដំណត់ដែកជំនួស ក្រៅពីនោះ គ្រឿង
ចាស់ទាំងប៉ុន្មាន ត្រូវទុកនៅដូចដែល ។ ការជួសជុលនោះ មិនទាន់
ទាំងបានរួចស្រេចផង ព្រះអគ្គក៏សោយព្រះទិវង្គតទៅ ។

ការរុះរើវិហារចាស់ និងការកសាងវិហារថ្មី

វិហារចាស់ដែលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់មានព្រះពជបញ្ជា
ឲ្យជួសជុលទើបតែនិងបានប្រមាណ ៣០ ឆ្នាំប៉ុណ្ណោះ ក៏បានត្រូវទ្រុឌ
ទ្រោមយ៉ាងខ្លាំង មិនអាចនឹងប្រើប្រាស់តទៅទៀតបាន ព្រោះគ្រឿងឈើ
កាលដែលជួសជុល គេពុំបានផ្លាស់យកចេញ ក៏ពុកផុយអស់លើងទៅ
ឯគ្រឿងតូចតូចម្ភាះដំបូលដែលបានផ្លាស់ប្តូរក្នុងពេលដែលជួសជុលនោះក៏
ពុកទៅដែរ ដោយកណ្តៀរឡើងតាមជញ្ជាំងទៅបំផ្លាញខ្លួចខ្លឹអស់
ឥតសេសសល់ឡើយ ។

(នៅមានត)

បុណ្យឆ្លងវត្តប្រាង្គ និងបញ្ចុះសីមា

យើងគួរកត់សំគាល់ថាកិច្ចកសាងវិហារវត្តប្រាង្គ អស់ប្រាក់ចំនួន ២.៥០៧.៥៨៧ រៀល ។ ឯសម្តេចព្រះមហាក្សត្រិយានី ព្រះអង្គប្រទានប្រាក់ចំនួន ១០.០០០ រៀល ជាព្រះវិភាគទានក្នុងការកសាងព្រះវិហារនេះដែរ ។

លុះចប់ព្រះសុន្ទរកថារបស់ព្រះពោធិវង្សហើយ សម្តេចព្រះបិតាឯកឧត្តមជាតិ ទ្រង់ប្រទានព្រះពរជ័យសង្កត់ថាមួយ ប្រកបដោយអត្ថន័យយ៉ាងពិរោះអស្ចារ្យ ដែលយើងចុះផ្សាយដោយសង្ខេប នៅក្នុងទំព័រជាបន្ទាប់ ។

លុះចប់ហើយ សម្តេចព្រះមាតាជាតិនីងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងទៅកាត់និមិត្តសីមា ហើយព្រះសង្ឃស្មូត្រជ័យជមិមង្គលសូត្រ នីងពុទ្ធមន្ត ជាពិធីសម្ពោធឆ្លងវិហារថ្មី ថ្វាយព្រះតារស័ព្ទសាធុការចំពោះសម្តេចតាំងពីព្រះអង្គ ។

ព្រះរាជសង្ឃថានៃសម្តេចក្នុងឱកាសពិធីបញ្ចុះសីមា វត្តប្រាង្គ

ខាងក្រោយការថ្លែងសុន្ទរកថា ព្រះតេជព្រះគុណ ព្រះពោធិវង្ស សម្តេចឧត្តមសង្ឃព្រះពជហប្ញទ័យ ថ្លែងព្រះសង្ឃកថាឥតព្រាងទុកយ៉ាងពិរោះក្បោះក្បាយ ។ នៅក្នុងព្រះពជសុន្ទរថានោះ ព្រះអង្គទ្រង់សរសើរដឹងស្មោះស្ម័គ្រចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ដែលជាមេគំនិតកសាងព្រះវិហារវត្តប្រាង្គនេះ ។ ព្រះអង្គទ្រង់ដៅថាព្រះសង្ឃមិនត្រឹមតែស្មូនរកន្ទូរមោក្នុងម៉ូរេ ព្រះអង្គបានភាំងជួយដល់អាណាចក្រ



សម្តេចព្រះបិតាឯករាជ្យជាតិ ព្រះប្រមុខរដ្ឋ ទ្រង់អនុគ្រោះកំពុងប្រោរព្វកាត់ឬសសីមា
កិលក្នុងពិធីបញ្ចុះសីមាវត្តប្រាង្គ (ឧត្តុង្គ) ដោយមានសហជីវិន ម៉ែន ឈុំ អនុរដ្ឋ
លេខាធិការ ក្រសួងធម្មការ ជាអ្នកកាន់កាំបិត នៅថ្ងៃទី ២២-២-៦៤

ទៀត ដូចជាព្រះពោធិវង្សដែលដួយខ្ទេចខ្ទីនកសាងវត្តប្រាង្គនេះ ដែលជាកត្តិយសមួយដ៏អស្ចារ្យ នៅកន្លែងជុំដ្ឋនេះ ដែលជាអតីតកាលជានិដ្ឋរឿងមួយជាប់នៅកន្លែងប្រវត្តិសាស្ត្រខ្មែរ ។ សង្ឃមកស្ត្តនិយមដែលមានការលួតលាស់ហើសដូច្នេះ ព្រោះមានព្រះសង្ឃដួយជាវិភាគទាន ក្នុងការកសាងដូចជាសាលា ស្ពានជាដើម ។

ខាងនយោបាយវិញ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រទានឲ្យកូនៗដឹងថា :

- សារតែមានក្រុមលោកសើរ ឬានចាត់ព្រះអង្គខុតជាមនុស្សក្បត់ថាព្រះអង្គជាអ្នកដឹកនាំប្រជាពលរដ្ឋកូនចៅព្រះអង្គ ឲ្យចូលទៅរកបបក្ខុមួយនិស្ស ទៅពេលដែលប្រទេសយើងកំពុងតែជួបប្រទះនឹងសន្តិសុខ ក្នុងមាគាអព្យាក្រិត ។ ថ្ងៃនេះ ដែលយើងកំពុងតិចិនតិច្ចនូវរៀបចនការមួយដើម្បីធ្វើជាបក្សសម្ពន្ធសឹកជាមួយបក្សសង្គមនិយម ក្នុងបំណងនឹងចៀសភាងឲ្យប្រទេសជុតពីការតំកមកំហែងជាអាយុជីវិតរបស់ខ្មែរយើង ដែលសហរដ្ឋអាមេរិកតំងបក្សពួករបស់ក កំពុងតែធ្វើសកម្មភាពសព្វថ្ងៃនេះ ។ ចំណែកសារតែមានហ្វីលីពីន នឹងម៉ាឡាស៊ីយ៉ា ឬានចំលាក់កំហុសនេះតាំងស្រុងចោទប្រកាន់ដោយអយុត្តិធម៌ថាព្រះអង្គហ្នឹកហ្នឿន ប្រជាពលរដ្ឋទៅរកផ្លូវកុម្មុយនិស្ស នឹងបង្កសង្គ្រាម ដោយឯកាងលេសត្រង់សេចក្តីសំរេចចិត្ត ដែលព្រះអង្គប្រកាន់យកជាការចំបាច់ ដល់អាយុជីវិតប្រជា

ពលរដ្ឋខ្មែរ ដែលស្ថិតនៅក្នុងបច្ចុប្បន្ននេះ ដើម្បីការពារនឹងរក្សាទុកនូវ
ឯករាជ្យ នឹងអត្តាក្រឹតរបស់ខ្មែរ ដោយហេតុមានការគំរាមកំហែងដ៏
អស្ចារ្យក្នុងការប៉ុនប៉ងបំណងកំទេចដីវិតខ្មែរ ដែលមានពួកចក្រពត្តិនិយម
ឋស្តឹម នឹងពួកបក្សវ ។ មិនតែប៉ុណ្ណោះ វាបានចាំងមួលបង្កាច់ពោពាំង
ល្មើថា ព្រះអង្គជាអ្នកបង្កសង្គ្រាមក្នុងប្រទេសនិងក្នុងអាស៊ុចាំងមួល ។

សម្តេចព្រះចំតាសន្តិភាព ទ្រង់បានតូសដៀបញ្ជាក់ថា សន្តិសិទ
ហ្សឺណែវស្តីអំពីស្រុកលាវនោះជាការបង្កសង្គ្រាម ឬ ជាការស្វែងរក
សន្តិភាពឱ្យលាវ (នៅក្នុងអាស៊ី) ? ។

ដោយយើងតែងតែទទួលរងគ្រោះជានិច្ច ពីយួនសៀម ត្រង់ម-
ឡោះបាយអមិត្តក្រៅប្រទេស ការចាំបាច់ យើងត្រូវតែស៊ុមិត្តដែលតែង
តែជួយគាំទ្រជួយការពារយើង មានមិត្តចិនប្រជាមានគុណអាណិនោះ ឱ្យ
រតដួយការពារ ។

តំនិតរបិលរប៉ូចរបស់អង់តូសាក់-សុង (អង់គ្លេស) បានប្រើនិតក្រមមួយ
មកតឿតតឿរពេល ដោយមិនត្រមទទួលយកការស្នើសុំឱ្យទាន់ប្រ-
ទេសព័ម្ភរងអត្តាក្រឹតភាពរបស់យើងតាំងពីឆ្នាំ ១៩៦១ ។ នៅពេលដែល
ពួកនេះតឿតតឿរពេល ពួកចៃចក្រពត្តិនិយម បានមកកាប់សម្លាប់ខ្មែរ
ចំណាក់គ្រាប់បែកលើអីខ្មែរលើ គ្មានលោះពេលណាឡើយ ។

នៅទីបំផុត ព្រះអង្គបានប្រទានដំណឹងដល់កូនចៅថា ពួកជាញ់



សម្តេចព្រះមហាក្សត្រិយានីព្រះអាមាតាជាតិ សម្តេចព្រះឧបយុវរាជ និងព្រះគេងជាព្រះគុណព្រះពោធិវង្ស ហួត - ពាត អគ្គាធិការពុទ្ធិកសិក្សា ទ្រង់កំពុងសន្ទនានៅយ៉ាព្រះវិហារ ក្នុងឱកាសពិធីសម្ពោធឆ្លងព្រះវិហារវត្តប្រាង្គ (ខត្តុង្គ) នៅថ្ងៃទី ២២-២-៦៤

សារីកថានឹងមកធ្វើពិធីបូលថ្នាំថ្មីនៅភ្នំពេញ ក្នុងថ្ងៃថ្មីខាងមុខនេះ ។ ហើយ
ព្រះអង្គបានបញ្ជាក់ថា កូនចៅត្រៃតអរធ្វើចាំទទួលនៅកន្លែង ដែលអា
ព្រាប-អ៊ុន ជាស្នងការនយោបាយ ទើបនឹងទទួលរង្វាន់ជាវិតាសានពីប៉ុន្មាន
ថ្ងៃនោះ ចំណែកកងទ័ពរក្សាមិនឲ្យ កំប្រុងប្រៀបរៀបចំអាវុធយុទ្ធភណ្ឌគ្រប់
ជាស្រេច ដើម្បីទទួលជាកិត្តិយសដូចព្រាប-អ៊ុន ទៀត ។ សូមជ្រាប
ថា គ្រឿងសាស្ត្រាវុធនេះ មិនមែនបានពីណាក្រៅពីប្រទេសចិន
ប្រជាមានិតទេ ។ គ្រឿងអាវុធនេះ បានមកត្រៀមចាំមុនស្រេច
ដល់ទៃមិនា ជំនួយសឹករបស់ចាក់ឆ ទឹងសូវៀត ដែលឥតមានចំណង
ទឹងមកដល់ទៀត ដូច្នេះសម្ភារៈទាំងនេះហើយ ដែលកងទ័ពរក្សាមិនឲ្យគ្រប់
ចាំទទួលថាន់-សារី ក្នុងទុកាសបូលឆ្នាំថ្មីនេះ ទល់តែទឹងសម្ភារៈសឹក
ដែលខ្វែរសេរី បានទទួលពីព្រៃនគរ ទឹងចាងកក ។

ទៅទីបញ្ចប់នៃព្រះសង្ឃថា ព្រះអង្គបានព្រះពរជាទាន ចាប់តុសលចំនួន
២០ ០០០ រៀល ទឹងព្រះតេជៈព្រះគុណព្រះរតនវង្ស ដើម្បីជាវិភាគ
ទានដល់ការចំណាយចាំបាច់ ក្នុងពិធីបុណ្យបញ្ចុះសីមានេះ ។

អំពីព្រះនាមព្រះតេជព្រះគុណ

ដែលបានទទួលសញ្ញាបត្រចាត់តាំងជាចៅអធិការនិងគ្រូសូត្រ

ក្នុងវត្តនានា (ក្នុងព្រះភិក្ខុអាណាចក្រ)

(ក)

៥៨- ព្រះតេជព្រះគុណ ខុន-សាលី នាមឆាយា ចរិបុណ្ណា កើតឆ្នាំថោះ អាយុ ២៤ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រស្ថាំក្នុងវត្តអម្ពនទិយោភម ឃុំពាមក្រសោប ស្រុក-ខេត្តកោះកុង លេខ-សញ្ញាបត្រ ៣៤៤២ ចុះថ្ងៃទី ១៥-១-៦៣ ។

៥៩- ព្រះតេជព្រះគុណ សេង-វឿន នាមឆាយា អមរពេ កើតឆ្នាំម្សាញ់ អាយុ ២៤ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រធ្នូង ក្នុងវត្តអម្ពនទិយោភម ឃុំពាមក្រសោបស្រុក-ខេត្តកោះកុង លេខសញ្ញាបត្រ ៣៤៤៣ ចុះថ្ងៃទី ១៥-១-៦៣ ។

៦០- ព្រះតេជព្រះគុណ យ៉ី-ចំប៉ា នាមឆាយា សមាចារពេ កើតឆ្នាំជូត អាយុ ២៦ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រស្ថាំក្នុងវត្តអម្ពវ័ន ឃុំពាមក្រសោបស្រុក-ខែត្រកោះកុង លេខសញ្ញាបត្រ ៣៤៤៤ ចុះថ្ងៃទី ១៥-១-៦៣ ។

៦១- ព្រះតេជព្រះគុណ ឈុំ-ឈឿ នាមឆាយា ធម្មទិន្នោ កើតឆ្នាំមមី អាយុ ២១ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រធ្នូង ក្នុង

ទៀត ដូចជាព្រះពោធិវង្សដែលជួយទ្រទ្រង់កសាងវត្តប្រាំង្គនេះ ដែលជាកត្តិយសមួយដ៏អស្ចារ្យ នៅកន្លែងដុន្តនេះ ដែលជាអតីតភជាន់ដ៏ធំរឿងមួយជាប់នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ។ សង្គមកស្ត្រីយមដែលមានការលួតលាស់រហ័សដូច្នេះ ព្រោះមានព្រះសង្ឃជួយជាវិភាគទាន ក្នុងការកសាងដូចជាសាលា ស្ពានជាដើម ។

ខាងនយោបាយវិញ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រទានឱ្យកូនចៅដឹងថា :

- សារតែមានក្រមលោកសេរី ឃានចាត់ព្រះអង្គខុកជាមនុស្សឆ្កួត ថាព្រះអង្គជាអ្នកដឹកនាំប្រជាពលរដ្ឋកូនចៅព្រះអង្គ ឱ្យចូលទៅរកវបបកុម្មុយនិស្ត នៅពេលដែលប្រទេសយើងកំពុងតែជួបប្រទះនឹងសន្តិសុខ ក្នុងមាគ៌ាអព្យាក្រឹត ។ ថ្ងៃនេះ ដែលយើងកំពុងពិនិត្យទូរទាំងការមួយដើម្បីធ្វើជាមកស្រមៃសឹកជាមួយបក្សសង្គមនិយម ក្នុងបំណងនឹងចៀសវាងឱ្យប្រទេសផុតពីការគំរាមកំហែងជាអាយុជីវិតរបស់ខ្មែរយើង ដែលសហវដ្តអាមេរិកចាំងបក្ខពួករបស់ក៏ កំពុងតែធ្វើសកម្មភាពសព្វថ្ងៃនេះ ។ ចំណែកសារតែមានហ្ស៊ីលីពីន នឹងម៉ាឡេស៊ីយ៉ា ឃានចំលាក់តំហុសនេះ ចាំងស្រងឹងចោទប្រកាន់ដោយអយុត្តិធម៌ថាព្រះអង្គហ៊ឺកហ៊ឺន ប្រជាពលរដ្ឋទៅរកផ្លូវកុម្មុយនិស្ត នឹងបង្កសង្គ្រាម ដោយពាក់ព័ន្ធលេសត្រង់សេចក្តីសំរេចចិត្ត ដែលព្រះអង្គប្រកាន់យកជាការចំបាច់ ដល់អាយុជីវិតប្រជា

៦៦- ព្រះតេជព្រះគុណ ខាត់-ម៉ុត នាមឆាយាមន្តត្រេ កើតពី គ.ស. ១៩២០ អាយុ ៤៣ ឆ្នាំ វស្សា ២៦ ជានខេត្តលែងតាំងជាចៅអធិការវត្តអង្គត្រគៀត ឃុំកន្ទោក ស្រុកកំពង់ពេញ ខែត្រកណ្តាល លេខសញ្ញាបត្រ ៣៤៩០ ចុះថ្ងៃទី ៧-២-៦៣ ។

៦៧- ព្រះតេជព្រះគុណ ហ៊ឹម-ប៊ែន នាមឆាយាធម្មសុវណ្ណ កើត ឆ្នាំម្សាញ់ អាយុ ៤៦ ឆ្នាំ វស្សា ២៦ ជានខេត្តលែងតាំងជាចៅអធិការកុង វត្តសុវណ្ណសនារាម ឃុំចោងមោង ស្រុកខ្មែរជ្រុស ខែត្រកំពង់ឆ្នាំង លេខ សញ្ញាបត្រ ៣៤៩១ ចុះថ្ងៃទី ៧-២-៦៣ ។

៦៨- ព្រះតេជព្រះគុណ ភូន-ហ៊ាង នាមឆាយា ឥន្ទបញ្ញា កើតពី គ.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា ៩ ជានខេត្តលែងតាំងជាគ្រូសូត្រ ស្ថាក់កន្លែងវត្តរុន ឃុំរុនតាឯក ស្រុកសូត្រនិគម ខែត្រសៀមរាប លេខសញ្ញា បត្រ ៣៤៩២ ចុះថ្ងៃទី ៧-២-៦៣ ។

៦៩- ព្រះតេជព្រះគុណ ចូវ-ធន នាមឆាយាសុវណ្ណជោតិ កើតពី គ.ស. ១៩៣៣ អាយុ ៣០ ឆ្នាំ វស្សា ៩ ជានខេត្តលែងតាំងជាគ្រូសូត្រ ស្ថេរកន្លែងវត្តរុន ឃុំតាឯក ស្រុកសូត្រនិគម ខែត្រសៀមរាប លេខសញ្ញា បត្រ ៣៤៩៣ ចុះថ្ងៃទី ៧-២-៦៣ ។

៧០- ព្រះតេជព្រះគុណ សៀ-ដុង នាមឆាយា សង្កាសថារ កើត ពី គ.ស. ១៩៣៤ អាយុ ២៩ ឆ្នាំ វស្សា ៨ ជានខេត្តលែងតាំងជាចៅអ-

ធំគារក្នុងវត្តសាលាម្នាង ឃុំត្រពាំង ស្រុកកំពង់សោម ខែត្រកោះកុង លេខ
សញ្ញាបត្រ ៣៤៥៤ ចុះថ្ងៃទី ៨-២-៦៣ ។

៧១- ព្រះតេជព្រះគុណ ជា-ប៉ែត នាមឆាយា ឥន្ទវត្ថ្រ កើតឆ្នាំ
ម្សាញ់ អាយុ ៤៦ ឆ្នាំ វស្សា ២៦ ជានទទួលតែងតាំងជាចៅអធិការក្នុងវត្ត
ស៊ីវ៉ែន ឃុំទ្រា ស្រុកសំរោង ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៥៥ ចុះ
ថ្ងៃទី ១៨-២ ៦៣ ។

៧២- ព្រះតេជព្រះគុណ សរ-សាមឿន នាមឆាយាមុន្នីវង្ស កើត
ពី គ.ស. ១៩៣៥ អាយុ ២៨ ឆ្នាំ វស្សា ៨ ជានទទួលតែងតាំងជាគ្រូ
សូត្រស្តាំក្នុងវត្តស៊ីវ៉ែន ឃុំទ្រា ស្រុកសំរោង ខែត្រតាកែវ លេខសញ្ញា-
បត្រ ៣៤៥៦ ចុះថ្ងៃទី ១៨-២-៦៣ ។

៧៣- ព្រះតេជព្រះគុណ ខេត-សុខ នាមឆាយាវជិរប្បញ្ញោ កើត
ពីគ.ស. ១៩៣៩ អាយុ ២៤ ឆ្នាំ វស្សា ៤ ជានទទួលតែងតាំងជាគ្រូសូត្រ
ធ្វើឆទក្នុងវត្តស៊ីវ៉ែន ឃុំទ្រា ស្រុកសំរោង ខែត្រតាកែវ លេខសញ្ញាបត្រ
៣៤៥៧ ចុះថ្ងៃទី ១៨-២-៦៣ ។

៧៤- ព្រះតេជព្រះគុណ សូរ-ម៉ុម នាមឆាយាតរុធម្មវេរ កើតឆ្នាំ
ច អាយុ ៧៧ ឆ្នាំ វស្សា ៥៦ ជានទទួលតែងតាំងជាចៅអធិការវត្តចំការ
ខ្លាច់ ឃុំស្លាធ្នង់ ស្រុកកណ្តាលស្ទឹង ខែត្រកណ្តាល លេខសញ្ញាបត្រ-
៣៤៥៨ ចុះថ្ងៃទី ២១-២-៦៣ ។

៧៥- ព្រះតេជព្រះគុណ អ៊ូច-សេន នាមឆាយាសុវណ្ណថេរ កើតឆ្នាំរកា អាយុ ៥៤ ឆ្នាំ វស្សា ១៩ ជានខេត្តលតែងតាំងជាគ្រូសូត្រស្តាំកង់វត្តចំការខ្លាច ឃុំស្តានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៥៨ ចុះថ្ងៃទី ២១-៤-៦៣ ។

៧៦- ព្រះតេជព្រះគុណ ខឹម-ម៉ាក នាមឆាយាធម្មថេរ កើតឆ្នាំឆ្លូវ អាយុ ៥០ ឆ្នាំ វស្សា ១ ជានខេត្តលតែងតាំងជាគ្រូសូត្រធ្វេងកង់វត្តចំការខ្លាច ឃុំស្តានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៦០ ចុះថ្ងៃទី ២១-៤-៦៣ ។

៧៧- ព្រះតេជព្រះគុណ ខាង-ហុង នាមឆាយា សុវណ្ណត្ថេរ កើតព.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា ១២ ជានខេត្តលតែងតាំងជាចៅអធិការកង់វត្តពោធិព្រឹក្ស ឃុំក្តឿងកាយ ស្រុកកន្ត្រៃ ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦១ ចុះថ្ងៃទី ២៩-៤-៦៣ ។

៧៨- ព្រះតេជព្រះគុណ ពុត-វង់ នាមឆាយា មុនីសត្ថេរ កើតព.ស. ១៩៣៤ អាយុ ៣១ ឆ្នាំ វស្សា ១០ ជានខេត្តលតែងតាំងជាគ្រូសូត្រស្តាំកង់វត្តពោធិព្រឹក្ស ឃុំក្តឿងកាយ ស្រុកកន្ត្រៃ ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦២ ចុះថ្ងៃទី ២៩-៤-៦៣ ។

៧៩- ព្រះតេជព្រះគុណ មួល-កន នាមឆាយា ជោតិប្បញ្ញា កើតឆ្នាំមមី អាយុ ៥៧ ឆ្នាំ វស្សា ៣៣ ជានខេត្តលតែងតាំងជាចៅអធិការកង់វត្តនខ-

ជោតវាគាម ឃុំមេសរប្រចាន់ ស្រុកភាពំង ខែត្រព្រៃវែង លេខសញ្ញាបត្រ ៣៤៦៣ ចុះថ្ងៃទី ២៥-២-៦៣ ។

៨០- ព្រះតេជព្រះគុណ ទិន-ហ៊ុន នាមឆាយាចន្ទប្បញ្ញា កើតឆ្នាំខាល អាយុ ៣៧ ឆ្នាំ វស្សា ១៣ ជានខេត្តលតែងតាំងជាគ្រូសូត្រស្តាំកង់វត្តនគរជោតវាគាម ឃុំមេសរប្រចាន់ ស្រុកភាពំង ខែត្រព្រៃវែង លេខសញ្ញាបត្រ ៣៤៦៤ ចុះថ្ងៃទី ២៥-២-៦៣ ។

៨១- ព្រះតេជព្រះគុណ គិន-ឌិន នាមឆាយា ធម្មសេរី កើតឆ្នាំ គ.ស. ១៩២៣ អាយុ ៤០ ឆ្នាំ វស្សា ៥ ជានខេត្តលតែងតាំងជាគ្រូសូត្រឆ្វេង កង់វត្តនគរជោតវាគាម ឃុំមេសរប្រចាន់ស្រុកភាពំង ខែត្រព្រៃវែង លេខសញ្ញាបត្រ ៣៤៦៥ ចុះថ្ងៃទី ២៥-២-៦៣ ។

៨២- ព្រះតេជព្រះគុណ អ៊ុន-កុន នាមឆាយា ធម្មប្បញ្ញា កើតឆ្នាំ គ.ស ១៩០៣ អាយុ ៦៣ ឆ្នាំ វស្សា ១០ ជានខេត្តលតែងតាំងជាចៅអធិការកង់វត្តឧលគគីរឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខែត្រកណ្តាល លេខសញ្ញាបត្រ ៣៤៦៦ ចុះថ្ងៃទី ១០-៣-៦៣ ។

កម្ពុជសុរិយា សូមអភ័យទោស អំពីសំណាក់នៃមិត្រអ្នកអានចាំង
ឡាយដែលមានការយល់ខ្លាន នៅវគ្គនេះ ក្នុងព្រះពុទ្ធសាសនាចក្រ
ធ្វាយតិចក្រែងភ្លេចភ្លាំ ហើយដែលបានមានសោមនស្សចេតនា បន្ទរដោះ
ស្រាយចំណាត់ន័តនៃខ្លួន រួចចម្លើយពុំបានមកដល់ទីសំណាក់ការខាន
ការវែង ព្រោះទស្សនាវដ្តីក្រៅដល់ ។ ឯការក្រៅដល់នេះ
មិនមែនជាកំហុសនៃពុទ្ធសាសនបណ្ឌិត្យក្របញ្ជូនទៅនោះទេ គឺជាកំហុស
នៃការធ្វើដំណើរយឺតយូរនៃទស្សនាវដ្តីនីមួយ ។ ជាតិតូចកជ ។

ចំពោះចំណាត់ទី ១ កម្ពុជសុរិយាទើបនឹងបានទទួលចម្លើយជាច្រើន
ទៀតកន្លងពេលថ្មី ៗនេះ តែធ្វើដូចម្តេច បើចម្លើយចំណាត់ទី ១ ចេញ
ផ្សាយហួសទៅហើយ សូមមិត្រដែលទើបនឹងផ្ញើចម្លើយទៅនោះ មេត្តា
អភ័យទោស ដោយពុំបានចុះនាមមិត្រផ្សាយក្នុងទស្សនាវដ្តី ។

បម្លើយបំណោទគំនិតទី ២

(អានសេចក្តីចោទក្នុងទស្សនាវដ្តីលេខ ២ ទំព័រ ១៣០ ឆ្នាំ ១៩៦៤)

ទី ១ បម្លើយរបស់លោក គីម-ឃីន-សុំសាម៉ុត

ចាងហ្វាងទូទៅសាលាឯកជន នៅទីស្តីការក្រសួងអប់រំជាតិ

ផ្នោត } : មនុស្សក្នុងលោកនិយមស្រឡាញ់ចូលចិត្តគ្រប់គ្នា
ផោត }

: បើកាត់ដើងចោល ត្រូវក្លាយជាកម្មវត្ថុសម្រាប់តែគេ
ចំអកសើចលេង ។

ទី ២ បម្លើយរបស់លោក គុយ-សូត្រ
ភ្នាក់ងារនៅពុទ្ធសាសនបណ្ឌិត្យ

របស់សម័យ ដែលមនុស្សសព្វថ្ងៃ ចូលចិត្តផ្សងព្រេង គឺផ្នោត
ជាតិពិត បើគិតឲ្យវែង កាត់ដើងចេញជេង គេថា « ផោតវិញ »។

ទី ៣ បម្លើយរបស់លោក លី-ប៊ុនប៉ា
ក្រសួងអប់រំជាតិ ភ្នំពេញ

គ្មានអ្នកសំគីរ ជួយផ្តល់គំនិត ទ្វើយតាមប្រជាន ថាមានតែ « ផ្ងិត »
កាត់ដើងប្រែ « ផិត » ត្រឡប់អប្រិយ៍ ។ ផ្ងិតឲ្យត្រជាក់ គេចូលចិត្តស្ទ្រក
ពាក់កេមេត្រី បើកាត់ដើង « ល » ក្លាយជាសំដី ឡកឡឺយប្រក្រតី ជិត
ដល់អាត្មា ។

ទី ៤ បម្លើយរបស់លោក សំ-ជ័យ
នៅលាសាជំបូង ព្រៃវែង-ក្រុង

ខ្ញុំជាខោ ដែលជាសម្លៀក សម្រាប់មហាជន ក្នុងលោកស្លៀក
មហាជននិយមពាក់អានស្រឡាញ់គ្រប់គ្នា តែបើ « ខោ » នេះ គេកាត់
ដើងចោលចេញទៅវិញ មហាជនក្នុងលោក តែងតែចំអកសើចលេង

ទៅវិញជាច្រើនដង ព្រោះបេះដែលគេកាត់ដើងចោល ឲ្យទៅជាកំបុតដូច្នោះ មនុស្សក្នុងលោកពុំអាចនឹងមកបូលចិត្តឡើយ ហើយតែងចំអកសើចលេងទៅវិញ ដោយចំអកថា «ទោ» កំបុតដើង។ បើសិនណាជាមាននរណាស្លៀកទោកំបុតដើងនោះ អ្នកនោះនឹងត្រូវគេសើចចំអក ឥតទៅស្លៀមជានរសោះឡើយ ។

សេចក្តីកោតសរសើរ

ចំពោះចម្លើយចាំង ៤ ខាងលើ កម្ពុជសុរិយា សូមថ្វាយអំណរគុណនឹងកោតសរសើរយ៉ាងស្មោះស្ម័គ្រដល់លោក គីម-ឃីន-ស៊ុសាមុត និងលោក គុយ-សូត្រ ដែលមានច្រើនជាវាងនឹងអាចជោះស្រាយចំណោទគំនិតយើង យ៉ាងត្រឹមត្រូវឥតស្ទាំង ។ កម្ពុជសុរិយា ក៏សូមថ្វាយអំណរគុណដែរដល់លោក លី.ប៊ុនចាំ និងលោក សំ-ដុយ ពោះចម្លើយរបស់លោក មិនសូវត្រូវមែនទែនក៏ដោយ តែយើងសង្ឃឹមថាក្នុងចំណោមទី ៣ លោកប្រហែលជានឹងរកឃើញហើយត្រឹមត្រូវជាមិនខាន ។

សេចក្តីបញ្ជាក់

ចាប់ពីពេលនេះទៅ កម្ពុជសុរិយា នឹងបង្ខំនូវពេលខ្លះឲ្យបានយូរបន្តិចមុននឹងយកចម្លើយរបស់អស់លោកមកបុះផ្សាយ ព្រោះខ្លះពេលឲ្យមិត្រអ្នកអានទៅឆ្ងាយ ។ ដែលក្រចានខ្លួនខ្លះទៀតវាវែង ចានធ្វើយជង ។

ភគ្គិយសុត្តន្ត

ទស្សនាវដ្តី ផ្សាយជំនឿជាំងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៦ លេខ ៥ ខែ មុសភា

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ភ្នំពេញ -

ទេះជាព្រះរាជរថសម្រាប់ ស្តេចយាង ទៅ ក្រុងភ្នំពេញ ដើម្បីទទួលយក ព្រះកេសាធាតុ ព្រះសង្ឃនាយក នៅថ្ងៃទី ១៩ ខែសីហា
ឆ្នាំ ១៩៣៤ ព្រមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រីយានី ព្រះមាតាធិ នឹងសម្តេចព្រះនាគ្គនិ ស៊ីសុវត្ថិ
ព្រះបុត្រា ។



អង្គសន្និសីទ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ព.ស. ២៥៣៤ ពេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

	ទំព័រ
ផ្នែកសាសនា	
ឧទ្ទេសកថា របស់ឧបាសក សុខ-សាខឿន ស្តីពីពិធីដង្ហែព្រះបរមសារីរិកធាតុនៅសៀមរាប	៤៦៣
ភាអភិធម្មបិដក (គម្ពីរព្រះមហាបង្គាន) លោក ចូ-ប៊ី តែងរៀបរៀង (ត) . . .	៤៧៧
ខេត្តណា រៀបរៀងដោយលោក ហោង-សមអាន នៅសេនាធិការ ខេត្តកំពង់ចាម (ត)	៤៨៤
– ព្រះវិធូរជាតក (ត)	៤៩៧
ផ្នែកអក្សរសាស្ត្រ	
– អំពីរបបការរស់នៅនៃមនុស្ស (វិចារណកថា) លោក ផេង-ស្រីវ៉ា និពន្ធ . . .	៥០៦
– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហាចាំង-ខាត់ រៀបរៀង (ត)	៥១៣
– រឿងអាថ៌លហ្គាំគូរីស៍ លោក វ៉ាយ-ស្មុត ដំណាងអាស្ត្រ ប្រែរៀបរៀង (ត) . .	៥១៥
– រឿងបងប្អូនពីរនាក់ ចែកមតិគ្នា លោក ផេង-ស្រីវ៉ា និពន្ធ	៥២២
– រឿងសាមកុក អ្នកទាញរ៉ាបុលរាជសេនា នូ-ហាន ប្រែរៀបរៀង (ត) . . .	៥២៩
– ព្រះរាជនិពន្ធ វាមល្លី ស្រាវជ្រាវ ដោយលោក ខ-ខាម (ត)	៥៣៧
– ចំនៀមទម្ងាប់ខ្មែរ ប្រាសាទវត្តព្រះធាតុ ទំពាធ (ខេត្តកំពង់ចាម)	៥៤៨
ផ្នែកកំណត់ទិន្នប្រវត្តិការណ៍	
– ប្រវត្តិនៃវត្តប្រាង្គ រៀបរៀងដោយព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-ខាត (តបប់) .	៥៦០
– បុណ្យបញ្ចុះសីមា និងជួងព្រះវិហារវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ. . . .	៥៦៧
– រឿងតាំងចៅអធិការ និងត្រួសត្រាក្នុងវត្តខាងក្នុងព្រះរាជអាណាចក្រ (ត) . .	៥៧៣
- ចំព័រកម្មន្ត	៥៧៧

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ២៣០រ៉ៀល

ពាក្យឃោសនាមិនឲ្យ	ធ្វើការអាក្រក់
ជាការសោមក	ឲ្យធ្វើល្អទៅ
ឲ្យផ្ទុះសាតាន់ចិត្ត	កុំឲ្យហ្មងសៅ
ប៊ីនេះលោកហៅ	ពុទ្ធសាសនា

ប.ព.

សុន្ទរកថា

បុណ្យដង្ហែព្រះបរមសារីរិកធាតុ ថ្ងៃអាទិត្យ ១៥ កើតខែពិសាខ ឆ្នាំកេរឯកស័ក ព.ស. ២៥០៧ ត្រូវនឹងថ្ងៃទី ២៦ ខែមេសា ១៩៦៤ ខេបសាក សុខ-សាមឿន រៀបរៀង

សូមក្រាបថ្វាយបង្គំ ដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ *មាន* ព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ *មេគណជាប្រធាន* *សូមប្រណិប័តន៍* ព្រះតេជព្រះគុណ *លោក-អ្នក*ទេកញ្ជាំប្រមុខខេត្ត ព្រះតេជព្រះគុណវរៈសេនីយ៍ត្រី *មេបញ្ជាការយោធភូមិភាគទី ៤* ព្រះតេជព្រះគុណវរៈសេនីយ៍ត្រី *មេបញ្ជាការផ្នែកសឹកវង* ព្រមទាំង*អស់លោកអ្នក* នាម៉ឺនសព្វមុខមន្ត្រី *ក្នុង*ខេត្ត

សូមគោរពសប្បុរសពុទ្ធបរិស័ទ គ្រប់រូប

*សូមទាន*ជ្រាប *សូម*ជ្រាប ។

*តាង*នាម*នៃ*ព្រះតេជព្រះគុណ *អនុគណ* *ខ្ញុំ*ជាភៅអធិការវត្តដំ-ណាក់នេះ *ខ្ញុំ*តាងនាមគណៈកម្មការបុណ្យ *ខ្ញុំ*ព្រះករុណា-ខ្ញុំបាទ *សូម* សម្តែងនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ *ខ្ញុំ*សូមានចិត្តយ៉ាងពាក់ព័ន្ធ *ចំ* ពោះព្រះតេជព្រះគុណ*លោក-អ្នក* ដែលបានអញ្ជើញមកជាអធិបតី *ក្នុង*

តាំងពីបុណ្យដង្ហែព្រះបរមសារីរិកធាតុយ៉ាងខ្លាំងអធិកអស្ចារ្យ គួរឲ្យរំភើប
ព្រឺរោមត្រឹស្បែកខ្លួនតាំសព្វថ្ងៃរៀងមក ។

ព្រះថេរានុត្ថេរៈ ព្រះតេជព្រះគុណ លោកអ្នកសប្បុរសតាំងពីឆ្នាំ
ចូលមកកាន់ឆ្នាំជាគំរប់ ១៧ ហើយ ដោយគិតពីឆ្នាំ ១៩៤៧ មក
ទល់ថ្ងៃនេះ ដែលតុន្ទបរិស័ទវត្តដំណាក់ មានព្រះតេជព្រះគុណព្រះនាម
ខិត-ខិម អតីតមេគណ ទីឯជាចៅអធិការវត្តដំណាក់ជាប្រធាន ចាប់ផ្តើម
ធ្វើបុណ្យដង្ហែព្រះបរមសារីរិកធាតុរៀងរាល់ឆ្នាំមក មិនដែលអាក់ខានឆ្នាំណាឡើយ ។ ចំណែកខាងវត្តព្រះព្រហ្មវត្តម៍ ដែលមានព្រះតេជ-
ព្រះគុណមេគណបច្ចុប្បន្ននេះ ចាប់នាំពុទ្ធបរិស័ទ មកចូលរួមដង្ហែជាមួយទីឯ
ក្រុមពុទ្ធបរិស័ទវត្តដំណាក់ ជាគំរប់ ៣ ឆ្នាំហើយដែរ គិតពីឆ្នាំ ១៩៦២
មក ។

តទៅនេះ ខ្ញុំព្រះករុណា ខ្ញុំចាប សូមថ្វាយរៀបរាប់ដោយសង្ខេប
ពីប្រវត្តិការណ៍នៃការប្រតិស្ឋានដ៏តល់ទុក នៃព្រះបរមសារីរិកធាតុដំ-
ណាក់ដូចតទៅនេះ សូមពុទ្ធបរិស័ទប្រុងស្តាប់តើស្តាប់ចុះ ៖

ប្រមាណ ៤០ ឆ្នាំកន្លងទៅហើយ កាលខោះព្រះតេជព្រះគុណអា-
ចារ្យព្រះនាម ខែក ទីឯព្រះអាចារ្យ ចាន់ គង់វត្តនេះ ចាប់ខំមនុស្សទៅកាន់
ប្រទេសសៀម ដើម្បីបំពេញវិជ្ជាធម៌ុះ ក្នុងសំណាក់លោកគ្រូអាចារ្យ
ព្រះនាម ផាង ធំផាវ ជាយោគាវចរកិត្តិ ព្រះអង្គ មានឧត្តមលក្ខណ្ឌ

តង់នៅព្រៃក្តុំ ជាំជាំដរកា ខាងលិចក្រុងជាងកក ។ ទុកាសនោះលោក
គ្រូអាចារ្យខែក ទើបលោកគ្រូអាចារ្យចាន់ ជានសាកសួរលោកគ្រូអាចារ្យ
ជាវ៉ាថា : ព្រះតេជព្រះគុណ ព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធ
ម្ចាស់យើងសព្វថ្ងៃនេះ ប្រតិស្ឋានទៅកន្លែងណាខ្លះ លោកគ្រូអាចារ្យជាវ
ឆ្លើយថា : តាមកូនគម្ពីរ ព្រះសារីរិកធាតុស្ថិតនៅលើអាកាសទៅ
ហើយ ដោយមិនស្ថិតមានគេទឹកនាគោរពបូជា ។ លោកអាចារ្យខែក
មានថេរៈដីកាថា : នៅស្រុកខ្មែរសព្វថ្ងៃនេះ មិនមានមានព្រះសារីរិកធាតុ
ទេ តើគប្បីស្វែងរកដោយវិធីណា ព្រះតេជព្រះគុណ ។ លោកគ្រូអា
ចារ្យជាវ ឆ្លើយថា : បើដូច្នេះ យើងអធិដ្ឋានផ្សងលមើល ក្រែងជាន
ដូចបំណង ។ កុងយប់ ១ នោះ យោគាវចរកុំពុំតាំងឡាយនោះ ជានធ្វើ
សមណៈធម៌ផ្សង ៗ ពីគ្នា រួចនមស្សការអធិដ្ឋាន ។ ដល់យប់ជ្រៅ
ស្រាប់តែឮសូរសន្ធឹកឮល់ ខណដូចជាសូរគ្រាប់ភ្លៀងធ្លាក់រណ្តៅស្ទឹកឈើ
បៃបអស្ចារ្យចំឡែកពីធម្មតា ។ វេលាភ្លឺឡើង ទើបឃើញព្រះបរមសារី.
រិកធាតុប្រើនអង្គ ស្ថិតនៅចំពោះព្រះកែវ្រលោកគ្រូអាចារ្យជាវ ទើបលោក
ចែកប្រគេនមកលោកគ្រូអាចារ្យខែក ខណលោកគ្រូអាចារ្យ ចាន់ លោក
គ្រូអាចារ្យខែក ខណលោកគ្រូអាចារ្យ ចាន់ ក៏ជានខិមន្តព្រះបរមសារីរិកធាតុ
ៗ ព្រះអង្គមកប្រគេនព្រះតេជព្រះគុណព្រះនាមអ៊ុត អតីតចៅអធិការវត្ត
ដំណាក់ ជានដំកល់ទុកមក រហូតដល់សព្វថ្ងៃនេះ ។ ព្រះបរមសារីរិកធាតុ

នេះ ចំហាំខ្លាតតណ្ដាល ប៉ុនតំណាត់ត្រាប់អង្គរ ពណ៌ដូចតែវាលលិក មានពណ៌ច្រែនយ៉ាង មានពណ៌តណ្ដៀងទឹកខ្ចី ទំនងពាលវគ្គន៍ជាដើម ។ ដោយហេតុមានការគោរពបូជាជានិច្ចកាល ព្រោះបុរាសន៍តាំងឡាយ ព្រះបរមសារីរិកធាតុ ចានកើនចំនួនឡើងពី ៣ ព្រះអង្គ ទៅប្រមាណ ៨ ព្រះអង្គ ហើយចានចែកផ្សាយទៅវត្តដទៃ ។ ទៀត មានវត្ត ធម្មិស្សរភាម វត្តបទុម ស្រុកស្អាង វត្ត តរ ចាត់ជំបង វត្តសំប៉ាន វត្តជម្ពុត្តិ ខេត្តកំពតជាដើម ។ល។ នេះ សរឲ្យឃើញថា មានសេចក្ដីអស្ចារ្យណាស់ ។

រីឯប្រវត្តិនៃព្រះសារីរិកធាតុ ដែលស្ថិតនៅក្នុងវត្តព្រះព្រហ្មវគ្គន៍នោះ កាលពីថ្ងៃទី ៧ ខែ មីនា គ.ស. ១៩៥៦ ព.ស. ២៤៩៩ មានព្រះថេរៈ ១ ព្រះអង្គព្រះនាម អ៊ូ-តេជេន្ទ្រៈ ជាតិភូមា គ្រូបង្រៀនកម្មដ្ឋាន ចានទាំយកព្រះសារីរិកធាតុ ៣ ព្រះអង្គ មកប្រគេនព្រះសុមង្គលសីលាចារ្យ មេគណបច្ចុប្បន្ននេះ តែព្រះមេគណក្ដី ពុទ្ធបរិស័ទដទៃៗក្ដី មានសេចក្ដីសង្ស័យក្រែងមិនមែនជាព្រះសារីរិកធាតុ ជារបស់ក្លែងក្លាយ ព្រោះព្រះសារីរិកធាតុជារបស់ក្រណាស់ ហេតុអ្វីក៏ចានដោយងាយ-ងាយម្ល៉េះ ។ លុះថ្ងៃទី ៤ ខែ មិថុនា គ.ស. ១៩៥៨ ព.ស. ២៥០១ ព្រះថេរៈអង្គនេះក៏និមន្តមកគាន់សំណាក់ព្រះមេគណម្ដងទៀត ដោយដួនដំណើរព្រះថេរៈជាតិភូមាដទៃ ។ មកទស្សនាបូកណាវត្ត ព្រះមេគណាចានសួរលោកថា ព្រះសារីរិកធាតុដែលចានមកពីមុននោះ តើចានពីណាមក មិនពិតទេដឹង ។ លោក

ឆ្លើយថា ក្នុងប្រទេសកូមា មានព្រះចេតីយធំចាស់ ១ ពាដកាបានរុះរើ ដើម្បីស្ថាបនាជាថ្មី លុះរើទៅបានឃើញ ព្រះសារីរិកធាតុច្រើន គេបានប្រគេនព្រះថេរៈធំ ៗ ខ្លះ ទុកជាសក្ការៈបូជា ខ្លួនលោកត្រូវបានចំណែក ៣ ព្រះអង្គដែរ គឺព្រះសារីរិកធាតុនេះឯង ហេតុនេះមិនត្រូវសង្ស័យឡើយ ព្រោះការកុហក ឬបញ្ឆោតនោះមិនមានប្រយោជន៍អ្វីទេ ។ ព្រោះហេតុនេះហើយ លោក-អ្នកជាពុទ្ធបរិស័ទគាំងឡាយ មិនត្រូវមានការសង្ស័យទៀតឡើយ ។ ព្រះសារីរិកធាតុនេះ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ មានពណ៌ដូចមាស ។

ព្រះថេរកន្តេរៈ ព្រះតេជព្រះគុណ លោក-អ្នកសប្បុរសគាំងឡាយ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង កាលព្រះអង្គទ្រង់បរិនិព្វានទៅមានតែ ៤ យ៉ាងជាមតកវបស់ព្រះអង្គ ទុកជាគ្មើរដំណែល យ៉ាងជាក់ស្តែងណាស់ សម្រាប់ពុទ្ធបរិស័ទជំនាន់ក្រោយ គោរពប្រណិប័តន៍ស្នងព្រះអង្គ ដើម្បីបំពេញមគ្គផលតាមប្រាថ្នាគឺ :

១- ព្រះបដិមាករ គឺព្រះពុទ្ធរូប ដែលពុទ្ធបរិស័ទសាងឡើងអំពីមាសក្តី ប្រាក់ក្តី តែវក្តី ថ្មក្តី ។ល។

២- ព្រះមហាពោធិព្រឹក្សនៅប្រទេសឥណ្ឌា សព្វថ្ងៃគង់ព្រះជន្មនៅឡើយ ។

៣- ព្រះស្តូបបញ្ចុះព្រះបរមសារីរិកធាតុ ។

๔- ព្រះត្រៃយបិដក ប្រកបដោយព្រះធម្មក្ខន្ធ ๘๔.๐๐๐ កំមាន ស្ថិតនៅទាំងអស់ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមរៀបរាប់ដោយសង្ខេបអំពីព្រះបរមសារីរិកធាតុដូចតទៅនេះ :

ព្រះបរមគ្រូនៃយើង ព្រះអង្គប្រកបដោយនិព្វាន ៣ ប្រការ គឺ កិលេសនិព្វាន ๑ ខន្ធនិព្វាន ๑ ធាតុនិព្វាន ๑ ។

- កិលេសនិព្វាន គឺកាលព្រះអង្គបានបរមាភិសេកអនុត្តរសម្មាសម្ពោធិញ្ញាណ ក្រោមម្លប់មហាពោធិព្រឹក្ស ក្នុងព្រះជន្មាយុ ๓๕ ព្រះវស្សា ព្រះអង្គបានរំលត់កិលេស ๑.๕๐๐កង់ នឹងតណ្ហា ๑๐๘ ដោយជ្រះស្រឡះ ចំថ្ងៃ ๑๕ កើត ខែពិសាខ ឆ្នាំរកា ។

ខន្ធនិព្វាន គឺលុះព្រះអង្គប្រោសសត្វលោកបានគ្រប់ ๔๕ ព្រះវស្សាហើយ ចូលក្នុងព្រះជន្មាយុ ๘๐ ឆ្នាំគត់ នៅថ្ងៃ ๑๕ កើតខែពិសាខ ឆ្នាំម្សាញ់បញ្ចស័ក ថ្ងៃអង្គារ ព្រះអង្គទ្រង់រំលត់បញ្ចក្ខន្ធ ចូលកាន់ព្រះបរមនិព្វាន ក្រោមលង្វែកមែកសាលព្រឹក្សទាំងគូ ក្នុងនគរកុសិនារ ។

- ធាតុនិព្វាន គឺគិតពីឆ្នាំដែលព្រះអង្គចូលកាន់ព្រះនិព្វាន ទៅខាងមុខ្ងសាសនាកាលគ្រប់ ๕.๐๐๐ ព្រះវស្សា ដែលត្រូវនឹងឆ្នាំជូត ហើយព្រះបរមសារីរិកធាតុទាំងអស់នៅទីស្ថានណាក៏ដោយ ក៏ត្រូវតែនិមន្តទៅប្រជុំសមោធាន កើតជាព្រះភ្នំខ្ពស់ម្តែងថ្កានដ៏ហារ្យ ๑ ព្រះអង្គដូចដើម

ហើយក៏រលាយរលត់ទៅ ។

ចំណែកឯកំលេសនិព្វាន ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមស្នើទុក សូមអធិប្បាយតិទ្ធនិព្វាន នឹងជាតុនិព្វាន ដូចតទៅនេះ :

- អំពីទុទ្ធនិព្វាន : កាលព្រះអង្គរលត់ទុទ្ធចូលព្រះនិព្វាន ហើយ ផ្នែកបឋមដំណាក់ព្រះអានន្ទត្ថេរ នឹងព្រះអនុរុទ្ធត្ថេរជាប្រធាន ផ្នែកគ្រហស្ថ មានពពួកមល្លក្សត្រជាប្រធាន បានរៀបចំធ្វើឈាបនកិច្ច រំលាយព្រះបរមសពដូចតទៅ ។ មុនដំបូង គេរុំព្រះសរីរៈព្រះអង្គដោយសំពត់ថ្មី រួចរុំសំឡី រុំសំឡីហើយ រុំសំពត់ថ្មីថែមទៀត រុំព្រះសរីរៈព្រះមានព្រះភាគ ដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយដាក់ក្នុងមណ្ឌលសមាសដែលជាក់ប្រែង ។ គ្រាក្រោយមក ពួកមល្លក្សត្របានធ្វើបុណ្យដង្ហែព្រះបរមសពតាមបំណងរបស់ពួកទេវតា គឺហៅទៅទិសទាន ដើងក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារទោងដើង ហើយហៅទៅត្រង់កណ្តាលក្រុង ទើបចេញទៅតាមទ្វារទោងកើត ហើយថ្វាយព្រះភ្លើងព្រះសរីរៈព្រះមានព្រះភាគកងមកុដពន្ធនចេតីយ តែភ្លើងពុំឆេះសោះ ។ ព្រះអនុរុទ្ធត្ថេរ មានថេរដីកាថា : បំណងទេវតា ថាឲ្យចាំព្រះមហាកស្សប និងតិក្ខុ ៥០០ រូបនិមន្តមកថ្វាយចង្គំព្រះបាទ ទើបដើងថ្វាយនេះដូចបំណង។ បន្ទាប់មក ព្រះមហាកស្សបត្ថេរ និងតិក្ខុ ៥០០ រូបនិមន្តមកដល់ កំលោកប្រណម្យអញ្ជលី ធ្វើប្រទក្សិណដើងថ្វាយ ៣ ដុំ ស្រាប់តែព្រះបាទព្រះអង្គ

ទាំងគួរលឿនជ្រាយចេញមកពីមឈូសមាស ទើបលោកថ្វាយបង្គំជាក់លើ
ព្រះសិរ្ស ហើយត្រង់អង្គហើយ ដើងថ្វាយព្រះមានព្រះភាគក៏នេះឯង ដោយអានុ-
ភាពនៃទេវតា ។ បណ្តាសំពត់ ៩០០ គូ គឺនេះតែ ២ គូ គឺសំពត់ជាន់ទាង
ក្នុងបំផុត ១ សំពត់ជាន់ក្រៅបំផុត ១ សំពត់ឯទៀត ។ ទៅសល់ទាងអស់
បំណែកព្រះឆៅ គឺពណ៌សម្បុរសែ្បកក្តី ព្រះចម្ងៃ គឺសែ្បកក្តី ព្រះមំសៈ
គឺសាច់ក្តី ព្រះហ្គារូ គឺសសៃក្តី ព្រះលសិកា គឺខ័កអំលែក្តី ក៏នេះអស់លើង
មិនមានផេះនឹងកំញាមជ្រូងឡើយ ។ រីឯព្រះកេសធាតុ «សក់» ព្រះលោម
ធាតុ «រោម» ព្រះនខធាតុ «ក្រចក» ព្រះទន្តធាតុ ៤០ «ធ្មេញ» នៃព្រះ
អង្គទាងប៉ុន្មាន ពុំមានផេះសោះឡើយ សូម្បី ១ សសៃនឹង ១ កូនដុំ ហើយ
ទេវតានាំយកក្នុង ១ អង្គ ។ ឆ្អឹងព្រះធាតុ ១ អង្គ ទៅកាន់ចក្រវាឡរៀង
ខ្លួន សម្រាប់គោរពបូជា ។ ព្រះអដ្ឋិធាតុដែលនៅសល់ សុទ្ធតែបែកចេញ
ជាបំណែកតូច ។ រៀវលែងតែព្រះអដ្ឋិធាតុ ៧ ព្រះអង្គ គឺឆ្អឹងថ្ងាស ១ ព្រះ
បង្គុមកែវ ៤ ខ័ងឆ្អឹងជង្គាបាត ២ ។ ព្រះសារីរិកធាតុទាងអស់ វាល់បាន ១២
នាឡិ គឺខ្នាតធំ ចំហាប៉ុនកំណាត់ត្រាប់សណ្តែកចុយ ពណ៌ដូចមាស វាល់
បាន ៥ នាឡិ ។ ព្រះធាតុខ្នាតកណ្តាល ចំហាប៉ុនកំណាត់ត្រាប់អង្គរ
ពណ៌ដូកែវផលិក វាល់បាន ៦ នាឡិ ។ ព្រះធាតុខ្នាតតូច ចំហាប៉ុនគ្រាប់
សែ្ពៃ ពណ៌ដូចផ្កាផ្កុល វាល់បាន ៥ នាឡិ ។ តទៅនេះ សូមអធិប្បាយ
ពីធាតុនិព្វាន :

២- ជាតុដ្ឋាន : លុះព្រះពុទ្ធសាសនកាល ស្ថិតនៅជាង
គ្រប់ ៥.០០០ ព្រះវស្សាហើយ ព្រះបរមធាតុសម្តេចព្រះមុនីនាថជាម្ចាស់
ទាំងប៉ុន្មាន ដែលទៅប្រតិស្ឋាននៅក្នុងតំបន់ផ្សេង ។ ក៏អណ្តែតត្រសែត
មកប្រជុំសមោធាន ជាអង្គព្រះសម្មាសម្ពុទ្ធ ដូចជាមានព្រះជន្មាយុគ្រង់នៅ
ដូចដើម ហើយគ្រង់ផ្តត់ព្រះកែ្ខនលើតេនចល្លង្ក គ្រង់កន្ទេងព្រះមហាពោ-
ធិព្រឹក្សសព្វថ្ងៃនេះ គ្រង់ព្រះមហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០
ព្រះឆព្វណ្ណរង្សី ៦ ពណ៌ គ្រង់សំដែងព្រះធម៌ជាហេតុអស់៧ថ្ងៃ ពួកទេវតា
ព្រះឥន្ទ ព្រះព្រហ្ម ។ ល ។ ទាំងឡាយ ដែលកាន់ផ្លូងបុប្ផា កម្រងមាលា
សក្ការៈគ្រប់ប្រការ ចុះចាកវិមានរបស់ខ្លួន នាំគ្នាតីតកងមកថ្វាយបង្គំប្រ-
ណម្យនមស្ការបូជា បានសម្រេចជាមិរិសេសជាន់ខ្ពស់ តាំងពីសោតាបត្តិ
ដល់ព្រះអរហត្តភាប់បាន ២៤ អសង្ខ្យេយ្យ ៦ លាន ៦សែន ៧ពាន់ ៨០
កោដិ ។ ដល់គ្រប់ ៧ ថ្ងៃហើយ តេជោធាតុកំតាំងឡើងប្រលឹយអង្គព្រះ-
ពុទ្ធរូប ព្រះបរមធាតុឲ្យសុះសូន្យអស់ទៅ ។ ព្រះពុទ្ធសាសនកាលនៃព្រះ
គោតមជាម្ចាស់នៃយើង បបរបាបូណិតែប៉ុណ្ណោះ ។

ហេតុនេះ សូមពុទ្ធបរិស័ទទាំងឡាយ បញ្ចោញសទ្ធាឲ្យមាំមួន ប
ន្ទោះព្រះបរមសារីរិកធាតុចុះ ចំណាប់យើងកើតមក ពិតតែពុំបានទាន់ព្រះ
អង្គតង់ធមានៅឡើយ តែទុកដូចជាយើងបានទាន់ដូចគ្នា ព្រោះមានវត្តុដ៏
ប្រសើរ ៤ ប្រការជាសក្ខីភាព ជាមគេកដ៏ថ្លៃថ្លា រកវត្តុអ្វីមកប្រៀបធ្ងឹមស្មើ
គ្មានរបស់ព្រះបរមត្រៃនៃយើង ប្រតិស្ឋានទុកសម្រាប់គោរពបូជាពាល់ថ្ងៃ

គឺ ១- ព្រះបដិមាករ ២- ព្រះមហាពោធិព្រឹក្ស ៣- ព្រះបរមសារីរិកធាតុ ៤- ព្រះត្រៃយបិដក ប្រកបដោយព្រះធម្មក្ខន្ធ ៨៤.០០០ ។

ទីបំផុតនៃសុន្ទរកថានេះ យើងខ្ញុំតាំងអស់គ្នា សូមប្រមូលបុញ្ញកុសលវិជ្ជាចេតសិកធម៌ សព្វសក្ការៈ-ថ្វាយសក្ការៈបូជា ទីឆកំលាំងពលំ ទំដង្ហែព្រះបរមសារីរិកធាតុនេះ ថ្វាយជាព្រះពរជ័យសួស្តីជល់ព្រះសង្ឃគ្រប់តាំង ២ គណៈ ជល់សម្តេចអម្រិន្ទវន្ទ្រាធិបតីជាសក្តេវរាជ ទីឆ៍ទេវតាកង់អនន្តចក្រវាឡ ជល់សម្តេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិតលើត្បូង ទីឆ៍សម្តេចព្រះទេបយុវរាជ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ជូនជល់មាតាបិតាគ្រូទេបជ្ឈាយាចារ្យ ទីឆ៍ញាតិមិត្តគ្រប់រូប ឲ្យបានប្រកបតែទីឆ៍សេចក្តីសុខ ទីឆ៍សេចក្តីចំរើន ហើយលុះដល់អវសានជាតិ សូមឲ្យបានសម្រេចព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ ។

រៀបរៀងដោយ ឧបាសក សុខ - សាមឿន កែសម្រួលដោយ ឧបាសក ឆង - ប៊ុនឡុង ឧបាសក អាំង - ហួត ព្រះតេជព្រះគុណ មេគណ ឈិត - តិត ព្រះតេជព្រះគុណអាចារ្យ ស៊ុន - សាន ទីឆ៍ព្រះតេជព្រះគុណ មេគុណព្រះនាម កែ-អឿន ។

សូមព្រះបដិមាករ ព្រះស្រីមហាពោធិព្រឹក្ស ព្រះបរមសារីរិកធាតុ ព្រះត្រៃយបិដក ព្រះសម្មតិសង្ឃសាវកព្រះបរមគ្រូ ស្ថិតនៅគ្រប់ ៩.០០០ ព្រះវស្សា ដើម្បីជាមូលដ្ឋានគ្រឹះដ៏ត្រជាក់ជល់ពុទ្ធបរិស័ទ សត្តនិកាយទាំងត្រៃភព . . . ។

ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ - ប៉ូ រៀបរៀង

ពន្យល់

វិបាកបច្ចុយ

វិបាកបច្ចុយនិទ្ទេសេ កុសលំ កម្មំ កត្វា តស្ស វិបាកេន សុគតឹ គច្ឆតិ អកុសលំ កម្មំ កត្វា តស្ស វិបាកេន ទុគ្គតឹ គច្ឆតិ តស្មា វិបាកបច្ចុយោ ជាមាតិ វេទិតព្វោ ។

លំដាប់នេះ សូមវិសជ្ជនាកន្លងវិបាកបច្ចុយតទៅ ដំណើរសេចក្តីថា វិបាកបច្ចុយនិទ្ទេសេ ក្នុងវិបាកបច្ចុយនិទ្ទេសនោះ សម្តេចព្រះព្រំព្រះភាគត្រាស់ព្រះសព្ទមួយទេសនាដោយវិបាកបច្ចុយ ។ ឯវិបាកនោះ បានន័យដូចផលនៃកុសលន័យដូចផលនៃអកុសលដែលបុគ្គលធ្វើហើយ ។ កុសលំ កម្មំ កត្វា បុគ្គលណាធ្វើការកុសល ។ នោះឈ្មោះ បុគ្គលនោះ ក៏បានទៅកាន់សុគតិភព ដោយផលនៃការកុសលនោះ ។ អកុសលំ កម្មំ កត្វា បុគ្គលដែលធ្វើអកុសលកម្ម ក៏បានទៅកាន់ទុគ្គតិភព ដោយផលនៃអកុសលកម្មនោះ ។

តស្មា វេនិតព្វោ ហេតុនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា វិបាក
គឺផលនៃកម្មនោះ ជាបច្ច័យចែកចេញជាពីរប្រការ គឺផលនៃកុសលកម្ម
ប្រការ ១ ផលនៃអកុសលកម្មប្រការ ១ ។

ផលនៃកុសលនោះ ចើបុគ្គលបានចំរើនឈាន ផលឈាននោះ
តំនាំឲ្យទៅកើតក្នុងព្រហ្មលោក ។ ផលនៃទានក៏តំនាំឲ្យទៅកើតក្នុងសុគតិ
ភព ។ ផលនៃសីលក៏តំនាំឲ្យទៅកើតក្នុងព្រហ្មលោកដូចគ្នា ។ ហេតុនោះ
វិបាកគឺផលនៃកម្ម ទើបឈ្មោះថាជាបច្ច័យ ។ ផលនៃបុគ្គលដែលបាន
ចំរើនឈាន ទំនងបានទៅកើតក្នុងព្រហ្មលោក ។

ព្រះអដ្ឋកថាចារ្យ ពោលពុទ្ធដីកាឧទានសូត្រ ក្នុងសត្តកអង្គុត្តរ
សូមនាំមកសំដែងឲ្យជាទុតាហរណ៍ដោយសង្ខេបក្នុងវិបាកបច្ច័យថា ផល
នៃកុសលកម្មនោះតែងនាំបុគ្គលអ្នកធ្វើ ឲ្យទៅកើតក្នុងព្រហ្មលោក សេចក្តី
ថា ៖

ក្នុងគ្រានោះ ព្រហ្មវិមានគឺបឋមជ្ឈានក៏មិនមានទេ គ្មានព្រហ្មទៅកើត
សោះ តថា ពោលេ ពោះបានឮមក គ្រានោះ សម្តេចព្រះពុទ្ធអង្គជា
ម្ចាស់នៃយើង នៅគ្រាចំរើនតំកូនសង្ឃរាវជ្ជ ជាចរមពោធិសត្វ ទ្រង់កសាង
ព្រះបារមី ទ្រង់បួសជាឫសីឈ្មោះថាសុនេត្តតាបស បំពេញព្រហ្មវិហារធម៌
នៅក្នុងវិត្រហិមភាគ្គ អដ្ឋ សមាបត្តិលាភី សុនេត្តតាបសនោះបាន
សមាបត្តិ ៨ ប្រការ ទំនងបានអភិញ្ញា ៥ ប្រការ តាំងពីណាមើលរបស់ដែល

ជាប្រយោជន៍ដល់សត្វសត្វ ខ្ញុំឯងបានមើដែលនឹងញាំងព្រះហឫទ័យឲ្យបានបរមតុដ្ឋភាពសេចសម្បត្តិ ខ្ញុំឯងបានត្រាស់ជាអគ្គព្រះអរហន្ត កន្លងកាលខាងមុខ ឯកាឆ្ពី ឧបរាធេត្វា ទើបញាំងសេចក្តីត្រេកអរឲ្យកើតមានក្នុងឈាន ពីរប្រការ គឺមេត្តាព្រហ្មវិហារនឹងករុណាព្រហ្មវិហារ ។ តាបសដែលបានស្តាប់នូវទំនៅនៃសុនេត្តតាបសនោះច្រើនជាងរយរូប តាំងនៅក្នុងទំនាក់នៃសុនេត្តឫសី លុះអស់ជីវិតទៅ ក៏មានសុគតិជាទីទៅខាងមុខ ។ ពួកខ្លះបានទៅកើតក្នុងព្រហ្មលោក ។ ពួកខ្លះបានទៅកើតក្នុងឆកាមាវចរសួគ៌ ។ ពួកខ្លះបានទៅកើតក្នុងត្រកូលនៃក្សត្រជាខត្តិយមហាសាល ជាព្រាហ្មណមហាសាល ជាគហបតីមហាសាលផ្សេង ។ គ្នា ។ ឯបុគ្គលដែលរក្សាសីល ។ ក៏ឲ្យផលមានប្រការផ្សេង ។ តាមតែចេតនា គឺអ្នកខ្លះបានរក្សាសីលប្រាំប្រការ សីលប្រាំបីប្រការ ទឹងសមាទានសីលដប់ប្រការ សីលពីរយេម្ភៃប្រាំពីរ (២២៧) សមាទានជាឯកជ្ឈសមាទាន ជាបច្ចេកជ្ឈសមាទាន ។ អ្នកខ្លះវៀរចាកបាណាតិបាត ដោយអំណាចសម្បត្តិវៀតនឹងសមាទានវៀត ។ អ្នកខ្លះតាំងនៅក្នុងព្រះត្រៃសរណគមន៍ អ្នកខ្លះចំរើនពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ឧបសមានុស្សតិ មរណានុស្សតិ កាយគតាសតិ អានាបានសតិ ។ ផលនៃកុសលកម្មទាំងនោះ ជាបច្ច័យឲ្យបានទៅកើតក្នុងសុគតិភពផ្សេង ។ ។

ឯបុគ្គលដែលបានរក្សាសីល ផលនៃសីលនោះជាបច្ច័យដូចសត្វល្អ
បាយិកាខេត្តា កាលកើតជាមនុស្សនៅឡើយ ធ្វើជាឈ្មួញសំពៅប្រាំពីរ
រយនាក់ បានទទួលសីលប្រាំក្នុងវេលាជិតនឹងផុតជីវិត លុះបុគ្គលចុតចិត្តហើយ
បានទៅកើតក្នុងស្ថានសួគ៌ ។ រុក្ខទេវតាបានរក្សាទុកបាសាទសីលពាក់
កណ្តាលថ្ងៃ គឺកន្លះថ្ងៃ កាលទៅជាមនុស្ស ធ្វើជាកូនឈ្លួលនៃអនាថ-
បិណ្ឌិកសេដ្ឋី ។ អ្នកដែលបានរក្សាសីលជាប់ ដូចទេវតាមួយអង្គមាននៅក្នុង
មាសេយ្យសូត្រដោយពិស្តារ ។ អ្នកដែលមិនបានសមាទានសីលអំពីសំ
ណាក់លោកណាឬខ្លួនឯងទេ ប៉ុន្តែវៀរចាកការសម្លាប់សត្វដោយសម្បត្តិ
វិរតិ គឺសត្វមានជីវិតមកជល់ ខ្លួនមិនបានសម្លាប់ ដូចបក្ខនទុបាសកក្នុង
សីហលទ្វីប ទៅចាប់ខន្ធាយយកមកធ្វើថ្នាំរក្សាជម្ងឺមាតា លុះខន្ធាយមក
ជាប់អន្ទាក់ហើយ មិនបានសម្លាប់ ត្រឡប់ជាលែងខន្ធាយឲ្យរួចជីវិតទៅ
វិញ នេះជាសម្បត្តិវិរតិ ។ កាលបក្ខនទុបាសកវិលមកជល់ផ្លុះ ធ្វើសប្ប
កិរិយា មាតាក៏បានសះជាភេត ដោយកម្លាំងផលនៃពាក្យសត្យនឹងផលនៃ
សម្បត្តិវិរតិនោះឯង ។

ឯសមាទានវិរតិ គឺកិរិយាដែលបុគ្គលវៀរចាកបាណាតិបាតដោយ
អំណាចសមាទាន ផលនៃកុសលនោះជាបច្ច័យឲ្យផុតចាកអន្តរាយនៃជី-
វិតក្នុងបច្ចុប្បន្ន ដូចខន្តវៀរឲ្យមានទុបាសក ។ នោះ ឬទ្ធិទៅឯកំពូលភ្នំ
តិតនឹងកាប់ឫស្សី ពស់ថ្លាន់រឹតជាប់ ហើយមិនបានសម្លាប់ពស់ថ្លាន់នោះ

ធ្វើសច្ចកិរិយាចប់ ពស់ថ្នាន់តិណាលែងរឹត លូនចូលទៅកន្លែងព្រៃជាតិដដែល ។

បុគ្គលអ្នកកាន់តាមព្រះវិន័យ ហើយកើតមានខ្លាចភ័យនោះ ក៏អត្តភាពជាតិដដែល ដូចអ្នកនគរវាសាលី កាលកើតមានភ័យបីប្រការ គឺភេតភ័យ អមនុស្សភ័យ និងពុំពួកភ័យ ភ័យទាំងនេះ ក៏អត្តភាពជាតិដដែល ដោយអានុភាពនៃព្រះវិន័យ ។ ម្យ៉ាងទៀត ដូចសុបតិស្សទេវបុត្ត ដែលនឹងដល់នូវមរណភ័យ ក្នុងរោងចក្រ ៧ថ្ងៃ អត្តភាពនៃជីវិតនោះ ក៏អត្តភាពជាតិដដែល ដោយអានុភាពនៃផល ដែលខ្លួនបានស្តាប់ព្រះធម្មទេសនាមេត្តាព្រះពុទ្ធសាសនា ផលកុសលនោះជាបច្ច័យបំបាត់នូវទោសៈចនូវនិព្វាន ។

បុគ្គលទាំងឡាយដែលបានបំពេញទាន ផលនៃទានក៏ជាបច្ច័យ ។ ទានដែលឲ្យដល់បុគ្គលឥតសីលបានផលតិចជាង ឲ្យដល់បុគ្គលមានសីល ។ ទានដែលឲ្យដល់អ្នកមានសីល មោះមានផលច្រើនអស្ចារ្យ ។ ការឲ្យទានដល់អ្នកមានសីលនោះមានច្រើនស្ថាន គឺឲ្យដល់គ្រហស្ថ១ ចាសក១ ចាសិកា អ្នករក្សាសីលប្រាំ រក្សា១ ចាសថ សមាទានសីលដប់ និងសាមណេរដែលរក្សាសិក្ខាបទនៃសាមណេរ និងប្រគេនដល់ភិក្ខុសង្ឃអាទិសង្ឃក៏ចេះតែមានច្រើនកើនឡើងតាមលំដាប់ ។ ផលនៃទាននោះក៏ជាបច្ច័យឲ្យនូវសុខដរាបដល់បរិនិព្វាន ។ ប៉ុន្តែ ការធ្វើទានឲ្យបានជាសង្ឃទាននោះ កម្រនឹងតាំងចិត្តណាស់ គឺថាខ្លួនទៅសូមសង្ឃមកតំណាងសង្ឃ តបបីតាំងចិត្តគោរពក្នុងសង្ឃឲ្យស្មើគ្នា បើសូមបានព្រះមេ-

ហាវេរ កំពុងត្រេកអរថាអញបានព្រះមហាវេរជាធំ ថើបបានកំពុងក្មេងខ្ចី
វស្សាក៏កំពុងតូចចិត្ត តបប្រតាំងចិត្តឲ្យស្មើគាកងសង្ឃ ធ្វើវត្តប្រតិបត្តិឲ្យល្អស្មើ
គ្នា កុំមានសេចក្តីគោមនស្សទំនងសោមនស្ស ទានេះទើបចាត់ជាសង្ឃ
ទានបាន ដូចទេចាសកម្ចាត់សាងវិហារនៅជិតនេះស្មើង ។ ទេចាសកនោះ
ធ្វើសង្ឃទានពាលថ្ងៃ តាំងចិត្តគោរពយាំងមាំកងសង្ឃស្មើគ្នា មិនតិតថា
ជាកិកូតូចប្តូរឡើយ ស្រេចតែបានមកអំពីសំណាក់សង្ឃ ហើយក៏គោរព
ស្មើគ្នា ។ ទេចាសកនោះប្រគេនអាហារចំណាបាតជាន់ច្រ ។

មានកាលថ្ងៃមួយ កិកូដែលទៅទទួលសង្ឃទាន ប្រព្រឹត្តទូរអសទ្ធម្ម
សមាចារនឹងកិរិយារបស់ទេចាសកនោះមកជាច្រើនថ្ងៃ ច្រើនវេលា លុះដល់
វេនវៃនកិកូនោះ សង្ឃចាត់ឲ្យមកទទួលសង្ឃទាន នៅផ្ទះទេចាសក។ កំតាំង
ចិត្តស្មោះត្រង់ថា សង្ឃមកទទួលសង្ឃទានហើយ ធ្វើអាការជាមិគោរព
គ្មានចិត្តក្តៅក្រហាយសោះឡើយ ។ កិកូនោះទទួលសង្ឃទានរួចហើយ
ត្រឡប់ទៅវិហារវិញ លុះដល់វេលារសៀលទំនងធ្វើកុដិ ចូលមកផ្ទះទេចាស
នោះ ហើយមិយាយខ្ចីចបទេចាសក ។ ក្រាប់ថា ចបនៅក្រោមផ្ទះ លោក
ចូរទៅយកតាមចិត្តចុះ ។ កិកូនោះមិនបានដឹងថាទេចាសកដឹងរឿងខ្លួនស្រ
ស្បាញ់កិរិយាសោះ ព្រោះកាលកិកូនោះមកទទួលសង្ឃទានពីពេលព្រឹក
ទេចាសកនោះធ្វើអាការគោរពណាស់ ហេតុដូច្នោះ កិកូនោះក្រាប់ថា
បព្វជិតោ ម្ហិ អាត្មាជាបព្វជិត ទំនងចូលទៅយកចបក្រោមផ្ទះមិនកើតទេ

ទុបាសក ។ នោះបុរសក៏លើកផ្ទះកៀបចងធំដើរដោះឲ្យកំភ្លុនោះ ដោយគ្មានការគោរពសោះឡើយ ។ ជនទាំងឡាយនៅក្នុងទីជិតបានឃើញទុបាសកធ្វើអាការដូច្នោះ ទើបសួរថា ហេតុអ្វីបានជាអ្នកធ្វើយ៉ាងនេះ កាលព្រឹកអ្នកនិយាយគោរពណាស់ ដល់ពេលរសៀលបែរជាអ្នកកៀបចងធំដើរគ្រវែងឲ្យដោយឥតគោរពសោះដូច្នេះ ។ ទុបាសកនោះប្រាប់ថា កាលព្រឹកដែលយើងគោរពនោះ ព្រោះហេតុថាទានរបស់ខ្ញុំជាសង្ឃទានទុំសដល់សង្ឃ ការទុំសដល់សង្ឃនឹងតាំងចិត្តឲ្យស្មើតែមួយក្នុងសង្ឃហើយ ផលទាននោះមានច្រើនណាស់ ហេតុនោះបានជាខ្ញុំគោរពឥតរង្គើសសោះ ។

ពាក្យដែលសំដែងមកនេះ ប្រាថ្នាដើម្បីឲ្យបុគ្គលអ្នកមានសទ្ធាធ្វើសង្ឃទានគោរពក្នុងសង្ឃឲ្យស្មើគ្នា ឲ្យមើលអាការនៃទុបាសកគោរពចំពោះកំភ្លុនោះដែលទ្រទ្រង់សំពត់កាសាវពស្ត្រជាទង់ជ័យនៃព្រះអរហន្ត ។ សម្តេចព្រះពុទ្ធអង្គ កាលសោយព្រះជាតិជាចរមពោធិសត្វ ជាស្តេចនាគសារ ឃើញនាយព្រានទុំសំពត់កាសាវពស្ត្រមិនហ៊ានសម្លាប់ ព្រោះខ្លាចមានពាក្យតេតិះដៀលថាគ្មានសេចក្តីអៀនខ្មាសក្នុងព្រះអរិយៈ ជាម្ចាស់ទាំងឡាយ លុះតិតដូច្នោះហើយ ក៏លាប្រមោយលែងរួបរឹតហត្ថិមារកនោះ ។

(នៅមានត)

អ្នកមានគុណ (ត)

រៀបរៀងដោយ ហេង-សំអាន នៅសេនាធិការយោធភូមិភាគទី ១ ខេត្តកំពង់ចាម
អតីតគ្រូបង្រៀនឃុំស្រែស្តៅនៃមជ្ឈមណ្ឌលសិក្សាពលច្មើរដើងខែត្រពោធិសាត់

គ្រានោះឯងព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិពាណាសី
ព្រះអគ្គជាយាល្អប្រិមប្រិយ បុត្រាបុត្រីស្រស់ឆើតឆាយ ។
ថ្ងៃមួយព្រះរាជកុមារ ព្រួយព្រះចិត្តាហប្តូរណាយ
បងំចេញប្រពាតព្រៃធ្លាយធ្លាយ កំសាន្តព្រះកាយបានមួយថ្ងៃ ។
ប្អូលថ្វាយបង្គំព្រះបេះស្តា សម្តេចមាតាចិតាថ្លៃ
លាចេញដានីពីក្រុងរៃក្រ កំសាន្តព្រះទ័យព្រៃព្រឹក្សា ។
ព្រះចៅបញ្ញាឡេមេទ័ព តាមការពារជាប់រាជបុត្រា
ដោយខ្លាចសត្រូវនៅព្រឹក្សា បៀតបៀនកាយាបុត្រាតិសី ។
ព្រះរាជកុមារយាងចេញចរ តង់លើអស្សតរល្អប្រិមប្រិយ
ចំណាយចូលកន្លងអរញ្ញ៍ ព្រះកក្តែប្រិមប្រិយតន់មើលព្រៃ ។
ឆ្ងាយទៅ ឆ្ងាយទៅ ដាច់សង្វែងន តែមួយអង្គឯងឥតកិតក័យ
មានខ្លាមួយធំសម្បើមក្រៃ លួចខះមួយដៃចំសរសា ។
ភ្លាក់ចុះប្រកាច់ដួលផ្ងារផ្ងាប់ ដោះយកប្រដាប់តែងកាយា
កាច់កហុតឈាមធំមំសា ឆ្អែតហើយស្តេចខ្លាគេចចេញឆ្ងាយ ។
ព្រះរាជាយាខស្តេចសុគត ពលក័យខន្តត់ញាប់ញ័រកាយ
នាំគ្នាចូលគាល់បង្គំថ្វាយ ព្រឹត្តិការណ៍ទាំងឡាយថ្វាយពារជា ។

ព្រះបាទព្រហ្មទត្តរដ្ឋការ៉ី ស្តាប់ស័ព្ទសំដីនៃយោធា
រន្ធត់ញាប់ញ័រព្រះទ័យ អាណិតបុត្រាជាអនេក ។
ទ្រង់ព្រះតម្រេងថ្វែងសោកស្តាយ មន្ត្រីចាំឯឡាយគ្រប់ក្រុម-ផ្នែក
ចាំឯប្រជារាស្ត្រច្រើនអនេក យំស្រែកកាន់ទុក្ខគ្រប់ៗ គ្នា ។
រីឯខ្លាំងចោលប្រញាប់ នាំយកប្រជាប់ពាជបុត្រា
ជូនព្រាហ្មណ៍តម្រោះស្មោះចិត្តា មានគុណនឹងខ្លាចន់អនេក ។
ហើយខ្លាច្រាប់ព្រាហ្មណ៍យ៉ាងល្បាស់ ។ ថា«សូមលោកម្ចាស់កុំទុកស្អែក
យកទៅរំលាយជាចំណែក បំបែកឲ្យថ្លែក ។ កុំខាន ។
ទើបលោកបានរួចពីទោសពៃរ៍ ទុក្ខសោកកិតភ័យឃ្លាតពីច្រាណ
បានសុខសប្បាយកាយក្សេមក្សាន្ត រហូតអាសានៃជីវិត» ។
ព្រាហ្មណ៍ត្រេកអរណាស់វេចស្តាយទៅ កាន់តែលំទៅជាឯមាសពិត
ដល់ហើយព្រាហ្មណ៍សែនសប្បាយចិត្ត ច្រាប់ថា«នែមិត្រស្មើជីវ៉ ។
នេះ! ខ្លាឲ្យមកធ្វើវិញ្ញែក បន្ទោឯយ៉ាឯល្អកាវ-រយ៉ា
កឯដៃកឯជើងចិញ្ចៀនដង្កា ចូរមិត្រចេញឲ្យបានស្រស់ ។
ថ្លៃឈ្នួលប៉ុន្មានអ្នកកុំគិត ខ្ញុំចេញឲ្យមិត្រគ្រប់ចាំឯអស់
ចូរអ្នករំលាយពេជ្រភ្លឺស្រស់ ឯឯមាសចាំឯអស់នេះកុំខាន» ។
ជាឯមាសជាមនុស្សទ្រុស្តអន្ធពាល ថ្លើមធំពាសពាលពាលសាមាន្យ
ឃើញមាសនឹងតេជ្រចំណាំបាន ត្រឿនតែឯអង្គច្រាណាពជកុមារ ។

ចិត្តសោកចង់ប្រាន់យសស័ក្តិធំ ទុក្ខុគ្គទុក្ខមទ្ធុកជការ
ចិត្តគួចបំណងច័ន្ទប្រហារ យកអលង្ការជូនមន្ត្រី ។
តែបានគិតថាបើនៅរស់ ទើបបានខ្ពង់ខ្ពស់ក្បែរឈ្មោះល្បី
ត្រូវតែទៅច្ចីសោកកុង្ស៊ីយ ចាប់ព្រាហ្មណ៍តិរ៍យថ្វាយក្សត្រា ។
គិតហើយប្រាប់ព្រាហ្មណ៍ថា «លោកម្ចាស់ មានគុណធ្ងន់ណាស់ឥតឧបមា
ខ្ញុំធ្វើជូនលោកតាមប្រាថ្នា រចនាផ្តិតផ្តង់ត្រាតែល្អ ។
ថ្ងៃនេះខ្ញុំមានការចាំបាច់ ទៅកន់ទីស្ថាប់ធ្វើសម្ភ
ជប់លៀងគាហានមានចិត្តល្អ ទើបមកពីភនធីងពួកខ្ញុំង ។
ហេតុនេះសូមលោកសម្រាកកាយ ដើរមកពីឆ្ងាយអស់កម្លាំង
ខ្ញុំរៀបចង្ហប់ទុកសម្រាំង ទៅអីតុតាំងតែរ-ចាំនំបាន ។
ប្រាប់ហើយលាព្រាហ្មណ៍ចេញចាកចរ ត្រេកអរក្នុងចិត្តឥតប្រៀបបាន
ឆ្ពោះវង្វេងទាធិការដ្ឋាន លំពោនទន់ប្រាណដំកបថា ។
«ខ្ញុំបានចាប់មនុស្សអ្នកធ្វើឃាត ព្រះរដ្ឋថាយោងក្នុងព្រឹក្សា
កាលទ្រង់គង់សេះចោលសេនា ក្នុងព្រៃព្រឹក្សមណ្ឌ្រង់ង ។
មិនមែនខ្លាំងព្រះអង្គទេ សូមលោកៈរតែតគ្រប់យ៉ាង
មានអលង្ការជាសំគាង កស្តុតាងច្បាស់ណាស់លោកម្ចាស់ថ្លៃ
ឃុំទុកនៅក្នុងផ្ទះខ្ញុំបាន រៀបរយស្អាតបាតហ្មត់ចត់ក្រៃ
សូមលោកចាត់ការពន់សម័យ ឲ្យដឹងស្មាដៃនៅថ្ងៃថ្ងៃ » ។

កុន្ធីក្រសួងសន្តិសុខ កំពុងរិតក្តុមិនចេញស្តី
ស្តាប់ពាក្យជាធំមាសកយសេចក្តី ចំរឿនថ្មីថ្មីស្តីស្មាលស្ងួត ។
សូមអរគុណលោក ទំសង្កេត ជនគ្រប់ប្រភេទពាំងធ្វាយដាត
ដើរឈ្លបយកការណ៍ជាន់ពិតពិត ចាប់ជនខុសច្បាប់តែចិត្តមោហា ។
លោកទំធំជាន់បុណ្យសក្តិខ្ពង់ខ្ពស់ និងឥស្សរៃយយសអនុស្សរ
កុងពេលឡើងគាល់ព្រះករុណា ព្រះមហាក្សត្រាដែនកាស៊ី » ។
ហើយលោកកុន្ធីស្តីបង្គាប់ ឲ្យក្នាក់ងារផ្ទាប់ពូតែលី
ទៅចាប់ចងព្រាហ្មណ៍រំពេចនឹ ដើម្បីនាំថ្វាយព្រះករុណា ។
កុន្ធីនាំព្រាហ្មណ៍មនុស្សក្បាលឆ្កៀ ឡើងគាល់ព្រះទៅចមសេមា
ថ្វាយអលង្ការពាជបុត្រា ខួលថ្វាយមុសាយ៉ាងក្បោះក្បាយ ។
ព្រះទៅទ្រង់ទតយ៉ាងប្រចក្ស ខ្លួរសម្ភារៈបុត្រធើតធាយ
ស្គាល់ច្បាស់ខ្នត់ព្រះអង្គកាយ តំខ្សែនសោកស្តាយពាជបុត្រា ។
ក្រែវក្រោធពិរោធហួសប្រមាណ ញ័រអស់អង្គប្រាណបង្គាប់ថា
« នែវើយពេជ្ឈឃាតប្រញាប់ព័ ចាប់ព្រាហ្មណ៍មោហាអឡតិ្ថយ ។
នាំយកទៅចងរិតដើងដៃ ជាក់ទ្រូងហាលថ្ងៃកុំប្រណី
ប្រាំពីរថ្ងៃគត់រឹងសិរសី នៃព្រាហ្មណ៍តិ្ថយចោរចង្រៃ » ។
ពេជ្ឈឃាតស្តុះបួលទៅចាប់ចង ភយវិធាត់ថងចងផ្ចាប់ដៃ
ធ្វើខ្ញុកម្មុក្តុំប្លុំ ជាក់ទ្រូងហាលថ្ងៃឥតមេត្តា ។

ឯទោសឯងខុសច្បាស់ដល់ចម្លែក ទៅក្នុងទ្រុងដែកបែកកាយ
ឈាមហូរហៀរខ្លាយកាយតើតផ្សា កន្ទេងសោកានន្តគ្រាណា ។
ស្តាយអើយសែនស្តាយ កាយឯងខុសក្ខ
ពីនេះទៅមុខ ឥតស្រោកស្រាន្ត
ខុសក្ខធ្ងន់សែនធ្ងន់ តន់ម្រមាណ
ខុសក្ខជួយពុំបាន ត្រាណាមតា ។
អាសូរខ្លួនខ្ញុំ ចំត្រូវស្លាប់
តេជ្ឈយាតកាប់កាត់ ផ្តាច់សរីរសោ
ចោលឲ្យក្អែកតគ្នាត ឆ្កែកាយ
ជូចសត្វឆ្កែធា អកតូវក្រៃ ។
ស្លាប់នេះដោយសារ ការកម្ចៅ
នៃមនុស្សក្បាលខ្ចៅ ខ្លៅចង្រៃ
អកតញ្ញូ អាក្រក់ក្រៃ
ថ្លើមខ្លៅចង្រៃ អន្ធពាលា ។
អាក្រក់ណាស់ហ្ន៎ មនុស្សក្បាលខ្ចៅ
ភ្លាត់កន្លងរណ្តៅ ទៅវេទនា
ជួយស្រង់ពុំបានរួច ពីមរណា
ឥឡូវបែរជា ទោសវិញ្ញាណ ។

លុះដល់យប់ជ្រៅយាមទី ៣ ទឹកឃើញស់ដ៏ស្តើសច្បា
របស់ពស់វែកក្នុងព្រឹក្សា ថាបើមានការណ៍ឲ្យនឹកភ្លាម ។
នឹកភ្លាមពស់វែកញែកស្មៅគ្រាស់ លូនលឿនហ៊ាសទៅដល់ព្រាហ្មណ៍
ឃើញជាប់ទ្រុងដែកស្រែកសួរភ្លាម លោកជាប់ចាក់ចាមពីរឿងអី ? ។
ព្រាហ្មណ៍ឆ្លើយប្រាប់ថា «មនុស្សក្បាលខ្មៅ ឡើងខ្ញុលព្រះហៅដែនគាស៊ី
ថាខ្ញុំធ្វើគត់បុត្រប្រមប្រិយ កូនអញ្ចឹ ណាពស់ណា ! ។
មិនចាន់ចានខ្ញុលព្រះអង្គជង ពេជ្ឈឃាតចាត់ចងចងហត្ថា
ប្រាំពីរថ្ងៃទៀតគាត់សំរេច ផ្តាច់ជនជីវិតខ្ញុំមិនខាន » ។
ពស់ថា «លោកម្ចាស់កុំយំស្រែក ពេលល្ងាចថ្ងៃស្អែកខ្ញុំលាក់ប្រាណ
ចាំចឹកក្បត្រីស្រីកល្បាណ នៅបុប្ផដ្ឋានពាដក្បត្រី ។
ពិសខ្ញុំពូកែស៍ក្តីសិទ្ធិណាស់ ត្រូតេឲ្យក្មេងចាស់ពូកែល្បី
ចេះប្បាំដកពិស មន្តថ្មលី ដែលធ្លាប់ល្បាញល្បីពាំងប៉ុន្មាន ។
មិនអាចមកអាមដកពិសខ្ញុំ ស្តេចផ្ញើឲ្យសព្រះអង្គប្រាណ
មានតែលោកមួយទើបជួយបាន ក្បត្រីកល្បាណទៅធីតា ។
បើមានអាមាត្យប្បាំតែងរក លោកហៅគេមកជំរាបថា
ចេះមន្តអាគមពីដូនតា គាថាផ្ញើដកពិសពស់បាន ។
លោកនឹងបានចូលទៅដំណាក់ ក្បត្រីវិលក្បាណ៍តែវែកល្បាណ
ហើយត្រូវផ្តិតផ្តង់ប្រុងប្រៀបប្រាណ កុំបង្អង់មានឲ្យយូរយារ ។

ចំពោះស្វាមីស្តេចផែតផែត ខ្ញុំលួនចូលក្នែតទៅគាបពារ
ស្រួបយកពិសពស់មិនឃ្លៀងឃ្លាត ហើយចេញពពាលចូលព្រៃ ។
ព្រះពជ្ជតាកល្យាណី ឃាតដឹងស្មានតើស្តេចក្រោតរៃ
ខ្លួនលោកក៏ឃាតរួចទោសពៃរ៍ ពីទុក្ខកិតក័យនៃជីវ៉ ។
ក្រាប់ហើយពស់វែកលួនញែកស្មៅ សំដៅលួនទៅសួនបុប្ផា
លាក់ខ្លួនពួនទៅតង្គុម្ពា ចាំពជ្ជតាកល្យាណី ។
ដែលព្រះនាងតែងក្រសាលលេង កំប្រៀងតាមក្នែងតួរតន្ត្រី
បេះផ្កាចំប៉ាផ្កាចំប៉ី ភ្លាំងងាណាត្រេសៀតកេសា ។
ស្តេចព្រះសុរិយោចុះខន់ឋាច ខេរតាមសភាពលោកធម្មតា
ហៀបនឹងលាក់ខ្លួនពួនអាត្មា នាទិសបច្ចិមាចោលស្មើ ។
ពេលនោះកញ្ញាត្រីយស្រីកល្យាណ តែងព្រះអង្គច្រាណស្រស់ច្រមុះច្រមាយ
ឃាងចាកតំណាក់ចោលស្មើ ហាក់គឺនារីស្រីសួគ៌ ។
ព្រះនាងក្រសាលលេងសប្បាយ ស្រីស្ងាត់ឯឡាយថ្ងាយបុប្ផា
ភ័ក្ត្រាច់កាច់កងខន់កាយា ច្រៀងបទសក្តវាថ្ងាយក្បត្រ ។
ព្រះនាងក្រោកពាំស្រីស្ងើ ខន់ភូនទុកមសមលើសស្រី
ព្រះហស្តបេះផ្កាសៀតកេសី ព្រះកន្ត្រកច្រមុះច្រមាយញញឹមត្រាយ ។
ពស់វែកក្រឡេកឃើញជាក់ច្បាស់ ស្តុះហក់ហ៊ោសមិនកយមាយ
ចឹកចំព្រះកន្ត្រកផ្កាក់ផ្កាកយ ហើយលួនទម្លាយពួនលាក់ច្រាណ ។

ស្រីស្ងំស្ងុះបួលត្រកងជំបិ លើកពាជក្សត្រីយស្រីតលក្ខណ
ជាក់លើតំណាក់ថ្មាក់ថ្មមច្រាណ ខ្សឹងគាល់ក្សត្រក្សត្តម្ចាស់ផែនដី ។
សម្តេចមាតាធំធិតា ព្រះបៀសេមាម្ចាស់ផែនដី
ទ្រង់បានយើញព្រះពាជបុត្រី ស្ងាត់បាត់ស្មារតីក៏ក្រៀមអែ ។
គ្រាពេទ្យទុមអាមមន្តអាគម ទុនស្តោះព្រួសផ្ងុំមុំមិត្រស្នេហ៍
គ្រាក្មេងគ្រាចាស់ខ្ចាប់ពួកែ គ្រាចាមគ្រាខ្មែរដៃលលាញលាញ ។
មិនអាចទុមអាមជកពិសពស់ ថ្វាយថ្នាំឲ្យសេព្រះជន្មស្រី
កំថ្វាយបង្គំព្រះចក្រី លាចុះទៅដំដើរស្បៃមស្ងាត់ ។
ព្រះបៀទ្រង់ព្រួយព្រះចិត្តា អាណិតធិតាពន់ពេកក្តាត់
ព្រះកាយទៀងជាំស្មារតីបាត់ គ្រាពេទ្យកំចាត់ពិសមិនបាន ។
ទើបស្តេចទ្រង់ត្រាស់បង្គាប់ថា នែ! រើយសេនាឬទ្ធិក្លាហាន
ចូរប្រាំពីរតង្រៃពេទ្យចំណាន មើលកូនកល្យាណាពៅធិតា ។
បើគ្រាពេទ្យណាពួកពិត ជាន់ស្រង់ជីវិតធុតមរណា
ខ្ញុំលើកពេទ្យខោះជាសុណិសា ត្រង៉ាកដសេមាតរៀងទៅ„ ។
អាមាត្យទទួលពាជបញ្ជា រួតរះម៉ឺមាដើរសំដៅ
ទៅភូមិឃុំស្រុកកងខែត្រក្រៅ ជាំវាតង៉ាស្រែកហៅប្រាប់ប្រុសស្រី ។
សួរហើយសួរទៀតមិនឮឆ្លើយ ក៏មិនកន្តើយដោយសំដី
បេះតែដើរសួរគ្រប់ទិសទី គ្មានស្រីប្រុសណាថាបេះសោះ ។

លុះដើរមកដល់តែក្បែរទ្រុងដែក ឮសូរសម្រែកព្រាហ្មណ៍កម្ងោះ
«លោកអើយខ្ញុំបានច្រាច់ដោយស្មោះ ចេះមន្តផ្ទុំស្គោះពិសពស់បាន ។
អាមាត្យឮហើយស្រែកដេរថា «អាចារអាហាកាចសាមាន្យ
អួតខ្លួនថាចេះមន្តច្រើនណាន មើចអាតិរច្ឆានជាប់ទ្រុងដែក,, ។
ដេរហើយកំចូលក្រាបបង្គំ ព្រះចៅជាធំមិនខុកស្លុក
«ក្រាបទូល! ព្រាហ្មណ៍ជាប់ក្នុងទ្រុងដែក គួរឲ្យបម្រែកប្លែកអស្ចារ្យ ។
ទូលព្រះបង្គំខំស្រមៃ គ្រប់ទីកន្លែងស្រែចំការ
គ្រប់ក្រុងតូច-ធំនិងគ្រប់ផ្សារ គ្មានប្រុសស្រីណាថាចេះឡើយ ។
មានតែព្រាហ្មណ៍ដែលជាប់ទ្រុងដែកកំពុងយំស្រែកខ្លួនឥតស្បើយ
ច្រាច់ថាចេះមន្តមិនកើរឡើយ ស្គោះពិសពស់ស្បើយហើយជាស្លាប់
ព្រះបាទព្រហ្មទត្តរដ្ឋការី ស្តាប់ពាក្យសំដីនៃអាមាត្យ
ទ្រង់ព្រះបញ្ជាថាវៃឆ្លាត បង្គាប់អាមាត្យឲ្យាស់ ។ ថា ។
នៃវើយអាមាត្យចេញទៅភ្លាម ដោះព្រាហ្មណ៍កំឡោះទោះមកណា
ឲ្យធាប់ប្រញាប់ពាន់ចិត្តា មើលរាជធិតាវិសសអញ» ។
ខ្លួលព្រះរាជបញ្ជាហើយ មិនទៅកន្តើយរត់ត្រចាញ់
ទៅដល់ច្រាច់ថា «អីសំឡាញ់ ឥឡូវនេះអញមកដោះឯង ។
ព្រះករុណាជាម្ចាស់ជីវិត ឲ្យអញ្ជើញមិត្រទៅតន្លែង
ព្រះរាជតំណាក់កុំតិតក្រែង ឲ្យឯងស្គោះពិសពស់អញ្ចឹង ។

ព្រាហ្មណ៍ចូលទៅគាល់ព្រះមហាក្សត្រ តិតភ័យពេកក្តាត់ជាត់សំដី
ព្រះចៅទ្រង់គ្រាសក្រោសប្រណី ស្តីខ្លួស្ញាលមេត្រីនឹងព្រាហ្មណ៍ថា ។
«នែអ្នកកម្ទេចបូបប្រពៃ អ្នកកុំតិតភ័យណាប្រុសណា
អ្នកជួយសង្គ្រោះស្រង់ដល់ព្រះពជនតាខ្ញុំជានរសំ ។
ខ្ញុំលើកជូនអ្នកជាប្រពន្ធ គ្រងប្រជាជនច្ចើនខ្ពង់ខ្ពស់
បងអ្នកផ្តុំស្មោះឲ្យជានរសំ បណ្តេញពិសពស់ណាប្រុសណា ។
ព្រាហ្មណ៍ក្រាបបង្គំថា «ជតិត្រ សូមព្រះទ្រង់ប្តូរក្រោសមេត្តា
ខ្ញុំលព្រះបង្គំសូមសច្ច មើលថ្វាយជតិតាត្រាតែជា» ។
ខ្ញុំលហើយព្រាហ្មណ៍ធ្វើមាត់អូបអូប ហាក់ដូចខុមអាមមន្តគាថា
ព្រួសផែតផែតផែតសព្វកាយា ព្រឺព្រើតពេមាស្រើតើតធាយ ។
ពស់វែកស្រូបជកយកពិសអស់ ក្សត្រិយបានរសំប្រែព្រះកាយ
ក្រោតតង់ចៅកាំហៅនាយគាយ ហៅស្តុំតាំងឡាយតាមធម្មតា ។
មាតាបិតាតាំងពីអន្តិ អាមាត្យរហង់គាល់ត្រៀបត្រា
សប្បាយកាយចិត្តឥតឧបមា ខ្ញុំងពៅជតាកល្យាណី ។
តមកទ្រង់រៀបអភិសេក បុត្រីល្អឯកឆ្នើមលើសស្រី
ជាមួយខ្ញុំងព្រាហ្មណ៍មានជាមី គ្រងដែនតាស័ដោយស្មោះសរ ។
ព្រាហ្មណ៍អភិសេកជាឯកអគ្គ គ្រងអាណាចក្រល្អខ្លាយខ្លរ
ព្រះពជនតាស្តេចរ ហាក់ដូចកំនរស្មានសួគ៌ ។

ស្វាមី-មហេសីមេត្រីភ្ស៊ូ បីបមថ្នមថ្នាក់ស្នេហ៍ដូចគ្នា
តាំងយប់តាំងថ្ងៃត្រង់រសៀល មិនដែលឃ្លាតឃ្លាគ្រាថ្មោងថ្មី ។
ថ្ងៃមួយក្សត្រីស្រីរសែកូណ៌ ទ្រង់សួរបញ្ជាក់ពីដស្វាមី
ថា« សូមស្តេចបងប្រាប់ប្រណី តើរឿងព័រអី ជាប់ទ្រូងដែក ? » ។
ព្រាហ្មណ៍ប្រាប់មហេសីស្រីស្នេហា ពីមនុស្ស-ពស់-ខ្លាពុំគួរអនេក
រហូតដល់ជាប់ក្នុងទ្រូងដែក ជារឿងចម្លែកត្រង់ត្រង្គឃ្លោ ។
ព្រះពៅធិតាកល្យាណី ឯកអគ្គមហេសីក្រែវក្រោធា
នឹងមនុស្សក្បាលខ្លៅខ្លៅពាលា កំទ្រង់ចង្ហាយ៉ាងច្បាស់ច្បាស់ ។
ឮពាក្យអាមាត្យចងហត្ថា តាត់ផ្តាច់សិរសាមនុស្សឥតខ្លាស់
អកតញ្ញូមួយក្រាស់ ដូចឆ្កែចង់ម្ចាស់កន្ទុយខ្វៀន ។
ព្រះចៅទ្រង់ឃាត់ព្រះទេពី ថា„ នោមនារីកុំបៀតបៀន
អ្នកកុំសម្លាប់មនុស្សឥតអៀន ត្រូវដាក់មេរៀនប្រៀនប្រដៅ„ ។
ព្រះនាងយល់ស្របតាមភស្តា កំប្រាប់សេនាថា „ព្រះចៅ
ស្តេចទ្រង់សន្តោសមនុស្សក្បាលខ្លៅ គ្រាន់តែប្រដៅប៉ុណ្ណោះឯង ។
ហេតុនេះចូរលោកទៅចាប់ចង ឲយរ៉ែងតាត់ចងកុំគិតក្រែង
ដាក់មេរៀនឲ្យខ្លៅនេះឯង ចាប់ចាងសម្តែងចែងមាគ្រា ។

រីមនុស្សក្បាលខ្លៅខ្លៅអបលក្ខណ៍ ចានបណ្តាសក្តីពាក់លើស្មា
ហានៈត្រូវចាប់អកញ្ញាំ គ្រួតគ្រានៅជាយដែនគាស៊ី ។

កំពុងតែនិកតាអតីត សញ្ញឹងក្នុងចិត្តគិតជាថ្មី
ដឹងច្បាស់ថាព្រាហ្មណ៍មានចារម៉ែ ត្រង់ត្រង់កាស៊ីកដង្ហើ ។
តេលនោះតេជ្ឈឃាតមានឧធំធាត់ ស្ទុះចូលវាយដំធាត់កាយា
ថែកឈាមរហាមតាមម៉ាសា ឈឺចាប់ខ្លោចផ្សាពន់ពេកក្រៃ ។
ទោសខ័ណ្ឌចម្លែកប្លែកតែងឆ ស្រែកយំក្តែងៗកណ្តាលថ្ងៃ
ចំណងចងតឹងតួតដៃដៃ ស្រែកថាម្ចាស់ថ្ងៃខ្ញុំកន្ទើយ ។
តេជ្ឈឃាតប្រដៅ ១០ សប្តាហ៍ គ្មាននាទីណាបានស្រាកឡើយ
មានតែឈឺចាប់គ្មានបានស្បើយ រួចហើយបញ្ចាលតន្ទនា ។
និតានចប់ហើយស្តេចខ្ញាក់ ប្រាប់ទៅស្មាសមិនយូរយារ
«បងកុំយាយាំងកំងការគារ ព្រានព្រៃតាលាក់ខ្លួនស្តមិត្រ ។
ព្រោះមនុស្សក្បាលខ្លៅខ្លៅកំចាប ឆ្អែះឆ្អាបធាបដល់រូបបងពិត
ឲ្យទោសត្រាតែផុតជីវិត ចូរមិត្រច្រានមកណាមិត្រណា,
ស្មាថា «មិនឲ្យអ្នកស៊ីទេ ជីវិតយើងនេដូចដូចគ្នា
បងរស់ចង់សុខស្រណុកជា មនុស្សសត្វដូចគ្នាគ្មានប្លែកអ្វី, ។
ស្តេចខ្ញាក្រេវក្រោធសោតក្រឡឺង សម្លក់សម្លឹងដាក់ក្រមៈ(១)
ហើយបែរលួងលោមថ្នមសំដី ស្ងើចស្ងាលមេត្រីធ៌ព្រានថា ។
ព្រានអើយសូមអ្នកអត់យោទស សន្តោសដល់ខ្ញុំណាព្រានណា!

១-ស្វា

ខ្ញុំសូមជាមិត្រភូមដីវ៉ា ស្នេហាលុះត្រាអវសាន្ត ។
បើខ្ញុំចាប់បានគោក្របី ឈ្នួសច្រើសដំរីម៉ាន់ប៉ុន្មាន
ខ្ញុំបែកឲ្យអ្នកមិនដែលមាន បើអ្នកចាប់បានបែកខ្ញុំផង ។
អ្នកឧកចិត្តខ្ញុំកុំកិតក័យ ទម្លាក់ស្វាព្រៃមកណាបង
ស្វាព្រៃតំណាចកាចកន្ធង ឲ្យទោសដល់បងជាមិនខាន,, ។
ព្រានតាលប្រុសមិត្រចិត្តតិរ៍ិយ ឮពាក្យសំដីម៉ាន់ប៉ុន្មាន
ពោលតបទៅថា ស្វាតិរច្ឆាន គោង៍គាចសាមានព្យែចយ៉ាំងណា។
សូមបងនិយាយឲ្យខ្ញុំស្តាប់ សាសំភ្លូវៀចចាប់មកណាអ្នា
តើមាននិទានដូចម្តេចវ៉ា ព្រហើនយ៉ាំងណាស្វាចង្រៃ ? ។
ស្តេចខ្លាអណាស់ក្បាលនឹងើ ងើបមើលទៅលើឃើញទៅថ្ម
និតថាអាស្វាពាលចង្រៃ មិនរួចពីដៃអញទេណា ។
ហើយប្រាប់ទៅព្រានថានែមិត្រ បុកណាបណ្តើតបានបងថា
ចូរបងប្រុងស្តាប់ណាបងណា រឿងស្វាកំណាលតាវែតញ៉ើ ។

(នៅមានត)

វិធ្សរជាតក (ត)

ព្រះបាទពិរុណនាគរាជស្តាប់ហើយ ទ្រង់ឃើញថាវិធាវៅមាណពអើយ ចៅ
មិនដែលបានឃើញបានស្តាប់គាត់ទេហ៎ះ នាចៅពិធូរអ្នកប្រាជ្ញនោះ គាត់
ជាពាជអាមាត្យព្រះបាទសញ្ជ័យការត្បាញដសោយពាជសម្បត្តិ ស្ថិតនៅ
ឰដឥន្ធបត្ថបុរី ស្រីមហានគរនោះហោង ។ ឰដ៏កាលនោះ បុណ្ណកយក្ខ
ស្តាប់ ព្រះបន្ទូលព្រះបាទពិរុណនាគរាជ មានចិត្តនោះត្រេកអរសាទរនោះ
ហ៊ាមាក្រៃពេក ម្ល៉ោះហើយក្រាបលា ព្រះពិរុណនាគរាជ ចុះមកហើយបង
គ្រឿងសេះមនោម័យស្រេចហើយនៃ បុណ្ណកយក្ខដែលព្រមប្រុចឡើងលើ
ខ្នងមនោម័យ ដៃកាន់តែតត់ហើយទៀងថាហ៊ានមនោម័យ ម្ល៉ោះក៏រមនោ-
ម័យ ស្ទុះហៀរហោះច្រៀវច្រៃ ទំលាយទឹកឧទ្ធមហាសមុទ្រ ប្រាកដ
ឡើងមកដល់មនុស្សលោក ហើយបុណ្ណកយក្ខបរសេះមនោម័យនោះ
ហោះម្ល៉ោះអណ្តែតត្រសែតឡើងទៅ នាគណ្តាលអាកាស ឱដ៏ទៅក្រាប
លាព្រះបាទវេស្សវណកុវេរមហារាជ ដ្បិតគាត់ជាមា ។ កាលនោះ
បុណ្ណកយក្ខ គិតថាអញឱដ៏ក្រាបលាអ្នកមាទៅ ឯកឯង ក្រែងគាត់មិនបើក
អញ ថាបើដូច្នោះហើយ អញឱដ៏ធ្វើជាស្រដីសរសើរអំពី ពីកពនាគ
ប្រាប់អ្នកមា ហើយទើបអញឱដ៏ក្រាបលានោះ ទើបអ្នកមាបើកអញធាប់
ហោង បុណ្ណកយក្ខ គិតនូវប្រការអម្បាលនោះហើយ ថ្វាយបង្គំប្រ-
ណម្យខ្លួលថា បពិត្រអ្នកមាអម្ចាស់ខ្ញុំអើយ នាគាលខ្ញុំហោះផ្លោះ ចុះ

ទៅកាន់ពិភពនាគនាយ នោះខ្ញុំបានយល់អស់ស្ដាន់រឿងព្រះចាតុរាណ
នាគរាជនោះ ខ្ញុំគិតស្មានថាជាសំនៅនោះ ធ្វើខ្លួនប្រជាប់ប្រដាប់ខ្លួនចន្លួច
ទៅទេ មិនដឹងឡើយ ព្រះមាអើយ មើលទៅប្រាសាទព្រះរាជមន្ទីរមណ្ឌល
នោះ មិនយល់ហាក់ដាទៅនាពិភពនាគឡើយ យល់ហាក់ដូចស្ដាន់រឿ-
មានសួតិ មុខគួរតែពិតពិលរមិលមើលទៅយល់ល្អក្រៃពេក ទឹងពណ៌នា
ទៅប្រាសាទព្រះរាជមន្ទីរ នោះវាក្លឹបាលរន្ធាលសឹងតែរស្មី មាសប្រាក់
តែវ ទឹងគណនាគ្រាប់តុំបានឡើយ ព្រះអង្គអើយ មានតាំងទីតាប់តាយ
លំហ នាងប្រាល ពិពិណ ខ្លូវផ្លូវតួត្រលែងតែងតំពែងបាការក្លាងខ្លារ
ផងវាក្លឹប្រុះធ្លុះ អស់តាំងពិភពនោះ សឹងតែរស្មីមាសប្រាក់តែវសព្វពិធ
រតន៍រចនានោះល្អក្រៃពេក ហើយមានតាំងស្រះស្រង់ចោកមណីចរ
ខ្យាទដ៏មានះឈើផងតាំងខ្យាយនោះច្រើនអនន្តនឹងគណនាគ្រាប់តុំបាន
ឡើយ ហើយព្រះចាតុរាណនាគរាជនោះ មានព្រះរាជទេវី ១
ព្រះអង្គទ្រង់ព្រះនាមឈ្មោះនាងវិមលាទេវី នាងនោះសោតទើបតេញក្រ
មុំនត្តមសមខ្លួរូបនោះល្អ ហើយនាងមានពន់នោះធំស្រឡះស្រលួតសួត
ស្តើរល្អោះល្អើ ដូចកលំពាងំរុនហើយមានសម្បុរនាងនោះក្រហមល្អ
ដូចឥតលំទ្ធ មានព្រះភក្ត្រនោះមូល សុសូលក្រៀវកុំសមខ្លួរព្រះថនា
នោះល្អដូចផ្លែទ្រាប់ តិតម្មកងាប់ស្រាកប់ឮដ៏ឥតនាង មានរូបនោះល្អ
ដូចស្រីសួតិ មុខគួរតែពិតពិលរមិលមើល នាងវិមលាទេវីនោះប្រាថ្នាចង់

ស៊ុតែថ្វែមហៅតាឆូរអ្នកច្រាជ្ញ បពិត្រអ្នកព្រះមារអើយ ខ្ញុំសូមក្រាបលា
អ្នកទៅ យកថ្វែមហៅតាឆូរអ្នកច្រាជ្ញនោះមកថ្វាយ ព្រះមហាក្សត្រទ្រង់ឆ
ពីព្រះអង្គហើយ ព្រះអង្គនឹងយកព្រះរាជបុត្រី ១ ឈ្មោះនាងឥន្ទតី ឲ្យ
ជាប្រតិទ្ធខ្ញុំហោង ព្រះបាទវេស្សវណកុវេរមហារាជស្តាប់ពាក្យ បុណ្ណក-
យក្ខ ក្រាបទូលលាដូច្នោះហើយ ព្រះអង្គគង់ស្ងៀមពុំមានបន្ទូល ចេីតឲ្យ
បុណ្ណកយក្ខទៅវិញ ។ ជាកកវំ ភក្ខិ ឯដ្ឋិតំ ។ បពិត្រអើយ នេះ
យើងស្រដី សរសើរតែតនាតដែលបុណ្ណកយក្ខ ក្រាបទូលព្រះបាទវេស្ស
វណ កុវេរមហារាជមិញ ស្រេចនូវប្រការអម្បាលនេះហោង ។ វេស្ស-
វណោ បុណ្ណកយក្ខំ ភក្ខិ ឯ ឥសុ ណោតិ ។ ពាក្យចំណោទថា
ជណ្តឹងថាអ្នកអើយ ហេតុអ្វីព្រះបាទវេស្សវណ កុវេរមហារាជ តែមិនស្រដី
នឹងបុណ្ណកយក្ខនោះ ។ បម្រើយឆ្លើយថាអ្នកអើយ កាលនោះព្រះបាទវេស្ស
វណកុវេរមហារាជ អាល័យតែគាត់សេចក្តី ឲ្យទៅបុត្រតែអង្គ កាលនោះ
បុណ្ណកយក្ខ ដឹងថាព្រះវេស្សវណ មិនស្រដីនឹងអាត្មាដូច្នោះហើយ បុណ្ណ
កយក្ខ ទៅអង្គុយផ្ងាប់ជាក្រោយទៅបុត្រឈ្មោះសេចក្តី កាលនោះ ព្រះ
បាទវេស្សវណបង្គាប់សេចក្តីឲ្យទៅបុត្រ ១ ឈ្មោះហើយ មានព្រះបន្ទូល
ថាម្ន៉ោះហើយ អ្នកទៅសាងវិមានអ្នកហោង ។ កាលនោះ បុណ្ណកយក្ខ
ស្រែកឆ្ងឹងយោសនា ក្រាបទៅអស់ទៅតាមឆងថា បពិត្រទៅតាមឆងទាំង
ឡាយអើយ ចូរអ្នកជាបន្ទាល់សាក្សីខ្ញុំផង ឥឡូវនេះព្រះមាន្ធកបើកឲ្យ

ខ្ញុំទៅហើយណា ឮខ្ញុំទៅហើយ ម្ចាស់ហើយបុណ្ណកយក្ខក្រាបលា ព្រះ
ចុងវេស្សវ័ណ ហើយហៅទៅតាមឮចងគ្រឿងសេះស្រេចហើយ បុណ្ណ
កយក្ខ ផែលឡើងលើខ្នងមនោម័យទៅហោង ។ បុណ្ណកយក្ខបរសេះ
មនោម័យ ទៅដោយកណ្តាលអាកាស ហើយគិតថាទៅពិធូរអ្នកច្រកជ្រ
នោះមានបរិវារច្រើន ម្រាងឡើយអញនឹងទៅចាប់គាត់បានអេះ ហើយ
ព្រះចុងធនញ្ជយកោរព្យាកដនោះ គាត់មានច្រកជ្រកទូវល្ឋងស្ពារផង
ហើយអញនឹងទៅលេងស្ពារផងគាត់ កាលបើអញលេងឈ្នះគាត់ហើយ
អញមិនយកអ្វីដទៃបើក្រៃ នឹងចៅពិធូរអ្នកច្រកជ្រនោះឡើយ អញយក
តែចៅពិធូរអ្នកច្រកជ្រនោះជា ដំណាងស្ពារអញហោង ។ ទៅព្រះពជ
មន្ទីរព្រះចុងធនញ្ជយនោះ មានមាសច្រាក់តែវសព្វពិធរតនជាច្រើន កំ
អញនឹងបានអ្វីជាតែវមណីរត្ន នឹងទៅលេងស្ពារផងស្តេចនោះ ថាបើអញ
ឈ្នះកំបានយកចៅពិធូរអ្នកច្រកជ្រនោះ ថាបើអញចាញ់គាត់វិញហើយ
តើអញបានតែវមណីរត្នអំពីឯណា ជាដំណាងស្ពារនោះ ដូច្នេះត្រូវអញ
ទៅកាន់ពជត្រែនតរ យកតែវមណីសំពាប់មហាចក្រពត្តិពជទៅក្នុងកំប៉ុលប
ព៌ត កាលបើបានតែវមណីនោះហើយ អញនឹងយកទៅលេងស្ពារ នឹង
ស្តេចនោះហោង បុណ្ណកយក្ខ គិតអម្បាលណោះហើយ បរសេះមនោ-
ម័យទៅកាន់ពជត្រែមហានតរ ជាស្ថានលំទៅនៃព្រះចុងអង្គកស្សប ថានតរ
នោះ ស្រណុកសុខសប្បាយ ដ៏មានបាយទឹកចំណីគោជនអាហារ

ផងច្រើន ហើយមានមាសប្រាក់តែវែងឆ សព្វពិធភ្នែផងជាច្រើន ដូចកល់សម្បត្តិត្រៃត្រឹង្ស សម្តេចឥន្ទ្រាធិរាជ ហើយមានចាំឆមក្បែរក្បាលក្បែរជើងសេះ ប្រឡាំទៅខ្លួរសេកសារិកា សឹងដ៏ធំយ៉ាលើមែកឈើ ហើយមានសំឡេងពេកយ គ្រោះគ្រៀវគ្រៀវ ទាទេះស្ងាប ខន្ធាប ចំសព្វលាផ្លែឆមែកឈើផង ហើយកំពេញទៅខ្លួរផ្កាឈើផង ដូចកលអ្នកក្រងរំយោលទៅលើកុំ ដូចកលព្រៃព្រះហេមពាន្ត បុណ្ណកយក្ខនោះ ឡើងទៅលើកុំរៀបុលបពិតប្រាកដសឹងថ្មគាន់ ជាមានកំពស់នោះខ្ពស់ក្រៃជំពេញទៅខ្លួរពពួក តន្ទេ ផងចាំឆឡាយច្រើន បុណ្ណកយក្ខ ក្រវែនតែឆនឹងស្មែងរកតែវមណីរត្ន មានស្មើនោះក្តីប្រាត់យល់ភ្នាត់ចេញអំពីកុំរៀបុល ពិតដូចកលផ្លែកបន្ទោរត្ន ប្រាត់ភ្នាត់ចេញអំពីកណ្តាលស្រាចាប់មេយ បុណ្ណកយក្ខនោះ កាលបើបានយល់តែវមណីរត្ននោះជាក់ច្បាស់ប្រាកដហើយ មានចិត្តនោះត្រេកអរសោទរមហិមា ថាអញនឹងបានតែវមណីប្រាកដឥឡូវនេះឯង ម្ល៉ោះហើយ បុណ្ណកយក្ខនោះ ដើរសរសៀរមៀរចូលទៅឆកំយកតែវមណីនោះ ។ កាលនោះ មានយក្ខកុមណ្ឌចាំឆ ៤ ខ្លួរ ពលចាំឆ ១ ពាន់ តែឆនឹងទៅពិតកំពុងក្បែរនៃតែវមណីនោះ កាលបើរម៉ិលមើលទៅយល់ បុណ្ណកយក្ខ ដើរទៅទៀបតែវមណីនោះហើយ រ៉ែអស់យក្ខចាំឆភាន់នោះ សឹងតែកាន់ដំបងផ្ចែក ស្រែកគំរាមថា ពះនរណាតើកមកនៅទាឆកុំនោះហ៎ា: ខេរើយមិនគាប់ហើយ កំសរសៀរមៀរមកឆក់

ឯតែវាលោកនៅនោះហើយ ប្រសិនបើដូច្នោះហើយណា កំយើងលំអិតសាច់
នោះជាដើ ឲ្យល្អិតជាផុយផង់ធូលី មិនឲ្យមានឈាម ១ ដំណក់ស្រក់ដល់
ស្មៅ ឥឡូវនេះនេះ រឯបុណ្ណកយក្ខឯង ត្រូវត្រាធពាក្យមហិមាតេតវត្រ
តុំមាត់ ខះដៃជាង កាន់ក្រចាបាមេកាយ មឹង មិនដឹងអញឈ្មោះ បុណ្ណក-
យក្ខទេហ៎ះ អញឯងជាកូយព្រះបាទវេស្សវណមហារាជ មឹងមិនខ្លាច
អញទេឬហ៎ះ រឯយក្ខកុម្ភណ្ឌទាំង ៤ នូវតលទាំង ១ ពាន់នោះ លុះឮពាក្យ
បុណ្ណកយក្ខ ស្រែកសន្ធាប់ទៅដូច្នោះហើយ សឹងតែកិតភ័យញ័រ អស់
ដើងដៃរូតរត់ខ្ចីខ្ចាវ ញញ័រទៅក្រៅកណ្តាលចក្រវាឡនាយហើយ
ទើបទំនៃស្រដីក្រឡេកក្រឡក់ កំមើលមុខគ្នាថា ឧស្តាយអើយណាស់
អន្តរាយគ្រាជាម្ល៉ះ ។ នេះ លុះកណ្តាប់ដៃវាបុណ្ណកយក្ខនេះហើយហ៎ះ
ឯបុណ្ណកយក្ខនោះសោត កាលបើយលំអិតយក្ខ កុម្ភណ្ឌទូវតលទាំងនោះ
រត់ជាត់អស់ហើយ បុណ្ណកយក្ខ សរសៀរដើរចូលទៅឆក់ ចានតែវមណី
នោះមក ជក់ទៅថ្នក់ស្រេចហើយ ស្ទុះផ្ទាត់លោតទៅដិះ លើខ្នងសេះ
មនោម័យបរទៅកាន់ ឥន្ទបត្តបុរីកាលនោះហោង ។ បុណ្ណកយក្ខបាន
ទៅដល់ឥន្ទបត្តបុរី ស្រីមហានគរនោះហើយ ចុះពីលើខ្នងសេះមនោម័យ
ដៃម្ខាងដឹកសេះដៃម្ខាងខ្ចើខ្ចែតែរដើរចូលទៅកាន់ដំនុំ ព្រះបាទធនញ្ជយ
កោរព្យាកដ ។ ឯកសតរាជស្តេច ១ រយនឹងមួយ កាលនៅនោះឯង បុណ្ណ
កយក្ខឥតខ្លាចសីហនាដគគាតស្រដី អួតអាងទៅថា ។ តោ ឯឯ រញ្ញោ

វ៉ាមាកិនេតិ កាមាកិនេយោមវ៉ាទូនេន ។ ថាមហាពរលើស្ថាវ
ចំពោះនរណាទៅនេះ ក៏នឹងអាចលើស្ថានេធ៌យើង ដែមហាពរដើយ
អញ្ជើញព្រះអង្គទ្រង់ស្ថាវ៉ា ក្រែងមហាពរមានដ៏យជំនះឈ្នះយើងហើយ
ក៏នឹងបានទ្រព្យប្រសើរអំពីយើង កាលនោះព្រះបាទធនញ្ជយគោរព្យាពរ
ព្រាហ្មណ៍កុណ្ឌកយក្ខ ស្រដាំអង្គប្រកួតទៅដូច្នោះហើយ មហាក្សត្រទ្រង់ព្រះ
ចិន្តាតិថាណា ថា តាន់នេះតើមកអំពីឯណានេះ ក៏អាចហានក្លាក្រខាដល់
ម្ល៉ះ មាល្បាយហ៊ាៈ មកោក្សត្រតិតម្ល៉ាៈហើយ ព្រះអង្គសួត្រដាបទព្រះ
គាថាដណ្តឹងទៅថាៈ កុហិ ឧ ៈដ្ឋ តៈ ជាតិភូមិ ។ ថារើយចៅមា
ណពដ៏កសេះ ចៅមកអំពីស្ថានឯណា លំនៅតំណើតចៅតើនៅឰដ៏ស្ថាន
ឯណា ម៉ៅដោយសំដីពាក្យចៅហើយ មិនយល់ជាចៅនៅស្រុកគោរព្យ
ពស្តេច្បើយ រឯពាក្យសំដីអ្នកស្រុកគោរព្យពស្តេនេះស្រដីផ្សេង ឯចៅ
ស្រដីនោះយល់ ឥតភ្លឹកឥតខ្ចាច ចៅស្រដីរះតែប្រកួតលើស្ថាវ កណ្តាល
ជំទុំអស់មហាក្សត្រជង ដើយចៅមាណព តើចៅឈ្មោះអ្វីហ៊ាៈចៅប្អូនសំ
ដែងប្រាប់យើងឲ្យទាប់ តើញាតិគាវៅតង្ស្យចៅនៅឯណា ? បុណ្ណក-
យក្ខស្តាប់ហើយ ទ្វើយថាមេយោ ស្តេចនេះ ចេះឯណ្តឹងដល់ឈ្មោះអញ
ហើយតើ អញនឹងប្រាប់ថាឈ្មោះអ្វីទៅនេះ អញនឹងប្រាប់ថាឈ្មោះ
ចៅបុណ្ណទៅហ៊ាៈ ឯឈ្មោះបុណ្ណ ។ នោះ អស់អ្នកផងចាំងតួងឯចំណាំតែចៅ
អាបុណ្ណ ។ ថាបើអញប្រាប់ថាឈ្មោះបុណ្ណដូច្នោះហើយ សំមហាក្សត្រ

ខ្ញុំដ៏មានព្រះបន្ទូលអ្វី ។ ខ្ញុំដ៏អញ សំមិនកោតញញើតអញដល់តិចឡើយ
បើដូច្នោះហើយ អញខ្ញុំដ៏ច្រាប់ឈ្មោះអញ កុំឲ្យមហាក្សត្រហៅត្រង់ ។
ណាបានឡើយ បុណ្ណកយក្ខគិតម្ងាំះហើយឆ្លើយទៅថា ។ កាច្ចាយ
នោមាណវកោស្មឹ ភាគ ។ បពិត្រព្រះមហាក្សត្រអើយ ឈ្មោះខ្ញុំ
នេះគេហៅថាកំចាយមាណព ដ្បិតអ្វីគេហៅកំចាយមាណពនោះ ថា
ដ្បិតខ្ញុំដាក់ត្រង់ណាហើយ វាខ្ចាយត្រង់នោះឯង ហេតុដ្បិតដូច្នោះហៅខ្ញុំ
ថាកំចាយមាណព គេមិនហៅតែចៅកំចាយមាណពឡើយ គេហៅថា
ចៅមិនចេះថយផង ដ្បិតចិត្តខ្ញុំនេះរឹង ថាបើខ្ញុំដើរត្រង់ណាហើយ កំមិន
ចេះថយក្រោយឡើយ ចេះតែទៅមុខ ពោះយោបក្រក្រាយប៉ុន្មាន ។
ក្តី កំខ្ញុំទៅត្រាតែបាន ហេតុដូច្នោះហោង គេហៅខ្ញុំថាចៅមិនចេះ
ថយក្រោយឡើយ ហើយគេហៅចៅអនន្តនាមផង នាគេហៅខ្ញុំថាចៅ
អនន្តនាមនោះ ដ្បិតគេយល់ឈ្មោះខ្ញុំនេះច្រើនជាអនេកអនន្ត ខ្ញុំគណនា
ត្រាប់ពុំបានឡើយ ហើយភូមិស្ថានលំនៅកំណើតកើតជាមេឋាតិកា
ផៅពណិខ្ញុំនោះសោត នៅស្រុកអង្គពស្ត្រនាយ ខ្ញុំមកតាំងអម្បាលនេះ
ប្រយោជន៍បុំនបំងសេងស្ការនឹងមហាក្ស សូមគាន់អញ្ជើញព្រះអង្គទ្រង់
ស្ការនឹងខ្ញុំ ។ ខ្ញុំសេងរៀបព្រះអង្គផង ។ អណ្តាប់នោះ មហាក្សត្រគិតថា
រីចៅមាណពនេះខ្ញុំចង់សេងស្ការនឹងអញ តើមានប្រថ្នាអ្វីអេះ ថាបើ
គាត់ឈ្នះអញមិញ កំបានទ្រព្យអំពីអញ ថាបើគាត់ចាញ់អញហើយ

តើគាត់ចាន់អ្វីឲ្យអញ ស្តេចសូត្រជាបទព្រះគាថាដណ្តឹងថា: កិំ មាណ
វស្ស រតនាឯ អត្ថិ ។ ហៃចៅមាណពអើយ នាចៅនឹងមកលេងស្ពារ
នឹងយើង តើចៅមានទ្រព្យអ្វី បើចៅមានជ័យដំនះឈ្នះយើងមិញ ចៅចាន
ទ្រព្យរបស់អំពីយើងនោះច្រើន បើចៅចាញ់យើង តើចៅនេះជាអ្នកកំសត់
ទុគ៌ត ចៅនឹងចាន់ទ្រព្យរបស់អ្វីជាលំអ ក៏ចៅនឹងឲ្យយើងហ៎: បុណ្ណក-
យក្ខស្តាប់ហើយឆ្លើយថា: មនោ ហាវេ ជាម មណិ មមាយំ ។
ថាបតិត្រមហាកដ តែវមណីរត្នៈខ្ញុំមួយនោះ ឈ្មោះមនោ នឹងសេះមនោ-
ម័យខ្ញុំ ១ នោះសឹងជាទ្រព្យប្រសើរ ខ្ញុំយកមកនេះប៉ុនប៉ងនឹងលេងស្ពារ
ថាបើខ្ញុំចាញ់ហើយ ខ្ញុំនឹងថ្វាយជាដំណាងស្ពារ នៃព្រះអង្គហោង ស្តេច
ស្តាប់ហើយឆ្លើយថា ។ ឯកោ មណិ មាណវ កិំ ករិស្សតិ ។
ថាហៃចៅមាណពហើយ នឹងធ្វើអ្វីតែវមណីរត្នៈ ខ្លួវសេះមនោម័យ ចៅ
តែមួយនោះ ប្រាក់តែសត្វតិរច្ឆានយើងមានច្រើនរះជាករជុល កល់ជា
ដើងក្រាន់ដណ្តើ ចាយមិញហើយ សេះអាជានីយសោតជារយជាពាន់ សឹង
តែមានកំលាំងរួសធាប់ស្មើឲ្យល់ សត្វថ្ងៃនេះខ្ញុំលែតែនឹងបានឹងប្រើវិញ ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ ខ្មែរត្រូវថែរក្សា
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សតរៀងមិនត
ព្រោះអក្សរជាតិ ជោលជាតិប្រាកដ
អក្សរលត់ ជាតិក៏រលាយ

ប. ព.

អំពីរបបការរស់នៅនៃមនុស្ស

(វិចារណកថា)

លោក ផេង-ជ្រឹះ និពន្ធ

ផែនដីមូលដែលគេនិយមហៅ « ពិភពលោក ឬ សាកលលោក » មានសត្វអាស្រ័យនៅគ្រប់តំបន់ ។ ឯសត្វ (មនុស្ស) ពួកនេះមានប្រកាន់លទ្ធិផ្សេងៗគ្នា : លទ្ធិប្រជាធិបតេយ្យលោកសេរី លទ្ធិប្រជាធិបតេយ្យប្រជាមានិត និងលទ្ធិប្រជាធិបតេយ្យអតន្ត្រាក្រិត ។

តាមការពិនិត្យ មុនសង្គ្រាមលោកលើកទី ១ (គ.ស. ១៩១៤) របបត្រប់ត្រងនៃប្រទេសទីមួយៗ ក្នុងសាកលលោក មិនមានលទ្ធិធំផ្សេងគ្នាទេ បើមានខ្លះនៅត្រង់ពាជនិយម និងសាធារណរដ្ឋនិយមតែប៉ុណ្ណោះ ឯរបបចាត់ការនឹងការត្រួតត្រាប្រទេស មានសភាពប្រហែលគ្នា ។

នៅគ.ស. ១៩១៧ (សង្គ្រាមលោកលើកទី ១ មិនទាន់ចប់) ស្រាប់

តែមានកើតរបបគ្រប់គ្រងច្បាប់មួយនៅឯប្រទេសរុស្សី របបនេះមានឈ្មោះថា «សង្គមនិយមឬកុម្មុយនិស្ត» ជារបបដែលធ្វើឲ្យប្រទេសដទៃមានការព្រួយបារម្ភយ៉ាងខ្លាំង ដែលព្រួយខ្លាំងជាងគេ គឺប្រទេសប្រជាធិបតេយ្យលោកសេរី មានអាមេរិកាំងជាដើម ។

សួរថា : យ៉ាងដូចម្តេច ឈានជាប្រទេសដទៃ មានសេចក្តីព្រួយព្រោះតែលទ្ធិច្បាប់នេះ ?

ឆ្លើយថា : ព្រោះខ្លាចលទ្ធិនេះចូលមកកាន់ប្រទេសខ្លួន គេនិយមពុកលទ្ធិកុម្មុយនិស្តជាធម្មឆ្នងមួយដ៏សាហាវ ប្រៀបបាននឹងជម្ងឺពិស ឬអាសន្នរោគដែលគេនិយមថាដុះជានរសើរកោតមនុស្ស ។

លុះផុតសង្គ្រាមលោកទី ១ (គ.ស. ១៩១៨) ពិភពលោកចេះតែនាំគ្នាដើរទៅមុខជាជាងមុន ក៏ប៉ុន្តែ ប្រទេសនានា ខ្លាចលទ្ធិកុម្មុយនិស្តដូចមនុស្សខ្លាចខ្លា ។ គេដើរឃោសនាថាលទ្ធិនេះធ្វើបាបប្រជាពស្ត្រណាស់ ប្រជាពស្ត្រគ្មានសេរីភាពសល់តែសោះ ម្ល៉ោះហើយ មនុស្សទាំងឡាយដែលនៅឆ្ងាយពុំបានដឹងពុំបានយល់ ពាលបើឮថាលទ្ធិកុម្មុយនិស្តនៅត្រង់ណា នាំគ្នាព្រឺក្បាលសំពោងចង់តែរត់ចេញ ដូចក្មេងខ្លាចខ្មោចលង ប៉ុន្តែគួរឲ្យធ្វេសណាស់ លទ្ធិកុម្មុយនិស្តដែលគេនិយមពោលថា អាក្រក់ ដុះជានប្រជាពស្ត្រ ចេះតែមានដំណើរដែរតាមធាតុធម្មជាតិ ដោយពង្រីកអានុភាពលឿនសន្សឹម ។ ឥតយូរក្រោយ ដូចដើមឈើដុះនៅដីមានជីរជាតិ ។

នៅឆ្នាំ ១៩៣៧ សង្គ្រាមលោកលើកទី ២ កំពុងផ្ទុះឡើង ដែលមានប្រទេសអាឡឺម៉ង់ ប្រទេស អ៊ីតាលី ទឹងប្រទេសជប៉ុនជាអ្នកចង្អុ តែប្រទេសទាំង ៣ នេះ ត្រូវបានទទួលបរាជ័យទៅវិញនៅឆ្នាំ ១៩៤៣ ដោយមានប្រទេសអាមេរិក ទឹងប្រទេសរុស្ស៊ីជាមេក្នាងចំបាក់ចំបាប ជាមួយប្រទេសសម្ពន្ធមិត្តដទៃ តែគេះជាសាកលលោកត្រឡប់មានសន្តិភាពខ្លះឡើងវិញ ក៏លុះនៃមេក្នាងទាំងពីរ នៅតែប្រទាំងគ្នាជានិច្ចកាល ចង់ពៀរទឹងគ្នាដូចក្អែកទឹងមៀម ។

ដើម្បីការពារនឹងរក្សាលទ្ធិបស់ខ្លួនឲ្យគង់វង្សទឹងឲ្យរីកចម្រើន មេក្នាងទាំងពីរត្រូវតែស្វែងរកមិត្ត ។ ព្រោះតែការស្វែងរកគូកនេះហើយ ទើបសាកលលោកត្រូវធ្លាក់ចុះកន្លងរណ្តៅអសន្តិសុខខ្លះឡើងវិញ ដ្បិតអ្នកមូលធនិយម ត្រូវចិត្តទឹងលទ្ធិលោកសេរី អ្នកពាស្តែនិយម ពេញចិត្តទឹងលទ្ធិកុម្មុយនិស្ត ម្ល៉ោះហើយមតិនៃប្រទេសគូចតាចត្រូវបែកខ្ញែកគ្នា ហើយដណ្តើមអំណាចគ្នាដូចក្តាតប្រជែងសត្វគោ ដោយមធ្យោបាយផ្សេង ។ ត្រូជាក់ក៏មាន ក្តៅក៏មាន ។

សូមបញ្ជាក់ថា កាលសង្គ្រាមលោកលើកទី ២ ដែលបានផ្ទុះឡើង កំមិនបណ្តាលមកពីអ្វី ក្រៅពីបញ្ហាក្រពះលោភឡំដោយការស្វែងអំណាចអន្តរជាតិធ្វើជាមួយផងឡើយ ព្រោះនៅសម័យនោះ ចក្រពត្តិនិយមទឹងអាណានិគមនិយមខាងបស្ចិមទិសមានជាអាទិ គឺចាក់ឯ អង់គ្លេស ទឹង

អាមេរិកាំង ជាន់ពត់អំណាចត្របដណ្តប់លើសាកលលោកទាំងមូល ជាពិ-
សេសលើទ្វីបអាស៊ីនិងអាហ្វ្រិក ស្បៀតនឹងចុកដង្កើមរស់នៃប្រទេសដទៃ
ទាំងផ្លូវសេដ្ឋកិច្ច មិនឲ្យសឹកសត្វខ្លាដែលជាន់ឈាហើយ គ្មានចែករំលែក
ភាគខ្លះឲ្យសត្វដទៃ តែប្រមូលទុកសម្រាប់តែខ្លួនមួយ ម្ល៉ោះហើយប្រទេស
ដទៃមានសេចក្តីក្តៅក្រហាយមហិមា ទើបក្លាយទៅជាភ្លើងសង្គ្រាម ។

ទាំងក្រោយសង្គ្រាមលោកលើកទី ២ ប្រទេសចំណុះទាំងប៉ុន្មានក្នុង
ទ្វីបអាស៊ីនិងអាហ្វ្រិក ជាន់ឈ្នាន់គ្នារើសាស់នឹមចក្រពត្តិនិយម ទើងអាណានិ
គមនិយមចោលចេញ ដើម្បីតាមការយកឯករាជ្យវិញ ។ ខ្លួន ។ ឯការ
តាមការឯករាជ្យនេះ ខ្លះក៏យកបានដោយមធ្យោបាយក្តៅ ខ្លះក៏យក
បានដោយមធ្យោបាយត្រជាក់ (ប្រទេសកម្ពុជាបានដោយមធ្យោបាយត្រ
ជាក់ ដោយសារព្រះប្រាជ្ញាញាណដ៏ក្លាហានទើងមានមុតនៃព្រះករុណាព្រះ
បាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន នៅថ្ងៃទី ៩ វិច្ឆិកា ១៩៥៣) ។

ប្រទេសឯករាជ្យថ្មីទាំងប៉ុន្មាន ការបើរួចខ្លួនពីក្រញាំចក្រពត្តិនិងអា
ណានិគមនិយមហើយ ត្រូវលែតំនិតស្វែងរកសុខ ព្រោះអើនឹងសង្គ្រាម ១
លើក ២ លើកមកហើយ ។ ដែលត្រូវនាយទៅហ្វាយប្រើឲ្យទៅស្លាប់ជួសគេ
ក្នុងសមរភូមិ ។ ប្រទេសទាំងនេះ ខ្លះក្រេចខ្លួនប្តេជ្ញាដោយខ្លាច ក៏ត្រូវត្រឡប់
ចូលធ្វើជាគូកនទើងចក្រពត្តិមូលធននិយមវិញ ម្ល៉ោះហើយក៏ត្រូវចក្រពត្តិ
មូលធនធ្វើឲ្យដុះគោះដូចជ្រូកណែលណាល ។ ឈប់មានតំនិតទើងនាំប្រជា-

រាស្ត្រប្រកបការងារ ព្រោះថាយាគេឲ្យស៊ីស្រាប់ ស្លាប់គំនិតស្លុក ខ្លះភ្លាក់ខ្លួនធំដាមានគំនិតរឹងប៉ឹង មិនចូលដៃនឹងប្រទេសណា គឺប្រកាសខ្លួនជាអព្យាក្រឹត តួយ៉ាងដូចប្រទេសកម្ពុជាដែលមានអង្គសម្តេចព្រះនរោត្តម សីហនុជាព្រះអគ្គមគ្គុទ្ទេសក៍ ព្រះអង្គនេះជារដ្ឋបុរសដ៏ឆ្នើមនឹងពាំងវៃបំផុត រកវដ្ដបុរសណាក្នុងលោកមកប្រៀបស្មើពុំបាន ។ ហេតុបានជាហ៊ានថាដូច្នេះ ព្រោះប្រទេសកម្ពុជាតូច ក្រ ហើយមនុស្សកំតិច បេះអាចធ្វើអព្យាក្រឹតភាពបានសុខធំដាមានស្មោះត្រង់បានជាឯអព្យាក្រឹតភាពប្រទេសនានា ឥតលំអៀងចាក់ទៃលទៅខាងណា ម្ខាំះហើយ ប្រជាពស្ត្របស់ព្រះអង្គបានសុខណាស់ទើបជនបរទេសឲ្យនាមប្រទេសកម្ពុជាថា «កោះសន្តិភាព» ល្បីខ្ទឹមពេញពាំងពិភពលោក ដែលជាហេតុនាំឲ្យប្រទេសជិតខាងដែលត្រូវប៉ះភ្លាក់ទៅក្នុងរណ្តៅចាស់ ប្រណែនណ្នាះ ហើយបង្កើនវិអសន្តិសុខខ្លះទៅតាមត្រាំប្រទល់ដែនជារឿយ ។ តាមសេចក្តីណែនាំទៅហ្វាយខ្លួន ។ ព្រោះហេតុនេះទើបប្រទេសកម្ពុជាផ្តាច់មិត្តភាពចេញពីប្រទេសទាំងនេះ ព្រោះជាប្រទេសគ្មានសេចក្តីយោគយល់នឹងស្មោះត្រង់ចំពោះគ្នានឹងគ្នា មានគោលបំណងធ្វើយ៉ាងណាឲ្យតែកម្ពុជាធ្លាក់ក្នុងក្តក់អសន្តិសុខដូចខ្លួនដែលវាស់ទៅក្រោមនឹមគំនិតបរទេសដែលគេឲ្យថាយខ្លួនស៊ី ប្រយោជន៍ឲ្យខ្លួនធ្វើជារបងការពារនឹងឲ្យទៅស្លាប់ជួសគេ មិនប្លែកគ្នាពីអ្នកលេងស្លាប់គំនិតដែលថៅតែរថយក្តៅ ជួលឲ្យរកប្រយោជន៍ឲ្យគេ ឲ្យជួយការពារថយក្តៅឲ្យ

គេ ស្វាប់រស់ជាប់គុកជាប់ច្រវាក់ស្រេចលើគេ ហើយគេឲ្យប្រាក់បំណាច់ប្រចាំថ្ងៃសំរាប់ចិញ្ចឹមជីវិតខ្លួនទឹងតែក្រុមគ្រួសារតែប៉ុណ្ណោះ ។

សព្វថ្ងៃ កងលោក តាមការសង្កេត លក្ខិណៈ ។ មានតែបី គឺលក្ខិ-ណៈសេរី លក្ខិកុម្មយនិស្ស័យលក្ខិអព្យាក្រឹត ។ ការរស់នៅនៃបេបលក្ខិណៈសេរី ដែលមានសហជីពគាំទ្រកាមេរិកជាមេក្តោង និយមពឹងផ្អែកទៅលើសេរីភាពខាងសម្ភារៈ គឺថាជនណាបរិបូណ៌ដោយសម្ភារៈ ទើបអាចរកសុភមង្គលត្រប់ឃ្លាំងបាន ទោះសម្ភារៈនោះ ខ្លួនកេបានមកដោយមធ្យោបាយបែបណាក៏ដោយ ។ ឯការរស់នៅនៃបេបលក្ខិកុម្មយនិស្ស័យ មានសភាពផ្ទុយពីបេបខាងលើ គឺពឹងផ្អែកទៅលើសុឆន្ទៈនឹងកម្លាំងសេរីភាពខាងចំណេះវិជ្ជា ជនដែលទៅកងលោកកុម្មយនិស្ស័យ អាចជួបប្រទះនឹងសុភមង្គលត្រប់ប្រការបាន ឲ្យតែខ្លួនមានសុឆន្ទៈចំពោះការងារ បានន័យថាឲ្យតែខ្លួនស្មគ្រនឹងស្មោះកងការងារ ។

សួរថា : មនុស្សត្រប់រូបរស់នៅប្រាថ្នាអ្វីចំពោះខ្លួនឯងចំពោះគ្រួសារ?

ឆ្លើយថា : តាមការយល់ មនុស្សរស់នៅប្រាថ្នាតែសុភមង្គលតែប៉ុណ្ណេះ ដើម្បីខ្លួនឯងគ្រួសារ ។

តមកទៀត ឯលក្ខិទី ៣ គឺលក្ខិអព្យាក្រឹត ។ យ៉ាងដូចម្តេចបានជាមានលក្ខិនេះឡើង ! លក្ខិនេះកើតមានឡើង មានចំនងប្រហែលនឹងធម៌នៃព្រះពុទ្ធបរមគ្រូ បើតាមខ្ញុំប្រៀបធៀប ទ្រឹស្តីនៃព្រះពុទ្ធសំដៅយកការប្រ

ព្រឹត្តជាកណ្តាលហៅថា «មជ្ឈិមាបដិបទា» មិនតឹងពេកមិនធូរពេក ។
លទ្ធិអត្ថក្រិត ជាលទ្ធិអ្នកសង្កេតការយកប្រយោជន៍ : ឃើញបទត្រង់ណាល្មម រើសយកមក ឃើញបទត្រង់ណាជ្រោកជ្រាកពេកឬក៏តឹងរឹងជ្រុលពេក ត្រូវចាត់ចោល ឬានសេចក្តីថាមេលទ្ធិអត្ថក្រិតមានគោលបំណងតែមួយ គឺសេចក្តីសុខ មិនច្រាំថ្មាក់តអំណាច មិនច្រាំថ្មាជិះជាន់លោកយកទឹកដីប្រទេសដទៃ ។ នេះបាយធំបំផុតនៃអ្នកអត្ថក្រិត ទី១ស្នេហាជាតិឥតរើសមុខ ទី ២ ខំធ្វើការដើម្បីញុំាងប្រទេសជាតិខ្លួនឲ្យមានវឌ្ឍភាព ទី ៣ មិនត្រូវការរកវឿងហេតុបង្កើតសំលេះនឹងប្រទេសណាកុំឲ្យតែប្រទេសនោះគំហែងគំរាមខ្លួន ។

រួមសេចក្តីទៅ នៅលើផែនដីមូលដែលមានឆាមថាពិភពលោកសព្វថ្ងៃមានលទ្ធិ ៣ ដូចពោលមកនេះ សូមអ្នកអានចាំងឡាយពិចារណានឹងជ្រើសរើសដោយសុភនិច្ឆ័យធងចុះ ។

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ទ៉ាំង-ខាត់ រៀបរៀង

(តមក)

អនង្គីកប្បត គុ. ដែលគេមិនចុះឈ្មោះ ដែលគេមិនត្រូវការ ។

អនង្គុលីយក គុ. ដែលមានចិញ្ចៀនមិនមាន ។

អនញ្ជិត គុ. ដែលមានថ្នាំសាបមិនមាន ។

អនឌ្វា (ប្រឋម – អានឌ) គុ. គោ ។ អនឌុទ្ធ គុ. អ្នកឲ្យគោ ។

អនណ្ដ ដែលល្អិតមិនមាន ដែលមិនមែនជាអណ្ដ ។ អនណីយោម្ស គុ.

អនតិក្កប្ប្រ គុ ដែលមិនលំបាកក្រៃលែង។ ។

អនតិក្រមនីយ គុ. ដែលមិនគប្បីប្រព្រឹត្តកន្លង ។

អនតិត្រស្ន គុ ដែលខ្លាចក្រៃលែងមិនមាន ដែលមិនខ្លាចក្រៃលែង ។

អនតិទគ៌ន នបុ. តិរិយាឈើញក្រៃលែងមិនមាន ។

អនតិទូរ ក្រ. វិ. មិនឆ្ងាយក្រៃលែង ។

អនតិទុច្ចរ្យ គុ. ដែលឈើញក្រៃលែងមិនមាន ដែលស្រអាប់ ។

អនតិបក្ង គុ. ដែលទុំក្រៃលែងមិនមាន ដែលស្រគាល ។

អនតិបាត្យ ដែលធ្លាក់ក្រៃលែងមិនមាន ដែលមិនប្រមាទ ។

អនតិបឹងមិ ក្រ.វិ. ដោយការរៀនរៀនក្រៃលែងមិនមាន ។

អនតិប្រត្តិ គុ. ដែលដាប្រស្នាក្រៃលែងមិនមាន ។

អនតិប្រៀង្ស គុ. (ផ្លែ) ដែលរីកក្រៃលែងមិនមាន ។

អនតិភង្គុរ គុ. (សក់) ដែលមានដ្ឋត់ក្រៃលែងមិនមាន ។

អនតិរក្ខ គុ. ដែលឆោះបង់ក្រៃលែងមិនមាន ។ ដែលរក្សាទុក ។

អនតិរេប ឧបុ. កិរិយាមិនឆោះបង់ចោលក្រៃលែង កិរិយារក្សាទុក ។

អនតិលំពិត គុ ដែលប្រគោងក្រៃលែងមិនមាន ។

អនតិលុលិត គុ· ដែលឯបក្រៃលែងមិនមាន ។

អនតិលោលមិ ក្រ.វិ ដែលមិនប្រញាប់ក្រៃពេក ។

អនតិវិលិត គុ. (ពោះ) ដែលធូលក្រៃលែងមិនមាន ។

អនតិវិលមិ ក្រ.វិ. ដោយវែលាដ៏ខ្លី ។

អនតិគង្គា ស្ត្រី. កិរិយាមិនខ្ជាបក្រៃលែង ។

អនតិអយនីយ គុ. ដែលមិនគប្បីកន្ទុងក្រៃលែង ។

អនតីត គុ. ដែលមិនទាន់កន្ទុង ។

រឿងអាប៊ូលហ្វាអ៊ូរីស

លោក ភ័ឃ ល្មុត តំណាងកម្ពុជ ប្រែរៀបរៀង

(ក)

នាងនិយាយមកកាន់ខ្ញុំថា៖ អាប៊ូលហ្វាអ៊ូរីស៍អើយ! ខ្ញុំមានសេចក្តីតែកយត្រង់ ១ នេះ គឺ ១ ដែលលោកឪពុកខ្ញុំ លោកជ្រើសអ្នក ដើម្បីធ្វើជាប្តីរបស់ខ្ញុំ ព្រោះខ្ញុំឥតមានសន្ទិះសង្ស័យសូម្បីតែបន្តិចបន្តួចក៏គ្មានដែរថា អ្នកគឺពិតជាមនុស្សស្មោះស អាចហ៊ានយកខ្លួនអ្នកទៅចូលចុក្ខ ទោសត្រង់យ៉ាងណាលែលកឆ្លើយយ៉ាងម្តេច ឲ្យតែរូបខ្ញុំបានដល់ខ្លួវស្មុកមង្គល...

(គ) - សូមអ្នកស្រីក្រមុំកុំប្រឡឹ ។ ខ្ញុំជាមនុស្សកំសត់ពន់ពេក ខោះបើខ្ញុំខំតស៊ូយ៉ាងណាក៏ដោយ ខ្ញុំដឹងថា ខ្ញុំត្រូវកេស្មុកមង្គលជូនអ្នកស្រីក្រមុំបានត្រឹមតែតបស្នងស្នេហ៍ស្មើតែគ្មានផងក៏ពុំដឹង ដូច្នេះប្រហែលជាពិតខ្លះ... ។

(ហ្វា) - ចូរអ្នកប្រុសស្តាប់ខ្ញុំ ។ ការណ៍ពិតគឺដូច្នេះ! ជាយូរហើយ ខ្ញុំដាក់ចិត្តស្រឡាញ់កូនរបស់ពាណិជម្នាក់នៅទីក្រុងតួលក្នុងនេះឯង កូនពាណិជនោះ ក៏តេស្រឡាញ់ខ្លួនខ្ញុំមកវិញដែរស្មើចិត្តគ្នា ស្រឡាញ់គ្នាទៅវិញទៅមកស្មើស្មាច់រៀងកាល់ខ្លួន ។ គេបានឲ្យចៅមហាមកជួបឪពុកខ្ញុំ ស្តីដណ្តឹងខ្ញុំ ឲ្យប៉ុះសេដ្ឋីថ្លៃថ្លារបស់ខ្ញុំនេះ ជាច្រើនលើកណាស់ហើយ ។ ឪពុកខ្ញុំលោកចេះតែពុំព្រមសោះ ព្រោះគ្រួស្មារ

យើងតាំងពីតុំសូវត្រូវគ្នា ដោយរឿងថាស់ឃ្លាយោរណាស់ទៅហើយ... ខ្ញុំគិតធ្វើដូច្នេះ គឺសូមអ្នកប្រុសកុំអាក់អន់ចិត្តម្ដងទៀតខ្ញុំ សូមអ្នកប្រុសរៀបអាពាហពិពាហជាមួយនឹងខ្ញុំទៅចុះ... ដល់មួយថ្ងៃបន្ទាប់ពីថ្ងៃផ្សំដំណោកអ្នកប្រុសត្រូវធ្វើជាទឹងក្ងាន ស្រែកឡូនឡាងក្អេងក្អាង បណ្ដេញប្អូនខ្ញុំឲ្យចេញពីផ្ទះជាប្រញាប់ ។ តទៅទៀត អ្នកប្រុសត្រូវធ្វើមុខស្រងូតស្រងាត់ សង្ខាចំសង្ខាញឹងស្ដាយក្រោយ បង់ឲ្យខ្ញុំត្រឡប់មកផ្ទះវិញ រួមរស់នាគ្នាតទៅ... លុះដល់ដំណើរឈឺដល់... អ្នកប្រុសត្រូវចង្អុលសុំឲ្យគូស្នេហារបស់ខ្ញុំខោះ ធ្វើជា «ហុល្លា(១)» របស់អ្នក ។

(ក) - មិនអីទេ ខ្ញុំធ្វើជូនអ្នកស្រីបាន! តាមតែក្រូងខ្ញុំតានតឹងយ៉ាងណាក៏ដោយ ចិត្តខ្ញុំទន្លិះចង្អៀតណែនយ៉ាងណាក៏ដោយ ក្នុងកាលប្រាសនឹកសន្ធូវគ្នាមួយដឹកពូលចិត្តស្រស់ប្រឹមប្រើយតាំងម្ល៉ះ... តែលោកមហាសេដ្ឋីខ្មៅពុក តើលោកនឹងទៅជាយ៉ាងណាទៅ អ្នកស្រីអើយ! ។ អ្នកស្រីជ្រាបស្រាប់ហើយ លោកមានគុណនឹងខ្ញុំច្រើនណាស់ លោកមុខតែឆ្ងល់ ហើយក្តៅក្រហល់ក្រហាយខ្លាំងហើយ! ចំពោះមារយាទអកុសល

---

(១) តម្លឺរក្លាំនពោលថា អ្នកម៉ាហ្វូម៉ុតណាបណ្ដេញប្រពន្ធរបស់ខ្លួនទៅហើយ ហើយចង់បានស្រីនឹងដែលនោះ មកធ្វើជាប្រពន្ធរបស់ខ្លួនវិញ អ្នកម៉ាហ្វូម៉ុតនោះត្រូវប្រតិបត្តិដូចតទៅ: ត្រូវរកបុរសម្នាក់ហៅថា ហុល្លា រៀបអាពាហពិពាហជាមួយនឹងស្រីនោះសិន (រៀបអាពាហ៍ពិពាហ៍ ដាឯបកិច្ចកំរៀបទៅចុះ) ហើយមួយថ្ងៃបន្ទាប់ពីថ្ងៃផ្សំដំណោកមក ហុល្លាត្រូវបណ្ដេញស្រីសាមីនោះចេញពីផ្ទះ ធ្វើដូច្នេះ ទើបនាងនោះត្រឡប់មកយកក្ដីដើមរបស់ខ្លួនវិញបាន.. ។

រថស់ខ្ញុំ មុខតែលោកបន្ទោសខ្ញុំយ៉ាងធ្ងន់ជាមិនខាន . . . ចុះខ្ញុំត្រូវធ្វើយ
តបទៅលោកវិញយ៉ាងម្តេចទៅ អ្នកស្រីអើយ . . . ។

(ហ្វា) – កុំអ្នកប្រុសត្រួយថប់ចាម្តេអ្វី អ្នកធ្វើដូចខ្ញុំប្រាប់អ្នកអំបាញ់
. មិញទៅចុះ ឥពុកខ្ញុំមុខតែលោកសប្បាយចិត្តនឹងអ្នកហើយ ! ។

(អា) – លុះបានទំនុកចុកចិត្តគេញឹ ចំពោះសេចក្តីស្មោះត្រង់របស់
ខ្ញុំក្តីរឿងអាថកំបាំងនេះ ! អ្នកស្រីហ្វាក្រែងនិយាយ តាំងខ្លួចសុំឥពុកនាងឲ្យ
រៀបអាពាហ៍ពិពាហ៍ជាប្រញាប់ទៅ ! តមក មានការរៀបពិធីលះបង់សាស
នារបស់អ្នកស្រី នឹងពិធីបញ្ចូលអ្នកស្រី មកសាសនាម៉ាហ្គូម៉ែតខានខ្ញុំ ស្រេច
ហើយ មានបុណ្យមង្គលការមួយយ៉ាងធ្ងន់ធ្ងរក... ខ្ញុំកំបានបណ្តោញនាង
ស្រី ជូបសេចក្តីសន្យាគ្នា . . . ។ ព្រឹកថ្ងៃខោះ ឥពុកនាងស្រី លោក
ប្រញាប់ប្រញាល់មកសួរហេតុផល ។ ខ្ញុំពន្យល់ថា ខ្ញុំយើញច្បាស់ថា
នាងស្រីមានដំណក់ចិត្តយ៉ាងខ្លាំងនឹងវត្ថុអ្វីមួយ ថ្វីបើនាងមានប្តូលខ្លាំងម្ល៉ះ
ខ្ញុំនឹងយកនាងធ្វើជាប្រពន្ធពុំបានទេ ។ លោកឥពុក លោកមានប្រសាសន៍
ចំអកឡកឡេបជ្រាយថា ខ្ញុំជាមនុស្សកំសាកញ៉ី ញាក់ញ៉ីតក្រអឺមក្រអៀម
ខ្លាចស្រី ទៅយកការបន្តិចបន្តួចមកពុកជាប្រមាណពួតជាដុំកជារឿងឲ្យធំ
ដល់ជាក់បែកគ្នាទៅកើត ! ម្ល៉ៃ ទៅធ្វើឲ្យវែលវាតប្រយោជន៍ អត់ធ្មត់
នៅជាមួយគ្នាចេះធ្វើស្ងួនភ្ញី ។ ទៅ កូនស្រីលោកវាជាប់ចិត្ត នឹងខ្ញុំទៅ
ហើយ ហើយលោកអង្វរកសុំឲ្យខ្ញុំទូលយកកូនលោកវិញទៅចុះ ។

ខ្ញុំធ្វើទឹកមុខដូចជាពេញចិត្តណាស់នឹងសំដីរបស់លោក ។ ខ្ញុំធ្វើជាប្រញាប់ប្រញាល់នឹងនរនាថ ទៅរក ហុល្ស៉ូ ម្នាក់ដោយខ្លួនខ្ញុំ សំដៅទៅចង្អុលយក អ្នកប្រុសគួរស្នេហារបស់អ្នកស្រី ហ្វាក្រ៊ីនិសា នោះតែម្តង! លោកត្រិត្តាចារ្យនៃវិហារ កាឌីកំរៀបអាពាហពិពាហនៅចំពោះមុខខ្ញុំ ។ សាមីខ្លួនចាំងពីរនៃបទនិត្យ រួមរ័កស្នេហ៍ស្និទ្ធជាមួយគ្នាមួយរយៈ...ដល់ព្រឹកឡើងពុំឃើញ ហុល្ស៉ូ បណ្តេញអ្នកស្រីប្រពន្ធរបស់ខ្ញុំសោះ ខ្ញុំចាំបាត់ទាំងអស់សង្ឃឹម ក៏ខ្ញុំធ្វើជារត់ហត់ម្លប ។ ទៅដំណបលោក ឌើហាអូស្ស ធ្វើមុខខ្ញុំធោធ្បោ ស្ងាំង ក្រៀមក្រំខ្លាំង ក្រញាវដៃម្ខាងទោកស្មាលខ្លួនឯង ដៃម្ខាងទៀតខ្ទាចក្រចៅមុខ ឆ្មេញចាំងចាំពួកគ្រឹត ។ ឈឺចិត្តណាស់ ស្ងាប់ទៅវិញល្អជាង!!...។

លោក ឌើហាអូស្ស ដកដង្ហើមធំយូរ! ហើយមានប្រសាសន៍ថា: ទៅមើល ហុល្ស៉ានេះ តើនរណាទៅ បើកជាមនុស្សក្រៃត់ទេ អញមានសិទ្ធិ អញមានច្បាក់ត្រប់ត្រាន់នឹងចោទកន្ត្រាក់យកកូនស្រីអញមកវិញឲ្យខាងតែបាន ...។

នៅពេលនោះ ខ្ញុំលោក ណាអ៊ីប ព្រឹទ្ធាចារ្យអញ្ជើញមកដល់ ហើយដំណបដុតក្អេកខ្ញុំថា ហុល្ស៉ានោះ មិនតើនរណាទេ គឺកូនរបស់លោក អាម៉ែពោណាង..., ហើយលោកបន្ថែមសេចក្តីថា ដូច្នេះកូនស្រីរបស់លោក ត្រូវចុះបង់ប្តីឲ្យ ហើយ ព្រោះហុល្ស៉ា ជានសម្រេចចិត្តជា

ស្ដាពរ តស៊ូគ្រប់បែបគ្រប់យ៉ាងដាច់អហង្ការ មិនត្រមង់ឲ្យប្រតន្ទខ្លួន ទៅ
នណាទៀតឡើយ ។ ខ្ញុំដឹងថាលោកអាម៉ែរ មិនមែនជាមិត្តរបស់លោក
ទេ តែខ្ញុំយល់ថា នេះជាឱកាសមួយ ដើម្បីយើងធ្វើការសម្រុះសម្រួល
គ្នា ។ ក្នុងរឿងនេះ ខ្ញុំសូមស្នើខ្លួនខ្ញុំធ្វើជាអ្នកកណ្ដាល យកអាសាលោក
ចុង ប្រសិនបើលោកត្រូវការខ្ញុំ ... ។

លោក ឌេហាអូស្ស សមលោកជាមនុស្សអ្នកដឹងខុសត្រូវស្រាប់
លោកនោកក្បាលយល់ព្រម ។ លោកណាអ៊ិបទៅជួបនឹងលោកអាម៉ែរ
ភ្លាមក្នុងពេលនោះ លោកអាម៉ែរ កំពុងមានទុក្ខព្រួយសោយសល់ក្រៃលែ
ក្រៃឃ ដូចលោកឌ្យូហាអូស្សដែរ . . , លោកណាអ៊ិប ចាប់ផ្ដើយ
សម្រុះសម្រួលលែលកផ្សែផ្សំ ទាល់តែឪពុកខាងប្រុសខាងស្រីចាំងពីសេ:
ជាស្រុះស្រួលនឹងគ្នា ញាញិមរីករាយទៅវិញទៅមក ដូចកូនប្រុសស្រីចាំង
ពីរនោះដែរ . . ។

លោកឌ្យូហាអូស្ស លោកដឹងខ្លួនភ្លាមថា កិច្ចស្រុះស្រួលគ្នាដូច្នេះ
ត្រូវនាំឲ្យខ្ញុំ (អា) វង់ទុក្ខវេទនាជាខ្លាំង ។ លោកមានសេចក្ដីអាណិត អា
ណោចលះទ្វោចចិត្តចំពោះខ្ញុំ ដោយឲ្យប្រាក់ខ្ញុំយ៉ាងសន្ធឹកសន្ធាប់ រួច
លោកលះលាត្រាប្រណីឲ្យខ្ញុំរួចខ្លួនជាអ្នកជា បង់ត្រឡប់ទៅបាសវ៉ាវិញ
ថ្ងៃណាក៏ទៅចុះ ។

(អា)- ត្រូវចំចំណុចចិត្តខ្ញុំតែម្ដង ! មួយថ្ងៃ ។ ខ្ញុំចង់តែលែត្រឡប់

ទៅស្រុកខ្ញុំវិញ ជួបគោរពឪពុកម្តាយខ្ញុំ ព្រោះឃ្លាតពីលោកជាយូរណាស់ ហើយ . . . ។ ខ្ញុំចេញដំណើរដល់ទីក្រុងសុភត , . . ។

នៅទីក្រុងសុភត ខ្ញុំរកសំពៅធ្វើដំណើរទៅកោះបាសក៏ស្រុកកំណើត ខ្ញុំពុំបាន ត្រូវតែខ្ញុំឈប់សំណាក់នៅទីក្រុងនេះ ។

ទីក្រុងសុភត ជាទីជាន់មនោរម្យ មានវត្តកសិការចំឡែក ។ ពាស ពេញនាំមនឲ្យខ្ញុំគប្រក ។ ជារឿយ ។ ខ្ញុំទៅដូតទឹកសាធារណៈថ្វាល្អ ណាស់ ហើយមានអ្នកចំរើប្រសើរត្រកាល ជាធំនាទាក្នុងតំតលោក ខ្ញុំបានដើរកំសាន្តជាញឹកញយនៅជាយក្រុង ទំនឹកនូវកំរៃថាំដ៏ពួនក្រោម ជួនព្រះចន្ទ កន្លែងខ្លះមានម្ចប់ត្រសុំត្រសាយត្រជាក់កាយសប្បាយចិត្ត ។ ជួនកាលខ្ញុំដើរបណ្តែតអារម្មណ៍នៅក្នុងសួនច្បារ មានផ្កាសៀង ស ក្រហមឆ្ងៃន . . . (ល) កុំនឈ្មួយឈ្មប់ ក្រអូបដ៏ឆ្ងៃតក្នុងចិត្តខ្ញុំ . . . មានតែថាំដ៏ធ្ងន់សំអិតសំអាតស្អាតហ្មត់ហ្មង ហើយគេបើកឲ្យមហាជនចូលដើរលេងកំសាន្តបានដោយសេរី ។

មានមួយថ្ងៃនោះ ខ្ញុំកំពុងដើរលេងក្នុងសួនច្បារមួយ ស្រាប់តែខ្ញុំជួបប្រទះមនុស្សម្នាក់ មានចំណាស់បន្តិចហើយ គាត់មកទាក់ទងក្តៅក្រៅស្រ័យនិយាយនឹងខ្ញុំនៅក្រង់ផ្លូវបត់ ។ គាត់ជំរាបសួរខ្ញុំដោយសេចក្តីគួរសម ។ ខ្ញុំក៏គួរសមនឹងគាត់ទៅវិញដូចគ្នា ហើយយើងទាំងពីរសន្ទនាគ្នា

ដោយស្មើខ្ញុំស្មាល ។ សេចក្តីស្មោះត្រង់របស់គាត់ នាំឲ្យខ្ញុំបញ្ចេញ សេចក្តី
ស្មោះស្ម័គ្រប្រសើរជាងខ្ញុំដែរ ។ គាត់ច្រើបខ្ញុំថាគាត់ឈ្មោះ ហ៊ីហ៊ូម ថាគាត់
ជាបរទេស តាលពីដើមគាត់មានសំពៅមួយ ធ្វើដំណើរជួញដូរប្រៃតាមតំបន់
ខ្ញុំក្រុងសុភត ហើយរៀងរាល់ខែ គាត់តែងតែធ្វើដំណើរតាមសមុទ្រ ... ។
ចំណែកខ្ញុំ ខ្ញុំបានច្រើបឈ្មោះខ្ញុំ ថាខ្ញុំគាន់សាសនាម៉ាហ្គូម៉ិត ហើយខ្ញុំ
រៀបចំច្រើបគាត់ ឲ្យដំណើរផ្សងព្រេងរបស់ខ្ញុំ ។ ដល់បានស្គាល់រឿង
អស្ចារ្យ ។ របស់ខ្ញុំ គាត់មានសេចក្តីពោរពេញចិត្តខ្លាំង ចំពោះខ្ញុំក្នុងវេទនា
ដ៏ធំប៉ុន្មានរបស់ខ្ញុំ ។ ខ្ញុំមានសេចក្តីឆ្ងល់ថា ចុះអ្នកនេះម្តេចគិយកចិត្ត
ទុកដាក់ទីធំរឿងខ្ញុំអីម្ល៉ះ ? អ្នកនេះយើញខ្ញុំឆ្ងល់ដូច្នេះ គិសួរខ្ញុំថា ៖ កូន
សំឡាញ់ឥតុកអើយ ! អំបាញ់មិញកូនមានសេចក្តីងឿងឆ្ងល់ ដោយកូន
យើញខ្ញុំខ្លួលខ្លុកអាក់អួលខ្លឹកខ្លួលអណ្តឹតអណ្តក ឈឺចាប់ដូចខ្លួនកូន
ដែរ ។ ធ្វើម្តេចកូនកើយ ! ធម្មជាតិលោកបង្កើតខ្ញុំមកដូច្នេះ ខ្ញុំមិន
គ្រាន់តែជាមនុស្សមានវិស័យចិត្តចេះតែអាណិតមេត្តាតែ តាលណាយើញ
មនុស្សយើងឆង្គាងខ្លុកវេទនាប៉ុណ្ណោះទេ ខ្ញុំមានសេចក្តីមេត្រីភាពអាន
ដល់រូបអ្នកថែមទៀតផង ថ្វីបើខ្ញុំជាអ្នកគាន់សាសនាខុសគ្នាពីអ្នកកូន ។

(នៅមានត)

រឿងបងប្អូនពីរនាក់បែកមត៌កគ្នា

លោកដេង ទ្រីវ ទិញ្ញ

នៅពេលមុនវិស្សកាលតូច ១ ខែ គឺខែមេសា ចំនួនពីរថ្ងៃប៉ុណ្ណោះ គ្រូបង្រៀនភាគច្រើន ទំយមទំយោយរឿងព្រេងឲ្យសិស្សស្តាប់ ដើម្បីជាការកម្សាន្ត ព្រោះដឹងជាពេលត្រូវបែកគ្នាទៅកាន់ស្រុកកំណើតរៀងខ្លួន ។

កាលខ្ញុំនៅសិក្សានាថ្នាក់មជ្ឈមជ្ឈនទី ២ ឯសាលាបឋមសិក្សាបំពេញវិជ្ជា «ហ្វ្រង់ស្វាបូជ្ញាំង» នៅឆ្នាំ ១៩៣០ នាក្រុងភ្នំពេញ សម័យនោះ លោកគ្រូដែលបង្រៀនខ្ញុំ ឈ្មោះលោក មោនសៀរ «ម៉ឺម» ។

នៅពេលមុនវិស្សមកាលតូចមួយថ្ងៃ មោនសៀរ «ម៉ឺម» បានទំយោយរឿងព្រេងចំនួន «បងប្អូនពីរនាក់បែកមរតកគ្នា» ឲ្យយើងស្តាប់ដូចដែលខ្ញុំនៅចាំបានដូចតទៅ :

មានបងប្អូនពីរនាក់ តែពុំឮមានសៀរ ម៉ឺម ប្រាប់ឈ្មោះ ក្រោយដែលមាតាបិតាអនិច្ចកម្មអស់ទៅ បាននាំគ្នាបែកក្តើមតិកដែលនៅសល់អំពីលោក ។ បងជាមនុស្សលោភអាក្រក់ ចំណែកប្អូនជាមនុស្សសុភាព ហើយសុចរិតស្មូតត្រង់ ។

ក្នុងកាលដែលបងប្អូនបែកសម្បត្តិគ្នា សម្បត្តិនោះមិនមានអ្វីច្រើនទេ គឺមានតែគោមួយទំម ទំនៃមួយគូ ។ សម័យបូកណា បងមានសេចក្តីជាន់ប្អូន ។ ពាំងអស់ ។ បងយកគោមួយទំម ទំនៃមួយគូមកជាក់ពីមុខ

ហើយពោលថា អញយកគោយកទៅ ឯងយកឆ្កែយកទៅ ។

ប្អូនសួរថា : បងឯងនិយាយអីចឹង ខ្ញុំស្តាប់មិនបានសោះ ? – បងពោលឡើងថា : អើ ! អញនិយាយថា បើឯងយកឆ្កែយកទៅ អញយកគោយកទៅ ។ ប្អូនតបទៀតថា : អើ ! និយាយអីចឹង ខ្ញុំស្តាប់មិនបាន ?

– ដូចម្តេចកើឯងស្តាប់មិនបាន ! គឺថាអញយកគោយកទៅ ឯងយកឆ្កែយកទៅ ។

ទោះបីប្អូនខ្លួនសុំឲ្យបងបែកក្តីឲ្យត្រឹមត្រូវ ព្រោះមានតែពីរនាក់ទេ តែបងនៅតែប្រកាន់ពាក្យដដែល គឺថា : ឯងយកឆ្កែយកទៅ អញយកគោយកទៅ – អញយកគោយកទៅ ឯងយកឆ្កែយកទៅ ។

ដោយមិនចង់បែកសាមគ្គីភាពនឹងបងប្អូន ជាអាសាន ប្អូនក៏សុខចិត្តយកឆ្កែមួយគូនោះមក ហើយប្រគល់គោមួយនឹមនោះទៅបង ។

សូមបញ្ជាក់ថា បងប្អូនពីរនាក់ សុទ្ធសឹងមានជួរសម្បែងរៀងខ្លួនហើយ ។

ផ្លូវដើមគ្នាំ ដែលមានភ្ញៀងធ្លាក់មក អ្នកស្រុកនិយមធ្វើស្រែចំការ បុរសប្អូនជញ្ជាំងគិតថា តើខ្លួនឯងបានគោឯណាទៅភ្ជួរដើម្បីជាំដំណាំ ? ព្រោះគ្មានគោសោះ ទៅខ្ចីបង ។ មិនត្រូវឲ្យ ដោយសារអាងថាគាត់ត្រូវការភ្ជួរដែរ ។ ណាខ្លួនក្រតេក ណាគ្មានគោ ហើយមានតែឆ្កែមួយគូដែលជាតេរ៍តេតីអាពុកម្តាយ ទើបបុរសប្អូនសម្រេចចិត្តថាត្រូវតែយកឆ្កែ

មួយគូនេះទៅឲ្យជួយពាញខ្លឹលក្តារដ៏ ។ តែដោយយល់ថាខ្លែមានកម្លាំងខ្សោយ មិនអាចពាញខ្លឹលដែលក្តារដោយគាបាន បុរសប្អូនក៏បានខ្លឹលថ្មមួយ ឲ្យសមល្មមនឹងកម្លាំងខ្លែដែលអាចពាញបាន ។

មុននឹងក្តារដ៏ បុរសប្អូនប្រាប់ប្រពន្ធឲ្យដាំបាយ ហើយគាត់យកបាយមកតូតជាតំខូតតូច ។ ខុកសម្រាប់ឲ្យខ្លែស៊ី កាលណាបើខ្លែអស់កម្លាំង ឬក៏យើញខ្លែពាញខ្លឹលដោយលំបាក ។ ចំណែកខ្លួនគាត់ឥតមានខ្លួលពានអ្វីឡើយ ព្រោះក្រពេក អង្ករមានតែប៉ុណ្ណេះ បំរុងខុកឲ្យតែខ្លែគាត់ផឹកទឹកបបរនាយអាយ ។

កន្លងគេលក់តុងក្តារ គាត់តែងបោះបាយមួយតំខូត ។ ដល់ខ្លែគាត់ដើម្បីញ៉ាំងទឹកចិត្តវាឲ្យខំពាញតទៅទៀត ។

ទុកាសនោះ មានតាចាស់ម្នាក់ស្លៀកសពាក់ស ដើរមកជិតគាត់ដែលកំពុងក្តារដ៏ហើយសួរថា : ចៅឯងក្តារស្រែហ្នឹងហើយឬទេ បើក្តារហើយ តាឲ្យវែកចៅឯងមួយ ? ។

បុរសកំសត់ឆ្លើយដាក់តានោះវិញថា : រឿងក្តារហើយឬ មិនហើយនោះ មិនមែនស្រែចលើខ្ញុំឯទេ គឺស្រែចលើខ្លែខ្ញុំឯទេ បើវាមានកំលាំងអាចពាញខ្លឹលក្តារបានត្រឹមណា ស្រែចតែលើវា ខ្ញុំឯមិនអាចហ៊ានសម្រេចបានទេ លោកតា ។

ដោយយល់ថាបុរសកំសត់មានក្តីសុចរិតនឹងយុត្តិធម៌ ហើយជាមនុស្ស

ចិញ្ចឹមដំរែតដោយចិត្តសន្ទោស លោកតានោះក៏ឲ្យវែកមួយដល់បុរសកំសត់ ហើយពោលប្រាប់ថា : នែ៎ចៅ ! វែកនេះ មានគុណានអាការគាចញ៉ាំងសេចក្តីប្រាថ្នាសព្វយ៉ាំងឲ្យសម្រេចបាន តើថាបើចៅចង់បានអ្វីយកតែវែកហ្នឹងទៅកូរ ហើយតាំងប្រាថ្នាទៅ អ្វីៗដែលចៅត្រូវការចង់បាន ទំនងកើតមានឡើងមួយរំពេចគាន់ចិត្ត ។

និយាយប្រាប់តែប៉ុណ្ណេះហើយ តាចាស់នោះក៏លាចេញ រួចបាត់ខ្លួនមួយរំពេចទៅ ។

និគានពីបុរសកំសត់យើង កាលបើពេលដល់ហើយ គាត់នាំឆ្កែត្រឡប់មកផ្ទះវិញ យកតាំងវែកដែលតាចាស់ឲ្យមកផង តែគាត់មិនមានសង្ឃឹមថាវែកនោះ ទំនងមានឥទ្ធិពលដូចតាចាស់បរិយាយប្រាប់នោះឡើយ ព្រោះយើញជាវែកធម្មតាសោះ ។

អស់កំឡាំងពេក ព្រោះតាំងពីព្រលឹមដល់ថ្ងៃនេះ គ្មានបាយមួយគ្រាប់ចូលពោះសោះ គាត់ប្រុងខ្លួនសម្រាក់នៅលើគ្រែតញ្ចាស់មុខផ្ទះ ហើយហៅភរិយាឲ្យមកជិតប្រាប់ថា : ចូរអូនទៅបង្កាត់ភ្លើងកូនដើម្បីនិងហើយយកថ្នាំងបាយយើងងាក់ទឹកជាំទៅ ។

ប្រពន្ធប្រាប់ប្តីថា : យើងគ្មានអង្ករទេបង នៅសល់បន្តិចបន្តួចប្រមូលជាំឲ្យឆ្កែអស់លើងហើយ បងឲ្យខ្ញុំងាក់ទឹកប្រយោជន៍អ្វី ?

ប្តីឆ្លើយតបថា : អើ! ការណ៍ហ្នឹងបងក៏ដឹងដែរ តែបងហៅវែក

ព្រោះគ្មានអ្វីនៅក្នុងពោះសោះ ខ្ញុំបង្ក្រែងក៏ទៅជាខ្សល់ ចាន់ជាឲ្យអ្នកយក
ឆ្នាំងចាយជាក់ទឹកដាំ ដើម្បីយកទឹកផឹក ព្រោះមានជាតិព្រះមេទៅមោះ
ខ្លះ ទាំងមានកំឡាំងផងដែរ ។ ប្តីបន្តទៅទៀតថា : ហ៎ា! អូនឯងយកវែក
នេះទៅ ! វែកនេះមានតាចាស់ម្នាក់ចានឲ្យមកបង ក្នុងពេលដែលបងកំពុង
ក្លែវស្រែ បើទឹកពុះហើយ យកវែកនេះដួសបងទឹកជាក់ចានមកឲ្យបង ។
ប្រពន្ធប្រតិបត្តិតាមបង្គាប់ប្តីទាំងអស់ ។ លុះទឹកពុះហើយ ប្រពន្ធ
យកវែកលូកទៅក្នុងទឹកឆ្នាំង ចំរុងដងទឹកជាក់ចាន យកមកជូនប្តី ស្រាប់
តែសេចក្តីអស្ចារ្យកើតឡើង បណ្តាលឲ្យនាងកវិយាមានចិត្តរឿងឆ្ងល់
ក្រៃពេក ស្មានថាជាខ្លួនយល់សប្តិ ព្រមទាំងត្រេកអរឥតឧបមា ។ ឆ្នាំង
ទឹកសោះ ក្លាយទៅជាមានបាយឆ្អិនស្រាប់ ពេញទាំងឆ្នាំង ។

ចំពោះរឿងនេះ ស្វាមីកវិយាកំសត់ មានសេចក្តីសប្បាយរីករាយ
ពេក ដោយនឹកគុណដល់ទេព្តាដែលលោកអាណិតអាសូរដល់ខ្លួនជាអ្នក
កំសត់ ហើយបានប្រទានដំណឹងដ៏អស្ចារ្យនេះ ។

ចាប់តាំងពីពេលនេះទៅ បុរសប្អូនមិនមានខ្វះគ្រឿងបរិភោគនឹងឧប-
ភោគឡើយ : ដង្រែកមានស្រូវពេញ សំពត់អាវសំរាប់ស្លៀកមានគ្រប់គ្រាន់
សម្រាប់ប្រើប្រាស គេហដ្ឋានក៏ល្អសមនឹងឋានៈនៃខ្លួន មាសប្រាក់មិនខ្វះ
ចាយគ្រឿងអលង្ការសម្រាប់តាក់តែងលំអកាយក៏មាន រួមសេចក្តីទៅ គឺ
មានសព្វ ។ ចំណែកឯឆ្កែមួយគូនោះវិញ គាត់ចិញ្ចឹមថែរក្សាថ្នាក់ថ្នម ដោយ

ឲ្យគាហារបរិបូណ៌ត្រមាំឆ័តនៃខ្លួនដែរនៅ ។

រឿងបុរសប្អូនជាន់ទៅជាអ្នកមានគោគក្បាលនេះ កំលេចឮទៅដល់បុរសបង (តាមស្មានប្រហែលអ្នកចាំងពីរនៅតូមិត្យយពីគ្នា?) ។ កាលបើបានដឹងរឿងនេះក្តាម សេចក្តីច្រណែនទឹងសេចក្តីលោភបានតើនឡើងដល់សន្ធានរបស់បងទឹងបងថ្លៃស្រី ។ ប្រពន្ធបងណែនាំប្តីឲ្យទៅសួរគោណែនេះទឹងប្អូន តើវាទៅជាមានសម្បត្តិដោយសារអ្វី បើក្តើរអាកវែមុខគ្នាខ្លាន សោះ យើងប្រគល់ឲ្យដល់វាតែឆ្កែមួយគូ?

ពេលដែលបងទៅដល់ បុរសប្អូនត្រមាំឆ័តរាយ ធ្វើបដិសណ្ឋារះត្រកអរសោរចំពោះបង អញ្ជើញបងឡើងលើផ្ទះ រៀបគោជនាហារមានរសជាតិសាជួនបងបរិភោគយ៉ាងឆ្អែតស្កប់ស្កល់ ។

បដិសណ្ឋារកិច្ចដ៏ប្រពៃនេះ មិនមែនធ្វើឲ្យបុរសបងសប្បាយចិត្តឡើយ ផ្ទុយទៅវិញ បងវិងវែតែមានសេចក្តីច្រណែនលើសមុនទៅទៀតៗ នេះជាធម្មតានៃសន្ធានចិត្តអសប្បុរស ។

ដោយបងមានបានដូចប្អូន បុរសបងក៏សួរប្អូនថា : ឯងធ្វើដូចម្តេចក៏បានជាមានសម្បត្តិសុខសប្បាយម្ល៉ះ?

បុរសប្អូនជាមនុស្សអសប្បុរស គ្មានចិត្តវៃវែរ ក៏និយាយរឿងត្រង់ប្រាប់បងថា : កាលដែលបងយកគោតែម្នាក់ឯងអស់ ហើយខ្ចុកតែឆ្កែឲ្យខ្ញុំ ពេលក្លូដើរដេញដើមឆ្នាំ ដោយគោគាត់ពុំបាន ខ្ញុំប្រជុំយកឆ្កែទៅ

ខ្ញុំមដំនួសគោ ។ កន្លងពេលតំពុងក្លែក្លរ ឃើញគាថាស់ម្ខាក់មក ហើយគាត់ឲ្យវែកដល់ខ្ញុំមួយ ។ ដោយសារតែវែកនេះហើយ បានជាខ្ញុំក្លាយទៅជាអ្នកមានសម្បត្តិទ្រព្យយ៉ាងនេះ ។

លុះបានឮប្អូនគោលក្រាបដូច្នោះ ដោយបងបានវែកពីមុនដែរ បងក៏និយាយសុំខ្លែងប្អូន ដើម្បីយកទៅខ្ញុំមក្លរដើម្ពីង ។ ប្អូនដកបបងថា : មានពាស់អី បងឯងចង់យកទៅខ្ញុំមក៏យកទៅចុះ តែខ្ញុំសូមផ្តាំបន្តិច ព្រោះខ្លែងខ្ញុំ ។ ថ្មមណាស់ បើបងយកទៅ សូមបងមេត្តាកុំយកវាឲ្យសោះហើយខ្ញុំមទៀត សូមកុំបង្ខំវា ព្រោះគាជាសត្វតូច កំឡាំងខ្សោយ មិនអាចពាញង្គិលដូចជាគោក្របីនោះបានឡើយ ។ ម្យ៉ាងទៀតសូមបងឲ្យវាស៊ីស្លែងបរិបូណ៌ផង ។

បងខ្លួលតាមពាក្យបណ្តាំប្អូនពាំងអស់ ហើយនាំខ្លែងទៅ ។

បុរសបងចាប់ក្លរដើ ដោយយកខ្លែងខ្ញុំមដំនួសគោ ធ្វើដូចគាលដែលប្អូនក្លរដូច្នោះ ។ កំពុងតែក្លរ លេចគាថាស់ម្ខាក់ ស្ទៀកសពាក់សមកមែន គាថាស់សួរទៅបុរសបងថា : អ្នកឯងក្លរដើហ្នឹងហើយឬទេ បើក្លរហើយតាឲ្យវែកមាសដល់អ្នកឯងមួយ ? ! មិនតែប៉ុណ្ណោះ គាថាស់ថែមទាំងយកវែកបញ្ជាញឲ្យបុរសយើងឃើញទៀតផង គឺជាវែកមាសលឿងផ្លៅភ្លឺយ៉ាងល្អអស្ចារ្យ ។

រឿងសាមកុក

ពុកញ៉ាវិបុលពាជសេនា ឆ្នៃ-ភាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកពុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃដឹងសព្វបើបានអាន
ទឹងចេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

——— ឃ្លេ-អ៊ុន ———

ខ្មៅតាថា លោកតាំងើយញាននាណាដែលនឹងប្រើឲ្យកាន់សំបុត្រទៅ
និយាយការនឹងស៊ុនតួនខោះ ។ អ៊ីចៀឆ្លើយទទួលខ្លួនថា ខ្ញុំបាទសុំ
យកអាសាកាន់សំបុត្រទៅនិយាយការនោះឲ្យបាន ។ ខ្មៅតាក៏ឲ្យកាន់
សំបុត្រ រួចប្រគល់ឲ្យអ៊ីចៀហើយថែមផ្តាំពាក្យក្រៅថា បើអ្នកឯងទៅ
ដល់ ត្រូវនិយាយប្រាប់តួនអ៊ូឲ្យឈប់សេចក្តីជាមុន អ៊ីចៀទទួលសំបុត្រ
ហើយក៏លាខ្មៅតាស្រួតតម្រង់ទៅស្រុកកេងជីវ ដល់ហើយក៏ពណិនា
សេចក្តីប្រាប់តួនអ៊ូតាមដែលបានទទួ លើកទីពីរទៅវាយយកស្រុកហាន់តុង
ឥឡូវខ្មៅតាប្រើខ្ញុំឲ្យកាន់សំបុត្រទៅឲ្យស៊ុនកួន និយាយហើយក៏លាតួន
អ៊ូទៅស្រុកកាំងតាំង កាលទួលទៅដល់ក៏ប្រាប់អ្នកចាំទ្វារថា ខ្ញុំជាម៉ៅ
ខ្មៅតានាំសំបុត្រមកជូនស៊ុនតួន អ្នកចាំទ្វារក៏ចូលទៅជំរាបស៊ុនតួន ។

ស៊ុនតួនដឹងដូច្នោះ ក៏ឲ្យហៅខ្លួនអ៊ីចៀចូលទៅហើយសួរថា ឡៅតី ប្រើមកដោយហេតុអ្វី ? ។ អ៊ីចៀក៏ជូនសំបុត្រនោះទៅឲ្យស៊ុនតួនហើយដំណាលថា កាលជូកាត់កំនទៅនិយាយការពីស្រុកកេងដីវនោះ ឡៅតីក៏ខ្លួលថានឹងបង្វិលស្រុក ៣ ដំបន់ជូនលោក តែពាក្យនោះក៏ខុសទៅហើយ ឥឡូវឡៅតីព្រមបង្វិលស្រុកគាំងវែ ស្រុកខៀងសា ស្រុកហ៊ុយអៀង ជូនលោកសិន ចានជាផ្ញើសំបុត្រនេះមកជូនលោកជាសំគាល់ ឯស្រុកកេងដីវ ស្រុកឡេងឡេង ស្រុកឡាំងគុននោះ គង់នឹងបង្វិលជូនលោកវែរ តែនៅជាប់កិច្ចបន្តិច ព្រោះបូឆួលើកកងទ័ពទៅវាយស្រុកហាន់តុង គួនអ៊ូនៅមិនទាន់មានទ័ពស្រុយ ចានជាខ្លីឲ្យគួនអ៊ូនៅសិន ឯស្រុកហាប់ប៉ាវែលបូឆួចាត់មនុស្សឲ្យទៅឈរឆ្កាំនោះ ពាហានក៏ស្លុចស្តើង សូមឲ្យលោកលើកកងទ័ពទៅវាយយកចុះ បើលោកលើកកងទ័ពទៅវាយយកវេលាណា ក៏គង់តែបូឆួនឹងលើកកងទ័ពមកជួយ ឡៅតីចានជម្រួយនឹងលើកកងទ័ពទៅវាយយកស្រុកហាន់តុងខាងនោះ បើឡៅតីចានស្រុកហាន់តុងចំពោះហើយ ក៏នឹងឲ្យគួនអ៊ូទៅនៅស្រុកហាន់តុង ឯស្រុកកេងដីវ ស្រុកឡេងឡេងនឹង ស្រុកឡាំងកុន ទាំង ៣ នោះ ក៏នឹងចានមកជារបស់លោកវិញ ។

ស៊ុនតួនឮដូច្នោះ ក៏ហែករស្រាម ហួតសំបុត្រមកមើល ឃើញសេចក្តីត្រូវគ្នានឹងពាក្យអ៊ីចៀនិយាយ ហើយក៏ឲ្យអ៊ីចៀទៅឈប់ស្នាក់ឯផ្ទះខ្លួល

ក្បៀវជាបណ្តោះអាសន្ន ស៊ុនគួនក៏យកសំបុត្រនោះទៅប្រដុំប្រឹក្សាទីឆីនា-
ម៉ុនចាំងពួន ។ ទៀវចៀវថា ដែលឡៅតាំងឲ្យសំបុត្រមកនេះ ជាកល។ ចាយ
គ្រោះខ្លាចខ្ជូនទីឆីលើកទ័ពមកវាយយកស្រុកសែឈួន តែថាបើគេះជា
កល។ ចាយយ៉ាំងណាក្តី កិតឆីជាគប្បីបានប្រយោជន៍ដល់យើងពីរប្រការ។
ប្រការ ១ យើងត្រូវបានស្រុក ៣ ដំបន់ ប្រការ ២ យើងបានស្រុកហាប់
ប៉ាផង គេះបើថា ឡៅតាំងមានចិត្តកំរើបល្ងង់បញ្ជោតយើងបានក៏តាម
ការចុះ ត្រូវតែតិតធ្វើតាមសំបុត្រឲ្យបាន ។

ស៊ុនគួនយល់ឃើញត្រូវ ក៏ឲ្យហៅខ្ជួនអ៊ុចៀចូលមក ហើយនិយាយ
ថា អ្នកឯងត្រូវស្រែតប្រញាប់រំលៅទៅប្រាប់ឡៅតាំងចុះ ថាយើងព្រមលើកទ័ព
ទៅវាយស្រុកហាប់ប៉ាហើយ អ៊ុចៀខ្លួលប្រសាសន៍ហើយក៏លាចេញទៅ
ខណៈនោះឆៀវ អ៊ុយតាយ ហាន់តុង ចេញទៅត្រួតតយល្បាតពុំ
ទាន់ត្រឡប់រំលៃមកវិញ ។ ស៊ុនគួនក៏ប្រើឡាសុកទៅខ្លួលយកស្រុក
ចាំង ៣ ដំបន់ ហើយទីឆីត្រាសម្រាប់ទីចៅហ្វាយស្រុកនោះ ឯស៊ុនគួន
ក៏នាំទាហានទៅតាំងទៅមាត់តាមកំពង់ឡុកទៅ ហើយរកកាំឡែង លីបង
ឡែងបង់ទៅប្រដុំគ្នា ។ ខណៈនោះ កាំឡែងទីឆីលីបង់ទៅដល់មុន ។

ស៊ុនគួនក៏ប្រឹក្សាថា តឡូវបើខ្លួលើកទ័ពទៅវាយស្រុកហាន់តុង ឯ
យើងទីឆីតលើកទ័ពទៅវាយស្រុកហាប់ប៉ា បើអ្នកកាល់គ្នាទីឆីយល់ឃើញ
ដូចម្តេច ? ។ លីបង់ឆ្លើយថា បើខ្លួលប្រើជ្ជកុងឲ្យទៅឈប់ស្រុកលោកាំង

ដូចគ្នានៅតាំងខ័ណ្ឌនៅស្រុកអូនសៀ តម្លៃវាជាទេសភាល ស្រូវគោជសាលីខុំ ដូចគ្នាឲ្យប្រូតស្រូវគោជសាលីសន្សំទុកក្នុងស្រុកហាប់ចាំ សូមឲ្យលោកលើកខ័ណ្ឌទៅវាយយកស្រុកអូនសៀឲ្យបានមុនសិន រួចសឹមលើកទំលងទៅវាយយកស្រុកហាប់ចាំជាក្រោយ ទើបបានដោយងាយ ។

ស៊ុនគួនយល់ឃើញត្រូវ ក៏តាំងបាត់ពែនភាហានបាន ១០ ម៉ឺន ឲ្យកាំភ្លើង លីបងជានាយកងខ័ណ្ឌមុខ ជីវឃើមទើងកូដៀងជានាយកងខ័ណ្ឌក្រោយ ជីវថាយ តាន់ប៊ូ តាំងស៊ុត ស៊ុសេង ៤ នាយ ទុកក្នុងកងខ័ណ្ឌហ្លួងជាមួយស៊ុនគួន ។ លុះបាត់ខ័ណ្ឌរួចហើយ ស៊ុនគួន ក៏លើកទ្លងត្រើយទៅឡើងតាមផ្លូវតម្រង់ទៅស្រុកហៃជីវ ហើយលើកជាក្បួនខ័ណ្ឌតោកទៅ លុះទៅដល់ស្រុកអូនសៀហើយ ក៏ឲ្យបោះខ័ណ្ឌឈប់តាំងបន្ទាយនៅទីនោះ ។

ឯដូចគ្នាដឹងថា ស៊ុនគួនលើកកងខ័ណ្ឌមកដូច្នោះ ក៏ឲ្យប្រមូលភាហានឡើងរក្សាសើនបន្ទាយយ៉ាងមាំមួន ហើយបាត់បំរើនាំសំបុត្រទៅដល់ខៀវសៀវដែលនៅស្រុកហាប់ចាំ ស៊ុនគួននាំភាហានទៅត្រួតមើលកំដែនស្រុកអូនសៀ បើឃើញទ័ព្រងំណាស្តើង បន្ទោះស្រួលនឹងប្រមូលភាហានឲ្យចំតានចំលាយវាយយកស្រុកនោះតែម្តង នោះពួកភាហានដែលរក្សាសើនបន្ទាយ ឃើញស៊ុនគួននាំភាហានដើរត្រួតមើលដូច្នោះក៏នាំគ្នាចាញ់ចម្រុះសំដៅទៅជាច្រើន ។

ស៊ុនគួនមានបារម្ភ កំនាំពាហានចូលបន្ទាយវិញ ហើយប្រឹក្សានឹងពាហានថាំងពួងថា យើងនឹងគិតបង្ក៏ងយ៉ាងម្តេចទើបនឹងបានស្រុកអ៊ូនសៀនោះ ? ។ តាំងស៊ុតធ្វើយថា ឲ្យប្រមូលពាហានដីកយកដាមកគរធ្វើជាកំឡែងខ្ពស់ស្មើនឹងកំផែងស្រុកជុំវិញ ហើយឲ្យពាហានបាញ់ធ្វើឲ្យភ្លាក់ចូលទៅជួបគ្រាប់ភ្លើង ពាហានដែលនៅលើសើនខាងក្នុង គង់នឹងដោះខ្លួនចេញអស់ រួចយើងត្រូវយកបង្ហោងនឹងជើងជណ្តើរតាក់ឡើងជុំវិញឲ្យព្រមគ្នា គង់នឹងតាវ៉ែលាយយកស្រុកនោះដោយងាយបាន ។ លីបង់ឱយាយនឹងតាំងស៊ុតថា ដែលនឹងធ្វើការតាមគំនិតអ្នកថានោះ យូរណាស់មុខជាកងទ័ពស្រុកហាប់ចាំមកជួយពាន់ វេលានោះពាហានរបស់យើងកំពង់ថ្មើងកំឡាំង ត្រូវតែលើកចំពាវ៉ែលាយពាយឲ្យបែកក្តងពេលមួយតែម្តងទៅ ទើបនឹងបានស្រុកអ៊ូនសៀនោះ រួចនឹងបានលើកកំលែងទៅវាយយកស្រុកហាប់ចាំទៀត ។

ស៊ុនគួនយល់ឃើញត្រូវ លុះដល់ពេលយាម ៣ យប់ កំបង្គាប់ឲ្យពាហានដាំបាយស៊ុជាស្រេច រួចលើកទ្ធង់គួស្រុតសម្រុកចូលទៅវាយទ័ពាវ៉ែលាយតាមកំផែង សំឡេងមនុស្សនឹងគង់ឮកងរំពងសន្ធឹកគគ្រឹកគគ្រេងហាក់ដីដូចនឹងផ្អៀងក្រឡាប់ផែនដី ឯពាហានដែលនៅលើសើនបន្ទាយខាងក្នុង កំប្រុងតែបាញ់ធូចម្រុះចុះមក ព្រួញភ្លាក់ហាក់ដីដូចគ្រាប់ភ្លើង គាំងឡើងនឹងលីបង់ ដែលជានាយពាហានកងមុខឃើញដូច្នោះ

កំបង្គំតាហានឲ្យយកដើងដណ្តើរទំងំបង្អើងពាក់លើកំផែង ប្រវារឡើងទៅ
តផៃគ្នាលើសើន ចាំងខ្លួនកាំឡេងក៏ឡើងតាមបង្អើងទៅដល់ពាក់កណ្តាល
កំផែង ហើយយកប្រវាក់ចោលចំពាក់ទៅលើកំផែងប្រគោងឡើងទៅ
ច្បាំងចាក់កាច់សម្លាប់គ្នានៅលើសន្ទឹកសីមាខ្នងកំផែងនោះ ។

ឯជួកុងក៏ឲ្យតាហានយកដុំថ្មទំងំគ្រួសច្បាច់ចុះសាចចុះទៅមិនឈប់
កាំឡេងក៏ក្រវែងប្រវាក់ទៅត្រូវជួកុងជួលចុះ ពួកតាហានដែលនៅលើ
សើននោះ ក៏ស្ទុះទៅគ្រាប់លើកឡើង កាំឡេងទំងំតាហានពីក្រោមក៏ប្រ
វារឡើងទៅបាន ហើយក៏យកគ្រួចំទំងំដាវលំតែងព្រួតចាក់កាប់ស្លាប់ជួកុង
នៅទីនោះ ពួកតាហានជួកុងចាំងប៉ុន្មាន កំនាំគ្នាចំណុះចុះចូលកាំឡេង
ចាំងអស់ ។

ឯខ្មៀវលៀវ កាលខ្លួលសំបុត្រជួកុងដឹងដំណឹងហើយ ក៏រៀបចាត់
ចែងតាហានលើកទៅជួយស្រុកអ៊ួនសៀ លុះទៅដល់កណ្តាលផ្លូវដឹងដំ
ណឹងថា ស៊ុនគួនវាយយកស្រុកអ៊ួនសៀហើយ ខ្មៀវលៀវក៏លើកទ័ព
ត្រឡប់ទៅស្រុកហាច់ប៉ាវិញ ។

ខណៈនោះឡេងថង ក៏លើកតាហានស្រុតតាមស៊ុនគួនទៅ លុះ
ទៅដល់ ខ្លួលស៊ុនគួនវាយបានស្រុកអ៊ួនសៀហើយ ស៊ុនគួនក៏នាំឡេង
ថងនឹងតាហានចាំងអស់ចូលទៅស្រុកអ៊ួនសៀ ហើយឲ្យចែកចំណាប់
រង្វាន់ដល់តាហានតាមលំដាប់ រួចឲ្យរៀបគុលៀងអាហារពួកតាហាននឹង

នាម៉ឺនពាំងពួង ស៊ុនគួនថា យើងមកពីយកបានស្រុកអ្ជូនសៀគ្រានេះ កាំ
ខ្សែងមានសេចក្តីតាប់ប្រសើរច្រើនជាងគេ ព្រោះចូលពីយទំលាយស្រុក
បានមុន ត្រូវឲ្យកាំខ្សែងអង្គុយស៊ុលៀងត្រង់ទីកន្លែងមន្ត្រីជាន់ខ្ពស់ ។
ខណៈនោះ ទីប្រឹក្សាទីឆាហានពាំងពួងក៏អង្គុយស៊ុលៀងត្រមគ្នា
ខ្សែងថងយើញកាំខ្សែងអង្គុយកន្លែងជាន់ខ្ពស់ ជាងនាយឆាហានពាំងពួង
ក៏តែតែមានសេចក្តីគាន់គ្នាញ៉ាំណាស់ ព្រោះកាំខ្សែងសម្លាប់បីតារបស់ខ្លួន
សូន្យដីតែម៉ៅ ចេះតែសំឡឹងចុងក្រែកមើលកាំខ្សែង ហើយនិយាយទីង
នាយឆាហានពាំងពួងថា យើងទីងខ្សែងកំត្រូវឲ្យអ្នកពាល់គ្នាមើល ហើយ
ខ្សែងថងក៏ខ្សែងកំពុលទីប្រជុំនោះ ។

កាំខ្សែងយើញដូច្នោះក៏គិតថា ខ្សែងថងនេះកំមានចិត្តអាឃាត
ញ៉ាចាខមិនជាច់សោះ ដៃលកំត្រូវនោះ បំណងទីងប្រទូស្តកាយយើងជា
ប្រាកដ យើងក៏ត្រូវតែកំដើម្បីទីងការពារខ្លួនវិញ គិតហើយក៏ថា ខ្សែង
ថងកំតែម្នាក់ឯងនោះ មិនសូវល្អមើលទេ យើងចេះកំពាន់លំតែងតែ ២
ស្មាត់ជាងអ្នកឯង យើងទីងកំឲ្យអ្នកពាល់គ្នាមើល ថាហើយក៏ក្រោក
ខ្សែងកំ ។ លីបងយើញកាំខ្សែងទីងខ្សែងថងកំលំតែងទីងត្រូវគ្នាដូច្នោះ
គិតថា នាយឆាហានពាំង ២ នាក់នោះ មានចិត្តគិតតែញ៉ាចាខគ្នាមិន
ជាច់សោះ ចាំយើងទីងការពារកុំឲ្យមានសេចក្តីអន្តរាយដល់គ្នាទីងគ្នា គិត
ហើយក៏និយាយប្រកាសប្រាប់នាម៉ឺនពាំងអស់ថា ខ្លួនយើងចំណានស្មាត់

ខាងកំរៃល យើងនឹងកំឡៃអ្នកកាល់គ្នាមើល ថាហើយក៏ក្រោកឡើងកំ
កណ្តាលចន្ទោះកាំឡេងនឹងឡេងថង ច្រាច្បាមិនឲ្យអ្នកចាំងពីរប្រកួសកំយ
គ្នា ។ គាហានម្នាក់យើញដូច្នោះ ក៏នាំសេចក្តីនោះទៅប្តឹងស៊ុនគួន ។
ឮក្លាមក៏ភ័យស្លុត រត់ទៅកាន់ទីប្រជុំមន្ត្រីចាំងនោះ ក្រឡេកទៅយើញ
កាំឡេងនឹងឡេងថងកំពុងកំអាវុធគ្នាចាំងសងខាង យើញលើចងកំ
ជាកណ្តាល ។ កាំឡេងនឹងឡេងថងយើញស៊ុនគួនមកដល់ក៏ភ័យណាស់
ចោះអាវុធចេញពីដៃចាំង ២ នាក់ ហើយលុតជង្គង់ចុះ តំនាប់ស៊ុនគួន ។
ក៏និយាយច្រាច់ឡេងថងថា ហេតុដែលអ្នកឯងជាប់ចិត្តគិតព្យាបាទ
កាំឡេងនោះយើងក៏បានសុំឲ្យលើកចោលពីគ្រាមុនទៅហើយ ហេតុម្តេច
ក៏មកនាំបណ្តាលឲ្យកើតឡើងក្នុងគ្រានេះទៀត ។ ឡេងថងមិនឆ្លើយ
តបថាអ្វីសោះ ចេះតែអង្គុយយំ ។

(នៅមានត)

ព្រះរាជនិពន្ធរាមកេរ្តិ៍

តាមការស្រាវជ្រាវរបស់ ឧ.តាម

(រក្សាសិទ្ធិមិនឲ្យចម្លង មិនឲ្យតួរបបឡើយ)

វាគ្គ ២

និយាយតាំងតែពីព្រះជាទមាលវែងដមកស្តេចព្រះបាទជនុរភត្រ លុះទៅដល់ ត្រីបួរាម តាំងពិធី ព្រះទេពទ័យតាំងចិព្រះអង្គប្រាថនសរសើស្បែរហួតទៅទៀមកទូលព្រះតិស្សរ ព្រះតិស្សរ លើកទ័ពទៅសម្លាប់ត្រីបួរាម ។ រហួតទៅដល់ព្រះតិស្សរយោះធ្លុដ័យមក ទុកឯនគរមិថិលាបុរី នឹងអារក្រោះតេជ្រកែវឡែតសីអាតគៈយការក្សាទុកថ្វាយព្រះរាម រហួតដល់មហេសីព្រះបាទឡាស្សរទៀតទាំង ៥ អង្គ តែ ៤ ព្រះអង្គនោះមានកូន លុះទៅដល់នគរកុះសុំពរពីព្រះតិស្សរ ព្រះនារាយណ៍សម្លាប់នគរកុះហើយ នគរកុះទៅកើតជាទសកណ្ឋ ទសកណ្ឋប្បាំនឹងព្រះបាទអរិដ្ឋនការទសកណ្ឋបាញ់។ មហាតិសីពោះបុត្រមកសុំយកទសកណ្ឋ។ រហួតទៅដល់ព្រះតិស្សរឲ្យទេវ័នទៅកើតជាពិភេក្ស លុះទៅដល់ព្រះបាទគោត្តមទៅបួសជាតិសី ។ ជិច់នាងមួយធ្វើជាប្រពន្ធ សឹកមកបានកូនមួយឈ្មោះនាងស្វាហាយ ហើយព្រះតិន្ទុចុះមកបង្កើតបុត្រមួយទុកដួយដល់ព្រះនារាយណ៍ ដែលចុះមកបង្ក្រាបអសុរពោល រហួតដល់ព្រះអាទិត្យចុះមកកាន់នាងកាលអច្ចនា ។

លុះស្តេចមកដល់លង្កាទ្វីបហើយ ព្រះបាទឡាស្សរទៀន ឃើញព្រះបាទមាលវែងជាព្រះបិតុលាមកហើយ កំរ្ងន់ត្រេកអរសោទរទទួលហើយក្រាបថ្វាយបង្គំដកដង្ហើមធំ ព្រះបាទមាលវែងដើមមានទន្លង់សួរថាសម្តេចព្រះបិតាបាងឯងតើទៅឯណា ព្រះបាទឡាស្សរទៀនបានស្តាប់ពាក្យលើកករអញ្ជលីទូលតបទន្លង់រៀបថា រីសម្តេចព្រះបិតុរង្គំទ្រង់ឫទ្ធិនោះព្រះអង្គក៏សោយព្រះវិលាល័យក្សីយព្រះជន្មាជាយូរហើយ ខ្ញុំលហើយកំទបព្រះបាទាព្រះបិតុលាទ្រង់ព្រះកន្សែងសោយសោក រ័ព្រះបាទមាលវែងបានស្តាប់ដីងហើយក៏ទ្រង់សង្វេគកង់ព្រះទ័យ ថាទសត្វអើយកើតមកកង់ក្នុ

លោកា មិនមានអ្នកណាខ្លាំងចៀសរួច ព្រោះកាលនោះកំគ្មាន ទាំងឯ
កតត្រប់ដល់ស្ថានសួគ៌តណ្ហាតែខ្លាំងក្លាយដូចគ្នា ឯខ្លួនបងនេះកំគង់តែខ្លាំងមរ
ណដូចអនុជាហោង ។ ឥឡូវនេះ មានតែចៅឯងបានសោយរាជ្យស្នងត្រង់រាជសម្បត្តិជាស្ថាន សូមឲ្យអ្នកបានក្តីសុខស្គាតរបំរុងនគរបូរីឲ្យរុងរឿងថ្កើងកើយសសត្តុរក្សាអាណាប្រជាជនឲ្យសុខក្សេមក្សាន្ត ត្រកូលរៀងទៅហោង ។ ដ៏តានីឯលាអ្នកទៅវិញហើយ ស្រេចហើយ ព្រះអង្គកំលើតរេហ៍ពលសកលយោធាវិលស្ថានអាត្មាវិញហោង ។ ឈប់ស្ទះ ។

ឥឡូវនេះ ខ្លាំងសំដែងពីត្រីបូរាម(១)យក្សសោយរាជ្យនៅសោឡសបុរីរាជធានីមានឫទ្ធីអានុភាពខ្លាំងពូកែណាស់ ទាំងទេវតាសព្វតែឈ្នះកំទ្រង់ខ្លាចអំណាចចេស្តាគ្មានអ្នកណាហ៊ានតវែងអស់ពីកំពើងតែត ក្នុងចិត្តថា ខ្លួនអញនេះ មានឫទ្ធីអានុភាពលើសលើមនុស្សទេវតាមហាឥសីគ្រប់ទាងគន្ធទន្ត្រប់ស្ថានមែន តែអង្គព្រះនាងយណ៌ដែលបួនខេះ មានឫទ្ធីខ្លាំងជាងអញ តែលោកមកបំផ្លាញអញ ។ យើញថាទំងក្រយ បើដូច្នោះគួរអញនឹងទៅសូមពរពើរសូរឲ្យមានឫទ្ធីឈ្នះលើព្រះនាងយណ៌ទៅវិញ គិតហើយអាសុកក៏ហោះទាំរេហ៍ពលទៅតាំងពិធី លុះមកដល់សារក្ខេត្តសមុទ្រសាគរ ទឹកហូរលាន់ឮគ្រឹកគ្រែងជាទីស្អូត មានខែនសីលាអាសនៈ នៅក្រោមដើមកំងមានស្ទឹកនោះបិទបាំងតទ្វីព្រះអាទិត្យ ឋាន

១- ពាក្យនេះ តាមវចនានុក្រមសំស្ក្រឹតថា ត្រីបូរ: ចោ:+ អាគម អ្នកត្រួកអរ ត្រីបូរាម: យក្សនៃលោកស៊ីទាងលួច ។

សប្បាយដូចខន្ធទ្យាន ហើយអស្សុកកំពុលទៅអគ្គិយតាំងហោមពាធ
កងអគ្គិបរិកម្មតាមគម្ពីរសៃយកេទ ដោយវេទមន្ត សំរួមចិត្តស្មាធិ
ចំរើនទៅដល់បាន ៧ ឆ្នាំ ៧ ថ្ងៃ ។ កំណើតក្រហាយទៅដល់ទេពទ័យជា
ធំ ទ្រង់បើកទិព្វចក្ខុមើលមើលចុះមកឃើញអស្សុកត្រីហូកម តាំងពាក់ព័ន្ធ
កម្មចំរើនសីលនៅទីសាកូដលសារ ។ ទើបអគ្គីព្រះឥសូរជាធំស្តេច
គង់លើគោទសុភជាហោះចុះមកកាន់អស្សុក លុះមកដល់ហើយក៏ស្តេច
ឈរពើមុខត្រង់ហើយ មានព្រះបាសិតថា ណែអស្សុកយក្ស ឯងមកធ្វើមាន
តាយកងអគ្គីតាំងហោមពាធជាយូរឆ្នាំអង្វែង តើឯងជ្រុះថ្នាលបានរបស់អ្វី
ខ្លះ ចូរប្រាប់មកអញហោង កាលនោះអស្សុកត្រីហូកមបានឮសំឡេង
ព្រះឥសូរស្រែកសួរដូច្នោះហើយ ក៏ចេញក្តែកឡើងឃើញព្រះត្រ័យលោក
នាថ កំមានសេចក្តីត្រេកអរណាស់ ក៏ក្រាបថ្វាយបង្គំទៅក្រោមព្រះបាទ
ក្រាបទូលថា ទូលព្រះបង្គំខ្ញុំនេះ ព្យាយាមបរិកម្មការនាំងម្ល៉ះនេះ ទទឹង
សុំពរពីព្រះអង្គឲ្យខ្ញុំឯងកុំឲ្យព្រះនាគយក្ស សម្លាប់បានឡើយ ។ កាល
នោះ ព្រះឥសូរបានស្តាប់ហើយ ព្រះអង្គមានព្រះទន្ទ្រាថា អើចេឯងប្រ
ព្រឹត្តកាន់ទសពិធរាជធម៌ទាំង ១០ ប្រការ កុំផ្តន្ទាយាយីត្រៃលោកឲ្យក្តៅក្រ
ហាយនោះ ទើបអញឲ្យខ្ញុំឯងកើតមានឫទ្ធានុភាពលើសអស្សុរតេពគន្ធពគន្ធ
ត្រូវនាគពិភពឲ្យដូចក្តីប្រាថ្នាឯង ទាំងព្រះនាគយក្ស កុំឲ្យធ្វើអ្វីឯងបាន
អស្សុរត្រីហូកមនោះក៏ថ្វាយបង្គំទូលយកពរពីព្រះឥសូរ ហើយទូលតប-

ស្តេចសង្ឃព្រះកថាថា ដែលព្រះអង្គទ្រង់តុកខ្ញុំខ្ញាន់ចាំងប៉ុន្មានៗក្តី ខ្ញុំព្រះករុណាក៏ធំងប្រព្រឹត្តធ្វើតាមចាំងអស់ហោង ។ ព្រះឥសូរទ្រង់ប្រថានពាអស្ចារស្រេចហើយ ព្រះអង្គក៏ស្តេចហោះវិលទៅគាន់កៃលាសហោង រីឯត្រីបូរាម លុះបានសម្រេចកិច្ចពិធីដូចក្តីប្រាថ្នាហើយ ក៏វិលត្រឡប់មកនគរវិញហោង លុះយូរបន្តិចទៅ ក៏មានដួងចិត្តនោះកំរើប(១) ឬខ្លួចន់ថ្លង់រុងរឿង ចន់ទៅសេពសមស្វាគមន៍ទាន់ទេពធីតាស្រីសួគ៌ត្រង់ពាមាន កំសាន្តសប្បាយដោយឫទ្ធិតាលាកាយ ក្នុងពាក្យសន្យាធំងព្រះឥសូរអស់តែតហើយក៏ហោះឡើងទៅដល់ជាន់ចតុមហារាជិកាស្ថាន តាំងសំដែងអំណាចដេញអស់ទេវបុត្រទេវតាជាកោលាហល រីទេវលោកចាំងអស់ក៏ខ្លាចឫទ្ធិអស្ចារកិតក័យរចល់ រត់ចោលប្រាសាទពាមានស្ថានអាត្មាទៃ ។ អស្ចារ្យត្រី.ចូរាមក៏តាំងសេពសមស្វាគមន៍ធំងទេពកញ្ញាស្រីសួគ៌តាមចិត្តចិន្តា មិនប៉ុន្មានម្ល៉ោះ ក៏ហោះឡើងទៅស្ថានតាវតិង្សាយាមាតុសិតាន់ម្ចាស់តេ ចាំងបានមិត្តសេវត្តី រីស្រីសួគ៌កន្ត្រាំនោះ មានសេចក្តីភ័យកិតរត់ព្រោងព្រាយប្រញាយទៅចំដាំទៃ ។ អស្ចារ្យត្រីបូរាម លុះបានសម្រេចដូចក្តីប្រាថ្នាហើយ ក៏ហោះវិលមកគាន់នគរវិញហោង ។ កាលនោះ ទេវរាជធំងហ្វូងទេវលោកតូចធំត្រេកអរក៏បានសេចក្តីក្តៅក្រហាយ កំនាំគ្នាហោះទៅគាល់ព្រះឥសូរខ្លួលតាមដំណើរសត្វត្រេកប្រកាវ ។ ទើបព្រះឥសូរបានជ្រាបសេចក្តីសព្វ

១- កំរើក = រំជួល ។

ត្រាប់ហើយក៏ទ្រង់ព្រះក្រោធក្រៃគ្រាស់ថា អសុរត្រីបូកមកធ្វើចិត្តអហង្ការក្អេចពាក្យសម្បានឯងអញ ។ ទុកជាពុំបាន ម្ចាលព្រះឥន្ទ្រាធិរាជដែលនឹងទៅបំផ្លាញវានោះ មិនមានយើញអ្នកណានឹងបំផ្លាញវាបាន ទុកជាព្រហ្មក្តី ឬក៏នាគយណ៍ក្តីក៏ធ្វើវាមិនបាន ទ្រង់មានព្រះឧទ្ធារតែប៉ុណ្ណោះហើយក៏ត្រាស់ប្រើចេតបុត្រ ចេតបាទ ឲ្យទៅហៅមហាព្រហ្មនឹងព្រះនាគយណ៍មកជាឆាប់ កាលនោះ រីឯចេតបុត្រ ចេតបាទជាពដម៌រើកគ្រាបថ្វាយបង្គំលាទៅលុះដល់ទៅព្រះព្រហ្មនឹងព្រះនាគយណ៍ ក៏ទូលថាព្រះឥសូរជាម្ចាស់ត្រាស់ឲ្យហៅទៅជាឆាប់ ។ កាលនោះព្រះនាគយណ៍នឹងព្រហ្មធតាបានស្តាប់ហើយក៏នាំគ្នាហោះមកកាន់ស្ថានកៃលាស ដល់ហើយក៏នាំគ្នាចូលទៅគាល់ព្រះឥសូរ ។ យល់ព្រហ្មធតានឹងនាគយណ៍មកគាល់ហើយ ទើបស្តេចត្រាស់ថា ឥឡូវនេះអសុរត្រីបូកម ពាធ្វើបាបអស់ពួកទេវលោកខ្លាំងណាស់ នឹងទុកជីវិតវាពុំបានឡើយ ។ កាលនោះ ព្រះនាគយណ៍បានស្តាប់ព្រះឧទ្ធារហើយក៏ក្រាបទូលថា ដែលទ្រង់ព្រះករុណានឹងបំផ្លាញអសុរឲ្យបានទេវសុខសប្បាយនោះ ទូលព្រះបង្គំជាខ្ញុំមានសេចក្តីត្រេកអរណាស់ ស្រេចហើយ ទើបព្រះឥសូរមានព្រះឧទ្ធារថា ដែលនឹងទៅបង្ក្រាបអសុរត្រីបូកមក្នុងគ្រានេះ គឺខ្លាំងណាស់ ហើយនឹងបានជាកើតអន្ទឹងរឿង រហូតទៅដល់នាគយណ៍ឯងនឹងចុះទៅបង្ក្រាបអសុរតជាខាងក្រោយហោង ។ ត្រាស់ហើយ ព្រះអង្គទ្រង់ជម្ងឺយកកម្លាំងព្រហ្មធតានោះមកធ្វើជាអាវក្រោះពេជ្រ-

កែវ ទើបដប់យកកម្លាំងព្រះសុមេរុកដជាដងធដ័យឈ្មោះហៅថា មហា
លោហាមោលីហនឫទ្ធីអានុភាពខ្លាំងណាស់ ហើយដប់យកកំលាំងស្តេច
អនន្តកគជដែលមានតំលៃមកធ្វើជាខ្សែបន្ទោះឆ្កូ ដប់យកកម្លាំងព្រះនា-
ភយណ៍មកធ្វើជាព្រួញឆ្កូសរនើងបាញ់បង្ហាញអសុរត្រៃបូរម រីបណ្តាគ្រឿង
អាវុធទាំងពួងនោះសុទ្ធសឹងតែព្រះអង្គដប់យកកម្លាំងទេវបុត្រទេវតា គ្រប់
ស្ថានមកជួយ ស្រេចហើយទ្រង់ចាត់ឲ្យរៀបទ័ពភាន ។ ទើបចេត-
បុត្រ ចេតបាទទទួលព្រះឫទ្ធិរចាត់យកព្រះខ័នកុមារដ៏មានឫទ្ធិខ្លាំងនោះ
ជាទ័ពស្រួច ឲ្យឃុំពលខ្មោចអសុរមាយា ព្រះករហូឲ្យកាន់ទង់ជ័យ អគ្គ
ព្រះកិនេតជាទ័ពបែកឆ្វេង ឃុំពលខ្មោចព្រាយស្មាប់តាយហោងគួចធំ ព្រះ
កីណាយជាទ័ពបែកស្តាំឃុំពលកុម្ភណ្ឌ (១)គន្ធ័ន ទ័ពកៀកកាយព្រះកាល
ឃុំពលតិខ្មាជរ ឃុក្សាត់ទ័ពនោះព្រះចុទវេស្សវ័ណឃុំពលកុម្ភណ្ឌ ព្រះ
ភ្លើងឃុំពលខ្មោចអសុរកាយភូតបិសាច លុះរៀបស្រេចគំរង់ចាំព្រះអង្គ
ហោង ។ ទើបព្រះឥសូរស្តេចទ្រង់គ្រឿងតែងព្រះអង្គស្តេចគង់លើគោ-
ឧសភរាជហើយ គ្រឹងហោយកពាជយុទ្ធស្រេចហើយ គំលើកទ័ព
ចេញទៅ លុះដល់សោឡសនគរហើយ ទើបបោះកងទ័ពឲ្យឈប់រហ៍ពល
ហើយទ្រង់បង្គាប់ឲ្យព្រះខ័នកុមារ ចូលខ្មាមចាមដុំកំផែងព្រះនគរអសុក
គ្រានោះ រីឯកខ្មោចព្រាយបីសាចរាជកូតនោះ ស្រែកហៅគឺកកងំរំពង

១- កុម្ភណ្ឌ អានុស្សពួកយក្ស ។ ពាក្យខ្មែរប្រើរហៅក្លាយថា កុម្ភណ្ឌ

រំពើកកក្រើកកោលហាលដល់ទៅអស្សុរត្រីបួកម ។ គង់ទៅក្នុងប្រាសាទ
នោះ លុះឮស័ព្ទសំឡេងហ៊ោហើយ កំក្រេឡកមើលទៅឃើញ
ពួកតាលយោធាមកពីចម្ងាយដូច្នោះ ដូច្នោះ
ហើយ កំទ្រេងក្រេវក្រោធតិរេចក្រៃ ដូចភ្លើងប្រល័យកល្បនេះ
ក្នុងទុក ហើយត្រាស់ថា អ្នកណាកំហែងលើកកងទ័ពមកពីចម្ងាយនេះ
អញនេះរហ៍តលសកលយោធីក៏មានតិចណាស់ កាលណាឡើយទឹងត្រាំ
ទ្រូតយុទ្ធទឹងអញបាន ស្រេចហើយទើបបង្គាប់ប្រាប់ទៅសេនាអាមាត្យឲ្យ
កេណ្ឌកងសកលយោធារហ៍តលលើកទៅតទល់ច្បាំងគ្នា រើសកយកតែ
ខ្លាំងពូកែស្រេចហើយ អស្សុរត្រីបួកម កំលើកចេញទៅដល់ទ្វារក្រៅកំ
ផែងព្រះនគរហើយ កំបញ្ជាប់ទ័ពឲយកយកយឿបបំរុងការជាមាំមួន ហើយ
អស្សុរកំក្រេឡកមើលមើលទៅ ឃើញអង្គព្រះឥសូរលោការជាចមកំពូល
ត្រយកពជូច្នោះហើយ អស្សុរត្រីបួកមកំតក់ស្លុតខ្លាចក័យតិតខ្លាំងណាស់
កំទឹកតូចចិត្ត ហើយកំពិការលំទ្រល់សង្ឃឹយទឹកចិត្តក្រៃ មិនលើកដៃថ្វាយ
បង្គំ ហើយស្រែកថាដូចម្តេចកំបានជាព្រះអង្គលើកកងទ័ពមកច្បាំងនឹង
ខ្ញុំព្រះបង្គំន៎ជាខ្ញុំ ។ មានសេចក្តីខ្មុសពីរឿងភ្លូ ។ ទើបអង្គព្រះចមត្រយ
លោកនាថបានស្តាប់ហើយកំស្រែកតបទៅវិញថា អាឯងនេះជាមនុស្ស
ពុំចុះតែប្រព្រឹត្តខ្មុស កាលដើមឡើយអាឯងបានសុំពរអញ ។ បានផ្តាំថា
បើអាឯងកាន់ខ្សែពិធប្រព្រឹត្តធម៌ទាំង ១០ ប្រការបាន ទើបអញប្រសិទ្ធពរ

ឲ្យពួកតែដូចក្តីប្រាថ្នាអាងឯង ។ កំបានខ្ញុំលួចថាកាន់ចាន ឥឡូវនេះអាងឯង
មិនប្រព្រឹត្តតាមទុក្ខខ្ញុំអញ ហើយទៅបៀតបៀនផ្តន្ទាពាក្យចាខ្ញុំវិលោក
គ្រូឧនាគាពិឡាធរមហាឥសី ឲ្យចានក្តីក្តៅក្រហាយត្រង់ស្ថាន ចានជា
ទុក្ខអស្ចារឯងមិនចាន ។ គ្រានោះ ត្រីចូរាមចានឮព្រះអង្គហើយ កំនឹកឡើង
នឹងព្រះឥសូរណាស់ថា ម្ល៉ះហើយអញស៊ូតែស្លាប់ អញនឹងអង្វរសូម
ទោសក៏ឥតប្រយោជន៍ អញនឹងប្លាំងតតាំងប្តូនុកាពនឹងព្រះឥសូរ
ឲ្យឮល្បីក្តើរឈ្មោះកូនវៃត្រលោកា ស្រេចហើយអស្ចារកំតឿនពលសកល
យោធាឲ្យចូលប្លាំង ។ រីឯព្រះខ័នកុមារជាទ័ពស្រួចនោះ លុះឃើញ
ពលអស្ចារចូលចំប្លាំងតតាំងនឹងខ្ញុំចពលព្រាយមាយា កំត្រេវ ត្រាជតឿន
ពលឲ្យចូលកាប់កពលយក្ស ។ ខ្លះជាច់ក្បាលជាច់ខ្លួនស្លាប់វិនាសជាស
ប្រឋម៌ អស្ចារត្រីចូរាមលុះឃើញពួកពលយោធាស្លាប់វិនាសដូច្នោះហើយ
កំត្រេវក្រោធក្រៃ ចាប់យកព្រះខ័នចានហើយ ដេញកាប់ខ្ញុំចព្រាយ
ជាកោលាហលហោង ។ ទើបព្រះឥសូរស្តេចឃើញអស្ចារដេញពល
ខ្ញុំចព្រាយដូច្នោះហើយ ព្រះអង្គទ្រង់ព្រះក្រោធចាប់យកធ្នូសរដ៏ឃដែល
ជាប់នោះយកមកទ្រង់ថ្នូងជាប់ជាជង ព្រួញសរនោះក៏មិនលឿនទៅឡើយ
ព្រោះអង្គព្រះនាគយណ៍ក្តេចខ្លួនដេកលក់ទៅ ចានជាថ្នូងមិនលឿនទៅ
ព្រះឥសូរទ្រង់ខ្ញាល់ខ្លាំងណាស់ កំបោះបោលធ្ងន់ឃ ទឹងព្រួញសរបេញ
ហោង ។ គ្រានោះព្រះនាគយណ៍ដែលក្រឡាជាព្រួញសរនោះ លុះ

ភ្ញាក់ខ្លួនឡើងភ័យកិត ហើយក៏ក្រាបបង្គំទូលទៅព្រះឥសូរថា ដែលទ្រង់ព្រះករុណាប្រើឲ្យប្រហារជីវិតអសុរនោះ ព្រោះវាបានសុំពរពីព្រះអង្គថាមិនឲ្យស្លាប់ទីដែលទូលព្រះបង្គំទ្រង់ជាខ្ញុំ ទើបបណ្តាលឲ្យទូលព្រះបង្គំទ្រង់ ជាខ្ញុំក្មេងធ្វើសខ្លួនដេកលក់ទៅ តាមតែទ្រង់ព្រះមេត្តាប្រោស អភ័យទោសានុទោសហោង ។ ទើបអង្គព្រះឥសូរជាមកពីដែលត្រៃលោកបានស្តាប់ព្រះនាងយណីទូលដូច្នោះហើយ ស្តេចគិតឃើញមែនហើយ ។ ព្រះអង្គថាអាត្រីបូរមនេះសម្លាប់វាទីនឹងធ្វើសសារសិល្បជ័យមិនបានដូច្នេះ ចាំអញទីនឹងតែងសំឡាប់វាទីនឹងក្តើងវិញ ត្រាស់ស្រេចហើយទើបស្តេចចាប់យកចក្រកែវមណីរត្នៈចោលចំពោះអសុរ ដោយឫទ្ធិចក្រកែវមួយរំពេច គំនេះទៅជាក្តើងក្រុតនេះស្រាប់រៀបពលសាកលយោធា នេះគាំងអាត្រីបូរមស្លាប់អន្តរធានវិនាសអស់ហោង ។ លុះសម្លាប់អសុរត្រីបូរមស្រេចហើយ ព្រះអង្គឲ្យយកធ្វើសសារសិល្បជ័យឈ្មោះមហាលោហៈមាលីនោះមក ទ្រង់ឲ្យយកទៅទុកឯនគរមិថលាបុរី ។ ក្រោះតែវានោះ ទ្រង់ប្រគល់ឲ្យទៅតាបសឈ្មោះអាគតៈឥសីយកទៅរក្សាទុកថា លុះដល់ព្រះនាងយណីចុះមកបង្ក្រាបអសុរយក្ស ឲ្យយកមកថ្វាយព្រះភមាសំរាប់តាវត្រឿងសាស្ត្រាវុធគាំងពួង ។ ស្រេចហើយ ទើបអង្គព្រះឥសូរស្តេចលើកព្យាហ៍ត្រឡប់វិលទៅស្ថានកៃលាសវិញហោង ។

គ្រានេះ ទីនឹងសំដែងតិអគ្គមហេសីព្រះចាតុម្មាគ្យៈឲ្យនាងទាំង ៥ ព្រះ

អង្គ តែ ៤ ព្រះអង្គនោះមានតតិត្រប់ទសមាស កំប្រសូតព្រះកដកុមារ រីបុត្រនាងសុនន្ទានោះឈ្មោះកុវេបណ្ណ នាងចិត្តមាលា ឯដបុត្រនោះឈ្មោះទេពនាសូរ នាងសុវណ្ណមាលីយ បុត្រនោះឈ្មោះអគ្គជាតា កូននាងវៃប្រដៃសុី ឈ្មោះមារទ្ធ រីកុមារកូនទាំង ៤ នាក់នោះ នាងជាមាតាកំស្នេហាស្រឡាញ់ដូចជួនដីវិត ហើយចាត់តីលៀនមេទំបំរើថែទាំជាប្រក្រតី ។

(ឈប់ស្ទះ) ទីនិយាយពីនទ្ធកៈនោះ អង្គព្រះឥសូរស្តេចឲ្យទៅចាំគ្រាឲ្យចាំលាងដើងទេវបុត្រទេវតាឥន្ទ្រហ្មទាំងពួង អង្គីយទៅមាត់ជណ្តើរស្ថានតៃលាសជានិច្ចប្រក្រតី រីទេវលោកទាំងពួងដែលឡើងទៅគាល់ព្រះឥសូរ កាលណាហើយ ទេវលោកខ្លះ ប្រើឲ្យយកទឹកមកលាងដើងរួចហើយ កំត្បុកក្បាលលេង ទេវលោកខ្លះកំចាប់ដកសក់លេងជាល្បែងលុះពាល់តែចំពែកក្បាលរលីងដល់ត្រចៀក ទន្ធកៈកំយំជានិច្ច ហើយនឹកក្តៅក្នុងចិត្តណាស់ ថាខ្លួនអញនេះកំកើតមកជាកូនប្រុសដូចគេដែរ ដូចម្តេចទេវលោកទាំងអស់នេះ កំមើលងាយអញដល់ម្ល៉េះ ថាបើអញនេះមិនស្លាប់ទេ គង់តែនឹងសងសឹកឲ្យបាន តែតហើយទន្ធកៈកំដើរឡើងទៅគាល់ព្រះឥសូរជាម្ចាស់សិរសី លុះដល់ហើយ កំក្រាបថ្វាយបង្គំទូលសុំតាតើព្រះឥសូរ ថាទូលព្រះបង្គំខ្ញុំនេះ មានសេចក្តីតាប់ទឹងទ្រង់ព្រះករុណាជាយូរឆ្នាំអង្វែងមកមួយកាដឹឆ្នាំហើយ ដែលប្រើឲ្យលាងដើងទេវលោកជាប្រក្រតី គួរតែព្រះអង្គទ្រង់ព្រះមេត្តាប្រោស សព្វថ្ងៃនេះ

ខ្លួនខ្ញុំព្រះករុណាកំមានសេចក្តីវេទនាណាស់ ទើរខេវរលោកធ្វើបាបកម្ម
តៀរខ្ញាំងណាស់ អង្គព្រះសយម្ភូញ្ញាណបានស្តាប់អានន្ទកៈយំខូលដូច្នោះ
ហើយ ព្រះអង្គក៏ទ្រង់មានព្រះទ័យនោះតិតមេត្តាហើយ មានព្រះឱង្ការ
ត្រាស់ថា អើឯងចង់ក្រាបថ្វាយអ្វី ចូរឯងក្រោបមកអញទើរឲ្យតាមចិត្តឯង
ណ្តើយកុំយំសោកឡើយ រីឯន្ទកៈនោះ លុះបានឮព្រះពជនឱង្ការត្រាស់
ថាដូច្នោះហើយ ក៏ឱនកាយថ្វាយបង្គំខូលសុំពរ ឲ្យទ្រង់ប្រសិទ្ធិពរឲ្យគ្មាន
ម្រាមដៃឲ្យតូចៗ ថាបើបង្គំលទៅត្រង់អ្នកណាហើយ ឲ្យស្លាប់តែនាស
ហោង ។ ខូលព្រះបង្គំនំជាខ្ញុំទើរនៅចាំរើឲ្យតាល់តែអស់មួយជាតិ នៅ
ក្រោមល្អង់ធូលីព្រះជាទ សូមទ្រង់ជ្រាប ។ ទើបអង្គព្រះឥសូរបានស្តាប់
ន្ទកៈខូលដូច្នោះហើយ ព្រះអង្គទ្រង់រំពឹងគិតថាអានេះកមានសេចក្តីតាប់
ន្ទិងអញនេះមកជាយូរអង្វែងណាស់ហើយ គួរអញប្រសិទ្ធិពរឲ្យវាចុះ
ទ្រង់គិតស្រេចហើយ កំប្រសិទ្ធិពរឲ្យអានន្ទកៈហោង ។ រីឯន្ទកៈនោះជាអ្នក
ចិត្តថ្លាបម្ចាំដូកាចផង លុះបានព្រះឥសូរប្រសិទ្ធិពរឲ្យតូចដូច្នោះហើយ
កំមានចិត្តនោះត្រេកអរសោទរក្រៃ ហើយកំក្រាបថ្វាយបង្គំលាថយចុះមក
វិញលុះមកដល់នៅទីមាត់ជណ្តើរដែលចាំនោះហើយ កំអង្គុយនៅខាង
តាងទឹកដែលធ្លាប់ជនលាងដើងខេវលោក ហើយធ្វើសេចញញឹមញញែមញែម
រង់ចាំមើលខេវលោកដែលឡើងមកគាល់ព្រះឥសូរ ។

(នៅមានត)

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

ប្រាសាទ វត្តព្រះជាតុ ទឹកធា

(នៅខេត្តកំពង់ចាម)

លោក លី-ជាមតេង សមាជិកក្រុមជំនុំទំនៀមទម្លាប់រៀបរៀង

ដោយប្រទេសខ្មែរយើង ជាប្រទេសមានអារ្យធម៌បរិបូណ៌ កាលអំពីព្រេងនាយ ថាទជាមានប្រាសាទបុកណាទៅតាសពេញក្នុងដែនអាណាចក្រតាំងមូល ។ ក្រៅអំពីខេត្តសៀមរាប ដែលមានបុកណាវត្តថែមទេះច្រើនជាងគេ យើងប្រទះឃើញទៅខេត្តដទៃ ។ ទៀត តំមានច្រើនណាស់ដែរ ដូចមានខេត្តកំពង់ធំ កំពង់ចាម ចាត់ដូចជា ខ្ទឹង តាកែវ ។

ដើម្បីឱ្យថាទស្គាល់ឱកន្លែងបុកណា ។ ក្នុងប្រទេសជាតិកាន់តែច្បាស់លាស់ឡើង ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ សូមធ្វើសេចក្តីពិភាក្សាអំពីប្រាសាទបុកណាមួយឈ្មោះ វត្តព្រះជាតុ ដៅធឹកធា ស្ថិតនៅក្នុងឃុំចំការស្វាយ ស្រុកចំការលើ ខេត្តកំពង់ចាម ។ ហេតុដែលនាំឱ្យយើងលើកប្រាសាទនេះមកអធិប្បាយ ព្រោះសព្វថ្ងៃឈ្មោះ « ធឹកធា »

ចានក្តាយទៅជារមណីយដ្ឋានមួយ សំរាប់ទេសចរជាតិយើង ធ្វើដំណើរ
ទៅកំសាន្ត នៅពេលបុណ្យចានអ្វីមួយដែលចានទំនៀមទំលាប់តាមមាញឹក។
ទេសចរចាំងនេះ មិនត្រឹមតែអ្នកនៅកន្លែងខេត្តកំពង់ចាមប៉ុណ្ណោះទេ អ្នក
នៅឆ្ងាយនឹកុំពេញក្តី នៅខេត្តជិតខៀតក្តី តែកាលណាពោលពីដំណើរ
កំសាន្តក្នុងខេត្តកំពង់ចាមហើយ គេតុំដែលក្មេងឈ្មោះ « ទឹកទា » ទេ ។
តើទីនោះមានអ្វីខ្លះ ចានជាលេចឮឈ្មោះខ្លាំងម្ល៉ះ ? តាមពិតមិនមានភូមិ
អ្នកស្រុកផ្សារផ្សេងអ្វីឡើយ ពីដើមមកមានតែតួប្រាសាទថ្មចាក់បែកស្ទើរតែ
អស់គ្មានសល់ ស្ថិតនៅពីកន្លែងតែ ។ គ្នា ហើយនៅប្រមប្រាសាទ
ចាំងពីរនេះ មានជ្រោះប្រឡាយទឹកអំពីបុកណា ដ៏មានទឹកហូរខ្លួបប្រាំង
ខ្លួបវស្សា តំរង់វស្សាមានទឹកសឹងពេញត្រៀប រង់ប្រាំងនៅសល់ត្រឹម
ក្បាលជង្គង់ឬលើក្បាលជង្គង់បន្តិច ។ ទឹកនេះថ្លាឈ្វង ហើយហូរប៉ុច ។ មិន
ចេះឈប់ ជាហេតុនាំឲ្យអ្នកនៅជុតលេងលំហែប្រាណយ៉ាងសប្បាយរីក
រាយ ។ សង្ឃានប្រឡាយទឹកថ្លាឡង់នេះ មានក្តាលតាវល្លិ៍ដុះខ្ចស់ស្រោង
ស្រឹង ប្រជាក់ប្រជិនគ្នា បៃបជាព្រៃស្បាត តែសព្វថ្ងៃគេបានកាប់រំលើងឲ្យ
បានជាកលមួយកន្លែងយ៉ាំងធំ នៅត្រង់ផ្លូវទឹកនេះបែកជាគ្នាធំល្អក្បាច
តំបន់ត្រង់តួប្រាង្គថ្មដែលយើងអធិប្បាយខាងលើនេះ ។ មិនតែប៉ុណ្ណោះកដ-
ការបានកសាងជាចំនប់ទឹកមួយសំខាន់ ដើម្បីទាញប្រយោជន៍អំពីប្រឡាយ
ទឹកបុកណា នាំយកទឹកទៅបែកឲ្យពេលស្រែយ៉ាងធំខួលយក្នុងស្រុក

ព្រៃឈរ ខេត្តកំពង់ចាម និងស្រុកចុកយណ៍ ខេត្តកំពង់ធំ ។

អាស្រ័យដោយទឹកទន្លេងត្រជាក់ត្រជុំ ដោយផ្ទាល់ទឹក ដោយមូលឈើ ត្រឈឹងត្រឈៃ និងដោយទិដ្ឋភាពស្មោកស្មាញនៃព្រៃស្រោងជុះព័ទ្ធ ប្រាង្គសិលាបុរាណ ដូច្នេះហើយ បានជាទេសចរ នាំគ្នាទៅទស្សនាកំសាន្តក្នុងពេលសំពះមួយជង្គុយមួយកាល នាំឲ្យលេចឮឈ្មោះទីស្ថាននេះខ្ទរយ៉ាងខ្លាំង ។ ម្យ៉ាងទៀត គមនាគមន៍ទៅកាន់ទីតាំងទន្លេងនេះ ក៏ជាការងាយផង ដ្បិតវេយន្តភូមិ-ធំគ្រប់ម៉ាកគ្រប់ប្រភេទទៅមកបានតាំងអស់តែថាបើគេចង់ទៅកាន់តាំងទន្លេងនេះ គេងទៅតាមផ្លូវជាតិលេខ ៧ (ផ្លូវពីភ្នំពេញ ទៅកំពង់ចាម) ទៅដល់ត្រង់ផ្សារព្រៃខ្ទង ដែលជាទីតាំងស្រុកព្រៃឈរ មានផ្លូវបំបែកចូលតាមផ្លូវខេត្តខាងត្បូងដៃ ឆ្ពោះទៅដើង ។ ទៅខាងផ្លូវខេត្តនេះ មានភូមិអ្នកស្រុកជាច់ហូតមិនស្ងាត់ឡើយ ហើយស្មុគ្គជាភូមិស្អាតបាត ផ្ទះកៀនដំបូលក្រហមផ្ទៅ ថ្នល់ក៏ក្រាលថ្មហូតមិនព្រួយពីកកាំជាច់ផុងឡើយ ។ ចូលពីផ្លូវជាតិប្រមាណជា ១៣ គីឡូម៉ែត្រ ដល់ភូមិក្រូច ឃុំក្រូច ត្រូវបែកចេញពីថ្នល់ខេត្ត ងាកទៅស្តាំដៃ តាមផ្លូវលំសម្រាប់ណាយតាមប្រឡាយទឹក (ជាប្រឡាយដែលកាជាការខ្ទេចតែតែរៀបចំជាថ្មយ៉ាងស្អាត) ប្រមាណ ៩ គីឡូទៀត ទើបដល់ទៅកន្លែងជ្រោះទឹកធំ មានបុរាណវត្ថុ ដែលគេហៅថា ឧកញ៉ា នោះ ។

តាមែនហើយតែយើងស្គាល់សព្វថ្ងៃថាកន្លែងនេះ បានជារមណីយដ្ឋាន

ដ៏សំខាន់សំរាប់ទេសចរណ៍ជាតិ ប៉ុន្តែប្រវត្តិពិតរបស់ទីស្ថាននេះ
ស្ថិតនៅក្នុងសភាពងងឹតនៅឡើយ ពុំដឹងថាតើ ទីនេះពីបុរាណជាអ្វី ?
កើតមានពីត្រឹមណាមក ?

ដើម្បីដម្រះមន្ទិលពាំងនេះខ្លះ ក្រុមដំទុំខ្ញុំខ្ញៀមទទួលបានប្រមែប្រមូល
ឯកសារដែលមានដម្កល់ទុកយូរមកហើយផង ហើយចាត់ឱ្យសមាជិកទៅ
ពិនិត្យសង្កេតដល់ទីកន្លែងផង ក៏រៀបចំធ្វើជាសេចក្តីពិយការណ៍ អំពីទី
កន្លែងនេះឡើង ដាក់ចំណងជើងថា « ប្រាសាទវត្តប្រជាតុទឹកធា » តាម
ឈ្មោះបុរាណនៃប្រាសាទដែលហៅថា « តុកព្រះជាតុ ឬ វត្តព្រះជាតុ »
នៅត្រង់កន្លែងទឹកធានេះៗ ពាក្យ ធឹកធា នេះទៀត ក៏ពុំមែនជាពាក្យទើប
តែបង្កើតថ្មីដែរ គឺមានមកតាំងពីយូរណាស់ហើយ ទើបបានជាមានជាប់
រហូតនៅក្នុងសៀវភៅសិលាចារឹកប្រទេសកម្ពុជា របស់លោកហ្សូ-ស៊ីដេស
(Inscriptions du Cambodge Par G. Cœdès) សរសេរកំណត់
ឈ្មោះកន្លែងនេះថា « វត្តព្រះជាតុ នៅធឹកធា (Vat Prah thât
de Tuk-C'à) » ។

ដើម្បីទទឹងយកជាសំអាងបាន យើងគោងតែលើកយកសិលាចារឹក
មួយ ដែលអ្នកស្រាវជ្រាវបានរកឃើញហើយនាំមកតំកល់ទុកនៅសារ
មន្ទីរជាតិ (១) នាក្រុងភ្នំពេញសព្វថ្ងៃ ។ សិលាចារឹកនេះនៅបែកធ្លាស្អាតល្អ

១- លេខសំគាល់ Cote D. 61

អក្សរនៅបាស់ ជាថ្មបន្ទះក្រាស់កំពស់ ១ ម៉ែត្រ (មិនគិតជើងតម្កល់) ទទឹង
មុខ ០ម ៥០ ខាងជួរក្រោមមានធ្នាក់ជារូបព្រះតណោស ។ អក្សរចារឹក
មានចំនួនសងខាង គឺម្ខាងមាន ២៣ បន្ទាត់ ជាភាសាសំស្ក្រឹត ទឹងម្ខាង
ទៀតមាន ១៦ បន្ទាត់ជាភាសាខ្មែរ ។ សេចក្តីកងសិលាចារឹកនេះហើយ
ជាគ្រាចើកចំហឲ្យយើងមើលផ្លូវយើញនូវប្រវត្តិដ៏វែងឆ្ងាយនៃទឹកដែនេះ។

សិលាចារឹកឲ្យការណ៍ថា ទឹកដែនេះកសាងឡើងតាំងពី ៨៤៧
ស័ក (២) (គ.ស. ១០២៥) ក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី ១ ។ កាល
នោះព្រះរាជាទ្រង់ទទួលព្រះរាជទានតាមសេចក្តីក្រាបបង្គំទូលស្នើ
អំពីអ្នកក្រុងជម្ងាក់ឈ្មោះជង្ឃាល ហើយដែលមានសម្មតិនាមមួយទៀតថា
លក្ស្មីន្ទ្របណ្ឌិត ។ លោកជង្ឃាល បានរកឃើញទីដ៏មួយកន្លែងក្នុងដំបន់
មួយហៅថា សិទ្ធិបុរ (ត្រង់កន្លែងទឹកឆាសត្វថ្លែ) មានទំនងស្រឡះស្រៈ.
លំស្អុ កំទូលស្នើចំពោះព្រះរាជា សុំទីនេះធ្វើអាស្រមសំរាប់ជាសក្ការៈបូជា
ដល់សាសនាព្រាហ្មណ៍ ដោយថ្វាយទាំងសេចក្តីព្រៃនសព្វគ្រប់សំរាប់រៀប
ចំកន្លែងនេះទុកជាស្នាដៃដ៏សំខាន់ផង ។ គ្រានោះ ព្រះបាទសុរ្យវរ្ម័ន ព្រះ
អង្គទ្រង់ព្រះរាជានុញ្ញាតតាមសេចក្តីសុំ ព្រមទាំងប្រទានទូលព្រៃព្យ
សម្បត្តិជាច្រើនទៀត ដើម្បីជាមធ្យោបាយក្នុងការកសាងនេះទៀត ។
បណ្ឌិតជង្ឃាល ឬលក្ស្មីន្ទ្របណ្ឌិត ចាប់ផ្តើមកិច្ចការស្ថាបនានេះឡើង តាម

២- G. Cœdès Inseriptions du Cambodge Tome V pp222-228

កំឡាំងព្រះរាជទ្រព្យ ទឹងតាមប្រថ្នាជារបស់លោកក្នុងការបញ្ចុះបញ្ចូលរកជំនួយអំពីអ្នកស្រុក លុះគ្រាតែបានហើយស្រេចសព្វគ្រប់តាមគំរោងដែលជាក់ថ្វាយព្រះរាជាទ្រង់ខត ។ គឺនៅក្នុងប្រាសាទធំមានតំកល់សិវលិង្គមួយនៅកណ្តាល សន្មតតាមលិង្គនោះថា «ស្រីភទ្រេស្វរៈ» ទឹងទេវរូបពីរអមសងខាង មួយមានឈ្មោះថា «បវរមេស្វរៈ» មួយទៀតថា «សរស្វតី» ។ ចំពីមុខទិសខាងកើត មានគុហាមួយទៀត ជាទេវស្ថានមានទំហំតូច (ដែលសព្វថ្ងៃយើងឃើញថាតំណាក់ថ្មតាជាតំនាក់ក្នុងព្រៃ ក្បែរប្រឡាយទឹកជ្រោះ មានតែស៊ុមទ្វារមួយនៅសល់គ្រាន់ជាការបង្ហាញហេតុតែប៉ុណ្ណោះ) ។ ស្តាបត្យករ បានចាត់ការជីកស្រះមួយយ៉ាងធំទូលាយនៅចំហៀងខាងស្តាំនៃប្រាសាទឈ្មោះថា «លក្ស្មីន្ទ្រតដាក» ហើយប្រតិស្ឋានលិង្គមាសមួយ តម្កល់នៅកណ្តាលស្រះនេះឯង ។ ព័ទ្ធជុំវិញនៃទីបរិវេណនេះ មានការរៀបចំជាន់ជាស្រុកភូមិមួយយ៉ាងស្តុកស្តម្ភដោយប្រជុំអ្នកស្រុកជិតខាងឲ្យមករស់នៅជួបជុំកុះករគ្នាឡើង ក្នុងសម័យនោះ ។ ដូច្នេះ បរិយាកាសក្រុងថ្មីនេះឯងក៏បានជាសភាពអឺកធឹកឡើង។

ក្រោយដែលរៀបចំរួចស្រេច លក្ស្មីន្ទ្របណ្ឌិត បានទាំងតែមានបួលក្រាបបង្គំទូលព្រះបាទសុរ្យវរ្ម័នទី ១ ព្រះអង្គក៏ទ្រង់ស្តេចយាងប្រារព្ធពិធីសម្ពោធទឹកខ្នងនេះយ៉ាងមហោឡារឹក នៅក្នុងឆ្នាំ ៤៨៧ ស័ក (គ.ស ១០៦៥) ដែលយើងបង្ហើលម្តងមកហើយពីខាងលើ ។ ក្នុងព្រះរាជពិធី

សម្ភោធនេះ ព្រះរាជាទ្រង់ប្រទានទូលបង្គំជាន់ជាប្រជាប់ប្រើប្រាស់ តួកពលព្រះ ២៩ នាក់ ដែស្រែនៅជុំវិញប្រាសាទនឹងស្រះទឹកនេះទាំងអស់ ព្រមទាំងទីលានធំ ។ សំរាប់ប្រកបពិធី ឬជាគ្រឿងលំអ ពុកជាទ្រព្យផ្ទាល់ នៃព្រះគុហានេះផង ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានប្រទានព្រះរាជទាន នាមទឹកខ្នងនេះថា « លក្ស្មីន្ទ្របថ » ដោយនិយមតាមនាមបណ្ឌិតអ្នក ភស្ដាងនេះ ។

សេចក្ដីហូរហែអធិប្បាយមកនេះហើយ ជាប្រវត្តិដើមនៃប្រាសាទនៅ ទឹកខ្នងទឹកទី ។

ឥឡូវយើងអធិប្បាយពីទ្រង់ទ្រាយ ដែលនៅជាតម្រាយសល់មក ដល់សព្វថ្ងៃនេះម្ដង ព្រោះសំរាប់ជួយណែនាំទូលដល់ទេសចរយើង ដែល ត្រូវការទេស្សនាទឹកខ្នងនេះផង ។

សព្វថ្ងៃស្រះបុកណាដែលយើងពោលខាងលើ ថាជាស្នាដៃបណ្ឌិត ជង្ឃាលនោះហើយ ដែលជាគ្នាទឹកដ៏ធំមួយនៅចំមុខទំនប់ដែលក្រសួង កសិកម្មទើបនឹងស្ថាបនាឡើងក្នុងបច្ចុប្បន្ននេះ ។ រីឯប្រឡាយទឹកនេះ វិសាត ហូរភ្ជាប់ពីស៊ីសប្រកបនៅទិសខាងជើងឯក្នុងដីខ្វែកត់ពង់ធំឯនោះ ហើយហូរត្រង់មកក្បែង លុះមកដល់ចំចំហៀងប្រាសាទនេះ ក៏ភ្ជាប់ទឹក ចូលក្នុងរន្ធធំមួយដែលយើងហៅថា « គ្នារ » ខាងលើនេះឯង ។ តាំពុ- ភណាមក ទឹកដក់តេញប្រៀបនៅត្រង់នេះ តែមានកូនជ្រោះតូច ។ បែក

មែកជាន់នាំបង្ហូរយកទឹកទៅចាក់បញ្ចូលដីស្រែទាក្បែរដីតាន់នេះ មានក្បែរក្រូចក្នុងស្រុកព្រៃឈរ នោះជាដើម ។ អាស្រ័យប្រឡាយចាស់ដូច្នេះហើយ បានជាពួកអាខាងកសិកម្មចាត់ចែងក្នុងគ្រា ៥-៦ ឆ្នាំកន្លងទៅនេះ ធ្វើជាចំនប់មួយ រក្សាទឹកទុកក្នុងឆ្នាំរនេះឲ្យតែតែច្រើនឡើង សំរាប់បន្ថែមកំឡាំងឲ្យហូរទៅតាមប្រឡាយដែលគេជីករួចសំអាតជាថ្មី នាំទឹកទៅចាក់ចែកឲ្យស្រែអ្នកស្រុកបានជាច្រើនតាន់ហ៊ាតា ក្នុងស្រុកព្រៃឈរ និងស្រុកបាកយណ៍ ។

ប្រឡាយទឹកដែលហូរនាំទឹកត្រង់មកតាមទិសខាងជើង កាត់មកខាងក្បែរភ្នំក់ចូលឆ្ងាយរួចហើយ ក៏បែរឆ្ពោះទៅខាងលិចត្រង់ទៅវិញ ដូចនេះត្រង់ទឹកធា មានសណ្ឋានដូចកែងប្រដាប់ជាងឈើ គឺហូរត្រង់ពីដើងមកដល់នេះក៏ត្រង់ទៅលិចវិញ ។ ឯកន្លែងដែលគេជួតទឹកលេងសព្វថ្ងៃ គឺនៅចំត្រង់កែងនោះឯង បើខ្លះណាចូលចិត្តទឹកពាក់ កំដួតក្នុងប្រឡាយចាស់ខាងជើងចំនប់ ព្រោះប្រឡាយនេះជាតក្រោមមានទទឹងប្រមាណជា ៤ ឬ ៥ ម៉ែត្រដែរ ។ ទឹកថ្លាឈ្វេងមើលឃើញជាតកបស្មៅដែលមានក្បូនឬដុំតូចៗតម្រៀបត្រៀបត្រា គួរឲ្យចង់រើសយកមកមើល ឬ អង្អែលលេង ។ ក្បូនត្រីមួយហ្វូង ។ រត់ប្រាសទឹកហូរ ប្រជេញគ្នា ។ ឯអ្នកដែលចេះហែល ចូលចិត្តហែល គេលេងក្នុងផ្ទៃទឹកជ្រៅ ផ្នែកខាងក្បួនចំនប់ ដែលជាឆ្នាំរទឹកដ៏ល្អស្អាត ។ ដុំវិញរន្ធែរមាត់ទឹកនេះ មានដើមឈើខ្ពស់ ។ ស្រោងស្រឹង

ជុះខ្ចាន់ខ្ចាប់ នាំឲ្យបានជាជំរកអ្នកទេសចរទៅលេងកំសាន្តផង ទំនងជាទីជ្រកនៅនៃសត្វបក្សាបក្សី ដែលស្រែកឆ្លើយឆ្លងគ្នាបញ្ចេញសូរច់ឡែក ។ រីតែបង្កើនដួងចិត្តពួកទេសចរឲ្យអណ្តែតអណ្តូងឡើងទៀតផង ។

ក្រោយពីឆ្លងតំបន់ជម្រះកាយហើយ ទេសចរអាចដើរទៅមើលដំ-ណាលប្រាង្គប្រាសាទបុកណា ដូចមានប្រវត្តិដែលយើងអធិប្បាយមកខាងលើរួចហើយ ។ ជាដំបូង គេទៅមើលទេវស្ថានខាងកើតសិន ព្រោះទៅជាបន្ទឹងមាត់ប្រឡាយត្រង់គេឆ្លងតំបន់នេះតែម្តង ។ បម្រាយពីវាលទៅប្រ-មាណជា ៥០ ម៉ែត្រប៉ុណ្ណោះ គឺដើរតាមផ្លូវដើរឆ្ងាយត្រង់ទៅកើត ឆ្ងាកខាងស្តាំ មើលក្នុងតន្ត្រៃបង្រៃ ដែលមានស្លែជុះពាក់ព័ន្ធគ្នាប្រគោងទៅដើមឈើត្រចឹតពីលើ ។ ប្រសិនជាផ្លូវច្រាំងជាការស្រួលងាយ តែបើផ្លូវវៃស្បាមានដើមបន្ទាស្ងួត ជុះខ្ចាន់ខ្ចាប់នាំឲ្យពិបាកវុកវុលបួលទៅខ្លោះណាស់ មានតែតំនរឬថ្មាយក្រៀមបួនៗ ជ្រុងត្រវែង ។ ប្រតង់ប្រតាក់លើគ្នាមានចាំងដីជាប់ដិតពីលើនាំឲ្យជុះកូនឈើតូចតាចត្រចឹតណាប់ ដំណាលនេះផង ត្រាន់តែមានចំនងជាផ្ទាំងថ្មមួយ គឺមានឮដុំវែង ។ បញ្ជាតើរ ទំនងពីលើមួយ សល់ជាដំណាលឲ្យសំគាល់បានថាភ្នោងថ្មតែប៉ុណ្ណោះ ។

មើលចំនេះរួចហើយ គេចុះមកតាមផ្លូវដដែលវិញ ដើរតាមប្រ-ឡាយចំតបន្តែងជាកទៅស្តាំតទៅលិច ប្រមាណជា ២០០ ម៉ែត្រ មានស្ពានចេតុងដែលជាខ្នងចំនប់សំពាប់ចំពុំឲ្យទឹកហូរខ្ទាំងពេក កាលណាបើ

មានទឹកតិច ហើយមាត់អូរនេះអាចបើកឲ្យហូរភ្ញាក់ឆាបាន កាលណាបើ
មានទឹកច្រើនបរិបូណ៌ តើថាត្រង់នេះជាមាត់អូរបើក-បិទប្រឡាយទឹកតាម
គេត្រូវការ ម្ល៉ោះហើយបានជាតិខាងលើត្រូវធ្វើឲ្យមានសណ្ឋានដូចជា
ស្ពាន ដែលអាចឲ្យគេដើរឆ្លងបាន ។ ឆ្លងពីកូនស្ពាននេះទៅ យើងនឹង
ប្រទះផ្លូវលំស្រឡះស្រឡាំទៅឯបបរណ្តាយតាមប្រឡាយនេះឯង ។ យើង
បៃស្តាំ ដើរតាមផ្លូវលំនេះប្រមាណជា ២០០ ម៉ែត្រទៅទៀត ស្រាប់
តែប្រទះទៅខាងឆ្វេងដៃយើង នូវគំនរថ្មបាយក្រៀម ដែលរុះភ្ជាក់ប្តោត់
របាំយបង្គុំគ្នាខ្លះ ទៅជាប់តម្រៀបគ្នាជាកំពែងបន្តាយខ្លះ ប៉ុន្តែគ្មានក្បាច់
រចនាឆើតឆាយអ្វីទេ ។ មិនតែប៉ុណ្ណោះ មានដើមស្រទៀ ដើមឈើ
ទាល ដើមសំពៅង ជុះពីលើគំនរថ្ម ថ្ម ពីលើកំពែងថ្មនេះ ចាក់ឫសប្រ-
ភាត់ប្រវែងដូចតស់លូនប្រពាត់ប្រព័ន្ធគ្នា តាំងពីកំពូលលើភ្នាក់រហូតដល់
ដី ។ រុក្ខាតាំងនេះ មានទំហំពីរទប ឬបីទបមនុស្ស ខ្ពស់លសើយ
រមើលជ្រុះឈូតពីក្បាល ។ ត្រង់នេះ នាំឲ្យយើងនឹកស្ទើចន្ទត់ចិត្តព្រោះទំ-
ហំដើមឈើដ៏ធំមហិមាតាំងនោះ ពុំគួរណាជុះលើគំនរថ្មតាំងនេះកើតសោះ
ហើយថ្មនេះទៀត ក៏ពុំគួរណានឹងទ្រទម្ងន់ដើមឈើដ៏សម្បើម ។ តាំងនេះ
រួចឡើយ ។ កំពុងតែគិតយាំងនេះ យើងស្រមៃភ្លែតទៅដល់ប្រាសាទ
តាព្រហ្មទៅក្នុងវាំងអង្គរ ដែលមានភាពខ្មុរខ្រម ហើយមានដើម
រឈើធំ ។ ជុះគ្របសង្កត់ជាច្រើនកន្លែងពាសពេញតែបរិវេណប្រាសាទ

ដែលមានទំហំធំខ្លាយជាងគេក្នុងព្រះជាតុ ដែលអធិប្បាយនេះទៅទៀត ។

យើងឈានដើងចូលទៅក្នុងបរិវេណគុកគុហាបុរាណនេះ យើងប្រទះឃើញរាងដើរជាជួនជ្រុងទ្រវែង ហែរមុខខ្ពោះទៅខាងកើតចំ មានតែទ្វារចូលពីកើតមក ឯខាងជើងនិងខាងត្បូងមានតែបង្អួចដ៏ធំវែងប្រកបដោយចំរឹងថ្មក្រឡឹងជាក្បាច់ដើងខៀន ចំណែកខាងលិចចំពុំមានទ្វារបង្អួចទេ ។ សព្វថ្ងៃជញ្ជាំងជុំវិញនៅគង់ទ្រង់ទៅឡើយ ដែលយើងនិយាយមកហើយថាមានដើមឈើធំ ៗ ដុះពីលើនោះឯង ។ រីឯដំបូលឬកំពូលប្រាង្គវិញគ្មាននៅសល់បន្តិចទេ សព្វថ្ងៃទៅតាលហាលរកឲ្យយើងសន្និដ្ឋានថាតើគុហានេះ ពីដើមឡើយមានកំពូលដូច្នេះឬដូច្នោះពុំបាននឡើយ យើញមានតែថ្ងាក់មកគរទៅកណ្តាលបរិវេណ តែមានថ្នូរខ្លះ មានកងរៀងនិងជាថ្ងាក់ពីកំពូល គឺក្បាច់ត្របកដែលគេសំពាប់បន្តូបធ្វើជាកំពូលប្រាង្គ ថ្ងាក់មកគរលាយឡំជាមួយថ្មដទៃទៀតច្រើនធន ។ ទំហំតួប្រាសាទនេះ មានបរណ្តាយប្រមាណជា ២០ ម៉ែត្រ ទទឹង ១៩ ម៉ែត្រប៉ុណ្ណោះ ។ ដុំថ្មចាំងនោះភាគច្រើនជាថ្មបាយក្រៀមពុំសូវមានថ្មសំលៀងដែលធ្លាក់ជាក្បាច់ស្អាតឆើតឆាយអ្វីឡើយ ប្រទះឃើញតែផ្លែវ (Linteau) មួយដែលមានធ្លាក់ជារូបព្រះនាគមណ៌នៅចំកណ្តាល ទំនងមានក្បាច់ស្មុកស្មាញនៅព័ទ្ធព័ន្ធជុំវិញ ។

ការទស្សនាបុរាណដ្ឋាននេះ ធ្វើបានស្រួលតែនៅរដូវប្រាំងជាជាងរដូវវស្សា ហើយពេលថ្មើរមានកំមិនខាស់ ព្រោះមានដើមឈើធំ ។

ត្រជាក់ត្រឈៃ មិនព្រួយតិះត្តាឡើយ ប៉ុន្តែពេលល្ងាចនាប់ផឹងតិចតួច ដោយសារមួយឈើធំៗនោះ ។ ភាគច្រើនអ្នកទស្សនាទីកន្លែងនេះ គេចូលចិត្តទៅនៅពេលព្រឹកប្រមាណជាម៉ោង ៨-៩ ព្រោះបានទុកសំរាប់ចិត្ត តែទៅដល់ហើយគេដើរទស្សនាទីប្រមប្រពណាំងនេះ ឲ្យសព្វគ្រប់រហូតដល់ម៉ោង ១១-១២ ថ្ងៃត្រង់ បន្ទាប់មកគេរៀបម្ហូបម្ហាអាស្រ័យតាមបែបដើរព្រៃ អាស្រ័យរួច គេសំពាកដេកលេងក្រោមដើមឈើត្រជាក់ត្រឈៃ រហូតម៉ោង ២-៣ ទើបក្រោកឡើងដូតទឹកលេង លុះដល់ម៉ោង ៤-៥ រសៀល ទើបចេញដំណើរត្រឡប់មកលំនៅវិញ ។ របៀបដូនជាដំណើរវិលត្រឡប់នេះ ជាពេលរសៀលខាងភ្នំងចិត្តិចផង , សម្រែកបក្សី ខឹងដំនោរពេលល្ងាចរណ្តំស្ទឹកឈើ ព្រមជាមួយកាំរស្មីដ៏ស្រទន់នៃព្រះសុរិយោហៀបនឹងអស្តង្គត ច្បាស់ជារត់មកបបោសអង្អែលដួងចិត្តនៃទេសចរ មិនឲ្យងាប់អាល័យបានឡើយ ហាក់ដូចជាបណ្តុះរសជាតិទីកលើកមួយឲ្យមកលេងទីនេះនៅពេលណាមួយទៀតជាមិនខាន។

X

X X

ប្រវត្តិវត្តប្រាង្គ (ត)

រៀបរៀងដោយ ព្រះពោធិវង្ស ហ្សូត-តាត

អគ្គាធិការនៃពុទ្ធកសិក្សា

ខ្ញុំ (ព្រះ ពោធិវង្ស ហ្សូត-តាត វជីរបញ្ញោ) ដែលជាអ្នក ទទួលមក វត្តប្រាង្គនេះ ចាប្រជុំគ្នាសង្ឃដែលមានព្រះគ្រូពោធិញ្ញាណ និត-កុ ជាចៅអធិការ ធ្វើទុក្ខសក ទុក្ខសិកាចំណុះវត្តប្រាង្គទាំងអស់ ដើម្បីពិគ្រោះគ្នាអំពីការខ្វះខ្រោមនៃវិហារនោះ តើត្រូវជួសជុល ឬត្រូវ រុះរើធ្វើជាថ្មី? ពីប្រជុំបានជជែកពិភាក្សាគ្នា ខ្លះយល់ថា គួរជួសជុលតែ គ្រឿងដែលពុកផុយខ្លាំងជាងគេសិនហើយ ខ្លះទៀតយល់ថា គួរតែរក្សា ទុកនូវក្តើរដំណែលបុព្វបុរសឲ្យគង់វង្សទៅជាដែលកុំរុះរើ គឺត្រូវទុកឲ្យទៅ ជាវិហារពុកបាក់បែកខ្ទេចខ្ទីតាមសភាពដើមទៅចុះ បើត្រូវការសង់វិ- ហារថ្មី គួរតែរកទីដីឯទៀតសង់ទៅ អ្នកខ្លះទៀតយល់ថា ការរក្សាទុក នូវបស់កំពុកកំបាក់ដែលជាប់ថ្នាក់ប្រើការលែងកើតទៅហើយដូច្នេះ ទើប តាំងឲ្យទីវត្តទាំងមូលមានសភាពខ្ជិលខ្ជា ព្រោះតាមធម្មតា គេរក្សានូវបស់ល្អ ហើយគេមិនរក្សាទុកនូវបស់មិនល្អទេ ។ មតិទាំងប៉ុន្មានទាំងនេះ បែរជារលាយចូលគ្នាតែមួយ គឺយល់ស្របគ្នាជាឯកច្ឆន្ទថា ត្រូវតែរុះរើ

ចេញ ហើយសង់ឡើងវិញជាថ្មី ។ ក្រោយដែលទីប្រជុំបានពិនិត្យមើលសព្វអង្គ ឃើញថា មិនអាចនិយមទុកប្រើការយ៉ាងណាតទៅទៀតបានឡើយ ព្រោះ សូម្បីតែឥដ្ឋដញ្ជាំង ក៏ពុកផុយអស់ទៅហើយ ។

ដោយវត្តប្រាង្គ ជាវត្តព្រះពុទ្ធសាសនាតាំងពីកន្លងបុពណាកាល ទើបរុំបានធ្វើបុតហ្វាយថ្វាយព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះនរោត្តមសុភមង្គល នឹងសម្តេចព្រះនរោត្តមសីហនុ ព្រះទុបយុវរាជ ដើម្បីទ្រង់ជ្រាបតាមដំណើរការណ៍ ហើយសូមព្រះបរមរាជានុញ្ញាតរុះរើវិហារចាស់ ហើយនិងកសាងជាថ្មី ។ ព្រះករុណាជាម្ចាស់ជីវិត នឹងសម្តេចព្រះទុបយុវរាជ ក៏ទ្រង់បានប្រោសព្រះរាជទានព្រះរាជានុញ្ញាត តាមសេចក្តីទូលសូម ។

លុះបានទទួលព្រះបរមរាជានុញ្ញាតហើយ ការរុះរើវិហារចាស់ក៏បានចាប់ផ្តើមឡើង នៅថ្ងៃអាទិត្យ ៦ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥០៣ គឺថ្ងៃទី ៧ មេសា ១៩៦០ ។ ការរុះរើបានធ្វើដោយធាប់ហើសណាស់ ត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ ក៏បានហើយស្រេច ដោយលោកគ្រូព្រះគ្រូ ឯក-គាំ ចៅអធិការវត្តស្បែង បានជួយទុបត្តម្ភដោយយកព្រះទ័យទុកដាក់យ៉ាងពេញសមត្ថភាព ប្រើឱនាំញាតិញោមដើងវត្តរបស់លោកមកប្រជុំជាមួយនឹងពុទ្ធបរិស័ទដើងវត្តប្រាង្គ ដើម្បីធ្វើការរុះរើឲ្យបានធាប់រហ័សតឹង ១ ថ្ងៃ ។ មានគ្នាពី ៤០០ ទៅ ៦០០ នាក់ ។ សូមធ្វើតយកឱកាសនេះ សំដែងនូវអំណរគុណជ្រាលជ្រៅក្រៃលែង ចំពោះលោកគ្រូ

ព្រះគ្រូ ឃុក-គាំ ទឹងញាតិញោមរបស់លោក ព្រមទាំងពុទ្ធបរិស័ទទៀត ដែលបានជួយទុបត្ថម្ភកន្លងមក ។

ក្រោយដែលបានរុះរើរបស់ចាស់ចេញអស់ហើយ ការចាប់ផ្តើមកសាងវិហារថ្មី កំបានធ្វើជាបន្តបន្ទាប់គ្នារៀងមក គឺផ្តើមវាស់ដែង ដីកដី ក្រយ ឫស ចាក់គ្រឹះ ពីថ្ងៃ ១០ កេីតខែពិសាខ ឆ្នាំជូតទោស័ក ព ស. ២៥០៣ គឺថ្ងៃទី ២០ ឧសភា ១៩៦០ ហើយបន្តរហូតដល់ថ្ងៃ ១៣ កេីតខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព ស. ២៥០៦ គឺថ្ងៃទី ២០ ឧសភា ១៩៦៣ នេះ ទេីបបានហើយស្រេចសម្រេចជារូបវិហារ ។ រួបរួមពេលនៃការកសាងវិហារនេះ គឺ ៣ ឆ្នាំគត់ ។

វិហារនេះកសាងដោយបេតុងអារម៉ែ (គឺការប្រកបផ្សំនៃគ្រួសខ្សាច់ ស៊ីម៉ងត៍ ទឹងបង្កប់ដែកជាឆ្អឹងនៅខាងក្នុង) ទាំងអស់គ្មានគ្រឿងឈើ លាយឡំផងទេ សូម្បីតែបង្កន់ដែរណែង គ្រឿងដំបូលទាំងអស់ ក៏សុទ្ធសឹងជាបេតុងអារម៉ែដែរ មានតែសន្ទះទ្វារប៉ុណ្ណោះទេ ដែលធ្វើដោយឈើ ហើយទឹងក្បឿងក្បាច់ប្រក់ដំបូលដែលធ្វើដោយដីដុត ។

វិហារថ្មីនេះ មានទទឹង ១៣ ម៉ែត្រ (បេីគិតទាំងយ៉ាងជើងទឹងខាងត្បូងផង រួមជា ២០ ម៉ែត្រ) បណ្តោយ ២៧ ម៉ែត្រ (បេីគិតទាំងយ៉ាងកេីតទឹងខាងលិចផង រួមជា ៣៤ ម៉ែត្រកន្លះ) ។

តម្លៃការកសាងវិហារនេះ រួមទាំងតម្លៃនៃពុទ្ធបល្ល័ង្កខាងក្នុងវិហារ

តំពែងជាដើងទើនទប់ដី ទឹងការក្រាលផែនស៊ីម៉ងត៍ដុំព្រៃបរិវេណវិហារ
ផង មានចំនួនពីរលានបួនសែនពីរម៉ឺនបួនពាន់ហាសិបប្រាំបួនរៀល
(២.៤២៤.០៥៥រៀល) ។

ចំនួនប្រាក់ជាតម្លៃនៃការកសាងវិហារនេះ មិនមែនបានមកពីតហបតី
ណាម្នាក់ទទួលការកសាងជាចម្បងតែម្នាក់ឯងឡើយ គឺបានមកពីពុទ្ធបរិស័ទ
ចាំងឡាយ ដែលជាចំណុះវត្តប្រាង្គធង ដែលនៅក្នុងស្រុកកំពេញផង
ដែលនៅក្នុងខេត្តនានាផង បានបរិច្ចាគធនធានតាមកម្លាំងរៀងខ្លួនដោយ
សេចក្តីជ្រះថ្លាធ្វើជាកថិនទាន ធ្វើជាបុណ្យផ្កាខ្លះ ចូលចាប់កុសលក្នុង
ការកសាងដោយផ្ទាល់ខ្លួនម្នាក់ៗ ខ្លះ ។ ជាពិសេស សម្តេចព្រះមហា-
ក្សត្រិយានី សុីសុវត្ថិ កុសុមចារីវ័ត្តន វឌ្ឍនា ដែលព្រះអង្គ
ជាប់តែមានព្រះពុទ្ធសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា ទឹងជាព្រះអគ្គពុទ្ធសាសន-
បត្ថម្ភិកា ទ្រង់បានបរិច្ចាគព្រះពជ្រទ្រព្យផ្ទាល់ព្រះអង្គចំនួន ១០០.០០០ រៀល
ដើម្បីស្ថាបនាពុទ្ធបល្ល័ង្កដែលតាំងនៅក្នុងវិហារនេះ ។

អស់លោកអ្នកពុទ្ធបរិស័ទចាំងឡាយ ដែលបានជួយកាតពានក្នុង
ការកសាងវិហារនេះ ឈ្មោះថាបានជួយឧបត្ថម្ភព្រះពុទ្ធសាសនាដោយពិត
ត្រង់វិហារនេះ ដែលអស់លោកអ្នកពុទ្ធបរិស័ទចាំងឡាយ បានជួយឧបត្ថម្ភ
ត្រាតែបានសម្រេចហើយនេះ ជានិមិត្តរូបនៃការញ៉ាំងព្រះពុទ្ធសាសនាឲ្យ
ចំរើនរុងរឿងអស់កាលជាអង្វែងតទៅ ។ ការកសាងវិហារនេះទឹងនាំឲ្យមាន

ផលានិសង្សជាអនេកប្រការដល់អ្នកកសាង ព្រោះវិហារគេចចាត់ទុកជា
សេនាសនៈជាដំរៀសសក្តិព្រះពុទ្ធសាសនា ជាទីប្រាសចាកសម្រាប់ធ្វើ
សង្ឃកម្មត្រង់យ៉ាង ។ តាមច្បាប់ពុទ្ធសាសនា ជនអ្នកមានសទ្ធាជ្រះថ្លា
កសាងសេនាសនៈបែបនេះ ឈ្មោះថាជាអ្នកទ្រទ្រង់ពុទ្ធសាសនា ទ្រទ្រង់
ធម៌ ជាអ្នកបរិបូណ៌ដោយសីលធម៌ដោយពិត ។ ជនទាំងឡាយដែល
បានចូលកុសលក្នុងការកសាងសេនាសនៈដ៏ប្រសើរបែបនេះ ក្នុងព្រះពុទ្ធ-
សាសនា នឹងត្រូវបានទទួលនូវសេចក្តីសុខចំរើន កាលទីកកត្រី ដោយ
អំណាចកុសលកសាងនេះផ្តល់ឲ្យ លុះចំណាយទៅក្នុងលោកនេះទៀ ជន
ទាំងនោះ នឹងត្រូវបានទៅកើតក្នុងសុគតិភពមិនខាន ។

ទៅទីអវសានេះ ខ្ញុំសូមលើកយកភាគផលនៃកុសលដែលកើត
ឡើងអំពីការស្ថាបនាវិហារថ្មីនេះ ជាព្រះពរកុសលទាំងមូល ថ្វាយចំពោះ
ព្រះករុណាព្រះបាទសម្តេចព្រះហរីរក្សរាមា ឥស្សរាធិបតី ព្រះអង្គឌួង
(ព្រះបរមរាជ) ដែលទ្រង់បានកសាងវិហារវត្តប្រាង្គ ព្រមទាំងបាន
ឧបត្ថម្ភវត្តប្រាង្គនេះជានិច្ចផង ឲ្យមានសភាពរុងរឿងក្នុងរជ្ជកាលនៃព្រះ
អង្គ សូមព្រះអង្គបានស្ថិតនៅក្នុងទំព្ងសម្បត្តិប្រកបដោយសេចក្តីសុខក្សេម
ក្សាន្តនិរាសផុតចាកទុក្ខ អស់កាលជានិច្ចនិរន្តរ៍ ! ។

សូមថ្វាយព្រះពរកុសល ចំពោះព្រះមហាក្សត្រទាំងឡាយ ដែល
ជាព្រះពរនរសេ នឹងជាព្រះពរនត្តារបស់ព្រះអង្គត ។ មក តែព្រះបាទ

សម្តេចព្រះនរោត្តមបរមរាជវាតារ (ព្រះសុវណ្ណគោដ្ឋ) ព្រះបាទ
សម្តេចព្រះស៊ីសុវត្ថិ (ព្រះកជានុគោដ្ឋ) ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-
មុនីវង្ស (ព្រះបរមទុតិយគោដ្ឋ) ទីឯព្រះបាទសម្តេចព្រះនរោត្តម-សុភម្រឹត
(ព្រះមហាកាញ្ចនគោដ្ឋ) ដែលសុទ្ធសឹងតែជាព្រះអគ្គឧបត្ថម្ភក
សូមព្រះអង្គទ្រង់ស្ថិតនៅក្នុងទិព្វសម្បត្តិ ប្រកបដោយសេចក្តីសុខ-ចំរើន
សមតាមព្រះពជ្ឈំណង់កុំបីឃ្លាត ! ។

សូមថ្វាយព្រះពជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានី
បរមបពិត្រ ជាម្ចាស់ដីវិត ទីឯសម្តេចព្រះនរោត្តម.សីហនុ ។បយុវរាជ
ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា សូមព្រះអង្គបានប្រកបដោយស៊ីរីសុវត្ថិ-
វឌ្ឍនមង្គលវិបុលសុខត្រចំប្រការ ព្រមទាំងប្រកបដោយពុទ្ធពរទាំង ៥
ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ទីឯ បដិភាណៈ អស់កាលជា
និច្ចនិរន្តរ៍តរៀងទៅ ។

មួយចំណែកទៀត សូមឧទ្ទិសផលដែលកើតឡើងអំពីការកសាង
វិហារវត្តប្រាង្គនេះ ជូនចំពោះពុទ្ធបរិស័ទទាំងឡាយ ដែលជាចំណុះវត្ត
ប្រាង្គ ដែលតាស្រ័យនៅតាក្រុងភ្នំពេញ និងក្នុងស្រុក-ខេត្តនានាក្នុង
ព្រះពជអាណាចក្រកម្ពុជា ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា
រហើយបានបរិច្ចាគធនធាន ជួយកសាងវិហារវត្តប្រាង្គនេះ ជាបដល់រហើយ
រស្រេច ។ សូមផលដែលឧទ្ទិសជូនទៅនេះ ជួយផ្តល់ឱ្យបានសម្រេច

ខ្លួរសេចក្តីសុខក្សេមក្សាន្ត ទីដ៏សេចក្តីចំរើនចំរើន សមតាមបំណងកុំបីឃ្លាតលុះដល់អវសានជាតិ សូមឲ្យបានសម្រេចខ្លួរអមតធម៌ គឺព្រះនិព្វានដែលមានសេចក្តីសុខសាន្តដ៏លើសលុប ឥតមានសុខអ្វីប្រៀបស្មើបានឡើយ ។

សូមប្រទេសកម្ពុជាឯកភាព អព្យាក្រឹត បឹតនៅជាសុខសាន្ត បានប្រកបដោយវឌ្ឍនភាព ឈ្នះអស់សត្រូវគ្រប់ទិសទី សូមឲ្យសត្រូវក្លាយមកជាមិត្ត ! ។



ញុះញង់ចំបែកឲ្យកើតក្បត់ ១
ខ្សោមព័ន្ធខ្ទុកឲ្យបានយូរ ១
ចូលលុកចោមរាយ ១
ក្លាហានក្រៃលែង ១
ពាំងបួនប្រការនេះ លោកពោលថា
ជាមគ្គាបាយ សម្រាប់វាយបង្ខាយ
ឲ្យបែក ។



សម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ស្តេចយាងលើព្រះរថម្រាលសុទ្ធសឹងបុប្ផា ទៅជាព្រះរាជាធិបតីនីដ៏ខ្ពង់ខ្ពស់
ក្នុងឱកាសពិធីបុណ្យបង្ហុះទណ្ឌសីមា នឹងធ្លងព្រះវិហារវត្តលង្កា នៅថ្ងៃទី ១៩ ខែសា ១៩៦៤ ។

បុណ្យបញ្ចុះសីមាវត្តលង្កា

សង្កាត់លេខ ៦ ក្រុងភ្នំពេញ

វិហារថ្មីវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ ចាប់ផ្តើមសង់ឡើងជួបស្រេច គួរជាទីចាប់អារម្មណ៍របស់ពុទ្ធសាសនិកជនជាពន់ពេក ។ ពេលណាខ្សែនិកជនដើរកំសាន្តនៅក្នុងសួនច្បារនៃវិមានឯកភាជ្យ គេតែងឃើញវិហារវត្តលង្កាប្រកបដោយកំពូលលេចខ្ពង់ចេញពីសេនាសនៈនៅក្នុងអាកាសនោះ ។ ពិតមែនតែយើងមើលទៅ ឃើញថាវិហារនេះជួបស្រេចជាច់ តែតាមច្បាប់ព្រះពុទ្ធសាសនាទើនចំនៀមរបស់យើង នៅខ្វះត្រង់ធ្វើបុណ្យកឋិនទើនបញ្ចុះសីមា ។ អាស្រ័យហេតុនេះហើយ ទើបគណៈកម្មការនៃវត្តលង្កាទើនពុទ្ធបរិស័ទជាអ្នកសាងវិហារនេះ បានព្រមព្រៀងគ្នាធ្វើបុណ្យកឋិនព្រមទាំងបញ្ចុះខណ្ឌសីមា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើក្បួន ទើនសម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ តាមកម្មវិធីដូចខាងក្រោមនេះ ៖

ថ្ងៃទី ១ ថ្ងៃសុក្រ ៦ កើតតែពិសាខ (ថ្ងៃទី ១៣ មេសា ១៩៦៤)


នៅវេលាម៉ោង ៤ រសៀល ពិធីចូលបុណ្យក៏ចាប់ផ្តើមឡើង ។ ភ្លាមពុទ្ធបរិស័ទបានមកប្រជុំគ្នានៅមុខព្រះវិហារ ដើម្បីទទួលព្រះសារីរិកធាតុព្ធជុំវិញព្រះវិហារ ហើយយកទៅដាក់លំដាប់នៅថ្នាក់ខាងលើ ។

បន្ទាប់មក ទើបមានពិធីសូត្រប្រកាសទៅតាទៅមុខព្រះវិហារ ។ លុះរួចពិធីនេះហើយ ពុទ្ធបរិស័ទប្រគេនកេសជ្ជៈដល់ព្រះសង្ឃ ទៅខាងក្រៅព្រះវិហារ ។

ម៉ោង ៧ យប់ ទេសភាពនៅមុខវត្តលង្កា មានសភាពអ៊ូអរហាក់ដូចជាផ្សារដើមធំមួយ ដោយពុទ្ធបរិស័ទនិងអ្នកជំនួញខ្មែរធួបត្រកូប និងវត្តខ្លះៗទៀត តាំងតុៈជាស្រេចវត្តតាំងនោះ ពុទ្ធបរិស័ទអ្នកប្រុងប្រយ័ត្នកុសល ប្រជ្រៀតរុលត្បុលចូលទៅទិញវត្តតាំងនោះ យកទៅជាស្រេចក្នុងរណ្តៅសីមាខ្លះទៀត រំលេចូលចាប់កុសលតាមតុៈដែលមាននៅទីនោះ ។ ដល់ម៉ោង ៧ កន្លះ ព្រះសង្ឃចំនួន ១០០ អង្គចំរើនព្រះបរិត្តនៅថ្នាក់ខាងលើ ហើយពិធីវេនទិមិត្តសីមា និងវិហារថ្វាយដល់ព្រះសង្ឃ ក៏មានជាស្រេចដាប់ហូរហែ ។ កិច្ចខាងលើនេះរួចហើយ ទើបមានអុជគាំជ្រួចរន្ទា ដែលធ្វើឲ្យអ្នកភជានតែតាំងឡាយចាំនៅក្នុងចិត្តនឹងភ្លាត់រលឹកនឹកដល់ថ្ងៃអុំទូក ។

លុះដល់ម៉ោង ៩ កន្លះ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត តាត ប្រចាន ធម្មទេសនា (ធម្មត្រាស់) នៅព្រះវិហារថ្នាក់លើ ហើយទើបរៀបចំធ្វើកិច្ចពុទ្ធាភិសេក ។

បើយើងសង្កេតមកខាងក្រៅវេធិវិញ ពុទ្ធបរិស័ទកកកុញរុញគ្នាដណ្តើមចូលទៅក្នុងវត្ត ដើម្បីទាំយកចង្ហ័យទៅចូលចាប់កុសល ខ្លះប្រជ្រៀតចូលទៅមើលភាពយន្ត ខ្លះទៀតបណ្តើរគ្នាត្រសង៉ទៅមើលល្ខោន



សម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់កំពុងប្រណម្យគោរពព្រះសង្ឃស្វាធ្យាយធម៌
បង្សុកូល ព្រះអដ្ឋិធាតុ ព្រះរាមាទា ព្រះអយ្យកា ដំកល់ក្នុងព្រះចេតិយនេះ នៅទីកាសពិធីបុណ្យបញ្ចុះខណ្ឌសីមា នឹងធ្វើង
ព្រះវិហារវត្តលង្កា នៅថ្ងៃទី ១៩-៤-១៩៦៤ ។

ដែលតាំងនៅកំផែងវត្តខាងលិចឆ្ងៀងទីតែ ។ អ្នកខ្លះមិនអើពើទឹងលែងខេ គេនាំគ្រួសារទៅអង្គុយមើលព្រះវិហារ ពីក្នុងសួនបន្លាវិញ ។

ប្រៀទី ២ ថ្ងៃសៅរ៍ ៧កើត ខែពិសាខ (ថ្ងៃទី ១៨ មេសា ១៩៦៤)

នៅថ្ងៃទី ២ នេះ វេលាព្រឹក មានប្រគេនយាគូដល់ព្រះសង្ឃចំនួន ១០០ អង្គ ដែលចំរើនព្រះបរិត្តពីល្ងាច នៅឧបដ្ឋានសាលា ដល់ម៉ោង ១០-៣០ ទើបប្រគេនចង្ហាន់ដល់កិក្ខុសង្ឃ ១០០ អង្គ នៅកន្លែងដដែល ។

នៅពេលរសៀល ម៉ោង ៣ ទឹមន្តធម្មកថឹក ១ អង្គ សំដែងធម៌ទេសនា ។ ម៉ោង ៤ ប្រគេនភេសជ្ជៈដល់ព្រះសង្ឃជូនថ្ងៃទី ១ ដែរ ។ ដល់ម៉ោង ៨ យប់ ព្រះសង្ឃចំនួន ៥០០ អង្គចំរើនព្រះបរិត្តនៅកន្លែងវិហារថ្នាក់លើ ដល់ម៉ោង ១០ យប់ ព្រះសង្ឃគាំង ៥០០ អង្គនោះ ប្រជុំធ្វើសង្ឃកម្មសូត្រចង់ទីមិត្តសីមា ដើម្បីបញ្ចុះនៅកន្លែងវិហារថ្នាក់ខាងក្រោម ។


ដើម្បីទឹងសម្តែងឲ្យឃើញ។ ឡាកែកាតនៃបុណ្យនោះ ពេលចប់សង្ឃកម្ម នៅខាងក្រៅវត្ត មានអុជកាំជ្រួចរន្ទា ហើយទឹងមានប្រាំកំសាន្តកំដរបរិយាកាសនៃបុណ្យនោះផង ។

ប្រៀទី ៣ ថ្ងៃអាទិត្យ ៨ កើតខែពិសាខ (ថ្ងៃទី ១៩ មេសា ១៩៦៤)

នៅព្រឹកនេះ ជាថ្ងៃដែលត្រូវកាត់ឫសសីមា ព្រមទាំងធ្វើព្រះវិហារ

ថ្មីនោះ ដូច្នេះហើយបានជានៅពេលមាំង ៩ ព្រឹក គេឃើញមានពុទ្ធបរិ-
ស័ទមកជួបជុំគ្នានៅទីភ្លាមាង់ដើង់ព្រះវិហារ ត្រៀមខ្លួនរង់ចាំសំដែងតារ
កិច្ច ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ទឹងសម្តេច
ព្រះប្រមុខរដ្ឋ ។ ចំណែកព្រះសង្ឃ យើងសង្កេតឃើញជាអាទិតីសម្តេច
ព្រះសង្ឃរាជទាំងពីរព្រះអង្គជាប្រធាន ហើយចំណែកភាង់ត្រហស្ថមាន
ឥស្សរជនជាន់ខ្ពស់ភាង់ស៊ីវិល ភាង់ឥហានជាច្រើនរូប មានជាអាទិ
តីសម្តេចដហ្វាកំងថែន ខុត ។

លុះដល់ជិតពេលដែលសម្តេចព្រះមាតាជាតិ ទឹងសម្តេចព្រះប្រមុខរដ្ឋ
ទ្រង់ស្តេចយាងដល់ យើងសង្កេតឃើញប្រជាពលករទាំងអតីតនើបឲ្យខ្ពស់
ជាងគេ កែកតយតនបែរខេរកមើលព្រះពជទីនាំងព្រះអង្គ ។ នៅម៉ោង ៩
សម្តេចព្រះមាតាជាតិទឹងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងដល់ ដោយមាន
ឥស្សរជនជាន់ខ្ពស់ជាច្រើនទឹងគណៈកម្មការនៃពិធីបុណ្យ ក្រាបបង្គំគោរព
ព្រះអង្គនៅត្រង់ភ្លារធំភាង់ដើង់ព្រះវិហារ ។ ឥរិយាបថរូបបានថ្វាយបុជមាលាដ៏
វិចិត្រចំពោះព្រះអង្គហើយក្រុមភាហានរក្សាព្រះអង្គថ្វាយគារវកិច្ចតាមប្រពៃ
ណី ។ ក្រុមក្មេងជាតិក៏បន្ទឹសួរសេពថ្វាយជាព្រះពជកិត្តិយស ហើយសម្តេច
ព្រះមាតាជាតិទឹងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងទៅគោរពព្រះចតុយ
ទៅមុខព្រះវិហារដែលជាបរមស្ថបបង្គុះព្រះបរមអដ្ឋិធាតុ នៃសម្តេចព្រះវរ
មាតានៃសម្តេចព្រះមហាក្សត្រិយានី ព្រះសង្ឃចំនួន ៦០ អង្គ បង្សុកូល



ព្រះឃោសនធម្ម ភៅ-សុីម ចៅអធិការវត្តលង្កា កំពុងថ្លែងសុន្ទរកថា ក្នុងឱកាស
ពិធីបុណ្យបញ្ចុះទណ្ឌសីមានៃឧទ្ធរព្រះវិហារវត្តលង្កា នៅថ្ងៃទី ១៩ មេសា ១៩៦៤

សត្តប្បការណ៍ ថ្វាយព្រះកុសលផលព្រះញាណក្ខន្ធនៃព្រះបវរមោគា ។ បន្ទាប់មក សម្តេចព្រះមោគាជាតិនឹងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងនិវត្តមកគង់នៅលើវេទិកាកិត្តិយស ហើយសម្តេចព្រះមហាសង្ឃរាជចាំងពីព្រះអង្គព្រមចាំងព្រះសង្ឃដទៃទៀតចំនួន ១៣ អង្គ ទ្រង់ស្វាធ្យាយ ខ្លួជយន្តោជយមង្គល ថ្វាយជាព្រះបរមសិរីសួស្តី ។

ក្នុងឋានៈជាលៅអធិការនៃវត្តលង្កា ព្រះយោសធម្មព្រះនាម កៅស៊ុម ចាន់ថ្លែងសុន្ទរកថា រៀបរាប់ប្រវត្តិនៃការកសាងវិហារថ្មី (១) ។ លុះចប់សុន្ទរកថានេះហើយ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រទានសង្ឃាថ្វាយប្រកបដោយអត្ថន័យដ៏មានខ្លឹមសារគ្រប់លេន ។ នៅទីបញ្ចាប់នៃសុន្ទរកថារបស់ព្រះអង្គ សម្តេចទ្រង់ព្រះកឋិនព្រះកឋិនទ្រព្យថ្វាយព្រះអង្គចំនួន ៦ ម៉ឺនរៀល គឺ ១ ម៉ឺន ចូលក្នុងពិធីបុណ្យ ១ ម៉ឺន ប្រគេនព្រះយោសធម្មយកទៅជួសជុលកុដិសាលានៅក្នុងអារាមនោះ ។

ដើម្បីបញ្ចាប់ពិធីបុណ្យនេះ សម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងចូលទៅក្នុងព្រះវិហារ ដើម្បីប្រោព្រឹកាត់និមិត្តសីមា ហើយព្រះសង្ឃមានសម្តេចព្រះមហាសង្ឃរាជចាំងពីព្រះអង្គជាប្រធានស្វាធ្យាយធម្មិកខ្លួជយមង្គល ជាកិច្ចបញ្ចាប់ពិធីសម្ពោធឆ្នាំងវិហារថ្មីព្រមចាំងបង្គុំសីមានិងថ្វាយព្រះពរស័ព្ទសាធុការចំពោះសម្តេចចាំងពីព្រះអង្គផង ។

១- សូមរង់ចាំអានសុន្ទរកថាលៅអធិការវត្តលង្កានៅលេខក្រោយ ។

លុះរួចពិធីដ៏ឧត្តមនេះហើយ សម្តេចចាំឆន់ពីព្រះអង្គ ស្តេចទ្រង់នំខាត្តចូលព្រះពាជនវៃសន៍វិញដោយព្រះសុវត្ថិភាព ។

នៅរសៀលថ្ងៃនោះ នាថ្នាក់លើ មានទិមន្តធម្មកថិក ៣អង្គ ទេសនាសង្គ្រាយនា ហើយមានព្រះសង្ឃ ៣០ អង្គគង់ហត្ថបាសផង ។

តាមកម្មវិធី បុណ្យបញ្ចុះសីមាចប់សព្វគ្រប់នៅថ្ងៃនេះហើយ តែដោយថ្ងៃទី ២០-៤-៦៦ ស្អួនទៅលើថ្ងៃខួបនៃព្រះសពសម្តេចព្រះធម្មលិខិតល្វី-តែម អតីតចៅអធិការវត្តលង្កា ទើបគណៈកម្មការបុណ្យមួយអន្ទឹងទុកចាំសិន ក៏បន្តបុណ្យនេះមួយយប់ទៀត ។

នៅយប់ថ្ងៃអាទិត្យទី ១៨ មេសា ១៩៦៦ នេះ មានទិមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចទេសនា នៅពេលព្រឹក ទិមន្តព្រះសង្ឃចំនួន ៨០អង្គ ចិណ្ឌបាត ដើម្បីឧទ្ទិសបុណ្យកុសលប្រគេនដល់ព្រះវិញ្ញាណក្ខន្ធ នៃសម្តេចព្រះធម្មលិខិត ជាកិច្ចបញ្ចប់បុណ្យ ។



សម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ប្រទេសកម្ពុជា ទ្រង់កំពុងគាត់ឫសសីមាកំលៀ ក្នុងឱកាសពិធីបញ្ចុះខណ្ឌសីមាគ្រឹះ
ព្រះវិហារថ្មីវត្តលង្កា ថ្ងៃទី ១៩-៤-៦៤

អំពីព្រះនាមព្រះតេជព្រះគុណ

ដែលបានទទួលសញ្ញាបត្រចាត់តាំងជាចៅអធិការនៃឯគ្រូសូត្រ

ក្នុងព្រះពុទ្ធសាសនា ចក្រ (ត)

៨៣- ព្រះតេជព្រះគុណ សោម សំ នាមធម្មយោគីឧទ្ទេសកើតឆ្នាំ ស. ១៨០៨ អាយុ ៥៥ ឆ្នាំ វស្សា ២៨ បានទទួលតែងតាំងជាចៅអធិការកុដិវត្តអរិយក្សត្រ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៦៧ ចុះថ្ងៃទី ១០-៣-៦៣ ។

៨៤- ព្រះតេជព្រះគុណ ហាម ជាម នាមធម្មយោគីឧទ្ទេសកើតឆ្នាំ ស. ១៨៣៣ អាយុ ៣០ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រធ្វើកុដិវត្តឥន្ទ្រកោសិយ ឃុំកោះជាច់ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៦៨ ចុះថ្ងៃទី ១០-៣-៦៣ ។

៨៥- ព្រះតេជព្រះគុណ ស្រី ខៀវ នាមធម្មយោគីឧទ្ទេសកើតឆ្នាំវក អាយុ ៧៨ ឆ្នាំ វស្សា ៥៨ បានទទួលតែងតាំងជាចៅអធិការកុដិវត្តគ្នោត ឃុំតាកមស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣៤៦៩ ចុះថ្ងៃទី ១៦-៣-៦៣ ។

៨៦- ព្រះតេជព្រះគុណ កែប ហួត នាមធម្មយោគីសុវណ្ណភូមិប្បញ្ញា កើតឆ្នាំឆ្លូវអាយុ ៥០ ឆ្នាំ វស្សា ២៩ បានទទួលតែងតាំងជាគ្រូសូត្រកុដិ

វត្តគ្នោតឃុំពាកម ស្រុកចាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៧០ ចុះថ្ងៃ
ទី ១៦-៣-៦៣ ។

៨៧- ព្រះតេជព្រះគុណ ញឹង ប៉ូរ នាមឆាយា សុវណ្ណជោតិប្ប-
ញ្ញោ កើតឆ្នាំមមែ អាយុ ៥៦ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាគ្រូ
សូត្រធ្វើកងវត្តគ្នោត ឃុំពាកម ស្រុកចាទី ខែត្រតាកែវ លេខសញ្ញាបត្រ
៣៤៧១ ចុះថ្ងៃទី ១៦-៣-៦៣ ។

៨៨- ព្រះតេជព្រះគុណ តន់ ឈួន នាមឆាយាសុជម្មជោតិ កើត
ពីគ.ស. ១៩១២ អាយុ ៥១ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំងជាចៅអធិ
ការកងវត្តកំគួច ឃុំគ្នោត ស្រុកចាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៧៤
ចុះថ្ងៃទី ១៦-៣ ៦៣ ។

៨៩- ព្រះតេជព្រះគុណ កឹម មៅ នាមឆាយា សុវណ្ណតេរកើត
ពីគ ស. ១៩២៧ អាយុ ៣៦ វស្សា ១៦ បានទទួលតែងតាំងជាគ្រូសូត្រ
ស្តាំកងវត្តកំគួចឃុំគ្នោតស្រុកចាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៧៣
ចុះថ្ងៃទី ១៦-៣-៦៣ ។

៩០- ព្រះតេជព្រះគុណ ទិត ជាន់ នាមឆាយាជលធរោ កើតពី
គ.ស. ១៩០៤ អាយុ ៥៩ ឆ្នាំ វស្សា ៣៦ បានទទួលតែងតាំងជាចៅអ
ធិការកងវត្តចំប៉ា ឃុំសូរកើ ស្រុកចាទី ខែត្រតាកែវ លេខសញ្ញាបត្រ
៣៤៧៤ ចុះថ្ងៃទី ១៦-៣-៦៣ ។

៨១- ព្រះតេជព្រះគុណ ស្រ៊ី ខូច នាមឆាយាទ័យវាសប្បោ កើត
ពី គ.ស.១៨៣១ អាយុ ៣៦ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូ
សូត្រស្តាំកងឃុំសូរកើ ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ៣៤៧៥
ចុះថ្ងៃទី ១៦-៣-៦៣ ។

៨២- ព្រះតេជព្រះគុណ ម៉ុក សាមឿន នាមឆាយាមុនីវង្សោ
កើតពី គ.ស. ១៨៣៩ អាយុ ៦៦ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជា
គ្រូសូត្រធ្វើកងវត្តចំបក់ ឃុំសូរកើ ស្រុកបាទី ខែត្រតាកែវ លេខសញ្ញា-
បត្រ៣៤៧៦ ចុះថ្ងៃទី ១៦-៣-៦៣ ។

៨៣- ព្រះតេជព្រះគុណ អ៊ុម តេង នាមឆាយា ឥន្ទវង្សោ កើតឆ្នាំ
រោះ អាយុ ៤៨ ឆ្នាំ វស្សា ១៧ បានទទួលតែងតាំងជាចៅអធិការ វត្ត
វត្តព្រៃជា ឃុំពុទ្ធសរ ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៧៧
ចុះថ្ងៃទី ១៦-៣-៦៣ ។

៨៤- ព្រះតេជព្រះគុណ ឡូញ ចុ៉ក នាមឆាយាយសវង្សោ កើត
ពីគ.ស. ១៨៣៨ អាយុ ២៥ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រ
ស្តាំកងវត្តព្រៃជា ឃុំពុទ្ធសរ ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ
៣៤៧៨ ចុះថ្ងៃទី ១៦-៣-៦៣ ។

៨៥-ព្រះតេជព្រះគុណ អ៊ុក សុផល នាមឆាយាកេសរបញ្ញោ កើត
ពីគ.ស ១៨៣៨ អាយុ២៥ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រ

ធ្វើឆ្នងក្នុងវត្តព្រៃជា ឃុំតុងសរ ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៧០ ចុះថ្ងៃទី ១៦-៣-៦៣ ។

៩៦- ព្រះតេជព្រះគុណ តឹម ឌុល នាមឆាយាខន្តិវត្ត កើតពីឆ.ស. ១៩០៩ អាយុ ៤៩ ឆ្នាំ វស្សា១៣ បានខណ្ឌលតែងតាំងជាចៅអធិការក្នុងវត្តកំភូច ឃុំសូរភី ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៨០ ចុះថ្ងៃទី ១៦-៣-៦៣ ។

៩៧- ព្រះតេជព្រះគុណ ហែម មៀវ នាមឆាយាឥន្ទបញ្ញោ កើតពីព.ស. ២៤៦៦ អាយុ ៥៩ ឆ្នាំ វស្សា ៣ បានខណ្ឌលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តកំភូច ឃុំសូរភី ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៨១ ចុះថ្ងៃទី ១៦-៣-៦៣ ។

៩៨- ព្រះតេជព្រះគុណ កង ឃុត នាមឆាយាធម្មវង្សោ កើតពីឆ.ស. ១៩១៥ អាយុ ៤៨ ឆ្នាំ វស្សា ៣ បានខណ្ឌលតែងតាំងជាគ្រូសូត្រឆ្នងក្នុងវត្តកំភូច ឃុំសូរភី ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៨២ ចុះថ្ងៃទី ១៦-៣-៦៣ ។

៩៩- ព្រះតេជព្រះគុណ មាន់ អ៊ុន នាមឆាយាឥន្ទសរបញ្ញោ កើតពីឆ.ស. ១៨៩៩ អាយុ ៧៩ ឆ្នាំ វស្សា ៥១ បានខណ្ឌលតែងតាំងជាចៅអធិការក្នុងវត្តឈើទាលជ្រៃ ឃុំក្រាំងលាវ ស្រុកបាទី ខែត្រតាកែវ លេខសញ្ញាបត្រ ៣៤៨៣ ចុះថ្ងៃទី ១៦-៣-៦៣ ។

ទំព័រកម្ពុជ

សេចក្តីដូចតទៅនេះ សុទ្ធសឹងជាចម្លើយនៃមិត្តអ្នកអានចាំងឡាយ ចំពោះ ចំណោទគំនិតទី ៣ ដែលមានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា ខែតុ ២៥៤ ឆ្នាំ ខ ៣ ខែមិនា ឆ្នាំ ១៩៦៤ ។

ទី ១ / លោក លី-ប៊ុនប៉ា (ក្រសួងអប់រំជាតិ ភ្នំពេញ)

« ទស្សនាវដ្តី កម្ពុជសុរិយា បន្ទែមមួយទៀត ទ្វៀតចោទបញ្ហា តើជាអ្វីណា ទីសាមសិបបី ។ តែបើគ្មានគេ ខែត្រខ្លះគ្មានទេ កម្ពុជបុរី ភ្នំពេញកំពត ចាត់ដំបងក្តី កម្មអ្វីត្រង់អី ដល់កំពង់ធំ ។ ខែត្រកំពង់ស្តឺ កំពង់ចាមឬ កំពង់ឆ្នាំងសម ឥឡូវមិនបានឡើយ ហើយចិត្តនៃខ្ញុំ ចាន់មកជំនុំ តិតគ្នាឈឺធរ ។ ទីសាមសិបបី គ្មានក្រៅពីអ្វី ប្លាស់ជាតួ « អ្ន » តែវាមិនសម ល្មមដាក់អក្សរ គេឈប់មាត់ការ ត្រូវនាំហាត់ ។ គ្មានអ្នកណាដឹង ខ្ញុំទៅសម្ងឹង សឹងក្តេចចិត្តមាត់ អ្នកចំរើជាតិ សាមបីប្រាកដ ជាន់ចាស់កំណាត់ អានថា ឡ « អ្ន » ។ តែពេលឥឡូវ គេបានតម្រូវ សម្រួចសម្រាំង ឲ្យអាន ឡ « អ្ន » ឈប់ពាក់ ឡ « អ្ន » នេះឬទីតាំង ចំណោទអក្សរ ។ នៅទីបញ្ចប់ ខ្ញុំលើកម្រាមដប់ គោរពស្មោះសរ ដល់អ្នកដើមចោទ តើអាក្រក់ល្អ មេត្តាតបត គឺធិគ្គហិត (១) ។ កុំក្លាយជាក្ន ធំប្រែអានធ កំឆ្នាំងពិនិត្យ ខែត្រចាំងច្រាំពីរ ឥឡូវមិន

---

(១) និគ្គហិត ំ

មានពិត បើខ្ញុំធ្វើគ្រហិត ពិតគ្មានឥចឹង ។ បើត្រូវគួរតែ បានរៀនកល់ ខ្មែ រង្វាន់ធួរតឹង ខស្សនាវដ្តី ថ្មី ត្រាន់ជឹង អស់ពាន់ដំណឹង ព្រោះ ស្តើងធនធាន ។ ឬមួយខ្ញុំសូម ត្រាន់ជាសំណូម ដល់លោកប្រធាន ផ្ញើឲ្យខ្ញុំផង កាលណាខ្ញុំមាន បង់ជូនមិនហ៊ាន ខកខានកូនតកា ។ ខែ ឆ្នូហុកបួន បង់ត្រប់ចំនួន នេះសំណេរមក បើសិនជាព្រម ចិត្តខ្ញុំសោរ បើមិនចង់ល ខ្ញុំពុំពោមនស្ស ។

ទី ២/ លោក ទិត-ហ៊ោង លេខាហ៊ីនៅមន្ទីរពេទ្យព្រះកេតុមាលា ភ្នំពេញ ។

ក្នុងក្រុមអ្នកបំរើជាតិចាំង ៣៣ នាក់ ប្រសិនបើគ្មានខ្ញុំគឺខ្លួនក្នុងក្បាល ហៅ មត្តឡុង្កុំ:ខេ នោះខែត្រចាំង ៣២ ខានដើម មានភ្នំពេញ គឺ កេសាជាដើម ខឹងមិនឡើយ ។

ខ្ញុំជាខ្លួនក្បាល ។

ទី ៣/ លោក សឹក្ខ-សាធ្មឹង មន្ទីរពេទ្យ ព្រះកេតុមាលា

ក្នុងព្យញ្ជនចាំង ៣៣ អក្សរទី ៣៣ គឺអក្ស «អ្ន»

ក្នុងខែត្រចាំងអស់ ក្នុងព្រះពជអាណាចក្រកម្ពុជាយើងចាំងមួល មាន តែខែត្រ ៧ ក្នុងចំណោមខេ ដែលមានស្រៈ «ឧ» ឬស្រៈពេញគួ គឺ ស្រៈ «អ្ន» :

បានសេចក្តីថា ខ្ញុំជាស្រៈ «អ្ន»

ទី ៤/ កុមារ សុភ-សួភិង ជាសិស្សរៀនថ្នាក់ទី ៦ ទំនើបជាតិសៅសាលា

ពញាយ៉ត ។

អ្នកបំរើជាតិទី ៣៣ តឺអក្សរ «អ្ន»

ទី ៥/ ឯកឧត្តម ភឹ-ធៀនឡាយ រដ្ឋលេខាធិការក្រសួងយុត្តិធម៌

អ្នកបំរើជាតិ តូចធំតាមមាឌ ដល់សាមសិបប៉ី អ្នកនៅខាងក្រោយ នោះតើជាអ្វី ប៉ែតាមខ្ញុំស្តី តឺអក្សរ «អ្ន» ។ អក្សរនេះឯង អ្នកច្រើជ្រុតខែង តែងស្រាក់លំអ ធ្វើជាដើមស្រាក់ ពប់តាំងពី «ក» តួងនឧបអ យកស្រាក់ពីនេះ ។ អញអិអី ពាក្យពេចស្រដី ច្រើជច្រើយ ជំរេះ ពប់អំអាំអះ កើតជាចំណេះ រៀនសូត្រចានចេះ ចានចប់គ្រប់គ្នា ។ ឥតពីស្រាក់«ន្ន» គ្មានត្រឹងអ្វីធ្យុំ ឲ្យកើតចានជា ឲ្យកើតក្រុងផង ក្នុងកម្ពុជា ដូចលោកពណិនា នោះទើចានឡើយ ។ ហេតុនេះខ្ញុំពាយ ខ្ញុំមិនពាយមាយ ខ្ញុំមិនកន្តើយ ថាពាក្យចោទសួរ នៅជិតបង្កើយ រូបអ្នកនេះហើយ តឺអក្សរ «អ្ន» ។

ទី ៦/ លោក ប៉ែត្ន-សារ៉ាវុធ ក្រសួងការពារប្រទេស

ក្នុងក្រុមអ្នកបំរើជាតិចាំង ៣៣ នាក់ ឯអ្នកទី ៣៣ តឺអក្សរ «អ្ន» ។

ទី ៧/ ព្រះគេជព្រះគុណ ពេជ្រ-សម៉ន់ ធង់នៅវត្តកោះ ពុធិ៍លេខ ១៩ ក្រុងភ្នំពេញ សង្កាត់លេខ ៣ ។

ក្នុងក្រុមអ្នកបំរើជាតិចាំង ៣៣ នាក់ ខ្ញុំជាអ្នកទី ៣៣ ។ ប៉ែសិនគ្មានខ្ញុំទេ កុំពេញក្តី ខេត្តចាត់ដំបងក្តី កំពង់ចាមក្តី កំពតក្តី កំពង់-

ឆ្នាំងក្តី កំពង់ធំក្តី កំពង់ស្ពឺក្តី ទឹងពុំមានខ្សោយ ។ តើខ្ញុំជាអ្វី ?

អធិប្បាយដោយខ្លី សង្ខេបគឺ : «ខ្ញុំជាស្រះអ្នក»

ទី ៨/ លោក ហេង-សមអាង សេនាធិការយោធភូមិភាគទី ១

អ្នកចំរើជាតិទី ៣៣ គឺអក្សរ «អ្ន»

ទី ៩/ លោក ព្រុំ-សាយ លេខាហារី សាលាស្រុកព្រះនេតព្រះ (ជាប់ជិតបង)

អ្នកចំរើជាតិទី ៣៣ គឺស្រះអាង (ខ)

សេចក្តីថ្លែងអំណរគុណ

កម្មជសុរិយា សូមថ្លែងអំណរគុណ ទឹងកោតសរសើរយ៉ាងពន់ពេក ចំពោះគំនិតឆ្នាតពាងវៃ នៃលោក លី-ប៊ុនចាំ លោក ច័ន្ទ-សាផុន នាយ សុក-សូកិន ឯកឧត្តម ភី-ឆៀនឡាយ លោក ច័ន្ទ-សាកវុធ ព្រះតេជព្រះគុណ តេជ្រ-សមន៍ លោក ហេង-សមអាន ទឹងលោក ព្រុំ-សាយ ដែលមានសោមនស្សចេតនា ខំដោះស្រាយនូវចំណុចគំនិតទី ៣ របស់យើង ហើយបានយោបល់ដ៏ចង់ឆ្ងោះបើមានអស់លោកខ្លះក្នុងចំណោមនេះ មិនសូវល្អាសនៃក្នុងពិធីវេយ្យាករណ៍ខ្មែរ គឺយើងសន្និដ្ឋានថាអស់លោក សុទ្ធតែយល់ត្រូវគាំងអស់ ។

សេចក្តីបញ្ជាក់

សូមបញ្ជាក់ថា តាមច្បាប់វេយ្យាករណ៍ ឯព្យញ្ជនៈទី ៣៣ នោះ

គឺ "ដិគ្គីហ៊ីតិ" ហើយនិគ្គហិតនេះ លោកឲ្យសរសេរជា "ឧ" រួចត្រូវ
អានឲ្យឮសូរដូចជាមានតួ "ង" ប្រកប។ លុះឡាយៗមក ស្រាប់តែយើញ
សរសេរជាតួ "ង" តែម្តង នៅត្រង់កន្ទែង "ឧ" នោះ មិនដឹងជាបណ្តាល
មកពីហេតុអ្វី ។

សូមបញ្ជាក់ទី ២ ថា: បម្រើយដែលចុះផ្សាយខាងដើមប៉ុន្មាននេះ នោះ
ប៉ាមានសេចក្តីជាពាក្យពេយ ខ្លឹងជាពាក្យគាត្យសមរម្យក្តី មិនសមរម្យក្តី
មានខាស់សេចក្តីក្តី ខុសអក្ខរាវិរុទ្ធក្តី សូមមិត្តអ្នកអានខាំងឡាយអភ័យ
ទោស ព្រោះយើងចុះផ្សាយខាំងស្រុង តាមបម្រើយដើមរបស់អស់លោក
ម្នាក់ៗ ដែលសរសេរផ្ញើទៅ ឥតកែសម្រួល ខ្លឹងតែតម្រូវឡើយ ដ្បិតខំព័រ
អស់នេះ ជាភាគកម្សាន្ត ។

សូមបញ្ជាក់ទី ៣ ចំពោះលោក ខិត-ហេងថា អាការៈកន្លងមួនយើង
មានតែ ៣៤ ទេ ហើយនៅប្រទេសកម្ពុជា ក៏គ្មានទៀត្រដល់ទៅ ៣៤
ឡើយ ដូច្នេះកម្ពុជសុរិយាសង្ឃឹមថា កន្លងចំណាទលើកក្រោយ ព្រោះ
លើកនេះលោកយល់កាន់ លោកតិតជាខ្លឹងកែយើញដោយត្រឹមត្រូវប្រាកដ ។

សូមបញ្ជាក់ទី ៤ ចំពោះលោក លី.ចិនថ្ម៉ាថា: គួរណាស់តែអនុលោម
តាមសំណូមពរបស់លោកស្តីពីផ្នែងន់ទស្សនាដ្ឋីកម្ពុជសុរិយា តែយើង
មានសេចក្តីស្តាយខាន់ខាក ដោយពុំអាចបំពេញបំណងលោកបាន ព្រោះ

តាមច្បាប់ខាងក្នុងថា: ខ្ញុំមិនអាចជូនខសៀវភៅដែលជារង្វាន់ដល់អ្នកអានណាបាន លុះត្រាតែអ្នកអាននោះ មានអត្ថបទយកទៅចុះផ្សាយអស់រយៈពេលមួយឆ្នាំ បើលោកសុំជាវវិញ យើងខ្ញុំមិនអាចជូនដល់លោកបាន ក្នុងរយៈកន្លះឆ្នាំមុន មិនខាន់បន់ថ្លៃ ។ ដូច្នេះសូមលោកធ្វើលិខិតសុំជាវត្រឹមត្រូវទៅ យើងខ្ញុំនឹងផ្តល់ជូនលោកភ្លាមៗ ចាប់ពីលេខ ១ ទៅ តាមចំណង់របស់លោក ។

បំណោទគំនិតទី ៤

ខ្ញុំជាអ្នកដំណើរ តែងបញ្ជូនគំនាំគេកាលរួបឲ្យទៅជាមួយផង កាលបើត្រមទៅជាមួយហើយ ខ្ញុំនាំទៅរហូត មិនដែលជូនត្រឡប់មកវិញម្តងណាឡើយ ទោះបីតែអង្វរយំតួញយ៉ាងណាក៏ដោយ។

តើខ្ញុំជាអ្វី?

បើមិត្តអ្នកអានណារកឃើញ និងចុះផ្សាយនូវសេចក្តីសរសើរផ្ញើន ។

ទំព័រកម្ពុជ

សេចក្តីដូចតទៅនេះ សុទ្ធសឹងជាចម្លើយនៃមិត្តអ្នកអានចាំងឡាយ ចំពោះ ចំណោទគំនិតទី ៣ ដែលមានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា ទំព័រ ៤៦៤ លេខ ៣ ខែមិនា ឆ្នាំ ១៩៦៤ ។

ទី ១ / លោក លី-ប៊ុនប៉ា (ក្រសួងអប់រំជាតិ ភ្នំពេញ)

« ទស្សនាវដ្តី កម្ពុជសុរិយា បានមួយខែត ឆ្លៀតចាខបញ្ហា តើជាអ្វីណា ទីសាមសិបបី ។ តែបើគ្មានគេ ខែត្រខ្លះគ្មានខេ កម្ពុជបុរី ភ្នំពេញកំពត ចាត់ដំបងក្តី កម្មអ្វីត្រង់អី ដល់កំពង់ធំ ។ ខែត្រកំពង់ស្តឺ កំពង់ចាមឬ កំពង់ឆ្នាំងសម ឧដុងមិនបានឡើយ ហើយចិត្តនៃខ្ញុំ ចានមកជំនុំ គិតគ្នាឈឺធរ ។ ទីសាមសិបបី គ្មានក្រៅពីអ្វី ឬស្រស់ជាតួ « អ្ន » តែកមិនសម ល្មមជាក់អក្សរ គេឈប់មាត់ករ ត្រង់ទៅហត់ ។ គ្មានអ្នកណាជឹង ខ្ញុំទៅសម្លឹង សឹងក្អេចចិត្តមាត់ អ្នកប៉ះជាតិសាមបីប្រាកដ ជាខ្ចាស់កំណត់ គានថា ឲ្យ « អ្ន » ។ តែពេលឥឡូវ គេបានតម្រូវ សម្រួចសម្រាំង ឲ្យគាន ឲ្យ « អ្ន » ឈប់កប់ ឲ្យ « អ្ន » នេះឬទីតាំង ចំណោទអក្សរ ។ នៅទីបញ្ចប់ ខ្ញុំលើកម្រាមដប់ គោរពស្មោះសរ ដល់អ្នកដើមចាខតើអាក្រក់ល្អ មេត្តាតបត តិធិគ្គហិត (១) ។ ភ្នំក្រាយជាក្ត ធំប្រែគានឆ កំឆ្នាំងពិនិត្យ ខែត្រតាំងច្រាំពីរ ឧដុងមិន

---

១) និគ្គហិត ំ

តម្រងសទ្ធិយា

ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៦ លេខ ៦ ខែ មិថុនា

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ភ្នំពេញ -

សេចក្តីប្តឹងសួរ

សូមព្រះតេជៈដ៏តស់លើសួរ


សូមព្រះពុទ្ធជាន់ក្រោមបង្គំទូលថ្វាយ សម្តេចព្រះមហាវីរៈជាព្រះនាយកនៃតួមសីហនុ ព្រះប្រមុខដួងកម្ពុជា ក្រោមល្អងធូលីព្រះបាទ

សូមទ្រង់ជ្រាប ។

ក្នុងឧកាសដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាប្រទេសថៃក៏ដោយ ដើម្បីញ៉ាំងព្រះកេតដែលយាយីព្រះសុខភាពព្រះអង្គនោះ ទូលព្រះបង្គំខ្ញាំងខ្ញាយ ក្រុមពុទ្ធសាសនបណ្ឌិត្យ ដោយនៅឆ្ងាយ មិនអាចគាល់ប៉ះប៉ោលជាន សូមសំបួងសម្រួងតិចម្ងាយ ដល់គុណព្រះរតនត្រ័យ ប្រកបដោយមហិទ្ធិពលក្រៃលែង ទឹងវត្ថុសក្តិសិទ្ធិក្នុងលោកដែលជាសម្ភូតិដ្ឋិមានទេពារក្សាព្រះមហាសួតច្បងត្រជាដើម សូមជួយថែរក្សាទឹងការពារព្រះអង្គសម្តេចជាទីស្នេហាស្មើដីតែទឹងសត្រូវគ្រប់យ៉ាង ព្រមទាំងសូមជួយញ៉ាំងព្រះពេតឲ្យវិនាសខ្ចាតឆ្ងាយពីព្រះកាយព្រះអង្គ ក្នុងរយៈពេលដ៏ខ្លី សូមព្រះសុខភាពដ៏លើសលប់ត្រឡប់កើតមានយ៉ាងឆាប់ ចំពោះព្រះអង្គដើម្បីទ្រង់សប្បាយព្រះកាយ ក្នុងព្រះដំណើរការជាព្រះបរមសុខតរៀងទៅ.

សូមព្រះទេវន្តរក្ខិច្ចនៃព្រះអង្គ នៅបារទេសនេះ ជួបប្រទះតែទឹងជោគជ័យដូចព្រះពាជបំណង ហើយសូមព្រះអង្គទ្រង់ព្រះទិវង្គតមកមាតុប្រទេសវិញ. ដោយព្រះសុវត្ថិភាព ។

ពុទ្ធសាសនបណ្ឌិត្យ



ភ័ទ្ធសុទិយរ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ជ.ក្រ បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

	ទំព័រ
ផ្នែកសាសនា	
- សុខុប្បត្តិមូលកថា ព្រះមហា នៅ-ជា រៀបរៀង	៥៨៣
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ី តែងរៀបរៀង (ត)	៦០១
- អ្នកមានគុណ តែងដោយលោក ហេង-សមអាន នៅសេនាធិការ ខេត្តកំពង់ចាម (ត)	៦០៧
- ព្រះវិន្ធូជាតក (ត)	៦១៤
ផ្នែកអក្សរសាស្ត្រ	
- សមត្ថភាពគំអ៊ូ ព្រះមុនីកោសល សូ-ហាយ អធិបតីរង ក្រុមជំនុំព្រះត្រៃបិដក តែងៈ	៦២១
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	៦២៧
- រឿងអាថ៌លហ្គាំអូរីស៍ លោក ភ័ឃ-ល្មុត ជំណាងភាស្ត្រ ប្រែរៀបរៀង (ត)	៦៣៩
- រឿងបង្ហូនពីរនាក់ ចែកមតិកថ្នា លោក ផេង-គ្រីវ៉ តែងថ្មី	៦៣៥
- រឿងសាមកុក អ្នកឯកញ្ញាវិបុលវាដសេនា ស្វ-កន ប្រែរៀបរៀង (ត)	៦៤៣
- ព្រះរាជនិពន្ធ ភាមល្លី ស្រាវជ្រាវ ដោយលោក ឧ-គាម (ត)	៦៥១
- សេចក្តីយុត្តិធម៌នឹងប្រាក់ លោក ភ័ឃ-ប៊ុក ប្រែរៀបរៀង	៦៦៧
- ទំនៀមទម្លាប់ខ្មែរៈ ប្រកាសប្រឡងទំនៀមទម្លាប់ខ្មែរ	៦៧៣
ផ្នែកកំណត់ទីឯប្រវត្តិការណ៍	
- ព្រះពិធីថ្វាយគ្រឿងឥស្សរិយភណ្ឌ ចំពោះសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ រៀបរៀងដោយ ឧ៊ិក-គាម (នៅមានត)	៦៨១
- សុន្ទរកថា នៃព្រះឃោសធម្ម ភៅ-សឹម ចៅអធិការវត្តលង្កា	៦៨៧
- រឿងតាំងចៅអធិការ និងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ (ត)	៦៩១

តម្លៃមាន ១២ សៅរ៍ភៅ តម្លៃជាវ ៤៣០រ៉ៀល

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការលាមក	ឲ្យធ្វើល្អវិញ
ឲ្យរុំសាត់ចិត្ត	កុំឲ្យហ្មងសៅ
ប៉ះនេះលោកហៅ	ពុទ្ធសាសនា

សុខុប្បត្តិមូលកថា

ព្រះមហា ដៅ · ជា តន់វត្តទ ណ្ណាលោម តែងរៀបរៀង

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការ ចំពោះព្រះភគវន្តមុនី សម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ នឹងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

អំពីបទនមស្សការនេះ នឹងសូមអត្ថាធិប្បាយនូវដើមកំណើត នៃសេចក្តីសុខ តាមពុទ្ធភាសិត ដូចតទៅនេះ ៖

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា

សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។

ប្រែថា : ការទប្បត្តិឡើងឬកើយោគ្រាស់ដឹងឡើង នៃព្រះពុទ្ធទាំងឡាយ ក្នុងលោក ជាហេតុនាំមកនូវសេចក្តីសុខ ។

កើយោសំដែងនូវព្រះសទ្ធម្ម នៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្តីសុខ ។

ការប្រមូលផ្តុំគ្នាជាពួកជាក្រុម (ពួតដៃគ្នា រួបរួមគ្នា ស្រុះស្រួលគ្នា) ជាហេតុនាំឲ្យកើតសេចក្តីសុខ ។

ក្នុងថ្ងៃនៃពុទ្ធកាលនេះ ចែកចេញជា ៤ ឃ្លា ក្នុងឃ្លាមួយ ។ សុទ្ធតែបញ្ជាក់អំពីហេតុដែលនាំឲ្យកើតសេចក្តីសុខទាំងអស់ ។

ជាដំបូង សូមលើកយកឃ្លាទី ១ មកសំដែង ដូចតទៅនេះ ទី ១ សុខោ ពុទ្ធានមុប្បាទោ ការដែលបានត្រាស់(១)ដឹងឡើងនៃព្រះពុទ្ធទាំងឡាយត្រង់ព្រះអង្គ ជាហេតុនាំឲ្យកើតសេចក្តីសុខ ជាប្រយោជន៍ដល់សត្វសត្វក្នុងត្រៃភព ។

អធិប្បាយថា : ក្នុងកាលណាមួយ ។ ដែលមានព្រះសម្ពុទ្ធបានត្រាស់ដឹងឡើង ក្នុងកាលនោះ សត្វមានសេចក្តីចំរើនឥតគណនា តែងបានជួបប្រទះប្រយោជន៍ធំធំសេចក្តីសុខយ៉ាងក្រៃលែង ព្រោះព្រះអង្គបានឧប្បត្តិឡើង ទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរឲ្យស្ញើច ជាទីបូជារបស់ជនជាមនុស្ស ទេវតា ព្រហ្ម ព្រមទាំងមានព្រះទ័យពេញប្រៀបដោយសេចក្តីករុណា ទៅរកសត្វលោកឥតរើសមុខ ព្រះដ៏មានព្រះភាគទ្រង់បានជួបប្រទះសេចក្តីក្សេមក្សាន្ត ដ៏ខ្ពង់ខ្ពស់ផុត ក្នុងចំណោមមនុស្សដោយគោត្រត្រកូល ភជសម្បត្តិជាដើម ក៏ព្រោះតម្រៃសេចក្តីល្អ (បុណ្យ) ដែលទ្រង់បានកសាងសន្សំជាលំដាប់ជាតិតៗ មកដោយពិត ។

---

១) ត្រង់នេះបើថា " ការកើតឡើង " មានន័យទូលាយជាង ។

មហាការុណិកោ ជាទេវ ព្រះលោកនាថប្រកបដោយមហាករុណាគុណ ទោះបីព្រះអង្គបានប្រកបដោយសេចក្តីសុខស្រួលយ៉ាងណាក៏ដោយ ទ្រង់ក៏មិនទម្រន់ទ្បើលធ្វើដកជាប់ព្រះទ័យ ទ្បើតាលែតលធ្វើតំនិតដល់ទៅក្នុងសេចក្តីសុខទុក្ខរបស់សត្វដែលលិចលង់ ក្នុងលោកសន្និវាសនេះទេ ព្រះអង្គមិនត្រមះសោយសុខថ្កុំថ្កើង ដែលបានតាំងនៅសិប់កន្លងកណ្តាលព្រះហស្តនៃព្រះអង្គតែមួយព្រះអង្គឯងប៉ុណ្ណោះទេ ទ្រង់ស៊ូលះបង់ប្រយោជន៍តាំងនោះមិនខឹកនា ទំប្រឹងប៉ំពេញព្យាយាមតាលែតសម្រេចប្រាជ្ញាសម្ពោធិញ្ញាណលើតេនបល្ល័ង្ក ព្រះអង្គបានតាំងជាសត្វនាយក ដឹកនាំស្រោចស្រង់សត្វតាំងឡាយឲ្យទៅកន្លងវិត្រតភ ទ្បើរួចផុតអំពីសេចក្តីទុក្ខលំបាកកើតចាស់ឈឺស្លាប់ ។

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធ ស្តេចយាងប្រកាសសាសនា ប្រទានធម្ម ប្រៀនប្រដៅណែនាំពួកសត្វ មានមនុស្សនិងទេវតាជាដើម ទំប្រឹងព្យាយាមសំដែងធម៌ប៉ុន្មានទ្បើលប្រាប់បាថ-បុណ្យ គុណទោស ល្អអាក្រក់ ទុសត្រូវ ទ្បើសត្វយល់ឃើញតាម ។ ឥតរួញរាធនិងសេចក្តីខ្មីឃ្មាតព្រួយព្រះកាយពាល ក្នុងការប្រកាសប្រាប់ប្រយោជន៍ដល់សត្វតាំងនោះឡើយ ។ ព្រះអង្គទ្រង់ប៉ំពេញពុទ្ធកិច្ច ៥ គ្រប់គ្រាន់ សមសក្តិជាសត្វនាយក អ្នកដឹកនាំស្រោចស្រង់ ជាតំនិងនៃសត្វក្នុងវិត្រតភមែន តាំងមានវត្តយោបថស្រគត់ស្រគំសមមេរ្យ មានព្រះអជ្ឈាស្រ័យទន់ភ្លន់ស្មោះស្ម័គ្រស្ងួតត្រង់ទៅ

រកពួកសត្វទួលទៅក្នុងត្រៃភព គួរតាប់ចិត្តល្មមឲ្យមនុស្សខ្លះតាម ទំនងសត្វ
គ្រប់ឈ្មោះ មានសេចក្តីសង្ឃឹមយ៉ាងកក់ក្តៅ ចូលទៅជ្រកកោនក្រោម
ពោធិសម្ភារ ជាន់សន្តិសុខតាមប្រាថ្នា ព្រះអង្គមានព្រំទំនងឲ្យសត្វលោកយក
តំរាប់តាម ដោយសេចក្តីពេញចិត្តមិនចាប់ចង្អុំ ព្រះពុទ្ធគុណដែលសំដែង
មកខាងលើនេះ បើពោលបំព្រួញឲ្យខ្លីជាយចំណាំមកពៀតថា : ព្រះ
សម្មាសម្ពុទ្ធ មានព្រះវិជ្ជាស្អាត មិនប្រឡាក់ដោយបាប-អំពើអាក្រក់ណា
មួយហៅថា « វិសុទ្ធិគុណ » ។ ទ្រង់ទំបំពេញប្រយោជន៍ដល់សត្វលោក
តាមផ្លូវតែងលោក តែងធម៌ស្មើ ៗ គ្នា តាមសមគួរដល់ទិស្សជ្ជនៃសត្វ មិន
តែងប្រយោជន៍ផ្ទាល់ព្រះអង្គហៅថា « ករុណាគុណ » ។ ទ្រង់មានឧបាយ
ដ៏ប្រពៃក្នុងការទូន្មានសត្វ ធ្វើសេចក្តីដែលស្រួលឲ្យកក់ អាចរំចាំងឲ្យ
ងាយយល់ ងាយតែងជាដើមហៅថា « បញ្ញាគុណ » ។

ម៉្យាងទៀត ការកើតឡើងឬការបានត្រាស់ដឹងឡើងក្នុងលោក នៃ
ព្រះពុទ្ធទាំងឡាយ ជាការកម្រក្រៃកម្រៃថែមទៀតផង ។ ព្រោះថាព្រះពុទ្ធ
មួយអង្គ ។ មុនទទឹងបានក្លាយទៅជាព្រះពុទ្ធនោះ តែងមានការតេសាងសន្សំ
បន្ទូចារមី អស់កប់សុទ្ធតែអសង្ខ្យេយ្យ ទំនងកម្រៃកប់សែនកប្ប ទើបបាន
សម្រេច ។ ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់មានព្រះពុទ្ធតម្រាស់
ជាមួយស្តេចនាគរាជមួយឈ្មោះ ឯរកបត្ត ខុតក្នុងធម្មបទខុទ្ទកនិកាយឆដ្ឋម
ភាគ ក្នុងពុទ្ធវគ្គ ត្រង់ទំព័រ ១៩១ ថា ម្នាលមហារាជ សត្វលោកមិនងាយ

បានកើតកមជាមនុស្សទេ កើតមកជាមនុស្សហើយ មិនងាយបានស្តាប់ព្រះសទ្ធម្ម ឱដ៏មិនងាយបានជួបប្រទះនូវការកើតឡើង នៃព្រះពុទ្ធទាំង៤ព្រះអង្គ ក្រៃពេកណាស់ រួចហើយព្រះអង្គទ្រង់សំដែងធម៌ទេសនា ជាបទព្រះគាថាតទៅទៀតថា :

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

ប្រែថា : ការកើតមក ជាមនុស្ស ជាការក្រ ការចិញ្ចឹមជីវិតរបស់សត្វទាំង៤ ជាការលំបាក ការស្តាប់នូវធម៌ ជាកិច្ចដ៏កម្រ ការបានត្រាស់ដឹងឡើងនៃព្រះពុទ្ធទាំង៤ ក៏ជាការកម្រ ។

អធិប្បាយថា : សត្វទាំង៤ ក្រៃពេកណាស់ លុះបានកើតមកជាមនុស្សហើយ លំបាកនឹងចិញ្ចឹមជីវិត លំបាកនឹងរស់នៅឲ្យបានស្រួល លំបាកនឹងរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីដោះស្រាយបញ្ហាជីវិត ឲ្យបានជួបប្រទះសុភមង្គល ឱដ៏សេចក្តីចំរើនៗ មិនតែប៉ុណ្ណោះ បានរស់នៅសួរសុខទុក្ខហើយ មិនងាយនឹងបានស្តាប់នូវពាក្យប្រៀនប្រដៅណាមួយ ដែលប្រកបដោយហេតុផលត្រឹមត្រូវល្អ ពោលគឺព្រះសទ្ធម្មជាធម៌ពិត ព្រោះកម្រនឹងមានបុគ្គលដទៃឯណាមួយក្រៅពីព្រះពុទ្ធ តាបនឹងរំសែងបង្ហើយយល់ត្រាស់ដឹងពិតប្រាកដបាន ។ ព្រះសទ្ធម្ម

នេះ ជាធម៌ពិតមួយ ប្រសូតចេញពីព្រះឧស្សរបស់ព្រះពុទ្ធ ។ ដោយសារតែ ព្រះសទ្ធម្មជាធម៌ពិត ជាធម៌ដែលគេមិនងាយនឹងបានស្គាប់ ព្រមទាំងជា ធម៌ដែលប្រសូតចេញពីព្រះពុទ្ធជនោះ ដូច្នេះបានជាព្រះពុទ្ធទាំងឡាយ កម្រនឹងបានត្រាស់ដឹងឡើងក្នុងលោកដែរ ។ ព្រោះហេតុនោះ បើព្រះ ពុទ្ធត្រាស់ដឹងឡើងក្នុងលោកហើយ សត្វលោកឈ្មោះថាបានខាងភាគ សម្បើម ។

ហេតុដូចសំដែងមកខាងលើនេះ ទើបប្រកាសដថាព្រះពុទ្ធត្រង់អង្គបាន ត្រាស់ដឹងឡើងក្នុងលោក ជាហេតុនាំឲ្យបានសេចក្តីសុខដល់ពពួកសត្វ។

ទី ២ សុខា សទ្ធម្មទេសនា តំរិយាសំដែងនូវព្រះសទ្ធម្ម នៃ ព្រះពុទ្ធទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្តីសុខ ។

អធិប្បាយថា : កាលណាព្រះពុទ្ធទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ហើយ ព្រះអង្គទ្រង់សំដែងធម៌ទេសនាប្រៀនប្រដៅពពួកសត្វឲ្យចេះដឹង យល់យ៉ាងច្បាស់លាស់ថា ធម៌នេះពិត ធម៌នេះមិនពិត ធម៌នេះមានហេតុ ផល ធម៌នេះប្រាសចាកហេតុផល ។

ស្វាក្ខាតោ ភគវតា ធម្មោ ធម៌ដែលព្រះមានព្រះភាគ សំដែង ហើយដោយប្រពៃ ជាធម៌ពិត ជាសច្ចធម៌ ព្រមទាំងមានគុណានុភាព អាចយកឥន្ទ្រោងស្រោចស្រង់សត្វដែលគាន់តាម ប្រតិបត្តិតាម ធ្វើតាម ឲ្យផុតចាកទុក្ខទោស ហើយផ្តល់ឲ្យយ៉ាងជាក់ច្បាស់នូវសេចក្តីសុខ តាម

នាទីថ្នាក់នៃសេចក្តីប្រតិបត្តិរបស់ខ្លួន សមដូចពាក្យភាសិតថា ឯម្នោ
សុចិណ្ណោ សុខមាវហាតិ ធម៌ដែលសត្វបានរក្សាត្រឹមត្រូវហើយ
រមែងផ្តល់សេចក្តីសុខមកវិញពុំខាន ។ ធម៌ក្នុងទីនេះ ប្រែថា អំពើល្អ
គោលតឺបុណ្យ អ្នកដែលប្រព្រឹត្តតាមធម៌ ឈ្មោះថាបានរក្សាធម៌ខុកជោយ
ប្រពៃ ទីដ៏ត្រូវបានផលមកជាសេចក្តីសុខ ។ អំពើអាក្រក់ហៅថាអធម៌
តឺមិនមែនធម៌ អ្នកដែលប្រព្រឹត្តតាមអធម៌នោះ ឈ្មោះថាបានប្រមូល
មកនូវអកុសលកម្មទីដ៏ត្រូវបានផលមកជាសេចក្តីទុក្ខ ។ ពុទ្ធបរិស័ទជាំង
ឡាយ ដែលតាប់អធ្យាស្រ័យចង់បានប្រយោជន៍សេចក្តីសុខ-ចំរើន
ក្នុងលោកនេះក្តី ក្នុងបរលោកក្តី គួរទំរក្សាទុកនូវធម៌នេះឲ្យមំតំចត់
ព្រោះវិបាករបស់ការរក្សាធម៌នេះ តឺសេចក្តីសុខចំរើន តិតប្រាកដ ។
សេចក្តីដែលបានពណ៌នាមកប៉ុណ្ណេះ ត្រឹមត្រង់តាមដើមនៃពុទ្ធចំណង
ពិត ។ ព្រះអង្គដែលទំព្យាយាមសំដែងប្លាប់ប្រាប់ពន្យល់យ៉ាងនេះ ដោយ
មានព្រះទ័យករុណាចង់ដោះសត្វដែលជាប់ចំណង សេចក្តីទុក្ខ មាន
ជាតិ ជរា ព្យាធិ មរណៈ ជាដើម ឲ្យរួចចាកទុក្ខបាន ។

សូមពុទ្ធបរិស័ទអ្នកអាន ! អានហើយកំណត់ទុកក្នុងចិត្តចុះ ! ថា
ព្រះពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្ស សត្វ កើតមកក្នុងលោក សុទ្ធសឹង
ប្រាថ្នាសេចក្តីសុខ-ចំរើន ខ្ពង់ខ្ពស់-ថ្លៃថ្នូរគ្រប់រូប ដែលមែរនៅជាអាប់ខ្មៅ
មិនដូចចំណង់ទៅវិញនោះ បណ្តាលមកពីហេតុច្រើនយ៉ាងណាស់ ខ្លះ

កើតមកដោយសេចក្តីក្រីក្រខ្វះខាតល្ងង់ខ្លៅស្រាប់ មកអំពីកំណើត គឺមានគ្រោះផលនៃអំពើស្អ មានតិចតួចជាតិ ខ្លះកើតមកបានជួបប្រទះនឹងសេចក្តីសុខ-ចំរើន ថ្កុំថ្កើងសម្បូណ៌ដោយសម្បត្តិគ្រប់គ្រាន់ស្រាប់ អំពីកំណើត តែធ្វេសប្រហែសក្នុងតិតរើខ្លួន បណ្តោយចិត្តឲ្យទៅប្រព្រឹត្តទាស់វិន័យ ពាន់ទៅលើអំពើមិនមែនជាធម៌ មានការថ្នាំរង្គាយថ្នាក់ខ្លួនជាអ្នកខ្វះខាតអាប់ឧន្ទខ្លួចទៅវិញក៏មាន ខ្លះរបប់ខ្លួនឲ្យនៅត្រឹមតែស្មើ ។ មិនខាតមិនខ្ពស់ក៏មាន តាមសមគួរដល់អំពើដែលសត្វធ្លាប់រៀង ។ ខ្លួន ដូចពុទ្ធភាសិតថា កម្មំ សត្តេ វិភជ្ជតិ អំពើដែលសត្វធ្វើទុកមក ជាមេចំណែកចែកឲ្យបានសុខ ឬបានទុក្ខផ្សេង ។ គ្នា មិនមានអ្វីផ្សេងពីកម្ម ឬការងារបស់ខ្លួនទោះចែកឲ្យខ្លាយ ។ ឯអំពើលាមកអាក្រក់ មិនត្រូវតាមធម៌ នាំឲ្យមនុស្សវិនាស បានសេចក្តីទុក្ខលំបាក ។ ដូច្នេះ សេចក្តីវិនាសលាញ់អន្តរាយ គឺជាសេចក្តីទុក្ខ សេចក្តីទុក្ខ គឺមិនមែនជាការស្រួល ការសប្បាយរីករាយទេ ។ ព្រោះហេតុនោះ ដើម្បីនឹងរក្សាទុកខ្លួនវិសេចក្តីសុខនេះ ឲ្យបានមាំមួន គោងតែព្យាយាមលះខ្លួនអំពើអាយមុខធម៌ ដែលជាដើមធម៌ នៃសេចក្តីវិនាសដ៏ធំបំផុត ដូចមានសំដែងទុកក្នុងបាកវិសូត្រថា :

ឥត្តិដ្ឋោ សុភដ្ឋោ អត្ថាដ្ឋោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ

ប្រែថា : អ្នកចូលចិត្តនឹងមាតុគ្រាម មិនមានចិត្តសន្តោសត្រឹមតែ

ភវិយោវបស់ខ្លួន អ្នកសេពគ្រឿងស្រវឹង អ្នកលេងល្បែងក្តាល់ រមែង
ញ៉ាំងវត្ថុដែលខ្លួនបាននោះ ឲ្យវិនាស អង្គាយមុខប្រកែកនេះ ជាប្រ
ធាននៃសេចក្តីវិនាស ហើយជាពាសេស តែកុំតប់កេមនុស្សអន្ធពាល
លាមកជាមិត្រ ហេតុទាំងអម្បាលនេះ ជាដើមចមប្តូជាប្រធាននៃ
សេចក្តីវិនាស ដែលផ្តួយអំពីសេចក្តីសុខនោះ ។ មិនតែប៉ុណ្ណោះ ថែម
ទាំងញ៉ាំងសង្គមមនុស្ស ទ្រព្យសម្បត្តិ ចំណេះវិជ្ជា ឥទ្ធិវត្តុវិយោ
សណ្តាប់ធ្នាប់ ឲ្យស្រុតស្រុតចុះថោកទាប ថ្លោះឆ្ងាយទាំងវិនាស
ថ្លោះឆ្ងាយចូចបង់សេចក្តីសុខ-ចំរើន រមែងមនុស្សក្នុងសកលលោកជាក់
ស្តែងក្លាម ។ មិនចាំបាច់តោលថ្លដល់ទៅលោកខាងមុខឡើយ ។ អំពើ
នេះ បើសត្វទំប្រឹងប្រព្រឹត្តធ្វើមិនលែង លោកតោលថា ខុកដូចជាយក
គល់ភ្លើងយ៉ាងធំ មកដុតកេលកម្ទេចបំផ្ទិចបំផ្លាញ បង្កិនបង្ក្រាច ឲ្យទ្រព្យ
សម្បត្តិ ចំណេះវិជ្ជា វត្តុវិយោ សណ្តាប់ធ្នាប់ ឬមាយោជាតិត្រកូល
ឥទ្ធិសេចក្តីសុខដ៏ថ្កុះថ្កើងរុងរឿង ឲ្យឆ្ងុំឆ្ងុតម ថ្លៃថ្លា វិសេសវិសាលឡើ
ងោចបង្ក្រោសក្រំនតូច លែងល្អតលាស់ទៅទៀតបាន ។

ពុទ្ធបរិស័ទទាំងឡាយ ! កាលបើសាធុជនណា បានវៀរចាកអំពើ
ដូចបានសំដែងមកខាងលើនេះហើយ សាធុជននោះ ឈ្មោះថាបានក្សា
ធម៌ខុកដោយប្រពៃ ហើយត្រូវបានកម្រៃផលជាសុខ ។

បើតោលខ្លី ។ សង្ខេបវិញតើ ១- បានសុខព្រោះមានចិត្តស្រុះស្រួល

ស្មោះស្ម៊ៅទៅរកតវិយោស្ងាមី ដោយមិនជាប់ចិត្តទៅលើស្ត្រី ឬបុរសឯ
ទៀត ។ ៦- ជានសុខ ព្រោះមានសំដីសុភាពរាបសារ មិនទិយាយ
ឡេះឡោះចៅឡែតតែកកកោក រកវឿនឈ្លោះ មិនចង់ប្រាស័យគាស
ព្រោះតែខ្លួនផឹកអាការសាហាវគឺស្រា បើតាមវិន្យាសាស្ត្រ គេថាមិនខូច
សរសៃប្រព័ន្ធប្រសាទ មិនខូចខួរក្បាល មិនខូចស្មារតី ឬសម្បជញ្ញៈ
អតិក្ស មនោគតិ ការនឹកឃើញឡើងវិញ ការដំនាញ ទឹងមជ្ឈដ្ឋាន
ទាំងឡាយនៃមេតំនិតបញ្ញាសំខាន់ ។ ដោយហេតុតែមិនសេពសុរា ។ ៣-
ជានសុខ ព្រោះគ្មានភ័យទន្ទឹងគេចាប់ឃុំឃាំងលក់ពិន័យ ជាកំគុតប្រកាក
អន្ទាក់ណែនាំខ្មោះឃ្មាង ដោយហេតុតែមិនលេងល្បែងភ្នាល់ ។ ៤-
ជានសុខ ព្រោះមានចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ ដោយហេតុ
តែមិនសេពគប់នូវជនពាល ។ រីឯការគប់រកជនពាលអាក្រក់ នាំឲ្យចេះ
ចំណេះអាក្រក់ ព្រោះមនុស្សពាល មិនដែលដឹកនាំឲ្យប្រព្រឹត្តល្អទេ មិន
ស្គាល់ហេតុនាំឲ្យជានសេចក្តីសុខទេ ស្តាប់ពាក្យសំដីដែលត្រូវ ។ មិនស្ងប់
ជានឡើយ បើអ្នកដែលសេពគប់ផងខ្មោះ មិនចេះលេងស្រី នាំឲ្យចេះលេង
មិនចេះផឹកស្រា នាំឲ្យចេះផឹក មិនចេះលេងល្បែង នាំឲ្យចេះលេង រហូតដល់
ចេះដើរលេងយប់ ចោកប្លាសប្រវាញ្ជគេ ភ្ជាក់ដល់ចេះលួចប្លន់ចាក់គាប់
សម្លាប់គេកំសឹងមាន គឺវាបង្រៀនឲ្យចេះប្រព្រឹត្តអំពើអាក្រក់ទាំងអស់ ។
ត្រូវដូចពុទ្ធភាសិតក្នុងមង្គលសូត្រថា : អសេវនា ច ពាលានំ ....

ឯតម្មង្គលមុត្តមំ ។

ការមិនគប់រកពួកជនពាល ចាត់ជាមង្គលដ៏ប្រសើរ អ្នកដែលរៀបចាក
អំពើទុច្ចរិតដូចពោលមកនេះ ទុកដូចបណ្តុះប្រយោជន៍ធំទូលាយទុកសំរាប់
ខ្លួនឯងនឹងសម្រាប់សង្គមមនុស្សជាតិ ឲ្យបានចម្រើនទៅអនាគតផង ។
សេចក្តីពណ៌នាអំពីការលះបង់អកុយមុខ ដែលជាព្រះធម្មទេសនាពិត ។
ផ្តល់ឲ្យនូវសេចក្តីសុខ-ចំរើនដល់សត្វលោកនេះ ជាសេចក្តីសង្វេច អ្នក
ប្រាជ្ញជាន់ខ្ពស់ដែលមានឈ្មោះពុះជាប់ក្នុងចំព័ត្រប្រវត្តិសាស្ត្រ រៀងមកដរាប
ដល់សព្វថ្ងៃនេះក្តី ដែលកំពុងមានទៅសព្វថ្ងៃនេះក្តី គាលបើលោកឥត
ប្រកបកិច្ចការណាមួយ ដែលជាប្រយោជន៍ដល់ខ្លួនក្តី សុទ្ធតែលោកលះ
បង់ស្រឡះនូវអកុយមុខទាំងនេះចោលចេញ ទើបការនោះ ។ បាន
សម្រេចដូចប៉ំណាង ។ ព្រះសទ្ធម្មទេសនារបស់ព្រះសម្ពុទ្ធជាម្ចាស់ទាំង
អស់ ពោលគឺព្រះធម៌ ៨៤០០ ធម្មក្ខន្ធហ្នឹងឯង ដែលជាព្រះសទ្ធម្មដ៏ប-
រិសុទ្ធ ដែលជាព្រះសទ្ធម្មពិតប្រាកដ ជាសច្ចធម៌ គាចជ្រោងសត្វដែល
កាន់តាម ដឿតាម ប្រព្រឹត្តតាមនឹងប្រតិបត្តិតាមឲ្យលឿន ទៅរកសេចក្តី
សុខ-ចំរើន ខុសសត្វដែលប្រតិបត្តិតាមមិនឲ្យធ្លាក់ទៅកាន់ទីថោកគាបមាន
នរកជាដើម ទាំងធ្វើឲ្យអ្នកដឿស្តាប់ ជួបប្រទះប្រយោជន៍សេចក្តីចំរើន
ដោយកោតសម្បត្តិ ជាព្រះសទ្ធម្មប្រៀនប្រដៅមនុស្សមិនឲ្យឱ្យលប្រអូស
ដេកទម្រន់ចាត្រង់សំណាងតែម្យ៉ាងទេ ព្រោះត្រង់សំណាង បើប្រាស

ចាកការកសាង ការងារ រៀនសូត្រ ស្រែវស្រែខេញ ត្រែងសំណាងមិនដួចខេ តែកុំដេកចាំត្រែងសំណាងតេក ស៊ីដេក ។ ហើយគួញថាត្រូ ។ សមដួចពុទ្ធភាសិតមានដើមថា សុសុ្សសំ លភតេ បញ្ញំ អ្នកប្រាជ្ញ បេះដើងចំណេះវិជ្ជាត្រប់បៃបេ ចាន់មកអំពីការប្រឹងស្តាប់ប្រឹងនេញ ។ ឧបដ្ឋាតា វិជ្ជតេ ធនំ អ្នកមានធនធានមកពីរៀសរៀប្រឹងរកប្រឹងធ្វើ ដួចបូកណាភាសិតពោលថា « តើតមកជាមនុស្សត្រូវតែប្រឹង ត្បាយាម ឲ្យតើដកុំបន្ទរ ប្រាសខ្លួនដេកទៅកុំដេកយូរ ភ្ញាក់ឡើងគិតគួរកធ្វើការ» ។ សេចក្តីដែលសំដែងមកខាងដើមប៉ុន្មាននេះ ត្រូវតាមលំអាន នៃព្រះធម្មទេសនា របស់ព្រះពុទ្ធ ដែលជាព្រះសទ្ធម្មប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឲ្យសត្វអ្នកកាន់ ងាកទៅលើផ្លូវប្រតិបត្តិដែលហៅថា អន្តាបដិបទា សេចក្តីប្រតិបត្តិលាមក ឬសេចក្តីប្រតិបត្តិតាមធម៌អមនុស្ស មិនមែនជាមគ្គាមាបដិបទានោះ ។

ព្រោះហេតុនោះ កិរិយាសំដែងនូវព្រះសទ្ធម្មទេសនា នៃព្រះពុទ្ធខាងដើម ឬការប្រាប់នូវធម៌ពិត ជាធម៌ស្អិតស្អាងសត្វលោកឲ្យរុងរឿង ខប់សត្វមិនឲ្យទៅកាន់ទីទុគ្គលំបាក ជាហេតុនាំឲ្យកើតសេចក្តីសុខដល់សត្វលោក ។

ទី ៣- សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងគ្នារួបរួមគ្នា ស្រុះស្រួលគ្នា ប្រមូលគ្នាជាចុច់ រួបរួមជាក្នុងមួយ ជាហេតុ

នាំឲ្យបាននូវសេចក្តីសុខ ។

អធិប្បាយថា : ពាក្យថាសាមគ្គី ប្រែថាព្រមព្រៀងគ្នា ដំណើរមិនប្រឆាំងគ្នា ដំណើរមិនបែកកន្លែកគ្នា សេចក្តីពេញអាងជិតស្និទ្ធនឹងគ្នា ការចូលចិត្តមូលគំនិតគ្នា ការស្រុះស្រួលគ្នា ការរួបរួមចងចាប់គ្នា បានសេចក្តីថា ការជែលស្រុបគ្នា ការបណ្តាយគ្នា ការស្មើចិត្តស្មើគំនិតនឹងស្មើអធ្យាស្រ័យគ្នា ។

សាមគ្គីនេះជា ៣ ប្រភេទគឺ :

១- កាយសាមគ្គី សេចក្តីព្រមព្រៀងគ្នាដោយកាយ

២- វចីសាមគ្គី ការព្រមព្រៀងគ្នាដោយសំដី

៣- ចិត្តសាមគ្គី ការព្រមព្រៀងគ្នាដោយចិត្ត ។

១- កាយសាមគ្គី ព្រមព្រៀងគ្នាដោយកាយ គឺព្រមព្រៀងគ្នាធ្វើការងារ ព្រមព្រៀងគ្នារៀនសូត្រ ព្រមព្រៀងគ្នាស្តាប់ធម៌ ព្រមព្រៀងគ្នាប្រតិបត្តិ ព្រមព្រៀងគ្នាអនុវត្ត ព្រមព្រៀងគ្នាសន្សំ ព្រមព្រៀងគ្នាសំចៃ ព្រមព្រៀងគ្នារក្សា ព្រមព្រៀងគ្នាស្វែងរក នឹងព្រមព្រៀងគ្នាការពារ ។

បើផ្នែកខាងបព្វជិតវិញ គឺព្រមព្រៀងគ្នាប្រតិបត្តិតាមធម៌ពិត ព្រមព្រៀងគ្នាធ្វើឧបោសថកម្ម ស្រុះស្រួលគ្នាប្រជុំស្តាប់ឱវាទ ពាក្យប្រៀនប្រដៅរបស់ព្រះអាចារ្យ រួបរួមគ្នាធ្វើកិច្ចការសង្ឃជាដើម ។

ផ្នែកខាងគ្រហស្ថ គំប្រៀបលគ្នាដែរ ដូចជាខៅកូនសង្គមភូមិខ្មែរមួយ។ ដើម្បីកុំឲ្យសត្រូវតីក្រៅមើលងាយ គោរពតែពួតដៃគ្នាការពារ រក្សាទុកអត្តភាយឬហេតុការណ៍ណាមួយ ដែលជាឧបសគ្គដល់ដំណើរដំណែរបស់ខ្លួន។ ចំពោះការណីយកតួចខ្លះទៅ ក៏ជួយគ្នាទៅវិញទៅមក ធ្វើការហត្ថកម្មដោយយកដៃគ្នា ផ្ទាស់វេនគ្នា ជួយធ្វើការងារគ្នាម្ខាងម្ខាក់ ហួតដល់ទៅជួយធ្វើការក្នុងសង្គមជាតិផង។ ដោយសារការឆ្លុកម្ចាំងគ្នា រួបរួមគ្នាធ្វើឲ្យជាកម្លាំងរួម ហើយអនុវត្តខ្លឹង ការងារទាំងឡាយដែលលំបាក។ ខោះ រមែងដើរទៅដល់ទីដៅពោលគឺសេចក្តីសំរេចបានយ៉ាងពិតប្រាកដ។ ការព្រមព្រៀងគ្នាធ្វើដោយការយដូច្នេះ ឈ្មោះថាការយសាមគ្គី។

២- វិធីសាមគ្គី ព្រមព្រៀងគ្នាដោយពាក្យ: សំដីដែលស្រុបគ្នា សំដីដែលចុះសម្រុងគ្នា សំដីដែលបណ្តោយគ្នា មិនខ្វែងគ្នា មិនប្រទាំងគ្នា និយាយទៅហើយប្រកបដោយហេតុផល គួរយកជាការបាន គួរយកទៅប្រតិបត្តិបាន ហើយស្រុះស្រួលអនុវត្តតាមសំដីខោះទៅ:

ផ្នែកខាងព្រះសង្ឃពុទ្ធសាសនិក បានដល់ការសិក្សាស្វាធ្យាធម្មវិន័យត្រូវបែបបទគ្នា មានវាទៈប្រកបដោយធម៌ និងប្រកបដោយហេតុផលដូចគ្នា។

ចំណែកខាងគ្រហស្ថ បានដល់សំដីដែលគេពោលអំពីប្រយោជន៍អ្វីមួយ ដែលអាចប្រើប្រាស់បានទាំងអស់គ្នា ជាសំដីដែលមានមតិភាគ

ច្រែនយល់ព្រមជាមួយផង ជាសំដីដែលប្រកបដោយហេតុ-ផលស្តាប់គ្នាបាន់ គោលគឺសំដីដែលប្រកបដោយទុតមតិពិតប្រាកដផង ។ ពាហារណ៍ក្នុងសមាជជាតិ ឬប្រជុំសន្និសីទអ្វីមួយ បើសំដីរបស់សមាជិក ឬសមាជិកាណាមួយនៃអង្គប្រជុំសមមម្បត្តរយកជាការបានក៏ព្រមដឿស្តាប់ចាំងអស់គ្នាវៅ ។ ការព្រមព្រឿងគ្នាដោយវាចាយ៉ាងនេះ ហៅថាវចីសាមគ្គី ។

៣- ចិត្តសាមគ្គី សេចក្តីព្រមព្រឿងគ្នាដោយចិត្ត បានសេចក្តីថា មានចិត្តស្រុះស្រួលគ្នា មានចិត្តស្មើគ្នា មានគំនិតស្មើគ្នា ខឹងមានអធ្យាស្រ័យស្មើៗគ្នា ។

ក្នុងផ្នែកពុទ្ធសាសនា ដូចជាភិក្ខុសង្ឃមានចិត្តចុះសម្រុងគ្នា ក្នុងការធ្វើឧបោសថកម្ម មានអធ្យាស្រ័យខន់ក្នុន ចេះគោរពចាប់តេគ្នាវៅវៃញវៅមកដោយចិត្តស្មោះស្មើ ចេះជួយជុះគ្នាកង់តេលមានជម្ងឺជម្ងាត់ ដោយចិត្តស្មោះស្មើ ចេះព្រមព្រឿងគ្នាកង់កិច្ចប្រតិបត្តិតាមធម៌វិន័យឲ្យត្រឹមត្រូវប្លែរយោចល់គ្នា ក្នុងតេលមានប្រជុំអ្វីមួយ ដែលជាប្រយោជន៍ដល់ពុទ្ធសាសនាដោយចិត្តស្មោះត្រង់ពិត ។ ។

ចំណែកខាងគ្រហស្តក៏ស្រេដឿងគ្នាដែរ គឺចេះពាប់អានគ្នាដោយចិត្តដ៏ស្មោះស្មើរកង់ពីភូមិមួយវៅភូមិមួយ ពីស្រុសារមួយវៅស្រុសារមួយ ពីវណ្ណៈមួយវៅវណ្ណៈមួយ ពីសង្គមមួយវៅសង្គមមួយទៀត រហូតដល់សង្គមជាតិចាំងមូល ។ គោលគឺចេះគោរពគ្នា ចេះខ្ចាចចិត្ត ចេះពាប់អានគ្នា

រវេះស្រឡាញ់ចិត្តថ្នមគ្នាខុកដូចជាបងប្អូនបង្កើត មិនប្រទូស្តគ្នា មិនក្បត់ចិត្តគ្នា មិនប្រើអំណាចឃោរឃៅលើសេរីភាពគ្នាទឹងគ្នា មិនលួចប្លន់កាប់សម្លាប់គ្នា មិនឈ្លានពានរំលោភគ្នាទៅវិញទៅមក ហើយមូលមតិគ្នាជាធ្លុងមួយ ប្រតិបត្តិតាមច្បាប់ធម៌វិន័យរបស់ព្រះពុទ្ធសាសនា ឬប្រតិបត្តិតាមច្បាប់សំពាប់រដ្ឋ ដោយសភាពរួបរួមមូលត្រកូលរាក់ទាក់រាយជាមួយគ្នា សេចក្តីព្រមព្រៀងគ្នាដោយចិត្តយ៉ាងនេះ ហៅថាចិត្តសាមគ្គី ។

៤- សមគ្គានំ តបោ សុខោ សេចក្តីព្យាយាមរបស់អ្នកព្រមព្រៀងគ្នា ជាដើមកំណើតនៃសេចក្តីសុខ ។

សេចក្តីព្យាយាមរបស់បុគ្គលអ្នកព្រមព្រៀងនេះ ព្រះអដ្ឋកថាចារ្យលោកតែងតម្កើងនៅក្នុងធម្មបទខុទ្ទកនិកាយត្រង់ពុទ្ធវគ្គថា ចានដល់ពួកភិក្ខុអក្ខរួបរួមគ្នា ហើយព្យាយាមរៀនខ្លួនឯង ឬក៏រក្សាខ្លួនឯងក្តី ពុំនោះសោតក៏ព្យាយាមធ្វើសមណធម៌ សមាធិកម្មដ្ឋាន ដោយចិត្តស្មោះស្ម័គ្រតម្រង់ទៅរកតែផ្លូវមួយទំនឹងចិត្តគំនិតមួយ ដើម្បីឈោងចាប់យកអមតដ្ឋានរៀង ។ ខ្លួន ។ នេះគឺសេចក្តីព្យាយាមរបស់ពួកភិក្ខុ អ្នកមានសាមគ្គី ដើម្បីប្រតិបត្តិយកផ្លូវទៅកាន់ទីរំលត់ទុក្ខ ។

បើអធិប្បាយឲ្យកាន់សេចក្តីដាយស្តាប់មកខ្មែរថា : ១- ព្យាយាមលះចោសដែលកើតឡើងទៅក្នុងពួកក្រុមដែលមានសាមគ្គី ។ ២- ព្យាយាមរាំងចោសមិនឲ្យកើតឡើងក្នុងពួកក្រុមដែលមានសាមគ្គី ។ ៣- ព្យា

យាមបង្កើតសេចក្តីល្អឲ្យកើតមានដល់ពួកក្រុមដែលមានសាមគ្គី ។ ៤- ព្យាយាមកម្ចាត់សេចក្តីល្អដែលកើតមានក្នុងពួកក្រុម ប្រកបដោយសាមគ្គីហើយមិនឲ្យបាត់បង់ទៅវិញ ។ ភាពនៃសេចក្តីសាមគ្គីនិងសេចក្តីព្យាយាមរបស់អ្នកមានសាមគ្គីនេះ ជាធម៌មានគុណានុភាពណាស់ កាលបើយើងប្រតិបត្តិតាមដោយហ្មត់ចត់ ។ សូមលើកយកជាតកមួយមកសំដែងដោយសង្ខេបជាបុគ្គលាធិដ្ឋានដូចតទៅនេះ ៖

កាលកន្លងទៅហើយ ព្រះពោធិសត្វយោនយកកំណើតជាសត្វចាប ។ សម័យថ្ងៃមួយ ចាបជាបរិពាររបស់ពោធិសត្វ ព្រមទាំងចាបពោធិសត្វផងនោះ បានទាំគ្នាទៅកេងំណីអាហារក្នុងស្រែមួយដែលបរិបូណ៌ដោយស្រូវ ពេលនោះ មានព្រានបក្សីម្នាក់ បានយកសំបុកទៅដាក់ដើម្បីឲ្យជាប់ចាប ។ ខណៈនោះ ក្រុមចាបពោធិសត្វ ក៏បានចុះទៅស៊ីស្រូវក្នុងស្រែដែលមានសំបុកនោះ លុះកេស៊ីបានមួយសន្ទុះ ក៏មានគ្រោះថ្នាក់មកដល់ពួកក្រុមស្រាប់តែបានចូលទៅក្នុងសំបុកនោះ ចាបពោធិសត្វក៏និយាយថា បើយើងប្រឹងហើរទំលាយសំបុកនេះម្នាក់ម្តង ។ សំបុកនេះមិនខ្លាយទេ ដូច្នេះយើងទាំងអស់គ្នាត្រូវប្រឹងចុះកាងហើរព្រមគ្នាតែម្តង ទើបសំបុកនេះខ្លាយបាន ។ លុះចាបជាបរិពារស្តាប់បានដូច្នោះហើយ ក៏ព្រមព្រៀងគ្នាហើរព្រុសឡើង ។ ដោយសារកម្លាំងរួបរួមគ្នាភាគច្រើនរបស់ចាប សំបុកនោះក៏ខ្លាយទៅ ។ ពួកចាបទាំងនោះ ក៏ទាំគ្នាហើរចេញរួចពីសំបុកហើយទៅដល់ទីកន្លែងរៀងៗខ្លួន

ចានគេចផុតអំពីសេចក្តីស្លាប់ត្រប់ ๆ គ្នា ។ នេះហើយជាអានិសង្សនៃការ
ព្រមព្រៀងគ្នា ហើយឰយាយាមចំលុះចំលាយនូវទុច្ចរិតផ្សេង ។ ដែលកើត
មានដល់ពួកក្រុមរបស់ខ្លួន ។ ត្រង់ការរួបរួមគ្នារបស់ពួកសត្វចាបនេះ ពុកជា
សាមគ្គីភាព ត្រង់ការប្រឹងប្រែងរំហើរចំលាយលប់ពាំងអស់គ្នា នៃពួកសត្វ
ចាប ពុកជាសេចក្តីឰយាយាមរបស់អ្នកមានសាមគ្គី ហើយផលវិបាករបស់
សាមគ្គីនេះ គឺសេចក្តីសុខហ្នឹងឯង ។

ពៀរតបពៀរ	ពាំនៀរម៉ិនស្ងប់
ផលជាដល់កូន	ដូចកង់ប្រវាត់ ។
ប្តូរដូចសម្ងួ	កំពឹសប្រពាត់
ពាក្យឆ្មិតឥតអាក់	គ្នានឹអរសាន ។
ចូរក្លេងពាំងឰយ	កំចាយឥប្រាណ
ប្រសើនបើមាន	នូវពៀរចង្រៃ ។
ពុំនោះសោតទេ	អ្នកនឹងជាប់ដៃ
ពុំអាចកែវៃ	ដូចក្អែកនឹងមេម ។

ព្រះអភិធម្មបិដក

(កម្ពីរព្រះមហាឧដ្ឋាន)

លោក ប៊ូ - ប៉ុំ រៀបរៀង

ពុម្ព

បុគ្គលនឹងធ្វើសង្ឃទានឲ្យជាសង្ឃទានល្អបំរុង ចូរមើលកំរៃយោបល់អ្នកប្រាជ្ញមុំពីមុន ផលនៃទាននោះទើបជាផលដ៏អស្ចារ្យ ។

ចំណែកផលនៃអកុសលកម្មក៏ជាបច្ច័យ ដូចផលនៃកុសលកម្មដែរ គឺបុគ្គលធ្វើឃ្លាតណាត់ឃ្លាត អទិន្នាទាន កាមេសុមិច្ឆាចារ មោសវាទ បេសុញ្ញវាទ ផរុសវាទ ទីឆ្នប្រព្រឹត្តមនោទុច្ចរិតបីប្រការក្តី ទុច្ចរិតទាំងដប់ប្រការនេះ បើបុគ្គលឯណាធ្វើហើយ រមែងនាំបុគ្គលនោះឲ្យទៅកាន់អបាយភូមិ ។

បុគ្គលធ្វើឃ្លាតណាត់ឃ្លាត ទីឆ្ងាត់ទៅក្នុងសញ្ញីនរក អស់កាលជាយូរៗ អំពីការប្រៀបធៀបកាលវិញ ៩០ឆ្នាំកង់មនុស្ស ឃ្លាតថ្ងៃមួយយប់មួយក្នុងចាតុមហារាជិកា ៩០ ឆ្នាំ កង់ចាតុមហារាជិកា ឃ្លាតថ្ងៃមួយកង់សញ្ញីនរក ។ សត្វសោយផលនៃអកុសលកម្ម ទីឆ្ងាតកង់តំណើតដ៏លាមកគឺទីឆ្ងាតជាប្រេតប្រាំរយជាតិ ជាត្រី ជាតស់ ជាខាត ជាប្រើសក្តាត់ជាគោក្របីទីឆ្ងាសុទ្ធ កង់ជាតិមួយៗ ប្រាំរយៗ ដូចគ្នា ដោយអំណាចនៃឃ្លាតណាត់ឃ្លាតដ៏ជាការយុច្ចរិត ។

យោ អនិដ្ឋាឆានោ បុគ្គលឯណាមានលោភចិត្ត ប្រើនធ្វើអនិដ្ឋាឆាន គឺលួចយកវេសវ្រត្យដែលម្ចាស់មិនបានឲ្យ ដោយវេយ្យាវេតនា បុគ្គលនោះ លុះលែងបញ្ចក្ខន្ធហើយ ក៏ទៅកើតក្នុងកាលសូតនរក កាលផុតពីនរកហើយ មកកើតជាមនុស្ស ទំនងជាអ្នកខាល់ក្រកំព្រា ទំនងជាអ្នកមានរូបកាយអាក្រក់ជាទីស្អប់ខ្ពើមនៃជនពាលឯណោះ ទំនងប្រកបទៅដោយទុក្ខកាយគ្គឆាយជាច្រើន ទំនងចាប់ផ្តើមដល់សន្ធិក្នុងត្រកូលថោកទាប ។

បុគ្គលឯណាប្រកបដោយឆាតតណ្ហា ច្រើនតម្រេកខ្លាំងក្នុងស្ត្រីជាកវិយាវេសរបស់អ្នកដទៃ ដោយអំណាចមេថុនធម្ម ផលនៃកម្មគឺកាមេសុមិច្ឆាចារនោះ រមែងជាបច្ច័យនាំបុគ្គលនោះឲ្យទៅកើតក្នុងសង្ឃាដនរក លុះច្យុតពីនរកោះហើយ ផលនៃកាមេសុមិច្ឆាចារ ឲ្យមកកើតជាស្ត្រីថ្កុំរយជាតិ ជាខ្ជើយថ្កុំរយជាតិ ជាទីស្អប់ខ្ពើមដល់មនុស្សប្រុសស្រីទំនងពាលពួន ។

បុគ្គលឯណាពោលមុសាវាទគឺនិយាយមិនពិត ផលនៃមុសាវាទនោះជាបច្ច័យដឹកនាំបុគ្គលនោះឲ្យទៅកើតក្នុងកេរុវនរក លុះច្យុតពីនរកហើយមកកើតជាមនុស្សមានក្លិនមាត់ស្អុយ បក់ផ្សាយទៅដូចជាក្លិនមូត្រ ទំនងលាមក ទំនងជាមនុស្សល្ងង់ខ្លៅឥតបញ្ញា មិនបានដឹងភ្លុំវចនៈឡើយ ។

សុរំ បិវន្តោ បុគ្គលឯណាគ្រេបផឹកនូវសុរាទំនងមេរ័យ បុគ្គលនោះលុះអស់ជីវិតហើយ ក៏ធ្លាក់ទៅសោយទុក្ខក្នុងនិមហាកេរុវនរកអស់កាល

ជាយូរ លុះរួចពីនរកហើយ មកកើតជាយក្សថ្កុំរយជាតិ ដោយអំណាចផលនៃអកុសលកម្មគឺការធ្វើកន្ធវ៍សុកនឹងមេរ៉ាយនោះ ។

ផលនៃកម្មជាកុសលនិងកម្មអកុសលទាំងពីរប្រការនេះ សម្តេចព្រះទ្រង់ព្រះភាគ ត្រាស់ទេសនាថាជាវិបាកបច្ចុយ ក៏បញ្ចូលកន្លងបច្ចុយមួយក្នុងប្លួនប្រការដូច្នេះឯង ។

វិបាកបច្ចុយ ចប់ប៉ុណ្ណេះ

អាហារបច្ចុយ

អាហារបច្ចយោតិ ឯត្ថ ចត្តារោ អាហារា កវឡីការាហារោ ផស្សាហារោ មនោសញ្ចេតនាហារោ វិញ្ញាណាហារោតិ កវឡី ការា អជ្ឈាហរិតព្វតោ អាហារោ កវឡីការាហារោតិ ។

លំដាប់នេះ សូមវិសជ្ជនាកន្លងអាហារបច្ចុយតទៅ ដំណើរសេចក្តីថា អាហារបច្ចយោតិ ឯត្ថ ក្នុងអាហារបច្ចុយនោះ ចានផលអាហារប្លួនប្រការ គឺកវឡីការាហារ១ ផស្សាហារ១ មនោសញ្ចេតនាហារ១ វិញ្ញាណាហារ១ ។ អាហារទាំងប្លួនប្រការនេះឯងជាបច្ចុយឲ្យសត្វទាំងឡាយដែលមានអាហារផ្សង ។ ជាបច្ចុយ គឺពួកមួយមានកវឡីការាហារជាបច្ចុយ ពួកមួយមានផស្សាហារជាបច្ចុយ ពួកមួយមាន

មនោសញ្ចេតនាហារជាបច្ច័យ ពួកមួយមានវិញ្ញាណាហារជាបច្ច័យ ។

ក៏ឬកាពហារនោះ ជានន្ធិឆ៌អាហារដែលបុគ្គលធ្វើឲ្យជាពំនូត រហើយបរិភោគ ជាឈ្មោះនៃជាយន្ធិឆ៌សណ្តែកជាដើម ជាអាហារដ៏គ្រោតគ្រាត ព្រោះហេតុវត្ថុទើតគ្រោតគ្រាត ជាអាហារដ៏ល្អិត ព្រោះហេតុវត្ថុទើតល្អិត ។ អាហារក្រៅគ្រោតគ្រាត ព្រោះរលេបនូវដុំថ្ម ។ មោរកំ សុខុមោ អាហារនៃក្មេកល្អិតជាងអាហារនៃក្រៅ ព្រោះក្មេកពាងឡាយស៊ីសត្វទីយជាតិនន្ធិឆ៌ជាដើម ។ អាហារនៃខ្លាល្អិតជាងអាហារនៃក្មេក ព្រោះខ្លាពាងឡាយស៊ីនូវក្តៅសត្វនន្ធិឆ៌ពាងឡាយដែលចោលអស់ជាដាំ គ្រាន់តែឆ្អឹងនោះត្រូវខ្ចីកមាត់ខ្លាក្តាម កំខន់ដូចជាដំឡូង ។ អាហារនៃគជសារពាងឡាយល្អិតជាងអាហារនៃខ្លា ព្រោះដំរីស៊ីស្មៅនន្ធិឆ៌ស្លឹកឈើ ។ អាហារនៃសកុណជាតិ សត្វស្វាបពាងឡាយល្អិតជាងអាហារនៃគោនន្ធិឆ៌ម្រឹគ ព្រោះពស៊ីគ្រាប់ស្មៅនន្ធិឆ៌សត្វល្អិត ។ ជាដើម ។ អាហារនៃមនុស្ស ល្អិតជាងអាហារនៃសកុណជាតិ ។ អាហារនៃអមាត្យនន្ធិឆ៌ក្សត្រល្អិតជាងអាហារនៃមនុស្សធម្មតា ។ អាហារនៃព្រះបរមចក្រពត្តិ ល្អិតជាងអាហារនៃខត្តិយាធិបតី ដែលមិនមែនជាបរមចក្រពត្តិ ។ អាហារល្អិតនន្ធិឆ៌គ្រោតគ្រាតជាងគ្នាជាជាន់ ។ ឡើងទៅ ព្រោះហេតុមានវត្ថុទើតគ្រោតគ្រាតនន្ធិឆ៌ល្អិត(១) ជាដើមដូច្នេះ ។

---

១) ពាក្យថា "អាហារគ្រោតគ្រាត,, សំដៅយកអាហារមិនស្អិតល្អប្រណីត ។ អាហារល្អិត សំដៅយកអាហារល្អប្រណីត ។

ឧបាទិន្នកោបិ អនុបាទិន្នកោបិ អ្នកប្រាជ្ញគប្បីដឹងថា កវឡីការាហារនោះមានពីរប្រការ គឺឧបាទិន្នការាហារ ១ អនុបាទិន្នការាហារ ១ ។ កវឡីការាហារមែនទាំមកនូវរូបចាំងឡាយមានឧជរូបជាគំរប់ ៨៨ ។

ផស្សាហារនោះ គឺផស្សៈ ៦ ប្រការ មានចក្ខុសម្ផស្សជាដើម ។ សោ អាវហតិ ផស្សាហារនោះ រមែងទាំមកនូវវេទនា ៣ ប្រការ គឺសុខវេទនា ១ ទុក្ខវេទនា ១ ឧបេក្ខាវេទនា ១ ។

មនោសញ្ចេតនាហារនោះ រមែងទាំមកនូវភពចាំងបី គឺកាមភព ១ រូបភព ១ អរូបភព ១ ។

វិញ្ញាណាហារនោះ រមែងទាំមកនូវនាមនឹងរូប ។ សត្វចាំងឡាយនឹងកើតឡើងបាន អាស្រ័យហេតុមានការាហារជាបច្ច័យ បើគ្មានការាហារជាបច្ច័យទេ នឹងកើតឡើងមិនបានឡើយ សមតាមព្រះពុទ្ធដីកាថា ផស្សបច្ចយា វេទនាយ បច្ចយោ ផស្សៈជាបច្ច័យដល់វេទនា ។ ផស្សបច្ចយា វេទនានឹងកើតឡើង ព្រោះហេតុមានផស្សៈជាបច្ច័យ ។ ហេតុនោះ បានជាថាការាហារគឺផស្សៈទាំមកនូវវេទនាបីប្រការ នឹងការាហារគឺវិញ្ញាណ ទាំមកនូវនាមនឹងរូប ។

កវឡីការាហារ កាលមនុស្សគឺស្ត្រីនឹងបុរសបរិភោគនោះ ធ្មេញខាងក្រោមសម្រេចកិច្ចជាគ្រាល ធ្មេញខាងលើ សម្រេចកិច្ចជាអង្រែ លុះ

ខំពារួច លេបចូលទៅក្នុង១ទម្រេសតីពោះហើយ ក្លើងជាតុដុតឲ្យឆ្អិន
សព្វគ្រប់ល្អិតល្អះហើយ តំជ្រួតជ្រាបទៅគេញចាំងសរីរៈឥន្ទ្រីយ៍ ញ៉ាំង
អាការ ៣២ មានកេសាតីសក់ជាដើម ឲ្យសម្រេចបរិបូណ៌ ។ អាហារនោះ
កាលបើក្លើងជាតុដុតចំអិនមិនឆ្អិនសព្វគ្រប់ទេ កំញ៉ាំងរោគចាំងឲ្យ
មានធាតុមិនប្រក្រតីជាដើម ឲ្យកើតខ្យើង កាលបើក្លើងជាតុដុតឲ្យល្មួយ
រលាយល្អិតល្អះតាមប្រក្រតីហើយ ចែកចេញទៅជា ៩ ចំណែក គឺសព្វ
ចាំងឲ្យស៊ុ ១ ចំណែក តេជោធាតុដុតឲ្យឆេះ ១ ចំណែក ជាមួយក្រតី
ទឹកនោម ១ ចំណែក ជាកំសៈគឺអាចម៍ ១ ចំណែក ជាវសជ្រួតជ្រាប
ទូទៅសព្វសរីរកាយ ១ ចំណែក ។

ហេតុនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា សត្វក្នុងកពចាំងពួងរមែង
មានអាហារជាទីតាំង តាំងនៅដោយអាហារត្រប់រូប ។ អាហារជាហេតុ
ញ៉ាំងសត្វចាំងឲ្យស្ថិតនៅបាន សមតាមព្រះពុទ្ធភាសិតដែល
សម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទុកថា សត្វេ សត្តា អាហារ-
ដ្ឋិតិកា សត្វចាំងឲ្យចាំងពួងរមែងតាំងនៅដោយអាហារ បើ
ប្រាសចាកអាហារហើយ ក៏មិនអាចតាំងនៅបានឡើយ ។

(នៅមានត)

អ្នកមានគុណ (ត)

រៀបរៀងដោយលោក ហេង-សំអាន នៅសេនាធិការយោធភូមិភាគទី ១ ខេត្តកំពង់ចាម
អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្ខាសាលាថ្មើរជើង ខែត្រពោធិសាត់

រឿងស្វាកំជិលការតែញី

កាលពីអតីតយូរយោរណាស់ ព្រៃក្រាស់ដុះស្បៃវែនកាស៊ី
ជាព្រៃសម្បូណ៌សត្វបក្សី បក្សាប្រញឹងផ្ទៃស្វាយ ។
ពេលល្ងាចត្រជាក់ចូលសំបុក ដោយនៅស្រណុកសុខសប្បាយ
ព្រឹកឡើងនាំគ្នាហើរប្រញាយ ចឹកផ្លែស្វាយល្មុតសេដា ។
ពេលនោះមានស្វាព្រៃចង្រៃ អង្គុយនុបដៃក្រោមព្រឹក្សា
គយគន់សំឡឹងកេងលា មង្សឹតសេដាណាពុំពុំ ។
ស្ទុះលោតប្រគេងឈោងប្រឡែះ ស្រាក់លូកបេះផ្លែធំធំ
មង្សឹតសេដាដែលពុំពុំ ចែកស្វាក្រមុំធីសប្បាយ ។
ស្វាញីស្វាឈ្មោលគោលទ្ធឹងធ្វើយ អូនអើយបងអើយកើយកៀកកាយ
ស្រឡាញ់គ្នាស្និទ្ធឥតក្លែងក្លាយ រួមរ័សប្បាយតន់ពេកក្រៃ ។
ស្រាប់តែឮសំឡេះបោកបក់មក បុកញាពពកមកជាំនឹងខ្លួ
ធនធីតជុំជិតកន្ធរព្រៃវែង ឮសំឡេះខ្លាំងក្រៃចាក់មែកស្វាយ ។
បក្សាបក្សីយើញឮសំឡេះ នាំគ្នាហើរចុះស្រុះប្រញាយ
ចូលកន្ធរសំបុកសុខសប្បាយ ផុតពីអន្តរាយឮសំណាង ។

ក្នុងមួយសន្ទុះនោះភ្លៀងធ្លាក់ ខ្លោចខ្លោចឥតអាក់ធ្លាក់ចាប់សាច
រន្ទះចាំងផ្លាំងគួរឲ្យខ្លាច ខ្យល់ត្បូរកំណាចចោកម្ពង់ម្ពង់ ។
ស្វាញីស្វាឈ្មោលគួរច្បាំងថ្នី ស្ទុះចុះមកដីស្ដីសាសង
អួនរងាណាស់ណាអ្នកបង ខ្យល់បក់ម្ពង់ម្ពង់ត្រីរេមា ។ ។
ស្វាឈ្មោលគោលថា ។ ព្រលឹងរៀម នាងនៅឲ្យស្ងៀមណាតុំងា
រៀមបងត្រសោចទុចស្ងួនក្ងា ឲ្យចាត់រងាណាវរមិត្រ ។ ។
ស្វាឈ្មោលតំពុងទុបញីជាប់ ឮសូរសេន្ធាប់ព្រុះមកជិត
នាំគ្នារត់ជ្រកក្រោមដើមទ្វិត កែ្សរដើមត្រឹងត្រែងជិតដើមស្វាយ ។
គេលនោះមានចាបធ្វើសំបុក ដេកនៅស្រណុកសុខសប្បាយ
គ្មានសត្រូវអ្វីបៀតបៀនកាយ សែនសុខសប្បាយឥតឧបមា ។
ចាបក្រឡេកក្បែកគន់រំពៃ ឃើញសត្វស្វាព្រៃញីឈ្មោលណា
រងាញ់រួនពួនអាត្មា ជ្រកក្រោមរុក្ខាការភ្លៀងខ្យល់ ។
ចាបឃើញដូច្នោះគោលថា « បង ភ្លៀងខ្លាំងខ្លងបងគ្មានសល់
ខ្ញុំសែនអាណិតគំតទ្វាយខ្លាល់ សូមដួនយោបល់ជល់បងស្វា ។
បងមានកម្លាំងក្លាខ្លាំងក្រៃ មានដើងមានដៃដូចមនុស្សា
មានឧត្តមសមស្ដា ជាមហាក្សត្រាចតុប្បាទពិត ។
គួរណាស់តែបងធ្វើផ្ទះនៅ ការពារកំដៅព្រះអាទិត្យ
ភ្លៀងខ្យល់មកជល់ការពារជិត ខោះយប់ងងឹតឥតកិតភ័យ ។

ចូរបងក្រេឡកមើលពួកយើង　　គ្មានដៃគ្មានជើងយើងលកលៃ
ធ្វើសំបុកនៅធុតកិតក័ឃ　　អាស្រ័យក្នុងព្រៃយ៉ាងកក់ក្តៅ ។ ។
ស្វាព្រៃកំចាបអន្សត់ប៉ែយ　　ឮពាក្យសំដីស្តីប្រដៅ
ក្រែវក្រោធពាំពេធក្តុកក្តួលក្តៅ　　មួរមៅនឹងចាបស្រែកដេរថា ។
« អង្គអញឮដូនឥន្ទ្រហេនុមាន　　ឋិតិក្នុងហានលើសលោកា
មិនដែលធ្វើផ្ទះដូចមនុស្សា　　តាំងពីដូនតាតូដចម្ល៉ាង ។
ហាលភ្លៀងហាលខ្យល់កាលថ្ងៃយប់　　នៅចូលឈប់យកកម្ចាំង
បើមានសត្រូវនៅពាក់ព័ន　　តស៊ូប្រតាំងចង្កាំងឲ្យខ្លាច ។
ចុះអាចាបឯងឈឺកក្រាលអី　　ខ្ជិនតូចតូចស្តើងប៉ោចប៉ាច
អញរើសំបុកគុកហិនហោច　　អញចោចចោះចោលឥឡូវណា ។
ឲ្យដឹងថ្លៃដៃផៅសន្តាន　　នៃហានុមានឫទ្ធិក្លា
ពោះត្រូវពោះនាគឬយក្ស　　ខ្លួបខ្លាចចេស្តានៃហានុមាន » ។
ចាបយើញស្វារក្រោធប្រលោតខ្លាំង　　ភ្លោលអួតកម្ចាំងខ្លាំងក្លាហាន
កិតកិយាខ្នត់ញាប់ញ័រប្រាណ　　ខ្លាចស្វាសាមាន្យចាន់អង្វរ ។
« បងអើយបងស្វាឫទ្ធិក្លាខ្លាំង　　ពួកអ្នកចម្ល៉ាងខ្លាំងមិនមរណ៍
ពីដូនពីតាល្បីខ្លាយខ្ចរ　　ជាតូដមានធម៌ដ៏ឧត្តម ។
សូមអភ័យទោសប្រោសមេត្តា　　ខ្ញុំវាក្យណាណាដែលមិនសម
សូមបងកុំប្រោចសំបុកខ្ញុំ　　មានកូនតូច-ធំនៅនេះណា ។

បងអើយកូនខ្ញុះខើបនឹងញាស់ កូនខ្ញុះខៀតលាស់ដុះរកមា
មិនមានចេះហើរឆកគ្នា ដោយខ្លួនឯងណាំណាំក្រមើ! » ។
ស្វាព្រៃមួរមៅក្តៅក្នុងចិត្ត គ្មានតិតអាណិតសត្វបក្សី
សុះខ្សឹងដើមឈើរើក្រញី ទម្លាក់មកដីស្ទាប់ក្រៀបក្រា ។
មេហើរប្រញាយយំស្តាយកូន ចោកខ្លួនស្ទាប់សូន្យក្នុងព្រឹក្សា
ហូនចាបនៅជិតតិតនឹងស្វា ឆ្ពើលគេញាត់ក្បាលទៅទីណៃ ។
លុះចប់អតីតនិទាន ខ្ញុំប្រាប់ទៅព្រានថា « កុំកំយ
សូមបងទម្លាក់សត្វស្វាព្រៃ ទុកនាំតិតកំយដល់ដំរិត ។
ព្រោះស្វាជាសត្វខូចទិលណាស់ ដូចរឿងព្រះវិស្សន្តរតតិ
បើបងយកវាធ្វើជាមិត្រ ខឹងឲ្យគេសតិតដល់មរណា » ។
ព្រានព្រៃឮស្តីមិត្រចិត្តគិរីយ ស្តាប់ពាក្យសំដីនៃសត្វខ្ញុំ
ក៏បែរប្រែចិត្តស្និទ្ធស្នេហា ជាមួយសត្វខ្ញុំយ៉ាំងជិតជិត ។
គិតថា « បរបាញ់កល់ថ្ងៃ·ខៃ ខ្ញុំបតែសត្វខ្ញុំផ្តាច់ដំរិត
ឥឡូវបានខ្ញុំធ្វើជាមិត្រ អញលែងកំយគិតគិតខ្ញុំបអ្វី » ។
គិតហើយព្រានព្រៃប្រាន់ខ្លាក់ ស្វាសក៏ធ្លាក់ខ្លាកដល់ដី
ខ្ញុំធំសុះភ្លែតបាប់ក្រញី ជាន់តប្រុងធ្លីពេលខោះណា ។
ស្តេចស្វាជម្ចាស់ហាមាត់ស្រែញ មាត់ខើបឆ្មៃញាចេញជ្រួញចង្កា
ដោយស្វាកំយខ្ញុំបអំណាចខ្ញុំ ញាប់ញ័រកាយាញើសហូរខ្លាយ ។

ឃើញស្វា មុខជូចថ្លៃក្រូចស៊ើច ជ្រួញទើចថាស៊ើចលេងសប្បាយ
ក៏សួរទៅស្វាថា « អាអន្តរាយ អាស៊ើចសប្បាយដោយហេតុអ្វី? ។
អញខំត្រែវចំកន្ទែងល្អ កាច់កសម្ងាប់ចាប់សាច់ខ្លី
ខំឆ្លៃថ្លើមអាឯងជាន់ថ្មីៗ អញធ្វើឲ្យធ្លាញ់មាត់អញម្តង ។
ស្វាសព្វជាតិឈ្លេចតែសត្វ មានឫទ្ធិម៉ាត់លើសសត្វផង
ប្រាប់ថ្លាមុតក្រែកទូន្ធង ខំយោយសាសង់ខំធ្វើថា ។
ខ្លាអើយអីខ្លាអាស់ឈ្លាញ់ បង់ស៊ីថ្លើមអញធ្លាញ់ពិសា
ថ្លើមទៅកន្ទុយធ្លាញ់ណាស់ណា ថ្លើមធ្លាញ់ពីសាថ្លើមស្វាស » ។
ឮស្វាថាថ្លើមទៅកន្ទុយ មានសេដ្ឋតឈ្មួយ ខ្លាលែងតែ
ស្រែកកន្ទុយនៃស្វាស ស្វាសែនត្រេកអរផុតទប្រមា ។
ស្ទុះឡើងដើមឈើញាញីមព្រាយ ពាក់ពាក់រុះរាយខំយោយថា
« ម៉េចទៅថ្លើមអញធ្លាញ់ពិសា ឈ្មួយធ្លាញ់យ៉ាងណាអាចត្រែ » ។
ស្តេចខ្លាចាញ់កលធ្វើអំមើអឿន មៀមៀទៅកៀនគេចដោះដៃ
រត់ចៀសកៀសខ្លួនពួនក្នុងព្រៃ ខ្លាស់ស្វាសក្រៃថ្ងៃនោះឯង ។
ស្វាសត្រេកអរពន់ពេកក្តាត់ ឃើញខ្លាគេចបាត់ពីកន្ទែង
ចូលទៅជិតព្រានឥតគិតក្រែង សំដែងកាក់ពាក់ហាក់សន្ធាន ។
ពោលថា « ព្រានអើយអ្នកកុំព្រួយ ជំនិតអ្នកមួយខ្ញុំជួយបាន
អ្នកកុំកិតក័យន្ទែត់ប្រាណ នៅឲ្យសុខសាន្តណាព្រានណា ។

គេឯងយកកម្ចាំងនៅទីនេះ ខ្ញុំទៅរកបេះខ្នុរចាយស្រា
ខ្លះណាំងមង្សឹតលុតសេដា ជូនអ្នកតាសាតាមសប្បាយ ។ ។
ថារហើយស្វាសចរចេញទៅ ចូលក្នុងព្រៃជ្រៅភ្នើសហូរខ្លាយ
ស្ទើងរកផលាក្នុងព្រៃធ្លាយ ដោយគ្មានដឹងណាយកាយចិត្ត ។

ព្រានតាលតម្ងៅទ្រៀមទ្រុស្តមិត្ត ស្ទុះចូលទៅជិតកូនស្តេចស្វា
វាយដែងាត់ធាក់បែកកាយា បែកក្បាលចាក់ស្មាចាក់ដើងដៃ ។
ហ្វូងស្វាផ្អើលជ្រួលចាំងគួច-ធំ ចោមរោមតទ្ធំហ៊ីដុំព្រានព្រៃ
ស្ទុះចូលប្រុងទាំហែកដើងដៃ ព្រានព្រៃតយព្រៃក្រៃហោយំ ។
ពេលនោះស្វាសចូលមកជល់ ឃើញចលាចលផ្អើលពួកក្រុម
ស្វាឈ្មោលស្វាញីចាំងគួច-ធំ តទ្ធំហ៊ីប្រុងចាំទាំព្រានព្រៃ ។
ក៏ស្រែកសំឡុតឃាត់ស្វាថា «នែវើយក្រុមស្វាប្រញាប់ហៃ
ចៀសចេញឲ្យផុតពីព្រានព្រៃ គ្មានតយទ្ធត់ព្រលឹងគ្មាន ។
តើរឿងហេតុអីអ្នកវាល់គ្នា ធ្វោឡោពាធាយាយីព្រាន ? »
ក្រុមស្វាចាំងឡាយថ្វាយតតិមាន ថា « ព្រានឈ្មោនពានអន្សតុំរ៉ៃ ។
វាយដែងាត់ធាក់ប្អូនធីតា ចាក់ដៃចាក់ស្មាបែកសរីរៈ
ឈាមក្រហមច្រាលជាលពាសដី លែតស់សញ្ញីសូន្យក្សីណាក្សី » ។
ស្វាសមើញកូនសូន្យដូរិត ស្ទុះចូលទៅជិតឥតសង្ស័យ
លើកថ្នមបីបម្រុងដោយអាល័យ អង្អែលដើងដៃសព្វកាយា ។

ក៏ក្រាបទៅថា «អ្នកចាំងឡាយ ចិត្តខ្ញុំសែនស្តាយបុត្តធីតា
ម៉ែនក្នុងលោកជោកកាម តែងតែស្នេហាកូនប្រុសស្រី ។
ខ្លួនខ្ញុំជាឥតិសិទ្ធស្នេហ៍ កូនដូច្នោះដែរណាក្រៃ
កូនខ្ញុំកំពុងតេញបេតិ៍ រលត់សញ្ញីសូន្យដីវ ។
បើអ្នកចាំងឡាយសម្លាប់ព្រាន ត្រូវតែអ្នកហ៊ានខសន្យា
ព្រានស្លាប់ កូនខ្ញុំរស់វិញណា សឹមផ្តាច់ដីវនៃព្រានវិត្រ ។
បើកូនខ្ញុំមិនរស់វិញទេ ត្រូវអ្នកវិនេតិលកលៃ
ខ្លួនអ្នកមានទុក្ខជាប់ទោសពៃរ៍ យាមខ្មោចព្រានវិត្រតកូន-ចៅ» ។
ក្រុមស្វាចាំងឡាយថ្វាយបង្គំ លើកដៃប្រណាមស្រុតលើស្មៅ
ទូលព្រះបង្គំល្ងិតល្ងង់ខ្លៅ សូមស្តេចប្រដៅច្បាប់បណ្ឌិត» ។
ស្តេចស្វាពោលថា «អ្នកចាំងឡាយ កុំក្តៅក្រហាយស្តាយដីវិត
របស់កូនខ្ញុំណា ណាមិត្រ ព្រោះកម្មអតីតរបស់វា ។
បើយើងសម្លាប់ព្រានវិត្រទៅ កម្មពៀរជាប់នៅគ្រប់វេលា
តាមជាប់គ្រប់ជាតិឥតឃ្លាតឃ្លា សោយទុក្ខវេទនាជាអង្វែង ។
ដូចមានព្រះពុទ្ធកាសិតនិ៍ កម្មតាមជាប់ស្ថិតឥតគោតក្រែង
ដូចកង់វេះគ្រប់កន្លែង កន់តែងវិលតាមដើងគោ ណា ។

(នៅមានត)

ពោហលកណ្ឌំ ដ្ឋិតំ ។ យើងស្រដីកណ្ឌំណាំពីរប្រការ នៃនាង
វិមលាទេវីនោះមិញ ស្រេចនូវប្រការអម្បាលនេះហោង ។ សោ រញ្ញោ
កថំ សុត្វា ។ រីឯបុណ្ណកយក្ខនោះ ស្តាប់ព្រះបន្ទូល ព្រះមហាសត្វនោះ
ហើយ ទើបទូលថា បពិត្រមហាកដ ព្រះអង្គមានព្រះបន្ទូលម្តេចដូច្នោះ
រីសេះខ្ញុំតែ ១ នេះ មានកំលាំង មានលក្ខណៈប្រសើរលើស ឧដ្ឋសេះព្រះ
អង្គជារយជាពាន់ ។ ឧដ្ឋស្មើសេះខ្ញុំតែមួយនោះពុំបានឡើយ សូមមានព្រះ
អង្គទតកំលាំងសេះខ្ញុំហោង បុណ្ណកយក្ខ ទូលមហាសត្វ នូវប្រការ
អម្បាលនោះហើយ ផែលព្រួចរួចឡើងលើខ្នងសេះមនោមយ ប្រពៃបរ
ទៅលើភាគបន្ទាយ សឹងដឹមានទំហំនោះ ៧ យោជន៍យល់មិនហក់ជាសេះ
តែមួយឡើយ ហាក់យល់ដូចសេះជារយជាពាន់ ប្រកិត ។ ឧដ្ឋគ្នា វិសេយ
ហាក់ដូចអ្នកដឹកនូយសេះឧដ្ឋគ្នា យល់ពាសពេញ លើភាគបន្ទាយហោង
រីឯបុណ្ណកយក្ខនោះ មិនយល់ច្បាកដឡើយ យល់ច្បាកដប៉ុន្តែសំពត់ដម្ក
បុណ្ណកយក្ខ ចោមពួងនោះ យល់ហាក់ដូចអ្នកយកភ្លើងត្រីរលើភាគបន្ទាយ
នោះហោង បុណ្ណកយក្ខបរសេះចុះមកហើយ ក្រាបទូលព្រះធនញ្ជយ
កោរព្យាកដថា បពិត្រមហាកដ ព្រះអង្គទតយល់ កំលាំងសេះមនោ-
មយនេះ តើយល់ជាម្តេចទៅព្រះអង្គ ព្រះបាទធនញ្ជយកោរព្យាកដ
មានព្រះបន្ទូលថា ម្នាលទៅកំចាយមាណពអើយ យើងយល់កំលាំងសេះ
ទៅខ្លាំងហោង ឥតសេះឯណាឧដ្ឋដូមសេះទៅបានឡើយ បុណ្ណកយក្ខ

ទូលថាមហាភដ ព្រះអង្គ មួយវិញទៀត កាលមុននោះ ខ្ញុំដុះបរផង ឥឡូវ
នេះខ្ញុំឲ្យប៉ុន្តែតួមនោម័យនោះទៅតែឯង បុណ្ណកយក្ខថាម្ល៉ោះហើយ
ស្រដីទៀនមនោម័យថាវៃមមនោម័យ ចូរព្រះស្តេចរត់ទៅ លើខ្នងទឹក
ស្រះមានតាកង់ព្រះនគរ កណ្តាលមុខព្រះលាន ព្រះមហាក្សត្រនោះ។
រីឯមនោម័យនោះ លុះឮពាក្យបុណ្ណកយក្ខ ទៀនដូច្នោះហើយស្តុះហៀ
ហោះទៅមួយរំពេចលើទឹកស្រះនោះសោត ខាប៉ោលក់ទឹកនឹងជិតក្រចក
ដល់តិចនោះគ្មានឡើយ មួយសោត នោះប៉ស្តឹកឈូកក្រមុខទត្សលក្តី
ឧដ្ឋានស្មៅស្មោកជាច់ជាចដល់តិចនោះគ្មានឡើយ ទើបបុណ្ណកយក្ខ
លាបាតដៃ ស្រែកហៅទៅមនោម័យថានែមនោម័យ ព្រះស្តេចមកឈរ
លើបាតដៃអញឥឡូវនេះឯង ឯមនោម័យឮពាក្យបុណ្ណកយក្ខ ស្រែក
ហៅដូច្នោះ ហើយក៏វៃ ក្រដូវរត់អំពីនាយមកឈរលើបាតដៃ បុណ្ណកយក្ខ
មួយរំពេចនោះផង មិនយល់ជាបុណ្ណកយក្ខសួយសេះមនោម័យឡើយ
យល់ហាក់ដូចកល់គេសូនក្រមួន ជារូបសេះ ហើយយកមកជាក់លើបាត
ដៃ បុណ្ណកយក្ខសួយមនោម័យ ហើយចូលមកទូលមហាក្សត្រថា បពិត្រ
មហាភដ ព្រះអង្គទតសេះមនោម័យខ្ញុំនេះ តើយល់ជាម្តេចព្រះអង្គ ជា
សេះព្រះអង្គជារយៈជាតាន់ តើបានឧឡឹងសេះខ្ញុំតែមួយឬទេព្រះអង្គ ? រ័មហា-
ក្សត្រស្តាប់ហើយឆ្លើយថា ចៅតំបាយមាណពអើយ នាពាក្យចៅស្រដី
នោះពិពេះគាប់ពិតហោង យើងរកសេះឯណាមកផ្ទឹមនឹងសេះចៅនេះមិន

ជានឡើយ ចៅបុណ្ណកយក្ខទូលថា បពិត្រមហាពាជ តែសេះមនោម័យ
ម៉ែចនឹងរកឱ្យស្មើគ្នាន ចំណាន់បើតែវមណីរត្នខ្ញុំនេះ នឹងជាល្អលើសអស់
តែវផងតាំងឡាយអេះ រីសេះមនោម័យនេះ ខ្ញុំពុកស្ទេះនៅនេះ សូមមាន
ឥឡូវនេះ ព្រះអង្គខតឯរស្មើមណីរត្នេះវិញ បុណ្ណយក្ខស្តួយតែវមណីរត្ន
នោះឡើង នឹងសំដែងថ្លែង រស្មើតែវមណីរត្នោះហើយ ទើបទូលទៅព្រះ
មហាក្សត្រ សូត្រជាបទព្រះគាថា: ឥទញ្ហ មណិរតនំ ។ ថាបពិត្រ
មហាពាជដ៏ជាធំទត្តមកទ្ធនវិក្រលែងនឹងក្សត្រផងតាំងឡាយអើយ អញ្ជើញ
ព្រះអង្គខតរស្មើតែវមណីរត្នេះមានជាជំពូក ។ មានស្រីផងសឹងមានត្រឿង
ប្រដាប់ សំពាប់គាត្តាតែ ។ ហើយមានសត្វម្រឹគបក្សី ខាតនូវគ្រុឌពាជ
យល់ច្បាតជ កន្តតែវមណីរត្នេះ សូមព្រះអង្គខតមើលមានសេនាតាំង
៤ ជំពូក សេនាដ៏រ សេនាសេះ សេនារទេះ សេនាពលថ្មើជើង សឹងកាន់
ត្រឿនអាវុធ ប្រកិតឈរវៀងត្រវផង សូមមានមហាពាជ អញ្ជើញខត
រមិលមើល មានតាំងតែពាយល់ហានាន់ច្រាលពិពណិ នូវគូត្រលែងតែង
កំពែងក្លោងទ្វារ ច្រការ ច្រើនសឹងយល់ជាក់ច្បាស់ក្នុងមណិខ្ញុំនេះហោង
មហាពាជ សូមមានព្រះអង្គខតរមិលមើល មានតាំងពពួកសត្វបក្សីបក្សាផង
ច្រើនផ្សេង ។ មានតាំងក្ងានក្អែកចុងលេខាក តាវើហង្ស ក្រៀលចន្ទ្រៀល
ខ្យង ត្រយ៉ង កងកេង តូ ត្រុំ តាជក ចាកក្រពាក ដំរុកដំរាក សឹងដំចំយ
នៅលើ កំពែងច្បាការក្លោងទ្វារ នោះយល់ជាក់ច្បាតជ កន្តតែវមណីរត្ន

នេះហោង មហាពជសូមព្រះអង្គ ទតរមិលមើលមានតាំងនគរ ហើយ
មានតំពែងបាការក្នោងទ្វារយល់អស្ចារ្យ ត្រកាលក្រៃពេក ហើយមាន
តាំងខន់មាសខន់ប្រាក់ ត្រសាក់ត្រសុំល្អ នាស្ថាននោះសោត ដុះដាស
ពាសពេញទូវឡាច់មាសផងច្រើន ហើយមានខ្លាសាលដំទុំមន្ទីរតូចធំ
ហើយមានពពួកប្រុសស្រីផង ដើរទៅមក ហើយមានតាំងផ្ទះអ្នកប្រមឹក
ស្រា មានតាំងផ្ទះតូចធំ មានផ្ទះផ្កាមាសតូចទូវផ្ទះផ្កាមាសធំ យល់ជាក់
ច្បាស់ ប្រាកដក្នុងតែវមណីវត្ថុខ្ចីនេះហោង មហាពជ សូមមានព្រះអង្គ
ទតរមិលមើលមានតាំងអ្នកក្រងផ្កាមាលាក្តី មានតាំងអ្នកវិញ្ញែរ្យ មាន
តាំងអ្នកបោះ កប្បាស ចោកសំពត់ មានតាំងអ្នកជាងខន់ដំមាស មាន
តាំងអ្នកទ្វាស់ធ្នាក់តែវ យល់ជាក់ច្បាស់ក្នុងតែវខ្ចីនេះ មហាពជ ព្រះអង្គ
ទតរមិលមើល មានអ្នកពិសេស ចេះចំអិន ក្រយ៉ាំស្ងោយ មាន
តាំងអ្នកចេះមើលកំណាព្យគាថាឃ្លោងតន្ទោងតន្ទាស់ចំរៀងផង មានតាំង
អ្នកចេះពាក្យ សំគោហោចិត្តផងកើរ មានតាំងអ្នកចេះផ្ទុំត្រែស័ង្ខប៊ីប៊ីឡុយ
មានតាំងអ្នកចេះកូតខ្លែ ដេញចាប៊ីសាដៀវ មានតាំងអ្នកចេះខេះខៃ ចេះ
ដំខ្លៀង មានតាំងអ្នកចេះច្រៀងចេះរាំ ខ្លាសារតើជូរឈ្នួតន្ត្រីផងតាំង ៤
យល់ជាក់ប្រាកដ ក្នុងតែវមណីវត្ថុខ្ចីនេះហោង មហាពជ ព្រះអង្គទតរមិល
មើល មានតាំងអ្នកប្រតប់ប្រដាល់ ខ្លាំរំលោត ពួនសួត្រាត់ មាន
តាំងអ្នកចេះរាំពេនក្លោក ខ្លាំរាំពេនជាវ យល់ជាក់ច្បាស់ប្រាកដក្នុងតែវ

ខ្ញុំខេះហោង មហាពជ ព្រះអង្គខតរមិលមើលទៅអ្នកចំបាប់ ប្រចាប់ប្រកៀក ប្រកេះប្រកោះគ្នាចោតវាត់មក រីឯអ្នកឈ្នះនោះឈរនៅរីអ្នកចាញ់វត់ចេញទៅ យល់ជាក់ច្បាស់ច្រាកដក្នុងកែវមណីរត្នខ្ញុំខេះហោង មហាពជ ព្រះអង្គខតរមិលមើលសត្វម្រឹគផងពាំងព្រាយច្រើនជាដើម គឺពជសីហ៍ ដំរី ក្រែក ខ្លា រមាំង រមាស ឈ្លូស ជមាំខ្លាត្រែក ក្រចៀក ប្រើស ត្រាយ ខន្សាយ ខន្សោង ខ្លោងគោរៃ ស្វាខស្វា ឆ្មាជាដង់ច្រើន យល់ជាក់ច្បាស់ច្រាកដក្នុងកែវមណីរត្នខ្ញុំខេះហោង មហាពជ ព្រះអង្គខតរមិលមើល មានបក្សីផងច្រើនផ្សេង ។ ជាដើមតីហង្ស ក្រៀល ចង្រៀលខ្យង ត្រយ៉ង កណ្តឹង តុំ តាជក ចាកក្រពាកជីវុកដីវាក ក្ងានក្ងោក ចោរសោត តារើដងច្រើន យល់ជាក់ច្បាស់ច្រាកដក្នុងកែវខ្ញុំខេះហោង មហាពជ ព្រះអង្គខតរមិលមើល មានពាំងត្រពាំងបឹងស្ទឹងស្រះ មានទឹកហូរថ្វាជ្រះស្រឡះរុះមក មានពាំងត្រីផងពាំងច្រាយ ជាដើមតីបង្កង តិន្ទង ក្រពើ ឆ្លាម ឋបែល កំកេលផ្សោតនូវអណ្តើកកន្ធាយ ត្រសៃ ក្រាសល្ងិច សឹង ហែបហែល អង្គែលអង្កែ ព្រៀវព្រៃទៅមក ដោយខ្លួវសេតវង់ថ្នា សឹងយល់ច្បាស់ច្រាកដក្នុងកែវមណីរត្នខ្ញុំហោង មហាពជ ព្រះអង្គខតរមិលមើល ទៅយល់អស់ទ្វីបពាំង ៤ គឺបូពវិទេហទ្វីប ១ អមរគោយានីទ្វីប ១ ឧត្តរកុរុទ្វីប ១ ជម្ពូទ្វីប ១ សឹងយល់ជាក់ច្បាស់ក្នុងកែវមណីរត្នខ្ញុំខេះហោង មហាពជ សូមខានព្រះអង្គខតរមិលមើល មាន

ចាំងព្រះអាទិត្យ ត្រះច័ន្ទ ខ្លួវអស់ផ្កាយផង ប្រទក្សិណភ្នំព្រះសុមេរុបព៌ត
ភជមានចាំងសត្តបរិកណ្ឌាចាំង ៧ ហើយ មានចាំងព្រៃព្រះហេមពាន្តស្ថាន
ប្រទេស មានចាំងសមុទ្រធំ ចាំង ៤ យល់ជាក់ប្រាកដ ក្នុងតែវត្ថុនេះ
ហោង មហាភជ ត្រះអង្គខតរមិលមើល ធតាមាសួតិចាំង ៦ ជាន់ខ្លួសោ
ឡសត្រហ្មសួតិចាំង ១៦ ជាន់ យល់ចាំងខេវបុត្រ ខេវតា ខេពតញ្ញាផង
កម្ពាន្តសម្បាយ ប្រសែងប្រចាប់គ្នាយល់ជាក់ច្បាស់ប្រាកដ ក្នុងតែវត្ថុនេះ
ហោង មហាភជ សូមមានព្រះអង្គខតរមិលមើល ខៅស្ទឹកនងតែវនោះ
សឹងល្អ ១០ ជំពូក មុខតួរតិតពិលមិលមើល ខៅយល់ល្អប្រសែត តាប់ចិត្ត
ពេកក្រៃ រីស្ទើលឿងនោះសោត មាន ២០ ជំពូក រស្ទើដូចរមៀតនោះ ១៤
ជំពូក រស្ទើដូចមាស ២០ ជំពូក រស្ទើដូចប្រាក់នោះ ២០ ជំពូក រស្ទើពណ៌
ដូចខ្នងអណ្តើកមាសនោះ ៣០ ជំពូក រស្ទើខ្មៅនោះ ១៦ ជំពូក រស្ទើហង្ស
ស្បាទនោះ ២៩ ជំពូក រីតែវមណិរត្នៈនេះ ដំតិចត្រ ទីខៅខ្លួវផ្កា
ខិល្យលទ្ធស្ល ខ្លួវផ្កាច័ន្ទន៍ មហាភជ ត្រះអង្គខតរមិលមើល ឲ្យសព្វ
ត្រប់ដោយជ្រុងតែវមណិរត្នៈខ្ញុំនេះ មានរស្ទើនោះផ្លុក ៗ ផ្លេកបន្ទោរវត់
ប្រវាត់ មើលហើយគួរតែត្រេកអរមិនលែងឡើយ ។ មណិតណ្ឌំខិដ្ឋិត ។
នេះស្រដីតាន់មណិរត្នៈ បុណ្ណកយក្ខ សំដែងថ្វាយព្រះមហាកប្បត្រមិញ
សូរបេខ្លួវប្រតារអម្បាលនេះហោង ។ ឯវ្ញា បន វត្ថា បុណ្ណកោ តហិវ្ញា
តុត្តមានសោ វេតេន តន្ថា ធម្មសភំ បវិសិ ។ រីបុណ្ណកយក្ខ ស្រដីសរសើរ
តែវមណិរត្នៈ ឧដ្ឋសេះមនោមយ ខ្លួវប្រតារអំបាលនោះហើយ ខេប

ទូលទៅ មហាសត្រូវថា បពិត្រមហាភាគ លេងស្អាតនឹងខ្ញុំនេះ ថា
បើខ្ញុំចាញ់ព្រះអង្គហើយ ខ្ញុំថ្វាយតែវមណិរត្ន នឹងសេះមានាម័យ ជា
ដំណាំងស្អា ព្រះអង្គហោង ថាបើព្រះអង្គចាញ់ខ្ញុំ តើព្រះអង្គឲ្យអ្វីជា
តំណាំងស្អាខ្ញុំព្រះអង្គ ។ ព្រះបាទធនញ្ជយកោរព្យាភ ស្តាប់ហើយឆ្លើយ
ថា ចៅមាណពអើយ រឿងប៉ុន្តែខ្លួនអញ នឹងព្រះភាគរបស់ខ្លួនត្រូវសេនច្ចត្រភាគ
សម្បត្តិ សំពប់ព្រះភាគច្រើនឯណា សំណល់លែងនោះ អញខុតជាច្រើន
ដំណាំងស្អាចៅហោង ថាបើចៅឈ្នះអញហើយ កំអញតាមតែចិត្តចៅ
នឹងច្រើនយកហោង បុណ្ណកយក្ខ ថាបពិត្រមហាភាគ បើដូច្នោះព្រះអង្គ
កុំឲ្យយូរឡើយ ដ្បិតខ្ញុំនេះមកអំពីចម្ងាយ គោះបើខ្ញុំចាញ់ឈ្នះក្តី ខ្ញុំនឹងអាល
ត្រឡប់ទៅឆាប់ សូមព្រះអង្គឲ្យណ្តាប់លែងស្អានោះ ឲ្យឆាប់ហោង
មហាសត្រូវស្តាប់ហើយ បន្ទូលទៅនឹងអស់អាមាត្យថា នែ ម្នាលអស់អាមាត្យ
ផងតាំងឲ្យាយអើយ ចូរគ្នាតាំងឲ្យាយទៅរណ្តាប់ភេងស្អាឲ្យឆាប់ រីអ
មាត្យក្នាក់ងារ តែងប្រដាប់ភេងស្អានោះរួចដូចព្រះបង្គាប់ច្រើនោះស្រេច
ហើយ ទើបក្រាលនីទៅខ្ទរចៀមចំព្រៃត្រាំតន្ទនិត្ថប្រដាប់តម្រាល ព្រះបាទ
ធនញ្ជយនោះផ្សេង តំកលស្តេចមួយរយនឹងមួយនោះផ្សេង ។ តម្រាល
បុណ្ណកយក្ខនោះផ្សេងទៀត ដោយខ្ទរសំគួរជាទីស្តេច ទីកស្តេហោង លុះ
រៀបស្រេចហើយ ចូលទៅក្រាបទូល ព្រះមហាសត្រូធិកភ ស្តេចស្តាប់
ហើយ មានព្រះបន្ទូលទៅនឹងស្តេចមួយរយ នឹងមួយ នឹងបុណ្ណកយក្ខថា ឥ
ឡូវនេះ ភេងស្អារៀបស្រេចហើយ គួរយើងនឹងលេងហោង ។

(នៅមានត)

សមត្ថភាពគឺអ្វី

ព្រះមុនីកោសល ស្វ.ម.ហាយ អធិបតីវគ្គក្រុមដំទុំព្រះវិន័យបិដក

តែងរៀបរៀង

សមត្ថភាព ជាធម៌ចាំបាច់ជាងគេបំផុត ដែលមនុស្សត្រូវជាន់ជ្ញាក់តែងត្រូវការ ។ ពាក្យថាសមត្ថភាពនេះ មកអំពីបាលីថា សមត្ថភាវោ ប្រែថា «ភាពអង់អាច កងវៃ ចុំនប្រសប់ ខ្លៀវខ្លាស ឈ្លាសវៃពូកែ» ។ បាលីមួយទៀតថា បដិពលោ ប្រែថា «ការអង់អាច ។ល។ ដូចគ្នានឹងពាក្យថា សមត្ថភាពដែរ ឬប្រែថាប៉ស្ទាថា «ប្រតិពល» ក៏បាន

ពាក្យថា សមត្ថភាព នឹងពាក្យ ប្រតិពល មានសេចក្តីដូចគ្នា ។ ពាក្យទាំងពីរម៉ាត់នេះ បើយើងត្រូវការយកមកនិយាយក្តី សរសេរក្តី អាចប្រើប្រាស់បានដូចគ្នា ។ ក្នុងអត្ថបទនេះ យើងសូមយកពាក្យប្រែថា «ពូកែ» មកធ្វើអត្ថាធិប្បាយ ព្រោះពាក្យថា «ពូកែ» ជាពាក្យសម្រាយ វប្បធម៌ របស់ខ្មែរយើងគ្រាប់ប្រើមកហើយ ដែលប្រែចេញមកអំពីពាក្យថា សមត្ថភាព ឬ ប្រតិពល ។ ពាក្យទាំងពីរម៉ាត់នេះ ជាឈ្មោះប្រាជ្ញាកងវៃក៏បាន ជាឈ្មោះកាយ ដែលប្រកបដោយសិល្បៈស្ទាត់ជំនាញក៏បាន

មនុស្សពេលបួស សុទ្ធតែត្រូវការចង់ឲ្យមានសេចក្តីពូកែអង់អាច

ឈ្មោះវៃនៅកន្លែងខ្លួនតាំងអស់ ឥតមានឧរណាមួយបដិសេធចោលឡើយ ។ ភាពនៃសេចក្តីពូកែនេះ តែងមាននៅក្នុងកាយរបស់មនុស្សស្មើរតែគ្រប់គ្នាដែរ ប៉ុន្តែភាពពូកែនោះមិនស្មើគ្នាទេ គឺអ្នកខ្លះមានភាពពូកែច្រើនមុខ អ្នកខ្លះមានភាពពូកែតិចមុខ ឬក៏អ្នកខ្លះពូកែកន្លែងនេះ អ្នកខ្លះពូកែកន្លែងនោះ ឃើញថាភាពពូកែនេះផ្សេង ។ គ្នាជាដរាប ដោយសេចក្តីរួបរួមថា មនុស្សដែលបានឧទ្ទេសសេចក្តីសុខ សេចក្តីចំរើនតាំងអស់ សុទ្ធតែកើតមកអំពីសេចក្តីពូកែ ។

ពាក្យថា « ពួកពៅ » នេះ មានច្រើនយ៉ាងណាស់គឺ ពូកែខាងការសរសេរ ពូកែខាងការអាន ពូកែខាងការទេសនា ពូកែខាងការស្តាប់ ពូកែខាងជាងឈើ ពូកែខាងជាងកំបោរ ពូកែខាងធ្វើមន្ត្រី ពូកែខាងពាណិជ្ជកម្ម ពូកែខាងកសិកម្ម ពូកែខាងចែវទូក ពូកែខាងបាររេះ ពូកែខាងចើករថយន្ត ។ ល ។ ភាពពូកែតាំងនេះ ត្រូវតែប្រឹងប្រែងធ្វើឲ្យមានកន្លែងក្នុងចិត្ត ដើម្បីអាចដោះស្រាយបញ្ហាដ៏វិត ឲ្យបានសុខចំរើនខ្ពង់ខ្ពស់បានប្រាកដពិត ។ ការកើតមកជាមនុស្ស ក្នុងសង្គម ក្នុងប្រទេស ជាមួយគ្នាក្តី ផ្សេងគ្នាក្តី ត្រូវតាំងផ្នែកលើភាពពូកែជាដរាប ទើបយោងខ្លួនរួច ។

មនុស្សតាំងអស់ក្នុងសកលលោក ដែលខាត់ខន់ដោយការណ៍យកចិត្តខ្លះច្រើន ខ្លះតិច ខ្លះធ្ងន់ ខ្លះស្រាលពិតមែន ប៉ុន្តែការខាត់ខន់តាំងនោះ

សុទ្ធតែឈមមុខទៅរកនឹងជីវិតមួយ គឺជីវិតប៉ុណ្ណោះឯង ។ ការណីយកិច្ច
គ្រប់យ៉ាងរបស់មនុស្ស ប្រព្រឹត្តទៅ ដើម្បីរៀបចំជីវិត ការងារជីវិតរបស់
ខ្លួន ឲ្យបានខ្ពស់ហាន:ថាជាជីវិតខ្ពង់ខ្ពស់ប្រសើរឡើងប៉ុណ្ណោះ ។

ហេតុដូចបានរៀបរាប់មកនេះ បញ្ជាក់ឲ្យឃើញថា ភាពពូកែរបស់
មនុស្សក្នុងលោក មានតិរយ៉ាង ដោយសេចក្តីប្រមូលមួយ៉ាងខ្លីបំផុតដូចការ
រៀបរាប់ខាងក្រោម ព្រមទាំងអធិប្បាយពន្យល់សេចក្តីនៅទៅនេះ ៖

ភាពពូកែ ២ យ៉ាង គឺ

១-បិត្តពូកែ គឺភាពពូកែនោះមុត ទាន់ផ្លូវចិត្ត

២-កាយពូកែ គឺភាពពូកែដោយសុខភាព មានកម្លាំងកាយរឹងប៉ឹង។

ពាក្យថា « បិត្តពូកែ » បានដល់សេចក្តីត្រិះរិះគិតដោយចិត្ត ដែល
ស្ទាត់ទាន់ពៀរធាប់ហ៊ាសធង់ ទាំងសេចក្តីគិតនោះច្រើនតែប្រកបដោយហេតុ
ផលល្អផង ។ ភាពឈ្វាសពៀរបស់ចិត្ត ដែលអាចគិត អាចពិចារណា
បានច្រើនយ៉ាងនោះ ត្រូវប្រកបដោយហេតុពីរយ៉ាងទៀតគឺ សេចក្តីនឹក
រឭកចាំបាន ចំពោះការណីយកិច្ចគ្រប់កាលទាំងអស់ ទាំងអតីត ទាំង
បច្ចុប្បន្ន នឹងអនាគត ១ សេចក្តីដឹងខ្លួន ក្នុងការធ្វើ ការនិយាយ នឹង
ការគិតគូរ ១ ។

ពាក្យថា « កាយពូកែ » បានដល់ភាពពូកែដោយកាយ ដែលប្រ-
កបដោយសុខភាពល្អ មានសាច់ឈាមធំធាត់ល្មម មានកម្លាំងគ្រប់គ្រាន់

ផងមានសិល្បៈដោយការតាំងសោធន៍ ក្នុងរបៀបតន្ត្រីឲ្យស្ងាត់ជ្រាកដូចផង គឺ
ភាគកាយពូកែខាងដើរ ខាងរត់ ខាងលោតផ្លោះ ខាងប្រដាល់ ខាងហែល
ទឹក មុជទឹក ឬខាងតន្ត្រីណាមួយ ដែលត្រូវប្រើដោយកម្លាំងកាយ ។
ភាពពូកែស្ងាត់ដំនាញដោយអាស្រ័យឥទ្ធិពលរបស់កម្លាំងកាយនេះ ហៅ
ថាកាយពូកែ ។

បិត្តពូកែ ឧទ « កាយ្យពូកែ » នេះ រកបានដោយក្រណាស់ ជា
ពិសេស ដើម្បីត្រូវកសាងខ្លួនឲ្យមានភាពពូកែតាំងពីរយ៉ាង ទើបជាការ
ប្រសើរបំផុត ប៉ុន្តែភាពពូកែខាងចិត្ត មានប្រៀបប្រសើរជាង ព្រោះថា
កិច្ចការតាំងអស់ ដែលត្រូវធ្វើដោយកាយ ក៏សុទ្ធតែត្រូវអាស្រ័យចិត្តជាមុន
ទើបប្រព្រឹត្តទៅបានដោយស្រួលល្អ ។ ពាហារហ៍ ដូចយ៉ាង ការសរ
សេរតែងសេចក្តី និពន្ធចងក្រង ធ្វើជាសៀវភៅណាមួយ មនុស្សខ្លះ សរ
សេរភ្ជួរអក្សរបានល្អ តាំងរបៀបអក្ខរាវិរុទ្ធក៏ត្រឹមត្រូវល្អ ប៉ុន្តែសេចក្តីកន្លះ
យោគទីមួយ ។ មិនសូវត្រឹមត្រូវ មិនច្បាស់ដោយពាក្យតេចន្តំខ្លះ
ឃើញថា សេចក្តីកន្លះអត្ថបទនោះ ។ មិនខ្ពង់ខ្ពស់ មិនមានគោលការណ៍
ល្អ ដែលគួរអ្នកមើលចាប់ចិត្តបានឡើយ ។ អ្នកនិពន្ធនេះឈ្មោះថា មាន
ភាពពូកែតែខាងកាយ មិនពូកែខាងចិត្តទេ លុះតែមនុស្សដែលមានចិត្ត
ពូកែ កាយក៏ពូកែ ទើបសរសេររៀបរៀងតែងសេចក្តីបានល្អគ្រប់លក្ខ-
ណៈ គឺតាំងភ្ជួរអក្សរ តាំងរបៀបអក្ខរាវិរុទ្ធ តាំងសេចក្តី ។

ការដើងខ្លួនជានិច្ចគ្រប់អវយវៈ មិនបណ្តាយសតិសម្បជញ្ញៈឲ្យ

ឃ្លាតចេញអំពីចិត្ត ដើម្បីជាហេតុនាំមិនឲ្យក្ងេចដើម ក្ងេចពុង ក្ងេចមុខ ក្ងេចក្រោយ ។ ប្រៀបដូចអ្នកបរវេយ្យន្ត ដែលប៉ុនប្រសប់បរទៅតាមថ្នល់ស្គាល់របៀបថ្នល់ដែលមានបត់រៀបវេរ ឬភ្លុកដង្កឹក តែងយកចិត្តទុកជាក់ចាំជាក់ជានិច្ចឥតក្ងេចភ្លាំង ដើម្បីវេយ្យន្តមិនខាសចេញអំពីថ្នល់ មិនផ្ទោះផ្ងោយ មិនប្រទះគ្រោះថ្នាក់ ដោយហេតុអ្នកបរវេយ្យន្ត មានស្មារតីបិតទៅក្នុងចិត្តជានិច្ច ទោះបីឆាកភ្នែកមើលទៅខាង កឺឆាកមើលតែមួយភ្នែក មិនបណ្តោយឲ្យចក្ខុវិញ្ញាណ ចាប់អារម្មណ៍ដែលយើញនោះឡើយ ។ ការនឹកវៃក ការដឹងខ្លួនជានិច្ច មិនក្ងេចភ្លាំងមិនធ្វេសប្រហែស នេះជាលំហើយថា សតិសម្បជញ្ញៈ ឈ្មោះថាជាធម៌មានឧបការៈច្រើនណាស់ ។

ចិត្តរបស់បុគ្គលណាដែលបរិបូណ៌ដោយសតិ នឹងសម្បជញ្ញៈ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាមាន សមត្ថភាព ឬហៅថា បិត្តព្យកៃ គឺជាចិត្តនឹងធ្ងន់ ជាចិត្តសម្បូណ៌ដោយធម៌ជាដំនួយ កាលបើចិត្តព្យកៃ ចាំងកាយក៏ជានហាត់រៀន តាមកម្មវិធីដែលប្រកបដោយសិល្បៈ កំរែងនាំកាយឲ្យព្យកៃ ទៅតាមចិត្តដែរ ដែលហៅថា នាំកាយឲ្យមានសមត្ថភាព ដើរទៅជាមួយនឹងចិត្តដោយពិត ។

បុគ្គលកំពុងប្រកបការណាមួយ ត្រូវកំណត់ទុកជាមុនថា បើសតិសម្បជញ្ញៈ របស់អាត្មាអញជាប់កិច្ចការណាមួយយូរៗទៅ ច្រើនតែចិត្តឃ្លាតចេញអំពីគោលការ ដែលកំពុងធ្វើ ។ ដំណើរនេះ ហៅថា

ចិត្តស្ទុះចេញរួចអំពីសតិសម្បជញ្ញៈ នាំឲ្យចិត្តនៅតែម្នាក់ឯង មិនមានធម៌ជាមិត្រសម្លាញ់នៅជាមួយ ជាហេតុនាំឲ្យថ្ងោះគ្មាយកន្លងពេលខ្លះឯង កន្លងរយៈពេលនៃចិត្តដែលប្រាសចាកសតិសម្បជញ្ញៈនេះហើយ ដែលហៅថាប្រមាទ គឺសេចក្តីធ្វេសប្រហែសរបស់មនុស្ស ដែលតែងកើតមានឡើងកន្លងពេលដែលចិត្តខ្លាតចេញអំពីសតិសម្បជញ្ញៈ ។ បុគ្គលមានចិត្តថ្លៃបន្តិច សូម្បីដើរក៏ភ្លាត់ ធ្លើការក៏ភ្លាត់ និយាយក៏ភ្លាត់ សរសេរក៏ភ្លាត់ ។ ការភ្លាត់ភ្លាត់ ការភ្លេចនេះ ក៏នាំឲ្យទៅជាភ្លើ ព្រោះហេតុតែចិត្តមិនមាន សម្បជញ្ញៈ ជួយគ្របដណ្តប់អប់រំ យូរៗទៅក៏ភ្លាយទៅជាមនុស្សខ្វះ សតិសម្បជញ្ញៈ មិនអាចប្រើការកើត ដោយហេតុតែចិត្តអណ្តែតអណ្តូនតែលតោល មិនមានធម៌ជួយទប់ត្តម្ភ នេះឯងហៅថាចិត្តគ្មានសមត្ថភាព គឺចិត្តមិនភ្លឺថែក កាលបើចិត្តមិនភ្លឺថែក កាយដែលភ្ជាប់មានសិល្បៈ ក៏មិនភ្លឺថែដែរ ។

គ្រោងកាយរបស់យើងទាំងមូលនេះ បើដកចិត្តចេញផុតហើយ ឥតមានអ្វីជាតម្លៃទៀតទេ ហៅថា អស់សារប្រយោជន៍របស់កាយហើយ ចំណែកខាងចិត្ត កាលបើដកសតិសម្បជញ្ញៈចេញផុតហើយ ក៏ឥតមានអ្វីជាតម្លៃដូច្នោះដែរ ។ ចិត្តនឹងកាយ ត្រូវតែប្រាស្រ័យទាក់ទងរួបរួមគ្នាដោយសាមគ្គីជាឯកភាព បរិបូណ៌ដោយសុខភាព ដោយសតិសម្បជញ្ញៈទើបហៅថា មានសមត្ថភាព គឺភាពភ្លឺថែកងងៃទាំងចិត្តទាំងកាយ កន្លងរ៉ាំណាយកិច្ចត្រូវយ៉ាងដោយពិត ។ ចប់ ។

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង-ខាត់ រៀបរៀង

(តមក)

អនន្តុធ្យាយន្តិ កាលមិនឆំកដល់ ។

អនន្តុរូប គុ. ដែលមិនអន្លូប ដែលមិនសំគ្រេ ។

អនន្តុម្នាន ន. បុ. កិរិយាប្រហែសធ្វេស ។

អនន្តុសន្ធាន ន បុ. កិរិយាមិនស្វែងរក ។

អនន្តុសរណ ន បុ. កិរិយាមិនរឭកតាម ។

អនន្តុត្តាន ន បុ. កិរិយាមិនរក ឬមិនប្រតិបត្តិតាម ។

អនន្តូពី គុ. ដែលមិនខុស ពិត ។

អនន្ត គុ. ដែលមិនមានទីបំផុត បិតថេរ ។ បុ. ព្រះសិរ ព្រះវិស្ណុ គេមះ តាមស្តេចនាគ ។ ន បុ. សេចក្តីភ្ញៀងខាត់ ។ – ៣ ស្ត្រី. ភាវនៃ សេចក្តីភ្ញៀងខាត់ ។ – ក គុ. ដែលមិនមានទីបំផុត – វិត្តិ គុ. ដែលមានសេចក្តីភ្ញៀងខាត់ – ការ គុ. ដែលធ្វើមិនឲ្យមានទីបំផុ ។ – កីត បុ. ឈ្មោះមនុស្ស ។ – គុណតា ស្ត្រី. ភាវនៃ . . . មានគុណមិនមានទីបំផុត ។ - ជ្ជិន គុ. ដែលមានខ្នងកង់តាប់មិន អស់ ។ - ជារ គុ. ដែលមានត្រើយតំរឹងតាប់មិនអស់ ។ វីរិយ បុ. ឈ្មោះឡងសង្ខនៃព្រះជាទ្យយុធិដ្ឋិរ ។ - សីរ បុ ឈ្មោះមនុស្ស ។

អនន្តរ គុ. ដែលមិនមែនខាងក្នុង ដែលទៅភ្លាម (ក្នុងអាកាស ក្នុងដួង ឬក្នុងពេល)
អនន្តធម៌ ក្រ. វិ. តាមលំដាប់ ។ ប៉ុ. បងប្អូនដែលមានអាយុបន្ទាប់ ។ ឬ
- ដ គុ. ប្លែនបន្ទាប់ ។ - ជាត គុ. ដែលកើតបន្ទាប់ ប្លែនបន្ទាប់ ។
- ទ្រ គុ. ដែលមិនស្គាល់សេចក្តីផ្សេងគ្នា ។

អនន្តរាសសិ គុ. ដែលមិនមានអាវក្រៅខាប់ ។

អនន្តរ្យ ន ប៉ុ. កិរិយាមិនមានទីបំផុត ។

អនន្ត ប៉ុ ឈ្មោះតិរិភពលោក ។

អនន្ត ន ប៉ុ. (វត្ថុ) ដែលមិនមែនជាអាហារ ។

(នៅមានត)

ម្ចាស់ផែនដី ១ អាមាត្យ ១ អាណាបក្រ ១
បន្ទាយ ១ ឃ្លាំង ១ សេនាង្គភាព ១
សម្ពន្ធមិត្រ ១ ពលរដ្ឋ ១ សង្គមប្រជាករ ១
ទាំងអស់នេះ ជាអង្គនៃរាជ្យគឺប្រទេសជាតិ ។

ហិតោបទេស

រឿងអាប៊ូលេបហ្វ៉ាស្ស៊ីរ៉ែស

លោក ភ័ឃ.ល្មុត តំណាងកម្ពុជា ប្រែរឿបរឿង

(ភ)

អ) ឃើញថាគាត់មានពាចាចន់តែយកអាសាខ្ញុំ ខ្ញុំមានចិត្តខ្មាសខ្លួន សប្បាយត្រេអរកេរ៉ិបំផុតគ្មាន . . . គាត់ក៏ប្រែមានចិតមុខចិញ្ចឹង ជញ្ជាចដូចមនុស្សត្រូវស្នេហ៍ ហើយគាត់អង្វរខ្ញុំឲ្យទៅទៀវផ្ទះគាត់ ។ គាត់និយាយតទៅទៀតថា ៖ ខ្ញុំចាស់ហើយ ខ្ញុំជាអ្នកមានធនធានទ្រព្យសម្បត្តិសុកស្តួម ខ្ញុំគ្មានកូន ខ្ញុំសុំយកអ្នកជាកាយាទ អ្នកទទួលមរតកពីខ្ញុំ . . . មាត់និយាយ ដៃគាត់លូកមកប្រវ៉ាទុបរតែខ្ញុំ ទៅនឹងដើមទ្រូងគាត់ ដូចជាខ្ញុំ កូនគាត់បន្តើតដូច្នេះ ។

លុះឃើញសក្តីសញ្ញានៃសេចក្តីពាក់ព័ន្ធពាក់ព័ន្ធអាន ព្រមទាំងចិត្តស្រឡាញ់អាសារាយដោយមេត្តាដូច្នេះ ខ្ញុំក៏មានទំនុកចុកចិត្តអស់ពីពោះ ទើបដើរដោយស្ងួតបូតតាមទៅគេហដ្ឋានគាត់ ។ ឯផ្ទះគាត់នោះសោតទៅទីក្រុងសុភ័ត ទំនឹងថាឥតសេចក្តីរង្គើរឿងសម្បូណ៌សប្បាយនោះ ឥតអង្គុីមានឡើយ ទាំគ្នាដើរដល់ទៅផ្ទះ មានឪយទាំប្រដាប់ដោយឯកសណ្ឋានយ៉ាងល្អមកបើកទ្វារ ក្រឡេកក្រែកទៅឃើញ មានសួនព័ទ្ធជុំវិញគ្រប់ថែបគ្រប់យ៉ាង ទៅកណ្តាលសួនព័ទ្ធនោះ មានផ្ទះមួយខ្ពស់ឈរក្រាលថ្មយអរឆ ហើយល្អ រំលេចពណ៌ក្តីថ្មាជាងថ្មកែវទៅទៀត ។ ផ្ទះនោះជាប់

ផុតឯផ្ទះធំតែម្តង ។ ថ្ងៃបើគ្មានលេនមាសរលើបរលោង ដើម្បីឲ្យឆើតជាយទៅខៀតកំពិតមែន តែផ្ទះធំនោះមានគ្រឿងលំអ មានតុៈខ្ពស់ ។ មិនដឹងបើនឹកបាប ។ កម្រាលនឹងព្រំតាំងឡាយ សុទ្ធសឹងតែបចនាលើសំពត់ តែសំពត់តាំងនេះស្រស់បស់គួរស្ញើច ព្រោះមានសាច់ម៉ដ្ឋលើសំពត់តាំងអស់ដែលមានទៅទីក្រុង ម៉ាស៊ុលីប៉ាតាន នឹងតាមឆ្នេរសមុទ្រកូរម៉ង់ដែល ។

ជាបឋម លោកហៅខ្ញុំឲ្យទទួលទឹកដូចលោកដែរ កងអាងទឹកមួយធំធ្វើពីថ្ម មានទឹកថ្លាត្រជាក់ស្អាត ។ អាងទឹកនេះ តាមធម្មតា គឺសម្រាប់លោកងូតទឹក ដើម្បីឲ្យត្រជាក់កាយលោក ហើយដើម្បីបំពេញការណ៍ឃ្លាំងលោកខាងសាសនាផងដែរ ។ នៅពេលងូតទឹករួចហើយ មានភាសាជាច្រើនយកសំពត់ស្តើង ។ មកជូតខ្លួនយើងតាំងពីនាក់ស្រេចហើយ យើងតាំងពីនាក់ទាំងគ្នាទៅអង្គុយ នៅកងសាលមួយត្រង់តុៈមួយ ពោរពេញទៅដោយសាច់ច្រើនបែប នឹងម្ហូបអាហារកងភាជនៈពីរឿនឯ ។ បណ្តាភោជនៈតាំងនោះ មានជាអាទិ៍គឺសម្លធ្វើពីផ្លែម្ទុស្ការ ពីក្តាំពូនៃស្រុកម៉ាកាស្សារ ពីខេតពាស្រែម្ទារស្លែងនៃក្រុងសេវេនឌីប . . . ។ ដល់ទទួលទានអាហារភោជនឆ្អែតឆ្អល់តាមត្រូវការស្រេចហើយ យើងតាំងពីនាក់ផ្ទានសេពស្រាគ្នាត ដែលខ្ញុំឃើញថា មានឧជារសអស់ពីចិត្ត ។

លោកឪពុកថ្មីរបស់ខ្ញុំ លោកមានប្រសាសន៍កាន់ខ្ញុំជាលំដាប់លំ

ដោយខ្សឹបៗ ប្រើសំឡេងជាអាថ៌កំបាំង សេចក្តីថា៖ ឪពុកនឹងប្រាប់កូន
ខ្លួនឯងសម្ងាត់មួយ ដើម្បីជាបន្ទាល់សាក្សីនៃសេចក្តីស្រឡាញ់ដោយ
ស្មោះចំពោះរបស់ឪពុកទៅលើកូនឯង ។ ក្នុងដប់ប្រាំថ្ងៃទៀត កូនស្ងួន
អើយ! ឪពុកត្រូវធ្វើដំណើរចេញពីទីក្រុង ស៊ូអាលី ទីក្រុងនេះប្រហែល
កូនភ្លាំដឹងទេ គឺជាកំពង់សមុទ្ររបស់គោះសុព៌ត ឪពុកនឹងធ្វើដំណើរទៅ
កាន់គោះមួយ ដែលឪពុកធ្លាប់តែទៅជារឿងកាលឆ្នាំ ។ ឪពុកគិតនាំ
កូនឯងទៅជាមួយផង ។ គោះនោះជាទីរហោឋានស្ងាត់កំបាំង មានសត្វ
ខ្លាសាហាវពាសពេញ ។ ក្នុងគោះនោះ មានអណ្តូងចំនួនជាពីរយ
សុទ្ធសឹងជាអណ្តូងមានគន្លងវង្វេង គន្លុំគ្រុំធំ។ អស្ចារ្យ មានតែឪពុកម្នាក់
ឯងប៉ុណ្ណោះទេ ដែលដឹងរឿងនេះ ។ មានន័យសំរាប់ម្នាក់ឯង
ប្រាប់ឪពុក ខ្លួនតំណាងនេះ ព្រោះកាលឪពុកធ្វើជាទាសារបស់គាត់
គាត់ស្រឡាញ់ឱ្យចិត្តលើឪពុកជាទីបំផុត ហើយគាត់ឯងប្រាប់ឪពុក
អំពីរបៀបត្រូវធ្វើយ៉ាងណា។ អាចទៅដឹងគោះនោះបាន ថ្វីបើមានសត្វ
តំណាងតាំងនោះ គឺយើងត្រូវលែងឲ្យទៅដល់គោះ ទៅពេលយប់
ហើយនាំគ្នាលបឡើងទៅ ដោយកាន់ចន្ទុះអុជនេះក្តីទៅដៃ ។ សត្វតាំង
នេះ កាលបើវាឃើញភ្លើង វាតែយផ្តើលជ្រួលជ្រាលស្ទុះរត់អស់ទៅ
អំពីអណ្តូងដ៏មានតម្លៃវិសេសវិសាលតាំងនោះ យើងនឹងកេតដំបូន
សន្ធឹកសន្ធាប់តាំងការរុង។ នាំមកទីក្រុងស៊ីរ៉ាតវិញ លក់ទៅបានប្រាក់

មិនដឹងជើនឆកថ់ ហើយប្រាក់ដែលយើងបាននោះ យកមកផ្សំគ្នាជាមួយនឹងទ្រព្យសម្បត្តិឪពុកដូចកូនយើញនឹងក្អែកស្រាប់ យើងនឹងទៅជាអ្នកមានកោតទ្រព្យយ៉ាងសំបើម ប្រាក់កាសសម្បត្តិចាំងនេះ ចុះឪពុកយកទៅណា! មុខជាឪពុកឲកឲ្យកូនចាំងអស់ ដល់ឪពុកស្លាប់ចាត់បងជិវិតទៅ . . . . . ។ ដើម្បីឲ្យខ្ញុំជឿសិប់ គាត់ទាំខ្ញុំ (អ.) ចូលទៅក្នុងបន្ទប់មួយ ហើយគាត់បង្ហាញប្រាក់រូបីយ៍តរចាំងពន្លឺក ។ ឲ្យខ្ញុំមើល . . . ហើយគាត់និយាយមកកាន់ខ្ញុំទៀតថា អើ បើដូច្នេះ កូនសំឡាញ់អើយ ចូរកូនយកចិត្តឪពុកដាក់ឲ្យមែនទែន . . . . ចុះកូនសប្បាយឬមិនសប្បាយនឹងធ្វើដំណើរទៅជាមួយនឹងឪពុក ចូរប្រាប់សំឡាញ់ប្រាប់ឪពុកឲ្យត្រង់មកចុះ!

– ខ្ញុំ (អ.) ធ្វើយទៅវិញថា បាទ! ខ្ញុំសប្បាយនឹងធ្វើដំណើរទៅជាមួយលោកឪពុក តែសូមលោកឪពុកមេត្តាអញ្ញាតឲ្យខ្ញុំសរសេរសំបុត្រមួយទៅដំរបឪពុកខ្ញុំ រៀបរាប់ហេតុផលចាំងឡាយ ដែលនាំឲ្យខ្ញុំសំចតទៅតិក្រុងសុរ៉ាតនេះមួយគ្រាសិន . . . ។

(ហ៊ឺ) – ពិតហើយ! ត្រូវសរសេរសំបុត្រទៅ! កាលណាកូនសរសេរសំបុត្រហើយ កូនឲ្យសំបុត្រនោះមកឪពុក ។ ទឹងបញ្ជូនឲ្យដល់ទៅឪពុកកូនឲ្យ (អ.) – ដូច្នេះ ខ្ញុំមានទំនុកចិត្តចាំងស្រុងលើលោកហ៊ីហ៊ូម ក្នុងរឿងផ្ញើសំបុត្រនេះ ។ ដល់ថ្ងៃធ្វើដំណើរ យើងទៅចុះ

សំពៅទៅកំពង់ស៊ីអាល ហើយបើកក្តោងចេញទៅ ។ យើងបើកសំពៅ
អស់រយៈពេលប៉ុន្មានហ្ន៎ ឃ្លានយើញតិចម្ល៉ៃ ខ្លួរគោះតូចមួយរហា
ហាន លោក ហ៊ីហ្គ្រីមថា ហ្នឹងហើយ គោះខ្ទុះយើងបតនាវ៉ា ហើយរង់
ចាំដល់ពេលយប់ ទើបយើងចុះពីសំពៅទៅលើដីគោះ ។ នៅពេល
នោះ កម្មករសំពៅទាំងឡាយត្រូវនៅចាំសំពៅ ។ មានតែលោក
ហ៊ីហ្គ្រីម ខឹងខ្ញុំ (អ.) តែពីនោះប៉ុណ្ណោះ យើងនាំគ្នាយកថង់ជាច្រើន
ទៅផង សម្រាប់ដាក់គរដហើយនៅដៃយើង ។ កាន់ចន្ទុះនេះក្លឹង មាន
ចន្ទុះជាច្រើនទៀត យើងកៀបនៅក្រោមក្លៀក ដើម្បីបើចន្ទុះមួយអស់
យើងអូសបន្តទៅទៀត ។ យើងនាំគ្នាដើរស្ទាប ។ រកអណ្តូង ហើយមិន
ឃើញប៉ុន្មាន យើងប្រទះអណ្តូងមួយ អណ្តូងនេះជ្រៅជាងគេទាំងអស់ ។
លោក ហ៊ីហ្គ្រីម និយាយថា ៖ កូនសំឡាញ់ ចូរកូនចុះទៅក្នុងអណ្តូងនេះ
ខ្ញុំដឿថាត្រូវតែជាមានគរដល្អ ។ ច្រើនទៅទៀតនេះ . . . . ។

(អ.) – ខ្ញុំចុះតាមខ្សែពួរ លោក ហ៊ីហ្គ្រីម កាន់តន្ទុយខ្សែម្ខាង ។
លុះខ្ញុំដល់ទៅបាតអណ្តូង ខ្ញុំឆ្ពុកក្ងិន ខ្ញុំដឹងថាមានខ្យងក្រោមបាតជើងខ្ញុំ ។
ខ្ញុំរើសខ្យងទាំងនោះហើយប្រគល់ថង់មួយទៅឲ្យ ខ្ញុំបង់ថង់នោះភ្ជាប់ទៅនឹង
ខ្សែ ។ លោក ហ៊ីហ្គ្រីម លោកទាញខ្សែយោងថង់មកលើស្រាយមើល
តិចតួចខ្លាំង ដោយឃើញតែតន្ទុកគរដខ្លះ ។ គាត់បង់ថង់ទៅវិញ ហើយ
ទម្លាក់ទៅឲ្យខ្ញុំ ទាំងនិយាយថា ៖ គរដនៅក្នុងអណ្តូងនេះ មិនទាន់ចាស់

ល្មមលក់ចាន់ទេ ។ កូនឯងជាក់ទៅឯចាតអណ្តូង ហើយយកដំលុបទៅវិញ . . . ដល់ឆ្នាំខាងមុខ តដំចាំងនេះខ្ពង់ខ្ពស់ សឹមយើងយកវា ។

(អ.) ខ្ញុំធ្វើតាមលោក ហ៊ីហ៊ូមប្រាប់ ហើយគាត់ក៏ពាក្យយោងខ្ញុំឡើងមកវិញ ។ យើងចាំងពីរនាក់នាំគ្នាទៅឯអណ្តូងមួយទៀត ជ្រៅជាងអណ្តូងមួយនេះទៅទៀត ។ អណ្តូងនេះបិតទៅចាតនៃភ្នំមួយឮដំកណ្តាលគោះ ។ ខ្យងក្នុងអណ្តូងនេះ មានតដុស្ម ។ ថ្មែកខ្លុសគេ ។ ខ្ញុំប្រមូលច្រកថង់ជាច្រើន លោកហ៊ីហ៊ូមចេះតែពាក្យយោងមកខាងលើ ។

នាគាលគាត់ចាន់តដ៏ច្រើនគ្រប់គ្រាន់ ល្មមគាត់យកវួចហើយគាត់លែងខ្ទាក់ខ្សែទៅទៀត ហើយមុខគាត់ចាំងញញឹម ។ គេចង្រ្កាយនិយាយថា ៖

អញ្ជាលហើយអានាងអើយ! អញអរគុណហើយចំពោះកិច្ចការអកុសលកន្លះក់ដែលឯងធ្វើឲ្យអញ . . . ។

(អ.) ខ្ញុំយល់ចាន់ថា នេះពិតជាកលល្បិចឲ្យ ខាំឲ្យខ្លួនខ្ញុំដល់ខ្លួវមហាភ័យ មហាអាសន្នពន់ប្រមាណ ខ្ញុំក៏ស្រែកដង្ហើយថា ៖ ឱ! លោកឪពុក សូមលោកមេត្តា ។ ពាក្យយោងខ្ញុំចេញពីទីនេះ សូមលោកមេត្តា . . . ។

(នៅមានត)

រឿងបងប្អូនពីរនាក់បែកមតិគ្នា

លោក ជេង-ស្រីវ៉ា និតន្ត (តចប់)

ដោយបានឃើញវែកមាស ហើយបងបានវៃក្រពេក បុរសបងធ្វើយ ប្រាប់ទៅតាចាស់វិញថា: ជាន! លោកតា! ខ្ញុំបានក្លែរហើយ ខឿងតែ ក្លែរហើយឥឡូវ ។

បុរសបង គ្មានបានឲ្យថ្លាយមួយដុំដល់ឆ្កែសោះ ស្រាប់តែដេញ ឆ្កែឲ្យទាញខ្ទឹល បង្ខំឲ្យបានទាប់ហើយ ដើម្បីយកវែកមាសអំពីតាចាស ដួចមុស់លោកជ្រាបស្រាប់ ឆ្កែនឹងមានកម្លាំងពីណាដួចគេ ម្ល៉ោះហើយ គ្មានប្រឹងទាញទាំងត្រដរ ណាបុរសបងភ្លេសតងពីក្រោយ ។ ដោយ ភ័យនឹងរំពាត់ពេក ឆ្កែប្រឹងទាញខ្ទឹលទាល់តែចេញអាចម៍ ។ ឯបុរស់ បង ដោយក្តៅនឹងឆ្កែចេញអាចម៍ ទាញខ្ទឹលមិនរួច ក៏វាយសំតងថែម ខឿត ។ ទីបំផុត ឆ្កែទាំងពីរកំដួលដេកវាក់ទៅណាមិនរួច ជាក់លោង ដោយត្រូវនឹងដំបងបុរសកំណាច ។

ឃើញដូច្នោះ ដោយអស់សេចក្តីសង្ឃឹមថានឹងបានវែកមាស បុរសបង កើតចិត្តមោហោគសោដ៏ខ្លាំង ទើបស្រែកដេរឆ្កែថា: អាសត្វអពមង្គល អាសត្វចង្រៃ! អាសត្វហិនហោច! គេយកវែកមាសមកឲ្យ ។ តែវាទំ ទាញខ្ទឹលក្លែរដើរឲ្យហើយ វាពុំព្រមទាញ បើម្ចាស់វាក្លែរ ម្តេចវាទំទាញ

ឲ្យហើយតាល់តែបានវែកមួយ ។ ម្ល៉ះហើយអញក្តៅណាស់! អញមិន
ខុកអាឯងនិទេ ។

ថាតែប៉ុណ្ណោះហើយ បុរសកម្រោលកយឆ្កែតាល់តែក្រឡើយ ហើយ
អូសយកទៅចោលនៅក្បែរមាត់ព្រៃ រួចវិលត្រឡប់ទៅផ្ទះធ្វើព្រងើយ
ហើយរអ៊ូរទាំក្រុបក្រប្រពន្ធថា អូនឯងម៉ើលចុះ! យើងចំណាស់យមែន!
ព្រោះតែអាឆ្កែចង្រៃ វាមិនទំប្រឹងតាញឲ្យឯងសោះ កុំអីបានវែកមាសមួយ
តាចាស់ម្នាក់យកវែកមាសមួយលឿងឆ្អៅមកជាក់ពីមុខ ជាឲ្យតែបងក្លែដើ
ហើយ តាត់ខឹងឲ្យវែកនោះ អាឆ្កែចោលមឿត វាមិនព្រមតាញតាល់តែ
សោះ ឥឡូវខានបានវែកទិញ ទឹងតែក បងវាយវាសម្លាប់ចោលទៅហើយ។

ប្រពន្ធជាស្រីកាឡកណ្តើកពេញចិត្តចំពោះអំពើអកុសលរបស់ប្តីអាក្នា
រួចពោលបន្ទរថា: ត្រូវបង! បងឯងធ្វើនោះត្រូវតែតប្រាកដ ត្រូវតែសម្លាប់
វាចោល ព្រោះវាមិនទំជួយយើង ។

លុះកន្លងទៅបានមួយថ្ងៃ បុរសប្តូនមិនឃើញបងយកឆ្កែមកឲ្យ
តាត់ក៏ទៅឯផ្ទះបង ដើម្បីសួរទៅដំណឹងឆ្កែដែលបាត់ មិនឃើញយកទៅ
ប្រគល់ឲ្យ ហើយតាត់សួរបងថា: ដូចម្តេចទៅឆ្កែខ្ញុំ បងមិនឃើញ
យកទៅឲ្យខ្ញុំ ? ឥឡូវឆ្កែតាំងពីរទៅឯណាបង?

បងឃើញប្តូនទៅដល់ ទឹកភ្នែកស្រក់ ។ លុះឮប្តូនសួរដូច្នោះ បង
ឆ្លើយមកតាំងខឹងថា: ប្តូនឯងតំសួរ អញក្តៅណាស់ អាឆ្កែចង្រៃ តាចាស់

ម្នាក់ថាឲ្យវែកមាស ឲ្យតែក្លិនស្រែនោះហើយ អាឆ្កែចង្រៃ វាមិនចង់ច្រឹងជួយគាញនង្គ័លដើម្បីក្លែងឲ្យហើយសោះ បន្តិចឈប់ បន្តិចឈប់ ប្អូនឯងជួយគិតមើលណាមើល ធ្វើអីចឹង វាសមដែរឬ? ឲ្យតែវាជួយចំអូសបន្តិចទៅ ឯងបានវែកមាសស្រេចទៅហើយ ។

ប្អូនសួរទៀតថា: ហើយឥឡូវ ឆ្កែខ្ចីទៅឯណាបង? បងធ្វើយតាំងពីដំបូងថា: ប្អូនឯងកុំសួរវែកវង្វើអ្វី អាឆ្កែអតមង្គលនោះ អញវាយសម្លាប់ចោលហើយ ។

ខំមិត្តតែឮសំដីអកុសលដូច្នោះ បុរសប្អូន ស្តុតចិត្ត ភ្លាក់ខ្លែមក្តុកក្រោះអាណិតឆ្កែអាត្មាក្រែពេក តើឆ្កែនេះហើយជាប្រកួត នៃសុភមង្គលរបស់ខ្លួន រួចគាត់សួរថា: បងឯងវាយសម្លាប់ហើយ យកទៅចោលទៅណា? - បងប្រាប់ធ្វើត្រឹងើយថា: អញអូសយកទៅចោលទៅមាត់ព្រៃ ក្បែរចំការអញឯនោះ ។

បុរសប្អូនមិនឱយាយអ្វីតទៅទៀត ហើយទៅរកខ្ចោចឆ្កែជាទីស្នេហា រួចដឹកនាំទៅកាន់សំណាក់នៃខ្លួន ។ គាត់ដឹករណ្តៅកប់ឆ្កែរបស់គាត់យ៉ាងស្រួល ដូចជាគេកប់ខ្ចោចមនុស្ស ។ មិនយូរប៉ុន្មាន ស្រាប់តែមានចំពាំងឫស្សីព័ទ្ធដុះចេញពីផ្នូរខ្ចោចឆ្កែពាំងពីរនោះ ។ បុរសប្អូនមើលថែរក្សាថ្នាលំអាតក្បែរចំពាំងឫស្សីជាទីបួច ហើយកន្ធឹងយូរមក ចំពាំងពាំងពីរក្លាយទៅជាឫស្សីពីរដើម ប្រកបដោយស្លឹកបៃតងស្រស់ ។ គ្រប់ពេលចំ

នេះ បុរសប្អូនតែងទៅដេកលេងសម្រាកខ្លួនទៅខឹងមួយប្តីប្រពន្ធ រមែងតែជាធម្មតា ស្តាប់សូរសេពួស្ទឹកប្តីប្រពន្ធត្រូវឮលាន់បក់មក ដូចជាគួរឲ្យតក្កន្តី ។

រឿងប្តីប្រពន្ធនេះក៏លេចឮជាដំណឹងដល់ទៅបុរសបងនៀតថា ឆ្កែដែលគាត់ឲ្យសម្លាប់នោះ ឥឡូវដុះក្លាយទៅជាដើមប្តីមួយគួយ៉ាងស្រស់ ទៅខាងក្រោយផ្ទះប្អូនគាត់ ខាងក្រោយដែលប្អូនគាត់យកខ្មោចឆ្កែទៅកប់ ។ ដំណឹងនេះធ្វើឲ្យបុរសបងកើតក្តៅក្រហាយម្តងទៀត ដោយគាត់គិតថាឯងសម្លាប់ឆ្កែចោល ឥឡូវឆ្កែនោះជួយចំរើនក៏ដុះទៅជាប្តី ចើដូច្នេះអញត្រូវតែបំផ្លាញប្តីនេះចោល កុំឲ្យសល់ជាតិឆ្កែទៅ ។ ពេលយប់ស្ងាត់ បុរសបងបានកាប់ចិតមួយយ៉ាងមុត លបទៅលួចកាប់ប្តីរបស់ប្អូនរំលំពាំងពីរដើម ។

ព្រឹកឡើង បុរសប្អូនក្រាក់ពីដេក ឃើញប្តីរលំដូច្នោះ មានសេចក្តីស្តាយពន់ពេក ។ គាត់នឹកសង្ស័យគ្មានណាចអធមក្នុងចិត្តថា តុ ! អ្នកណាអើយ ម្តេចឡើយមានចិត្តព្យាបាទមកកាប់ចំផ្លាញប្តីជាទីស្រឡាញ់ពេញចិត្តនៃអាត្មាយ៉ាងនេះ ។ បុរសប្អូនក៏យកប្តីពាំងពីរដើមមកលួសពុះប្រៀកជាបន្តោះ ហើយតម្បាញបានជាជាលមួយ ។

គាត់យកមានជាក់ឲ្យដេកទៅក្នុងជាលកល់យប់ ។ ស្រាប់តែមានការអស្ចារ្យកើតឡើងទៀត គឺព្រឹកឡើងសុតមានពាំងប៉ុន្មានក្បាយជាដុំមាសពាំងអស់ ។ ដូច្នេះ ពល់ព្រឹក បុរសប្អូនតែងរើសយកមាសបួនដប់ដុំពីក្នុង

ជាលទ្រុងមាន់ជាធម្មតា ។

ដំណឹងស្តីពីជាលដែលធ្វើឲ្យមាន់ពងមក ចេញដុំមាសឮ សាយទៅ
ជល់បុរសបងម្ខាងទៀត ។ ដោយចង់បានដុំមាសដូចប្អូន ក្មេងតិតជល់កំ
ហុសបែរខ្លួនលើកមុន បុរសបងស៊ូត្រាំតាំងខ្លាស់ក្បែន ទៅខ្ចីជាលទ្រុង
មាន់ពីប្អូន ដើម្បីយកមកជាក់ឲ្យមាន់ពង ។ គាត់ចាប់មេមាន់ប្រមែលជប់
ជាក់ក្នុងជាល ដោយសង្ឃឹមថាព្រឹកស្អែក គាត់ខឹងបានមាសជប់ដុំជាពិត
ប្រាកដ តែជាការផ្ទុយទៅវិញ គាត់មិនឃើញដុំមាស ក្នុងគេលដែល
គាត់លូកដៃទៅរើស ត្រឡប់ឃើញសុទ្ធតែពស់វែកពុងបើកពពាប់ពុងចឹក
ដៃគាត់ទៅវិញ ។ បុរសបងកញ្ឆក់ដៃចេញយ៉ាងហ៊ោស ក័យផ្អែមមាត់
ស្ទើរបាត់ព្រលឹង ។ សេចក្តីមួម៉ៅក្តៅក្រហាយកំកើតមានឡើងដល់គាត់
លើសលើកមុនៗទៅទៀត ។ សេចក្តីព្យាបាទខាងមនុស្សយោជកកើត
មានពេញក្នុងសន្ធានគាត់ៗ គិតជាមួយនឹងកំហែងថា យើងត្រូវតែលបសែង
យកជាលទ្រុងមាន់ពេញសុទ្ធតែពស់វែកទៅចាក់ទៅផ្ទះអាប្អូនអញ ដើម្បី
ឲ្យពស់ចឹកសម្លាប់តាំងប្តីប្រពន្ធអស់ទៅ ទ្រព្យសម្បត្តិក៏ នឹងធ្លាក់មកលើ
យើងជាពិតប្រាកដ ។ នេះជាមធ្យោបាយកេប្រាក់បានដោយមិនបាច់ខំ ។

ប្រពន្ធឃើញប្តីត្រលប់ជាមួយជាន ។ ដល់អធ្រាត្រយប់ស្ងាត់ ប្តីប្រ
ពន្ធនាំគ្នាលើកសែងជាលទ្រុងមាន់ទៅលបទម្លាក់ចាក់ ទៅត្រង់មាត់ទ្វារផ្ទះ
ប្អូន រួចត្រឡប់តេរយ៉ាងប្រញាប់មកផ្ទះអាគ្នាវិញ ដោយសង្ឃឹមថាព្រឹក

ឡើង ខឿនតែបានដំណឹងល្អមកដល់ខ្លួនជាមិនខាន ។ តែមិនដូច្នោះ
ហេតុតែកុសលនៃអំពើសុចរិតរបស់ប្អូន ពស់កន្ធរជាលខាំប៉ុន្មានប្រែក្លាយ
ជាដុំមាសខាំអស់ ទៅតរត្រង់មាត់ទ្វារផ្ទះ តែជាលនោះបាក់ខ្ទេចគ្មាន
សល់ ដោយសារការខម្លាក់យ៉ាងខ្លាំងរបស់បុរសបង ។

ក្លឹឡើង ភ្ញាក់ពីដំណេក បុរសប្អូនឃើញមាសនៅក្បែរទ្វារ ក៏ហៅ
ប្រពន្ធឲ្យយកកញ្ជើមកកើបយកមាសចូលទៅកន្ធរផ្ទះ ចំណែកជាលដែល
បាក់ខ្ទេចនោះ គាត់ទឹកស្តាយរកអ្វីប្រៀបគ្មាន តែមិនដឹងធ្វើដូចម្តេច
គាត់ប្រមូលយកទៅបូជា ។ ឯផេះនៃជាល គាត់យកទៅតប់កន្ធរចំការ ។
ត្រង់កន្លែងតប់ផេះនោះ ស្រាប់តែឃើញមានដុះត្រឡាចចេញមក ។ បុរស
ប្អូនត្រេកអរ ទំថែថ្នាក់ថ្នមត្រឡាចមិនហ៊ានឲ្យនរណាទៅប៉ះពាល់ឡើយ ។

សូមដំណាលថា ត្រឡាចនេះថ្លែកពីត្រឡាចធម្មតា មានខន្ធប៉ុនកដៃកូន
ក្មេង ស្លឹកធំប៉ុនកញ្ជើ លាស់ខ្ចីលខ្ចប់ពាសពេញតែចំការរបស់គាត់ ហើយ
មានផ្លែធំ ។ អស្ចារ្យប្រមាណប៉ុនតាងលូ ។ ឃើញដូច្នោះ បុរសយើងមាន
សេចក្តីសប្បាយរីករាយក្រៃលែង ។

ដំណាលថា ទៅព្រៃក្តុំក្បែរនោះ មានស្វាមួយហ្វូង ពួកស្វានេះ
តែងតែមកលួចបេះផ្លែត្រឡាចគាត់ទៅស៊ីជាញឹកញាប់ ។ បុរសយើង
សង្កេតទៅ ឃើញបាត់អស់ផ្លែត្រឡាចច្រើន ទើបគាត់ត្រិះរិះរកឧបាយ
ដើម្បីចាប់ស្វា ។

ថ្ងៃមួយជាទិវាសល្អ គាត់បេះផ្លែត្រឡាចចាំងអស់ដឹកយកទៅផ្ទះ ហើយទុកឲ្យទៅសល់តែផ្លែត្រឡាចមួយដែលធំជាងគេ រួចគាត់លុងផ្លែត្រឡាចតូចៗទាំងអស់ យកគោះចោលចេញ ធ្វើយ៉ាងណាឲ្យគាត់អាចចូលទៅដេកសម្ងំនៅក្នុងផ្លែត្រឡាចបាន រួចយកសាច់ដុំកន្ទុយបិទក្លិតមកវិញ រើលទៅឲ្យឃើញដូចជាផ្លែត្រឡាចធម្មតា ។ គេលុយចប់ស្ងាត់ បុរសយើងយកដំបងមួយទៅជាមួយផង ហើយលូនចូលទៅដេកតួនក្នុងផ្លែត្រឡាច ។

ពួកស្វាដែលឆ្លាប់ចាន់ត្រឡាចស៊ី ចេះអង្រួតស្ងាត់ នាំគ្នាមកបេះផ្លែត្រឡាចនោះសែងយកទៅចីតនៃ្ងងបេះខ្លួនឯងព្រៃកុំ ដើម្បីចែកគ្នាបរិភោគ ។ លុះនាំយកដល់រួងជាទីលំនៅហើយ ហូងស្វាជាកំត្រឡាចចុះ ។ បុរសយើងចេញពីក្នុងត្រឡាចភ្លាមជាមួយនឹងដំបង ស្តេចស្វាឃើញបុរសយើងកេសំតង កិតក័យក្រៃពេក ក៏អង្វរសុំខុតជីវិត ហើយធ្វើសញ្ញាចង្អុលទ្រុបដល់បុរសហួនខ្លួនតំនាងពេជ្រ ថាសូមឲ្យយកតាមចិត្តចុះ សូមកុំឲ្យតែសម្លាប់ ។ បុរសហួនតើបយកពេជ្រចូកពេញហោរបាំអាវត្រមាំងក្តាប់នឹងដៃចាំងពីរ រួលត្រឡប់មកផ្ទះវិញ ។

ជំណឹងដំប្រពៃនេះ មិនយូរប៉ុន្មាន ក៏លេចឮទៅដល់បងខ្លៃត ។ ដោយបងបានពេជ្រដូចហួន បុរសបងក៏លាប្រពន្ធមកឯផ្ទះហួន ដោយសង្ឃឹមថាខ្លួនឯងក្លាយជាអ្នកមានដូចហួនមិនខាន ។ បងនិយាយទូចអង្វរចំពោះហួនថាឲ្យហួនមេត្តាដល់ខ្លួន ដ្បិតខ្លួនក្រណាស់សព្វថ្ងៃ ឥឡូវសុំ

ជួនអាណិតឲ្យចូលក្នុងផ្ទៃត្រឡាចម្តង ។ ជួនជាមនុស្សចិត្តល្អ អាណិតបង កំព្រមឲ្យបងចូលក្នុងផ្ទៃត្រឡាច ដូចកាលដែលខ្លួនចូលនោះ ។

មានស្ងាហ្ហង៍ដទៃដែលធ្លាប់មកលួចផ្ទៃត្រឡាចដែរ តែពុំបានដឹងមូលហេតុដូចបានពោលខាងលើ យប់នោះក៏នាំគ្នាមកលួចបេះផ្ទៃត្រឡាចយកទៅ ។ ភាសែងទ្រផ្ទៃត្រឡាចផ្ទាស់គ្នាច្រើនលើកច្រើនសា ព្រោះជួនថ្ងៃភ្លក់ជាឆ័ងធម្មតា ។ ចំណែកបុរសបងដែលនៅក្នុងត្រឡាច បេះតែទឹកភ័យផ្អក ។ មិនដឹងជាល់ទីបំផុតនឹងមានហេតុកេទយ៉ាំងណា ។ តំពុងតែសែងត្រឡាចសួតាមមែកឈើធ្ងន់ជ្រោះ ស្ងាស្រែកប្រាប់គ្នាថា : ប្រុងប្រយ័ត្ន ។ កុំឲ្យបេះភ្លាក់ជ្រោះ ។ លុះឮដូច្នោះ បុរសបងភ័យខ្លាចក្រែងស្ងាទ្រផ្ទៃត្រឡាចមិនជាប់ ហើយធ្លាក់ទៅក្នុងជ្រោះ ក៏គាន់តែបុកនោះខ្លាំងឡើងញ័រអស់ពាំងខ្លួន ។ ជាកម្មអកុសល ! បុរសបងភ័យពេក ស្រាប់តែធ្លាយផោម ។

សូមអស់លោកជ្រាប : ស្ងាខឹងខ្លួនស្អុយជាសត្រូវខឹងគ្នាពេក ។ លុះធុំខ្លួនមិនស្រួល ស្ងាសំឡឹងមើលគ្នាធ្វើមុខជូរ មាត់ស្បែញស្បាញខន់ដៃដើង ក៏ខម្លាក់ផ្ទៃត្រឡាចទៅក្នុងជ្រោះចោល ហើយដោយខាំងបុរសបងទៅផង ។ — រឿងព្រេងស្តីពីបុរសបងជួនពីរនាក់ ចប់តែប៉ុណ្ណោះ ។

រឿងសាមកុក

ទកញ្ញាវិបុលពាដសេនា ឬ-ភាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃដឹងសិល្បាសបើបានអាន
ទឹងចេះចាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

——— យួរ-អ៊ុន ———

ស៊ុនគួនកំនិយាយលួងលោមថ្នមយកចិត្តឡេងថងថា ខ្លួនអ្នកឯងនឹងកាំឡេងនេះ ទបមាដូចគ្រីនៅក្នុងអន្ទង់ជាមួយគ្នា គួរតែគាំងចិត្តគិតចងមេត្រីនឹងគ្នា ធ្វើពាសការជាមួយគ្នាដោយប្រក្រតីទៅចុះ ទើបប្រសើរក្តីរឿងណោះវែងឆ្ងាយ ។ ឡេងថង កំស្ងៀមមិនស្តី ។ ស៊ុនគួនកំឲ្យត្រួតត្រាមើលសេនាពាហានត្រង់ត្រង់ត្រៀមខុកព្រម លុះវេលាព្រឹក ស៊ុនគួនកំលើកទ័ពចូលទៅជិតស្រុកហាប់ប៉ា ហើយឲ្យតាំងបន្ទាយនៅទីនោះ ។

ខាងខៀវលៀវ កំប្រមូលពលពាហានឡើងរក្សាលើបន្ទាយជាមាំមួន មិនបានប្រហែសឆ្វេស លុះដឹងថា ស៊ុនគួនលើកកងទ័ពទៅតាំងបន្ទាយជិតស្រុកហាប់ប៉ាហើយ ខៀវលៀវ កំតិតនឹងលើកពលចេញទៅតស៊ូចាំងគ្នានឹងស៊ុនគួន ខ្លួលពាហានចូលទៅប្រាប់ខៀវលៀវថា ចូរឲ្យយកហ៊ិបតូចមួយមកជូនលោក ខៀវលៀវខ្លួលយកហ៊ិបនោះមកពិនិត្យ

មើល ឃើញសរសេរស្មាកដំនថា បើការណាមានសឹកសង្គ្រាមលើក
មកញាំញីស្រុកហាប់ចាំ ហើយគប្បីដល់នូវសេចក្តីលំបាកប្រការម្តេច
ឲ្យបើកយកសំបុត្រក្នុងហិបនោះមកមើល ហើយឲ្យដឹងតាមបុះ ។

ខណៈនោះ ខៀវលៀវ កំប្រឹក្សានឹងលីខៀន ដាក់ជំនថា : ដែល
ឧឹងចេញទៅតស៊ូនឹងស៊ុនគួននោះ កំទៅមិនទាន់ត្រមត្រៀងគ្នា ខៀវលៀវ
កំបើកហិបចេញ ហើយយកសំបុត្រចូលមកមើលឃើញសេចក្តីថា : បើ
ស៊ុនគួនលើកទ័ពមកវាយស្រុកហាប់ចាំវិលាណា ឲ្យខៀវលៀវនឹងលី
ខៀន លើកទាហានចេញទៅតនឹងស៊ុនគួន ឲ្យដាក់ជំនទៅរក្សាស្រុក លុះ
ខៀវលៀវមើលហើយ កំយកសំបុត្រនោះឲ្យទៅលីខៀន ដាក់ជំនមើល។

លីខៀន ដាក់ជំន ឃើញសេចក្តីសំបុត្រហើយ កំនិយាយនឹងខៀវ
លៀវថា បើសំបុត្រវុយកុងឲ្យមកដូច្នេះ លោកនឹងរិះគិតប្រការម្តេច
ខៀវលៀវថា ស៊ុនគួនដឹងថាវុយកុងលើកទ័ពទៅវាយស្រុកហាន់តុង ស៊ុន
គួនមានចិត្តកំរើប ទើបលើកទ័ពមកវាយស្រុកយើង ។ ត្រូវតែលើកទា-
ហានចេញទៅតច្បាំងយកជ័យជំនះស៊ុនគួនឲ្យបានម្តងសិន ដើម្បីឲ្យទា
ហានខាងយើងមានចិត្តកំរើបរំភើការតទៅមុខទៀត រួចសឹមយើងគិតការ
តាមការតទៅ លីខៀនឮដូច្នោះក៏សើម តែដាក់ជំនធ្វើយតបនឹងខៀវលៀវ
ថា ស៊ុនគួនលើកទាហានមកគ្រានេះច្រើនណាស់ ទាហានខាងយើងតិច
ដែលនឹងលើកចេញទៅនោះ មុខជានឹងតទល់នឹងស៊ុនគួនមិនបាន គួរឲ្យ

តែតក្សាស្រុកពីក្នុងឲ្យតង់ទៅសិន ដើម្បីកុំឲ្យសត្រូវចូលមកក្នុងស្រុកបាន។

ខ្មៅលៀវថា ដែលនឹងតែតក្សាស្រុកនៅតែស្ងៀមដូច្នេះ នឹងមិនខុសពីក្នុងសំបុត្របណ្តាំវុយកុងឲ្យមកនេះទេឬ នរណានឹងនៅតំនៅចុះ ខ្ញុំម្ចាស់ឯងនឹងលើកទាហានចេញធ្វើការសង្គ្រាមតនឹងស៊ុនតួន ថាហើយក៏បង្គាប់ឲ្យចាត់ចែងទាហាន លីខ្មៅ ងាក់ជិន កំនិយាយនឹងខ្មៅលៀវថា បើដូច្នោះខ្លួនយើងត្រូវរួមស៊ុខទុក្ខសុខត្រូវជាមួយគ្នា យើងនឹងសុំចេញទៅផង នឹងឲ្យតែទាហាននៅតក្សាស្រុកតំបាន ។

ខ្មៅលៀវឮដូច្នោះក៏អរណាស់ និយាយនឹងលីខ្មៅថា វេលាយាម ៣ ឃប់នេះ អ្នកឯងត្រូវឲ្យទាហានពីរចេញទៅចំលាយស្ពាន «សៀវកៀវ» ខាងទិសខាងត្បូងឲ្យអស់ចេញកុំឲ្យសត្រូវឆ្លងទៅមកបាន ហើយនាំទាហានទៅពួនបង្កប់នៅជិតនឹងសៀវកៀវនោះ ចាំស្លាត់វេលាស៊ុនតួនលុះដល់ព្រឹកឡើង យើងនឹងងាក់ជិនលើកទាហានចេញទៅចោមរោយថែមខ្មៅត លីខ្មៅយល់ឃើញត្រូវ ក៏លើកទាហានចេញទៅធ្វើតាមពាក្យខ្មៅលៀវបង្គាប់ លុះព្រឹកត្រហាមស្រាង ខ្មៅលៀវ ក៏ឲ្យងាក់ជិនលើកទាហានជាកងបញ្ជោត ឯខ្លួនខ្មៅលៀវ លើកទាហានចេញទៅពួនបង្កប់ចាំខ្ទប់រោយប្រសព្វគ្នា ។

ខណៈនោះ ស៊ុនតួនឮដឹងថាកំលើកកងទ័ពកន្ទុយចូលទៅឯកាំឡើង ឮដឹងលឺបន ដែលជាកងមុខនោះ លុះឃើញងាក់ជិនលើកទា-

ហានចេញមកពីក្នុងបន្ទាយ កាំឡេងក៏បរសេះចូលតប្លាំងទំនឹងវាំក់ជនជាន
១០ ភ្លេង វាំក់ជនធ្វើជាញាក់សេះថយរត់ ចូលទៅតាមមាត់ផ្លូវសៀវ-
រៀវ ហើយស្រួតបរសេះវេរទៅតាមផ្លូវបែក លឺបងឃើញជាន់ចំណាប់
ស្រួល ក៏បរតលចូលទៅជាជំនួយពីក្រោយ ស៊ុនគួនឃើញដូច្នោះក៏ប
ចោលសេះដេញតាហានតាមទៅខ្មែក រហូតដល់កន្លែងដែលខ្មៀវលៀវ
ពួនបង្កប់ចាំ ខ្លួលឮសូរផាវជាសញ្ញា ឮសូរហ៊ោកញ្ជ្រៀវជាតីកកង
ឃើញលីខ្មែនទៅខាងធ្លង នាំតាហានចេញមកវាយប្រសពួជាច្រើន
ឃើញខ្មៀវលៀវទៅខាងស្តាំ នាំតាហានចេញមកវាយខ្ទប់ប្រសពួគ្នាតាំង
សងខាង ចូលប្រកាប់សម្លាប់តាហានច្រើនណាស់ តាហានចាំងនោះ
ក៏ប្រេះតំខ្លាត់ខ្លាយបែកប្រពាក់ប្រពួន ស៊ុនគួនក៏បរដំយកតំយកតក់ស្លុត
មហិមា ឯកាំឡេងទំនឹងលីបង ក៏ដេញវាំក់ជនជ្រុលហួសទៅ ទឹងឲ្យតាហាន
បរសេះបំពានវិលមកក្រោយឲ្យហៅគ្នាទៅជួយ ក៏ខើសទំងតាហានខ្មៀវ
លៀវចេញមកកំងស្តាត់ជាប់តាន់តាប់ច្រើនណាស់ ។

ខណៈនោះស៊ុនគួន ក៏ទៅសល់តាហានពីស្ងាប់ប្រហែល ៣០០
នាក់ ខ្មែងថងក៏និយាយទំនឹងស៊ុនគួនថា លោកចូលទ្ធងតាមស្ពានទៅឲ្យ
ដល់ត្រើយម្ខាងជាប្រញាប់ចុះ ខើបរួចពីអន្តរាយ និយាយមិនទាន់ផុតមាត់
ខ្លួលខ្មៀវលៀវលើកតាហានដេញខ្មែងថងតាមពីក្រោយទៅខ្មែត ស៊ុន
គួនក៏បំបោលសេះរត់ទ្ធងតាមស្ពានឡូទៅត្រើយខាងលិច ឃើញចុងស្ពាន

នោះជាចំណុតគ្មានដំណើរ ទៅដល់ត្រើយចម្ងាយប្រហែល ៩ ហតុ្ត ១០ ហតុ្ត ស៊ុនគួនក៏យល់ឃើញតាមថា គ្រានេះមុខជាមិនរួចជីវិតនឹងសត្រូវនេះឡើយ ហើយក៏ញាក់សេះថយមកក្រោយវិញ ក៏ថយមកមិនបានព្រោះតាហានខ្មៀវលៀវដេញតាមស្ពានពីក្រោយ ទៅដល់ត្រើយឆាងកើត ហើយមានតាហានម្នាក់ដែលតាមទៅជាមួយ ក៏ដួយរំលឹកស្មារតីស៊ុនគួនថា លោកញាក់សេះបរទៅមុខទៅ លុះទៅដល់កណ្តាលស្ពានឲ្យលោកបង្ខំចំដាយសេះឲ្យកស្ទុះលោតទូងត្រង់ស្ពានជាប់ ទើបដល់ផែនដីស៊ុនគួនក៏មានស្មារតីយល់តាម តាំងតែកយចំដាយសេះទៅ សេះនោះក៏ស្ទុះអស់ចំហាំងប្រឹងលោតទៅដល់ផែនដីត្រើយម្ខាង ខ្លួលស៊ីសេងនឹងតាំងស៊ុតដំរកគួចមួយទៅដល់ខ្នើនោះ ក៏បង្ខំតាហានឲ្យបែរខ្នែកទៅខ្លួលស៊ុនគួនចុះខ្លួកបាន ឡើងថង់ដែលនៅពីក្រោយ ក៏ខ្លួលវង្គតស៊ីនឹងខ្មៀវលៀវ ។ ក៏កាប់តាហានឡើងថង់ស្លាប់អស់តាំង ៣០០ នាក់ ។

ឯកាំឡើងនឹងលីបង បានឮសូរតាហានហៅកន្ត្រាក់ពីក្រោយអឺងកងដូច្នោះ ក៏នាំតាហានចូលបម្រុងទៅជួយស៊ុនគួន ខ្លួលប្រទះនឹងលីខ្មៀន ក៏តាំងប្រយុទ្ធគ្នាទៅយូរណាស់ ដាក់ជិនក៏នាំតាហានលបត្រឡប់ចូលពីក្រោយ ឃើញលីខ្មៀននឹងកាំឡើងលីបង កំពុងប្រកាប់គ្នាក៏ស្ទុះចូលទៅជួយលីខ្មៀន ។ ឝឹងដាក់ជិន ក៏កាប់សម្លាប់តាហានកាំឡើងស្លាប់ជាច្រើនណាស់ ឡើងថង់អស់ពលសល់នៅតែខ្លួនម្នាក់ឯង ឯខ្លួនោះ

កំត្រូវរបួសដោយអាវុធមុតជាច់ជាច្រើនអន្ទើលើសកម្លាំង ទើបត្រាំតពុំឈ្នះ
កំប្រះត្រឡប់សេះស្ទុះបំបោលទៅ ខៀវលៀវកំដេញទៅជល់ចុងស្ពាន
ប្រទះនឹងលីបង កាំឡើងនឹងពាហនប្រហែល ១៤-១៥ នាក់ ពាំងអស់
គ្នានោះក៏លោតចុះពីលើសេះ លោតចុះទៅកន្លែតស្ទឹងប្រឹងហែលទៅ
ស៊ុនគួនឃើញដូច្នោះ កំឡែថយទូកចេញទៅទួលពាំងអស់គ្នាឡើង
មកលើទូក ហើយកំឡែចែវដម្រង់ទៅកំពង់ឃីស្ទឹងស្រុកកាំងតាំង ហើយ
ឡែតាំងបន្ទាយនៅលើគោក ។

ខណៈកាលស៊ុនគួនបែកទ័ពទៅនោះ ពាហនទើងអ្នកស្រុកកាំងតាំង
ពាំងស្រីពាំងប្រុស កំចេះតែញាញីតខ្លាចថ្លៃដៃខៀវលៀវជាប់កន្លែងចិត្ត សូម្បី
តែនួនក្មេងដែលលេងទើងគ្នាហើយយប់ បើមានគេបន្ទាចហើយចេញឈ្មោះ
ខៀវលៀវវិលាណា ក្មេងនោះកំខ្លាចតក្តមាមិនហ៊ានយំសោះ ស៊ុនគួន
វិលានោះ ក៏មានសេចក្តីពេមនស្សតូចចិត្តណាស់ តាំងតែបញ្ជូនបញ្ជាល
តាមពាហនប្រុងប្រៀងទើងលើកទៅសងសឹកខៀវលៀវវិញ ហើយឡែសំបុត្រ
បកទៅជល់ឡោសុកសេចក្តីថា ឡែឡោសុកប្រញាប់បញ្ជូនពាហនឡែទៅ
ជល់ ដើម្បីនឹងលើកទៅកាយយកស្រុកហាប់ជាំខៀត ទើបចាប់យកខ្លួន
ខៀវលៀវ ឡែបានសម្លាប់ចេញ ។

ឯខៀវលៀវនោះ លុះមានជ័យជំនះស៊ុនគួនហើយ ក៏លើកពាហន
ត្រឡប់ចូលទៅស្រុកវិញ ចេះតែគិតជាអ្នកខ្លាចក្រែងស៊ុនគួនបែកទៅគ្រា

នេះ ខ្ញុំឯកណ្ឌាហានមកបំពេញខ្លួនឡើងជាច្រើន ខ្ញុំឯងសឹកយើងវិញមិនលែង ឯងហានក្នុងស្រុកហាប់ចាំនេះកំមានតិចផង មុខជាតស៊ូខ្ញុំឯងស៊ុនគួនមិនបាន តួនខ្ញុំឯងប្តឹងទៅចូរឲ្យលើកទ័ពមកជួយ តែហើយកំធ្វើសំបុត្រប្តឹងជូនដំណឹងភ្លាមទៅដល់ចូរ តាមដែលមានជ័យដំនះស៊ុនគួននោះគ្រប់ប្រការ ហើយថាវេលានោះកំទៅមានបារម្ភក្រែងស៊ុនគួនខ្ញុំឯងលើកកងទ័ពទៅទៀត ព្រោះតាហានក្នុងស្រុកហាប់ចាំនោះស្តួចស្តើងណាស់ សូមឲ្យរុំយកកុងលើកទ័ពទៅជួយ លុះតែឯងសំបុត្រហើយកំប្រើស៊ីថៃឲ្យកាន់ចូលទៅ ។ ស៊ីថៃនោះលុះទៅដល់ស្រុកហាន់តុងហើយកំយកសំបុត្រនោះទៅជូនចូរ ។

ចូរទទួលសំបុត្រមើលដឹងសេចក្តីហើយ កំប្រឹក្សាខ្ញុំឯងតាហានទាំងពួងថា យើងខ្ញុំឯងតិតប្រការម្តេច ។ ខ្លៅហួថា ដែលខ្ញុំឯងលើកកងទ័ពទៅវាយយកស្រុកសៃឈួនោះ ត្រូវបង្ខំឯងឈប់សិនចុះ ព្រោះខ្លៅពីប្រុងប្រៀបតាហានមានគ្រឿងទុកជាច្រើនណាស់ ប្រុងខ្ញុំឯងការពារស្រុកសៃឈួនមិនឲ្យអន្តរាយ ឯស្រុកហាប់ចាំនោះ កំជាមណ្ឌលមួយធំ បើលោកលះបង់មិនតិត ស៊ុនគួនជាបច្ចាមិត្រខ្ញុំឯងលើកកងទ័ពទៅវាយយកខ្លះជាអសារ បើបែកស្រុកនោះគាលណា កំតង់ខ្ញុំឯងត្តៅវិលទៅដល់ក្រុងហ្វីះតាទៀត ហេតុនេះ សូមឲ្យលោកវៀសវៃ លើកទៅជួយស្រុកហាប់ចាំជាប្រញាប់ចុះទើបខ្ញុំឯងស្រួល ចូរក៏ទទួលថាត្រូវ ទើបនិយាយថា ក្នុតេងគុនសាន់ ខ្ញុំឯងបង់ទៅវិញ ២ ដំបន់នេះជាមាត់ប្រក

ស្រុកហាន់តុង ត្រូវឲ្យហែហ្វូងគៀន ឃុំតាហានទៅរក្សាត្រង់ភ្នំតេងគុន-
សាន់ ឲ្យខៀវនៅរក្សាត្រង់មាត់ប្រកងផ្លូវភ្នំចង្រៀមរៀងរៀម ហើយក៏ចាត់
វែងឆ្ងាយចោនបាន ៤០ ម៉ឺន ចូរគួរកំលើកទៅដល់ស្រុកហាប់ចាំ ហើយនាំ
ខៀវលៀវ លាខៀន ទឹងឆាំកំដែន លើកវិលឆ្ងាយចូលទៅត្រង់ដែន តវដែន
ស្រុកកាំងតាំង តាំងបន្ទាយទៅទីនោះ ។

បំរើរេះកំនាំយកសេចក្តីចូលទៅប្តឹងស៊ុនគួនថា ឥឡូវចូរគួរលើកកង
ទ័ពប្រហែល ៤០ ម៉ឺន មកបោះបន្ទាយនៅព្រំប្រទល់ដែនស្រុកហាប់ចាំ
ទឹងស្រុកយើងហើយ ។ ស៊ុនគួនឮដូច្នោះកំភ័យខ្លាំងណាស់ ទើបចាត់
ប្រើតាំងស៊ុនទឹងស៊ីសេង ឲ្យនាំទូកចម្បាំង ៥០ ចេញទៅកំងទ័ពនៅមាត់
តាមយីស៊ូ ប្រើតាន់ប៊ូឲ្យនាំតាហានទៅយោមលាតតាមកែ្សមាត់ទន្លេ ។
ខៀវចៀវកំនិយាយទឹងស៊ុនគួនថា វេលានេះចូរគួរទើបទឹងលើកពលមកដល់
ពលកំពុងហត់ទៀយ គួរទឹងលើកទ័ពទៅទប់ព័ទ្ធឲ្យតាហានចូរគួរជួយ
កម្លាំងចុះទើបទឹងធ្វើការមានជ័យជំនះតទៅ ស៊ុនគួនយល់ឃើញត្រូវទើប
សួរនាយតាហានតាំងអស់ថា នរណាទឹងអាសាចេញទៅធ្វើការតាមតាក្យ
ខៀវចៀវបាន។ ឡងឋងធ្វើយនចូលអាសាថា ខ្ញុំបាទទឹងសុំតាហាន៣០០
នាក់លើកទៅទប់បន្ទាយចូរគួរឲ្យបាន កាំឡងធ្វើយថា ឡងឋងទឹងយកតា
ហាន ៣០០ នោះច្រើនណាស់ ខ្ញុំបាទទឹងសុំតែតាហាន ១០០ នាក់ លើក
ទៅធ្វើការយកជ័យជំនះឲ្យបាន ។

(នៅមានត)

ព្រះរាជនិពន្ធរាមកេរ្តិ៍

ស្រាវជ្រាវដោយ ឌុ - ការម (ត)

(រក្សាសិទ្ធិមិនឲ្យចម្លង មិនឲ្យតួរូបឡើយ)

កាលនោះទេវតាសុភទ្ធិត្រូវចំសេចក្តីស្ងាត សុបណ្ណត្រូវគន្ធនពិឡាជកំនាតចាំងពួង ក៏នាំគ្នាលាលោះចុះមកគាល់ហ្លួងព្រះឥសូរ លុះមកដល់ស្ថានតែលាសគឺរីហើយក៏នាំគ្នាចូលទៅដល់ចំអង្គច័ន្ទដំណាក់ហើយ ឧទ្ធកៈក៏ដងចំតយកមកលាងដើងឲ្យតែត្រប ។ អង្គ រីទេវលោកកំត្បូកក្បាលអង្អែលលេងតែត្រប់គ្នាជម្មតាជូចសព្វជងរៀងមក ។ ឯនឧទ្ធកៈកំមានចិត្តជ្រះថ្លោះទឹកចិត្តទន់ឯទេវលោកចាំងអស់ ហើយក៏ស្រែកថា ឃ្មុំទេវលោកចាំងអស់ខេះ ធ្វើជ្រាបអញតែសព្វ។ ថ្ងៃមុខមានប្រណីអាណិតមេត្តា ត្បូកក្បាលអញលុះតែចំពែកអស់ កំទឹកចិត្តហើយថាថ្ងៃហ្នឹងគង់អ្នកលាក់គ្នាដឹងខ្លួន ថាហើយវាក៏ចង្អុលខ្លួនទេវលោកមួយរំពេច ក៏ស្ងាប់រំងាសអន្តរាយចាំងអស់ហោង ។ កាលនោះព្រះឥន្ទ្រាធិរាជឃើញអានឧទ្ធកៈវាស់ដែងចូលទ្វិ ចង្អុលពួកទេវលោកស្ងាប់អន្តរាធានអស់ដូច្នោះហើយ ក៏មានសេចក្តីតំយកតស់ស្តុតខ្លួតហើយគិតថាអ្នកណាអេះ ប្រសិទ្ធិចង្អុលដៃឲ្យកខេះមុខគួរឲ្យសង្វែយណាស់គិតហើយក៏ស្តុបឡើងទៅគាល់ព្រះឥសូរាធិបតី ។ លុះដល់ហើយក៏ក្រាបបង្គំទូលស្តេ ថាអានឧទ្ធកៈវាស់ដែងចូលទ្វិរ ។ ចង្អុលទេវាស្ងាប់រំងាសនោះ តើព្រះអង្គទ្រង់ប្រទានពរប្រសិទ្ធិឲ្យវាឬ ទើបបានជាវាពូកែធ្ងន

ឆាប់ម្ល៉ះ ហើយកាត្រូវតាំងនេះដូចជាវាមិនមានសេចក្តីក្រែងខ្ញុចបារមីព្រះតុណាសោះឡើយ ។ ទើបអគ្គព្រះបរមមកុដក្រែលោកបានស្តាប់ព្រះឥន្ទ្រទូលដូច្នោះ ហើយមានព្រះឱង្ការថា អានន្ទកៈនេះកាទៅបរើអញមកជាយូរឆ្នាំអន្លើនជាល់មួយកោដិឆ្នាំហើយ បានជាអញប្រសិទ្ធពរឲ្យវាព្រោះដោយគាណិត ឥឡូវនេះវាត្រឡប់មកត្រូចតល់ប្រទុសកយវិញ បើដូច្នេះ ចូរនាកយណ៌ឯងជាតិពីរនេះលោកតាំងពួងទៅចំផ្លាញឲ្យស្លាប់អន្តរាននេចញហោង ។ កាលនោះ ព្រះនាកយណ៌បានស្តាប់ព្រះតម្រាស់ប្រើដូច្នោះហើយ កំក្រាបថ្វាយបង្គំលាថយមកកំនិម្មិតកាឡកាយក្លាយកើតជាស្រីមួយល្អដូចទេពកញ្ញាសួគ៌ា ហើយដើរមកកាន់ទីដែលនន្ទកៈវាអង្គុយនៅនោះ រីឯនន្ទកៈនោះហួសមោ៌ងពេលវេលាហើយ កំត្រូចដើរលេងកំសាន្តសប្បាយ លុះលេចឃើញស្រីល្អនោមនាយ កំបង្កើតដួងចិត្តនោះស្រឡាញ់ណាស់ ហើយកំនិយាយថា ម្នាលនាងស្រីក្រមុំសមរូបនោមនវ៉ៃណ្ណដ៏ចំរើនអើយ នាងមកពីស្ថានណា មានបើប្រាថ្នាអ្វីអ្វី ហើយអូនស្រីឈ្មោះអីផង ដូចម្តេចបានមកនៅ ។ ចំនេះ ចូរអូនប្រាប់បងឲ្យបានដឹងផង ។ នាងព្រះនាកយណ៌បានស្តាប់ហើយ កំរំងាតែធ្វើក្តៅឥរិយាឲ្យនន្ទកៈ ហើយធ្វើជាក្រឡេកចុងក្រែកទៅ កំស្រដីតបទៅថា អ្នកបងឯងមកសួរគួរសមអីហើយកំហ៊ានមកអង្គុយជិតយើង មិនមានកោតក្រែងចិត្តយើងខ្លះ យើងនេះជាខ្ញុំបំរើព្រះឥសូរ មុខក្រសួងភ្នាក់ងារយើង

ខាងឯរជ្ជកំព្រៀង យើងឈ្មោះសុបណ្ណកល្យាណី ព្រោះមានសេចក្តីកើតទុក្ខរំខានចិត្ត ទើបបានដើរលេងកំសាន្តតែទុក្ខឲ្យបានស្បើយល្ហើយល្ហៃក្នុងឧទក អាត្មាយើងហោង ។ នន្ទកៈបានស្តាប់ហើយក៏មានចិត្តនោះរំងឹតតែស្រឡាញ់ឡើង ទើបនិយាយថាអូនអើយអូន ។ ឯងនេះមានរូបល្អដូចស្រីទៅស្មានសួគ៌ ល្អជាងចតុតវិយាវ៉ាចាក៏ពិកោះគួរមែន ហើយសមជាអ្នករជ្ជកំព្រៀង មួយទៀតដែលអូនថា មានទុក្ខក្នុងខ្លួននោះតើទុក្ខដូចម្តេច ប្រាប់អូនឯងសំដែងប្រាប់មកបងចុះ បើកស្មាយើងជាង ២ នាក់បានកសាងមកពីមុនមិនអីទេសូមបងជួយដោះទុក្ខអូនកុំព្រួយចិត្តឡើយ រីខ្លួនបងសព្វថ្ងៃនេះក៏កំព្រាគ្មានគូស្រករនឹងគេនោះក៏គ្មាន បើអនុជអ្នកមេត្តាស្នេហានឹងបង ។ សែនត្រេកអរណាស់ ។ កាលនោះនាងព្រះនាគយណ៍ឆ្លើយតបទៅវិញថាអ្នកបងអើយ សំដីអ្នកបងមានប្រសាសន៍មកនោះពិកោះណាស់ អូនមិនថាអ្វីទេ តាំតអូនចំណូលចូលចិត្តតែជាំកំលេង បើអ្នកបងឯងកំចាក់ក្បាច់ត្រូវតាមប្តូនបានទោះ ប្តូនក៏ព្រមយកអ្នកជាប្តីហោង ។ រីនន្ទកៈនោះបានស្តាប់នាងថាដូច្នោះហើយ ហេតុតែមិនដឹងជាព្រះនាគយណ៍កាឡ កំមានចិត្តសោមនស្សអរពេកក្រៃ ញញឹមហើយទើបឆ្លើយតបទៅវិញថា ម្នាលនាងដ៏ចំរើន នាងកុំព្រួយចិត្តឡើយខ្លួនបងនេះ កំនៅជាខ្ចឹបរើព្រះអង្គមកយូរផ្ទាំហើយជាមនុស្សចាស់ បងកំចេះដៃរបត្តិចបត្តួច សូមនាងកំពៅជាមុន សឹមបងកំតាមនាងជាក្រោយ

មិនឲ្យខ្ញុំសក្សាច់អូនឡើយ ។ ស្រេចហើយនាងព្រះនាគយណ៌ឃើញ
ខន្ធកៈព្រមតាមដូច្នោះហើយក៏ត្រេកអរ នាងក៏ពាក់ក្សាច់លេងសប្បាយ
បន្តិចទៅត្រូវត្រង់ក្សាច់នាគព័ន្ធកន្ទុយហើយនាងក៏ចង្អុលម្រាមដៃ ត្រូវត្រង់
ភ្លៅនាង ។ រីខន្ធកៈសោតក៏នោតទៅពាក់ក្សាច់តាមនាងវិញ ។ ទៅ លុះ
ដល់ក្សាច់ចង្អុលភ្លៅចង្អុលខ្លួនឯងមិនបានគិតពីចង្អុលដៃពេជ្រខ្លួនឯង ក៏
ត្រូវបាក់ភ្លៅដួលមួយរំពេចទៅ នាងព្រះនាគយណ៌ភាឡាភាយមកជាព្រះ
នាគយណ៌វិញ ក៏ស្ទុះទៅជាន់សង្កត់យោរព្រះខ័នឡើង ខន្ធកៈនោះ លុះ
ឃើញថាព្រះនាគយណ៌ទ្រង់ភាន់សង្ឃឹងចក្រដំបងពេជ្រ ព្រះខ័នត្រង់ដៃ
ខាំនឹងបួនធឹងសម្លាប់ខ្លួនដូច្នោះហើយ ក៏ស្រែកថាខ្លួលព្រះបង្គន់ជាខ្ញុំនេះ
មានទោសខ្មៅសពីអ្វីសូមទ្រង់មេត្តាច្រាប់មក ។ ទើបអង្គព្រះនាគយណ៌
ឮស្តាប់ហើយ ក៏ឆ្លើយតបទៅវិញថា អាឯងនេះមានទោសជាខំហ៊ាន់
ណាស់ អាឯងមិនត្រែងព្រះចារមើអង្គព្រះឥសូរជាអធិបតីសោះឡើយ
ហើយអាឯងហ៊ានសម្លាប់ទេវតាសុភកណ្យាខាំនឹងពួង ទោសអាឯងនេះធ្ងន់
ណាស់ អញក៏មានសេចក្តីអាណិតមេត្តាដែរ តែថាខ្លឹងខុកដើរតអាឯងពុំ
ឃ្លានឡើយ ខន្ធកៈវាក៏ឆ្លើយតបទៅវិញ ថាដូចម្តេច ក៏ព្រះអង្គកែងឆ្លើយ
ស្រើមក មិនឆ្លើយព្រះនាគយណ៌វិញ ឬខ្លាចខ្ញុំចង្អុលនិងម្រាមដៃពេជ្រស្លាប់
មួយទៀតគ្រោះខ្លួនខ្លួលព្រះបង្គន់ជាខ្ញុំនេះមានដៃតែពីរ តាលណាឡើយ
ឱងតឬខ្ញុំឃ្លានឈ្នះព្រះអង្គ ថាបើមានដៃបួនដូចព្រះអង្គហើយ ម្តេចឡើយ

ព្រះអង្គនឹងធ្វើថ្កុបថ្កាន ។ ទើបអង្គព្រះទ្រង់ព្រៃ ស្តេចបានស្តាប់ហើយទ្រង់ខ្ញាល់ណាស់ ព្រោះថាអាឯងនេះ ព្រោះខំនាយអាឯងនឹងដល់ស្លាប់ បានជាអញនិម្មិតកាឡាធ្វើជាស្រី អញមិនមែនខ្លាចបាមើអាឯងនោះទេ ណ្ហើយចុះ អាឯងកើតជាតិនេះ អាឯងកើតមកមានតែដៃពីរដល់ទៅជាតិមុខទៀត ឲ្យអាឯងកើតមកមុខ ១០ ដៃ ២០ ហើយឲ្យគ្រឿងសាស្ត្រាវុធគាន់ព្រះខ័នឆ្លុះសេលៀជ័យឲ្យគ្រប់ដៃចុះ ហើយហោះហើរលើអាកាសបាន តែអង្គអញសុំទៅកើតតែជាមនុស្សដើរដី ដៃតែពីរដើងតែពីរ អញនឹងកាប់សម្លាប់ឲ្យអស់ពូជតន្ត្រៃឲ្យត្រកូលអាឯងឲ្យវិនាសតាំងពីសន្ដាន ត្រាស់ហើយស្តេចក៏កាប់ដាច់ក្បាលអានន្ទកៈស្លាប់ទៅហោង ។ លុះសម្លាប់នន្ទកៈស្រេចហើយ ព្រះអង្គក៏ហោះទៅលើវេហាស៍ក៏ចុះទៅគង់ឯឆ្នេរសមុទ្រសោតរជាកំសាន្ត ។

ឯឯស្រដីពីនាងផ្លែជា ទេវីមហេសីព្រះបាទព្រហ្មទត្តទៀនោះ ក៏នាងទ្រង់មានគភ៌ តែអានន្ទកៈនោះកាមកចាប់កំណើតកើតនៅផ្ទៃនាងផ្លែជាត្រប់ទសមាសកាលណាហើយ ក៏នាងប្រសូតកជបុត្រា ១ នោះមានមុខនោះ ១០ ដៃ ២០ ព្រះបិតាឲ្យឈ្មោះ ទសកណ្ឋកុមារ ប្អូនបង្អាប់ក្រោយទៀតឈ្មោះកុម្ភកាណ៌អសុរ អង្គព្រះបិតាមានសេចក្តីស្នេហាស្រឡាញ់ពេញចិត្តណាស់ហោង ។ លុះចំរើនវ័យនាជន្មាទីយោយុធំហើយ

អស្សរទសកណ្ឌអាយុបាន ១៤ ឆ្នាំ ហើយក៏មានចិត្តតិតចង់រៀន
សិល្បប្រសាស្ត្រឲ្យបានមានឫទ្ធិអានុភាពខ្លាំពូកែ គិតហើយក៏មកគាល់
សម្តេចព្រះបិតុរង្គីមាតុកជ ដល់ហើយក៏ក្រាបថ្វាយបង្គំទូលថា ខ្ញុំ
ព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំលាទៅរកគ្រូរៀនសិល្បវិជ្ជាន៍ឯព្រះមហាឥសី ឲ្យ
ខ្លាំឯពូកែនឹងគេ តែវិនាទូលនេះគ្មានសិល្បវិជ្ជាអ្វីនឹងក្បែរបូកាយ តាម
តែទ្រង់ព្រះករុណាវិសេសទ្រង់ព្រះមេត្តាប្រោសកូនហោង ។ កាលនោះ
ព្រះជនកជននីនោះ លុះបានស្តាប់ព្រះពាក្យបុត្រក្រាបបង្គំលាទៅរករៀនវេទ
វិជ្ជាដូច្នោះហើយ ក៏មានទុក្ខាវេថា អើរបើបាអ្នកទៅរៀនវិជ្ជាវេទមន្ត
នឹងព្រះឥសីសិន្ធា ចូរកូនទុសប្បាហ៍ខំរៀនសូត្រនេះឲ្យចាំចេះឲ្យបាន
ដូចប្រាថ្នា ទ្រង់ឲ្យពរស្រេចហើយ ទសកណ្ឌកុមារក្រាបទូលពរតាមហើយ
ក៏លើកដៃថ្វាយបង្គំលាមកប្រាសាទអាត្មាវិញហោង ។

អស្សុកក៏រៀបប្រដាប់ប្រដាទ្រង់គ្រឿងអលង្ការស្រេចហើយ ក៏ហោះផ្លោះ
ចាកពីក្រុងលង្កាទ្វីបសំដៅទៅព្រៃហេមក លុះដល់មណ្ឌលព្រះសិន្ធាចារ្យ
ឈ្មោះព្រះមហាឥសីគោបុត្រ ហើយក៏ចុះចូលទៅដល់ក្រាបថ្វាយបង្គំនៅ
មុខអាស្រមណ៍បរមសាលាដូច្នោះហើយ ។ ខេីបអង្គព្រះមហាឥសីគោបុត្រ
បានឃើញព្រះពាក្យទសព្រះបាទឡាត្សរៀនហើយ ខេីបមានព្រះពុទ្ធដីកា
សួរថាម្នាលទសកណ្ឌអសុក ចាឯងតេីមកមានប្រាថ្នាការអ្វីបានជាគ្មាន
រវៅពលសកលយោធា អាត្មានេះធ្លាប់សង្ស័យណាស់ ខេីបទសកណ្ឌ

អសុក ក្រាបតបត្រះពាថា ខ្ញុំព្រះករុណាដែលមកនេះសូមទានមកវៀន
សិល្ប៍សាស្ត្រដ្ឋាការក្សាបូបកាយតាមតែសម្តេចព្រះអយ្យកោ មេត្តា
ប្រោសចៅឲ្យទានវៀនផង ។ ព្រះមហាឥសីគោបុត្រទានស្តាប់ហើយ កំ
មានព្រះទ័យនោះត្រេកអរសោមនស្សយកដៃអង្អែលខ្នងចៅហើយថា ចៅ
អើយជាតាចេះប៉ុន្មាន តានឹងប្រដៅឲ្យចៅវៀនចាំងអស់ ចូរចៅទំនាក
សង្ឃាតវៀនសូត្រទៅ ធ្វើសេចក្តីជ័យនោះជាតានឹងជម្រឿ ។ ទាន
ដូចក្តីប្រាប្តាចៅហោង ។ ខសកណ្ឌអសុក កំទុស្សហ៍គោតប្រណិប័តន៍
បំរើតក់ប្រចាំ ហើយទំទុស្សហ៍សូត្រវៀនទន្ទេញការនាជាអចិន្ត្រៃយ ។
លុះវៀនយូរបន្តិចទៅ កំចេះចាំចប់ស្រេចហើយ ទំហាត់ប្តាញ់ធ្នូសិល្ប
កំបានត្រង់ដូចសេចក្តីប្រាប្តាហោង ។ លុះមានសម័យថ្ងៃមួយ ក្រុង
ខសកណ្ឌអសុក កំទៅក្រាបបង្គំលាជាតាទៅលេងព្រៃព្រឹក្សា ស្រេចហើយ
អសុក ត្រេចយាត្រាដើរលេងសប្បាយ លុះឆ្ងាយបន្តិចទៅ ។ ដល់ព្រៃ
ស្មូនទន្សាយព្រះបាទ អរជុនការ ខសកណ្ឌ អសុក កំដើរលេងចេះផ្តាន់ប្តូរ
ផ្លែឈើតាំងតួង ហើយកាច់មែកឈើលេងតាមកំសាន្តសប្បាយចិត្តឥតកោតក្រែងឡើយ ។

ខឹងសំដែងពីព្រះបាទ អរជុនការ គង់តែងពិមានវ័ន្តរក្សាទៅលើកំពូលភ្នំចក្រវាឡ មានថ្ងៃតបះតេជៈខ្លាំងតូចក្រៃ ស្តានសួគ៌តាំង ១៦ ជាន់ សុទ្ធ
សឹងតែចាក់បបូរបញ្ចាចមិនអាចនឹងហ៊ានតដៃឡើយ ។ រីព្រះបាទ អរជុន-

ការនោះ មានតំណាត់តែ ៧ ថ្ងៃទៅប្រពាធទុក្ខានតំសាន្តព្រះទ័យម្តង ព្រះ
ចាំទអរជុនការ លុះតំរង់ថ្ងៃហើយ ក៏កាន់ដំបងហោះទៅ ។ លុះដល់
សួនទុក្ខាន ហើយបើកព្រៃព្រឹក្សាតូចធំជាក់មែកបែកដើមផ្សេងៗសភាស
ពេញព្រះធរណី អសុកនឹកឆ្ងល់សង្ស័យក្នុងចិត្តគិតថានរណាអេះ មក
ធ្វើដូច្នេះ មិនក្រែងខ្លាចអញសោះឡើយ លុះលប ។ ដើរមើលទៅក៏
ឃើញទសកណ្ឌមុខ ១០ ដៃ ២០ ក៏ខឹកខឹងក្រៃវិក្រាធហើយស្រែកថា
វើយអសុកឯងនេះមកពីណា ក្លាដឥង្គីវង្សាត្រកូលឯងហើយទៅខនរណា
នាមាឯងតើឈ្មោះអ្វី ទើបឯងហ៊ានព្រហើនហានក្លាមកកាប់ដើមព្រឹក្សា
នៃសួនទុក្ខានអញ មិនមានកោតញញើតក្រែងចិត្តអញជាម្ចាស់សោះ
ឡើយ កុំថាឡើយឯងមុខ ១០ ដៃ ២០ អញនឹងបំផ្លាញអាឯងឲ្យស្លាប់ដោ
យក្នុងគ្រានេះ ទោះទេវសុកឬទ្ធិក៏គង់ក្រែងខ្លាចឫទ្ធានុភាពអញពាំងអស់
ហោង ។ គ្រានោះទសកណ្ឌអសុក ឮនស្តាប់អង្គុនការថាដូច្នោះហើយ
ក៏ខ្ពើងក្រែវក្រោធពីកេងក្រៃ ឆ្លើយតបទៅវិញថា ណែអសុកឯងតើនាម
ឈ្មោះអ្វី ទើបឯងអួតអាងកាងក្រខារលើកែខ្ញាំងម្ល៉េះ រីឯនអញនេះឈ្មោះ
ហៅទសកណ្ឌអសុក ពង្សាព្រះចាទទ្យាត្សរទៀន វង្សត្រហ្មាសោយ
ពជ្យនៅខនក្រុងលង្កាទ្វីប អង្គព្រះមហាឥសីគោបុត្រជាគ្រូចាអាចារ្យអញ
ចានបង្ហាញបង្ហាត់បង្រៀនវេទមន្តវិជ្ជា អញដើរមកកេងលេងព្រៃពនាល័យ
ទ័ហោមវៃសន៍ អញនេះមិនចានដឹងជាសួនទុក្ខានរបស់អ្នកណានោះកំពេ

លុះស្រាប់តែឃើញព្រៃផ្លែផ្កាជាទីសប្បាយភាយ ក៏គិតថាតែជាព្រៃព្រឹក្សា
ពនាល័យទីហោមភាន្ត ណែវើយកុំអាលអួតអាងឫទ្ធានុភាពខ្លាំងពូកែ រីឯ
អង្គអញសោតកំមិនមានកោតខ្លាចក្រែងឯងនោះតំណេ ខ្លួនឯងនេះប្រៀបដូច
ជាហ្វូងម្រឹគដងចាំងភ្លឺ គាលណាឡើយគ្រាំទ្រនឹងដៃអញបានតងំតែនឹង
ស្លាប់ហោង ។ គាលនោះព្រះបាទអរជុនការបានស្តាប់ពាក្យអសុកហើយ
ទ្រង់ក្រេវក្រោធក្រេញឹងនឹងខ្លាំងណាស់ ដូចភ្លើងប្រល័យកល្បហើយ
ទ្រង់ចាប់យកកូនធ្នូសិល្បសរដ៏យ៉ាងស្រួច ស្តេចគំរាបចំទៅវិញថា
អញនេះឈ្មោះហៅថាព្រះបាទអរជុនការថាតែប៉ុណ្ណោះហើយ អសុក តើស្តុះ
ទៅសំពងខ្លួកណាអសុក ។ តើព័ប់ងើគេចតែបែរបៀងតែរៀងខ្លួន អ្នកចាំង
តាស្មុខ្លួសឹងតែតូចតែ កងចិត្តគិតប៉ងប្រថុយយកជីវិត រួចហើយព្រះបាទអរ
ជុនការ តំចាប់យកធ្នូសរសិល្បដ៏យថ្លែងទៅតកើតជាខាតពជដេញតែតំ
ខ្លួនខ្លួកណាដុំខ្លួន ហើយនាំហោះទៀងទៅតណ្តាលវៃហាស៍ប្រទក្សិណ
ទៅមក ។ គាលនោះ ព្រះមហាឥសីគោបុត្រ វេលាថ្ងៃនោះ តំតាំងស្ថិតិ
ចំរើនឈានទៅកងកុដិ ឃាតឮស័ព្ទសំឡេងខ្លះខ្លាកក្រើតទឹតដីដូច្នោះហើយ
ក៏នឹតពិការណ៍នឹងខ្លួកណ្តា ជាសិស្សលោទៅលេងព្រៃ ប្រាកដជាមាន
ហេតុ ដូច្នេះគួរគាត្រាវទៅកាន់អសុកតាមមើលឲ្យដឹងនូវហេតុការណ៍
គិតហើយក៏ចេញចាកពីអាស្រមណ៍ ហើយហោះទៅដោយឫទ្ធិអានុភាព
លុះហោះទៅបានដល់ឃើញព្រះបាទអរជុនការទេវេ ថ្ងៃនឹងសរជាខាតពជ

តវ៉ាតចាប់ចង់ទសកណ្ឋ អសុក ទក្សិណទៅកណ្តាលអាកាសដូច្នោះហើយ
ក៏ខឹកគ័យតិតក្រែងទសកណ្ឋស្ងាប់ ទើបស្រែកថា ម្នាលអ្នកអរជុនការ
ខ្ញុំ ហេតុដូចម្តេចបានជាធ្វើដូច្នេះ ។ ព្រះបាទអរជុនការបានឮសំដី
ព្រះមហាឥសីគោបុត្រហើយ ក៏ធ្វើយតបទៅមហាឥសីវិញថា អានេះជា
មនុស្សព្រហើនដូរអាក្រក់ណាស់ រាមកកាច់មែកហែកដើមព្រឹក្សសួនទេវ៉ាន
ជារបស់ខ្ញុំ ហើយមិនប៉ុន្តែម្ល៉ោះទៀតក៏អួតអាងកាឯក្រគា បានជាខ្ញុំព្រះ
ករុណាចាប់ចង់ផ្តាសផ្តាញ់ឲ្យវាដឹងថ្នូខ្ញុំអំណាចខ្ញុំ ទៅមុខក្រោយឲ្យវាកង
ចាស ។ ព្រះមហាឥសីបានស្តាប់ហើយក៏ធ្វើយតបទៅនឹងព្រះបាទអរ.
ជុនការថា ណ្ហ៎ើយបុះសិស្សអាគ្មានេះវាធ្វើទុសទោសដល់ដីតមែនពិត
ហើយ តែវាជាកូនសិស្សអាគ្មាកាពតាំងតែពីទៅក្មេងតូច ៗ រៀងមក ឲ្យ
អាគ្មាកាតបិណ្ឌបានសូមដីតបានម្តង ។ រីព្រះបាទអរជុនការ បាន
ស្តាប់តុទ្ធដីកាមហាឥហើយ ក៏មានជំក្តីខោះនឹកអាណិតមើត្តាព្រះមហាឥសី
គោបុត្រនិយាយលួងលោមសុំសិស្សដូច្នោះហើយ ទើបទូលតបទៅវិញថា
ដែលព្រះអង្គសុំទោស ខ្ញុំព្រះករុណាក៏ប្រគេន ថាហើយក៏ស្រោចក្រុង
ទសកណ្ឋ ប្រគេនព្រះមហាឥសីស្រេចហើយក៏បង្គំលាឥសីហោះទៅគាន់
ស្តានវិមានវិញហោង ។

នេះនឹងសំដែងពីព្រះឥសូរ លោកគ្រងរាតើងកុងញាណ ឈ្វេងយល់
ឃើញអានន្ទកៈខោះ ឥឡូវនេះវាទៅចាប់កំណើតកើតជាទសកត្តអសុក

ម្ភុ ๑๐ ដៃ ๒๐ ជាព្រះពាជបុត្រព្រះបាទឧត្តាសខៀន នៅឯនគរក្រុងលង្កាទ្វីប អានេះវាកាចម្នាមានះអាក្រក់ក្រៃពេក ខឹងបានសេចក្តីក្តៅក្រហាយគ្រប់ ๆ ស្ថាន មិនដឹងជាខឹងបានអ្នកណាបង្ក្រាបបាន មានតែអង្គនាកយណ៌ទើបទៅបង្ក្រាបវាបាន ដូច្នេះត្រូវតែអញគិត ទ្រង់គិតដូច្នោះហើយ ទើបឲ្យព្រះវេស្សវ័ណ ទៅបង្កើតរួមវង្សត្រកូលជាមួយនឹងវា ទើបនឹងបានដឹងហេតុការណ៍ក្នុងភូពនឹងវង្វាក់អស់ ។ ហើយក៏ឲ្យរៀនគម្ពីរហោរាសាស្ត្រឲ្យចប់អស់ រង់ចាំព្រះនាកយណ៌បែងភាគទៅកាលណាហើយ អ្នកនឹងបានដឹងហេតុការណ៍សារពើគ្រប់ដំណូកហោង ។ ហើយទ្រង់ប្រទានវេតាតេជ្ជ ๑ ដំរីសេសប្រសើរឲ្យទៅបង្កើតទៅជាដួងក្នុកចាំងសង្ខាង នឹងបានឆ្នុះមើលក្នុងត្រើយលោកចាំង ๓ ដួចក្នុកចិត្តហោង ។ គ្រានោះ ព្រះវេស្សវ័ណទេវបុត្រក៏ទទួលព្រះពាទិដ៏វេនតាតេជ្ជវែរហើយ ក៏ប្រតាចកចុះមកកើតក្នុងគភ៌នាដ៏ជាគ្រប់ទសមាសក៏ប្រសូតមកជាប្រុស ព្រះបិតាសន្ធតឈ្មោះហៅពាកេកអសុក លុះចំរើនវ័យខាងឡើង មានប្រាជ្ញាឆ្លៀវឆ្លាតណាស់ តែបុព្វជិតានុភាពនោះខន់ជាបជាដ៏តេមិនខ្វាំងពូកែដូចទសកណ្ឌនិងកុម្ភកាណ៌ក៏ទេ រីឯសមលក្ខាជាប្អូនទៅបំផុត ព្រះបិតាក៏មានចិត្តនោះស្នេហាប្រដិព័ទ្ធពេកហោង ។

ខឹងនិយាយពីព្រះបាទគោត្តមដែលសោយពាជសម្បត្តិនៅនគរសាកេតបូរីពាជធានី លុះសោយពាជ្យរៀងក៏គ្មានព្រះពាជបុត្រាបុត្រីនឹងតែ

ឡើយ ហើយទ្រង់តែងឿយណាយនឹងការសម្លាត់ជាតិស្ពាន កំទ្រង់លះបង់ការសម្លាត់ទៅបួសជាតាបសឥសី ចំរើនឈានជាយូរអង្វែងបាន ២០០០ ឆ្នាំ លុះតាលតែពុកមាត់ពុកចង្កា ដុះវែងដល់ទៅដើមទ្រូងច្រើនដូចស្មៅក្រពញជ្រូក មហាឥសីប្រឹងតែខំការនាសង្រួមចិត្តប្រព្រឹត្តតាមកេរតាបស គ្រានោះមានសត្វតាបត្រៃមួយគូញីឈ្មោល លុះឃើញពុកមាត់តាបសឥសីដូច្នោះហើយ ក៏នាំគ្នាមកទៅធ្វើជាសំបុកតែពស់ឆ្នាំ លុះដល់នាងតាបនោះមានពងក្នុងពុកមាត់មហាឥសី រៃងនោះតិរហោង ។ ដួងជាសម័យថ្ងៃមួយនោះជាហេតុនឹងបណ្ដាលឲ្យមានហេតុនោះ សត្វតាបឈ្មោលនោះក៏និយាយនឹងនាងតាបជាប្រពន្ធថា ម្នាលនាង ចូរនាងនៅរក្សាកូននឹងសំបុកនេះចុះ បងនឹងលានាងទៅ ។ រកចំណីអាហារគោក្តា ថាតែម៉្លោះស្រេចហើយ តាបឈ្មោលនោះក៏ហើរចាកសំបុកទៅ លុះដល់ព្រៃហេមពាន្តហើយ ក៏ក្រឡេកមើលទៅឃើញផ្លាឈូកហើយក៏ចុះទៅជញ្ជក់ចឹកស៊ីសប្បាយ តាំងតែពីព្រឹកលុះដល់ថ្ងៃជ្រលងព្រលប់ឃប់ រីផ្លានោះ ការពីព្រឹកវិតឡើង លុះដល់ព្រលប់ការណាហើយផ្លានោះក៏ក្រសោបក្តាបដិតវិញ តាលំតែព្រឹកឡើងវិញនោះ ទើបផ្លាឈូកវិតវិញហោង ហើយក៏ហើរទៅតាន់សំបុកអាត្មាវិញហោង ។ គ្រានោះនាងតាបជាប្រពន្ធឃើញប្តីមកការណាហើយ ក៏បង្កើតក្តៅក្រហាយក្នុងចិត្តខឹងខ្លាំងណាស់ ទើបស្តីទៅថាអ្នកទៅឯណាថ្មើរណោះទើប

ចានមកដល់ស្ថានលំនៅ រីចាបឈ្មោលនោះទើបស្តីប្រាប់នាងចាបញី ជា
ប្រពន្ធថា ម្នួនបងនេះទៅរកចំណីឯព្រៃហោមភាន្ត កំចានឃើញផ្ទៃឈូក
ផ្កាឈូក បងក៏ចុះទៅជញ្ជក់ចំកស៊ី ហើយនឹងចំកព័ន៌នាំយកមកធ្វើជួនឯង
អាស្រ័យ លុះស្រាប់តែថ្ងៃលិចល្ងាចយប់ទៅ ផ្កានោះក៏ក្រសោបក្តោប
ម្នួនបងទៅក្នុងផ្កានោះ ដល់ព្រឹក ចានដាបងចាត់ លុះដល់ថ្ងៃរះឡើងកាល
ណាទើបផ្កានោះរីកវិញ បងក៏ចានមក ចាបឈ្មោលនិយាយប្រាប់តាំដើម
ដល់ចុងឲ្យប្រពន្ធស្តាប់ នាងចាបជាប្រពន្ធនោះ កាលណាចានស្តាប់ប្តី
ស្រដីប្រាប់ដូច្នោះហើយ កំនឹកក្នាញ់នឹងប្តីណាស់ក៏ប្រតាំងមែរមុខចេញ
កំនិយាយតបទៅនឹងប្តីថាមែនហើយ ខ្ញុំក៏ដឿអស់ពីចិត្ត ព្រោះតែអ្នក
មានសហាយស្នេហ៍អន្ទកអើបចានទៅដេកនឹងគ្នា មិនដែលមានផ្កាណា
នឹងក្រសោបក្តោបរូបអ្នកទៅចាន ខ្ញុំមិនដឿស្តាប់ពាក្យអ្នកឯងនិយាយទេ
រីចាបឈ្មោលនោះ លុះចានឮពាក្យសំដីនាងចាបជាប្រពន្ធថាកៀសគៀង
ដៀងពាក្យក្តួចគាន់ប្រច័ណ្ឌនឹងដូច្នោះហើយ ចាបឈ្មោលក៏ធ្វើយតបទៅ
វិញថា ។ បើនាងមិនដឿ បងហ៊ានសច្ចាស្បថឲ្យនាង ម្នួនបងនេះត្រង់
ពិតប្រាកដ ។ នាងចាបញីនោះធ្វើយតបសួរតាមពាក្យស្លាមីថា អ្នកនឹង
ស្បថយ៉ាងដូចម្តេច ទើបចាបឈ្មោលថាបងហ៊ានស្បថឲ្យចាបដូចមហា
ឥសីនេះ ។ គ្រានោះព្រះមហាឥសីនោះ លុះចានស្តាប់ស័ព្ទសត្វចាប
វាទិយាយស្បថឲ្យប្រពន្ធវាដូច្នោះហើយ កំនឹកឆ្ងល់ពីការនឹងសត្វចាប

ណាស់ ទើបមានពុទ្ធដីកាសួរថា ណែចាបឈ្មោលអើយ ឯងអាំគ្នា
មកធ្វើសំបុកនឹងពុកមាត់អញផង ម្តេចឡើយឯងត្រឡប់មកថាខ្លួនអញជា
មានចាបវិញ អញសព្វថ្ងៃនេះ ព្រោះខ្លាចចាបខ្មាស់ចាប ទើបចាន
ជាលះពជសម្បត្តិមកសាងត្រីដ្ឋិ ឋួសជាតាបសឥសីចំរើនមេត្តាភាវនាជា
អចិន្ត្រៃយ៍ ឥឡូវនេះឯងថាអញមានចាបពីដំណើរអ្វី ។ ទើបចាបខ្លួល
តបព្រះពុទ្ធដីកាថាព្រះអង្គនេះ ចានជាខ្ញុំថាមានចាប ព្រះអង្គជាមហា
ក្សត្រសោយពជសម្បត្តិ ហើយមិនមានបុត្រាបុត្រី កំលះបង់ពជ
សម្បត្តិមកបួសជាតាបសនៅព្រៃ ឲ្យសូន្យតង្សារវង្សាក្សត្រនឹយាដែល
នឹងត្រូវការពាជានឹតនៅចានជាមានចាបធំណាស់ ទើបចានជាខ្ញុំព្រះក
រុណាសូមឲ្យចាបដូចព្រះអង្គសព្វថ្ងៃនេះ មិនចានសំរេចឈាន សូមទ្រង់
រំពឹងគិតនៅចុះ ។ គ្រានោះព្រះតាបសឥសីចានស្តាប់ពាក្យចាបច្រាប់ថា
ដូច្នោះហើយ ព្រះអង្គទ្រង់រំពឹងយល់ឃើញដូចជាពាក្យពោល កំទ្រង់
មានមនោថិតិត្រេកអរសាទរណាស់ ហើយព្រះអង្គកំទ្រង់តាំងពិធីកម្មកង
អគ្គីតាមគេទព្រះមុខពីបូរាណរៀងមក ដល់បន្តើតចានជាស្រីមួយឈ្ម
ណាស់ ទើបសន្មត់ឲ្យឈ្មោះនាងកាលអច្ចនាស្រេចហើយ ឥសីគោត្តម
នោះក៏ចាកសិក្ខាបទមកនៅរួមព្រះវេណីនឹងនាង កាលអច្ចនា យូរវែងថ្ងៃមក
លុះតែនាងមានគភ៌គ្រប់ទសមាសហើយ លុះចានប្រសូតារពេលក៏សំ
រាលបុត្រ ១ ឲ្យឈ្មោះហៅនាងស្វាហាយ រូបនោមរោមពណ៌ក៏ល្អដូច

ខេពកញ្ញា ព្រះបិតាមាតាក៏មានចិត្តនោះស្រឡាញ់ណាស់ហោង ។ កាលនោះព្រះគោតម វេលាព្រឹកឡើងកាលណាហើយ ក៏តែងតែទៅបេះផ្លែឈើមើមឈើមកចិញ្ចឹមដីតែ តែទៅត្រៃកាលណាហើយប្តីផ្តាំទំាងប្រពន្ធថាចូរនាងរក្សាកូនឲ្យល្អ អញទៅនេះមិនយូរទេ ផ្តាំស្រេចក៏លើកដង្រែកសង្រែកដាក់លើស្មាហើយវែកដើរចូលទៅព្រៃ រកបេះផ្លែឈើមើមឈើក្នុងព្រៃពនាល័យតែហមវន្ត ។ (ស្មេះ) ទំាងនិយាយតាសម្តេចឥន្ទ្រាធិរាជគ្រង់បើកចិត្តចក្ខុញាណដំាងដោយព្រះបារមី ថាអានន្ទកៈនោះកំពុងតែឆ្លើតជាកូនព្រះបាទឱក្កាកៈឲ្យនាំយកសក្ក អស្សុកមានចិត្តមិច្ឆាទិដ្ឋិកាចហោរយៅ ទំាងបៀតបៀនព្រៃលោកាពុំលែងឡើយ គ្រង់តតាយល់ហើយថាដល់ព្រះនាគយណ៍កាឡាបែងកាតចុះមកចាប់ឫដំសន្ធិ ទំាងមហេសីព្រះបាទធនដ្ឋ ហើយស្តេចទំាងបង្ក្រាបប្រាប់អស្សុរោលតាលា តួអញទំាងបែងឫទ្ធិកំលាំងតែឆ្លើតកូនមួយ ទំាងបានជួយកំលាំងឫទ្ធិទំាងអស្សុរកពងង ។ ឥឡូវនេះប្តីនាងកាលអច្ឆា ក៏ទៅព្រៃរកបេះផ្លែឈើមើមឈើមិនបានមកដូច្នេះតួអញទៅសេពសម្ភពនឹងនាង កាលអច្ឆា បង្កើតកូនមួយទុកជួយព្រះនាគយណ៍ហោង ។ គ្រង់តតស្រេចហើយក៏ហោះចុះចាកទៅស្ថានអាត្មា មកកាន់អាស្រមណ៍បរមសាលានាងកាលអច្ឆា ហើយព្រះអង្គគ្រង់ចដិសណ្ឋានៈទៅរៃភ្យៅមក នាងក៏ត្រមដោយដួចសេចក្តីត្រេកអរ ហើយក៏សេពសមស្នេហមន៍រួមមនោសេនឹងគ្នា ស្រេចហើយព្រះកោសី

កំណាន់ត្រឡប់ទៅកាន់ស្ថានតិមានវិញហោង ។ រីព្រះគោតមនោះ កំ
ត្រឡប់រំលែមកពីព្រៃវិញហោ ។ លុះយូរបន្តិចទៅនាងកំមានគតកំត្រង់
ខែសមាស កំប្រសូតកូនជាបុត្រ ១ សម្បុរពណ៌ ខនោះថ្លាយតន៍ពណ៌ដូច
មកិត រីរូបកុមារនោះល្អដូចរូបព្រះឥន្ទជាបិតា រីឯនាងកាលអច្ចនា ខ្ញុំង
ព្រះគោតមជាបិតា កំមានចិត្តនោះស្នេហាស្រឡាញ់បុត្រនោះពេកក្រៃ រី
ឯព្រះគោតមតែព្រឹកឡើងកាលីណាហើយ កំតែងតែទៅកាបេះផ្លែឈើ
មើមឈើជាប្រក្រតីរៀង ។ ទៅ ។ លុះដួងថ្ងៃ ១ នោះ នាងកាល
អច្ចនា អង្គុយនៅក្នុងសាលាគស្រមណ៍ក្រឡេកមើលទៅឃើញព្រះអា
ទិត្យស្ថិតនៅកណ្តាលអាកាស មានរស្មីភ្លឺត្រចះត្រចង់ទ្វាស់សព្វទិស នាង
កំខំតក្នុងចិត្តាស្រឡាញ់ព្រះអាទិត្យ ហើយកំលើកដៃថ្វាយបង្គំទៅព្រះអា
ទិត្យ ។ កាលនោះព្រះអាទិត្យទ្រង់បើតព្រះនេត្រទិព្វមើលមក ឃើញនាង
កាលអច្ចនាហើយ កំចាប់ចិត្តប្រតិពទ្ធចង់រួមរស់នឹងបង្កើតកូន ១ ពុក ខ្ញុំង
ជានដួងព្រះនាកយណ៍ថែងតាត ចុះមកបង្ក្រាបអសុរ ទ្រង់តិតរំពឹងដួងចិត្ត
ហើយ ទើបមានទេវបញ្ជាទៅនឹងទេតសារថីថា ចូរអ្នកទៅបរកង់រថឲ្យ
ត្រង់ចក្រាឲ្យ អញនឹងចុះទៅកាន់នាងកាលអច្ចនា ស្រេចហើយទេវបុត្រ
ព្រះអាទិត្យកំហោះចុះមកដល់អាស្រមណ៍តុដិកាលណាហើយ ។

រឿងព្រេងបិន (ត)

១៦ សេចក្តីយុត្តិធម៌នឹងប្រាក់

16 — La justice et l'Argent (Conte mongol)

លោក ភ័យ-ប៊ុក ប្រែរៀបរៀង

តាំងពីព្រេងនាយ នៅកាលខ្ពស់នៃប្រទេសម៉ុងហ្គាលី មានអ្នកបម្រៀងម្នាក់ក្បែកខ្ញាក់ចាំងពីរ ។ កាលំពេលវេលា អ្នកបម្រៀងនោះស្លាយចាប៉ីត្រចុះឡើងតាមកាលនោះ ។ គាត់ញាំងចិត្តប្រជាជននៅទីនោះដោយបម្រៀង ការនិយាយរឿងផ្សេង ។ ឲ្យបាត់អផ្សុក ឲ្យកែកយសប្បាយ ។ លុះយូរថ្នាំៗ អ្នកបម្រៀងនោះប្រមូលប្រាក់សន្សំបានល្មមសម្រាប់ការចាស់ជរា នៅអនាគត ។ ដោយគាត់គ្មានផ្ទះសម្បែងដូច្នេះតើនឹងយកប្រាក់នោះ នៅលាក់ឯណា បើទីនោះសុទ្ធតែមានចោរដើរទៅមកជានិច្ចវិញ ។

ដល់ត្រង់រៀវទៅគាត់ក៏នឹកឃើញនូវមេល្បាចាយមួយបែប ដើម្បីរក្សាប្រាក់នោះ គឺយកប្រាក់នៅជាក់កន្ទុងថង់ស្បែកបន្ទប់នឹងបន្តុះឲ្យជាប់ ។ តែមិនយូរប៉ុន្មាន ក៏មានគ្រោះថ្នាក់មកដល់គាត់ដូចតទៅ :

មានកាលមួយថ្ងៃ ព្រះសុរិយាមានរស្មីត្រចះត្រចង់លើមេឃ ព្រះពាយបក់រំភើយ ។ លើកាលស្មៅ ពពកក៏គ្មានលើគាល័យ គ្មានអ្វីជាឧបសគ្គមកពាំងការសុខដុមរមនាសោះឡើយ ។

អ្នកបម្រៀង ចានប្រឹងសប្បាយក្សេមក្សាន្ត អង្គុយនៅមុខភ្នក

ចាស់ក្នុងដែលចាំស្តាប់គ្រប់ៗ គ្នា កំស្រាប់តែមានមនុស្សដើរតាមក្លាយម្ចាត់
មានគ្រឿងស្បែកពាក់ហឹកហាក់តិះ អាវកាក់សក្ខាតខៀវផ្លែមេយ ព្រៃ
រលើយរលង់ មួកព្រៃខ្មៅហើយស្បែកជើងខ្មៅភ្លឺរលោងស្រិល ។ មនុស្ស
នោះបានដើរមកចំអ្នកចម្រៀង ។ ក្រោយដែលបានចោលកន្ទុយភ្នែក
ទៅលើមនុស្សនោះកំរាត់ជ្រែកតួកជនាទុជន ទៅអង្គុយចំពីមុខមនុស្សខ្លាក់
នោះ ភ្នែកក្រឡេកវាតមើលត្រង់ដើមទ្រូង ។

ដល់មនុស្សខ្លាក់ច្រៀងចប់ហើយ តួកជនាទុជនកំនាំគ្នាលៃទៅគេ
ហាដ្ឋានសព្វ ។ ខ្លួន ។ មនុស្សនោះកំលោតទៅលើខ្លួនមនុស្សខ្លាក់នោះ
ប្រវាយដណ្តើមយកថង់ស្បែកនោះ ។ តែមនុស្សខ្លាក់បានចាប់ដៃអាវ
ចោរជាប់ ហើយស្រែកថា :

« ចោរ ! ចោរ ! មិនដែលឃើញអ្នកណាហ៊ានបែបនេះ ។
វាហ៊ានលួចនំងមុខគេឥតកោតញញើតសោះឡើយ » ។

មនុស្សជនាង លុះឮសម្រែកមនុស្សខ្លាក់នោះ ក៏រត់ប្រញាប់
ប្រញាល់មកកាន់ទីនោះ ។ មនុស្សពាំងឮយានោះបានឃើញមនុស្ស
ខ្លាក់កាន់ដៃអាវចោរជាប់ ក៏មានចិត្តខ្ពើមនស្សឥតឧបមា ហើយស្តី
បន្ទោសចោរនោះថា :

« អាតួជជ្រឹង ! ម្តេចក៏អាឯងធ្វើបាបមនុស្សខ្លាក់ដូច្នេះ ! » ។
ក្នុងពេលនោះ មនុស្សពាំងឮយាចាប់ចោរនោះដើម្បីនឹងតាំទៅសា-

លាស្រុក ។ តែ ចោរនោះបានលើកបង្ហាញជនានុជនទូវថនំស្បែកនោះ ហើយពោលថា :

« តើអ្នកឯងធ្លាប់ដឹងថាមនុស្សខ្លាក់ក្រក្រៃបែបនេះ មានប្រាក់ច្រើនម្ល៉េះ ! នេះគឺជាមធ្យោបាយចង់ធ្វើបាបខ្ញុំ ! » ។

ពួកប្រជាជនទាំងឡាយមានចិត្តខឹងខ្លាំង មហិមា បើពុំជាយ៉ាងណាក៏ត្រូវតែនាំចោរនោះ ទៅជូនលោកសុកា ។

លោកសុកាបានពិនិត្យសាកសួរ រឿងនេះសព្វគ្រប់ ក៏ឲ្យមនុស្សខ្លាក់មកអង្គុយជិតលោក ហើយបង្គាប់ទៅចោរថា :

« ឯងលុតជង្គង់មក ! ធ្វើយ៉ាងណាក៏ឲ្យបាន ។ លួចប្រាក់អ្នកចម្រៀងនេះ ! ឥតខ្មាស់អៀនគឺជាទោសធ្ងន់បំផុត ហើយនាំឲ្យអាម៉ាស់មុខដល់ពួកព្រះពុទ្ធសាសនា អ្នកឯងយកឈ្នាប់ឈ្មីធ្វើជាងបានជាឯងធ្វើដូច្នេះ ! » ។

តែ បើពុំជាលោកសុកាមានប្រសាសន៍យ៉ាងណា ចោរនោះស្ងៀមទៅស្ងៀមចាំស្តាប់ រួច ក៏ពោលទៅកាន់លោកសុកាថា :

« តឹជាកិត្តិយសនៃលោក ខ្ញុំជាពួកព្រះពុទ្ធសាសនា ម្តេចក៏លោកហ៊ានចោទថាខ្ញុំប្រព្រឹត្តបទទុក្រិដ្ឋបែបនេះកើត ! ។ ព្រះពុទ្ធអង្គ គោរពខ្ញុំមានព្រះកិត្តិសព្ទល្បីល្បាញពន់ពេក ! ហើយខ្ញុំ ។ មានប្រាក់កាសល្មមគួរសម ម្តេចលោកចោទថាខ្ញុំលួចប្រាក់មនុស្សខ្លាក់បែបនេះ

ដូចជាមិនសមរសោះ ? » ។

វាចាដែលបុរសជាចោរ ឮនូវពាក្យដូចខាងលើនេះ ឮនិយាយ
ឲ្យលោកសុភាកាន់តែខឹងយ៉ាងខ្លាំង ។

លោកសុភាឆ្លើយតបដោយចិត្តក្រេវក្រោធឥតខ្លួមា ទៅនឹងចោរថា:

« ប្រសែលជាជីដូនជីតាឯងមានពូជមិនល្អ ឬមានជាបន្តឹតកូនចៅ
ជាពូជចោរតមក ។ ឯងឯងដើលពាក្យស់ចង់យកកិត្តិយសជីដូនជីតាឯង
មកបិទបាំងកំហុសឯង ។ ឯងមានកស្តុតាងអ្វីថាជីដូនជីតាឯងមាន
សម្បត្តិ ! » ។

បុរសជាចោរពោលថា:

« សូមអភ័យទោស លោកសុភា នាមនៃជីតាខ្ញុំ អ្នកណា
ក៏ស្គាល់ដឹងឮ ! ។ តាំងពីព្រះចៅអធិរាជ ព្រះអង្គម្ចាស់ មន្ត្រីធំ ។
រហូតដល់ពួកអភិជនទាំងឡាយ គ្មានអ្នកណាមួយថាមិនស្គាល់ជីតាខ្ញុំ ! ។

លោកសុភាមានចិត្តធ្ងន់ធ្ងល់ពន់ពេក ។

បុរសជាចោរពោលបន្តមថា : ខ្ញុំសូមបញ្ជាក់លោកសុភា
សូម្បីតែលោកគឺតដ៏ដែលស្គាល់ជីតាខ្ញុំដែរ » ។

លោកសុភាក៏ឆ្លើយតបទៅនឹងបុរសជាចោរថា :

« ចើដូច្នោះ អ្នកណាជាជីតាឯង » ។

បុរសចោរតបវិញថា :គឺលោក « ជាចឺនវែត » ដែលមានខ្នងកោង

មុខអុតនោះឯង ជាដីតាំ្ង » ។

លោកសុភា ក្រោយដែលបានស្តាប់ខ្លឹមសារនៃបុរសជាចោរ កំតិតជញ្ជឹងមួយស្របក់ អង្អែលចង្កាហើយពោលថា :

« រឿងក្តីនេះលំបាកដំណុំដុះណាស់ យើងនឹងសម្រេចនៅពេលស្អែក » ។

លោកសុភាឃុំខាំងបុរសខ្វាក់ក្នុក នឹងចោរនៅបន្ទប់មួយ ។ ដោយឡែកពីគ្នា ។ ដល់ពេលអង្រួតស្ងាត់ ចោរយកស្បែកដើងក្រាក់មួយខម្ងន់ ๙๐ ដំឡឹងទៅជូនលោកសុភា ។

ដល់ពេលស្អែកនឹងដំណុំដុះក្តីនេះ លោកសុភាកំប្រែខ្លួរអាកប្បកិរិយាហើយស្រែកទៅកាន់បុរសខ្វាក់ថា :

« ឧបុរសខ្វាក់ ! ម្តេចក៏ឯងមិនរស់នៅជាអ្នកសុចរិត ស្មោះត្រង់ទៅ ! ម្តេចកំចាំលោកគ្រូឲ្យសម្លាប់គេ ហើយនាំរែនដល់គ្រួសារពួកអកិដនដោយហេតុបង្កាច់គេដាំងស្រុងដូច្នេះ ? តើឯងស្គាល់ទោសទ្រង់ខ្លួនឯងឬទេ ? » ។

អ្នកចម្រៀង ក្រោយដែលបានទទួលនូវពាក្យអសប្បុរសពីលោកសុភា កំយល់ជាក់ច្បាស់ស្ថានការណ៍ក្នុងពេលនោះ ។ បុរសខ្វាក់មិនឱយស្តីអ្វីសោះឡើយ យកម្រាមដៃកកាយព្រះឧទរហើយផ្លៀងត្រចៀកស្តាប់ ហាក់ដូចជាបានឮសំឡេងអ្វីមួយ ។

លោកសុភាឃើញគាត់ប្រកិរិយាប្លែកអស្ចារ្យ នៃមនុស្សខ្វាក់នោះ ក៏សួរថា :

ណែ បុរសខ្វាក់ អ្នកឯងធ្វើអ្វីដូច្នេះ !

បុរសខ្វាក់តបទៅនឹងលោកសុភាវិញថា :

« សូមអភ័យទោស ! ព័ម្យ៉ាលមេញ ខ្ញុំបានឮសំឡេងយុត្តិធម៌ ឥឡូវនេះ ខ្ញុំឮសូរសោហាជាតុម្យ៉ាង ប្រហែលជាប្រាក់ ខ្ញុំចង់កកាយយកប្រាក់នេះ ដើម្បីនឹងជូនលោក » ។

រួច បុរសខ្វាក់ បន្តមតទៅទៀតថា :

« ខ្ញុំអភ័ព គ្មានពន្លឺមើលឃើញទឹងគេ តែធម្មជាតិបានខុកគ្រចៀកខ្លាំងពីរឡើងខ្ញុំស្តាប់សំឡេងដែលចេញពីក្នុងមហាប្រថពី ហើយខ្ញុំអាចស្តាប់បានខ្លះសំឡេងដែលចេញពីចិត្តមនុស្ស ! » ។

ក្រោយដែលបានស្តាប់ខ្លះរាល់ពាក្យនៃបុរសខ្វាក់ លោកសុភាក៏ព្រួយចង់ចាម្តងខ្លាំង ក៏ឈប់លែងស្តាប់ពាក្យនេះតទៅទៀត ។ លោកចូលទៅក្នុងគេហដ្ឋានរបស់លោក ហើយលោកបង្គាប់គេឲ្យដោះលែងបុរសខ្វាក់នោះ ដែលមានប្រាជ្ញាឆ្លាតវៃនោះ ។

(ចប់)

នៅមានរឿងបន្ថែមទៀតពីខ្លាក់តទៅទៀត ។

តាមឯកសារបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃទេមរភាព
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរភាព ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងពីព្រេងតាយ ។

ប. ព.

ប្រកាសប្រឡងទំនៀមទម្លាប់

នៅឆមាសទី ២ គឺតាំងពីខែ កក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៤ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែងពីរមុខ គឺ :

១- អំពីសិប្បកម្ម ជារបររបស់ខ្មែរ ;

២- អំពីជំនួញត្រៀងបុរាណ របស់ខ្មែរ ។

ដូច្នេះ អស់លោកអ្នកចេះដឹងតាំងពីឆ្នាំយ ជាស្ត្រី ជាបុរស ឬជាបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងអត្ថបទ តាមគោលបញ្ញាដូចរៀបរាប់ខាងមុខ ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែធ្នូ ឆ្នាំ ១៩៦៤ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ជា ៤ ថ្នាក់ :

ថ្នាក់លេខ ១... ១.០០០រ៉ៀល	ថ្នាក់លេខ ៣... ៦០០រ៉ៀល
ថ្នាក់លេខ ២... ៨០០រ៉ៀល	ថ្នាក់លេខ ៤... ៤០០រ៉ៀល

បណ្ណាអត្ថបទពាក់ព័ន្ធមុខនេះ បើបេក្ខជនម្នាក់ ធ្លើរៀងជាក់ប្រឡងពាក់ព័ន្ធមុខ ហើយបានល្អពាក់ព័ន្ធមុខ អាចបានរង្វាន់ពាក់ព័ន្ធមុខ តែបើស្នាត្រជាក់ប្រឡងពាក់ព័ន្ធមុខ សូមសរសេរអត្ថបទមួយ ១ លើសៀវភៅសរសេរខ្នាតធំ ស្តើងឬក្រាស មានចំនួនទំព័រតិចឬច្រើន តាមសេចក្តីខ្វល់ខ្វាយ ផ្សេងពីគ្នា តែអត្ថបទ ១ មុខជាក់សៀវភៅ ១ កុំជាក់ ២ មុខបូលគ្នា ខ្ទង់កុំសរសេរលើក្រដាសតែ ១ សន្លឹក ២ សន្លឹកស្តើង ។ ល្អើយ ហើយសូមសរសេរនាម ខ្ទង់ទីលំនៅរបស់ខ្លួនឲ្យច្បាស់លាស់លើក្រដាសស ១ សន្លឹក ជាក់ក្នុងស្រោមសំបុត្រ ១ ដោយឡែក ជាមួយខ្ទង់អត្ថបទ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនកំពង់ យកទៅឲ្យមេឃុំធ្លើរៀងតាមប៉ុស្តិ៍ឲ្យកំពង់ ដោយកាន់សំបុត្រថា :

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

(ផ្នែកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)

គោលបញ្ញានៃការប្រឡង

១- អំពីសំបុរ្យការ ជារបររបស់ខ្មែរ :

ដោយវេបសំបារទេស ចេះតែមានចូលមកលក់ដូរក្នុងស្រុកខ្មែរយើង អ្នកស្រុកយើងគំចេះតែនិយមប្រើ ហើយលះបង់ការងារជារបររបស់ខ្លួន ចោលបន្តិចម្តង ។ ជណ្តាលឲ្យការបង្កើតផលរបស់ជាតិខ្លួនរលត់ទៅជាលំ-ជាប់ ទីឆ្ងាំឲ្យអ្នកស្រុកទៅជាលួងំ ចាំតែទិញរបស់គេប្រើស្រាប់ ហើយគេចង់ដំឡើងថ្លៃប៉ុន្មានក៏សឹងតែបាន ព្រោះខ្មែរយើងត្រូវការ ។ ប៉ុន្តែសម័យនេះ ដោយសារការតែទម្រង់សេដ្ឋកិច្ចរបស់សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ដឹកនាំឲ្យខ្មែរយើងចំបង្កើតផលិតផលរបស់ជាតិ កុំឲ្យខាតប្រយ័ណ្ឌទៅប្រទេសក្រៅ នោះគំផ្តល់ឱកាសល្អមួយដល់អ្នកបង្កបង្កើនទេសខ្មែរយើងដែលតាំមុនមកបានបង់ចោលមុខរបរអស់ជាច្រើនទៅហើយនោះ ឲ្យមានកម្លាំងប្រឹងកសាងថ្មីដៃរបស់ខ្លួនវិញជាថ្មី ដើម្បីពង្រីកផលិត-ផលរបស់ខ្លួនដោយខ្លួនឯង ។ ឧទាហរណ៍ដូចតាំដើមដែលស្រុកខ្មែរយើងមិនទាន់មានវេបសំបារទេសនាំចូលមកលក់ដូរច្រើនហើយថ្លៃក ។ ទៅឡើយខ្មែរយើងចេះធ្វើរបស់ច្រើនយ៉ាងតាមដែលខ្លួនត្រូវការ ជាអាទិ៍ សំពត់ហូល លៀក ក្របុង ជាហុំ ជាមួង អន្ទាក់ ក្រមួនសុទ្ធ ក្រមួនលាបមាត់ ទឹកអប់ មេរ៉ា ក្រជាសមន ស្មឹកតឹត ក្លស់ ផ្តិលខាត់ ផ្តិលស្ពាន់ ផ្តិលប្រាក់ ជាត្រកួក តុ-តោកជើងពានក្នុក ជាំឡង ប្តុ-តោកជើងពានឈើ តុ-ថាសជើងពានប្រាក់ . ស្ពាន់ ហឹបស្ងួ ប្រអប់ផ្សែង ។ មានពងជ្រូង-មូល ជាវិការៈនៃស្នែង នៃឈើ ក្នុកជាំឡង កាំប្លុងផ្សែង ។

រូបភាពផ្សេង ។ ជារំភាះនៃឈើ នៃលោហធាតុ ចម្លាក់ថៅហោជាដើរិហារ ខ្មុះសែ្មកជាក្បាច់ជារូបភាពផ្សេង ។ ស្បាលបក់ ស្បាលកំន ស្បាលជាន់ ស្បាលថ្នរហាត់ខឹត រហាត់រៃ រនេះគោ ខ្លូកផ្សេង ។ ជាក្នុមចំនួន ក្នុម ឆ្នាំង ដើង ដើងក្រាន ជារំភាះនៃដ ។ល។ ស្រា ទឹកស្ងួង ទឹកខ្មេះ ទឹកត្រី ។ល។ ជាគ្រឿង១បភោគ បរិភោគ សម្រាប់ប្រើប្រាស់ផ្ទាល់ ខ្លួនទឹងជារបរសម្រាប់លក់ដូរក្នុងប្រទេស តាំងអំពីអតីតកាល ។

សំប៉ាយការជារបរខ្មែរ ដែលក្រុមដំនុំរៀបរាប់ខាងលើនេះហើយ ដែលលោកអ្នកប្រឡងត្រូវសរសេរតែងផ្ទៀងប្រឡងក្នុងលើកនេះ ។ ការប្រឡងនេះក្រុមដំនុំ សូមបញ្ជាក់ថា លោកអ្នកអាចសរសេរអំពីរបរដែលគេលះបង់ចោលអស់ថៅហើយក៏បាន អំពីរបរដែលគេប្រកបធ្វើជាកលៃថ្ងៃនៅឡើយក៏បាន គ្រាន់តែ ចេះលោកអ្នកត្រូវការសរសេរអំពីរបរណា សូមធ្វើសេចក្តីអធិប្បាយអំពីរបរនោះឲ្យច្បាស់ទឹងឲ្យបានសព្វគ្រប់ផង ព្រោះលើកមុន ក្រុមដំនុំបានខ្លួលឯកសារស្តីអពីរបៀបសូដ៏រឆៅ ដែលលោកអ្នកសរសេរបានទឹយោយអំពីរបៀបសូ របៀបធ្វើ ទឹងត្រណមផ្សេង ។ ហើយ ប៉ុន្តែលោកក្មេចត្រាប់អំពីការប្រើ ថាមានរបៀបដូចម្តច ។

ដើម្បីជាការងាយចំពោះបញ្ហានេះ ក្រុមដំនុំសូមដួនសេចក្តីជាលំនាំ ខ្លះ ដល់អស់លោកអ្នកសរសេរតែងដូចតទៅ ៖

ក)- របៀបធ្វើវត្ថុទឹមួយ ។ វត្ថុដែលត្រូវយកមកធ្វើ ខ្មុន ប្តូរផ្ទាល់

នៃវគ្គទីមួយ ។ ព្រមទាំងប្រជាប់សម្រាប់ប្រើ ក្នុងការប្រកបធ្វើរបស់នោះ ។ផង ។

ខ)- ក្នុងពេលធ្វើ តើមានគ្រោះថ្នាក់ ឬតិចតួចអ្វីជាការចាំបាច់ឬទេ ?

គ)- ពាក្យចំនឹមចំនៀមឬពាក្យស្មោកផ្សេង ។ ព្រមទាំងរឿងព្រេងដែលភាក់ពន់ពឹងរបរនោះផង ។

ឃ)- វិធីប្រើរបស់ទីមួយ ។ ។

ង)- បើប្រសិនអស់លោកអ្នកសរសេរគែង អាចគូរប្លែកពីនៃរបស់ដែលលោកអ្នកសរសេរផងបាន នោះជាការប្រសើរណាស់ ។

ជាពិសេស សូមបញ្ជាក់អំពីរបៀបដែលលោកអ្នកសរសេរនោះថា : លោកអ្នកបានធ្វើផ្ទាល់ខ្លួន ឬបានឃើញគេធ្វើនៅស្រុកណា ភូមិណា ខេត្តណា បើលោកបានជ្រាបដោយមានគេនិយាយច្រាប់ កំសូមបញ្ជាក់ម៉ឺងខ្លែងដែលធ្វើរបរនោះ ព្រមទាំងអ្នកឲ្យការណ៍ដល់លោកអ្នកផង ។

๒- អំពីឱឡុកគ្រឿងបុកណា របស់ខ្មែរ :

ដែលហៅថា « ឱឡុកគ្រឿងបុកណា របស់ខ្មែរ » នេះ គឺសំដៅដល់ពាក្យកាត្យឃ្លោងខ្លី ។ ដែលអ្នកស្រុកធ្លាប់ចេះចាំត ។ គ្នាមក រកដើមកំណើតថាអ្នកណាមួយជាអ្នកតែងមិនឃើញ ប៉ុន្តែគេចេះខ្លះៗគ្រប់ស្រុក គេធ្លាប់ច្រៀងលេងតាមកាលស្រែចម្ការ នៅលើខ្នងក្របី នៅពុងត្នោត ឬនៅពេលបុណ្យទានតាមប្រពៃណីណាមួយ ។ ឧទាហរណ៍ដូចជា ឱឡុក

ចំតេកូន ចំនុកអ៊ុំខ្លួក ចំនុកប្រុបកៃ ចំនុកបើកជ្រុយខ្លួន.ភ្លាវ ចំនុកបើក
ភ្លំដ៏ខន ចំនុកសារិកាកែវ ចំនុកខន្សោងគោព្រៃ ចំនុកអាឡែវៅជាញ
ប្រពឹក ។ល។

សូមលោក-អ្នកណាដែលចេះចាំចំនុកទាំងនេះ មេត្តាសរសេរចម
រៀបចញ្ជូនទៅឲ្យក្រុមដំនុំចំនៀមខម្ចាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ
ក្រសួងធម្មការ ភ្នំពេញ ដើម្បីក្រុមដំនុំពិនិត្យដាក់ពិន្ទុ ឲ្យលេខ
តាមការគួរ ។

ដើម្បីឲ្យងាយស្រួលដល់លោក-អ្នក ដែលនឹងសរសេរដាក់ប្រឡង
យើងសូមជូនរបៀបសរសេរតាមលំដាប់ណាដូចតទៅ ៖

១- សេចក្តីចំនុក :

ក- សូមចញ្ជាក់ឈ្មោះចំនុកឲ្យច្បាស់ ថាឈ្មោះចំនុកអ្វី ?

ខ- សរសេរសេចក្តីដែលជាចំនុកនោះ ឲ្យចប់ចុងចប់ដើម ច្បាន
ច្បាស់លាស់ ចែកចេញឲ្យមានឃ្លាឈ្នះត្រឹមត្រូវផង ។

គ- បើចំនុកនោះ មានពាក្យចន្ទរថាម៉េច ? ហើយចន្ទរត្រង់ឃ្លា
ណា ? សុំកត់ចំណាំពាក្យចន្ទរនោះ ជាក់ជាប់ជាមួយចំនុកនោះ ត្រង់
ឃ្លានោះផង ។

២- បៅតុទាក់ទងដោយដើមកំណើត :

ក- សូមនិយាយពីប្រវត្តិដើមរបស់ចំនុកនីមួយ ។ ដែលលោកអ្នក

សរសេរនោះថា ហេតុអ្វីបានជាកើតមានទំនុកនេះឡើង ។បានថា កើត ដោយសារពួកអ្នកធ្វើសង្គ្រាម អ្នកអុំទូកដកត្រលិត អ្នករក។ស រកឃុំ យកដីរ សូចត្រី ឬបើមានរឿងត្រង់ណាមួយដែលនិទានទាក់ទង ដោយដើមកំណើតទំនុកនេះ បទនេះ ក៏សូមប្រាប់ផង ។

១- ទំនុកនោះ។ កើតមកពីសម័យណា បើដឹងច្បាស់ សូមប្រាប់ក៏បាន បើមិនដឹងច្បាស់សូមប្រាប់តែជំនាន់ ដូចជាជំនាន់អង្គរ-ជំនាន់លង្វែក-។ត្តឆ្ន ជាដើម ។

គ- តើនរណាម្នាក់ ឬ ក្រុមណាមួយជាអ្នកបង្កើតទំនុកនេះឡើង ? បើអ្នកនោះមានឈ្មោះមានដាវ សូមប្រាប់មកផង ។

ឃ- ហេតុអ្វីបានជាទំនុកនេះឯង មានចំណងដើងដូច្នេះ ព្រោះគេយកន័យទំនុកនេះប្រៀបធៀបនឹងអ្វី ? ឬមានការយកការដូចម្តេច ?

៣- ពត៌មានបន្ថែម :

ក- គេនិយមសូត្រ ឬប្រើទំនុកនេះនៅក្នុងពេលវេលាណា ? ដូចជា វេលាច្រូតកាត់ វេលារៀបអាពាហ៍ពិពាហ៍ ពេលស្មោះជុក ពេលអុំទូកលេង ពេលចាំចាប ពេលឡើងគ្នោត ។ល។

ខ- តើទំនុកនេះ អ្នកស្រុកខ្មែរយើង នៅភូមិភាគណាដែលនិយមប្រើង និយមសូត្រច្រើនជាងគេ ?

គ- តើទំនុកនេះមានទាក់ទងនឹងដំនៀយ៉ាំងណា ? ដូចជាប្រើង

ចញ្ជាន់ចេបអារក្ស អញ្ជើញទ្រមែ្ងតង្វាលឲ្យជួយពាក់ដំរី ប្រគំជួរដំបូរ លាបំណន់ ឡើងគ្រូ ឡើងរោង តាត់ខ័ណ្ឌស្វា ។ល។

ឃ- តើនៅក្នុងស្រុកភូមិបេះស់អស់លោក-អ្នក មានទំនៀមប៉ុន្មានប្រសប់ច្រៀង ឬសូត្រខ្ទុកណា ពិរោះជាងគេ ? សូមប្រាប់ឈ្មោះ ប្រាប់ទីលំនៅអ្នកនោះផង ។

សេចក្តីបញ្ជាក់ :

បេក្ខជនខ្លះមួយ ។ ដែលតាចសរសេរខ្ទុកច្រៀងបុកណារបស់ខ្មែរមកដាក់ប្រឡង់ថាន តាល់តែថាន យ៉ាងតិច ១០ ខ្ទុកឡើង។ ហើយខ្ទុកទាំងនេះ គឺតមានតំណត់ថាវែង ឬខ្លីប៉ុណ្ណា ។ ឡើយ ។ ពាក្យតាក្យខ្លះដែលតុំមែនសំរាប់ច្រៀង ហើយត្រង់តែសំរាប់សូត្រសេង ដើម្បីបញ្ចេីចក្ខេង ដូចជាពាក្យថា : តាច់សង្រែកបែកភ្លូមតាព្រហ្ម . . . បូតសណ្តែកវរេះចាក់ព្រៃក . . . ចាំត់ប៉ុយដៃសំអុយ ជាដើម តែអាចពាក់ថាជាខ្ទុកមួយដែរ ។ បើលោកអ្នកអាចសរសេរពាក្យបណ្តាមានជួន ។ ដែលគេតែងប្រជៀតគ្នាឲ្យរក ន័ងពាក្យលក់ដល់អ្នកដែលរកមិនឃើញផងតែថាន ។

ខ្ទុកន័មួយ ។ ដែលលោកអ្នកថានសរសេរនោះ សូមដាក់សេចក្តីបញ្ជាក់ថា លោកថានចេះផ្ទាល់ខ្លួន ឬថានសាកសួរ-កត់ចម្លងអំពីអ្នកណានៅស្រុកណាផង ។

អត្ថបទដែលដាក់ប្រឡងនេះ ទាំងដាប់ ទាំងមិនដាប់ ត្រូវទុកជាសម្បត្តិរបស់ក្រុមដំទុតទៅ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ព្រះរាជពិធីបង្ហាយព្រះពិសរ្សរ័យភណ្ឌ

ចំពោះ

សម្តេចព្រះសង្ឃរាជនាំងតាំងព្រះអង្គ

រៀបរៀងដោយ ឧ-តាម

ដូចលោកអ្នកអានបានជ្រាប ខ្ញុំព្រះករុណាព្រះបាទសម្តេចព្រះប្រមុខរដ្ឋនៅ
ពេលសម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងឱកាសបុណ្យចូលឆ្នាំ
ថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ១៤ ខែមេសា ឆ្នាំ
២០២៣ បានប្រកាសតែងតាំងព្រះតេជគុណ ប៊ុត សាវង្ស ជាសម្តេចព្រះមហាសុមេធាធិបតី
ជួនណាត សង្ឃនាយក គណៈមហានិកាយ តាំងជា សម្តេចព្រះសង្ឃរាជគង់ទី ១ និង
សម្តេចព្រះសុធម្មាធិបតី ពុទ្ធ ឈាង សង្ឃនាយក គណៈធម្មយុត្តិកនិកាយ តាំងជា សម្តេច
ព្រះសង្ឃរាជគង់ទី ២។

ការឡើងព្រះសមណសក្តិ ជាកំពូលនៃព្រះសង្ឃ និងពុទ្ធបរិស័ទ
ពិតជាសមរម្យតាមព្រះសមត្ថភាពព្រះបញ្ញាញាណ ព្រះគុណធម៌ និង
ព្រះគុណូបការដ៏ពិសេសនៃសម្តេចព្រះសង្ឃតាំងពីព្រះអង្គ ព្រមទាំង
ស្របតាមប្រពៃណីផង ព្រមទាំងជាជោគជ័យមួយដ៏ឧត្តមនៃសង្គមកម្ពុ
និយម ក្នុងការលើកដំកើងព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ

យើង ។ ព្រះរាជពិធីថ្វាយព្រះសព្វរៃយភណ្ឌ ចំពោះសម្តេចព្រះសង្ឃរាជ
តាំងពីព្រះតង្គ ចាប់ប្រព្រឹត្តទៅនៅព្រះទីតាំងខេត្តវាលិខ្ជួយ តាលពីព្រឹក
ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៦៤ ក្រោមព្រះកិច្ចចាត់ចែងនៃសម្តេចព្រះមហា
ក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

នៅវេលាម៉ោង ៧.៣០ ព្រះរាជវង្សានុវង្ស ឥស្សរជនជាន់ខ្ពស់
នៅក្នុងព្រះរាជធានី តាំងតាហានតាំងស៊ុំរាល ដែលមានជាអាទិ៍ស្រមាដិក
ព្រះរាជវង្សានុវង្ស សម្តេចដហ្វាកាំង ចែន-នុត សហជីវិន អ៊ុង-ហុងសាង
ប្រធានវុឌ្ឍសភា អ្នកអង្គម្ចាស់ នរោត្តម-ម៉ុងនាណា ប្រធានក្រុមប្រឹក្សា
ព្រះរាជអាណាចក្រ អ្នកអង្គម្ចាស់នរោត្តម-កន្ទុល នាយករដ្ឋមន្ត្រី ឯ.ឧ.
សាន-យុន អគ្គនាយកនៃក្រសួងនានាក្នុងព្រះបរមរាជវាំង សមាជិកឧត្តម
ក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក សហជីវិន ស៊ីន-សាន ទីប្រឹក្សាផ្ទាល់ព្រះអង្គនៃ
សម្តេចព្រះប្រមុខរដ្ឋ ឯកឧត្តមឧត្តមសេនីយ លន់-ណុល ឧបនាយករដ្ឋ
មន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេស សមាជិករដ្ឋាភិបាល សមាជិក
នៃសភាតាំងពីរ ឯ.ឧ. ញ៉ឹក-ខូវ ចាងហ្វាងពិធីការព្រះបរមរាជវាំង មេសេ-
ន្យាឧត្តមនៃកងទ័ពតាំង ៣ មន្ត្រីជាន់ខ្ពស់ត្រចំក្រសួងក្នុងព្រះរាជធានី ព្រម
តាំងនាម៉ឺនមុខមន្ត្រីនៃក្រនានាខ្លះ ចាប់ស្តេចយាងអញ្ជើញមកជួបជុំគ្នា
ព្រះរាជពិធីដ៏មហោឡារិកនេះ ។ នៅវេលាម៉ោង ៧,៤៥ នាទី ព្រះរាជ
គណៈ ៣៨អង្គ មានជាអាទិ៍ព្រះពោធិវង្ស ហួត-តាត ឱមន្តចូលគាន់

អាសនៈ ។

នៅវេលាម៉ោង ៧.៤០ នាទី សម្តេចព្រះមហាក្សត្រិយានី នឹង សម្តេចព្រះប្រមុខរដ្ឋ ដោយមានឥស្សរជនជាន់ខ្ពស់ជាព្រះរាជបរិពារតាមហែហមផង ចូលទៅកាន់ខេត្តប្រថាប់កន្លែងវាំនន់ដ្ឋ ដើម្បីវេនចាំក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជតាំងពីព្រះអង្គ ដែលនៅពេលនោះក្រុមចារគូបានថ្វាយបង្គំ ហើយក្រុមភ្លេងតិណាទ្យព្រះរាជទ្រព្យថ្វាយបង្គំភ្លេងជាតិជាព្រះកិត្តិយស ។ ឯនាម៉ឺនសព្វមុខមន្ត្រី កំក្រាបថ្វាយបង្គំតាមបង្គាត់គន ៣ ជន ។

នៅម៉ោង៨ សម្តេចព្រះសង្ឃរាជតាំងពីព្រះអង្គស្តេចមកដល់ ដោយមានក្បួនដង្ហែជាផ្លូវការផង តាមព្រះរាជទីនាំងវិសេស ដោយមានគ.ហានក្រុមរក្សាព្រះអង្គថ្វាយគារវកិច្ចជាព្រះកិត្តិយស ។ ឯ.ខ. មហាមន្ត្រី ញ៉ឹក-ខ្លូ ឧត្តមសេនីយឯកសារ-ហោ ព្រះរាជទ្ធិរក្សានៃសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ទទួលសម្តេចព្រះសង្ឃរាជតាំងពីព្រះអង្គនៅពេលយាងចុះពីរថយន្ត ។ មន្ត្រីគហានស៊ីវិល នៅកន្លែងព្រះទីនាំងខេត្តប្រថាប់ ឈរជែបមុខឈរមកគ្នា ។ សម្តេចព្រះទេពយុវរាជ ស្តេចយាងទៅចាំទទួលនៅមាត់ទ្វារ ហើយដង្ហែស្តេចយាងទៅតន់ប្រថាប់កន្លែងព្រះទីនាំងកោះកិត្តិយស ។

ក្រោយពេលដែលសម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះប្រមុខ

វដ្ត ព្រះរាជវន្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីក្រាបថ្វាយបង្គំ ថ្វាយគារវ-កិច្ច ចំពោះសម្តេចព្រះសង្ឃរាជហៅ ង. ទ. មហាមន្ត្រី ញឹក-ខូវ ជាន ថ្វែងសុន្ទរកថាខួលឆ្នងសម្តេចព្រះសង្ឃរាជ ក្នុងព្រះបរមនាមនៃព្រះរាជ បល្ល័ង្កដូចតទៅនេះ ។


សូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះសង្ឃរាជគណៈមហានិ កាយ សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ

សូមទ្រង់ជ្រាប ក្រោមល្អងជួលីព្រះបាទ ។

តាំតសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ដ៏វិតលើស្ងួន ខ្ញុំសម្តេច ព្រះទេបយុវរាជព្រះប្រមុខរដ្ឋ ជាអគ្គឧត្តមសាសនូបត្ថម្ភក៍ ព្រះអង្គមានព្រះ រាជតំរិះថា ទីស្តេចសង្ឃជាន់ចំហាំនេះ ជាច្រើនវដ្តកាលមកហើយ (១) ហើយម្យ៉ាងទៀត ព្រះអង្គទ្រង់ជាន់ជ្រាបជាក់ច្បាស់ថា សម្តេចតាំងពីព្រះ អង្គ មានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់លើសលប់លើព្រះសង្ឃតាំងច្រើយតាំងតួង

១- តាមព្រះរាជពង្សាវតារនៃប្រទេសកម្ពុជា ដែលដំកល់ទុកក្នុងបណ្ណាល័យ នៃភ្នំទ្វេសា សនបណ្ឌិត្យថា កាលក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សាតាតិស្សរាធិបតីព្រះអង្គឆ្នង ព្រះអង្គទ្រង់ជានកែងតាំងព្រះសង្ឃរាជ ២ ព្រះអង្គមកហើយ តំណាក់ពីថ្ងៃ ៩ កើតទៃបុស្ស ឆ្នាំ ម្មែ ឧពស័ក ព.ស. ២៣៩១ គ.ស. ១៨៤៧ តាំងសម្តេចព្រះ សង្ឃរាជ ព្រះនាម ខូ ទ្រង់ គង់នៅវត្ត ក្រាំងពាទ្យ ។ តមក នៅឆ្នាំរោងសប្តស័ក ព. ស. ២៣៩៩ គ. ស. ១៨៥៥ ជានតាំងសម្តេចព្រះសង្ឃរាជព្រះនាមទៀត នៅវត្តប្រាង្គ ប្រមុខពគង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។



ឯកឧត្តម ញឹក - ឆូវ ឧបាមន្ត្រី ជាព្រះរាជធំណាង ថ្លែងសុន្ទរកថាស្តីពីការថ្វាយគ្រឿងឥស្សរិយភណ្ឌ ចំពោះ
សម្តេច ព្រះសង្ឃរាជទាំងពីរព្រះអង្គ កាលពីថ្ងៃទី ១៩-៥-៦៤ នៅព្រះទីតាំងទេវាវិនិច្ឆ័យ ។

ក្នុងព្រះពុទ្ធសាសនាចក្រកម្ពុជា ព្រមទាំងមានព្រះគុណូបការដ៏ខ្ពល់ខ្ពស់ណាស់ ចំពោះជាតិសាសនា ទឹងព្រះពុទ្ធបល្ល័ង្ក ជាវិសេស សម្តេចទាំងពីរព្រះអង្គទ្រង់បានដួយចលនាសង្គមពីស្រុកទៅយុគ ដែលជាចលនាសំកប់បង្រួបបង្រួមជាតិឲ្យមានសាមគ្គីសាមគ្គាជាដុំ ១ ដើម្បីឲ្យមានសុភមង្គលទឹងឲ្យមានវឌ្ឍនាការដល់ប្រទេសជាតិទៀតផង អាស្រ័យហេតុនេះ បានជាសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដ៏វិសេសលើសូន្យ ទឹងសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះតំរិះថានៅពេលនេះហើយ ដែលត្រូវតែតែងតាំងថ្វាយព្រះថានន្តរសក្តិជាទីព្រះសង្ឃរាជ ដោយមានព្រះពុទ្ធត្រីស្យលេខ ២៤ ព.ស. ចុះថ្ងៃទី២៨ ខែកត្តិក ឆ្នាំ ១៩៦៣ លើកព្រះថានន្តរសក្តិជាទីសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ថ្វាយចំពោះព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ សម្តេចព្រះសង្ឃរាជថ្នាក់ទី ២ ថ្វាយសម្តេចព្រះសុធម្មាធិបតី កុល-ទេស សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ។ សព្វថ្ងៃដែលត្រូវប្រើភៀកាន់ល្អដ៏ធួលីព្រះបាទទាំងពីរព្រះអង្គ គឺត្រូវប្រើក្នុងពិធីសព្វទាំងអស់ត្រមទាំងមានសិទ្ធិត្រូវបានបុព្វសិទ្ធិប្រើច្រាស់ នូវព្រះទីនាំងកៅអីពីរសែងផ្ទៃតស្រួចពីរសែង វេងព្រះសិរពីរសែង ទង់ឈ្មោះព្រះទីនាំងវេយន្តពីរសែង ។

សូមទ្រង់ព្រះមេត្តាប្រោស

ថ្ងៃនេះ ជាថ្ងៃប្រកបដោយជោគជ័យសិរីមង្គលប្រសើរឯក ដែល

សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដ៏វិសេសលើសូរ្យ ខ្ញុំសម្តេចព្រះទេវយុវរាជ ព្រះប្រមុខរដ្ឋជាអម្ចាស់ ព្រះអង្គទ្រង់មានព្រះបរមរាជបញ្ជាឲ្យរាជសេវកាមាត្យឲ្យរៀបចំពិធីដ៏ឧឡារិកនៅទីនេះ ដើម្បីថ្វាយខ្លួនព្រះរាជឥស្សរិយភណ្ឌ ចំពោះសម្តេចព្រះសង្ឃរាជគាំងពីព្រះអង្គដោយផ្ទាល់ព្រះហស្ត ខ្ញុំសូមថ្វាយព្រះពរសំតួសាធុការ សូមសម្តេចគាំងពីព្រះអង្គ ទ្រង់ប្រកបដោយព្រះសុខុមាលភាព ខ្ញុំព្រះវរ្ឍនភាពមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីសូមព្រះអង្គទ្រង់តង់ជាម្លប់ជាទីជ្រកកោនដ៏ត្រជាក់ត្រជុំនៃពុទ្ធមាមកជនខ្ញុំៗ ក្នុងព្រះពុទ្ធសាសនាចក្រវឿងៗ ។

(នៅមានត)

---

๑ នេះលោកថា ចូរកុំតប៉ិ ប្រទាំងនឹងបុណ្យ ដូចគេលើកភ្នំ ជាធំពេកស៊ុន ខ្លួនឯងឥតគុណ នាំវិនាសច្រាណ ។ កាលៈទេសៈ កំពង់អន័ត្យ ប្រកួតពុំបាន ចាត់ជាទី ២ សម្តីពុំក្សត្តិ ខាតធម៌កល្យាណ ខេត្តសូន្យសោះ ។

ផេង-ជ្រើរ

សុគ្គរកថា

ដែលព្រះឃោសធម្ម គោរ-សិម

បៅអធិការវត្តលង្កា ថ្ងៃក្នុងឧកាសបុណ្យឆ្លងវិហារវត្តខេះ ថ្ងៃទី ១៩-៥-៦៤ ។

សូមគោរព

ទូលព្រះបង្គំជាខ្ញុំ សូមនមស្សការ

សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជទី ១

សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជទី ២

ដោយសិរោត្តម ។

សូមថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រិយានី បរមបពិត្រ ព្រះមាតាជាតិ

សម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ

សូមគោរព

ព្រះតេជព្រះគុណ ព្រះពោធិវង្ស

ព្រះតេជព្រះគុណ ព្រះធម្មវង្សាធិបតី មេគណខេត្ត កំពង់ឆ្នាំង

លោកគ្រូព្រះអនុគណ ខេត្តតាកែវ ស្វាយរៀង . . . ។

សូមថ្វាយព្រះពរ-សូមចំរើនពរ

ទ្រង់-ឯកឧត្តម លោកជំទាវ លោកស្រី ឧឪអស់លោកពុទ្ធបរិ-

ស័ខ ១ចាសក ១ចាសិកា តាំងព្យាយ ។

សូមទ្រង់ព្រះមេត្តាប្រោស

ខ្ញុំព្រះករុណា

អាត្មាភាព តាងនាមនៃគណៈកម្មាធិការចាត់ការបុណ្យ ពុទ្ធបរិស័ទ តាំងឋដ្ឋិត តាំងត្រហស្ថ នឹងកងនាមផ្ទាល់របស់អាត្មាភាព សូមព្រះរាជអភ័យ ព្រះរាជទាន ព្រះរាជវរោកាសថ្វៃនឹងអំណរគុណ ដ៏ធំក្រៃលែង ចំពោះព្រះមហាករុណាទេគុណដ៏ខ្ពង់ខ្ពស់នៃសម្តេចតាំងពីព្រះអង្គ ដែលទ្រង់ព្រះមេត្តាប្រោស ស្តេចយាងមកជាព្រះរាជធិបតី ក្នុងទេសកាលពិធីបុណ្យបញ្ចុះខណ្ឌសីមានឹងកូនព្រះវិហារថ្មី ព្រមតាំងកូនចម្ការនៃវត្តលង្កានេះ ដើម្បីជានិធានកម្មនឹងមហាកម្មដ៏ប្រសើរខ្ពង់ខ្ពស់បំផុត នាំឲ្យមានតិត្យានុភាពក្នុងព្រះពុទ្ធសាសនា ។ ខ្ញុំព្រះករុណាអាត្មាភាព សូមពណិនាថ្វាយដោយសេចក្តីសង្ខេប នូវដំណើរវិវត្តន៍នៃវត្តលង្កា នឹងកិច្ចការងារព្រះវិហារនេះដូចតទៅ ៖

វត្តលង្កានេះ មានកងប្រវត្តិនៃព្រះរាជពន្ធាវគារថា: ព្រះបរមរាជាព្រះនាម ពញាយ៉ាត ទ្រង់ចាកយាងចេញពីទីក្រុង ចាសាណ ដែលជាព្រះរាជវាំងចាស់ ទៅឃុំស៊ីជរ ស្រុកឧត្តរាចក្កាល ខេត្តកណ្តាល ទៅថ្ងៃ ៩ កើត ខែពិសាខ ឆ្នាំខាលឆស័ក ព.ស. ១៩៧៨ គ.ស. ១៦៣៤ ស្តេចមកគង់ទៅក្នុងព្រៃនេះ ទៅថ្ងៃ ១៥ កើត ខែពិសាខ ។ មាន

សេចក្តីដំណាលថា «ពស. ១៨៨១ គ.ស. ១៤៣៩ ទ្រង់បានបញ្ជា
ឲ្យកសាងវត្តជាច្រើន មានវត្តកុំដូនពេញ ។

វត្ត គោះ

- លង្កា

- ព្រះពុទ្ធយោសា ជាដើម

នៅទីជុំវិញកុំដូនពេញនោះ ។

ឯវត្តលង្កា បំតនៅទិសខាងកើតឆៀងត្បូងកុំដូនពេញ ទ្រង់
បានបញ្ជាតឲ្យ ជាមាកិនេយ្យ ហៅថា វត្តលង្កា ។ លេចឮល្បី
ឈ្មោះប្រាកដរឡើងតាំងពីសម័យជាន់នោះមក ជាបជល់សម័យឥឡូវនេះ ។

វត្តលង្កា នេះ កាលដែលបំតនៅកុំដូនពេញនោះ អស់រយៈកាល
៤៦០ ឆ្នាំ លុះដល់មកឆ្នាំកុរឯកស័ក ព.ស. ២៤៨១ តែថ្ងៃទី ១៩ ខែសីហា
គ.ស. ១៩៣៧ ទើបមានឧបាសគ្គៈស្មាក់ដំណើរ ដោយយកជការប្រតិកតូ
ភត៌ថាពាំងសែស បានបញ្ជាឲ្យរុះរើជញ្ជួនសម្ភារៈ ទីធ្លាវត្តមាកវ ថយ
ចេញពីកុំដូនពេញ យកមកកសាងនៅចំងីកេងកង ឃុំលេខ ៤ ដែលជា
សំយ៉ាយជាយត្រែងនៃព្រះពជាធីទីក្រុង ក្នុងសម័យជាន់នោះ ដើម្បី
យកកន្លែងនោះធ្វើជាមន្ទីរបុីយរ៉ូបេស់ពជាវ ហើយបានប្រគេនបច្ច័យ
៤.០០០ រៀល ជាតម្លៃរុះរើ ដល់ព្រះញាណវរៈជ្ឈ អុក ជាចៅអធិការ
ដើម្បីស្ថាបនាកេងឧបោសថ ទីធ្លាសេនាសនៈ ។

ឯវត្តតាំងមូល គឺនៅមានសុទ្ធតែព្រៃក៏ងស្រស់ ដើមប្រពួយតូចធំ ស្មៅដុះណែនណាន់តាន់តាប់ដីក្រហេងក្រហួង ថ្កុកជង្អុកជ្រៅ ។ គន់មើលទៅទិសខាងត្បូង ខាងលិច វាលស្ងៀវស្ងប់ ដល់រដូវខែតឡើងលិចព្រៃឈើតាំងនោះអស់លើងទៅ ឃើញសុទ្ធតែខែកសសំពោង រលកបៃតង្កាព្រៃងចោលខ្ចោល ។ មក ខែរួចរលកផ្កាក់ផ្អើក ។ គួរឲ្យស្រេងស្រេងរោចលន្ទោចចិត្តពន់ពេក ។

លុះចំណេរចិរកាលតមកដល់ឆ្នាំច ចោស័ក ព.ស. ២៤៥៣ គ.ស. ១៩១០ លោកគ្រូចៅអធិការ គឺព្រះញាណបវរវង្សា ខាត់ ដោយមានលោកអ្នកឧញ៉ាំ យោមកដ ម៉ែន ទឹងលោកដំណាវព្រាប ជាដើមជួយទប.តម្ល ចានុះរោងឧបោសថចាស់នោះ កសាងវិហារថ្មី គ្រឿងឈើប្រក់ក្បឿងឡើង អស់តម្លៃ ១.២៤៥ រៀល គឺនៅពុំទាន់ហើយស្រេច លោកគំអនិច្ចធម្មទៅ តមកខាងក្រោយទៀត លោកគ្រូព្រះញាណបវរវង្សា ល្វីឯម ទឹងលោកដំណាវម៉ែន-ព្រាប ព្រមគាំងពុទ្ធបរិស័ទ ឧបាសក-សិកា ចានធ្វើបុណ្យបញ្ចុះខ័ណ្ឌសីមាជាមហាឧត្តរកែក្រោមព្រះពុទ្ធរូបតិណ្ណាត ដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះករុណាព្រះចុលចមេ្ចមព្រះស៊ីសុវត្ថិ ជាអម្ចាស់ជីវិតដោយមានលោកឡឺរ៉ែស៊ីដង់ត៍ សុប៉ែរីយ៉ែរ (Supérieur) ជំនាន់នោះព្រមគាំងអស់លោកកុង្សីរសេនាបតីមន្ត្រីតូចធំ អ្នកមុខ អ្នកការជាច្រើនចានតាមវិហាមព្រះអង្គធង ដើម្បីជាកិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងទិកាសបុណ្យនោះ ។

(នៅមានត)

អំពីព្រះនាមព្រះតេជព្រះគុណ

ដែលបានទទួលសញ្ញាប័ត្រ ចាត់តាំងជាចៅអធិការ និងត្រួសត្រា ក្នុងវត្តខាង
ក្នុងព្រះរាជអាណាចក្រ (ខ)

១០១– ព្រះតេជព្រះគុណ ម៉ែន-ហ៊ុន នាមឆាយាសុវណ្ណបញ្ញាតេសរ កើតពី គ.ស. ១៨៨៦ អាយុ ៦៧ ឆ្នាំ វស្សា ៤៣ បានទទួលតែងតាំង ជាចៅអធិការកិត្តិវត្តថ្មស ឃុំលំពង់ ស្រុកបាទី ខេត្តតាកែវ លេខ សញ្ញាប័ត្រ ៣៤៨៥ ចុះថ្ងៃទី ១៦.១.៦៣ ។

១០២– ព្រះតេជព្រះគុណ យង់-ញ៉ែប នាមឆាយាឥតវិរិយោ កើតពី គ.ស. ១៨១៥ អាយុ ៤៨ ឆ្នាំ វស្សា ២៧ បានទទួលតែងតាំងជាចៅអធិ ការកិត្តិវត្តកំណប់ ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣៤៨៦ ចុះថ្ងៃទី ១៦.៣.៦៣ ។

១០៣– ព្រះតេជព្រះគុណ រ៉ែ-រ៉ែន នាមឆាយាទីឋធម្មោ កើតពី គ.ស. ១៨៣០ អាយុ ៣៣ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំង ជាចៅអធិការ កិត្តិវត្តមង្គលសាលវ័ន ឃុំខ្នោរជើមធ ស្រុកជើងព្រៃ ខេត្តកំពង់ចាម លេខ សញ្ញាប័ត្រ ៣៤៨៧ ចុះថ្ងៃទី ១៦.៣.៦៣ ។

១០៤– ព្រះតេជព្រះគុណ អ៊ុក-ខិត នាមឆាយាវិសាលត្ថេរ កើតពី គ.ស.១៨៤៨ អាយុ ៦៥ ឆ្នាំ វស្សា ៣៤ បានទទួលតែងតាំង ជាចៅ អធិការកិត្តិវត្តអម្ពវន ឃុំបុរីការស្រុកមុខកំពូល ខេត្តកណ្តាល លេខ

សញ្ញាប័ត្រ ៣៤៨៨ ចុះថ្ងៃទី ២៤ ៣.៦៣ ។

១០៥- ព្រះតេជព្រះគុណ ជុំ-វ័ណ្ណ ថា នាមឆាយាជាតិសរ កើតពី គ.ស. ១៩៣២ អាយុ ៣៩ ឆ្នាំ វស្សា ១៨ ជានិស្សិតវត្តសិរីសុវត្ថិ ស្ថិតក្នុងវត្តអម្ពវន ឃុំបុងកោរ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៨៩ ចុះថ្ងៃទី ២៤.៣.៦៣ ។


១០៦-ព្រះតេជព្រះគុណ ធី-ឈិត នាមឆាយាញាណសាពេ កើតពី គ.ស. ១៩២៩ អាយុ ៣៤ ឆ្នាំ វស្សា ១៤ ជានិស្សិតវត្តសិរីសុវត្ថិ ធ្វើតំណែងក្នុងវត្តអម្ពវន ឃុំបុងកោរ ស្រុកមុខកំពូល ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៩០ ចុះថ្ងៃទី ២៤.៣.៦៣ ។

១០៧- ព្រះតេជព្រះគុណ មៅ-ឌុល នាមឆាយាសុវណ្ណកេសរោ កើតពីគ.ស. ១៩២៨ អាយុ ៣៥ ឆ្នាំ វស្សា ១៥ ជានិស្សិតវត្តសិរីសុវត្ថិ ធ្វើជាមេអធិការ តំណែងក្នុងវត្តពពិស ឃុំព្រៃវែង ស្រុកព្រៃវែង ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣៤៩១ ចុះថ្ងៃទី ២៤ ៣.៦៣ ។

១០៨-ព្រះតេជព្រះគុណ ប៉ែន-សេង នាមឆាយាសទ្ធម្មវត្តេ កើតពី គ.ស. ១៩២២ អាយុ ៤២ ឆ្នាំ វស្សា ២៣ ជានិស្សិតវត្តសិរីសុវត្ថិ ធ្វើជាមេអធិការក្នុងវត្តអូរព្នៅ ឃុំចម្បក ស្រុកជុំគីរី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣៤៩២ ចុះថ្ងៃទី ៣១ ៣.៦៣ ។

(នៅមានត)

ក.ស.ជ.
លាំ ៤៩៥x៤៤០
១១០ ក្បាល
៩-ន-៧៧៤



ភ្នំពេញសិក្ខា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញាពល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

ផ្នែកសាសនា	ទំព័រ
ព្រះពុទ្ធសាសនា និងអពុទ្ធសាសនិក (វិចារណកថា) លោក ង៉ែង-ជ្រឿ និពន្ធ	១
ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៊ី តែងរៀបរៀង (ត)	៨
ទ្វាទសកម្មាថា ព្រះមុនីកោសល សូ-ហាយ អធិបតីរងនៃក្រុមដំនុំ ព្រះត្រៃបិដក រៀបរៀង	១៦

ផ្នែកអក្សរសាស្ត្រ	
បញ្ហាដ៏វិត (វិចារណកថា) សហដីវិន ផល-ទិត្យ នៅពុទ្ធសាសនបណ្ឌិត្យនិពន្ធ	៣០
វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	៤១
រឿងអាថ៌លហ្វាំអ៊ូរ៉ែស លោក ភយ-ល្មុត ដំណាងអាស្ត្រ ប្រែរៀបរៀង	៤៣
រឿងសាមកុក អ្នកនាកញ្ញាវិបុលរាជសេនា ង្ហួ-ពាន ប្រែរៀបរៀង (ត)	៥៤
ល្បើកឃ្លាហ្វុងតែន លោកផេង-ជ្រឿ ប្រែពីភាសាជាវ៉ាំង (ត)	៧៩
រឿងព្រេង ចិន (យើងគ្រូវបែកការគ្នាធ្វើ) លោក ភ័យ-ប៊ុក ប្រែពីភាសាជាវ៉ាំង (ត)	៨៤
ទំនៀមទម្លាប់ខ្មែរ ច្រាសទៅវត្តអង្គរ នៅខេត្តកំពង់ចាម	៨៦

ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍	
- អនុសាំវច្ឆរៈ មហាសន្និបាត នៃមន្ត្រីសង្ឃលើកទី ២០ ឆ្នាំ ១៩៦៤	៩៦
- សុន្ទរកថា សហដីវិនអនុរដ្ឋលេខាធិការ ក្រសួងធម្មការ	១០២
- រឿងតាំងលៅអធិការ សំរាប់វត្តនានា	១០៩

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ២៣០រ០០

គ្រួសជាតិដើម្បីវប្បធម៌ជាតិ
COMMISSION DES MŒURS & COUTUMES

ព្រះធម្មសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៦ លេខ ១ ខែ មករា

ព. ស. ២៥០៦ គ. ស. ១៩៦៤